ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

**រួមមាន៖**

១. រឿងកុលាបប៉ៃលិន
២. រឿងដើមកំណើតទីក្រុងភ្នំពេញ
៣. រឿងតេជោយ៉ត
៤. រឿងតេមិយជាតក
៥. រឿងចៅកែចិត្តចោរ
៦. រឿងទុំទាវ
៧. រឿងធនញ្ជ័យ
៨. រឿងប្រាសាទអង្គរវត្ត
៩. រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
១០. រឿងមហាវេស្សន្តរជាតក
១១. រឿងមហោសថជាតក
១២. រឿងមាលាដួងចិត្ត
១៣. រឿងរាមកេរ្តិ៍
១៤. រឿងសុផាត

**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

**ឆ្នាំ ២០១៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង កុលាបប៉ៃលិន

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ:..................................អយក.

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍ «រឿងកុលាបប៉ៃលិន»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

### សម្រេច

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងកុលាបប៉ៃលិន » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្ដុះបណ្ដាលគ្រូ គុណវុឌ្ឍគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្ដុះបណ្ដាលនាយក ព្រមទាំងមានការផ្លាស់ប្ដូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាមអនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បានផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជានេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាពចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការបច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្ដីពី»ការសិក្សាអត្ថបទអក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបានជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

# **អារម្ភកថា**

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ«**សិក្សាអត្ថបទអក្សរសិល្ប៍**» ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជាៈ

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ«**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង កុលាបប៉ៃលិន**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក យិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ តាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ុត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារឹទ្ធ

# មាតិកា

ទំព័រ

ប្រកាស ....................................................................................................i
បុព្វកថា ....................................................................................................ii
គណៈកម្មការ..............................................................................................iii
អារម្ភកថា...................................................................................................iv
មាតិកា........................................................................................................v
សេចក្ដីផ្ដើម...................................................................................................
I. ការបង្ហាញអត្ថបទ.........................................................................................
II. ទិដ្ឋភាពទំនាក់ទំនងរឿង..................................................................................
III. ទិដ្ឋភាពទំនាស់...........................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ......................................................................................
V. ទិដ្ឋភាពសង្គម.............................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ.......................................................................................
VII. ទិដ្ឋភាពតម្លៃ..............................................................................................
VIII. ការសន្និដ្ឋាន.............................................................................................
IX. ឯកសារពិគ្រោះ............................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

### រឿង កុលាបប៉ៃលិន

## ក.សេចក្តីផ្តើម

រឿងកូលាបប៉ៃលិន គឺជាស្នាដៃអក្សរសិល្ប៍ទំនើបបែបប្រលោមលោកមនោសញ្ចេតនា ដែរបានប្រសូត្រឡើងក្រោមទឹកដៃប៉ិនប្រសព្វរបស់អ្នកនិពន្ធដ៏ល្បីនាសវត្សទី២០គឺលោក ញ៉ុក ថែម។ ស្នាដៃនេះបានទាញការនិយមរាប់អាន និងការពេញចិត្តពេញថ្លើមពីសំណាក់ប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈជាមួយនឹងទេពកោសល្យរបស់អ្នកនិពន្ធ ដែលលាតត្រដាងឱ្យឃើញពីការតស៊ូពុះពារប្រកបដោយភាពអំណត់ មិនព្រមចុះញ៉មនឹងវាសនាកំសត់អនាថានៃតួអង្គចៅចិត្រ រហូតទទួលបានឧត្តមភាពជីវិត គឺក្លាយជាកូនប្រសារលោកហ្លួងរតនៈសម្បត្តិ ដែរជាអ្នកមានស្តុកស្តមនៅខេត្តប៉ៃលិន។ ស្ថិតក្នុងតម្លៃនេះហើយទើបក្រសួងអប់រំ យុវជន និងកីឡាពិសេសក្នុងពេលបច្ចុប្បន្នបានបញ្ចូលរឿងកូលាបប៉ៃលិនក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិសម្រាប់ជំនួយស្មារតីដល់យុវជនឱ្យចេះទទួលខុសត្រូវពីបញ្ហាជីវិត។

## I.ទិដ្ឋភាពប្រវត្តិ

### ១.ប្រភពអត្ថបទ

- ចំណងជើង : រឿងកុលាបប៉ៃលិន។
- ដកស្រង់ចេញពីសៀវភៅរឿងកុលាបប៉ៃលិនដែលរៀបរៀងបោះពុម្ពឡើងវិញ ដោយក្រសួងអប់រំយុវជន និងកីឡាឆ្នាំ២០០១។

### ២.អ្នកនិពន្ធ

+ឈ្មោះអ្នកនិពន្ធ : រឿងកុលាបប៉ៃលិន និពន្ធដោយលោក ញ៉ុក ថែម។

+ជីវប្រវត្តិអ្នកនិពន្ធ : លោក ញ៉ុក ថែម កើតនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩០៣ នៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ បិតាលោកឈ្មោះ ញ៉ុំ រី មាតាឈ្មោះ ហៀក ជាកសិករនៅភូមិអូតាគី ឃុំជ្រៃ ខេត្តបាត់ដំបង។

- ឆ្នាំ ១៩១៣ បានចូលរៀននៅវត្តពោធិ៍វាល ស្រុកសង្កែ ខេត្តបាត់ដំបងក្នុងសំណាក់គ្រូអាចារ្យ សនរៀនវិន័យក្នុងដំណាក់លោកគ្រូសូត្រអ៊ីវ ទូច។
- ឆ្នាំ ១៩១៨ លោកបានបួសជាសាមណេរ។
- ឆ្នាំ ១៩១៩ លោកបានបន្តការសិក្សានៅទីក្រុងបាងកកប្រទេសថៃ។
- ឆ្នាំ ១៩២១ ដល់ឆ្នាំ ១៩២៣ ជាប់សញ្ញាប័ត្រកម្មសិក្សាជាន់ត្រី-ទោ។
- ឆ្នាំ ១៩២៤ លោកបានបំពេញឧបសម្ប័ទជាភិក្ខុ។

- ឆ្នាំ ១៩២៧ ដល់ឆ្នាំ ១៩៣០ និមន្តមកទីក្រុងភ្នំពេញវិញដោយចូលធ្វើជាសមាជិកគណៈកម្មការប្រែព្រះត្រៃបិដក។
- ឆ្នាំ ១៩៣៦ លោកបានលាចាកសិក្ខាបទមកជាគ្រហស្ថ។
- ឆ្នាំ ១៩៣៨ លោកធ្វើការនៅក្នុងព្រះរាជបណ្ណាល័យកម្ពុជា។
- ឆ្នាំ ១៩៤៥ លោកធ្វើជាសាស្ត្រាចារ្យនៅសាលាគរុវិជ្ជា។
- ឆ្នាំ ១៩៤៦ លោកធ្វើការនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតព្រមទាំងជាសាស្ត្រាចារ្យនៅវិទ្យាល័យព្រះស៊ីសុវត្ថិ។
- ឆ្នាំ ១៩៥៦ លោកសុំផ្លាស់ទៅធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង។
- ឆ្នាំ ១៩៥៨ លោកបានផ្លាស់មកធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យនាក្រុងភ្នំពេញក្នុងឋានៈជាសាស្ត្រាចារ្យផង និងជាអ្នកស្រាវជ្រាវឯកសារអក្សរសាស្ត្រខ្មែរផង។

  ចំពោះអាពាហ៍ពិពាហ៍និងមរណភាពរបស់លោក ញ៉ុក ថែម យើងពុំបានដឹងច្បាស់នោះទេ។

  +ស្នាដៃ ស្នាដៃសំខាន់ៗរបស់លោក ញ៉ុក ថែមរួមមាន ៖

- រឿងកុលាបប៉ៃលិន ឆ្នាំ ១៩៣៦ឬ ១៩៤៣
- រឿងមហាវេស្សន្តរជាតក
- រឿងបិសាចស្នេហា បោះពុម្ពឆ្នាំ ១៩៤២
- ពុទ្ធប្បវត្តិសង្ខេប
- ប្រជុំភាសិត ភាគ ១ ភាគ ២
- ប្រជុំពុទ្ធភាសិត
- ឯកសហារាត្រី (បកប្រែ)
- ពន្លឺអាស៊ីទ្វីប (បកប្រែ)
- បញ្ញាសជាតកសង្ខេបភាគ ១ ភាគ ២
- ជាតិ សាសនា ព្រះមហាក្សត្រ
- វិធីប្រតិបត្តិធម៌....។

## ៣.កាលកំណត់តែងរឿង

ចំពោះកាលកំណត់តែងនៃរឿងនេះគឺពុំមានភាពច្បាស់លាស់ឡើយគ្រាន់តែដឹងថានិពន្ធនៅឆ្នាំ ១៩៣៦ឬឆ្នាំ ១៩៤៣ ក៏មិនដឹងមួយណាឱ្យពិតប្រាកដឡើយ។

## ៤.សង្គមបរិយាកាស

+ព្រឹត្តិការណ៍សំខាន់ៗ

-ប្រទេសកម្ពុជាស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំង។
-មានជនជាតិភូមា ជនជាតិកូឡារកស៊ីជីកត្បូងនៅប៉ៃលិន។
-មានការនាំត្បូងចេញទៅលក់នៅប្រទេសភូមា ចិន យួននិងបារាំង។
-នៅជនបទមានអំពើចោរកម្មនិងប្លន់ប្រដាប់អាវុធជារឿយៗ។
+សម័យកាលប្រវត្តិ
ដំណើររឿងនេះស្ថិតនៅក្នុងសម័យកាលមួយដែលប្រទេសកម្ពុជាស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំងពីឆ្នាំ ១៨៦៣ដល់ឆ្នាំ ១៩៥៣។ក្នុងសម័យកាលនេះអក្សរសាស្រ្តជាតិបានទៅជ្រកកោនតាមវត្តអារាម។

**5.ប្រភេទរឿង**

រឿងកុលាបប៉ៃលិនជាប្រភេទប្រលោមលោកទំនើបបែបអណ្តែតអណ្តូងនិយម។

## II.**ទិដ្ឋភាពទំនាក់ទំនងរឿង**

**១.សង្ខេបរឿង**

តាចឹមជនចាស់ជរាម្នាក់នៅភូមិស្វាយប៉ោ ខេត្តបាត់ដំបង ហើយគាត់ជាបុរសពោះម៉ាយ មានតែកូនកំលោះម្នាក់គឺចៅចិត្រ។ ជំងឺប្រចាំកាយបានធ្វើឱ្យតាចឹមទ្រុឌទ្រោមទៅៗជាលំដាប់ហើយក៏ត្រូវមច្ចុរាជមកឆក់យកជីវិតគាត់ទៅ ទោះបីជាចៅចិត្រខំរកគ្រូពេទ្យមកព្យាបាលយ៉ាងណាក៏ដោយ។ តាចឹមគ្មានបានទុកអ្វីឱ្យបុត្រជាទីស្រឡាញ់ ក្រៅពីបណ្តាំមួយឃ្លាជាពុទ្ធភាសិតថា"អត្តាហិ អត្តនោ នាថោ"ខ្លួនត្រូវទីពឹងខ្លួននោះឡើយ។ ចៅចិត្ររស់នៅកណ្តោចកណ្តែងកណ្តាលមហាទុក្ខទើបលោកគ្រូពេទ្យស្អាតបានជួយយកអាសាដោយធ្វើសំបុត្រឱ្យចៅចិត្រកាន់យកទៅសុំការងារធ្វើនៅឯគេហដ្ឋានលោកហ្លួងរតនៈសម្បត្តិដែលជាមារបស់ខ្លួននាស្រុកប៉ៃលិន។

ចៅចិត្រកាន់សំបុត្រលោកគ្រូពេទ្យស្អាតធ្វើដំណើរមកដល់ស្រុកបរប៉ៃលិនដោយក្រៀមក្រំ។ ពេលទៅដល់ផ្ទះលោកហ្លួងរតនៈសម្បត្តិ ចៅចិត្រក៏ចូលទៅសំពះសួរសួរដោយសេចក្តីគោរព រួចជូនសំបុត្រទៅលោកព្រមទាំងពណ៌នារឿងរ៉ាវដោយសព្វគ្រប់។ គ្រានោះឯង យុន នារីជាបុត្រីតែម្នាក់របស់លោកហ្លួងរតនៈសម្បត្តិបានមកឈរជិតបិតាដោយឫកពាឆ្មើងឆ្មៃរួចសំឡឹងទៅចៅចិត្រហើយលាន់មាត់ថា"ចៅចិត្រស្គមដូចមនុស្សញៀនអាភៀនមិនអាចជីកដីបានទេ"។ ចៅចិត្រកំសត់បានតបវិញថា"មនុស្សត្រង់គេមិនដែលសម្គាល់ថាជាមនុស្សល្ងង់ទេ ឯមនុស្សស្គមគេមិនសម្គាល់ថាជាមនុស្សខ្សោយដែរ" ជាហេតុធ្វើឱ្យលួងចិត្តកូនស្រី ហើយនាងក្រមុំរូបស្រស់មានការអាក់អន់ស្រពន់ចិត្តជាខ្លាំងជាមួយកំលោះអនាថានេះ។ លោកហ្លួងរតនៈសម្បត្តិក៏យល់ព្រមឱ្យចៅចិត្រធ្វើជាកម្មករជីកត្បូងនៅផ្ទះរបស់លោកទៅ។

នៅរាត្រីមួយ ថៅចិត្របានច្រៀងបទយុវាភិរម្យនៅក្នុងខ្ទមរបស់ខ្លួនធ្វើឱ្យ យុន នារីដែលចុះមកកម្សាន្តក្នុងសួនច្បារឮសូរពិរោះពេកទ្រាំមិនបាននាងលបចូលទៅស្តាប់ព្រមទាំងចូលទៅសួរនាំនូវរឿងរ៉ាវផ្សេងៗហើយរុវជនចិត្រក៏បបួលយុននារីទៅអង្គុយក្នុងសួនជជែកគ្នាពីនេះពីនោះមិនចេះចប់ជួនក៏ត្រូវគ្នាជួនក៏ខុសចិត្តគ្នាតែពោរពេញទៅដោយមនោសញ្ចេតនាក្រោមពន្លឺព្រះច័ន្ទនាពេលរាត្រី។ លុះស្អែកឡើងថៅចិត្រក៏ចេញទៅជីកត្បូងដូចធម្មតា ប៉ុន្តែគាបជួនជាចៃដន្យល្អថៅចិត្រក៏ជួយរវៃរថយន្តតាសុនបានឆេះ រួចក៏បើករថយន្តជំនួសតាសុន ជូនលោកហ្លួងរតនៈ និងនាងយុននារីទៅទទួលលោកបាឡាត់នៅឯស្រុកសង្កែ ខេត្តបាត់ដំបង។

ក្នុងការជូនដំណើរថៅហ្វាយទៅស្រុកសង្កែនេះ ថៅចិត្រមិនមានកិច្ចការអ្វីក្រៅពីធ្វើជាអ្នកបើករថយន្តនិងកាន់កន្ត្រកដើរតាមយុន នារីទៅទិញឥវ៉ាន់ឯផ្សារនោះឡើយ។លុះទិញឥវ៉ាន់រួចហើយយុន នារីក៏នាំថៅចិត្រមកទទួលលោកហ្លួងរតនៈសម្បត្តិនិងលោកបាឡាត់ឯស្រុកហើយវិលទៅប៉ៃលិនវិញ។ ដល់កណ្តាលផ្លូវរថយន្តក៏ខូចបណ្តាលឱ្យមានការទាស់ទែងខ្វែងសម្តីគ្នាខ្លះរវាងលោកបាឡាត់និងថៅចិត្រព្រោះម្នាក់ៗសុទ្ធតែមានការប្រច័ណ្ឌទៅលើសម្រស់នាងយុន នារី។

នៅក្នុងរាត្រីកាលដ៏សែនស្ងាត់ជ្រងំនាកណ្តាលព្រៃ ថៅចិត្រនឹកតូចចិត្តនឹងវាសនាខ្លួនណាស់ដែលកើតមកជាអ្នកក្រមានឋានៈតូចទាបបែរជាចង់ឈោងចាប់ផ្កាយលើមេឃព្រមទាំងដឹងសុភាសិតថា«ដៃខ្លីកុំតោង ខ្លួនទាបកុំឈោងស្រវាទ្រឱបភ្នំ»។នៅពេលដែលកំពុងតែស្លុងអារម្មណ៍ស្រាប់តែនាងយុន នារីមកដល់កន្លែងដែលថៅចិត្រកំពុងអង្គុយយាម។ យុន នារី និងថៅចិត្រអង្គុយសន្ទនាគ្នានូវរឿងរ៉ាវផ្សេងៗរហូតដល់រឿងស្នេហាអស់វេលាយ៉ាងយូរទើបថៅចិត្រប្រាប់យុន នារីឱ្យទៅដេក។ គ្រាន់តែយុន នារីរៀបចំបោះជំហានចេញពីកន្លែងនោះ ស្រាប់តែមានឧប្បត្តិហេតុមួយកើតឡើងគឺពួកចោរបានចូលមកប្លន់ដោយបាញ់កាំភ្លើងយ៉ាងខ្ទរខ្ទារ។ អ្នកទាំងប៉ុន្មានបានរត់ពួនអស់គ្មានសល់គឺមានតែថៅចិត្រម្នាក់ប៉ុណ្ណោះដែលនៅបាញ់តទល់ជាមួយចោរយ៉ាអង់អាច។ ដោយសារតែគ្រាប់កាំភ្លើងសល់តែមួយគ្រាប់ ថៅចិត្របានប្រាប់ឱ្យយុន នារីរត់ពួនព្រមទាំងសារភាពពីសេចក្តីស្នេហារបស់គេចំពោះយុន នារីទៀតផង។ ឯនាងយុន នារីវិញក៏បានឆ្លើយតបទៅថៅចិត្រថានាងក៏ស្រឡាញ់ថៅចិត្រដែរ។ គ្រាន់តែយុន នារីពួនក្រាបអែបឱនក្បែរគល់ស្រឡៅធំមួយរួចមក ស្រាប់តែឮសូរសម្លេងថៅចិត្រស្រែកល្វើយៗហើយក៏សន្លប់បាត់ស្មារតី។

គ្រោះមហន្តរាយក្នុងងព្រៃនារាត្រិនោះមិនបានធ្វើឱ្យជនណាម្នាក់ស្លាប់បាត់បង់ជីវិតឬបាត់បង់ទ្រព្យសម្បត្តិនោះទេព្រោះតាស៊ុនដោយបាត់លោកហ្លួងរតនៈសម្បត្តិយូរពេកក៏បានបើករថយន្តទៅតាមរកដល់កណ្តាលព្រៃ ហើយដេញចោរព្រៃឱ្យរត់

ខ្វាត់ខ្វាយអស់។ ក្រោយមកគេក៏ដឹកថៅចិត្រយកមកព្យាបាលនៅឯគេហដ្ឋានលោកហ្លួងរតនៈសម្បត្តិ។ ពេលដែលថៅចិត្របានជាសះស្បើយ យុវជនយើងក៏បន្តនូវសកម្មភាពនៃសេចក្ដីស្នេហាតទៅទៀតទាល់តែដឹងចិត្តថ្លើមនារីសំឡាញ់ចិត្តយ៉ាងច្បាស់។បន្តមកទៀត ថៅចិត្រត្រូវបានលោកហ្លួងរតនៈសម្បត្តិផ្ដល់ការងារឱ្យមើលការខុសត្រូវលើកម្មកររជំនួសលោក។

ថ្ងៃមួយលោកបាឡាត់បាននាំថៅកែផាន់ទៅរកទិញត្បូងពេជ្រនៅគេហដ្ឋានលោកហ្លួងរតនៈសម្បត្តិ។ ពេលដែលលោកហ្លួរតនៈសម្បត្តិនាំថៅកែផាន់ទៅមើលទៅមើលការជីកត្បូងនៅឯអណ្ដូង លោកបាឡាត់ដែលនៅចាំផ្ទះឯណោះវិញបាននិយាយផ្ដោះផ្ដងសុំសេចក្ដីស្នេហាពីនាងយុន នារីតែនាងមិនព្រម លោកបាឡាត់ក៏សំឡុតគំរាមនិងចាប់រំលោភនាងយុន នារីយ៉ាងសាហាវព្រៃផ្សៃតែពុំបានសម្រេចព្រោះជួនពេលនោះថៅចិត្រក៏បានមកដល់ហើយក៏បានដាល់លោកបាឡាត់ដួលជាហេតុធ្វើឱ្យលោកបាឡាត់មានការអាម៉ាសមុខយ៉ាងខ្លាំង។ថៅកែផាន់បាននាំលោកបាឡាត់ត្រឡប់ទៅផ្ទះវិញទាំងក្ដីហ្មងសៅ។ លុះយប់ឡើងលោកបាឡាត់និងថៅកែផាន់ព្រមទាំងបក្សពួកនាំគ្នាមកប្លន់ផ្ទះលោកហ្លួងរតនៈសម្បត្តិមួយលើកទៀត ប៉ុន្តែពួកចោរទាំងអស់នោះត្រូវពួកកម្មកររបស់លោកហ្លួងរតនៈសម្បត្តិបាញ់ស្លាប់ខ្លះ របួសខ្លះ ចំណែកលោកបាឡាត់និងថៅកែផាន់ត្រូវថៅចិត្របាញ់សម្លាប់ក្នុងគ្រានោះទៅ។
លុះបានសុខសប្បាយនិងបានឫក្សពារវេលាល្អហើយ លោកហ្លួងរតនៈសម្បត្តិក៏បានរៀបចំអាពាហ៍ពិពាហ៍ថៅចិត្រនិងយុន នារីយ៉ាងអធិកអធ័មនៅចំពោះមុខភ្ញៀវជាអ្នកជំនួញត្បូងគ្រប់ជាតិសាសន៍រួមមាន ភូមា បារាំង ចិន យួន...។

គូស្វាមីភរិយានេះបានរួមរស់ជាមួយគ្នាដោយក្ដីសុខសាន្តក្រៃលែងបង្កើតបានជាកូនពូនជាថៅរៀងដរាបមក។

**២.តួអង្គ**

-តាចឹម : ត្រកូលសិរីពង្ស ជាឪពុកថៅចិត្រ។

-ថៅចិត្រ : ជាកូនប្រុសទោលរបស់តាចឹម និងជាសង្សារនាងយុន នារី។

-ហ្លួងរតនៈសម្បត្តិ : ជាថៅកែត្បូងនៅប៉ៃលិន។

-យុន នារី : ជាកូនស្រីទោលរបស់ហ្លួងរតនៈសម្បត្តិ។

-លោកបាឡាត់ : ជាបាឡាត់ស្រុកសង្កែខេត្តបាត់ដំបង។

-តាស៊ុន : ជាអ្នកបើករថយន្តឱ្យហ្លួងរតនៈសម្បត្តិ។

- គ្រូពេទ្យស្អាត : ជាក្មួយហ្លួងរតនៈសម្បត្តិ និងជាគ្រូពេទ្យចិត្តធម៌ជួយព្យាបាលតាចឹម។

- ថៅកែផាន់ : ជាសម្លាញ់របស់លោកបាឡាត់ និងជាមេចោរ។

-ក្រុមកម្មករ

-គ្រូពេទ្យព្យាបាលថៅចិត្រ

៣.**កាលអាកាស**

-កាល : ពេលវេលាដែលដំណើររឿងប្រព្រឹត្តទៅប្រហែល៧ខែ។

-អាកាស : ទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅគឺផ្សារវិលក្នុងទីរួមខេត្តបាត់ដំបង តាមដងផ្លូវទៅប៉ៃលិន ស្រុកសង្កែកណ្តាលព្រៃ ផ្ទះលោកហ្លួងរតនៈសម្បត្តិនៅប៉ៃលិន អណ្តូងត្បូង ភ្នំសំពៅនិងភូមិស្ទឹង។

## III.**និដ្ឋភាពទំនាស់**

**១.ទំនាស់ទី១**

+ទីកន្លែងទំនាស់ : ខាងលិចផ្សារស្វាយប៉ោដែលជាផ្សារវិលក្នុងទីរួមខេត្តបាត់ដំបង។

+តួទំនាស់ : ថៅចិត្រនិងមរណភាពឪពុក(តាចឹម)។

ធម្មជាតិនៃជីវិតក្នុងលោកទាំងអស់រមែងកើត ចាស់ ឈឺ ស្លាប់ យ៉ាងទៀងទាត់ពោលគឺជាតិ ជរា ព្យាធិ មរណា នេះជាមរតកធម៌របស់សត្វលោក ឥតមានសត្វលោកណាមួយគេចវេះជៀសវាងរួចផុតបានឡើយ។តាមន័យនេះទោះបីថៅចិត្រខិតខំថែទាំនិងរកគ្រូពេទ្យមកព្យាបាលជំងឺចាស់ជរារបស់តាចឹមជាឪពុកយ៉ាងណាក៏ពុំបានសម្រេចតាមបំណងឡើយ ហើយទីបំផុតតាចឹមក៏បានស្លាប់នៅលើដៃថៅចិត្រតែម្តង។តាចឹមស្លាប់ទាំងបិទភ្នែកមិនជិតព្រោះគាត់នៅអាល័យអាលោះស្រណោះបុត្រទោលបណ្តូលចិត្តគាត់ដែលរស់នៅក្រីក្រតោកយ៉ាកឯកោគ្មានទីពឹងពំនាក់។ចំណែកឯថៅចិត្រវិញក៏ប្រឈមនឹងទុក្ខជាទម្ងន់សម្រាប់ជីវិតរបស់គេគឺទុក្ខនៃការព្រាត់ប្រាស់ឪពុកជាទីស្រឡាញ់ស្មើជីវិត។ យូរៗម្តងទឹកភ្នែកថៅចិត្រហូរស្រក់មកដោយមិនដឹងខ្លួន ឯទុក្ខមួយទៀតនោះគឺថៅចិត្រត្រូវរស់នៅជាក្មេងកំព្រាតោកយ៉ាកគ្មានបងប្អូន គ្មានញាតិមិត្ត គ្មានអ្នកពឹងពាក់ជ្រកកោនបាននោះទេ ប៉ុន្តែថៅចិត្រពុំបានចុះញ៉មចំពោះបញ្ហាទាំងនេះឡើយ ហើយគេបានគិតយ៉ាងច្បាស់ថា"កើតមកជាអង្គបុរសហើយមិនត្រូវខ្លាចសេចក្តីទុក្ខព្រួយលំបាកទេ តោងតែតស៊ូនឹងសេចក្តីទុក្ខព្រួយលំបាកអស់នេះឱ្យឃើញសខ្មៅទៅចុះ"។

ដោយសារការតាំងចិត្តយ៉ាងមុតមាំនេះ ទើបថៅចិត្រទទួលបានពន្លឺនៃក្តីសង្ឃឹមតូចមួយគឺថៅចិត្រត្រូវបានលោកគ្រូពេទ្យស្អាតជួយរកការងារឱ្យធ្វើនៅឯប៉ៃលិន។បញ្ហាប្រឈមទាំងអម្បាលមានលើជីវិតថៅចិត្រត្រូវបានធូរស្រាលមួយកម្រិត។

២.ទំនាស់ទី២

- ទីកន្លែងទំនាស់ : ក្នុងព្រៃតាមផ្លូវពីបាត់ដំបងមកប៉ៃលិន។

- តួទំនាស់ : ថៅចិត្រ និងចោរព្រៃ។
- បើតាមសភាពនៃទំនាស់ គឺនៅពេលដែលបររថយន្តជូនលោកហ្លួងរតនៈសម្បត្តិ នាងយុន នារី បាឡាត់ វិលត្រឡប់មកប៉ៃលិនវិញ ក៏ខូចឡាននៅកណ្ដាលព្រៃ ដោយពុំអាចជួសជុលបាន អ្នកដំណើររួមទាំងថៅចិត្រក៏បានសម្រាកនៅកណ្ដាលព្រៃ។ វេលានោះពិតជាលំបាកបន្តិចតែឱកាសនេះ វាបានបណ្ដុះនូវទឹកចិត្តស្នេហារបស់ថៅចិត្រ យុន នារីឱ្យរីកដុះដាលកាន់តែធំឡើង។ ពួកគេកាន់តែស្គាល់ចិត្តថ្លើមគ្នាយុន នារីឈប់ស្អប់ខ្ពើមថៅចិត្រ។ ស្របពេលដែលថៅចិត្រស្នើឱ្យយុន នារីទៅសម្រាក ក្រុមចោរប្លន់ក៏ធ្វើសកម្មភាព ស្រែកហ៊ោគឹលសម្រុកចូលមកកន្លែងអ្នកដំណើរសម្រាក ហើយបានឮសម្លេងកាំភ្លើងច្រើនណាត់បានបាញ់ ពេលនោះថៅចិត្តក៏បានបាញ់តបវិញ។ តែដោយសារគ្រាប់តិចពេក ថៅចិត្រក៏បានអស់គ្រាប់ ហើយត្រូវបានចោរបាញ់ចំទ្រូងបន្លឺសម្លេងគួរឱ្យសង្វេក ក្រោយពេលគេបានដឹងចម្លើយស្នេហាពីនាងយុន នារី រួចក៏សន្លប់បាត់ទៅ។ តែសំណាងល្អបានតាស៊ុន និងកម្មករជាច្រើនជិះឡានមកតាមជួយបាញ់តប និងស្រែកបង្អើល ក្រុមចោររត់ចូលព្រៃបាត់អស់ទៅ។ ថៅចិត្រត្រូវបានលោកហ្លួងរតនៈយកមកព្យាបាលដោយយកចិត្តទុកដាក់មើលថែពីនាងយុន នារី។ ទំនាស់នេះត្បិតតែថៅចិត្ររងគ្រោះ តែគ្រោះនោះក៏ក្លាយទៅជាលាភសំណាង «ក្រោយភ្លៀងធ្លាក់មេឃក៏ស្រឡះល្អ»។

៣.ទំនាស់ទី៣ : ថៅចិត្រ និងក្រុមបាឡាត់

- ទីកន្លែងទំនាស់ : នៅផ្ទះលោកហ្លួងរតនៈខេត្តប៉ៃលិន
- តួទំនាស់ : ថៅចិត្រ និងក្រុមលោកបាឡាត់
- បើតាមសភាពនៃទំនាស់នេះ វាផ្ដើមហេតុតាំងពីពេលគ្រួសារហ្លួងរតនៈទៅទទួលលោកបាឡាត់ពីស្រុកសង្កែម្លេះ លោកបាឡាត់ និងថៅចិត្រមានគំនិត អរិភាពនឹងគ្នាព្រោះតែមានចិត្តច្រណែនប្រច័ណ្ឌចំពោះនាងយុន នារី។ ប៉ុន្តែដោយសារលក្ខណសម្បត្តិល្អរបស់ថៅចិត្រ នាងយុន នារីក៏សម្រេចទទួលថៅចិត្រជាគូស្នេហ៍របស់នាង។ ផ្ដើមពីចំណុចនេះហើយបានជំរុញឱ្យលោកបាឡាត់មានគំនិតគំគួនសងសឹកចំពោះថៅចិត្រ និងគ្រួសារនាងយុន នារី។ ក្រោយមកលោកបាឡាត់បានសហការរួមគំនិតជាមួយថៅកែផាន់ជាចោរ ហើយចូលមកឈ្លានពានគ្រួសារយុន នារី ដោយលើកទី១លោកបាឡាត់រកល្បិចចាប់នាងយុន នារីតែត្រូវបរាជ័យក្រោមថ្វីដៃរបស់ថៅចិត្រ តែហ្លួងមិនយកទោសដោះលែងដោយកាត់ចំណងទាក់ទងនឹងបាឡាត់ក៏ដូចជាថៅកែផាន់។ រំលងមិនបានមួយថ្ងៃផងបាឡាត់ ថៅកែផាន់រួមនឹងចោរព្រៃជាច្រើនចូលមកឈ្លានពានផ្ទះលោកហ្លួង

បំណាងចាប់យុន នារី និងប្លន់ត្បូងពេជ្ររបស់លោកហ្លួង តែត្រូវថៅចិត្រ និងកម្មករ រួមរួមសាមគ្គីគ្នាកំចាត់ចោរ។ ថៅចិត្របានសម្លាប់បាឡាត់ និងថៅកែផាន់ដោយផ្ទាល់ដៃ។ ពេលមេចោរទាំងពីរស្លាប់កូនចោរក៏នាំគ្នារត់ចូលព្រៃអស់ទៅ។ លោកហ្លួងដោយរួចជីវិតពីក្តីអន្តរាយក៏ជប់លៀងឱ្យកម្មការ

## IV.**ទិដ្ឋភាពវិភាគតួអង្គ**

### ១.ថៅចិត្រ

**ក.គុណសម្បត្តិ**

-ជាកូនកតញ្ញូ

-ជាមនុស្សចេះតស៊ូអត់ធ្មត់ព្យាយាមក្នុងជីវិត

-ជាមនុស្សមានភាពអង់អាចក្លាហាន

-ជាមនុស្សម៉ឺងម៉ាត់ ហ្មត់ចត់ក្នុងការងារ

-ជាមនុស្សស្លូតបូត សុភាពរាបសារ

-ជាមនុស្សមានចំណេះវិជ្ជា

-ជាមនុស្សសុចរិតទៀងត្រង់

-ជាកូនគោរពតាមការទូន្មាននិងបណ្តាំឪពុក

-ជាមនុស្សមានការជឿជាក់លើខ្លួនឯង

-ជាមនុស្សហ៊ានប្រឈមមុខនឹងការពិត

-ជាមនុស្សមានស្នេហាមោះមុតនិងភក្តីភាពចំពោះនារីដែលខ្លួនស្រឡាញ់

-ជាមនុស្សចេះជួយយកអាសាអ្នកដទៃ

**ខ.គុណវិបត្តិ**

ជាមនុស្សលាក់ពុតនិងមានចិត្តឆេវឆាវប្រច័ណ្ឌច្រើន...។

### ២.នាងយុន នារី

**ក.គុណសម្បត្តិ**

-ជាស្រីចេះមានការភ្ញាក់រលឹកឈប់មានការរើសអើង

-ជាកូនគោរពឪពុកម្តាយ

-ជាស្រីមានភក្តីភាពចំពោះស្នេហា

-ជាមនុស្សគោរពសម្តីនិងការសន្យា

-ជាស្រីដែលមិនជឿតាមការលួងលោមផ្តេសផ្តាស

-ជាស្រីដែលចេះការងារផ្ទះយ៉ាងស្ទាត់ជំនាញ

-ជាស្រីអង់អាចក្លាហាន

-ជាស្រីដែលគោរពប្រពៃណី ទំនៀមទម្លាប់ខ្មែរ

-ចេះវិភាគនិងពិចារណាបានល្អិតល្អន់...។

**ខ.គុណវិបត្តិ**

-មានចរិកឆ្មើងឆ្មៃដោយវាយតម្លៃមនុស្សតែសម្បកក្រៅ

-ប្រើពាក្យសម្ដីអសុរស ពុំពីរោះពិសារចំពោះអ្នកក្រតូចទាប

-ឆាប់ផ្ដេកផ្ដួលនិងមានអារម្មណ៍ឆាបឆេះក្នុងរឿងស្នេហា...។

**៣.លោកហ្លួងរតនៈសម្បត្តិ**

**ក.គុណសម្បត្តិ**

**-មានទ្រព្យសម្បត្តិស្ដុកស្ដម**

-ជាបិតាប្រកបដោយព្រហ្មវិហារធម៌ចំពោះបុត្រ

-ផ្ដល់សិទ្ធសេរីភាពក្នុងការជ្រើសរើសគូស្រករដល់កូន

-ជាថៅកែឬថៅហ្វាយដែលមានចិត្តមេត្តា

-ជាមនុស្សដែលគ្មានការរើសអើងវណ្ណៈ

-ជាមនុស្សយកគុណសងដោយគុណ មិនមែនយកគុណសងដោយទោសឡើយ

-ជាមនុស្សគោរពច្បាប់រាជការ

-ជាមនុស្សចេះជួយយកអាសារអ្នកដទៃ

-ជាមនុស្សប្រកបរបរសុចរិត។

**ខ.គុណវិបត្តិ**

-អប់រំកូនមិនបានល្អ

-សេពគប់មនុស្សមិនល្អ...។

**៤.លោកបាឡាត់ស្រុកសង្កែ**

**ក.គុណសម្បត្តិ**

-ខិតខំរៀនសូត្ររហូតបានការងារធ្វើ

-មានចណេះដឹងខ្ពង់ខ្ពស់។

**ខ.គុណវិបត្តិ**

-ជាមន្ត្រីគ្មានក្រមសីលធម៌ និងសុជីវធម៌

-ជាមនុស្សមានអត្តចរិកក្រអឺតក្រទម

-ជាមនុស្សកំសាកមិនហ៊ានប្រឈមមុខនឹងឧបសគ្គ

-ខ្លួនជាមនុស្សតែចិត្តជាសត្វតិរច្ឆានដោយហ៊ានរំលោភបំពានលើនារីភេទទន់ខ្សោយ

-ជាព្រានតណ្ហាអាងអំណាចនិងទឹកប្រាក់

-ជាជនអន្ធពាល...។

-សេពគបមនុស្សអាក្រក់

## V.**ទិដ្ឋភាពសង្គម**

**១.វប្បធម៌**

**ក-ប្រពៃណីទំនៀមទម្លាប់** : ប្រពៃណីទំនៀមទម្លាប់ខ្មែរដែលគួរឱ្យកត់សម្គាល់នាសម័យនោះគឺពិធីរៀបអាពាហ៍ពិពាហ៍កូនកំលោះ ក្រមុំដើម្បីឱ្យក្លាយជាគូស្វាមីភរិយាស្របច្បាប់។

ឧទាហរណ៍"លោកហ្លួងរតនៈសម្បត្តិចាត់ចែងរៀបមង្គលការរវាងនាងក្រមុំនារីបុត្រីលោកជាគូនឹងចៅចិត្រ..."។

**ខ-ជំនឿ** : ប្រជាជនខ្មែរមានផ្នត់គំនិតជឿលើហោរា ជឿលើការទស្សន៍ទាយរកពេលវេលាល្អដើម្បីរៀបការកូនប្រុសស្រី។

ឧទាហរណ៍"លុះបានឫក្សពេលវេលាល្អតាមឫក្សហោរាសាស្ត្រ..."។

**គ-សាសនា** : ប្រជាជនគោរពប្រណិប័តនិព្រះពុទ្ធសាសនា ជាក់ស្តែងមានការបូជាសពតាមបែបព្រះពុទ្ធសាសនានិងមានទីវត្តអារាមសម្រាប់ជាទីស្នាក់អាស្រ័យរបស់ព្រះសង្ឃជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូផងដែរ។

ឧទាហរណ៍ ចៅចិត្រឮសម្លេងសូត្រធម៌របស់ព្រះសង្ឃរសាត់តាមខ្យល់ពីវត្តមួយ"...ឮសូរសម្លេងព្រះសង្ឃសូត្រធម៌នៅវត្តពិភិធារាមយ៉ាងច្បាស់..."។

**ឃ-ការសិក្សាអប់រំ** : នៅសម័យនោះវិស័យអប់រំពុំទាន់មានការរីកចម្រើននៅឡើយទេពោលគឺ មានការសិក្សាតាមទីវត្តអារាមខ្លះនិងសាលារដ្ឋខ្លះៗប៉ុណ្ណោះ។មានការសិក្សាភាសាបារាំងនិងការប្រឡងប្រកាសនីយ៍ប័ត្រ។

ឧទាហរណ៍ តាចឹមនិយាយទៅកាន់ចៅចិត្រថា"...ទុកដាក់ឱ្យកូនរៀនសូត្រទាល់តែប្រឡងជាប់ប្រកាសនីយ៍ប័ត្រនោះ..."។ឯនាងយុន នារីក៏បានពោលដែរថា"...តែខ្ញុំបានឃើញសៀវភៅអស់នេះនៅក្នុងបន្ទប់បងឯងហើយមានស៊ីញ៉េឈ្មោះបងឯងជាអក្សរបារាំងផង"។

**-សិល្បៈ** : ពុំមានការសម្តែងសិល្បៈជាសាធារណៈនោះទេ ប៉ុន្តែតាមសាលារៀននីមួយៗមានការបង្ហាត់ច្រៀង ជាក់ស្តែងចៅចិត្រចេះច្រៀងតាមទំនុកបទយុវាភិរម្យ។

ឧទាហរណ៍"ពួកយើងជាគណៈយុវជន ស្រុះស្រួលលើសលន់ទាំងប្រុសទាំងស្រីចូលយុវសាលាដែលទើបកើតថ្មី..."។

**ខ.សង្គមកិច្ច**

**-សន្តិសុខ** : សន្តិសុខ សុវត្ថិភាពពុំទាន់ធានាបានទាំងស្រុងទូទាំងប្រទេសនោះឡើយពោលគឺមានការប្រើប្រាស់អាវុធខុសច្បាប់និងមានអំពើចោរកម្មប្លន់ប្រដាប់អាវុធទៀត ជាក់ស្តែងលើកទី១ប្លន់លោកហ្លួរតនៈសម្បត្តិនៅកណ្តាលព្រៃ ហើយលើកទី២មកប្លន់ដល់គេហដ្ឋានលោកហ្លួងរតនៈសម្បត្តិតែម្តង។

ឧទាហរណ៍"ពួកមហាចោរក៏បាញ់កាំភ្លើងមកបាចសាចដូចជាគ្រាប់ភ្លៀង..."។

**-សុខាភិបាល** : មានការព្យាបាលតាមបែបបទក្បួនវេជ្ជសាស្ត្រទំនើបហើយមានតំបន់ខ្លះនៃប្រទេសកម្ពុជាតែងមានការយាយីដោយជំងឺគ្រុនចាញ់ដូចជាតំបន់ប៉ៃលិនជាដើម។

ឧទាហរណ៍ គ្រូពេទ្យស្អាតនិយាយថា"...ច្រើនធ្វេសប្រហែសមិនចេះរក្សាខ្លួនឱ្យផុតពីជំងឺគ្រុនចាញ់ ចំណែកអ្នកបានរៀនសូត្រចេះក្បួនអនាម័យមកខ្លះក៏ល្មមនឹងការពារខ្លួនបាន..."។

**-ស្ថានភាពរស់នៅ** : ប្រជាជនរស់នៅក្នុងស្ថានភាពក្រីក្រលំបាកតោកយ៉ាក ជាក់ស្តែងស្ថានភាពនៃការរស់នៅរបស់តាចឹមជាភស្តុតាងស្រាប់។

**-មុខរបររបស់ប្រជាជន** : ប្រកបរបរកសិកម្ម ហើយអ្នករស់នៅតំបន់ប៉ៃលិនគឺប្រកបរបរស៊ីឈ្នួលជីកត្បូងដើម្បីទទួលប្រាក់កម្រៃចិញ្ចឹមជីវិត។

ឧទាហរណ៍"ព្រឹកឡើង លោកហ្លួងរតនៈសម្បត្តិបានហៅពួកកម្មករទាំងអស់មកប្រជុំគ្នា..."។

**គ.សេដ្ឋកិច្ច**

**-កសិកម្ម** : ពុំឃើញមានអ្វីលេចធ្លោនោះទេ គ្រាន់តែអ្នកនិពន្ធរៀបរាប់ពីវាលស្រែចម្ការរបស់កសិករតែប៉ុណ្ណោះ។

ឧទាហរណ៍"...សឹងដេរដាសទៅដោយស្រែ ចម្ការ ច្បារដំណាំនិងភូមិ ស្រុកដោយអន្លើៗ..."។

**-ឧស្សាហកម្ម** : ពុំទាន់
មានការរីកចម្រើន ពុំទាន់មានរោងចក្រផលិតរថយន្តក្នុងស្រុកនោះទេ តែមានការប្រើប្រាស់រថយន្តនាំចូលពីបរទេស។

ឧទាហរណ៍"ស្រាប់តែឃើញនាងយុន នារីនិងលោកហ្លួងរតនៈសម្បត្តិអង្គុយក្នុងរថយន្តយីហោរីណូត៍..."។

**-ពាណិជ្ជកម្ម** : មានការនាំចេញត្បូងទៅលក់នៅទីផ្សារក្រៅប្រទេស។

ឧទាហរណ៍"...អ្នកជំនួញទាំងជាតិខ្មែរ ជាតិភូមា ចិន យួននិងបារាំង..."។

**-ហិរញ្ញវត្ថុ** : ការដោះដូរទំនិញឬការលក់ដូរនិងការបើកប្រាក់ខែពឹងផ្អែកលើរូបិយប័ណ្ណគឺប្រាក់រៀល។

ឧទាហរណ៍ លោកហ្លួរតនៈសម្បត្តិនិយាយថា៉...ខ្ញុំនឹងតាំងប្រាក់ខែឱ្យអ្នកឯង ត្រឹម៣០រៀលសិន...៉៉...យ៉ាងនេះទឹកល្អច្រើន ១ គ្រាប់ ២០០រៀល ក្នុង ១ គ្រាប់នេះ ប្រហែល ៤ ក្រាត់៉។

**-សិប្បកម្ម :** ឃើញមានតែសិប្បកម្មកែច្នៃត្បូងតែប៉ុណ្ណោះ។

**ឃ.នយោបាយ**

**+ក្នុងប្រទេស :** របបនយោបាយគ្រប់គ្រងប្រទេសនាសម័យនោះគឺ ប្រទេសកម្ពុជាប្រកាន់របបរាជានិយមដែលមានព្រះមហាក្សត្រជាប្រមុខដឹកនាំប្រទេស។

ឧទាហរណ៍៉...ចំពោះជាតិ សាសនា ព្រះមហាក្សត្រដែលជាឧត្តមគតិរបស់ពលរដ្ឋជាតិ...៉។

**+ក្រៅប្រទេស :** ពុំមានការបញ្ជាក់ឱ្យល្អិតល្អន់ឡើយព្រោះប្រទេសកម្ពុជាស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំងហើយទំនាក់ទំនងអន្តរជាតិគឺបារាំងជាអ្នកកាន់កាប់ត្រួតត្រានៅពីលើព្រះមហាក្សត្រខ្មែរមួយជាន់ទៀត។

## VI.**ទិដ្ឋភាពផែនកនិពន្ធ**

**១.ផ្តើមរឿង**

អ្នកនិពន្ធបានពណ៌នារៀបរាប់ពីទីកន្លែងដែលតួអង្គរស់នៅ។

ឧទាហរណ៍ គ្រានោះព្រះសុរិយទេវបុត្រទ្រង់គង់លើវិមានកែវផលិកដែលជារថព្រះទីនាំងទឹមដោយសេះអាជានេយ្យ១ពាន់ទ្រង់បរប្រទក្សិណ.......ឆ្ពោះចំទៅលើដំបូលគេហដ្ឋានមួយនៅខាងលិចផ្សារស្វាយប៉ោដែលជាផ្សារវិលក្នុងទីរួមខេត្តបាត់ដំបង។ឯគេហដ្ឋាននោះជាផ្ទះចាស់ប្រក់ក្បឿង ដំបូលពីរជាន់ ជញ្ជាំងក្តារ ក្រាលក្តារសសរមូល.....។

**២.តួរឿង**

**ក.ទម្រង់សំណេរ :** រឿងកុលាបប៉ៃលិនអ្នកនិពន្ធតាក់តែងជាប្រលោមលោកពាក្យរាយ។

ឧទាហរណ៍ ឯបុរសដែលមានជំងឺជាទម្ងន់កំពុងដេកស្តូកស្តឹងនៅលើដំណេកនេះឈ្មោះ៉ចឹម៉កំពុងធ្លាក់ខ្លួនទៅជាចំណីអាហារនៃរោគជរា......។

**ខ.បច្ចេកទេសក្នុងការតាក់តែង ឬវិធីតែង**

**-វចនៈវិធី :** ជាវិធីដែលអ្នកនិពន្ធប្រើពាក្យពេចន៍ដើម្បីតាក់តែងអត្ថបទរឿង។រឿងនេះអ្នកនិពន្ធប្រើពាក្យសាមញ្ញលាយជាមួយពាក្យកំចីបាលីសំស្ក្រឹតនិងពាក្យកំចីពីបរទេស។ ឧទាហរណ៍

+ពាក្យសាមញ្ញ : ជា ផ្ទះ ចាស់ ប្រក់ ក្បឿង...។

+ពាក្យកំចីបាលីសំស្ក្រឹត : សុរិយចក្រវាឡ ប្រទក្សិណ បុព្វតា...។

+ ពាក្យកំចីបរទេស : ភាសុី ប្រូក្រាម វ៉ាលី ហាឡាំងតាវ...។

**-ឧបមាណវិធី :** អ្នកនិពន្ធធ្វើការប្រៀបធៀបដោយប្រើចំណងធៀប។

ឧទាហរណ៍៖

+ "ជីវិតកូនមុខជារសោត់អណ្តែតឥតបង្គោលជាបង្អែក ដូចជាសំណាត់ដែលអណ្តែតក្នុងទន្លេដូច្នោះ" ។

+ "ដំណើរល្វាសល្វន់ដូចផ្កាកុលាបដែលត្រូវខ្យល់" ។

**-សំវាទវិធី :** តួអង្គតាចឹមពោលឆ្លើយឆ្លងជាមួយចៅចិត្រ។ឧទាហរណ៍

+តាចឹម "ចិត្រកូនមាសថ្លៃឪពុក យប់យន់ណាស់ហើយមិនទាន់ទៅដេកទេឬ?

+" ចៅចិត្រ "ខ្ញុំបាទមិនទាន់ងងុយទរលោកឪពុក..." ។

**-ឯកវាទវិធី :** តួងង្គចៅចិត្រពោលគិតតែម្នាក់ឯង។ឧទាហរណ៍

+" ឱ! ខ្លួនអញអើយ កណ្តែងកណ្តោច ខ្លោចផ្សាតែម្នាក់ឯងហើយ..."។

**-និទានវិធី :** អ្នកនិពន្ធប្រើវិធីនិទានតាមបែបបុរសទី៣។

ឧទាហេណ៍ "នាងអង្គុយស្តាប់សម្តីចៅចិត្រនិយាយដោយអារម្មណ៍អណ្តែតអណ្តូង នាងគិតថា កម្មករកំលោះនេះជាមនុស្សចម្លែក..."។

**-ទារុណវិធី :** ភាពទុក្ខសោកវេទនាតាមរយៈតួអង្គតាចឹម។

ឧទាហរណ៍ "...តាចឹមមានអាការៈដង្ហក់កាន់តែញឹកញាប់ខ្លាំងឡើង មានអាការៈក្រវល់ក្រវាយ ទំនងស្លឈាម..."។

- បំរៀបន័យវិធី : អ្នកនិពន្ធប្រើការប្រៀបធៀប ដោយមិនប្រើចំណងធៀប

ឧទាហរណ៍ កុលាបប៉ៃលិន

+កុលាបគឺជាផ្កា ប្រៀបដូចជាស្ត្រីដែលមានសម្រស់ស្អាតល្អ

+ប៉ៃលិនគឺឈ្មោះខេត្តមួយ ដូច្នេះពាក្យ« កុលាបប៉ៃលិន សំដៅលើនាងយុន នារីជានារីល្អដាច់គេនៅខេត្តបរប៉ៃលិន។

- ពណ៌នាវិធី : អ្នកនិពន្ធប្រើប្រាស់ឃ្លាប្រយោគបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ហើយមានភាពពីរោះផ្អែមល្ហែមគួរឱ្យចង់តាមដាន។

ឧទាហរណ៍ ព្រះសូរិយាទេវបុត្រទ្រង់គង់លើវិមានកែវផលិត(ផ្លេក)...។

- វឌ្ឍមានវិធី : អ្នកនិពន្ធបានបង្កឱ្យសាច់រឿងមានភាពតានតឹងឡើងៗ រហូតចុងបញ្ចប់បានធូស្រាលវិញ។

ឧទាហរណ៍ ស្ថានភាពជំងឺរបស់តាចឹមកាន់តែមានសភាពធ្ងន់ធ្ងររហូតចុងក្រោយបានស្លាប់ ហើយបន្សល់ទុក្ខនូវភាពកំសត់អនាថាដល់ចៅចិត្ររស់នៅលំបាកវេទនាប្រឈមមុខនឹងឧបសគ្គជាច្រើនដូចជា ត្រូវបានយុន នារីមើលងាយ

ត្រូវធ្វើការងារលំបាកៗប្រឈមមុខនឹងចោរព្រៃ ហើយចុងបញ្ចប់ត្រូវប្រយុទ្ធជាមួយលោកបាឡាត់ និងថៅកែផាន់។

- បដិវិធី ៖

+ អ្នកនិពន្ធបង្ហាញពីលក្ខណៈប្រឈមលើអង្គតែមួយ ៖

- ថៅចិត្រមាឧត្តចស្គម តែមានកម្លាំងខ្លាំង
- លោកបាឡាតមានឋានៈជាបាឡាត់ស្រុកតែកំសាក

+ អ្នកនិពន្ធបង្ហាញពីលក្ខណៈប្រឈមអង្គពីរ ឧទាហរណ៍ «បើទុកជាគេទីទ័លក្រ ក៏ទីទ័លក្រតែទ្រព្យសម្បត្តិប្រាក់មាស តែគុណសម្បត្តិសុខភាព រៀបរយជាសុភាពបុរសជាកូនប្រុសមែនៗ នោះថៅចិត្រមានសព្វគ្រប់ តែខ្លួនលោកមានតែមាសប្រាក់មែនហើយ...ដែលថៅចិត្រគ្មាន តែរបស់ដែរថៅចិត្រមានលោកមិនមានសោះឡើយ។

- បដិរូបភាសា

**-ភាសាច្បាស់លាស់** ឧទាហរណ៍

+ដំណើរល្វាសល្វន់

+ក្លិនក្រអូបឈ្ងុយឈ្ងប់

+ផ្ទះធំ

+ធម្មជាតិដ៏ស្រស់

+ធម្មជាតិដ៏ល្អល្អះ...។

**-ភាពរស់រវើក** ឧទាហរណ៍

+ផ្កាកុលាបដែលត្រូវខ្យល់បក់រវិចៗ......

+មានខ្យល់រំភើយៗបក់ចូលមកប៉ះនឹងខ្សែមុងរវិចៗ

+ស្តាប់សម្លេងស្លឹកឈើឮស្វូរប្រាវៗ។

**-បុគ្គលិកកម្ម** ឧទាហរណ៍

+មាន់ក៏មមើរងាវក្នុងរាត្រីស្ងាត់ ទឹកសន្សើមក៏ជ្រុះស្រក់...

+លុះរថយន្តបរផុត...ក៏ទច់ង៉ក់....

+ព្រះសុរិយទេវបុត្រទ្រង់គង់លើវិមានកែវផលិក....

**គ.បញ្ចប់រឿង**

រឿងកុលាបប៉ៃលិន អ្នកនិពន្ធបានបញ្ចប់រឿងដោយឱ្យតួអង្គឯកទាំងពីរគឺថៅចិត្រនិងនាងឃុន នារីរស់នៅជួបជុំគ្នាប្រកបដោយសុភមង្គលនិងក្តីសង្ឃឹមគួរជាទីមោទនៈ។

ឧទាហរណ៍"លុះអំណើសកាលតមក គូស្វាមីភរិយាទាំងពីរនាក់ក៏បាននៅរួបរួមរស់ជាមួយគ្នាជាសុខក្សេមក្សាន្ត ត្រាតែកើតកូន ពូនជាចៅ...."។

## VII.និជ្ជភាពតម្លៃ

១.បច្ចេករស : អ្នកនិពន្ធប្រើប្រលោមរស គឺតម្លៃនៃរឿងស្ថិតនៅលើភាពអណ្តែតអណ្តូងទាំងការប្រើប្រាស់ពាក្យពេចន៍ និងឃ្លាប្រយោគ។

ឧទាហរណ៍ មែនហើយ យុន នារីធម្មជាតិជារបស់ចម្លែកនេះអាចប្រលោម លួងលោមអារម្មណ៍របស់មនុស្សយើងឱ្យបានសុខស្រួល ពន្លឺរស្មីព្រះចន្ទ្រ ខ្យល់រំភើយផាត់ និងក្លិនក្រអូបឈ្ងុយឈ្ងប់របស់ផ្កានានាអាចធ្វើឱ្យចិត្តគំនិតរបស់យើងឱ្យមានអារម្មណ៍រីករាយទៅបានយ៉ាងចំឡែក។

២. វិសេសរស់ : តម្លៃស្ថិតនៅត្រង់ថៅចិត្របង្ហាញភាពអង់អាចក្លាហានពេលប្រយុទ្ធជាមួយចោរព្រៃ និងជាមួយបាឡាត់ហើយនិងថៅកែផាន់។

ឧទាហរណ៍

+ «ពួកមហាចោរក៏បាញ់កាំភ្លើងគ្រាប់បាយមកបាចសាចដូចជាគ្រាប់ភ្លៀង...ថៅចិត្របាញ់ទៅគ្មានខុសមួយគ្រាប់ចោខ្លះបាក់ដៃ ខ្លះបាក់ជើង...»។

+ «បាឡាត់ស្រែកគំរាមតបមកវិញ ហើយចាប់ហូតកាំបិតស្នៀតចាក់សំដៅដើមទ្រូងថៅចិត្រគេចផុតខុយទៅ ទើបគេជូនមួយកណ្តាប់ដៃចំត្របកភ្នែក បាឡាត់ទុច្ចរិតតែមួយដៃ ក៏ដួលស្រប៉ាបនៅទីនោះឯង...»។

៣.សព្វរស :

- តថរស : តម្លៃស្ថិតត្រង់ដំណើររឿងបានបង្ហាញភាពពិតជាក់ស្តែងដូចជា៖
    - អាកាសនៃរឿង : នៅខេត្តបាត់ដំបង ទីរួមខេត្ត ស្រុកសង្កែ នៅប៉ៃលិន តាមផ្លូវទៅប៉ៃលិន...។
    - ជីវភាពប្រជាជន ផ្អែកលើការធ្វើស្រែចំការ ធ្វើកម្មករជីកត្បូង រកស៊ីជំនួញត្បូង។
    - ស្ថានៅភាពសង្គម : នៅក្នុងសម័យអាណានិគម សង្គមអសន្តិសុខមានចោរប្លន់។
- កុសលរស់ : តម្លៃស្ថិតនៅលើការអប់រំទូន្មានប្រៀនប្រដៅ ដែលអ្នកនិពន្ធបានបង្កប់តាមរយៈដំណើររឿង ពិសេសតាមរយៈសំដីតាចឹម ដែលលើកពុទ្ធភាសិតទូន្មានថៅចិត្រ «អត្តាហិ អតនោនាថា» គឺខ្លួនជាទីពឹងរបស់ខ្លួន ដើម្បីឱ្យថៅចិត្រចេះតស៊ូក្នុងជីវិតដើម្បីអនាគតរុងរឿង។ ចំណុចនេះបានតភ្ជាប់មកនឹងសង្គម៖
    - ឱ្យយុវជនចេះប្រណិប័តន៍តាមដំបូន្មានឪពុកម្តាយ

- ឱ្យយុវជនខំព្យាយាមរៀនសូត្រក្រេបយកចំណេះវិជ្ជាទុកជាទីអាងជួយគាំពារជីវិតឱ្យបានខ្ពង់ខ្ពស់
- ចេះអំណត់ពុះពារគ្រប់ឧបសគ្គ
- ចេះជួយខ្លួនឯង មុននឹងពឹងអ្នកដទៃ

- សោភ័ណរស : គឺតម្លៃមួយស្ថិតនៅលើអ្នកនិពន្ធប្រើប្រាស់វិធីតែងបានល្អ ហើយនឹងមានអត្ថន័យយ៉ាងប្រសើរ ដែរពន្លិចចេញតាមរយៈការចោទ និងស្រាយទាក់ទងសំខាន់ជាមួយដំណើរជីវិតរបស់តួអង្គចៅចិត្រតាំងពីក្មេងកំព្រារហូតចៅចិត្រក្លាយជាកូនប្រសាលោកហ្លួងរតនសម្បត្តិ។
- ទារុណរស : គឺជាតម្លៃកំសត់សោកសង្រេងនៃជីវិតចុងក្រោយរបស់តាចឹមដែរប្រយុទ្ធប្រឆាំងនឹងកម្លាំងធម្មជាតិ «កើត ចាស់ ឈឺ ស្លាប់» ទីបំផុតតាចឹមក៏ត្រូវចុះចាញ់ស្លាប់ចោលចៅចិត្រឱ្យរស់នៅកំសត់ឯកកា។

  ឧទាហរណ៍ « ...តអំពីពេលនោះមក តាចឹមមានអាការដង្ហក់កាន់តែញឹកញាប់ខ្លាំងឡើង មានអាការក្រវល់ក្រវាយទំនងស្លឈាម ហើយទន់ពាបទៅ រាល់គ្រាមរលាសង្គ្រាមកំពុងទន្ទ្រានចូល...ឱព្រះគុណអើយ ត្រចៀកខ្ញុំបាទលែងឮហើយ ឱចិត្តកូន ពុទ្ធោអរហំ»
- ទស្សនីយរស : តម្លៃស្ថិតត្រង់អ្នកនិពន្ធរៀបរាប់ពីទេសភាពនៅតាមដងផ្លូវដែលចៅចិត្របានធ្វើដំណើរទៅប៉ៃលិន។

  ឧទាហរណ៍ «...ចៅចិត្រក្រឡេកមើលទេសភាពតាមដងផ្លូវសឹងដេរដាសទៅដោយស្រែចំការ ច្បារដំណាំនឹងភូមិស្រុកដោយអន្លើៗ...ដល់បប៉ៃលិនក៏ឃើញមានព្រៃព្រឹក្សា លតាវល្លិ៍ និងភ្នំតូចធំច្រើនអនេក ព្រមទាំងសត្វបក្សាបក្សី និងសត្វចតុប្បាទក៏មានកុះករ...»

## VIII.ការសន្និដ្ឋាន

រឿងកុលាបប៉ៃលិនជាស្នាដៃអក្សរសិល្ប៍មួយដែលរក្សាព្រលឹងអ្នក្សរសិល្ប៍បាននៅក្នុងរឿងអក្សរសិល្ប៍ជាតិខ្មែរតាំងពីមុនរហូតដល់បច្ចុប្បន្នព្រោះរឿងនេះបានផ្តល់តម្លៃជាកុសលមួយគឺអប់រំសិស្សានុសិស្សនិងយុវជនជាទំពាំងស្នងឫស្សីទាំងអស់ឱ្យខិតខំប្រឹប្រែងរៀនសូត្រ ចេះតស៊ូពុះពារគ្រប់ឧបសគ្គក្នុងជីវិតនៃការរស់នៅព្រមទាំងមានភាពអង់អាចក្លាហានប្រកបដោយស្មារតីទទួលខុសត្រូវ។ជាងនេះទៅទៀតរឿងនេះបានជាប្រទីបបំភ្លឺដល់ជនានុជនទាំងអស់ឱ្យយល់កាន់តែច្បាស់ថាតម្លៃរបស់មនុស្សស្ថិតនៅលើភាពសុចរិតទៀងត្រង់។មានតែភាពសុចរិតទៀងត្រង់ប៉ុណ្ណោះទើបជាអលង្ការយ៉ាងវិសេសសម្រាប់លើកស្ទួយមនុស្សឱ្យរស់នៅប្រកបដោយភាពថ្លៃថ្នូរនិងសុភមង្គល យ៉ាងណាមិញដោយសារកត្តាទាំងអស់នេះហើយទើបធ្វើឱ្យខ្មែ

ជីវិតក្រីក្រលំបាកតោកយ៉ាករបស់ចៅចិត្រឈានដល់ពន្លឺនៃសុភមង្គលយ៉ាងត្រចះត្រចង់។

ទន្ទឹមនឹងនេះ រឿងកុលាបប៉ៃលិនក៏បានដាស់តឿនក្រើនរំឮកដល់បុគ្គលមួយចំនួនមិនត្រូវមានចិត្តជាជនទុច្ចរិត ជាជនអន្ធពាល ជាជនបាតសង្គមហិង្សានិយមនោះឡើយ។បើបុគ្គលណាប្រកាន់នូវទង្វើបែបនេះរមែងរងនូវការស្អប់ខ្ពើមពីសំណាក់មនុស្សជុំវិញខ្លួនព្រមទាំងនាំក្តីអន្តរាយមកឱ្យខ្លួនឯងទៀតផង ជាក់ស្តែងចៅកែផាន់ លោកបាឡាត់ស្រុកសង្កែ ត្រូវស្លាប់តែហោងដោយសារមូលហេតុនេះឯង។

# ឯកសារពិគ្រោះ


១- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨

២- បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ ល.ស.«ឃិន វ៉ាន់ថា»

៣- មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សទី១៩ លោក ឃីង ហុកឌី ឆ្នាំ២០០៣

៤- សិក្សាអក្សរសាស្ត្រខ្មែរបទុមត្ថេរសោមកវីសតវត្សរ៍ទី១៩ ទុំទាវ ឆ្នាំ១៩៧១ ដោយ គង់ សម្ភារ

៥- វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧

៦- រឿងកុលាបប៉ៃលិន និពន្ធដោយ លោក ញ៉ុក ថែម

៧- ប្រវត្តិសាស្ត្រខ្មែរ ភាគ១-២ (ត្រឹង ងា) សំរាប់មធ្យមសិក្សា និងឧត្តមសិក្សា ព.ស. ២៥១៧ គ.ស.១៩៧៣

៨- កំណាព្យខ្មែរ ដោយលោក លី សុមុនី ព.ស.២៥៤៦ គ.ស.២០០២

៩- ជីវប្រវត្តិអ្នកនិពន្ធខ្មែរ សាលាគរុវិជ្ជាជាន់ខ្ពស់ (២១ .០៧.១៩៨៦)

១០- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ ២០១១

១១- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១ បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយឆ្នាំ ២០១២

១២- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ដល់ថ្នាក់ទី៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង ដើមកំណើតទីក្រុងភ្នំពេញ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..............................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងដើមកំណើតក្រុងភ្នំពេញ»

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងដើមកំណើតទីក្រុងភ្នំពេញ » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានថែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការច្នៃបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ"**សិក្សាអត្ថបទអក្សរសិល្ប៍**" ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូនិងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិនិង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជាៈ

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ«**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង ដើមកំណើតទីក្រុងភ្នំពេញ**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោក អោ សៀម

៥- លោក យិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន

២- លោកស្រី ម៉ៅ តាន់ណារី

៣- លោក ព្រៃ សំបូរ

៤- លោក ងិន សុតារា

៥- លោក ប៉ែន សំភាស់

៦- លោកស្រី វ៉ាន់ សុភី

៧- លោក រ៉ិត សុខខេង

៨- លោកស្រី ផាន់ សុជាតា

១០- លោកស្រី សេង ពិសិដ្ឋនារី

១១- លោកស្រី បែន នាង

១២- លោក កួយ សូគាន

១៣- លោក អ៊ិត សុធា

១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារិទ្ធ

# មាតិកា

ទំព័រ

ប្រកាស ..........i

បុព្វកថា ..........ii

គណៈកម្មការ..........iii

អារម្ភកថា..........iv

មាតិកា..........v

សេចក្តីផ្តើម..........

I. ការបង្ហាញអត្ថបទ..........

II. ទិដ្ឋភាពទំនាកទំនងរឿង..........

III. ទិដ្ឋភាពទំនាស់..........

IV. ទិដ្ឋភាពវិភាគតួអង្គ..........

V. ទិដ្ឋភាពសង្គម..........

VI. ទិដ្ឋភាពតែងនិពន្ធ..........

VII. ទិដ្ឋភាពតម្លៃ..........

VIII. ការសន្និដ្ឋាន..........

IX. ឯកសារពិគ្រោះ..........

# សិក្សាអត្ថបទអក្សរសិល្ប៍

## រឿង ដើមកំណើតទីក្រុងភ្នំពេញ

### សេចក្តីផ្តើម

រឿងដើមកំណើតទីក្រុងភ្នំពេញជាប្រភេទរឿងព្រេងដែលបានដកស្រង់ចេញពីប្រជុំរឿងព្រេងខ្មែរភាគទី៥រៀបចំដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរ តាំងពីខែមករា ឆ្នាំ១៩៥៩មកម្ល៉េះ។

រឿងនេះត្រូវបានក្រសួងអប់រំ យុវជន និងកីឡាដាក់បញ្ចូលឱ្យសិក្សាជាការសិក្សាអត្ថបទអក្សរសិល្ប៍សម្រាប់ថ្នាក់ទី៧ ដោយសាររឿងនេះមានទាក់ទងទៅនឹងប្រវត្តិនៃការកកើតទឹកដីទីក្រុងភ្នំពេញ ដែលជាទីតាំងសំខាន់និងជាអតីតទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ គោលបំណងសំខាន់គឺដើម្បីឱ្យសិស្សានុសិស្សយល់ដឹងពីប្រវត្តិសាស្ត្រនៃទីកន្លែងកំណើតនិងជាស្នាដៃបុព្វបុរសខ្មែរ ដែលបានកសាងទុកជាកេរតំណែលមកដល់សព្វថ្ងៃ។ លើសពីនេះទៅទៀត គឺបណ្តុះស្មារតីជាតិនិយម ថែរក្សាការពារបូរណភាពទឹកដីនិងស្នាដៃនិពន្ធរបស់ដូនតាយើង។ ទន្ទឹមនឹងនេះ រឿងដើមកំណើតទីក្រុងភ្នំពេញ យើងក៏ឃើញមានឯកសារជាច្រើនទៀត ដែលពាក់ព័ន្ធនឹងការរៀបចំកសាង ឬស្ថាបនាទីក្រុងភ្នំពេញនេះជាច្រើនលើកច្រើនសាដូចជាមានបង្ហាញពីការស្ថាបនាទីក្រុងភ្នំពេញនេះ ក្រោយរជ្ជកាលព្រះបាទពញាយ៉ាតដូចបានដកស្រង់ពីរឿងក្រុងភ្នំពេញ(ទំព័រទី១៨)មានបញ្ជាក់ពីការស្ថាបនាទីក្រុងភ្នំពេញចំនួន២លើក និងកាលបរិច្ឆេទរឿងដូចខាងក្រោម៖

**ការស្ថាបនាព្រះរាជវាំងនៅទីក្រុងភ្នំពេញលើកទី១**

ព្រះរាជពង្សាវតារប្រទេសកម្ពុជាថែងថា ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់គ្រប់គ្រងព្រះរាជសម្បត្តិ គង់នៅក្នុងព្រះរាជវាំងមហានគរ(នគរធំ) បាន១៥ឆ្នាំ លុះមកដល់ឆ្នាំគម្រប់គ្រប់១៦ នៃរជ្ជកាលរបស់ព្រះអង្គទើបទ្រង់មានព្រះយោបល់ថា និងទ្រាំនៅក្នុងមហានគរនេះតទៅទៀតពុំបានក៏មានព្រះបញ្ជាឱ្យកសាងព្រះរាជវាំងថ្មី នៅទួលបាសាណក្នុងខេត្តស្រីសឈរ ដែលសព្វថ្ងៃហៅថា ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ នៅថ្ងៃ១៣រោច ខែមិគសិរ ឆ្នាំជូតចត្វាស័កព.ស.១៩៧៦ ច.ស ៧៩៤ គ.ស. ១៤៣២។

ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់ស្តេចយាងចាកមហានគរមួយ អន្លើដោយរាជាសេវកាមាត្រ នាហ្មឺនសព្វមុខមន្ត្រីជាដើមដោយព្រះទីនាំង តាមជល មាគ៌ាមក នុះថ្ងៃ១៥កើត ខែបុស្ស ឆ្នាំជូតចត្វាស័ក នុះស្តេចយាងមកដល់ទួលបាសាណស្តេចគង់នៅជាសុខសម្រាន្ត ក្នុងព្រះរាជវាំងបាសាណនោះបានត្រឹមតែ១ឆ្នាំ ប៉ុណ្ណោះ ដោយទឹកទន្លេចេះតែឡើងលិចទីនោះ ទើបព្រះអង្គមានព្រះរាជបញ្ជាឱ្យស្តេចចៅពញា កែ និងឧកញ៉ាហោរាធិបតី ខៀវព្រមដោយមន្ត្រីឯទៀតខ្លះផងដែលស្គាល់ទីដីមានជ័យភូមិ ឱ្យទៅពិនិត្យមើលទីដីនៅជិតភ្នំដូន

ពេញ យើញថាទីដីនៅទិសអាគ្នេយ៍ ភ្នំដូនពេញជ័យភូមិល្អ ព្រះអង្គក៏មានព្រះរាជបញ្ជាឱ្យកសាងព្រះរាជវាំងថ្មីនៅទីត្រង់នោះ។ នៅថ្ងៃ៩កើត ខែពិសាខ ឆ្នាំខាល ឆស័ក ព.ស. ១៩៧៨ ច.ស.៧៩៦ គ.ស.១៤៣៤ ព្រះបាទសម្ដេចព្រះបរមរាជា(ពញាយ៉ាត) ស្ដេចយាងចេញចាកព្រះរាជវាំង បាសាណថ្ងៃ១៥កើត ខែពិសាខ ចូលគង់វាំងថ្មីនាទិសអាគ្នេយ៍ភ្នំដូនពេញ។

នៅថ្ងៃ១១រោច ខែពិសាខ ឆ្នាំម្សាញ់ នព្វស័ក ព.ស. ១៩៨១ ច.ស.៧៩៩ គ.ស.១៤៣៧ ព្រះអង្គប្រទាននាមថ្មីនេះថា ក្រុងចតុមុខមង្គល។ ឯទន្លេ ៤មុខ ដែលគេធ្លាប់ហៅថា ទន្លេច្រាបឈាមមកយូរហើយនោះ ទ្រង់ប្រទានឈ្មោះថា ទន្លេចតុមុខបូព៌ាវិញ។ល។ ព្រះអង្គព្រះរាជបញ្ជាឱ្យឧកញ៉ាតេជោ ស្រីថៅហ្វាយស្រុកសំរោងជាអ្នកកាន់ការលើកដីចាក់លុបបំពេញទីក្រុងថ្មី ទាំងឱ្យយកដីចាក់បំពេញភ្នំដូនពេញឱ្យរីកធំខ្ពស់ឡើងទៀតផង។ ទីក្រហូងជ្រៅដែលកើតពីការជីកយកដីនោះធ្លាប់មានឈ្មោះថា បឹងតេជោរៀងមកគឺទីដីត្រង់ផ្សារថ្មីសព្វថ្ងៃនេះ ។ល។ ទ្រង់មានព្រះរាជបញ្ជាឱ្យឧកញ៉ាផ្លុង ថៅហ្វាយស្រុកបាទីកាន់ការជីកព្រែកមួយ នៅខាងត្បូងភ្នំដូនពេញដែលជាប់មានឈ្មោះថា ព្រែកឧកញ៉ាផ្លុង ហើយចំណេរកាលតមកហៅថា ព្រែកពាមផ្លុង គឺត្រង់កន្លែងសួនវែងសន្លឹម នៅខាងកើតព្រះសក្យមុនីចេតិយសព្វថ្ងៃនេះ។ល។

ព្រះបាទសម្ដេចព្រះបរមរាជា (ពញ៉ាយាត) ទ្រង់មានព្រះរាជបញ្ជាឱ្យកសាងវិហារលើទីដីខ្ពស់ដែលចាក់ថែមថ្មី ត្រង់កន្លែងវិហារចាស់របស់ដូនពេញ ឱ្យកសាង ព្រះចេតិយធំៗពីខាងក្រោយវិហារ។ល។ ទ្រង់បញ្ញត្តិឱ្យហៅវត្តភ្នំដូនពេញថា វត្តព្រះចេតិយ បពិត្រ ដូច្នេះវិញ (លុះចំណេរកាលតមក មហាជនបែរជាហៅវត្តនេះថា វត្តភ្នំដូនពេញ អ្នកខ្លះហៅថា វត្តភ្នំពេញ ឬថា វត្តភ្នំ ជាប់រៀងមក)។ ទ្រង់មានព្រះរាជបញ្ជាឱ្យកសាងវត្ត ៦ ដទៃទៀតគឺ ៖

១- វត្តកោះ នៅត្រង់ទិសខាងកើតឆៀងអាគ្នេយ៍ភ្នំដូនពេញ

២- វត្តលង្កា នៅទិសខាងកើតឆៀងឦសានភ្នំដូនពេញ

៣-វត្តព្រះពុទ្ធឃោសានៅត្រង់ទិសខាងត្បូងព្រែកចិនដំដែកនាទិសខាងជើងភ្នំដូនពេញ។

បានជាព្រះរាជទាននាមវត្តទាំង៣នេះដូច្នេះ ដើម្បីឱ្យសមនឹងដំណើររឿងដែលថាព្រះពុទ្ធឃោសាចារ្យទៅចម្លងគម្ពីរពីកោះលង្កា។

៤- វត្តពាមផ្លុង នៅត្រង់ទិសអាគ្នេយ៍ភ្នំដូនពេញ ជិតជាប់នឹងមាត់ព្រែកឧកញ៉ាផ្លុង ឆ្ងាយបន្តិចពីវត្តកោះ។ ព្រះពុទ្ធរូបអង្គធំដែលតម្កល់ក្នុងព្រះវិហារវត្តពាមផ្លុងនោះ មានព្រះនាមថា ព្រះស្រកាលេញ ព្រោះគេបិទមាសរំលេចមាន សណ្ឋានស្រដៀងនឹងស្រកាត្រីលេញ[១] ។

៥- វត្តឧណ្ណាលោម ដែលមាននាមនេះស្រេចយូរមកហើយជានាមនៃព្រះចេតិយ ដែលបញ្ចុះព្រះឧណ្ណាលោម(រោមប្រជុំចិញ្ចើម)នៃព្រះអស្សជិតត្ថេរ នៅចំកណ្ដាលព្រះចេតិយទាំង៥ខាងលិចវិហារវត្តឧណ្ណាលោមសព្វថ្ងៃនេះ។

៦- វត្តខ្ពបតាយ៉ង ដោយនាមតាម្នាក់ឈ្មោះយ៉ង ដែលជាអ្នកជីកខ្ពបលុះចំណេរកាលមកវត្តខ្ពបតាយ៉ងគឺ វត្តបុទុមវតីសព្វថ្ងៃនេះ។ បន្ទាប់ពីនោះមកព្រះបរមរាជា (ពញាយ៉ាត) ព្រះអង្គមានព្រះរាជបញ្ជាឱ្យជីកព្រែកមួយទៀតនៅ ទិសខាងត្បូងព្រះបរមរាជវាំង ហើយឱ្យលើក

កំពែងព័ទ្ធជុំវិញក្រុង។ ព្រៃកនៅខាងត្បូងនោះថា ព្រៃកតាកែវ នៅខាងលិចព្រែកនោះមានអូរមួយហៅថា អូគរ ។ មានព្រែកមួយនៅខាងជើងភ្នំហៅថា ព្រែកពុំពាយ ប៉ុន្តែ ដោយ ហេតុត្រង់នោះមានរោងចិនដំដែក ទើបព្រែកពុំពាយនោះក្លាយឈ្មោះទៅជាព្រែកចិនដំដែកវិញ។

នៅតាមមាត់ទន្លេ៤មុខ ព្រះរាជាទ្រង់មានព្រះរាជបញ្ជាឱ្យលើកដីជាកំពែង ដើម្បីការពារទឹកទន្លេកុំឱ្យឡើងលិចទីក្រុង។ ខាងក្នុងកំពែងទីក្រុងថ្មីនេះ ពួកអ្នករាជការ និងអ្នកស្រុកសង់ផ្ទះសំបែងបានតាមចិត្ត។ ឯភូមិភាគខាងលិចទីក្រុងសុទ្ធតែជាវាលស្រែ។

បួនឆ្នាំក្រោយមកព្រះនារាយណ៍រាជា ជាព្រះរាជបុត្រច្បងនៃព្រះបរមរាជា(ពញាយ៉ាត) បានត្រូវតាំងជាព្រះឧបរាជ ហើយទ្រង់ទៅសាងប្រាសាទគង់នៅឯជាយរលួស។ ក្នុងពេលជាមួយគ្នានោះ ព្រះស្រីរាជា ជារាជបុត្របន្ទាប់នៃព្រះបរមរាជា (ពញាយ៉ាត) ទ្រង់ ទៅគង់នៅទិសខាងលិចអូរគរ លើទួលមួយដែលជាប់នាមហៅថា ទួលព្រះស្រី នៅខាង ជើងវត្តព្រះពុទ្ធមានបុណ្យ ។

## ការស្ថាបនាព្រះរាជវាំងនៅទីក្រុងភ្នំពេញលើកទី ២

នៅថ្ងៃព្រហស្បតិ៍ ៤ កើត ខែបុស្ស ឆ្នាំឆ្លូវ សប្តស័ក ព.ស. ២៤០៩ ម.ស. ១៧៨៧ ច.ស .១២២៧ គ.ស.១៨៦៥(១) ម៉ោង៩ព្រឹក ព្រះបាទសម្តេចព្រះនរោត្តម បរមរាមទេវតា (ព្រះសុវណ្ណកោដ្ឋ) ស្តេចយាងចេញចាកព្រះបរមរាជវាំងស្រះសពើយុត្ត ក្រុងឧត្តុង្គមានជ័យ មកគង់ក្រុងភ្នំពេញចតុមុខនគរ។

ការកសាងក្រុងភ្នំពេញក្នុងរជ្ជកាល ព្រះករុណានរោត្តមនេះជាការសាងលើកទី ២ តពីទី១ ក្នុងរជ្ជកាលព្រះបរមរាជា (ពញាយ៉ាត) បានប្រកបដោយជោគជ័យសិរីមង្គល រុងរឿងចម្រើនឋិតថេរ រហូតមកដល់សម័យបច្ចុប្បន្ន។

ខាងក្រោមនេះគឺជាការសិក្សាអត្ថបទអក្សរសិល្ប៍រឿងដើមកំណើតទីក្រុងភ្នំពេញ តាមទម្រង់សិក្សាអត្ថបទសម្រាប់មធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ទី៨ និងទី៩៖

### I-ទិដ្ឋភាពប្រវត្តិ

**១-អត្ថបទ**

- ចំណងជើង : រឿងដើមកំណើតទីក្រុងភ្នំពេញ
- ប្រភព : ប្រទេសកម្ពុជា
- ប្រភេទ : រឿងដើមកំណើតទីក្រុងភ្នំពេញជាប្រភេទអក្សរសិល្ប៍ប្រជាប្រិយបែបរឿងព្រេងកថា។
- ចលនា : ខេមរនិយម

**២.អ្នកនិពន្ធ**

- ឈ្មោះអ្នកនិពន្ធ : ពុំស្គាល់ឈ្មោះព្រោះជាការនិយាយតគ្នាពីមាត់មួយទៅមាត់មួយរួចត្រូវបានចងក្រងជាសៀវភៅប្រជុំរឿងព្រេងភាគទី៥។

- ជីវប្រវត្តិ: គ្មាន
- ស្នាដៃសំខាន់ៗ: គ្មាន

**៣-កាលកំណត់តែង៖** រឿងនេះបានរៀបចំចងក្រងនិងបោះពុម្ពដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរពុទ្ធសាសនបណ្ឌិត្យថ្ងៃទី ១ ខែមករា ឆ្នាំ១៩៥៩។

**៤-សង្គមបរិយាកាស**

**ក-កាលប្រវត្តិ**: ដំណើររឿងប្រព្រឹត្តទៅក្រោមរបបគ្រប់គ្រងនៃរជ្ជកាលព្រះបរមរាជាពញាយ៉ាត ពុទ្ធសតវត្សទី២១ គ្រិះសតវត្សទី១៥ ។

**ខ- ព្រឹត្តិការណ៍សំខាន់ៗ**

ព្រឹត្តិការណ៍សំខាន់ៗមាន៖

១. មានទឹកជំនន់ទន្លេនាំដើមគគីរមួយធំអណ្ដែតវិលវល់ក្បែរមាត់ច្រាំង ដូនពេញ និងអ្នកជិតខាងនាំគ្នាចងអូសរំកិលដល់មាត់ច្រាំងដុសសម្អាតកោសកៀរឃើញព្រះពុទ្ធរូបបួនអង្គតូចៗ។

២. ដូនពេញនាំអ្នកជិតខាងលើកដីពូនភ្នំតម្កល់ទេវរូប។

## II- **ទិដ្ឋភាពទំនាក់ទំនងរឿង**

### **១- សង្ខេបរឿង**

មានរឿងដំណាលថា៖ ក្នុងកាលកន្លងទៅហើយ(គ.ស១៣៧២) មានយាយចាស់ម្នាក់ឈ្មោះពេញជាអ្នកមានភោគសម្បត្តិបរិបូណ៌មានទីលំនៅ នៅក្បែរមាត់ច្រាំងទន្លេបួនមុខ។ ផ្ទះគាត់សង់នៅលើទួលមួយខាងកើតភ្នំតូចមួយ។ ថ្ងៃមួយ ទីនោះមានភ្លៀងធ្លាក់ខ្លាំង ទឹកទន្លេជន់លិចរហាចរហឹមដូនពេញគាត់ចុះទៅកំពង់ទឹកស្រាប់តែឃើញដើមគគីរមួយធំ អណ្ដែតមកក្បែរច្រាំងហើយដោយអំណាចទឹកហូរសងចុះឡើង ដើមគគីរនោះចេះតែអណ្ដែតវិលវល់នៅក្បែរមាត់ច្រាំងនោះ។ លុះដូនពេញឃើញដូច្នោះ ក៏ប្រញាប់រត់ទៅអំពាវនាវហៅអ្នកជិតខាងឱ្យមកជួយទាញយកដើមគគីរនោះ។ អ្នកជិតខាងក៏នាំគ្នាយកពួរទៅចង ហើយអូសរំកិលបន្តិចម្ដងៗ ទាល់តែមកដល់មាត់ច្រាំង។ ពេលដូនពេញយកកំណាត់ឈើទៅកោសកៀរសម្អាតភក់ចេញគាត់បានឃើញប្រហោងឈើគគីនោះមានព្រះពុទ្ធរូបបួនអង្គតូចៗ ធ្វើអំពើ សំរិទ្ធ និងទេវរូបមួយអង្គទៀតធ្វើអំពីថ្ម ។ ទេវរូបនោះទ្រង់ឈរព្រះហស្តម្ខាងទ្រង់ដំបង ព្រះហស្តម្ខាងទៀតទ្រង់ស័ង្ខព្រះកេសាបួង។ ដូនពេញនិងអ្នកជិតខាងដែលទៅជួយមានសេចក្ដីត្រេកអរណាស់ដោយរើសបានរបស់ជាទីគោរព ក៏នាំគ្នាដង្ហែព្រះបដិមាទាំងនោះមកដល់ផ្ទះដូនពេញ ហើយដូនពេញចាត់ការសង់ខ្ទមមួយតូចតម្កល់ជាបណ្ដោះអាសន្ន។

ថ្ងៃក្រោយមក ដូនពេញអំពាវនាវឱ្យអ្នកជិតខាងជួយលើកដីពូនភ្នំដែលនៅខាងលិចផ្ទះគាត់នោះឱ្យទៅជាភ្នំមែនទែន ។ បន្ទាប់ពីនោះ គាត់ឱ្យគេអារឈើគគីរនោះធ្វើជាសសរវិហារដែលគាត់បម្រុងនឹងសង់លើភ្នំនោះ។ ក្នុងគ.ស១៣៧២ ដូនពេញ និងអ្នកស្រុកច្រើននាក់ស្រុះស្រួលបបួលគ្នា សង់វិហារមួយខ្ទងប្រក់ស្បូវភ្លាំងនៅលើកំពូលភ្នំនោះ។ ហើយគាត់ដង្ហែព្រះ

ពុទ្ធរូបសំរិទ្ធទាំង៤អង្គទៅតម្កល់ទុកក្នុងវិហារនោះ។ ចំណែកទេវរូបថ្ម១អង្គ គាត់ដង្ហែទៅតម្កល់ទុកលើអាសនៈមួយនៅជើងភ្នំខាងកើតហើយដែលគាត់យល់ថាទេវរូបនោះអណ្តែតទឹករសាត់មកពីស្រុកលាវនិងមានឧបែបបទដូចជាលាវ គាត់ក៏បានសន្មតថា « អ្នកតាព្រះចៅ » នាមនោះជាប់មកដល់សព្វថ្ងៃនេះ។

កាលសាងវិហារហើយគាត់ក៏និមន្តព្រះសង្ឃមកគង់នៅលើជើងភ្នំនោះក្នុងទិសខាងលិច ទើបកើតមានឈ្មោះថា "វត្តភ្នំដូនពេញ" ដែលសព្វថ្ងៃគេហៅកាត់ខ្លីថា « វត្តភ្នំ » តាំងពីពេលនោះមករហូតដល់សព្វថ្ងៃ។ ឯព្រះពុទ្ធរូបទាំង៤ព្រះអង្គ និងអ្នកតាព្រះចៅនោះបានបញ្ចេញមឥទ្ធិឫទ្ធិឱ្យឃើញពូកែសក្តិសិទ្ធិណាស់ អ្នកណាបន់ស្រន់ក៏បានសម្រេចបំណងពិត (នេះជាជំនឿរបស់អ្នកស្រុក)។

នេះហើយជាដើមកំណើតក្រុងភ្នំពេញដែលក្រោយពីនោះរវាង៦០ឆ្នាំបានកើតជាទីក្រុងរបស់ស្តេចខ្មែរយ៉ាងស្កុកស្តម្ភ។

**២- តួអង្គ**

១- ដូនពេញ ជាអ្នកមានភោគសម្បត្តិបរិបូណ៌ មានទីលំនៅ នៅក្បែរមាត់ច្រាំងទន្លេបួនមុខ និងជាអ្នកផ្តើមគំនិតសាងសង់កន្លែងសម្រាប់តម្កល់ព្រះពុទ្ធរូបសំរិទ្ធ៤អង្គព្រមទាំងទេវរូបថ្ម១អង្គ។

២- អ្នកជិតខាងជាអ្នករស់នៅក្នុងភូមិជាមួយដូនពេញនិងជាអ្នកជួយទាញយកដើមគគីរពីក្នុងទន្លេមកដាក់លើមាត់ច្រាំងនិងជាអ្នកលើកដីពូនជាភ្នំសម្រាប់តម្កល់ព្រះពុទ្ធរូប។

៣- អ្នកស្រុកជាអ្នកជួយសង់វិហារលើកំពូលភ្នំសម្រាប់តម្កល់ព្រះពុទ្ធរូបទាំង៤អង្គ។

៤- ព្រះសង្ឃ ជាអ្នកគង់នៅលើជើងភ្នំដែលសាងសង់វិហារ ឬភ្នំដូនពេញ ឬវត្តភ្នំ។

**៣. កាលអាកាស**

**ក.កាលឬពេលវេលានៃរឿង**

១-ក្នុងកាលកន្លងទៅហើយ(គ.ស១៣៧២)មានដូនចាស់ម្នាក់ឈ្មោះពេញជាអ្នកមានភោគសម្បត្តិបរិបូរណ៍មានទីលំនៅ នៅក្បែរមាត់ច្រាំងទន្លេបួនមុខ។

២-ថ្ងៃមួយ ទីនោះមានភ្លៀងធ្លាក់ខ្លាំងទឹកទន្លេជន់លិចរហាចរហើមបាក់ច្រាំងទន្លេ។

៣-ក្រោយមកដូនពេញអំពាវនាវឱ្យអ្នកជិតខាងជួយលើកដីពូនជាភ្នំដែលនៅខាងលិចផ្ទះគាត់ឱ្យទៅជាភ្នំមែនទែន។

៤-ក្នុងគ.ស១៣៧២ដូនពេញ និងអ្នកស្រុកច្រើននាក់ស្រុះស្រួលបបួលគ្នាសង់វិហារមួយខ្ទង់ប្រក់ស្បូវភ្លាំងនៅលើកំពូលភ្នំនោះទុកតម្កល់ព្រះពុទ្ធរូប៤អង្គ។

៥-សព្វថ្ងៃគេហៅកាត់ខ្លីថា "វត្តភ្នំ" តាំងពីពេលនោះមករហូតដល់សព្វថ្ងៃ។

៦-ក្រោយពីនោះរវាង ៦០ឆ្នាំបានកើតជាទីក្រុងរបស់ស្តេចខ្មែរយ៉ាងស្កុកស្តម្ភ។

**ខ-អាកាសឬទីកន្លែងរឿង**

១-ផ្ទះដូនពេញនៅក្បែរមាត់ច្រាំងទន្លេបួនមុខ។

២-នៅកំពង់ទឹកក្បែរមាត់ច្រាំងទន្លេបួនមុខ ដូនពេញនិងអ្នកជិតខាងអូសដើមគគីរឡើងច្រាំង...។

៣-ដូនពេញ និងអ្នកជិតខាងលើកដីពូនភ្នំដែលនៅខាងលិចផ្ទះគាត់...។

៤-ដូនពេញ និងអ្នកជិតខាងជួយដង្ហែបដិមាមកផ្ទះដូនពេញ និងតម្កល់ទុកក្នុងខ្ទមតូចមួយ។

៥-ដូនពេញ និងអ្នកជិតខាងសង់វិហារប្រក់ស្បូវភ្លាំងនៅលើកំពូលភ្នំ។

៦-ទេវរូបមួយអង្គតម្កល់លើអាសនៈនៅជើងភ្នំខាងកើត។

**IV-ទិដ្ឋភាពវិភាគតួអង្គ**

**១- ដូនពេញ**

**គុណសម្បត្តិ:**

-ជាអ្នកមានម្នាក់ដែលមានចិត្តស្រឡាញ់រាប់អានអ្នកជិតខាងដោយមិនប្រកាន់វណ្ណៈ

-មានគំនិតដឹកនាំអ្នកស្រុកយកដើមគគីរពីក្នុងទន្លេមកដាក់លើច្រាំងទន្លេ

-ជាពុទ្ធសាសនូបត្ថម្ភដែលរកកន្លែងតម្កល់ និងគោរពព្រះពុទ្ធសាសនាពេលឃើញព្រះពុទ្ធរូប និងទេវរូបក្នុងដើមគគីរដែលជាទីសក្ការៈ។

**គុណវិបត្តិ:**

មានមហិច្ឆតាចង់សម្រេចបំណងរបស់ខ្លួនក៏អំពាវនាវហៅរកអ្នកស្រុកឬអ្នកជិតខាងមកប្រើដោយគ្មានគិតពីការហត់នឿយរបស់អ្នកស្រុកឬអ្នកជិតខាងឡើយ។

**២- អ្នកជិតខាងឬអ្នកស្រុក**

**គុណសម្បត្តិ:**

-ស្រឡាញ់គោរពរាប់អានដូនពេញ

-មានគំនិតចេះសាមគ្គីគ្នាក្នុងការជួយដូនពេញអូសដើមគគីរពីក្នុងទន្លេមកដាក់លើច្រាំង

-ជួយលើកដីពូនភ្នំសង់ព្រះវិហារទុកតម្កល់ព្រះពុទ្ធរូប និងទេវរូប

-មានការសហការគ្នាល្អ រីករាយជួយធ្វើការជាមួយដូនពេញដោយគ្មានត្អូញត្អែរដោយមិនគិតពីការនឿយហត់។

**គុណវិបត្តិ:** គ្មាន

**V-ទិដ្ឋភាពសង្គម**

**ក-វប្បធម៌**

- **ជំនឿ:** ប្រជាជនខ្មែរសម័យនោះជឿលើបារមីវត្ថុស័ក្តិសិទ្ធិនិងអ្នកតាជាដើម។
ឧទាហរណ៍៖ « អ្នកតាព្រះថៅបានបញ្ចេញមហិទ្ធិឫទ្ធិឱ្យឃើញពូកែ...»។

- **សាសនា:** ក្នុងសិក្សាអត្ថបទរឿងដើមកំណើតទីក្រុងភ្នំពេញមានជំនឿលើព្រះពុទ្ធសាសនាដូចការគោរពព្រះពុទ្ធរូប និងទេវរូបទាំងបួនព្រះអង្គនិងអ្នកតាព្រះចៅគឺជាវត្ថុស័ក្តិសិទ្ធិមានមហិទ្ធិឫទ្ធិ ហើយបានកសាងព្រះវិហារតម្កល់ទុកជាទីសក្ការៈគោរពបូជាទៀតផង។ ឧទាហរណ៍: «កសាងវិហាររួចហើយ គាត់និមន្តព្រះសង្ឃ...»
- **ការសិក្សាអប់រំ:** ក្នុងដំណើររឿងពុំមានបញ្ជាក់ ប៉ុន្តែប្រជាជនមានការយល់ដឹងចេះសាមគ្គីគ្នាជួយគ្នាទៅវិញទៅមក។ ឧទាហរណ៍: « អ្នកជិតខាងក៏យកពួរទៅចងហើយ អូសរំកិល...»
- **សិល្បៈ** : រឿងដើមកំណើតទីក្រុងភ្នំពេញតាមដំណើររឿងឃើញមានការបង្ហាញពីសិល្បៈតិចតួចដូចជាការធ្វើសសរវិហារពីដើមគគីរដើម្បីកសាងសង់វិហារតម្កល់ទេវរូប ។ ឧទាហរណ៍: « ...គាត់ឱ្យគេអារឈើគគីរនោះធ្វើជាសសរវិហារ...»

**ខ-សេដ្ឋកិច្ច**

ក្នុងរឿងដើមកំណើតទីក្រុងភ្នំពេញតាមដំណើររឿងយើងមិនឃើញមានបង្ហាញពីកសិកម្ម ផលិតកម្ម ឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្មច្បាស់លាស់ទេ ប៉ុន្តែអ្នកនិពន្ធបានបង្ហាញថា ដូនពេញជាអ្នកមានភោគសម្បត្តិបរិបូណ៌ នេះបញ្ជាក់ថា គាត់ជាអ្នកមានសេដ្ឋកិច្ចល្អក្នុងភូមិ ។ ឧទាហរណ៍: « មានដូនចាស់ម្នាក់ឈ្មោះ ពេញ ជាអ្នកមានភោគសម្បត្តិបរិបូណ៌... »

**គ-សង្គមកិច្ច**

- ស្ថានភាពរស់នៅ: ការរស់នៅចុះសម្រុងគ្នា មានសាមគ្គីភាពល្អមិនប្រកាន់វណ្ណៈជួយគ្នាពេលមានទុក្ខធុរៈឧទាហរណ៍ដូចជាដូនពេញនិងអ្នកស្រុកអូសដើមគគីរនិងលើកដីពូនភ្នំសង់ព្រះវិហារតម្កល់ទេវរូប។
- មុខរបរ និងជីវភាពរបស់ប្រជាជន គ្មាន(ដំណើររឿងមិនបានបង្ហាញទេ)

**ឃ-នយោបាយ**

- **ក្នុងប្រទេស:** រឿងដើមកំណើតទីក្រុងភ្នំពេញយើងមិនឃើញមានបង្ហាញផ្នែកនយោបាយទេ តែយើងឃើញមានរបបគ្រប់គ្រងដែលពឹងពាក់ទៅលើអ្នកមានឥទ្ធិពលនៅក្នុងសង្គម អ្នកមានឥទ្ធិពលអាចមានលទ្ធភាពប្រមូលប្រជាជនផ្តើមគំនិតកសាងសំណង់សាធារណៈឬធ្វើកិច្ចការសាធារណៈទាំងឡាយជំនួសអ្នកដឹកនាំនយោបាយបាន នៅក្នុងរឿងបង្ហាញថាដូនពេញគឺជាស្ត្រីម្នាក់តាងឱ្យអ្នកមានឥទ្ធិពលទាំងឡាយនៅក្នុងសម័យនោះ។ យើងសង្កេត ឃើញថា ការផ្តួចផ្តើមរបស់អ្នកមានឥទ្ធិពលទាំងនោះគឺបានចូលរួមពីឥទ្ធិពលជំនឿសាសនា ដោយហេតុនេះហើយទើបដូនពេញអាចប្រមូលបាននូវមនុស្សយ៉ាងច្រើនលើកដីពូនភ្នំកសាងព្រះវិហារដែលជាសំណង់សាធារណៈសម្រាប់ប្រើជាប្រយោជន៍ នៃមនុស្សទូទៅ។ ពោលគឺគាត់ដើរជាអ្នកនយោបាយក្នុងសម័យបច្ចុប្បន្ន។

- ក្រៅប្រទេសនិងទំនាក់ទំនងអន្តរជាតិ: តាមដំណើររឿងមិនឃើញមានបង្ហាញ ទេ (គ្មាន)

### VI-ទិដ្ឋភាពតែងនិពន្ធ

### ក.ផ្តើមរឿង

- អ្នកនិពន្ធបានបង្ហាញដោយប្រើឃ្លា "មានរឿងដំណើរថា...."

-បង្ហាញតួអង្គយាយពេញ"ក្នុងកាលកន្លងទៅហើយ(គ.ស.១៣៧២)មានដូនចាស់ម្នាក់ឈ្មោះពេញ..." រួចភ្ជាប់ទៅនឹងសកម្មភាពក្នុងដំណើររឿងតែម្តង។

### ខ.តួរឿង

**១.ទម្រង់សំណេរ:** រឿងដើមកំណើតទីក្រុងភ្នំពេញសរសេរជាពាក្យរាយ ងាយអានងាយយល់។

**២.បច្ចេកកទេសក្នុងការតាក់តែង៖**

- ***ភាសា:*** អ្នកនិពន្ធប្រើភាសាសាមញ្ញលាយចម្រុះ និងបាលីសំស្រ្កឹតព្រមទាំងរាជសព្ទ និងសង្ឃសព្ទផងដែរ ឧទាហរណ៍៖
  - ភាសាមញ្ញ : នៅ ក្បែរ មាត់ ច្រាំង ទន្លេ...
  - បាលីសំស្ក្រឹត : សម្បត្តិ ឥទ្ធិឫទ្ធិ ស័ក្តិសិទ្ធិ ស័ង្ឃ វត្ត...
  - រាជសព្ទ : ព្រះកេសា ព្រះហស្ថ...
  - សង្ឃសព្ទ : និមន្ត គង់ ព្រះសង្ឃ ព្រះបដិមា...
- **ទំហៀបន័យ :** ឧទាហរណ៍: មាឧបែបភាពដូចលាវ។
- **ភាពច្បាស់លាស់ :** ឧទាហរណ៍: ភ្នំតូចមួយ ដើមគគីរមួយធំ...
- **ការនិទាន :** ការនិទានរបស់អ្នកនិពន្ធគឺ និទានបែបបុរសទី៣

### គ.ការបញ្ចប់រឿង

ការបញ្ចប់រឿង(គ្មាន)មិនបានបង្ហាញពីការជួប ឬព្រាត់របស់តួអង្គនោះទេព្រោះដំណើរ រឿងបង្ហាញតែពីការកកើតទីក្រុងភ្នំពេញហើយបញ្ចប់រឿងគឺបានសង់វិហារជាទីតម្កល់ព្រះពុទ្ធរូប និងព្រះថៅទេវរបស់រិទ្ធបានសម្រេច ដោយបញ្ជាក់ថាទីនេះហេតុអ្វីបានជាមានឈ្មោះថាទីក្រុងភ្នំពេញ។

### VII-ទិដ្ឋភាពតម្លៃ

រឿងដើមកំណើតទីក្រុងភ្នំពេញដំណើររឿងបានបង្ហាញពីតម្លៃលេចធ្លោនៅក្នុងដំណើររឿងដើមកំណើតទីក្រុងភ្នំពេញគ្រង់ដូនពេញ និងអ្នកស្រុកស្រឡាញ់ទឹកដីនិងថែរក្សាកេរតំណែលដូនតាបានសាមគ្គីគ្នាពូនដីធ្វើជាភ្នំសង់ព្រះវិហារតម្កល់ព្រះពុទ្ធរូបនិងទេវ

របស់រឹទ្ធិនេះគឺជាទិដ្ឋភាពពិតនៅក្នុងសង្គមខ្មែរដែលមានជំនឿលើការគោរពបូជាពុទ្ធសាសនា។

## VIII-ការសន្និដ្ឋាន

សរុបមកក្រោយពីការសិក្សារឿងដើមកំណើតទីក្រុងភ្នំពេញចប់យើងឃើញថា រឿងទាំងមូល បានបង្ហាញពី "គំនិតសាមគ្គី សហការគ្នាល្អក្នុងសង្គម" ។ ពិសេសចង់អប់រំមនុស្សឱ្យមានសាមគ្គីភាព ឯកភាពជាតិ ចេះស្រឡាញ់ និងជួយគ្នាក្នុងគ្រាមានទុក្ខធុរៈដោយមិនប្រកាន់ឋានៈ។

# «សាមគ្គីពិតជាមានជ័យជំនះ»

ឯកសារពិគ្រោះ

១. វចនានុក្រមសម្ដេចជួន ណាត

២.ប្រជុំរឿងព្រេងភាគទី៥

៣. ឯកសារមហាបុរសខ្មែរភាគទី១

## រឿង ក្រុងភ្នំពេញ

ទីក្រុងភ្នំពេញបានចាប់ផ្ដើមស្ថាបនាលើកដំបូងបង្អស់នៅពុទ្ធសតវត្សរ៍ទី២១ គ្រិស្តសតវត្សរ៍ទី១៥ ក្នុងរជ្ជកាលព្រះបរមរាជា (ពញាយ៉ាត) គឺព្រះស្រីសុរិយោពណ៌ នៅពេលដែលទ្រង់បោះបង់ចោលព្រះរាជវាំងអង្គរ មកកសាងព្រះរាជវាំងថ្មីនៅទួលបាសាណ ក្នុងខែត្រស្រីសឈរសព្វថ្ងៃហៅថា ស្រុកស្រីសន្ធរក្នុងខែត្រកំពង់ចាម ប៉ុន្តែដោយទីទួលបាសាណនោះ ក្នុងរដូវភ្លៀងមានទឹកលិចរាល់ឆ្នាំ ទ្រង់សាងប្រាសាទព្រះរាជវាំង ហើយគង់នៅបានតែមួយឆ្នាំ ក៏ទ្រង់ស្ដេចយាងមកកសាងទីក្រុងថ្មីនៅឆ្នេរទន្លេបួនមុខ គឺក្រុងភ្នំពេញសព្វថ្ងៃនេះនៅគ.ស. ១៤៣៤។

ការស្ថាបនាព្រះរាជវាំង នៅទីក្រុងភ្នំពេញមានពីរលើកៈ

- លើកទី១ នៅគ្រិស្តសតវត្សរ៍ទី១៥ រជ្ជកាលព្រះបាទពញាយ៉ាតតែមិនឋិតថេរ។
- លើកទី២ នៅគ្រឹសសតវត្សរ៍១៩ រជ្ជកាលព្រះបាទនរោត្តមទើបឋិតថេរ។

បានជាការស្ថាបនាព្រះរាជវាំងនៅទៅក្នុងភ្នំពេញមាន២លើកព្រោះ ក្រោយពីការស្ថាបនាលើកទី១ពី គ.ស.១៣៤៤ ដល់១៤៩៧ នោះព្រះរាជវាំងបានទៅស្ថាបនាអង្គរវិញ... ក្រោយពីអង្គរ ទៅពោធិសាត់ ទៅបរិបូណ៌ ទៅលង្វែក ទៅឧត្តុង្គ ហើយក្រោយពីឧត្តុង្គព្រះរាជវាំង ត្រឡប់មកស្ថាបនានៅទីក្រុងភ្នំពេញវិញជាលើកទី២ នៅគ.ស.១៨៦៥ ទើបបានឋិតថេរ ដល់សព្វថ្ងៃ។

## រឿងដើមកំណើតទីក្រុងភ្នំពេញ

ភ្នំដែលសន្មតជានាមទីក្រុងរបស់ខ្មែរ គឺទីក្រុងភ្នំពេញសព្វថ្ងៃ កើតមានតាំងពីមុនពេលស្ថាបនាព្រះរាជវាំង ដោយមានរឿងដំណាលថា៖ ក្នុងកាលកន្លងទៅហើយ (គ.ស.១៣៧២) មានយាយចាស់ម្នាក់ឈ្មោះ(ពេញ)ជាអ្នកមានភោគសម្បត្តិបរិបូណ៌ មានទីលំនៅ នៅក្បែរមាត់ច្រាំងទន្លេបួនមុខ។ ផ្ទះគាត់សង់នៅលើទីទួលមួយ ខាងកើត ភ្នំតូចមួយ។ ថ្ងៃមួយទីនោះមានភ្លៀងធ្លាក់ខ្លាំង ទឹកទន្លេជន់លិចរហាចរហឹម ដូនពេញ គាត់ចុះទៅកំពង់ទឹកស្រាប់តែឃើញដើមគគីរមួយធំ អណ្តែតមកក្បែរច្រាំង ហើយដោយអំណាចទឹកហូរសងចុះឡើង ដើមគគីរនោះចេះតែអណ្តែតវិលវល់នៅក្បែរមាត់ ច្រាំងនោះ។ លុះដូនពេញឃើញដូច្នោះ ក៏ប្រញាប់រត់ទៅអំពាវនាវ ហៅអ្នកជិតខាងឱ្យ មកជួយទាញយកដើមគគីរនោះ។ អ្នកជិតខាងក៏នាំគ្នាយកពួរទៅចងហើយអូសរំកិល បន្តិចម្តងៗទាល់តែមកដល់លើមាត់ច្រាំង។ ពេលដែលដូនពេញយកកំណាត់ឈើទៅ កោសកៀរសំអាតភក់ចេញគាត់បានឃើញក្នុងប្រហោងឈើគគីរនោះមានព្រះពុទ្ធរូប ៤អង្គតូចៗធ្វើអំពីសំរិទ្ធិនិងទេវរូប១អង្គទៀតធ្វើអំពីថ្ម ទេវរូបនោះទ្រង់ឈរ ព្រះហស្តម្ខាង ទ្រង់ដំបង ព្រះហស្តខាងទៀតទ្រង់ស័ង្ខ ព្រះកេសាបួង។ ដូនពេញ និងអ្នកជិតខាងដែលទៅជាមួយមានសេចក្តីត្រេកអរណាស់ ដោយរើសបានរបស់ជាទីគោរព ក៏នាំគ្នាដង្ហែព្រះបដិមាទាំងនោះមកដល់ផ្ទះដូនពេញ ហើយដូនពេញចាត់ការសង់ខ្ទមមួយតូច តម្កល់ជាបណ្តោះអាសន្ន។ ថ្ងៃក្រោយមកដូនពេញអំពាវនាវឱ្យអ្នកជិតខាង ជួយលើកដី ពូនភ្នំដែលនៅខាងលិចផ្ទះគាត់នោះ ឱ្យទៅជាភ្នំមែនទែន។ បន្ទាប់ពីនោះគាត់ឱ្យគេអារ ឈើគគីរនោះធ្វើជាសសរវិហារ ដែលគាត់បម្រុងនឹងសង់លើភ្នំនោះ។ ក្នុងគ.ស.១៣៧២ ដូនពេញ និងអ្នកស្រុកច្រើននាក់ ស្រុះស្រួលបបួលគ្នាសង់វិហារមួយខ្ទងប្រក់ ស្បូវភ្លាំង នៅលើកំពូលភ្នំនោះ ហើយគាត់ដង្ហែព្រះពុទ្ធរូបសំរិទ្ធទាំង៤អង្គទៅតម្កល់ទុកក្នុងវិហារនោះ។ ចំណែកទេវរូបថ្ម១អង្គ គាត់ដង្ហែទៅតម្កល់ទុកលើអាសនៈមួយនៅ ជើងភ្នំខាងកើត ហើយដោយគាត់យល់ថាទេវ

រូបនោះអណ្តែតទឹករសាត់មកពីស្រុកលាវនិងមានឧបែបភាពដូចជាលាវគាត់ក៏បានសន្មថា« អ្នកតាព្រះចៅ »។ នាមនោះជាប់ មកដល់សព្វថ្ងៃនេះ។

កាលសាងវិហាររួចហើយ គាត់និមន្តព្រះសង្ឃមកគង់នៅលើជើងភ្នំនោះក្នុងទិសខាងលិច ទើបកើតមានឈ្មោះថា « វត្តភ្នំដូនពេញ » ដែលសព្វថ្ងៃហៅកាត់ខ្លីថា « វត្តភ្នំ » តាំងពីពេលនោះមករហូតដល់សព្វថ្ងៃ ។ ឯព្រះពុទ្ធរូបទាំង៤ ព្រះអង្គ និងអ្នកតា ព្រះចៅនោះបានបញ្ចេញឥទ្ធិឫទ្ធិឱ្យឃើញពូកែសក្តិសិទ្ធិណាស់ អ្នកណាបន់ស្រន់ក៏បានសម្រេចបំណងពិត (នេះជាជំនឿរបស់អ្នកស្រុក)។

នេះហើយជាដើមកំណើតក្រុងភ្នំពេញ ដែលក្រោយពីនោះរវាង ៦០ឆ្នាំ បានកើត ជាទីក្រុងរបស់ស្តេចខ្មែរយ៉ាងស្កុកស្តម្ភ។

## ការស្ថាបនាព្រះរាជវាំងនៅទីក្រុងភ្នំពេញលើកទី១

ព្រះរាជពង្សាវតារប្រទេសកម្ពុជាចែងថា ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់គ្រប់គ្រងព្រះរាជសម្បត្តិ គង់នៅក្នុងព្រះរាជវាំងមហានគរ(នគរធំ) បាន១៥ឆ្នាំ លុះមកដល់ឆ្នាំគម្រប់គ្រប់១៦ នៃរជ្ជកាលរបស់ព្រះអង្គទើបទ្រង់មានព្រះយោបល់ថា និងទ្រាំនៅក្នុងមហានគរនេះតទៅទៀតពុំបាន ក៏មានព្រះបញ្ជាឱ្យកសាងព្រះរាជវាំងថ្មី នៅទួលបាសាណក្នុងខែត្រស្រីសឈរ ដែលសព្វថ្ងៃហៅថា ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម។ នៅថ្ងៃទី ១៣រោជ ខែមិគសិរ ឆ្នាំជូតចត្វាស័កព.ស.១៩៧៦ ច.ស ៧៩៤ គ.ស. ១៤៣២។

ព្រះបាទសម្តេចព្រះបរមរាជា (ពញាយ៉ាត) ទ្រង់ស្តេចយាងចាកមហានគរមួយ អន្លើដោយរាជាសេវកាមាត្រ នាហ្មឺនសព្វមុខមន្ត្រីជាដើមដោយព្រះទីនាំង តាមជល មាគ៌ាមក លុះថ្ងៃទី១៥កើត ខែបុស្ស ឆ្នាំជូតចត្វាស័ក នុះស្តេចយាងមកដល់ទួលបាសាណស្តេចគង់នៅជាសុខសម្រាន្ត ក្នុងព្រះរាជវាំងបាសាណនោះបានត្រឹមតែជាង១ឆ្នាំប៉ុណ្ណោះ ដោយទឹកទន្លេចេះតែឡើង ទីនោះលិចរាល់ឆ្នាំ ទើបព្រះអង្គមានព្រះរាជបញ្ជាឱ្យស្តេចចៅពញា កែ និងឧកញ៉ាហោរាធិបតីខៀវ ព្រមដោយមន្ត្រីឯទៀតខ្លះផងដែលស្គាល់ទីដីមានជយភូមិ ឱ្យទៅពិនិត្យមើលទីដីនៅជិតភ្នំដូនពេញ ឃើញថាទីដីនៅទិសអាគ្នេយ៍ ភ្នំដូនពេញជយភូមិល្អ ព្រះអង្គក៏មានព្រះរាជបញ្ជាឱ្យកសាងព្រះរាជវាំងថ្មីនៅទីត្រង់នោះ។ នៅថ្ងៃទី៩កើត ខែពិសាខ ឆ្នាំខាល ឆស័ក ព.ស. ១៩៧៨ ច.ស.៧៩៦ គ.ស.១៤៣៤ ព្រះបាទសម្តេចព្រះបរមរាជា(ពញាយ៉ាត) ស្តេចយាងចេញចាកព្រះរាជវាំង បាសាណថ្ងៃ ១៥ កើត ខែពិសាខ ចូលគង់វាំងថ្មីនាទិសអាគ្នេយ៍ភ្នំដូនពេញ។ នៅថ្ងៃទី១១រោច ខែពិសាខ ឆ្នាំម្សាញ់ នពស័ក ព.ស. ១៩៨១ ច.ស.៧៩៩ គ.ស .១៤៣៧ ព្រះអង្គប្រទាននាមក្រុងថ្មីនេះថា ក្រុងចតុមុខមង្គល។ ឯទន្លេ៤មុខ ដែលគេធ្លាប់ហៅថា ទន្លេច្រាបឈាមមកយូរហើយនោះ ទ្រង់ប្រទានឈ្មោះថា ទន្លេចតុមុខបូព៌ាវិញ។ល។ ព្រះអង្គព្រះរាជបញ្ជាឱ្យឧកញ៉ាតេជោ ស្រីចៅហ្វាយស្រុកសំរោងជាអ្នកកាន់ការលើកដីចាក់លុបបំពេញទីក្រុងថ្មី ទាំងឱ្យយកដីចាក់បំពេញភ្នំដូនពេញឱ្យរីកធំខ្ពស់ឡើងទៀតផង។ ទីក្រហូងជ្រៅដែលកើតពីការជីកយកដីនោះធ្លាប់មានឈ្មោះថា បឹងតេជោរៀងមកគឺទីដីត្រង់ផ្សារថ្មីសព្វ

ថ្ងៃនេះ ។ល។ ទ្រង់មានព្រះរាជបញ្ជាឱ្យឧកញ៉ាផ្លុង ចៅហ្វាយស្រុកបាទីកាន់ការជីកព្រែកមួយនៅខាងត្បូងភ្នំដូនពេញដែលជាប់មានឈ្មោះថា ព្រែកឧកញ៉ផ្លុង ហើយចំណេរកាលតមកហៅថា ព្រែកពាមផ្លុង គឺត្រង់កន្លែងសួនវែងសន្លឹម នៅខាងកើតព្រះសក្យមុនីចេតិយសព្វថ្ងៃនេះ។ល។

ព្រះបាទសម្តេចព្រះបរមរាជា (ពញ៉ាយាត) ទ្រង់មានព្រះរាជបញ្ជាឱ្យកសាងវិហារលើទីដីខ្ពស់ដែលចាក់ថែមថ្មី ត្រង់កន្លែងវិហារចាស់របស់ដូនពេញ ឱ្យកសាង ព្រះចេតិយធំៗពីខាងក្រោយវិហារ។ល។ ទ្រង់បញ្ញត្តិឱ្យហៅវត្តភ្នំដូនពេញថា វត្តព្រះចេតិយ បពិត ដូច្នេះវិញ (លុះចំណេលកាលតមក មហាជនបែរជាហៅវត្តនេះថា វត្តភ្នំដូនពេញ អ្នកខ្លះហៅថា វត្តភ្នំពេញ ឬថា វត្តភ្នំ ជាប់រៀងមក)។ ទ្រង់មានព្រះរាជបញ្ជាឱ្យកសាងវត្ត៦ ដទៃទៀតគឺ ៖

១- វត្តកោះ នៅត្រង់ទិសខាងកើតឆៀងអាគ្នេយ៍ភ្នំដូនពេញ

២-វត្តលង្កា នៅទិសខាងកើតឆៀងឦសានភ្នំដូនពេញ

៣- វត្តព្រះពុទ្ធឃោសា នៅត្រង់ទិសខាងត្បូងព្រែកចិនដំដែក នាទិសខាងជើង ភ្នំដូនពេញ។

បានជាព្រះរាជទាននាមវត្តទាំង៣នេះដូច្នេះ ដើម្បីឱ្យសមនឹងដំណើររឿងដែលថាព្រះពុទ្ធឃោសាចារ្យទៅចម្លងគម្ពីរពីកោះលង្កា។

៤- វត្តពាមផ្លុង នៅត្រង់ទិសអាគ្នេយ៍ភ្នំដូនពេញ ជិតជាប់នឹងមាត់ព្រែកឧកញ៉ា ផ្លុងឆ្ងាយបន្តិចពីវត្តកោះ។ ព្រះពុទ្ធរូបអង្គធំដែលតម្កល់ក្នុងព្រះវិហារវត្តពាមផ្លុងនោះ មានព្រះនាមថា ព្រះស្រកាលេញ ព្រោះគេបិទមាសរំលេចមាន សណ្ឋានស្រដៀងនឹងស្រកាត្រីលេញ ។

៥- វត្តឧណ្ណាលោម ដែលមាននាមនេះស្រេចយូរមកហើយជានាមនៃព្រះចេតិយ ដែលបញ្ចុះព្រះឧណ្ណាលោម(រោមប្រជុំចិញ្ចើម)នៃព្រះអស្សជិតត្ថេរ នៅចំកណ្តាលព្រះចេតិយទាំង៥ ខាងលិចវិហារវត្តឧណ្ណាលោមសព្វថ្ងៃនេះ។

៦- វត្តខ្ពមតាយ៉ង ដោយនាមតាម្នាក់ឈ្មោះយ៉ង ដែលជាអ្នកជីកខ្ពបលុះចំណេះ កាលមក វត្តខ្ពមតាយ៉ងគឺ វត្តបុទុមវតីសព្វថ្ងៃនេះ។ បន្ទាប់ពីនោះព្រះបរមរាជា (ពញាយ៉ាត) ព្រះអង្គមានព្រះរាជបញ្ជាឱ្យជីកព្រែកមួយទៀតនៅ ទិសខាងត្បូងព្រះបរមរាជវាំង ហើយឱ្យលើកកំពែងព័ទ្ធជុំវិញក្រុង។ ព្រែក នៅខាងត្បូងនោះថា ព្រែកតាកែវ នៅខាងលិចព្រែកនោះមានអូរមួយហៅថា អូរគរ ។ មានព្រែកមួយនៅខាងជើងភ្នំហៅថា ព្រែកពុំពាយ ប៉ុន្តែ ដោយ ហេតុត្រង់នោះមានរោងចិនដំដែក ទើបព្រែកពុំពាយនោះក្លាយឈ្មោះទៅជាព្រែកចិនដំដែកវិញ។

នៅតាមមាត់ទន្លេ៤មុខ ព្រះរាជាទ្រង់មានព្រះរាជបញ្ជាឱ្យលើកដីជាកំពែង ដើម្បីការពារទឹកទន្លេកុំឱ្យឡើងលិចទីក្រុង។ ខាងក្នុងកំពែងទីក្រុងថ្មីនេះ ពួកអ្នករាជការ និងអ្នកស្រុកសង់ផ្ទះសំបែងបានតាមចិត្ត។ ឯភូមិភាគខាងលិចទីក្រុងសុទ្ធតែជាវាលស្រែ។

បួនឆ្នាំក្រោយមកព្រះនារាយណ៍រាជា ជាព្រះរាជបុត្រច្បងនៃព្រះបរមរាជា(ពញាយ៉ាត) បានត្រូវតាំងជាព្រះឧបរាជ ហើយទ្រង់ទៅសាងប្រសាទគង់នៅឯជាយរលួស។ ក្នុងពេល

ជាមួយគ្នានោះ ព្រះស្រីរាជា ជារាជបុត្របន្ទាប់នៃព្រះបរមរាជា (ពញាយ៉ាត) ទ្រង់ ទៅគង់នៅ ទិសខាងលិចអូរគរ លើទួលមួយដែលជាប់នាមហៅថា ទួលព្រះស្រី នៅខាង ជើងវត្តព្រះពុទ្ធមានបុណ្យ ។

## ការស្ដាបនាព្រះរាជវាំងនៅទីក្រុងភ្នំពេញលើកទី ២

នៅថ្ងៃព្រហស្បត៍ ៤ កើត ខែបុស្ស ឆ្នាំឆ្លូវ សប្តស័ក ព.ស. ២៤០៩ ម.ស. ១៧៨៧ ច.ស.១២២៧ គ.ស.១៨៦៥១ ម៉ោង ៩ ព្រឹក ព្រះបាទសម្ដេចព្រះនរោត្តម បរមរាមទេវតា (ព្រះសុវណ្ណកោដ្ឋ) ស្ដេចយាងចេញចាកព្រះបរមរាជវាំងស្រះសពើយុត្ត ក្រុងឧដុង្គមានជ័យ មកគង់ក្រុងភ្នំពេញចតុមុខនគរ។

ការកសាងក្រុងភ្នំពេញក្នុងរជ្ជកាល ព្រះករុណានរោត្តមនេះជាការសាងលើកទី ២ តពីទី១ ក្នុងរជ្ជកាលព្រះបរមរាជា (ពញាយ៉ាត) បានប្រកបដោយជោគជ័យសិរីមង្គលរុងរឿង ចម្រើន បិតថេរ រហូតមកដល់សម័យបច្ចុប្បន្ន៕

ដកស្រង់ពីរឿងក្រុងភ្នំពេញ៖

- ការស្ថាបនាព្រះរាជវាំងនៅទីក្រុងភ្នំពេញលើកទី១ នៅទួលបាសាណក្នុងខេត្តស្រីសឈរក្នុងខេត្តកំពង់ចាម។ព្រះបាទសម្តេចព្រះបរមរាជាពញាយ៉ាតទ្រង់យាងចាកចេញពីមហានគរ។ថ្ងៃ១៥កើតខែបុស្សឆ្នាំជូតចត្វាស័កព្រះបាទសម្តេច ព្រះបរមរាជាពញាយ៉ាតយាងដល់រាជវាំងទួលបាសាណ។

នៅថ្ងៃទី៩កើតខែពិសាខឆ្នាំខាល ឆស័ក ព.ស១៩៧៨ ច.ឆ.៧៩៦ គ.ស១៤៣៤ ព្រះបាទសម្តេចព្រះបរមរាជា(ពញាយ៉ាត)ស្តេចយាងចេញចាកព្រះរាជវាំងបាសាណ ថ្ងៃ១កើតខែពិសាខ ចូលគង់រាជវាំងថ្មីនាទិសអាគ្នេយ៍ភ្នំដូនពេញ។

នៅថ្ងៃ១១រោច ខែពិសាខ ឆ្នាំម្សាញ់ នពស័ក ព.ស.១៩៨១ ច.ស.៧៩៩ គ.ស.១៤៣៧ព្រះអង្គប្រទាននាមថ្មីនេះថា ក្រុងចតុមុខមង្គលឯទន្លេបួនមុខដែលគេធ្លាប់ហៅថា ទន្លេច្រាបឈាមយូរហើយនោះ ទ្រង់ប្រទានឈ្មោះថា ទន្លេចតុមុខបូព៌ាវិញ

- ការកសាងព្រះរាជវាំងនៅទីក្រុងភ្នំពេញលើកទី២ នៅថ្ងៃព្រហស្បត៍ទី ៩កើត ខែ បុស្សឆ្លូវសប្តស័ក ព.ស.២៤០៩ ម.ស.១៧៨៧ ច.ស.១២២៧ គ.ស.១៨៦៥ ម៉ោង ៩ព្រឹក ព្រះបាទសម្តេចព្រះនរោត្តម បរមរាមទេវតា(ព្រះសុវណ្ណកោដ្ឋ) ស្តេចយាងចេញ ចាកព្រះបរមរាជវាំងស្រះសរពើយុត្ត ក្រុងឧត្តុង្គមានជ័យមកគង់ក្រុងភ្នំពេញចតុមុខនគរ។

ខាងក្រោមនេះគឺជា ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងដើមកំណើតទីក្រុងភ្នំពេញ៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង គេហោយ៉ត

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..................................អយក.**

**ប្រកាស**
**ស្តីពី**
**ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ**
**សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍**
**«រឿងគេជោយ៉ត»**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងគេជោយ៉ត » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការច្នៃបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

# **អារម្ភកថា**

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ«**សិក្សាអត្ថបទអក្សរសិល្ប៍**» ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ «**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង តេជោយ៉ត**» នេះ មានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្រ្តខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោក អោ សៀម

៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន

២- លោកស្រី ម៉ៅ គាន់ណារី

៣- លោក ព្រៃ សំបូរ

៤- លោក ងិន សុតារា

៥- លោក ប៉ែន សំភាស់

៦- លោកស្រី វ៉ាន់ សុភី

៧- លោក រ៉ិត សុខខេង

៨- លោកស្រី ផាន់ សុជាតា

១០- លោកស្រី សេង ពិសិដ្ឋនារី

១១- លោកស្រី បែន នាង

១២- លោក ក្លួយ សូគាន

១៣- លោក អ៊ិត សុធា

១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ


ប្រកាស ..................................................................................................................i
បុព្វកថា ..................................................................................................................ii
គណៈកម្មការ..........................................................................................................iii
អារម្ភកថា................................................................................................................iv
មាតិកា......................................................................................................................v
សេចក្តីផ្តើម..............................................................................................................
I. ការបង្ហាញអត្ថបទ.................................................................................................
II. ទិដ្ឋភាពទំនាក់ទំនងរឿង......................................................................................
III. ទិដ្ឋភាពទំនាស់...................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ............................................................................................
V. ទិដ្ឋភាពសង្គម......................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ.............................................................................................
VII. ទិដ្ឋភាពតម្លៃ......................................................................................................
VIII. ការសន្និដ្ឋាន....................................................................................................
IX. ឯកសារពិគ្រោះ.................................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

# រឿងតេជោយ៉ត

## សេចក្តីផ្តើម

រឿង តេជោយ៉ត ជាប្រភេទរឿងល្ខោនបាសាក់មួយជាទីពេញនិយម ក្នុងចំណោមស្នាដៃរឿងល្ខោន អាយ៉ៃ និងយីកេ របស់អ្នកនិពន្ធ ទី ជីហួត។ រឿងនេះបានចាក់ផ្សាយតាមវិទ្យុជាតិច្រើនលើកក្នុងកំឡុងឆ្នាំ១៩៨៧ ដោយទទួលបានការគាំទ្រយ៉ាងច្រើនពីសំណាក់មហាជនខ្មែរនាសម័យនោះ។

រឿង តេជោយ៉តបានបង្កប់អត្ថន័យយ៉ាងជ្រាលជ្រៅនូវតម្លៃមនុស្សខ្មែរដែលយកប្រយោជន៍ជាតិជាធំ។ ពួកគេមានទឹកចិត្តស្មោះស្ម័គ្រចំពោះជាតិមាតុភូមិ ចំពោះមហាក្សត្រ ថ្នាក់ដឹកនាំរហូតដល់គ្រូបាអាចារ្យ ដោយមិនគិតថាខ្លួនជាបុរសឬស្ត្រីឡើយ។ ក្រៅពីនេះអ្វីដែលគួរឱ្យសរសើរនោះគឺការទទួលខុសត្រូវនូវទង្វើរបស់ខ្លួនដោយហ៊ានប្រឈមមុខនឹងបរិយាកាសសង្គមតានតឹងក្នុងរបបបក្សពួកនិយមដោយហ៊ានបកអាក្រាតអំពើអាក្រក់របស់ពួកឈ្លើងសង្គមដែលរមែងតែងតែយកជើងរាទឹកបន្ថយការរីកចម្រើនរបស់ប្រទេសជាតិ។កាលណាមានសង្គមគឺមានបញ្ហា។បញ្ហាចោទត្រូវបានដោះស្រាយដោយសន្តិវិធីខ្លះ ដោយហិង្សាខ្លះអាស្រ័យទៅលើប្រភេទបញ្ហា។តួយ៉ាងកំចាត់ជនក្បត់ជាតិត្រូវប្រើគ្រប់មធ្យោបាយដើម្បីចាប់ខ្លួនមេដឹកនាំឱ្យបាន ព្រោះពួកនេះជាជនទីមួយដែលបង្កអសន្តិសុខ ធ្វើឱ្យប្រជារាស្ត្ររស់ក្នុងការភ័យខ្លាចហើយជាឱកាសឱ្យសត្រូវចូលមកឈ្លានពានផងដែរម្យ៉ាងទៀតជនឱកាសនិយមបង្កអំពើពុករលួយ បង្កើតបក្សពួក គិតប្រយោជន៍ផ្ទាល់ខ្លួនហួសហេតុ ក៏ជាសត្រូវដែលបឺតជញ្ជក់ផលចំណេញពីប្រទេសជាតិជាហេតុនៃការផ្តល់ឱកាសឱ្យពួកជាតិដទៃងាយនឹងចាប់ចំណុចខ្សោយនិងកេងយកប្រយោជន៍បានយ៉ាងងាយដែរ។

រឿង តេជោយ៉ត ជាស្នាដៃមួយអាចនាំឱ្យយុវជនខ្មែរជ្រើសរើសយកបាននូវចំណុចជាច្រើនធ្វើជាគំរូ ដើម្បីកសាងខ្លួនឯងក៏ដូចសង្គមជាតិឱ្យរីកចម្រើនយ៉ាងពិតប្រាកដ។

## I. ការបង្ហាញអត្ថបទ

### ក- អត្ថបទ

**១- ចំណងជើង៖** រឿង តេជោយ៉ត។

**២- ប្រភព**

រឿង តេជោយ៉ត ជារឿងមួយដែលប្រសូតឡើងក្រោមស្នាដៃអ្នកនិពន្ធរបស់លោក ទី ជីហួត ក្នុងឆ្នាំ ១៩៨៣។ អ្នកស្រីប៊ី គឹមសែន បានសរសេរនៅក្នុងអារម្ភកថារបស់អ្នកស្រីថារឿងតេជោយ៉តដំបូងឡើយពុំត្រូវបានគេចងក្រងជាឯកសារសៀវភៅទេ មានតែឯកសារ ជាកាសែតម៉ាញ៉េ សម្រាប់ចាក់ឱ្យសិស្សស្តាប់នៅពេលដែលបង្រៀនដល់មេរៀននេះ។ លុះក្រោយមកនៅ

ឆ្នាំ២០០២ គេឃើញឯកសារជាសៀវភៅមួយចម្លងចេញពីកាសែតដោយសាស្ត្រាចារ្យ នុត វរភក្តិ បង្រៀនភាសាខ្មែរនៅវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង។ អត្ថបទនេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ គឺនៅមានឆាកខ្លះបាត់ការសន្ទនា និងខ្វះឃ្លាចម្រៀងរបស់តួអង្គ។ ដោយយល់ឃើញថាស្នាដៃនេះមានអត្ថប្រយោជន៍ចំពោះអ្នកសិក្សា អ្នកស្រាវជ្រាវ និងអ្នកអានទូទៅអ្នកស្រី ប៊ី គឹមសែន ក៏បានរៀបរៀងសរសេរបំពេញកន្លែងខ្វះចន្លោះទៅលើឯកសារដើមដែលមានស្រាប់។

យើងក៏ឃើញមានអ្នកនិពន្ធមួយរូបទៀតគឺលោក គង្គ ប៊ុនឈឿនក៏បានបង្កើតវណ្ណកម្មមួយមានចំណងជើងប្រហាក់ប្រហែលគ្នានេះដែរគឺរឿងតេជោមាស និពន្ធឡើងនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២។ តែបើយើងពិនិត្យមើលខ្លឹមសារនៃសាច់រឿងវិញ ថ្វីត្បិតតែវាមានបែបផែននៃតំណែងនិពន្ធក៏ខុសគ្នា គឺមួយសរសេរជាពាក្យរាយ ឯមួយទៀតជាប្រភេទល្ខោន។

**៣- ប្រភេទ:** អត្ថបទល្ខោនបាសាក់(នាដអក្សរសិល្ប៍)

**៤- ចលនា**: ខេមរនិយម។

**ខ- អ្នកនិពន្ធ**

**១- ឈ្មោះអ្នកនិពន្ធ:** ទី ជីហួត

**២- ជីវប្រវត្តិ:**

- ឈ្មោះអ្នកនិពន្ធ : លោក ទី ជីហួត
- ថ្ងៃ ខែ ឆ្នាំកំណើត : ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៥២
- ស្រុកកំណើត : ភូមិត្រពាំងស្វា ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ
- កម្រិតវប្បធម៌ : ថ្នាក់ទី៣ទំនើបជាតិ សាលាអនុវត្ត(មុនឆ្នាំ១៩៧៥)
- កម្រិតភាសាបរទេស : អាន និងសរសេរភាសាបារាំង
- ទទួលមរណៈភាព : ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៧ ដោយរោគាពាធ នៅរាជធានីភ្នំពេញ។

- **មុនឆ្នាំ១៩៧៥**
  - ជាងកាត់សក់ជិតផ្សារអូរឫស្សីនៅភ្នំពេញ។
  - ជាសិស្សសាលារៀនផង ដើរលក់នំប៉ុង លក់ប៉េងប៉ោះ បម្រើតុតាមហាង ដើម្បីចិញ្ចឹមក្រុមគ្រួសារ ក្នុងនាមខ្លួនជាកូនច្បង។
  - គេចាប់ធ្វើទាហាន។
  - ឆ្នាំ១៩៧២ បានចូលជាសមាជិកអ្នកនិពន្ធខ្មែរ។
- **ក្រោយឆ្នាំ១៩៧៥**
  - ជម្លៀសទៅស្រុកខាងម្តាយនៅភូមិកោះតូច ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាលបាន៦ខែ។
  - ខ្មែរក្រហមបញ្ជូនទាំងគ្រួសារឱ្យទៅនៅភូមិត្រពាំងថ្ម សង្កាត់ប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង មានការងារជាអ្នកលាយជីលេខមួយគឺជីលាមកមនុស្ស។
- **ក្រោយឆ្នាំ ១៩៧៩**

o បានមកនៅខេត្តសៀមរាប ពីរខែបន្តដំណើរទៅរស់នៅស្រុកកំណើតខាងម្តាយជាថ្មីទៀត។

o ក្រោយមកលោកបានមករស់នៅភ្នំពេញ ហើយចូលបម្រើការនៅវិទ្យុជាតិកម្ពុជា។

**៣- ស្នាដៃសំខាន់ៗ**

- កំណាព្យមានចំណងជើងថា"ក្តីលំបាកវេទនារបស់កូនអ្នកក្រនិងការបែងចែកវណ្ណៈក្នុងសង្គមមនុស្ស" ឆ្នាំ១៩៦៨
- ប្រលោមលោករឿង«អ្នកលេងជាយសមុទ្រ» ឆ្នាំ១៩៧០ ដោយបោះលក់តាមទីផ្សារ
- ប្រលោមលោកភាគ(៥ភាគ)រឿង"គុហារថ្មលឿង" ឆ្នាំ១៩៧១ដល់១៩៧២ ប្រលោមលោកនេះបានធ្វើឱ្យគាត់ល្បីឈ្មោះ
- ប្រលោមលោករឿង"អ្នកតាត្បូងខ្មៅ" ឆ្នាំ១៩៧២
- ប្រលោមលោករឿង"ឃាតកអាវសែ" ឆ្នាំ១៩៧២
- ប្រលោមលោករឿង"ម្រាមភ្លើង" ឆ្នាំ១៩៧៣
- ប្រលោមលោករឿង"ម្រេញគង្វាល" ឆ្នាំ១៩៧៤
- ប្រលោមលោករឿង"យមរាជប្រមឹក" ឆ្នាំ១៩៧៤
- ប្រលោមលោករឿង"ដាវផ្កា៦ពណ៌" ឆ្នាំ១៩៧៤
- ប្រលោមលោករឿង"អញមកវិញហើយ" ឆ្នាំ១៩៧៥
- អាយ៉ៃឆ្លើយឆ្លងមានចំណងជើងថា "ជ្រោងទង់ប្រយុទ្ធដើម្បីបំបាត់ភាពមិនចេះអក្សរ" ១២-០៧-១៩៨០
- អាយ៉ៃឆ្លើយឆ្លងមានចំណងជើងថា "អបអរខួបទី៣៥ បុណ្យឯករាជ្យសាធារណរដ្ឋវៀតណាម" ២៣-០៨-១៩៨០
- អាយ៉ៃឆ្លើយឆ្លងមានចំណងជើងថា "ពង្រឹងស្មារតីចំពោះឧបាយកលខ្មាំង" ១២-០៩-១៩៨០
- អាយ៉ៃឆ្លើយឆ្លងមានចំណងជើងថា "ប្រជាជនកម្ពុជាអបអរបុណ្យភ្ជុំបិណ្ឌតាមប្រពៃណី" ០៦-១០-១៩៨០
- យីកេរឿង "រឿងទម្ងន់ទោសរបស់បនក្សត់ប៉ុលពតក្នុងភ្លើងនរកអវិចី" ០៧-១០១៩៨០
- យីកេរឿង"៧មករាថ្ងៃជោគជ័យនៃបដិវត្តន៍សង្គមនិយមបរិសុទ្ធ" ៣០-១០-១៩៨០
- យីកេរឿង«មាយើង» (យកតាមលំនាំដើម) ១៩-១១-១៩៨០
- យីកេរឿង«ជីវិតថ្មីក្រោយថ្ងៃ៧មករា» ០១-០១-១៩៨១
- យីកេរឿង«ម៉ាក់ថឺង» (ខ្សែ៣) ០៩-០៦-១៩៨១
- យីកេរឿង«ការផ្ទេរតំណែងរវាងស្វានិងមាន់» ៣១-០៨-១៩៨១
- យីកេរឿង«៧មករាមហាជោគជ័យ» ១៥-១២-១៩៨១
- យីកេរឿង«ទម្ងន់ទោសបនក្សត់ក្នុងភ្លើងអវិចី» ឆ្នាំ១៩៨២
- អាយ៉ៃរឿង«វិធីផ្ទេរតំណែងរវាងមាន់និងឆ្កែ» ៣០-០៣-១៩៨២
- ល្ខោននិយាយរឿង«រឿងចិត្តប្រណី» (ខ្សែ២) ០៧-០៤-១៩៨២
- ល្ខោននិយាយរឿង«មាគ៌ាសន្តោសប្រោសប្រណី» ១៥-០៨-១៩៨២
- ល្ខោនបាសាក់រឿង«ព្រះឥន្ទ្រខ្វាក់ភ្នែក» (ខ្សែ២)៣០-១១-១៩៨២

- យីកេរឿង«យុនឆាងយុនផែន» (ខ្សែ៣) ០៧-០៩-១៩៨៣
- យីកេរឿង«៥ឆ្នាំក្នុងជីវិតថ្មី» (ខ្សែ១) ០៣-១២-១៩៨៣
- យីកេរឿង«សំឡេងនៃក្ដីសង្ឃឹម» (ខ្សែ១) ០៩-១២-១៩៨៣
- ល្ខោនបាសាក់រឿង«តេជោយ៉ត» (ខ្សែ៣) ២៨-១២-១៩៨៣
- ល្ខោននិយាយរឿង«វិលរកទ្រនំ» ២៩-១២-១៩៨៣
- ប្រលោមលោករឿង«វិលរកទ្រនំ» ១៩៨៩
- ល្ខោនបាសាក់រឿង«នាងបដាចារ») ២ខ្សែ( ០៦-០៩-១៩៨៩
- យីកេរឿង«ឈាមពលករ» )២ខ្សែ( ០៧-០៩-១៩៨៩
- យីកេរឿង«ស្នងសូរមនោកែវ» )១ខ្សែ( ២៧-០៦-១៩៨៩
- ល្ខោនបាសាក់រឿង«អរុណរះនៅទិសបូព៌» ២៨-០៦-១៩៨៩
- ល្ខោនបាសាក់រឿង«គូព្រេងចម្លែក» (ខ្សែ៥) ០៥-១២-១៩៨៩
- យីកេរឿង«ជនឥស្សរៈ» )១ខ្សែ( ០១-០១-១៩៨៥
- យីកេរឿង«បុរសបេះដូងមាស» )២ខ្សែ( ១៩-០៩-១៩៨៥
- យីកេរឿង«កុំភ្លេចរឿងចាស់» )១ខ្សែ( ១៩-០៥-១៩៨៥
- ប្រលោមលោករឿង«មេឃបាត់ដួងចន្ទ» ១៥-០៩-១៩៨៥
- ប្រលោមលោករឿង«ជីវិតអាថ៌កំបាំង» (មិនទាន់ចេញផ្សាយ) ១៩៨៦
- ល្ខោនបាសាក់រឿង«ព្រលឹងបន្ទាយស្រី» (ខ្សែ៥) ១២-០៩-១៩៨៦
- អាយ៉ៃរឿង«កងទ័ពគម្រ» ២៧-០៣-១៩៨៦
- យីកេរឿង«ក្បួនជីវិត» (ខ្សែ៣) ២៨-០៣-១៩៨៧
- ចម្រៀងបុរាណ ៥០បទ
- ចម្រៀងសម័យ ៩៨បទ។

❖ សម្គាល់៖ ស្នាដៃជាចម្រៀងអាយ៉ៃឆ្លងឆ្លើយមានច្រើនតែយើងមិនចាំអស់។

**គ- កាលកំណត់តែង**

**១- ថ្ងៃ ខែ ឆ្នាំ នៃការតាក់តែង**

ល្ខោនបាសាក់រឿងតេជោយ៉ត ជាស្នាដៃរបស់លោក ទី ជីហ្វ និពន្ធឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៨៣។

**២- ថ្ងៃ ខែ ឆ្នាំ នៃការបោះពុម្ព**

រឿងតេជោយ៉ត ជាប្រភេទល្ខោនបាសាក់ដែលបានថតជាសំឡេងដាក់ក្នុងកាសែតសម្រាប់ចាក់ផ្សាយតាមវិទ្យុជាតិ។ លុះក្រោយមកនៅឆ្នាំ២០០២ ទើបសាស្ត្រាចារ្យ នុត វរភក្តិ បង្រៀនភាសាខ្មែរនៅវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង បានចងក្រងជាសៀវភៅមួយដោយចម្លងចេញពីកាសែតទាំងនោះ។ ការចងក្រងអត្ថបទរឿងតេជោយ៉តដែលចម្លងមកនេះ នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ គឺនៅមានឆាកខ្លះបាត់ការសន្ទនា និងខ្វះឃ្លាចម្រៀងរបស់តួអង្គនៅឡើយ។ ក្រោមកទើបលោកស្រី ប៊ី គឹមសែន ជាអធិការមធ្យមសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ នៃមន្ទីរអប់រំ យុវជន និងកីឡា បានយកស្នាដៃនេះមករៀបរៀងសរសេរបំពេញបន្ថែមនូវចំណុចខ្វះចន្លោះទៅលើឯកសារដែលមានស្រាប់ ហើយបានបោះពុម្ពជាហូរហែរៀងមក។

## ឃ- សង្គមបរិយាកាស

### ១- កាលប្បវត្តិ(សម័យកាលកកើតរឿង)

ដំណើររឿងប្រព្រឹត្តទៅនៅក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី១(១៥៧៩-១៥៩៥) ស្ថិតក្នុងចុងសម័យកាលលង្វែក និងដើមសម័យកាលឧដុង្គ។ ពេលនោះ ប្រទេសខ្មែរយើងមានទំនាស់ផ្ទៃក្នុង ធ្វើឱ្យមានសង្គ្រាមដណ្ដើមអំណាច ផ្ដួលរំលំរាជបល្លង្ក។ លើសពីនេះទៀត ប្រទេសខ្មែររងការទន្ទ្រានឈ្លានពានជាញឹកញាប់ពីសំណាក់បរទេសគឺប្រទេសសៀម។ ដូច្នេះព្រះមហាក្សត្រគ្រងរាជ្យនាស័យនោះ ត្រូវប្រឈមមុខដោះស្រាយជាមួយសត្រូវពីរប្រភេទគឺ សត្រូវក្នុងស្រុកដែលជាជាតិសាសន៍ខ្មែរដូចគ្នាផង និងសត្រូវជាពួកបរទេសឈ្លានពានទឹកដីផង។

### ២- ព្រឹត្តិការណ៍សំខាន់ៗ

- ព្រះបាទជ័យជេដ្ឋាទី១ (គ.ស.១៥៧៩-១៥៩៥) បានសោយរាជ្យសម្បត្តិក្នុងជន្មាយុ១០វស្សា ដោយព្រះបិតាព្រះអង្គព្រះនាមព្រះបាទសត្ថាទី១ បានផ្ទេររាជសម្បត្តិឱ្យតែនៅគ្រប់គ្រងរដ្ឋអំណាចខ្លួនឯង។
- ប្រទេសមានការរីកចម្រើនទាំងកសិកម្ម និងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស រួមទាំងមានការទិញកាំភ្លើងកាណុង កាំភ្លើងដៃ គ្រាប់រំសេវ។ល។
- ទីក្រុងនានាមាន អង្គរ លង្វែក ឧដុង្គ ស្រីសន្ធរ ភ្នំពេញ ពោរពេញទៅដោយសិប្បករ ពាណិជ្ជករ មន្ត្រី នាហ្មឺន ទាហាន។
- គ.ស.១៥៨៣ កងទ័ពសៀមបានវាយលុកចូលបាត់ដំបង ពោធិ៍សាត់ ឡោមព័ទ្ធរាជធានី តែត្រូវកងទ័ពខ្មែរវាយបណ្ដេញទៅវិញ។
- បរមរាជវាំងមានការពង្រឹងកម្លាំងកងទ័ព បង្កើតកងឆ្មាំរក្សា
- មានការជ្រើសរើសទាហានស៊ីឈ្នួល ពីជនជាតិមាលាយូ ព័រទុយហ្គាល និអេស្ប៉ាញ៉ុល
- ប្រទេសត្រូវបានបែងចែកជាខេត្ត ស្រុក ឃុំ ភូមិ
- តាមទីក្រុងនានាមានមន្ត្រីជាតំណាងរាជបល្លង្កត្រួតត្រា ប៉ុន្តែគ្មានរបបស្វ័យគ្រប់គ្រងទេ
- កាន់ព្រះពុទ្ធសាសនាថេរវាទ
- ព្រះមហាក្សត្រអញ្ជើញពួកអេស្ប៉ាញ៉ុល និងព័រទុយហ្គាល បំពេញតួនាទីជាអាជ្ញាកណ្ដាល ដើម្បីទាក់ទាញកងនាវាអឺរ៉ុបចូលរួមយុទ្ធការផ្សេងៗ
- មានបន្តរបន្តសិទ្ធិពាណិជ្ជកម្ម និងសិទ្ធិក្នុងការផ្សព្វផ្សាយគ្រឹស្តសាសនា
- រវាងទស្សវត្សទី៩០ នៃសតវត្សទី១៦ សៀមទទួលជ័យជម្នះក្នុងការវាយលុកចូលប្រទេសកម្ពុជា។
- ព្រះបាទសត្ថាទី១ បានបញ្ជូនជនជាតិព័រទុយហ្គាលម្នាក់ឈ្មោះវែលឡូសូទៅហ្វីលីពីន ដើម្បីចរចាសុំជំនួយពីនាវាចម្បាំងរបស់អឺរ៉ុប និងចរចាជាមួយអាជ្ញាធរអេស្ប៉ាញ៉ុល តែមិនបានសម្រេច
- ឆ្នាំ១៥៩៤ សៀមវាយចូលទីក្រុងលង្វែក ដោយបានត្រួតត្រា និងបំផ្លិចបំផ្លាញឯកសារច្បាប់ទម្លាប់នានារបស់ខ្មែរ។
- សៀមបានយកព្រះពុទ្ធរូប ព្រះគោ ព្រះកែវ ព្រះពុទ្ធរូបធ្វើពីមរកត រូបព្រះគោណន្ទិន

និងសៀវភៅក្បួនតម្រាផ្សេងៗ(ពង្សាវតាខ្មែរសរសេរថា សៀមបានលួចគម្ពីរចំណេះវិជ្ជាពីខ្មែរ ហើយបានខ្លាំងពូកែក៏ដោយសារគម្ពីរទាំងនោះ)

- ជាលើកទីបីនៃស្ថានភាពកងទ័ពថៃនៅក្នុងរាជធានី ហើយមហាក្សត្រខ្មែរ និងកងទ័ពខ្មែរគ្រប់គ្រងប្រទេសទាំងមូល។
- ព្រះបាទសត្ថាទី១ និងរាជបុត្រ បានថយទៅគង់នៅទីក្រុងស្រីសន្ធរ ។ សង្គ្រាមរីករាលដាលពេញប្រទេស និងក្រោយមកបានទៅគង់នៅជិតព្រំប្រទល់ប្រទេសឡាវ
- រាជវង្សរបស់ព្រះបាទសត្ថាទី១មួយអង្គ បានបង្កបង្កើតទ័ពយ៉ាងធំ វាយយកទីក្រុង។ លង្វែកបានវិញ ហើយឡើងសោយរាជ្យមានព្រះនាមថា ព្រះបាទរាមាជើងព្រៃ(១៥៩៥-១៥៩៦) ព្រះអង្គសោយទិវង្គតនៅរាត្រីមួយ ដោយត្រូវគ្រាប់កាំភ្លើងរបស់សត្រូវ។
- ព្រះបរមរាជាទី១ឬព្រះចៅពញាតន់ ជារាជបុត្រព្រះបាទសត្ថាទី១ឡើងសោយរាជ្យ។
- ព្រះចៅពញាតន់បង្ក្រាបនៅត្បូងឃ្មុំ និងបានសោយទិវង្គតក្នុងចម្បាំងនៅទីនោះនាឆ្នាំ ១៥៩៧។
- អ្នកសោយរាជ្យបន្តគឺព្រះចៅពញាអន ជាបិតារបស់ពញាតន់គ.ស.១៥៩៧-១៥៩៩ ហើយព្រះអង្គបង្ក្រាបអំពើបះបោរនានានៅទីក្រុងភ្នំពេញ ។
- គ្រានេះពោរពេញទៅដោយភាពច្របូកច្របល់បង្ហូរឈាម ដណ្តើមរាជសម្បត្តិរវាងសមាជិករាជវង្ស និងមានការលុកលុយពីប្រទេសថៃ។
- ចៅហ្វាយខេត្តនីមួយៗគ្រប់គ្រងខេត្តតាមការចាត់តាំងរបស់ស្តេច ។
- មានចលនាបះបោរកុបកម្មប្រជាករណ៍ក៏បានកើតឡើងក្រោមកិច្ចដឹកនាំរបស់នាយកែវ គឺប្រហាក់ហែលនឹងនាយកនដែរ រហូតបានធ្វើឱ្យព្រះចៅពញាអនសោយទិវង្គត។
- ចលនាបង្រួបបង្រួមរាជវង្សានុវង្សកើតឡើងដឹកនាំដោយព្រះពញយុម ហើយបានប្រហារជីវិតនាយកែវ។
- តាមការទាមទាររបស់ព្រះវររាជមាតា និងរាជវង្សានុវង្ស នាហ្មឺនមន្ត្រី ចៅហ្វាយខេត្តនានាព្រមព្រៀងគ្នាសុំអញ្ជើញព្រះបាទសុរិយោពណ៌ ឬព្រះបរមរាជាទី៤(១៦០៣-១៦១៨) ដែលជាឈ្លើយសង្គ្រាមនៅប្រទេសថៃឡើងសោយរាជ្យ ហើយស្តេចថៃក៏យល់ព្រម។
- ការប្រយុទ្ធប្រឆាំងពីសំណាក់អ្នកប្រឆាំងឥទ្ធិពលសៀមដឹកនាំដោយព្រះឧបយោរាជ។
- ចម្បាំងនេះមហាក្សត្របានសុំជំនួយពីក្រុងអយុធ្យា ហើយបានទទួលជោគជ័យដោយធ្វើគតព្រះពញាយុម។
- ព្រះបាទសុរិយោពណ៌បានរៀបចំសណ្តាប់ធ្នាប់ឡើងវិញនៅខេត្តកំពង់ស្វាយ និងទីក្រុងអង្គរ និងនៅតំបន់ជង្រុកស្រូវខាងលិចប្រទេស
- ព្រះបាទសុរិយោពណ៌បានចាករាជសម្បត្តិ ហើយប្រគល់ឱ្យព្រះបាទជ័យជេដ្ឋាទី២។

## II. ការវិភាគអត្ថបទ

### ក- ស្ថានភាពរឿង

#### ១- សង្ខេបរឿង

នៅដែនដីកំពង់ស្វាយ មានបុរសម្នាក់ឈ្មោះ«មាស» មានងារជាឧកញ៉ាតេជោបរមរាជ ដែលហៅថា«តេជោមាស»។ លោកមានភរិយាឈ្មោះ«ស្រែន្យ» មានងារជាជំទាវ និងមានសិស្សជំនិតម្នាក់ឈ្មោះ«យ៉ត» ដែលតែងតែទៅសមរភូមិប្រយុទ្ធជាមួយនឹងលោកគ្រូគ្រប់

ទីកន្លែង។ ស្វាមីភរិយាទាំងពីរនេះ មានទឹកចិត្តស្រឡាញ់រាប់អាន«**យ៉ត**» ជាពន់ពេក។ ស្ដេចសម្រែបានតាំងខ្លួនឯងថា«ស្ដេចសម្រែរាជាធិរាជ» បានតាំងទីកងទ័ពនៅកំពង់ហៅ(កំពង់ឆ្នាំង) ដោយបានរៀបចំបន្ទាយមួយឱ្យឈ្មោះថា«បន្ទាយនគរ»។ស្ដេចសម្រែជាមេក្រុមបះបោរប្រឆាំងនឹងស្ដេចព្រះជ័យចេស្ដាដើម្បីដណ្ដើមអំណាចគ្រប់គ្រងផែនដី។តេជោមាសនិងយ៉តបានព្យាយាមលើកទ័ពទៅបង្ក្រាបក្រុមបះបោរនេះខ្លាំងណាស់ដែរតែត្រូវបរាជ័យ។ ជំទាវស្រែន្យបានរៀបចំល្បិចបញ្ឆោតឱ្យស្ដេចសម្រែធ្លាក់ក្នុងអន្លង់ស្នេហាចំពោះរូបនាង ហើយបង្អកស្រាហួតដល់ស្រវឹង។ស្ដេចសម្រែនិងបក្សពួកត្រូវបានតេជោមាស យ៉ត និងកងទ័ពចាប់ទៅថ្វាយព្រះចៅជ័យចេស្ដាកាត់ទោសតាមច្បាប់នគរ។

ក្រោយពីបានទទួលជោគជ័យលើស្ដេចសម្រែរួចមក តេជោមាស ក៏បានទទួលអនិច្ចកម្មទៅ។ ព្រះរាជាក៏ប្រទានងារនោះឱ្យទៅ តេជោយ៉តបំពេញនាទីដឹកនាំកងទ័ពជំនួស។ តេជោយ៉តបានទទួលរាជបញ្ជានិងដាវអាជ្ញាសឹកទៅបង្ក្រាបពួកឈ្លើយសឹកបះបោរ នៅខេត្តពោធិ៍សាត់។ ឆ្លងតាមបទពិសោធរបស់ឧកញ៉ាចក្រី និងក្រឡាហោមទទួលបរាជ័យក្នុងការបង្ក្រាបឈ្លើយសឹកនៅទីនោះ តេជោយ៉ត បានរកឃើញថាការចាញ់សង្គ្រាមនេះបណ្ដាលមកពីមានខ្មាំងនៅពីក្រោយខ្នង។ តេជោយ៉ត បានបញ្ជាកេណ្ឌទ័ពនៅលង្វែក កំពង់ស្វាយក្នុងនោះមានម៉ឺនចៃចុងរ៉ាក់ដែលជាប្អូនថ្លៃមហាក្សត្រផងដែរ ដើម្បីរកខ្មាំងខាងក្រោយខ្នង តេជោយ៉ត បានបញ្ជាឱ្យកងទ័ពកំណែនទាំងអស់អូសឫស្សីបញ្ច្រាសចុងសម្រាប់កសាងបន្ទាយ បើនរណាប្រឆាំងត្រូវសម្លាប់ចោល។បក្សពួកម៉ឺងចៃចុងរ៉ាក់មិនបានធ្វើតាមបញ្ជានេះឡើយ ហើយថែមទាំងធ្វើតាមទំនើងចិត្តរបស់ខ្លួនព្រោះសំអាងទៅលើបងស្រីដែលធ្លាប់ទទួលសំណូក និងជាអ្នកម្នាងនៃព្រះរាជាមហាក្សត្រនឹងជួយឱ្យរួចពីកំណែននេះ។ ទង្វើនោះត្រូវ តេជោយ៉ត រកឃើញថា ម៉ឺនចៃចុងរ៉ាក់នេះឯងជាខ្មាំពីក្រោយខ្នងហើយក៏ចាប់យកទៅសម្លាប់ទៅ។ ក្រោយពីបានទទួលដំណឹងថាប្អូនប្រុសស្លាប់ អ្នកម្នាងនូ បានទូលថ្វាតព្រះរាជាឱ្យចាប់ តេជោយ៉ត ទៅកាត់ទោសប្រហារជីវិត។ ព្រះរាជាបានធ្វើតាមការសុំរបស់អ្នកម្នាងតែ តេជោយ៉ត មិនបានមកតាមបញ្ជានោះឡើយដោយសំអាងថាខ្លួនេជាប់ដៃបង្ក្រាបសត្រូវបះបោរ ចាំរួចការនេះខ្លួននឹងមកទទួលទោសដោយខ្លួនឯង។ ដោយការទទូចសុំរបស់អ្នកម្នាងខ្លាំងពេកព្រះរាជាបានបង្ខំឱ្យតេជោយ៉ត មកជួបតទល់ជាមួយអ្នកម្នាងនូ។ពេលដែលកំពុងជជែកគ្នានោះ តេជោយ៉ត បានចោទប្រកាន់ថាអ្នកម្នាងជាខ្មាំងពីក្រោយខ្នង ព្រោះបានរំខានខ្លួនពពេលធ្វើសឹកបើកឱកាសឱ្យសត្រូវវាយលុកនិងទទួលសំណូកដើម្បីការពារបក្សពួកម៉ឺងចៃចុងរ៉ាក់ធ្វើឱ្យកងទ័ពបាក់ស្មារតី ហើយក៏គប់កូនដាវសម្លាប់អ្នកម្នាងនូតែម្ដង ។ តេជោយ៉ត ប្រកាសជម្រាបមន្ត្រីទាំងនោះថា ចាំបង្ក្រាបសត្រូវរួចនឹងចូលមកទទួលទោសពីព្រះអង្គដោយខ្លួនឯង។

ការបង្ក្រាបឈ្លើយសៀមបះបោរបានសម្រេចជោគជ័យ តេជោយ៉ត ឱ្យគេធ្វើឃ្នាង

ហើយដាក់ខ្លួនឯងដើរចូលទៅទទួលទោសពីព្រះរាជាពីបទដែលខ្លួនបានសម្លាប់អ្នកម្នាងនូ។ ព្រះរាជាមិនឱ្យចូលជួបរួចបញ្ជាឱ្យមន្ត្រីដោះលែងនិងឱ្យទៅត្រួតការងារឯខេត្តកំពង់ស្វាយ។ តេជោយ៉ត បានគួចចិត្តប៉ងប្រាថ្នាយកជំទាវស្រែនមកធ្វើជាភរិយាតែមិនបានសម្រេចទេពីព្រោះជំទាវស្រែន្យបានគិតថា យ៉ត ជាជនជាតិភាគតិចនិងជាសិស្សប្ដីនាងពីមុនផងដែរ។ ដោយសង្កេតឃើញជំទាវរើសអើងស្នេហា ប្រកាន់វណ្ណៈបែបនេះ តេជោយ៉តបានប្រើល្បិចលួចយកឈើកាំជណ្ដើរផ្ទះជំទាវស្រែនមកឱ្យជាងដាប់ឆ្លាក់ជារូបព្រះពុទ្ធបដិមានិងរូបតេជោមាស ហើយប្រកាសធ្វើបុណ្យយ៉ាងធំបញ្ជូនកុសលទៅគ្រូរបស់ខ្លួន។ជំទាវស្រែន្យ បានទៅចូលរួមពិធីនេះហើយថ្វាយបង្គំព្រះពុទ្ធបដិមានិងរូបសំណាក តេជោមាស នោះតែត្រូវបាន តេជោយ៉តប្រាប់បើការពិតថាថ្វាយបង្គំកាំជណ្ដើរផ្ទះរបស់ខ្លួនឯង។គ្រានោះជំទាវស្រែន្យយល់ន័យនៃទង្វើរបស់តេជោយ៉ត ហើយក៏ព្រមព្រៀងរៀបការជាមួយតេជោយ៉តនាពេលនោះទៅ។

**២- តួអង្គនិងមុខងារ**

- តេជោមាស៖ ជាស្វាមីជំទាវស្រែន្យ មានងារជា«តេជោបរមរាជ» ត្រួតត្រានៅក្នុងខេត្តកំពង់ស្វាយ។
- តេជោយ៉ត៖ ជាសិស្សជំនិតរបស់តេជោមាស មានងារជា«តេជោ» ហើយបានត្រួតត្រាខេត្តកំពង់ស្វាយ បន្ទាប់ពីតេជោមាសទទួលមរណភាព។
- ជំទាវស្រែន្យ៖ ជាភរិយារបស់តេជោមាស មានងារជា«ជំទាវ» ជាស្ត្រីឆ្នើមអាចអាចជួយស្វាមីក្នុងការកម្ចាត់ស្ដេចសម្រែ ដែលជាមេបះបោរដើម្បីដណ្ដើមរាជបល្ល័ង្ក។
- ព្រះចៅជ័យចេស្ដា៖ ព្រះមហាក្សត្រខ្មែរសោយរាជ្យនៅរាជធានីឧដុង្គ មានព្រះបរមងារថា «សម្ដេចព្រះរាជឱង្ការព្រះជ័យចេស្ដាបរមរាជ មហាខត្តិយា រាជាធិបតី ព្រះស្រីសុរិយោពណ៌មហាចក្រពត្រាធិរាជ»។
- អ្នកម្នាងនូ៖ ជាស្រីស្នំរបស់ព្រះចៅជ័យចេស្ដា មានងារជា«អ្នកម្នាង» និងជាបងស្រីម៉ឺនចៃចុងរ៉ាក់ ។
- ស្ដេចសម្រែ៖ មេបះបោរប៉ុនប៉ងដណ្ដើមរាជ្យពីព្រះចៅជ័យចេស្ដា ហើយតាំងនាមខ្លួនឯងថា«ព្រះសម្រែរាជាធិរាជ»។ កាលដើមឡើយជារាស្ត្រម្នាក់ឈ្មោះ សំ នៅក្រាំងសម្រែខេត្តបរិបូណ៌ ហើយបានទៅសិក្សាវិជ្ជាគុននៅ ភ្នំទូកមាស ខេត្តកំពង់ស្វាយ រហូតមានវិជ្ជាគុនខ្លាំងពូកែ។
- ឧកញ៉ាពិភា៖ មន្ត្រីជំនិតរបស់ស្ដេចសម្រែ។
- ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់៖ បម្រើការងារជាមួយតេជោមាសនិងតេជោយ៉ត។
- នាងម៉ែ៖ កូនស្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់និងជាអ្នកតាមស្រឡាញ់តេជោយ៉ត តែមិនបានសម្រេច ក្លាយទៅជាប្អូន ធម៌របស់តេជោយ៉តទៅវិញ។
- នាយឈិត៖ ឈ្លើយសឹកសៀមនិងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ។
- ម៉ឺនចៃចុងរ៉ាក់៖ ប្អូនអ្នកម្នាងនូ ប្រឆាំងនឹងបញ្ជាតេជោយ៉តដែលជាមេទ័ព ហើយត្រូវបានតេជោយ៉តចាត់ទុកជាសត្រូវក្រោយខ្នង ក៏ចាប់យកទៅសម្លាប់ចោល។
- តួអង្គរំព្ញកមួយចំនួនទៀត។

**៣- កាលអាកាស**

• **កាលៈ** ចុងសម័យលង្វែក ដើមសម័យកាលឧដុង្គ រជ្ជកាលព្រះបាទជ័យចេស្ដា(គ.ស ១៥៧៥-១៥៩៣) និងមានពេលវេលាខ្លីៗមួយចំនួនទៀតដូចជា ពេលកេណ្ឌកងទ័ព ពេលធ្វើការបង្ក្រាបក្រុមបះបោរខ្មែរ ពេលវេលាបង្ក្រាបក្រុមបះបោរសៀមជាដើម។

• **អាកាស ៖** រាជធានីឧដុង្គ ខេត្តកំពង់ស្វាយ(ស្ទឹងព្រៃប្រស់) ខេត្តពោធិ៍សាត់ ខេត្តលង្វែក ខេត្តបរិបូណ៌ កំពង់ហៅ(ទីរួមស្រុកកំពង់លែង) ក្រាំងសម្រែ ភ្នំទូកមាស ភូមិស្វាយអំពារ។

**៤- ព្រឹត្តិការណ៍សំខាន់ៗ ឬបញ្ហាសង្គមដែលបង្ហាញ**

• គ.ស.១៥៨៣ កងទ័ពថៃបានវាយលុកចូលបាត់ដំបង ពោធិ៍សាត់ ឡោមព័ទ្ធរាជធានី តែត្រូវកងទ័ពខ្មែរវាយបណ្ដេញទៅវិញ។ ចំណុចនេះ ស្របជាមួយព្រឹត្តិការណ៍រឿងត្រង់ពេលសៀមចាញ់សង្គ្រាមកងទ័ពមួយចំនួនបានក្លាយជាឈ្លើយសឹក ហើយឈ្លើយសឹកសៀមទាំងនោះស្ថិតនៅខេត្តពោធិ៍សាត់។ ក្រោយមក ឈ្លើយសឹកសៀមទាំងនោះបានធ្វើការបះបោរ ហើយត្រូវបានព្រះបាទជ័យចេស្ដាជាព្រះមហាក្សត្រខ្មែរសោយរាជ្យនៅរាជធានីឧដុង្គ បានដាក់ព្រះរាជបញ្ជាឱ្យតេជោយ៉តដែលជាអ្នកត្រួតត្រាខេត្តកំពង់ស្វាយដឹកនាំកងទ័ពបង្ក្រាប។ ជាក់ស្ដែងក្នុងសាច់រឿងបានបង្ហាញតាមរយៈព្រះបន្ទូលរបស់តួអង្គព្រះចៅជ័យចេស្ដា៖ «ឥឡូវនេះយើងមានកិច្ចការមួយយ៉ាងសំខាន់ដែលត្រូវប្រើលោក ដូចសេចក្ដីក្នុងសារយើងដែលផ្ញើទៅអញ្ជឹង។ ពួកឈ្លើយសឹកសៀមដែលបះបោរ បានវាយដណ្ដើមយកបានស្រុកពីរនៅខេត្តពោធិ៍សាត់។ វាកំពុងមានកម្លាំងណាស់។ យើងបានចាត់ឱ្យឧកញ៉ាក្រឡាហោមនិងឧកញ៉ាចក្រីលើកទ័ពទៅបង្ក្រាបក៏នៅតែបរាជ័យទៀត។ ឥឡូវឮថា ពួកវាចូលមកយកបន្ទាយព្រះច័ន្ទរាជាធ្វើជាមូលដ្ឋានទ័ពទៀតហើយ ដោយមានយុទ្ធវិធីការពារយ៉ាងមាំមួន។ ដូច្នេះ តើលោកតេជោមានគំនិតគិតយ៉ាងម៉េចដែរ?»។

• នៅក្នុងដំណាក់កាលមួយនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ត្រូវបានបែងចែកជាខេត្ត ស្រុក ឃុំ ភូមិ ហើយនៅតាមទីក្រុងនិងខេត្តនានាមានមន្ត្រីជាតំណាងរាជបល្ល័ង្កត្រួតត្រា ប៉ុន្តែគ្មានរបបស្វ័យគ្រប់គ្រងទេ។ ចំណុចនេះស្របជាមួយដំណើររឿងបង្ហាញពីរបបគ្រប់គ្រងបែងចែកជារាជធានី ក្រុង ខេត្ត ស្រុក ភូមិ។ ចំណុចនេះ ស្របតាមសាច់បង្ហាញមានដូចជា រាជធានីឧដុង្គ ក្រុងលង្វែក ខេត្តកំពង់ស្វាយ ខេត្តលង្វែក ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបរិបូណ៌ ភូមិស្វាយរំពារជាដើម។

• ព្រឹត្តិការណ៍ប្រវត្តិសាស្ត្របង្ហាញថា គ្រានេះពោរពេញទៅដោយភាពច្របូកច្របល់បង្ហូរឈាម ដណ្ដើមរាជសម្បត្តិរវាងសមាជិករាជវង្ស មានការលុកលុយពីប្រទេសថៃ និងមានចលនាបះបោរកុបកម្មប្រជាករណ៍ក៏បានកើតឡើងក្រោមកិច្ចដឹកនាំរបស់នាយកែវ គឺប្រហាក់ប្រហែលនឹងនាយកនដែរ រហូតបានធ្វើឱ្យព្រះចៅពញាអនសោយទិវង្គត។ ចំណុចនេះស្របជាមួយព្រឹត្តិការណ៍រឿងដែលបង្ហាញថា មានការបះបោរប៉ុនប៉ងដណ្ដើមរាជបល្ល័ង្ក ដឹកនាំដោយស្ដេចសម្រែ ដែលតាំងខ្លួនឯងថា«ព្រះសម្រែរាជាធិរាជ» ដោយបានតាំងបន្ទាយនៅភូមិស្វាយអំពារ មានឈ្មោះថា"បន្ទាយនគរ" ក្នុងដែនកំពង់ហៅ ហើយយកទីនេះធ្វើជារាជវាំង។ ជាក់ស្ដែងក្នុងសាច់រឿងបានបង្ហាញតាមរយៈសម្ដីរបស់តួអង្គស្ដេចសម្រែ៖ «ប្រសើរណាស់ៗលោកទាំងអស់គ្នា! បន្ទាយដែលយើងកំពុងសាងនៅភូមិស្វាយអំពារ ក្នុងដែនមឿងកំពង់ហៅនេះ ពុំទាន់រួចរាល់ទេ ប៉ុន្តែយើងសូមឱ្យឈ្មោះថា បន្ទាយនគរ ព្រោះទីនេះហើយជារាជវាំងរបស់
យើង។ ដូច្នេះសូមលោកផ្សព្វផ្សាយប្រជារាស្ត្រឱ្យហៅតាម ឮទេ!»។

**ខ- អត្ថន័យ**

**១- ប្រធានរឿង**

វីរភាពរបស់បុព្វបុរសខ្មែរ ដែលមានឧត្តមគតិស្នេហាជាតិ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ បានសុខសន្តិភាព និងការពារបូរណភាពទឹកដី បានគង់វង្ស ហើយនេះគឺជាគំរូដ៏ល្អប្រសើរគួរជាទីមោទនៈ និងស្ញប់ស្ញែងក្រៃលែង។

**២- មូលបញ្ហារឿង**

២.១- ការបះបោរប៉ុនប៉ងដណ្ដើមរាជបល្ល័ង្ក

ការបះបោរនេះ កើតចេញពីរាស្ត្រចង់ធ្វើជាស្ដេច។ ស្ដេចសម្រេ មានប្រភពកំណើតជារាស្ត្រសាមញ្ញ មានមហិច្ឆតាលោភលន់ និងមានមោទនភាពចំពោះខ្លួនឯងខ្លាំងពេកថាខ្លួនមានវិជ្ជាគុនខ្លាំងពូកែជាគេ ក៏បានឃោសនាប្រមូលកម្លាំងបង្កើតជាកងទ័ព រៀបចំផែនការ និងធ្វើចលនាបះបោរដើម្បីដណ្ដើមរាជបល្ល័ង្ក។ ជាក់ស្ដែងក្នុងសាច់រឿងបានបង្ហាញតាមរយៈសម្ដីរបស់តួអង្គយ៉ត៖ «យើងស្គាល់ច្បាស់ណាស់ ដើមឡើយឯងជារាស្ត្រម្នាក់ឈ្មោះ សំ នៅក្រាំងសម្រេខេត្តបរិបូណ៌នេះ ហើយបានទៅសិក្សាគុណវិជ្ជានៅ ភ្នំទូកមាស ខេត្តកំពង់ស្វាយ លុះដល់ចេះវិជ្ជាខ្លាំងពូកែហើយ អ្នកឯងមិនយកសមត្ថភាពរបស់ខ្លួនទៅបម្រើប្រទេសជាតិបែរជាបង្កចលាចលបំបះបំបោរបង្កើតទ័ពទឹង ហើយប្រកាសឈ្មោះខ្លួនឯងថា ព្រះសម្រេរាជាធិរាជ បណ្ដាលឱ្យមានអសន្តិសុខក្នុងនគរ នាំប្រជារាស្ត្រឱ្យធ្លាក់ទៅក្នុងគ្រោះមហន្តរាយ»។

២.២- ភាពខ្លាំងរបស់ស្ត្រីក្នុងការកម្ចាត់សត្រូវជូនជាតិមាតុភូមិ

ការកម្ចាត់សត្រូវដែលមានកងទ័ព ជាទូទៅគេយកកងទ័ពដែលដឹកនាំដោយបុរសទៅប្រយុទ្ធតតាំង។ តាមរយៈសាច់រឿងការកម្ចាត់សត្រូវដោយប្រើកម្លាំងកងទ័ពរបស់តេជោមាសត្រូវទទួលបរាជ័យ។ ក្នុងការកម្ចាត់សត្រូវនេះ ជំទាវស្រែន្យ បានប្រើឧបាយកលកម្ចាត់ស្ដេចសម្រេ ទទួលបានជោគជ័យដោយមិនប្រើកម្លាំងកងទ័ពប្រយុទ្ធ គ្មានការបង្ហូរឈាមឡើយ ដូចសុភាសិតមួយចែងថា«អូសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក»។ បើប្រៀបធៀបពីវិធីកម្ចាត់សត្រូវរបស់តេជោមាសជាមួយនិងជំទាវស្រែន្យឃើញថា ជំទាវស្រែន្យធ្វើបានល្អជាងតេជោមាស។ គេអាចនិយាយពីវិធីកម្ចាត់សត្រូវរបស់តេជោមាសនិងជំទាវស្រែន្យបានថា«ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ»។ ដូច្នេះជំទានស្រែន្យគឺជាស្ត្រីឆ្នើម ដែលបានបំពេញភារកិច្ចជូនជាតិមាតុភូមិបានល្អប្រសើរជាងបុរសទៅទៀត។ ជាក់ស្ដែងក្នុងសាច់រឿងបានបង្ហាញតាមរយៈសម្ដីរបស់តួអង្គជំទាវស្រែន្យ៖ «បង! ស្ដេចសម្រេត្រូវថ្នាំសណ្ដំសន្លប់ស្តូកទៅហើយ សូមបងចាត់ចែងទៅចុះ»។

២.៣- ការប្រយុទ្ធប្រឆាំងជាមួយពួកបរទេសឈ្លានពាន

តាមរយៈសាច់រឿងបង្ហាញថា ជារឿយៗប្រទេសសៀមតែងតែឈ្លានពានយកទឹកដីប្រទេសខ្មែរ។ ចំណែកប្រទេសខ្មែរវិញពុំដែលឈ្លានពានប្រទេសណាឡើយ ហើយតែងតែត្រៀមខ្លួនការពារការឈ្លានពានពីសំណាក់បរទេសជានិច្ច។ ដូច្នេះខ្មែរយើងហាក់ដូចជារង់ចាំតែរងគ្រោះពីពួកបរទេស។ ចំណែកបរទេសឈ្លានពានយើងហាក់ដូចជាមានប្រៀបលើយើងមានន័យថាបើគេឈ្លានពានយើងបានគេយកទៅ តែបើឈ្លានពានមិនបានគេត្រឡប់ទៅវិញ

ទៅ។ គ្រាដែលប្រទេសជាតិរងការឈ្លានពានពីបរទេស ការប្រយុទ្ធប្រឆាំងត្រូវតែមាន ពោលគឺសង្គ្រាមត្រូវតែកើតឡើង។ ក្នុងបរិកាណ៍នេះ ប្រទេសជាតិត្រូវការមេទ័ពខ្លាំងពូកែ មានឧត្តមគតិស្នេហាជាតិ ហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាងការពារទឹកដី។ ដើម្បីការពារទឹកដីបានគង់វង្ស គេត្រូវការកម្លាំងយុវជនដែលជាសសរទ្រូងនៃប្រទេសជាតិ រួមសាមគ្គីគ្នាជាធ្លុងមួយ ប្រយុទ្ធប្រឆាំងជាមួយពួកបរទេសឈ្លានពាន។ ក្នុងសាច់រឿងបានបង្ហាញតាមរយៈសម្ដីរបស់តួអង្គតេជោយ៉ត៖ «បពិត្រព្រះករុណាជាម្ចាស់! ទូលព្រះបង្គំពុំមានសមត្ថភាពដល់ថ្នាក់ស្មើនឹងលោកគ្រូទេ ប៉ុន្តែដោយមានការបង្ហាត់បង្រៀនអប់រំណែនាំពីគាត់ ទូលព្រះបង្គំបានប្ដេជ្ញាចិត្តរួចជាស្រេចថា ទោះបីឧបសគ្គធំប៉ុណ្ណាក៏ដោយ ទូលព្រះបង្គំពុះពារជាដាច់ខាត សូម្បីជីវិតក៏ហ៊ានបូជាដែរ ដើម្បីបុព្វហេតុប្រទេសជាតិមាតុភូមិក្រាបទូល!»។

២.៤- យុទ្ធវិធីក្នុងការធ្វើសឹកសង្គ្រាម

ការធ្វើសឹកសង្គ្រាមទទួលបានជោគជ័យ អាស្រ័យលើមេទ័ពខ្លាំងពូកែ។ មេទ័ពខ្លាំងពូកែអាស្រ័យលើការសិក្សារៀនសូត្រពីក្បួនធ្វើសឹកសង្គ្រាម និងបទពិសោធក្នុងការធ្វើសឹកសង្គ្រាម។ ចំណែកឯការសិក្សារៀនសូត្រពីក្បួនធ្វើសឹកសង្គ្រាម ពឹងផ្អែកទៅកម្ពីរក្បួនខ្នាត។ ភាពជោគជ័យនៃសង្គ្រាមក្នុងរឿងតេជោយ៉ត គឺដោយសារមេទ័ពអនុវត្តតាមក្បួនតម្រាពិជ័យសង្គ្រាមដែលមាន១២ប្រការ។ ក្នុងនោះមានចំណុចមួយលេចធ្លោរជាងគេគឺ ការកម្ចាត់សត្រូវក្រោយខ្នង មុននឹងចាប់ផ្ដើមច្បាំងជាមួយសត្រូវទល់មុខ។ សត្រូវក្រោយខ្នង មានន័យថាគឺជាកងទ័ពខ្លួនឯង ឬមន្ត្រីគ្នាឯងដែលធ្វើសកម្មភាពអ្វីមួយមិនល្អប្រសើរ ហើយវាជះឥទ្ធិពលធ្វើឱ្យបរាជ័យក្នុងសង្គ្រាម។ សត្រូវក្រោយខ្នងនេះ ចាស់បុរាណលោកប្រៀបធៀបទៅនឹង«ដង្កូវក្នុងសាច់»។ ជាក់ស្ដែងសាច់រឿងបង្ហាញតាមរយៈសម្ដីរបស់តួអង្គតេជោយ៉ត៖ «ព្រះករុណាថ្លៃវិសេស! ពួកឈ្លើយសឹកសៀមរាប់ម៉ឺននាក់នោះគឺបន្សល់ទុកមកពីចម្បាំងរវាងនគរនិងនគរ។ ដូច្នេះជាភារកិច្ចរបស់មេទ័ពហ្លួងទេដែលត្រូវចេញទៅបង្ក្រាប។ ក្នុងតម្រាពិជ័យសង្គ្រាមចែងថា ដើម្បីដណ្ដើមជ័យជម្នះពីខ្មាំងសត្រូវបាន មេទ័ពម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវលក្ខណៈ១២ប្រការ។ លោកឧកញ៉ាក្រឡាហោមនិងលោកឧកញ៉ាចក្រីប្រហែលមានការថ្លោះធ្លោយលើប្រការណាមួយហើយទើបត្រូវបរាជ័យយ៉ាងនេះ។ ដូច្នេះ ថ្វីបើទូលព្រះបង្គំជាមេទ័ពមកពីអាណាខេត្តមែន ប៉ុន្តែដើម្បីប្រទេសជាតិ ទូលព្រះបង្គំស្ម័គ្របម្រើជាតិជានិច្ចក្រាបទូល!»។ ព្រះករុណាថ្លៃវិសេស! លក្ខណៈ១០ប្រការខាងដើម ទូលព្រះបង្គំអាចអនុវត្តបានដោយខ្លួនឯង។ ប៉ុន្តែលក្ខណៈទី១១ និងទី១២ លុះត្រាតែមានព្រះរាជអនុញ្ញាតពីព្រះអង្គទើបទូលព្រះបង្គំជាខ្ញុំអាចដណ្ដើមយកជោគជ័យពីខ្មាំងសត្រូវបានក្រាបទូល!»។

២.៥- ការប្រឆាំងនឹងជំងឺបក្សពួកនិយម

បក្សពួកនិយម ជាជំងឺសង្គមមួយដែលពិបាករកថ្នាំមកព្យាបាលឱ្យជាសះស្បើយ។ សង្គមមួយក៏ដូចជាស្ថាប័នមួយដែរបើកាលណាកើតមានអំពើបក្សពួកនិយម គឺសង្គមនោះនឹងមិនមានការរីកចម្រើននោះឡើយ ហើយមិនតែប៉ុណ្ណោះវាថែមទាំងអាចធ្វើឱ្យសង្គមនោះរងគ្រោះរលំរលាយទៀតផង។ អំពើបក្សពួកនិយម គឺជាឫសគល់មួយធ្វើឱ្យកើតមាន ការកេងប្រវ័ញ្ចការស៊ីសំណូកសូកប៉ាន់ អំពើពុករលួយ ការធ្វើអ្វីៗដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ការបាត់បង់មនសិកា ការបាត់បង់ការទទួលខុសត្រូវ ប្រព័ន្ធរដ្ឋបាលដំណើរការបានដោយសារអំពើពុករលួយ ការជិះជាន់គាបសង្កត់ អំពើអយុត្តិធម៌ សាមគ្គីភេទ និងចុងក្រោយអាចឈានទៅដល់ការកើតសង្គ្រាមទៀតផង។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គតេជោយ៉ត៖ «កាលពីមុនឧកញ៉ាចក្រីនិងឧកញ៉ាក្រឡាហោមទៅកេណ្ឌពលទៅច្បាំងនោះ អ្នកម្នាងបានទៅកាត់

យកឈ្មោះអ្នកជាប់កំណែនអស់រាប់រយនាក់ ដោយយកលេសថាសុទ្ធតែត្រូវជាបងប្អូន ជាសាច់ជាញាតិ។ ប៉ុន្តែតាមការពិតអ្នកម្នាងបានទទួលការសូកប៉ាន់របស់គេ។ អ្នកម្នាងស្រវឹងនឹងអំណាច ស្រវឹងនឹងទ្រព្យសម្បត្តិគិតតែពីចេញមុខធានា ឥតរវល់ដល់ផលវិបាកដែលធ្លាក់លើប្រទេសជាតិសោះ។ ហេតុដូចនេះហើយបានជាទ័ពលោកឧកញ៉ាទាំងពីរត្រូវបរាជ័យព្រោះទ័ពពុំគ្រប់ចំនួនតាមសំណូមពរហើយពលទាហានសុទ្ធតែធ្លាក់ទឹកចិត្តចំពោះអំពើអយុត្តិធម៌របស់អ្នកម្នាង»។

២.៦- ការរើសអើងប្រកាន់វណ្ណៈនៅក្នុងសង្គម

វណ្ណៈនៅក្នុងសង្គមខ្មែរក៏ដូចជានៅក្នុងអក្សរសិល្ប៍ខ្មែរ គឺមិនមែនជាការបែងចែកវណ្ណៈដែលសង្គមបានកំណត់ច្បាស់លាស់ដូចនៅប្រទេសឥណ្ឌាបែងចែកវណ្ណៈជាបួនគឺ វណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវេស្សៈ និងវណ្ណៈសូទ្រ នោះទេ។ ពោលគឺវណ្ណៈដែលមនុស្សមួយក្រុម ឬក្រុមគ្រួសារ ឬក៏មនុស្សម្នាក់ៗ ធ្វើចំណាត់ថ្នាក់ដោយខ្លួនឯងតែប៉ុណ្ណោះដូចជាកាលណាគ្រួសារគេមានអ្នកមានបុណ្យស័ក្តិធំ ឬជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ គេចាត់ទុកមានវណ្ណៈខ្ពង់ខ្ពស់។ ចំពោះវណ្ណៈនៅក្នុងរឿងតេជោយ៉ត ជំទាវស្រែន្យបដិសេធនឹងការចូលស្តីដណ្តឹងរបស់តេជោយ៉ត ដោយចាត់ទុកថាខ្លួនមានងារជាជំទាវ ធ្លាប់មានស្វាមីជាមេទ័ព គឺមានវណ្ណៈខ្ពង់ខ្ពស់ ចំណែកតេជោយ៉តធ្លាប់ជាអ្នកបម្រើគឺមានវណ្ណតូចទាប ដូចពាក្យគេធ្លាប់និយាយថា«ស្នេហាមិនប្រកាន់វណ្ណៈ ប៉ុន្តែវណ្ណៈប្រកាន់ស្នេហា»។ ដូចសម្តីបានបញ្ជាក់តាមរយៈតួអង្គតេជោយ៉ត៖ «ហ៊ឺ! ជំទាវស្រែន្យជានារីបញ្ចពិធកល្យាណីស្រីគ្រប់លក្ខណ៍តែនៅមានគំនិតប្រកាន់វណ្ណៈដែលបណ្តាលមកពីបរិយាកាសរបស់សង្គម»។

**៣- ទំនាស់**

៣.១- ទំនាស់ទី១៖ ការបង្ក្រាបការបះបោរដណ្តើមរាជបល្ល័ង្គ

- ទីកន្លែងទំនាស់៖ បន្ទាយនគរ ភូមិស្វាយអំពារ ដែនកំពង់ហៅ
- តួទំនាស់៖ តេជោមាស និងស្តេចសម្រែ
- បញ្ហាទំនាស់៖ ដោយសារស្តេចសម្រែមានវិជ្ជាគុនខ្លាំងពូកែចង់ធ្វើជាស្តេច ដោយតាំងខ្លួនឯងជា«ព្រះសម្រែរាជាធិរាជ»។ ស្តេចសម្រែបានបង្កើតកម្លាំងទ័ព កសាងបន្ទាយ ធ្វើចលនាប៉ះបោរ ដើម្បីដណ្តើមរាជ្យសម្បត្តិពីព្រះបាទជ័យចេស្តា ជាព្រះមហាក្សត្រសោយរាជ្យនៅក្រុងឧដុង។ ក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គស្តេចសម្រែ៖ «អ្ហូ! លោកឧកញ៉ាពិភាត្រូវខិតខំកេណ្ឌពលសឹកបន្ថែមទៀតកុំបន្ធូរដៃឱ្យសោះ។ ព្រោះនៅរដូវខាងមុខនេះយើងត្រូវលើកទ័ពទៅឡោមព័ទ្ធវាំងរបស់ព្រះចៅជ័យចេស្តានៅក្រុងឧដុង្គដើម្បីដណ្តើមយករាជសម្បត្តិ ក្រុងកម្ពុជាឱ្យបានដាច់ខាត!»។
- ដំណោះស្រាយ៖ តេជោមាសដែលជាមេទ័ពដ៏ខ្លាំងពូកែប្រចាំនៅខេត្តកំពង់ស្វាយ រួមទាំងសិស្សជំនិតឈ្មោះយ៉ត បានដឹកនាំកងទ័ពទៅបង្ក្រាបក្រុមបះបោរដែលដឹកនាំដោយស្តេចសម្រែនេះ។ តេជោមាសតែត្រូវទទួលបរាជ័យ ដោយសារតែស្តេចសម្រែបានចាប់អ្នកនាំសារសម្ងាត់របស់ខ្លួន និងបានដឹងពីផែនការជាមុន។ ក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គយ៉ត៖ «ទ័ពយើងស្លាប់ របួស និងរត់ខ្ចាត់ខ្ចាយអស់ទៅហើយ ដូច្នេះយើងត្រូវដកថយទើបបានព្រោះទ័ពយើងស្លាប់ច្រើនណាស់!»។

៣.២- ទំនាស់ទី២៖ ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ

- ទីកន្លែងទំនាស់៖ កំពង់ហៅ
- តួទំនាស់៖ ជំទាវស្រែន្យ និងស្តេចសម្រែ
- បញ្ហាទំនាស់៖ ដោយសារជំទាវស្រែន្យបានស្នើសុំតេជោមាសដែលជាស្វាមី និងជាមេទ័ពត្រួតត្រានៅខេត្តកំពង់ស្វាយ ដើម្បីរៀបចំផែនការកម្ចាត់ស្តេចសម្រែ។ ជំទាវស្រែន្យបានប្រើឧបាយកលធ្វើជាលែងលះជាមួយស្វាមី ហើយមកតាំងទីលំនៅនិងបើកផ្ទះលក់គ្រឿងទៀត លក់អាវុធនៅកំពង់ហៅ។ ដើម្បីទាក់ទាញទឹកចិត្តស្តេចសម្រែ ជំទាវស្រែន្យបានលក់ទំនិញក្នុងតម្លៃថោកចំពោះទ័ពស្តេចសម្រែ និងលក់ថ្លៃចំពោះទ័ពតេជោមាស រហូតធ្វើឱ្យស្តេចសម្រែចាប់ចិត្តប្រតិព័ទ្ធលើជំទាវស្រែន្យយ៉ាងខ្លាំង។ ក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គស្តេចសម្រែ៖ «អា៎! ជំទាវស្រែន្យ! ជំទាវស្រែន្យលែងប្តី! យី! ជំទាវស្រែន្យស្អាតណាស់។ ឱ! យើងចង់បានណាស់។ (ច្រៀង)ឮឈ្មោះនាងស្រែន្យ ចាប់ផ្តើមស្នេហា ចង់បានកន្និដ្ឋា រួមរក្សមេត្រី។ អង្គអញជាស្តេច ត្រូវមានមហេសី(២ដង)រូបស្អាតប្រិមប្រិយ ដូចទេពកញ្ញា។(និយាយ)អា៎! បើតាមស្តាប់ការរៀបរាប់ របស់ពួកអាមាត្យជំទាវស្រែន្យប្រាកដជាមានកូនចិត្តមកលើយើងមិនខាន ហាស! ហាស! ហា!»។
- ដំណោះស្រាយ៖ ជំទាវស្រែន្យរៀបចំឧបាយកលដើម្បីខ្លួនស្តេចសម្រែ ដោយបានអញ្ជើញស្តេចសម្រែឱ្យចូលរួមក្នុងពិធីមង្គលការក្មួយ។ ក្នុងឱកាសនោះ ជំទាវស្រែន្យបានដាក់ថ្នាំសណ្តំនៅក្នុងស្រានិងម្ហូបអាហារ ប្រើពាក្យសម្តីផ្អែមល្ហែមលួងលោមបន្ទន់ចិត្ត ចាក់ស្រាឱ្យស្តេចសម្រែផឹក រហូតត្រូវថ្នាំសណ្តំសន្លប់បាត់ស្មារតី។ តេជោមាសនិងយ៉ត បាននាំកងទ័ពមកចាប់ស្តេចសម្រែនិងបក្សពួក នាំយកទៅកាត់ទោសតាមច្បាប់នគរ។ ក្រុមបះបោររបស់ស្តេចសម្រែ ក៏បានបែកខ្ញែកគ្នាអស់ទៅ។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គជំទាវស្រែន្យ៖ «បង! ស្តេចសម្រែត្រូវថ្នាំសណ្តំសន្លប់ស្តូកទៅហើយ សូមបងចាត់ចែងទៅចុះ»។

៣.៣- ទំនាស់ទី៣៖ ការកម្ចាត់សត្រូវក្រោយខ្នង

- ទីកន្លែងទំនាស់៖ ខេត្តពោធិ៍សាត់
- តួទំនាស់៖ តេជោយ៉ត និងម៉ឺនចែចុងរ៉ាក់
- បញ្ហាទំនាស់៖ ក្នុងគ្រាពួកឈ្លើយសឹកសៀមបះបោរវាយដណ្តើមបានស្រុកពីរនៅខេត្តពោធិ៍សាត់ ហើយកំពុងតែមានកម្លាំងខ្លាំងក្លាថែមទៀតនោះ។ លោកឧកញ៉ាក្រឡាហោមនិងឧកញ៉ាចក្រីលើកទ័ពទៅបង្ក្រាប តែត្រូវបរាជ័យ។ ព្រះបាទជ័យចេស្តា បានត្រាស់បញ្ជាឱ្យតេជោយ៉ត កេណ្ឌពលនិងដឹកនាំកងទ័ពទៅបង្ក្រាបពួកឈ្លើយសឹកសៀមបះបោរ។ ក្នុងកេណ្ឌទ័ពនេះ ម៉ឺនចែចុងរ៉ាក់ត្រូវជាប្អូនអ្នកម្នាងនូនិងបក្សពួក ក៏ត្រូវជាប់ក្នុងកំណែនទ័ពនេះដែរ។ តេជោយ៉តយល់ច្បាស់ថា ការបរាជ័យក្នុងសង្គ្រាមរបស់លោកឧកញ៉ាក្រឡាហោមនិងឧកញ៉ាចក្រី គឺកើតឡើងដោយសារមានសត្រូវពីក្រោយខ្នង។ ដោយយល់ឃើញដូច្នេះទើបតេជោយ៉តរកវិធីកម្ចាត់សត្រូវក្រោយខ្នងមុននឹងធ្វើសឹកសង្គ្រាមកម្ចាត់សត្រូវចំពោះមុខ។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គតេជោយ៉ត៖ «ដូច្នេះពេលនេះ មុននឹងវាយខ្មាំងពីមុខ យើងត្រូវរកខ្មាំងពីក្រោយខ្នងជាមុនសិន»។
- ដំណោះស្រាយ៖ ដើម្បីកម្ចាត់សត្រូវក្រោយខ្នង តេជោយ៉តបានបញ្ជាឱ្យកងទ័ពទាំងអស់ទៅកាប់ឫស្សីយកមកសង់បន្ទាយ។ ពេលកាប់ឫស្សីបានហើយ មេទ័ពបញ្ជាឱ្យកងទ័ពទាំងអស់ អូសឫស្សីបញ្ច្រាសចុង។ ក្នុងចំណោមពលទ័ពទាំងអស់ គឺមានតែម៉ឺនចែចុងរ៉ាក់និងបក្សពួកល្មើសនឹងបទបញ្ជាមេទ័ព ត្រូវបានតេជោយ៉តចាត់ទុកថាជាសត្រូវក្រោយ ក៏នាំយកទៅ

សម្លាប់ចោល។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គម៉ឺនចៃចុងរ៉ាក់៖ «ពួកយើងជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិស្ដុកស្ដម្ភ មានមុខមាត់យើងត្រូវការសប្បាយហ៊ឺហា។ យើងអត់ត្រូវការគិតពីរឿងប្រទេសជាតិ រឿងនគរស្អីទេ។ បែបនេះយើងរង់ចាំតែឱកាសរត់ទៅព្រះរាជធានី ទៅរកអ្នកបងនូដើម្បីឱ្យរួចខ្លួនពីកំណែនសឹកប៉ុណ្ណោះ។ ដូច្នេះចាំបាច់គោរពបញ្ជាឱ្យនឿយហត់នាំអស់កម្លាំងធ្វើអីទៅរឺ! ឈប់គោរពទៅ។ ឥឡូវនេះប្រាប់ពួកយើងអូសឫស្សីបណ្ដោយទៅវិញមានម៉ែអាណាអូសបញ្ច្រាសចុងទេ ចាំមើលវាធ្វើអីខ្ញុំ។ ស្រេចនឹងខ្ញុំ!» និងតាមរយៈសម្ដីរបស់តួអង្គតេជោយ៉ត៖ «ខ្ញុំធ្លាប់ទទួលពាក្យមើលងាយថាជាជនជាតិភាគតិចអស់រយៈពេលជាងម្ភៃឆ្នាំមកហើយ។ តាំងពីខ្ញុំធំ ទើបតែពេលនេះខ្ញុំតាំងចិត្តលែងខឹងឱ្យសង្គមយល់ដឹងខ្លួនឯងតាមពេលវេលា ប៉ុន្តែអំពើរបស់ម៉ឺនចៃចុងរ៉ាក់នៅពេលនេះមិនមែនរឿងសង្គ្រាមវណ្ណៈទេ គឺពួកលោកជាសត្រូវក្រោយខ្នងរបស់ប្រទេសជាតិដែលខ្ញុំកំពុងតែរកមុខ» «យើងសម្លាប់មនុស្សដើម្បីច្បាំងឈ្នះសត្រូវយកសេចក្ដីសុខជូនប្រជាជនក្នុងនគរ»។

៣.៤- ទំនាស់ទី៤៖ ការប្រឆាំងនឹងអំពើបក្សពួកនិយម

- ទីកន្លែងទំនាស់៖ រាជធានីឧដុង
- តួទំនាស់៖ តេជោយ៉ត និងអ្នកម្នាងនូ
- បញ្ហាទំនាស់៖ អ្នកម្នាងនូមានការខឹងសម្បារចំពោះតេជោយ៉ត ដែលហ៊ានសម្លាប់ប្អូនប្រសបង្កើតរបស់ខ្លួន ហើយក៏បានទូលព្រះរាជាឱ្យនាំយ៉តមកកាត់ទោស។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គអ្នកម្នាងនូ៖ «តេជោយ៉តស្អីគេនោះ មានវណ្ណៈថោកទាបណាស់ មិនគួរព្រះស្វាមីប្រទានដាវអាជ្ញាសឹកឱ្យវាសោះ។ សូមព្រះអង្គព្រះតម្រិះមើល តេជោយ៉តនោះបញ្ជាឱ្យពលទាហានអូសឫស្សីបញ្ច្រាសចុង លោកប្អូនមិនព្រមធ្វើតាមទើបវាសម្លាប់ក្រាបទូល!» «ខ្ញុំម្ចាស់មិនសុខចិត្តទេ ក្រាបទូល!»។
- ដំណោះស្រាយ៖ ដំបូងឡើយតេជោយ៉តពុំបាន ចូលខ្លួនមកឱ្យគេកាត់ទោសតាមព្រះរាជបញ្ជារបស់ព្រះបាទជ័យចេស្ដាដែលជាព្រះមហាក្សត្រឡើយ ដោយសំអាងថាខ្លួនកំពុងជាប់ដៃនៅក្នុងសង្គ្រាម។ លុះស្ថានភាពបានធូរស្រាលបន្តិច លោកមេទ័ពក៏មកជួបនិយាយតទល់ជាមួយអ្នកម្នាងនូនៅឯព្រះរាជវាំងឧដុង។ លោកមេទ័ពតេជោយ៉ត បាននិយាយបកអាក្រាតពីអំពើបក្សពួកនិយម ស៊ីសំណូកសូកប៉ាន់ និងចាត់ទុកថាអ្នកម្នាងនូថា ជាជនក្បត់ជាតិ។ ជាចុងក្រោយ តេជោយ៉តក៏ប្រើស្នៀតគប់កូនដាវសម្លាប់អ្នកម្នាងនូចោលទៅ។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គតេជោយ៉ត៖ «កាលពីមុនឧកញ៉ាចក្រីនិងឧកញ៉ាក្រឡាហោមទៅកេណ្ឌពលទៅច្បាំងនោះ អ្នកម្នាងបានទៅកាត់យកឈ្មោះអ្នកជាប់កំណែនអស់រាប់រយនាក់ ដោយយកលេសថាសុទ្ធតែត្រូវជាបងប្អូន ជាសាច់ជាញាតិ។ ប៉ុន្តែតាមការពិតអ្នកម្នាងបានទទួលការសូកប៉ាន់របស់គេ។ អ្នកម្នាងស្រើបនឹងអំណាច ស្រើបនឹងទ្រព្យសម្បត្តិគិតតែពីចេញមុខធានា ឥតរវល់ដល់ផលវិបាកដែលធ្លាក់លើប្រទេសជាតិសោះ។ ហេតុដូចនេះហើយបានជាទ័ពលោកឧកញ៉ាទាំងពីរត្រូវបរាជ័យព្រោះទ័ពពុំគ្រប់ចំនួនតាមសំណូមពរហើយពលទាហានសុទ្ធតែធ្លាក់ទឹកចិត្តចំពោះអំពើអយុត្តិធម៌របស់អ្នកម្នាង»។ «អ្នកម្នាងនូក្បត់ជាតិពេញទី! ព្រោះពេលដែលខ្ញុំកំពុងជាប់ដៃនាំទ័ពប្រយុទ្ធជាមួយខ្មាំង អ្នកម្នាងគិតតែពីពិតទូលព្រះរាជាឱ្យផ្ញើសារហៅខ្ញុំមកទទួលទោសដោយទុកឱ្យពួកឈ្លើយសឹកសៀមវាយកម្ទេចកងទ័ពដែលគ្មានមេដឹកនាំ»។ «វិជ្ជាដែលលោកគ្រូបានបង្ហាត់ហ្វឹកហ្វឺនយើងគឺដល់កម្រិត

ខ្ពស់បំផុតគឺស្នៀតគុនផ្តាក់និងស្នៀតគប់កូនដាវ។ ទោះជាសត្រូវធុនណាក៏ដោយមិនអាចគេចផុតពីស្នៀតគប់អាវុធនេះបានដែរ។ ស្លាប់ទៅស្រីចង្រៃ!»។

៣.៥- ទំនាស់ទី៥៖ ការប្រយុទ្ធប្រឆាំងនឹងពួកបរទេសឈ្លានពាន

• ទីកន្លែងទំនាស់៖ ខេត្តពោធិ៍សាត់

• តួទំនាស់៖ កងទ័ពខ្មែរ(តេជោយ៉ត) និងកងទ័ពសៀម(មេទ័ពឈិត)

• បញ្ហាទំនាស់៖ ពួកឈ្លើយសឹកសៀមបះបោរវាយដណ្តើមយកបានស្រុកពីរនៅខេត្តពោធិ៍សាត់។ លោកឧកញ៉ាក្រឡាហោមនិងឧកញ៉ាចក្រីលើកទ័ពទៅបង្ក្រាប តែត្រូវបរាជ័យ។ ព្រះបាទជ័យចេស្តា បានត្រាស់បញ្ជាឱ្យតេជោយ៉តជាអ្នក កេណ្ឌកងទ័ពនិងដឹកនាំកងទ័ពទៅបង្ក្រាបពួកឈ្លើយសឹកសៀមបះបោរនោះវិញម្តង។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈបន្ទូលរបស់តួអង្គព្រះបាទជ័យចេស្តា៖ «ឥឡូវនេះ យើងមានកិច្ចការមួយយ៉ាងសំខាន់ដែលត្រូវប្រើលោក ដូចសេចក្តីក្នុងសារយើងដែលផ្ញើទៅអញ្ចឹង។ ពួកឈ្លើយសឹកសៀមដែលបះបោរបានវាយដណ្តើមយកបានស្រុកពីរនៅខេត្តពោធិ៍សាត់។ វាកំពុងមានកម្លាំងណាស់។ យើងបានចាត់ឱ្យឧកញ៉ាក្រឡាហោមនិងឧកញ៉ាចក្រីលើកទ័ពទៅបង្ក្រាបក៏នៅតែបរាជ័យទៀត។ ឥឡូវឮថា ពួកវាចូលមកយកបន្ទាយព្រះច័ន្ទរាជាធ្វើជាមូលដ្ឋានទ័ពទៀតហើយ ដោយមានយុទ្ធវិធីការពារយ៉ាងមាំមួន។ ដូច្នេះ តើលោកតេជោមានគំនិតគិតយ៉ាងម៉េចដែរ?»។

• ដំណោះស្រាយ៖ មេទ័ពតេជោយ៉ត ដឹកនាំទ័ពទៅធ្វើសឹកសង្គ្រាមជាមួយពួកឈ្លើយសឹកសៀមបះបោរ ដោយបានអនុវត្តទៅតាមតម្រាពិជ័យសង្គ្រាមគឺប្រកាន់ខ្ជាប់នូវលក្ខណៈ១២ប្រការដូចខាងក្រោម៖

## តម្រាក្បួនព្យូហ៍សឹកទាំង១២

១- ត្រូវស្គាល់ទីណាត់សម្រាប់លើកទ័ពជួបជុំគ្នាព្រមទាំងទីបង្កប់ទ័ពនិងទីសម្ងែងទ័ព។

២- ត្រូវស្គាល់ចិត្តពលទាហានឱ្យច្បាស់ តើពលទាហានទាំងនេះគោរពកោតខ្លាចនិងទុកចិត្តលើមេទ័ពហើយឬនៅ?

៣- ត្រូវស្គាល់ឱ្យច្បាស់នូវស្វរស័ព្ទក្បួនទ័ពសឹករបស់បច្ចាមិត្តដែលលើកចូលមក។

៤- មេទ័ពមិនត្រូវភ្ញាក់ផ្អើលនឹងស្វរស័ព្ទសន្ធឹកសឹកនិងស្វរសម្រែកសត្វ មនុស្ស ឬព័ត៌មានពាក្យចចាមអារាមផ្សេងៗនោះឡើយបើឮ ហើយត្រូវពិចារណាឱ្យយល់ច្បាស់។

៥- ត្រូវស្គាល់ស្ថានភាពធាតុអាកាស រដូវខ្យល់នៃតំបន់ទីដែលត្រូវចេញទៅប្រយុទ្ធនោះ។

៦- បើមុននឹងចូលច្បាំង ត្រូវស្គាល់ឱ្យច្បាស់នូវច្រកទិសទីសម្រាប់ចូលប្រយុទ្ធនិងដកថយ។

៧- ត្រូវចេះប៉ាន់ស្មាននូវកម្លាំងស្បៀងអាហាររបស់សត្រូវ និងស្បៀងអាហាររបស់ខ្លួនយើង។

៨- ត្រូវស្គាល់ឱ្យច្បាស់ប្រាកដនូវកម្លាំង គ្រឿងសាស្ត្រាវុធរបស់ខ្លួននិងរបស់សត្រូវ។

៩- ត្រូវស្គាល់ទីជយភូមិដែលនឹងត្រូវតាំងទីបន្ទាយរាយត្បាត។

១០- ត្រូវឱ្យស្ទាត់ស្ទាញ ប៉ិនប្រសប់ក្នុងការចាត់តាំងអ្នកយាមល្បាត គឺកុំទុកចិត្តគេឱ្យ

ហួសពីគំនិតរបស់ខ្លួនយើង។

១១- ត្រូវកាន់អាជ្ញាសឹកឱ្យរឹងមាំដូចផែនសិលា កុំត្រចៀកស្រាលឆាប់ជឿគេឥតពិចារណា។

១២- រីឯព្រះករុណាអម្ចាស់ជីវិតដែលត្រាស់ប្រើមេទ័ពឱ្យចេញទៅច្បាំងនោះត្រូវកាន់ពាក្យសត្យឱ្យមេទ័ពទុកចិត្តកុំព្រួយបារម្ភពីទ័ពក្រោយឱ្យសោះ។

មេទ័ពតេជោយ៉ត ដឹកនាំទ័ពធ្វើសឹកសង្គ្រាម ដោយអនុវត្តតាម «តម្រាក្បួនព្យុហ៍សឹកទាំង១២»បានល្អប្រសើរ រហូតទទួលបានជោគជ័យក្នុងបង្ក្រាបឈ្លើយសឹកបរទេសឈ្លានពានបះបោរ។ ជាក់ស្តែងសាច់រឿងបង្ហាញតាមរយៈសម្តីរបស់តួអង្គតេជោយ៉ត៖ «ព្រះករុណាថ្លៃវិសេស! ពួកឈ្លើយសឹកសៀមរាប់ម៉ឺននាក់នោះគឺបន្សល់ទុកមកពីចម្បាំងរវាងនគរនិងនគរ។ ដូច្នេះជាភារកិច្ចរបស់មេទ័ពហ្លួងទេដែលត្រូវចេញទៅបង្ក្រាប។ ក្នុងតម្រាពិជ័យសង្គ្រាមចែងថា ដើម្បីដណ្តើមជ័យជម្នះពីខ្មាំងសត្រូវបាន មេទ័ពម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវលក្ខណៈ១២ប្រការ។ លោកឧកញ៉ាក្រឡាហោមនិងលោកឧកញ៉ាចក្រីប្រហែលមានការធ្វេះធ្លោយលើប្រការណាមួយហើយទើបត្រូវបរាជ័យយ៉ាងនេះ។ ដូច្នេះ ថ្វីបើទូលព្រះបង្គំជាមេទ័ពមកពីអាណាខេត្តមែន ប៉ុន្តែដើម្បីប្រទេសជាតិ ទូលព្រះបង្គំស្ម័គ្របម្រើជាតិជានិច្ចក្រាបទូល!»។ ព្រះករុណាថ្លៃវិសេស! លក្ខណៈ១០ប្រការខាងដើម ទូលព្រះបង្គំអាចអនុវត្តបានដោយខ្លួនឯង។ ប៉ុន្តែលក្ខណៈទី១១ និងទី១២ លុះត្រាតែមានព្រះរាជអនុញ្ញាតពីព្រះអង្គទើបទូលព្រះបង្គំជាខ្ញុំអាចដណ្តើមយកជោគជ័យពីខ្មាំងសត្រូវបានក្រាបទូល!»។ «ទី១ សូមព្រះអង្គព្រះរាជទានអាជ្ញាសឹកដល់ទូលព្រះបង្គំលុះត្រាតែចប់សង្គ្រាម។ ទី២ សូមព្រះករុណាទ្រង់ព្រះតម្រិះយ៉ាងណាកុំឱ្យទូលព្រះបង្គំព្រួយកង្វល់ពីសត្រូវនៅខាងក្រោយខ្នងឱ្យសោះ។ ព្រោះសត្រូវពីមុខយើងមើលឃើញ ងាយទប់ទល់ ឯសត្រូវពីក្រោយយើង មើលមិនឃើញទេ។ បើរវល់តែទប់ទល់ជាមួយសត្រូវពីក្រោយហើយទូលព្រះបង្គំពុំអាចយកជ័យជម្នះលើខ្មាំងទេក្រាបទូល!»។

៣.៦- ទំនាស់ទី៦៖ ការហ៊ានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន

- ទីកន្លែងទំនាស់៖ រាជធានីឧដុង
- តួទំនាស់៖ តេជោយ៉ត និងព្រះបាទជ័យចេស្តា
- បញ្ហាទំនាស់៖ ដោយសារតេជោយ៉តបានសម្លាប់ម៉ឺនចៃចុងរ៉ាក់ដែលត្រូវប្អូនថ្លៃរបស់ព្រះបាទជ័យចេស្តា និងអ្នកម្នាងនូ ដែលជាស្រីស្នំរបស់ព្រះចៅចេស្តា ហើយបានសន្យាថានឹងប្រគល់ខ្លួនឱ្យព្រះបាទជ័យចេស្តាជាព្រះមហាក្សត្រកាត់ទោសបន្ទាប់ពីចប់សង្គ្រាម។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈបន្ទូលរបស់តួអង្គតេជោយ៉ត៖ «លោកត្រឡប់ទៅបន្ទាយភ្លាមហើយលោកចាត់ឱ្យគេធ្វើឃ្នាងមួយប្រវែងប្រាំបីហត្ថលាបហឹង្គុរ មានច្រវាក់ដៃនិងជើងទាំងបួនសព្វគ្រប់ផងណា!» «ដាក់ខ្លួនខ្ញុំផ្ទាល់!»។
- ដំណោះស្រាយ៖ លុះបង្ក្រាបពួកឈ្លើយសឹកសៀមឈ្លានពាន ទទួលបានជោគជ័យរួចមក តេជោយ៉តចូលខ្លួនឱ្យស្តេចកាត់ទោសតាមពាក្យសន្យា ដោយបំពាក់ឃ្នាងខ្លួនឯង ហើយដើរចូលមកក្នុងបរមរាជវាំង ដើម្បីថ្វាយដាវអាជ្ញាសឹកវិញ។ ប៉ុន្តែព្រះរាជាបានលើកលែងទោសឱ្យតេជោយ៉ត ព្រោះដឹងពីទង្វើអាក្រក់របស់អ្នកម្នាងនូ។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈបន្ទូលរបស់តួអង្គព្រះចៅជ័យចេស្តា៖ «ហ៊ឺះ! វាឱ្យគេបំពាក់ឃ្នាំងមកទទួលទោស។ ហ៊ឺះ! អាយ៉

តចំជាក្លាហានមែន។ ស្តេចគិតម្នាក់ឯង«ប្រជាជនអស់ទាំងនគរនៃអាណាប្រជានុរាស្ត្រសុទ្ធតែបានដឹងថាអ្នកម្នាងទ្រង់ប្រព្រឹត្តអំពើក្បត់ជាតិ។ ដូច្នេះបើយើងសម្លាប់អាយ៉តខ្លាចក្រែងគេនិន្ទា» លោកចក្រីយើងមិនចង់ឃើញមុខអាយ៉តទេ។ លោកត្រូវទៅប្រាប់សម្តេចចៅហ្វាទឡ្ហៈឱ្យទទួលយកងារអាជ្ញាសឹកពីវា ហើយដោះឃ្នាងឱ្យវានិងបណ្តេញវាឱ្យចេញពីវាំងត្រឡប់ទៅត្រួតដែនកំពង់ស្វាយដូចដើមវិញចុះ»។

៣.៧- ទំនាស់ទី៧៖ ការទម្លុះជញ្ជាំងវណ្ណៈស្នេហា

- ទីកន្លែងទំនាស់៖ ខេត្តកំពង់ស្វាយ
- តួទំនាស់៖ តេជោយ៉ត និងជំទាវស្រែន
- បញ្ហាទំនាស់៖ តេជោយ៉តចាប់ចិត្តស្នេហាចង់បានជំទាវស្រែនឲ្យមកធ្វើជាភរិយាតែត្រូវបានជំទាវស្រែនឲ្យបដិសេធ ទោះបីតេជោយ៉តបានពឹងពាក់ចាស់ទុំឱ្យចូលស្តីដណ្តឹងជាច្រើនលើកក៏ដោយ។ បញ្ហានេះមិនមែនមានន័យថាជំទាវស្រែនឲ្យមិនស្រឡាញ់តេជោយ៉តនោះទេ តែនាងគិតថាយ៉តធ្លាប់ជាបាវបម្រើរបស់ខ្លួន ហើយថែមទាំងមានកំណើតជាកូនជនជាតិភាគតិចក្នុងទៅទៀត បើនឹងរៀបការជាមួយច្បាស់ជាអ្នកផង និន្ទាសើចចំអកជាមិនខាន។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈបន្ទូលរបស់តួអង្គជំទាវស្រែនឲ្យ៖ «ហ៊ឺ! ពិបាកចិត្តណាស់! យ៉តពឹងពាក់ចាស់ទុំឱ្យចូលមកស្តីដណ្តឹងខ្ញុំពីរបីសារទៅហើយ។ យី! គិតយ៉ាងម៉េចអ៊ីចេះ! ខ្ញុំដូចជាពុំយល់សោះ។ គិតមិនលេចសោះ។ (ច្រៀង)អាណិតស្រឡាញ់ ពេញក្នុងចិន្តា អឺយ ពេញចិត្ត ប៉ុន្តែអឺយ ចាប់ស្រវាពុំបានអឺយ ទទួលពុំបាន អឺយ ពីព្រោះខ្ញុំៗខ្មាស់អៀន អឺយ ខ្មាសអៀនញាតិសន្តាន អឺយ យើងទាំងពីរប្រាណៗ អឺយ វណ្ណៈខុសគ្នា អឺយ វណ្ណៈខុសគ្នា ខ្លួនអឺយៗចម្លែងថ្លៃ អឺយខ្ញុំវែងថ្លែងប្រាប់នរណា បើខ្ញុំអឺយហានក្លា អ្នកផងសើចនិន្ទា អឺយ ទុក្ខញាំញី អឺយ ប្រកែកវែកទុក្ខគ្រាំគ្រា អូយ ម្តេចក៏ពុំងារពារចាប់ស្រវា ឱប្រុសជីវាស្នេហាខ្ញុំអឺយ...។ (និយាយ)ហ៊ឺ! យ៉តជាបុរសមានឧត្តមគតិស្នេហាជាតិនិងលក្ខណសម្បត្តិថ្លៃថ្នូរដូចស្វាមីខ្ញុំគ្រប់យ៉ាង ប៉ុន្តែគេជាអតីតបាវបម្រើ ដូច្នេះបើរៀបការជាមួយយ៉តច្បាស់ជាអ្នកផងសើចនិន្ទាខ្ចរខ្ចាពេញនគរមិនខាន»។
- ដំណោះស្រាយ៖ តេជោយ៉តបានប្រារព្ធធ្វើបុណ្យធ្វើបុណ្យរំលឹកដល់វិញ្ញាណក្ខន្ធតេជោមាស។ ក្នុងពិធីបុណ្យនេះ គេបានរៀបចំដាក់តាំងព្រះពុទ្ធរូប និងរូបសំណាកតេជោមាសធ្វើអំពីឈើដែលដែលតេជោយ៉តបានបញ្ជាឱ្យកូនចៅលួចយកកាំជណ្តើរផ្ទះជំទាវស្រែនឲ្យមកឆ្លាក់។ នៅក្នុងពិធីបុណ្យ ជំទាវស្រែនឲ្យបានថ្វាយបង្គំរូបសំណាកនោះ។ តេជោយ៉ត បានឱ្យកាសល្អក៏បកស្រាយថារូបសំណាកនេះ ធ្វើពីឈើកាំជណ្តើរផ្ទះរបស់លោកជំទាវ គឺលោកជំទាវកំពុងតែថ្វាយបង្គំកាំជណ្តើរផ្ទះរបស់ខ្លួនដែលបានជាន់រាល់ថ្ងៃហើយ។ ជំទាវស្រែនឲ្យមានស្មារតីភ្ញាក់រឭក ឈប់រើសអើងប្រកាន់វណ្ណៈ ហើយយល់ព្រមរៀបការជាមួយតេជោយ៉ត។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គជំទាវស្រែនឲ្យ៖ «ខ្ញុំអាណិតនិងស្រឡាញ់យ៉តលើសដើមទៅទៀត។ ប៉ុន្តែដោយសារមានគំនិតប្រកាន់វណ្ណៈទើបចេះតែប្រកែក។ ឥឡូវនេះខ្ញុំលែងស្ទាក់ស្ទើរក្នុងចិត្តទៀតហើយ។ ជាពិសេសការប្រកាន់ពូជសាសន៍ គឺជាគំនិតអយុត្តិធម៌ជាទីបំផុត។ ឧទាហរណ៍ដូចរូបអ្នកដែលមានដើមកំណើតជាជនជាតិភាគតិច ប៉ុន្តែស្មារតីស្នេហាជាតិរបស់យ៉តខ្ពង់ខ្ពស់ជាទីបំផុត អឺ...វីរភាពរបស់អ្នកឧត្តុង្គឧត្តមណាស់សម្រាប់ទំព័រសាវតាររបស់នគរកម្ពុជាយើងនេះណា៎!»។

**៤- វិភាគតួអង្គ (គុណសម្បត្តិ និងគុណវិបត្តិ )**

៤.១- តេជោមាស

- គុណសម្បត្តិ៖
  - o មានចំណេះវិជ្ជាខាងសឹកសង្គ្រាមល្អប្រសើរ និងមានវិជ្ជាគុនខ្លាំងពូកែ
  - o ជាមេទ័ពអង់អាចក្លាហាន មានឧត្តមគតិស្នេហាជាតិមាតុភូមិ បម្រើជាតិដោយស្មោះត្រង់ និងហ៊ានលះបង់ជីវិតដើម្បីបុព្វហេតុជាតិ
  - o ស្អប់ខ្ពើមនិងប្រឆាំងដាច់ខាតចំពោះអំពើឈ្លានពានរបស់ពួកបរទេសជាពិសេសប្រទេសសៀម
  - o មិនរើសអើងវណ្ណៈ ជនជាតិ មានចិត្តសប្បុរសធម៌ មានគុណធម៌
  - o បណ្តុះបណ្តាលសិស្សបានល្អ មានព្រហ្មវិហារធម៌ចំពោះសិស្ស និងចេះគិតគូពីអនាគតសិស្ស
  - o ឱ្យតម្លៃស្ត្រីខ្ពស់ និងមានភក្តីភាពចំពោះភរិយា។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គតេជោមាស៖ «ចាំទុកណា យើងត្រូវធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីប្រទេសជាតិ មិនមែនបម្រើបុគ្គលណាម្នាក់ទេ ទោះជាស្តេចផែនដីក៏ដោយ បើប្រព្រឹត្តិអំពើអ្វីដែលផ្តល់គ្រោះមហន្តរាយដល់មាតុភូមិ យើងក៏តោងហ៊ានប្រឆាំងដែរ»។

- គុណវិបត្តិ៖
  - o មើលងាយសត្រូវ មានការធ្វេសប្រហែសក្នុងការធ្វើសឹកសង្គ្រាម រហូតធ្វើឱ្យបរាជ័យនៅក្នុងការបង្ក្រាបចលនាបះបោរ
  - o ខ្វះការប្រុងប្រយ័ត្ននាំឱ្យភ្លាត់ស្នៀត បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរដោយសារសត្រូវវាយ រហូតធ្លាក់ខ្លួនឈឺបាត់បង់ជីវិត។

៤.២- តេជោយ៉ត

- គុណសម្បត្តិ៖
  - o ជាមេទ័ពខ្លាំងពូកែចេះវិជ្ជាគុន និងមានចំណេះវិជ្ជាខាងសឹកសង្គ្រាមខ្ពង់ខ្ពស់
  - o ជាមេទ័ពអង់អាចក្លាហាន មានឧត្តមគតិស្នេហាជាតិមាតុភូមិ បម្រើជាតិដោយស្មោះត្រង់ និងហ៊ានលះបង់ជីវិតដើម្បីបុព្វហេតុជាតិ
  - o ស្អប់ខ្ពើមនិងប្រឆាំងដាច់ខាតចំពោះអំពើឈ្លានពានរបស់ពួកបរទេសជាពិសេសប្រទេសសៀម
  - o ស្រលាញ់យុត្តិធម៌ ប្រឆាំងនឹងអំពើបក្សពួកនិយម និងអំពើពុករលួយស៊ីសំណូកប៉ាន់
  - o ជាមនុស្សឆ្លាតឈ្លាសវៃ រហ័សរហួន ឆាប់យល់ហេតុការណ៍ និងល្បិចកលរបស់

សត្រូវ មានយុទ្ធវិធីខ្ពស់ក្នុងការកម្ចាត់សត្រូវក្រោយខ្នង

- o តស៊ូអំណត់ជម្នះរាល់ការមើលងាយ មើលថោកពីអ្នកដទៃ ព្រោះតែខ្លួនជាជនជាតិភាគតិចព្នង
- o ចេះរកវិធីដើម្បីជម្នះបានលើគំនិតរើសអើងប្រកាន់វណ្ណៈ
- o ជាសិស្សមានចិត្តកតញ្ញូ គោរពដឹងគុណគ្រូជានិច្ច ទោះបីគ្រូបានទទួលមរណភាពហើយក៏ដោយ
- o ជាបុរសឱ្យតម្លៃស្ត្រីខ្ពស់លើចរិយាធម៌ ដោយសុខចិត្តរៀបការជាមួយស្ត្រីបែបនេះ ទោះបីជាស្ត្រីម៉េម៉ាយក៏ដោយ។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គតេជោយ៉ត៖ «ដូចអស់លោកជ្រាបអស់ហើយ តាំងតែពីដើមមក សៀមតែងតែលើកទ័ពមករំលោភបំពានបង្កសង្គ្រាមវាយដណ្តើមយកអាណាខេត្តនានានិងទ្រព្យសម្បត្តិដ៏មានតម្លៃផ្សេងៗពីកម្ពុជាយើងស្ទើរគ្រប់សម័យកាល។ លើសពីនេះប្រជាជនយើងតែងរងគ្រោះវេទនាយ៉ាងខ្លោចផ្សា គួរឈឺចាប់ជាទីបំផុតដោយសារអំពើរំលោភរបស់សៀម។ ពេលនេះបើយើងបណ្តោយឱ្យពួកឈ្លើយសឹកបះបោរដូចនេះមានមូលដ្ឋានទ័ព ហើយចេញមុខប្រឆាំងយ៉ាងដូច្នេះមិនយូរមិនឆាប់ព្រះថៅក្រុងឰយុធ្យានឹងលើកទ័ពមកជួយពួកវាជាមិនខាន។ ដល់ពេលនោះសង្គ្រាមរវាងនគរនិងនគរមុខជាផ្ទុះទៀតហើយ។ សូមបងប្អូនទាំងអស់គ្នាប្តេជ្ញា! (កងទ័ពទាំងអស់ស្រែកប្តេជ្ញាបន្ទរព្រមៗគ្នា)។ (ច្រៀងរួមគ្នា)កងទ័ពកម្ពុជាប្តេជ្ញាការពារទឹកដី(២ដង)កម្ចាត់ចោរថៃឱ្យវាខ្ចាត់ខ្ចាយ(២ដង)ប្រជាទាំងអស់រស់នៅសប្បាយ(២ដង)រុងរឿងវែងឆ្ងាយផុតពីចម្បាំង(២ដង)»។

- គុណវិបត្តិ៖
  - o យកភរិយារបស់លោកគ្រូដែលធ្លាប់ចិញ្ចឹមបីបាច់ខ្លួន ហើយជាមនុស្សដែលខ្លួនធ្លាប់គោរពដូចជាម្តាយ មកធ្វើជាប្រពន្ធ
  - o មានគំនិតជាចោរ ហ៊ានលលួចកាំជណ្តើរផ្ទះគេ ដើម្បីសម្រេចបំណងស្នេហារបស់ខ្លួន។

៤.៣- ជំទាវស្រែន្យ

- គុណសម្បត្តិ៖
  - o ជាស្ត្រីឆ្នើមមានគំនិតឆ្លាតវាងវៃ ចេះរកវិធីកម្ចាត់សត្រូវជូនជាតិមាតុភូមិដោយមិនបានធ្វើសង្គ្រាមបង្ហូរឈាមឡើយ
  - o មានសមត្ថភាពខ្ពស់ និងចេះជួយស្វាមីក្នុងគ្រាមានអាសន្ន
  - o មានរូបសម្បត្តិ ចរិយាសម្បត្តិ និងសម្ថភាពល្អប្រពៃ
  - o មានភក្តីភាព និងចេះរៀបចំទំនុកបម្រុងគ្រប់បែបយ៉ាងចំពោះស្វាមី

o គោរពប្រតិបត្តិព្រះពុទ្ធសាសនាបានល្អប្រសើរ។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គតេជោមាសៈ «និយាយលាក់បាំងអី តាំពីអូនរៀបចំឧបាយកលជួយបងឱ្យចាប់ស្ដេចសម្រែបានមកនោះ បងយល់ថា អូនមិនត្រឹមតែជាភរិយាគ្រប់លក្ខណ៍របស់បងប៉ុណ្ណោះទេ ថែមទាំងជាកំពូលស្រីម្នាក់ដែលកម្ររកបានណាំអូនណាំ! (ច្រៀង)មាសអឺយមាសស្នេហ៍ ដូចខែពេញបូរមី(២ដង)អូនល្អលើសអស់ស្រី(២ដង)នៅក្នុងលោកា ប្រាជ្ញាអូនវាងវៃជាសមុតថ្លា(២ដង)អូនអាចប្រហារ(២ដង)ពួកក្បត់ជាតិបាន»។

- គុណវិបត្តិៈ
  - o មានគំនិតរើសអើងជនជាតិ និងប្រកាន់វណ្ណៈ
  - o យកសិស្សស្វាមីខ្លួនឯងធ្វើជាស្វាមី។

៤.៥- ស្ដេចសម្រែ

- គុណសម្បត្តិៈ

o មានវិជ្ជាគុនខ្លាំងពូកែ មានសមត្ថភាពបង្កើតជាអង្គការចាត់ចលនាបះបោរដោយមានរចនាសម្ព័ន្ធគ្រប់គ្រងមួយរួមមានទាំងកងទ័ពតាមទម្រង់ជារបបរាជានិយម ហើយប៉ុនប៉ងផ្ដួលរំលំដណ្ដើមអំណាចពីរាជរដ្ឋាភិបាលស្របច្បាប់ដែលដឹកនាំព្រះបាទជ័យចេស្ដា។

o មានសមត្ថភាពក្នុងការឃោសនាបញ្ចុះបញ្ចូលប្រជារាស្ត្រដើម្បីកេណ្ឌទ័ព ប្រមូល រៃអង្គាសស្បៀង

o ចេះយុទ្ធសាស្ត្រសឹកសង្គ្រាម និងស៊ើបការណ៍ពីកម្លាំងសត្រូវមុនប្រយុទ្ធ ចេះពិនិត្យមើលប្រៀបខ្លាំងនិងចំណុចខ្សោយរបស់សត្រូវ។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គស្ដេចសម្រែៈ «តាំងនាមខ្លួនឯងថាព្រះសម្រែរាជាធិរាជ មិនយូរមិនឆាប់យើងនឹងបានគ្រប់គ្រងរាជ្យជាស្ដេចនៅអាណាចក្រកម្ពុជាទាំងមូលមិនខាន(ច្រៀង) ដើមឡើយជារាស្ត្រ ស្រុកក្រាំងសម្រែ ឥឡូវពូកែ ដោយចេះវិជ្ជា(២ដង) តាំងខ្លួនជាស្ដេចមានកងយោធា ល្បីល្បាញខ្ទរខ្ទារ អឺយ...កៀរកេណ្ឌពលរដ្ឋ»។

- គុណវិបត្តិៈ
  - o មានមហិច្ឆតាលោភលន់ចង់បានអំណាចធ្វើជាស្ដេចផែនដី
  - o គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន

o បង្កើតចលនាបះបោរខុសច្បាប់ បង្កអសន្តិសុខក្នុងប្រទេស ធ្វើឱ្យប្រជារាស្ត្ររងទុក្ខវេទនា

o ជាអ្នកដឹកនាំលង់នឹងសម្រស់ស្រី ងប់ងល់នឹងកាមតណ្ហា ខ្វះការគិតពិចារណា រហូតធ្វើឱ្យចាញ់ឧបាយកលស្ត្រី កើតសេចក្ដីអន្តរាយដល់អាយុជីវិត ព្រមទាំងរលាយក្រុម

ចលនាបះបោរ។

៤.៥- ព្រះចៅជ័យចេស្តា

- គុណសម្បត្តិ៖
  - o ជាព្រះមហាក្សត្រមានឧត្តមគតិស្នេហាជាតិ ចេះគិតគូរពីផលប្រយោជន៍ប្រទេសជាតិជាតិជាធំ
  - o បង្ក្រាបចលនាបះបោរខុសច្បាប់បង្កចលាចល បង្កអសន្តិសុខក្នុងសង្គម ដើម្បីប្រជារាស្ត្រនិងនគរបានសុខសាន្ត
  - o ប្រឆាំងរាល់ការឈ្លានពានរបស់ពួកបរទេសជាពិសេសពួកសៀមឈ្លានពាន
  - o ជាអ្នកដឹកនាំចេះស្តាប់និងធ្វើតាមយោបល់មន្ត្រីក៏ដូចជាមេទ័ព
  - o មានការយល់ដឹងពីកំហុសនិងមានការភ្ញាក់រឭកក្នុងការសម្រេចចិត្តបានត្រឹមត្រូវទាន់ពេលវេលា។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈបន្ទូលរបស់តួអង្គស្តេចព្រះចៅជ័យចេស្តា៖ « ឥឡូវនេះ យើងមានកិច្ចការមួយយ៉ាងសំខាន់ដែលត្រូវប្រើលោក ដូចសេចក្តីក្នុងសារយើងដែលផ្ញើទៅអញ្ចឹង។ ពួកឈ្លើយសឹកសៀមដែលបះបោរ បានវាយដណ្តើមយកបានស្រុកពីរនៅខេត្តពោធិ៍សាត់។ វាកំពុងមានកម្លាំងណាស់។ យើងបានចាត់ឱ្យឧកញ៉ាក្រឡាហោមនិងឧកញ៉ាចក្រីលើកទ័ពទៅបង្ក្រាបក៏នៅតែបរាជ័យទៀត។ ឥឡូវឮថា ពួកវាចូលមកយកបន្ទាយព្រះច័ន្ទរាជាធ្វើជាមូលដ្ឋានទ័ពទៀតហើយ ដោយមានយុទ្ធវិធីការពារយ៉ាងមាំមួន។ ដូច្នេះ តើលោកតេជោមានគំនិតគិតយ៉ាងម៉េចដែរ?»។

- គុណវិបត្តិ៖
  - o ងប់ងល់នឹងស្រីស្នំ លង់នឹងអារម្មណ៍ស្នេហា បំពេញបំណងស្រីស្នំដោយមិនបានគិតពិចារណាអ្វីទាំងអស់
  - o ឆាប់ជឿតាមបញ្ចុះបញ្ចូលរបស់ស្រីស្នំ ដោយមិនបានត្រិះរិះពិចារណាឱ្យបានច្បាស់លាស់។

៤.៦- អ្នកម្នាងនូ

- គុណសម្បត្តិ៖
  - o ស្រលាញ់និងការពារបងប្អូនញាតិមិត្ត។
- គុណវិបត្តិ៖
  - o មានគំនិតបក្សពួកនិយម ពុករលួយ កេងប្រវ័ញ្ច ស៊ីសំណូកសូកប៉ាន់ ស្រលាញ់អំណាច លោភលន់នឹងទ្រព្យសម្បត្តិ
  - o គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ជាងប្រយោជន៍ជាតិ
  - o មានគំនិតញុះញង់ដើម្បីក្រុមគ្រួសារខ្លួន មិនបានគិតគូរពីសេចក្តីអន្តរាយដែលកើត

ឡើងចំពោះប្រទេសជាតិ

- មើលងាយអ្នកមានឋានៈតូចទាបជាងខ្លួន។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គតេជោយ៉ត៖ «កាលពីមុនឧកញ៉ាចក្រីនិងឧកញ៉ាក្រឡាហោមទៅកេណ្ឌពលទៅច្បាំងនោះ អ្នកម្នាងបានទៅកាត់យកឈ្មោះអ្នកជាប់កំណែនអស់រាប់រយនាក់ដោយយកលេសថាសុទ្ធតែត្រូវជាបងប្អូន ជាសាច់ជាញាតិ។ ប៉ុន្តែតាមការពិតអ្នកម្នាងបានទទួលការសូកប៉ាន់របស់គេ។ អ្នកម្នាងស្រវឹងនឹងអំណាច ស្រវឹងនឹងទ្រព្យសម្បត្តិគិតតែពីចេញមុខធានា ឥតរវល់ដល់ផលវិបាកដែលធ្លាក់លើប្រទេសជាតិសោះ។ ហេតុដូចនេះហើយបានជាទ័ពលោកឧកញ៉ាទាំងពីរត្រូវបរាជ័យព្រោះទ័ពពុំគ្រប់ចំនួនតាមសំណូមពរហើយពលទាហានសុទ្ធតែធ្លាក់ទឹកចិត្តចំពោះអំពើអយុត្តិធម៌របស់អ្នកម្នាង។

៤.៧- នាងម៉ែ

- គុណសម្បត្តិ៖
  - មានរូបសម្ផស្សស្អាត មានទ្រព្យសម្បត្តិ
  - មិនរើសអើងវណ្ណៈ
  - មានស្នេហាស្មោះត្រង់
  - ក្លាហានហ៊ានសារភាពប្រាប់ពីដួងចិត្តពិត
  - មានចិត្តទូលំទូលាយ ទទួលស្គាល់ការពិត មិនមានគំនុំគុំគួនទោះបីជាដឹងថាខ្លួនទទួលបរាជ័យក្នុងរឿងស្នេហាក៏ដោយ។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គនាងម៉ែ៖ «អាំ! នេះពិតជាគំនិតវីរបុរសមែន។ បងយ៉តខ្ញុំសូមសំពះសូមបងធ្វើជាបងធម៌រហូតអស់មួយជីវិតណាបងណា!»។

- គុណវិបត្តិ៖
  - មិនគិតខ្លួនជាស្រី ហ៊ានពោលពាក្យស្នេហាប្រាប់បុរសមុន
  - ចង់បួសព្រោះរឿងស្នេហា។

៤.៨- ម៉ឺនចៃចុងវ៉ាក់

- គុណសម្បត្តិ៖
  - កូនអ្នកមានទ្រព្យសម្បត្តិនៅខេត្តលង្វែក និងជាប្អូនថ្លៃរបស់ស្ដេច
  - ចេះជួយបក្សពួករបស់ខ្លួន។
- គុណវិបត្តិ៖
  - ល្មើសនឹងបទបញ្ជាកងទ័ព បបួលបក្សពួកគេចវេះពីកាតព្វកិច្ចកងទ័ព ដោយអាងលើខ្សែស្រឡាយបក្សពួកនិយម
  - មានចរិតក្អេងក្អាងតម្លើងឫក អាងខ្លួនជាត្រកូលអភិជន
  - ក្លាយខ្លួនជាសត្រូវក្រោយខ្នងរបស់កងទ័ព រហូតត្រូវមេទ័ពសម្លាប់ ព្រមទាំងបង្ក

មហន្តរាយដល់អាយុជីវិតរបស់បងថែមទៀត។

ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គម៉ឺនចៃចុងរ៉ាក់៖ «ពួកយើងជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិស្ដុកស្ដម្ភ មានមុខមាត់យើងត្រូវការសប្បាយហ៊ឺហា។ យើងអត់ត្រូវការគិតពីរឿងប្រទេសជាតិ រឿងនគរស្អីទេ។ បែបនេះយើងរង់ចាំតែឱកាសរត់ទៅព្រះរាជធានី ទៅរកអ្នកបងនូដើម្បីឱ្យរួចខ្លួនពីកំណែនសឹកប៉ុណ្ណោះ។ ដូច្នេះចាំបាច់គោរពបញ្ជាឱ្យនឿយហត់នាំអស់កម្លាំងធ្វើអីទេវ៉ី! ឈប់គោរពទៅ។ ឥឡូវនេះប្រាប់ពួកយើងអូសឫស្សីបណ្ដោយទៅវិញមានម៉ែអាណាអូសបញ្ច្រាសចុងទេ ចាំមើលវាធ្វើអីខ្ញុំ។ ស្រេចនឹងខ្ញុំ!»។

### ៥- ឧត្ដមគតិរឿង

រឿងតេជោយ៉តពិតជាផ្ដល់នូវឧត្ដមប្រយោជន៍យ៉ាងជ្រាលជ្រៅចំពោះអ្នកអាន អ្នកស្ដាប់ អ្នកទស្សនា ឬអ្នកសិក្សាទូទៅ។ តម្លៃអប់រំខ្លះធ្វើការបង្ហាញដោយត្រង់ៗ ហើយខ្លះទៀតទាមទារឱ្យគិតពិចារណាឱ្យបានម៉ត់ចត់ទើបអាចទាញតម្លៃអប់រំនោះបាន។ ដូច្នេះឧត្ដមគតិរឿងមានដូចតទៅ៖

- បណ្ដុះស្មារតីដល់កូនខ្មែរគ្រប់រូបឱ្យមានឆន្ទៈ ទឹកចិត្តស្រឡាញ់ ការពារ និងលើកស្ទួយប្រទេសជាតិខ្លួន។
- បុគ្គលគ្រប់រូបត្រូវមានទំនួលខុសត្រូវចំពោះភារកិច្ច និងដោះស្រាយបញ្ហាចំពោះមុខដោយភាពឆ្លាតវៃ។
- ពញ្ជាក់ស្មារតីដល់សង្គមខ្មែរអំពីតម្លៃស្ត្រីចំពោះការចូលរួមកិច្ចការប្រទេសជាតិ។
- ត្រូវមានចិត្តកតញ្ញូ ចេះដឹងគុណ តបគុណ ចំពោះបុគ្គលធ្វើគុណលើ។
- ចេះប្រើប្រាស់ចំណេះដឹងរបស់ខ្លួនក្នុងផ្លូវត្រូវ ព្រោះជាវិថីនាំខ្លួនទៅរកឧត្ដមភាព។
- ស្វាមី ភរិយាគ្រប់រូបត្រូវចេះឱ្យតម្លៃ និងធ្វើការពិភាក្សាជួយទុក្ខធុរៈគ្នា។
- អប់រំឱ្យមន្ត្រីរាជការទូទៅ គួរជៀសវាងអំពើបក្សពួកនិយម ពុករលួយ ស៊ីសំណូកសូកប៉ាន់ផ្សេងៗ ព្រោះវាអាចបង្កបាតុភាពអសកម្ម ឬអសន្តិសុខដល់សង្គម។
- ជៀសវាងការរើសអើងជនជាតិ ការប្រកាន់វណ្ណៈ ហើយចេះយល់ពីតម្លៃពិតរបស់មនុស្សទើបត្រឹមត្រូវ។
- អប់រំដឹកនាំ ឱ្យមានភាពប៉ិនប្រសប់ក្នុងការបំពេញភារកិច្ចដោយចេះពិនិត្យមើលគម្ពីរក្បួនខ្នាត សិក្សាស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងចាប់ផ្ដើមអនុវត្ត
- ជៀសវាងការឈ្លក់វង្វេងនឹងសម្រស់ស្រី ងប់ងល់នឹងកាមតណ្ហា ខ្វះគំនិតពិចារណាដែលនាំឱ្យអន្តរាយដល់ខ្លួន។

## គ- អត្ថរូប

### ១- វិធីតែងនិពន្ធ

អ្នកនិពន្ធតាក់តែងរឿងតេជោយ៉តជាប្រភេទល្ខោនបាសាក់ ដោយប្រើប្រាស់ភាសាពាក្យពេចន៍ខ្មែរតាមប្រភេទរឿងល្ខោន មានពាក្យខ្មែរសាមញ្ញ រាជស័ព្ទ លាយឡំជាមួយនិងសំណោរតាមទម្រង់អត្ថបទចម្រៀងបាសាក់។ ជាក់ស្ដែងសំណោរតាមទម្រង់អត្ថបទចម្រៀង

បាសាក់ច្រៀងដោយតួអង្គតេជោមាសៈ «(ច្រៀង)មាសពេជ្រកែវកង ពិទូរ្យស្វរ្យកាន្ត ពុំថ្លៃថ្កើងថ្កាន ស្មើនឹងវិជ្ជា(២ដង) ទឹកដីមាតុភូមិ ថ្លៃលើសជន្មា ចងចាំគ្រប់គ្នាកុំបីបែកបាក់ អឺយ»។

**២- ការផ្តើមរឿង**

អ្នកនិពន្ធផ្តើមរឿងដោយប្រើវិធីបង្ហាញតួអង្គដោយឱ្យតួអង្គបង្ហាញខ្លួនឯង តាមរយៈតួអង្គតេជាមាស។ ដូចក្នុងសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គតេជោមាសៈ «ខ្ញុំឈ្មោះ" មាស" មានគោរម្យងារជាឧកញ៉ាតេជោបរមរាជ...(ច្រៀង)តាំងចិត្តប្តេជ្ញា ការពារទឹកដី ដូចជាប្រស្រីក្នុងកែវនេត្រា(២ដង) ទោះត្រូវលះបង់ អាយុសង្ខារ ក៏ចិត្តស្នេហាជាតិមិនរសាយ។(និយាយ)ជិតចេញដំណើរហើយតើ! ឯណាយ៉ត?»។

**៣- ដំណើររឿង**

***ក-ពណ៌នាវិធីៈ*** គឺជាវិធីមួយដែលអ្នកនិពន្ធរៀបរាប់ពីទិដ្ឋភាពទាំងឡាយនៅក្នុងដំណើររឿងតាំងពីដើមរហូតដល់ចប់។ ការពណ៌នាអាចជាការរៀបរាប់ពីធម្មជាតិ តួអង្គ ទេសភាពនានា។ល។ ដោយរឿងតេជោយ៉តជាប្រភេទរឿងល្ខោន អ្នកនិពន្ធមិនសរសេររៀបរាប់ដោយផ្ទាល់ទេ តែបានសរសេររាប់តាមរយៈសម្តី ឬចម្រៀងរបស់តួអង្គវិញ។ ជាក់ស្តែងក្នុងរឿងមានដូចជារៀបរាប់ពីសម្រស់របស់ជំទាវស្រែន្យៈ

- ស្តេចសម្រែះ អាំ! ជំទាវស្រែន្យ! ជំទាវស្រែន្យលែងប្តី! យី! ជំទាវស្រែន្យស្អាតណាស់។ ឱ! យើងចង់បានណាស់។ (ច្រៀង)ឮឈ្មោះនាងស្រែន្យ ចាប់ផ្តើមស្នេហា ចង់បានកន្និដ្ឋា រួមរក្សមេត្រី។ អង្គអញជាស្តេច ត្រូវមានមហេសី(២ដង) រូបស្អាតប្រិមប្រិយ ដូចទេពកញ្ញា។(និយាយ)អាំ! បើតាមស្តាប់ការរៀបរាប់ របស់ពួកអាមាត្យជំទាវស្រែន្យប្រាកដជាមានកូនចិត្តមកលើយើងមិនខានហាស! ហាស! ហា!»។

***ខ- វចនវិធីៈ*** អ្នកនិពន្ធប្រើពាក្យចម្រុះមានជាច្រើនប្រភេទដូចជា ពាក្យសាមញ្ញ ពាក្យកម្ចីពីបាលីសំស្រ្កឹត រាជស័ព្ទ និងពាក្យកម្ចីពីបរទេសជាដើម។

ឧទាហរណ៍ៈ

- ពាក្យសាមញ្ញៈ កើត សេះ គោ អូន បង ...
- ពាក្យកម្ចីពីបាលីសំស្រឹតៈ តេជោ នេត្រា សង្ខារ នគរ ឧកញ៉ា ...
- រាជស័ព្ទៈ យាង ថ្វាយ ព្រះករុណា ព្រះក្រយា សោយ បិតា សុគត ភ្នងកេសា ព្រះរាជទ្រព្យ....ព្រះវស្សា ករុណាថ្លៃវិសេស ទូលព្រះបង្គំ សព្វព្រះរាជហឫទ័យ ...
- ពាក្យកម្ចីពីបរទេសៈ កម្ទី ផាយ ប៉ាក់ឌិន ...។

***គ- សំវាទវិធីៈ*** គឺជាវិធីដែលអ្នកនិពន្ធ ធ្វើឱ្យតួអង្គពីររូបឡើងទៅមានការសន្ទនានិយាយសាសងរវាងគ្នាអំពីបញ្ហាអ្វីមួយ ឬអំពីវិបត្តិទំនាស់ឈ្លោះទាស់ទែងគ្នាដោយពាក្យសម្តី។ ការសន្ទនារបស់តួអង្គនិងតួអង្គនៅក្នុងរឿងមានដូចជាៈ

- ការសន្ទនារវាងតេជោមាសជាមួយនិងជំទាវស្រែន្យៈ
  - ជំទាវស្រែន្យៈ បងគិតចេញដំណើរឥឡូវនេះឬ?
  - តេជោមាសៈហ្នឹងហើយអូន! ដល់ពេលវេលាបងហើយណា!
  - ជំទាវស្រែន្យៈ នេះថ្នាំព្យាបាលរបួសដែលបងតែងដាក់តាមខ្លួន អូនបានរៀបចំជូន

បងសព្វគ្រប់អស់ហើយ។

- តេជោមាសៈ អឺ ល្អហើយ!

- ការសន្ទនារវាងតេជោយ៉តជាមួយនិងព្រះចៅជ័យចេស្ដាៈ

- តេជោយ៉តៈ សូមក្រាបថ្វាយបង្គំព្រះករុណាជាម្ចាស់ជីវិតលើត្បូង!

- ព្រះចៅជ័យចេស្ដាៈ អើ! ល្អហើយ! នែ៎ តាមសេចក្ដីចុតហ្មាយបណ្ដាំរបស់លោកគ្រូតេជោមាសគាត់ថា តេជោយ៉តឯងហ្នឹង! មានថ្វីដៃខ្លាំងពូកែណាស់ក្នុងសឹកសង្គ្រាមពុំអន់ជាងគាត់ទេ ហើយជាសិស្សសំណព្វតែម្នាក់គត់ដែលជាអ្នកអាចស្នងមតិកគុនវិជ្ជានិងក្បួនតម្រាពិជ័យសង្គ្រាមរបស់គាត់បានមែនទេ?

**ឃ- ឯកវាទវិធីៈ** គឺជាវិធីដែលគេធ្វើឱ្យតួអង្គ ដែលទទួលរងទុក្ខទោសក្ដីមានការឈឺចាប់ទុក្ខព្រួយក្ដី ឬកើតវិប្បដិសារៈអំពីរឿងអ្វីមួយដោយការនិយាយរំលឹកអំពីហេតុភេទរឿងរបស់ខ្លួនតែម្នាក់ឯង។ ជំទាវស្រែន្យគិតម្នាក់អំពីបញ្ហាតេជោយ៉តចូលស្ដីដណ្ដឹង។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គជំទាវស្រែន្យៈ «ហ៊ឺ! ពិបាកចិត្តណាស់! យ៉តពឹងពាក់ចាស់ទុំឱ្យចូលមកស្ដីដណ្ដឹងខ្ញុំពីរបីសារទៅហើយ។ យី! គិតយ៉ាងម៉េចអ៊ីចេះ! ខ្ញុំដូចជាពុំយល់សោះ។ គិតមិនលេចសោះ។ (ច្រៀង)អាណិតស្រឡាញ់ ពេញក្នុងចិន្តា អឺយ ពេញចិត្ត ប៉ុន្តែ អឺយ ចាប់ស្រវាពុំបាន អឺយ ទទួលពុំបាន អឺយ ពីព្រោះខ្ញុំៗខ្មាសអៀន អឺយ ខ្មាសអៀនញាតិសន្តាន អឺយ យើងទាំងពីរប្រាណៗ អឺយ វណ្ណៈខុសគ្នា អឺយ វណ្ណៈខុសគ្នា ខ្លួនអឺយៗចម្បែងថ្លៃអឺយខ្ញុំរែងថ្លែងប្រាប់នរណា បើខ្ញុំអឺយហានក្លា អ្នកផងសើចនិន្ទា អឺយ ទុក្ខញាំញី អឺយ ប្រកែករែកទុក្ខគ្រាំគ្រា អួយម្ដេចក៏ពុំងារពារចាប់ស្រវា ឱប្រុសជីវាស្នេហាខ្ញុំអឺយ...។ (និយាយ)ហ៊ឺ! យ៉តជាបុរសមានឧត្តមគតិស្នេហាជាតិនិងលក្ខណសម្បត្តិថ្លៃថ្នូរដូចស្វាមីខ្ញុំគ្រប់យ៉ាង ប៉ុន្តែគេជាអតីតបាវបម្រើ ដូច្នេះបើរៀបការជាមួយយ៉តច្បាស់ជាអ្នកផងសើចនិន្ទាខ្ទរខ្ទាពេញនគរមិនខាន។

**ង- បដិវិធីៈ** អ្នកនិពន្ធធ្វើឱ្យមានវិធីផ្ទុយគ្នានៅក្នុងសាច់រឿង នៅត្រង់តួអង្គស្ដេចសម្រែជារាស្ត្រសាមញ្ញចង់ក្លាយជាស្ដេចផែនដី។ ចំណែកឯតេជោមាសនិងតេជោយ៉តចង់កម្ចាត់ស្ដេចសម្រែដើម្បីការពាររាជបល្ល័ង្កព្រះចៅជ័យចេស្ដា។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គៈ

- ស្ដេចសម្រែៈ «អ៊ូ! លោកឧកញ៉ាពិភាត្រូវខិតខំកេណ្ឌពលសឹកបន្ថែមទៀតកុំបន្ធូរដៃឱ្យសោះ។ ព្រោះនៅវដ្ដវខាងមុខនេះយើងត្រូវលើកទ័ពទៅឡោមព័ទ្ធវាំងរបស់ព្រះចៅជ័យចេស្ដានៅក្រុងឧដុង្គដើម្បីដណ្ដើមយករាជសម្បត្តិ ក្រុងកម្ពុជាឱ្យបានដាច់ខាត!»។

- តេជោមាសៈ «ហ៊ឺះ! អាមនុស្សថោកទាប ការស្រមើស្រមៃដ៏ស្អុយគ្រគុករបស់ឯងនេះ! វានឹងនាំឱ្យខ្លួនឯងវិនាសអន្តរាយជាមិនខានទេ!»។

**ច- សន្ទេហវិធីៈ** គឺជាវិធី ដែលកវីអ្នកនិពន្ធតែងសម្រាប់ធ្វើឱ្យអ្នកអានចង់ដឹងហើយចង់

ដឹងទៀតអំពី រឿងណាមួយដោយគេបែងចែករឿងជាខណៈផ្សេងៗ។ នៅក្នុងសាច់រឿង អ្នកនិពន្ធបានរៀបចំឈុតឆាកធ្វើឱ្យមានភាពងឿយឆ្ងល់៖

- តើផែនការរបស់ជំទាវស្រែន្យក្នុងការកម្ចាត់ស្តេចសម្រែបានជោគជ័យដែរឬទេ?
- តើផែនការរបស់តេជោយ៉តក្នុងការកម្ចាត់ខ្មាំងក្រោយខ្នងបានសម្រេចដែរឬទេ?

**ឆ- ឧបមានវិធី៖** គឺជាវិធីមួយដែលអ្នកនិពន្ធបានធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពនៅក្នុងដំណើររឿង ដើម្បីរំលេចចេញនូវជីវរូបារម្មណ៍ ឬមនោរម្មណ៍។ ការប្រើប្រាស់វិធីប្រៀបធៀបនៅក្នុងសាច់រឿងមានដូចជា៖

- តេជោយ៉តប្រៀបធៀបខ្លួនឯងទៅនឹងចក៖ «ជីវិតខ្ញុំ ដូចចករសាត់»។
- ស្តេចសម្រែប្រៀបធៀបផ្ទះជំទាវស្រែន្យទៅនឹងវាំង៖ «ជំទាវប៉ិនប្រសប់តុបតែងទីលំនៅស្អាតរុងរឿង ប្រៀបបាននឹងវាំងស្តេច»។

**ជ- រូបារម្មណ៍វិធី៖**

- ចក្ខុរូបារម្មណ៍៖ ការរៀបរាប់ដែលធ្វើឱ្យហាក់ដូចជាឃើញនឹងភ្នែក។ ដូចខ្លឹមសាររឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គ៖

- ស្តេចសម្រែ៖ យីជំទាវស្រែន្យស្អាតណាស់! អូ! យាងចូល! អូស្អាតណាស់ស្អាតលើសស្រីលើផែនដីនេះទៅទៀត។
- ជំទាវស្រែន្យ៖ យី បុណ្យគេអធិកអធមណាស់ហ្ន មនុស្សច្រើនអ៊ូអរសប្បាយមែន។ នែ ឯងមើលជាងណានេះ ចេះឆ្លាក់រូបសំណាក់ដូចប្តីខ្ញុំបេះបិទហ្ន!
- អ្នកបម្រើ៖ អូ! ស្អាតណាស់ស្លៀកហូលពណ៌បៃតង ពាក់អាវកម្មីខ្លាញ់ក្តាមអញ្ចឹង វាស៊ីជាមួយសាច់សរបស់អ្នកនាងតែម្តងចាស់!ហើយវាសមនឹងសក់វែងអន្លាយដល់ចង្កេះហើយពាក់កងដៃពេជ មើលទៅស្អាតប្រៀបដូចនារីសួគ៌នៅក្នុងរឿងព្រេងអញ្ចឹងណាអ្នកនាង។

- កាយរូបារម្មណ៍៖ ការរៀបរាប់ដែលធ្វើឱ្យហាក់ដូចជាបានប៉ះពាល់ឬក៏ស្ទាបអង្អែល។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គ៖

- ឧកញ៉ាពិភា៖ ព្រះករុណាថ្លៃវិសេស ក៏ប៉ុន្តែមិនទាន់មានកូនមួយសោះ។ ឯចំណែករូបទៀត នៃសាច់ក៏ល្អស្អាតលើសស្រីក្រមុំព្រហ្មចារីយដែលទើបចេញពីម្លប់ទៀតណាព្រះអង្គ។

- កាមរូបារម្មណ៍៖ ការរៀបរាប់ដែលធ្វើឱ្យកើតមានអារម្មណ៍ចំណង់តណ្ហា។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គ៖

- ស្តេចសម្រែ៖ អាំ! ជំទាវស្រែន្យ! ជំទាវស្រែន្យលែងប្តី! យី! ជំទាវស្រែន្យស្អាតណាស់។ ឱ! យើងចង់បានណាស់។ ឮឈ្មោះនាងស្រែន្យ ចាប់ផ្តើមស្នេហា ចង់បានកន្និដ្ឋា រួមរក្សមេត្រី។

- ឃាននិងជីវ្ហារូបារម្មណ៍៖ ការរៀបរាប់ដែលធ្វើឱ្យកើតមានអារម្មណ៍ចំណង់តណ្ហា។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គ៖

- ស្ដេចសម្រេះ អូ! អូ! ក្រយា! ... យី! ព្រះក្រយាស្ងោយក៏មានឱជារសក្រអូបឈ្ងុយឈ្ងប់។ អូន៉ែ! ស្រាក៏ឆ្ងាញ់។ យី! គ្រប់សព្វទាំងអស់ជំទាវ ហឺះ!ហ៊ឺះ!

- មនោរូបារម្មណ៍៖ ការរៀបរាប់ដែលធ្វើឱ្យកើតមានអារម្មណ៍ចំណង់តណ្ហា។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គ៖

- ស្ដេចសម្រេះ អូ! អូ! ក្រយា! ... យី! ព្រះក្រយាស្ងោយក៏មានឱជារសក្រអូបឈ្ងុយឈ្ងប់។ អូន៉ែ! ស្រាក៏ឆ្ងាញ់។ យី! គ្រប់សព្វទាំងអស់ជំទាវ ហឺះ!ហ៊ឺះ!

**៤- ការបញ្ចប់រឿង**

អ្នកនិពន្ធបញ្ចប់រឿងដោយឱ្យតួអង្គតេជោយ៉តទទួលជោគជ័យក្នុងការកម្ចាត់ពួកសត្រូវបរទេសសៀមដែលប៉ុនប៉ងឈ្លានពានទឹកដី ព្រមទាំងបានជំទាវស្រែន្យជាភរិយា។

**ឃ- អត្ថរស**

**១- កុសលរស**

រឿងនេះបានបង្កប់នូវតម្លៃអប់រំ៖

- មានមនសិការស្នេហាជាតិមាតុភូមិ
- ចេះប្រើយុទ្ធវិធីក្នុងកម្ចាត់សត្រូវ ជាពិសេសធ្វើសឹកសង្គ្រាម
- ដឹងពីស្ត្រីមានតួនាទីសំខាន់ក្នុងការដោះស្រាយបញ្ហាប្រទេសជាតិ
- អ្នកដឹកនាំឱ្យឈរលើគោលការណ៍ច្បាប់ និងយុត្តិធម៌ទើបប្រទេសជាតិបានសន្តិភាព និងមានការរីកចម្រើន
- ចៀសវាងការលោភលន់នឹងអំណាច ប្រកាន់អំពើបក្សពួកនិយម ស៊ីសំណូកសូកប៉ាន់ ព្រោះនាំឱ្យមានគ្រោះថ្នាក់ដល់ប្រទេសជាតិនិងខ្លួនឯង
- អ្នកដឹកនាំកុំឱ្យលង់នឹងសម្រស់ស្រី និងជឿតែតាមសម្ដីជនអែបអប
- ចៀងវាងឱ្យរើសអើងជនជាតិ ប្រកាន់វណ្ណៈ
- មានភក្ដីភាពចំពោះគូស្វាមីភរិយា។

**២- សង្គមរស**

រឿងតេជោយ៉ត បង្ហាញពីស្ថានភាពប្រទេសខ្មែរបានជួបប្រទះវិបត្តិមួយធំៗមួយចំនួនដូចជាសង្គ្រាមឈ្លានពានពីបរទេស សង្គ្រាមក្នុងស្រុកគឺការបះបោរដណ្ដើមរាជសម្បត្តិ អំពើបក្សពួកនិយមស៊ីសំណូកសូកប៉ាន់ក្នុងជួរមន្ត្រីរាជការ។ តាមរយៈដំណើររឿងបង្ហាញឱ្យឃើញពីផលលំបាននៃសង្គមនៅក្នុងសម័យនោះ ដោយសារជួបប្រទះអសន្តិសុខ ប្រជាជនជួបការលំបាកក្នុងជីវភាពរស់នៅ ព្រោះត្រូវជាប់កំណែនកងទ័ពមិនបានរស់នៅជួបជុំគ្រួសារ មិនបានប្រកបរបរចិញ្ចឹមជីវិត ត្រូវគេរែអង្គាសស្បៀងជាដើម។ ម្យ៉ាងទៀតក្នុងជួររាជការ មានអ្នកប្រកាន់បក្សពួកនិយម ស៊ីសំណូកសូកប៉ាន់ ដែលជាមូលហេតុនាំឱ្យមានភាពអយុត្តិធម៌ និងអាចធ្វើឱ្យសង្គមមានគ្រោះថ្នាក់។ ដូចខ្លឹមសាររឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គ៖

- ស្ដេចសម្រេះ យើងបញ្ជាឱ្យរែអង្គាសស្បៀងនិងកេណ្ឌពលសឹក តើបានលទ្ធផលយ៉ាងណាដែរ?

- តេជោយ៉ត៖ ដូចអស់លោកជ្រាបអស់ហើយ តាំងតែពីដើមមក សៀមតែងតែលើកទ័ពមករំលោភបំពានបង្កសង្គ្រាមវាយដណ្ដើមយកអាណាខេត្តនានានិងទ្រព្យសម្បត្តិដ៏មានតម្លៃផ្សេងៗពីកម្ពុជាយើងស្ទើរគ្រប់សម័យកាល។ លើសពីនេះប្រជាជនយើងតែងរងគ្រោះវេទនាយ៉ាងខ្លោចផ្សា គួរឈឺចាប់ជាទីបំផុតដោយសារអំពើរំលោភរបស់សៀម។ ពេលនេះបើយើងបណ្ដោយឱ្យពួកឈ្លើយសឹកបះបោរដូចនេះមានមូលដ្ឋានទ័ព ហើយចេញមុខប្រឆាំងយ៉ាងដូច្នេះមិនយូរមិនឆាប់ព្រះចៅក្រុងឲ្យយុធ្យានឹងលើកទ័ពមកជួយពួកវាជាមិនខាន។ ដល់ពេលនោះសង្គ្រាមរវាងនគរនិងនគរមុខជាផ្ទុះទៀតហើយ។ សូមបងប្អូនទាំងអស់គ្នាប្ដេជ្ញា! (កងទ័ពទាំងអស់ស្រែកប្ដេជ្ញាបន្ទរព្រមៗគ្នា)។ (ច្រៀងរួមគ្នា)កងទ័ពកម្ពុជាប្ដេជ្ញាការពារទឹកដី(២ដង)កម្ចាត់ចោរថៃឱ្យវាខ្ចាត់ខ្ចាយ(២ដង)ប្រជាទាំងអស់រស់នៅសប្បាយ(២ដង)រុងរឿងវែងឆ្ងាយផុតពីចម្បាំង(២ដង)។

**៣- តថរស**

ដំណើររឿងឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាចុងសម័យកាលលង្វែកនិងដើមសម័យកាលឧដុង្គក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី១ សោយរាជ្យនៅរាជធានីឧដុង្គ។ ក្នុងសាច់រឿងអ្នកនិពន្ធប្រើឈ្មោះព្រះមហាក្សត្រថា ព្រះចៅជ័យចស្តា។

លក្ខណៈតថសំខាន់ៗមាន៖

- របបគ្រប់គ្រង៖ នៅសម័យកាលនោះប្រទេសកម្ពុជាប្រកាន់របបរាជនិយម ព្រះមហាក្សត្រសោយរាជ្យនិងកាន់អំណាច។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖
    - ព្រះចៅជ័យចេស្តា៖ ទ្រង់ព្រះនាមសម្ដេចព្រះរាជឱង្ការព្រះជ័យចេស្ដាបរមរាជមហាខត្តិយា រាជាធិបតី ព្រះស្រីសុរិយោពណ៌មហាចក្រពត្រាធិរាជ។ (ច្រៀង)តាំងពីបិតាសុគតទៅ អឺយ... អង្គអញស្ថិតនៅសោយរាជ្យសម្បត្តិ(២ដង)ជាមួយនឹងមហេសីអង្គចូវវង្សក្សត្រីកែវាយពេកក្កាត់ ឥតមានកង្វល់ អឺយ...»។
- ទីកន្លែង៖ ឈ្មោះទីកន្លែងនៅក្នុងសាច់រឿងមានច្បាស់លាស់រហូតនៅដល់សព្វថ្ងៃដូចជា ឧដុង្គ លង្វែក កំពង់ស្វាយ កំពង់ហៅ ពោធិ៍សាត់ បាត់ដំបង បរិបូណ៌ ស្វាយរំពារជាដើម។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖
    - យ៉ត៖ យើងស្គាល់ច្បាស់ណាស់ ដើមឡើយឯងជារាស្ត្រម្នាក់ឈ្មោះ សំ នៅក្រាំងសម្រែខេត្តបរិបូណ៌នេះ ហើយបានទៅសិក្សាគុណវិជ្ជានៅ ភ្នំទូកមាស ខេត្តកំពង់ស្វាយ...។
- ព្រឹត្តិការណ៍៖
    - o នៅក្នុងប្រវត្តិសាស្ត្របានបញ្ជាក់ថាមានចលនាបះបោរដឹកនាំដោយនាយកែវ។ ចំពោះនៅក្នុងសាច់រឿងមានចលនាបះបោរដើម្បីដណ្ដើមរាជបល្ល័ង្គដឹកនាំដោយរាស្ត្រម្នាក់តាំងឈ្មោះខ្លួនឯងថាជាស្ដេចសម្រែ។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖
    - ស្ដេចសម្រែ៖ អ៊ូ! លោកឧកញ៉ាពិភាត្រូវខិតខំកេណ្ឌពលសឹកបន្ថែមទៀតកុំបន្ធូរ

ដៃឱ្យសោះ។ ព្រោះនៅវដូវខាងមុខនេះយើងត្រូវលើកទ័ពទៅឡោមព័ទ្ធវាំងរបស់ព្រះចៅជ័យចេស្តានៅក្រុងឧដុង្គដើម្បីដណ្តើមយករាជសម្បត្តិ ក្រុងកម្ពុជាឱ្យបានដាច់ខាត!

០ នៅក្នុងប្រវត្តិសាស្ត្របានបញ្ជាក់ថាប្រទេសសៀមតែងបង្កសង្គ្រាមដើម្បីឈ្លានយកទឹកដីប្រទេសកម្ពុជា។ កត្តាធ្វើឱ្យកើតចម្បាំងរវាងខ្មែរនិងសៀមនៅលើទឹកដីប្រទេសកម្ពុជា។ នៅក្នុងសាច់រឿងបានបង្ហាញពីសង្គ្រាមដើម្បីបង្ក្រាបពួកឈ្លើយសឹកសៀមដែលបានធ្វើការបះបោរនៅខេត្តពោធិ៍សាត់។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- តេជោយ៉ត៖ ដូចអស់លោកជ្រាបអស់ហើយ តាំងតែពីដើមមក សៀមតែងតែលើកទ័ពមករំលោភបំពានបង្កសង្គ្រាមវាយដណ្តើមយកអាណាខេត្តនានានិងទ្រព្យសម្បត្តិដ៏មានតម្លៃផ្សេងៗពីកម្ពុជាយើងស្ទើរគ្រប់សម័យកាល។ លើសពីនេះប្រជាជនយើងតែងរងគ្រោះវេទនាយ៉ាងខ្លោចផ្សា គួរឈឺចាប់ជាទីបំផុតដោយសារអំពើរំលោភរបស់សៀម។ ពេលនេះបើយើងបណ្តោយឱ្យពួកឈ្លើយសឹកបះបោរដូចនេះមានមូលដ្ឋានទ័ព ហើយចេញមុខប្រឆាំងយ៉ាងដូច្នេះមិនយូរមិនឆាប់ព្រះចៅក្រុងអយុធ្យានឹងលើកទ័ពមកជួយពួកវាជាមិនខាន។ ដល់ពេលនោះសង្គ្រាមរវាងនគរនិងនគរមុខជាផ្ទុះទៀតហើយ។ សូមបងប្អូនទាំងអស់គ្នាប្តេជ្ញា! (កងទ័ពទាំងអស់ស្រែកប្តេជ្ញាបន្ទរព្រមៗគ្នា)។ (ច្រៀងរួមគ្នា)កងទ័ពកម្ពុជាប្តេជ្ញាការពារទឹកដី(២ដង)កម្ចាត់ចោរថៃឱ្យវាខ្ចាត់ខ្ចាយ(២ដង)ប្រជាទាំងអស់រស់នៅសប្បាយ(២ដង)រុងរឿងវៃឆ្ងាយផុតពីចម្បាំង(២ដង)។

**៤- វីររស**

គឺជាការបង្ហាញពីវីរភាពរបស់តួអង្គនៅក្នុងរឿង ហើយតួអង្គទាំងនោះគឺជាវីរជន ដែលបានធ្វើវីរៈសកម្មភាពដើម្បីជាតិមាតុភូមិ និងមនុស្សជាតិទាំងមូល។ នៅក្នុងរឿងតេជោយ៉តយើងសង្កេតឃើញបង្ហាញពីវីរភាពរបស់តួអង្គតេជោមាស តេជោយ៉ត និងជំទាវស្រែន្យ។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- ឧកញ៉ាព្រហ្មស្រី៖ លោកតេជោមាស លោកជាមហាបុរសខ្មែរមួយរូបធ្លាប់មានគុណលើប្រទេសជាតិ ដោយបានស្រោចស្រង់មាតុភូមិពីគ្រោះមហន្តរាយជាច្រើនលើកច្រើនគ្រាមិនគួរស្លាប់ពេលនេះសោះ។ យើងទាំងអស់គ្នាសោកស្តាយចំពោះរូបលោកណាស់ ថ្វីបើលោកផុតជីវិតទៅមែន ក៏ប៉ុន្តែកេរ្តិ៍ឈ្មោះរបស់លោកនៅតែដក់ជាប់ក្នុងដួងចិត្តកុលបុត្រកម្ពុជារាប់ម៉ឺនឆ្នាំតទៅមុខទៀតឥតមានសាបសូន្យឡើយ។

- តេជោមាស៖ និយាយលាក់បាំងអី តាំពីអូនរៀបចំឧបាយកលជួយបងឱ្យចាប់ស្តេចសម្រេបានមកនោះ បងយល់ថា អូនមិនត្រឹមតែជាភរិយាគ្រប់លក្ខណ៍របស់បងប៉ុណ្ណោះទេ ថែមទាំងជាកំពូលស្រីម្នាក់ដែលកម្ររកបានណាំអូនណាំ! (ច្រៀង)មាសអឺយមាសស្នេហ៍ដូចខែពេញបូរមី(២ដង)អូនល្អលើសអស់ស្រី(២ដង)នៅក្នុងលោកា ប្រាជ្ញាអូនវាងវៃជាសមុតថ្លា

(២ដង)អ្វូនអាចប្រហារ(២ដង)ពួកក្បត់ជាតិបាន។

- ជំទាវស្រែន្យះ ខ្ញុំអាណិតនិងស្រឡាញ់យ៉តលើសដើមទៅទៀត។ ប៉ុន្តែដោយសារមានគំនិតប្រកាន់វណ្ណៈទើបចេះតែប្រកែក។ ឥឡូវនេះខ្ញុំលែងស្ទាក់ស្ទើរក្នុងចិត្តទៀតហើយ។ ជាពិសេសការប្រកាន់ពូជសាសន៍ គឺជាគំនិតអយុត្តិធម៌ជាទីបំផុត។ ឧទាហរណ៍ដូចរូបអ្នកដែលមានដើមកំណើតជាជនជាតិភាគតិច ប៉ុន្តែស្មារតីស្នេហាជាតិរបស់យ៉តខ្ពង់ខ្ពស់ជាទីបំផុត អឺ...វីរភាពរបស់អ្នកឧត្តុង្គឧត្តមណាស់សម្រាប់ទំព័រសាវតាររបស់នគរកម្ពុជាយើងនេះណា៎!

**៦- ហាសរស**

ដំណើររឿងបង្ហាញពីភាពកំប្លុកកំប្លែងគួរឱ្យចង់សើច។ ដូចក្នុងសាច់រឿងបញ្ជាក់តាមរយៈតួអង្គះ

- នាយទិនះ អាតយអឺយ អឺយអាតយ
- នាយតយះ បាទ លោកម្ចាស់អានេះឯងសោះរ៉ើយ....
- នាយទិនះ អាតយ អញស្តាប់ឯងនិយាយយូរៗទៅ វាឈឺបត់ជើង។ អញមិនចង់ដឹងអីវែងឆ្ងាយអីចឹងទេ។

**៧- ទារុណរស**

គឺជាការបង្ហាញពីការឈឺចាប់របស់តួអង្គ ដែលកើតចេញពីការធ្វើបាបពីអ្នកដទៃ ឬកើតចេញពីទំនាស់ផ្សេងៗជាដើម។ ដូចក្នុងសាច់រឿងបញ្ជាក់តាមរយៈតួអង្គះ

- តេជោមាសះ ហ៊ឺ! គ្រូឈឺចិត្តណាស់យ៉ត មិនគួរចាញ់ដៃអាមនុស្សក្បត់ជាតិហ្នឹងសោះ! (ច្រៀង)ច្រកអើយច្រកភ្នំ ក្តៅងំក្នុងចិត្ត អឺ...ចាញ់ជនឧក្រិដ្ឋត្បិតខូចផែនការ ធ្លាប់មានថ្វីដៃ នឹងស្តេចថៃណា ការពាររដ្ឋាយកជ័យគ្រប់ទិស...។

**៨- នាដរស**

នាដរសក្នុងរឿងតេជោយ៉ត កើតចេញពីទំនាស់រវាងតួអង្គនិងតួអង្គ។ ដូចក្នុងសាច់រឿងបញ្ជាក់តាមរយៈតួអង្គះ

- តេជោយ៉ត តេជោមាស និងស្តេចសម្រែះ ទំនាស់ផ្លូវវាចា ចិត្ត
- ជំទាវស្រែន្យនិងស្តេចសម្រែះ ទំនាស់ផ្លូវកាយ វាចា ចិត្ត
- តេជោយ៉តនិងអ្នកម្នាងនូះ ទំនាស់ផ្លូវកាយ វាចា ចិត្ត

ដោយសារតែវិបត្តិទំនាស់ទាំងនេះ កើតមកពីការឈ្នានីស ទង្វើក្បត់ជាតិនឹងការការពារ ការកេងប្រវ័ញ្ច ការក្រោធ តណ្ហាជាដើម បណ្តាលឱ្យតួអង្គភាគី ត្រូវទទួលរងសោកនាដកម្មដូចជាស្តេចសម្រែ តេជោមាស អ្នកម្នាងនូ។

**៩- សោភ័ណរស**

តាមរយៈដំណើររឿងបានបង្ហាញឱ្យឃើញពីសោភ័ណជំទាវស្រែន្យ។ ជំទាវស្រែន្យ ជា

នារីដែលមានគ្រប់លក្ខណៈទាំងរូបសម្បត្តិ ចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ។ ជំទាវស្រែន្យជាស្ត្រីស្អាតជាងគេនៅកំពង់ស្វាយ។ ដូចសម្ដីតួអង្គតេជោយ៉តបញ្ជាក់៖

- តេជោយ៉ត៖ និយាយលាក់បាំងអីស្រែន្យ នៅក្នុងដែនកំពង់ស្វាយទាំងមូល ខ្ញុំសម្លឹងរកនារីណាឱ្យមានលក្ខណៈល្អគ្រប់យ៉ាង ដូចស្រែន្យគ្មានសោះ។

**១០- ទស្សនីរស**

តម្លៃដែលកើតចេញមកអំពីការបង្ហាញទស្សនីយភាព ដែលធ្វើឱ្យសាច់រឿងកាន់តែពីរោះក្បោះក្បាយតាមរយៈការរៀបរាប់ទេសភាពធម្មជាតិ ព្រៃព្រឹក្សា មច្ឆា បក្សាបក្សី ប្រកបទៅដោយចុងចួន សូរសព្ទសំឡេងរណ្ដំគ្នា ដើម្បីបង្កើតជាបរិយាកាសមួយ ដែលហៅថាសិល្បៈបរិយាកាស។ ដូចជាសាច់បានបញ្ជាក់តាមរយៈតួអង្គ៖

- ក្រុមស្រីបម្រើច្រៀង៖ ម្ចាស់អើយគន់មើល អឺ...អឹង... អឺ...អឹង...អើយផ្កាក្នុងឧទ្យានកន្លង់បំពាន អឺ អឹង ក្រេបរុះលំអង អើយលំអង។ ចំប៉ីចំប៉ា អឺ...អឹង...អឺ...អឹង...អើយផ្កាម្លិះផងអើយម្លិះផង កុលាបរីកស្រស់ អឺ...អឹង...អឺ...អឹង...អើយសព្វសាយគន្ធាអើយគន្ធា។ ពេលថ្ងៃគងភ្នំ អឺ...អឹង...អឺ...អឹង...អើយនាំខ្ញុំអាល័យ អើយអាល័យកេសាម្ចាស់ស្រី អឺ...អឹង...អឺ...អឹង...អើយពាក់ភួងមាលាអើយមាលា។ ស្អាតដូចអប្សា អឺ...អឹង...អឺ...អឹង...អើយចុះចាកឰសួគ៌ា គួរអីប្រៃជា អឺ...អឹង...អឺ...អឺ...អើយអភ័ព្វ មេម៉ាយ អើយមេម៉ាយ។

**ង- បញ្ហាសង្គម**

**១- នយោបាយ**

១.១- នយោបាយក្នុងប្រទេស

- ការគ្រប់គ្រងប្រទេសបែបរាជានិយម ដែលមានព្រះមហាក្សត្រសោយរាជ្យនិងកាន់អំណាច ដោយមានការបែងចែងចែកអំណាចទៅតាមតំបន់ខេត្តផ្សេងៗ។ ការឡើងគ្រងរាជ្យធ្វើបន្តបន្ទាប់គ្នាពីក្សត្រមួយអង្គទៅក្សត្រមួយអង្គទៀតដោយជ្រើសរើសពីក្នុងខ្សែស្រឡាយរាជវង្សានុវង្ស ដែលមានព្រះមហាក្សត្រជាអ្នកជ្រើសរើស។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈបន្ទូលរបស់តួអង្គព្រះចៅជ័យចេស្ដា៖ «ទ្រង់ព្រះនាមសម្ដេចព្រះរាជឱង្ការព្រះជ័យចេស្ដាបរមរាជ មហាខន្តិយា រាជាធិបតី ព្រះស្រីសុរិយោពណ៌មហាចក្រពត្រាធិរាជ។ (ច្រៀង)តាំងពីបិតាសុគតទៅ អឺយ... អង្គអញស្ថិតនៅសោយរាជ្យសម្បត្តិ(២ដង)ជាមួយនឹងមហេសីអង្គចូវវង្សក្សត្រីរីករាយពេកក្ដាត់ ឥតមានកង្វល់ អឺយ...។

- ព្រះមហាក្សត្រគ្រប់គ្រងអំណាចទាំងអស់គឺ អំណាចនិតិបញ្ញត្តិ អំណាចនិតិប្រតិបត្តិនិងអំណាចតុលាការ។ ចំពោះតុលាការព្រះមហាក្សត្រជាអ្នកកាត់ក្ដីថែមទៀតផង។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្ដីរបស់តួអង្គ៖

- តេជោមាស៖ អូ! យ៉តមកវិញហើយប្រាប់បងថា ព្រះចៅជ័យចេស្ដា កាត់ទោសប្រហារជីវិតស្ដេចសម្រែនោះបាត់ទៅហើយអូន។
- ជំទាវស្រែន្យ៖ អូ! ការប្រហារជីវិតនេះសមនឹងទោសកំហុសរបស់វាដែលធ្វើទុក្ខ

បុកម្នេញប្រជាជនដើម្បីបម្រើសេចក្តីលោភលន់របស់ខ្លួនណា៎!

• ការរៀបចំរចនាសម្ព័ន្ធនិងបែងចែកអំណាចគ្រប់គ្រង គឺការបែងចែកភូមិសាស្ត្រក្នុងប្រទេសជា រាជធានី ក្រុង ខេត្ត ស្រុក ភូមិ មានដូចជា រាជធានីឧដុង្គ ក្រុងលង្វែក ខេត្តកំពង់ស្វាយ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ស្រុកបរិបូរណ៌ ភូមិស្វាយរំពារជាដើម។ ចំណែកបែងចែកអំណាចគ្រប់គ្រងមានតាំងពីថ្នាក់កណ្តាលរហូតទៅដល់ តំបន់ខេត្ត ដែលមានព្រះមហាក្សត្រត្រួតត្រាថ្នាក់កណ្តាល(មានរាជធានីឧដុង្គ) ចំណែកនៅតាមតំបន់ខេត្តផ្សេងៗមានមេទ័ពជាអ្នកត្រួតត្រា ដូចជាមេទ័ពតេជោមាកាន់កាប់ខេត្តកំពង់ស្វាយ មេទ័ពមឿងត្រួតត្រាខេត្តលង្វែល មេទ័ពមឿងត្រួតត្រាដែនកំពង់ហៅ។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គ៖

- តេជោមាស៖ មកហើយអី! លោកត្រូវធ្វើចុតហ្មាយមួយយកមកឱ្យខ្ញុំចុះហត្ថលេខាដើម្បីផ្ញើទៅថ្វាយព្រះរាជា គឺមុននឹងខ្ញុំស្លាប់ទៅ យើងសូមប្រគល់មុខតំណែងក្នុងដែនដីកំពង់ស្វាយនេះ ឱ្យទៅយ៉តៗដែលជាសិស្សរបស់យើងនេះ ជាតេជោយ៉ត ឮទេ?

- តេជោយ៉ត៖ មឿងលង្វែកត្រូវនាំទ័ពវាងតាមព្រៃទៅលាក់ខ្លួនប៉ែកខាងក្រោយបន្ទាយរបស់ខ្មាំង ពេលណាទ័ពមឿងកំពង់ហៅជន្លឱ្យពួកវាចេញពីបន្ទាយរួចហើយលោកត្រូវនាំទ័ពវាយលុកចូលកាន់កាប់បន្ទាយរបស់សត្រូវឱ្យបាន។

• ការគ្រប់គ្រងកងទ័ព៖ កងទ័ពចែកចេញជាពីរប្រភេទគឺ កងទ័ពហ្លួងជាទ័ពថ្នាក់កណ្តាលរបស់ស្តេច និងកងទ័ពនៅតាមតំបន់នីមួយៗគ្រប់គ្រងដោយមេទ័ពនៅតាមតំបន់។ ក្នុងជួរកងទ័ព មានកងទ័ពក្នុងក្របខ័ណ្ឌ និងកងទ័ពជ្រើសរើស។ កងទ័ពក្នុងក្របខ័ណ្ឌនៅឈរជើងជាប្រចាំនៅបន្ទាយតាមតំបន់នីមួយៗ។ ចំណែកកងទ័ពជ្រើសរើស គេកេណ្ឌមកនៅពេលមានសង្គ្រាម។ កងទ័ពថ្នាក់កណ្តាលមានភារកិច្ចការពារប្រទេសសម្រាប់ប្រឆាំងជាមួយសត្រូវបរទេសឈ្លានពាន។ ចំណែកកងទ័ពនៅតាមតំបន់ មានភារកិច្ចការពារផ្ទៃក្នុងប្រទេសពេលមានទំនាស់ផ្ទៃក្នុង និងបង្ក្រាបការបះបោរ។ កងទ័ពឈ្លើយសឹកបរទេសដែលចាប់បានពេលចាញ់សង្គ្រាម គេមិនសម្លាប់ទេគឺគេទុកឱ្យរស់នៅក្នុងតំបន់ណាមួយ។ ដូចសាច់រឿងបានបញ្ជាក់តាមរយៈសម្តីរបស់តួអង្គតេជោយ៉ត៖ «ព្រះករុណាថ្លៃវិសេស! ពួកឈ្លើយសឹកសៀមរាប់ម៉ឺននាក់នោះគឺបន្សល់ទុកមកពីចម្បាំងរវាងនគរនិងនគរ។ ដូច្នេះជាភារកិច្ចរបស់មេទ័ពហ្លួងទេដែលត្រូវចេញទៅបង្ក្រាប....»។ «មកដល់លង្វែកនេះកេណ្ឌទ័ពទាំងត្រើយខាងលិចនិងត្រើយខាងកើតបានតែមួយពាន់នាក់បូករួមទាំងមកពីកំពង់ស្វាយគឺបានតែមួយពាន់ប្រាំរយនាក់ ប៉ុណ្ណោះឃើញថានៅចាញ់ចំនួនទ័ពសត្រូវច្រើនណាស់ ប៉ុន្តែខ្ញុំជឿជាក់ថា(ច្រៀង)កងទ័ពមោះមុតមិនស្លុតស្មារតី គោរពវិន័យ មានសណ្តាប់ធ្នាប់(២ដង)ភូមិសាស្ត្រពួកខ្មាំង យើងបានក្តាប់ជាប់ មុខជាកងទ័ពទទួលបានជោគជ័យ»។

១.២- នយោបាយក្រៅប្រទេស

ក្នុងសាច់រឿងមិនបានបញ្ជាក់ច្បាស់លាស់ពីនយោបាយក្រៅប្រទេសនោះទេ តែបានពីការកើតសង្គ្រាមរវាងខ្មែរជាមួយនិងសៀម។ សង្គ្រាមនោះកើតឡើងដោយសារ ប្រទេសសៀម

តែងតែលើកទ័ពធ្វើការឈ្លានដើម្បីយកទឹកដីប្រទេសកម្ពុជា។ កងទ័ពខ្មែរតែងប្រយុទ្ធនាំងនឹងអំពើឈ្លានពានរបស់ពួកសៀមជានិច្ច របៀតទទួលបានជ័យជម្នះចាប់បានកងទ័ពសៀមរាប់ម៉ឺននាក់យកមកធ្វើជាឈ្លើយសឹកនៅក្នុងខេត្តពោធិ៍សាត់ទៀតផង។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- មេទ័ពឈិត៖ អើ! ដូចលោកបានដឹងស្រាប់ហើយ ជាច្រើនលើកច្រើនសារមកហើយ ទ័ពនគរយើងលើកយកមកវាយស្រុកខ្មែរពេលណាក៏តែងតែត្រូវតេជោមាសវាយខ្ចាត់ខ្ចាយជានិច្ច។ ពេលនេះ មេទ័ពដ៏ខ្លាំងពូកែនោះវាអស់ជីវិតទៅហើយ បើយើងមិនវាយយកស្រុកខ្មែរម្ដងទៀតនោះទេ បានឈ្មោះថាយើងល្ងង់ណាស់។

- ទាហានកៅ៖ លោកឈិត! ឆ្លៀតឱកាសដែលទ័ពបះបោរយើងកំពុងតែខ្លាំងក្លានេះ គួរតែផ្ញើសារមួយទៅក្រុងព្វយុធ្យាថ្វាយព័ត៌មានដល់ព្រះចៅយើងក្ដោបយកស្រុកខ្មែរតែម្ដងទៅទាន!

- តេជោយ៉ត៖ ព្រះករុណាថ្លៃវិសេស! ពួកឈ្លើយសឹកសៀមរាប់ម៉ឺននាក់នោះគឺបន្សល់ទុកមកពីចម្បាំងរវាងនគរនិងនគរ។ ដូច្នេះជាភារកិច្ចរបស់មេទ័ពហ្លួងទេ ដែលត្រូវចេញទៅបង្ក្រាប។ ក្នុងតម្រាពិជ័យសង្គ្រាមចែងថា ដើម្បីដណ្ដើមជ័យជម្នះពីខ្មាំងសត្រូវបាន មេទ័ពម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវលក្ខណៈ១២ប្រការ។ លោកឧកញ៉ាក្រឡាហោមនិងលោកឧកញ៉ាចក្រីប្រហែលមានការថ្លោះធ្លោយលើប្រការណាមួយហើយទើបត្រូវបរាជ័យយ៉ាងនេះ។ ដូច្នេះថ្វីបើទូលព្រះបង្គំជាមេទ័ពមកពីអាណាខេត្តមែន ប៉ុន្តែដើម្បីប្រទេសជាតិ ទូលព្រះបង្គំស្ម័គ្របម្រើជាតិជានិច្ចក្រាបទូល!

**២- សេដ្ឋកិច្ច**

២.១- កសិកម្ម៖ ប្រជាជនប្រកបរបរធ្វើស្រែចម្ការជាលក្ខណៈគ្រួសារនៅតាមភូមិស្រុកនានា។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- តេជោមាស៖ អូនស្រែន្យ! ស្ដេចសម្រែវាបានគាបសង្កត់ រឹបអង្គាសស្រូវអង្ករប្រជារាស្ត្រ ហើយកេណ្ឌ កៀរពលសឹកគ្រគឹកគគ្រេងប្រាថ្នា ទៅឡោមព័ទ្ធវាំងឧដុង្គធ្វើឱ្យប្រជារាស្ត្រខកខានធ្វើស្រែចម្ការបាត់បង់ភាពសុខសាន្តក្នុងនគរ។ដូច្នេះ បើឱ្យជនក្បត់ជាតិនេះនៅបន្តសកម្មភាពតទៅទៀត មិនយូរមិនឆាប់ប្រទេសជាតិនឹងត្រូវធ្លាក់ទៅក្នុងគ្រោះមហន្តរាយជាមិនខានទេណាអូន!

២.២- ផលិតកម្ម សិប្បកម្ម៖

- ផលិតកម្ម៖ មានផលិតពូក ខ្នើយ សម្លៀកបំពាក់ ដេប៉ាក់ តម្បាញ ស្រា ថ្នាំសណ្ដំជាដើម។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- ស្ដេចសម្រែ៖ អូ! អូ! ក្រយា! យី! ជំទាវប៉ិនប្រសប់តុបតែងទីលំនៅស្អាតរុងរឿងប្រៀបបាននឹងវាំងស្ដេច។ យី! មើល៍...នែ៎...អើ! តាំងពីពូកខ្នល់ខ្នើយសុទ្ធតែប៉ាក់ជិនរំលេចទឹក

មាស។ យី! ព្រះក្រយាស្ងោយក៏មានឱជារសក្រអូបឈ្ងុយឈ្ងប់។ អូនេ៎! ស្រាក៏ឆ្ងាញ់។ យី! គ្រប់សព្វទាំងអស់ជំទាវ ហ៊ឺះ!ហ៊ឺះ!

- ឧកញ៉ាពិភា៖ តាមការពិតក្នុងស្រានេះមានថ្នាំសណ្ដំទេតើ!

- អ្នកបម្រើ៖ អូ! ស្អាតណាស់ស្លៀកហូលពណ៌បៃតង ពាក់អាវកម្ពីខ្លាញ់ក្ដាមអញ្ចឹង វាស៊ីជាមួយសាច់សរបស់អ្នកនាងតែម្ដងចាស៎!ហើយវាសមនឹងសក់វែងអន្លាយដល់ចង្កេះហើយពាក់កងដៃពេជ្យ មើលទៅស្អាតប្រៀបដូចនារីសួគ៌នៅក្នុងរឿងព្រេងអញ្ចឹងណាអ្នកនាង។

- សិប្បកម្ម៖ មានការផលិត អាវុធមានដាវ លំពែង និងចម្លាក់ជាដើម។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- ឧកញ៉ាពិភា៖ ឯផ្ទះលក់អាវុធនោះ គឺមានសុទ្ធតែកាំបិតផ្គាក់ហើយនិងដាវល្អៗណាំព្រះអង្គ។

- ជំទាវស្រែន្យ៖ ហ៊ឺ! យ៉តកំប្លែងណាស់ ស្ពានថាលាបពណ៌ល្អស្អាតនិងតុបតែងវិចិត្រប៉ុណ្ណឹងខ្ញុំមើលមិនដឹងឬ? រូបសំណាកនិងរូបព្រះពុទ្ធនោះឆ្លាក់អំពីឈើមិនមែនថ្មទេណាយ៉ត!

២.៣- ពាណិជ្ជកម្ម៖ នៅក្នុងរឿងតេជោយ៉តបង្ហាញពីការលក់ដូរក្នុងស្រុក។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- ស្ដេចសម្រែះ អើ! មិនតែប៉ុណ្ណោះ មហាតលិកវាបានទូលថាពួកអ្នកបម្រើរបស់ជំទាវស្រែន្យដែលកាន់កាប់ផ្ទះលក់ត្រីងៀតនិងផ្ទះលក់អាវុធទាំងនោះ។

**៣- សង្គមកិច្ច**

៣.១- ស្ថានភាពរស់នៅ៖ ប្រជាជនជួបការលំបាកដោយសារប្រទេសកើតសង្គ្រាម រស់នៅក្នុងភាពភ័យខ្លាច រួមទាំងជួបការលំបាកក្នុងជីវភាពផង។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- តេជោមាស៖ អូនស្រែន្យ! ស្ដេចសម្រែវាបានគាបសង្កត់ រឹតអង្គាសស្រូវអង្គប្រជារាស្ត្រ ហើយកេណ្ឌកៀរពលសឹកគ្រឹកគគ្រេងប្រាថ្នា ទៅឡោមព័ទ្ធវាំងឧដុង្គធ្វើឱ្យប្រជារាស្ត្រខកខានធ្វើស្រែចម្ការបាត់បង់ភាពសុខសាន្តក្នុងនគរ។ ដូច្នេះ បើឱ្យជនក្បត់ជាតិនេះនៅបន្តសកម្មភាពតទៅទៀត មិនយូរមិនឆាប់ប្រទេសជាតិនឹងត្រូវធ្លាក់ទៅក្នុងគ្រោះមហន្តរាយជាមិនខានទេណាអូន!

៣.២- សុខាភិបាល៖ ក្នុងសាច់រឿងបង្ហាញខ្លះៗពាក់ព័ន្ធជាមួយវិស័យសុខាភិបាលដូចជាការប្រើថ្នាំសណ្ដំ ការប្រើថ្នាំព្យាបាលរបួស។ ជាក់ស្ដែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- ឧកញ៉ាពិភា៖ តាមការពិតក្នុងស្រានេះមានថ្នាំសណ្ដំទេតើ!

- ជំទាវស្រែន្យ៖ នេះថ្នាំព្យាបាលរបួសដែលបងតែងដាក់តាមខ្លួន អូនបានរៀបចំជូនបងសព្វគ្រប់អស់ហើយ។

៣.៣- មុខរបរនិងជីវភាពៈ ប្រជាជនប្រកបរបរធ្វើស្រែចម្ការ លក់ដូរ ចម្លាក់ ចាងដែក នេសាទជាដើម។ ជីវភាពប្រជាជនមាន អ្នកមានជាត្រកូលអភិជន អ្នកមធ្យម អ្នកក្រជាប្រជាជនតូចតាចជាដើម។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គៈ

- ម៉ឺនចៃចុងរ៉ាក់ៈ ពួកយើងជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ មានទ្រព្យសម្បត្តិស្តុកស្តម្ភមានមុខមាត់យើងត្រូវការសប្បាយហ៊ឺហា...។

- ស្តេចសម្រេះ ...ហាស! ហាស! ហា! ឥឡូវនេះនារីស្រែន្យមកបើកផ្ទះលក់ត្រីងៀតនិងលក់គ្រឿងអារុធនៅនឹងផ្សារកំពង់ហៅមែនទេ?

**៤- វប្បធម៌**

៤.១- ជំនឿ ប្រពៃណី ទំនៀមទម្លាប់

- ជំជឿៈ ប្រជាជនខ្មែរមានជំនឿជឿលើមន្តអាគម គឺមន្តវិជ្ជាហៅទឹកភ្លៀង។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គៈ

- ឧកញ៉ាពិភាៈ ករុណាថ្លៃវិសេស! ទូលបង្គមបានរៀបបំពេញព្រះរាជបំណាងរបស់ព្រះអង្គប្រកបដោយជោគជ័យយ៉ាងប្រសើរ ព្រោះទូលបង្គំបានចាត់ឱ្យមនុស្សដើរឃោសនាបញ្ចុះបញ្ចូលប្រជារាស្ត្រថា ព្រះសម្រេរាជាធិរាជចេះមន្តវិជ្ជាហៅទឹកភ្លៀងក្រាបទូល។

- ប្រពៃណីៈ តាមរយៈសាច់រឿងបានបង្ហាញប្រពៃណីក្នុងការរៀបអាពាហ៍ពិពាហ៍ និងការធ្វើបុណ្យទានជាដើម។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គៈ

- ជំទាវស្រែន្យៈ ចាំស! ខ្ញុំសូមអរគុណលោកទុកជាមុន។ អូ៎! ខ្ញុំនឹកឃើញហើយ នៅថ្ងៃ៨រោចខាងមុខនេះ ខ្ញុំត្រូវរៀបមង្គលការក្មួយម្នាក់។ ដូច្នេះ ខ្ញុំសូមពឹងលោកបានទេ?

- តេជោយ៉តៈ មិនអីទេ! ខ្ញុំនឹងព្យាយាមធ្វើឱ្យនាងភ្ញាក់រឭក លោកត្រូវចាត់ចែងសង់រោងឱ្យធំដើម្បីធ្វើបុណ្យរំលឹកដល់វិញ្ញាណក្ខន្ធរបស់គ្រូខ្ញុំណា។

- ទំនៀមទម្លាប់ៈ មានទំនៀមទម្លាប់ឱ្យកូនស្រីចូលម្លប់។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គៈ

- ឧកញ៉ាពិភាៈ ព្រះករុណាថ្លៃវិសេស ក៏ប៉ុន្តែមិនទាន់មានកូនមួយសោះ។ ឯចំណែករូបសោតទៀតនេ៎ សាច់ក៏ល្អស្អាតលើសស្រីក្រមុំព្រហ្មចារិយដែលទើបចេញពីម្លប់ទៀតណា៎ព្រះអង្គ។

៤.២- សាសនាៈ ប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនា មានការធ្វើបុណ្យទានតាមបែបព្រះពុទ្ធសាសនា មានព្រះពុទ្ធរូបជាដើម។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គៈ

- តេជោយ៉តៈ ឯរូបសំណាកលោកគ្រូនិងព្រះពុទ្ធរូបដែលខ្ញុំឱ្យជាងឆ្លាក់ពីថ្ងៃមុននោះត្រូវយកទៅតម្កល់លើអាសនៈកណ្តាលរោងបុណ្យណា៎! ដើម្បីធ្វើសក្ការៈបូជា។ សូមលោកជួយចាត់ចែងឱ្យបានអធឹកអធមណា។

៤.៣- ការសិក្សាអប់រំៈ តាមរយៈសាច់រឿងមិនមានបង្ហាញច្បាស់លាស់អំពីបញ្ហាការសិក្សាអប់រំនោះទេ។ ប៉ុន្តែមានការបង្រៀនសិស្សជាលក្ខណៈបុគ្គលដោយជាមួយគ្រូផ្ទាល់ដូចជាតេជោយ៉តបានរៀនសូត្រចំណេះវិជ្ជាខាងសឹកសង្គ្រាម ខាងវិជ្ជាគុន ជាមួយតេជោមាសជាគ្រូ។

ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- យ៉ត៖ លោកគ្រូ! រាល់ទិវារាត្រី ខ្ញុំនឹកមិនភ្លេចចំពោះឧបការគុណរបស់លោកគ្រូដែលមានចំពោះខ្ញុំ។ យ៉ត ខ្ញុំនេះជាកូនជនជាតិភាគតិចកំព្រាឪពុកម្តាយ ដើរសាត់គាត់សែងត្រែងត្រូវអ្នកផងទាំងពួងគេមើលងាយមើលថោកហៅថាអាកូនព្នង។ គេបណ្តេញមិនឱ្យចូលជិតគេ។ ខ្ញុំឈឺចាប់ណាស់ចំពោះការបែងចែកវណ្ណៈនិងប្រកាន់ពូជសាសន៍នេះ។ ទើបតែពេលបានជួបលោកគ្រូទេដែលការឈឺចាប់ទាំងប៉ុន្មានត្រូវបានជំនួសវិញដោយក្តីសង្ឃឹមយ៉ាងរីករាយ។ លោកគ្រូមិនត្រឹមតែបីបាច់ថែរក្សាយ៉ាងសមរម្យប៉ុណ្ណោះទេថែមទាំងបង្ហាត់បង្រៀនគុនវិជ្ជានិងអក្សរសាស្ត្រខ្ញុំរហូត ខ្ញុំកសាងខ្លួនបានប៉ុណ្ណេះគឺលោកគ្រូមានសប្បុរសធម៌មិនប្រកាន់វណ្ណៈ...។

៤.៤- សិល្បៈ៖ មានសិល្បៈក្រុមភ្លេងតន្ត្រីភ្លេង សិល្បៈក្នុងការតុបតែងរចនា ដេរប៉ាក់ ចម្លាក់ជាដើម។ ជាក់ស្តែងក្នុងសាច់រឿងបានបញ្ជាក់តាមរយៈតួអង្គ៖

- ជំទាវស្រែន្យ៖ ឯណាបងប្អូនអ្នកភ្លេង ឆាប់ប្រគំកំដរព្រះរាជាភ្លាមទៅ។

- ជំទាវស្រែន្យ៖ ចាំ! អូនចាក់ស្រោមខ្នើយថ្មីមួយទៀត ទុកចងដៃយ៉តនៅពេលដែលវារៀបអាពាហ៍ពិពាហ៍ ព្រោះខ្ញុំឮថា បុត្រីលោកឧកញ៉ាព្រហ្មស្រីទ្វារប្រាសាទដប់ធ្លាប់លួចស្រឡាញ់យ៉តណា!

- ស្តេចសម្រែ៖ អូ! អូ! ក្រយា! យី! ជំទាវប៉ិនប្រសប់តុបតែងទីលំនៅស្អាតរុងរឿងប្រៀបបាននឹងវាំងស្តេច។ យី! មើល៍...នែ៎...អើ! តាំងពីពូកខ្នល់ខ្នើយសុទ្ធតែប៉ាក់ឌិនរំលេចទឹកមាស។ យី! ព្រះក្រយាស្ងោយក៏មានឱជារសក្រអូបឈ្ងុយឈ្ងប់។ អូនែ៎! ស្រាក៏ឆ្ងាញ់។ យី! គ្រប់សព្វទាំងអស់ជំទាវ ហ៊ឺះ!ហ៊ឺះ!

## III. ការសន្និដ្ឋាន

រឿងតេជោយ៉តជាវណ្ណកម្មអក្សរសិល្ប៍មួយ ដែលបានលាតត្រដាងពីវីរភាពអង់អាចក្លាហានក្នុងការប្រយុទ្ធប្រឆាំងនឹងពួកសៀមឈ្លានពាន។ តួអង្គឯកជាវីរៈជនឆ្នើមរបស់ជាតិមានវីភាពប្រកបដោយភក្តីភាព គុណធម៌ មនសិការស្នេហាជាតិមាតុភូមិក្នុងរបបគ្រប់មួយបែបរាជានិយមនាសម័យឧដុង្គ។ ចំណុចលេចធ្លោរមួយនៅក្នុងរឿងនេះគឺការលើកតម្កើងស្ត្រីក្នុងការចូលរួមការងារសង្គមជាតិ។ រឿងនេះបង្ហាញពីទឹកចិត្តស្នេហាជាតិផ្សារភ្ជាប់នឹងគ្រួសារដោយយកបញ្ហាជាតិជាធំ។ ដូច្នេះការសិក្សារឿងតេជោយ៉ត ពិតជាបានបង្កប់អត្ថន័យយ៉ាងជ្រាលជ្រៅនូវតម្លៃមនុស្សខ្មែរដែលយកប្រយោជន៍ជាតិជាធំ និងបណ្តុះគំនិតស្នេហាជាតិមាតុភូមិ ស្នេហាព្រះមហាក្សត្រ ថ្នាក់ដឹកនាំរហូតដល់គ្រូបាអាចារ្យដោយមិនគិតថាខ្លួនជាបុរសឬស្ត្រីឡើយ។ ម្យ៉ាងទៀតការសិក្សាស្នាដៃរឿងតេជោយ៉តក៏ទុកជាបទពិសោធមួយសម្រាប់ដោះស្រាយបញ្ហានៅក្នុងសង្គមនិងដើម្បីធ្វើឱ្យសង្គមមានវឌ្ឍនភាព។

# ឯកសារពិគ្រោះ

- យើង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ ១៩៩៨
- ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៩៩
- មីសែលត្រាណេ ការសិក្សារឿងរាមកេរ្តិ៍ ១៩៩៥
- លាង ហាប់អាន សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ រាមាយណៈឥណ្ឌា ១៩៦៦
- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ១៩៨៨
- វេចនានុក្រមវចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ , ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ០៣លេខ ១២ដល់ ថ្នាក់ទី១០ថ្នាក់ទីអយក២០១៦ ខែមករា ឆ្នាំ ០៨ចុះថ្ងៃទី .សណន.
- សេង សោភា សិក្សារបៀបធៀបរឿងរាមកេរ្តិ៍ និងរឿងរាមគៀតថៃ សារណាបញ្ចប់ បរិញ្ញាអក្សរសាស្ត្រខ្មែរ ឆ្នាំ២០០៧
- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
- ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លែង ឆ្នាំ១៩៧៣
- សៀវភៅសិក្សាគោលភាសាខ្មែរ សៀវភៅសិស្សថ្នាក់ទី១០ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១០
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរ សៀវភៅសិស្សថ្នាក់ទី១១ បោះពុម្ពផ្សាយ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៥
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរសៀវភៅសិស្សថ្នាក់ទី១២បោះពុម្ពផ្សាយដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១២
- ទី ជីហ្វត រឿងតេជោយ៉ត (១៩៥២-១៩៨៧) និពន្ធឆ្នាំ១៩៨៣
- លី ធាមតេង សៀវភៅការផ្សាយរបស់អ្នកនិពន្ធខ្មែរ ឆ្នាំ១៩៧២។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង តេមិយជាតក

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:...................................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងតេមិយជាតក»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងតេមិយជាតក »ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ [illegible] ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

## បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## **អារម្ភកថា**

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ“**សិក្សាអត្ថបទអក្សរសិល្ប៍**” ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ«**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង តេមិយជាតក**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី ម៉ៅ តាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក គួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ

ប្រកាស ........................................................................................................i
បុព្វកថា ........................................................................................................ii
គណៈកម្មការ........................................................................................................iii
អារម្ភកថា........................................................................................................iv
មាតិកា........................................................................................................v
សេចក្តីផ្តើម........................................................................................................
I. ការបង្ហាញអត្ថបទ........................................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង........................................................................................................
III. ទិដ្ឋភាពទំនាស់........................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ........................................................................................................
V. ទិដ្ឋភាពសង្គម........................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ........................................................................................................
VII. ទិដ្ឋភាពតម្លៃ........................................................................................................
VIII. ការសន្និដ្ឋាន........................................................................................................
IX. ឯកសារពិគ្រោះ........................................................................................................

# សិក្សាអត្ថបទអក្សរសិល្ប៍

## រឿងតេមិយជាតក

### I-ការបង្ហាញអត្ថបទ

**១-អត្ថបទ**

**- ចំណងជើង :** រឿងព្រះតេមិយជាតក (រឿងទី១ក្នុងទសជាតក)

**- ប្រភព :** គម្ពីរនេះមានប្រភពដើមនៅកោះសិរីលង្កា ដែលសរសេរជាសីឡហៈភាសា។ លុះមកដល់អំឡុងពេលប្រហែលជា៥០០ឆ្នាំ ក្រោយពីព្រះពុទ្ធចូលបរិនិព្វាន ទើបមានពុទ្ធឃោសាចារ្យមួយអង្គ ជាមហាថេរ នៅឥណ្ឌា បាននិមន្តទៅកោះលង្កា ហើយប្រែព្រះត្រៃបិដកពីសីឡហៈភាសា មកជាមគធៈភាសា ទាល់តែចប់។ ក្រោយមក គម្ពីរនេះត្រូវនាំចូលមកក្នុងប្រទេសខ្មែរតាមរយៈការផ្សព្វផ្សាយលទ្ធិពុទ្ធសាសនា។ គម្ពីរទសជាតក ប្រភពដើមជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយជាតក មហានិបាតផ្នែកសុត្តន្តបិដក នៃគម្ពីរព្រះត្រៃបិដក។

- ក្នុងគ.ស ១៩៤៩ ព្រះគ្រូបុរត្ថិមវាសី អ៊ូ ចេរ គង់នៅវត្តលង្កា បានរៀបរៀងគម្ពីរនេះជាលក្ខណៈរឿងសម្រាប់ទេសនា ប៉ុន្តែរហូតដល់ឆ្នាំ១៩៥៨ ទើបសៀវភៅនេះបានចេញផ្សាយ។
- មកដល់ខែឧសភា ១៩៥៩ លោកបណ្ឌិតមហាឈឹម ស៊ុមន៍ សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត បានប្រែបង្រួញចាកភាសាបាលី រៀបរៀងជាសៀវភៅបោះពុម្ពផ្សាយជាលើកទី១ នៅក្នុងឆ្នាំ១៩៦២។ សៀវភៅក្រោយនេះ បានទទួលស្គាល់ជាផ្នែកសៀវភៅសិក្សាមធ្យមភូមិ តាមប្រកាសរបស់ក្រសួងអប់រំជាតិលេខ ១៩៩២ ចុះថ្ងៃទី១៣ មិថុនា ១៩៦២។ មកដល់ឆ្នាំ១៩៦៤ លោកឈឹមស៊ុមន៍ ក៏បាននិពន្ធសៀវភៅមួយទៀត មានចំណងជើងថា «អត្ថនិទស្សន៍» ដែលពន្យល់ទៅលើសេចក្ដីនៃពាក្យក្នុងការសិក្សាជាតក។
- នៅឆ្នាំ១៩៦៥ ក៏មានការបោះពុម្ពផ្សាយរឿងទសជាតកសង្ខេបនេះមួយទៀត ចេញពីរោងពុម្ពសឹង ហេង ដែលចម្លងផ្ទៀងផ្ទាត់តាមច្បាប់សាស្ត្រាស្លឹករឹតដោយលោក ស្ដើង ធូរ ក្រោមការពិនិត្យនិងនិវេទន៍របស់លោកលី ធាមតេងគណៈកម្មការស្រាវជ្រាវអក្សរសាស្ត្រខ្មែរ។ សៀវភៅនេះមានលក្ខណៈសង្ខេបខ្លីជាងរបស់ព្រះគ្រូ អ៊ូ ចេរ និងព្រះមហា ឈឹម ស៊ុមន៍ ទៅទៀត សម្រាប់ឱ្យអ្នកអានអាចអានចប់ក្នុងរយៈពេលខ្លី ងាយចងចាំសាច់រឿង។
- នៅឆ្នាំ១៩៦៥ ដដែលនេះ លោក ឱម ណាគ្រី បានយករឿងទសជាតកនេះ មកធ្វើអត្ថាធិប្បាយ បង្កើតបញ្ហាចោទ និងដោះស្រាយជារបៀបអត្ថបទតែងសេចក្ដី ដើម្បីឱ្យអ្នកដែលមានចំណង់ចំណូលចិត្តចង់ចេះចង់ដឹងក្នុងរឿងទសជាតកនេះ បានយល់កាន់តែច្បាស់នូវអាថ៌កំបាំងនិងគោលគំនិត ឧត្តមគតិក្នុងរឿងនីមួយៗបានច្បាស់លាស់។ សៀវភៅនោះមានចំណងជើងថា «អត្ថាធិប្បាយទសជាតក» ចុះកាលបរិច្ឆេទ ថ្ងៃទី២៩ សីហា ១៩៦៥។

**-ប្រភេទ** : រឿងតេមិយជាតក ស្ថិតនៅក្នុងប្រភេទអក្សរសិល្ប៍បុរាណ។ និយាយអំពីការកសាងនេក្ខម្មបារមី។ សរសេរជាភាសាខ្មែរ ដែលបានបកប្រែចេញពីភាសាបាលី ដកស្រង់ចេញពីគម្ពីរព្រះត្រៃបិដក។

**២-អ្នករៀបរៀង**

លោកសាស្ត្រាចារ្យ ឈឹម ស៊ុមន៍ កើតក្នុងឆ្នាំ១៩០៥ ព.ស ២៤៥០ នៅឃុំបសេដ្ឋ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ លោកបានសាងផ្នួសបួសជាសាមណេរក្នុងអាយុ១២ឆ្នាំ (ព.ស ២៤៦២) បានសិក្សាក្នុងសំណាក់លោកគ្រូអាចារ្យកន នៅឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាអ្នកប្រាជ្ញដ៏ឆ្នើមក្នុងសម័យនោះ។ លុះដល់លោកមានអាយុ២០ឆ្នាំ បានចូលរៀនមូលកច្ចាយនៈវេយ្យាករណ៍ និងសម្ព័ន្ធក្នុងសំណាក់ព្រះតេជគុណព្រះវិតទ្ធញ្ញាណសោម ឡុច (មហា៩ប្រយោគ) វត្តលង្កាក្រុងភ្នំពេញ។ អាយុ២១ឆ្នាំ ទើបឧបសម្បទាជាភិក្ខុភាវ ជាសិស្សសាលាបាលីជាន់ខ្ពស់ ហើយទទួលបានការសិក្សាផ្ទាល់ពីសម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណ ជួន ណាត ដែលជាព្រះសង្ឃរាជគណៈមហានិកាយ។ ក្នុងឆ្នាំដដែលនេះ លោកបានប្រឡងជាប់សាលាបាលីជាន់ខ្ពស់ ហើយបានធ្វើជាគ្រូឧទ្ទេសាចារ្យបង្រៀនបាលីនៅវត្តលង្កាកុសុមារាម ក្រុងភ្នំពេញ ដែលមានសិស្សច្រើនបំផុតជាងវត្តទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា នាសម័យនោះអស់រយៈពេល៥ឆ្នាំ។ លោកបានបង្រៀនវិជ្ជាខ្មែរ ដល់សិស្សខ្មែរមកពីវៀតណាមខាងត្បូង និងសិស្សឡាវមកពីប្រទេសឡាវ និងកូនចៅពួកទាហាន។

ក្រោយមក លោកសាស្ត្រាចារ្យ ឈឹម ស៊ុមន៍ បានលាចាកសិក្ខាបទ មកជាគ្រហស្ថមានភរិយាឈ្មោះ មុត សៀក និងមានកូនប្រុសម្នាក់ឈ្មោះ ឈឹម សុមេធ (បម្រើការនៅវិទ្យុសហរដ្ឋអាមេរិក បច្ចុប្បន្ននេះ)។ លោកបណ្ឌិតមហាឈឹម ស៊ុមន៍ បានទទួលអនិច្ចកម្មប្រហែលជាក្នុងឆ្នាំ១៩៧៥។

ចំពោះឋានៈ និងតួនាទីក្នុងសង្គម លោក ៖

- សាស្ត្រាចារ្យបង្រៀនបាលីរង វត្តលង្កា ក្រុងភ្នំពេញ
- សមាជិកក្រុមជំនុំបកប្រែព្រះត្រៃបិដក
- សាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះបាទសុរាម្រឹត ភ្នំពេញ
- សមាជិកក្រុមអភិបាលនៃសមាជិកអ្នកនិពន្ធខ្មែរ

**- ស្នាដៃ**

រាប់ទាំងទសជាតកនេះផង លោកបានបន្សល់ស្នាដៃចំនួនចំនួន៣០ចំណងជើងទៀត មានដូចជាវេយ្យាករណ៍បាលី ពុទ្ធប្រវត្តិកថា អធិប្បាយគាថា ធម្មបទភាគ១ ២ ៣ និង ភាគ៤...។

បន្ថែមពីលើនេះ លោកបណ្ឌិតមហា ឈឹម ស៊ុមន៍ ក៏មានស្នាដៃតែងក្នុងទស្សនាវដ្តីកម្ពុជសុរិយានិងទស្សនាវដ្តីពន្លឺពុទ្ធចក្រមិត្តសាលាបាលីពុទ្ធិកសិក្សាជាដើមទៀតផង។

**៣-កាលកំណត់រៀបរៀង**

រឿងដែលយើងយកមកសិក្សានេះ ស្ថិតនៅ សង្ខេបទសជាតក របស់

បណ្ឌិតមហាឈឹម ស៊ុមន៍ សាស្ត្រាចារ្យនៅព្រះពុទ្ធិកវិទ្យាល័យព្រះបាទសុរាម្រឹត នៅភ្នំពេញ ទំព័រ៥៤ ដល់៧៥។

ចំពោះសៀវភៅទសជាតកដែលមានការនិយមរាប់អានភាគច្រើន និងត្រូវបានក្រសួងអប់រំដកស្រង់យកមកសិក្សា ក្នុងកម្មវិធីសិក្សានៅថ្នាក់ចំណេះទូទៅនោះ គឺសៀវភៅ «សង្ខេបទសជាតក» របស់បណ្ឌិតមហា ឈឹម ស៊ុមន៍។ សៀវភៅនេះ យើងឃើញមានការបោះពុម្ពផ្សាយចំនួន៦លើក គឺ ៖

- បោះពុម្ពលើកទី១ ព.ស ២៥០៥ គ.ស ១៩៦៣ រោងពុម្ពតារា
- បោះពុម្ពលើកទី២ ព.ស ២៥០៧ គ.ស ១៩៦៥ រោងពុម្ពសំរងវណ្ណ
- បោះពុម្ពលើកទី៣ ព.ស ២៥០៨ គ.ស ១៩៦៦ រោងពុម្ពអ៊ុក ម៉ី កូស
- បោះពុម្ពលើកទី៤ ព.ស ២៥១០ គ.ស ១៩៦៨ រោងពុម្ពអ៊ុក ម៉ី កូស
- បោះពុម្ពលើកទី៥ ព.ស ២៥១៣ គ.ស ១៩៦៩ រោងពុម្ពតារារស្មី
- បោះពុម្ពលើកទី៦ ព.ស ២៥១៤ គ.ស ១៩៧១ រោងពុម្ពតារារស្មី

**៩-សង្គមបរិយាកាស**

- **កាលប្រវត្តិ** (សម័យកាលតាក់តែងរឿង)

រឿងដើម កើតឡើងក្នុងបរិយាកាសនៃសម័យពុទ្ធកាល ក្រោយពេលដែលព្រះពុទ្ធអង្គបានត្រាស់ដឹង ក្នុងបរិយាកាសសង្គមឥណ្ឌា សម័យដែលព្រហ្មញ្ញសាសនាកំពុងមានអត្ថិភាព និងមានការរីកចម្រើនក្នុងដំណាក់កាលដំបូងដែលព្រះពុទ្ធសាសនាពុំទាន់មានការរីកចម្រើនប៉ុន្មានទេ។ លុះក្រោយមក ក្នុងរជ្ជកាលព្រះបាទ កនិស្កៈ ប្រមាណក្នុងស.វទី១ ក្នុងគ.ស ពុទ្ធសាសនាចែកជាពីរនិកាយ គឺនិកាយហិនយាន ក្នុងរជ្ជកាលព្រះបាទអសោក ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញទាំងក្នុងប្រទេសឥណ្ឌា និងទាំងក្រៅប្រទេស។

ចំពោះក្នុងប្រទេសកម្ពុជាយើងវិញ ពុំឃើញមានសល់ឯកសារចាស់ៗពីសម័យបុរាណមកទេ។ ក្រោយការចូលមកដល់លទ្ធិពុទ្ធសាសនាបន្តិច ឬក្នុងដំណាក់កាលប្រហាក់ប្រហែលគ្នា លទ្ធិព្រហ្មញ្ញសាសនាក៏ចូលមកដល់ដែរ ប៉ុន្តែ ក្រោយសម័យអង្គរ គឺសម័យលង្វែក និងសម័យឧត្តុង្គ យើងឃើញនៅមានឯកសារសេសសល់ សរសេរជាសាស្ត្រាស្លឹករឹតខ្លះ។ បើតាមសិលាចារឹក វ៉ូ កាញ់ (នៅវៀតណាមខាងត្បូង) ទំនងជាពុទ្ធសាសនាចូលមកប្រតិស្ឋានក្នុងប្រទេសខ្មែរនៅស.វទី២ នៃគ្រឹស្តសករាជ ក្នុងរជ្ជកាលព្រះបាទស្រីមារៈ ឬហ្វាន់ចេម៉ាន់។ សង្គមបរិយាកាសនៅសម័យនោះបានឆ្លងកាត់នូវចម្បាំងរវាងគ្នាឯងយ៉ាងច្រើន សង្គ្រាមជាមួយបរទេស ឬសង្គ្រាមបរទេស និងបរទេសនៅក្នុងប្រទេសកម្ពុជាក៏មាន។ ក្នុងរយៈពេលដ៏ជូរចត់នេះ ប្រជាជនខ្មែរមានពុទ្ធសាសនានេះ ជាទីពឹង ជាទីគោរពបូជា និងបានជាកម្លាំងមួយយ៉ាងសំខាន់ក្នុងការអប់រំផ្លូវចិត្តខ្មែរ ឱ្យដឹងអំពើល្អ អាក្រក់ និងអំពើបុណ្យបាប ឱ្យចេះសាមគ្គីគ្នា ឱ្យចេះការពារវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីឱ្យគង់វង្សរហូតដល់សព្វថ្ងៃ។

- **ព្រឹត្តិការណ៍សំខាន់ៗ**

ព្រឹត្តិការណ៍ផ្សេងៗទាក់ទងសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣)

• នៅថ្ងៃ១១ សីហា ១៨៦៣ បារាំងបានតាំងអាណាព្យាបាលភាពរបស់ខ្លួនលើខ្មែរ ដោយបានចុះហត្ថលេខារវាងទេសាភិបាលបារាំង លោក Dela Grandiere និងព្រះបាទនរោត្តម លើសន្ធិសញ្ញាមិត្តភាព ការការពារ និងពាណិជ្ជកម្មជាមួយគ្នា។ នៅថ្ងៃ១៧ មិថុនា ១៨៨៤ បារាំងបានយក កប៉ាល់ចម្បាំងទៅឡោមព័ទ្ធវាំង ហើយបង្ខំឱ្យព្រះបាទនរោត្តម ចុះព្រះហស្តលេខាលើអនុសញ្ញាដកហូតអំណាចទាំងឡាយរបស់ព្រះអង្គ។ ប្រព័ន្ធរដ្ឋបាល ហិរញ្ញវត្ថុ តុលាការ ពាណិជ្ជកម្ម ត្រូវកែទម្រង់ ចំណែកក្រសួងគយ ពន្ធដារ សាធារណការ និងក្រសួងឯទៀត ដែលមានប្រើវិស្វករ ត្រូវបារាំងកាន់កាប់ដោយផ្ទាល់។

• នៅថ្ងៃ២៤ មេសា ១៩០៤ ព្រះបាទនរោត្តមសោយទិវង្គត។ នៅវេលាម៉ោង៣ និង២០ នាទី នាថ្ងៃខែឆ្នាំដដែល គណៈរដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់ (បព្វជិត និងគ្រហស្ថ) និងរ៉េស៊ីដង់ស៊ុបប៉េរីយើ បានសម្រេចជ្រើសរើសព្រះបាទស៊ីសុវត្ថិ ឱ្យឡើងសោយរាជ្យ។ ព្រះអង្គបានកែប្រែស្ថាប័នរដ្ឋបាលនានាឱ្យទំនើបឡើង កសាងគមនាគមន៍ជាច្រើន ព្រមទាំងសមិទ្ធផលផ្សេងៗទៀត។[1]

• ឆ្នាំ១៩១៦ ព្រះបាទស៊ីសុវត្ថិ អនុញ្ញាតឱ្យបារាំងកែនរាស្ត្រខ្មែរ ធ្វើទាហានយកទៅច្បាំងនៅប្រទេសបារាំង ក្នុងសង្គ្រាមលោកលើកទី១ (១៩១៤-១៩១៨) ដើម្បីជាការដឹងគុណចំពោះរដ្ឋការបារាំង។ នៅថ្ងៃ ១៨ មេសា ១៩២៥ នៅឃុំក្រាំងលាវ ខេត្តកំពង់ឆ្នាំង ដោយអត់ទ្រាំនឹងការជិះជាន់ពីបារាំងពុំបានក៏បះបោរឡើង រហូតដល់សម្លាប់រ៉េស៊ីដង់បារាំងឈ្មោះបាដេស។[2]

## ព្រឹត្តិការណ៍ទាក់ទងអក្សរសាស្ត្រសម័យអាណានិគមបារាំង

• វត្តមាននៃភាសាបាលី លេចរូបរាងឡើង តាមរយៈព្រះពុទ្ធសាសនា វត្តអារាម និងព្រះសង្ឃ។ នៅរជ្ជកាលព្រះបាទអង្គឌួង (១៨៤០-១៨៥៩) ព្រះអង្គបានគាំទ្រ និងយកព្រះទ័យទុកដាក់លើវិស័យអក្សរសាស្ត្រជាតិជាខ្លាំង ដោយព្រះអង្គទ្រង់បានបង្កើតសាលាតាមវត្តជាច្រើន លើកទឹកចិត្តពួកអ្នកប្រាជ្ញបណ្ឌិត កវី ដោយទ្រទ្រង់ជាលុយកាក់ និងមធ្យោបាយផ្សេងៗដល់ជនណាដែលស្វែងរកចំណេះវិជ្ជា។ ចំពោះសាសនា និងអក្សរសាស្ត្រវិញ ព្រះអង្គបានបរិច្ចាគព្រះរាជទ្រព្យដល់ព្រះសង្ឃសម្រាប់កសាងវត្តអារាម និងចំណាយផ្សេងៗតាមព្រះពុទ្ធបញ្ញត្តិ។

• គប្បីជ្រាបថា នៅសម័យអាណានិគមនិយមបារាំង វិស័យអក្សរសាស្ត្រជាតិ ត្រូវបានធ្លាក់ចុះយ៉ាងខ្លាំង។ បារាំងបានបញ្ចូលវប្បធម៌ពុករលួយ (វប្បធម៌អាណានិគម មិនមែនវប្បធម៌របស់ប្រជាជនបារាំងទេ) មកក្នុងប្រទេសខ្មែរ បានបង្ខំឱ្យកូនចៅខ្មែរបំភ្លេចក្បួនខ្នាតរបស់ជាតិ ដែលសុទ្ធសឹងមានខ្លឹមសារល្អៗ។ បារាំងបានបណ្តុះ និងបង្ខំឱ្យកវីខ្មែរ ឬអ្នកនិពន្ធខ្មែរសរសេរលើកតម្កើងជាតិបារាំងបង្អាប់បន្តុះខ្មែរ បង្វិលខួរក្បាលខ្មែរឱ្យនឹកឃើញថាក្រុងប៉ារីសជា

[1] យឹង ហុកឌី អក្សរសិល្ប៍ខ្មែរសតវត្សទី២០ កវីនិពន្ធ និងកម្រងអត្ថបទ ២០០៧។

[2] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ឆ្នាំ ១៩៧៣។

បានសួគិ បារាំងជាទេវតា។

• នៅឆ្នាំ១៩០៤ គេបង្កើតសាលាអប់រំសម្រាប់មធ្យមសិក្សា គឺអនុវិទ្យាល័យព្រះស៊ីសុវត្ថិ នៅភ្នំពេញ។ នៅឆ្នាំ១៩០៧ បង្កើតគណៈកម្មការពីរសម្រាប់ចងក្រងរាជពង្សាវតារខ្មែរ គឺគណៈកម្មការទី១មានលោកឧកញ៉ា វាំង ជួន ជាប្រធាន គណៈកម្មការទី២ មានលោកឧកញ៉ាវង្សាអគ្គរាជ ឌុច ជាប្រធាន។ នៅថ្ងៃទី ០៤ កញ្ញា ១៩១៥ ព្រះបាទស៊ីសុវត្ថិទ្រង់បង្កើតគណៈកម្មការមួយ ដើម្បីរៀបចំវចនានុក្រមខ្មែរជាលើកដំបូង និងឆ្នាំ១៩២១ ទ្រង់កសាងសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ។ នៅថ្ងៃ ១៤ វិច្ឆិកា ១៩២៩ បង្កើតក្រុមជំនុំព្រះត្រៃបិដកមានភារៈបកប្រែព្រះត្រៃបិដក មានទាំងអស់ ១១០ក្បាល។ នៅឆ្នាំ១៩៣០ ព្រះបាទស៊ីសុវត្ថិមុនីវង្ស ឱ្យបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដើម្បីសិក្សាស្រាវជ្រាវពីព្រះពុទ្ធសាសនា រៀបចំសិក្សាភាសាបាលី ពុទ្ធលទ្ធិ ក្នុងខេត្តទាំងឡាយនៃកម្ពុជា និងបង្កើតសាលាអនុវត្តសម្រាប់ព្រះសង្ឃ (សង្ឃគ្រូរៀនវិធីបង្រៀនបែបបទំនើប)។[3]

• នៅឆ្នាំ១៩៤២ សង្គ្រាមឆត្របានផ្ទុះឡើង លោកអាចារ្យ ហែម ចៀវ ជាអ្នកដឹកនាំចលនាបាតុកម្មរបស់ព្រះសង្ឃ នៅវត្តឧណ្ណាលោម មូលហេតុដោយសារ បារាំងចង់លុបបំបាត់អក្សរខ្មែរឱ្យទៅជាអក្សរឡាតាំង (ឡាតាំងនីយកម្ម)។ ក្រោយពីសង្គ្រាមលោកលើកទី២ បារាំងក៏បានយល់ព្រមដាក់ប្រទេសខ្មែរ ក្នុងអាណានិគមធូរស្រាល លុះដល់ឆ្នាំ១៩៥៣ កម្ពុជាក៏បានទទួលឯករាជ្យពេញលេញ។

## II-**ទិដ្ឋភាពទំនាក់ទំនងរឿង**

### ១- សង្ខេបរឿង

កាលព្រះពុទ្ធជាព្រះបរមសាស្ត្រាចារ្យ គង់នៅវត្តជេតពន ទ្រង់ប្រារព្ធនូវមហាភិនិក្ខមបារមី ទ្រង់សម្តែងធម៌ទេសនាថា **មាបណ្ឌិច្ចយំវិភាវយ** ដូច្នេះជាដើម។

សេចក្តីថា : ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងសាលាធម្មសភា សរសើរនូវមហាភិនិក្ខមបារមីរបស់ព្រះមានបុណ្យ។ ព្រះអង្គទ្រង់បុច្ឆាថា អ្នកទាំងឡាយ ប្រជុំនិយាយនូវរឿងអ្វី? ភិក្ខុទាំងនោះ ក្រាបបង្គំទូលតាមដំណើរ។ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា ឥឡូវនេះ តថាគតមានបារមីពេញគ្រប់គ្រាន់ ហើយលះបង់រាជសម្បត្តិ ទៅសាងមហាភិនិស្ក្រមណ៍ មិនអស្ចារ្យទេ បើពីដើមទើបអស្ចារ្យ។ កាលភិក្ខុទាំងឡាយ អារាធនា ក៏ព្រះអង្គទ្រង់សម្តែងនូវអតីតនិទានដូចតទៅនេះ ៖

អតីតេ ភិក្ខវេ ពារាណសីយំ កាសិករាជ នាមធម្មេន សម្មេន រជ្ជំ ការេសិ...។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលកន្លងទៅហើយ ព្រះមហាក្សត្រព្រះនាម កាសិការាជ សោយរាជ្យតាមច្បាប់ មានសមភាពក្នុងនគរពារាណសី។ ទ្រង់ពុំមានព្រះរាជបុត្រ ឬព្រះរាជធីតា សូម្បីមួយព្រះអង្គសោះ។ អ្នកនគរភ័យខ្លាចផុតព្រះរាជវង្ស ទើបទ្រង់ឱ្យស្រីស្នំទាំង១ម៉ឺន៦ពាន់នាក់បួងសួងសុំបុត្រ។ ព្រះអគ្គមហេសីព្រះនាមចន្ទា ជាព្រះរាជធីតានៃព្រះបាទមទ្ទរាជ សមាទាន

---

[3] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ឆ្នាំ ១៩៧៣។

ឧបោសថ ហើយធ្វើសច្ចកិរិយាប្រាថ្នាបុត្រ។ ដោយអំណាចតេជៈសីលឧបោសថ ទើបព្រះឥន្ទ្រាធិរាជអារាធនាព្រះពោធិសត្វជាទេវបុត្រនៅឋានត្រៃត្រឹង្ស ឱ្យមកចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងចន្ទានោះ។ ថ្ងៃដែលព្រះពោធិសត្វប្រសូត្រមកមានភ្លៀងអុរជោគជាំពេញដែនកាសី ហាក់ដូចជាធ្វើហឫទ័យនៃមហាជន ក្នុងប្រទេសឱ្យទទឹកគ្រប់គ្នាព្រោះហេតុនេះ ទើបព្រះរាជាទ្រង់ព្រះរាជទានព្រះនាមព្រះរាជបុត្រនោះថា តេមិយកុមារ។

កាលព្រះពោធិសត្វបានព្រះជន្ម១ខែ ពួកស្រីស្នំនាំគ្នាទៅគាល់ព្រះបរមរាជបិតា។ ព្រះអង្គទ្រង់សព្វព្រះទ័យណាស់ក៏លើកបីទ្រ ហើយនាំទៅផ្ដេកលើព្រះឧរូនាព្រះទីន័ងសម្រាប់គង់វិនិច្ឆ័យទោសចោរ។ ព្រះអង្គវិនិច្ឆ័យទោសចោរបួននាក់ថា ៖ ចោរម្នាក់វាយរ៉ាវដោយរំពាត់ផ្គៅ១ពាន់ខ្ទាប់ ចោរម្នាក់ត្រូវចងដោយច្រវាក់ដាក់ក្នុងពន្ធនាគារ ចោរម្នាក់ត្រូវចាក់សម្លាប់ដោយលំពែង ចោរម្នាក់ទៀត ត្រូវដោតឆ្កាងដោយអណ្ដាត។

ព្រះពោធិសត្វទ្រង់ព្រះសណ្ដាប់សេចក្ដីវិនិច្ឆ័យនោះ ក៏មានព្រះទ័យភិតភ័យគិតថា៖« ឱព្រះរាជបិតា ទ្រង់ធ្វើអំពើសម្រាប់ទៅនរកហើយតើ»។ ព្រះបិតាជ្រាបជាព្រះរាជបុត្រភ័យ ថ្ងៃក្រោយមក ទ្រង់ក៏ឱ្យយកទៅផ្ដេកនាមហាមន្ទីរ ក្រោមស្វេតច្ឆត្រ ដោយរក្សាយ៉ាងម៉ឺងម៉ាត់។ ព្រះពោធិសត្វទតឃើញស្វេតច្ឆត្រក៏ភ័យទៀត ទើបទ្រង់ព្រះចិន្តាថា ៖ « អាត្មាអញមកពីណាមកនៅក្រោមស្វេតច្ឆត្រនេះ » ទើបទ្រង់ជ្រាបដោយជាតិស្សរញ្ញាណថា ៖ « មកពីឋានតាវតឹង្សមកទីនេះ មកពីនរកមកកាន់ឋានតាវតឹង្ស ពីដើមទៅពីកន្លែងនេះទៅនរក ព្រោះធ្លាប់ជាស្ដេចសោយរាជ្យនៅនគរនេះអស់២០ឆ្នាំ ដោយទោសនៃការសោយរាជ្យ បានជាទៅរងទុក្ខក្នុងឧស្សុទនរកអស់៨ម៉ឺនឆ្នាំ»។ ទ្រង់ជ្រាបដូច្នេះក៏រឹតតែភ័យព្រួយព្រះរាជហឫទ័យខ្លាំង ខ្លាចក្រែងចៀសវាងការសោយរាជ្យពុំបាន។ ទេវតារក្សាស្វេតច្ឆត្រ ដែលជាអតីតមាតាព្រះអង្គពីជាតិមុនថ្វាយយោបល់ បញ្ចេញកិច្ចកលដល់ព្រះអង្គថា ៖ « **មា បណ្ឌិច្ចយំ វិភាវយ**... » អ្នកកុំប្រកាសនូវភាពជាអ្នកចេះដឹង គឺមិនខ្វិនត្រូវធ្វើជាខ្វិន មិនថ្លង់ត្រូវធ្វើជាថ្លង់ មិនគត្រូវធ្វើជាគជនទាំងពួងស្គាល់អ្នកថា ជាមនុស្សល្ងង់ក៏ដោយចុះ មើលងាយអ្នកយ៉ាងណាក៏ដោយចុះ សេចក្ដីចម្រើននឹងមានដល់អ្នកដោយវិធីយ៉ាងនេះ។

ព្រះពោធិសត្វ ទ្រង់មានព្រះអស្សាសៈធូរស្រួល ព្រោះពាក្យនៃទេវតានោះ ទើបទទួលថា ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នក អ្នកឈ្មោះថា ធ្វើនូវសេចក្ដីចម្រើន និងប្រយោជន៍ដល់ខ្ញុំ។

ព្រះរាជាទ្រង់ឱ្យនាំកុមារទាំង៥០០នាក់ ជាបុត្រនៃមន្ត្រី ដែលប្រសូត្រថ្ងៃជាមួយនឹងព្រះពោធិសត្វ យកមកឱ្យនៅជាបរិវារដើម្បីបន្ទោរបង់នូវសេចក្ដីអផ្សុកនៃព្រះរាជបុត្រ។ កុមារទាំងនោះ ខ្លះយំ ខ្លះស្រែកទារទឹកដោះ។ ឯព្រះមហាឱរស ដែលមេដោះដាក់ត្រង់ណានៅត្រង់ណោះឥតកម្រើក ឥតយំទារព្រះក្សីរសោះ។ ព្រះរាជាទ្រង់ជ្រាបដូច្នោះ ក៏ឱ្យប្រជុំព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតអ្នកប្រាជ្ញមកពិគ្រោះ។ ជនទាំងនោះយល់ថា៖ « ដៃជើងមនុស្សខ្វិនមិនមែនយ៉ាងនេះទេ ចង្កាមនុស្សគមិនមែនយ៉ាងនេះទេ សោតប្រសាទក្នុងត្រចៀកនៃមនុស្សថ្លង់មិនមែនយ៉ាងនេះទេ ប្រាកដមានហេតុទើបបានជាយ៉ាងនេះ»។ ព្រះពោធិសត្វមិនទ្រង់ព្រះកន្សែង មិនទារព្រះក្សីរ មិនកម្រើកអស់វេលាមួយឆ្នាំ ទោះបីគេរកឧបាយកលពិសោធដោយទឹកដោះយ៉ាង

ណាក៏នៅតែដដែល។ តមកព្រះរាជបិតាឱ្យពិសោធដោយហេតុ១៦ប្រការ ៖

**១-ការពិសោធដោយនំចំណី** : ក្នុងកាលដែលពោធិសត្វមានព្រះជន្ម១ឆ្នាំកន្លងហើយ គឺទ្រង់ឱ្យយកនំចំណីគ្រប់ប្រភេទមកដាក់ជុំវិញព្រះរាជកុមារ កណ្ដាលហ្វូងទារកទាំង៥០០។

**២-ការពិសោធដោយផល្លានុផល** : ក្នុងកាលដែលមានព្រះជន្ម២ឆ្នាំកន្លងទៅហើយ គឺទ្រង់ឱ្យយកផ្លែឈើ មានប្រការផ្សេងៗមកតម្កល់ទុកក្នុងទីជិត ហើយបញ្ជាកផង។

**៣-ការពិសោធដោយគ្រឿងកីឡា** : ក្នុងឆ្នាំទី៣កន្លងហើយ គឺទ្រង់ឱ្យយកវត្ថុជាល្បែងកូនក្មេងគ្រប់ប្រការ មានរូបដំរីជាដើម មកដាក់ក្នុងទីជិតព្រមទាំងនាំក្រសាលផង។

**៤-ការពិសោធដោយភោជន** : ក្នុងឆ្នាំទី៤កន្លងហើយ គឺទ្រង់ឱ្យយកភោជនាហារមកដាក់ក្នុងភាជន៍ជិតព្រះអង្គ ព្រមទាំងបញ្ជាកផង។ កុមារឯទៀតៗដណ្ដើមគ្នានូវវត្ថុទាំងនោះ ឯរាជកុមារឥតកម្រើកសោះ។

**៥-ការពិសោធដោយភ្លើង** : ក្នុងឆ្នាំទី៥កន្លងហើយ គឺទ្រង់ឱ្យធ្វើផ្ទះធំៗមានទ្វារច្រើនបាំងដោយស្លឹកត្នោតជុំវិញឱ្យពោធិសត្វគង់ក្នុងផ្ទះនោះ ទើបឱ្យលបបឈូលភ្លើង។

**៦-ការពិសោធដោយដំរីចុះប្រេង** : ក្នុងឆ្នាំទី៦កន្លងហើយ គឺទ្រង់ឱ្យបង្ហាត់ដំរីមួយឱ្យយ៉ាងស្ទាត់ អាចធ្វើបានតាមបង្គាប់គ្រប់ប្រការ ហើយយកដំរីនោះមកឱ្យបំភ័យព្រះពោធិសត្វដោយប្រការផ្សេងៗ។

**៧-ការពិសោធដោយពស់** : ក្នុងឆ្នាំទី៧កន្លងហើយ គឺទ្រង់ឱ្យយកពស់គ្រប់ប្រភេទមកចងមាត់ ហើយយកទៅដាក់ឱ្យព័ទ្ធជុំវិញសកលសរីរៈនៃព្រះពោធិសត្វ។

**៨-ការពិសោធដោយមហោស្រព** : ក្នុងឆ្នាំទី៨កន្លងហើយ គឺទ្រង់ឱ្យអ្នកលេងមហោស្រពគ្រប់ប្រភេទ គ្រប់និគមជនបទ មកបញ្ចេញសិល្បកម្មថ្វាយ។

**៩-ការពិសោធដោយគ្រឿងអាវុធ** : ក្នុងឆ្នាំទី៩កន្លងហើយ គឺទ្រង់ឱ្យបុរសម្នាក់ៗកាន់គ្រឿងអាវុធផ្សេងៗទៅគំរាមកំហែងម្ដងម្នាក់ៗ។

**១០-ការពិសោធដោយសូរសព្ទត្រែស័ង្ខ** : ក្នុងឆ្នាំទី១០កន្លងហើយ គឺទ្រង់ឱ្យបាំងព្រះសន្ទិយាជុំវិញព្រះសយនា ចោះព្រះសន្ទិយាគ្រប់ទិសទាំងបួន ឱ្យអ្នកផ្លុំស័ង្ខ ផ្លុំត្រែដ៏ពូកែៗលបផ្លុំពញ្ញាក់តាមប្រហោងព្រះសន្ទិយា។

**១១-ការពិសោធដោយសូរសព្ទស្គរ** : ក្នុងឆ្នាំទី១១កន្លងហើយគឺទ្រង់ឱ្យវាយស្គរពញ្ញាក់។

**១២-ការពិសោធដោយពន្លឺភ្លើងប្រទីប** : ក្នុងឆ្នាំទី១២កន្លងហើយ គឺព្រះរាជកុមារពុំដែលប្រទះទីងងឹត ព្រះរាជាឱ្យលត់ភ្លើងព្រមគ្នា ឱ្យរាជកុមារគង់តែមួយព្រះអង្គក្នុងទីងងឹត កំពុងតែងងឹតៗឱ្យលបបើកភ្លើងព្រមគ្នា ដែលមានចំណាំងយ៉ាងខ្លាំង។

**១៣-ការពិសោធដោយរុយ** : ក្នុងឆ្នាំទី១៣ កន្លងហើយ គឺទ្រង់ឱ្យយកស្ករអំពៅ មកលាយទឹកលាបព្រះរាជកុមារពេញសព្វព្រះសរីរៈរាងកាយ ឱ្យរុយទាំងឡាយរោមអែអុក។

**១៤-ការពិសោធដោយគ្រឿងសម្អុយ** : ក្នុងឆ្នាំទី១៤កន្លងហើយ គឺទ្រង់ឱ្យយកគ្រឿងសម្អុយគ្រប់យ៉ាង មានមូត្រ និងករីសជាដើម មកលាបព្រះពោធិសត្វ មានព្រាចពាសពេញ

ទីកន្លែង ដែលពោធិសត្វគង់។

**១៥-ការពិសោធដោយដុតភ្លើងឆ្អើរ** : ក្នុងឆ្នាំទី១៥ កន្លងហើយ គឺទ្រង់ញ៉ាំងពោធិសត្វឱ្យផ្ទុំលើព្រះបញ្ចា ញ៉ាំងរាជបុរសឱ្យដុតភ្លើងពេលពីក្រោម។

**១៦-ការពិសោធដោយមាតុគ្រាម** ក្នុងឆ្នាំទី១៦ កន្លងហើយ គឺទ្រង់ញ៉ាំងពួកកញ្ញាដ៏ល្អៗឱ្យស្អិតស្អាងដោយប្រការផ្សេងៗមកប្រឡូកប្រឡែងប្រលោមតាមផ្លូវកាម។

អ្នកចាត់ការពិសោធទាំង១៦បែប ក្នុងមួយបែបៗធ្វើអស់រយៈកាល១ឆ្នាំៗ ដោយល្បិចផ្សេងៗ យ៉ាងណាក៏ដោយក៏ព្រះពោធិសត្វនៅតែខ្ជិនខ្ជង់ គថ្លង់ដដែល ពុំមានកម្រើកដោយការស្រេកឃ្លាន ដោយការចង់បាន ដោយការភិតភ័យឡើយ។

កាលបើអ្នកពិសោធអស់ចំណេះ ទាល់គំនិតហើយ ទើបព្រះមហាក្សត្រ ទ្រង់ចាត់ឱ្យអញ្ជើញពួកព្រាហ្មណ៍ អ្នកទាយលក្ខណៈមកបន្ទោសថា នៃព្រាហ្មណ៍ទាំងឡាយ ក្នុងកាលដែលរាជកុមារប្រសូត្រ អ្នករាល់គ្នាទាយថា៖ «កុមារនេះប្រកបដោយធញ្ញបុញ្ញលក្ខណៈ សេចក្ដីអន្តរាយរបស់កុមារនេះមិនមាន កុមារនេះនឹងមានសមត្ថភាពអាចគ្រប់គ្រងមហាទ្វីបទាំងបួន មានទ្វីបតូចពីរពាន់ជាបរិវារបានផង» ឥឡូវនេះឃើញថា ទំនាយនៃអ្នករាល់គ្នានេះផ្ដាសតែម្ដង ព្រាហ្មណ៍ទាំងឡាយគន់គូរមើលទៀត ក៏ឃើញទំនាយនៅដដែល ប៉ុន្តែព្រោះមានសេចក្ដីអន់ចិត្តក៏បែរជាកែថា៖ «សូមទ្រង់ព្រះមេត្តាប្រោស គ្មានអ្វីដែលទូលព្រះបង្គំគ្រប់គ្នាពុំឃើញនោះទេ ប៉ុន្តែ កុមារនេះ គឺព្រះរាជត្រកូលទាំងឡាយបួងសួងសុំបានមក បើខ្ញុំព្រះអង្គទាំងឡាយក្រាបទូលថា៖«កុមារកាឡកិណ្ណី» ដូច្នេះ សមជាព្រះអង្គនឹងមានព្រះរាជហឫទ័យទោមនស្ស ហេតុដូច្នោះ បានជាពុំក្រាបបង្គំទូលតាមត្រង់។ ព្រះរាជាទ្រង់បុច្ឆាថា ឥឡូវនេះគួរយើងធ្វើដូចម្ដេច? ព្រាហ្មណ៍ក្រាបបង្គំទូលថា កាលបើព្រះរាជកុមារគង់នៅក្នុងដំណាក់នេះនឹងមានសេចក្ដីអន្តរាយដល់ព្រះជន្មាយុព្រះអង្គ ឬដល់ស្វេតច្ឆត្រ ឬដល់ព្រះអគ្គមហេសី។ ដូច្នេះ សូមព្រះអង្គកុំបង្អែបង្អង់ឡើយ សូមទ្រង់ញ៉ាំងនាយសារថី ឱ្យទឹមរថអពមង្គល ផ្ទេកព្រះរាជកុមារលើរថនោះឱ្យនាំចេញតាមទ្វារខាងលិចទៅជីកកប់សម្លាប់ចោលឯព្រៃខ្មោចទៅ។ ព្រះរាជាទ្រង់អនុម័តតាមសម្ដីព្រាហ្មណ៍។ ព្រះនាងចន្ទាទេវីស្ទុះមកប្រញាប់ប្រញាល់តែមួយអង្គឯង ទ្រង់ព្រះកន្សែងអង្វរករព្រះរាជាថា ទោះបីម្ដេចម្ដាក៏សូមព្រះអង្គទ្រង់ព្រះរាជានុញ្ញាតឱ្យបុត្រខ្ញុំម្ចាស់បានសោយរាជ្យកុំខាន។ ព្រះរាជាពុំព្រម។ ព្រះនាងសុំត្រឹម៧ឆ្នាំ, ៧ខែ, ៨ថ្ងៃក៏ព្រះរាជាពុំព្រម។ ព្រះនាងសុំត្រឹម៧ថ្ងៃព្រះមហាក្សត្រទ្រង់ព្រះរាជានុញ្ញាត ហើយចាត់ធ្វើជារាជាភិសេកថ្វាយរាជសម្បត្តិ ចំពោះព្រះតេមិយរាជកុមារ។ ព្រះនាងចន្ទាទេវីជាព្រះមាតាតែងអង្វករសព្វទិវារាត្រីថា ហៃតេមិយកុមារកូន ម្ដាយធ្មេចភ្នែកមិនលក់សោះអស់១៦ឆ្នាំហើយ ហឫទ័យរបស់ម្ដាយស្ទើរបែកធ្លាយហើយ ព្រោះម្ដាយដឹងថាកូនមិនខ្វិនខ្វង់គថ្លង់ទេ ប៉ុន្តែក្រាញមិនព្រមស្រដីសោះ ហៃកូនប្រុស បាជារាជបុត្រតែមួយកុំឱ្យម្ដាយព្រួយដល់ណាទៀត និយាយជាមួយម្ដាយមួយម៉ាត់មកណាកូន។ ទោះបីមាតាអង្វករអស់វេលា៧យប់ ៧ថ្ងៃក៏ព្រះពោធិសត្វពុំស្រដី។ ដល់ថ្ងៃគម្រប់៨ថ្ងៃ ព្រះនរបតីកាសិករាជ ត្រាស់ព្រះរាជបញ្ជាឱ្យសុនន្ទសារថី ទឹមរថនាំព្រះពោធិសត្វទៅកប់សម្លាប់ចោល។

សុនន្ទសារថីទទួលធ្វើតាមព្រះរាជបញ្ជា ប៉ុន្តែដោយអានុភាពព្រះរាជកុមារ ក៏ទេវតាបង្វែងឱ្យទឹមនូវរថមង្គល ដោយសេះទាំងឡាយជាមង្គល នាំព្រះពោធិសត្វចេញទៅតាមទ្វារខាងកើតវិញ ចេញអំពីនគរអស់ផ្លូវចម្ងាយ៣យោជន៍ ដល់ព្រៃស្ទាប់មួយ សារថីស្មានថាជាព្រៃខ្មោចក៏ដោះសេះបញ្ឈររទេះ ដោះគ្រឿងអម្ពរបស់មហាក្សត្រវេចជាបង្វេច ហើយទាញចបកាប់រណ្តៅរាង៤ជ្រុង។

នៅពេលនោះមហាក្សត្រទ្រង់ព្រះចិន្តាថា «កាលនេះជាកាលគួរអាត្មាអញព្យាយាម» ហើយក៏ក្រោកច្របាច់ព្រះហស្តឆ្វេងដោយព្រះហស្តស្តាំ ច្របាច់ព្រះហស្តស្តាំដោយព្រះហស្តឆ្វេង ច្របាច់ព្រះបាទាដោយព្រះហស្តទាំងពីរ ហើយចុះចាករថឈានពីរបីជំហានស្មានបានថា «បើទៅមួយថ្ងៃចម្ងាយ១យោជន៍ក៏បាន» ហើយទ្រង់ព្រះចិន្តាទៀតថា «បើនាយសារថីចាប់គ្រញិចព្រះអង្គកប់ទៅក្នុងរណ្តៅ ព្រះអង្គអាចគ្រញិចនាយសារថីវិញបាន» ទើបព្រះអង្គចង់ល្បងព្រះពលំ ក៏ចាប់ទីបំផុតរទេះរថគ្រវីរវិលខ្វាល់ដូចជាគេគ្រវីកូនរទេះសម្រាប់កូនក្មេងលេង ហើយទ្រង់មានព្រះរាជបំណងចង់បានគ្រឿងប្រដាប់ស្អិតស្អាងព្រះកាយ។ ព្រះឥន្ទ្រឱ្យវិស្វកម្មទេវបុត្រ យកគ្រឿងមហាប្រសាធន៍មកថ្វាយ។ ទ្រង់តែងព្រះកាយរួច ស្តេចសួរទៅនាយសារថីដែលកំពុងលុងរណ្តៅថា៖ «នែសារថី អ្នកជីករណ្តៅដើម្បីអ្វី?អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅនេះ?»

ព្រះតេមិយប្រែប្រាណជាចេះនិយាយស្តី ហើយបណ្តេញឱ្យនាយសារថី នាំគ្រឿងអភរណៈត្រឡប់ចូលនគរវិញ ហើយទ្រង់ស្លៀកពាក់សមណៈបរិក្ខារ គង់ក្នុងអាស្រម ដែលព្រះឥន្ទ្រកោសីនិមិត្តថ្វាយ ៣០យោជន៍ ឆ្ងាយពីព្រះនគរ ជាសុខសាន្តរហូតដល់រន្ទឺ ឮសព្ទដល់ព្រះបិតា មាតា ទ្រង់លើកពលចតុរង្គសេនា មកអញ្ជើញព្រះអង្គ ឱ្យយាងត្រឡប់ទៅសោយរាជ្យវិញ ប៉ុន្តែព្រះពោធិសត្វមានបន្ទូលថា « អាត្មាភាពនឹងប្រព្រឹត្តព្រហ្មចរិយាធម៌ ពុំត្រូវការរាជសម្បត្តិទេ ព្រោះក្មេងៗក៏គង់តែស្លាប់យប់ថ្ងៃកន្លងផុតទៅ ទឹកដែលហូរហើយមិនវិលត្រឡប់ ហើយអាយុជីវិតមនុស្សក៏យ៉ាងនេះដែរ។ ជាងនេះ ភរិយាក៏គង់តែស្លាប់ ផ្លែឈើទាំងឡាយក៏គង់តែជ្រុះ ជនខ្លះដែលឃើញតែពេលព្រឹកមិនឃើញពេលល្ងាច ឯខ្លះទៀតឃើញតែពេលល្ងាចមិនឃើញពេលព្រឹក សេចក្តីព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណាដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក។ អាត្មាភាពផុតស្រឡះហើយ អំពីចំណង់ គឺការប្រាថ្នាទ្រព្យ មិនត្រូវការរាជសម្បត្តិទេ សុខចិត្តនៅក្នុងព្រៃបួសធ្វើអំពើជាកុសល ប្រព្រឹត្តព្រហ្មចរិយាធម៌»។

កាលនោះ ព្រះបាទកាសិការាជ និងព្រះនាងចន្ទាព្រមទាំងស្នំ១មុឺន៦ពាន់ ហើយព្រមទាំងបរិពារសព្វព្រះហឫទ័យនឹងទ្រង់សាងផ្នួស ទើបទ្រង់ឱ្យចំហទ្វារឃ្លាំងទាំងអស់ និងទ្វារផ្សារ ហើយទៅកសាងបុណ្យកុសល នៅពេញអាស្រម។ នាម៉ឺន ពលនិកាយបានសម្រេចមគ្គផលគ្រប់ៗគ្នា។ លុះស្លាប់ទៅបានកើតជាទេវតានៅឆកកាមាវចរសួគ៌ ហើយអ្នកទាំងឡាយដែលបានបួសរៀន គឺជាពុទ្ធបរិស័ទនៃព្រះពោធិសត្វ។

**២- តួអង្គ**

- ព្រះតេមិយ : ព្រះពោធិសត្វ។

- ព្រះកាសិការាជ : ព្រះមហាក្សត្រនគរពារាណសី។
- ព្រះនាងចន្ទា : មហេសីព្រះបាទកាសិករាជ។
- នាយសារថី : អ្នកបររាជរថ។

៣- **កាលអាកាស**

- កាល : មុនសម័យពុទ្ធកាល (មិនដឹងច្បាស់)
- អាកាស : នគរពារាណសី

## III-ឧិដ្ឋភាពទំនាស់

**១-ទីកន្លែងទំនាស់** (ទីកន្លែងសំខាន់ៗទៅតាមកាលអាកាសរឿង)

**២-តួទំនាស់**

-ព្រះតេមិយ និងព្រះបិតា

-តួអង្គឯក ឬតួអង្គសំខាន់ ចិត្តគំនិតខ្លួនឯង ឬសភាវៈក្នុងខ្លួន (ទំនាស់ក្នុងខ្លួន)

**៣-បញ្ហាទំនាស់** (បង្ហាញឱ្យឃើញពីបញ្ហាទំនាស់ និងដំណោះស្រាយ)

តាមដំណើររឿងបង្ហាញថា ពេលទ្រង់ជ្រាបពីបញ្ហាអតីតជាតិ ដែលធ្លាក់ទៅនរក៨ម៉ឺនឆ្នាំហើយ ក៏រឹតតែភ័យព្រួយព្រះរាជហឫទ័យខ្លាំង ខ្លាចក្រែងចៀសវាងការសោយរាជ្យពុំបាន។ ទេវតារក្សាស្វេតច្ឆត្រ ដែលជាអតីតមាតាព្រះអង្គពីជាតិមុនថ្វាយយោបល់ បញ្ចេញកិច្ចកលដល់ព្រះអង្គថា ៖ « **មា បណ្ឌិច្ចយំ វិភាវយ**...» អ្នកកុំប្រកាសនូវភាពជាអ្នកចេះដឹង គឺមិនខ្វិនត្រូវធ្វើជាខ្វិន មិនថ្លង់ត្រូវធ្វើជាថ្លង់ មិនគត្រូវធ្វើជាគ ជនទាំងពួងស្គាល់អ្នកថា ជាមនុស្សល្ងង់ក៏ដោយចុះ មើលងាយអ្នកយ៉ាងណាក៏ដោយចុះ សេចក្ដីចម្រើននឹងមានដល់អ្នកដោយវិធីយ៉ាងនេះ។ ព្រះតេមិយ ក៏ទទួលស្ដាប់នូវសំឡេងនាងទេពធីតា ដែលជាសំឡេងនៃវិចារណញ្ញាណ សំឡេងសុភវិនិច្ឆ័យ សំឡេងនៃមនសិការ ដោយធ្វើឧបាយជាគ ថ្លង់ ខ្វិនខ្វង់ លែងនិយាយស្ដី ទោះបីព្រះវររាជបិតាខិតខំប្រើមធ្យោបាយបន្លាច បំភ័យយ៉ាងណាក៏ដោយ ក៏ព្រះរាជកុមារ ក៏ព្រះរាជកុមារនៅតែខិតខំរក្សាអាកប្បកិរិយា ជំហរស្មារតីរបស់ខ្លួនមិនតបឆ្លើយមិនព្រមនិយាយស្ដី ធ្វើទាល់តែព្រះមហាក្សត្របិតាទាល់តម្រិះ ខ្វាល់ប្រើរាជអាមាត្យនាំយកទៅជីកដីកប់ទាំងរស់។ សកម្មភាពរបស់ព្រះតេមិយអាចរំងាប់តណ្ហាដោយខ្លួនព្រះអង្គផ្ទាល់បាន ព្រោះព្រះអង្គយល់ថា បើធ្វើជាមនុស្សធម្មតា អាចមានលោភៈ ទោសៈ មោហៈ ហើយត្រូវគេបង្ខំឱ្យសោយរាជ្យជាក់ជាមិនខាន។ ដូច្នេះហើយ ទើបព្រះអង្គសុខចិត្តរងទារុណកម្មតាំងពីអាយុ១ខែដល់ ១៦ឆ្នាំ ហើយទទួលរងនូវការប្រមាថជាកុមារកាឡកិណី ដែលត្រូវគេយកទៅកប់ទាំងរស់។

សកម្មភាព និងលក្ខណៈដ៏រឹងប៉ឹង តាំងស្មារតីស៊ប់ គ្មានប្រែប្រួលក្នុងឧត្ដមគតិ ក្នុងគោលបំណងត្រូវរបស់ខ្លួនបែបនេះ ដែលធ្វើឱ្យព្រះតេមិយឆ្លងផុតពីទោសច្រឡំ ទោសអគតិ អយុត្តិធម៌ ឬចាកអំពើបាប គ្រោតគ្រាតបាន។

ចំណែកព្រះបិតា តាមដំណើររឿង កំហុសនៃព្រះបាទកាសិការាជ មានដល់ទៅ២លើក ស្ទួនៗគ្នាគឺ លើកទី១ ធ្វើទោសចោរ៤នាក់ នៅចំពោះមុខកូន ធ្វើឱ្យកូននេះភ័យខ្លាច ស្អប់ខ្ពើមអំណាចបែបនេះយ៉ាងខ្លាំង។ លើកទី២ ប្រើមធ្យោបាយដាក់ទណ្ឌកម្ម បន្លាចបំបាក់ស្មារតីដោយពិសោធហេតុ ១៦ប្រការ ដែលមាន ៖

១-ពិសោធនំចំណី
២-ពិសោធផល្លានុផល
៣-ពិសោធគ្រឿងកីឡា
៤-ពិសោធភោជន
៥-ពិសោធភ្លើង
៦-ពិសោធដំរីចុះប្រេង
៧-ពិសោធពស់
៨-ពិសោធមហោស្រព
៩-ពិសោធគ្រឿងអាវុធ
១០-ពិសោធស្ទូរសព្វគ្រៃស័ង្ខ
១១-ពិសោធស្ទូរស័ព្ទស្គរ
១២-ពិសោធពន្លឺភ្លើងប្រទីប
១៣-ពិសោធរុយ
១៤-ពិសោធគ្រឿងស្អុយ
១៥-ពិសោធដុតភ្លើងឆ្អើរ
១៦-ពិសោធមាតុគ្រាម

នៅទីបញ្ចប់ប្រើនាយសុនន្ទសារថី ឱ្យចាប់ចងយកទៅកប់ដីទាំងរស់។

ទាំងអស់នេះ គឺជាអំពើដែលរាជកុមារឃើញផ្ទាល់នឹងព្រះនេត្រ ដែលជាកំហុសច្រើនឥតគណនារបស់ស្តេចបិតា ដែលខ្លួនត្រូវតែខ្លាច ត្រូវតែគេចចេញកុំទៅស្នង ដើរតាមកំហុសបែបនេះទៀត។

ដូច្នេះមានតែការបួស គឺចាកភាពជាគ្រហស្ថ ដើម្បីចូលព្រៃបួសជាសាមណៈឥសី លះបង់នូវអំណាចទ្រព្យសម្បត្តិជាចំណងច្រើនប្រការ ពោលគឺរំដោះចិត្តគំនិតឱ្យផុតពីកាមតណ្ហា រាគៈ កិលេស កម្មអាក្រក់ អកុសលកម្មបាន។

សរុបសេចក្តីទៅ ការបួស គឺជាការផ្តាច់ឫសគល់នៃលោភៈ ទោសៈ និងមោហៈ និងអវិជ្ជា ដើម្បីស្វែងរកបរមសុខ មានមោក្សៈ ការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ជាទីអវសាន។ ម្យ៉ាងទៀត ការបួសនេះ គឺដើម្បីសន្សំកុសល ជួយខ្លួនព្រះអង្គ ជួយព្រះញាតិវង្សានុវង្ស និងប្រជានុរាស្ត្រសម័យនោះឱ្យចាកចេញពីអំពើអកុសល និងចម្លងសត្វលោកឱ្យឆ្លងផុតវាលវដ្តសង្សារ ដែលពោរពេញដោយតណ្ហា។

## IV.និជ្ជភាពវិភាគតួអង្គ

### ១.ព្រះបាទកាសិករាជ

**ក.គុណសម្បត្តិ**

- ព្រះរាជាដែលស្រឡាញ់ព្រះនគរ
- ស្រឡាញ់គ្រួសារ
- មានចិត្តតស៊ូ
- មិនអត្តនោម័ត ស្រឡាញ់លទ្ធិប្រជាធិបតេយ្យ
- ចេះបែងចែកសេចក្តីល្អនិងអាក្រក់បានច្បាស់លាស់ មានចិត្តជ្រះថ្លាក្នុងការសាងផ្នួស

**ខ.គុណវិបត្តិ**

- ជាមនុស្សចិត្តដាច់
- មិនចេះគិតវែងឆ្ងាយ បានសាងនូវកំហុសជាច្រើន
- ឆាប់ជឿពាក្យសំដីពួកព្រាហ្មណ៍
- ជាមនុស្សមានល្បិចកិច្ចកលច្រើន

### ២.ព្រះនាងចន្ទា

**ក.គុណសម្បត្តិ ៖**

- ជាមនុស្សដែលគោរព និងស្រឡាញ់ប្តី ជាភរិយាល្អ
- ជាម្តាយល្អស្រឡាញ់កូន
- ចេះគិតពិចារណាវែងឆ្ងាយ

**ខ.គុណវិបត្តិ ៖**

- មានគំនិតលោភលន់ ចង់ឱ្យកូនបានសោយរាជ្យ
- មានចិត្តគំនិតទន់ជ្រាយ
- មិនចេះដោះស្រាយទុក្ខ

### ៣.ព្រះតេមិយ

**ក.គុណសម្បត្តិ ៖**

- មានចិត្តតស៊ូព្យាយាមក្នុងជីវិត
- ចេះសន្សំបុណ្យកុសល
- មានចិត្តស្លូតបូត សាងតែអំពើល្អ
- មានចិត្តស្មោះត្រង់ មិនលោភលន់ទ្រព្យសម្បត្តិ
- ជាមនុស្សមានប្រាជ្ញាវាងវៃ
- មានសមាធិធម្មចរិយាខ្ពស់ ស្មោះសក្នុងការសាងផ្នួស
- ចេះជួយអ្នកដទៃឱ្យរួចផុតពីសេចក្តីបាប

**ខ.គុណវិបត្តិ ៖**

- ជាមនុស្សចិត្តដាច់ មិនស្រឡាញ់ឪពុកម្តាយ

• ជាមនុស្សគិតតែប្រយោជន៍ផ្ទាល់ខ្លួន អាត្មានិយម
• មិនចេះដោះស្រាយបញ្ហាចំពោះមុខ

**៩.នាយសារថី**

**ក.គុណសម្បត្តិ ៖**

• ជាមនុស្សស្មោះត្រង់ចំពោះព្រះរាជា
• គោរពពាក្យសំដីតាមតួនាទីរបស់ខ្លួន
• រីករាយនឹងសេចក្តីល្អបរិសុទ្ធ

**ខ.គុណវិបត្តិ ៖**

• ជាមនុស្សមិនសួរហេតុផល
• មិនចេះគិតពិចារណាចំពោះអ្វីដែលកើតមានចំពោះមុខ។

**V-ទិដ្ឋភាពសង្គម**

**១-វប្បធម៌**

**-ជំនឿ :** ជឿលើវត្ថុសក្តិសិទ្ធិ លើការបន់ស្រន់ និងជឿលើហោរាទស្សន៍ទាយ។ ព្រះអគ្គមហេសីព្រះនាមចន្ទា ជាព្រះរាជធីតានៃព្រះបាទមទ្ទរាជ សមាទានឧបោសថ ហើយធ្វើសច្ចកិរិយាប្រាថ្នាបុត្រ។ ដោយអំណាចតេជះសីលឧបោសថ ទើបព្រះឥន្ទ្រាធិរាជអារាធនាព្រះពោធិសត្វជាទេវបុត្រនៅឋានត្រៃត្រឹង្សឱ្យមកចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងចន្ទានោះ។

**-ប្រពៃណី ទំនៀមទម្លាប់** : កូនប្រុសត្រូវស្នងរាជ្យសម្បត្តិពីព្រះបិតា។

**-សាសនា** : កាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។

**-សិល្បៈ ល្បែង** : ក្នុងរឿងឃើញមានធ្វើការពិសោធដោយគ្រឿងកីឡា គ្រឿងភ្លេង ជាដើមក្រៅពីនេះ មានសម្តែងផ្សេងៗជាលក្ខណៈមហោស្រពផងដែរ។

**២.សេដ្ឋកិច្ច**

-កសិកម្ម : ប្រជាជនប្រកបរបរកសិកម្ម ធ្វើស្រែចម្ការ

-ផលិតកម្ម : គ្រឿងអាវុធ គ្រឿងកីឡា គ្រឿងភ្លើង...។

-សិប្បកម្ម : ចេះផលិតអាវុធ គ្រឿងកីឡា គ្រឿងភ្លេង ភ្លើងប្រទីប...។

-ពាណិជ្ជកម្ម : មានការជួញដូរនៅក្នុងស្រុក (តាមដងទន្លេ) និងជួញដូរជាមួយចិន។

**៣.សង្គមកិច្ច**

-ស្ថានភាពរស់នៅ : ប្រជាជនរស់នៅក្រោមការគ្រប់គ្រងរបស់ព្រះរាជា ប្រទេសមានអសន្តិសុខ (មានចោរ)។

-មុខរបរ និងជីវភាពប្រជាជាជន : ប្រជាជនប្រកបរបរកសិកម្ម និងសិប្បកម្ម។

៤.នយោបាយ

-ក្នុងប្រទេស (អ្នកគ្រប់គ្រង របបគ្រប់គ្រង) : ជាសង្គមដែលមានស្តេចគ្រប់គ្រង

-ក្រៅប្រទេស (ទំនាក់ទំនងអន្តរជាតិ) : មិនឃើញមាននិយាយពីទំនាក់ទំនងជាមួយបរទេសឡើយ។

VI-**ទិដ្ឋភាពតែងនិពន្ធ**( **អត្ថរូប** )

**១-ផ្តើមរឿង**

ជាការប្រារព្ធប្រភពរឿង៖ « កាលព្រះពុទ្ធជាព្រះបរមសាស្តាចារ្យ គង់នៅវត្តជេតពន ទ្រង់ប្រារព្ធនូវមហាភិនិក្ខម្មបារមី ទ្រង់សម្តែងធម៌ទេសនាថា៖ **មាបណ្ឌិច្ចយំវិភាវយ**» ដូច្នេះជាដើម។

សេចក្តីថា៖ «ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងសាលាធម្មសភា សរសើរនូវមហាភិនិក្ខម្មបារមីរបស់ព្រះមានបុណ្យ។ ព្រះអង្គទ្រង់បុច្ឆាថា អ្នកទាំងឡាយ ប្រជុំនិយាយនូវរឿងអ្វី? ភិក្ខុទាំងនោះ ក្រាបបង្គំទូលតាមដំណើរ។ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា ឥឡូវនេះតថាគតមានបារមីពេញគ្រប់គ្រាន់ ហើយលះបង់រាជសម្បត្តិ ទៅសាងមហាភិនិស្រ្កមណ៍ មិនអស្ចារ្យទេ បើពីដើមទើបអស្ចារ្យ។ កាលភិក្ខុទាំងឡាយ អារាធនា ក៏ព្រះអង្គទ្រង់សម្តែងនូវអតីតនិទានដូចតទៅនេះ...»

**២-តួរឿង**

អត្ថបទរឿង ចាប់ជាបាលី រួចផ្តើមដំណើររឿង ដោយសង្កត់ធ្ងន់ទៅលើគោលឧត្តមគតិជាប្រធានរឿងណាមួយយ៉ាងច្បាស់ ដូចជាក្នុងតេមិយជាតកនេះ គេសង្កត់ធ្ងន់លើការប្រាថ្នាបួសជាធំ៖ « អតីតេ ភិក្ខុខេ ពារាណសីយំ កាសិករាជ នាមធម្មេន សម្មេន រជ្ជំ ការេសិ...។ ម្នាលភិក្ខុ ទាំងឡាយ ក្នុងកាលកន្លងទៅហើយ ព្រះមហាក្សត្រព្រះនាម កាសិការាជ សោយរាជ្យតាមច្បាប់ មានសមភាពក្នុងនគរពារាណសី។...»

ក្នុងរឿងព្រះតេមិយ អ្នកនិពន្ធបានប្រើប្រាស់នូវសិល្បវិធីមួយចំនួនដូចខាងក្រោមនេះ ៖

- **វចនវិធី** : អ្នកនិពន្ធប្រើពាក្យពេចន៍ ច្រើនជាពាក្យបាលី (មគធភាសា) ពីព្រោះជាអត្ថបទប្រែចាកពីគម្ពីរបាលី (ហើយជាអត្ថបទបែបពុទ្ធនិយមផង)។ រីឯឃ្លាប្រយោគ រៀបរយល្អ ពុំមានឃ្លាវែងនាំឱ្យពិបាកយល់នោះឡើយ។
- **រចនាវិធី** : អ្នកនិពន្ធបានសរសេរជាជាអត្ថបទបែបទេសនា តែងជាពាក្យរាយធម្មតា។
- **ពណ៌នាវិធី** : អ្នកនិពន្ធពណ៌នារៀបរាប់ពីទេសភាព ឬសកម្មភាពជីវភាពរបស់តួអង្គ ដូចជា «បពិត្រព្រះបិតា អាត្មាភាពឃើញគេក្មេងៗទើបនឹងចេះនិយាយក៏ស្លាប់ដែរ...ពួកខ្លះដែលគេឃើញក្នុងពេលល្ងាច តែមិនឃើញក្នុងពេលព្រឹក»។
- **ឯកវាទវិធី** : គឺជាវិធីដែលគេធ្វើឱ្យតួអង្គ ដែលទទួលរងទុក្ខទោសក្តីមានការឈឺចាប់ទុក្ខព្រួយក្តី ឬកើតវិប្បដិសារីអំពីរឿងអ្វីមួយ ដោយការនិយាយរំលឹកអំពីហេតុភេទរឿងរបស់ខ្លួនតែម្នាក់ឯង។ ក្នុងរឿង ព្រះពោធិសត្វទតឃើញស្វេតច្ឆត្រ ក៏ភ័យទៀត ទើបទ្រង់ព្រះចិន្តាថា

«អាត្មាអញមកពីណា មកនៅក្រោមស្វេតច្ឆត្រនេះ»។ ទើបទ្រង់ជ្រាបដោយជាតិស្សរញ្ញាណថា ៖ «មកពីឋានតាវតិង្ស មកទីនេះ មកពីនរកមកកាន់ឋានតាវតិង្ស ពីដើមទៅពីកន្លែងនេះទៅនរក ព្រោះធ្លាប់ជាស្តេចសោយរាជ្យនៅនគរនេះអស់២០ឆ្នាំ ដោយទោសនៃការសោយរាជ្យបានជាទៅរងទុក្ខក្នុង ឧស្សុទនរកអស់៨ម៉ឺនឆ្នាំ»។

• **សំវាទវិធី :** សំវាទវិធី គឺជាវិធីដែលអ្នកនិពន្ធធ្វើឱ្យតួអង្គចាប់ពីពីរឡើងទៅសន្ទនាគ្នាពីបញ្ហាអ្វីមួយ។ ក្នុងរឿងតេមិយ អ្នកនិពន្ធបានបង្ហាញពីការសន្ទនារវាងព្រះតេមិយ និងនាយសារថី៖ «នែសារថី អ្នកជីករណ្តៅដើម្បីអ្វី? អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅនេះ?»

• **វឌ្ឍមានវិធី :** អ្នកនិពន្ធបង្ហាញពីស្ថានភាពរឿង ដែលមានលក្ខណៈកាន់តែតឹងតែងឡើងជាលំដាប់ គឺ ការទាយរបស់ព្រាហ្មណ៍លើកទី២ បានធ្វើឱ្យស្ថានការណ៍កាន់តែស្មុគស្មាញ ដោយព្រាហ្មណ៍ទាយថា «ព្រះរាជបុត្រជាកុមារកាឡកិណី» រហូតដល់សម្រេចចិត្តយកព្រះតេមិយទៅសម្លាប់ចោល។

• **សន្ទេហវិធី :** ជាវិធីដែលអ្នកនិពន្ធធ្វើឱ្យអ្នកអានចង់ដឹងហើយចង់ដឹងទៀតអំពីរឿងអ្វីមួយ។ ក្នុងរឿងតេមិយ អ្នកនិពន្ធបានបង្ហាញពីតួអង្គព្រះតេមិយបានជួបឧបសគ្គរហូត គឺចេញពីបញ្ហាមួយ ចូលបញ្ហាមួយទៀត ដូចជាការចូលស្តាប់ការវិនិច្ឆ័យទោសចោរ៤នាក់។ បន្ទាប់មក រងការពិសោធ១៦ប្រការ រហូតយកទៅសម្លាប់ចោល ដែលធ្វើឱ្យអ្នកអានចង់ដឹងថា តើតួអង្គព្រះពោធិសត្វនឹងទៅជាយ៉ាងណា បើជួបការលំបាកយ៉ាងដូច្នេះ?

**៣.បញ្ចប់រឿង**

ក្នុងរឿងពុទ្ធនិយម គេបញ្ចប់ដោយការសរជាតិ។

ក្នុងរឿងព្រះតេមិយ គេបញ្ចប់រឿងដូច្នេះថា៖ «សម្តេចព្រះបរមសាស្តា ទ្រង់នាំព្រះធម៌ទេសនា នេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ៖

• ទេវតារក្សាស្វេតច្ឆត្រក្នុងគ្រានោះ គឺជានាងឧប្បលវណ្ណាថេរី

• នាយសារថី គឺសារីបុត្តត្ថេរ

• ព្រះឥន្ទ្រ គឺជាព្រះអនុរុទ្ធត្ថេរ

• ព្រះមាតា ព្រះបិតាទាំងឡាយ គឺព្រះមហារាជត្រកូល

• បរិស័ទទាំងឡាយ គឺជាពុទ្ធបរិស័ទក្នុងគ្រាឥឡូវនេះ

• ឯបណ្ឌិតដែលពុតធ្វើជាគ គឺអង្គអញតថាគត ជាសម្មាសម្ពុទ្ធនេះឯងហោង»។

## VII-**ទិដ្ឋភាពតម្លៃ** (**អត្ថរស**)

**១.វិសិដ្ឋរស :** គឺជាតម្លៃវិសេសរកគ្មាន ក្នុងអំពើតស៊ូ តាំងក្នុងស្មារតីលះបង់ប្តូរផ្តាច់ សុខចិត្តអត់ធ្មត់ពុំតក់ស្លុត ពុំខ្លាចស្លាប់របស់ព្រះតេមិយ ជាអង្គពោធិសត្វនេះឯង។

**២.កុសលរស :** ជាតម្លៃទាក់ទងដល់ការអប់រំ។ តាមដំណើររឿង ព្រះតេមិយអប់រំនាយសារថីឱ្យធ្វើតែអំពើល្អ មិនបៀតបៀនអ្នកដទៃ ៖ « បុគ្គលណាមិនទ្រុស្តមិត្ត ឬបុគ្គលនោះមិនខឹងរមែងមកកាន់ផ្ទះរបស់ខ្លួនដោយទឹកមុខរីករាយ ហើយជាអ្នកដែលត្រូវគេទទួលដោយរីករាយ ក្នុងសាលប្រជុំទាំងជាបុគ្គលឧត្តមរបស់ក្រុមញាតិផង»។

**៣.វីររស** : ជាតម្លៃ ដែលលេចចេញមកពីសកម្មភាពរបស់តួអង្គវិជ្ជមាន។ តួយ៉ាងតួអង្គព្រះតេមិយ ដែលមានសកម្មភាពអង់អាចក្លាហានជំនះការពិសោធទាំង១៦ប្រការ និងអូសទាញចិត្តមនុស្សទូទៅឱ្យជឿជាក់លើព្រះពុទ្ធសាសនាដោយការសាងផ្នួស។ ព្រះបាទកាសិករាជ ព្រះនាងចន្ទាទេវី និងស្រីស្នំមួយម៉ឺនប្រាំពាន់នាក់ ព្រមទាំងពួករាជបរិពារមានអាមាត្យជាដើម បានសព្វព្រះទ័យសាងផ្នួសជាមួយព្រះអង្គដែរ។

**៤.ទារុណរស** : អ្នកនិពន្ធបង្ហាញភាពកំសត់របស់ព្រះតេមិយ ដែលធ្វើបាបខ្លួនឯងដោយការធ្វើខ្លួនជាមនុស្សគ ថ្លង់ ខ្វិនខ្វង់ ដើម្បីជៀសផុតពីអំពើបាប។

**៥.អច្ឆរិយរស** : នៅក្នុងរឿងបានបង្ហាញពីភាពអច្ឆរិយៈរបស់ព្រះតេមិយ ដែលព្រះអង្គអាចទទួលរងនូវការពិសោធ១៦ឆ្នាំ ដែលមនុស្សធម្មតាមិនអាចធ្វើបាន។ ម្យ៉ាងទៀត នៅចុងបញ្ចប់ព្រះអង្គអាចគ្រវីរថវិលខ្ទាល់ ហួសពីការស្មាន។

**៦.សង្គមរស** : តម្លៃនៃសង្គមក្នុងរឿងព្រះតេមិយ គឺជាសង្គមដែលជឿទៅលើបុណ្យបាប ការកសាងបុណ្យកុសល ការសាងផ្នួស។ ពាក្យទូន្មានរបស់ព្រះតេមិយបានធ្វើឱ្យព្រះរាជាមហេសី ស្នំ និងប្រជារាស្ត្រទាំងអស់លះបង់នូវទ្រព្យសម្បត្តិរបស់ខ្លួនទាំងមិនសោកស្តាយ ហើយនាំគ្នាទៅសាងព្រះផ្នួសទាំងអស់។

## សន្និដ្ឋាន

សរុបមក រឿងព្រះតេមិយជារឿងទី១ ស្ថិតក្នុងទសជាតក ដែលបំពេញនូវនេក្ខម្មបារមី គឺការចេញសាងផ្នួស។ រឿងនេះមានលក្ខណៈពុទ្ធនិយមសុទ្ធសាធ ពោលគឺជារឿងដែលមានគោលធំស្ថិតនៅលើឧត្តមគតិ ដែលទាក់ទងទៅនឹងទ្រឹស្តីក្នុងពុទ្ធសាសនា។ ព្រះអង្គបានអប់រំមនុស្សឱ្យប្រព្រឹត្តតែអំពើល្អ ជៀសវាងនូវអំពើអាក្រក់ ចាកផុតទុក្ខវេទនាផងទាំងពួង។

## ឯកសារពិគ្រោះ


១- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨

២- បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ ល.ស.«យិន វ៉ាន់ថា»

៣- មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សទី១៩ លោក ឃីង ហុកឌី ឆ្នាំ២០០៣

៤- សិក្សាអក្សរសាស្ត្រខ្មែរបទុមត្ថេរសោមករីសតវត្សរ៍ទី១៩ ទុំទាវ ឆ្នាំ១៩៧១ ដោយ គង់ សម្ភារ

៥- វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧

៦- រឿងតេមិយជាតក បណ្ឌិតមហាឈឹម ស៊ុមន៍ សាស្ត្រាចារ្យនៅព្រះពុទ្ធិកវិទ្យាល័យ ព្រះបាទសុរាម្រឹត នៅភ្នំពេញ ទំព័រ៥៤ ដល់៧៤។

៧- ប្រវត្តិសាស្ត្រខ្មែរ ភាគ១-២ (ត្រឹង ងា) សំរាប់មធ្យមសិក្សា និងឧត្តមសិក្សា ព.ស. ២៥១៧ គ.ស.១៩៧៣

៨- កំណាព្យខ្មែរ ដោយលោក លី សុមុនី ព.ស.២៥៤៦ គ.ស.២០០២

៩- ជីវប្រវត្តិអ្នកនិពន្ធខ្មែរ សាលាគរុវិជ្ជាជាន់ខ្ពស់ (២១ .០៧.១៩៨៦)

១០- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ បោះពុម្ពដោយគ្រឹស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ ២០១១

១១- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១ បោះពុម្ពដោយគ្រឹស្ថានបោះពុម្ព និងចែកផ្សាយឆ្នាំ ២០១២

១២- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ដល់ថ្នាក់ទី៩ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង ចៅកែចិត្តចោរ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ...................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងចៅកែចិត្តចោរ»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងចៅកែចិត្តចោរ » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការច្នៃបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ“**សិក្សាអត្ថបទអក្សរសិល្ប៍**” ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ **«ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង ថៅកែចិត្តចោរ»** នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី ម៉ៅ គាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក រ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារឹទ្ធ

# មាតិកា

ទំព័រ
ប្រកាស ........................................................................................................i
បុព្វកថា ........................................................................................................ii
គណៈកម្មការ.....................................................................................................iii
អារម្ភកថា.......................................................................................................iv
មាតិកា...........................................................................................................v
សេចក្តីផ្តើម.........................................................................................................
I. ការបង្ហាញអត្ថបទ..............................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង......................................................................................
III. ទិដ្ឋភាពទំនាស់.................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ............................................................................................
V. ទិដ្ឋភាពសង្គម....................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ.............................................................................................
VII. ទិដ្ឋភាពតម្លៃ...................................................................................................
VIII. ការសន្និដ្ឋាន..................................................................................................
IX. ឯកសារពិគ្រោះ..................................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

## រឿងថៅកែចិត្តចោរ

## សេចក្តីផ្តើម

រឿងថៅកែចិត្តចោរតាក់តែងឡើងតាមរចនាបថល្ខោននិយាយដោយអ្នកនិពន្ធពីររូប គឺលោក ពៅ យូឡេង និង លោក អ៊ុំ ឈីន។ រឿងនេះប្រសូតឡើងក្រោយពីប្រទេស ខ្មែរទទួលបានឯករាជ្យពីរបបអាណានិគមនិយមបារាំងនាឆ្នាំ១៩៥៣។ នៅក្នុងដំណាក់កាលនោះដែរ គឺជាពេលដែលខ្មែរ ចាប់ផ្តើមប្រជែងគ្នាដើម្បីរស់ ជាពិសេសការស្រវាទាញយក ផលចំណេញ របស់ពួកនាយទុន ឬអ្នករក ស៊ីដែលមានគំនិតលោភលន់ជាដើម។

រឿងថៅកែចិត្តចោរគឺជារឿងដែលបានបង្ហាញពីអំពើអយុត្តិធម៌របស់អ្នកមានលុយអាឈ្នះនូវអ្វីៗទាំងអស់ ពោលគឺ ឈ្នះទាំងយុត្តិធម៌របស់កម្មករ ឈ្នះទាំងអាជ្ញាធរដែលជាអ្នកកាន់ច្បាប់របស់រដ្ឋ។

លើសពីនេះទៅទៀតតាមរយៈរឿងនេះក៏បានបង្ហាញពីចិត្តកំណាចឃោរឃៅរបស់ថៅកែ និងការប្រកាន់ជំហរយុត្តិធម៌ ការចេះសាមគ្គីគ្នារបស់កម្មករក្រីក្រ ទោះដំណើរវិវត្តន៍ទៅកាន់ការបាត់បង់អាជីពក៏ដោយ ។

តាមរយៈរឿងនេះ ក៏ជាកញ្ចក់មួយសម្រាប់ឆ្លុះបញ្ចាំងថា សម័យកាលនោះអំណាចទឹកប្រាក់ មានអានុភាពខ្លាំងក្លាណាស់ដោយអាចប្រើមនុស្សឲ្យធ្វើអ្វីក៏បាន ពោលគឺ មានប្រាក់ មានអំណាច។

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ គឺនៅថ្ងៃទី៣០ កញ្ញា ១៩៨១ រឿងនេះត្រូវបានចម្លង និងកែសម្រួលឡើងវិញដោយនាយកដ្ឋានសិល្បៈនៃក្រសួងឃោសនាការ រួចត្រូវបានបញ្ចូលក្នុង កម្មវិធីសិក្សា នាសាលាចំណេះទូទៅ សម្រាប់ថ្នាក់ទី១២ នាឆ្នាំ១៩៨៩។

## I- ការបង្ហាញអត្ថបទ

### ១- អត្ថបទ

– **ចំណងជើង** : ចំណងជើងរឿងនេះ គឺរឿងថៅកែចិត្តចោរ។ គ្រាន់តែឃើញចំណងជើងគេ អាចដឹងបានថា រឿងនេះប្រាកដជាបង្ហាញពីចិត្តសាហាវឃោរឃៅ ឬ ចិត្តដ៏ពិសពុលរបស់ថៅកែ។

– **ប្រភព** : មកពីប្រទេសកម្ពុជា

– **ប្រភេទ** : រឿងថៅកែចិត្តចោរតាក់តែងឡើងជាប្រភេទល្ខោននិយាយ។

– **ចលនា** : ស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ខេមរនិយមព្រោះដំណើររឿងឆ្លុះ បញ្ចាំងពីជីវភាពរស់នៅរបស់កម្មករខ្មែរក្នុងសម័យនាយទុនជិះជាន់។

## ២- អ្នកនិពន្ធ

– **ឈ្មោះអ្នកនិពន្ធ** : រឿងថៅកែចិត្តចោរជាកិច្ចសហការនិពន្ធរបស់លោក ពៅ យូឡេង និង លោក អ៊ុំ ឈឺន។

– **ជីវប្រវត្តិរបស់អ្នកនិពន្ធ** : រឿងថៅកែចិត្តចោរ ជាវណ្ណកម្មរួមរបស់លោក ពៅ យូឡេង និង លោក អ៊ុំ ឈឺន។ ចំពោះប្រវត្តិលោក អ៊ុំ ឈឺន ពុំមានឯកសារណាបញ្ជាក់ឲ្យបានច្បាស់លាស់ឡើយ។

ឯលោក ពៅ យូឡេង វិញ កើតនៅឆ្នាំ១៩១៩ នៅស្រុកកំពង់សោម ខេត្តកំពត។ ឪពុករបស់លោកឈ្មោះ ពៅ ឡុង ជាស្មៀននៅសាលាស្រុក។ ម្ដាយឈ្មោះ អ៊ុំ រស់។ លោកពៅ យូឡេង ជាកូនទីមួយ។ កាលលោកអាយុបាន៣ឆ្នាំ ឪពុកលោកត្រូវបានផ្លាស់មកធ្វើការនៅ សាលាស្រុកក្រគរ ខេត្តពោធិ៍សាត់វិញ។ គម្រប់វ័យសិក្សា លោក ពៅ យូឡេង បានចូលរៀននៅ សាលាបឋមសិក្សាពោធិ៍សាត់។

• នៅឆ្នាំ១៩៣៩លោកផ្លាស់ប្ដូរតាមឪពុកម្ដាយមករស់នៅទីក្រុងភ្នំពេញ ដោយចូលបន្តការសិក្សានៅសាលាបឋមសិក្សា ហ្វ្រង់ស្វា ប៊ូដ្វាំង (Frangcois Boudoin)

• អាយុ១៩ឆ្នាំ លោកបានប្រឡងជាប់ជាគ្រូបឋមសិក្សា ហើយទៅបង្រៀននៅខេត្តព្រៃវែង។

• នៅឆ្នាំ១៩៤៤ លោកត្រឡប់មកបង្ហាត់កីឡានៅភ្នំពេញវិញ។

• ចាប់ពីឆ្នាំ១៩៥៩មក លោកជាចាងហ្វាងសាលាផ្នែកល្ខោនជាតិ។ លោកបានខិតខំសហការជាមួយមិត្តភក្ដិជាច្រើន ដើម្បីកសាងស្នាដៃតែងចាប់ពីឆ្នាំ១៩៥៩មក។ លោកបានខិតខំនិពន្ធរឿងល្ខោនសម្រាប់សម្ដែង សម្រាប់លេងផ្សាយតាមវិទ្យុ និងរឿងថតខ្សែភាពយន្ត ជាច្រើនទៀត។

• នៅឆ្នាំ ១៩៧០-១៩៧៥ លោកបានចូលនិវត្តន៍តែលោកនៅតែបន្តកសាងស្នាដៃតាម រយៈទូរទស្សន៍និងភាពយន្តជានិច្ច។

• នៅឆ្នាំ១៩៧៥-១៩៧៩ : លោករស់នៅស្រុកពារាំង ខេត្តព្រៃវែង ក្រោមការដឹកនាំដោយប៉ុល ពត លោកបានក្លាយជាទាសករ ដូចប្រជាពលរដ្ឋខ្មែរដទៃទៀតដែរ ។

• នៅឆ្នាំ១៩៧៩ លោកមានតួនាទីជាអនុប្រធានទី៤ នៃមជ្ឈឹមរណៈសិរ្ស។

• នៅឆ្នាំ ១៩៨០ លោកត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតខ្មែរប្រចាំប្រទេសឥណ្ឌា។

លោក ពៅ យូទ្បេង ទទួលមរណភាពនៅខែធ្នូ ឆ្នាំ១៩៨០ នៅប្រទេសអាឡឺម៉ង់។

– **ស្នាដៃសំខាន់ៗ**

ស្នាដៃដែលលោកតាក់តែងសុទ្ធតែជាស្នាដៃដែលរួមសហការគឺ:

- រឿងថៅកែចិត្តចោរ
- រឿងព្រះអាទិត្យរះ
- រឿងសំបុកឥតមេបា
- រឿងឬទ្ធិសែននាងកង្រី...ព្រមទាំងមានរឿងដែលសម្តែងជាល្ខោនវិទ្យុជាច្រើនទៀត។

## ៣- ការតាក់តែង

– ថ្ងៃខែឆ្នាំនៃការតាក់តែង : រឿងថៅកែចិត្តចោរតាក់តែងឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ ១៩៥៦។

– ថ្ងៃខែឆ្នាំនៃការបោះពុម្ព : បន្ទាប់ពីបានកែសម្រួលរួច រឿងថៅកែចិត្តចោរ ត្រូវបានបោះពុម្ពឡើងវិញ នៅឆ្នាំ១៩៨៩ ដោយក្រសួងអប់រំ។

## ៤- សង្គមបរិយាកាស

– កាលប្រវត្តិ

- ដំណើររឿងនេះ កើតឡើងក្នុងកំឡុងឆ្នាំ១៩៥៤ - ១៩៥៦។

– ព្រឹត្តិការណ៍សំខាន់ៗ

- នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជា ទទួលបានឯករាជ្យពីរបបអាណានិគមនិយមបារាំង ។
- នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ សន្និសីទទីក្រុងហ្សឺណែវ។
- នៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តមសីហនុប្រកាសដាក់រាជ្យសម្បត្តិថ្វាយរាជបល្ល័ង្កទៅព្រះបិតានរោត្តម សុរាម្រឹត។
- នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តមសីហនុ បានបង្កើតគណបក្សសង្គមរាស្ត្រនិយម។
- នៅឆ្នាំ១៩៥៥ មានគណបក្សចម្រុះចូលរួមការបោះឆ្នោត តែលទ្ធផល គឺគណបក្សសង្គមរាស្ត្រនិយម ទទួលអាសនៈច្រើនជាងគេ។

- នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តមសីហនុឡើងជានាយករដ្ឋមន្ត្រីដឹកនាំរាជរដ្ឋាភិបាល។
- នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥៧ សមាជលើកទី៤ របស់សង្គមរាស្ត្រនិយម។

## II- ការវិភាគអត្ថបទ

### ក- ស្ថានភាពរឿង

### ១- សង្ខេបរឿង

មនុស្សបីនាក់ និងក្រោយពីបើកឡានទៅបុកឡានថៅកែ ហុងលី បង្កអោយស្លាប់មនុស្សរបួសជាច្រើននាក់រួចមក ពូហាំបានមករកថៅកែនៅផ្ទះដើម្បីទារប្រាក់ថ្លៃឈ្នួលចំនួន ១ម៉ឺនរៀល ដែលថៅកែជួលគាត់ឱ្យប្រព្រឹត្តអំពើនេះ ពេលមកដល់មិនជួបនឹងថៅកែទេ គាត់បានជួបនឹង ផានីត។ ពូហាំបាននិយាយរឿងនេះប្រាប់ផានីត។ ផានីត បានបញ្ឆេះឱ្យគាត់រត់គេចព្រោះដឹងថា រាជការកំពុងតែតាមរកចាប់គាត់។ ពូហាំមិនព្រមធ្វើតាមផានីតប្រាប់ទេ។ ផានីតបានឱ្យពូហាំពួនរង់ ចាំថៅកែ។ ពេលនោះថៅកែបានមកដល់ ពូហាំក៏ស្ទុះទៅស្ទាក់ទារលុយ១ម៉ឺនរៀលតាមការសន្យា តែត្រូវថៅកែបដិសេធ ធ្វើមិនដឹងមិនឮ រួចប្រាប់ឱ្យពូហាំរត់គេចខ្លួនដោយឱ្យប្រាក់២០០រៀល។ ពូហាំមិនព្រមក៏បង្កឱ្យមានការប្រកែកគ្នាខ្លាំងៗឮដល់ កម្មករសុខ គង់ ទ្រី ពួកគេក៏ចេញមកមើល។ ផានីតបានរៀបរាប់រឿងថៅកែឈ្លោះជាមួយពូហាំ ប្រាប់ពួកគេ។ ថៅកែនៅតែមិនព្រមឱ្យលុយ ទៅពូហាំ រីឯពូហាំវិញ ក៏មិនព្រមចេញទៅណាដែរ គាត់នៅតែជជែក ទាមទារ ទោះបី ថៅកែ គម្រាមយ៉ាងណាក៏ដោយ។

នាងយ៉ាន ប្រពន្ធពូហាំដោយបាត់ប្តីមិនឃើញមកផ្ទះក៏ទៅផ្ទះថៅកែ ចៃដន្យបានជួបពូហាំនិងថៅកែកំពុងឈ្លោះប្រកែកគ្នា។ ថៅកែបាននិយាយកុហកនាងយ៉ានពីការប្រព្រឹត្តអំពើអាក្រក់របស់ពូហាំ។ ថៅកែធ្វើជាចិត្តល្អប្រាប់នាងយ៉ានថាឱ្យពូហាំរត់គេចខ្លួនទៅ។ ថៅកែថែមទាំងឱ្យលុយទៅនាងយ៉ាន៣០០រៀល តែត្រូវពូហាំហាមមិនឱ្យទទួលយកឡើយ។ នាងយ៉ានមិនដឹងសាច់រឿង បានជឿតាមសម្តីថៅកែ។ នាងបានអង្វរប្តីឱ្យរត់គេច ព្រោះគាត់មិនចង់ឱ្យប្តីជាប់គុក តែត្រូវពូហាំបដិសេធ និងថែមទាំងច្រឡោតខឹងនឹងនាងយ៉ានជាប្រពន្ធថែមទៀត។ ផានីត បានឃាត់ពូហាំ តែត្រូវថៅកែគំរាមបញ្ឈប់ពីការងារ។ ផានីត មិនខ្លាចទេ ថែមទាំងតមាត់យ៉ាងខ្លាំងជាមួយថៅកែរហូតឮដល់កម្មករ សុខ មាន គង់ ទ្រី ចេញមក។ ពេលនោះទំនាស់កាន់តែ រីកធំឡើងៗ ហើយជជែកបើកកកាយកាន់តែខ្លាំងបានធ្វើឱ្យអ្នកទាំងអស់គ្នាដឹងពីអំពើអាក្រក់ របស់ថៅកែ។ អ្នកទាំងអស់ជួយគាំទ្រខាងពូហាំ។ ដោយឃើញសភាពការណ៍មិនស្រួល ថៅកែ បានប្រើ

ល្បិចបំបែកដោយសន្យាឱ្យលុយទៅ កម្មករ សុខ មាន គង់ ទ្រី ម្នាក់ៗ១ម៉ឺនរៀល ដោយ គ្រាន់តែធ្វើមិនដឹងមិនឮ ពេលមាននគរបាលមកសួរ។ ក្រោយពីស្តាប់ការពន្យល់របស់ពូហាំ ផានីត និងនាងយ៉ាន់រួចមកពួកគេមិនព្រមធ្វើតាមថៅកែឡើយ។ បន្ទាប់មកក្រុមនគរបាល បានចូលមកដល់។ ក្រោយពីសាកសួរដឹងរឿងហេតុអស់ហើយ សែហ្វបានបញ្ជាទៅភ្នាក់ងារ នគរបាល ឱ្យចាប់ខ្លួនពូហាំទៅក្រសួងនគរបាល។ គង់គ្រាន់តែស្រែករកយុត្តិធម៌មួយម៉ាត់ប៉ុណ្ណោះ ក៏ត្រូវក្រុមនគរបាលចាប់យកទៅដាក់ គុកជាមួយពូហាំទៀត។

ចំណែកកម្មករដទៃទៀត ត្រូវថៅកែដេញលែងឱ្យធ្វើការចាប់ពីថ្ងៃនោះមក។

**២- តួអង្គ**

- ពូហាំ : ជាតួអង្គឯក
- ផានីត : ជាតួអង្គរង
- ថៅកែ : ជាតួអង្គរង
- នាងយ៉ាន : ជាតួអង្គបន្ទាប់បន្សំ
- សុខ មាន គង់ ទ្រី : ជាតួអង្គបន្ទាប់បន្សំ
- សែហ្វ : ជាតួអង្គបន្ទាប់បន្សំ
- ភ្នាក់ងារនគរបាល : ជាតួអង្គបន្ទាប់បន្សំ
- យាយចាន់ កាទូច ថៅកែ ហុង លី : ជាតួអង្គរំពូក ។

**៣-កាលអាកាស**

+ កាល : ដំណើររឿងប្រព្រឹត្តទៅក្នុងកំឡុង ១ថ្ងៃពេញ។
+ អាកាស : រោងជាងជួសជុលរថយន្ត ថៅកែ របស់ពូហាំ នៅទីក្រុងភ្នំពេញ។

**ខ- អត្ថន័យ**

**១- ប្រធានរឿង** : ប្រធានរឿងនៃ រឿងថៅកែចិត្តចោរ ផ្តោតជាសំខាន់ គឺ " ភាពអយុត្តិ ធម៌ និងការកេងប្រវ័ញ្ចរបស់ពួកនាយទុនមកលើកម្មករក្រីក្រ " ។

**២-មូលបញ្ហារឿង** : ចំពោះមូលបញ្ហានៃរឿងថៅកែចិត្តចោរបានលើកយកបញ្ហា សំខាន់ៗ ជាច្រើនមកបង្ហាញ ៖

**+ បញ្ហាអំពើពុករលួយក្នុងសង្គម**

បញ្ហានេះជាបញ្ហាដ៏ចម្បងមួយដែលកើតឡើងស្ទើរគ្រប់ទិសទីក្នុងសង្គមនៅលើពិភពលោកគ្រាន់តែតិចឬច្រើនតែប៉ុណ្ណោះ។ បញ្ហាពុករលួយនេះបើកើតឡើងនៅទីណា ទីនោះប្រាកដជានឹងជួបនូវបញ្ហារីកវរបង្កឱ្យមានបញ្ហាសង្គមផ្សេងៗជាច្រើនដែលរីកសាយភាយមិនចេះចប់

មិនចេះហើយ ប្រៀបដូចជាដំបៅស៊ីរូងដូច្នេះដែរ។ តាមរយៈរឿងថៅកែចិត្តចោរយើងឃើញថា អំពើពុករលួយ បានកើតឡើងតាមរយៈការស៊ីសំណូករវាងនាយទុននិងអ្នកមានអំណាចដើម្បីបិទបាំងអំពើអាក្រក់របស់ខ្លួន ដែលកើតឡើងនៅក្នុងសម័យឯករាជ្យ។ ជាក់ស្តែងតាមរយៈតួអង្គថៅកែឡាន បានយកលុយទៅដោះស្រាយ ឬសម្រួលជាមួយក្រសួងគិញ ដើម្បីទប់កុំឱ្យ គេរករឿងក្នុងករណីឡានរបស់ថៅ កែបង្កគ្រោះថ្នាក់រហូតធ្វើឱ្យស្លាប់មនុស្សបីនាក់ ហើយ និងករណីដែលថៅកែបានខ្សឹបប្រាប់ដល់ភ្នាក់ងារនគរបាលជាតិ ក្រោយពីកម្មករទាំងអស់ បាន ចោទថា ថៅកែជាអ្នកផ្តើមគំនិតបញ្ញាឱ្យពូហាំបង្កគ្រោះថ្នាក់ឡើង ពេលនោះនគរបាល ជាតិមិន បានចាប់ខ្លួនថៅកែដែលជាមេគំនិតនោះទេ គឺចាប់ខ្លួនតែពូហាំម្នាក់គត់ដែលបង្ហាញ អំពីភាព អយុត្តិធម៌មួយចំពោះអ្នកទន់ខ្សោយដោយសារតែនាយទុនប្រើ ទឹកប្រាក់សូកប៉ាន់ទិញ ទឹកចិត្ត មន្ត្រីរាជការ ។

ឧទាហរណ៍១ : នៅត្រង់ឆាកទី២ ទំព័រទី៨ ត្រង់ពេលដែលថៅកែនិយាយជាមួយផានីតថា "អញទៅស្នាក់ខ្ទប់ឯក្រសួងគិញហើយ តែមិនដឹងជាបានផលយ៉ាងណា? តែនៅផ្ទះប្រយ័ត្នមើល បើមានមនុស្សចម្លែកមកសួរឆ្លើយថាមិនដឹងៗទៅ ។"

ឧទាហរណ៍២ : នៅត្រង់ឆាកទី៧ ទំព័រទី៣១ ត្រង់ពេលដែលនគរបាលមកចាប់ខ្លួនពូហាំ ហើយ ពេលនោះទាំងមីងយ៉ាន ទាំងផានីត ទាំងពូហាំ ហើយនិងកម្មករទាំងបួន (គង់ មាន ទ្រី សុខ) សុទ្ធតែ បានប្រាប់ដល់សែហ្វអំពីអំពើអាក្រក់របស់ថៅកែ តែថៅកែបានទៅខ្សឹបដាក់សែហ្វ ដូចដែលរឿង បង្ហាញ " ផានីត : ខ្ញុំបានឱ្យឃោបល់ហើយ តើឈ្មោះនេះឯងដែលខ្ញុំស្រែក ចង្អុលថាចោរនោះ ពេលដែលពួកលោកមកដល់ (ថៅកែអូសដៃនគរបាលទៅខ្សឹប) ។"
សែហ្វ : " តាងនាមក្រសួងនគរបាលខ្ញុំ សម្រេចថា នាំខ្លួនឈ្មោះ ហាំ **ទៅក្រសួងនគរបាលជាតិចូលទៅចាប់** (ភ្នាក់ងារនគរបាលក៏ចាប់តាម។ ចាប់តែពូហាំ) ...។"

លើសពីនេះទៅទៀត នៅត្រង់កន្លែងសន្ទនារវាងពូហាំ និងផានីតដែលពូហាំបានរៀបរាប់អំពីមូលហេតុដែលគាត់ប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់អ្នកដទៃដើម្បីបានលុយរស់ ដោយចោទប្រកាន់ទៅលើសង្គមដែលមានអំពើពុករលួយស៊ីសំណូក។ ជាក់ស្តែងដូចនៅត្រង់ឆាកទី១ ទំព័រទី៦ « ផានីត : នេះហើយសង្គមសក្តិភូមិគ្មានរបៀបបណ្តោយមនុស្សប្រយុទ្ធគ្នាតាមចិត្តប្រកាប់ប្រចាក់គ្នាបោកបន្លំគ្នាលួចប្លន់គ្នាកេងប្រវ័ញ្ចគ្នារហូតដល់ច្បាំងគ្នាដើម្បីតែម្យ៉ាង គឺដើម្បីរស់ទៅតាម សេចក្តីលោភមិនចេះឆ្អែត។ នេះហើយសង្គមពុករលួយដែលអ្នកប្រសប់ចេះតែសប្បាយនៅចំពោះមុខមនុស្សភាគច្រើន ដែលវេទនាពីរឿងរស់... ។"

អំពើពុករលួយនេះហើយដែលកើតមាននៅក្នុងសង្គមនាសម័យនោះ ហើយដែលធ្វើឱ្យអ្នកស្លូតត្រង់ត្រឹមត្រូវរងនូវអំពើអយុត្តិធម៌ អំពើកេងប្រវ័ញ្ច អំពើគាបសង្កត់ ត្រូវរស់នៅដោយប្រជែងគ្នា ដើម្បីរស់ខ្លួនឯង សុខចិត្តធ្វើឱ្យអ្នកដទៃស្លាប់ បើមិនសម្លាប់គេ មានតែទុកឱ្យខ្លួនស្លាប់ ។

**+ បញ្ហាកេងប្រវ័ញ្ចរបស់នាយទុនមកលើអ្នកក្រីក្រទន់ខ្សោយ**

ទន្ទឹមនឹងបញ្ហាពុករលួយ បញ្ហាដែលគេសង្កេតឃើញនៅក្នុងរឿងមួយទៀតនោះគឺ បញ្ហាកេងប្រវ័ញ្ចរបស់នាយទុនមកលើអ្នកក្រីក្រទន់ខ្សោយ។ យើងឃើញថាការរំលោភកេងប្រវ័ញ្ចរបស់នាយទុនមកលើអ្នកក្រីក្រទន់ខ្សោយនេះគឺអ្នកមានអាងខ្លួនថា មានលុយបានប្រើលុយជានុយជាអន្ទាក់សម្រាប់អូសទាញអ្នកក្រីក្រ អ្នកទន់ខ្សោយ អ្នកត្រដរចង់រស់ឱ្យហ៊ានប្រព្រឹត្តអំពើដែលផ្ទុយនឹងច្បាប់ អំពើអាក្រក់ដែលសង្គមស្អប់ខ្ពើម ការបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ដើម្បីខ្លួនបានរស់ ព្រោះបើខ្លួនគេមិន ស្លាប់មានតែរង់ចាំស្លាប់ ខ្លួនឯង។ ករណីនេះគឺថៅកែរបស់ពូហំតែម្ដង ថៅកែឡានដើម្បីការរកស៊ីរបស់ ខ្លួនហ៊ានសូម្បីតែ ធ្វើអំពើស្មោកគ្រោក ដោយបានសន្យានឹងពូហំបើបុកឡានរបស់ថៅកែហុងលីបាន នឹងបានទទួលប្រាក់១ម៉ឺនរៀល ដោយត្រូវការលុយជាចាំបាច់ផង ពូហំបានប្រថុយធ្វើដើម្បីឱ្យគ្រួសាររស់សុខចិត្តមានឈ្មោះមិនល្អ រត់ចោលស្រុក ប៉ុន្តែពេលដែលពូហំធ្វើការងារបានសម្រេច ថៅកែឡានរបស់គាត់បែរជាមិនគោរពពាក្យសន្យា ហើយថែមទាំងចោទពូហំថាជាអ្នកបង្កគ្រោះថ្នាក់ និងធ្វើឱ្យឡានរបស់ខ្លួនខូចខាតទៀត ចុងក្រោយ ពូហំត្រូវបាននគរបាលចាប់ខ្លួន ចំណែកឯថៅកែរស់នៅធម្មតា ដែលត្រង់នេះបានបង្ហាញ ឱ្យយើងឃើញនូវអំពើអយុត្តិធម៌ ពីសំណាក់ថៅកែដែលបំពានគាបសង្កត់បោកប្រាស់កម្លាំង និងទឹកចិត្តរបស់កម្មករ ។

ឧទាហរណ៍ ៖ នៅត្រង់ឆាកទី២ ទំព័រទី៨ នៅពេលដែលពូហំទៅទទួលរង្វាន់ពីថៅកែ តែបែរ ជាថៅកែមិនឱ្យរង្វាន់ថែមទាំងស្តីបន្ទោសពូហំថែមទៀតផង ។

ហំ ៖ ខ្ញុំដឹងថាគេរកចាប់ខ្ញុំហើយ បានជាខំឆ្លៀតមកបើកលុយរង្វាន់ រួចនឹងអាលគេច។

ថៅកែ ៖ យីអានេះ វង្វេងខួរហើយ! គិតតែរង្វាន់ជាប់គុកឯណោះមិនគិតទេ។ ទៅរត់ឱ្យបាត់ពី ទីនេះទៅ!

ហំ ៖ ថៅកែមេត្តាឱ្យលុយមកសិន!

ថៅកែ ៖ (ហូតកាបូបយកលុយ)ហ៏! យក២០០៛ រួចទៅឯណាឱ្យបាត់ទៅអាចង្រៃវាយក៏ ។

ហំ ៖ កាលដែលថៅកែមានប្រសាសន៍នឹងខ្ញុំថាឱ្យខ្ញុំ១ម៉ឺន! ទាល់តែប៉ុណ្ណឹងដែរបានខ្ញុំប្រថុយ លក់ស្បែក ។

ថៅកែ ៖ យីអានេះ! អញមិនដឹង! បើ២០០មិនយកអញមិនដឹងអីទេទៅ! ចេញទៅ! ធ្វើឱ្យអញមានរឿងដោយសារផងឥឡូវមកលំអុករក១ម៉ឺនទៀតអាណាតាមអាងឯងទាន់។

ហំ ៖ ព្រះតេជគុណ ខ្ញុំទុកជាម៉ែឪហើយ មេត្តាខ្ញុំចុះ។ ជីវិតខ្ញុំថ្លៃតែ១ម៉ឺនទេម្តេចព្រះបាទម្ចាស់មានប្រសាសន៍ឯណាទៅវិញ។ ឱ្យខ្ញុំភ្លាមមក១ម៉ឺនដូចជាបោះចោលឱ្យសត្វលង់ទឹកទៅចុះ។ ព្រះតេជគុណស្គាល់ចិត្តខ្ញុំស្រាប់ហើយស៊ូស្លាប់រស់នឹងព្រះតេជគុណយ៉ាងណាៗ... ។

ថៅកែ ៖ យីអានេះ និយាយច្រើនណាស់ អញថាមិនដឹងៗហើយ។ យកឡានអញទៅបុកគេ ខូចឡានអញងាប់មនុស្ស៣នាក់ រឿងរ៉ាវនឹងអាឯងនេះសម្បើមណាស់ ប៉ោគេវាក្តីផងឥឡូវមក រឹត

ឯងមួយទៀត។ ផានីតជួយគិតមើល អានេះវាគិតជញ្ជក់ឈាមឯង ឱ្យនៅតែស្បែកនិងឆ្អឹងតែ ម្ដង។ ព្រះតេជគុណជ្រាបស្រាប់ហើយ! ខ្ញុំបរឡានបុកគេគឺធ្វើតម្រូវចិត្តព្រះតេជគុណ។

បន្ថែមពីលើនេះទៅទៀត នៅត្រង់ឆាកទី១ ទំព័រទី៦ ត្រង់កន្លែងដែលពូហាំ និងផានីតជជែក គ្នាអំពីរឿងសង្គម ដែលជាសង្គមសក្តិភូមិ សង្គមពុករលួយ សង្គមអយុត្តិធម៌ អ្នកមាននាយទុនគាប សង្កត់ជិះជាន់អ្នកទន់ខ្សោយ។ ដូចដែលមាននៅក្នុងឃ្លាសន្ទនា ខាងក្រោមនេះស្រាប់។

ផានីត : ទំព័រទី៨ត្រង់សម្ដី...នេះហើយសង្គមនាយទុនមនុស្សជិះជាន់មនុស្សព្រោះពួកឈ្មុះចេះរៀបចំគ្នាដើម្បីសង្កត់ពួកអ្នកចាញ់ឱ្យធ្វើការបង្កើតផលអោយខ្លួនរស់បានស្រួល។

ហាំ : ក្មួយបានរៀន ក្មួយចេះរកពាក្យចំៗថាបាន។

ផានីត : ពូឯងហ្នឹងក៏សម្លាប់គេ ដើម្បីខ្លួនរស់ដែរ។

ហាំ : ពូមានចង់ឯណាក្មួយ តែជីវិតវាបង្ខំទេតើ! ដូចពូបានជម្រាបក្មួយរួចមកហើយស្រាប់។

ផានីត : ថៅកែហ្នឹងបង្ខំពូឯង។

ដូចនេះយើងឃើញថានៅក្នុងសម័យនោះបញ្ហានាយទុនដែលធ្វើបាបមកលើអ្នកក្រីក្រទន់ខ្សោយ ដើម្បីផលប្រយោជន៍ខ្លួន ដែលមិនចេះឆ្អែតមិនចេះឆ្អន់។

**+ បញ្ហាជីវិតនិងតម្រូវការរស់នៅ**

ជីវិតគឺជារបស់ដ៏មានតម្លៃបំផុតសម្រាប់មនុស្ស។ ដើម្បីឱ្យជីវិតរស់នៅគង់វង្ស មនុស្សត្រូវតែ បង្ខំចិត្តហ៊ានប្រព្រឹត្តនូវអំពើសព្វបែបយ៉ាងទោះបីជាដឹងថា អំពើនោះជាអំពើ អមនុស្សធម៌ ឬផ្ទុយពី ច្បាប់សង្គមហាមឃាត់ក៏ដោយ។

ដោយសារបញ្ហាជីវិត និងជីវភាពគ្រួសារទើបពូហាំសម្រេចចិត្តស៊ីឈ្នួលថៅកែ ដោយបើកឡាន ទៅបុកឡានថៅកែ ហុង លី។ ការសម្រេចចិត្តរបស់ពូហាំនេះ ជាការសម្រេចចិត្ត ផ្សងគ្រោះថ្នាក់ និងជាការហ៊ានទទួលយកធ្វើរឿងអមនុស្សធម៌ដែលសង្គមស្អប់ខ្ពើម។ ការសម្រេចចិត្តនេះក៏ព្រោះតែពូហាំ ចង់បានលុយ១ម៉ឺនរៀល យកមកផ្គត់ផ្គង់ជីវភាពគ្រួសារ ដូចសម្ដីហាំ នៅឆាកទី១ ទំព័រទី៦ ថា "ពូត្រូវការលុយ១ម៉ឺន គ្មាន១ម៉ឺនប្រពន្ធពូងាប់ ឈឺដើមទ្រូង ក្អកខះៗ ត្រូវការសម្រាកមិនធ្វើការ តើបានអ្វីស៊ី។ ទៅពេទ្យៗឱ្យសំបុត្រទិញថ្នាំចាក់ ។ ពូគ្មានលុយ ទិញថ្នាំ ធ្វើម្ដេចទុកឱ្យប្រពន្ធពូស្លាប់ឬ? កូនស្រីពូប្រឡងជាប់ចូលអនុវិទ្យាល័យនារី សាលាតម្រូវឱ្យ ទិញសំពត់ អាវ សៀវភៅ មុងតាមរបៀបគេ មិនទិញឱ្យកូន កូនខានរៀន។ ខានរៀនល្ងង់ដូច ពូទៀត។ ធំឡើងវេទនា...។ ម្ដាយពូគាត់ចាស់ហើយ ហើយគាត់ចង់ធ្វើបុណ្យ មុននឹងគាត់ អនិច្ចកម្ម

គាត់សុំលុយពូ ឱ្យពូធ្វើម្ដេច មិនឱ្យគាត់ធ្វើបុណ្យធ្វើទានហាក់ដូចជាធ្វើទណ្ឌកម្ម សម្លាប់ជីវិតគាត់ អ៊ីចឹង...។ ពូគិតស្រេចយូរណាស់មកហើយ ពូល្បងស្រាយរឿងនេះ តាមវិធីច្រើនណាស់ តែទៅមិនរួចបានជាសល់តែផ្លូវមួយហ្នឹង...”។

បើតាមសម្ដីពូហ៊ាំខាងលើនេះ អាចបញ្ជាក់បានថា ពូហ៊ាំ ជាមនុស្សមានវិចារណញ្ញាណ មានការ គិតគូរយ៉ាងល្អិតល្អន់ ជាពិសេសមុននឹងគាត់ធ្វើកិច្ចការអ្វីមួយគាត់តែងសាកល្បង រកវិធីដោះស្រាយ។ ដូច្នេះបើតាមការសង្កេតពិនិត្យរបស់យើងទៅលើសកម្មភាពរបស់គាត់ យើងឃើញថា អំពើរបស់គាត់ អមនុស្សធម៌បន្តិចមែន ប៉ុន្តែពុំមែនជាអំពើដែលគាត់ចង់ ធ្វើនោះទេ ផ្ទុយទៅវិញ មកពីជុំបាយជុំរុញ ទៅលើវិចារណញ្ញាណ។ ជាងនេះទៅទៀតមកពីសង្គមនាសម័យ នោះគ្មានការធានាលើជីវិតកម្មករ ក្រីក្រ ទើបគាត់ប្រថុយនិងភាពផ្សងព្រេងបែបនេះ។ មួយវិញទៀត ការហ៊ានរបស់ពូហ៊ាំ នេះបានត្រឹមតែស្វែងរកការរស់របស់ជីវិតមួយខណៈពេលៗ ប៉ុណ្ណោះ ពោលគឺ មិនបានធ្វើមានបានជា ដុំកំភួននោះឡើយ។

ដូចនេះដោយសារបញ្ហាជីវិត និងជីវភាពគ្រួសារគាបសង្កត់ពិតបានបង្ខំអោយពូហ៊ាំ ហ៊ានប្រព្រឹត្ត អំពើមួយក្បត់នឹងឧត្ដមគតិ ក្បត់នឹងសីលធម៌ ព្រមទាំងផ្ទុយពីច្បាប់ដែលបានកំណត់។ ប្រការគួរឱ្យ សោកស្ដាយ ទោះបីក្រដាច់ពោះស្លាប់ក៏មិនត្រូវសម្លាប់មនុស្សឡើយ។

**+ បញ្ហានៃការសាមគ្គីភាពរបស់កម្មករ**

ជនជាតិខ្មែរ ជាជនជាតិមួយដែលតែងតែប្រកាន់នូវវប្បធម៌ចែករំលែកប្រកបដោយស្មារតីសាមគ្គីទាំងក្នុងការងារ ក៏ដូចជាក្នុងការរស់នៅ។ ឆ្លើយតបនឹងបញ្ហានេះ រឿងថៅកែចិត្តចោរ ក៏បាន លើកយកពីបញ្ហាសាមគ្គីដ៏ស្អិតរមួតរបស់ពួកកម្មករមកបង្ហាញយ៉ាងសកម្មដែលផ្ទុយពី ទស្សនៈនាយទុនដែលឱ្យតម្លៃខុសទៅលើលុយពោលគឺ “ មានលុយមានអ្វីៗទាំងអស់ ” ដូចសម្ដីថៅកែក្នុងឆាកទី២ បានពោលថា៖ “ កុំអាងទឹកចិត្តមនុស្សធម៌ មើលងាយកម្លាំងប្រាក់ អាហ៊ំ ” ផ្ទុយទៅវិញកម្មករបានឱ្យតម្លៃយ៉ាងខ្ពស់ទៅលើទឹកចិត្តមនុស្សធម៌ និងយុត្តិធម៌ ដើម្បីពុះពារ រកសខ្មៅឱ្យឃើញ ដូចសម្ដីពូហ៊ាំក្នុងឆាកទី២ បញ្ជាក់ថា៖ “ កុំអាងទឹកប្រាក់ ហើយមើលងាយ មនុស្សពេកថៅកែ ”។ ដោយសារបុព្វហេតុនេះហើយបានជាថៅកែឱ្យលុយពួកកម្មករច្រើន យ៉ាងណាក៏ដោយ ក៏ពួកគេមិនសុខចិត្តចូលដៃជាមួយ ថៅកែឡើយ ហើយបែរជាមកគាំទ្រ និងធ្វើជាសាក្សីអោយពូហ៊ាំទៅវិញ ដូចសម្ដីគង់នៅឆាកទី៦ បញ្ជាក់ថា៖ “ មែន! ពួកយើងកុំចាញ់ បោកថៅកែ កុំចាញ់បោកអាពួកនាយទុន មូលធនដែលជាឈ្លើង ជញ្ជក់ឈាម អារកយើង ជិះជាន់យើង បឺតញើសបឺតឈាមយើងគ្រប់ពេលវេលា យើងត្រូវតែរួបរួមគ្នា ពួតដៃគ្នា ចង សាមគ្គីឱ្យស្អិតរមួត ហើយពុះពាររកសខ្មៅទាល់តែឃើញ ”។ ជាមួយគ្នានេះទ្រីក៏បាន ស្វាគមន៍ សម្ដីគង់ “ អាគង់

និយាយត្រូវ ខ្ញុំមិនព្រមយកលុយ១ម៉ឺនរបស់ថៅកែ ដើម្បីឱ្យមិត្តអ្នកក្រដូចគ្នា ស្លាប់ដោយអយុត្តិធម៌ទេ »។

សរុបមកយើងឃើញថា កម្មករដែលធ្លាប់រស់នៅរួមសុខទុក្ខជាមួយគ្នា បានរួបរួមសាមគ្គីយ៉ាងស្អិតរមួតដោយសុខចិត្តស្លាប់រស់ជាមួយគ្នា ដើម្បីការពារកម្មកររួមឈាមដូចគ្នា ប៉ុន្តែបែរជាត្រូវទទួល បរាជ័យទៅវិញ ដែលផ្ទុយនឹងសុភាសិតថា « សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់ »។ ទោះយ៉ាង នេះក៏ដោយន័យរបស់សាមគ្គីនៅតែឈ្នះ បើចាញ់មិនហៅថាសាមគ្គីនោះទេ ហើយបើចាញ់វិញក៏ចាញ់មួយរយៈពេលខ្លី ឬ បណ្ដោះអាសន្នប៉ុណ្ណោះ ដោយមូលហេតុអាជ្ញាធររក្សាច្បាប់ឃុបឃិតប្រព្រឹត្ត អំពើពុករលួយជាមួយនាយទុន ដោយមិនបានគិតពីសុខទុក្ខកម្មករក្រីក្រ។ ដូច្នេះយើងមិនត្រូវស្ទាក់ ស្ទើរ គឺត្រូវប្រមូលផ្ដុំរួមជាកម្លាំងសាមគ្គី ដើម្បីបង្កើតបានជាមហាគ្រួសារមានកម្លាំងខ្លាំងក្លារហូត ទទួលបានជ័យជម្នះ។

**៣- ទំនាស់**

**ទំនាស់ទី១ :** ទំនាស់រវាងថៅកែ និងពូហំ។

– បុព្វហេតុទំនាស់ : ថៅកែបានជូលលុយ១ម៉ឺនរៀល ឱ្យពូហំបើកឡានទៅបុកឡានថៅកែ ហុងលី ហើយថៅកែមិនគោរពតាមពាក្យសន្យា។

– លទ្ធផល : ថៅកែបានទទួលជ័យជម្នះលើពូហំ និងភ្នាក់ងារនគរបាលជាតិ។

– ផលវិបាក : ពូហំ ត្រូវជាប់គុក ព្រាត់ប្រាស់គ្រួសារ រងទុក្ខវេទនាតែម្នាក់ឯង។

**ទំនាស់ទី២ :** ទំនាស់រវាងថៅកែ និងកម្មករ (ផានីត សុខ មាន គង់ ទ្រី)

– បុព្វហេតុទំនាស់ : ថៅកែជាមនុស្សក្បត់ពាក្យសន្យា ហើយចង់អូសទាញកម្មករទាំងអស់ឱ្យគាំទ្រខ្លួន តែកម្មករទាំងអស់បែរជាគាំទ្រពូហំ។

– លទ្ធផល : ថៅកែបានទទួលជ័យជម្នះលើក្រុមកម្មករទាំងអស់។

– ផលវិបាក : កម្មករទាំងអស់ត្រូវថៅកែបណ្ដេញឱ្យឈប់ធ្វើការងារតទៅទៀត។

**ទំនាស់ទី៣ :** ទំនាស់រវាងពូហំ និងនាងយ៉ាន

– បុព្វហេតុទំនាស់ : នាងយ៉ានមិនដឹងច្បាស់ពីរឿងពូហំ និងថៅកែហើយគាត់បែរជាកាន់ជើងថៅកែ ជឿថៅកែ មិនស្ដាប់សម្ដីពូហំជាប្ដីឡើយ។

– លទ្ធផល : នាងយ៉ានត្រូវពូហំត្មះតិះដៀល

– ផលវិបាក : នាងយ៉ានយំសោកតូចចិត្តខ្លួនឯងជាមនុស្សល្ងង់។

**ទំនាស់ទី៤ :** ទំនាស់រវាងគង់ និងភ្នាក់ងារនគរបាល

- បុព្វហេតុទំនាស់ : ដោយឃើញភ្នាក់ងារនគរបាលចាប់តែពូហាំ ហើយមិនចាប់ថៅ កែគង់ក៏ស្រែករកយុត្តិធម៌ ភ្នាក់ងារនគរបាលបានចាប់គង់ទៀត។
- លទ្ធផល : គង់ត្រូវនគរបាលចាប់វាយដំ និងដាក់ខ្នោះ។
- ផលវិបាក : គង់ត្រូវជាប់គុកដោយសារសម្ដី។

**៤- វិភាគតួអង្គ**

**ផានីត**

**ក- គុណសម្បត្តិ**

- មានចរិតស្លូតបូតចេះគោរពចាស់ទុំ
- ជាអ្នកសិក្សារៀនសូត្រមានចំណេះដឹងសមល្មម
- ជាមនុស្សមានឧត្តមគតិ ស្រឡាញ់យុត្តិធម៌
- ជួយអ្នកដែលរងនូវការចោទប្រកាន់ដោយអយុត្តិធម៌ ហ៊ានតវ៉ានឹងអំពើអយុត្តិធម៌
- ដាស់តឿនអ្នកដទៃឱ្យស្រឡាញ់យុត្តិធម៌មិនត្រូវធ្វើជាមនុស្សខ្វះឧត្តមគតិ
- មិនទទួលយកការបញ្ចុះបញ្ចូលពីមនុស្សអាក្រក់។

**ខ- គុណវិបត្តិ**

-ចូលរួមក្នុងការលាក់បាំងជនប្រព្រឹត្តអំពើអាក្រក់ដែលបង្កគ្រោះថ្នាក់ចរាចរណ៍(ឆាកទី១)

**ពូហាំ**

**ក- គុណសម្បត្តិ**

- ជាប្ដីដែលស្រឡាញ់ប្រពន្ធ
- ជាឪពុកដែលស្រឡាញ់កូន
- ជាកូនកត្តញ្ញូរកប្រាក់ដើម្បីឱ្យម្ដាយធ្វើបុណ្យ
- ជាមនុស្សដែលចេះត្រិះរិះពិចារណាអំពីសង្គម
- ហ៊ានចេញមុខទទួលកំហុសដើម្បីប្ដូរយកភាពសច្ចៈត្រឹមត្រូវ(ឆាកទី៧)
- មានការភ្ញាក់រំឭកអំពីកំហុសរបស់ខ្លួន ទទួលយកកំហុស។

**ខ- គុណវិបត្តិ**

- ដើម្បីតែប្រាក់ ហ៊ានប្រព្រឹត្តអំពើអាក្រក់
- ចង់បានលុយរហូតដល់ហ៊ានបង្កគ្រោះថ្នាក់បណ្ដាលឱ្យអ្នកដទៃស្លាប់

- ខ្វះការពិចារណាច្បាស់លាស់មុននឹងសម្រេចចិត្តធ្វើអ្វីមួយ។

**ថៅកែឡាន**

**ក- គុណសម្បត្តិ**

- ជួយទទួលយកអ្នកដែលក្រីក្រលំបាកមកធ្វើការ

**ខ- គុណវិបត្តិ**

- មានគំនិតច្រណែនឈ្នានីសអ្នករកស៊ីដូចគ្នា
- ហ៊ានបញ្ជាគេធ្វើអ្វីដែលផ្ទុយនឹងច្បាប់ បង្កគ្រោះថ្នាក់ដើម្បីផលប្រយោជន៍ខ្លួន
- មិនគោរពពាក្យសន្យា
- ប្រព្រឹត្តអំពើសូកប៉ាន់ ពុករលួយ
- ប្រើលុយទិញទឹកចិត្តអ្នកដទៃ លាក់បាំងអំពើអាក្រក់របស់ខ្លួន
- ជានាយទុនដែលកេងប្រវ័ញ្ចកម្លាំងពលកម្មកម្មករ។

**មីងយ៉ាន**

**ក- គុណសម្បត្តិ**

- ជាប្រពន្ធដែលស្រឡាញ់ប្តីបារម្ភអំពីសុខទុក្ខរបស់ប្តីនិងគ្រួសារ
- មានការភ្ញាក់ខ្លួនចំពោះទង្វើអាក្រក់របស់ថៅកែ
- ដាស់តឿនអ្នកដទៃឲ្យប្រកាន់នូវយុត្តិធម៌ ភ្ញាក់រឭក

**ខ- គុណវិបត្តិ**

- ជឿសម្តីញុះញង់របស់ថៅកែចោទប្រកាន់ប្តីរបស់ខ្លួន
- ចោទប្រកាន់ប្តីរបស់ខ្លួន ខ្លាចអាប់ឱនដល់កិត្តិយសគ្រួសារ
- ចង់ទទួលប្រាក់ពីថៅកែដោយខ្វះការពិចារណា

**គង់ មាន សុខ ទ្រី**

**ក- គុណសម្បត្តិ**

- ចេះដាស់តឿនមិត្តភក្តិ
- ចេះជួយគ្នាក្នុងគ្រាអាសន្ន
- ប្រកាន់នូវជំហរយុត្តិធម៌មិនទទួលនូវសំណូកពីថៅកែឡាន។

**ខ- គុណវិបត្តិ**

– មានការស្ទាក់ស្ទើរក្នុងការចេញមុខការពារយុត្តិធម៌ដែលឃើញជាក់ស្តែងនៅចំពោះមុខ។

**៥- ឧត្តមគតិរឿង**

តាមរយៈរឿងថៅកែចិត្តចោរនេះ យើងឃើញថាអ្នកនិពន្ធមានបំណងចង់អប់រំដល់ជនានុជន គ្រប់រូបឲ្យឃើញអំពី ការជិះជាន់របស់នាយទុន ស្មារតីការពារយុត្តិធម៌ ការប្រព្រឹត្តអំពើពុករលួយរបស់នាយទុន និងមន្ត្រីរាជការព្រមទាំងការតស៊ូដើម្បីសច្ចភាពនៅក្នុងសង្គមខ្មែរ។

– អ្នកនិពន្ធចង់ឱ្យកូនខ្មែរចេះងើបឡើងប្រឆាំងនឹងការគាបសង្កត់ពីសំណាក់ថៅកែ នាយទុន ដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន
– មិនត្រូវបណ្តោយខ្លួនឱ្យនាយទុនជិះជាន់កេងប្រវ័ញ្ចកម្មករស្លូតត្រង់តទៅទៀត
– កុំជឿលើការបញ្ចុះបញ្ចូលបន្តិចបន្តួច ដែលជាការធ្វើដើម្បីបិទបាំងអំពើអាក្រក់របស់គេនោះឡើយ
– ត្រូវចេះរួបរួមគ្នាជាធ្លុងមួយដើម្បីប្រឆាំងនឹងអំពើអយុត្តិធម៌ អំពើអមនុស្សធម៌ដែលបង្កចលាចលនៅក្នុងសង្គម
– មិនត្រូវឱ្យអំពើអាក្រក់អូសទាញ ឬទឹកប្រាក់អូសទាញរហូតធ្លាក់ខ្លួនទៅប្រព្រឹត្តអំពើមិនល្អ ដែលសង្គមស្អប់ខ្ពើមនោះទេ
– ដាស់តឿនកូនខ្មែរឱ្យខិតខំរកវិធីដោះស្រាយក្នុងសង្គមដើម្បីកុំឱ្យអំពើអយុត្តិធម៌កើតមានតទៅទៀត។

**គ- អត្ថរូប**

**១-វិធីតែងនិពន្ធ :** រឿងថៅកែចិត្តចោរ អ្នកនិពន្ធគាត់តែងឡើងតាមរចនាបថល្ខោននិយា យ សរុបមានចំនួន៧ឆាក។

**២-ការផ្តើមរឿង** : នៅក្នុងរឿងនេះអ្នកនិពន្ធផ្តើមរឿងតាមរយៈការចាប់ផ្តើមដោយឱ្យ តួអង្គពីររូបសន្ទនាគ្នា។ ដោយសាររឿងនេះជាប្រភេទរឿងល្ខោននិយាយ ការផ្តើមរឿងនេះ មិន ដូចការផ្តើមរឿងបែបប្រលោមលោកដទៃឡើយ។

**៣-ដំណើររឿង** : (តួរឿង) នៅក្នុងតួរឿង អ្នកនិពន្ធបានប្រើវិធីតែងសំខាន់ៗដូចជា ៖

**+ វចនៈវិធី** រឿងនេះអ្នកនិពន្ធប្រើពាក្យសាមញ្ញ ពាក្យកម្ចីបាលីសំស្ក្រឹត សង្ឃសព្ទ រាជសព្ទ និងពាក្យកម្ចីពីបរទេសផងដែរ។

**ឧទាហរណ៍**

- ពាក្យសាមញ្ញ : ខ្យ៉ាន , ហាង , អញ , ម៉ែ , កាទូច....
- ពាក្យកម្ចីបាលីសំស្រ្កឹត : ពេទ្យ , បុណ្យ , វង្ស , ទណ្ឌកម្ម ....
- សង្ឃសព្ទ : ព្រះសង្ឃ , អនិច្ចកម្ម , ព្រះពុទ្ធជាប្រធាន ....
- រាជសព្ទ : រាជការ , ស្តេច ....។
- ពាក្យកម្ចីពីបរទេស : តៃកុង , អ៊ុងប៉ាង , គិញ , សែហ្វ ....

+ **សំវាទវិធី** មានការសន្ទនាគ្នារវាងតួអង្គនិងតួអង្គរហូតដល់បញ្ចប់រឿងជាក់ស្តែង ផានីត និយាយជាមួយពូហាំ ៖

**ឧទាហរណ៍**

- ពូហាំ : លោកក្មួយមានរឿងអ្វីបានជាមើលពូតាំងពីក្បាលដល់ចុងជើង...
- ផានីត : ពូក្រែង... ក្រែងឡានពូ...

+ **ឯកវាទវិធី** តួអង្គថៅកែបានពោលគិតតែម្នាក់ឯង។

**ឧទាហរណ៍**

- ឆាកទី៦ ថៅកែពោលថា៖ " នៅទីបំផុត ខ្ញុំនៅតែម្នាក់ឯងទេដឹងទេ! ដូចនេះមិនកើតទេ អញយកលុយអញចាយទាំងអស់... "។

+ **បដិវិធី** ទំនាស់រវាងថៅកែ និងកម្មករគឺថៅកែកេងចំណេញលើញើសឈាម កម្មករ ឯកម្មករទាមទាររកយុត្តិធម៌ និងសិទ្ធិសេរីភាពក្នុង ការរស់នៅ។

+ **រចនាវិធី** អ្នកនិពន្ធតាក់តែងរឿងនេះតាមរចនាបថល្ខោននិយាយ ។

+ **វឌ្ឍមានវិធី** ដំណើររឿងមានការវិវត្តកាន់តែតឹងតែងទៅៗ រហូតដល់ទីបំផុតពូហាំ និង គង់ត្រូវប៉ូលិសចាប់ទៅដាក់គុកដោយបន្សល់ទុក មីងយ៉ាន យំសោកសង្រេង ។

+ **ឧបមាណវិធី** អ្នកនិពន្ធបានធ្វើការប្រៀបធៀបចរិតនាយទុនមូលធនទៅត្រីឆ្តោ ដូចសម្តីទ្រីក្នុងឆាកទី៣ថា៖ " ពួកអានាយទុនទុកចិត្តមិនបានទេ ដូចត្រីឆ្តោអីចឹង ដើម្បីវាធំធាត់ គ្មានញញើតនិងស៊ីកូនឯងឡើយ " ។

៤- **ការបញ្ចប់រឿង** : រឿងនេះបានបញ្ចប់ទៅ ដោយតួអង្គឯកពូហាំជាប់គុក។ ថៅកែដែល ជាមេគំនិតបទឧក្រិដ្ឋត្រូវរួចខ្លួន ឯតួអង្គកម្មករទាំងអស់ត្រូវបញ្ឈប់ពីការងារ។ ការបញ្ចប់រឿងបែប នេះ ដើម្បីបណ្តុះគំនិតអ្នកអាន អ្នកសិក្សាឱ្យចេះត្រិះរិះពិចារណាតស៊ូពុះពារគ្រប់ឧបសគ្គ និងចេះដោះស្រាយបញ្ហាក្នុងការស្វែងរកសិទ្ធិសេរីភាពនិងយុត្តិធម៌។

**ឃ- អត្ថរស**

– **តថរស** ៖ ជាតម្លៃដែលកើតចេញពីការបង្ហាញនូវភាពពិតជាក់ស្ដែង រឿងរ៉ាវដែលកើតឡើងក្នុងរឿងថៅកែចិត្តចោរនេះ គឺជារឿងដែលកើតមានឡើង ពិតប្រាកដជាក់ស្ដែងនៅក្នុងសង្គមខ្មែរ បន្ទាប់ពីប្រទេសបានទទួលឯករាជ្យពីពួកអាណានិគម។ បញ្ហាសង្គមជាក់ស្ដែងទាំងនោះ មានដូចជា អំពើពុករលួយ ការជិះជាន់ ការគាបសង្កត់ពី សំណាក់នាយ ទុនមកលើអ្នក ទន់ខ្សោយ ការប្រើប្រាស់អំណាចទឹកប្រាក់ធ្វើឱ្យរឿងខ្មៅទៅស សទៅខ្មៅ អ្នកទន់ខ្សោយ ទទួលរងនូវការបោកប្រាស់ពីអ្នកមានជាដើម។ ចំពោះបញ្ហាទាំងនេះ យើងក៏ឃើញអ្នកនិពន្ធ បង្ហាញនៅចុងបញ្ចប់នៃរឿងផងដែរ។

– **វីររស** ៖ ជាតម្លៃដែលកើតចេញពីការបង្ហាញពីវីរភាពរបស់តួអង្គ។ តាមរយៈរឿងនេះ យើងឃើញថាតួអង្គផានីត មីងយ៉ាន ពូហាំ និងកម្មករទាំងបួនសុទ្ធតែបង្ហាញជំហររបស់ខ្លួនដើម្បីតស៊ូនឹងថៅកែឡានដែលជាមនុស្សអាក្រក់ ពួកគេហ៊ានបកអាក្រាតមុខមាត់របស់ថៅកែចំពោះមុខនគរបាល បើទោះជាការបកអាក្រាតនេះមិនទទួលជោគជ័យក៏ដោយ។

– **កុសលរស** ៖ ជាតម្លៃអប់រំដែលមាននៅក្នុងរឿង។ ក្នុងរឿងនេះបានអប់រំអ្នកអានឱ្យមានស្មារតីប្រកាន់យកនូវយុត្តិធម៌ មិនត្រូវបណ្ដោយខ្លួនឱ្យធ្លាក់ចូលក្នុងអន្ទាក់របស់នាយទុន ឬត្រូវអំណាចនៃទឹកប្រាក់អូសទាញបាននោះទេ ឱ្យចេះរួបរួមសាមគ្គីគ្នា និងចេះជួយគ្នាក្នុងគ្រាមានអាសន្ន ជៀសវាងការបែកបាក់សាមគ្គី។ សកម្មភាពទាំងនេះ គឺស្ដែងឡើងតាមរយៈតួអង្គ ផានីត ពូហាំ មីយ៉ាន និងកម្មករទាំងបួនដែលពួតដៃគ្នាជាធ្លុងមួយក្នុងការទាមទាររកយុត្តិធម៌ ។

– **សង្គមរស** ៖ ជាតម្លៃដែលអ្នកនិពន្ធលើកឡើងពីរឿងរ៉ាវរបស់មនុស្សនៅក្នុងសង្គម។ តាមរយៈរឿងថៅកែចិត្តចោរនេះ យើងឃើញថា អ្នកនិពន្ធបានបង្ហាញពីជីវភាពរស់នៅរបស់

មនុស្សដូច ជាពូហាំ និងកម្មករ ផានីតដែលជាកម្មកររបស់ថៅកែឡាន ធ្វើការដើម្បី ដោះស្រាយជីវភាពនិងការរកស៊ីប្រជែងគ្នារបស់ថៅកែឡានដូចគ្នាជាដើម។

– **សញ្ចេតនារស** ៖ ជាតម្លៃដែលកើតចេញពីសញ្ចេតនារបស់តួអង្គដោយរួមមាន សញ្ចេតនា របស់តួអង្គរវាងម្ដាយ ឪពុក កូន ប្ដីប្រពន្ធជាដើម។ នៅក្នុងរឿងថៅកែចិត្តចោរនេះ យើងសង្កេតឃើញ មានការបង្ហាញអំពីសញ្ចេតនារវាងពូហាំ និងប្រពន្ធគាត់ រវាងពូហាំចំពោះកូន និងម្ដាយ ព្រមទាំងរវាង ពូហាំនឹងមិត្តរួមការងារទាំងអស់របស់គាត់។

– **នាដ្យរស** ៖ ជាតម្លៃដែលបង្ហាញពីភាពកំសត់ព្រាត់ប្រាស់ វិបត្តក្នុងគ្រួសារជាដើម។ តាមរយៈរឿងថៅកែចិត្តចោរយើងសង្កេតឃើញអំពីវិបត្តដែលកើតមានក្នុងគ្រួសារពូហាំ ធ្វើឲ្យគាត់

សម្រេចចិត្ត ប្រព្រឹត្តអំពើខុសឆ្គង ហើយចុងក្រោយត្រូវព្រាត់ប្រាស់គ្រួសារព្រោះខ្លួន គាត់ត្រូវជាប់គុក។

**ខ- បញ្ហាសង្គម**

**១- នយោបាយ**

– **របបគ្រប់គ្រង** : របបគ្រប់គ្រងសង្គមខ្មែរនាសម័យនោះគឺរបបរាជានិយមដែលគ្រប់គ្រងដោយព្រះមហាក្សត្រ។

**២- សេដ្ឋកិច្ច**

+ **អជីវកម្ម** : ក្នុងរឿងបានបង្ហាញពីរោងជាងជួសជុលរថយន្តដែលប្រើប្រាស់កម្លាំងកម្មករតិចតួចជាក់ស្ដែង សុខ មាន គង់ ទ្រី ជាជាងជួសជុលរថយន្តរបស់ថៅកែចិត្តចោរ ។

ឧទាហរណ៍ ឆាកទី៣ " ពួកកម្មករធ្វើឡាន... " ។

+ **ពាណិជ្ជកម្ម** : មានការលក់ដូរឆ្នោតវត្ត និងការប្រកបអាជីវកម្មរថយន្តឈ្នួល។

ឧទាហរណ៍: ក្នុងឆាកទី២ ថៅកែបានពោលថា "...អញមិនដែលខានទេ តាំងពីសង់សាលារៀន ទិញឆ្នោតវត្ត..." ។

+ **គមនាគមន៍** : អ្នកនិពន្ធបានបង្ហាញពីគមនាគមន៍តាមរយៈតួអង្គថៅកែដែលមានរថយន្តដឹកអ្នកដំណើរ។

ឧទាហរណ៍: រថយន្តឈ្នួលមានតែថៅកែពូហំ និងថៅកែ ហុង លី។

+ **ហិរញ្ញវត្ថុ**: តាមរយៈដំណើររឿងបានបង្ហាញអំពីបញ្ហាប្រាក់បានន័យថាមានការចាយវាយនិងប្រើប្រាស់ រូបិយបណ្ណប្រាក់រៀល។

ឧទាហរណ៍: ក្នុងឆាកទី១ ពូហំ និយាយថា ៖ " មិនហ៊ានឯណា១ម៉ឺនរៀល " ។

**៣- សង្គមកិច្ច**

– **ស្ថានភាពរស់នៅរបស់ប្រជាជន** : ប្រជាជនរស់នៅក្នុងស្ថានភាពក្រីក្រលំបាកតោកយ៉ាក បានព្រឹកខ្វះល្ងាច ហើយទទួលរងការ បំបិទសិទ្ធិសេរីភាពសព្វបែបយ៉ាង។

ឧទាហរណ៍ ក្នុងឆាកទី១ ពូហំ បានបញ្ជាក់ថា៖ "...មានមនុស្សច្រើនបានព្រឹកខ្វះ ល្ងាច គ្មានអ្វីវ័ណ្ណ គ្មានដំបូលជ្រក រស់ដោយសារលក់កម្លាំងប្រចាំថ្ងៃ លោតែឈឺ ដេកចាំងាប់... " ។

– **សន្តិសុខសង្គម** : ក្នុងដំណើររឿងអ្នកនិពន្ធបបានឆ្លុះបញ្ចាំងអំពីការរស់នៅរបស់កម្មករដែលទទួលរងនូវការជិះជាន់កេងប្រវ័ញ្ច អំពើពុករលួយដែលថៅកែបានប្រព្រឹត្តនិងពុំមាន

ការធានាលើសិទ្ធិសេរីភាពរបស់ ប្រជាពលរដ្ឋឡើយ ជាក់ស្តែងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិត្រូវបិទទាំងស្រុង ។

ឧទាហរណ៍ ក្នុងឆាកទី៧ គង់គ្រាន់តែស្រែកថា " តើខែណា! ឆ្នាំណា! សតវត្សណា! ទើបរើបំរះពីការជិះជាន់បែបនេះ..."។ គង់ក៏ត្រូវប៉ូលិសចាប់ដាក់ខ្នោះភ្លាម ។

– **សុខាភិបាល** : ប្រជាជនក្រីក្រខ្វះលទ្ធភាពក្នុងការព្យាបាលជំងឺ ខ្វះថ្នាំសង្កូវ ពេទ្យគ្រាន់ តែពិនិត្យជំងឺ ឯអ្នកជំងឺត្រូវទិញថ្នាំព្យាបាលខ្លួនឯង ។

ឧទាហរណ៍ ក្នុងឆាកទី១ ពូហំ បានបញ្ជាក់ថា៖ " ទៅពេទ្យៗឱ្យសំបុត្រទិញថ្នាំចាក់ ពូគ្មានលុយទិញថ្នាំ ធ្វើម្តេចទុកឱ្យប្រពន្ធស្លាប់ឬ?"

– **ការងារនិងមុខរបរ** : ក្នុងដំណើររឿងអ្នកនិពន្ធបង្ហាញពីមុខរបរជាច្រើនដូចជាមានថៅកែ កម្មករជួសជុលរថយន្ត(សុខ ទ្រី មាន គង់) អ្នកបើកឡាន(ពូហំ) និងលេខា(ផានិត)។

ឧទាហរណ៍ ក្នុងឆាកទី១ ពូហំ បានពោលថា៖ "...ពូមកនេះមកបើកលុយរង្វាន់ មិនមែនមកបើកប្រាក់ខែទេប្រាក់ខែបើកចាយអស់១ខែមុនស្រេចទៅហើយ "។

**៤- វប្បធម៌**

– **ជំនឿ** : ប្រជាជនខ្មែរនាសម័យនោះជឿលើបុណ្យបាប ។

ឧទាហរណ៍ ក្នុងឆាកទី១ ពូហំបានពោលថា៖ "...ម្តាយពូគាត់ចាស់ហើយ ហើយគាត់ចង់ធ្វើបុណ្យ មុននឹងគាត់អនិច្ចកម្ម គាត់សុំលុយពូឱ្យពូធ្វើម្តេចមិនឱ្យគាត់ធ្វើបុណ្យ ធ្វើទាន... "។

– **សាសនា** : ប្រជាជនខ្មែរគោរព និងជឿលើព្រះពុទ្ធសាសនា ដើរតាមពុទ្ធោវាទ ព្រមទាំង មានការសាងសង់សាលាបាលី សង់វត្តសម្រាប់ព្រះសង្ឃផងដែរ។

ឧទាហរណ៍ ក្នុងឆាកទី៥ តាមសម្តីនាងយ៉ាងនិយាយជាមួយគិញ៖ " ចាសទេយកព្រះពុទ្ធធ្វើជាប្រធានខ្ញុំមិនបានដឹងទេ... "។

– **ការសិក្សាអប់រំ** : ក្នុងរឿងការសិក្សាអប់រំមានតាំងពីអនុវិទ្យាល័យរហូតដល់វិទ្យា ល័យ។ ពិសេសមានការបែងចែកសិស្សប្រុស និងស្រីជាក់ស្តែង ផានីតសិក្សានៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ឯកាទូចចូលសិក្សា អនុវិទ្យាល័យនារី ។

ឧទាហរណ៍: ក្នុងឆាកទី១ ផានីតបានពោលថា៖ " នៅរៀនវិទ្យាល័យស៊ីសុវត្ថិ... ក៏មកសុំធ្វើការនៅនេះ យកលុយរៀនឈ្នួលយប់ៗទៀត " ។

**សេចក្តីសន្និដ្ឋាន**

តាមការសិក្សាវិភាគខាងលើ យើងអាចវាយតម្លៃបានថា រឿងថៅកែចិត្តចោរ គឺជារឿងមួយ ដែលលោក ពៅ យូឡេង និងលោក អ៊ុំ ឈឺន ប្រឌិតឡើងលើបញ្ហាពិតខ្លះ ដែលកើតមាននៅក្នុងសង្គមខ្មែរយើង។ ការណ៍នេះដើម្បីស្តែងឡើងពញ្ញាក់អារម្មណ៍ខេមរជន ពិសេសយុវជនជំនាន់ក្រោយ ឱ្យចាប់អារម្មណ៍ពីបញ្ហាសង្គម ហើយចូលរួមចំណែករកវិធីដោះ ស្រាយ ដើម្បីប្រែក្លាយសង្គមខ្មែរមួយ ទៅជាសង្គមនីតិរដ្ឋ ពិតប្រាកដ។ ជារួមមករឿងថៅកែចិត្ត ចោរ ល្អទាំងផ្នែកអត្ថន័យ អត្ថរស និងអត្ថរូប ពិសេស អ្នកនិពន្ធមានទេពកោសល្យប៉ិនប្រសប់ ក្នុងការជ្រើសរើសពាក្យពេចន៍ឱ្យស៊ីតាមស្ថានភាព រឿង និងសម័យកាលនៃស្រុកទេស ។

## ឯកសារពិគ្រោះ

១.លោក ពន់ ឆាយ *ទ្រឹស្តីអក្សរសិល្ប៍ខ្មែរ* ឆ្នាំ ២០០៨ ។

២.លោក ពុយ គា *រដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ដល់ឆ្នាំ២០១០* ឆ្នាំ ២០១០ ។

៣.លោក ពេជ្រ ទុំក្រវិល *តន្ត្រី របាំ និងល្ខោនខ្មែរ* ឆ្នាំ២០១០ ។

៤.លោក លាង ហាប់អាន *សិក្សាអត្ថបទ* ឆ្នាំ១៩៦៦ ភាគ១ និងភាគីទី២

៥.លោក លី ធាមតេង *ការស្រាវជ្រាវអំពីល្ខោនខ្មែរ* ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ១៩៧១។

៦. វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រក្រសួងអប់រំ *ថៅកែចិត្តចោរ* ឆ្នាំ១៩៨៩ ។

៧. អ្នកស្រី ត្រឹង ងា *អរិយធម៌ខ្មែរ* ឆ្នាំ១៩៧៤ ។

៨. វចនានុក្រម ជួន ណាត

៩. រឿងថៅកែចិត្តចោរ និពន្ធដោយលោក អ៊ុំ ឈឺន និងលោក ពៅ យូឡេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង ទុំទាវ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..........................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងទុំទាវ»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍ « រឿងទុំទាវ » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណោះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណោះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណោះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ[illegible] ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមានការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាពចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការបច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី "ការសិក្សាអត្ថបទអក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបានជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ"**សិក្សាអត្ថបទអក្សរសិល្ប៍**" ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ «**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង ទុំទាវ**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាប់នាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោក អោ សៀម

៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន

២- លោកស្រី ម៉ៅ គាន់ណារី

៣- លោក ព្រៃ សំបូរ

៤- លោក ងិន សុតារា

៥- លោក ប៉ែន សំភាស់

៦- លោកស្រី វ៉ាន់ សុភី

៧- លោក វ៉ិត សុខខេង

៨- លោកស្រី ផាន់ សុជាតា

១០- លោកស្រី សេង ពិសិដ្ឋនារី

១១- លោកស្រី បែន នាង

១២- លោក កួយ សូគាន

១៣- លោក អ៊ិត សុធា

១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ
ប្រកាស ........................................................................................................i
បុព្វកថា ........................................................................................................ii
គណៈកម្មការ....................................................................................................iii
អារម្ភកថា........................................................................................................iv
មាតិកា............................................................................................................v
សេចក្តីផ្តើម.........................................................................................................
I. ការបង្ហាញអត្ថបទ..............................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង.......................................................................................
III. ទិដ្ឋភាពទំនាស់..................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ...........................................................................................
V. ទិដ្ឋភាពសង្គម....................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ.............................................................................................
VII. ទិដ្ឋភាពតម្លៃ....................................................................................................
VIII. ការសន្និដ្ឋាន...................................................................................................
IX. ឯកសារពិគ្រោះ..................................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

### រឿង ទុំទាវ

## ផ្ដើមសេចក្ដី

រឿងទុំទាវ ត្រូវបានជាស្នាដៃមួយដែលផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតជាតិ យ៉ាងជ្រាលជ្រៅ ហើយក៏មានការគាំទ្រដ៏លើសលុប ក្នុងមជ្ឈដ្ឋានសង្គមខ្មែរ ជាពិសេសពីសំណាក់អ្នកសិក្សា អ្នកអាន។ មួយវិញទៀត រឿងទុំទាវក៏បានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៃក្រសួងអប់រំ គ្រប់សម័យកាល។ បើយើងធ្វើការប្រៀបធៀប រវាងរឿងទុំទាវទៅនឹងស្នាដៃអក្សរសិល្ប៍បរទេស មួយចំនួនយើងប្រាកដជាឃើញថា តម្លៃដ៏ពិសិដ្ឋនៃស្នាដៃនេះពិតជាមានលក្ខណៈល្អពិសេស លេចធ្លោទាំង អត្ថន័យ អត្ថរូប និងអត្ថរសស្ទើរតែនឹងរកអ្វី មកបរិយាយឱ្យអស់សេចក្ដីពុំបានឡើយ។ ស្របជា មួយគ្នានេះ កវីក៏បានបញ្ចេញទេពកោសល្យប្រកបទៅដោយគុណតម្លៃនៃសិល្បវិធី ក្នុងការផ្ចិតយកតថភាពសង្គមខ្មែរនាសម័យលង្វែក មកបង្ហាញយ៉ាងប្រត្យក្ស។ ការសិក្សារឿងទុំទាវមិនត្រឹមតែផ្ដល់ចំណេះដឹងជាមូលដ្ឋានពីវិស័យផ្សេងៗក្នុងសម័យអតីតកាលនៃសង្គមខ្មែរប៉ុណ្ណោះទេ វាថែមទាំងបានបណ្ដុះឆន្ទៈដល់កូនខ្មែរគ្រប់រូប ឱ្យមានមោទនភាពចំពោះភូមិសាស្ត្រទឹកដី ព្រៃព្រឹក្សា បក្សាបក្សី ឈ្មោះ ភូមិស្រុកមួយចំនួននិងមុខរបររបស់ប្រជារាស្ត្រខ្មែរដែលជាអត្តសញ្ញាណជាតិពិតៗទៀតផង។

### I.ការបង្ហាញអត្ថបទ៖

### ១.អត្ថបទ

- **ចំណងជើង** : រឿងទុំទាវ
- **ប្រភព** : មានប្រភពមកពីប្រទេសកម្ពុជា
- **ប្រភេទ** : រឿងទុំទាវ ជាស្នាដៃអក្សរសិល្ប៍ទំនើប ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។

រឿងនេះត្រូវសបានតាក់តែងឡើងជាបទកាព្យពាក្យ៧មានចំណាប់ចុងចួននិងឃ្លាប្រយោគពីរោះណែងណងគួរជាទីចាប់ចិត្តដែលតាក់តែងឡើង ដោយព្រះបទុមត្ថេរសោមក្នុងរវាងឆ្នាំ១៩១៥។ ខ្លឹមសាររឿងតាំងពីដើមរហូតដល់ចប់កវីបានសរសេរជាពាក្យកាព្យមានចំនួន១០៥០ល្បះ ឬវគ្គ ដោយបានបង្ហាញពីតថភាពសង្គមខ្មែរនាសម័យលង្វែក។ ជាមួយនេះដែរ កវីក៏បានរំលេចឱ្យឃើញភូមិសាស្ត្រនិងស្ថាននាមទឹកដីខ្មែរនាសម័យនោះ ដូចជាត្បូងឃ្មុំ បាភ្នំ វិហារធំ លង្វែក សំរោងទង ស្អាង កណ្ដាលស្ទឹង លើកដែក ព្រែកហ្លួង ព្រែក ដំបង ជ្រោយចង្វា ព្រែកព្នៅ ជាដើមដើម្បីឱ្យកូនខ្មែរបានស្គាល់។

- **ចលនា** : ខេមរនិយម

### ២.អ្នកនិពន្ធ

- **ឈ្មោះអ្នកនិពន្ធ**: ព្រះបទុមត្ថេរសោម (ងួន សោម ឬភិក្ខុសោម)
- **ជីវប្រវត្តិ** : **ព្រះបទុមត្ថេរសោម(១៨៥២-១៩៣២)**

ជាកវីដ៏ល្បីល្បាញនៅព.ស.២៤៥៨ ត្រូវនឹងគ.ស.១៩១៥ ដែលយើងស្គាល់នាមនិងប្រវត្តិត្រួសៗខ្លះតាមរយៈស្នាដៃរឿងទុំទាវ ។

កុមារងួនសោមកើតនៅឆ្នាំ១៨៥២ ក្នុងឃុំកំព្រៅ ខេត្តស៊ីធរកណ្តាល(សង្កាត់កំព្រៅ ស្រុក ស៊ីធរកណ្តាល ខេត្តព្រៃវែង)[1]។ បិតានាមងួននិងមាតានាម **ឃិន** ជាកសិករធុនមធ្យមនៅភូមិកំព្រៅ។ កុមារសោមមានបងប្អូនប្រាំពីរនាក់ សុទ្ធតែប្រុសទាំងអស់គឺឈ្មោះសរ នង កិម អុក ស្រី សោម និងសម។

លុះកុមារសោម មានអាយុ១៥ឆ្នាំ បិតាបានបញ្ជូលរូបលោកឱ្យមករៀននៅវត្ត ឥន្ទកាលា ហៅកំព្រៅ ដើម្បីឱ្យសិក្សាអក្សរ លេខនព្វន្តផ្សេងៗ។ពីរឆ្នាំក្រោយមក មាតាបិតាក៏បំបួសកុមារសោម ជាសាមណេរក្នុងវត្តដដែលនេះ។ បួសបានពីរវស្សាក៏លាលោកគ្រូចៅអធិការចាកសិក្ខាបទ ដើម្បីទៅជួយធ្វើការ និងបម្រើ អ្នកមានគុណដែលមានភាពជរា។ប៉ុន្តែ ដោយហេតុចង់ឱ្យកូនបានចេះដឹងនឹងគេពេក មាតាបិតាជី[2]សោម បានបំបួសបុត្រសម្លាញ់ជាភិក្ខុ ក្នុងវត្តកំព្រៅទៀត ដែលមានព្រះតេជគុណរស់ហៅ គង់ ជាឧបជ្ឈាយ៍មាននាមបញ្ញត្តិថា ព្រះបទុមត្ថេរសោម ក្នុងជន្មាយុ ២១ឆ្នាំ។

ព្រះភិក្ខុសោមជាសាមណៈ មានចិត្តស្រឡាញ់ព្រះពុទ្ធសាសនាណាស់ លោកខិតខំសិក្សាធម៌វិន័យ ឥតមានធ្វេសប្រហែសឡើយ។ ព្រះសង្ឃក្តី ឧបាសក ឧបាសិកាក្តីតែងតែគោរពរាប់អានលោកគ្រប់ពេលវេលាដោយលោកតែងតែណែនាំឱ្យស្គាល់ខុសត្រូវក្នុងផ្លូវជីវិត។ ព្រះអង្គសុគតនៅឆ្នាំជូត ខែមាឃ ក្នុងជន្មាយុ៨០វស្សា ដោយជរាពាធ ត្រូវ នឹងគ.ស.១៩៣២។

ភិក្ខុសោមឧស្សាហ៍សរសេររឿងផ្សេងៗណាស់ ។ តាមទម្លាប់របស់លោក ច្រើនសរសេរវេលាថ្ងៃរសៀលនៅលើក្តារឈ្នួន ឬខ្មៅដៃ ហើយឱ្យគេចារចម្លងដាក់ក្នុងសាស្ត្រាលោកបានសរសេររឿងចៅស្រទបចេក វិមានចន្ទ មរណមាតា សព្វសិទ្ធិ ផ្កាវាំទឹកវាំ តែមិនដឹងលោកយកពីណាមកទេ ដោយចាំមាត់ក៏មិនដឹង ព្រោះមិនឃើញ មាន[3]។

ចំពោះរឿងទុំទាវ លោកបាននិពន្ធឡើង តាមការស្តាប់នៃស្ត្រីអ្នកចម្រៀងម្នាក់ឈ្មោះ «សៃបួរ»។អ្នកចម្រៀងនេះគាត់រមែងដើរច្រៀងពាសពេញស្រុកស៊ីធរកណ្តាល និងខេត្តដទៃទៀតជាច្រើន ដែលគាត់បានដាក់ងារខ្លួនឯង «សៃបួរជាជួរញ៉ាំញ៉ើ ចេះច្រៀងចាប៉ីគ្រាន់បើដើរច្រៀងរៀងមក...»។

ដូច្នេះរឿងទុំទាវ ដែលយើងសិក្សាសព្វថ្ងៃ មិនមែនជារឿងរបស់លោកបង្កើតឡើងទេ គឺជារឿងប្រជាប្រិយ ឬមានរឿងទុំទាវនេះ ប្រាកដមែនក្នុងសង្គមខ្មែរយើង។ កវីគ្រាន់តែបង្កើតពាក្យពេចន៍ចងក្រងជារឿងមិនខុសពីអ្នកសរសេររឿង ប្រលោមលោកផ្នែកប្រវត្តិសាស្ត្រ ឬវីរជនស្នេហាជាតិណាម្នាក់ គ្មានឯកសារតែមានអ្នកស្រុកនិយាយតៗ គ្មានាសម័យបច្ចុប្បន្ន
ឡើយ ហើយលោកក៏បានបញ្ជាក់ក្នុង អារម្ភកថារបស់លោកផងដែរ «នេះនឹងថ្លាថ្លែងថៃងចរចាល្បើកល្បងល្បែងល្បាយកាយកាព្យា តាំងតែតំណាលកាលមុនជា និទានយូរយារឃ្លាឃ្លាតឆ្ងាយ។ មិនទៀង

[1]សិក្សាអក្សរសាស្ត្រខ្មែរ បទុមត្ថេរសោមកវីសតវត្សទី១៩ ទុំទាវ ឆ្នាំ១៩៧១ ដោយគង់ សម្ភារ

[2] ជី តាមចាស់ៗបុរាណលោកសម្រាប់ហៅអ្នកសឹកពីសាមណេរ

[3] សិក្សាអក្សរសាស្ត្រខ្មែរ បទុមត្ថេរសោមកវីសតវត្សទី១៩ ទុំទាវ ឆ្នាំ១៩៧១ ដោយគង់ សម្ភារ

ល្បៀងល្អក់តក់ឃ្លាឃ្លាត សង្វាតផ្ទៀងផ្ទាត់បទបរិយាយ យើងកែជាថ្មីដែនដីអាយ ស្រង់ស្រាយតទុកទៅមុខទៀត។ ឱ្យអស់មហាជនជាតិប្រុសស្រី ក្នុងដែនលោកិយដឹងទៅមុខ»។

កំណាព្យត្រង់នេះ សឱ្យឃើញថា ព្រះភិក្ខុ សោម ពិតជាកវីចេះដឹងជ្រៅជ្រះ មែនដោយលោកបានបញ្ជាក់ថែមទៀតក្នុងរឿងទុំទាវនេះថា«និទានយូរយារ...» មកហើយ។ ព្រះបទុមត្ថេរសោម បានសុគតនៅ គ.ស១៩៣២ ក្នុងព្រះជន្មាយុ៨០ ព្រះវស្សា។

1. - **ស្នាដៃសំខាន់ៗ** : ស្នាដៃសំខាន់ៗរបស់លោកដែលនៅសេសសល់មានៈ

- •រឿង ផ្កាវាំទឹកវាំ(១៩១១)
- •រឿង ទុំទាវ(១៩១៥)
- •រឿងសព្វសិទ្ធិ(១៩១៨)

## ៣.កាលកំណត់តែង

- **ថ្ងៃ ខែ ឆ្នាំនៃការតាក់តែង** : រឿងទុំទាវ ដែលជាស្នាដៃរបស់ភិក្ខុសោម បានតាក់តែឡើងនៅព.ស២៤៥៨ គ.ស.១៩១៥ មានចំនួន១០៥០ល្បះ ជាបទពាក្យ៧តាំងពីដើមដល់ចប់។ ស្នាដៃនេះតាក់តែងក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ(១៩០៤-១៩២៧)។

- **ថ្ងៃ ខែ ឆ្នាំនៃការបោះពុម្ព** : បោះពុម្ពនៅឆ្នាំ១៩៧១ ព.ស.២៥១៤[4]

## ៤.សង្គមបរិយាកាស

- **កាលប្រវត្តិ** : (សម័យកាលកកើតរឿង)ក្នុងការពិពណ៌នាអំពីតួអង្គ ព្រះបាទរាមា អ្នកនិពន្ធ បានបញ្ជាក់ថា«រីឯដំណើរអំបាលនេះ នឹងបញ្ឈប់ស្លេះទុកសិនខ្ចី ថ្លាថ្លែងពីអង្គព្រះចក្រី ស្ដេចគង់បុរីវដ្ឋរាជស្ថាន។ ស្ដេចគង់នគរកម្ពុជា ឈ្មោះព្រះរាមាវិទ្ធិថ្កើងថ្កាន អស់រាស្ត្រប្រជាសឹងសុខសាន្តរាជស្ថានស្ដេចគង់បន្ទាយលង្វែក»។

តាមរយៈការរៀបរាប់នេះ យើងអាចសន្និដ្ឋានបានថា ដំណើររឿងទុំទាវ ប្រព្រឹត្តទៅក្រោមរបបរាជានិយមនាសម័យលង្វែក (១៥៦១ - ១៦១៨) [5] ។

- **ព្រឹត្តិការណ៍សំខាន់ៗ**

ក្នុងសម័យលង្វែក ប្រទេសកម្ពុជាបានជួបប្រទះនឹងសង្គ្រាម ជាញឹកញយ ដោយមានទាំងការឈ្លានពានពីប្រទេសសៀមផងនិងការដណ្ដើមរាជ្យ គ្នាក្នុងវង្សរាជាខ្មែរផង។

•ស្ដេចអង្គច័ន្ទទី១ ពេលត្រឡប់ពីសៀមមកវិញបានសម្លាប់ស្ដេចកននៅសំរោង ហើយឡើងគ្រងរាជ្យ (១៥០៥-១៥៥៦)ដោយលើករាជធានីទៅគង់នៅលង្វែក ។[6]

.បន្ទាប់មក សៀមបានចាត់ឱ្យពញាអុងជាស្ដេចខ្មែរ ដែលចិញ្ចឹមទុកឱ្យចេញមក ច្បាំងជ

[4] រឿងទុំទាវ ព្រះបទុមត្ថេរសោម រៀបរៀង បោះពុម្ពលើកទី៧ ចំនួន១០.០០០ច្បាប់ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១៤

[5]សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨

[6]សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨

ណ្តើមរាជ្យ ដោយមានទ័ពសៀមជំនួយផង ។

.សៀមវាយកបន្ទាយលង្វែកបាន ជាដំបូងនៅឆ្នាំ ១៥៣២ ។

.ឆ្នាំ១៥៨១ ស្តេចសៀមព្រះចៅ នរេសួនបានបញ្ជូនទ័ពយ៉ាងច្រើនមានពល ១៥០.០០០ នាក់ ដំរី ៨០០ សេះ ១៨៥០ មកវាយខ្មែរ។

.ទ័ពសៀមចូលលុកលុយដល់ខេត្តបាត់ដំបង ពោធិសាត់ អង្គរ រលៀប្បៀរ និងបរិបូណ៌ (កំពង់ឆ្នាំង)។

.ព្រះបាទជ័យជេដ្ឋាទី១(១៥៨៦ -១៥៩៣) បានវាយកម្ចាត់សៀមទៅវិញ ។

.ឆ្នាំ១៥៩៣ សៀមលើកទ័ពមកវាយយកខេត្តកំពង់ស្វាយទន្លេសាបហើយទីបំផុត យកលង្វែកបាន ។ សៀមបានចាប់ស្តេចស្រីសុរិយោពណ៌ និងប្រជាជន ប្រមាណ ៩០.០០០ នាក់ព្រមទាំងប្រមូល ក្បួនខ្នាតនិងឯកសារផ្សេងៗទៀត យកទៅស្រុកវា ។

•ព្រះបាទរាមាជើងព្រៃ«១៥៩៤-១៥៩៦» បានកេណ្ឌទ័ពទៅវាយសៀមយកលង្វែកបានមកវិញនាឆ្នាំ ១៥៩៤ ដោយបានសម្លាប់មេទ័ពសៀម និងពួកពលរបស់វា ប្រមាណ ២០.០០០នាក់ ។

## II.ការវិភាគអត្ថបទ

## 1.ស្ថានភាពរឿង

### ក- សង្ខេបរឿង

ដំណើររឿង បានចាប់ផ្តើមដោយរៀបរាប់ពីតួអង្គទុំ ដែលជាកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់រស់នៅស្រុកបាភ្នំ ខេត្តព្រៃវែង។ ទុំបានបួសរៀនជាមួយមិត្តម្នាក់ឈ្មោះ ពេជ្រនៅក្នុងវត្តវិហារធំ។អ្នកទាំងពីរមានចំណេះខាងធ្វើតោកលក់។ ដោយឡែកទុំមានរូបខ្ចីល្អក់ ព្រមទាំងមានសំឡេងយ៉ាងពីរោះចេះទាំងមន្តអាគម ចំណែកពេជ្រចេះផ្លុំបុី។ ថ្ងៃមួយនេនទាំងពីរ បានសុំលាលោកគ្រូយកតោកទៅលក់នៅត្បូងឃ្មុំ។ លោកគ្រូក៏អនុញ្ញាតដោយផ្តែផ្តាំ ឱ្យចេះរក្សាតម្លៃខ្លួនជាសង្ឃ។ មកដល់ត្បូងឃ្មុំ អ្នកស្រុកពេញចិត្តនឹងទុំយ៉ាងខ្លាំង ព្រោះទុំស្មូតបានពីរោះធ្វើឱ្យអ្នកស្រុកត្បូងឃ្មុំផ្អើលឈូរឆរមកស្តាប់។ នាងនៅជាភីលៀងរបស់នាងទាវ បានឃើញទុំដែលមានរូបសម្បត្តិស្រស់ស្អាត និងមានសំឡេងពីរោះ ក៏កួចចិត្តស្នេហា តែសុខចិត្តត្រឡប់ទៅ ជម្រាបទាវវិញ។ នាងទាវបានដឹងដំណឹងនេះភ្លាម នាងខិតខំអង្វរករអ្នកម្តាយឱ្យទៅ និមន្តនេនទុំមកស្មូតនៅលើផ្ទះរបស់ខ្លួន។ នេនទុំក៏មកស្មូតនៅផ្ទះទាវតាមការនិមន្ត របស់ម្តាយទាវ យ៉ាងពីរោះធ្វើឱ្យ នាងទាវចាប់ចិត្តស្រឡាញ់ រួចក៏យកគ្រឿងបរិក្ខារ ដូចជាផាហ៊ុមជន្លាប់ និងស្លាបារីមកប្រគេនទុំ។មុននឹង យកមកប្រគេននេនទុំនាងទាវក៏បានបួងសួងសូម ឱ្យខ្លួនបានជួបជុំរួមរស់ជាមួយទុំ

គ្រប់ៗជាតិទៀតផង។ ចំណែកនេនទុំ ក៏កួចចិត្តលួចស្រឡាញ់ទាវដែរ។ លុះពេល ត្រឡប់មកដល់វត្តវិញទុំនឹករកតែនាងទាវ រួចក៏រកឧបាយកលសុំលោកគ្រូសឹក តែលោកគ្រូពុំព្រមឱ្យសឹក ព្រោះតាមការទស្សន៍ទាយទៅឃើញថា បើទុំសឹកក្នុងខែបុស្ស នឹងត្រូវមានគ្រោះរហូតបាត់បង់

ជីវិត។ តែបើសិនជាសឹកខែពិសាខវិញ នឹងត្រូវបានធ្វើជាអ្នកធំ។ ប៉ុន្តែទុំមិនបានស្តាប់តាមការហាមប្រាមនេះទេ ផ្ទុយទៅវិញទុំព្យាយាម ឱ្យម្តាយជួយអង្វរលោកគ្រូឱ្យខ្លួនបានសឹកតាមបំណងតែមិនបានសម្រេច

ឡើយ។ ទីបំផុតទុំក៏សម្រេចចិត្តលួចសឹកតែម្នាក់ឯង ដោយចោទថាសេចក្តីស្នេហានេះ បណ្តាលមកពីកម្ម រួចទុំក៏សឹកក្នុងព្រៃក្បែរដំបូក ហើយប្រញាប់ប្រញាល់បបួលពេជ្រវិលទៅត្បូងឃ្មុំវិញ។ ដោយចៃដន្យនៅពេលទុំមកដល់ផ្ទះនាងទាវ គាប់ជួនម្តាយនាងមិននៅផ្ទះ អ្នកទាំងពីរក៏បានរួមចិត្តរួមកាយក្នុងក្តីស្នេហាមួយដ៏ផ្អែមល្ហែម។

ក្រោយមកអរជូន ជាចៅហ្វាយខេត្តត្បូងឃ្មុំ និងភរិយាបានចូលមកស្តីដណ្តឹងនាងទាវឱ្យទៅម៉ឺនងួនជាកូនប្រុសរបស់ខ្លួន។ ម្តាយទាវសប្បាយចិត្តណាស់ ព្រោះខ្លួននឹងបានធ្វើជាដន្លងជាមួយលោកឧកញ៉ាអរជូន ដែលមានទ្រព្យសម្បត្តិច្រើន។ ប៉ុន្តែនាងទាវបានប្រកែកពុំយល់ព្រមទទួលម៉ឺនងួនជាប្តីឡើយ ហើយម្តាយនាងក៏បានបង្ខំ ដោយរំឭកដល់ពាក្យព្រេងបុរាណថា «នំមិនធំជាងនាឡិ» និងព្រមានថានឹងវាយឱ្យស្លាប់ដូចកូនគោមិនព្រមចូលនឹងតាមម្ចាស់វា។ ទន្ទឹមនឹងនោះទុំនិងពេជ្រត្រូវព្រះរាជាឱ្យចូលគាល់បម្រើក្នុងរាជវាំងដោយពេជ្រចេះផ្លុំប៉ីនិងទុំចេះស្មូតយ៉ាងពីរោះក៏ប្រទានងារជាម៉ឺនឯក។ ទន្ទឹមនឹងនោះដែរព្រះរាជាទ្រង់ចង់បានស្ត្រីរូបស្អាត យកមកធ្វើជាស្នំឯកក៏ជ្រើសរើសចំលើនាងទាវដែលជាសង្សាររបស់ទុំ។ នាងទាវត្រូវបានចៅហ្វាយខេត្តអរជូន ចាត់ចែងនាំយកទៅថ្វាយព្រះរាជា។ រឿងនេះបានធ្វើឱ្យម្តាយទាវសប្បាយចិត្តយ៉ាងខ្លាំង ព្រោះគាត់សង្ឃឹមថានឹងបានធ្វើជាម្តាយក្មេករបស់ព្រះរាជា។ ពេលបានជួបគ្នានៅរាជវាំងស្ថិតនៅចំពោះព្រះភក្ត្រព្រះរាជា ទុំក៏ច្រៀងរៀបរាប់ដំណាលសព្វ តាំងពីខ្លួនធ្លាប់បានរួមស្នេហាជាមួយទាវថ្វាយដល់ព្រះរាជា។ ព្រះរាជាខ្ញាល់យ៉ាងខ្លាំងក៏សាកសួរនាងទាវថា រឿងនេះពិតដូចជាទុំច្រៀងរៀបរាប់នោះទេ ? នាងទាវបានទូលនិងសម្តែងអាកប្បកិរិយា ក្នុងនាមទុំជាសង្សារខ្លួនដែរ។ ដំបូងព្រះរាជាខ្ញាល់ តែក្រោយមកទ្រង់ក៏យកធមិមកជាទីពឹង មានព្រះទ័យមេត្តាសន្តោសអ្នកទាំងពីរ ហើយព្រះអង្គក៏សព្វព្រះទ័យរៀបចំផ្សំផ្គុំអ្នកទាំងពីរ ជាគូស្វាមីភរិយាតាំងពីពេលនោះមក។ ហេតុការណ៍បានធ្វើឱ្យម្តាយទាវនឹកតូចចិត្តយ៉ាងខ្លាំង ក៏វិលមកស្រុកកំណើតវិញ ដើម្បីរកឧបាយកលនាំនាងទាវមករៀបការនឹងម៉ឺនងួន វិញ ដោយគាត់បានក្លែងសំបុត្រថា គាត់មានជំងឺជាទម្ងន់ ឱ្យនាងទាវជាកូនឆាប់វិលមកស្រុកកំណើតវិញជាប្រញាប់។ ក្រោយពីបានទទួលដំណឹងនេះភ្លាម នាងទាវក៏ប្រញាប់លាទុំជាប្តីធ្វើដំណើរមកមើលម្តាយជាមួយនាងនោ។ មកដល់ផ្ទះនាងទាវត្រូវម្តាយបង្ខំឱ្យរៀបការជាមួយម៉ឺនងួន។ នាងទាវអស់សង្ឃឹមក៏សរសេរសំបុត្រមួយច្បាប់ផ្ញើ ឱ្យគេយកទៅជូនទុំជាប្តីនាង ។ ទុំទទួលដំណឹងនេះភ្លាម ក៏រន្ធត់ចិត្តយ៉ាងខ្លាំងរួចក៏ទៅទូលព្រះរាជា ដើម្បីសូមលាទៅជួយនាងទាវជាប្រពន្ធ។ ព្រះអង្គទ្រង់ខ្ញាល់និងអរជូនបានប្រទានព្រះរាជសារដល់ទុំនិងពេជ្រ ឱ្យយកទៅឃាត់អរជូន និងម៉ឺនងួនឱ្យបញ្ឈប់អាពាហ៍ពិពាហ៍នោះជាបន្ទាន់។ ពេលមកដល់ផ្ទះនាងទាវទុំឮសូរភ្លេងការ ក៏ស្រងាកចិត្តវង្វេងបាត់ បង់អស់ស្មារតីអស់សង្ឃឹម។ ក្រោយពីស្លៀកពាក់បានត្រឹមត្រូវ តាមមន្ត្រីរាជវាំងរួចមកទុំក៏យករាជសារមកក្រវាត់នៅនឹងចង្កេះ រួចក៏ឡើងមកលើផ្ទះការច្រៀងអន្ទង ឱ្យនាងទាវចេញមកចាក់ស្រាឱ្យខ្លួនផឹក។ ពេលផឹកស្រាស្រវឹងទុំក៏ប្រកៀកប្រឱបនាងទាវ ដែលជាប្រពន្ធខ្លួននៅចំពោះមុខភ្ញៀវ ជាហេតុធ្វើឱ្យម្តាយទាវខឹងច្រឡោតក៏ពន្យុះឱ្យអរជូនយកទុំទៅសម្លាប់។ ទុំក៏ត្រូវអរជូន និងបក្សពួកយកទៅសម្លាប់ចោលក្រោមពោធិ៍ដើងខាល។

កាលបើដឹងថា ប្តីខ្លួនត្រូវគេសម្លាប់ដូចនេះ នាងទាវក៏នាំនាងនោទៅតាមរកទុំ ឃើញខ្មោចទុំ

ហើយ ក៏នាំគ្នាអាករនឹងកាំបិតស្លាប់សម្លាប់ខ្លួនទាំងពីរនាក់នៅលើសាកសពទុំ។ ពេជ្របានយកដំណឹងនេះមកថ្វាយព្រះរាជា ជាបន្ទាន់ព្រះអង្គទ្រង់ជ្រាបហើយ ទ្រង់ខ្ញាល់យ៉ាងខ្លាំងរួចក៏ទ្រង់ប្រជុំអស់សព្វមុខមន្ត្រី រួចក៏យាងទៅជំនុំជំរះក្ដីនេះ ដោយតម្រូវឱ្យវាស់ក្បាលទាំងរស់ ចំពោះពួកអរជូន និងម្ដាយទាវចំណែកអ្នកត្បូងឃ្មុំវិញត្រូវបញ្ចូលជាអ្នកងារទាំងអស់។

ខ.**តួអង្គ**

- **តួអង្គឯក**

•នេនទុំ ៖ ជាកូនស្រីមេម៉ាយម្នាក់នៅបាភ្នំ បានបួសរៀនជាសាមណេរនៅវត្តវត្តវិហារធំបាភ្នំ ខេត្តព្រៃវែង និងជាស្វាមីនាងទាវ ដែលបានព្រះរាជារៀបការឱ្យ។

•នាងទាវ ៖ ជានារីកំព្រាឪពុក រស់នៅជាមួយម្ដាយមេម៉ាយនៅត្បូងឃ្មុំ នាងជា នារីល្អដាច់គេហើយត្រូវបានព្រះរាជាជ្រើសតាំងជាស្នំឯកតែដោយជាអតីតសង្សារទុំព្រះអង្គក៏រៀបផ្សំផ្គុំទុំទាវជាប្ដីប្រពន្ធ។

- **តួអង្គរង**

•ព្រះរាជា ៖ ជាស្ដេចសោយរាជ្យនៅក្រុងលង្វែក ។

•អរជូន ៖ ជាចៅហ្វាយខេត្តត្បូងឃ្មុំ ជាឪពុករបស់ម៉ឺនងួន។

•ម៉ឺនងួន៖ កូនប្រុសអរជូននិងជាគូដណ្ដឹងនាងទាវ។

•ម្ដាយទាវ ៖ ជាអ្នករៀបចំសកម្មភាពបំបែកបំបាក់ទាវពីទុំ និងពន្យុះឱ្យអរជូនយកទុំទៅសម្លាប់។

•នេនពេជ្រ ៖ មិត្តភក្ដិរបស់ទុំជាអ្នកធ្លាប់បានបួសរៀននិងដើរ ដើរលក់តោកជាមួយទុំហើយត្រូវព្រះរាជាឱ្យចូលរាំងជាមួយទុំ។

•នាងនោ ៖ ជាភីលៀងរបស់នាងទាវ សុខចិត្តសម្លាប់ខ្លួនតាមនាងទាវ ក្រោយពីទុំស្លាប់ទៅ។

•គ្រូចៅអធិការ ៖ គ្រូរបស់ទុំនិងពេជ្រនៅវត្តវិហារធំ លោកបានហាមឃាត់ទុំមិនឱ្យសឹក ព្រោះទំនាយថា នឹងមានគ្រោះថ្នាក់។

•ម្ដាយទុំ៖ ជាស្ត្រីមេម៉ាយនៅបាភ្នំ ។

•ប្រជារាស្ត្រ ៖ អ្នករស់នៅខេត្តត្បូងឃ្មុំដែលព្រះរាជាបញ្ជូនជាអ្នកងារ។

គ- **កាលអាកាស**

- **កាល** : ដំណើររឿងប្រព្រឹត្តទៅនាសម័យលង្វែក ។

- **អាកាស** : ដំណើររឿងនេះបានប្រព្រឹត្តទៅនៅទីកន្លែងមួយចំនួន ដូចជានៅតាមជួរមាត់ទន្លេដែលមាន ជ្រោយចង្វារ ព្រែកដំបង ជ្រោយមេត្រី ព្រែកបង្កង កងមាស កៀនស្វាយ ពាមតាឯក ពាមជរ លើកដែក ស្អាង កញ្ជរ ក្រចេះ ...។ នៅតាមភូមិស្រុកខ្លះទៀត ដូចជា កំពង់សោម បន្ទាយមាស សំរោងទង ភ្នំស្រួច គងពិសី ព្រែកប្បាស កណ្ដាលស្ទឹង ពោធិ៍សាត់ បាត់ដំបង កំពង់ស្វាយ កំពង់សៀម បារាយណ៍ រាជធានីលង្វែកត្បូងឃ្មុំពោធិ៍ជើងទាលវត្តវិហារធំស្រុកបាភ្នំជាដើម។

### ឃ- ព្រឹត្តិការណ៍សំខាន់ៗឬបញ្ហាសង្គមដែលបានបង្ហាញ

រឿងទុំទាវ បានបង្ហាញពីព្រឹត្តិការណ៍សំខាន់តាមរយៈសកម្មភាពតួអង្គតាងរបស់យុវជនខ្មែរនាសម័យលង្វែក ដែលទាមទារសិទ្ធិក្នុងការជ្រើសរើសគូស្រករ ក្រោមផ្នត់គំនិតអភិរក្សនិយម«នំមិនធំជាងនាឡិ»។ ជាមួយនឹងគំនិតខាងលើនេះ ជាកត្តាសំខាន់ដែលជំរុញឱ្យកើតមានជាវិបត្តិដ៏ធ្ងន់ធ្ងរ ជះឥទ្ធិពលមកលើវិចារណៈនិងសញ្ចេតនារបស់យុវជនយើង ឈានទៅរកការតស៊ូប្ដូរផ្ដាច់ ដើម្បីគ្រប់គ្រងជោគវាសនាខ្លួនដោយខ្លួនឯង។ ប៉ុន្តែសំណូមពរយុគសម័យកាលលង្វែកពុំអនុញ្ញាតឱ្យបុគ្គលណាមួយ បំពានលើប្រពៃណីដែលជាច្បាប់បានប្រកាន់កន្លងមកនោះបានឡើយ។ ទន្ទឹមនឹងនោះទស្សនៈ«ពងមាន់ កុំជល់នឹងថ្ម»បានបង្ក្រាបយ៉ាងមានប្រសិទ្ធភាពតាំងពីថ្នាក់កំពូលដែលមានស្ដេចផែនដី ស្ដេចត្រាញ់ ជាពិសេសមេគ្រួសារ។ ទោះបីរូបភាពនៃការគ្រប់គ្រងនោះ មិនដូចគ្នាយ៉ាងណាក៏ដោយ ក៏ខ្លឹមសារនៃការគ្រប់គ្រងតែមួយដូចគ្នា គឺ«អំណាចផ្ដាច់ការ» ដែលផ្ទុយស្រឡះពីបំណងប្រាថ្នា ឬឆន្ទៈអ្នកក្រោមបង្គាប់ ឬកូនប្រុស កូនស្រីរបស់ខ្លួនដែរ។

ដូច្នេះ អ្វីដែលលេចធ្លោ ហើយជាបំណងប្រាថ្នារបស់កវីចង់បង្ហាញនោះ គឺសិទ្ធិក្នុងការ ជ្រើសរើសគូស្រកររបស់យុវជន ត្រូវប្រឈមនឹងគំនិតអភិរក្សដែលជាផ្នត់គំនិតសង្គម។ មានន័យថា មានតែការសម្របសម្រួលតាមសុភាសិត «ចូលស្ទឹង តាមបត់...»នោះទេ ទើបរក្សាអាយុជីវិត ឬធ្វើឱ្យខ្លួនមានសេចក្ដីសុខ ឬក៏មានតម្លៃទៅបាន បើពុំដូចនោះទេ គេពិតជាមានក្ដីសោកស្ដាយជាមិនខាន។

## ២-អត្ថន័យ

### ក- ប្រធានរឿង

ខ្លឹមសារសំខាន់ក្នុងរឿងទុំទាវ គឺកវីចង់រំលេចឱ្យឃើញ«ប្រវត្តិស្នេហ៍ដ៏ឈឺចាប់របស់យុវជនខ្មែរក្រោមរបបសក្ដិភូមិផ្ដាច់ការនាសម័យលង្វែក»។ ជាមួយនឹងប្រវត្តិស្នេហ៍របស់តួអង្គឯកទាំងពីររូបគឺទុំនិងទាវនេះ កវីក៏បានលាតត្រដាងឱ្យឃើញពីរបបគ្រប់គ្រងនិងច្បាប់ទម្លាប់ដ៏តឹងតែងរបស់រាជានិយមផ្ដាច់ការនាសម័យលង្វែក ជាឥទ្ធិពលធ្វើឱ្យស្ថានភាពស្នេហារបស់ទុំទាវ ត្រូវឆ្លងកាត់ជាដំណាក់កាលដូចតទៅៈ

- **ស្នេហាទុំទាវ ជាស្នេហាកាំរន្ទះ**

ជាការពិតសម្រាប់យុវវ័យ សេចក្ដីស្នេហាពិតជាមានឥទ្ធិពលយ៉ាងខ្លាំងក្លា ដែលមានមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ និងផ្អែមល្ហែមជាទីបំផុត គឺផ្សារភ្ជាប់ទៅនឹងចិត្តសាស្ត្រ ព្រមទាំងជីវសាស្ត្ររបស់មនុស្សពិតប្រាកដ។ ទន្ទឹមនឹងនេះ សេចក្ដីស្នេហារបស់អ្នកទាំងពីរបានកើតឡើងពីការប៉ះទង្គិច រវាងក្រសែភ្នែកនឹងក្រសែភ្នែកនៃកំលោះក្រមុំដែលមានអារម្មណ៍ភ្លើតភ្លើនជិតដាមទៅដោយតណ្ហាពុះកញ្ជ្រោលនឹងស្នើររកអ្វីមកប្រៀបពុំបានឡើយ។ អ្នកទាំងពីរមានកំណួចចិត្តលើគ្នា ទៅវិញទៅមកក្នុងពេលដែលទុំទៅស្មូតនៅ លើផ្ទះទាវនោះតែម្ដង។ ស្ថិតក្នុងស្ថានភាពនោះនាងទាវគ្រាន់តែបានឃើញទុំមកដល់ផ្ទះខ្លួនភ្លាម នាងមានភាពច្របូច្របល់ក្នុងចិត្ត ៖

«អើតអើមដកកច្រហមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្លុតស្លឹងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពារនា»។

នាងទាវពុំអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបាន បណ្ដាលឱ្យនាងមានឥរិយាបថ បែបនេះ

ទៅវិញ។ តាមពិតនាងក៏បានត្រៀមខ្លួនត្រៀមចិត្តរួចជាស្រេច តាំងពីនាងនោបានធ្វើការរៀបរាប់ពេលនាងបានជួបទុំពីដំបូងមកម្ល៉េះថា ៖

«ទាវអើយទាវស្រីសេចក្តីនេះ　　លោកនេននោះចេះមើលសាស្ត្រា
សំឡេងស្រួយស្រាប់ស្តាប់ភាសា　　ដូចសត្វសារិកាពីសាចេក»។

ម្យ៉ាងទៀត គួបផ្សំនាងទាវនៅក្នុងម្លប់ផងដែលជាកត្តាជំរុញឱ្យនាងកាន់តែជ្រួលជ្រើមថែមទៀត។

រីឯទុំវិញក៏មិនចាញ់នាងទាវដែរ ព្រោះខ្លួនគ្រាន់តែបានឃើញនាងទាវភ្លាម ស្ទើរតែគ្រប់គ្រងខ្លួនឯងសឹងមិនបានផង។ ប៉ុន្តែដោយខ្លួនជាសង្ឃ នេនទុំក៏ខិតខំសន្សំចិត្តអត់ធ្មត់ទាំងក្តីក្តុកក្តួល៖

«នេនយល់ដូច្នោះក្នុងពោះព្រួច　　កាន់ក្ងួចកើតទុក្ខចុកឱរ៉ា
ឱរូបហ្នឹងហើយទាវពុំងា　　មិនងាកបំពារបំពេរនេ»។

ឥទ្ធិពលនេះ ដោយសារតែនេនទុំគង់នៅតែក្នុងវត្តមិនដែលធ្លាប់ទទួលអ្វី ដែលយុវវ័យចង់បានក្រៅពីស្តាប់ការទូន្មាន ឬបំពេញវិជ្ជាជាសាមណេរ តាមការបង្ហាត់បង្រៀនពីលោកគ្រូឧបជ្ឈាយ៍នោះឡើយ។ ដូចជាទុំធ្លាប់បានបញ្ជាក់ថា៖

«នៅវត្តប្រាកដជាអផ្សុក　　ជាទុក្ខគ្មានល្ហែក្នុងអង្គកាយ
ខ្ជិលណាស់ព្រះគុណមិនសប្បាយ　　ក្របាល់ក្រហាយខ្វល់ចង់ដើរ»។

សេចក្តីស្នេហារបស់អ្នកទាំងពីរ ពិតជាមានសន្ទុះខ្លាំងក្លា ព្រមទាំងពោរពេញទៅដោយមន្តស្នេហ៍ជ្រាលជ្រៅ គឺមិនចាញ់ស្នេហារបស់រ៉ូមេអូស៊ូលីយែតរបស់លោក **សេក ស្ពៀរ** ឡើយ។ ដោយសារកត្តានេះហើយ ដែលជំរុញឱ្យទុំទាវក្លាហានប្តូរផ្តាច់ហ៊ានស្លាប់រស់ជាមួយគ្នាក្នុងគ្រាក្រោយៗមកទៀត។

- **ស្នេហាទុំទាវ ជាស្នេហាប្តូរផ្តាច់**

ជាមួយនឹងក្តីស្រឡាញ់ ដ៏លើសលុបរបស់អ្នកទាំងពីរដូចនេះហើយ ទើបពួកគេមានឆន្ទៈ រួមគ្នាគឺរួមកាយរួមចិត្តពុះពារជំនះឧបសគ្គគ្រប់យ៉ាង ដោយមិនញញើត សោះឡើយ។ ជាក់ស្តែងនាងទាវហ៊ានប្រឆាំងអ្វីៗទាំងអស់ដើម្បីរក្សាគោលបំណងចំពោះស្នេហារបស់ខ្លួន។ ទឹកចិត្តដ៏សន្ធោរសន្ធៅរបស់អ្នកទាំងពីរនេះ ជាកត្តានាំមកនូវគុណវិបត្តិយ៉ាងធ្ងន់ធ្ងរចំពោះប្រពៃណីជាតិ ព្រោះ៖

«ទុំឱបបីបមថ្នមប្រឡែង　　ទាំងពីរផតក្រែងរួមមេត្រី
នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្តី　　ស្រស់ស្រីស្រួលស្រើបដោយតណ្ហា»។

ចំពោះទុំវិញ ធ្លាប់តែស្តាប់តាមដំបូន្មានគ្រូ ឥឡូវក៏បែរជាហ៊ានជំនះវិន័យសង្ឃជំនះពាក្យទស្សន៍ទាយរបស់លោកគ្រូប្តេជ្ញាចិត្តលាចាកសិក្ខាបទ ដើម្បីទៅជួបទាវទៅវិញ៖

«វន្ទាវន្ទៈអ្នកកុំឃាត់　　ផ្លាស់ស្បង់ចោលម៉ត់មិនស្រណោះ
រួចស្លៀកសំពត់ហូលល្អស្រស់　　លើកអស់អង្សែកដាក់ទុកទើរ»។

មិនតែប៉ុណ្ណោះ ទុំក៏មិនខ្លាចស្លាប់ដែរ គឺហ៊ានបកស្រាយរឿងរ៉ាវស្នេហា ជាមួយទាវនៅចំពោះព្រះភក្ត្រព្រះបាទរាមា ដោយហ៊ានបញ្ជាក់យ៉ាងច្បាស់ថា៖

«ករុណាសម្លាប់តាមទោសធំ　　ទុករស់ជាខ្ញុំព្រះបារមី

ទូលបង្គំជាខ្ញុំនឹងលាក់ថ្វី ឯនាងទាវស្រីសង្សារពិត»។

ជាងនេះទៅទៀត ទុំហ៊ានឡើងទៅប្រកៀកប្រឱបនាងទាវនៅចំពោះមុខអរជូន ម៉ឺនងួន ដែលជាសត្រូវរបស់ខ្លួនៈ

«ទុំខិតជិតជួបរួមត្រកង បីហើយថើបផងថាទាវអញ
ទាវអាងទុំប្ដីឥតគិតកាញ់ ខ្លាចគេចាក់បាញ់ចាញ់នរណា»។

ចំពោះនាងទាវ ក៏ពោរពេញទៅដោយភក្ដីភាពដោយនាងហ៊ានប្រឆាំង នឹងម្ដាយដែលប្រុងប្រៀបលើកខ្លួនឱ្យទៅម៉ឺងួនៈ

«ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ»។

នាងក៏ហ៊ានប្រឆាំងនឹងព្រះទ័យរបស់ព្រះរាមានៅពេល ដែលទ្រង់សព្វព្រះទ័យត្រូវជ្រើសរើសនាជាស្នំរបស់ព្រះអង្គ។ នាងបានសារភាពៈ

«ទាវទូលទៅអង្គព្រះចក្រី បពិត្រនរបតីសូមមេត្តា
ខ្ញុំនិងទុំពិតទៀងសត្យា ដូចព្រះករុណាទ្រង់ជ្រាបស្រាប់»។

ពិសេសជាងនេះ នាងទាវក៏ហ៊ានបូជាជិវិតតាមទុំៈ

«ទាវប្រេះប្រូបប្ដីដៃប្រវា បានកាំបិតស្លាអាផៀងឆិត
ត្រូវដាច់បំពង់កក្ស័យពិត កៀកកិតកើយគងទំនងជុំ»។

ស្ថិតក្នុងស្ថានភាពបែបនេះ ហើយដែលជាកត្តាចម្បងនាំឱ្យស្នេហាទុំទាវ មានលក្ខណៈជាស្នេហាកាំរន្ទះផង និងជាស្នេហាប្ដូផ្ដាច់ផង។

- **របបផ្ដាច់ការនាសម័យលង្វែក**

ជាការពិត តួនាទីនៃអក្សរសិល្ប៍ គឺឆ្លុះបញ្ចាំងពីតថភាពសង្គម។ យ៉ាងណាមិញរឿងទុំទាវ មិនគ្រាន់តែជារឿងឆ្លុះបញ្ចាំងពីចំណងស្នេហា ដ៏ឈឺចាប់ប៉ុណ្ណោះទេ ប៉ុន្ដែវាជាតថភាពមួយរបស់សង្គម ដែលមានរបបគ្រប់គ្រង និងច្បាប់ទម្លាប់ផ្ដាច់ការនាសម័យនោះទៀតផង។ តាមរយៈរឿងទុំទាវយើងឃើញថាសម័យកាលនោះមានលក្ខណៈផ្ដាច់ការ តាមលំដាប់ថ្នាក់តាំងពីលើរហូតដល់ក្រោមដែលបានគ្របដណ្ដប់ និងស្ទើរតែក្លាយទៅជាផ្នត់គំនិតទៀតផង។ ដូចជាក្នុងដំណើររឿងបានរៀបរាប់ និងបញ្ជាក់អំពីអំណាចទាំងបីនោះតាមរយៈការឆ្លុះបញ្ចាំងដូចតទៅ ៖

**•ចំពោះអំណាចស្ដេចផែនដី**

ជាមួយនឹងសកម្មភាពក្រេវក្រោធរបស់ព្រះរាមា ចំពោះអរជូនម៉ឺនងួន រហូតទ្រង់សម្រេចព្រះទ័យក្នុងការកាត់ទោសប្រហារជីវិតនោះ ពុំមែនមកពីមរណភាពរបស់ទុំទាវនោះទេ។ ប៉ុន្ដែអ្វីសំខាន់ មកពីអរជូនហ៊ានប្រឆាំងនឹងព្រះអង្គ ព្រោះទុំទាវព្រះអង្គសព្វព្រះទ័យ និងរាជានុញ្ញាតរៀបការឱ្យពួកគេបានរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ ហើយរឿងនេះអរជូនក៏ជ្រាបស្រាប់ដែរ តែអរជូនបែរជាបំពានទៅវិញ។ ដូចកវីបានរៀបរាប់ៈ

« ហ៊ានហែកដុតចោលបន្ទូលអញ ទោសវាចងចាញ់អាងួនកូន

ធ្វើទុក្ខធ្វើទោសឱ្យអស់សូន្យ      សន្តានបងប្អូនបញ្ចូលងារ »។

បើសិនជាអ្នកស្លាប់នោះ   មិនមែនជាទុំទាវទេម្ល៉េះសមព្រះអង្គក៏មិនមានព្រះទ័យខ្ញាល់ក្រេវក្រោធបែបនេះដែរ  ហើយបើសិនជាព្រះអង្គមិនព្រមធ្វើទោសដល់អរជូនម៉ឺនងួនទេព្រះអង្គនឹងមានអ្នក  ប្រឆាំងលើកក្រោយៗទៀត  ដោយយកគំរូតាមអរជូន  និងម៉ឺនងួនជាមិនខាន។  ម្យ៉ាងទៀតការដាក់ទោសមកលើក្រុមគ្រួសារអរជូន[7]បានឆ្លុះបញ្ចាំងឱ្យឃើញពីព្រះហឫទ័យព្រះរាជា  ដែល  ចង់ពង្រឹងឫទ្ធិចេស្តារបស់ទ្រង់ដោយធ្វើការវាយបង្ក្រាបរាល់ការបះបោរ  រពើតរពើងទាំងឡាយពីសំណាក់ពួកចៅហ្វាយស្រុក(ចៅហ្វាយខេត្ត) គឺ«សម្លាប់មាន់ បំភ័យស្វា»។ យ៉ាងនេះហើយ  ទើបទ្រង់ដាក់ទោសអរជូន និងម៉ឺនងួនយ៉ាងធ្ងន់ធ្ងរ៖

«ប្រាប់កងសេនាពួកទាហាន        ពុំមានបង្អង់ឱ្យលង់ឡើយ
ទៅចាប់អាចោរចិត្តឥតត្រើយ       ហ៊ានហើយប្រឡេះជាផេះផង់។
វាហ៊ានទទឹងនឹងអញច្នោះ          ទោសកាប់ស្ងោរស្រុសរាស់ជីកបង់
ជីកបុកក្នុងដីក្ស័យរូបអង្គ          កុំសង្ស័យសោះអាអរជូន»។

ទន្ទឹមនឹងនេះ បើនិយាយពីអរជូន ម៉ឺនងួនទោសកំហុសគាត់វាសមនឹងស្លាប់មែនហើយ តែចំពោះការដាក់ទោសមកលើអ្នកត្បូងឃ្មុំជាអ្នកងារ[8] ដូចជាមិនសមស្របទេ។ ដូចព្រះអង្គបានសម្រេចព្រះទ័យ៖

« ... ធ្វើទុក្ខធ្វើទោសឱ្យអស់សូន្យ      សន្តានបងប្អូនបញ្ចូលងារ »។

អំពើនេះ ជាអំពើអាចចាត់ទុកថា ជាអំពើឃោរឃៅព្រៃផ្សៃ គឺអំណាចស្តេចជាអំណាចផ្តាច់ការពិតប្រាកដ ។

**•អំណាចស្តេចត្រាញ់**

នៅសម័យលង្វែក ស្តេចត្រាញ់ជាមន្ត្រីជាន់ខ្ពស់មានងារជាចៅហ្វាយស្រុក។ មន្ត្រីនេះមានសក្តិដប់ហ្មឺពាន់[9] ហើយក្រៅពីត្រួតត្រាលើដែនសីមារបស់ខ្លួន ចៅហ្វាយស្រុកមានតួនាទីជាមេទ័ពធំ ទទួលរ៉ាប់រងរក្សាការពារប្រទេសជាតិទាំងមូល។       ចំពោះការគ្រប់គ្រងនេះពីបុរាណចំពោះស្តេចត្រាញ់មានប្រាំ។ ចំណែកឧកញ៉ាអរជូន[10] ក្នុងរឿងទុំទាវ ក៏មានអំណាចខ្លាំងក្លាហាក់ដូចជាអំណាចនៃស្តេចត្រាញ់នាសម័យបុរាណក្នុងប្រវត្តិសាស្ត្រនោះដែរ។ សមដូចជាអ្នកកវីសោមបានពណ៌នាយ៉ាងច្បាស់៖

«ឧកញ៉ាអរជូនមួនមាំពេក          ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ          កាប់ចាក់វាយដំពុំប្រណី»។

ដោយសារតែមានអំណាចបែបនេះហើយ  ដែលជាហេតុធ្វើឱ្យអរជូន  មានចិត្តប្រមាថជីវិតទុំព្រមទាំងបង្កស្ថានការណ៍រហូតទុំដោរ នាំឱ្យមានវិនាសកម្មដ៏រន្ធត់។

---

[7] បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ ដោយលោកស្រី យិន វ៉ាន់ថា

[8] វណ្ណៈអ្នកងារ(មនុស្សដែលមានទោស) ជនប្រភេទនេះគ្មានសិទ្ធិដូចពួកអ្នកព្រៃងារទេ។ គេតម្រូវឱ្យមនុស្សវណ្ណៈនេះធ្វើការថ្វាយស្តេច និងក្រុមញាតិវង្សស្តេច ឬឱ្យទៅបម្រើនៅវត្តអារាម។

[9] បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ ដោយលោកស្រី យិន វ៉ាន់ថា

[10]កវីមិនបានឱ្យយើងស្គាល់ឈ្មោះរបស់អ្នកឧកញ៉ាអរជូន ដែលចៅហ្វាយស្រុកត្បូងឃ្មុំទេ ដោយកវីប្រើតែគោរម្យ  ងារសម្រាប់ហៅ តែប៉ុណ្ណោះ។

**•ចំពោះអំណាចមេគ្រួសារ**

ខ្មែរយើងតែងតែចាត់ទុកថាការទុកដាក់កូនចៅឱ្យមានគូស្រករ គឺជាភារកិច្ចដ៏ចម្បងចំពោះ ម្ដាយឪពុក។ ចំពោះបញ្ហានេះ កូនប្រុស កូនស្រីច្រើនតែមិនសូវចុះសម្រុងជាមួយម្ដាយឪពុករហូតជំរុញឱ្យមានទំនាស់និងសោកនាដ្យកម្មគួរឱ្យរន្ធត់ទៀតផងដែរ។ ផ្ទុត់គំនិតសង្គម បានហាក់ដូចជាបានដាក់សម្ពាធមកលើផ្លូវចិត្តគ្នា យុវជនយើងនាំឱ្យកើតមានការតស៊ូជម្នះប្រឆាំងនឹងការសម្រេចចិត្តរបស់ម្ដាយឪពុក។ ប្រការនេះហើយ ជាហេតុជំរុញឱ្យម្ដាយទាវប្រើប្រាស់សិទ្ធិខ្លួនជាម្ដាយបង្ខំឱ្យទាវយល់ព្រមទទួលម៉ឺនងួនជាប្ដីដោយនាងមិនស្រឡាញ់បន្តិចសោះឡើយ។ ការប្រើសិទ្ធិអំណាចបែបនេះ ដោយគាត់គិតថាកាលណាភ្នែកគាត់មើលឃើញថាល្អគាត់ក៏បង្ខំកូន ឱ្យឃើញថាល្អដូចគាត់ដែរ។ តែគាត់មិនបានគិតថា បំណងរបស់គាត់បានធ្វើឱ្យកូនក្លាយទៅជាឧបករណ៍ចេះដកដង្ហើម ព្រោះគាត់មិនបានគិតថា កូនចិញ្ចឹមបានតែរូបរាងកាយខាងក្រៅតែប៉ុណ្ណោះ។ ដោយស្ថិតក្នុងទស្សនៈអភិរក្សបែបនេះហើយ ទើបម្ដាយទាវបានប្រកាសគំរាមនាង

ទាវ៖

«មិនដែលសោះឡើយទាវអើយនំ ច្រឡើសបើសធំម្ដេចជាងនាឡិ
កូនគោកាចកៀចដោយព្រៃវាល ពេលវាលឈឺខ្លួនជូនដល់ស្លាប់»។

សម្ដីនេះបញ្ជាក់ឱ្យឃើញថា អំណាចមេគ្រួសារតាមរយៈម្ដាយទាវ នាសង្គមសក្តិភូមិសិទ្ធិផ្ដាច់ការសេរីភាពរបស់មនុស្ស ត្រូវបានគេដកហូតអស់ហើយ សូម្បីតែសិទ្ធិក្នុងការកសាង ឬជ្រើសរើសគូស្រករក៏គ្មានដែរ។ ដោយគេចាត់ទុកមនុស្សហាក់ដូចជាសត្វធាតុដែលត្រូវទទួលទារុណកម្មរហូតដល់ស្លាប់ដរាបណាគេមិនបានបំពេញតាមបំណងម្ចាស់ឬម្ដាយឪពុក។

**ខ- មូលបញ្ហារឿង**

ឆ្លងកាត់ជីវិត ដ៏សោកសៅនៃសេចក្ដីស្នេហាទុំទាវកវីក៏បានរំលេចឱ្យឃើញកាន់តែច្បាស់អំពីបំណងរបស់តួអង្គទាំងពីរ គឺ **ការតស៊ូដើម្បីទាមទារសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ**។ ជាការពិតបើនិយាយពីក្រឹត្យក្រមនៃធម្មជាតិ ចាស់ទុំបុរាណខ្មែរ តែងចងក្រងជាពាក្យទូន្មាន ប្រៀនប្រដៅនានា «មានខ្យល់ ទើបមានរលក» ឬ«មានភ្លើង ទើបមានផ្សែង»។ យ៉ាងណាមិញចំពោះសម្ពាធនៃទំនៀមអភិរក្សនាសម័យលង្វែក មកលើផ្លូវចិត្តរបស់យុវជនយើងក៏បណ្ដាលឱ្យមានឆន្ទៈដ៏មុតស្រួចរើបម្រះចេញពីគំនាបអភិរក្សនោះ។ ដោយស្ថិតក្នុងឥរិយាបថបែបនេះហើយទើបទុំចេះតែមានការភ័យខ្លាច និងព្រួយបារម្ភថាតើស្នេហារបស់ខ្លួនចំពោះទាវជាការកំណត់ពីព្រហ្មលិខិត? ឬមួយជាស្នេហាធម្មតា ដែលតែងកើតមានសម្រាប់មនុស្សគ្រប់រូប ស្របទៅតាមច្បាប់ធម្មជាតិ?

- **កត្តាចាំបាច់នៃសេចក្ដីស្នេហាទុំទាវ**
  - **បញ្ហាព្រហ្មលិខិត ឬកម្មផល**

ប្រការនេះ បានស្ដែងឱ្យឃើញពីសកម្មភាពទុំ ដែលខ្លួនជាសាមណេរបានរៀនធម៌អាចិក្នុងសំណាក់ព្រះពុទ្ធសាសនាយ៉ាងច្បាស់លាស់ ។ ពិសេស បានស្វែងយល់ពីវាលវដ្ដសង្សារវិលកើតវិលស្លាប់ ដោយសារភាពថា ស្នេហានេះបណ្ដាលមកពីកម្ម។ ជាក់ស្ដែង មុននឹងខ្លួនជម្នះចាកសិក្ខាបទ

ដោយមិនស្តាប់តាមពាក្យទូន្មានគ្រូទុំបានថ្លែង៖

« រួចថាអញនៅមិនបានឡើយ ព្រះគុណខ្ញុំអើយហេតុតែកម្ម
ជាកាលនឹងប្រឹងទ្រទ្រាំ ម្ល៉េះសមស្លាប់ខ្លួនមួនមែនពិត។
មិនស្តាយផ្នួសប្រាណបានប៉ុនសក់ កម្មនាំកញ្ឆក់ឱ្យងងឹត
មោហ៍បាំងឆ្នាំងគ្រប់ក្រសោបរឹត គ្មានគិតគ្មានគួរលោកគ្រូខ្វាល់»។

តាមរយៈពាក្យពេចន៍ខាងលើនេះ អាចសន្និដ្ឋានថា ទុំបានផ្តេកគំនិតទាំងស្រុងទៅលើទស្សនៈកម្មផល ក្នុងទ្រឹស្តីព្រះពុទ្ធសាសនាទាំងស្រុង។ ប៉ុន្តែបើគិតទៅតាមចិត្តសាស្រ្តវិញទោះបីមានកម្ម ឬគ្មានកម្មក្តី ក៏ទុំនៅតែចាប់ចិត្តស្រឡាញ់នាងទាវបានដែរ។ ដោយហេតុថា ទុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចជា៖

« ទុំមានវោហារប្រាជ្ញាផ្សេង មានទាំងសំឡេងរូបខ្ទីល្វក់
ល្អទ្រង់អង្គកាយសាយទឹកមុខ រួចទុកនេនពេជ្រស្រេចជាប្អូន»។

គេអាចនិយាយបានថា ទុំជាយុវជនមួយរូបដែលពោរពេញទៅដោយសម្រស់និងថាមពល គ្រប់គ្រាន់ ព្រមទាំងមានមនោសញ្ចេតនាជ្រាលជ្រៅ។មនុស្សប្រភេទនេះហើយ ដែលមានសេចក្តីត្រូវការខ្ពស់ក្នុងរឿងស្នេហានេះ ខ្លាំងក្លាបំផុត ។

- តាមច្បាប់ធម្មជាតិ

តាមច្បាប់ចិត្តសាស្រ្ត កាលណាមានវ័យកំលោះក្រមុំហើយ មនុស្សរាល់រូបគេចមិនផុតពីច្បាប់ធម្មជាតិនេះឡើយ។ ពិសេសគឺមនុស្សដែលមានសុខភាពល្អ មានភាពអផ្សុក និងរវើរវាយច្រើន។ រីឯទុំក៏យ៉ាងដូច្នេះដែរ៖

« នៅវត្តប្រាកដជាអផ្សុក ជាទុក្ខគ្មានល្ហែក្នុងអង្គកាយ
ខ្ជិលណាស់ព្រះគុណមិនសប្បាយ ក្រហល់ក្រហាយខ្វល់ចង់ដើរ»។

ចំពោះទុំនៅពេលនេះ អារម្មណ៍នៃសេចក្តីត្រូវការក្នុងរឿងស្នេហា កាន់តែមានកម្រិតខ្លាំងក្លាណាស់។ ឯទាវក៏មិនខុសពីទុំដែរ គឺនាងមានវ័យក្រមុំហើយបែរជារស់នៅតែជាមួយម្តាយដែល មានវ័យចាស់ទុំ និងជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនត្រូវបង្ខាំងនៅក្នុងម្លប់តាមប្រពៃណីថែមទៀត។ កត្តាទាំងនេះជាមូលហេតុនាំឱ្យនាងកាន់តែគេចពុំផុតពីច្បាប់ធម្មជាតិនេះឡើយគឺពេលឃើញទុំក៏កើតនូវក្តីស្នេហាភ្លាម។

- **លទ្ធផលនៃសេចក្តីស្នេហាទុំទាវ**

រាល់សកម្មភាពយុវជនទុំ និងទាវពិតជាមានឆន្ទៈខ្ពស់ ខុសពីយុវជនដទៃ គឺមិនលុតជង្គង់ចំពោះមុខអំណាចផ្តាច់ការនោះឡើយ។ការតស៊ូរបស់អ្នកទាំងពីរគឺជាការតស៊ូដែលមានលក្ខណៈជាបុគ្គលក៏ពិតមែន ប៉ុន្តែវាមានលក្ខណៈស្រួចស្រាល់និងមានអត្ថន័យជ្រាលជ្រៅជាទីបំផុត។ ដូចជាទុំបានប្រឆាំងនឹងវិន័យសង្ឃ និងទំនាយគ្រូដោយហ៊ានសឹកដោយខ្លួនឯងគ្មានគ្រូឧបជ្ឈាយ៍៖

« វន្ទាវន្ទៈអ្នកកុំឃាត់ ផ្លាស់ស្បង់ចោលម៉ត់មិនស្រណោះ
រួចស្លៀកសំពត់ហូលល្អស្រស់ លើកអស់អង្សកែដាក់ទុកទើរ »។

ដោយឡែកចំពោះនាងទាវវិញ ក៏ហ៊ានជម្ទះនឹងម្ដាយ ដែលតម្រូវលើកខ្លួនឱ្យទៅម៉ឺនងួន ដោយពោលផ្ដាញ់ផ្ដាលះ

« ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ »។

លើសពីនេះទុំទាវបានរួមចិត្តរួមកាយហ៊ានប្រព្រឹត្តខុសនឹងប្រពៃណីជាតិះ

« ទុំឱបបីបមថ្នមប្រឡែង ទាំងពីរតេតក្រេងរួមមេត្រី
នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្ដី ស្រស់ស្រីស្រួលស្រេីបដោយតណ្ហា។
ទាវស្រួលទទួលព្រមចូលជិត ទុំសោតស្នេហ៍ស្និទ្ធថើបភក្ត្រា
ទាំងពីរហ៊ានស្បថប្រាកដថា ខ្ជាក់ស្លាប្ដូរគ្នារួចទាវឆ្លើយ»។

ទុំទាវហ៊ានប្រឆាំងនឹងបំណងប្រាថ្នារបស់ព្រះរាមាដោយមិនខ្លាចស្លាប់ះ

« ទុំច្រៀងរៀបរាប់ដំណាលសព្វ តាំងពីទុំធ្លាប់រួមស្នេហា
ទាវសោតក្រៀមក្រំអន់អួលផ្សា ក្ដួលក្ដៅឱរាមិនមានស្ដី »។

តែទោះជាយ៉ាងណាក៏ដោយ ក៏ការទាមទារសិទ្ធិសេរីភាពរបស់ទុំទាវ ក្នុងសង្គមផ្ដាច់ការសម័យលង្វែកគឺជាការទាមទារ ដែលមានលក្ខណៈជាបុគ្គលនៅឡើយ។ ដោយយុគសម័យនោះទុំនិងទាវនេះឯងហើយ ដែលជាយុវជនឈានមុខគេបង្អស់ មានគំនិតប្រឆាំងនឹងអ្វីៗដែលជាផ្នត់គំនិតលូនក្រាបរណោបរណបឬក៏«ពងមាន់កុំជល់នឹងថ្ម»ជាដើម។ ហេតុដូចនេះហើយ ទើបមរណភាពរបស់ទុំទាវនៅតែមានអត្ថន័យជ្រាលជ្រៅ លើកតម្លៃស្នាដៃនេះ ឱ្យកាន់តែលេចធ្លោឡើងក្នុងមជ្ឈដ្ឋានអ្នកសិក្សា។

**គ- ទំនាស់**

- **ទំនាស់ទី១ ៖ ស្នេហា និងកិត្តិយស**
  - **គូទំនាស់ ៖ ទុំទាវ >< អ្នកមានគុណ**

ជាការពិតខ្មែរយើងជាអ្នកស្រឡាញ់កិត្តិយសណាស់ ជាពិសេសគឺកិត្តិយសក្នុងការរក្សាពូជពង្សវង្សត្រកូល ព្រោះខ្មែរយល់ថា «ពូជស្វាយ ផ្លែស្វាយ ពូជក្រូច ផ្លែមកក្រូច» ហើយការទុកដាក់កូនចៅឱ្យមានគូស្រករក៏ខ្មែរយល់ថា « ធ្វើស្រែឱ្យមើលស្មៅ ទុកដាក់កូនចៅឱ្យមើលផៅសន្ដាន» ដែរ ។ ចំណែកទុំទាវបានធ្លាក់ជ្រៅទៅៗក្នុងអន្លង់ស្នេហា ជាស្នេហាដ៏បរិសុទ្ធរវាងកំលោះនិងក្រមុំ នាំទុំឱ្យហ៊ានបូជាចិត្តថ្លើមខ្លួនប្រាណព្រមទាំងកិត្តិយសដល់រូបទាវ ហេតុនេះហើយទើបទុំមិនញញើតនឹងភូតភរម្ដាយភូតភរគ្រូហើយមកលួចសឹកដើម្បីជួបទាវទាល់តែបាន។ នាងទាវដែលធ្លាប់តែគោរពម្ដាយ ដើម្បីការពារកិត្តិយសគ្រួសារនិងធ្លាប់ស្រឡាញ់ម្ដាយលើសអ្វីៗទាំងអស់ ក៏បែរមកជាបែកបាក់ប្រេះឆាទៅវិញ។ ចំពោះម្ដាយទាវដែលនិយមប្រកាន់ជំហរដាច់ខាត «នំមិនធំជាងនាឡិ» ក៏មិនព្រមយល់ចិត្តកូនស្រីខ្លួន ដោយសារគាត់ស្រឡាញ់តែអំណាច បុណ្យសក្ដិ និងទ្រព្យសម្បត្តិផងនោះធ្វើឱ្យគាត់ភ្លេចអ្វីៗទាំងអស់ គឺភ្លេចគិតទាំងមហន្តរាយ ដែល បណ្ដាលមកពីការលោភលន់នេះទៅវិញ។ លើសពីនេះទៀត គាត់ភ្លេចគិតពីជីវិតកូនស្រី គឺគិតតែពីជំរុញទាវឱ្យយកម៉ឺនងួន ដែលនាងមិនស្រឡាញ់សោះឡើយ ទោះបីពេលនាងមានប្ដីហើយក៏ដោយ។ ទំនាស់នេះ បានវាយបំបាក់ផ្នត់គំនិតមាតាខ្មែរជាច្រើនដែលធ្លាប់ប្រកាន់អាកប្បកិរិយា

របៀបម្ដាយទាវនេះ ឱ្យមានការប្រុងប្រយ័ត្ន។ ជាក់ស្ដែង ក្នុងសង្គមខ្មែរបច្ចុប្បន្ន គេនិយមរិះគន់មាតាទាំងឡាយ ដែលល្មោភទ្រព្យសម្បត្តិ និងបុណ្យសក្តិនេះតាមរយៈដាក់ងារថា«យាយផាន់»នេះទៅវិញ (យាយផាន ឈ្មោះម្ដាយទាវក្នុងរឿងទាវឯករបស់នូ កន១៩៤២)។

- **ទំនាស់ទី២ : ស្នេហា និងជីវិត**

 **•គូទំនាស់ ៖ ទុំទាវ>< ព្រះរាជា**

អ្នកនិពន្ធសូវៀត បានសរសេរថា « អ្វីដែលមានតម្លៃសំខាន់ជាងគេបំផុតសម្រាប់មនុស្ស គឺជីវិត ...»។ លោកកេងវ៉ាន់សាក់ក៏បញ្ជាក់ថា មនុស្សស្រឡាញ់ជីវិតខ្លាំងណាស់ ក្នុងស្នាដៃគុកកាមកិលេសរបស់លោកមានឃ្លាមួយនិយាយ «តែមនុស្សមិនព្រមស្លាប់សោះឡើយ អូនអើយស៊ូរស់រងវេទនាកណ្ដាលភក់ជ្រាំទ្រាំវេរាឱ្យតែការពារជីវិតបាន...»។

ជាការពិត មនុស្សណាក៏ខ្លាចស្លាប់ ហើយខំចៀសវាងសេចក្ដីស្លាប់គ្រប់ៗគ្នា តាមសមត្ថភាពរបស់ខ្លួន។ ប៉ុន្តែដើម្បីសេចក្ដីស្នេហារបស់ខ្លួនទុំទាវហ៊ានប្រឆាំងនឹងអ្វីទាំងអស់មិនខ្លាចស្លាប់។ ការប្រឆាំងរបស់ទុំទាវស្ថិតនៅលើការប្រើប្រាស់ឆន្ទៈខ្លួនជាធំ ពោលគឺកម្លាំងនៃសេចក្ដីស្នេហារបស់គេនេះតែម្ដង ដែលជំរុញឱ្យគេក្លាហាន។

ទំនាស់ខាងលើនេះបានបង្ហាញ ពីសេចក្ដីស្រេកឃ្លានសេរីភាពរបស់យុវជនយុវនារីខ្មែរ ក្រោមរបបផ្ដាច់ការសក្តិភូមិ។ សេចក្ដីស្រេកឃ្លាននេះ គឺជាការចង់បានសិទ្ធិសេរីភាពក្នុងការរស់នៅសិទ្ធិសេរីភាពក្នុងរឿងស្នេហា ឬសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ ដែលមានទំហំធំធេងជាងអាយុជីវិតទៅទៀត។ តែនៅក្រោមរបបសក្តិភូមិ គេមិនអាចសម្រេចបាននូវសិទ្ធិនេះឡើយ គឺរបបផ្ដាច់ការឃោរឃៅបានវាយបង្ក្រាបយ៉ាងព្រៃផ្សៃ ហើយបង្កើតឡើងនូវសោកនាដ្យកម្ម
រាប់មិនអស់។

- **ទំនាស់ទី ៣ : វិបត្តិអំណាចសក្តិភូមិ**

 **•គូទំនាស់ : ស្ដេចផែនដី>< ស្ដេចត្រាញ់**

កវីបានបង្ហាញវិបត្តិអំណាចសក្តិភូមិ តាមរយៈអំណាចពីរយ៉ាងដែលមានទម្រង់ខុសគ្នា តែមានខ្លឹមសារតែមួយក្នុងរបបសក្តិភូមិ គឺអំណាចស្ដេចផែនដីព្រះរាមា និងអំណាចស្ដេចត្រាញ់របស់អរជូន។ តាមពិតអំណាចអរជូន គឺជាតំណាងឱ្យអំណាចស្ដេចតែម្ដង រីឯគ្រួសាររបស់អរជូនទៀតសោតក៏ជាគ្រួសារមួយ ដែលប្រកាន់ផ្ទត់គំនិតស្ដេចដែរ។ ប្រសិនបើអរជូនមានគំនិតខុសពីស្ដេចនោះប្រហែលជាពុំបានធ្វើជាស្ដេចត្រាញ់ខេត្តត្បូងឃ្មុំឡើយ។ គំនិតរបស់អរជូននិងព្រះរាមានោះ គឺដូចគ្នាត្រង់ការពារអំណាច ការពារផលប្រយោជន៍ខ្លួនដូចៗគ្នា។ ព្រះរាជាជេរអរជូនកាត់ ទោសអរជូន មិនមែនមកពីគេមានគំនិត ឬទស្សនៈខុសគ្នានោះទេតែមកពីការប្រឆាំងនឹងដណ្ដើមផលប្រយោជន៍គ្នាតែប៉ុណ្ណោះ។

ស្ដេចបានផ្សំផ្គុំនាងទាវឱ្យទុំ ព្រោះដឹងថាគេស្រឡាញ់គ្នាទៅហើយ។ អរជូនបានធ្វើឱ្យខុសបំណងព្រះរាជា ដោយបំពានគឺមិនមែនដោយមិនដឹងខ្លួននោះទេ ព្រោះតាមពិតអរជូននេះ ឯងដែលជាអ្នកនាំនាងទាវយកទៅថ្វាយព្រះរាជា។ ដោយសារតែកំហុសនេះឯង ដែលអរជូនត្រូវវិនាសទាំងគ្រួសារ ហើយផ្ដល់នូវផលវិបាកយ៉ាងធ្ងន់ធ្ងរដល់អ្នកស្រុកត្បូងឃ្មុំថែមទៀតផង។

**ឃ- វិភាគតួអង្គ**

**-នេនទុំ** ៖ ទុំជាកូនកសិករនៅខេត្តបាភ្នំ ហើយបានបួសនៅវត្តវិហារធំ ដោយយកនេនពេជ្រជាមិត្ត ជិតស្និទ្ធិ ហើយបានលួចសឹកទៅស្រឡាញ់ទាវ។

•**គុណសម្បត្តិ** ៖ អំណោយទានពីធម្មជាតិ ដែលទុំមានគឺចេះសូត្រយ៉ាងពីរោះ និងមានប្រាជ្ញាដ៏ លើសលុបគួរជាទីពំនាក់អាស្រ័យរបស់នារី។ ក្រៅពីនេះនេនទុំមានរូបឆោមស្អាតណាស់ អ្នកណាក៏ ស្រឡាញ់ទុំនេះដែរ។ សមដូចការពិពណ៌នារបស់កវី៖

« ទុំមានវោហារប្រាជ្ញាផ្សេង មានទាំងសំឡេងរូបខ្ចីល្វក់
ល្អទ្រង់អង្គកាយសាយទឹកមុខ រួចទុកនេនពេជ្រស្រេចជាប្អូន។....
ប្រទល់ដែនដល់ខេត្តទទឹង ថ្ងៃតែងឈប់នឹងត្បិតជនជុំ
ចង់ទិញតោកនេនខ្លះគន់គុំ សម្លឹងនេនទុំសមរូបឆោម ។
ខ្លះថាអើម្ល៉េះប្រសិនណា បានអញប្រវាឱបប្រលោម
ប្រលែងតាមចិត្តគិតចង់ចោម មៀងមើលព្រឹព្រមប្រឈមឈប់។
បៀតបៃរស្នេហ៍ស្និទ្ធជិតអណ្តូង ជ្រួលច្រូងស្រើបស្រួលទីទួលម្លប់
ឈ្មោះពោធិជើងខាលត្រកាលគ្រប់ មើលសព្វស្រីប្រុសស្រុះស្រើបស្រាល»។

បន្ថែមពីរូបសម្បត្តិដ៏ប្រពៃនេះ តួអង្គទុំនៅមានលក្ខណៈពិសេសមួយទៀត ដែលយុវជននាសម័យ នោះគ្មាន គឺអាកប្បកិរិយាដែលផ្ទុយពីផ្ទត់សង្គម។ ទុំរស់នៅក្រោមឥទ្ធិពលនៃច្បាប់សង្គមអប់រំមនុស្ស ឱ្យខ្លាចញញើតឱ្យលុតក្រាបនិងឱ្យធ្វើតាមដោយមិនបាច់ពិចារណាតែទុំបែជាមិនខ្លាច មិនលុតក្រាប ហើយធ្វើអ្វីៗតាមតែឆន្ទៈរបស់ខ្លួនសុទ្ធសាធ។ ដូចជាទុំមានទឹកចិត្តស្មោះត្រង់ និងប្តូរផ្តាច់ជាមួយទាវ គឺ ជម្នះនឹងឧបសគ្គគ្រប់យ៉ាង ដែលមករារាំងស្នេហាខ្លួននោះឡើយ។ ដោយសារតែឆន្ទៈដ៏មោះមុតរបស់ទុំ បែបនេះហើយដែលជាហេតុនាំឱ្យទុំសម្រេចចិត្ត ស្រាយបញ្ហាចំពោះមុខដោយខ្លួនឯង មិនពឹងពាក់កម្លាំង ក្រៅខ្លួន។ ទុំមិនប្រើរាជសារព្រះរាជា ឬព្រះបន្ទូលព្រះអង្គឡើយ ព្រោះពេលដែលទុំមុននឹងទៅដល់ផ្ទះទាវ ទុំបានស្លៀកពាក់តាមឋានានុក្រមជាមន្ត្រីរាជវាំងម៉ឺនឯកដែរ៖

« ទុំឮពេជ្រប្រាប់ចាប់សំពត់ ហូលព្រៃទាំងផ្ទត់ទុំមើលទៅ
យល់ឈ្នួតជាហ៊ុមសូត្រពណ៌ខ្មៅ សំពត់ព្រះចៅប្រោសប្រទាន។
ទុំស្លៀកហូលចាក់ជរបីជាន់ រូបមាន់សូត្រខ្សែរសយមាសមាន
ពាក់អាវបៃតងបំណងធ្យាន ឈោងឈានបត់បែរប្រែស្រដី»។

ដូច្នេះ បើសិនជាអរជូន មានចេតនាគោរពព្រះរាជាពិតជាមិនមែនបង្កើតស្ថានការណ៍ដ៏ឃោរឃៅ បែបនេះឡើយ។ ទន្ទឹមនឹងនេះ មរណៈភាពរបស់ទុំក៏បានវែកមុខ និងបានបកអាក្រាត កេរ្តិ៍ឈ្មោះអសោចរបស់អរជូនបានគ្រប់សម័យកាល ព្រមទាំងពញ្ញាក់ស្មារតីយុវជនជំនាន់ក្រោយ ឱ្យ មើលឃើញពីភាពអយុត្តិធម៌ក្នុងសង្គមនាសម័យនោះ។

•**គុណវិបត្តិ** ៖ ដោយសារតែការងប់ងល់នឹងស្នេហាបានជំរុញឱ្យទុំបាត់បង់អស់ សម្បជញ្ញៈ វិចារណៈ និងការទទួលខុសត្រូវបណ្តោយខ្លួនទៅតាមតែចំណង់របស់ខ្លួន។ ទុំធ្លាប់តែគោរពអ្នកមានគុណ

ដែលមានលោកគ្រូឧបជ្ឈាយ៍ជាទីគោរពហើយធ្លាប់បានទទួលកោតសរសើរនូវចំណេះដឹងទេពកោសល្យពីសំណាក់អ្នកស្រុកបែរជាធ្វើឱ្យអ្នកជុំវិញខ្លួនអស់សង្ឃឹម ដោយសារខ្លួនទៅវិញគឺត្រូវបាត់បង់ជីវិតដោយសារតែស្នេហា។តាមពិតមុនពេលចាកចេញទៅ ព្រះរាជាទ្រង់រំឭកៈ

« ឯទុំបើបានបន្ទូលទៅ រួសរាន់ឱ្យត្រូវតាមសន្មត
បើវាមិនស្តាប់ឯងឆាប់បត់ វិលមកឈប់អត់ឱមើលវា»។

មានន័យថាព្រះរាជាក៏ឈឺឆ្អាល និងយកព្រះទ័យទុកដាក់ទៅលើទុំដែរ ដោយគ្រាន់តែដឹងដំណឹងនេះព្រះអង្គក្រេវក្រោធយ៉ាងខ្លាំងចំពោះអរជូនៈ

« ស្តេចទ្រង់សណ្តាប់សព្វវាចា ទ្រង់មានឱង្ការត្រាស់រួសរាន់
អាចោរអរជូនដូចពងមាន់ វាភ័ន្តហ៊ានភព្វនឹងម្លប់ពោធិ៍។
មិនដឹងខុសត្រូវស្រូវស្រងៃ អាចោរដូចឆ្កែស៊ីសាច់គោ
វាហ៊ានទទឹងទោសត្រូវស្ងោរ អញស្រាវរាវរកស្ងោរខ្ទះដែក»។

នេះគឺជាការប្រមាទមួយរបស់ទុំ ដោយយកស្រាជាឧបករណ៍មកស្រាយបញ្ហាធ្វើឱ្យស្ថានការណ៍ទុំដោររហូតមានសោកនាដ្យកម្មកើតឡើង។សមដូចកវីរៈគន់ទុំៈ

« ស្រឡាញ់ស្នាលស្និទ្ធឥតមានមោះ ទុំស្លាប់នេះខុសពីព្រោះស្រី
សម្លាញ់សង្សារនាលោកិយ លោកអើយគប្បីវេះវាងវៀរ»។

ក្រៅពីងប់ងល់នឹងស្នេហា ទុំនៅមានគុណវិបត្តិច្រើនទៀតដូចជាៈ

- ខុសវិន័យសង្ឃ ដាក់ស្នេហ៍ទាវ លួចសឹកដោយគ្មានឧបជ្ឈាយ៍

«នេនទុំទទួលគ្រឿងបរិក្ខារ ស្រេចស្រាយយកស្លាឆាន់រួចទៅ
ឈប់អង់បន្តិចសែកប្រេងម្សៅ រំលឹកដល់ទៅមុនសារិកា។
លិនថោងកវិលរំឭករក សិម្ពលីហៅយកមណីចិន្តា
លូកយកប្រទាលឆាន់នឹងស្លា សូត្រសាគ្រប់សព្វចប់តែម្តង។

..........................................................................................

វន្ទាវន្ទៈអ្នកកុំឃាត់ផ្លាស់ស្បង់ចោលម៉ត់មិនស្រណោះ រួចស្លៀកសំពត់ហូលល្អស្រស់លើកដាក់អង្ស័កដាក់ទុកទើរ»។

- យកស្រាធ្វើត្រីមុខធ្វេសប្រហែសមិនបង្ហាញរាជសាស្តេច ហើយប្រកៀកប្រអោបទាវនៅមុខភ្លៀវ

«ទុំខិតជិតជួបរូបត្រកង បីហើយថើបផងថាទាវអញ
ទាវអាងទុំប្តីឥតគិតកាញ់ ខ្លាចគេចាក់បាញ់ចាញ់នរណា។
ទាវស្តាប់សាស័ព្ទទុំស្រដី ហុចស្លាបាលីទុំស៊ីជក់
ដងស្រាឱ្យផឹកទាវមើលមុខ ឆ្អែតឆ្អល់វិតក្កខ្លាំង។

- ក្បត់ប្រពៃណី

«ទុំអោបបីបមថ្នមប្រឡែង ទាំងពីរឥតក្រែងរូបមេត្រី

នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្តី ស្រស់ស្រីស្រួលស្រើបដោយតណ្ហា»។

- **នាងទាវ :** នាងជាកូនស្រី អ្នកមេម៉ាយម្នាក់ ដែលមានទ្រព្យសម្បត្តិជាបង្គួរដែរ នៅត្បូងឃ្មុំទើនឹងពេញក្រមុំ ហើយចាប់ចិត្តស្រឡាញ់នេនទុំ តាំងពីពេលជួបគ្នាដំបូង។

- **គុណសម្បត្តិ :** ចំពោះរូបសម្បត្តិ នាងទាវមិនចាញ់ទុំឡើយ មានតែស្អាតលើសទុំផង ព្រោះនាងជានារីម្នាក់ ដែលត្រូវគេជ្រើសរើសធ្វើជាស្នំព្រះរាជា «យើងដើររកសព្វក្នុងបុរី មិនបានរូបស្រីស្រស់បវរ អាជ្ញាទាំងនោះឆ្ពោះស្មោះសរ អំណរពេកពិតឥតស្មើបាន។ ចាំគ្នាមើលមៀងផ្ទៀងអង្គកាយ អង្គីដៃនអាយកបកល្យាណ សមជាមហេសីមហាក្សត្រក្សាន្ត ស័ក្តិសមអង្គប្រាណស្រស់ប្រិមប្រិយ»។

រីឯអាកប្បកិរិយា និងផ្នត់គំនិតវិញនាងទាវក៏ដូចជាទុំដែរ គឺជាអ្នកដែលក្លាហានហ៊ានប្រឆាំងនឹងអំណាចផ្តាច់ការ គ្រប់លំដាប់ជាន់ថ្នាក់ដោយសារនាងមានភក្តីភាព ហើយស្រឡាញ់តែទុំម្នាក់ប៉ុណ្ណោះ។ ក្នុងពេលគេចាប់ទុំ នាងទាវខិតខំអង្វរះ

« ទាវឮអង្វរគេទៅថា សូមលោកករុណាមេត្តាទៅ
ចងទុំលោកកុំចងនឹងផ្តៅ ចងនឹងឈ្នួតខ្មៅប្រោសប្រទាន»។

ទោះបីម៉ឺនងួនជាកូនចៅហ្វាយខេត្ត មានទ្រព្យមានអំណាចយ៉ាងណាក៏ដោយ ក៏នាងមិនព្រមស្រឡាញ់ដែរ។ នៅចំពោះមុខមរណភាពដ៏ខ្លោចផ្សារបស់ទុំ នាងទាវពិតជាមិនអាចមកភ្លើតភ្លើន ឬត្រេកត្រអាលនឹងពិធីអាពាហ៍ពិពាហ៍ជាមួយម៉ឺនងួនបានឡើយ។ ជាពិសេសគឺម៉ឺនងួននេះហើយ ដែលជាឃាតករសម្លាប់ប្តីរបស់នាង។ គេអាចសួរថា តើមាននារីខ្មែរប៉ុន្មាននាក់ ដែលសុខចិត្តរៀបការជាមួយឃាតកសម្លាប់ប្តីខ្លួន ចំពោះមុខយ៉ាងដូច្នេះ? ប្រសិនជានាងទ្រាំសិន ចាំរកឱកាសសងសឹកជាក្រោយនោះ តើនាងអាចធ្វើការសងសឹកបានដែរ ឬទេ? ជាការពិត បើសិនជានាងប្រព្រឹត្តអំពើបែបនេះមែន នាងរឹតតែមិនអាចធ្វើបានទេ។ បើសិនជានាងទ្រាំរៀបការជា មួយម៉ឺនងួន នាងនឹងបាត់បង់ភក្តីភាពជាលើកទីមួយ ហើយបើនាងសម្លាប់ម៉ឺនងួន នាងនឹងមានឈ្មោះអាក្រក់ជាលើកទីពីរទៀត គឺជាឃាតកសម្លាប់ប្តីឯង។ ប្រការទាំងពីរនេះ វាអាក្រក់បំផុតចំពោះស្ត្រីខ្មែរ និងផ្នត់គំនិតនាសម័យនោះ ដែលតម្រូវឱ្យស្ត្រីរក្សាភក្តីភាព គឺទាំងខ្លឹមកាយ និងទាំងខ្លឹមចិត្តចំពោះស្វាមីខ្លួន។ ហេតុដូចនេះហើយបានជានាងះ

« ទាវប្រះប្របប្តីដៃប្រវា បានកាំបិតស្លាអាផៀងផិត
ត្រូវដាច់បំពង់កក្ស័យពិត កៀកកិតកើយគងទំនងជុំ»។

ដូចច្នេះអត្តឃាតកម្មរបស់ទាវវាមានលក្ខណៈសមស្របបើផ្អែកទៅតាមសម័យកាលដែលនាងកំពុងរស់នៅនោះ។ អត្តឃាត្តកម្មនេះ បានរក្សាភក្តីភាពរបស់នាងរហូតសព្វថ្ងៃ គឺបានបកអាក្រាតអំណាចផ្តាច់ការក្នុងសម័យកាលនោះ ព្រមទាំងបានកាត់បន្ថយនូវភាពមានះ និងសេចក្តីលោភលន់អំណាចបុណ្យសក្តិទ្រព្យសម្បត្តិរបស់មាតាខ្មែរមួយចំនួនធំ ដែលតែងតែមានផ្នត់គំនិត
ដូចម្តាយទាវ។

តែយើងមានសុទិដ្ឋិនិយមថា សម័យកាលថ្មីនេះ ទស្សនៈនារីខ្មែរពិតជាថ្មីជឿនលឿនជាងនាងទាវមួយកម្រិតថែមទៀត ហើយនិងឈានទៅរកអ្វីដែលប្រាកដនិយម ដែលមានតម្លៃចំពោះសង្គមជាតិ និង

សុភមង្គលរបស់ខ្លួនសមស្របតាមសីលធម៌សង្គមថែមទៀតផង។

• **គុណវិបត្តិ** ៖ ដោយមានចិត្តស្រឡាញ់ដ៏លើសលុបចំពោះទុំ នាងទាវភ្លេចគិតដល់ម្ដាយ នាងហ៊ានប្រព្រឹត្តដែលអំពើប្រាសចាកពីប្រពៃណីជាតិ៖

« ទាវស្រួលទទួលព្រមចូលជិត ទុំសោតស្នេហ៍ស្និទ្ធថើបភក្ត្រា
ទាំងពីរហ៊ានស្បថប្រាកដថា ខ្ជាក់ស្លាប្ដូរគ្នារួចទាវឆ្លើយ។
អ្នកថ្លៃប្អូនអើយក្រែងអ្នកបង បានរួមស្នេហ៍ស្នងនៅកៀកកើយ
ចេញចាកចោលប្អូនទេដឹងអើយ អ្នកអើយអាសូរចិត្តប្អូនរ៉ា»។

មួយវិញទៀត ព្រះពុទ្ធទ្រង់សម្ដែងធម៌អប់រំចិត្តដល់ពុទ្ធបរិស័ទឱ្យចេះរស់ក្នុងតម្លៃជាកុសលមិនគប្បីប្រមាថដែលមនុស្សគ្រប់រូបត្រូវពិចារណា។ ជាមួយនឹងបញ្ហាអត្តឃាតកម្មនេះ គេយល់ថា វាមានលក្ខណៈទាល់ច្រកខ្វះការពិចារណាការតស៊ូ ព្រោះជីវិតនាងទាវពិតជាមានតម្លៃលើសអ្វីៗទាំងអស់។ ដោយសារតែនាង ជានារីដែលព្រះរាជាសព្វព្រះទ័យ ស្រឡាញ់រាប់អាន ហើយទុំដែលជាប្ដីនាងក៏ព្រះអង្គសព្វព្រះទ័យដែរ។ ម្យ៉ាងទៀតក្នុងពេលនោះ នាងក៏នៅមានពេជ្រម្នាក់ទៀត ដែលនាងជឿជាក់ថា អាចប្រាស្រ័យជួយស្រាយបញ្ហានៅពេលនោះបានដែរ។ ដូច្នេះបើ នាងរស់នៅនាងក៏អាចសងសឹកជូន ទុំជាប្ដីនាងបានដែរ ហើយអាចជួយសម្រាលទោសដល់ម្ដាយនាងបានទៀតផង។

- **ម្ដាយទាវ ៖**

ជាស្ត្រីមេម៉ាយដ៏ស្ដុកស្ដម្ភម្នាក់រស់នៅត្បូងឃ្មុំ ហើយមានកូនស្រីម្នាក់ គឺនាងទាវ ។

• **គុណសម្បត្តិ ៖**

« នាងនោះមានម្ដាយមេម៉ាយសោះ ប៉ុន្តែរបស់តាមទំនើង
មែនបានបាវព្រាវប្រើលាងជើង ចុំថ្កើងគ្រប់សព្វចប់ដល់ចាស់»។

គាត់អាចជាអ្នកគ្រប់គ្រងមរតកដីធ្លី បន្តពីប្ដីគាត់ដែលជាជនសក្តិភូមិម្នាក់[11] ទើបគាត់មានអ្នកបម្រើមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ហើយមានជីវភាពរុងរឿង ព្រមទាំងមានឥទ្ធិពលគ្រាន់បើម្នាក់ដែរនៅក្នុងស្រុកនាពេលនោះ។

ម្ដាយទាវក៏ដូចម្ដាយរាល់រូប តែងតែខិតខំចិញ្ចឹមបីបាច់ថែរក្សាកូនអប់រំកូននិងស្វែងរកអនាគតថ្កើងថ្កានឱ្យកូន។ គាត់ស្រឡាញ់នាងទាវដ៏លើសលុបថ្នមទាំងចិត្តថ្នមទាំងកាយ។ តួ យ៉ាងគ្រាន់តែឮកូនប្រាប់ថាចង់ស្ដាប់នេនទុំសូត នាងជាម្ដាយក៏ប្រញាប់ទៅនិមន្តនេនទុំ បំពេញតាមបំណងកូនស្រីភ្លាម៖

« នាងជាម្ដាយទាវផ្ទៀងស្ដែងស្ដាប់ ឮទាវកូនប្រាប់ឆ្លើយថាអើ
លូកដៃយកស្បៃដណ្ដប់ដើរ ញាំងញើផ្ទងឈ្នងទំនងចាស់»។

មិនតែប៉ុណ្ណោះ គាត់បានសម្ដែងសេចក្ដីរីករាយជាពន់ពេក នៅពេលដែលអរជូនចូលដណ្ដឹងកូនស្រីខ្លួនឱ្យទៅម៉ឺនងួនគាត់មិនបានសម្រេចភ្លាមទេ គាត់ទៅសួរកូនគាត់ជាមុន៖

«គួរហើយខ្ញុំសុំជម្រាបញាតិ ទៅសំពះបាទលោកប្រុសស្រីថា បើលោកចង់ចងមេត្រីគប្បីចាំខ្ញុំលបសួរកូន»។ រួចមកគាត់បានសួរទៅកូនដោយក្ដីរំភើបថា៖

[11] បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ ដោយលោកស្រី យិន រ៉ាន់ថា

« ហើយសួរទៅកូនថាមាសម្ដាយ សមយើងសប្បាយថ្លារីកមុខ
ម្ដាយឱ្យទៅកូនចៅហ្វាយស្រុក បានសុខដោយបុណ្យដោយបានថ្កើង»។

ពេលដឹងថា កូនត្រូវចូលវាំងធ្វើជាស្នំព្រះរាជាគាត់ក៏រីករាយ ហើយបានឱ្យគេរៀបចំតុបតែងកូនយកទៅថ្វាយស្ដេចៈ

« កាលនោះម្ដាយទាវគិតជំនុំ នឹងអស់ចាស់ទុំថាឥឡូវ
យើងស្អាងទាវកូនឱ្យត្រឹមត្រូវ រួចចរចុះទៅទូកម្នីម្នា»។

ទន្ទឹមនឹងព្រហ្មវិហាររបស់ម្ដាយខាងលើនេះ នាងជាម្ដាយទាវក៏កើតក្ដីឈឺចាប់ នៅនឹងមុខព្រោះតែកូនមិនបានបំពេញភាពកតញ្ញូដល់ខ្លួនវិញឡើយ គឺទាវយល់ព្រមទទួលទុំជាប្ដីដែលធ្វើឱ្យគាត់មានក្ដីឈឺចាប់យ៉ាងខ្លាំងៈ

« ថ្លែងពីម្ដាយទាវវិលដល់ស្រុក វិតក្កព្រួយប្រាណពុំបានស្បើយ
ថាឱទាវថ្លៃកែវកូនអើយ ម្ដេចឡើយមកបានប្ដីកម្សត់ »។

• **គុណវិបត្តិ** : ប៉ុន្តែគាត់បែរជាមានកំហុសយ៉ាងច្រើនទៅវិញ ព្រោះនៅទីបញ្ចប់គាត់មានកំហុសមួយយ៉ាងធ្ងន់ធ្ងរបំផុតគឺគាត់បង្កឱ្យមានមរណភាពរបស់ទុំទាវ។គាត់មានចេតនាបំបែកទាវពីទុំយកមករៀបការជាមួយ ម៉ឺនងួនដោយប្រើកលល្បិចៈ

« ទាវកូនឱ្យវិលមកប្រញាប់ ពាក្យពេចន៍សាសព្ទថាម្ដាយនៅ
ឯនាយឈឺធ្ងន់គ្រុនចុកក្ដៅ ផ្ដាំមកកូនចៅសាច់សន្ដាន។
វិលឆាប់ទើបទាន់ម្ដាយផ្ដែផ្ដាំ រង់ចាំរឹតខ្លាំងភាំងប្រមាណ
កម្លាំងតិចណាស់ខ្វះក្នុងប្រាណ ម្ល៉េះខានឃើញមុខជាទុក្ខធ្ងន់»។

មិនតែប៉ុណ្ណោះ ដោយសារតែលោភៈ ទោសៈ មោហៈ គាត់ហ៊ានពន្យុះអរជូនជាចៅហ្វាយស្រុកសម្លាប់ទុំៈ

« នាងម្ដាយទាវទប់ឈប់មិនបាន មោហ៌មកបាំងប្រាណឱ្យងងឹត
ទោសាទោសៈមកបាំងបិទ មិនគិតមិនគន់ធន់មិនឈ្នះ។
ស្រែកថាអរជូនខ្លួនមានបុណ្យ មិនគិតកែកុនឆាប់រហ័ស
ចាប់អាទុំចោរចិត្តមានះ ទាញពីលើផ្ទះទម្លាក់ទៅ។
ហៅអស់ពួកក្រុមនាំវាឆាប់ ចាក់បាញ់សម្លាប់កុំឱ្យនៅ
ធ្ងន់ផ្ទះធ្ងន់ដីអប្រិយត្រូវ កើតកេរ្ដិ៍អាស្រូវឥឡូវហើយ»។
.............................................
ឃើញអញមានទ្រព្យផ្គាប់តម្រូវ ថាដូចបង្វចពូជមាយា
មារយាទកញ្ច្រាស់ច្បាស់ជាក់ជា បញ្ចូលអ្នកងារទាំងវាឯង»។

ចំពោះមរណភាពរបស់ទាវវិញនាងជាម្ដាយ ពិតជាមិនដាច់ចិត្តឱ្យកូនស្លាប់ទេតែទាវស្លាប់ដោយសារការយល់ខុស និងសេចក្ដីលោភលន់មានះរបស់គាត់។ ពិសេសគឺដោយសារតែផ្នត់គំនិតចាស់គំរិលដែលទទួលការអប់រំ បែបសម័យកាលតែប៉ុណ្ណោះ។ លើសពីនេះទៀត គាត់មិននឹកស្មានដល់ថា នាង

ទាវមានចរិតរឹងរូសមិនព្រមស្តាប់បង្គាប់គាត់នោះឡើយ។

ដូច្នេះ មរណភាពទុំទាវ គឺបណ្តាលមកពីការដែលគាត់មិនយល់ហេតុ ការណ៍ដែលនឹងកើតមានឡើង ពិសេសគឺមកពីផ្ទត់គំនិតទាំងសងខាង មានលក្ខណៈផ្ទុយគ្នាទាំងស្រុង។ ហេតុនេះហើយ ទើបមុនពេលស្លាប់ទុំស្រែកៈ

« នៅចុះណ៎ានួនស្ងួនសម្លាញ់ គេចាក់គេបាញ់បងស្លាប់សូន្យ
ស្លាប់គឺគាត់ម្តាយកម្ជាយកូន ឱ្យសូន្យបាត់ឈ្មោះមិនរស់នៅ»។

**-អរជូន** : តាមការរៀបរាប់របស់កវីបានឱ្យដឹងថា ឧកញ៉ាអរជូនជាអ្នកមានមានទ្រព្យស្តុកស្តម្ភម្នាក់ និងជាអ្នកមានអំណាចត្រួតត្រានៅខេត្តត្បូងឃ្មុំ ដែល ហៅថាស្តេចត្រាញ់។

• **គុណសម្បត្តិ** : ជាប្តីដ៏ល្អដោយចេះពិចារណា និងពិភាក្សាជាមួយប្រពន្ធ ក្នុងការសម្រេចរកគូស្រករឱ្យកូនៈ

« បងឮអស់រាស្ត្រប្រជាជាក់ និយាយមិនលាក់ដូចមាំមួន
ប្រាយប្រាប់ដោយស័ព្ទសក្តិសមសួន កូនគេផងខ្លួនដូចងួនយើង»។

ក្នុងគ្រួសារអរជូនពិតជាបានបំពេញកាតព្វកិច្ចជាប្តី និងជាឪពុកដ៏ល្អក្នុងការស្វែងរកសុភមង្គលដល់គ្រួសារ។

• **គុណវិបត្តិ** : គ្រប់ការបង្ហាញរបស់កវីយើង អរជូនគឺតំណាងឱ្យអ្នកកាន់អំណាចសក្តិភូមិផ្តាច់ការមួយយ៉ាងពិតប្រាកដនៅសម័យនោះដែលតែងតែប្រើអំណាចធ្វើបាបអ្នកទន់ខ្សោយៈ

« ឧកញ៉ាអរជូនមួនមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី»។

អំណាចនេះធ្វើឱ្យគាត់អាចធ្វើអ្វីៗគ្រប់យ៉ាង ដោយមិនគិតពីក្តីវិនាសចំពោះមុខឡើយ។ សមដូចជាក្នុងដំណើររឿងបានឱ្យឃើញថា អរជូនហាក់ដូចជាគ្មានគោលជំហរអ្វីជាក់លាក់សោះឡើយ។ ក្នុងនាមជាចៅហ្វាយខេត្តបែរជាធ្វើតាមការអូលទាញ និងធ្វើតាមបញ្ជារបស់ម្តាយទាវ ដូចដំណើររឿងបានពោលថាៈ

« ក្តៅណាស់ចៅហ្វាយនឹងអាទុំ នាំឱ្យអាប់ឱនកេរ្តិ៍មេបា
ព្រហើនមិនមានខ្លាចនរណា ឥឡូវខ្ញុំថាសូមចៅហ្វាយ»។

ប៉ុន្តែនៅពេលដែលនាំនាងទាវយកទៅថ្វាយព្រះរាជា ហើយព្រះរាជារៀបការឱ្យទុំនិងទាវក៏គាត់មិនខឹងសម្បារ ឬសោកស្តាយអ្វីឡើយ។ ផ្ទុយទៅវិញ នៅពេលដែលម្តាយទាវបញ្ចុះបញ្ចូល គាត់ឱ្យបញ្ឆោតទាវយកមករៀបការជាមួយម៉ឺនងួនគាត់បែរជាអនុវត្តតាម។ ម្យ៉ាងទៀត គាត់បានក្លាយជាអ្នកដៃដល់ក្នុងការសម្លាប់ទុំនេះគឺៈ

« ទុក្ខម្នោទោម្នេញខ្នាញ់ឆុះឆាវ កន្ទ្រាក់បានដាវស្ទុះចូលជុំ
ចូលចាប់ចាក់កាប់ឥតជំនុំ ចងទុំក្រញើតស្លឹតស្លាបសេក»។

ដូច្នេះអរជូនក៏ដូចជាអ្នកកាន់អំណាច គ្រប់រូបក្នុងសម័យនោះដែរ គឺសុទ្ធតែមានមោទនភាពលើខ្លួនឯង។ ការភ្លើតភ្លើននឹងអំណាចបែបនេះ ដែលជាប្រការជំរុញឱ្យគេតែងតែអនុវត្តទាំងងងឹតងងុល តាម

ការញុះញង់ពីមនុស្សក្នុងការបញ្ចើចបញ្ចើលើកជើង ឬបញ្ចោរគេ។

- **ម៉ឺនងួន** : ជាកូនប្រុសតែមួយរបស់ អរជូន ។

+ **គុណសម្បត្តិ** : ក្នុងដំណើររឿងបានបង្ហាញថា ម៉ឺនងួនជាកំលោះមួយរូប ដែលមានភាពកតញ្ញូចំពោះម្តាយឪពុក។ ទោះបីម៉ឺនងួនជាកូនអ្នកមានអំណាចជាងគេក្នុងស្រុកក៏ពិតមែន ប៉ុន្តែកវីមិនបានបង្ហាញពីសកម្មភាពខិលខូច ឬព្រហើនកោងកាចរបស់គេ ចំពោះបុគ្គលណាមួយ
ឡើយ។ រីឯសេចក្តីស្នេហាវិញ ម៉ឺនងួនចាប់ចិត្តស្រឡាញ់ទាវ តែគេមិនបានប្រើឥរិយាបថណាមួយមិនល្អទៅលើទាវឡើយ គឺអរជូនជាឪពុកខ្លួនបានចាត់ឱ្យអ្នកផ្លូវថៅមហាចូលថែចូវស្ដីដណ្តឹងនាងទាវតាមប្រពៃណី។ លុះមានការយល់ព្រមពីម្តាយទាវហើយ ទើបម៉ឺនងួនហ៊ានមកជួបទាវនិយាយលួងលោមៈ

«...សរសើរគេថាហៃប្អូនស្ងួន នាងនួនល្អដាច់ស្រេចផែនដី។
ប្រសិនស្ងួនព្រមល្មមចិន្តា បងថ្មមកនិដ្ឋារួមមេត្រី
មិនឱ្យមានមួយជាពីរបី បងថ្មមប្អូនស្រីកែវចរណៃ»។

មិនតែប៉ុណ្ណោះ ម៉ឺនងួនឧស្សាហ៍ទៅផ្ទះទាវញឹកញាប់ក្នុងភាពថ្លៃថ្នូរ ដើម្បីបង្កើនការយល់ចិត្តគ្នាអនាគតជាប្តីប្រពន្ធ។ ដូច្នេះម៉ឺនងួន ពិតជាមានសេចក្តីស្មោះស្ម័គ្រចំពោះនាងទាវប្រាកដមែន។

+**គុណវិបត្តិ** : ប៉ុន្តែអ្វីសំខាន់នៅពេលនេះ ភក្តីភាពរបស់ម៉ឺនងួននោះធ្វើឱ្យម៉ឺនងួន មើលមិនឃើញពីកំហុសទាវដែលលួចរួមរ័ក្សនឹងទុំ ទើបធ្វើឱ្យយម៉ឺនងួនបរាជ័យទៅវិញ។ គ្រោះថ្នាក់បំផុតសម្រាប់ម៉ឺនងួន គឺខ្លួនមិនយកចិត្តទាវមិនបាន ព្រោះនាងមិនដែលស្រឡាញ់ខ្លួនម្តងណាឡើយៈ

« គ្រាក្រោយថ្លាថ្លែងពីម៉ឺនងួន កូនលោកអរជូនមានមាសប្រាក់
យកមកផ្គាប់ផ្គុនទាវវរលក្ខណ៍ ប្រមាណទាវស្ម័គ្រស្មោះនឹងខ្លួន។
មិនដឹងកលកិច្ចគេឧបាយ ទាវមានសហាយទេម៉ឺនងួន...»។

ការដែលម៉ឺនងួន ប្រឡងចាញ់ទុំក្នុងរឿងស្នេហានេះ មិនមែនមកពីម៉ឺនងួនគ្មាន សម្រស់ឬគ្មានទ្រព្យសម្បត្តិនោះទេ តែបណ្តាលមកពីនាងទាវពុំចាប់ចិត្តស្រឡាញ់។ ដំណើររឿងបានបង្ហាញថា ម៉ឺនងួនក៏មិនខុសពីអរជូនដែរ គឺជាមនុស្សងងឹតងងល់ដែលធ្វើអ្វីៗ តាមការអូសទាញពីអ្នកដទៃ គ្មានវិចារណញ្ញាណ។ យ៉ាងនេះហើយ ទើបម៉ឺនងួនខ្សល់ព្រមការជាមួយប្រពន្ធគេ ដោយគ្មានជំទាស់ដែរ។

- **ព្រះរាជា** : តាមដំណើររឿងទ្រង់មានព្រះនាមរាមាជាស្តេចសោយរាជ្យនៅក្រុងលង្វែក។

+ **គុណសម្បត្តិ** : ជាក្សត្រមួយអង្គ គ្រប់គ្រងនគរនាសម័យលង្វែក។ ព្រះអង្គសព្វទ័យ និងឱ្យតម្លៃទៅលើវិស័យសិល្បៈ។ ដូចជាក្រោយពីបានដឹងថាទុំនិងពេជ្រជាសិល្បៈករដ៏ចំណាន ដោយទុំចេះខាងស្មូត ពេជ្រចេះខាងផ្លុំប៉ីៈ

« ស្តេចត្រាស់បង្គាប់ឱ្យទៅយក ទុំនិងពេជ្រមកថ្វាយក្សត្រា
ចាត់រាជបម្រើតាមរាជការ ដោយព្រះចិន្តាទ្រង់ប្រញាប់»។

មួយវិញទៀតទោះបីទ្រង់ជាស្តេចផែនដី ដែលតែងតែមានអំណាចអាចប្រមូលយកស្រីស្អាតដូចជាទាវធ្វើស្នំក៏ដោយ ក៏ទ្រង់សព្វព្រះទ័យប្រគល់ទាវទៅឱ្យទុំវិញតាមទសពិធរាជធម៌របស់ព្រះមហាក្សត្រ ក្រោយពីទ្រង់បានឆ្ងេងយល់ថា ទុំទាវជាសង្សារនឹងគ្នាតាមចម្លើយសារភាព។

ដូចឃ្លាកាព្យ៖

« ទ្រង់ធម៌បើអញយកទោសវា សមនឹងឃ្លាតឃ្លាសង្សារសត្វ
ព្រះធម៌មេត្តានឹងបង់បាត់ គួរផាត់ទាត់ចោលចេញទើបជា។
មានព្រះតម្រាស់ប្រាប់មន្ត្រី ឱ្យយកទាវស្រីមកសួរវា
បើឆ្លើយទៅហើយត្រូវពាក្យគ្នា យើងលើកលែងវាតាមចម្លើយ» ។

មានន័យថា ទ្រង់បានទុកឱកាសដល់អ្នកទាំងពីរនិយាយការពិតរហូតពួកគេបានសារភាពដោយផ្ទាល់មាត់ថា៖

«ករុណាសម្លាប់តាមទោសធំ ទុករស់ជាខ្ញុំព្រះបារមី
ទូលបង្គំជាខ្ញុំនឹងលាក់ថ្វី ឯនាងទាវស្រីសង្សារពិត។
...ទាវទូលទៅអង្គព្រះចក្រី បពិត្រនរបតីសូមមេត្តា
ខ្ញុំនិងទុំពិតទៀងសត្យា ដូចព្រះករុណាទ្រង់ជ្រាបស្រាប់»។

នៅទីបំផុតព្រះអង្គ ក៏សម្រេចព្រះទ័យឱ្យអ្នកទាំងពីរបានរៀបការ ជាប្ដីប្រពន្ធស្របតាមបំណងរបស់ពួកគេ។

+ **គុណវិបត្តិ** : ទោះជាយ៉ាងណាក៏ដោយក៏ទ្រង់ចៀសមិនផុតពីវិបត្តិទោះចេតនាក្ដី អចេតនាក្ដី។ ដោយហេតុថា ព្រះអង្គលើកតម្កើងខ្លួនឯងហួសឆ្ងាយបំផុតពីប្រជារាស្ត្រ។ ដូច្នេះហើយ ទើបស្ដេចតែងតម្រូវថា អ្វីៗដែលខ្ពស់បំផុត គឺសម្រាប់តែបុគ្គលអង្គឯង។ ទស្សនៈបែបនេះបានជំរុញឱ្យទ្រង់ក្លាយទៅជាបុគ្គលអាជ្ញានិយម ក្នុងការគ្រប់គ្រងទៅវិញ។ ព្រះអង្គជាអ្នកប្រើអំណាចផ្ដាច់ការហើយការកាត់ទោសរបស់ព្រះអង្គ ពុំមានសុភវិនិច្ឆ័យទេជាការកាត់ទោសតាមរយៈកំហឹងបុគ្គល។ ចំពោះអរជូន ម៉ឺនងួន ម្ដាយទាវជាអ្នកមានកំហុសជាការត្រឹមត្រូវ តែទោសនេះមិនគួរបានធ្វើបន្តទៅលើប្រជារាស្ត្រត្បូងឃ្មុំទាំងមូលថែមទៀតនោះឡើយ។

ចំពោះមរណភាពរបស់ទុំ ព្រះអង្គក៏រួមចំណែកខុសដែរ។ កំហុសនោះគឺស្ថិតនៅត្រង់ព្រះអង្គយល់តែអំណាចទ្រង់ តែមិនបានយល់ពីអំណាចរបស់អរជូន ដែលជាតំណាងឱ្យទ្រង់នៅខេត្តត្បូងឃ្មុំនោះទេ។ មានន័យថាអំណាចរបស់ព្រះអង្គមួយនគរ រីឯអំណាចអរជូនក៏មួយខេត្តដែរ។ ដូច្នេះការដែលព្រះអង្គបញ្ជាឱ្យទុំ និងពេជ្រយកព្រះរាជសារ ទៅឃាត់ដំណើរការអាពាហ៍ពិពាហ៍ម៉ឺនងួននោះគឺប្រៀបដូចជាបញ្ជូនមនុស្សឱ្យចូលរូងខ្លាយ៉ាងនោះដែរ។ បើសិនជាព្រះអង្គចង់ជួយទុំ គួរតែទ្រង់យល់ថា អរជូនហ៊ានរៀបការកូន ជាមួយនាងទាវ ដែលជាប្រពន្ធពេញច្បាប់របស់ទុំនោះ អរជូនពិតជាហ៊ានសម្លាប់ទុំដោយមិនញញើតដៃឡើយ។ យ៉ាងនេះហើយ ទ្រង់គួរតែបញ្ជូនទ័ពឱ្យទៅជាមួយទុំ មិនគួរបណ្ដោយទុំឱ្យទៅតែម្នាក់ឯងនោះឡើយ។

- **ពេជ្រ** : ជាមិត្តស្និទ្ធស្នាល និងស្មោះត្រង់របស់ទុំដូចជាបងប្អូនបង្កើត។

+ **គុណសម្បត្តិ** : ពោរពេញទៅដោយភាពស្មោះត្រង់ចំពោះទុំ គ្រប់ស្ថានភាពដ៏លំបាក។ តួយ៉ាងមុនពេលទុំនិមន្តទៅស្ទូតផ្ទះទាវពេជ្របានផ្ដាំ៖

« ថាដើរមានប្អូនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ

បើដើរទៅក្ដីបាសកសោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ»។

នៅពេលឃើញទុំមានការឈឺចាប់ពេកពេជ្ររំឭកទុំ៖

« ពេជ្រប្រាប់ថាទុំកុំយំសោក ចូរបងប្រឹងក្រោកខំកំឡា

ស្លៀកពាក់ប្រដាប់អង្គអាត្មា ឆាប់ណាអ្នកណាកុំអង់នៅ»។

ជាងនេះទៅទៀតក្នុងកាលៈទេសៈពោរពេញទៅដោយគ្រោះថ្នាក់ពេជ្រក៏បានយកដំណឹង មក ថ្វាយព្រះរាជា៖

« ក្រោមល្អងធូលីទីទុក្ខា អរជូនប្រហារជីវិតទុំ

តាមទ្រង់ប្រណីភ័យបារម្ភ ប្រោសសុំជីវិតបិតតតទៅ»។

+ **គុណវិបត្តិ** : ដោយស្រឡាញ់ទុំខ្លាំងពេក ទើបពេជ្រភ្លេចករណីយកិច្ចជាមិត្តភក្តិ ដែលត្រូវចេះជួយរំឭកជាសតឿនទុំ នៅពេលទុំប្រព្រឹត្តខុសពេជ្របែរជាបណ្ដោយនិងជួយទុំគ្រប់ពេលដែលទុំប្រព្រឹត្តអំពើពុំគប្បី។ ដូចជាករណីទុំបានកុហកគ្រូសឹក ដើម្បីត្រឡប់ទៅជួបទាវវិញនិងការនាំទុំលួចសឹកដោយខ្លួនឯង ជាពិសេសទុកឱកាសឱ្យទុំលួចទៅរួមរក្សជាមួយទាវខុសប្រពៃណី។ កំហុសមួយទៀតរបស់ពេជ្រគឺពេលនាំព្រះរាជសារមកដល់នៅចំពោះស្ថានការណ៍កំពុងតែដុនដាបពេជ្រ មិនបានផ្លាស់ប្ដូរយោបល់រកវិធានការ ដើម្បីទប់ទល់ជាមួយអរជូនទេ តែបែរជាបណ្ដែតបណ្ដោយឱ្យទុំផឹកស្រាស្រវឹងបាត់បង់ម្ចាស់ការរហូតមិនបានបង្ហាញរាជសាររបស់ព្រះរាជាដល់អជូនត្រូវបក្សពួកអរជូនចាប់ យកទៅសម្លាប់យ៉ាងអណោចអធម៌។

- **នាងនោ** : ជាអ្នកបម្រើទាវដែលមានចិត្តស្មោះត្រង់បំផុត។

+ **គុណសម្បត្តិ: នៅ**ពេលឃើញទុំជាលើកដំបូង នាងនោះ

« ឈរទ្រឹងរឹងខ្លួនពួនចាំស្ដាប់ ពីរោះហាក់ផ្កាប់មុខដល់ដី

ស្រងេះស្រងោចស្រងល់ស្រី នោទឹកបេតីមិនស្ដីសោះ»។

មានន័យថា នាងក៏ស្រឡាញ់ទុំណាស់ដែរ តែដោយភាពស្មោះត្រង់គោរពទាវនិងយល់ពីស្ថានភាពរបស់នាងផង នាងក៏សុខចិត្តលាក់ទុកក្នុងចិត្តខ្លួននូវក្ដីស្រឡាញ់នេះ ហើយក៏ផ្ទេរនៃក្ដីស្រឡាញ់នេះទៅឱ្យនាងទាវវិញ។

+ **គុណវិបត្តិ** : តែនាងនោក៏មិនខុសពីពេជ្រដែរសុទ្ធតែជាអ្នកស្រឡាញ់មិត្តមិនចេះអប់រំមិត្ត។ នាងបានចូលរួមបិទបាំងកំហុសទាវ ដែលប្រព្រឹត្តខុសប្រពៃណីជាតិជាមួយទុំ មិនឱ្យម្ដាយទាវបានដឹង។ នៅទីបំផុតនាងនោក៏បានសម្លាប់ខ្លួនតាមទាវ និងទុំដោយគ្មានស្ដាយស្រណោះអាយុជីវិតខ្លួនឡើយ។ នាងនោសម្រេចចិត្តសម្លាប់ខ្លួនបែបនេះ ព្រោះចិត្តនាងនោបានដក់ទៅលើអ្នកទាំងពីរយ៉ាងខ្លាំង។ ទុំនាងក៏ស្រឡាញ់ហើយទាវ នាងក៏ស្រឡាញ់ បើសិនជាគ្មានអ្នកទាំងពីរនេះទេនាងពិតជាមិនអាចរស់នៅបានឡើយ។ តាមពិតនាងក៏គួរតែគិតពីស្ថានភាព ឬអាចជំនុំជាមួយពេជ្រគឺរកផ្លូវដោះស្រាយនោះទើបជាការប្រសើរ។

**ង.ឧត្តមគតិរឿង**

ស្ថិតក្នុងពេលមួយ ដែលឃើញប្រជាជនកំពុងតែលិចលង់ក្នុងទស្សនៈ សំដំសុខនិយម

ដូចជា«ចូលស្ទឹងតាមបទ» ឬ«ពងមាន់កុំជល់នឹងថ្ម»អ្នកនិពន្ធមានបំណង ឱ្យខ្មែរពិសេសយុវជនហ៊ាន ប្រឆាំងនឹងអ្វីៗដែលរាំងស្ទះដល់ដល់ការប្រើប្រាស់សិទ្ធិសេរីភាពដើម្បីស្វែងរកសុភមង្គលរបស់ប្រជាជន។ ពោល គឺត្រូវតែហ៊ានកែប្រែលុបបំបាត់នូវរាល់ទស្សនៈគាបសង្កត់ស្មារតីមនុស្ស និងរាល់របៀបរបបមនុស្ស ជិះជាន់មនុស្ស ដើម្បីកសាងសង្គមមួយដែលមនុស្សមានសិទ្ធិសេរីភាពនិងមានសមត្ថភាព ដែលអនុវត្ត តាមឆន្ទៈរបស់ខ្លួនពិតៗ។ ក្រៅពីនេះទៀត កវីមានបំណងដាស់តឿនយើងឱ្យទទួលយកលោកទស្សនៈ មួយចំនួនទៀត ដែលប្រាប់យើងថាដើម្បីកែប្រែផ្នត់គំនិតសង្គមមួយទាមទារឱ្យមានការឯកភាពជាតិ សាមគ្គីភាពមិនមែនតស៊ូតែបុគ្គល មួយនាក់ឬពីរនាក់នោះឡើយ។ ម្យ៉ាងទៀតការតស៊ូនេះ ទាមទារប្រើ ពេលវេលាយូរអង្វែង ត្រូវមានចិត្តអត់ធ្មត់ទៀតផង។ យ៉ាងនេះហើយទើបកវីខិតខំប្រើសិល្បវិធីបង្ហាញឱ្យ យើងបានដឹង «ស្មារតីឯករាជ្យម្ចាស់ការ» ដែលទុំមានតាំងពីដើមរឿងដល់ទីបញ្ចប់រឿងនោះ ក៏ត្រូវស្លាប់ យ៉ាងអណោចអាធម៌ទៅវិញ។ ម៉្យាងវិញទៀតស្នាដៃនេះ កវីក៏មានបំណងចង់ឱ្យយុវជនពិសេសកូនចៅ ត្រូវចេះគោរព មាតា បិតា មិនត្រូវប្រើប្រាស់ពាក្យទ្រគោះបោះបោកជាមួយលោកនោះឡើយ ដើម្បីសេចក្តី សុខ ក្នុងគ្រួសារ។

## ៣.*អត្ថរូប*

### ក.វិធីតែងនិពន្ធ

រឿងទុំទាវ កវីបានសរសេរជាពាក្យកាព្យបទពាក្យប្រាំពីរ ដោយប្រើវិធីតែងនិពន្ធយ៉ាងល្អប្រណីត គឺ៖

ក.១.វិធីផ្តើមរឿង

អ្នកនិពន្ធបានផ្តើមដោយរៀបរាប់ពីទីកន្លែងដែលតួអង្គទុំ ពេជស្នាក់នៅបួសរៀន(វត្តវិហារធំ) សកម្មភាពតួ អង្គទាំងពីរដែលចេះធ្វើជន្លាប់ គោកយកទៅលក់និងជំនាញនៃអ្នកទាំងពីរដូចជាទុំវោហារបាន ចេះមន្ត អាគម សម្លេងពីរោះ «សំដីផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកំលោះចាស់មេម៉ាយ ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់សព្ទភាសា» ឯពេជវិញពូកែខាងផ្លុំប៉ី៖

ថ្លាថ្លៃងសម្តែងដើមឈ្មោះទុំ នៅខេត្តបាភ្នំដែនដីស្រែ
កើតកបទំនៀមមានឪម៉ែ ប៉ុន្តែហេតុត្បិតឥតសម្តែង។
កើតឡើងលុះធំល្មមប្រមាណ ឆ្នាំច្រើនសោតបានម្តាយតុបតែង
យកទៅឱ្យរៀនចោលគ្រឿងល្បែង ស្វះស្វែងនៅវត្តវិហារធំ។
លោកគ្រូទទួលស្រួលព្រះទ័យ ប្រឹតប្រៀនទុំវៃខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជញ្ជ្រំ ខិតខំចង់បួសផ្នួសសាមណេរ។

ក.២.ដំណើររឿង

ដំណើររឿងនេះ បានប្រព្រឹត្តទៅនៅទីកន្លែងមួយចំនួន ដូចជានៅតាមជួរមាត់ទន្លេដែលមាន ជ្រោយចង្វារ ព្រែកដំបង ជ្រោយមេត្រី ព្រែកបង្កង កងមាស កៀនស្វាយ ពាមតាឯក ពាមជរ លើកដែក ស្អាង កញ្ជរ ក្រចេះ ...។ នៅតាមភូមិស្រុកខ្លះទៀត ដូចជាកំពង់សោម បន្ទាយមាស សំរោងទង ភ្នំស្រួច គងពិសី ព្រែកប្បាស កណ្តាលស្ទឹង ពោធិ៍ សាត់ បាត់ដំបង កំពង់ស្វាយ កំពង់សៀម បារាយណ៍ រាជធានីលង្វែក

ជាដើម។ ដោយអ្នកនិពន្ធប្រើប្រាស់វិធីតែងសំខាន់ៗដូចខាងក្រោម៖

- **វចនវិធី** : ក្នុងខ្លឹមសាររបស់ស្នាដៃ កវីបានប្រើពាក្យពេចន៍ចម្រុះគឺ ៖
  - ពាក្យសាមញ្ញ : ជុះ នោម ផ្អើល ដៀរ ចោម...
  - សង្ឃសព្ទ : នេន និមន្ត ឆាន់ ស្រង់ ស្បង់ អង្សក...
  - បាលីសំស្ក្រឹត : បរិក្ខារ សទ្ធា ជាតិ ...
  - រាជសព្ទ : ព្រះចៅ ថ្វាយ ព្រះករុណា វិយោគ...
- **វចនាវិធី** : កវីបានសរសេរជាពាក្យបទពាក្យ៧ ដោយគោរពតាម

រង្វាស់កាព្យ ចំណាប់ចួន ចង្វាក់ បរិយាកាស បានត្រឹមត្រូវតាំងពីដើមដល់ចប់ ធ្វើឱ្យកាព្យកាន់តែមានសម្ផស្សថែមទៀត។

ឧទាហរណ៍ : ឈរទ្រឹងរឹងខ្លួនពួនចាំស្ដាប់ ពីរោះហាក់ផ្កាប់មុខដល់ដី
ស្រងាកស្រងោចស្រងល់ស្រី នោនឹកបេតីមិនស្ដីសោះ
ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់ ទាវនៅក្នុងម្លប់សមស្រណោះ
នាងជាម្ដាយទាវមានរបស់ កូនស្រស់រូបស្រេចដាច់ស្រីផង។

- **និទានវិធី ៖**

កវីបានធ្វើការនិទាន តាមបែបបុរសទី៣ អំពីសកម្មភាពតួអង្គ និងដំណើរ រឿងតាំងពីដើមដល់ចប់៖

« ថ្លាថ្លែងសម្ដែងដើមឈ្មោះទុំ នៅខេត្តបាភ្នំដែនដីស្រែ
កើតកបទំនៀមមានឪម៉ែ ប៉ុន្តែហេតុត្បិតឥតសម្ដែង។
ឯរំតែងតាំងតាមវោហារ យើងសន្មតថាទុកជាច្បាប់
ស្រេចនូវប្រការជាអណ្ដាប់ សាសព្ទចែងចប់ម្ល៉េះឯងហោង»។

- **ឯកវាទវិធី** : កវីបានតម្រូវឱ្យតួអង្គទុំមានអារម្មណ៍នឹកគិតតែម្នាក់ឯង ក្នុងពេលដែលដឹងថា ទាវត្រូវម្ដាយយកមករៀបការជាមួយម៉ឺនងួន៖

« ឱ! ទាវអើយM\BIព្រោះម្ដាយ មិនដឹងប្រែក្លាយមានប្រើស្នៀត
ទាវអើយទុក្ខទុំធំចង្អៀត ស្ដាត់ស្មៀតដូចភ្នំរលំលើ ។
ទាវអើយទាវស្រីប្រណីបង មែនពិតជាម្ដងទើបហ៊ានធ្វើ
អក្ខរីទាវស្រីប្អូនចាត់ប្រើ ដំណឹងដំណើរឱ្យឆាប់ដើរដល់»។

- **សំវាទវិធី** : កវីបានតម្រូវឱ្យតួអង្គនិយាយឆ្លើយឆ្លងគ្នា ៖
  - ព្រះរាជា «ស្ដេចមានព្រះរាជឱង្ការ បន្ទូលសួរថានែទុំអើយ ទាវសង្សារមែនចូរឯងឆ្លើយ កុំបិទបាំងឡើយប្រាប់តាមត្រង់»។
  - ទុំ «ករុណាសម្លាប់តាមទោសធំ ទុករស់ជាខ្ញុំព្រះបារមី
    ទូលបង្គំជាខ្ញុំនឹងលាក់ថ្វី ឯនាងទាវស្រីសង្សារពិត»។
  - ទាវ «ទាវទូលទៅអង្គព្រះចក្រី បពិត្រនរបតីសូមមេត្តា

ខ្ញុំនិងទុំពិតទៀងសត្យា ដូចព្រះករុណាទ្រង់ជ្រាបស្រាប់»។

- **បំរៀបន័យវិធី** : កវីបានធ្វើការប្រៀបធៀប ដោយមិនប្រើចំណងធៀប ក្នុងពេលដែលម្ដាយទាវគំរាមនាងឱ្យទទួលយកម៉ឺនងួនជាប្ដី៖

« គិតក្រែងបែកបាក់ធ្លាក់ថ្លោះធ្លោយ ពងមាន់មកឱ្យមានអំពល់

ប្រមៀលត្រូវថ្មល្អិតគ្មានសល់ ហ៊ានទល់ផ្ទាល់ផ្ទាញ់សង្កុញខឹង»។

មានន័យថាពងមាន់មិនអាចប៉ះទង្គិចនឹងថ្មបានឡើយ វាងាយបែកប្រៀបដូចជាមនុស្សទនខ្សោយ ឬកូនមិនអាចប្រឆាំងឪពុកម្ដាយបានឡើយ។

- ទំហៀបន័យវិធី : កវីបានប្រើការប្រៀបធៀប ដោយប្រើចំណងធៀប«ប្រៀប ជាង»៖

នៃទាវទំនៀមព្រេងប្រៀបស្រាប់ ថាកូនមិនស្ដាប់ចចេសរឹង

លោកយកទាញមករកសន្ទឹង របឹងរបាញសាញចណ្ដាល។

មិនដែលសោះឡើយទាវអើយនំ ច្រឡើសបើសធំម្ដេចជាងនាឡិ

កូនគោកាចកៀចដោយព្រៃវាល ពោលវាលឈឺខ្លួនជូនដល់ស្លាប់។»

ចាស់ប្រៀបប្រដូចកូនដែលចចេសរឹងរូសមិនស្ដាប់ឪពុកម្ដាយ គឺកូនគ្មានត្រកូល គ្មានពូជ អំបូរ គ្មានមេបាប្រដៅ។

ម៉្យាងវិញទៀតកូនប្រៀបដូចនឹងនំ ហើយម្ដាយប្រៀបដូចជានាឡិ មិនអាចល្មើសនឹងគំនិត ម្ដាយក្នុងការទុកដាក់កូនឱ្យមានគូស្រករបានឡើយ។ បើសិនជាប្រកែកឬជំទាស់កូននោះ នឹងត្រូវទទួលទណ្ឌកម្ម ដូចកូនគោមិនព្រមចូលនឹមតែងត្រូវម្ចាស់វាវាយរហូតស្លាប់ទៀតផង។

- **បដិវិធី** : កវីបានប្រើវិធីនេះ ដោយបង្ហាញនូវភាពផ្ទុយគ្នា ក្នុងការបញ្ជាក់ទស្សនៈពីរមានភាពផ្ទុយគ្នា គឺរវាងម្ដាយនិងកូន ម្ដាយទាវនិងនាងទាវក្នុងការជ្រើសរើសគូស្រករ៖

« ហើយសួរទៅកូនស្ងួនមាសម្ដាយ សមយើងសប្បាយថ្លាវីកមុខ

ម្ដាយឱ្យទៅកូនចៅហ្វាយស្រុក បានសុខដោយបុណ្យដោយបានថ្កើង។

...................................................

ទាវឮម្ដាយប្រាប់ចាប់ចាំទុក ស្ទើរធ្លាក់ថ្លើមក្ដុកពុំរសាយ

ទើបមានវាចាថាម៉ែអាយ ខ្ញុំកូនដូចស្ដាយបាយចំណី។

ថាម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី

លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ »។

មានន័យថា នាងទាវមិនពេញចិត្តនឹងធ្វើជាភរិយារបស់ម៉ឺនងួនទេ រីឯម្ដាយទាវមានបំណងលើកនាងទាវឱ្យធ្វើជាភរិយារបស់ម៉ឺនងួន។ ជាងនេះទៀតកវីក៏បានប្រើវិធីនេះ បង្ហាញពីលក្ខណៈតួអង្គដែលមានរូបកាយមានអំណាចដូចជាព្រះរាជា អរជូន និងម្ដាយទាវនិងមួយក្រុមទៀតពុំមានអំណាច ដែលមានទុំនិងទាវ។ ប៉ុន្តែទុំទាវមិនចុះញ៉ម ដោយធ្វើការប្រឈម រហូតដល់ទីបំផុតម្ដង ហើយម្ដងទៀត។

- ទារុណវិធី : ស្ថិតត្រង់កវីបង្កើតឱ្យមានភាពកំសត់សោកសង្រេងដល់អ្នកអានតាមរយៈសកម្មភាពតួអង្គទុំ ដែលត្រូវបក្សពួកអរជូនចាប់ចងនឹងផ្តៅវាយដំទាត់ធាក់ចាក់កាប់ រហូតស្លាប់នៅក្រោមដើមពោធិ៍ជើងខាលៈ

« កាលអើយកាលណោះឯអរជូន | ម៉ឺនងួនជាកូនគិតរៀបការ
បង្កើតអកុសលក្នុងអាត្មា | ឥតមានករុណាមេត្តាទុំ។
គេចោមចាប់ទុំចងនឹងខ្សែ | ចាក់មុខដង្ហែរឥតគិតធ្យាន
គិតធ្យោគប្រណីដល់តិចគ្មាន | ធ្វើទោសបំពានឥតមានខុស។
ទុំឈឺជំងឺងៀងងឹតមុខ | ឈមចុកឆ្អល់សៀតក្តៅដូចស្រុស
ដូចស្រេកទឹកពេកណាធ្លាយពោះ | សាប់សុសធ្លុះសាច់ដាច់សសៃ។
.............................................
នាំដល់ខាងថ្នល់នៅទីល្ហាល | បៀតពោធិ៍ជើងខាលដួលភ្លឹកភ្លឹង
ប្រេះប្របហាបផុត រលត់ឈឹង | ខ្យល់ចេញរឹងៗសន្ធឹងស្លុក»។

- **វិធីបង្កើតរូបារម្មណ៍** : ដើម្បីជម្រុញឱ្យអត្ថបទកាព្យនេះកាន់តែពីរោះរណ្តំណែងណងអន្ទងទាក់ទាញអារម្មណ៍អ្នកអានអ្នកសិក្សា កវីបានប្រើវិធីបង្កើតរូបារម្មណ៍ ៖

**+ ឧបមានរូបារម្មណ៍ :**

កវីបានប្រើវិធីនេះ ក្នុងពេលដែលទុំនិងទាវបានផ្តោះផ្តងគ្នា ដោយធ្វើការប្រៀបធៀបៈ

« ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា | ឯអ្នកឧបមាដូចកន្លង់
ហើរមកឃើញផ្កាចូលត្រឹបត្រង់ | រួចមិនបង្អង់ចរលីលា។
ទុំថាខ្លួនបងដូចរាជសីហ៍ | ខ្លួននាងទាវស្រីដូចគុហារ
រាជសីហ៍បើបានលំនៅជា | មិនឱ្យឃ្លាតឃ្លាគុហាឡើយ។
...មកយល់វាលវែងគ្រែងដួលដុះ | ផ្កាសត្រសុសផ្លេកភ្លឺថ្លា
ដូចរូបសម្បុរពណ៌កនិដ្ឋា | ដូចផ្កាគ្រែងត្រស់ស្រណោះពេក។
មៀងមើលទឹកជ្រៅស្មៅត្រកៀត | ចិត្តបងចង្អៀតរឹងរិវេក
ត្រកូនដូចខ្លួនបងឈប់ដេក | ឈប់ដោយម្លប់មែកត្របែកព្រៃ»។

| អង្គទី១(អង្គបង្គោល) | សំនួនប្រៀបធៀប | អង្គទី២(អង្គទំហៀប) |
|---|---|---|
| •ខ្លួនប្អូន(ទាវ) | •ដូច | •ផ្កា |
| •អ្នក (ទុំ) | •ឧបមា | •កន្លង់ |
| •ទុំ | •ដូច | •រាជសីហ៍ |
| •ទាវ | •ដូច | •គុហា |

| | | |
|---|---|---|
| •ផ្កាសត្រសុស | •ដូច | •សម្បុរកនិដ្ឋា |
| •ត្រកួន | •ដូច | •បង |

+និមិត្តរូបារម្មណ៍ ៖ កវីបានយកសញ្ញាភាពមួយមកប្រើមតិយោបល់គំនិតទស្សនៈ របស់អង្គទុំទាវ ដែលទាវយកផាហ៊ុមដណ្ដប់ តំណាងឱ្យគំនិតរបស់នាងចំពោះទុំ ហើយ ដោយសារតែវត្ថុទាំងនេះហើយនាំឱ្យទុំយល់ចិត្តទាវ ហើយពុះពារសឹកមករកទាវ ៖

ឧទាហរណ៍ « ឥឡូវធ្វើឆ្មើងថាមិនស្គាល់ មានជាបន្ទូលនៅដៃស្រាប់

ប្រាថ្នាមានឈ្នួតនឹងដណ្ដប់ ឱ្យបងសឹកឆាប់កុំយូរឡើយ។
ទាវឮពាក្យទុំថាដូច្នេះ ព្រឺព្រួចពុងពោះពុំមានស្បើយ
បើកទ្វារចេញមកថាលោកអើយ ហ៊ានយកឈ្នួតហើយជាបន្ទូល។
នរណាផ្ដាំថានឹងឈ្នួតទៅ ឱ្យអ្នកមកកូវនាំកង្វល់
ទុំថាបើបានតែដៃដល់ ប្រាប់មិនឱ្យឆ្ងល់សល់សេចក្ដី។ »

ដូច្នេះ ផាហ៊ុម ឬឈ្នួត ដន្លាប់ដែលទាវប្រគល់ឱ្យទុំ គឺជាសញ្ញាភាពមួយសម្គាល់ឱ្យចិត្ត ស្រឡាញ់របស់នាងចំពោះទុំ។

**+ ចក្ខុរូបារម្មណ៍** ៖ កវីបានធ្វើការពណ៌នារំលេច ដែលហាក់ដូច ជាឱ្យឃើញនឹងភ្នែកផ្ទាល់ ៖

- តាមរយៈសកម្មភាពជ្រួលច្របល់របស់ទុំ និងទាវ។

  សកម្មភាពទុំពេលឃើញទាវ៖

« រួចនេនស្ដាប់ជាក់ភ្ញាក់ព្រើតប្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ
យល់ទាវឈរស្ងបដើររេរា ស្ទុះស្វារចូលក្នុងស្លុងចេញក្រៅ »។

ពេលនាងទាវបានឃើញទុំដែលមកស្ទួតលើផ្ទះខ្លួនភ្លាមនាងក៏៖

« អើតអើមដកកច្រហមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្លុតស្លឹងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពានា»។

- តាមរយៈសកម្មភាពចុងភៅដែលដាំស្លក្នុងមង្គលការម៉ឺនងួន និងទាវដែលម្ដាយទាវបានរៀបចំឡើង ហើយអរជូនក៏បានបញ្ជាទៅ៖

« ប្រាប់ស្នងបាឡាត់ចាត់មេស្រុក រកជ្រូកព្រៃកុកគោមាន់ទា
ដៃប៉ូវខ្ទឹមម្រេចជំឡូងជ្វា គ្រឿងភ្លាផ្ទឺផ្ទីជីរបារាំង។
គ្រឿងទេសគ្រឿងតែងបន្លែគ្រប់ ទុកមនុស្សប្រសប់ទិញស្រាខ្លាំង
សាច់ក្រកសាបក្រៀមសាច់ចៀមអាំង បបែលទំពាំងក្រសាំងខ្យង។
គ្រប់ម្ទេសស្លឹកគ្រៃខ្ទីរំដេង ក្រអៅរលីងឈូកសម្រង
ស្ពៃក្ដោបស្ពៃលាភ្លាអង្រ្កង បង្កងស្នងគោនូវខ្ទុរល្ហុង»។

- តាមរយៈទេសភាពព្រៃព្រឹក្សាហាក់ដូចជាបានឃើញនឹងភ្នែក៖

« មើលមានផ្លែចន្ទន៍សិរមានព្រីង ដូចទាវស្រីឈ្វេងនឹកសង្សារ
សង្ស័យស្រមៃមិនបានថា ដូចចន្ទនផលាផុតចាកឆ្ងាយ។
ស្រគំស្រគត់រលត់ធាតុ ព្រួសព្រើលមារយាទមើលយល់ស្វាយ
យល់ស្វាទាំងហ្វូងលោតប្រញាយ ព្រោះញាតិនៅឆ្ងាយសំដី»។

+**សោតរូបារម្មណ៍** : ដោយកវីបានប្រើវិធីរណ្តំ ៖

- រណ្តំសូរស្រៈ កវីបានយកស្រៈមកប្រើឱ្យផ្ទួនសូរសំឡេងទាក់ទងរណ្តំគ្នា បង្កើតជាតន្ត្រីភាពដែលធ្វើឱ្យពីរោះដល់សោតិន្ទ្រីយ៍[12]។

*«...ឃើញត្រង់ព្រាហ្មណ៍ចោរកន្លង*
*នាំកុមារចងនឹងវល្លិវ៉ែ។»*

(រណ្តំសូរស្រៈ [អោ])

« អើតអើមដកកច្រហមាត់...»
(រណ្តំសូរស្រះ [ អើ ] )
(រណ្តំសូរស្រះ [ អ ] )

*«...ជន្លាប់ក្រមួនិធ្វនពាសពេញ*
*ទាវអើយទុក្ខអញម្នេញខ្លោចផ្សា...។»*

(រណ្តំសូរស្រៈ [អួ])

- រណ្តំព្យញ្ជនៈ កវីប្រើព្យញ្ជនៈរណ្តំផ្ទួនៗគ្នា ដើម្បីបង្កើតសោតរូបារម្មណ៍។

***.រណ្តំព្យញ្ជនៈទោល*** ៖

*«ថៃរកាត់កោះកុកកោះសុទិន*
*បាយផ្អិនឈប់ទូកគិតជញ្ជីង*
*បានបោះបង្គោលចូលឈប់ទ្រឹង*
*រំពឹងសុរិយេក៏ទេរទៅ»។*

(រណ្តំព្យញ្ជនៈទោល[ក] )

***.រណ្តំព្យញ្ជនៈផ្សំ*** ៖

*«ទុំឱបបីបមថ្នមប្រឡែង*
*ទាំងពីរឥតក្រែងរួមមេត្រី*
*នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្តី*
*ស្រស់ស្រីស្រូបស្រើបដោយតណ្ហា»។*

(រណ្តំព្យញ្ជនៈផ្សំ[ស្រ])

---

[12] កំនាព្យខ្មែរ លោក លី សុមុនី ឆ្នាំ២០០២

**+ជីវ្ហា.ឃានរូបារម្មណ៍** : កវីបានលើកយកពាក្យពេចន៍ឃ្លោងឃ្លាស្របទៅនឹងក្លិន រសជាតិ ដើម្បីប្រើប្រាស់ជាសញ្ញារំលឹកឱ្យនឹកភ្នក ឬនឹកឃើញដល់វត្ថុភេទ និងចំណង់ចិត្តទាក់ទងនឹងឃាន: ជីវ្ហាវិញ្ញាណ។ ដូចជានាងទាវដែលនឹករលឹកទុំ ធ្វើឱ្យនាងហូបមិនចូល ម្ហូបទាំងនោះហាក់ដូចជាគ្មានរសជាតិ៖

« ដំណើរទុំទុកស្លេះបង្អង់ ថ្លែងទៅទាវផ្ចង់ប្រុងអាត្មា
តាំងពីទុំឃ្លាតឃ្លាកាយា ទាវកើតទុក្ខាពុំមានក្សាន្ត។
ចំណីបាយទឹកមិននឹកនា សាច់ជ្រូកមាន់ទាពោរពេញចាន
សល់នៅក្រៀមផ្អេសស៊ីមិនបាន រំខានវិយោគសោយសោកា»។

**+ កាយរូបារម្មណ៍** : កើតឡើងដោយកវីលើកយកកាយារម្មណ៍ ផ្សេងៗមករៀបរាប់ដូចជារលីង រលោង គ្រជាក់ ក្ដៅ ទន់ ស្រលូន ជាដើម។ ដូចជាកវីបានបង្ហាញពីអារម្មណ៍ទាវដែលមានចិត្តអាលោះអាល័យទុំ៖

« ថ្លែងពីទាវទុក្ខពុំសុខសោះ នឹកឡើងស្រណោះទុំដោយនូវ
យល់យូរស្ងប់ស្ងាត់បាត់ស្អុះក្ដៅ ព្រះពាយផាត់ត្រូវរហើយប្រាណ។»

**+កាមរូបារម្មណ៍** : កវីបានប្រើពាក្យសម្គាល់នូវចិត្តស្នេហាក្នុងការថ្នាក់ថ្នមលួងលោមតាមរយ:ទុំនិងទាវ៖

« ទុំឱបបីបមថ្នមប្រឡែង ទាំងពីរឥតក្រែងរួមមេត្រី
នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្ដី ស្រស់ស្រីស្រួលស្រើបដោយតណ្ហា។
ទាវស្រួលទទួលព្រមចូលជិត ទុំសោតស្នេហ៍ស្និទ្ធថើបភក្ត្រា...»។

**+វេទនារូបារម្មណ៍ : កវីប្រើពាក្យពេចន៍ឃ្លាឃ្លោង បង្ហាញចិត្តរំភើបទុកព្រួយព្រឺព្រួច៖**

«នេនយល់ដូច្នោះក្នុងពោះព្រួច កាន់ក្ដួចកើតទុក្ខចុកឱរា
ឱរូបហ្នឹងហើយទាវពុំងារ មិនងាកបំពារបំពេរន»។

ក.៣- **ការបញ្ចប់រឿង**

បង្ហាញពីឧត្ដមគតិអប់រំទូន្មានដល់អ្នកអាន ការបញ្ចប់រឿងមានឈ្នះមានចាញ់ ជួបជុំ បែកបាក់ព្រាត់ប្រាស បាត់បង់ជីវិតទៅតាមការពិតជាក់ស្ដែងនៃបញ្ហា។ ដោយសារអំណាចផ្ដាច់ការរបស់ស្ដេចគ្រាញ់អរជូនធ្វើឱ្យតួអង្គទុំទាវ និងនាងនោក្នុងរឿងទុំទាវបានបាត់បង់ជីវិតគួរឱ្យសោកសង្រេងជាទីបំផុ

## ៤.អត្ថរស

រឿងទុំទាវបានបង្ហាញតម្លៃមួយចំនួន ដូចខាងក្រោមនេះ ៖

**ក.កាព្យរស** : តម្លៃលេចចេញពីកវីបានរចនាអត្ថបទនេះជាពាក្យកាព្យឱ្យមានសម្ផស្សសូរសំឡេងចូនរណ្ដំណៃងលងអន្ទងអារម្មណ៍អ្នកអានអ្នកស្ដាប់ជក់ចិត្តតាំងពីដើមដល់ចប់។ដូចជា៖

« លុះជួបជូនយប់យន់ស្ងប់ស្ងាត់ ព្រួចព្រឺប្រមាត់រន្ធត់កាយ
រន្ធត់ថៃថប់ជ្រប់ខ្វល់ខ្វាយ មិនស្កាយចង់សឹកនឹកទាវស្រី។
ព្រឹកព្រាងឡើងច្បាស់ព្រះសូរ្យសែង ចាំងថៃងពីបូព៌ារស្មី

ចំហាយដល់អង្គពុំលង់ខ្មី ទុំចុះដល់ដីដើរចេញទៅ»។...

**ខ.ប្រលោមរស** : តម្លៃលេចចេញពីកវី បានបង្ហាញពីសកម្មភាព ដែលមានភាពអណ្ដែតអណ្ដូងនៃស្នេហាទុំទាវស្នេហាទុំទាវប្រកបដោយមនោសញ្ចេតនាផ្អែមល្ហែមៈ

« ទុំថើបល្ងងលោមថ្លែនួនល្អង ថាឱមាសបងដួងជីវា
បងមិនដោះដៃចោលកនិដ្ឋា បងផ្ញើអាត្មាអស់ជន្មជីព។»

**គ.កម្សត់រស** : តម្លៃលេចចេញពីភាពកំសត់របស់តួអង្គ ដែលបង្ហាញពីការព្រាត់ប្រាស់រងការធ្វើបាបទុំពីសំណាក្រុមអរជូនៈ

« ទាវឮគេថាចោមចាប់ប្ដី ក្ដួលក្ដៅទាវស្រីនឹកសង្វេគ
ទុំថាទាវអើយសមបងបែក បងលាទៅដេកលើផែនដី»។

**ឃ.ទស្សនីយរស** : តម្លៃដែលលេចចេញមកអំពីការបង្ហាញទស្សនីយភាពដែលធ្វើឱ្យសាច់រឿងកាន់តែពីរោះក្បោះក្បាយដោយការរៀបរាប់របស់កវីនូវទេសភាពព្រៃព្រឹក្សា មច្ឆជាតិ បក្សាបក្សី បង្កើតជាបរិយាកាសដ៏មនោរម្យៈ

« ទុំរាប់ដើមឈើបណ្ដើរទៅ មើលយល់ទឹកជ្រៅឃើញហ្វូងត្រី
ចង្វារភ្លៀងផ្លោងលោតឡើងខ្មី ខ្លួនអើយគួរអីបែកចែកឋាន។
មើលមានជ្រៃជ្រេសង្កែថ្វាន់ ត្រៀលត្រស់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ងម្ព ទ្រនំអាអូដ្ឋចង្អូតត្នាត»។

**ង.កុសលរស** : ជាតម្លៃលេចចេញពីការអប់រំ ទូន្មាន តាមរយៈដំណើររឿងខាងលើនេះឱ្យមើលឃើញថា គ្រប់ស្ថានភាពជីវិតមនុស្សពិតជាមានតម្លៃលើសពីអំណាច បុណ្យសក្តិ និងទ្រព្យសម្បត្តិ។ ទីបញ្ចប់នៃជីវិតទុំទាវ ពុំមានន័យថាបរាជ័យនោះទេ ប៉ុន្តែអ្វីដែលសំខាន់ចង់រំឭកដល់អ្នកសិក្សាអ្នកអានឱ្យជ្រាបថា គេគួរងាកមករកការសន្តោសប្រណី ឬអហិង្សា ប្រសើរជាងការបង្ក្រាបដោយអំណាច ក្រោមអំណាចផ្ដាច់ការរបស់ខ្លួននោះ។ បើសិនជាគេនៅតែប្រកាន់ជំហរបែបនេះ វានឹងមានរឿងរបៀបទុំទាវជាច្រើនគួទៀត ដោយជៀសមិនផុតឡើយ។ ម្យ៉ាងទៀត រឿងនេះក៏ចង់រំលឹកដល់យុវជនខ្មែរដែរថា ការកែប្រែផ្នត់គំនិតសង្គមមួយ គេមិនអាចធ្វើតែមួយថ្ងៃនោះទេទាមទារប្រើពេលវេលាណាមួយឱ្យសមស្របនោះទើបបានជោគជ័យ។ រឿងទុំទាវបានបង្កប់នូវតម្លៃអប់រំជាច្រើនដូចជាៈ

•អប់រំឱ្យមនុស្សគ្រប់រូបគោរពសាសនា ពិសេសសាសនាព្រះពុទ្ធ។

•អប់រំយុវជនឱ្យចេះស្ដាប់ដំបូន្មានឪពុកម្ដាយ គ្រូបា អាចារ្យ ចាស់ព្រឹទ្ធាចារ្យ

•អប់រំបុរសស្ត្រីគ្រប់រូបឱ្យគោរពតាមប្រពៃណី កុំឱ្យភ្លើតភ្លើន កុំលលេងនឹងល្បែងស្នេហារំលងប្រពៃណី ព្រោះស្នេហាអាចធ្វើឱ្យការសប្បាយក្លាយជាទុក្ខបាន

•អប់រំមិនឱ្យមនុស្សកាប់សម្លាប់គ្នា ប្រើអំណាចផ្ដាច់ការ ជិះជាន់ គាបសង្កត់កេងប្រវ័ញ្ចលើអ្នកទន់ខ្សោយ។

•រំឭកដល់មាតាបិតាគ្រប់រូបកុំឱ្យប្រកាន់យកទស្សនៈ«នំមិនធំជាងនាឡិ»មកគាបសង្កត់កូនត្រូវចេះស្ដាប់ហេតុផលនិងផ្ដល់សិទ្ធិសេរីភាពក្នុងការសម្រេចចិត្តក្នុងការជ្រើសរើសគូស្រករបស់កូនៗ

•អប់រំមនុស្សឱ្យមានឆន្ទៈមុះមុតក្នុងការរើបម្រាស់ពីការពីការគាបសង្កត់ ជំនះរាល់ឧបសគ្គដើម្បីសម្រេចនូវឧត្តមគតិត្រឹមត្រូវមួយ។

•អប់រំមនុស្សឱ្យចេះដោះស្រាយដោយបញ្ហាសន្តិវិធី មិនយកកំហឹងទល់កំហាល់ ឈ្លាសវៃ មិនយកស្រីស្រាជាត្រីមុខជាមូលហេតុនាំឱ្យវិនាសខ្លួន។

**ច.សង្គមរស** : តម្លៃលេចចេញពីការលាតត្រដាងនៃសង្គមមនុស្សនៅក្នុងស្នាដៃដែលមានលក្ខណៈសង្គមមនុស្សពិតៗ ទាំងទំនៀមទម្លាប់ប្រពៃណី សាសនា មុខរបរ របបគ្រប់គ្រងជាដើម។

•អ្នកដឹកនាំមិនត្រូវធ្វេសប្រហែសចំពោះមន្ត្រីក្រោមឱវាទ។

**ឆ. តថរស** : តម្លៃលេចចេញដោយកវីបានរំលេចពីព្រឹត្តិការណ៍ជាក់ស្តែងនៃសង្គមខ្មែរ ដែលមាន នៅសម័យលង្វែក ៖

•ទីកន្លែង ត្បូងឃ្មុំ បាភ្នំ ពោធិជើងខាល .....

•តួអង្គទោះបីមិនមែនជាមនុស្សជាក់ស្តែងក៏ជាតួអង្គតាងដែរៈ

.អរជូន តំណាងអំណាចស្តេចត្រាញ់។

.ម្តាយទាវ តំណាងឱ្យមេគ្រួសារនិយមអំណាចបុណ្យសក្តិទ្រព្យសម្បត្តិ។

.ព្រះរាមាតំណាងរាជាខ្មែរ ដែលក្នុងសង្គមខ្មែរតែងនិយមគោរពជានិច្ច។

•ដំណើររឿង ប្រព្រឹត្តនៅក្នុងសម័យកាលមួយពិតប្រាកដ សម័យលង្វែក។

**ជ. វីររស** : តម្លៃលេចចេញដោយកវី បានបង្ហាញអាកប្បកិរិយាចិត្តក្លាហានមោះមុត របស់តួអង្គទុំទាវដែលហ៊ានប្រឈមនឹងព្រះរាជាក្នុងការសារភាពពីការពិតចំពោះអតីតកាលរបស់អ្នកទាំងពីរព្រមទាំងមិនញញើតចំពោះការប្រហាររបស់ម៉ឺនងួន ដែលយកទុំទៅសម្លាប់ឯទាវក៏ហ៊ានពលី ដើម្បីភក្តីភាពជាមួយទុំដែរ។

**ឈ. ទារុណរស** : តម្លៃលេចចេញដោយកវីបង្ហាញពីការធ្វើទារុណកម្មមកលើទុំមុនយកទៅប្រហារដោយៈ

« គេចាប់វាយដំក្រំសព្វសាច់ ឈាមហូរគ្មានដាច់បែកសិរសី
ឈាមកកខាន់ស្ទះបម្រះស្តី ផ្តែផ្តាំទាវស្រីប្តីលាប្អូន។
នៅចុះណ៌ានួនស្ងួនសម្លាញ់ គេចាក់គេបាញ់បងស្លាប់សូន្យ
ស្លាប់គឺគាត់ម្តាយកម្ទាយកូន ឱ្យសូន្យបាត់ឈ្មោះមិនរស់នៅ»។

## ៤.បញ្ហាសង្គម

### ក.នយោបាយ ៖

តាមរយៈរឿងទុំទាវ យើងអាចស្វែងយល់បានពីរបៀបរបបគ្រប់គ្រងប្រទេសខ្មែរនាសម័យលង្វែក។ ពេលនោះ ការគ្រប់គ្រងមានរូបភាពជារបបរាជានិយម។ អំណាចរដ្ឋទាំងមូលមានស្តេចជាអ្នកកាន់កាប់ហើយ ដែលមានស្តេចត្រាញ់ជំនួយត្រួតត្រាតាមតំបន់។កវីបានធ្វើការប្រៀបធៀបអំណាចស្តេចទៅនឹងភ្នំដែលខ្ពស់បំផុត នៅក្រោមមេឃលើដីនេះ។ ឯអំណាចស្តេចត្រាញ់ គឺទាបជាងភ្នំតែមួយប៉ុណ្ណោះ៖

« ឧកញ៉ាអរជូនមួនមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានរិទ្ធិអំណាចឥតជំនុំ កាប់ចាកវាយដំពុំប្រណី»។

វណ្ណៈខ្ពស់បំផុតក្នុងសង្គមគឺពួកសក្តិភូមិ ដែលក្តាប់អំណាចទាំងអស់ ហើយមានសិទ្ធិកាប់សម្លាប់ប្រជាជនគ្មានរើសមុខ។ អរជូនសម្លាប់ទុំដោយគ្មានការវិនិច្ឆ័យ។ ស្តេចរាមាកាត់ទោសបក្សពួកអរជូនមិនស្តប់ចិត្ត ថែមទាំងដាក់ទណ្ឌកម្មអ្នកស្រុកត្បូងឃ្មុំ ដោយបញ្ចូលជាអ្នកងារយ៉ាងព្រៃផ្សៃ អយុត្តិធម៌ក៏មិនបាច់ជំនុំជំរះក្តី។វណ្ណៈទាបជាងគេគឺមហាជនប្រជាជន ដែលស្ថិតនៅក្នុងក្តីលំបាកវេទនារែកពុននូវបន្ទុកទាំងអស់នៃវណ្ណៈដឹកនាំគឺស្តេច។ ប្រជាជនគ្មានសិទ្ធិសេរីភាពគ្មានអំណាចអ្វីទាំងអស់គឺមានតែវាសនា ដែលស្ថិតក្រោមការគួរវាសពីពួកអ្នកកាន់អំណាចតែប៉ុណ្ណោះ។ ប្រជាជនត្បូងឃ្មុំត្រូវបញ្ចូលជាអ្នកងារ ដោយគ្មានដឹងហេតុផលទាំងអស់។

**ខ.សេដ្ឋកិច្ច ៖**

- **កសិកម្ម** ដោយស្ថានភាពទឹកដីនៃប្រទេសខ្មែរ បង្កលក្ខណៈយ៉ាងប្រសើរដល់របរកសិកម្ម។ ក្នុងផ្ទៃរឿង អ្នកនិពន្ធបានរៀបរាប់យ៉ាងពិស្តារពីសម្បត្តិធម្មជាតិយ៉ាងស្កុកស្តម្ភនៅលើទឹកដីកម្ពុជា។

•**ចំពោះព្រៃឈើ** ប្រទេសកម្ពុជា ជាប្រទេសមួយពោរពេញទៅដោយឈើគ្រប់ប្រភេទដែលមានប្រយោជន៍ក្នុងជីវភាពប្រចាំថ្ងៃ របស់រាស្ត្រខ្មែរគ្រប់សម័យកាល។ ជាពិសេសក៏បានជួយទ្រទ្រង់បរិស្ថានគឺមិនឱ្យប្រែប្រួលអាកាសធាតុ ការពារព្យុះ ទឹកជំនន់ជាដើម។ ដូចជាតាមការរៀបរាប់របស់កវីបានឆ្លុះឱ្យឃើញពីឈើគ្រប់ប្រភេទ ដែលមានតាំងពីបុរាណកាលមកម្ល៉េះ ហើយអាចយកទៅប្រើប្រាស់តាមតម្រូវការផ្សេងៗគ្នាទៀតផង។ បានសេចក្តីថាមានឈើខ្លះអាចយកធ្វើជាឱសថកែរោគឈើខ្លះយកទៅសាងសង់លំនៅស្ថាន ហើយឈើខ្លះទៀតជាដំណាំហូបផ្លែទៀតផង។ តួយ៉ាងកវីបានពណ៌នាថា៖

« មើលមានជ្រៃជ្រែសង្កែថ្នាន់ ត្រៀលត្រស់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ទម្ព ទ្រនំអាអូជ្ជចង្អុរត្បាត។
ដង្កោទ្រយឹងខ្នឹងក្រសាំង អំពិលភ្លូងភ្លាំងទាំងភ្លូបាត
គូលែនទុរេនមៀនលាំងសាត មាក់បាតបង្គៅញ្ញៅចាន់ចារ។
ត្របែកត្រសេកអំបែងថ្ងៃ អង្គ្រងស្នាច់ស្មៃរោគរកា
ក្រូចក្រាយស្វាតស្វាយត្រាចត្រៀលស្វា សេដាសណ្តាន់ថ្នាន់ជ្រៃជ្រៃ។
មានទាំងដកពាយវាយដកព សង្ឃ័រពង្ររាក់រាំងស្មី
ភ្នំភ្នែងផ្តៃស្រែងលោតលាំងដៃ សន្ទៃក្រខុបងប់ក្រឡាញ់»។

ឈើទាំងអស់នេះ គឺជាអត្តញាណជាតិពិតៗរបស់ជនជាតិខ្មែរ។

•**ចំពោះវារីជាតិ** ដែលដុះក្នុងទឹកត្រូវបានកវីលើកយកមកបង្ហាញដែរដូចជា៖

« ព្រលឹតដុះជិតដើមត្រកៀត ត្រកួនដុះបៀតដូចអង្គបង
ត្រកៀតដុះបៀតដូចនួនល្អង ត្រកួនដូចបងត្រកងបី។
...មៀងមើលទឹកជ្រៅស្មៅត្រកៀត ចិត្តបងចង្អៀតរឹងរិរេក

ត្រកួនដូចខ្លួនបងឈប់ដេក ឈប់ដោយម្លប់មែកត្របែកព្រៃ។
យាប្លងដូចបងភ្លាត់ឃ្លាតឆ្ងាយ...»។

**•ចំពោះបក្សាបក្សី** ក៏ជាប្រភពធនធានធម្មជាតិមួយ ដ៏សំខាន់ក្នុងការចូលរួមលំនឹងបរិស្ថាន។តាមការរៀបរាប់បានឱ្យឃើញមានបក្សាបក្សីគ្រប់ប្រភេទដូចជា៖

« ថាអូនមើលសត្វច្រវាត់ទុំ មៀមមុំទីទុយហើរលលេច
លលកហើរជ្រកដើមព្ញូសព្រេច ពពេចហើរគេចដើមពពូល។...
កន្លង់ក្រឡឹងផ្កាក្រឡាញ់ ដូចរូបអង្គអញត្រាច់ដើររក
ពពេចពពូលហើរចូលជ្រក ...គ្រលេងគ្រលោងគ្រលែងវែក
ក្រឡុះហើរបែកកូនហ្វូងហ្វាយ... »។

**•ចំពោះមច្ឆជាតិ** តាមរយៈការធ្វើដំណើររបស់ទុំ កវីក៏បានលើកយកមច្ឆជាតិគ្រប់ប្រភេទមកបង្ហាញ៖

« រ៉ស់ឆ្តោកាហោរាជរាហូ ព្រួលប្រាទីពោព្រុយកន្លង់
ដំរីក្អិតក្អីឫស្សីច- ង្វាត្លៀងរហង់រហ័សហែល។
សណ្តាយក្រុសក្រាយឆ្តិនច្រកែង ផ្ទក់ក្រាញ់អណ្តែងច្រើនក្រាស់ក្រែល
សរសៃក្រពតផ្សោតប្របែល ផុសផែលផុលផុងក្នុងគង្គា»។

- **ផលិតកម្ម សិប្បកម្ម ៖**

ក្នុងដំណើររឿងបានឱ្យឃើញថា ប្រជារាស្ត្រខ្មែរមានសមត្ថភាពផលិតវត្ថុប្រើប្រាស់គ្រប់យ៉ាងដូចជា៖

« សឹងព្រៃសូត្រសុទ្ធសាច់ល្អស្អាត លាំងកែម៉ូតម៉ាតពណ៌ពណ៌លឿងខ្ចី
សម្បុរស្រៀបស្រស់ឆ្លុះរស្មី នៅថ្មីភ្លឺទែងកន្សែងស។
ស្លៀកពាក់គ្រលុំធុំរមៀត យកឆ្វិតស៊កសៀតរូបឆោមល្អ
យាមឈ្នួងទំនងលើកបង់ក ស្រេចចរចាកទីលីលាទៅ។
...ទឹកអប់ត្រឡប់ធុំគន្ធរស សាប៊ូជូតដុសជ្រះសន្លាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង ដោយយល់សំណាងសាមណេរនេន»។

ក្នុងការផលិតរបស់ប្រើប្រាស់នេះ សូម្បីតែព្រះសង្ឃ ក៏អាចផលិតសម្ភារៈប្រើប្រាស់បានដូចជាប្រជារាស្ត្រដែរ។ ដូចជានេនទុំ និងនេនពេជ្រអាចផលិតតោកយកទៅធ្វើអាជីវកម្មបានដែរ។ «ធ្វើតោកធ្វើទុកលក់ដាច់ខ្លះនៅផ្ទះទៀបវត្តជាមីងមា លុះដល់រដូវស្រូវរងារព្រឹប្រុងអង្គារជាទុក្ខព្រួយ»

- **ពាណិជ្ជកម្ម ៖**

តាមការនិទានរបស់អ្នកនិពន្ធបានឃើញថា នៅសម័យនោះមានផ្សារលក់ទំនិញ មានលុយកាក់ចាយ គឺមិនមានត្រឹមតែការដោះដូរគ្នារវាងផលិតផលនឹងផលិតផល។ ដូចជាពេលដែលទុំស្កាត់មករកជួបទាវ ទុំនិយាយប្រាប់ក្មេង៖

« យើងជួលអាឱ្យលុយកាក់ កុំឱ្យសល់ម្នាក់ថាឱ្យហើយ

ឱ្យហ៊ានទាំងអស់ប្រុងចាំឆ្លើយ ក្មេងអើយអញសួរគួរឯងប្រាប់»។

ម្យ៉ាងទៀត នៅពេលដែលអាមាត្យនាំនាងទាវទៅរាជវាំង៖

« ដល់ក្រុងភ្នំពេញដែនរាប រសៀលទន់ទាបព្រះសុរិយា
ឡើងមើលទំនិញគ្រប់តាមផ្សារ គ្រៀបគ្រាចិនខ្មែរហៃគឹកកង»។

**ឃ.គមនាគមន៍ ៖**

វិស័យគមនាគមន៍ពុំសូវមានការរីកចម្រើនទេ គឺគេអាចធ្វើដំណើតាមទឹកដោយប្រើទូក ហើយជើងគោកគេប្រើរទេះគោ។ ដូចជាពេលធ្វើដំណើរទៅត្បូងឃ្មុំដើម្បីតាមទាវ ដែលម្ដាយនាងបង្ខំយករៀបការជាមួយម៉ឺនងួន៖

« ពេជ្រអើយទុក្ខបងម្ដងហ្នឹងធ្ងន់ ប្រពន្ធគេយកទៅរៀបការ
ចូរពេជ្ររួសឆាប់ប្រញាប់ណា រករៀបទូកក្ដារច្រវាចែវ។
នូវគ្រឿងស៊ីសព្វប្រអប់ស្លា ក្រមាហូលព្រៃដបតែកែវ
បម្រុងទាញទូកមកខាងចែវ ហៅក្រុមយើងចែវចេញឥឡូវ»។

ម្យ៉ាងទៀត នៅពេលទុំនិងពេជ្រយកគោកទៅលក់នៅត្បូងឃ្មុំ៖

« នេនរៀបបម្រុងការុងបាយ បង្ការទៅឆ្ងាយផ្លូវគ្រាច់ចរ
ប្រឹងអូសរទេះមកបញ្ឈរ ដឹកគោនឹកបរចរចេញទៅ»។

**គ.សង្គមកិច្ច**

- **ស្ថានភាពរស់នៅ** : រឿងទុំទាវបានបង្ហាញឱ្យឃើញពីការរស់នៅ របស់ប្រជាជនក្នុងសង្គមមួយដែលមានស្ដេចគ្រប់គ្រង។ អំណាចកំពូលត្រូវស្ថិតនៅលើស្ដេចផែនដី។ ក្រៅពីនោះគឺមានស្ដេចត្រាញ់ដែលមានអរជូនជាសក្ខីភាពស្រាប់ ហើយអរជូននេះមានអំណាចដ៏លើសលប់ថែមទាំងផ្ដាច់ការទៀតផង «ឧកញ្ញាអរជូនមាំមួនពេក ធម្មតាក្រោមមេឃទាបជាងភ្នំ មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី។» ម្យ៉ាងទៀតរឿងទុំទាវបានបង្ហាញផងដែរនូវឥទ្ធិពលគ្រួសារក្នុងការរៀបចំអនាគតគូស្រករបស់កូនជាពិសេសកូនស្រីដោយអនុវត្តនូវទ្រឹស្ដី ឬទស្សនៈ«នំមិនធំជាងនាឡិ»។ បញ្ហានេះបានធ្វើឱ្យកើតឡើងនូវការប្រឆាំងដើម្បីទាមទារសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការសម្រេចចិត្តរើសគូស្រករ។

- **សុខាភិបាល** : វិស័យសុខាភិបាលក្នុងរឿងទុំទាវមិនទាន់មានការរីកចម្រើននៅឡើយទេពេលមានជំងឺដង្កាត់ពួកគេប្រើឱសថបុរាណ(ស្លឹក ដើម សំបក ឫសរុក្ខជាតិផ្សេងៗ)ប៉ុណ្ណោះ។

- **មុខរបរនិងជីវភាពរបស់ប្រជាជន** : ក្នុងរឿងទុំទាវ ប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែចម្ការនេសាទ ធ្វើកញ្ជើ ល្អី ជន្លាប់ គោកជាដើម។ មុខរបរបែបនេះធ្វើឱ្យជីវភាពរបស់ពួកគេរស់នៅសមរម្យនិងសាមញ្ញបំផុត។

**ឃ.វប្បធម៌ ៖**

នៅសម័យលង្វែកប្រជារាស្ត្រខ្មែរមានវប្បធម៌សម្បូរបែប ដោយបានផ្សារភ្ជាប់ទៅនឹងលក្ខណៈជាតិដូចជា៖

- **ជំនឿ ៖**

.ការទស្សន៍ទាយគ្រូបានទស្សន៍ទាយឃើញថា បើទុំសឹកខែបុស្ស ត្រូវស្លាប់តែសឹកខែពិសាខនឹងបានបុណ្យសក្តិធំ៖

« អញវាយលេខលុបគ្រប់ជើងហារ　　លេខឆ្លើយឡើងថាអាកុំពារ
កុំពុះទម្លុះក្រែងវេទនា　　ឃើញជានេនពេជ្រគេចគ្រាន់បើ។
នេនពេជ្រសឹកចុះខែបុស្សបាន　　ទុំឯងឈប់ខានទើបប្រសើរ
ចាំដល់ពិសាខសិនសឹមដើរ　　សឹកហើយត្រូវលើបានជាធំ»។

.ឥទ្ធិពលទស្សនៈកម្មផលបានជិតដាមក្នុងផ្នត់គំនិតខ្មែរ ជាយូរយារមកហើយៗ ទស្សនៈនេះក៏ជាឱកាសសម្រាប់ទុំយកមកលួងលោមចិត្តដើម្បីបង្កើតឆន្ទៈក្នុងការចិត្តលួចសឹក៖

« មិនស្ដាយផ្នួសប្រាណបានប៉ុនសក់　　កម្មនាំកញ្ឆក់ឱ្យឯងធឹត
មោហ៍បាំងឆ្នាំងគ្របក្រសោបរឹត　　គ្មានគិតគ្មានគួរលោកគ្រូខ្វាល់»។

.មិនតែប៉ុណ្ណោះ នៅសម័យលង្វែក ខ្មែរយើងក៏មានជំនឿទៅលើមន្តអាគមនានាដែលមានក្នុងគម្ពីរអថវវេទ ជាឥទ្ធិពលព្រាហ្មណ៍និយមនោះ៖

« នេនទុំទទួលគ្រឿងបរិក្ខារ　　ស្រេចស្រាយយកស្លាឆាន់រួចនៅ
ឈប់អង់បន្តិចសែកប្រេងម្សៅ　　រំឭកដល់ទៅមន្តសារិកា។
លិនថោងករវីករំលឹករក　　សម្ពលីហៅយកមណីចិន្តា
លូកយកប្រទាលឆាន់នឹងស្លា　　សូត្រសាគ្រប់សព្វចប់ជាម្តង»។

- **ទំនៀមទម្លាប់ប្រពៃណី ៖**

•ពិធីចូលម្លប់ : កូនស្រីពេញវ័យតម្រូវឱ្យចូលម្លប់ ដើម្បីសិក្សាវិជ្ជាគេហកិច្ចត្រៀមខ្លួនកសាងគ្រួសារនាពេលអនាគត។ ដូចជានាងទាវពេលពេញវ័យនាងត្រូវនៅក្នុងម្លប់៖

« ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់　　ទាវនៅក្នុងម្លប់សមស្រណោះ
នាងជាម្តាយទាវមានរបស់　　កូនស្រស់រូបស្រេចដាច់ស្រីផង»។

ការចូលម្លប់ សាមីពិធីត្រូវបំពេញកិច្ចនានា តាមការបង្ហាត់បង្រៀនពីម្តាយ។

•បួសរៀន : កូនប្រុសពេលពេញវ័យ ត្រូវបួសរៀននៅតាមវត្តអារាម ដែលមានលោកគ្រូឧបជ្ឈាយ៍ជាអ្នកបង្ហាត់បង្រៀន។ ដូចជាទុំនិងពេជ្រនៅពេលពេញវ័យត្រូវម្តាយយកទៅបួសរៀននៅវត្តវិហារធំដែលត្រូវសិក្សាទាំងធម៌អាថ៌ទាំងអក្សរសាស្ត្រនិងវិជ្ជាជីវៈ

« ...ប្រឹតប្រៀបទុំវៃខាងអាគម...　　សំណាក់បិតបេរចំណោរលង់
មាននេនមួយអង្គគ្រាន់បើដែរ　　នាមឈ្មោះនេនពេជ្រលេចក្រសែ
នេនទាំងពីរកែតែតោកលក់»។

ការសិក្សាបែបនេះ បានផ្តល់ប្រយោជន៍ដល់យុវជនយើង គឺនៅក្រោយពេលចាកសិក្ខាបទ គេនឹងមានអាជីពក្នុងការចិញ្ចឹមជីវិតបានយ៉ាងប្រសើរ។

•ពិធីចូលស្តីដណ្តឹង : មុននឹងរៀបមង្គលការ ខ្មែរយើងតម្រូវឱ្យកូនប្រុសចូលស្តីដណ្តឹងកូនស្រីជាមុនសិន ទោះបីកូនប្រុសស្ថិតក្នុងត្រកូលណាក៏ដោយ។ ដូចជាអរជូនដែលជាចៅហ្វាយខេត្តត្បូងឃ្មុំបាន

ចាត់ឱ្យអ្នកផ្លូវថៅមហាចូលចៃចូវស្ដីដណ្ដឹងនាងទាវ ដែលមានបណ្ណាការហៃហាម ទៅជាមួយផង។

•ពិធីមង្គលការ : បានប្រព្រឹត្តទៅនៅគេហស្ថានខាងស្រីដោយធ្វើកិច្ចទៅតាមពិធីផ្សេងៗដែលជាទំនៀមទម្លាប់ខ្មែរ។ ដូចជា អរជូនបានរៀបការម៉ឺនងួន ជាកូនជាមួយនាងទាវនៅផ្ទះម្ដាយទាវ៖

« អធិប្បាយនិយាយខាងចៃចូវ ជាអ្នកនាំផ្លូវតាមជូនតា
ឱ្យទៅស្រដីខាងមេបា នាងទាវតើថាប្រការម្ដេច។
ប្រពន្ធអរជូនជំនូនស្រាប់ ភ្ជុំគ្នាប្រញាប់រាន់រំពេច
យកសព្វភោជ្ជផលថ្កល់និងវេច រៀបរួចស្រាប់ស្រេចត្រាច់ចរចេញ»។

- **សាសនា(ព្រះពុទ្ធ)**

**+ពុទ្ធសាសនា :** បានចាក់ឫសចូលជ្រៅទៅក្នុងផ្នត់គំនិតខ្មែរតាំងពីដើមរៀងមក ហើយដើរតួយ៉ាងសំខាន់ក្នុងការអប់រំយុវជនខ្មែរឱ្យចេះរៀបចំឥរិយាបថល្អនិងស្គាល់ពីតួនាទីខ្លួននាពេលអនាគត៖

« កើតឡើងលុះធំល្មមប្រមាណ ឆ្នាំច្រើនសោតបានម្ដាយតុបតែង
យកទៅឱ្យរៀនចោលគ្រឿងល្បែង ស្វះស្វែងនៅវត្តវិហារធំ។

+ព្រាហ្មណ៍សាសនា : ក៏មាននៅក្នុងផ្នត់គំនិតខ្មែរលាយឡំ និងពុទ្ធសាសនាផង ដែរ៖

លោកគ្រូទទួលស្រួលព្រះទ័យ ប្រិតប្រៀនទុំវៃខាងអាគម
អាចគាបដោយប្រាជ្ញាប្រឹងជញ្ជ្រំ ខិតខំចង់បួសផ្នួសសាមណេរ»។

- **ការសិក្សាអប់រំ**

វត្តអារាមមានតួនាទីសំខាន់ ក្នុងការអប់រំបណ្ដុះសតិបញ្ញាស្មារតីសីលធម៌ ហើយជាកន្លែងអប់រំកាយវាចាចិត្ត ព្រមទាំងបណ្ដុះចំណេះវិជ្ជាគ្រប់ផ្នែក ដូចជាវប្បធម៌សង្គមធម៌ជាដើម។ ការសិក្សានៅតាមវត្តអារាមក៏ជាកន្លែងបណ្ដុះស្មារតី ឱ្យស្រឡាញ់សន្តិភាពសេរីភាពសាមគ្គីភាពគ្រប់មនុស្សសត្វទាំងអស់ ព្រមទាំងផ្ដល់ចំណេះដឹងទូទៅ និងវិជ្ជាជីវៈផងដែរ។ ដូចជាអាចធ្វើនង្គ័ល រនាស់ រទេះ តុ ទូ ផ្ទះ ក្បាច់ចម្លាក់និងបង្រៀនខាងសិប្បកម្មពាណិជ្ជកម្មជាដើម។ ជាក់ស្ដែងនេនទុំ និងនេនពេជចេះធ្វើគោក ដន្លាប់ ហើយចេះដើរជួញគោករហូតដល់ត្បូងឃ្មុំ ព្រមទាំងចេះស្មូត្រដោយប្រើសំឡេង ពីរោះក្នុងការទាក់ទាញអ្នកស្ដាប់។ ការបង្រៀនបែបនេះគឺវត្តអារាមចង់បំពាក់វិជ្ជាជីវៈឱ្យមានចំណេះដឹងជាមូលដ្ឋាន មួយចំនួនសម្រាប់ជាទីពឹងក្រោយពេលចាកសិក្ខាបទមករស់នៅក្នុងសង្គមគ្រួសារនោះ។

- **សិល្បៈ** មានប្រជាប្រិយភាពយ៉ាងខ្លាំងគឺប្រជារាស្ត្រខ្មែរនិយមចូលចិត្តណាស់។ ដូចជាទុំនៅពេលយកគោកទៅដល់ត្បូងឃ្មុំបានស្មូត៖

« ប្រមាណដោយគិតគំនិតអ្នក ដែលឱ្យនេនស្នាក់ប៉ងប្រាថ្នា
ប្រយោជន៍ឱ្យនេនមើលសាស្ត្រា នេនមានប្រាជ្ញាចេះលៃបខាយ។
សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្ដាប់ទាំងកំលោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្ដាប់សព្វភាសា»។

ជាងនេះទៅទៀតដោយសារតែសិល្បៈនេះ ហើយដែលនាំឱ្យទុំនិងពេជ្រត្រូវព្រះរាជាសព្វព្រះទ័យឱ្យចូលវាំងបម្រើទ្រង់៖

« បណ្ឌិតពេជ្រទុំផ្គុំហាត្ថា ដាក់លើសិរិសាប្រវាចាប់
ចាប៉ីសាដៀវដេញប្រញាប់ ទុំស្រែកសាសព្ទសងឆ្លងឆ្លើយ។
...ស្រុកភូមិទេតើទុំកុំភ័យ កុំគិតនឹកអ្វីចូរឯងនៅ
អញឱ្យរបស់យសស័ក្តិត្រូវ ទុំឯងឱ្យហៅថាម៉ឺនឯក»។

**III.សន្និដ្ឋាន**

រឿងទុំទាវ ពិតជាស្នាដៃមួយដ៏ល្អឯក ដោយបានបង្កប់លក្ខណៈជាតិយ៉ាងជ្រាលជ្រៅ ។ អត្ថន័យរបស់រឿង មានទំនាក់ទំនងជាពិសេសទៅនឹងផ្នត់គំនិតជាតិ ហើយត្រូវបានកវីលើកយកមកឆ្លុះបញ្ចាំងជាមួយនឹងសិល្បវិធីយ៉ាងដ៏ល្អប្រណីត។ ទោះបីរឿងនេះជារឿង របស់យុវជននាសតវត្សទី១៦ ក៏ពិតមែន ប៉ុន្តែវិសាលភាពអត្ថន័យរបស់ស្នាដៃទាំងមូល បានគ្របដណ្តប់ លើ
ទស្សនៈចិត្តគំនិតរបស់យុវជនយើងនាសម័យថ្មីនេះដែរ។ នោះក៏មកពីស្ថានភាពជីវិតនៃតួអង្គ បានរួមចំណែកក្នុងការផ្តល់ពុទ្ធិដល់យុវជនយើង ឱ្យមើលឃើញពីទំហំនៃសេចក្តីស្រេកឃ្លានសេរីភាពដែលកើតចេញពីតម្រូវការរបស់ខ្លួនដ៏ចាំបាច់ក្នុងការគ្រប់គ្រងជោគវាសនាខ្លួនដោយខ្លួន
ឯង។ មិនតែប៉ុណ្ណោះស្នាដៃនេះ ក៏បានរំលេចបន្ថែមទៀតនូវផលអវិជ្ជមានដែលបណ្តាល មកពីការគាបសង្កត់ស្មារតីនៃប្រពៃណីអភិរក្សនិយម ឱ្យមនុស្សជំនាន់ក្រោយ ចេះពិចារណា ក្នុងការបែងចែករវាងសិទ្ធិបុគ្គល និងប្រពៃណីជាតិឱ្យប្រព្រឹត្តទៅស្របគ្នា ជៀសវាងសោកនាដកម្មណាមួយជាយថាហេតុ។

ដូចនេះរឿងទុំទាវពិតជាមានតម្លៃដ៏លើសលុប សម្រាប់ផ្តល់បទពិសោធ និងមេរៀនសីលធម៌ល្អៗដល់យុវជនជំនាន់ក្រោយ ឱ្យចេះទទួលស្គាល់ការពិត រាល់ការសម្រេចចិត្ត ក្នុងការប្រព្រឹត្តអំពើណាមួយដោយភាពថ្លៃថ្នូរ មិនបង្កឱ្យ កើតមានសោកនាដ្យកម្មណាមួយឡើយនៅក្នុងជីវិតរបស់ពួកគេ។

# ពន្យល់ពាក្យគន្លឹះ

«ក»

**-កន្លង់** ( ន. ) ឈ្មោះសត្វល្អិតមួយប្រភេទ ចោះឈើ ឬ ឫស្សីឱ្យមានជារន្ធល្មមនៅបាន ហើយនៅអាស្រ័យក្នុងរន្ធនោះ, ចេះត្រឹបកេសរផ្កាដូចឃ្មុំ, ហើរឮសូរវង្វងៗ ។

**-កាញ់** ( កិ. ) គិតគ្នេរដោយពិនិត្យពិច័យ : កាញ់គ្នេរ, គិតកាញ់ ។

**-ការុង** ( ន. ) ប្រដាប់សម្រាប់ច្រកអ្វីៗ ពួកស្បោង, បាវ, ប៉ូវតេ ត្បាញដោយស្លឹកជ្រៃ ឬដោយចចូតជាដើម មានបាតសំប៉ែត មានរាងជ្រៅ : អង្ករមួយការុង ។

**-កាំបិត** ( ន. ) ប្រដាប់ធ្វើដោយដែកមានមុខម្ខាង, មានដងម្ខាង តូចក៏មាន ធំក៏មាន, សណ្ឋានផ្សេងៗ សម្រាប់ប្រើកាប់, កាត់, បិត, ចិត, អារ, ពន្លះ ជាដើម : កាំបិតចែត, កាំបិតព្រា, កាំបិតបន្ទោះ, កាំបិតស្លា, កាំបិតប៉ុងតោ ។ល។

**-ក្ទម្ព** ក្ទំ សំ. បា. ( ន. ) (កទម្ព) ឈ្មោះឈើមួយប្រភេទ មានផ្កាចេញមកសណ្ឋានផ្លែតែម្តង ដូចផ្កាថ្កូវ, ផ្កាខ្នុរ ជាដើម ច្រើនដុះនៅទីទំនាប ឬនៅទីត្រពាំង, រំលោង, រំហាច, អ្នកស្រុកច្រើនយកត្រួយធ្វើជាថ្នាំទាស់ ។

**-ក្រខុប** ( ន. ) ឈ្មោះឈើមានផ្លែបរិភោគបាន; ក្រខុបមានច្រើនយ៉ាង ។

**-ក្របៅ** ( ន. ) ឈ្មោះឈើមួយប្រភេទ មានផ្លែបរិភោគបាន ។ អ្នកស្រុកធ្លាប់ជឿមកថា កាលណា ត្រីព្រលូងស៊ីផ្លែក្របៅ សាច់ត្រីនោះ កាលណា គេបរិភោគទៅនឹងបណ្តាលជាពិសពុល។

**-ក្រពត** ( ន. ) ឈ្មោះសត្វទឹកមួយប្រភេទ សន្តាននឹងត្រីមានធ្មេញតែពីរ លើមួយក្រោមមួយ មុតដូចកាំបិតកោរ, ជាសត្វសាហាវ អាចច្រឹបសាច់មនុស្សបាន, មានស្បែកគ្រាតៗ ដូចស្បែកបបែល ឬ ពោះប្រមោយដំរី, កាលណាតែចាប់ខ្លួនវា វាបំប៉ោងពោះប៉ោងដូចជាសត្វហ៊ីង ។

**-ក្រវាន់** ( ន. )ឈ្មោះឈើមួយប្រភេទមានផ្កាក្រអូបឈ្ងុយស្រដៀងគ្នានឹងក្លិនចេកនួនទុំ ។

**-ក្រសាំង** ( ន. ) ឈ្មោះឈើមួយប្រភេទ មានផ្លែប្រើជាម្ជូរបាន, ស្លឹកល្អិត, ផ្កាធ្វើជាអន្លក់ទឹកគ្រឿង ឬ ជាបន្លែសម្លកកូរ, ជាឈើមានបន្លា ។

**-ក្រឡាញ់** ( ន. ) ឈ្មោះឈើមួយប្រភេទ មានផ្លែបរិភោគបាន ។ ឈ្មោះស្រុក ១ ក្នុងខេត្តសៀមរាប ។

**-ក្រាញ់** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ ក្បាលក្រមប់រាងស្ទើរមូល មានសភាពរឹងប៉ឹង, អត់ធន់ : ត្រីក្រាញ់ ។

**-ក្រាយ** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ មានសណ្ឋានដូចត្រីស្លាត តែធំជាងត្រីស្លាត ហើយមានគ្រាអុចៗជាជួរនៅដើមជាយគ្រែង : ត្រីក្រាយ ។

**-ក្រាយ** ( ន. ) ឈ្មោះឈើធំមួយប្រភេទ ដើមស្រលួត ស្លឹកប្រហែលនឹងស្លឹករំដួល ។

**-ក្រុស** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ សណ្ឋានដូចត្រីក្អែក តែតូចជាងត្រីក្អែក ទំហំប៉ុនត្រីលេញ : ត្រីក្រុស ។

-**ក្រូច** ( ន. ) ឈ្មោះឈើមួយពួកមានផ្លែប្រកបដោយក្លែប, កំពឹសមានរសជូរ ឬ ផ្អែមសម្រាប់ប្រើជាអាហារ ឬ ជាប្រយោជន៍ក្នុងគ្រឿងញាំភ្លាជាដើម ។ ក្រូចមានច្រើនយ៉ាង : ក្រូចថ្លុង, ក្រូចសើច, ក្រូចឆ្មារ, ក្រូចចងសក់, ក្រូចឃ្វិច, ក្រូចពោធិ៍សាត់ ។ល។

-**ក្រំ** ( កិ. ) ប្រកប, បញ្ចុះលោហជាតិផ្សេងៗ នឹងដែក : ក្រំមាស គឺយកមាសមកប្រកប ឬ បញ្ចុះនឹងដែក ។

-**ក្រំ**( គុ. ) ខ្ទាំ; ស្ងួតស្ងប់, អន់; សៅហ្មង : ក្រំខ្លួន, ក្រំចិត្ត, ក្រៀមក្រំ ។

-**ក្អិត** ( ន. ) ឈ្មោះត្រីតូចក្នុងពួកត្រីចង្វា : ត្រីក្អិត ។

-**ក្អី** ( ន. ) ឈ្មោះត្រីមួយប្រភេទ ពួកត្រីក្រាយ ស្លាត តែធំជាងត្រីស្លាត តូចជាងត្រីក្រាយ : ត្រីក្អី។

«**ខ**»

-**ខ្នឹង** ( ន. ) ឈ្មោះឈើមួយប្រភេទ សំបក និង ស្លឹកប្រហែលនឹងសុរភី, ផ្លែធ្វើប្រេងបាន, ផ្កាសម្បុរសក្រអូប ។

-**ខ្លឹម** ( ន. ) សាច់ឈើដែលរឹងនៅខាងក្នុងស្រាយ : ខ្លឹមឈើ ។ ទ្រព្យអ្វីៗដែលជាទ្រព្យឧត្តមមានតម្លៃក៏ហៅថាខ្លឹមដែរ: ខ្លឹមទ្រព្យ,ទ្រព្យមានខ្លឹម ។ អ្វីៗដែលជាទីគាប់ចិត្តណាស់ក៏ហៅ ខ្លឹម ដែរ : ខ្លឹមចិត្ត ។

«**គ**»

-**គង្គា** សំ. បា. ( ន. ) ឈ្មោះទន្លេធំ ១ នៅក្នុងមជ្ឈិមប្រទេស ដែលមានក្បាលជាប់ពីភ្នំហិមាល័យ ហូរចុះមកដល់ក្រុងក័លក័ត្តា ( Calculta ) រហូតមកដល់សមុទ្រឥណ្ឌា ។ អាកាសគង្គា គឺផ្ទារទឹកនៅនាអាកាស ។ ពាក្យនេះគេប្រើក្លាយមក ហៅចំពោះទឹកតែម្តង : ស្រង់ព្រះគង្គា(រ. ស.)ស្រង់ទឹក ។

-**គុយ** ( ន. ) ឈ្មោះឈើតូចមានដើមជាវល្លិ ផ្លែមានរសផ្អែមលាយជូរ
ប្រើជា អាហារ ។

-**គូលែន** ( ន. ) ឈ្មោះឈើមួយប្រភេទ មានផ្លែជាអាហារ, ផ្លែមានសណ្ឋានប្រហែលផ្លែទៀបខ្មែរតែតូចជាងច្រើន, ស្រដៀងគ្នាស្ទើរចាប់ច្រឡំផ្លែសិរមាន់, មានគ្រាប់តែ ១ សណ្ឋានសាច់រុំគ្រាប់ដូចផ្លែមៀន, ស្លឹកវែងៗស្រួចចុង; ក្នុងកម្ពុជរដ្ឋមានសម្បូរណ៍តែនៅភ្នំគូលែន ក្នុងខែត្រសៀមរាប, ប៉ុន្តែមានផ្លែតូចៗហើយសាច់ស្តើងៗ ទាំងរសជាតិក៏ជូរ, ចាញ់គូលែនដែលមកពីប្រទេសក្រៅ ។

-**គ្រលេងគ្រលោង** ( ន. ) ឈ្មោះសត្វស្លាបមួយប្រភេទសម្បុរប្រផេះ លាយខ្មៅខ្លះ សំឡេងស្រួយ រូបទ្រើសជាងលលកបន្តិច; បើយកមកចិញ្ចឹម ហាត់ឱ្យនិយាយភាសាមនុស្ស មានចេះនិយាយបានខ្លះ ។

-**គ្រលែងវែក** ( ន. ) ឈ្មោះសត្វបក្សីមួយប្រភេទ រូបប៉ុនមាន់ទឹក សម្បុរត្រសក់ ច្រើនយំព្រមគ្នាដំណើរលោត ដូចជាក្អែក ។ ឈ្មោះឈើមួយយ៉ាងដើមតូច ស្លឹកស្រដៀងនឹងស្លឹកក្រូចសើច, ប្រើធ្វើថ្នាំស្តោះគ្រេច ឬថ្នាំឫសដូងវិលមុខ ។

«**ង**»

-**ងប់** ( ន. ) ឈ្មោះឈើតូចមួយប្រភេទ ស្លឹកក្រពុល, ស្លឹកប្រើធ្វើជាថ្នាំ
ស្រឡាបរំងាប់ចំហាយគ្រុនក្តៅ ឬ ធ្វើជាបន្លែស្លស្រឡក់ក៏បាន; អ្នកខ្លះហៅថា ដើមឡៀវអាវ ព្រោះមានផ្កា, ផ្លែសណ្ឋានដូចឡៀវអាវ ។

**-ងារ** ( ន. ) មុខការ, ទីតំណែងរាជការតាមបណ្ដាស័ក្តិ, តាមក្រសួង, បណ្ដាស័ក្តិ, យសស័ក្តិ, ឋានន្តរ ។ លោកហ្នឹងមានងារជាអ្វី ? មានងារជាហ្លួង ពិភក្តិអក្សរ ។

**-ងារ** ( ន. ) ភាគដីល្មមកម្លាំងបុរសធ្វើមួយពេលហើយការ : ដីមួយងារ, ភ្ជួរស្រែមួយព្រឹកបានពីរងារ ។ ការដែលចែកដោយមុខ, ដោយឡែក ក៏ហៅថា ងារ ដែរ : ធ្វើការតាមមុខងារ, ធ្វើការកាន់មុខងារ, ធ្វើការកាន់ងារ, ភ្ជួរកាន់ងារ ។

**-ងារ** ( ប. ) ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យការ : ការងារ គឺកិច្ចការដែលត្រូវធ្វើដោយមុខ ។

«**ច**»

**-ចក្រី** សំ.; បា. ( ន. ) (ចក្រិន៑; ចក្កី) អ្នកមានចក្រ, អ្នកទ្រទ្រង់ចក្រ, (វិស្ណុ, ស្ដេចចក្រពត្តិ, ព្រះមហាក្សត្រ); អ្នកជិះលើរថ ... ។ ងារសេនាបតីក្នុងកម្ពុជរដ្ឋ សម្រេចកិច្ចខាងក្រសួងយុទ្ធនាធិការ ចម្បាំងជើងគោក :លោកអ្នកឧកញ៉ាចក្រីកុញ្ជរាធិបតី។សម័យបច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងការពារប្រទេស ខាងយុទ្ធនាធិការដែរ ។

**-ចង្វា** ( ន. ) ឈ្មោះត្រីល្អិតមានស្រកា; ត្រីចង្វាមានច្រើនប្រភេទ : ត្រីចង្វាមូល, ត្រីចង្វាភ្លៀង ជាដើម ។

**-ច្រកែង** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ រូបស្រដៀងនឹងត្រីកាហែ ប៉ុន្តែមានស្រកា-សជាងត្រីកាហែ ។

«**ឆ**»

**-ឆ្កែស្រែង** ( ន. ) ឈ្មោះឈើមួយប្រភេទ សំបកក្រាស់សាច់ធូរជ្រោក ច្រើនប្រើជាថ្នាំបង្អួយដំបៅ ដែលកើតដោយរបួស ឬរូស, កោសលាយនឹងថ្នាំឯទៀត ជក់កែរោគឫសដូងខ្យល់ ។

**-ឆៀង** ( គុ. ) ល្មៀងបន្តិចៗពីគ្នា : ស្ពាយឆៀងឬព័ទ្ធឆៀង គឺស្ពាយឬព័ទ្ធតែមួយចំហៀង។

**-ឆ្តោ** ជើង ដ ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ ពួកត្រីរ៉ស់; កាលនៅតូចគេហៅថា ត្រីដៀប, ធំទៅទៀតហៅថា ត្រីឆ្តោ, ទៅពីឆ្តោទៅទៀតហៅថា រាហូ ។

**-ឆ្កិន** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ សន្តានត្រីគជ្រា ។ ច្កិន

«**ជ**»

**-ជ្រៃ** ( ន. ) ឈ្មោះឈើតចសារជាតិមួយប្រភេទ ពួកទ្រាំង, ពួកត្នោត សាច់ក្នុងដើមបុកច្រោះយកម្សៅ ប្រើការធ្វើជានំបានយ៉ាងច្រើន : នំលតម្សៅជ្រៃ ។

**-ជ្រៃ** ( ន. ) ឈ្មោះឈើមានជ័រ ពួកពោធិ៍, ពួកល្វា,មានឫសរយីករយាកឬព័ទ្ធព័ន្ធ; ជ្រៃមានច្រើនយ៉ាងគឺ ជ្រៃពោធិ៍, ជ្រៃក្រឹម, ជ្រៃលៀប, ជ្រៃគ្រាង, ជ្រៃវល្លិ ...។

«ដ»

**-ដង្កោ** ( ន. ) ឈ្មោះឈើមួយប្រភេទ ផ្លែមូលៗមានរសចត់សម្រាប់ប្រើជាគ្រឿងជ្រលក់ ឬយកមកកែផ្សំធ្វើជាអាហារក៏បាន : ផ្លែដង្កោទុំក្រហមប្រាក ។

**-ដកព** ( ន. ) ឈ្មោះឈើមួយប្រភេទ មានសាច់ស្វិត; និយាយក្លាយថា ដក់ព ក៏មាន ។

**-ដកពាយ** ( ន. ) ឈ្មោះវល្លិធំមួយប្រភេទ មានផ្លែប្រើជាអាហារបាន; ហៅក្លាយជា ដក់ពាយ ក៏មាន ។

**-ដំរី** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ មានសណ្ឋានធំកន្ទុយមូល
សាច់ជ្រាយ : ត្រីដំរី (ខ្មែរបុរាណមិនយកមកប្រើជាអាហារទេ) ។

«ត»

**-តោក** ( ន. ) ភាជនៈឈើឬស្មាច់មានជើងស្រដៀងនឹងតុស្ពាន់ រាងកាច់ជ្រុងក្រឡូមជ្រៅជាងតុខ្មែរដាំខ្យង ឬដាំកញ្ចក់, បិទមាសសម្រាប់ដាក់ទ្រអ្វីៗដែលជាវត្ថុចេញមុខ ។

**-ត្បូងឃ្មុំ** ( ន. ) ឈ្មោះស្រុកមួយនៅក្នុងខេត្រកំពង់ចាម (ក្នុងបុរាណសម័យជាខេត្រសម្រាប់ស្ដេចត្រាញ់ងារជា អ្នកឧកញ៉ាអជិន (អរជូន) សព្វថ្ងៃងារនេះក៏នៅតែដដែល) ។

**-ត្រស់** ( ន. ) ឈ្មោះឈើរនាមមួយប្រភេទត្រួយមានរសចត់, ប្រើជាថ្នាំរមាស់កមក៏បាន។

**-ត្រកៀត**( ន. )ឈ្មោះស្មៅទឹកពួកត្រាវ ធាងនិងគល់ប្រើជាបន្លែបាន: សម្លម្ជូរត្រកៀត ។

**-ត្រាច** ( ន. ) ឈ្មោះឈើធំពួកឈើទាលសម្រាប់យកជ័រទឹក ខ្លឹមប្រើការជាប់ធន់ជាងឈើទាល ។ ត្រាចមានពីរប្រភេទគឺ ត្រាចស មានផ្កាលឿងឆ្នូតសៗតូចៗ មានខ្លឹមសស្រគាំ : ត្រាចក្រហម មានផ្កាក្រហមធំៗ មានខ្លឹមក្រហម ។

**-ត្រៀល** ( ន. ) ឈ្មោះឈើព្រៃមានផ្លែ ប្រើជាអាហារបាន; ត្រៀល

មាន ២ ប្រភេទគឺ ត្រៀលដោះក្របី មានដើមជាវល្លិឡើងអាស្រ័យនឹងឈើឯទៀត ផ្លែមានទំនងស្រដៀងនឹងដោះក្របី ផ្លែជាចង្កោម; ត្រៀលស្វា ដុះជាគុម្ព មានដើមតូចៗ ផ្លែជាចង្កោមតែតូចៗ ។

«ថ»

**-ថ្វាន់** ( ន. ) ឈ្មោះឈើមួយប្រភេទ សន្ដានទន្លា តែដុះនៅដីគោក ដំបូក ទួល ត្រួយនិងផ្កាជ្រក់ធ្វើជាអាហារបាន ។

«ទ»

**-ទស** ទស់ បា. ( ប. សំ. ) ដប់ (១០) : យើងខ្ញុំបង្គំព្រះទ្រង់យស ដោយម្រាមទាំងទសផ្ងង់គោរព ព្រមដោយសក្ការៈទាំងគ្រប់ សូមឱ្យឧបទ្រពចៀសចេញឆ្ងាយ ។ ប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃទៀត អ. ថ. ទៈសៈ ដូចជា ទសក័ណ្ឋ (--ក័ន) ន. (បា. ទសកណ្ឋ; សំ. ទគកណ្ឋ) អ្នកដែលមាន-ក ១០ គឺរាពណ៍ : ព្រះបាទទសក័ណ្ឋ (ក្នុងរឿងរាមកេរ្តិ៍ ។ ទសធម្ម (--ធ័ម ឬ--ធ័ម-ម:) ន. (បា.) ធម៌ ១០ ។

ឈ្មោះសូត្រមួយក្នុងព្រះសុត្តន្តបិដក សំដែងពីធម៌ ១០ ប្រភេទ ។

ទសបារមី (ទៈសៈបារ៉ៈម៉ី) ន. (បា.) បារមី ១០ គឺចរិយាដ៏លើសលន់ ឬគុណជាតិដ៏ល្អ ដែលគួរ

បំពេញមាន ១០ យ៉ាងគឺ ១-ទានៈ ការធ្វើអំណោយ; ២-សីលៈ ការរក្សាកាយវាចាឱ្យបរិសុទ្ធប្រពៃ; ៣- នេក្ខម្មៈ ការចេញចាកកាម គឺចេញបួស; ៤-បញ្ញា ការដឹងច្បាស់នូវសេចក្ដីពិត; ៥-វីរិយៈ ព្យាយាម; ៦-ខន្តិ សេចក្ដីអត់ធន; ៧- សច្ចៈ ការកាន់សំដីពិតមិនវើរុះ; ៨-អធិដ្ឋានៈ ការអធិដ្ឋានឱ្យឃើញជាក់ស្ដែងតាមហេតុពិត; ៩-មេត្តា ការផ្សាយសេចក្ដីរាប់អានចំពោះសព្វសត្វមិនរើសមុខ; ១០-ឧបេក្ខា ដំណើរតាំងចិត្តជើយព្រងើយដោយស្មោះស្មើ ។ បារមីទាំង ១០ នេះឯងដែលពោធិសត្វរាល់ព្រះអង្គបំពេញឱ្យបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ ។

ទសពល (--ពល់) គុ. ឬ ន. (បា.) ដែលមានកម្លាំង ១០ គឺមានកម្លាំងស្មើនឹងដំរីវិសេស ១០ (ព្រះសម្មាសម្ពុទ្ធ) : ព្រះទសពល ។

ទសពិធ (--ពិត) គុ. (បា. ទសវិធ, វ > ព=ទសពិធ) ដែលមាន ១០ យ៉ាង,មាន១០ប្រការ ។ ទសពិធរាជធម៌ (ទៈ សៈពិធៈរាជៈ ធ័រ, ឬតាមទម្លាប់ថា ទស់សៈពិត--) ន. (បា. ទសវិធ + រាជធម្ម) រាជធម៌ ១០ យ៉ាង គឺធម៌ ១០ ប្រការ សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូចនិងពួករាស្ត្រប្រជាឱ្យប្រព្រឹត្តផង ។

ទសពិធរាជធម៌នោះគឺ ១-ទានៈ ការធ្វើអំណោយ; ២-សីលៈ ការរក្សាសីល ៥ជានិច្ច ឬរក្សាសីល ១០ មួយដងមួយកាល; ៣-បរិច្ចាគៈ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ; ៤-អាជ្ជវៈ មានសេចក្ដីត្រង់; ៥-មទ្ទវៈ មានសេចក្ដីទន់ភ្លន់ស្លូតសុភាពរាបសា; ៦-តបៈ ការកាន់ឧបោសថសីលតាមកាលកំណត់ម្ដងៗ (ម. ព. តបៈ ឬ តបះ ផង); ៧-អក្កោធៈ មិនកម្ដៅក្រហាយអ្នកដទៃ; ៨-អវិហឹសា មិនបៀតបៀនអ្នកដទៃ; ៩-ខន្តិ មានសេចក្ដីអត់ធន់; ១០-អវិរោធនៈ មិនបំពានលើធម៌លើច្បាប់ ។ ច្រើនប្រើកាត់ខ្លីត្រឹមតែ ទសពិធ ឬ ទសពិធធម៌ ។ ទសមុខ (ទៈសៈមុក, ឬ ត. ទ. ថា. ទស់មុខ) ន. ឬ គុ. (បា.) មុខ ១០; ដែលមានមុខ ១០ (ពពណ៌) : ព្រះបាទ
ទសមុខ (ក្នុងរឿងរាមកេរ្តិ៍) ។

**-ទីទុយ** ( ន. ) ឈ្មោះសត្វបក្សីរត្តិចរមួយប្រភេទ មានភ្នែកធំ មានរោមនៅក្បាលសណ្ឋានស្រដៀងនឹងស្នែង គេឱ្យឈ្មោះតាមសំឡេងដែលវាយំ ។ ស្នែងទីទុយ សក់កូនក្មេងតូចគេកោរទុកត្រង់ចំហៀងក្បាលខាងស្ដាំមួយ ខាងឆ្វេងមួយ ហៅថា កោរទុកស្នែងទីទុយ ។

**-ទម្លុះ** ( កិ. ) ធ្វើឱ្យធ្លុះពីម្ខាងទៅម្ខាង : ទម្លុះភ្លឺស្រែ, ខ្វងទម្លុះក្ដារ ។ ទម្លុះទម្លាយ ធ្វើឱ្យធ្លុះធ្លាយ (ឱ្យឃើញតាមការណ៍ពិត) ព. ប្រ. ។

**-ទីពោ** ( ន. ) ឈ្មោះត្រីរំអិលពួកត្រីប្រា, ច្រើនហៅក្លាយមកជា ត្រី
ពោ; មាន ២ ប្រភេទគឺ ត្រីពោព្រុយ, ត្រីពោខ្មៅត្រចៀក ។
កន្លង់ ( ន. ) ឈ្មោះសត្វល្អិតមួយប្រភេទ ចោះឈើ ឬ ឫស្សីឱ្យមានជារន្ធល្មមនៅបាន ហើយនៅអាស្រ័យក្នុងរន្ធនោះ, ចេះត្រឹបកេសរផ្កាដូចឃ្មុំ, ហើរឮសូរវ៉ូងៗ ។

**-ទុរេន** ( ន. ) ឈ្មោះឈើដំណាំមួយប្រភេទ ផ្លែមានឱជារសផ្អែម, សម្រាប់ប្រើជាបង្អែមមានតម្លៃ,

សំបកផ្លែមានបន្លារឹង; ក្នុងកម្ពុជរដ្ឋ ដាំកើតត្រង់ទីតំបន់ខ្លះដោយអន្លើ ។ ឈ្មោះស្វាយមួយប្រភេទផ្លែមានក្លិននិងឱជារសស្រដៀងនិងទុរេន : ស្វាយទុរេន ។

**-ទៀប** ( អា. និ. ) ជិត, ក្បែរ : ម៉ោង ៤ ទៀបភ្លឺ, ផ្ទះទៀបគ្នា ។

**-ទ្រនំ** ( ន. ) ទីដែលសត្វស្លាបតែងទំ : កុកហើររកទ្រនំ ។ (ព. ប្រ.) : ផ្ទះធំទ្រនំខ្ពស់ ដែលគេមានផ្ទះធំទូលំទូលាយមានទ្រព្យសម្រាប់ចាយវាយគ្រប់គ្រាន់ ។ គេបានទ្រនំខ្ពស់ គេបានភរិយាជាអ្នកមានទ្រព្យស្តុកស្តម្ភ ឥតព្រួយពីក្រទ័ល ។ គេមានទ្រនំរបស់គេ គេមានទីសម្នាក់ស្តុកស្តម្ភមិនព្រួយបារម្ភពីការលំបាក ។

**-ទ្រយឹង** ( ន. ) ឈ្មោះឈើមួយប្រភេទ ពួកឈើខ្មៅផ្លែទុំមានក្លិនក្រអូបឆ្ងាញ់ ប្រើជាចំណីបាន។

«**ធ**»

**-ធ្យាន** (ម. ព. ឈាន ន.)។ពាក្យនេះខ្មែរយើងប្រើជា កិ. ក៏មាន : ធ្យានទៅ គឺទៅដោយអំណាចធ្យាន; ហោះធ្យាន សំដៅសេចក្តីថា ទៅតាមអាកាសជាប្រឹចពីដោយអំណាចឬដោយឫទ្ធិនៃធ្យាន ។

«**ន**»

**-នាលិ** នាល បា.; សំ. ( ន. ) (នាឌិ "ទង; ឡូត; ឈ្មោះទម្ងន់ម្យ៉ាងដែលថ្លឹង...") ទម្ងន់ ១៦ តម្លឹង ។ រង្វាល់តូចមួយប្រភេទសម្រាប់វាល់អង្ករ ឬវាល់គ្រាប់អ្វីៗមានគ្រាប់សណ្តែកបាយជាដើម : អង្ករមួយនាឡិ (សរសេរជា នាល ឬ នាឡ ក៏មាន) ។ នាឡិ

**-និន្ទា** សំ. បា. ( ន. ) ដំណើរតិះដៀល, ការរិះគន់, ដំណៀល : មនុស្សក្នុងលោក ពុំអាចចៀសផុតអំពីនិន្ទាបានឡើយ ។ ឈ្មោះលោកធម៌ទី ៥ ក្នុងពួកលោកធម៌ទាំង ៨ (ម. ព. លោកធម៌ ក្នុងកាព្យ លោកទៀតផង) ។ ខ្មែរយើងប្រើជា កិ. ក៏មាន : កុំនិន្ទាគេ គឺកុំតិះដៀលគេ ។ និន្ទាឈ្នានីស និន្ទាផងច្រណែនឈ្នានីសផង ។

«**ប**»

**-បង្គោ** ( ន. ) ឈ្មោះឈើមួយប្រភេទ មានផ្លែបរិភោគបាន ។ (ព. កា. រាប់ឈើ) : បង្គោដុះជិតបង្គាមានទាំងដើមធ្នា ទ្រមូងសេកផង ។

**-បណ្ឌិត** ប័ន-ឌិត ឬ បន់-ឌិត បា. ( ន. ) ជនអ្នកមានប្រាជ្ញាឈ្មោះ
បណ្ឌា, ជនអ្នកប្រព្រឹត្តល្អគឺអ្នកកាន់សុចរិត ១០ ប្រការ, ឬដោយពិស្តារ, កាន់សុចរិត ៤០ ប្រការដោយខ្ជាប់ខ្ជួនឬគត់ចត់ជានិច្ច; អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌ (ព. ពុ.) ។ ព. ផ្ទ. ពាល ។ ពាក្យសាធារណ:ថា អ្នកមានចំណេះជ្រៅជ្រះ, អ្នកឈ្លាសវៃ, អ្នកប្រាជ្ញ ។ តាមទម្លាប់ខ្មែរក្នុងសម័យបុរាណដែលគេគោរពព្រះពុទ្ធសាសនាណាស់, សូម្បីគ្រហស្ថកំលោះដែលទើបសឹកចាកផ្នួសថ្មីៗ គេក៏ហៅអ្នកនោះថា បណ្ឌិត ដែរ, ហៅក្លាយមកថា បន្ទិត, ហៅក្លាយឃ្លាតមកថា អន្ទិត ព្រោះគេយល់ថា អ្នកនោះបានបួស មានការចេះដឹងមានចរិយាមារយាទត្រឹមត្រូវ...។ ពាក្យសន្មតប្រើតាមសម័យនិយម, ហៅអ្នកមានវិជ្ជាថ្នាក់ខ្ពស់ដែលមានសញ្ញាបត្រ ដុកតូរ៉ា (Doctorat) ថា បណ្ឌិត ដុកទ័រ (Docteur) តាមឈ្មោះនៃវិទ្យាសាស្ត្រនោះៗ ដូចជាវេជ្ជបណ្ឌិត,បណ្ឌិតខាងច្បាប់, បណ្ឌិតខាងវិទ្យាសាស្ត្រ..., បណ្ឌិតខាងអក្សរសាស្ត្រ ជាដើម...។

**-បញ្ញត្តិ** ប័ញ-ញ៉ាត់ បា.; សំ. ( ន. ) (ប្រជ្ញប្តិ) សេចក្តីហាមប្រាម, បម្រាម, សេចក្តីដែលគេតែងតាំង, រៀបចំ; ពាក្យដែលគេកំណត់ហៅ : មានបញ្ញត្តិ, ធ្វើខុសនឹងបញ្ញត្តិ ។ ពាក្យនេះច្រើនប្រើជាបទសមាស គឺរៀងឱ្យជាខាងចុងសព្ទឯទៀត ដូចជាពុទ្ធបញ្ញត្តិ, រាជបញ្ញត្តិ, បទេស បញ្ញត្តិ, បឋមបញ្ញត្តិ, នាម

បញ្ញត្តិ, វោហារបញ្ញត្តិ ជាដើម (បែបត្រឹមត្រូវតាមភាសាបាលី, កាលណាបើរួមជាបទសមាស រៀងជាខាងចុងសព្វងទៀតយ៉ាងនេះ, ត្រូវតម្រួត ប ជាពីរតួជា ពុទ្ធប្បញ្ញត្តិ, រាជប្បញ្ញត្តិ, បទេសប្បញ្ញត្តិ; បឋមប្បញ្ញត្តិ, នាមប្បញ្ញត្តិ, វោហារប្បញ្ញត្តិ) ។ ព. ផ្ទ. អនុញ្ញាត ។

**-បបែល** ( ន. ) ឈ្មោះមច្ឆជាតិពួកមួយមានរូបមូល នៅមាត់ខាងក្រោម មានជាយគ្រែងជុំវិញ កន្ទុយវែង ស្បែករឹងគគ្រាត, បើស្ងួតក្រៀម ប្រើការូសឈើបាន ។

**-បារមី** បារៈមី សំ. បា. ( ន. ) គុណជាតិដ៏ល្អដែលបុគ្គលគួរបំពេញ (ម. ព. ទសបារមី ផង) ។

**-បាសក** បាសក់ ( ន. ) គ្រហស្ថ; ពាក្យដើមជា ឧបាសក, គេកាត់តួ ឧ ចេញហៅថា អាទិលោប(លុបអក្សរខាងដើម) : ពួកបាសកជើងវត្ត, បាសកទាយក (ម. ព. ឧបាសក) ។ ព. ផ្ទ. បព្វជិត, អ្នកបួស ។

**-ប៉ី**( ន. ) ឈ្មោះគ្រឿងភ្លេងផ្លុំពួកមួយ មានបែបផ្សេងៗ។ប៉ីកែវ ឈ្មោះភ្លេងខ្មែរមួយមេ : ភ្លេងប៉ីកែង ។ ប៉ីបបុស ឈ្មោះប៉ីមួយបែប មានបបុសជាអណ្ដាត (ស. ប៉ីអ្វ៥ អ. ថ. ពីអ "ប៉ីបបុស") អ្នកភ្លេងខ្មែរច្រើនហៅ ប៉ីអ ដែរ។ប៉ីពក ប៉ីធ្វើដោយដើមពកមានសូរសព្ទធំក្រអួន សម្រាប់ផ្លុំប្រគុំ ។

**-បាវព្រាវ** ( ន. ) មនុស្សអ្នកខ្សត់ខ្សោយទន់ទាបឥតមានទីពំនាក់ ដែលចូលមកសុំជ្រកអាស្រ័យនៅផង,ជាអ្នកធ្វើកិច្ចការបម្រើដូចបាវ, សម្រេចការបរិភោគនិងការដេកនៅជាមួយនឹងបាវ (សម័យសព្វថ្ងៃនេះ ឈប់ប្រើពាក្យ បាវព្រាវ នេះហើយ) ។

**-ប្រប** ( និ. ) ទៀប, ជិត, ក្បែរ : ប្របផ្លូវ, ប្របខ្លួន ។ កិ. អែប, អែបអប, ផ្គាប់ផ្គុន ដោយអែបអបឱ្យត្រូវចិត្ត : មនុស្សនោះប៉ិនប្របណាស់ ។ (ព. ទ. បុ.) : មនុស្សប្របមានរបបតែខាងបញ្ចោរលើកជើង ។ ប្រាជ្ញពុំស្មើប្រប ទន់ស្លឹកត្រចៀកខ្លប ពុំស្មើឡេមឡឺម មានអត្ថន័យថា អ្នកប្រាជ្ញមិនចេះប្រប គឺមិនមានការប្រាស្រ័យនឹងអ្នកធំ ទោះស្លូតសុភាពយ៉ាងណាក្ដី ក៏ពុំស្មើនឹងអ្នកខ្លៅដែលគេជាមនុស្សជិតដិតនឹងអ្នកធំឡើយ (ម. ព. ប្រយោគសម្បត្តិ ផង) ។

**-ប្រមាទ** --ម៉ាត សំ.; បា. ( ន. ) (បមាទ) ការភ្លេចស្មារតី, ធ្វេសស្មារតី, សេចក្ដីប្រហែស,ការប្រហែសធ្វេស។ កិ. ភ្លេច, ធ្វេស,ប្រហែស ស្មារតី : ជនណាប្រមាទប្រព្រឹត្តឃ្លៀងឃ្លាត ចាកធម៌សុចរិត ជននោះទោះបី នៅមាន។

**-ប្រា** ( ន. ) ឈ្មោះត្រីរំពលមួយប្រភេទ ពួកត្រីទីពោ : ត្រីប្រា, ងៀតប្រា ។

**-ប្រុះ** ( គុ. ឬ កិ. វិ. ) ព្រោងព្រាយ, ដែលភ្លឺចម្រុះគ្នា : ពន្លឺប្រុះ; ភ្លឺប្រុះ (ព. កា.) : សេពគប់ប្រាជ្ញប្រុះប្រាជ្ញនាំឆ្លុះ ឃើញក្ដីខុសត្រូវ សេពគប់ជនពាល វង្វេងវាលខុសផ្លូវ នាំឱ្យអាស្រូវ បង់កេរ្ដិ៍បង់ឈ្មោះ ។

«ផ»

**-ផ្ដៅ** ជើង ដ (ន. )ឈ្មោះវល្លិដើមរឹងមួយប្រភេទមានបន្លានៅស្រទប, ធាង, ស្លឹក (ទីទៃពីរពាក់); ផ្ដៅមានឈ្មោះច្រើនប្រភេទគឺ ផ្ដៅទឹក, ផ្ដៅក្រែក, ផ្ដៅឈ្មាំង, ផ្ដៅអារ៉េច, ផ្ដៅដំបង, ព្រះផ្ដៅ..., ជាវល្លិមានប្រយោជន៍យ៉ាងសំខាន់ ប្រើការបានច្រើនយ៉ាង មានប្រើធ្វើចំណងនិងធ្វើកៅអីជាដើម ។

**-ផ្ទក់** ( ន. ) ឈ្មោះត្រីស្រកាមួយប្រភេទ សន្ដានត្រីរស់ប៉ុន្តែរូបតូច : ត្រីផ្ទក់ ។

**-ផ្សោត** ( ន. ) ឈ្មោះមច្ឆជាតិមួយប្រភេទឥតស្រកា ខ្លួនធំ មានដោះសណ្ឋានស្រដៀងនឹងដោះមនុស្ស : ផ្សោតងើបព្រួសទឹកផែតៗ ។

«ព»

**-ពង្រ** ពង់-រ ( ន. ) ឈ្មោះឈើធំមួយប្រភេទ មានសាច់រឹង មានផ្លែ
ប្រើជាម្ជូរ : ផ្លែពង្រខ្លះមិនសូវជូរប៉ុន្មាន ខ្លះជូរណាស់ ។

**-ពង្សាវតារ** ពង់-សាវ៉ៈដា បា.; សំ. ( ន. ) (វំស; វំគ + អវតារ "ដំណើរ
ឆ្លងចុះ, ការឃ្លាតនៃវង្សត្រកូល") រឿងរ៉ាវតាមលំដាប់នៃវង្សត្រកូល,ប្រវត្តិដែលឆ្លងពីសង្កាត់មួយមកសង្កាត់មួយ, ដំណើរសេចក្ដីសម្ដែងអំពីតំណនៃវង្សត្រកូល:ពង្សាវតារកម្ពុជរដ្ឋ; ពង្សាវតារលោក ។ (ព. សា.) លុប ពង់ ចេញនៅត្រឹមតែ សាវតារ និយាយក្លាយមកទៀតជា សៅវតារ ។

**-ពពូល** ( ន. ) ឈ្មោះសត្វស្លាបមួយប្រភេទ រូបស្រដៀងនឹងព្រាប តែតូចជាងបន្តិច សម្បុរបៃតងប្រផេះ មានផ្លែឈើជាចំណី : ពពូលមួយហ្វូងស៊ីផ្លែជ្រៃ ។

**-ពពេច** ( ន. ) ឈ្មោះសត្វស្លាបមាឧតូចមួយប្រភេទ ពួកចាប មាន
សម្ដីច្រើន និយាយចេចចាចៗមិនសូវស្រាក ។ (ព. កា.) : ពពេចទុំមែកពពូល
ថ្ម កុកសហើរព្រាតលើបឹងធំ ត្រយងយំថ្ងូរសូររងំ វាទំលើមែកពពូលទឹក ។

**-ពិស្ដារ** ជើង ដ, ច្រ. និ. ពឹស-ស្ដា សំ. ; បា. ( ន. ) (វិស្ដារ; វិត្ថារ) សេចក្ដីទូលាយ, សេចក្ដីវែង; ដំណើរយឺតយូរ : និយាយដោយពិស្ដារ ។ ខ្មែរប្រើជាឈ្មោះធម៌ព្រះអភិធម្មបិដកនិងអដ្ឋកថាព្រះអភិធម្មយកមករួបរួមចារឹកទុកក្នុងភាណវារបាលីសម្រាប់ព្រះភិក្ខុសង្ឃសូត្រដារ ជាធម៌វែងជាង សត្តប្បករណ៍ ឬ សប្តប្រករណ៍ : និមន្តលោកសូត្រពិស្ដារ ។ ប្រើជា គុ. ឬ កិ. វិ. ក៏បាន : សេចក្ដីពិស្ដារ គឺសេចក្ដីវែង ឬទូលាយ; និយាយពិស្ដារ គឺនិយាយ
រៀបរាប់ដោយសព្វគ្រប់ ។ ព. ផ្ទ. សង្ខេប ។

**-ពិភាល់** ( កិ. ) ចាប់មន្ទិល, ភ្ញាក់គិតព្រួយដោយចាប់មន្ទិល:ពិភាល់ក្នុងចិត្ត។ ប្រើជា ន. ក៏បាន : មានពិភាល់, កើតពិភាល់, ចាប់ពិភាល់ ។ពីភាល់ ។

**-ពុទ្ធដីកា** ន. ព្រះបន្ទូលព្រះពុទ្ធ, សំដៅចំពោះពុទ្ធវចនៈ គឺ បាលី ដែល
ជាគោលដើមនៃព្រះពុទ្ធសាសនា : អដ្ឋកថាកែព្រះពុទ្ធដីកា ។ ខ្មែរប្រើក្លាយៗមកហៅថា ពុទ្ធដីកាដែរ គឺហៅដោយគោរពថាបព្វជិតនិយាយស្ដីតែពាក្យពិត តាមលំអានពុទ្ធវចនៈប្រយ័ត្នមិនហ៊ានឱ្យល្មៀងៈលោកគ្រូមានពុទ្ធដីកា,ស្ដាប់ព្រះពុទ្ធដីកាលោក។

**-ព្រមាន** ( កិ. ) ប្រាប់, រំឭក, ឱ្យដំណឹងជាមុន ឱ្យដឹងថាអ្នកម្ខាងមានដំណើរភ្លាំងភ្លាត់ ឬប្រព្រឹត្ត
ល្មើស ច្រឡើសលើស, ដូចយ៉ាងគោចូលលុកលុយក្នុងចម្ការដំណាំគេៗឱ្យដំណឹងដល់ម្ចាស់គោឱ្យប្រយ័ត្នតទៅជាដើម : កូនគាត់ចេះតែវាយកូនខ្ញុំៗបានព្រមានគាត់ពីរដងហើយ...។

**-ញ្ញា** ( ន. ) ឈ្មោះឈើពួកមួយ ស្លឹកហាងប្រហើរ, ត្រួយឬស្លឹកខ្ចីប្រើធ្វើជាអន្លក់របោយបាន (បរិភោគទៅនាំឱ្យផាយខ្យល់ស្រួលខ្លួន), ផ្លែមានជ័រស្អិតនៅរុំគ្រាប់ កាលនៅខ្ចីមានរសហាងលុះដល់ទុំឡើងសម្បុរលឿងមានក្លិនក្រអូបឈ្ងុយ មានសាច់ម៉ដ្ឋ, ប្រើជាចំណីឬជាថ្នាំកែរោគប្រជិតជាដើម; ញ្ញាមាន

ច្រើនប្រភេទផ្សេងៗគ្នាមាន ញ្ញៅពងមាន់, ញ្ញៅសណ្ដាយ ជាដើម។

**-ព្រលឹត** ( ន. ) ឈ្មោះឧប្បលពួកមួយដុះក្នុងទឹក លូតតាមទឹក, មានដើមមូលត្រសូល, ប្រើធ្វើជាបន្លែឬអន្លក់បាន; ព្រលឹតមានច្រើនប្រភេទ ខ្លះដើមស្រួយ, ខ្លះដើមស្វិត, ខ្លះផ្កា-ស, ខ្លះផ្កាលឿង ។ល។ ឈ្មោះពស់ឥតពិស

មួយប្រភេទកើតនៅក្នុងទឹក : ពស់ព្រលឹត ។ ព្រលិត

**-ព្រួស** ( ន. ) ឈ្មោះឈើព្រៃមួយប្រភេទ ពួកទ្រមូងមានផ្លែប្រើជាអាហារបាន:ផ្លែព្រួស ។

**ព្រួល**(ន.) ឈ្មោះត្រីស្រកាមួយប្រភេទ មានសម្បុរស : ត្រីព្រួល, ព្រួលកន្លង់, ព្រួលខ្មៅមុខ ឬ ព្រួលកោង ។

**-ព្រេច** ( ន. ) ឈ្មោះឫស្សីពួកមួយ ដើមតូចៗស្លឹកល្អិតៗច្រើនដុះតាមដងព្រៃ:គុម្ពព្រេច, របះព្រេច; កាត់ព្រេចធ្វើអំបោស

«**ភ**»

**-ភិក្ខុ** ភិក-ខុ ឬ ភិក បា.; សំ. ( ន. ) (ភក្សុ) សមណអ្នកសូម, សមណៈអ្នកខ្លាចភ័យក្នុងវដ្តសង្សារ,អ្នកខ្លាចបាបជានិច្ច,អ្នកមានព្យាយាមដុតបំផ្លាញអំពើអាក្រក់...។ខាងពុទ្ធសាសនា ហៅចំពោះតែបុរសអ្នកបួសដែលមានភេទឧត្តមជាងសាមណេរ : ភិក្ខុច្រើនរូប, បួសភិក្ខុ, លោកភិក្ខុ ។ ភិក្ខុភាព, ភោក្ខុភាវ ឬ ភិក្ខុភាវៈ ដំណើរបានទទួលឧបសម្បទាជាភិក្ខុ គឺការបានភេទជាលោកភិក្ខុ ។ ភិក្ខុសង្ឃ ប្រជុំភិក្ខុច្រើនតាំងពី ៤ រូបឡើងទៅ ។

**-ភ្នំភ្លើង** ( ន. ) ឈ្មោះឈើរនាមមួយប្រភេទដើមតូចៗសាច់រឹងសម្បុរក្រហម ប្រើធ្វើជាឧស, ផ្លែសំប៉ែតៗ ទំហំប្រមាណប៉ុនៗមេដៃ មានរសជូរ ប្រើធ្វើជាម្ជូរស្លបាន ។

**-ភ្លង** ( ន. ) ឈ្មោះឈើព្រៃមួយប្រភេទ មានសាច់រឹងស្វិត្វ, មាន ២ ប្រភេទគឺភ្លងជូរ ស្លឹកជូរបន្តិចៗប្រើស្ងោរលាងសំពត់បាន;ភ្លងក្អែកស្លឹកធំៗក្រាស់ៗជាងភ្លងជូរ ។

**-ភ្លាំង** ( ន. ) ឈ្មោះឈើតូចមួយប្រភេទ ដើមតូចៗទាបៗ ផ្លែតូចៗ មូលៗជាចង្កោមៗ ផ្លែទុំមានសម្បុរស-រលោង ។ ផ្លែភ្លាំង ឈ្មោះអុតមួយប្រភេទ ឡើងដោរត្រឡុងៗស្រដៀងនឹងផ្លែភ្លាំងទុំ : អុតផ្លែភ្លាំង ឬហៅដោយបញ្ចៀសថា ផ្កាឈើផ្លែភ្លាំង ។ ឈ្មោះស្បូវមួយប្រភេទ ស្លឹកធំៗជាងស្បូវរណ្ដាសសម្រាប់ប្រើការដេរប្រក់ផ្ទះ ឬធ្វើជាចំណងកណ្ដាប់សំណាបជាដើម : ស្បូវភ្លាំង; ដកស្បូវភ្លាំងចងកណ្ដាប់ ។

**-ភ្លូ** ( ន. ) រុក្ខជាតិមួយប្រភេទ ស្លឹកមានមមីសគ្រើមៗផ្លែមានសណ្ឋានមូលមានគ្របកជាស្រទាប់ៗ រុំជុំវិញបណ្ដូល មានរសជាតិជូរបរិភោគបាន; ភ្លូមានពីរប្រភេទគឺ ភ្លូធំ, ភ្លូបាត ។ ពាក្យបណ្ដៅលេងថា:មួយត្របកបីមួយត្របកបួនបកៗផ្លេចខ្លួនដល់ដន្លាប់ខាងក្នុង(តើគឺអ្វី?--គឺផ្លែភ្លូ។ ត្រូវហើយ !) ។

«**ម**»

**-មានៈ** សំ. បា. ; ឬ សំ. ( ន. ) (មាន; មានសិ > មានះ) សេចក្ដីប្រកាន់, ដំណើរប្រកាន់ខ្លួន, សេចក្ដីរឹងត្អឹង : មានមានៈ ។ ខ្មែរប្រើជា គុ. ក៏បាន : មនុស្សមានៈ គឺមនុស្សមុខរឹង, ចចេស ។ ប្រើជា កិ. ក៏

មាន : កុំមានះពេក ! (កុំប្រកាន់ពេក ! កុំរឹងត្អឹងពេក !) ។ ព. ពុ. ថា : មានះមាន ៣ យ៉ាងគឺ ១ ប្រកាន់មាំស៊ុបថា មានតែអញឯងជាអ្នកប្រសើរជាងគេ, ក៏មើលងាយគេឥតជឿស្ដាប់គោរពអ្នកណា; ២- ប្រកាន់មាំស៊ប់ថា គេនិងអញស្មើៗតែគ្នា គេម៉េចអញម៉េច ប្រហែលតែគ្នា, ក៏ឥតមានការសេពគប់រាប់រកយកគេជាគ្នា; ៣- ប្រកាន់មាំស៊ប់ថា អញឯងជាអ្នកទន់ខ្សោយថយថោកជាងគេ, គេដោយគេ អញដោយអញ, ក៏ឥតមានការប្រាស្រ័យនឹងគ្នា, (ព្រោះមានះនេះ)...។
មានះទាំងនេះ ជាប្រភពឬជាមូលដ្ឋាននៃសាមគ្គីភេទ...។

**-មាក់បាត** ( ន. ) ឈ្មោះឈើដំណាំមួយប្រភេទ ក្នុងពួកទៀប ស្លឹកទ្រវែងស្រួច ក្លិន

ក្រពុល ជាឈើធំខ្ពស់ជាងទៀបបារាំង ផ្លែធំប៉ុនផ្លែញ៉ៅ ប៉ុន្តែរាងទ្រវែងជមខាងចុង សំបករលីងវេលាទុំឡើងសម្បុរក្រហម សាច់ជ្រាយ
មានរសផ្អែម ប្រើបរិភោគជាអាហារ (អ្នកស្រុកខ្លះហៅ តុង) ។

**-ម៉ឺន** ស. ( ប. សំ. ) ចំនួនសំខ្យាដប់ពាន់ (១០.០០០) ។ ន. បណ្ដាស័ក្តិមន្ត្រីមុនទីឃុន (រាប់តាមលំដាប់បណ្ដាស័ក្តិពីថ្នាក់ក្រោមបំផុតឡើងរៀងទៅថ្នាក់លើថា : ម៉ឺន ឬ ហ្មឺន, ឃុន, ហ្លួង, ព្រះ, ឧកញ៉ា), តាមបវេណីរាជ្យក្នុងកម្ពុជរដ្ឋពីកាលជាន់បុរាណ, កូនប្រុសរបស់សេនាបតីឬរបស់ស្ដេចត្រាញ់ ត្រូវហៅម៉ឺនតាំងពីនៅជាកុមារតូចពុំចាំបាច់តាំងឡើយ(បើកូនស្រី ហៅ អ្នកនាង) ។ ហ្មឺន

**-មៀន** ( ន. ) ឈ្មោះឈើមួយប្រភេទ ជាដំណាំស្រុកផ្លែមូលៗ ទំហំខ្នាតមេដៃ វេលាទុំមានក្លិនសាច់ក្រអូប មានរសផ្អែមប្រើជាបង្អែម : បបរមៀន (បបរដែលលាយសាច់ផ្លែមៀន) ។ មៀនព្រៃ ឈ្មោះឈើមួយប្រភេទស្លឹកធំជាងមៀនតែផ្លែតូចជាង សាច់ស្ដើង ក្លិនក្រអូបស្រដៀងនឹងមៀនដែរ ។

**-មៀម** ( ន. ) ឈ្មោះសត្វស្លាបវត្តិចរមួយប្រភេទ ពួកទីទុយ តែមាឌតូចជាង, ក្បាលនិងភ្នែកធំមិនសមនឹងរូប ។

**-មេត្រី** សំ.; បា. ( ន. ) (មៃត្រី; មេត្តិ) សេចក្ដីរាប់រក, សេចក្ដីរាប់អាន, ប្រណី វេវ. មេត្តា ។

មេត្រីចិត្ត ចិត្តដែលប្រកបដោយមេត្រី :មានមេត្រីចិត្តរកគ្នា។មេត្រីភាពភាពមានមេត្រីរកគ្នា ។ល។

**-មោហះ** សំ. បា. ( ន. ) (មោហា) អវិជ្ជា, សេចក្ដីវង្វេង, សេចក្ដីល្ងង់ ឬភ័ន្តស្មារតីមិនយល់ការណ៍ពិត, មិនស្គាល់ខុសត្រូវ ។ និយាយថា មោហ៍ ឬ មោហា ក៏មាន : មោហ៍គ្រប, មោហ៍បាំង, មោហោគ្របគឹងងឹតវិងស៊ុងភ្លេចស្មារតីភ័ន្តច្រឡំ ពុំយល់ការខុសត្រូវបណ្ដាលឱ្យធ្វើអំពើអាក្រក់ឥតញញើត ។ មោហចិត្ត (មោហៈចិត) ចិត្តដែលលាយឡំដោយមោហៈ, ចិត្តងងឹតល្ងង់ ។ មោហប្រព័ន្ធន៍ (មោហ៍ប-ប្រព័ន) ចំណងមោហៈ, មោហៈដែលចងឆ្វាក់; អ្នកដែលមានមោហៈចងឆ្វាក់ ។ មោហមូល (មោហៈ--) មោហៈដែលជាឫសអកុសល ។ល

**-ម្យៀត** ( ន. ) ប្រយោជន៍, សេចក្ដីកើតការ : មានម្យៀត ។ ចោល
ម្យៀត មិនកើតការ, មិនបានការ, ប្រើការមិនកើត : មនុស្សចោលម្យៀត, របស់ចោលម្រៀត។ បង់ម្យៀត បង់ប្រយោជន៍, អសារឥតការ, ដែលគួរតែចោល : ខូចបង់ម្យៀត (ម. ព. បង់សៀត ផង) ។

«**រ**»

**-រកា** ( ន. )ឈ្មោះឈើព្រៃមួយប្រភេទ សន្ដាននឹងគដើមមានបន្លាធំៗរង្វើលៗផ្លែតូចៗខ្ចីៗ ជាង

ផ្លែគ មានប៉ុយសាច់ម៉ដ្ឋត្រសុសសម្បុរសស្រអាប់ : ប៉ុយរកា ។

**-រ័ស់** ( ន. ) ត្រីស្រកាមួយប្រភេទ ខ្លួនមូលវែង សម្បុរក្រមៅ, ជាពួកត្រីឆ្ដោ : ត្រីរ៉ស់, ងៀតរ៉ស់ ។

**-រាក់**( ន. ) ឈ្មោះឈើតូច ស្លឹកក្រាស់សម្បុរ-សប្រផេះ ដែលយ៉ាងធំប៉ុនៗបាតដៃ មានជ័រស, មាន ២ ប្រភេទគឺ រាក់ស ផ្កាសម្បុរ-ស, រាក់ក្រហម ផ្កាសម្បុរស្វាយស្រគាំ; ផ្ការាក់ទាំង ២ យ៉ាងនេះមានក្លិនក្រអូបសាយក្រពុលបន្តិចៗ ជនានុជនរាប់អាន ច្រើនដោតក្រងជាផ្លូងមាលា ឬប្រើក្នុងវេលាថ្វាយបង្គំទទួលឋានន្តរ (ថ្វាយបង្គំងារ)។

**-រាជ** (រាច) ( ន. ) ត្រីឥតស្រកាមួយប្រភេទសន្តានត្រីប្រាតែធំជាងត្រីទន្លេទាំងអស់ រាប់ថាជាស្ដេចត្រីក្នុងទន្លេ : ត្រីរាជជាមច្ឆជាតិមានមាឌធំជាងត្រីទាំងអស់ក្នុងទន្លេ ។

**-រាហូ** -ហ៊ូ ( ន. ) ត្រីឆ្ដោដែលធំអស់កំណត់ហើយ; ត្រីនេះ កាលនៅតូចហៅ ត្រីដៀប, ដល់ធំយ៉ាងអណ្ដាលហៅ ត្រីឆ្ដោ, លុះធំអស់ទំហំហើយហៅ ត្រីរាហូ ។

**-រាំង**( ន. ) ឈ្មោះឈើ, មាន ២ ប្រភេទគឺ រាំងភ្នំ ឈើធំមួយប្រភេទ ដុះក្នុងព្រៃភ្នំឬព្រៃទួលធំៗ ជាឈើមានខ្លឹមជាប់ធន់បានយូរ សម្រាប់ប្រើការធ្វើគ្រឿងគ្រឹហា, ជាគូគ្នានឹងធ្នឹក, គេច្រើននិយាយថា ធ្នឹករាំង គឺធ្នឹក និងរាំងភ្នំ; រាំងអន្លក់ ឈើរនាមមួយប្រភេទ ស្លឹកខ្ចីប្រើជាអន្លក់ឬរបោយ មានរសចត់ : អន្លក់រាំង, របោយត្រួយរាំង ។

«ល»

**-លលក** ( ន. ) ឈ្មោះបក្សីមួយប្រភេទ ពួកទទា, ឈ្មោលចេះរងាវ ។ លលកទ្រោល លលកឈ្មោលក្លារងាវខ្វរ ។ លលកបរ លលកឈ្មោលដើរដំណើរក្រទា ពង់កធ្វើជីកងាកៗ បញ្ចេញសូរសព្ទរនញាប់រន្ថាន់ កៀងញីឬអួតជល់គ្នា ។ លលកបូល លលកបញ្ចេញសំឡេងឯកសព្ទផ្ទួនពីរៗស្រាលៗ រងើ្វលៗ ។

**-លង្វែក**( ន. ) ឈ្មោះខែត្រមួយក្នុងកម្ពុជរដ្ឋពីសម័យបុរាណ, តមក តាំងជាស្រុកហៅថា ស្រុកលង្វែក នៅក្នុងខែត្រកំពង់ឆ្នាំង, លុះចំណេរតមកក្រោយទៀត ដាក់ទៅជា ស្រុកកំពង់ត្រឡាចវិញ នៅក្នុងខែត្រដដែល ដរាបដល់សព្វថ្ងៃ។ ឈ្មោះបន្ទាយមួយជារាជធានីចាស់របស់កម្ពុជរដ្ឋ, បិតនៅខាងទិសឦសាននៃបន្ទាយឧដុង្គមានជ័យ : បន្ទាយលង្វែក; សព្វថ្ងៃនេះ ត្រង់បន្ទាយចាស់នោះ រាជរដ្ឋាភិបាលបានតាំងជាបន្ទាយខេមរភូមិន្ទ មិនឱ្យបាត់ដំណែលចាស់ ។

**-លៃបខាយ** ( គុ. ឬ កិ. វិ. )ដែលចេញម៉េតប្រាយ : សម្ដីលៃបខាយ; និយាយលៃបខាយ ។ មនុស្សលៃបខាយ មនុស្សដែលច្រើនប្រើសម្ដីម៉េតប្រាយ ។ ឡៃបខាយ

**-លាំងសាត** ស. ( ន. ) (លាងសាត អ. ថ. ល៉ាង--) ឈ្មោះឈើមួយប្រភេទ ផ្លែជាប់គ្នារដឹកចេញពីស្នែងសំបកផ្លែស្តើងសម្បុរ-សសាច់ជាក្លែបៗដូចបង្គោ តែជ្រាយបន្តិចជាងបង្គោ មានរសផ្អែមលាយជូរបន្តិចៗ, បរិភោគបាន, គ្រាប់មានរសល្វីង ។

**-លាំងជ័យ** ( ន. )ឈ្មោះឈើ, មានពីរប្រភេទគឺ មួយប្រភេទស្លឹកតូចៗ ជាសំណុំៗ, មួយប្រភេទទៀតស្លឹកធំៗរាយៗ, ច្រើនកើតមានដង្កូវដូងស៊ីដើមចេញជ័រជ្រាយគគុល, ដង្កូវដូងនោះហៅថា ដូងលាំងជ័យ ។ លាំងដៃ

**-ល្មុត** ស. ( ន. ) (លះមុត អ. ថ. ល៉ះមុត) ឈ្មោះឈើដំណាំ ប្រើផ្លែទុំជាអាហារ, មានពីរប្រភេទ គឺ ល្មុតសែដា ផ្លែថ្លោសៗមានច្រើនបែប; ល្មុតខ្មែរ (ស. លះមុតសីដា ឬ លះមុតទៃយ អ. ថ. ល៉ះមុតស៊ីដា ឬ --ថៃ "ល្មុតសៀម") ដើមធំស្លឹករង្វើលៗ ផ្លែសណ្ឋានស្រដៀងនឹងផ្លែពុលតែធំជាង វេលាទុំជោរឡើង សម្បុរក្រហមក្រមៅសាច់ផុសៗបន្តិច មានរសផ្អែមស្រាល ច្រើនមានគ្រាប់តែមួយៗ; ល្មុតបារាំង ឬ ល្មុតទេស ដើមតូចជាងល្មុតសែដា ស្លឹកញឹកជិត ផ្លែមានច្រើនបែបខ្លះរាងមូល សាច់ស, ខ្លះរាងទ្រវែងសាច់ក្រហមស្ទើរ, ផ្លែធំៗប៉ុនស៊ុតមាន់ឬស៊ុតទាក៏មាន ទ្រើសជាងនុះក៏មាន តូចៗចុះពីនុះមកក៏មាន, ផ្លែទុំសាច់ជ្រាយមានរសផ្អែមឈ្ងុយ (បែបដែលមានផ្លែរាងទ្រវែងសាច់ស្ទើរក្រហមនោះ អ្នកស្រុកខ្លះច្រឡំហៅថាសែដា ក៏មាន) ។

**-ល្វក់** ( គុ. ) ដែលនៅខ្ចីណាស់ : ត្រួយឈើខ្ចីល្វក់ ។

«**វ**»

**-វន្ទា** វ័ន-ទា បា. ( កិ. ) (វន្ទ) ថ្វាយបង្គំ, សំពះ, គំនាប់ (ព. កា.) : សូមថ្វាយវន្ទា ឆ្ពោះព្រះភគវា សម្មាសម្ពុទ្ធ អង្គព្រះអរហន្ត ព្រះទ័យបរិសុទ្ធប្រសើរបំផុតឥតមានប្រៀបបាន ។

«**ស**»

**-សក្តិ** ស័ក សំ.; បា. ( ន. ) (គក្តិ; សត្តិ) អំណាច, សេចក្តីអង់អាច, សេចក្តីក្លាហាន; កម្លាំង; ព្យាយាមរឹងប៉ឹង; ការខ្លាំងពូកែ; ការជំនាញ; សេចក្តីធន់, ការប៉ិនធន់ទ្រាំ; លំពែង : អ្នកមានស័ក្តិ, ស័ក្តិតូច, ស័ក្តិធំ, ស័ក្តិស្មើគ្នា ។ ឥស្សរិយាភរណៈដែលប៉ាក់ដោយចេសមាសឬចេសប្រាក់ជាដើម សម្រាប់ដាក់ភ្ជាប់នឹងអាវរបស់មន្ត្រី សម្គាល់ឱ្យដឹងថ្នាក់ធំតូច: ពាក់ស័ក្តិ, ស័ក្តិមាស, ស័ក្តិប្រាក់; ស័ក្តិ១, ស័ក្តិ២,... ។ សក្តិត្រ័យ (ស័ក-ក្តិ-ត្រៃ) ប្រជុំ ៣ នៃស័ក្តិ ឬអង្គ៣ នៃរាជស័ក្តិ គឺ ព្រះរាជា, អមាត្យ ឬ មន្ត្រី, ពលស័ក្តិ (ពលរដ្ឋដែលមានកេរ្តិ៍ឈ្មោះ) ។ សក្តិធរ (ស័ក-ក្តិ-ធ) អ្នកទ្រទ្រង់ស័ក្តិ (អ្នកមានស័ក្តិ); អ្នកកាន់រំពែង ។ ស័ក្តិ ៩ ហ៊្មឺពាន់ (ម. ព. ហ៊្មឺពាន់) ។ ស័ក្តិយស (--យស់) អំណាចនិងបរិវារ, ទ្រព្យសម្បត្តិ, កេរ្តិ៍ឈ្មោះល្អ, សេចក្តីរាប់អាននៃអ្នកដទៃ (និយាយថា យសស័ក្តិ ក៏បាន "បរិវារនិងអំណាច" ឬ "អំណាចលើបរិវារ") ។ ស័ក្តិសម (--សំ) សមដោយអំណាច ។ សមស័ក្តិ (សំ--) អំណាចដ៏សមរម្យ ឬអំណាចស្មើគ្នា ។ ព. បុ. ថា: ស័ក្តិពុំស្មើយស នាអ្នកខ្ពង់ខ្ពស់ ពុំស្មើចិត្តជា ។ល។ ស័ក្តិ

**-សង្កែ** ( ន. ) ឈ្មោះឈើអសារជាតិមួយប្រភេទ សាច់សរឹង, អ្នកស្រុកកណ្តាលស្ទឹងពេញចិត្តដាំតាមភ្លឺស្រែ, ជ្រុះស្លឹកមកនាំឱ្យដីស្រែចម្រើនជាតិល្អ, ជាឈើងាយកើត ទោះកាប់ក្របែលដើមទុកឱ្យនៅតែគល់ ក៏អាចចាប់ដុះជាលំពង់លូតលាស់ចម្រើនឡើងទៀតបាន, គេប្រើការបន្ទំល័ក្តក៏បាន ធ្វើជាឧសដុតក៏បាន ស្លឹកប្រើការមូរបារីក៏បាន, ជាឈើមានប្រយោជន៍ គួរប្រជាពលរដ្ឋគ្រប់ស្រុកពេញចិត្តដាំតាមភ្លឺស្រែរាល់គ្នា ឬដាំធ្វើជារបងភូមិរបងចម្ការផងក៏ស្រួលណាស់, បើឧស្សាហ៍កាប់កាត់សម្រួលរឿយៗ មិនចម្រើនម្លប់ដល់ទៅបោកស្រូវ ឬបោកដំណាំឱ្យអន់ឡើយ ។

**-សង្ឃ័រ** ( ន. ) ឈើតូចមួយប្រភេទ មានបន្លាខុបៗ ផ្លែតូចៗវេលាទុំ ឡើងសម្បុរក្រមៅ មានរសជូរអែម បរិភោគបាន : ផ្លែសង្ឃ័រទុំ គេអាចទុកបានយូរថ្ងៃ ។

**-សណ្តាន់** ស. ( ន. ) (មះដ័ន អ. ថ. ម៉ៈដាន់) ឈើរនាមមួយប្រភេទ ស្លឹកនិងផ្លែមានរសជូរ

សម្រាប់ប្រើធ្វើជាម្ហូរស្ល ឬផ្លែដែលចិតហាលឱ្យក្រៀមប្រើជាម្ហូរជ្រក់ក៏បាន:សម្លស្លឹកសណ្ដាន់, សម្លម្ហូរសណ្ដាន់, បង្កងស្ងោរជ្រក់ម្ហូរសណ្ដាន់ក្រៀម។មានពាក្យទំនៀមចាស់ថាស្លត្រីប្រាកុំចោលម្ហូរសណ្ដាន់ ។

**-សណ្ដាយ** ( ន. ) ឈ្មោះត្រីឥតស្រកាមួយប្រភេទ ខ្លួនវែង រាងសំប៉ែតរង្វះមាត់ធំ : ត្រីសណ្ដាយ។ ឈ្មោះគ្រាប់មួយប្រភេទ ផ្លែធំរាងមូលទ្រវែង ប្រើការជាបន្លែ, ជាអន្លក់ : គ្រាប់សណ្ដាយ (អ្នកស្រុកខ្លះហៅគ្រាប់វែង)។ ញ្ញាសណ្ដាយ (ម. ព. សណ្ដាយ ១ គុ.) ។

**-សន្ធោ** ( គុ. ឬ កិ. វិ. ) ដែលភ្លឺឆ្លោឡើង, ដែលភ្លឺរុងរឿងខ្លាំង : ភ្លឺសន្ធោ, ភ្លើងឆេះសន្ធោ ។ ដែលហ៊ឹកហ៊ាក់អង់អាច, គគាត : ឫកសន្ធោ, ដំណើរសន្ធោ ។ សន្ធោសន្ធៅ សន្ធោឆ្លោឡើងខ្លាំង, ភ្លឺសន្ធោខ្លាំង : ភ្លើងឆេះសន្ធោសន្ធៅ ។

**-សត្យា** ស័ត-ត្យា សំ. ( ន. ) ពាក្យស័ត្យ : មានសត្យា។ នាងសិតា (ជាយារបស់ព្រះរាម) : នាងសត្យា ។

**-សមិទ្ធិ** ស:មិត-ធិ បា. ( ន. ) សេចក្ដីសម្រេច; សេចក្ដីកើតការ, ការសម្រេចប្រយោជន៍ដ៏ស្តុកស្តម្ភ, សំរឹទ្ធិ, លទ្ធផលដែលសម្រេចបានពិតៗដូចជាការកសាងសាលារៀន, ការលើកថ្នល់ ឬលើកទំនប់ទឹកជាប្រយោជន៍សាធារណៈជាដើម ។ សមិទ្ធិការណ៍ ហេតុនៃសេចក្ដីសម្រេច, ដំណើរដែលនាំឱ្យបានសម្រេច, ឱ្យកើតបាន។សមិទ្ធុបាយ ឬ សមិទ្ធោបាយ (បា. < សមិទ្ធិ + ឧបាយ) ឧបាយនៃសេចក្ដីសម្រេច ។ល។ ព. កា. ថា: កម្ពុជរដ្ឋ ឯករាជ្យទៀងទាត់ អព្យាក្រឹតា រដ្ឋរាស្ត្រនិយម សង្គមសត្យា កាន់ពុទ្ធសាស្នា មានក្ដីសុខស្ងប់ ។ សមិទ្ធិកើត សុទ្ធតែឆើតៗ ពីមួយទៅដប់ ពីដប់ទៅរយ រាប់រយក្រចប់ ចម្រើនគ្រប់សព្វ ដូចផ្សិតត្រូវភ្លៀង ។

**-សម្ដេច** ជើង ដ. សំ-ដាច់ ( ន. ) លោកអ្នកមានតេជះច្រើន, លោកអ្នកមានបុណ្យមានអំណាចធំ ។ គុ. ខ្ពង់ខ្ពស់, ឧដុង្គឧត្ដម, ថ្កើងស័ក្តិ ថ្កើងអំណាច, ថ្កើងថ្កាន (សមតែនឹងយល់ថាក្លាយមកពីបា. សំ + តេជ ឬ សំ. សំតេជសិ "ដែលមានតេជះខ្លាំង" ព្រោះខ្មែរបុរាណសរសេរជា សម្ដេជ ក៏មាន) ។ ពាក្យសម្រាប់ប្រើបន្ថែមលើព្រះនាម ឬលើឋានន្តរក្សត្រិយ៍ មន្ត្រីស័ក្តិខ្ពស់ : ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី...; សម្ដេចព្រះមហាក្សត្រិយានី; សម្ដេចព្រះឧបយុវរាជ; សម្ដេចព្រះឧភយោរាជ; សម្ដេចព្រះវររាជជននី; សម្ដេចព្រះមហាឧបរាជ; សម្ដេចព្រះសង្ឃរាជ; សម្ដេចព្រះរៀម; សម្ដេចព្រះអនុជ ។ល។ សម្ដេចចៅពញា ឋានន្តរសេនាបតី ទី ១ សម្រាប់ទោ
(មានតែពីក្នុងសម័យបុរាណ) ។ល។

**-សាមណេរ** --ម៉:ណេ ឬ --ណែ បា.; សំ ( ន. ) (គ្រាមណេរ "កូនចៅឬផៅពង្សនៃសមណ:") បព្វជិតពុទ្ធសាសនិកអ្នកកាន់សីល ១០ ... (លោកនេន); បើស្ត្រីជា សាមណេរី (តែសម័យឥឡូវមិនមាន)។ សាមណេរគ្រោង សាមណេរធំ, សាមណេរបួសឯចាស់ ។ សាមណេរសិក្ខា (--ណេរ៉:--) សិក្ខាសម្រាប់សាមណេរ (ព. វិ. ពុ.) ។ល។

**-សីល** សិល បា.; សំ. ( ន. ) (គីល) វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា, ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ (ព. ពុ.) ។ ការកាន់ចរិយាល្អ; ការសង្រួម; អង្គនៃចរិយា; ចរិត, ចរិយា; មារយាទល្អ; សេចក្ដីល្អ; គតិ; លក្ខណ:; និស្ស័យ; អធ្យាស្រ័យ; សភាព;

ប្រក្រតី; ទម្លាប់; សណ្ដាប់ធ្នាប់; ធម្មជាតិ; ធម្មតា ។ល។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ (ដែលជាបាលីឬសំស្ក្រឹត) អ. ថ. សីល៉:, ដូចជា សីលកថា សម្ដីនិយាយអំពីសីល, និយាយអំពីការប្រព្រឹត្តល្អ ។ សីលខណ្ឌ (--ខ័ន) ឬ សីលភេទ ការដាច់សីល, ដំណើរខូចការប្រព្រឹត្តល្អ ។ សីលក្ខន្ធ (--ល័ក-ខ័ន) កងសីល ។ សីលគន្ធ (--គន់-ធ ឬ--គន់) ក្លិនសីល គឺកេរ្តិ៍ឈ្មោះល្អ ។ សីលគុណ គុណសីល ។ សីលច្ចាគ ឬ--ត្យាគ ការលះបង់សីល, ការលះសេចក្ដីល្អចោល ។ សីលតេជះ តេជះសីល, អំណាចការប្រព្រឹត្តល្អ ។ សីលទាយក (--យក់) អ្នកឱ្យសីល (បើស្ត្រីជា សីលទាយិកា) ។ សីលធន (--ធន់) សីលដែលទុកជាទ្រព្យ (របស់សត្វលោក) ។ សីលធម្ម ឬ --ធម៌ សីលដែលជាធម៌ (របស់សត្វលោក) ឬសីលនិងធម៌; កិរិយាមារយាទ, សណ្ដាប់ធ្នាប់; ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ : ប្រកបដោយសីលធម៌, ប្រាកចាកសីលធម៌ ។ សីលនិធិ ការប្រព្រឹត្តល្អដែលទុកជាកំណប់ទ្រព្យ(របស់សត្វលោក)។ សីលវន្ត (--វ័ន) អ្នកមានសីល (បើស្ត្រីជា សីលវតី ឬ សីលវន្តី) ។ សីលវិបត្តិ (--ប័ត) ការវិនាសសីល, ការដាច់សីល; ការខូចមារយាទល្អ ។ សីលវិសុទ្ធិ សេចក្ដីបរិសុទ្ធនៃសីល ។ សីលសមាទាន (--សៈម៉ា--) ការទទួលសីល, ការកាន់សីល ។ សីលសម្បត្តិ, --សម្ប័ទ ឬ --សម្បទា (--សំប័ត ឬ--ស័ម-ប៉ៈទា) ការបរិបូណ៌ដោយសីល, ការជាប់សីល ។ សីលសារ សីលដែលទុកជាខ្លឹម (របស់សត្វលោក) ។ សីលាចារ (បា. < សីល + អាចារ "មារយាទ") សីលនិងមារយាទ ។ សីលាទិគុណ (បា. < សីល + អាទិ "ជាដើម" + គុណ) គុណមានសីលជាដើម ។ សីលានុស្សតិ (បា. < សីល + អនុស្សតិ "ការរឭកតាម") ការនឹករំពឹងដល់សីល ។ល។

**-សុគត** --គត់ សំ. បា. ( កិ. ) ទៅហើយដោយស្រួលឬដោយប្រពៃ។ គុ. ដែលទៅហើយដោយស្រួល។ ខ្មែរប្រើពាក្យនេះសំដៅសេចក្ដីថា "ទទួលមរណភាពទៅកើតឯឋានល្អហើយ", និយាយចំពោះតែឥស្សរជនជាតិក្សត្រិយ៍ក្រៅពីព្រះរាជា :...ទ្រង់សុគតពីរឆ្នាំហើយ ។

**-សូរ្យ** សំ.; បា. ( ន. ) (សូយ៌; សុរិយ) ព្រះអាទិត្យ ។ ប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃបានតាមការប្រកប (ដូច សុរិយ ដែរ) : សូរ្យករ, --ការ ឬ-- រស្មីព្រះអាទិត្យ ។ សូរ្យកាល ពេលថ្ងៃត្រង់ ។

**-សៀម** ( ន. ) ឈ្មោះប្រទេសមួយមានព្រំប្រទល់ជាប់គ្នានឹងប្រទេសកម្ពុជា ភាគខាងលិចនិងភាគខាងជើង មួយចំហៀងខាងលិចឬខាងពាយ័ព្យ : ប្រទេសសៀម ។ ជាតិមនុស្សក្នុងប្រទេសនោះ ក៏ហៅសៀម ដែរ: ជាតិសៀម, ភាសាសៀម (ពាក្យសម្រាប់ហៅប្រទេសនោះថា ស្យាម ឬទៃយ អ.ថ.ថៃ)។

**-ស្ដេចត្រាញ់** ជើង ដ ( ន. ) ចៅហ្វាយស្រុកស័ក្តិ១០ហ៊ឺពាន់ (ហៅថា ១០ ហ៊ឺពាន់ក្នុង) នៅប្រទេសកម្ពុជាក្នុងរជ្ជកាលព្រេងនាយ ជាមេទ័ពធំ ហៅថាស្ដេចសឹក មានអំណាចកាប់សម្លាប់បាន ក្នុងនាទីរបស់ខ្លួន; ក្នុងប្រទេសកម្ពុជានាសម័យបុរាណព្រេងនាយនោះ មានស្ដេចត្រាញ់៥ស្រុក គឺៈ

១-ស្រុកកំពង់ស្វាយមានងារជា អ្នកឧកញ៉ាតេជោបុរារាជ...;

២-ស្រុកពោធិ៍សាត់មានងារជា អ្នកឧកញ៉ាសួគ៌ាលោក...;

៣-ស្រុកទ្រាំង រួមទ្រាំងត្រើយខាងត្បូងនិងទ្រាំងត្រើយខាងជើងជា ស្រុកតែមួយ មានងារជា អ្នកឧកញ៉ាពិស្ណុលោក...;

៤-ស្រុកត្បូងឃ្មុំ មានងារជា អ្នកឧកញ៉ាអជុន (ហៅក្លាយជា អរជួន)...

៥-ស្រុកបាភ្នំទាំង ២ ផ្នែកគឺ ខាងត្រើយនិងខាងកោះ រួមជាស្រុកតែមួយមានងារជា អ្នកឧកញ៉ា

ធម្មាតេជោ... ។

កាលបើប្រទេសមានសង្គ្រាម ស្ដេចត្រាញ់ទាំង ៥ នេះ ត្រូវទទួលរ៉ាប់រងរក្សាការពារប្រទេសដោយពេញសមត្ថភាពរៀងរាល់ខ្លួន ។ល។

**-ស្បង់** ( ន. ) កាសាវព័ស្ត្រសម្រាប់បព្វជិតពុទ្ធសាសនិកស្លៀកជានិច្ច
(អន្តរវាសក:) : កាសាវព័ស្ត្រ ៣ ផ្ទាំងគឺស្បង់, ចីពរ,សង្ឃាដី ហៅថាត្រៃចីវរ។
ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា ឃើញសេះថាជាលា ឃើញគជាថាកណ្ដុរ (សាស្ត្រាច្បាប់ពាក្យចាស់) ។

**-ស្មី** សំ.; បា. ( ន. ) (ឝ្មី; សមី) ឈ្មោះឈើមួយប្រភេទស្លឹកល្អិតល្វន់ ប្រើជាអន្លក់ឬជាបន្លែស្លស្រឡក់បាន ។

**-ស្វូត** ( កិ. )សូត្របទរលាក់រលែកស្រែកជាតម្នូញមានទំនងជាទំនួញរៀបរាប់ : ស្វូតឱ្យគេស្ដាប់ ។ ប្រើជា ន. ក៏បាន។គួរតែប្រើជា ស្វធ្យ ប៉ុន្តែពុំធ្លាប់ដែលប្រើបើប្រើក៏បានសមតាម សូធ្យ ។ ស្វូត្រ

**-ស្រគំ** ( ន. ) ឈ្មោះឈើធំមួយប្រភេទ ផ្លែតូចស្រួចៗមានជ័រស្អិត វេលាទុំបរិភោគបាន មានរសផ្អែមត្រជាក់ ។

**-ស្រងៃ** --ង៉ៃ ( ន. ) ធញ្ញជាតិមួយប្រភេទ ដើមដូចស្រូវ ដុះឯងក្នុងទឹក ផ្លែមានព្រុយជាកន្ទុយត្រង់ខាងចុងគ្រាប់, ប្រើការដូចស្រូវបានដែរ ប៉ុន្តែបាយរឹងណាស់ រសជាតិផ្អោះៗ : ស្រងៃដំណើប, ស្រងៃខ្សាយ ។ ឈ្មោះក្ដាមស្រែមួយប្រភេទ មាឧតូច ច្រើនជ្រកនៅក្នុងគុម្ពស្រងៃ, ក្នុងគុម្ពស្រូវ : ក្ដាមស្រងៃ ។

**-ស្រងេះស្រងោច** --ង៉េះ-ង៉ោច ( កិ. ) នឹកភ្នកដល់ទីដែលធ្លាប់ឃើញ, ធ្លាប់នៅ មកពីដើម ឬនឹកភ្នកដល់រឿង, ហេតុ ដែលធ្លាប់ដឹងមកពីមុនយូរហើយ ក៏ស្រណោះលន្លង់លន្លោច : លុះឃើញកន្លែងដែលធ្លាប់លេងពីក្មេងក៏នឹកស្រងេះស្រងោច ។

**-ស្លឹត** ( គុ. ) ដែលតឹងខ្លាំង : តឹងស្លឹត ។

**-ស្លេះ** ( កិ. ) ឈប់បង្អង់ទុកដោយឡែកឬដោយអន្លើសិន: ត្រូវស្លេះសេចក្ដីនេះទុកសិន ។

**-ស្វាត** ( ន. ) ឈ្មោះវល្លិមួយប្រភេទ មានបន្លា, គ្រាប់ប្រើជាថ្នាំ ។

«**ហ**»

**-ហាទ័យ** ហាៈទៃ បា.; សំ. ( ន. ) (ហាទយ; ហ្ឫទយ) បេះដូង , ដួងចិត្ត , ចិត្ត ; ទ្រូង ។
រ. ស. ព្រះហឫទ័យ ឬព្រះរាជហឫទ័យ ។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ ត្រូវសរសេរ ហទយ អ. ថ. ហៈទៈយៈ, ដូចជា ហទយពិការ ឬ--វិការ ពិការបេះដូង, ដំណើរខូចបេះដូង ។ ហទយរូប រូបបេះដូង, តួបេះដូង ។ ហទយរោគ រោគបេះដូង; រោគឈឺចិត្ត ។ ហទយវត្ថុ លំនៅរបស់ចិត្ត (តួបេះដូង) ។ល។ ហឫទ័យ ហ្ឫទ័យ

«**អ**»

**-អរជុន** អរ-ជុន សំ.; បា. ( គុ. ) (អជ៌ុន; អជ្ជុន) ស, សថ្លា; ថ្លា; ភ្លឺ, ភ្លឺថ្លា ។ ន. សម្បុរស; ព័ណ៌អរុណភ្លឺបំព្រាង គឺព័ណ៌អរុណសដែលរះបំព្រាងពីឯកើត ។ នាមនៃបាណ្ឌវៈទី ៣ ក្នុងរឿងមហាភារតៈ ។ ព្រះនាមក្សត្រិយ៍និងនាមមេទ័ពឯទៀតក្នុងរឿងសម័យបុរាណ ។ ឈ្មោះឈើមួយប្រភេទ ។ ខ្មែរយកពាក្យ

នេះមកប្រើជាឋានន្តរនៃពួកមន្ត្រីខាងក្រសួងចម្បាំង, ប៉ុន្តែប្រើក្លាយជា អរជូន ឬ អជិន, ដូចជា ឧកញ៉ា អរជូន (អភិបាលស្រុកត្បូងឃ្មុំ) និងមន្ត្រីឯទៀត, ដូចជា អរជូនឫទ្ធិរង្គ, ពិភ័ក្តិអរជូន, ជំនិតអរជូន, ទេពអរជូន, ភក្តីអរជូន ជាដើម។ អជិន **-អង្សក** អង់-ស័ក សំ. បា. ( ន. ) (អំស "ស្មា", អំសក ឬ អំសិក "ដែលទាក់ទងឬជាប់ដោយស្មា") កាសាវពស្ត្រមួយយ៉ាងសម្រាប់បព្វជិតពុទ្ធសាសនិកសម័យសព្វថ្ងៃពាក់ពាតលើស្មាខាងឆ្វេងព័ទ្ធមកក្រោមក្លៀកខាងស្ដាំ ប្រើជាទ្រទាប់ញើសពីខាងក្នុងឧត្តរាសង្គ, ជាគ្រឿងបរិក្ខាររាយរង ឬបរិក្ខារពិសេស ប្រើក៏បាន មិនប្រើក៏បាន ព្រោះគ្រឿងបរិក្ខារនេះ ពុំមែនជាពុទ្ធានុញ្ញាតទេ ... ដូចគ្នានឹង វត្ថពន្ធទ្រូង ដែរ ប្រើក៏បាន មិនបាច់ប្រើក៏បាន ជាចីវររាប់ចូលក្នុង បរិក្ខារចោឡៈ ដែលអដ្ឋកថាប្រាប់ថា បព្វជិតប្រើច្រើនប៉ុន្មានក៏បានឥតមានកំហុសទេ (ព. វិ. ពុ.) ។ ម. ព. វត្ថពន្ធ ផង ។

**-អណ្ដែង** ( ន. ) ឈ្មោះត្រីរអិល ក្បាលសំប៉ែត មានពុកមាត់ មានធ្មុង
ពីរ មានពិស កាលណាមុតសាច់មនុស្សឈឺចាប់ពើត; ត្រីអណ្ដែងមាន ២ ប្រភេទគឺ អណ្ដែងងាំង មាឌតូចជាងអណ្ដែងទន់ ក្បាលធំទ្រងាងសាច់ហាប់; អណ្ដែងទន់ មាឌធំជាងអណ្ដែងងាំងសាច់ទន់ជ្រាយ ។

**-អន្ទង** ( កិ. ) នាំសរសៃអំបោះឬសូត្រទៅមកៗរៀបចំឱ្យមានរបៀបបណ្ដោយគ្នាហើយ មូរដោយក្ដារមូរដាក់ព័ទ្ធមូលនឹងដាម ដើម្បីថ្កូរត្បាញ : អន្ទងអំបោះ ។ ន. អំបោះឬសូត្រដែលអន្ទងរួចហើយ : អន្ទងខ្មៅ ។ គុ. ដែលអន្ទងរួចហើយ : អំបោះអន្ទង ។

ព. ប្រ. ( កិ. ) ដឹកនាំឬបញ្ចុះបញ្ចូលឱ្យព្រមតាម, ឱ្យដោយតាម : អន្ទងកូនឱ្យខំប្រឹង
រៀនសូត្រ។ទាញយោងឱ្យហើប, ឱ្យអណ្ដែតឡើង, ឱ្យឃ្លាតចាកទី : អន្ទងឈើហុប ។
យោងអន្ទង ទំនុកបម្រុងឱ្យចម្រុងចម្រើន (មើលក្នុងពាក្យ យោង ទៀតផង) ។

**-អាគម** សំ. បា. ( ន. ) ការមក, ដំណើរមកដល់; ការរៀនសូត្រ; សេចក្ដីដឹង; ការចេះដឹង; គម្ពីរ, សាស្ត្រឬសាស្ត្រា, ពុទ្ធមន្ត; គាថាដែលរៀនចេះចាំតៗគ្នាមក; របៀន ។ ខ្មែរច្រើនហៅចំពោះតែមន្តគាថាសម្រាប់សូត្រសែកឬស្ដោះផ្លុំថា អាគម "របៀន" : ចេះអាគម, សូត្រអាគម, មន្តអាគម

**-អាណោច** ( កិ. ) ស្រងោចលន្លោចចិត្ត; នឹកអាណិតខ្លោចចិត្ត : អាណោចចិត្ត។(ព. កា.) : នឹកឃើញចេះតែអាណោចចិត្ត ព្រោះដ្បិតធ្លាប់រាប់អានគ្នាមក ឥឡូវពុំដឹងទៅជ្រក សំណាក់អាស្រ័យនៅទីណា ?-- ឃ្លាតបាត់ទៅហើយតើធ្វើម្ដេច បើលេចដំណឹងខ្លះទៅរ៉ា នឹងបានលៃលកតាមរកគ្នា ឥឡូវទៅជាទាល់គំនិត។ គុ.ដែលស្រងោចលន្លោចក្រៃពេក : ចិត្តអាណោច។ អាណោចអាធ័ម ស្រងោចលន្លោចចិត្តពោរពេញដោយទុក្ខ ឬចង្អៀតចិត្តណែនតឹងស្ទើរប្រេះទ្រូង : នឹកអាណោចអាធ័មពុំស្រាក ។ ប្រើជាអាធម្ម ក៏មាន, ប៉ុន្តែសព្ទទាំង ២ នេះមានសេចក្ដីផ្សេងគ្នា គឺ អាធ័ម "ដែលពេញ, ដែលពោរពេញ; មិនប្រកបដោយធម៌, មិនតាមយុត្តិធម៌" : អាណោចអាធម្ម ស្រងោចលន្លោចចិត្ត ប៉ុន្តែមិនត្រូវចំពោះត្រង់ អនិច្ចំ ទុក្ខំ អនត្តា (ម. ព. អធ័ម និង អាធម្ម ទៀតផង) ។

**-អម្បាល** ( និ. ) ដូចជា, ប្រហែលដូច, ប្រហែលដូចជា : អម្បាលលោកសង្ឃម៉េច វាហ៊ាន
ជេរ, ចំណង់បើយើងជាគ្រហស្ថ វាខ្លាចអ្វីវា ! ។ អម្បាលដូច ដូចយ៉ាង : អម្បាលដូចខ្ញុំ។ អម្បាលណា ? ត្រឹមណា ?, ប៉ុនណា ?, យ៉ាងណា ? : ល្អអម្បាលណាទៅ ?, ឆ្ងាយអម្បាលណាទៅ ? ។ អម្បាលថ្ងៃ? ប៉ុន្មានថ្ងៃ ? (ប្រ. ប្រ. អម្បាលង៉ៃ ព. សា.) ។ អម្បាលម៉ាន ប៉ុន្មាន, ម្ល៉ា, យ៉ាងណា: ល្អអម្បាលម៉ានទៅ ?; ធំ

អម្បាលម៉ានក៏ដោយ ! ។ ព. ទ. បុ. ពិសាក្រៃណានឹងឃ្លាន អាក្រក់អម្បាលម៉ាន ក្រៃណានឹងគាប់ចិត្ត ឆ្ងាញ់ព្រោះឃ្លាន ទោះរូបអាក្រក់យ៉ាងណាក៏ដោយស្រេចហើយនឹងគាប់ចិត្ត ។ អម្បាលយ៉ាង ឬ អម្បាលដូចយ៉ាង ប្រហែលដូចយ៉ាង : អម្បាលដូចយ៉ាងខ្ញុំ វាហ៊ានស្តីឱ្យខ្លាំងៗ ឥតញញើត ។ អម្បាលអី ? ប្រហែលនឹងអ្វី ?

**-អាយ** សព្វ, ដែលទីទៃពីពាក្យថា នាយ ឬ ខាងនាយ គឺខាងនេះ, ខាងឯណោះ : ខាងអាយ; ត្រើយអាយ, ស្រុកអាយ, ឯអាយ, រៀងអាយ, មកអាយសិន ! ។ នាយអាយ កិ. វិ. ពីនេះពីនោះ, ខាងណោះខាងណោះ, ត្រង់ណោះត្រង់ណោះ : និយាយលេងនាយអាយ; ចាំរកនាយអាយមើល ក្រែង លោបាន។ថានាយថាអាយ ថានេះថានោះ,ថានេះហើយថានោះទៀត ។ លូកនាយលូកអាយ លូកនេះហើយលូកនោះទៀត ។ល។ ព. ទ. បុ. ថា : ជួញជិតៗ ជាជាងជួញឆ្ងាយ ជួញរៀងអាយ ចិញ្ចឹមមាតា ។ ព. កា. ថា : ... ហៃកូនមាសម្ដាយ មកអាយឆាប់ព៉ា ម្ដាយនឹងប្រាប់បា ឱ្យដឹងរឿងហេតុ ។

**-ឧបជ្ឈា** អ៊ុប៉ុច-ឈា ប៉ុន្តែ ឧបជ្ឈា មិនដែលប្រើទេ បា.; សំ. ( ន. ) (ឧបជ្ឈា ឬ ឧបជ្ឈាយ; ឧបាធ្យាយ) គ្រូបង្រៀនធម៌ ឬគ្រូបង្រៀនច្បាប់។ ព. ពុ. ព្រះថេរៈ ដែលភិក្ខុឬសាមណេរសូមនិស្ស័យ ប្រគល់ខ្លួនឱ្យលោកត្រួតត្រាស្ដីថា ទូន្មានបង្រៀនប្រដៅតាមច្បាប់ពុទ្ធសាសន គឺលោកគ្រូអ្នកពិនិត្យមើលការខុសត្រូវរបស់សទ្ធិវិហារិក (ក្នុងវិន័យពុទ្ធសាសនាថា លុះតែភិក្ខុដែលមានវស្សាយ៉ាងតិចត្រឹម ១០ ហើយ ចេះធម៌វិន័យល្មមដល់ឋានៈជាឧបជ្ឈាយ៍ ទើបអាចធ្វើជាឧបជ្ឈាយ៍ បាន) : លោកដែលជាគ្រូរបស់សទ្ធិវិហារិក ហៅថា ឧបជ្ឈាយ៍ (ម. ព. សទ្ធិវិហារិក ផង) ឧបជ្ឈាយវត្ត (--យៈ--) វត្តប្រតិបត្តិដែលសទ្ធិវិហារិកត្រូវធ្វើចំពោះឧបជ្ឈាយ៍របស់ខ្លួន (ជាគូគ្នានឹង សទ្ធិវិហារិកវត្ត) ។ ឧបជ្ឈាយ៍

**-ឧកញ៉ា** អុក-- ( ន. ) ពាក្យប្រើជាឋានន្តរស័ក្តិនៃមន្ត្រីថ្នាក់ខ្ពស់ជាងទីព្រះ សំដៅសេចក្តីថា"អ្នកចេះត្រួតត្រាមុខការក្នុងក្រសួងឬនាទីរបស់ខ្លួន" (មកពី ពាក្យខ្មែរ ឧក ឬ អុក "ត្រួតត្រាពេញអំណាច" + បា. ញា "ដឹង; ចេះ; ស្គាល់"), ប្រើតាមលំដាប់ថ្នាក់ស័ក្តិធំតូចថា លោកអ្នកឧកញ៉ា..., អ្នកឧកញ៉ា..., ឧកញ៉ា... (មាននិយាយក្នុងច្បាប់ទម្រង់ស័ក្តិ) ។ មានអត្ថកោវិទខ្លះយល់ថា ឧក ក្លាយមកពី សំ. ឧ "ព្រះព្រហ្ម; ព្រះឥសូរ" + បា. ញា "ដឹង; ចេះ; ស្គាល់" សំដៅសេចក្តីថា "អ្នកស្គាល់ការគោរពព្រះព្រហ្មឬព្រះឥសូរ" (តាមលទ្ធិខ្មែរសម័យបុរាណ); អត្ថកោវិទខ្លះយល់ថា ឧក ក្លាយមកពី សំ. ឧក្ត "ពោល, ស្តី, និយាយ, ថា" + បា. ញា សំដៅសេចក្តីថា "អ្នកស្គាល់ការស្តីនិយាយ" (ការយល់ទាំងពីរយ៉ាងក្រោយនេះក៏បានសេចក្តីដោយឡែកដែរ គង់នៅប្រើជា ឧកញ៉ា ដូចគ្នា ផ្សេងគ្នាតែសេចក្តីប៉ុណ្ណោះ) ។ កាលក្នុង ព. ស. ២៤៥៨ គ. ស. ១៩១៤ គណៈកម្មការបង្កើតវចនានុក្រមខ្មែរ បានផ្ដើមប្រឹក្សាគ្នាជាដំបូងបង្អស់ អំពីអក្សរ ៤ តួគឺ ឱ, ឪ, ឲ, ឳ, (អុក, អុវ ឬ អូវ, អោ, អៅ) នេះ ក៏បានយល់ព្រមគ្នាជាឯកច្ឆន្ទថា ឱ បុរាណយក (ំ) នេះដែលហៅថាសក់ក មកដាក់ពីលើជាតួប្រកបជាជំនួស ក (ឧក) ត្រូវលែងប្រើ ត្រូវប្រើ ឧក វិញ (ឧកហ្លួន... ឧកញ៉ា) ។ ឲ ដែលប្រកបនឹង យ ជា ឲយ ឬ អោយ នេះត្រូវកុំប្រើត្រូវប្រើ ឱ្យ ដូចពីដើមទុកថាជា អញ្ញត្រសព្ទ ។ ឪ និង ឳ ដែលយកចុងឬកន្ទុយ វ មកដាក់ពីលើជា ឪ, ឳ (អុវ, អៅ) ត្រូវទុកឱ្យនៅដូចពីដើម (ម. ព. ឪ, ឲ, ឳ តាមលំដាប់ ទៀតផង) ។ សៀមសម័យបុរាណយកពាក្យ ឧក ទៅប្រើជា អក, សរសេរជា អ្នក ប្រើជាពាក្យនាំមុខឋានន្តរមន្ត្រីគ្រប់ថ្នាក់ជា អ្នកហ្លួន, អ្នកខុន អ្នកហ្លួង, អ្នកព្រះ, អ្នកញា (អកហ្លួន, អកឃុំន, អកហ្លួង, អកផ្រះ, អកយ៉ា) ។ អ្នក នេះសៀមប្រើជាពាក្យហៅបិតាមាតាថា ព់អ្នក, ម៉េអ្នក ផងក៏បាន (អ. ថ. ផអក, ម៉ែអក "ឪពុកបង្កើត, ម្ដាយបង្កើត")។លាវប្រើពាក្យ ព់អ្នក, ម៉េអ្នក នេះជាសម្ដីសម្រាប់បព្វជិតហៅឧបាសកឧបាសិកា ផងក៏បាន ។

## ឯកសារពិគ្រោះ


១- សិក្សាអត្ថបទទុំទាវ ពាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ឆ្នាំ១៩៨៨

២- បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ ឆ្នាំ១៩៨៩ ល.ស.«យិន វ៉ាន់ថា»

៣- មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សទី១៩ លោក យឹង ហុកឌី ឆ្នាំ២០០៣

៤- សិក្សាអក្សរសាស្ត្រខ្មែរបទុមត្ថេរសោមករីសតវត្សរ៍ទី១៩ ទុំទាវ ឆ្នាំ១៩៧១ ដោយគង់ សម្ភារ

៥- វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧

៦- រឿងទុំទាវនិពន្ធដោយព្រះបទុមត្ថេរសោមការផ្សាយរបស់ពុទ្ធសាសន បណ្ឌិត្យ ព.ស២៥១៤

៧- ប្រវត្តិសាស្ត្រខ្មែរ ភាគ១-២ (ត្រឹង ងា) សំរាប់មធ្យមសិក្សា និងឧត្តមសិក្សា ព.ស. ២៥១៧ គ.ស .១៩៧៣

៨- កំណាព្យខ្មែរ ដោយលោក លី សុមុនី ព.ស.២៥៤៦ គ.ស.២០០២

៩- ជីវប្រវត្តិអ្នកនិពន្ធខ្មែរ សាលាគរុវិជ្ជាជាន់ខ្ពស់ (២១ .០៧.១៩៨៦)

១០- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ បោះពុម្ពដោយគ្រឹស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១១

១១- អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១ បោះពុម្ពដោយគ្រឹស្ថានបោះពុម្ព និងចែកផ្សាយឆ្នាំ ២០១២

១២- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ថ្នាក់ទី១២ លេខ០៣ អយក.សណន ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង ធនញ្ជ័យ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..................................អយក.**

## ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងធនញ្ជ័យ»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងធនញ្ជ័យ » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ អង្គារ ៥ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន "
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ«**សិក្សាអត្ថបទអក្សរសិល្ប៍**» ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ «**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង ធនញ្ជ័យ**» នេះ មានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្វាគមនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី ម៉ៅ គាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សុគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ
ប្រកាស .......................................................................................................................i
បុព្វកថា .......................................................................................................................ii
គណៈកម្មការ...................................................................................................................iii
អារម្ភកថា......................................................................................................................iv
មាតិកា..........................................................................................................................v
សេចក្តីផ្តើម.......................................................................................................................
I. ការបង្ហាញអត្ថបទ.........................................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង.................................................................................................
III. ទិដ្ឋភាពទំនាស់...........................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ......................................................................................................
V. ទិដ្ឋភាពសង្គម.............................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ.......................................................................................................
VII. ទិដ្ឋភាពតម្លៃ.............................................................................................................
VIII. ការសន្និដ្ឋាន.............................................................................................................
IX. ឯកសារពិគ្រោះ..........................................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

## រឿង ធនញ្ជ័យ

### I-ទិដ្ឋភាពប្រវត្តិ

**ក-អត្ថបទ**

-ចំណងជើង : ធនញ្ជ័យ ដែលមានន័យថា អ្នកមានទ្រព្យ ដោយជ័យជម្នះ ដែលជាស្នាដៃនៅក្នុងសៀវភៅកម្រងអត្ថបទអក្សរសិល្ប៍របស់ក្រសួងអប់រំបោះពុម្ពឆ្នាំ១៩៨២ (សាធារណៈរដ្ឋកម្ពុជា)

-ប្រភព : តាមការស្រាវជ្រាវ រឿងនេះមាននៅក្នុងប្រភពមួយចំនួនដូចខាងក្រោម ៖

-ការនិទានពីមាត់មួយទៅមាត់មួយ របស់ប្រជាជនខ្មែរស្ទើរគ្រប់តំបន់

-ឯសារដែលគេបានកត់ត្រាឡើងវិញដោយពុទ្ធសាសនបណ្ឌិត្យលើកទី១ ឆ្នាំ១៩៦៥

-ផ្សាយតាមទស្សនាវដ្ដីកម្ពុជាសុរិយា និងសៀវភៅកម្រងអត្ថបទអក្សរសិល្ប៍របស់ក្រសួងអប់រំបោះពុម្ពឆ្នាំ១៩៨២ (សាធារណៈរដ្ឋកម្ពុជា)

-ប្រភេទ : រឿងធនញ្ជ័យ ជាអក្សរសិល្ប៍ប្រជាប្រិយ ដែលគេនិទានពីមាត់មួយទៅមាត់មួយ ពីជំនាន់មួយទៅជំនាន់មួយ ពីតំបន់មួយទៅតំបន់មួយ តាំងពីយូរយារណាស់មកហើយ។

**ខ-អ្នកនិពន្ធ**

-ឈ្មោះអ្នកនិពន្ធ : យើងពុំបានដឹងថា អ្នកណាជាអ្នកនិពន្ធដំបូងគេឡើយ ព្រោះពុំទាន់មានការស្រាវជ្រាវពីឈ្មោះអ្នកនិពន្ធឱ្យបានច្បាស់លាស់ទេ។

-ជីវប្រវត្តិ : គ្មាន

-ស្នាដៃសំខាន់ៗ : គ្មាន

**គ-កាលកំណត់តែង**

-ថ្ងៃខែឆ្នាំនៃការតាក់តែង : ពុំដឹងពេលវេលាពិតប្រាកដ។ បើយោងទៅលើពាក្យពេចន៍ និងដំណើររឿង យើងអាចសន្និដ្ឋានបានថា រឿងនេះកើតឡើងនៅពេលដែលប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយប្រទេសចិន។

-ថ្ងៃខែឆ្នាំនៃការបោះពុម្ព : ពុំច្បាស់លាស់ទេ ដឹងតែឯកសារដែលគេបានកត់ត្រាឡើងវិញដោយពុទ្ធសាសនបណ្ឌិត្យក្នុងឆ្នាំ១៩៦៥។

**ឃ-សង្គមបរិយាកាស**

-**កាលប្រវត្តិ** : (សម័យកាលកកើតរឿង)

យោងតាមខ្លឹមសារនៃការកំណត់តែងខាងលើ រឿងធនញ្ជ័យប្រហែលជាត្រូវបានប្រជាជនយើងតាក់តែងឡើងក្នុងសម័យសក្តិភូមិពេលដែលសមត្ថភាពដឹកនាំរបស់ស្តេចបានធ្លាក់ចុះដល់កម្រិតទាប ហើយអំណាចផ្តាច់ការបានឡើងដល់កម្រិតខ្ពស់ដែលធ្វើឱ្យប្រជាជនមិនអាចទ្រាំទ្របាន ពោលគឺកំឡុងសម័យក្រោយអង្គរ។

**-ព្រឹត្តិការណ៍សំខាន់ៗ**

ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរឿងធនញ្ជ័យមានដូចខាងក្រោមៈ

-ខ្មែរតែងមានប្រពៃណី ជំនឿ(លើការទស្សទាយរបស់ហោរាសាស្ត្រ)

-មានការបែងចែកវណ្ណៈគ្នា(ទាសករ ខ្ញុំបម្រើ អ្នកក្រ អ្នកមាន សេដ្ឋី មន្ត្រី...)

-ប្រទេសមានរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ មានស្តេច មន្ត្រីរាជការ ចៅហ្វាយខេត្តឬស្តេចត្រាញ់ជាដើម។

-ប្រទេសមានទំនាក់ទំនងទៅនឹងប្រទេសក្រៅ(ប្រទេសចិន)

-មនុស្សមានបញ្ញា មានវិជ្ជា ធ្វើបាបអ្នកគ្មានប្រាជ្ញាជាល្បែងកម្សាន្ត។

## II-ទិដ្ឋភាពទំនាក់ទំនងរឿង

### ក-សង្ខេបរឿង

កាលដែលធនញ្ជ័យចាប់កំណើតក្នុងផ្ទៃម្តាយនាពេលទៀបភ្លឺនាងម្តាយបាន « យល់សប្តិដូចជាយល់សូង យល់សប្តិឃើញដូង បេះបានទាំងផ្លែ យល់សប្តិឃើញខែ ខែនោះពេញបូណ៌មី» ។ ម្តាយធនញ្ជ័យបានទៅរកលោកតាហោរាទាយពីសុបិនរបស់ខ្លួន។ គាប់ជួនពេលនោះ លោកតាហោរមិននៅផ្ទះ ម្តាយធនញ្ជ័យបាននិយាយប្រាប់ប្រពន្ធតាហោរ។ ប្រពន្ធតាហោរដឹងថា តាមសប្តិនេះ នាងនឹងមានកូនប្រុសម្នាក់អាចនឹងឡើងធ្វើជាស្តេច ក៏ទាយបង្ខុសថា «នាងឯងនឹងមានកូនប្រុស កូននោះនឹងទៅជាខ្ញុំគេ»។

ក្រោយមកនាងកើតបានកូនប្រុសម្នាក់ដូចហោរទាយមែន។ នៅពេលធនញ្ជ័យអាយុ៧ឆ្នាំ វាតែងតែទៅលេងផ្ទះសេដ្ឋី។ ថ្ងៃមួយ ពេលកំពុងត្បាញនៅលើផ្ទះ ប្រពន្ធសេដ្ឋីបានធ្វើឱ្យជ្រុះត្រល់ទៅដី ក៏ស្រែកហៅធនញ្ជ័យឱ្យរើស ដោយបានព្រមព្រៀងជាមួយធនញ្ជ័យថា នឹងប្រគល់អំបុកច្រើន ឱ្យទៅធនញ្ជ័យ។ លុះពេលប្រគល់អំបុក ទោះបានអំបុកមួយកញ្ជើហើយក៏ដោយ ក៏ធនញ្ជ័យនៅតែយល់ថាពុំច្រើនដដែល ដែលធ្វើឱ្យវាគិតតែពីយំ។ សំឡេងយំរបស់ធនញ្ជ័យបានឮទៅដល់លោកសេដ្ឋី។ លោកក៏រកវិធីលួងធនញ្ជ័យ ដោយយកអំបុកដាក់ក្នុងចង្អេរមួយ និងក្នុងកញ្ជើមួយ រួចឱ្យធនញ្ជ័យជ្រើសរើស។ ធនញ្ជ័យបានយកអំបុកក្នុងចង្អេរ ព្រោះវាយល់ថាច្រើនតែ

ពេលទៅដល់ផ្ទះទើបវាដឹងថាអំបុកក្នុងចង្អេរតិចជាងអំបុកក្នុងកញ្ជើ។ វាអន់ចិត្តយ៉ាងខ្លាំង ក៏សុំម្ដាយឱ្យយកខ្លួនទៅនៅបម្រើលោកសេដ្ឋីដើម្បីផ្ចាញ់ផ្ចាលសេដ្ឋីវិញ។ នៅពេលនៅជាមួយសេដ្ឋី ធនញ្ជ័យបានផ្ចាញ់ផ្ចាលសេដ្ឋីឱ្យបាត់បង់ទាំងទ្រព្យសម្បត្តិ និងកិត្តិយស ជាច្រើនលើកច្រើនសា ដូចជា ៖

-ស្ពាយថង់យាមរត់តាមសេះជូនសេដ្ឋីទៅវាំង ដែលនៅពេលនោះដើម្បីរត់ទាន់សេះ ប្រដាប់ប្រដាក្នុងថង់យាមត្រូវជ្រុះអស់។ នៅពេលសេដ្ឋីបន្ទោស ហើយបញ្ជាឱ្យរើសរាល់អ្វីៗដែលជ្រុះ ធនញ្ជ័យរើសទាំងអាចម៍សេះដាក់ពេញថង់យាម។

-ទៅចាំចម្ការ ធនញ្ជ័យមើលចម្ការមិនឱ្យបាត់ ហើយបណ្ដោយឱ្យគោស៊ីដំណាំអស់។

-ឃ្វាលគោញី (ចាប់គោឈ្មោលពិន័យព្រោះហ៊ានសាហាយនិងគោញីប្រពន្ធរបស់ខ្លួន)។

-ទៅហៅសេដ្ឋីពិសាបាយ ធនញ្ជ័យស្រែកហៅខ្លាំងៗ ធ្វើឱ្យសេដ្ឋីអាម៉ាស់មុខ។

-ពេលភ្លើងឆេះផ្ទះ ធនញ្ជ័យទៅប្រាប់សេដ្ឋី តែមិននិយាយខ្លាំងៗទេ គឺនិយាយខ្សឹបៗ ធ្វើឱ្យភ្លើងឆេះអស់ ហើយធនញ្ជ័យជញ្ជូនតែរបស់ស្រាលៗ ធ្វើឱ្យសេដ្ឋីខាតបង់វិនាសទ្រព្យអស់។

សេដ្ឋីទ្រាំមិនបានដោយខ្លាចរលាយទ្រព្យសម្បត្តិ ក៏នាំធនញ្ជ័យទៅថ្វាយស្ដេច។ ស្ដេចទទួលធនញ្ជ័យឱ្យនៅបម្រើ ព្រោះចង់ដឹងប្រាជ្ញាធនញ្ជ័យ ព្រមទាំងចង់ដេញប្រាជ្ញាធនញ្ជ័យផង។

នៅជាមួយដំបូង ស្ដេចបានដេញប្រាជ្ញាធនញ្ជ័យ ដូចជាឱ្យធនញ្ជ័យភរស្ដេច ឱ្យរកពងមាន់ឱ្យបានមួយ ពេលមុជចូលទៅក្នុងទឹក ឱ្យធនញ្ជ័យជិះដំរីចាស់គ្រេចជើងដឹកក្រយាស្ងោយស្ដេចទៅប្រពាតព្រៃជិះសេះអុកចត្រង្គ ឱ្យបោសសំរាមនៅក្រោមដំណាក់ ឱ្យរកមាន់មកប្រជល់ជាមួយមាន់ស្ដេច ឱ្យរកក្របីមកជលជាមួយនឹងក្របីស្ដេច ប្រមាថលោកគ្រូសង្ឃរាជដើម្បីបានចូលវាំង។ ក្នុងការដេញប្រាជ្ញានេះ ធនញ្ជ័យបានឈ្នះស្ដេចគ្រប់លើក ធ្វើឱ្យស្ដេចខ្មាស ហើយដុះគំនិតព្យាបាទកាច់បំបាក់ ដូចជា ស្អប់មុខធនញ្ជ័យ ហើយមិនឱ្យធនញ្ជ័យចូលវាំង។ តែគ្រប់អំពើព្យាបាទរបស់ស្ដេច ត្រូវបានធនញ្ជ័យផ្ចាញ់ផ្ចាលយ៉ាងដំណំ ដូចជាធនញ្ជ័យហ៊ានចំតិតគូថដាក់ស្ដេច ហ៊ានវាយពួកមេនំមេនាងដែលស្ដេចប្រើឱ្យទៅជុះអាចម៍ដាក់ផ្ទះ។

កិត្តិស័ព្ទធនញ្ជ័យឮដល់ស្ដេចស្រុកចិន ពេលនោះស្ដេចស្រុកចិនបញ្ជូនអ្នកប្រាជ្ញឱ្យមកសាកល្បងជាមួយធនញ្ជ័យ។ ក្នុងការដោះចំណោទទាយរកចំនួនគ្រាប់ឪឡឹកដែលចិនយកមកនោះ ពិបាកពេក ក៏បានលោតទឹកសម្លាប់ខ្លួន តែគាត់មិនលិច បែរជារសាត់ទៅប៉ះសំពៅចិន ក៏តោងចង្កូតជាប់។ ពេលនោះជួនជាយប់ស្ងាត់ ធនញ្ជ័យបានឮពួកមន្ត្រីចិន និងអ្នកប្រាជ្ញរបស់គេ

ជជែកគ្នាអំពីចំនួនគ្រាប់ឪឡឹកក្នុងផ្លែនីមួយៗ។ ស្អែកឡើងគាត់បានទាយចំនួនគ្រាប់ឪឡឹកត្រូវទាំងអស់ ដោះប្រស្នាសាច់ជ្រូក១នាឡិស៊ីពីរឆ្នាំ។ បន្ទាប់មកធនញ្ជ័យដោះស្រាយប្រស្នា ត្រូវយកចាបមួយធ្វើម្ហូបសម្រាប់មនុស្ស៥០០នាក់ និងធ្វើយុថ្កា៥០០ក្នុងរយៈពេលមួយថ្ងៃ។ ពួកចិនទទួលព្រមចុះចាញ់ បានប្រគល់សំពៅឱ្យស្តេចខ្មែរបាន៥០០គ្រឿង។ ធនញ្ជ័យបានធ្វើឱ្យចិនបរាជ័យឈប់មកបង្ករឿងទៀត ដោយចិនសង្ឃឹមថា ត្រូវរង់ចាំឱ្យអត់ពីធនញ្ជ័យសិនទៅ ទើបមកស្រុកខ្មែរម្តងទៀត។

ចំណែកស្តេចស្រុកខ្មែរ ដោយនឹកឃើញគំនុំចាស់ផង ខ្លាចប្រាជ្ញាធនញ្ជ័យផង ពិសេសខ្លាចធនញ្ជ័យបង្កហេតុទៅថ្ងៃក្រោយ ក៏បញ្ជាឱ្យធនញ្ជ័យចេញពីវាំងទៅនៅជនបទ។

នៅឯជនបទ ធនញ្ជ័យបានធ្វើសកម្មភាពច្រើនយ៉ាងដូចជាបង្កើតឱ្យមានការបង់ពន្ធគយដាក់ឈ្មោះស្ទឹង ទន្លេ ព្រៃ ជាច្រើនធ្វើឱ្យមានច្បាប់សម្រាប់នគរ តែបែរជាមានទំនាស់ជាមួយពួកឈ្មួញរកស៊ីតាមដងទន្លេ ធ្វើឱ្យស្តេចកាន់តែក្តៅក្រហាយ ចាប់កំហុសមិនបាន ក៏បញ្ជាឱ្យយកធនញ្ជ័យទៅសម្លាប់ចោលក្នុងទឹកទន្លេ។ ពេលយកទៅសម្លាប់ធនញ្ជ័យបានបោកពេជ្ឈឃាតរួចខ្លួនទៀត ទើបរត់ទៅបួសយ៉ាងស្ងាត់កំបាំង។ ស្តេចនិងនាម៉ឺនសប្បាយចិត្តណាស់ ព្រោះជឿថាធនញ្ជ័យស្លាប់បាត់ទៅហើយ។

ដំណឹងមរណភាពរបស់ធនញ្ជ័យលេចឮទៅដល់ស្តេចស្រុកចិន។ ស្តេចស្រុកចិនក៏បញ្ជូនអ្នកប្រាជ្ញមកម្តងទៀត ដើម្បីឱ្យស្តេចបញ្ជូនអ្នកប្រាជ្ញមកដោះប្រស្នា ដោយគិតថា ម្តងនេះស្រុកខ្មែរនឹងបានទៅចិន ព្រោះធនញ្ជ័យស្លាប់ហើយ។ ការសង្ឃឹមរបស់ចិនខុសស្រឡះ ព្រោះធនញ្ជ័យ មិនទាន់ស្លាប់ឡើយ ក្រោយមកដោយឮថាធនញ្ជ័យទៅបួសហើយសឹក ស្តេចក៏បញ្ជាឱ្យនាម៉ឺនរកធនញ្ជ័យឱ្យឃើញ រួចនាំចូលវាំង។ ដោយស្មារតីស្រឡាញ់ប្រទេសជាតិ ខ្លាចប្រទេសជាតិធ្លាក់ក្នុងកណ្តាប់ដៃចិន ធនញ្ជ័យសុខចិត្តមកដោះប្រស្នាជាមួយអ្នកប្រាជ្ញចិននូវប្រស្នាចំនួនប្រាំ និងមានចម្លើយបួនផ្សេងគ្នា ជាមួយអ្នកប្រាជ្ញចិន សង្ឃរាជ សម្តេចចៅហ្វា និងព្រះរាជា និងធ្វើគម្ពីរអក្សរជើងក្អាម រហូតទទួលបានជោគជ័យជាលើកទីពីរ។

ពេលនោះ ស្តេចត្រេកអរណាស់ឱ្យរង្វាន់ធនញ្ជ័យជាច្រើន តែធនញ្ជ័យមិនទទួល ដោយគ្រាន់តែសុំស្តេចចេញរកប្រពន្ធដែលមានលក្ខណៈសក្តិសមជាស្ត្រីពិតប្រាកដ។

ទីបំផុត ធនញ្ជ័យបានជួបនឹងនាងសួស្តី ដែលគាត់ចាត់ទុកថាជាស្ត្រីពេញលក្ខណៈ រួចបានស្តីដណ្តឹង និងរៀបការតាមប្រពៃណីខ្មែរ។ ក្រោយរៀបការរួច ធនញ្ជ័យបានរកល្បិចធ្វើឱ្យនាម៉ឺនប្រគល់ប្រាក់កាសជាច្រើនឱ្យប្រពន្ធ និងម្តាយថែមទៀត។ រឿងនេះបានធ្វើឱ្យពួកនាម៉ឺន

មានការក្តៅក្រហាយជាខ្លាំង ក៏នាំគ្នាទៅទូលស្តេចឱ្យបំបរបង់ធនញ្ជ័យទៅស្រុកចិន ដោយជឿថា នឹងត្រូវស្លាប់បង់នៅទីនោះមិនខាន។

នៅឯស្រុកចិន ធនញ្ជ័យបានធ្វើនំបញ្ចុកលក់ល្បីដល់ស្តេចចិន។ ស្តេចចិនចង់សោយចំណីចម្លែករបស់ធនញ្ជ័យ ក៏ហៅធនញ្ជ័យឱ្យយកនំទៅថ្វាយ ដែលជាហេតុបណ្តាលឱ្យគាត់មានលទ្ធភាពអាចមើលមុខស្តេចចិនបាន ព្រមទាំងបានពោលពាក្យប្រមាថឱ្យផង។ ស្តេចចិនខឹង ក៏ឱ្យអាមាត្យចាប់ធនញ្ជ័យទៅដាក់គុកសំរិទ្ធ។ ក្នុងគុក ធនញ្ជ័យបានប្រដាល់គ្នាជាមួយអ្នកទោសចិន ដើម្បីកុំឱ្យរងាស្លាប់ រួចគាត់ឆ្លៀតធ្វើខ្លែងឯកបង្ហោះពេលយប់។ ស្តេចចិនបានឮសំឡេងខ្លែងមានការភិតភ័យព្រួយបារម្ភក៏ហៅហោរាមកគន់គូរមើល។ ហោរាចិនបានទាយថា គឺជាសំឡេងនៃសត្វចម្លែកមួយ នឹងចូលមកស៊ីមនុស្សក្នុងស្រុកចិននោះអស់មិនខាន បើមិនព្រមដោះលែងអ្នកប្រាជ្ញស្រុកខ្មែរចេញពីគុក ហើយជូនគេត្រឡប់ទៅស្រុកវិញទេ។ ស្តេចចិនឮដូច្នោះ ក៏បញ្ជាឱ្យគេដោះលែងធនញ្ជ័យ ហើយរៀបចំសំពៅមួយមានវត្ថុប្រើប្រាស់ល្អៗជាច្រើន និងប្រជាជនចិន ១០០នាក់ ជូនដំណើរធនញ្ជ័យត្រឡប់មកស្រុកខ្មែរវិញ។

មកដល់ស្រុកខ្មែរវិញ ធនញ្ជ័យត្រូវបានស្តេចខ្មែរទទួលស្គាល់ឈប់រករឿង ថែមទាំងឱ្យធនញ្ជ័យធ្វើខ្លែងថ្វាយទ្រង់ទុកជាកេរដំណែលតរៀងមក។

ចំណេរក្រោយមក ធនញ្ជ័យមានជំងឺជាទម្ងន់ តែមុននឹងដាច់ខ្យល់ស្លាប់ធនញ្ជ័យបានហៅស្តេចមកផ្តែផ្តាំថា «បើសោយត្រីព្រួលកុំចោលស្រកា បើសោយត្រីប្រាកុំចោលស្រកី បើស្លម្ជូរក្បាលត្រីប្រាត្រូវដាក់ម្ជូរសណ្តាន់» ដើម្បីឱ្យស្តេចមានការភ្ញាក់រឭក និងគ្រប់គ្រងប្រទេសបានល្អ។ ជាមួយគ្នានេះ គាត់ក៏បានផ្តាំប្រពន្ធថា កាលណាគាត់ស្លាប់ទៅឱ្យយកសាកសពគាត់ទៅកប់ហើយធ្វើចម្រូង ដាំខ្មែរលើផ្នូរ ដើម្បីការពារផ្នូរនោះតទៅ។ បញ្ហានេះ បានធ្វើឱ្យពួកនាម៉ឺនងឿងឆ្ងល់ ហើយកាន់តែខ្លាចប្រាជ្ញាធនញ្ជ័យ និងគោរពកោតខ្លាចស្តេចគ្រប់ៗគ្នា។

**ខ-តួអង្គ**

-ធនញ្ជ័យ (អ្នកប្រាជ្ញស្រុកខ្មែរ)

-ម្តាយធនញ្ជ័យ

-ប្រពន្ធហោរ

-សេដ្ឋី និងភរិយា

- ព្រះសង្ឃរាជ

-ស្តេចខ្មែរ

-នាម៉ឺន មន្ត្រី

-ឈ្មួញរកស៊ី

-នាងសួស្ដី (ប្រពន្ធធនញ្ជ័យ)

-ស្ដេចចិន

-អ្នកប្រាជ្ញចិន

-ហោរាចិន

**គ-កាលអាកាស**

-កាល : រឿងនេះបានបង្ហាញពីកាលវេលានៃរឿងដែលប្រព្រឹត្តទៅ ដោយអ្នកនិពន្ធចបញ្ជាក់ថា៖“កាលដើមឡើយ...”

-អាកាស : ស្រុកខ្មែរ ផ្ទះសេដ្ឋី តាមដងទន្លេ ក្នុងរាជវាំង... ស្រុកចិន គុកសំរិទ្ធ រាជវាំង...

**III-ទិដ្ឋភាពទំនាស់**

នៅក្នុងរឿងធនញ្ជ័យ ដែគូទំនាស់របស់ធនញ្ជ័យមាននៅតាមទីតាំងផ្សេងៗគ្នា ដូចជានៅផ្ទះលោកសេដ្ឋី ក្នុងព្រះរាជវាំងនិងនៅប្រទេសចិនជាដើម។

**១-ទំនាស់វិបត្តិទី១**

**ក-ទីកន្លែងទំនាស់** : នៅផ្ទះសេដ្ឋី

**ខ-តួទំនាស់**

- **តួអង្គធនញ្ជ័យ និង តួអង្គសេដ្ឋី**«ទំនាស់នឹងសេដ្ឋី»

  សេដ្ឋីគឺតំណាងឱ្យពពួកសក្តិភូមិម្ចាស់ដីទាំងឡាយដែលគេតែងយល់ថា«ខ្លួនមានការឈ្លាសវៃជាងពួកកសិករ»ហើយគេយល់ថា«កសិករអាចនឹងបំរើប្រយោជន៍របស់ខ្លួនគ្រប់ពេលវេលា»។ តែទស្សនៈនេះត្រូវបានធនញ្ជ័យវាយបំបាក់ចោលទាល់តែសេដ្ឋីត្រូវទទួលបរាជ័យទាល់តែអាម៉ាស់។

**គ-បញ្ហាទំនាស់** : គឺស្ថិតនៅលើបញ្ហាដែលប្រពន្ធសេដ្ឋីឱ្យអំបុកមួយកញ្ជើទៅធនញ្ជ័យ ឯធនញ្ជ័យយល់ថាតិច។ ដូចនេះបញ្ហាទំនាស់កើតឡើងដោយសារការគិតរបស់ធនញ្ជ័យមិនបានយល់ពីបញ្ញាត្តពាក្យអ្វីដែល«ច្រើន»។ ហេតុនេះហើយធ្វើឱ្យសេដ្ឋីមានឱកាសប្រើល្បិចរាយអំបុកក្នុងកញ្ជើ និងរាយក្នុងចង្អេរ ដើម្បីឱ្យធនញ្ជ័យជ្រើសរើស។

**ឃ-ដំណោះស្រាយ :** ធនញ្ជ័យយល់ព្រមជ្រើសរើសយកអំបុកក្នុងចង្អេរ ព្រោះកុមារជ័យយល់ថាអំបុកក្នុងចង្អេរគិតថាច្រើនជាងអំបុកក្នុងកញ្ជើ។

សំណួរភ្ជាប់វិបត្តិទំនាស់ : តើការជ្រើសរើសយកអំបុកក្នុងចង្អេររបស់ធនញ្ជ័យធ្វើឱ្យគាត់សប្បាយចិត្តរហូតលែងមានបញ្ហាទំនាស់ជាមួយសេដ្ឋី ឬយ៉ាងណា?

**២-ទំនាស់វិបត្តិទី២**

ទោះយ៉ាងណាក៏ដោយទំនាក់ទំនងរវាងធនញ្ជ័យ និងសេដ្ឋីគឺនៅមានបន្តទៀត ព្រោះធនញ្ជ័យគិតថា សេដ្ឋីបានបោកប្រាស់ខ្លួនដែលជាហេតុចម្បងធ្វើឱ្យធនញ្ជ័យមានគំនិតដោះស្រាយបញ្ហាទំនាស់ជាមួយសេដ្ឋីម្តងហើយម្តងទៀតតាំងពីរឿង៖

-រត់តាមសេះរើសអាចម៍សេះដាក់ថង់យាម

-ចាំចម្ការឱ្យគោស៊ីដំណាំ

-ឃ្វាលគោញី ចាប់គោញីធ្វើជាប្រពន្ធ

-អញ្ជើញសេដ្ឋីពិសាបាយស្រែកខ្លាំងៗ

-ភ្លើងឆេះផ្ទះស្រែកតិច

-ចាប់មេភ្លើង«ចង្រ្កាន»ជូនសេដ្ឋីជាដើម។

ហេតុនេះហើយទើបសេដ្ឋីមិនអាចទប់ទល់នឹងប្រាជ្ញាធនញ្ជ័យ រួចក៏បញ្ជូនធនញ្ជ័យទៅបម្រើស្តេច ហើយជួបបញ្ហាជាបន្តបន្ទាប់ជាមួយស្តេចដូចជា៖

**ក-កន្លែងទំនាស់** : នៅក្នុងព្រះរាជវាំង

**ខ-តួទំនាស់** : ធនញ្ជ័យ និង ស្តេច

**គ-បញ្ហាទំនាស់**

បញ្ហាទំនាស់រវាងធនញ្ជ័យ និងស្តេច ដំបូងឡើយគឺផ្តើមចេញពីការអួតអាងរបស់សេដ្ឋីដែលថាធនញ្ជ័យជាក្មេងមានប្រាជ្ញាឈ្លាសវៃហើយជាងគេ ហើយគ្មានមនុស្សឯណានឹងកុហកដូចគ្មាន។ បញ្ហានេះហើយជាបុព្វហេតុធ្វើឱ្យធនញ្ជ័យដោះស្រាយបញ្ហាទាំងនោះដូចជា៖

-រកក្បួនភរ

-មុជទឹករួចយកពងមាន់១ថ្វាយស្តេច

-ជិះដំរីចាស់ គ្រេចជើង

-ជិះសេះអុកចត្រង្គ

-បោសសម្អាតដំណាក់ស្រីស្នំ

-ជល់មាន់ជាមួយមាន់ស្តេច

-បណ្តេញធនញ្ជ័យចេញពីវាំង

-ចំតិតគូទថ្វាយស្តេច

-វាយសំស្រីស្នំព្រះនាងទៅ ជុះផង នោមផង ជោមផង ដែលខុសពីបណ្តាំស្តេច។

ដូច្នេះយើងឃើញថា បញ្ហាទាំងអស់ខាងលើនេះ ធនញ្ជ័យបានតស៊ូ អំណត់ព្យាយាមប្រើប្រាស់ប្រាជ្ញាមកដោះស្រាយបញ្ហា សមហេតុសមផល ច្បាស់លាស់ដោយជោគជ័យ។

សំណួរភ្ជាប់វិបត្តិទំនាស់ទី២ : តើភាពជោគជ័យរបស់ធនញ្ជ័យត្រូវបញ្ចប់ត្រឹមនេះឬយ៉ាងណា?

**៣-ទំនាស់វិបត្តិទី៣**

កិត្តិសព្ទប្រាជ្ញាដ៏ល្បីរបស់ធនញ្ជ័យបានល្បីរន្ទឺដល់ស្រុកចិន ជាហេតុធ្វើឱ្យស្តេចស្រុកចិនបញ្ជូនអ្នកប្រាជ្ញឱ្យមកសាកល្បងប្រាជ្ញា ហើយកើតចេញជាបញ្ហាជាច្រើនដូចជានៅស្រុកខ្មែរ និងស្រុកចិន។

**ក-ទីកន្លែង** : នៅស្រុកខ្មែរ និងស្រុកចិន

**ខ-តួទំនាស់** : ធនញ្ជ័យជាមួយអ្នកប្រាជ្ញចិន និងស្តេចស្រុកចិន។

**គ-បញ្ហាទំនាស់**

បញ្ហាទំនាស់រវាងធនញ្ជ័យជាមួយអ្នកប្រាជ្ញចិននិងស្តេចចិន រហូតដល់ស្តេចខ្មែរ គឺកើតឡើងដោយសារ«ភាពល្បីល្បាញនៃប្រាជ្ញារបស់ធនញ្ជ័យ»។ ដូច្នេះហើយបានជាស្តេចចិនបញ្ជាឱ្យអ្នកប្រាជ្ញ និងពួកនាម៉ឺនរបស់ខ្លួនមក «ភ្នាល់» ធនញ្ជ័យទាយ និងដោះប្រាស្នាជាបន្តបន្ទាប់ដូចខាងក្រោម៖

-ទាយគ្រាប់ឪឡឹកក្នុងដៃ

-ប្រស្នាសាច់ជ្រូក១នាឡិស៊ីបាន២ឆ្នាំ

-ចាបមួយធ្វើម្ហូបសម្រាប់៥០០នាក់

-ដោះប្រស្នាធ្វើយុថ្កាឱ្យបាន៥០០ក្នុង១ថ្ងៃ

-ដោះប្រស្នាជាមួយអ្នកប្រាជ្ញចិនចំនួន៥ដែលមាន៖

| | |
|---|---|
| ១-ចិនចង្អុលលើមេឃ | ធនញ្ជ័យចង្អុលព្រះអាទិត្យ |
| ២-ចិនចង្អុលក្រោមដី | ធនញ្ជ័យលាបាតដៃលើកម្រាមមួយ |
| ៣-ចិនចង្អុលចុះក្រោម | ធនញ្ជ័យចង្អុលមកខ្លួនឯង |
| ៤-ចិនលាម្រាមដៃប្រាំ | ធនញ្ជ័យបង្ហាញម្រាមមួយ |
| ៥-ចិនលាដៃសធ្វើជារង្វង់ | ធនញ្ជ័យបត់ដំដៃ |

-ធ្វើគម្ពីអក្សរជើងក្អាម។

## IV-**ទិដ្ឋភាពវិភាគតួអង្គ**

### ១-ធនញ្ជ័យ

**ក-គុណសម្បត្តិ**

-មានប្រាជ្ញាឈ្លាសវៃ ចេះដោះស្រាយបញ្ហាបានទាន់ពេលវេលា

-មានល្បិចកលខ្ពស់ ទប់ទល់ជាមួយអ្នកដែលមានបំណងធ្វើបាបខ្លួន

-ស្រឡាញ់កិត្តិយស ស្រឡាញ់ប្រទេសជាតិសុខចិត្តស្លាប់មិនឱ្យបាត់បង់កិត្តិយស និងទឹកដី

-ស្គាល់ច្បាស់នូវសុភមង្គលរបស់ខ្លួន «រកប្រពន្ធលុះត្រាតែពេញចិត្តទើបទទួល»

-គោរពច្បាប់ប្រពៃណី (ឱ្យម្ដាយចូលស្ដីដណ្ដឹងតាមប្រពៃណី)។

**ខ-គុណវិបត្តិ**

-មានគំនិតផ្ចាញ់ផ្ចាលសេដ្ឋី

-ប្រមាថលោកគ្រូសង្ក្រាជ

-មើលងាយស្ដេច

-ប្រើពាក្យអសុរោះជេរមេនំមេនាង

-ខ្វះសុជីវធម៌ក្នុងទំនាក់ទំនងជាមួយបរទេស (ជេរស្ដេចចិនថា មុខដូចឆ្កែ)។

### ២-សេដ្ឋី

**ក-គុណសម្បត្តិ**

-មានចិត្តសាស្ត្រខ្ពស់ ក្នុងការល្បួងលោមធនញ្ជ័យឱ្យបាត់យំ

-ដោះស្រាយបញ្ហាដោយសន្តិវិធី

-ព្រមទទួលយកធនញ្ជ័យឱ្យនៅបម្រើខ្លួន

-មិនប្រើអំពើហិង្សាលើធនញ្ជ័យ

-មានអំណត់អត់ធនចំពោះទង្វើរបស់ធនញ្ជ័យ។

**ខ-គុណវិបត្តិ**

-ធ្វើបាបធនញ្ជ័យដោយគ្មានពិចារណា (ដូចជាក្មេងអាយុ៧ឆ្នាំ ឱ្យរត់តាមសេះ...)

-ឆោតល្ងង់ ធ្វេសប្រហែសធ្វើឱ្យធនញ្ជ័យចាប់ចំណុចខ្សោយបាន។

### ៣-ស្ដេចខ្មែរ

**ក-គុណសម្បត្តិ**

-ខំការពារទឹកដី ទោះបីដឹងថាខ្វះសមត្ថភាពក៏ដោយ ក៏ខំពឹងលើ ធនញ្ជ័យ ធ្វើយ៉ាងណាកុំ

ឱ្យបរទេសយកទឹកដីបាន

-មានខន្តី អត់ធ្មត់ មិនធ្វើបាបធនញ្ជ័យ

-មិនអត្តនោម័ត អាងអំណាចឡើយ (សុខចិត្តធ្វើតាមបណ្តាំធនញ្ជ័យ សុខចិត្តសុខកាយទៅសួរសុខទុក្ខធនញ្ជ័យពេលគេឈឺ...)។

**ខ-គុណវិបត្តិ**

-ខ្វះសុភវិនិច្ឆ័យ ខ្វះការពិចារណា ជឿតែលើមន្ត្រី មានបំណងសម្លាប់ធនញ្ជ័យ ជាច្រើនលើក ខ្លាចធនញ្ជ័យដណ្តើមអំណាច

-ប្រើល្បិចកលមិនត្រឹមត្រូវក្នុងការផ្ចាញ់ធនញ្ជ័យ

-មិនចេះប្រើមនុស្សស្មោះត្រង់ និងមានប្រាជ្ញា

-អាត្មានិយម។

**៩-ស្តេចស្រុកចិន**

**ក-គុណសម្បត្តិ**

-មានគំនិតយល់ត្រូវ បានបញ្ជូនធនញ្ជ័យ ព្រមទាំងផ្តល់សម្ភារៈ និងមនុស្សឱ្យមកតាមថែរក្សាធនញ្ជ័យ។

**ខ-គុណវិបត្តិ**

-មានគំនិតចក្រពត្តិ ចង់លេបទឹកដីគេ ដោយគំនិតលោភលន់។

**V-ទិដ្ឋភាពសង្គម**

**ក-វប្បធម៌**

-ជំនឿ : ក្នុងរឿងបង្ហាញពីជំនឿលើការយល់សប្តិ ជឿលើហោរទស្សន៍ទាយ

-ប្រពៃណី ទំនៀមទម្លាប់ : មានពិធីចូលស្តីដណ្តឹង និងពិធីរៀបអាពាហ៍ពិពាហ៍

-សាសនា : ខ្មែរកាន់ព្រះពុទ្ធសាសនា ដោយនិយមឱ្យកូនទៅបួស មានគ្រូសង្រ្គាជ

-ការសិក្សាអប់រំ : ការសិក្សានៅក្នុងវត្តអារាម ដោយមានព្រះសង្ឃជាគ្រូ

-សិល្បៈ ល្បែង : និយមលេងល្បែងផ្សេងៗដូចជា លេងខ្លែង ជល់មាន់ ជល់ក្របី ល្បែងចត្រង្គ ល្បែងភ្នាល់ផ្សេងៗ។ ក្រៅពីនេះមានល្បែងអប់រំកាយ ដូចជាប្រដាល់ ចំបាប់...។

**ខ-សេដ្ឋកិច្ច**

-កសិកម្ម : ប្រជាជនប្រកបរបរកសិកម្ម ធ្វើស្រែចម្ការ (ក្នុងរឿងបង្ហាញពីប្រពន្ធសេដ្ឋីឱ្យអំបុកធនញ្ជ័យ ហើយធនញ្ជ័យទៅចាំចម្ការរបស់សេដ្ឋី...)

-ផលិតកម្ម : ខ្មែរចេះធ្វើនំបញ្ចុក (ធនញ្ជ័យធ្វើនំបញ្ចុកលក់នៅស្រុកចិន) និងចេះផលិតវត្ថុ សិល្បៈមានខ្លែងឯកជាដើម។

-សិប្បកម្ម : ប្រជាជនចេះត្បាញរវៃ (ប្រពន្ធសេដ្ឋីត្បាញសំពត់ ជ្រុះត្រល់ឱ្យធនញ្ជ័យរើស)

-ពាណិជ្ជកម្ម : មានការជួញដូរនៅក្នុងស្រុក តាមដងទន្លេ និងជួញដូរជាមួយចិន។

**គ-សង្គមកិច្ច**

-ស្ថានភាពរស់នៅ

-សុខាភិបាល

-មុខរបរ និងជីវភាពប្រជាជាជន

**ឃ-នយោបាយ**

-ក្នុងប្រទេស (អ្នកគ្រប់គ្រង របបគ្រប់គ្រង) ៖

-ក្រៅប្រទេស (ទំនាក់ទំនងអន្តរជាតិ)

**VI-ទិដ្ឋភាពនៃខនិពន្ធ(អត្ថរូប)**

**ក-ផ្ដើមរឿង**

-រឿងធនញ្ជ័យចាប់ផ្ដើមដោយបង្ហាញពីការចាប់កំណើតរបស់ធនញ្ជ័យ ដែលបណ្ដាលឱ្យម្ដាយធនញ្ជ័យយល់សប្ដិឃើញរឿងចម្លែក ដោយពុំមានរៀបរាប់វែងអន្លាយដូចប្រលោមលោកទេ។ «នេះនឹងស្រដីពីរឿងទៅធនញ្ជ័យ។ កាលដើមឡើយនៅពេលដែលមកចាប់កំណើតក្នុងពោះនាងជា ម្ដាយនាងនោះយល់សប្តិនៅពេលទៀបភ្លឺ ដូចជាយល់សូង យល់សប្តិឃើញ ដូងបេះបានទាំងផ្លែ យល់សប្តិឃើញខែ ខែនោះពេញបូណ៌មី...»។

**ខ-តួរឿង**

រឿងធនញ្ជ័យ ជារឿងប្រជាប្រិយ សរសេរជាពាក្យរាយ ដែលអ្នកនិពន្ធប្រើសិល្បវិធីមួយចំនួនដូចខាងក្រោម ៖

**-ពណ៌នាវិធី** : ការរៀបរាប់ដំណើររឿងធនញ្ជ័យ ពុំមានលក្ខណៈលន្លង់លន្លោចដូចរឿងប្រលោមលោកឡើយ គឺអ្នកនិពន្ធនិយាយត្រង់ៗ ចំៗ គ្មានបញ្ឆិតបញ្ឆៀងទេ «នេះនឹងស្រដីរឿងចៅធនញ្ជ័យ...»។

**-សន្ទេហវិធី** : ដំណើររឿងធនញ្ជ័យមានលក្ខណៈពិសេសមួយ គឺឈានពីធូរស្រាលសាមញ្ញ ទៅរកភាពស្មុគស្មាញ តានតឹងជាបន្តបន្ទាប់។ ប្រការនេះធ្វើឱ្យអ្នកអានមានការព្រួយ

បារម្ភចំពោះវាសនាធនញ្ជ័យចំពោះប្រស្នាស្ដេច ដែលកាន់តែពិបាកទៅៗ និងងឿងឆ្ងល់ ថាតើធនញ្ជ័យអាចដោះប្រស្នាបានឬទេ។

**-វឌ្ឍមានវិធី** : បញ្ហាចោទនៅក្នុងរឿងកាន់តែមានកម្រិតឈានឡើង ស្មុគស្មាញទៅៗ ធ្វើឱ្យធនញ្ជ័យជួនកាលអស់សង្ឃឹមទាល់ប្រាជ្ញាផងដែរ ដូចជាបញ្ហាទាយគ្រាប់ឪឡឹកជាដើម។

-រាល់ដំណោះស្រាយបញ្ហាគឺពឹងលើសមត្ថភាពផ្ទាល់ខ្លួនដូចនេះ(ធនញ្ជ័យអាចយកឈ្នះសេដ្ឋី ស្ដេចខ្មែរ ស្ដេចចិន ដោយប្រាជ្ញារបស់ខ្លួន)។

**-វចនវិធី** : ការប្រើប្រាស់ពាក្យសំដីក្នុងរឿង ជាពាក្យសាមញ្ញធម្មតារបស់អ្នកស្រុក ងាយ ស្ដាប់បានងាយយល់ ដូចជា អញ មឹង អា ឯង...។ យើងពុំសូវឃើញមានប្រើពាក្យបាលីឬសំស្ក្រឹតឡើយ ដោយឡែកមានការប្រើពាក្យបុរាណខ្លះ ដូចជា «បាទ» (មួយបាទស្មើនឹង ៦កាក់ ឬ៦០សេន) ដែលបច្ចុប្បន្នសៀមយកទៅប្រើជារូបិយវត្ថុរបស់គេ។ ក្រៅពីនេះ ឃើញមានប្រើពាក្យសង្ឃ (និមន្ត ពុទ្ធដិកា ព្រះតេជគុណ...) និងពាក្យស្ដេច (ទូលព្រះបង្គំ សព្វព្រះទ័យ...) ផងដែរ។

**-វចនាវិធី** : ចំពោះឃ្លាប្រយោគ ក៏ងាយយល់ ស្រួលស្ដាប់ពុំមានបង្កប់អត្ថន័យពិបាកយល់ឡើយ ឃ្លាខ្លី តែត្រឹមត្រូវ លើកលែងតែបណ្ដាំចុងក្រោយរបស់ធនញ្ជ័យ ដែលបង្កប់ន័យជ្រាលជ្រៅសម្រាប់អ្នកដឹកនាំពិចារណា។

**-សំវាទវិធី** : មានការសន្ទនារវាងធនញ្ជ័យ និងសេដ្ឋី, ធនញ្ជ័យនិងស្ដេច, ធនញ្ជ័យនិងមន្ត្រី...។

**-ឯកវាទវិធី** : ធនញ្ជ័យអង្គុយសញ្ជឹងគិតតែម្នាក់ឯង «ពេលនេះអញមុខជាស្លាប់មិនខានណ្ហើយធម្មតាទេសេចក្ដីស្លាប់តែងតែមានដល់សត្វទូទៅគ្រប់រូប...»។

**គ-បញ្ចប់រឿង**

-រឿងធនញ្ជ័យបញ្ចប់ដោយឱ្យអំពើល្អឈ្នះអំពើអាក្រក់ យុត្តិធម៌ឈ្នះអយុត្តិធម៌ ដែលស្របទៅតាមលក្ខណៈរបស់រឿងព្រេងទូទៅ។ ធនញ្ជ័យត្រូវស្លាប់ក៏ពិតមែន តែកេរ្ដិ៍ឈ្មោះ និងជ័យជំនះរបស់គេនៅតែមាន។ រាល់អំពើព្យាបាទរបស់ពួកស្រីស្នំ មន្ត្រី នាម៉ឺនទាំងអស់ត្រូវបរាជ័យនៅទីបំផុត។ ទោះបីធនញ្ជ័យត្រូវបាត់បង់ជីវិតក៏ដោយ ក៏ធនញ្ជ័យនៅតែឈ្នះជានិច្ចព្រោះថា ៖

-ធនញ្ជ័យអាចហៅស្ដេចមកជួបផ្ដែផ្ដាំ

-ធនញ្ជ័យធ្វើឱ្យស្ដេចបាត់ខឹង បាត់គំនុំ ហើយមកសួរសុខទុក្ខពេលឈឺធ្ងន់

-ធនញ្ជ័យអាចធ្វើឱ្យស្ដេចទទួលយកពាក្យបណ្ដាំរបស់ខ្លួន

-ធនញ្ជ័យអាចធ្វើឱ្យពួកមន្ត្រីកោតខ្លាចប្រាជ្ញារបស់ខ្លួន

-ធនញ្ជ័យអាចឈ្នះពួកស្រីស្នំ និងនាម៉ឺន តាមរយៈឱ្យប្រពន្ធយកចម្រូងឫស្សីមកដោតលើផ្ទះ។ ជ័យជម្នះរបស់ធនញ្ជ័យនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា«ប្រាជ្ញាជាអាវុធ»ពិតប្រាកដមែន។

**VII-វិជ្ជភាពតម្លៃ( អត្ថរស )**

**១-សោភណរស** : រឿងនេះល្អត្រង់ ៖

-ក្នុងផ្នែកអត្ថន័យ ប៉ិនចោទ និងប៉ិនស្រាយ

-ក្នុងផ្នែកអត្ថរូប រឿងនិយាយខ្លី តែពិរោះ ស្រួលស្ដាប់ ងាយយល់។

**២-នាដ្យរស** : បង្ហាញពីវិបត្តិទំនាស់មនុស្សធម្មតា មានឈ្នះ មានចាញ់ «ធនញ្ជ័យត្រូវគេព្យាបាទ និងសម្លាប់ជាច្រើនលើកច្រើនសាតាំងពីស្រុកខ្មែរដល់ស្រុកចិន ធ្វើឱ្យធនញ្ជ័យ និងក្រុមគ្រួសាររងវិបត្តិផ្លូវចិត្ត និងផ្លូវកាយ...»។

**៣-តថរស** : តម្លៃពិតស្ថិតនៅត្រង់ដំណើររឿងដែលអ្នកនិពន្ធបានបង្ហាញពីសច្ចភាពដែលកើតក្នុងជីវភាពរស់នៅក្នុងសម័យនោះដូចជា៖

-ពិតក្នុងការបង្ហាញតួអង្គដែលតំណាងឱ្យក្រុមមនុស្សគ្រប់ប្រភេទក្នុងសម័យនោះ មានប្រជារាស្ត្រ សេដ្ឋី នាម៉ឺន អាមាត្យ ស្ដេច ស្រីស្នំ ព្រះសង្ឃ មន្ត្រីចិន ស្ដេចចិន...។

-ពិតក្នុងបញ្ហាទំនាស់ គឺវណ្ណៈដែលត្រូវគេជិះជាន់ ក្រោកតស៊ូនឹងវណ្ណៈជិះជាន់គេ។

-ពិតក្នុងការពណ៌នារឿង (មនុស្សជិះជាន់ធ្វើបាបគ្នាពីមួយទៅមួយតាមឋានៈសង្គម)

-ពិតក្នុងបញ្ហារស់នៅរបស់ប្រជាជនក្នុងសង្គម ដែលមានការទាក់ទងជាពិសេសទៅលើជំនឿ ទំនៀមទម្លាប់ប្រពៃណីជាតិ ដូចជាការជឿលើយល់សប្តិ ការទស្សន៍ទាយ ការស្ដីដណ្ដឹងប្រពន្ធ និងពិធីរៀបមង្គលការ...។

-ពិតក្នុងវិធីដោះស្រាយបញ្ហា គឺមានចំណេះប្រាជ្ញា មានការតស៊ូព្យាយាមអង់អាចក្លាហានគឺឈ្នះ។

-ពិតត្រង់ខ្មែរមានទំនាក់ទំនងជាមួយចិនជាយូរមកហើយ ហើយជានិច្ចកាលចិនតែងប៉ុនប៉ងរំលោភលើអធិបតេយ្យភាពរបស់ខ្មែរ។

**៤-ហាសរស** : បង្ហាញពីភាពកំប្លែងក្នុងពាក្យសំដីកាយវិការ សកម្មភាពរបស់តួអង្គ(ធនញ្ជ័យរើសអាចម៍សេះដាក់ថង់យាមជូនសេដ្ឋីហូប ធនញ្ជ័យជិះសេះចត្រង្គ ជិះដំរីចាស់គ្រេចជើងដោលនឹងថ្មោលបើកក្ដោងតាមស្ដេច។ល។)។

**៥-សង្គមរស :** តម្លៃស្ថិតនៅលើអ្នកនិពន្ធបង្ហាញពីការរស់នៅរបស់មនុស្សក្នុងសង្គម ដូចជាប្រជាជនប្រកបរបរកសិកម្ម របបគ្រប់គ្រងដឹកនាំតាមបែបរាជានិយម ពួកមន្ត្រីមានអំណាចធ្វើបាបរាស្ត្រទន់ខ្សោយ ប្រទេសខ្មែរមានទំនាក់ទំនងជាមួយចិន។

**៦-កុសលរស :** អ្នកនិពន្ធបានផ្តល់នូវតម្លៃអប់រំដូចជា ៖

-ឱ្យស្រឡាញ់ចំណេះវិជ្ជា និងយុត្តិធម៌ ស្អប់ខ្ពើមអំពើជិះជាន់

-ឱ្យស្រឡាញ់ប្រជាជន មាតុភូមិ និងចេះថែរក្សាការពារបូរណភាពទឹកដី។

-មានស្មារតីអង់អាចក្លាហាន ព្យាយាម តស៊ូ ដើម្បីយុត្តិធម៌និងសិទ្ធិសេរីភាពរបស់ប្រជាជន

-កុំឱ្យមើលងាយមនុស្ស «ចេះឯងឱ្យក្រែងចេះគេ»

-មិនត្រូវជឿលើអបិយជំនឿហួសហេតុ មានការទស្សន៍ទាយជាដើម

-ឱ្យមានស្មារតីប្រុងប្រយ័ត្នជាប់ខ្លួនជានិច្ច។

## ការសន្និដ្ឋាន

រឿងធនញ្ជ័យជាអក្សរសិល្ប៍ប្រជាប្រិយ ដែលដូនតាខ្មែរបានបន្សល់ទុកមកតាំងពីយូរយារណាស់មកហើយ។ រឿងនេះត្រូវបានប្រជាជនទាំងចាស់ ទាំងក្មេងនិយមចូលចិត្ត ព្រោះវាមានទាំងកំប្លែង និងការអប់រំដ៏ល្អឱ្យចេះតស៊ូ អំណត់ព្យាយាម និងដោះស្រាយបញ្ហាដោយមានហេតុផល សម្រាប់បម្រើដល់ប្រយោជន៍ទូទៅរបស់ប្រជាជន។ ហេតុនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡា លើកយករឿងនេះ មកបញ្ចូលក្នុងកម្មវិធីសិក្សា ដើម្បីឆ្លុះបញ្ចាំងគ្រប់ទិដ្ឋភាពសង្គម ឱ្យសិស្សានុសិស្ស និងអ្នកអានជ្រួតជ្រាបកាន់តែស៊ីជម្រៅ។

# ឯកសារពិគ្រោះ


- ឃីង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ ១៩៩៨
- ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៩៩
- មីសែលត្រាណេ ការសិក្សារឿងរាមកេរ្តិ៍ ១៩៩៥
- លាង ហាប់អាន សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ រាមាយណៈឥណ្ឌា ១៩៦៦
- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ១៩៨៨
- វេចនានុក្រមវចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ , ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ ថ្នាក់ទី១២ លេខ០៣ អយក.សណន. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦
- សេង សោភា សិក្សារបៀបធៀបរឿងរាមកេរ្តិ៍ និងរឿងរាមគៀតថៃ សារណាបញ្ចប់ បរិញ្ញាអក្សរសាស្រ្តខ្មែរ ឆ្នាំ២០០៧
- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
- ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លេង ឆ្នាំ១៩៧៣
- សៀវភៅសិក្សាគោលភាសាខ្មែរ សៀវភៅសិស្សថ្នាក់ទី១០ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១០
- សៀវភៅសិក្សាគោលអក្សរសាស្រ្តខ្មែរ សៀវភៅសិស្សថ្នាក់ទី១១ បោះពុម្ពផ្សាយ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៥
- សៀវភៅសិក្សាគោលអក្សរសាស្រ្តខ្មែរសៀវភៅសិស្សថ្នាក់ទី១២បោះពុម្ពផ្សាយដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១២
- លី ធាមតេង សៀវភៅការផ្សាយរបស់អ្នកនិពន្ធខ្មែរ ឆ្នាំ១៩៧២។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង ប្រាសាទអង្គរវត្ត

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..........................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងប្រាសាទអង្គរ»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងប្រាសាទអង្គរ » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ«**សិក្សាអត្ថបទអក្សរសិល្ប៍**» ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ «**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង ប្រាសាទអង្គរវត្ត**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក យិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ តាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ

ប្រកាស ........................................................................................................i

បុព្វកថា ........................................................................................................ii

គណៈកម្មការ....................................................................................................iii

អារម្ភកថា........................................................................................................iv

មាតិកា............................................................................................................v

សេចក្តីផ្តើម.......................................................................................................

I. ការបង្ហាញអត្ថបទ..........................................................................................

II. ទិដ្ឋភាពទំនាកទំនងរឿង..................................................................................

III. ទិដ្ឋភាពទំនាស់..............................................................................................

IV. ទិដ្ឋភាពវិភាគតួអង្គ.......................................................................................

V. ទិដ្ឋភាពសង្គម................................................................................................

VI. ទិដ្ឋភាពតែងនិពន្ធ.........................................................................................

VII. ទិដ្ឋភាពតម្លៃ................................................................................................

VIII. ការសន្និដ្ឋាន...............................................................................................

IX. ឯកសារពិគ្រោះ.............................................................................................

# សិក្សាអត្ថបទអក្សរសិល្ប៍

## រឿងប្រាសាទអង្គរ

### I-ទិដ្ឋភាពប្រវត្តិ

### ក-អត្ថបទ

- ចំណងជើង:ប្រាសាទអង្គរ
- ប្រភព: ចំពោះប្រភពនៃរឿងប្រាសាទអង្គរនេះ គឺយកចេញពីប្រជុំរឿងព្រេងខ្មែរភាគ៥ ទំព័រ(១-១៧)របស់វិទ្យាស្ថានពុទ្ធសានបណ្ឌិត្យ ដែលបានប្រមូលចងក្រងឡើងតាមបណ្តាស្រុក ភូមិ ខេត្ត ខណ្ឌរបស់ខ្មែរនៅទូទាំងប្រទេសដោយក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ ដែលបោះពុម្ព និងផ្សព្វ ផ្សាយតាមរយ:ទស្សនាវដ្ដីកម្ពុជសុរិយានៅឆ្នាំ១៩៥៩។
- ប្រភេទព្រេងកថា

### ខ-អ្នកនិពន្ធ

- ឈ្មោះអ្នកនិពន្ធ : ចំពោះអ្នកនិពន្ធរឿងនេះគ្មាន ព្រោះជារឿងបែបប្រជាប្រិយដែលបាន កើតឡើងក្នុងស្រទាប់ប្រជាជន មហាជន ពោលគេអាចនិយាយថា ប្រជាជនជាអ្នកនិពន្ធដែល និយាយតគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងពីសម័យកាលមួយទៅសម័យកាលមួយ ផ្សេងទៀតហើយបន្តដល់សព្វថ្ងៃនេះ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានបង្កើតឡើងក្នុងឆ្នាំ ១៩៣០ដោយលោកស្រីស៊ុយហ្សាន ការប៉ឺឡែស(បារាំង) ហើយមានបេសកកម្មប្រមូលចង ក្រង និងស្រាវជ្រាវពីវប្បធម៌ អរិយធម៌ និងអក្សរសាស្ត្រខ្មែរក្នុងនោះវិទ្យាស្ថានបានខិតខំចង ក្រងរឿងព្រេងជាបន្តបន្ទាប់ពីស្រុក ភូមិ ខេត្ត ខណ្ឌ ហើយបានបោះពុម្ពពីភាគ១ដល់ភាគ៩ ដែលរួមមានរឿងប្រាសាទអង្គរវត្តក៏ជារឿងមួយក្នុងភាគ៥ផងដែរ។

### គ-កាលបរិច្ឆេទ

- រឿងប្រាសាទអង្គរនេះត្រូវវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបោះពុម្ពក្នុងឆ្នាំ១៩៥៩ ហើយ បានផ្សព្វផ្សាយតាមរយ:ទស្សនាវដ្ដីកម្ពុជសុរិយាជាបន្តបន្ទាប់។

### ឃ-សង្គមបរិយាកាស

### ១-កាលប្រវត្តិ

បើផ្អែកតាមដំណើររឿង គេអាចវាយតម្លៃបានថា រឿងប្រាសាទអង្គរនេះត្រូវបានបង្កើត

ឡើងក្រោយសម័យអង្គរ ព្រោះស្ថានភាពពិតនៃសង្គមខ្មែរនាពេលនោះ គឺប្រជាជនខ្មែរភាគច្រើនជឿលើកម្លាំងក្រៅខ្លួន ហើយអស់ជំនឿលើសមត្ថភាពខ្លួនឯងក្នុងការកសាងសមិទ្ធផលនានាជាពិសេសការកសាងប្រាសាទអង្គរជាស្នាដៃឯករបស់ខ្មែរគ្មានពីរ ដែលបានកសាងឡើងដោយព្រះបាទសូរ្យវរ្ម័នទី២(១១១៣-១១៥០គ.ស)តាមប្រវត្តិសាស្ត្រខ្មែរ។ ផ្ទុយទៅវិញប្រជាជនខ្មែរបែរជាជឿថា ប្រាសាទអង្គរត្រូវបានកសាងឡើងដោយព្រះពិស្ណុការទៅវិញដែលជាកូនកាត់រវាងតាលឹម សេង និងទេពធិតា ទិព សុតាចន្ទ។ទោះបីស្ថានភាពសង្គមខ្មែរនាពេលនោះមានវិបត្តិយ៉ាងណាក៏ដោយក៏អ្នកនិពន្ធរឿងប្រាសាទអង្គរនៅតែអះអាងថា ប្រាសាទអង្គរជាស្នាដៃឯកគ្មានពីរ ដែលបានកសាងឡើងដោយសមត្ថភាពមនុស្សពិតៗ(ព្រះពិស្ណុការ)ពោលពុំមានក្រុមទេវៈណាមួយមកជួយកសាងនោះទេ។

**២-ព្រឹត្តិការណ៍សំខាន់ៗ**

តាមប្រវត្តិសាស្ត្របានបញ្ជាក់ថា ប្រទេសកម្ពុជាក្រោយសម័យអង្គរបានជួបនូវវិបត្តិផ្ទៃក្នុងយ៉ាងធ្ងន់ធ្ងរ គឺការដណ្តើមអំណាចគ្នា។ក្រៅពីនេះ ក៏មានការឈ្លានពានពីប្រទេសជិតខាងមកលើប្រទេសកម្ពុជា ហើយបានបន្សល់នូវទុក្ខវេទនាគ្មានទីបញ្ចប់ដល់ប្រជាជនខ្មែរនៅពាសពេញផ្ទៃប្រទេស។ពេលខ្លះទៀត សង្គ្រាមរាំងជល់គ្នាឯងគ្មានទីបញ្ចប់ ហើយព្រះរាជាអង្គខ្លះបានទៅពឹងបរទេសឱ្យមកជួយធ្វើសង្គ្រាមបំផ្លិចបំផ្លាញស្ទើរគ្មានសល់ និងឈានដល់ដំណាក់កាលមួយ គឺប្រទេសកម្ពុជាគ្មានស្តេចសោយរាជ្យ ហើយត្រូវផ្សងព្រេងរកអ្នកមានបុណ្យមកសោយរាជ្យជំនួសខ្សែព្រះមហាក្សត្រទៅវិញ។

**II-ទិដ្ឋភាពទំនាក់ទំនងរឿង**

**ក-សង្ខេបរឿង**

ថ្ងៃមួយមាននាងទេពធិតា៥នាក់ស្ថិតនៅឯប្រាសាទព្រះឥន្ទ្រ បានហោះមករត់ប្រលែងគ្នាលេងឯស្ថានក្រោមក្នុងសួនច្បាររបស់តាលឹមសេង ដែលជាជនជាតិចិនម្នាក់មកពីក្រុងសៀងហៃ។ ពួកទេព ធិតាបានឃើញផ្ការីកស្គុះស្គាយព្រោងព្រាតក៏បបួលគ្នាចូលទៅក្នុងសួននោះ ទេពធិតាម្នាក់ឈ្មោះទិព សុតាចន្ទ ក៏បានបេះផ្ការបស់តាលឹមសេងចំនួន៦ទងព្រោះផ្កានោះមានក្លិនក្រអូបសាយល្អ។ នាងទិពសុតាចន្ទ បានក្លាយជាប្រពន្ធរបស់តាលឹមសេង អស់រយៈពេល៦ឆ្នាំ ដោយទទួលទណ្ឌកម្មតាមវិន័យនៃព្រះឥន្ទ្រក្នុងទោសលួចបេះផ្កា ។ ប្រមាណជាមួយឆ្នាំកន្លងមក ស្នេហារវាងតាលឹម សេង និងនាងទិព សុតាចន្ទក៏បង្កើតបានបុត្រប្រុសម្នាក់ឈ្មោះពិស្ណុការ។ ទារកនេះរពិសពន់ពេកនៅពេលដែលចេះវារ ចេះដឹកដីធ្វើជា

កំពែងការពារ ពេលចេះអង្គុយវាគូរលេងនៅលើដីធ្វើជារូបសត្វ រូបមនុស្ស ពោលគឺវាចូលចិត្ត គូរដីលេងឥតចេះខ្ជិល វាជាក្មេងពុំចេះនៅស្ងៀមមួយស្របក់ណាឡើយ។ ៦ឆ្នាំក្រោយមក នាង ទិព សុតាចន្ទក៏បានវិលត្រឡប់ទៅស្ថានលើវិញដោយបានយកបុត្រទៅជាមួយផងដែរ។នៅ គ្រានោះព្រះរាជាណាចក្រកម្ពុជា គឺព្រះបាទប្រទេសរាជ្យទ្រង់សោយព្រះទិវង្គតទៅ ព្រះអង្គ គ្មានព្រះរាជបុត្រា បុត្រីមួយព្រះអង្គណាដើម្បីសោយរាជ្យស្នងព្រះអង្គឡើយ។ព្រះញាតិវង្ស ព្រះថោងក៏បានផុតរលត់ទៅដែរ គេសង្កេតឃើញមាននៅសល់តែក្រុងហ្ស៊ីវ និងក្រាយហ្ស៊ីវពីររូប តែប៉ុណ្ណោះ ដែលជាអ្នកជាប់ព្រះលោហិតក្សត្រ កាលបើដូច្នេះព្រះរាជបល្ល័ង្កក៏នៅទំនេរ។

ថ្ងៃមួយមានបុរសទុគ៌តម្នាក់កំពុងប្រកបរបរកាប់អុសចិញ្ចឹមជីវិតស្រាប់តែមានភ្លៀងធ្លាក់ ចុះយ៉ាងខ្លាំង គាត់ក៏បានរត់ទៅជ្រកក្នុងខ្ទមអ្នកតាមួយ។ មួយសន្ទុះក្រោយមកក៏មានមាន់ស និងមាន់ខ្មៅ ជាការនិម្មិតរបស់ព្រះឥន្ទ្រាធិរាជ។ មាន់សរងាវ ឯមាន់ខ្មៅចេះនិយាយភាសា មនុស្សក៏និយាយថា នរណាមករងាវលើក្បាលអញដូច្នេះ? តើអ្នកឯងមានរិទ្ធិអំណាចយ៉ាង ណាទៅ?។ មាន់សឆ្លើយ«យើងមានរិទ្ធិអំណាចខ្លាំងណាស់ ប្រសិនបើនរណាមួយបានស៊ី សាច់យើងអ្នកនោះនឹងបានជាស្តេចផែនដី»រីឯមាន់ខ្មៅឆ្លើយថា «បើមនុស្សណាបានស៊ីក្បាល យើង អ្នកនោះនឹងបានជាស្តេចសង្ឃ បើមនុស្សស្រីណាបានស៊ីសាច់ភ្លៅយើង ស្រីនោះនឹង បានជាអគ្គមហេសីស្តេច បើមនុស្សប្រុសណាបានស៊ីសាច់ទ្រូងយើង អ្នកនោះនឹងបានសោយ រាជ្យ។ បុរសកំសត់បានស្តាប់ឮក៏លបៗចូលទៅចាប់មាន់ខ្មៅបាន ហើយសម្លាប់ភ្លាមយួរយក ទៅផ្ទះខ្លួន។ បុរសក៏និយាយការសម្ងាត់នេះប្រាប់ប្រពន្ធ។ ប្រពន្ធមានសេចក្តីរីករាយក្រៃលែង យកមាន់នោះទៅចម្អិនធ្វើម្ហូបដួសដាក់ចាន ដាក់ថាស លើកយកមកបម្រុងនឹងបរិភោគ ប៉ុន្តែ នៅពេលនោះ បុរសប្តីនិយាយទៅកាន់ប្រពន្ធថា «យើងជិតបានមកុដពាក់ហើយ ដូច្នេះយើង ត្រូវយកម្ហូបពិសេសនេះទៅឯមាត់ស្ទឹង យើងមុជទឹកដុសខ្លួនឱ្យស្អាតយកសម្លៀកបំពាក់ថ្មីៗ មកស្លៀកពាក់ឱ្យហើយហាររួចសឹមចាប់បរិភោគម្ហូបមាន់នេះ។ បុរសប្តីប្រពន្ធក៏ជញ្ជូនម្ហូបអាហារ ទៅដាក់មាត់ទឹក មុជទឹកក្នុងស្ទឹងលេងយ៉ាងសប្បាយ លុះងើបពីទឹកឡើងបុរសប្តីប្រពន្ធរក មើលថាសដាក់ម្ហូបពុំឃើញ ដោយរលកទឹកបានគួចយកថាសនោះរសាត់ទៅតាមខ្សែទឹកបាត់ ទៅ។

នៅថ្ងៃនោះដែរមានទម័កដំរីម្នាក់ឈ្មោះទា បាននាំដំរីជាច្រើនទៅឱ្យចុះត្រាំទឹកស្ទឹង នោះក៏បានឃើញថាសនោះអណ្តែតមក គាត់ក៏លើកយកថាសទៅបង្ហាញព្រះសង្ឃមេវត្ត

មួយព្រះអង្គ។ លោកសង្ឃបានស្គាល់ច្បាស់នូវគុណភាពនៃសាច់នោះ ក៏ចាប់យកក្បាលមាន់ឆាន់ទៅរួចលោកប្រទានសាច់ទ្រូងទៅឈ្មោះទា ឯសាច់ភ្លៅទៅនាងវងជាប្រពន្ធ ប៉ុន្តែលោកឥតមានពុទ្ធដីកាថាអ្វីឡើយ។ទា និងវងក៏បួលគ្នាត្រឡប់ទៅផ្ទះវិញទៅ។និយាយពីបុរសប្តីប្រពន្ធ គាត់បានខំដើររកថាសម្ងួបនោះគ្រប់កន្លែងទាំងអស់ ប៉ុន្តែពុំឃើញសោះ គាត់គិតថាប្រាកដជាមាននរណាមកលួចយករបស់នេះទៅ គាត់ក៏ប្រទេចផ្តាសាជនពុំស្គាល់មុខនោះរាប់ពុំអស់។ខណៈនេះដែរ ព្រះរាជណាចក្រកម្ពុជាពុំទាន់មានព្រះមហាក្សត្រគ្រងរាជ្យនៅឡើយទេ ដូច្នេះគេត្រូវបញ្ចេញដំរីមកចងកូប ហើយបួងសួងដល់ទេវតាសូមឱ្យនាំដំរីចេញទៅលុតជង្គង់ខ្លួនឯងចំពោះមុខជនណាមួយ ដែលអាចអង្គុយលើរាជបល្ល័ង្គបាន ហើយសូមឱ្យដំរីលើកបុរសនោះដាក់លើក្បាលនាំមកទីនេះ ដើម្បីយើងនឹងរៀបព្រះរាជពិធីអភិសេកបុរសនោះឱ្យឡើងសោយរាជ្យក្នុងព្រះនគរ ។ ដំរីដើរទៅរកហ្មទា និងនាងវង ហើយលុតជង្គង់នៅមុខជនទាំងពីរនាក់រួចលើកអ្នកទាំងពីរនាក់នោះដាក់លើក្បាលបញ្ជិះមកកាន់ព្រះបរមរាជវាំង។ពេលជាមួយគ្នានេះ ពួកមន្ត្រីក៏រៀបចំធ្វើព្រះរាជពិធីរាជាភិសេកភ្លាមតាមប្រពៃណី។ ហ្មទាក៏បានទទួលព្រះបរមនាមថា ទេវងអស្ចារ្យ។

រីឯក្រុងហ្វិវ និងក្រាយហ្វិវមានសេចក្តីអន់ព្រះទ័យមិនព្រមចុះចូលព្រះមហាក្សត្រអង្គថ្មី ក៏រត់ទៅស្រុកបាកានខេត្តពោធិ៍សាត់ ហើយទ្រង់បានសង់ប្រាសាទមួយនៅទីនោះ។ តំណាលពីព្រះឥន្ទ្រាធិរាជទ្រង់សង្កេតឃើញព្រះអគ្គមហេសីនៃព្រះមហាក្សត្រអង្គថ្មីពុំទាន់មានព្រះរាជបុត្រនៅឡើយក៏ទ្រង់ព្រះចិន្តាថា «យើងនឹងផ្តល់ព្រះរាជបុត្រមួយអង្គដល់ព្រះនាងវងព្រះរាជបុត្រនេះមានសញ្ជាតិជាព្រះឥន្ទ្រសុទ្ធ ដើម្បីឱ្យជាប់ជាព្រះញាតិវង្សសោយរាជ្យក្នុងប្រទេសខ្មែរជានិរន្តតទៅ។ព្រះអគ្គមហេសីវងទ្រង់មានព្រះគិភពីត្រឹមពេលនោះមក ហើយទ្រង់ប្រសូតព្រះរាជបុត្រាមួយព្រះអង្គថ្វាយព្រះនាមថា «ព្រះកេតុមាលា»មានន័យថា កម្រងផ្កា។ព្រះឥន្ទ្រក៏លើកពព្រះកេតុមាលាហោះទៅកាន់ឋានទេវតា។ បន្ទាប់មកព្រះឥន្ទ្រក៏នាំព្រះកេតុមាលាចូលទៅក្នុងប្រាសាទព្រះអង្គរួច ព្រះឥន្ទ្រអញ្ជើញទេវតា៧នាក់ឱ្យមកសូត្រសែកមន្តគាថា និងប្រោះព្រំទឹកមន្តទៅលើព្រះកេតុមាលា ដើម្បីឱ្យបានអាយុជាងមួយរយឆ្នាំ។ កាលបើព្រះកេតុមាលាបានសង្កេតឃើញប្រាសាទព្រះឥន្ទសព្វគ្រប់អស់ហើយ នាយសារថីក៏នាំព្រះកេតុមាលាទៅមើលក្រោលគោសួគ៌ទៀត។ ព្រះឥន្ទ្រក៏សួរទៅព្រះកេតុមាលាថា «អ្នកពេញចិត្តនឹងអ្វី ដែលអ្នកបានឃើញឬទេ?» ព្រះកេតុមាលាទូលថា«ទូលព្រះបង្គំចង់ឱ្យគេសង់ប្រាសាទ

មួយដែលមានលម្អប្រហែលក្រោលគោព្រះអង្គ»។ ព្រះអង្គក៏ទ្រង់ព្រះសម្រួលថា «ក្រោលគោនេះជារបស់ល្អចំពោះភ្នែកឯងហើយឬ?» ហើយទ្រង់មានបន្ទូលទៅកាន់ព្រះពិស្ណុការថា «ថៅឯងជាមនុស្សលោកពុំអាចស្ថិតក្នុងឋានលើនេះបានរហូតទេ យើងបញ្ជូនថៅឯងទៅប្រទេសកម្ពុជា ហើយត្រូវឯងសង់ប្រាសាទឱ្យព្រះរាជបុត្រ យើងមួយខ្នងឱ្យមានសោភណភាពល្អជាងក្រោលគោយើង។

កាលបើព្រះពិស្ណុការបានពិនិត្យមើលក្រោលគោព្រះឥន្ទ្រសព្វគ្រប់ហើយ ព្រះឥន្ទ្រក៏ទ្រង់ព្រះរាជបញ្ជាឱ្យគេរៀបចំទឹមព្រះរាជរថព្រះអង្គ បញ្ជិះព្រះកេតុមាលា និងព្រះពិស្ណុការចុះមកកាន់ដីត្រង់ប្រទេសកម្ពុជា។ ព្រះពិស្ណុការក៏ចាប់សង់ប្រាសាទភ្លាមនៅព.ស៦២០[1]។ លោកបង្គាប់ឱ្យជីកស្នាមភ្លោះយកអាចម៍ដីចាក់គរលើគ្នាយ៉ាងខ្ពស់រួចទើបព្រះពិស្ណុការយករូបចម្លាក់ផ្សេងៗទៅផ្តិតលើដីនោះគ្រប់ទិសទាំងអស់។ តំណាលពីកូនមេភូមិម្នាក់ឈ្មោះសុវណ្ណ អ្នកកម្លោះបានចូលធ្វើជាកម្មករព្រះពិស្ណុកា។ ការសង់ប្រាសាទនេះ ព្រះពិស្ណុការឥតចាំបាច់ចងរន្ទាដាំសសរម្តងមួយៗនោះទេ គឺលោកយកដីមកសង់ជាប្រាសាទ៥ជាន់តែម្តងទើបយកទឹកថ្នាំលាយទៅលាបពីលើតួប្រាសាទដីទាំងមូល។ ប្រាសាទនោះក្លាយទៅជាថ្ម។ អាស្រ័យហេតុនេះហើយ បានជាយើងឃើញត្រង់រង់កោងនៃដំបូលប្រាសាទឥតមានរន្ធូត ឬសសរទ្រូពីក្រោមទេ។ លុះស្ថាបនាបានជាស្រេចកាលណា ព្រះពិស្ណុការក៏លាបថ្នាំលើរូបចម្លាក់ទាំងអស់នោះតម្រូវទៅតាមពណ៌ផ្សេងៗធ្វើឱ្យប្រាសាទមានលម្អយ៉ាងត្រចះត្រចង់ គឺល្អដូចក្រោលគោព្រះឥន្ទ្រ។ ព្រះកេតុមាលាពេញចិត្តនឹងប្រាសាទនោះណាស់បានពោលសរសើរព្រះពិស្ណុការពុំដាច់ពីមាត់ឡើយ ហើយបានសុំឱ្យព្រះពិស្ណុការសង់ប្រាសាទឯទៀតជាច្រើន ដែលមានរូបចម្លាក់យ៉ាងឆើតឆាយ។ ព្រះឥន្ទ្រាធិរាជ និងពួកទេវតាជាច្រើនតាមដង្ហែផងបានយាងចុះមកឋានក្រោមប្រសិទ្ធពរអភិសេកព្រះរាជបុត្រព្រះអង្គ គឺព្រះកេតុមាលា រួចទ្រង់ហៅប្រទេសខ្មែរយើងដូចសព្វថ្ងៃ។

ពេលក្រោយមក ព្រះកេតុមាលាទ្រង់បានសង្កេតឃើញកំពូលប្រាសាទមួយពុំសូវត្រង់ ទ្រង់ក៏មានព្រះបន្ទូលប្រាប់ព្រះពិស្ណុការឱ្យឡើងតម្រង់កំពូលនោះ។ព្រះពិស្ណុការក៏ប្រើស្ត្រីម្នាក់។ឱ្យយកផ្លែឃ្លោកទុំទៅគោះកំពូលប្រាសាទ កំពូលប្រាសាទនោះបានត្រង់ឡើងវិញ។ ក្រោយពីនោះបន្តិចមកទៀត ព្រះកេតុមាលាទ្រង់បានប្រគល់ដែកទម្ងន់៣ហាប ដើម្បីឱ្យព្រះ

[1] ខុសសម័យកាលនៃការកសាងប្រាសាទអង្គរ

ពិស្ណុការធ្វើព្រះខ័នមួយជានិម្មិតរូបនៃតេជានុភាពព្រះអង្គថ្វាយព្រះអង្គ។ ព្រះពិស្ណុការបានយកដែកទៅស្ល

រំលាយធ្វើព្រះខ័នតូចមួយមានមុខស្ដើងមុតក្រៃលែង។ ព្រះពិស្ណុការបានយកព្រះខ័ន

នោះទៅលត់ទឹកយ៉ាងត្រឹមត្រូវរួចយកទៅថ្វាយព្រះកេតុមាលា។ ព្រះកេតុមាលាបានទតឃើញទំហំព្រះខ័នភ្លាមទ្រង់ក៏ក្រោធខឹងក្រៃលែង និងស្ដីបន្ទោសដល់ព្រះពិស្ណុការនៅចំពោះមុខនាម៉ឺន អស់មន្ត្រីទាំងឡាយ។ ព្រះពិស្ណុការខឹងច្រឡោត ហើយក៏ត្រឡប់ទៅនៅប្រទេសចិនវិញដែលជាស្រុកកំណើតរបស់បិតាតាមសំពៅបាត់ទៅ។

**ខ-វាយតួអង្គ**

**ខ-១-តួអង្គជាទេវៈ និងមនុស្ស**

១-ព្រះកេតុមាលាៈជាបុត្ររបស់ស្ដេចទេវងអស្វារ្យដែលព្រះឥន្ទ្រាបានមកចាប់កំណើត និងជាអ្នកបញ្ជាឱ្យព្រះពិស្ណុការសាងសង់ប្រាសាទអង្គរ

២-ព្រះពិស្ណុការៈ បុត្ររបស់តាលឹម សេង និងនាងទិព សុតាចន្ទ និងជាអ្នកមានបញ្ញាវាងវៃក្នុងការសង់ប្រាសាទអង្គរ

៣-ព្រះឥន្ទ្រាធិរាជៈជាស្ដេចនៃទេវតា និងជាអ្នកដាក់ទណ្ឌកម្មនាងទិព សុតាចន្ទ និងជាបិតាជាតិមុនរបស់ព្រះកេតុមាលាតាមរយៈការទម្លាក់កម្រងផ្កា

៤-ព្រះសង្ឃៈ ជាមេវត្ត និងក្លាយជាស្ដេចសង្ឃបន្ទាប់ពីបានឆាន់ក្បាលមាន់

៥-តាលឹម សេងៈ ជនជាតិចិនមកពីខេត្តសៀងហៃ ជាស្វាមីនាងទិព សុតាចន្ទ និងជាឪពុករបស់ព្រះពិស្ណុការ

៦-នាងទិព សុតាចន្ទៈជាទេពធិតាមកពីស្ថានព្រះឥន្ទ្រ និងជាប្រពន្ធតាលឹម សេងនិងជាម្ដាយរបស់ព្រះពិស្ណុការ

៧-ទេវងអស្វារ្យៈអតីតហ្មដំរីឈ្មោះទា ហើយក្លាយជាស្ដេចផែនដី និងជាបិតាបង្កើតរបស់ព្រះកេតុមាលា

៨-អគ្គមហេសីវងៈជាមហេសីរបស់ស្ដេចទេវងអស្វារ្យ និងជាមាតារបស់ព្រះកេតុមាលា

៩-ក្រុងហ៊្សូវ ក្រាយហ៊្សូវៈ ជាអ្នកជាប់ខ្សែស្រឡាយព្រះរាជាមុនៗ និងបានកសាងប្រាសាទនៅខេត្តពោធិ៍សាត់

១០-ព្រះឥន្ទ្រៈ ជាអ្នករស់នៅស្ថានលើ និងបញ្ជូននាងទិព សុតាចន្ទមកស្ថានកណ្ដាល

១១-ទេវបុត្រៈ ជាអ្នកបច្ចេកទេសខាងសិល្បៈ សំណង់ និងជាគ្រូបង្រៀនដល់ព្រះ
ពិស្ណុការនៅស្ថានទេវតា

១២-បុរសកំសត់ពីរនាក់ប្ដីប្រពន្ធៈ ជាអ្នកក្រទុគ៌ត មហិច្ឆតាលោភលន់ចង់ក្លាយជាស្ដេច
ផែនដី តែឆោតល្ងង់

**ខ-២-តួអង្គជាសត្វ**

១-ដំរីៈ ជាសត្វប្រចាំព្រះបរមព្រះរាជវាំងសម្រាប់ផ្សងស្វែងរកអ្នកមានបុណ្យដើម្បីក្លាយ
ជាស្ដេចសោយរាជ្យ

២-មាន់ស និងមាន់ខ្មៅៈ ជាមាន់ដែលកើតចេញពីទេពនិម្មិតរបស់ព្រះឥន្ទ្រាធិរាជ

**គ-កាលអវកាស**

\+ **កាល**

ចាប់តាំងពីនាងទេពធិតា ទិពសុតាចន្ទចុះមកលេងស្ថានកណ្ដាលនិងរយៈពេលត្រឡប់ទៅស្ថានលើវិញ រួមទាំងត្រឡប់មកនៅជាមួយតាលឹម សេងរយៈពេលប្រាំមួយឆ្នាំ រួចត្រឡប់ទៅស្ថានលើវិញ។ ក្រោយមកយកពិស្ណុការទៅស្ថានលើរៀនខាងសិល្បៈសំណង់ប្រហែលជាងដប់ឆ្នាំ រួចចុះមកវិញកសាងប្រាសាទអង្គរ។ ដូចនេះពេលវាលាដែលដំណើររឿងប្រព្រឹត្តទៅប្រហែលពីដប់ប្រាំឆ្នាំទៅម្ភៃឆ្នាំ ឬអាចច្រើនជាងនេះ។

\+**អវកាស**

ដំណើររឿងបានប្រព្រឹត្តទៅនៅស្ថានកណ្ដាល(មនុស្ស) និងស្ថានលើ(ទេវតា)។
ស្ថានកណ្ដាលមានជាប់ទាក់ទងជាមួយភូមិសាស្ត្រនៃប្រទេសកម្ពុជាដូចជា បឹងទន្លេសាប
ស្រុកសំរោងសែន ស្រុកកំពង់លែង(កំពង់ឆ្នាំង) តំបន់ប្រាសាទអង្គរ(ខេត្តសៀមរាប) និងខេត្តពោធិ៍សាត់ជាដើម។ ចំណែកឯក្រៅប្រទេសទាក់ទងជាមួយប្រទេសចិន ខេត្តសៀងហៃ។

**III-ទិដ្ឋភាពទំនាស់**

**១-ទីកន្លែងទំនាស់**

ក-ស្ថានទេវតា និងស្ថានមនុស្សលោក

ខ-ស្ថានមនុស្សលោក និងស្ថានមនុស្សលោក

**២-តួទំនាស់៖**

ក-ទេវតា និងមនុស្ស

ខ-មនុស្ស និងមនុស្ស

## ៣-បញ្ហាទំនាស់

### ក-សារជាតិទេវតា និងសារជាតិមនុស្ស

- ទំនាស់៖

ទេវតា និងទេពធិតា ដែលតែងតែតំណាងសភាវៈល្អ អ្នកសង្គ្រោះ អ្នកអន្តរាគមន៍ដល់មនុស្ស ឬសត្វឱ្យរួចផុតពីទុក្ខគ្រប់យ៉ាង តែទេពធិតានៅទីនេះបែរជាទៅលួចបេះផ្កាចំនួន៦ទងក្នុងសួនច្បាររបស់តាលឹម សេង(មនុស្សលោក)។ទង្វើនៃអំពើលួចរបស់នាងទិព សុតាចន្ទបានក្លាយជាអំពើបាបដោយទទួលទោសទណ្ឌកម្មពីព្រះឥន្ទ្រាធិរាជ គឺនាងត្រូវមកបម្រើមនុស្សលោកគឺតាលឹម សេងចំនួន៦ឆ្នាំទៅតាមចំនួនទងផ្កា។

- ដំណោះស្រាយ៖

ចំណងនៃទំនាក់ទំនងរវាងទេពធិតា និងមនុស្សក៏បានក្លាយជាចំណងស្នេហ៍ប្ដី ប្រពន្ធ ហើយប្រសូត្របានកូនប្រុសម្នាក់ឈ្មោះពិស្ណុការ មានបញ្ញាឈ្លាសវៃ ឆ្លាត ចេះគូសវាស ឆ្លាក់។ ក្រៅពីនេះ នាងទិព សុតាចន្ទបានបង្ហាត់បង្រៀនពីជំនាញត្បាញដល់មនុស្សលោកឱ្យចេះត្បាញសំពត់ ក្រមារហូតក្លាយជាមុខរបរចិញ្ចឹមជីវិតទៀតផង។រយៈពេល៦ឆ្នាំកន្លងផុត នាងទិព សុតាចន្ទក៏បានវិលត្រឡប់ទៅស្ថានទេវតាវិញដោយបន្សល់ទុកកូនប្រុស និងស្វាមីនៅស្ថានមនុស្សលោក។

### ខ-មនុស្ស និងមនុស្ស

- ទំនាស់៖

ស្ថានភាពនៃប្រទេសកម្ពុជាពុំមានស្ថិរភាពនយោបាយច្បាស់លាស់ បង្កើតនូវភាពចលាចលពេញនគរ ដែលបណ្ដាលឱ្យប្រជាជនជួបគ្រោះទុរ្ភិក្ស។ចំណែកឯអ្នកគ្រប់គ្រងវិញគឺចាប់ពីរាជវង្សព្រះថោងបានផុតរលត់ទៅ ប្រទេសកម្ពុជាពុំមានព្រះមហាក្សត្រមកសោយរាជ្យនោះទេ ដែលទំនងបណ្ដាលមកពីកត្តាសង្គ្រាម។

- ដំណោះស្រាយ៖

ព្រះឥន្ទ្រាធិរាជបាននិម្មិតធ្វើជាមាន់គកពីរមួយសម្បុរសមួយ សម្បុរខ្មៅមួយ។ទម័កដំរីម្នាក់ឈ្មោះទា និងប្រពន្ធឈ្មោះរងបានបរិភោគសាច់មាន់គកនោះក៏បានក្លាយជាស្ដេចនៃប្រទេសកម្ពុជាតាមរយៈការផ្សងនៃសត្វដំរីរបស់ព្រះបរមរាជវាំង។ ព្រះមហាក្សត្រថ្មីមានព្រះនាមថា ស្ដេចទេវងអស្ចារ្យ ហើយប្រសូតបានបុត្រាមួយព្រះអង្គមានព្រះនាមថា ព្រះកេតុមាលា ដែលជាបុត្ររបស់ព្រះឥន្ទ្រាធិរាជមកចាប់ជាតិ ហើយមានន័យថា កម្រងផ្កា។

ដោយអំណាចបារមីនៃកេតុមាលាក៏ព្រះឥន្ទ្របានយកទៅស្ថានទេវតា ដើម្បីបានពិនិត្យមើលទេសភាពដ៏ត្រកាលដែលក្នុងនោះមានប្រាសាទក្រោលគោដ៏ប្រណិតគ្មានពីរ។ ព្រះឥន្ទ្រាធិរាជបានបញ្ជាឱ្យព្រះពិស្ណុការកសាងប្រាសាទក្រោលគោនៅស្ថានមនុស្ស ដើម្បីថ្វាយព្រះកេតុមាលាជាស្តេចសោយរាជ្យ។

IV-**ផិដ្ឋភាពវិភាគតួអង្គ**

**១-ព្រះកេតុមាលា**

**ក-គុណសម្បត្តិ**

-ជាមនុស្សមិនលោភលន់

-ជាមនុស្សគោរពនិងខ្លាចចិត្តអ្នកដទៃ

-មានការគោរពនិងស្តាប់បង្គាប់ឪពុកម្តាយ

-ស្រឡាញ់និងថែរក្សាប្រាសាទ

-ចេះកសាងនិមិត្តរូបដែលជាដួងព្រលឹងជាតិ

-ជាក្សត្រគ្រប់គ្រងនិងដឹកនាំជាតិឱ្យមានការរីកចម្រើន។

- ព្រះកេតុមាលា(កម្រងផ្កា)ជាបុត្ររបស់ស្តេចទេវងអស្វារ្យ និងព្រះអគ្គមហេសី ដែលព្រះឥន្ទ្រាធិរាជបានមកចាប់កំណើត។ព្រះកេតុមាលាត្រូវបានព្រះឥន្ទ្រាធិរាជសព្វព្រះទ័យយកទៅស្ថានទេវតាហើយឱ្យទស្សនាទេសភាពទាំងឡាយនៅស្ថានព្រះឥន្ទ្រនិងបានងូតទឹកក្រអូបនិងបានទទួលមន្តសីលពីព្រះឥន្ទ្រ ដើម្បីបានអាយុច្រើនជាងមនុស្សលោកគឺ១០០ឆ្នាំ។

- ព្រះកេតុមាលាត្រូវបានព្រះឥន្ទ្រាធិរាជប្រគល់អាណាចក្រកម្ពុជាឱ្យគ្រប់គ្រងជាស្តេចសោយរាជ្យ ដែលមានព្រះនាមថា អរិដ្ឋពលពាហនោចាប់ពីពេលនោះតរៀងមក។ ក្រៅពីនេះព្រះឥន្ទ្រាធិរាជបានបញ្ជាព្រះពិស្ណុការកសាងប្រាសាទ ដែលចម្លងតាមប្រាសាទក្រោលគោរបស់ព្រះអង្គនៅស្ថានទេវតាឱ្យមកកសាងនៅស្ថានមនុស្ស ដើម្បីថ្វាយព្រះកេតុមាលាដែលជាស្តេចអាណាចក្រកម្ពុជា។ ជាមួយគ្នានេះ ព្រះពិស្ណុការក៏បានកសាងប្រាសាទថ្មីៗនិងបានសិតព្រះខ័នរាជដ៏មុតស្រួចដូចស្លឹកស្រូវថ្វាយព្រះកេតុមាលា។

**ខ-គុណវិបត្តិ**

-ឆាប់ស្ដីបន្ទោស ដាក់កំហុសដល់អ្នកដទៃដោយខ្វះការពិចារណារកហេតុផលបានត្រឹមត្រូវ

-ធ្វើឱ្យបាត់បង់មនុស្សមានសមត្ថភាព។

- ព្រះកេតុមាលាដែលមានកំណើតពីព្រះឥន្ទ្រាធិរាជ និងជាបុត្ររបស់ព្រះរាជាប៉ុន្តែពុំមាន

បញ្ញាបារមី ចំណេះដឹង ជំនាញខាងសិល្បៈកសាងប្រាសាទ សិតដែក ឆ្លាក់មាស ប្រាក់ សំរិទ្ធ បានដូចព្រះពិស្ណុការឡើយ។

▪ ព្រះកេតុមាលាជាស្តេចចូលចិត្តឆាប់ស្តីបន្ទោស ដាក់កំហុសដល់អ្នកដទៃ ដែលនៅក្រោមឱវាទដោយខ្វះការពិចារណារកហេតុផលឱ្យបានត្រឹមត្រូវ និងជាអ្នកមិនសូវដឹងគុណសម្បត្តិដល់អ្នកចេះដឹងដូចជា ការស្តីបន្ទោសដល់ព្រះពិស្ណុការដែលធ្វើឱ្យគាត់ខឹងក៏រត់ទៅកាន់ប្រទេសចិនវិញតាមសំពៅបាត់ទៅ។

**២-ព្រះពិស្ណុការ**

**ក-គុណសម្បត្តិ**

-ស្រឡាញ់ឪពុកម្តាយ

-ជាមនុស្សមានទេពកោសល្យនិងសមត្ថភាពខ្ពង់ខ្ពស់

-ព្យាយាមសិក្សារៀនសូត្ររហូតមានចំណេះជំនាញពិតប្រាកដ

-ព្យាយាមស្វះស្វែងរកម្តាយជាអ្នកមានគុណគ្រប់ច្រកល្ហក

-មានបច្ចេកទេស វិធីសាស្ត្រក្នុងការតម្រង់កំពូលប្រាសាទ

-ចេះវិជ្ជាសិល្បៈសព្វបែបយ៉ាងដូចជា ឆ្លាក់ សូនរូប ស្លលោហធាតុ។

▪ ព្រះពិស្ណុការ គឺបុត្ររបស់តាលឹម សេង(សារជាតិមនុស្ស) និងនាងទិព សុតាចន្ទ(ជាតិទេវតា) ហើយត្រូវបានម្តាយរត់ចោលនៅអាយុ៥ឆ្នាំក្លាយជាកុមារកំព្រារស់នៅយ៉ាងកំសត់ជាមួយឪពុក។ ព្រះពិស្ណុការជាកុមារពិសពន់ពេក នៅពេលដែលវាចេះវារ វាចេះជីកដីធ្វើជាកំពែង ការពារ ពេលចេះអង្គុយវាគូរលេងនៅលើដីធ្វើជារូបសត្វ រូបមនុស្ស ចូលចិត្តគូរដីលេងឥតចេះខ្ជិលឥតឈប់ឈរ វាជាក្មេងពុំចេះនៅស្ងៀមមួយស្របក់ណាសោះឡើយ ពោលគឺជាក្មេងរៀនចេះចំណេះ ជំនាញដោយពុំមានគ្រូបង្រៀនឡើយ។

▪ ព្រះពិស្ណុការមានសារជាតិជាមនុស្សលោក ប៉ុន្តែមានឱកាសបានទៅបន្តការសិក្សានៅស្ថានទេវតាជាមួយទេវបុត្រ ដែលជាអ្នកបច្ចេកទេសខាងវិជ្ជាសិល្បៈ និងខាងសំណង់។យុវជននោះខំរៀនគូរ រៀនឆ្លាក់ រៀនភ្លេង អំពីសំណាក់ទេវតបុត្រជាគ្រូទាំងនោះបានចេះចាំស្ទាត់សព្វគ្រប់ទាំងអស់ គឺចេះសង់នាវាអាចបើក បរលើគោកបាន ចេះឆ្លាក់ប្រាក់ ឆ្លាក់មាស ចេះស្លដែកគ្រប់យ៉ាង និងចេះវិជ្ជាលាយទឹក ហើយទឹកនោះបើកាលណា គេចាក់លើដីឥដ្ឋ ដីនោះនឹងក្លាយទៅជាថ្ម។

▪ ព្រះពិស្ណុការបានក្លាយវិស្វករគ្មានពីរក្នុងការកសាងប្រាសាទនានាដ៏ល្អរហូតក្លាយជានិមិត្តរូបនៃការស្ថាបនារបស់មនុស្សក្នុងសង្គមខ្មែរ ពោលគឺនៅពេលមនុស្សលោកតែងតែរៀបចំដង្វាយថ្វាយព្រះពិស្ណុការជាមុនសិន។ប្រដាប់ដង្វាយមានដូចតទៅនេះ គឺស្រាមួយដបប្រាក់១រៀល ដើមចេក៤កង់ មានដោតម្លូស្លាលើនោះផង សំពត់៤ហាត្ថ អង្ករ១ផ្តិល និងទៀន១ដើម។

**ខ-គុណវិបត្តិ**

-ជាមនុស្សបំភ្លេចជាតិ មាតុភូមិខ្លួន

-ជាមនុស្សឆេវឆាវ ឆាប់ខឹង។

▪ ព្រះពិស្ណុការជាមនុស្សមានសមត្ថភាពខ្ពស់ តែមានចិត្តឆេវឆាវ ខ្វះការអត់ធ្មត់ជាមួយស្តេចផែនដី ហើយសុខចិត្តរត់ចោលទឹកទីកំណើតរបស់ខ្លួន(អាណាចក្រកម្ពុជា)ទៅរស់នៅប្រទេសចិន។ ព្រះពិស្ណុការមិនបានបំពេញកាតព្វកិច្ចជាកូន ដើម្បីតបស្នងសងគុណមាតាបិតាវិញនោះទេ។

**៣-ព្រះឥន្ទ្រាធិរាជ**

**ក-គុណសម្បត្តិ**

-ជាបុគ្គលប្រកាន់ជំហរយុត្តិធម៌

-ជាបុគ្គលមានការយល់ដឹងច្បាស់អំពីរបៀបនៃការរៀនសូត្រ

-ជាបុគ្គលចេះជួយទំនុកបម្រុងនិងបណ្តុះបណ្តាលមនុស្សដោយមិនប្រកាន់ជាតិសាសន៍

-ជាបិតាប្រកបដោយព្រហ្មវិហារធម៌

-ជាបុគ្គលធ្វើឱ្យសង្គមមានសុខសន្តិភាពនិងរីកចម្រើនគ្រប់វិស័យ។

▪ ព្រះឥន្ទ្រាធិរាជ ជាស្តេចពួកទេវតារស់នៅស្ថានលើ និងជាអ្នកស្រឡាញ់យុត្តិធម៌មិនថាជាកូនចៅ ឬបក្សពួករបស់ព្រះឥន្ទ្រនោះទេ។ទិព សុតាចន្ទជាទេពធិតាក៏ទទួលទោស៦ឆ្នាំពីកំហុសនៃការលួចបេះផ្កា៦ទងរបស់តាលឹម សេង។

▪ ព្រះឥន្ទ្រាធិរាជជាអ្នកជួយសង្គ្រោះមនុស្សលោកដូចជា ជួយបណ្តុះបណ្តាលព្រះពិស្ណុការឱ្យមានចំណេះ ជំនាញខាងសិល្បៈស្ថាបត្យកម្ម ដើម្បីមកជួយកសាងសំណង់ប្រាសាទនានានៅស្ថានមនុស្សលោកជាពិសេសថ្វាយព្រះកេតុមាលា ដែលជាបុត្ររបស់ព្រះអង្គនឹងមកសោយរាជ្យនៅអាណាចក្រកម្ពុជា។ក្រៅពីនេះ ព្រះអង្គក៏បាននិម្មិតជាមាន់គកស និងខ្មៅ ដើម្បី

ឱ្យរាស្ត្រណាបានបរិភោគនឹងក្លាយជាស្តេចគ្រប់គ្រងអាណាចក្រកម្ពុជា ព្រោះពេលនោះអស់ខ្សែរាជវង្សដែលនឹងមកសោយរាជ្យហើយ។

**ខ-គុណវិបត្តិ**

-ផ្តាច់មនោសញ្ចេតនាមាតានិងបុត្រ

-ជាបុគ្គលប្រកាន់បក្សពួកនិយម។

▪ ព្រះឥន្ទ្រាធិរាជខ្វះការផ្តល់មនោសញ្ចេតនារវាងម្តាយ និងកូនពោលគឺមិនអនុញ្ញាតឱ្យទិព សុតាចន្ទបានរួមរស់ជាកូន(ព្រះពិស្ណុការ)នៅស្ថានទេវតាបានយូរនោះទេដោយគិតថា ព្រះពិស្ណុការមានសារជាតិជាមនុស្ស។ ដូច្នេះ អាចនិយាយបានថា មនោសញ្ចេតនារវាងម្តាយ និងកូនត្រូវបានផ្តាច់រវាងស្ថានទេវតា និងស្ថានមនុស្សមលោកគឺវាខុសគ្នារវាងមនោសញ្ចេតនាដ៏ជ្រាលជ្រៅរបស់ព្រះឥន្ទ្រាធិរាជ និងព្រះកេតុមាលាដែលមិនមែនជាបុត្របង្កើតនោះទេ។

**៤-តាលឹម សេង**

**ក-គុណសម្បត្តិ**

-ជាមនុស្សព្យាយាមក្នុងការងារ

-មានចិត្តសប្បុរសធម៌ជាមួយអ្នកជិតខាង

-ចេះថៃរក្សាបុត្របានល្អនៅពេលអត់ពីភរិយា

-ចេះស្តាប់បង្គាប់ភរិយារហូតក្លាយជាអ្នកមាន

-ស្រឡាញ់និងនឹកប្រពន្ធដោយក្តីអាឡោះអាល័យ។

▪ តាលឹម សេងជាជនជាតិចិនមកពីក្រុងសៀងហៃ ប្រទេសចិន។ គាត់ជាអ្នកបម្រើដែលមានចិត្តស្មោះត្រង់ តស៊ូនឹងការងារចំពោះថៅកែ ហើយក៏ជាប្តីដ៏ល្អម្នាក់ចំពោះនាងទិព សុតាចន្ទដែលខិតខំរៀនសូត្រលើវិជ្ជាត្បាញដែលនាងបានបង្រៀនរហូតក្លាយជាអ្នកមានទ្រព្យសម្បត្តិ និងមានទឹកចិត្តល្អជាមួយអ្នកជិតខាង។

▪ តា លឹមសេង គឺជាប្តីដែលមានភក្តីភាពជាមួយប្រពន្ធ។ គាត់បានយំសោកបោកប្រាណនៅពេលនាងទិព សុតាចន្ទវិលត្រឡប់ទៅកាន់ស្ថានទេវតាវិញ ដែលធ្វើឱ្យគាត់រស់នៅតែ២នាក់ឪពុក និងកូន។

**ខ-គុណវិបត្តិ**

-ជំពាក់បំណុលគេដោយពុំមានលទ្ធភាពសងរហូតធ្លាក់ខ្លួនជាអ្នកបម្រើគេ។

▪ តា លឹមសេងជាឪពុករបស់ព្រះពិស្ណុការប៉ុន្តែពុំមានបញ្ញាបារមី មានជំនាញវិស្វកម្ម

ដូចព្រះពិស្ណុការឡើយ។ គាត់មិនមែនជាឪពុកតាមថៃកូនគ្រាប់ពេលវេលានោះទេពោលគឺបណ្តែតបណ្តោយឱ្យព្រះពិស្ណុការផ្សេងព្រេងគ្រប់ទីកន្លែង និងចុងក្រោយព្រះពិស្ណុការបានវិលត្រឡប់ទៅប្រទេសចិនវិញដោយមិនយកបិតាទៅជាមួយនោះទេ។

**៥-នាងទិព សុតាចន្ទ**

**ក-គុណសម្បត្តិ**

-ហ៊ានទទួលកំហុសដែលខ្លួនបានប្រព្រឹត្ត

-ជាស្ត្រីមេផ្ទះដែលមានភាពឆ្លាតវៃក្នុងការលើកស្ទួយជីវភាពគ្រួសារ

-ចេះចែករំលែកបទពិសោធដល់អ្នកដទៃ

-ជាម្តាយដ៏ល្អជួយបណ្តុះបណ្តាលកូនឱ្យមានចំណេះដឹង

-ចេះស្គាល់ហេតុផលដែលនាំឱ្យចម្រើន។

- នាងទិព សុតាចន្ទ គឺជាទេពធិតារស់នៅស្ថានទេវតា ហើយប្រពន្ធរបស់តាលឹមសេង និងម្តាយរបស់ព្រះពិស្ណុការ។ ព្រះនាងជាទេពធិតាបានមកតស៊ូរស់នៅលំបាកវេទនាគ្រប់បែបយ៉ាងជាមួយមនុស្សលោក ហើយថែមទាំងខិតខំណែនាំ និងបង្រៀនវិជ្ជាត្បាញដល់តាលឹមសេង និងអ្នកជិតខាងដទៃ ដើម្បីរំដោះខ្លួនចេញផុតពីភាពក្រីក្រ។

- នាងទិព សុតាចន្ទគឺជាទេពធិតាស្តាប់បង្គាប់ ដែលព្រះឥន្ទ្រាធិរាជដាក់ទណ្ឌកម្មនាងពីទោសលួចបេះផ្កា ហើយសុខចិត្តធ្វើជាប្រពន្ធតាចាស់ដែលជាម្ចាស់ផ្កា។ នាងគឺជាម្តាយដ៏ល្អដែលមានទឹកចិត្តអាណិតស្រឡាញ់កូន ហើយយកកូនទៅកាន់ស្ថានទេវតា ដើម្បីបានរៀនសូត្របន្ថែមពីគ្រូល្បីៗនៅស្ថានទេវតារហូតដល់ព្រះពិស្ណុការក្លាយជាស្ថាបត្យករដ៏ចំណានគ្មានពីរក្នុងកសាងប្រាសាទ។

**ខ-គុណវិបត្តិ**

-មិនគោរពតាមឱវាទរបស់ព្រះឥន្ទ្រ

-នាងមានមនោសញ្ចេតនាតិចតួចជាមួយនឹងកូននិងប្តី ក្រោយពេលរួចផុតទណ្ឌកម្ម

- នាងទិព សុតាចន្ទ គឺជាទេពធិតា ដែលមានចិត្តលោភលន់លួចបេះផ្កា៦ទងរបសលឹមសេង ដែលប្រាសចាកពីវិន័យរបស់ព្រះឥន្ទ្រាធិរាជនៅស្ថានទេវតា។

ក្រៅពីនេះ ព្រះនាងដូចជាមានមនោសញ្ចេតនាតិចតួចណាស់ជាមួយស្វាមី និងបុត្រសុខចិត្តរត់ចោលពួកគេទៅកាន់ស្ថានទេវតាវិញ នៅពេលដែលនាងរួចផុតពីទណ្ឌកម្មរយៈពេល៦ឆ្នាំ។

**៦-ស្តេចទេវងអស្ចារ្យ**

**ក-គុណសម្បត្តិ**

-ជាស្តេចមានទសពិធរាជធម៌

-មិនប្រឆាំងជំទាស់នឹងបំណងព្រះឥន្ទ្រ

-ស្រឡាញ់ថ្នាក់ថ្នមបុត្រនិងអប់រំបុត្រឱ្យដើរតាមគន្លងធម៌។

▪ ស្តេចទេវងអស្ចារ្យ គឺជាអតីតហ្មដំរីម្នាក់ឈ្មោះទា និងប្រពន្ធឈ្មោះវង ហើយត្រូវជាបិតារបស់ព្រះកេតុមាលា។អតីតហ្មដំរីនេះបានទទួលជោគជ័យដោយសារកត្តាចៃដន្យដូចជាបានបរិភោគសាច់មាន់គក និងបានក្លាយជាស្តេចផែនដីជាដើម។ ស្តេចមានទសពិធរាជធម៌ គ្រប់គ្រង និងដឹកនាំប្រទេសឱ្យមានសុខសន្តិភាព និងស្ថិរភាពនយោបាយដែលផ្តល់សិទ្ធិឱ្យព្រះពិស្ណុការកសាងប្រាសាទជាច្រើននៅគ្រប់ទីកន្លែង។

**ខ-គុណវិបត្តិ**

-មិនអាចបង្រួបបង្រួមខ្សែរាជវង្សក្រុងហ្វិរ និងក្រាយហ្វិរ។

▪ ព្រះអង្គគឺក្សត្រដែលមិនអាចបង្រួបបង្រួមខ្សែរាជវង្សដទៃឱ្យមករួមរស់ជាមួយព្រះអង្គបានដូចករណីក្រុងហ្វិរ និងក្រាយហ្វិរបានរត់ទៅកសាងប្រាសាទនៅខេត្តពោធិ៍សាត់។

V-**ទិដ្ឋភាពសង្គម**

**១-វប្បធម៌**

**ក-ជំនឿ**

ដំណើររឿងបានបង្ហាញពីជំនឿដូចជា៖

▪ ការជឿលើបុណ្យបាបរវាងម្ចាស់ទ្រព្យ និងអ្នកលួច។ អ្នកលួចនឹងត្រូវទទួលទោសទណ្ឌកម្មត្រូវទៅនៅបម្រើម្ចាស់ទ្រព្យតាមទង្វើដែលខ្លួនបានអនុវត្តដូចករណីនាងទិព សុតាចន្ទមានសារជាតិជាទេវតាក៏ត្រូវបានក្លាយជាប្រពន្ធរបស់តាលឹម សេង ពីបទលួចបេះផ្កា៦ទងក្នុងសួនច្បាររបស់តាលឹម សេង។ លុះអស់នូវអំពើបាបរយៈពេល៦ឆ្នាំទើបមានសិទ្ធិសេរីភាពទៅរស់នៅស្ថានលើវិញ ហើយក៏ពុំមានសិទ្ធិគ្រប់គ្រាន់ចិញ្ចឹមកូន(ព្រះពិស្ណុការ)នៅស្ថានលើជាមួយបានដែរ ព្រោះព្រះពិស្ណុការជាប់ឈាមជ័រតាលឹម សេងដែលជាសារជាតិមនុស្សលោក។

▪ ជំនឿលើការបួងសួង ដើម្បីសូមបានជួបជុំគ្នាដូចករណីព្រះពិស្ណុការបួងសួងឱ្យបានជួបម្តាយរបស់ខ្លួនក្នុងខណៈពេលកំពុងស្វែងរកម្តាយ ហើយក៏បានជួបក្រុមទេពធិតាចុះមកកម្សាន្តនៅស្ថានកណ្តាល។ជាមួយគ្នានេះក៏មានជំនឿលើខ្មអ្នកតាដើម្បីបន់ស្រន់។

▪ ជំនឿផ្សងរកអ្នកមានបុណ្យ ដើម្បីយកមកសោយរាជ្យដូចករណី ប្រទេសកម្ពុជា

គ្មានស្តេចសោយរាជ្យ។ គណៈរដ្ឋមន្ត្រីបានឱ្យដំរីផ្សងស្វែងរកអ្នកមានបុណ្យមកសោយរាជ្យក្នុងខណៈពេលដំរីលត់ជង្គង់ចំពោះហ្មដំរីឈ្មោះទា និងនាងវង ហើយទម័កទាក៏ក្លាយជាស្តេចទេវងអស្ចារ្យរបស់ព្រះរាជាណាចក្រកម្ពុជាចាប់ពីពេលនោះមក។

- ជំនឿថា បើនរណាបានស៊ីសាច់មាន់ស អ្នកនោះនឹងបានជាស្តេចផែនដី ហើយបើនរណាស៊ីក្បាលមាន់ខ្មៅអ្នកនោះនឹងបានក្លាយជាស្តេចសង្ឃ បើមនុស្សស្រីណាបានស៊ីសាច់ភ្លៅមាន់ខ្មៅ ស្រីនោះនឹងបានជាអគ្គមហេសីស្តេច បើមនុស្សប្រុសណាបានស៊ីសាច់ទ្រូងអ្នកនោះនឹងបានសោយរាជ្យ។
- ជំនឿ ជឿថាបើនរណាបានកសាងផ្លូវថ្នល់ ទំនប់ទឹក សង់សាលា សង់ស្ពាន ធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រលំបាក បានផលទៅកើតនៅស្ថានសួគ៌។

**ខ-ប្រពៃណី ទំនៀមទម្លាប់**

- ប្រពៃណីយកដំរីមករៀបចំចងកូប និងគ្រឿងលម្អជាច្រើន ហើយលែងឱ្យវាដើរទៅតាមអំពើចិត្តរបស់វា ដើម្បីផ្សងរកអ្នកមានបុណ្យ។ដំរីបានដើរទៅរកហ្មទា និងនាងវង ហើយលុតជង្គង់នៅចំពោះមុខជនទាំងពីរនាក់រួចក៏លើកអ្នកទាំងពីរនោះដាក់លើក្បាល បញ្ជិះមកកាន់បរមរាជវាំង ដើម្បីក្លាយជាស្តេចសោយរាជ្យ។ខណៈនោះដែរ ពួកមន្ត្រីក៏បានរៀបចំធ្វើព្រះរាជពិធីរាជាភិសេកភ្លាមតាមប្រពៃណីព្រះមហាក្សត្រ។ហ្មទាក៏បានទទួលព្រះបរមនាមថាទេវងអស្ចារ្យ ។
- តាមប្រពៃណីរបស់ព្រះឥន្ទ្រនៅស្ថានលើ គឺអ្នកដែលមានសារជាតិជាមនុស្សទៅកាន់ស្ថាននោះត្រូវមុជទឹកអាងក្រអូបនៅក្នុងសួនព្រះឥន្ទ្រ ហើយទឹកនោះនឹងបានជម្រះកាយឱ្យបាត់ធុំក្លិនមនុស្សលោក។ បន្ទាប់មកទើបចូលទៅក្នុងប្រាសាទថ្វាយបង្គំព្រះឥន្ទ្រាធិរាជបានដូចករណីនាងទិព សុតាចន្ទបាននាំកូនរបស់នាងទៅកាន់ស្ថានទេវតា។
- ការសាងសង់សំណង់ទាំងឡាយមនុស្សលោកតែងតែរៀបចំតង្វាយថ្វាយព្រះពិស្ណុការជាមុនសិន។ប្រដាប់ដង្វាយមានដូចតទៅនេះ គឺស្រាមួយដប ប្រាក់១រៀល ដើមចេក៤កង់មានដោតម្លូស្លាលើនោះ សំពត់៥ហត្ថ អង្ករ១ផ្តិល និងទៀន១ដើម។
- ព្រះកេតុមាលាបានប្រគល់ដែកទម្ងន់៣ហាប ដើម្បីឱ្យព្រះពិស្ណុការសិតធ្វើព្រះខ័នរាជ្យមួយ ដែលជានិមិត្តរូបនៃតេជានុភាពព្រះមហាក្សត្រ។ តាមទំនៀមទម្លាប់ប្រពៃណីក្សត្រ គឺត្រូវតែមានព្រះខ័នរាជ្យដែលជាតំណាងឱ្យអំណាចរបស់ព្រះអង្គ។

**គ-សាសនា**

- ព្រះពុទ្ធសាសនា(ថេរវាទ)មានស្ដេចសង្ឃ ចៅអធិការវត្ត ការជឿលើកម្មផល (ទទួលទោសទណ្ឌកម្មតាមអំពើ)ការធ្វើទានដល់អ្នកក្រីក្រ និងការធ្វើអំពើល្អ។

**ឃ-ការសិក្សាអប់រំ**

- ការកសាងសាលារៀនសម្រាប់បង្រៀនមុខវិជ្ជាផ្សេងៗទាំងនៅស្ថានកណ្ដាល និង ស្ថានលើ(ទេវតា) ដែលជាកន្លែងបណ្ដុះបណ្ដាលបច្ចេកទេសខាងវិជ្ជាសិល្បៈ និងសំណង់។ យុវជនខិតខំរៀនគូរ រៀនឆ្លាក់ រៀនភ្លេង អំពីសំណាក់ទេវបុត្រដែលជាគ្រូទាំងអស់ ហើយបាន ចេះចាំស្ទាត់សព្វគ្រប់ទាំងអស់ គឺចេះសង់នាវាអាចបើកបរលើគោកបាន ចេះឆ្លាក់ប្រាក់ ឆ្លាក់ មាស ចេះស្លដែកគ្រប់យ៉ាង និងចេះវិជ្ជាលាយទឹក ហើយទឹកនោះបើកាលណាគេចាក់លើដី ឥដ្ឋ ដីនោះនឹងក្លាយទៅជាថ្ម និងចេះវិជ្ជាធ្វើទូក សំពៅជាដើម។ល។
- ព្រះពិស្ណុការបានចេះចាំទាំងអស់នូវមុខវិជ្ជាទាំងឡាយណា ដែលទេវបុត្របាន បង្រៀន ហើយទេវបុត្របាននិយាយលើកទឹកចិត្តកុមារថា «កិច្ចការទាំងឡាយដែលអ្នកបាន ចេះធ្វើទាំងប៉ុន្មាននេះ វាអាចគង់វង្សស្ថិតស្ថេរនៅបានអស់ពេលជាច្រើនពាន់ឆ្នាំ។

**ខ-សិល្បៈ**

- សិល្បៈផ្នែកស្ថាបត្យកម្មក្នុងការសាងសង់ប្រាសាទដ៏ល្អប្រណីត ដែលមានព្រះ ពិស្ណុការជាស្ថាបត្យករដ៏ចំណានក្នុងការកសាងប្រាសាទអង្គឱ្យព្រះកេតុមាលា និងប្រាសាទ ល្អៗប្រណីតជាច្រើនទៀត។ ក្រុងហ្វ៊ វ និងក្រាយហ្វ៊ វទៅសាងសង់ប្រាសាទនៅស្រុកបាកាន ខេត្តពោធិ៍សាត់។
- សិល្បៈចម្លាក់ គឺឆ្លាក់ថ្ម សិតដែក មាស ប្រាក់ និងចម្លាក់ផ្សេងៗទៀតសម្រាប់លម្អ ក្នុងប្រាសាទ និងព្រះបរមរាជវាំង។

**២-សេដ្ឋកិច្ច**

**ក-កសិកម្ម**

- កសិកម្មផ្អែកលើការធ្វើស្រែចម្ការ ការកាប់ឆ្ការព្រៃនៅក្បែរមាត់ទន្លេ ដើម្បីដាំដំណាំ ទាញយកកសិផលសម្រាប់ចិញ្ចឹមជីវិត និងការចិញ្ចឹមសត្វនានាសម្រាប់ជួយវិស័យកសិកម្ម។
- ប្រកបរបរចិញ្ចឹមជីវិតដោយការកាប់អុសលក់នៅក្នុងព្រៃ បេះផ្លែឈើធ្វើជាអាហារ ប្រចាំថ្ងៃ ការទាក់ដំរីសម្រាប់ជំនួយកម្លាំងមនុស្ស និងបម្រើក្នុងវិស័យផ្សេងៗទៀត។
- ការនេសាទតាមបឹងទន្លេសាបសម្រាប់បំពេញតម្រូវការក្នុងការរស់នៅប្រចាំថ្ងៃនិង

សម្រាប់លក់ដូរ ដើម្បីបង្កើនជីវភាពឱ្យកាន់តែល្អប្រសើរ។

**ខ-ផលិតកម្ម**

ផលិតផល ដែលទទួលបានដូចជាស្រូវ អង្ករ ផ្លែឈើ សាច់សត្វ រុក្ខជាតិ និងសំបកលៀស គ្រំ (ផលិតជាកំបោរ)សម្រាប់សង់ប្រាសាទ។

ផលិតផលទាញចេញពីដែក មាស ប្រាក់ដូចជាផលិតជាដាវ កាំបិត និងគ្រឿងអលង្ការផ្សេងៗសម្រាប់ក្រុមទេវតា និងមហាក្សត្រ។

**គ-ឧស្សាហកម្ម**

ឡស្លដែកសម្រាប់យកមកប្រើក្នុងវិស័យផ្សេងៗដូចជាដែកទម្ងន់ពហាបសម្រាប់ធ្វើព្រះខ័នរាជ្យឱ្យព្រះកេតុមាលា។ក្រៅពីនេះ នៅមានការផលិតចម្រាញ់មាស ប្រាក់ ទង់ដែង សំរិទ្ធ ដើម្បីយកទៅឆ្លាក់ធ្វើជាគ្រឿងអលង្ការផ្សេងៗតាមតម្រូវការ។

**ឃ-សិប្បកម្ម**

- ត្បាញសូត្រ(សំបុកដង្កូវនាង)ដូចករណីនាងទិព សុតាចន្ទបង្ហាត់បង្រៀនតាលឹមសេង និងមនុស្សដទៃឱ្យចេះត្បាញសូត្រធ្វើជាសំពត់ហូល ក្រមាសម្រាប់ធ្វើអាជីវកម្មរហូតដល់តាលឹម សេងក្លាយជាអ្នកមាន។ ត្បាញជាសំពត់ផ្សេងៗមានសំពត់ប៉ាក់ជាច្រើនរាប់ពុំអស់ដែលត្រូវយកទៅលក់ដូរដល់អ្នកដទៃ។
- ឆ្លាក់ចម្លាក់ជារូបផ្សេងៗនៅតាមជញ្ជាំងប្រាសាទ និងព្រះបរមរាជវាំង។
- ធ្វើទូក សំពៅ សម្រាប់ធ្វើដំណើរតាមផ្លូវទឹក
- ក្រៅពីនេះនៅមានឡផលិតឥដ្ឋសម្រាប់សង់ប្រាសាទថែមទៀត។

**ខ-ពាណិជ្ជកម្ម**

- ការធ្វើជំនួញ ដែលមានម្ចាស់បំណុល និងអ្នកស៊ីឈ្នួលជំពាក់ម្ចាស់បំណុល
- ការធ្វើចរាចរណ៍ប្រាក់រៀល ប្រាក់ណែន មាស ប្រាក់ សម្រាប់ធ្វើការដោះដូរផ្នែកពាណិជ្ជកម្ម។

**៣-សង្គមកិច្ច**

**ក-ស្ថានភាពរស់នៅ**

- ស្ថានភាពរស់នៅរបស់មនុស្សក្នុងពេលនោះ គឺមិនដូចគ្នាទេ ខ្លះជាវណ្ណៈស្តេចមន្ត្រី ដែលមានជីវភាពរស់នៅយ៉ាងល្អប្រសើរ។
- ក្រុមទេវតាក៏មានស្ថានភាពជីវភាពរស់នៅបានយ៉ាងល្អ ដែលស្ថិតនៅស្ថានមួយ

ខ្ពស់ខុសពីស្ថានមនុស្សលោក។

អ្នកជំនួញបានក្លាយជាម្ចាស់បំណុល ដែលមានអ្នកបម្រើជាអ្នកជំពាក់បំណុល ហើយមកធ្វើការបម្រើដើម្បីដោះបំណុល និងអាចក្លាយជាប្រពន្ធដើម្បីជម្រះនូវអំពើទាំងឡាយដែលខ្លួនបានប្រព្រឹត្ត

- ប្រជាជនជាអ្នកក្រលំបាក ដែលមានមុខរបរជាអ្នកកាប់អុស ទាក់ដំរី ធ្វើស្រែចម្ការ ដាំដំណាំសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ។

**ខ-សុខាភិបាល**

- ព្យាបាលមនុស្សតាមរយៈសែនព្រេនបន់ស្រន់។

ឧទាហរណ៍៖បើជនណាមួយចាប់ធ្វើកិច្ចការអ្វីៗមិនបានរៀបដង្វាយថ្វាយព្រះពិស្ណុការអ្នកនោះឯងនឹងបើកភ្នែកពុំរួចឡើយ  ទោះបើករួចមើលឃើញពន្លឺថ្ងៃក៏នៅតែមានពពឹកភ្នែកគ្រាប់ភ្នែក (ភ្នែកអៀស៊ី)

- ព្យាបាល ឬចង់ឱ្យមនុស្សអាយុវែង គឺត្រូវឱ្យទេវតាសូត្រសែកមន្តគាថា និងប្រោះទឹកមន្ត។ ឧ៖ ទេវតា៧នាក់មកសូត្រសែកមន្តគាថា និងប្រោះព្រំទឹកមន្តទៅលើព្រះកេតុមាលាដើម្បីឱ្យបានអាយុជាង១០០ឆ្នាំ។

**គ-មុខរបរ និងជីវភាពរបស់ប្រជាជន**

គឺមានលក្ខណៈខុសគ្នាៗដូចជា៖

- កសិកម្ម(ដាំដំណាំ ចិញ្ចឹមសត្វ កាប់ឧស និងការទាក់ដំរី)
- សិប្បកម្ម(ត្បាញសូត្រ សំពត់)
- ឧស្សាហកម្ម(ការធ្វើជំនួញ)
- ការគ្រប់គ្រង និងដឹកនាំ(ស្តេចព្រះឥន្ទ្រាធិរាជ ស្តេចផែនដី និងស្តេចសង្ឃ)

**៤-នយោបាយ៖**

**ក-ក្នុងប្រទេស**

- របបគ្រប់គ្រង គឺរបបរាជានិយមដែលត្រូវបានគេជ្រើសតាំងតាមការផ្សងព្រេងនៃសត្វដំរីរបស់ព្រះបរមរាជវាំង។
- អ្នកគ្រប់គ្រង គឺស្តេចទេវងអស្ចារ្យ ដែលជាអតីតហ្មដំរី ដែលអាចបញ្ជាក់ថាអាស្រ័យបុណ្យសំណាងរបស់មនុស្ស ទោះបីអ្នកនោះឯងជាអ្នកក្រីក្រលំបាកក៏ដោយ។

**ខ-ក្រៅប្រទេស**

- ប្រទេសកម្ពុជាមានទំនាក់ជាមួយប្រទេសចិន ដែលមានតា លឹមសេងមកពីក្រុងសៀងហៃ(ប្រទេសចិន) ហើយព្រះពិស្ណុការដែលជាបុត្ររបស់តាលឹម សេង និងនាងទិព សុតាចន្ទ ក៏បានវិលត្រឡប់ទៅកាន់ប្រទេសចិនវិញតាមសំពៅ។

VI-**ទិដ្ឋភាពតែងនិពន្ធ**

រឿងប្រាសាទអង្គរ គឺជាប្រភេទអក្សរសិល្ប៍ប្រជាប្រិយបែបព្រេងកថា ស្ដីពីកំណើតប្រាសាទអង្គរ។ ដំណើររឿងបង្ហាញដូចជា៖

**១-ផ្ដើមរឿង**

បង្ហាញពីតួអង្គ កាលពីព.ស.៦០០ មានចិនម្នាក់ឈ្មោះលឹម សេងនៅក្នុងខែត្រសៀងហៃ។

**២-ដំណើររឿង**

ក-ទម្រង់សំណេរ សរសេរជាពាក្យរាយតាំងពីដើមដល់ចប់។

ខ-បច្ចេកទេសក្នុងការតាក់តែង

❖ ភាសា : ភាសាដែលប្រើប្រាស់ក្នុងអត្ថបទនេះ គឺមានលក្ខណៈចម្រុះពោលគឺភាសាបាលី សំស្ក្រឹត និងភាសាខ្មែរលាយឡំគ្នា។

ឧទាហរណ៍៖

- ភាសាបាលី

បុត្រ (បា) កូនប្រុសរបស់ក្សត្រ។

ឥន្ទ (បា) ព្រះនាមទេវរាជជាអធិបតីនៃពួកទេវតាក្នុងស្ថានត្រៃត្រិង្ស។

ពិស្ណុការ(បា) វិស្សកម្ម។

- ភាសាសំស្ក្រឹត

ហាប (សំ) ទម្ងន់១០០នាឡិ។

នាឡិ (សំ) ឈ្មោះទម្ងន់ម្យ៉ាងដែលថ្លឹងមានទម្ងន់១៦តម្លឹង។

កេតុមាលា(សំ)ព្រះនាមស្ដេចមួយអង្គសោយរាជ្យនៅនគរធំគឺព្រះបាទជ័យវរ្ម័នទី២។

- សាភាខ្មែរសុទ្ធ

ស្លា (ន) ដំណាំមួយប្រភេទមានដើមមូលស្រលូតត្រង់ ផ្លែមានរសជាតិចត់។

សំពត់(ន)របស់ដែលកើតចេញពីការត្បាញដោយអំបោះ សូត្រ។ល។

ប្រាក់ (ន) រតនវត្ថុមួយប្រភេទដែលមានសម្បុរស សាច់រឹងមានតម្លៃបន្ទាប់ពីមាស។

❖ ការប្រៀបធៀប គឺប្រៀបធៀបវត្ថុមួយទៅវត្ថុមួយផ្សេងទៀត
ឧះ ព្រះខ័នតូចមួយមានមុខស្តើងជាងមុខស្រូវទៅទៀត

❖ សំណើច គឺអស់សំណើចបុរសប្តីប្រពន្ធ២នាក់ ដែលសប្បាយភ្លេចខ្លួនដូចជា៖ បុរសប្តីប្រពន្ធក៏ជញ្ជូនម្ហូបអាហារទៅដាក់មាត់ទឹក មុជទឹកក្នុងស្ទឹងលេងយ៉ាងសប្បាយលុះងើបពីទឹកឡើងបុរសប្តីប្រពន្ធរកមើលថាសដាក់ម្ហូបពុំឃើញ ដោយរលកទឹកបានគួចយកថាសនោះរសាត់ទៅតាមខ្សែទឹកបាត់ទៅ។

❖ ទុក្ខសោក គឺបង្ហាញពីទុក្ខសោករបស់ព្រះពិស្ណុការដែលស្វែងម្តាយមិនឃើញដូចជា៖ អញឥតដែលបានជួបមនុស្សម្នាក់សោះ សម្លៀកបំពាក់អញក៏រហែកដាច់ដោច ហើយអញពុំអាចរកអ្វីមកផ្លាស់បានទេ ក្រៅពីយកស្លឹកឈើមកចងបិទបាំងខ្លួនដូច្នេះ។

❖ សន្ទនា(សំវាទវិធី)៖ ព្រះពិស្ណុការសន្ទនាជាមួយឪពុកក្នុងន័យនឹករលឹកដល់ម្តាយដូចជាកុមារក៏កើតទុក្ខរកទីបំផុតគ្មាន ទើបថ្ងៃមួយសួរឪពុកថា «ម្តាយខ្ញុំជាអ្វី?» ឪពុកឆ្លើយថាម្តាយកូនឯងជាទេពធិតា នាងត្រូវមកនៅក្នុងឋានមនុស្សយើងនេះត្រឹម៦ឆ្នាំទេ ឥឡូវនាងត្រឡប់ទៅឋានទេវតាវិញហើយ។

❖ ឯកវាទវិធី៖ ព្រះពិស្ណុការសញ្ជឹងគិតតែម្នាក់ឯងថា៖

«បើក្នុងស្ត្រីទេពធិតាទាំងអស់នេះ ឥតមានម្តាយខ្ញុំនៅក្នុងនេះផងទេសូមឱ្យហោះហើរទៅឋានលំនៅគេវិញកុំបីមានសល់ឡើយ ប៉ុន្តែបើមានម្តាយខ្ញុំមកនៅក្នុងនេះផងខ្ញុំសូមកុំឱ្យម្តាយខ្ញុំហោះហើរទៅជាមួយនឹងគេរួច»។

❖ បុគ្គលិកកម្ម៖ គឺជាវិធីដែលអ្នកនិពន្ធផ្តល់បុគ្គលិកលក្ខណៈរបស់មនុស្សឱ្យដល់សត្វរុក្ខជាតិជាដើម ដូចជាត្រង់ចំណុចមាន់ស មាន់ខ្មៅនិយាយគ្នាអំពីឫទ្ធិរបស់ខ្លួន។

**គ-បញ្ចប់រឿង**

▪ ការបញ្ចប់រឿងដោយឱ្យតួអង្គឯកទទួលបានជ័យជម្នះក្នុងបេសកកម្មរបស់ខ្លួន ដូចជាព្រះកេតុមាលាបានឱ្យព្រះពិស្ណុការសងប្រាសាទមួយ ដែលមានលម្អប្រហែលក្រោលគោរបស់ព្រះឥន្ទ្រាធិរាជនៅឯស្ថានទេវតា។ ចំណែកព្រះពិស្ណុការក៏ទទួលបានចំណេះដឹងថ្មីបន្ថែមពីព្រះឥន្ទ្រក្នុងវិស័យស្ថាបត្យកម្ម សិតដែក សំណង់ ជាពិសេសមានសមត្ថភាពកសាងប្រាសាទក្រោលគោមួយដ៏ល្អប្រណិតគ្មានពីរនៅស្ថានកណ្តាលដើម្បីថ្វាយព្រះកេតុមាលាជាស្តេចនៃប្រទេសកម្ពុជា។ ចំណែកឯពិស្ណុការបានវិលត្រឡប់ទៅស្រុកកំណើតឪពុកវិញនៅក្រុង

សៀងហៃប្រទេសចិន។

VII-**ឧិដ្ឋភាពតម្លៃ**

**ក-សកម្មភាពល្អ និងវិជ្ជមានជាគំរូ**

❖ ព្រះឥន្ទ្រាធិរាជដែលជាស្តេចពួកទេវតាបានផ្តល់នូវភាពយុត្តិធម៌មិនរើសមុខដូចករណីនាងទិព សុតាចន្ទបានលួចបេះផ្កាត្រូវតែទទួលទោស៦ឆ្នាំនៅបម្រើតាលឹម សេងក្នុងឋានៈជាប្រពន្ធរបស់គាត់ ។ ចំពោះព្រះពិស្ណុការ ដែលមានម្តាយជាទេពធិតាក៏មិនអាចធានាកូនរបស់ខ្លួនឱ្យរស់នៅស្ថានទេវតាបានដែរ ពោលគ្មានគ្រួសារនិយម បក្សពួកនិយមនោះទេ។

❖ ព្រះពិស្ណុការ ដែលមានសារជាតិជាមនុស្សលោកក៏មានឱកាសបានទៅសិក្សាបន្ថែមជាមួយទេវតានៅស្ថានទេវតា ហើយបានក្លាយវិស្សុកម្មដ៏ចំណានក្នុងការសាងសង់ប្រាសាទសំពៅ ស្ពាន និងមានទេពកោសល្យឆ្លាក់ចម្លាក់បានល្អៗដូចពួកទេវតានៅស្ថានលើដែរ។

❖ ហ្មជំរីដែលជាកសិករក្រីក្រក៏មានឱកាសក្លាយជាព្រះរាជាដឹកនាំប្រទេសដូចខ្សែរាជវង្សដទៃទៀតដែលអាចបញ្ជាក់ថាកសិករ កូនអ្នកក្រីក្រក៏មានឱកាសក្លាយជាអ្នកដឹកនាំប្រទេស។

❖ ការខិតខំប្រឹងប្រែង និងការផ្តល់យោបល់ពីភរិយាលើជំនាញវិជ្ជានោះនឹងក្លាយជាអ្នកមានទ្រព្យ និងមានកិត្តិយសជាមួយអ្នកជិតខាងទៀតផងដូចករណីនាងទិព សុតាចន្ទបានជំរុញតាលឹម សេងឱ្យខិតខំខ្វិលុយកាក់ ដើម្បីប្រកបរបរត្បាញរហូតក្លាយជាអ្នកមានទ្រព្យ។

**ខ-សកម្មភាពអាក្រក់ អវិជ្ជមានត្រូវចៀសវាង ស្អប់ខ្ពើម លះបង់**

❖ ករណីលួចបេះផ្កា ដែលជាគ្រឿងលម្អក៏គួរជៀសវាង ពោលគឺមិនគួរមានដៃ មានជើងដោយខ្វះការអនុញ្ញាតពីម្ចាស់ទោះបីវត្ថុនោះតូចតាចក៏ដោយ ហើយទោះជាទេពិតាក៏ត្រូវទទួលទោសដូចមនុស្សដទៃដែរ។

❖ ការធ្វេសប្រហែសវានឹងនាំមកនូវភាពបរាជ័យដូចកសិករក្រីក្រពីរនាក់ប្តីប្រពន្ធដែលនឹងត្រូវបានសាច់មាន់សបរិភោគ ហើយក្លាយជាស្តេចផែនដីក៏ត្រូវបរាជ័យ ដោយការសប្បាយជ្រុលហួសហេតុពេក។

❖ អ្នកដឹកនាំមិនគួរមានចិត្តឆេវឆាវដែលនាំឱ្យខាតប្រយោជន៍រួមសម្រាប់ប្រទេសជាតិដូចជាព្រះកេតុមាលានិងពិស្ណុការនាំឱ្យគាត់រត់ទៅប្រទេសចិនវិញ។

VIII-**ការសន្និដ្ឋាន**

**ក-អត្ថប្រយោជន៍របស់រឿង**

រឿងប្រាសាអង្គរ គឺជារឿងព្រេងបែបប្រវត្តិសាស្ត្រ ហើយបានក្លាយជាអត្តសញ្ញាណនៃ

វប្បធម៌ខ្មែរដែលបង្ហាញពីទេពកោសល្យដ៏ប៉ិនប្រសប់របស់ជនជាតិខ្មែរក្នុងការកសាងប្រាសាទអង្គរវត្ត ដែលគ្មានការអន្តរាគមន៍ ឬកម្លាំងសិល្ប៍សាស្ត្ររបស់ក្រុមទេវតាណាមួយមកជួយកសាងនោះឡើយ ពោលគឺព្រះពិស្ណុការ(សារជាតិមនុស្ស) ដែលជាក្មេងដ៏ឈ្លាសវៃ ឆ្លាតមានទេពកោសល្យផ្នែកស្ថាបត្យកម្មពីកំណើត ហើយត្រូវបានព្រះឥន្ទ្រាធិរាជអនុញ្ញាតឱ្យបន្តសិក្សាជំនាញបន្ថែមនៅស្ថានទេវតាជាមួយគ្រូជំនាញៗរហូតក្លាយជាស្ថាបត្យករដ៏ចំណានគ្មានពីរ។

ក្រៅពីឆ្លុះបញ្ចាំងពីកំណើតប្រាសាទអង្គរវត្ត រឿងនេះក៏បានបង្ហាញពីតថភាពសង្គមមួយចំនួនទៀតដូចជា ភាពយុត្តិធម៌ក្នុងសង្គម ការផ្តល់ឱកាសដល់ប្រជាកសិករក្រីក្រ និងទំនាក់ទំនងល្អរវាងឋានមនុស្ស និងឋានទេវតាផងដែរ។

**ខ-ចំណាប់អារម្មណ៍៖**

ដូច្នេះក្នុងនាមជាពលរដ្ឋខ្មែរជំនាន់ក្រោយត្រូវមានកាតព្វកិច្ចសិក្សារឿងប្រាសាទអង្គរនេះ ដើម្បីស្វែងយល់ពីតម្លៃមហាសាលនៃអត្តសញ្ញាណវប្បធម៌ខ្មែរ(ព្រលឹងជាតិ) ក្នុងទិសដៅថែរក្សា និងអភិវឌ្ឍកេរមតិកវប្បធម៌ដូនតាខ្មែរឱ្យសក្តិសមជាសម្បត្តិបេតិកភណ្ឌពិភពលោក។ រឿងប្រាសាទអង្គរបានឆ្លុះបញ្ចាំងប្រាប់កូនខ្មែរគ្រប់រូបថា វត្ថុអច្ឆរិយៈមួយនេះគឺកើតចេញពីបញ្ញាមនុស្សសុទ្ធសាធនាសម័យមហានគរ ដែលអាចបញ្ជាក់ប្រាប់ថា ធនធានមនុស្សរបស់ខ្មែរយើងនាសម័យនោះគឺបានឡើងដល់កម្រិតកំពូលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្ថាបនាសិល្បៈស្ថាបត្យកម្ម និងសិល្បៈដទៃទៀតបានបន្សល់ទុកជាមតិកដល់សព្វថ្ងៃ។ ដូច្នេះយើងទាំងអស់គ្នាត្រូវតែខិតខំបន្តវេនដូនតារបស់យើង ដើម្បីឱ្យសង្គមខ្មែរមានភាពល្បីល្បាញដូចសម័យមហានគរដែរ។

# ឯកសារពិគ្រោះ


- យឹង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ ១៩៩៨
- ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៩៩
- មីសែលត្រាណេ ការសិក្សារឿងរាមកេរ្តិ៍ ១៩៩៥
- លាង ហាប់អាន សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ រាមាយណៈឥណ្ឌា ១៩៦៦
- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ១៩៨៨
- វេចនានុក្រមវចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ , ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ ថ្នាក់ទី១២ លេខ០៣ អយក.សណន. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦
- សេង សោភា សិក្សារបៀបធៀបរឿងរាមកេរ្តិ៍ និងរឿងរាមគៀតថៃ សារណាបញ្ចប់ បរិញ្ញាអក្សរសាស្ត្រខ្មែរ ឆ្នាំ២០០៧
- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
- ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លែង ឆ្នាំ១៩៧៣
- សៀវភៅសិក្សាគោលភាសាខ្មែរ សៀវភៅសិស្សថ្នាក់ទី១០ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១០
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរ សៀវភៅសិស្សថ្នាក់ទី១១ បោះពុម្ពផ្សាយ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៥
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរសៀវភៅសិស្សថ្នាក់ទី១២បោះពុម្ពផ្សាយដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១២
- លី ធាមតេង សៀវភៅការផ្សាយរបស់អ្នកនិពន្ធខ្មែរ ឆ្នាំ១៩៧២។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

## រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:**........................**អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍ «រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ »ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

<u>កន្លែងទទួល:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការច្នៃបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ"**សិក្សាអត្ថបទអក្សរសិល្ប៍**" ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជាៈ

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ **«ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់»** នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោក អោ សៀម

៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន

២- លោកស្រី ម៉ៅ តាន់ណារី

៣- លោក ព្រៃ សំបូរ

៤- លោក ងិន សុតារា

៥- លោក ប៉ែន សំភាស់

៦- លោកស្រី វ៉ាន់ សុភី

៧- លោក វ៉ិត សុខខេង

៨- លោកស្រី ផាន់ សុជាតា

១០- លោកស្រី សេង ពិសិដ្ឋនារី

១១- លោកស្រី បែន នាង

១២- លោក កួយ សូគាន

១៣- លោក អ៊ិត សុធា

១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

៣- ឯកឧត្តម រស់ សាលីន

៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារិទ្ធ

# មាតិកា

ទំព័រ
ប្រកាស ......i
បុព្វកថា ......ii
គណៈកម្មការ......iii
អារម្ភកថា......iv
មាតិកា......v
សេចក្តីផ្តើម......
I. ការបង្ហាញអត្ថបទ......
II. ទិដ្ឋភាពទំនាក់ទំនងរឿង......
III. ទិដ្ឋភាពទំនាស់......
IV. ទិដ្ឋភាពវិភាគតួអង្គ......
V. ទិដ្ឋភាពសង្គម......
VI. ទិដ្ឋភាពតែងនិពន្ធ......
VII. ទិដ្ឋភាពតម្លៃ......
VIII. ការសន្និដ្ឋាន......
IX. ឯកសារពិគ្រោះ......

## សិក្សាអត្ថបទអក្សរសិល្ប៍

## រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់

### សេចក្ដីផ្ដើម

គ្រប់ស្នាដៃអក្សរសិល្ប៍ទាំងអស់ ដែលអ្នកនិពន្ធបានតាក់តែងឡើង គឺសុទ្ធតែមានគោលបំណង និងសំណូមពររបស់ខ្លួនយ៉ាងជាក់លាក់ពិតប្រាកដ។ តាមទ្រឹស្ដីអក្សរសិល្ប៍បានបញ្ជាក់ថាៈ អក្សរសិល្ប៍ គឺជាកញ្ចក់ឆ្លុះបញ្ចាំងនូវតថភាពសង្គមនាសម័យកាលមួយជា កំណាត់។ លើសពីនេះទៅទៀត អក្សរសិល្ប៍ជាកម្រងឯកសារស្ដីពីជីវិតរបស់មនុស្សក្នុងសង្គមតាម រយៈសិល្ប៍វិធីរបស់អ្នកនិពន្ធ។-ដោយឡែករឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដែលអ្នកនិពន្ធយើងបានតាក់តែងឡើងមកនេះ មានគោលបំណង សំណូមពរ និងឆ្លុះបញ្ចាំងឱ្យឃើញពីតថភាពសង្គមនាសម័យសង្គមរាស្ត្រនិយមមួយយ៉ាងពិតប្រាកដ។

រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ គឺជាស្នាដៃនៃពានរង្វាន់ឥន្ទ្រ ទេវីលើកដំបូងក្នុងការប្រឡងប្រជែង ផ្នែកអក្សរសាស្ត្រខ្មែរនាសម័យសង្គមរាស្ត្រនិយម (១៩៦០- ១៩៦១)។

អាស្រ័យដោយសារគុណតម្លៃនៃរឿងនេះហើយបានជាក្រសួងអប់រំ យករឿងនេះដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ ក្រោយពេលបោះឆ្នោតអាណត្តិទី១(១៩៩៣)ដើម្បីបង្រួបបង្រួមជាតិនិងផ្សះផ្សាជាតិ។

### I-ការបង្ហាញអត្ថបទ

### ១. អត្ថបទ

**ក- ចំណងជើង :** រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ។

រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ត្រូវបានអ្នកនិពន្ធដកស្រង់ព្រឹត្តិការណ៍នយោបាយសម័យសង្គមរាស្ត្រនិយមមកប្រកួតប្រជែងពានរង្វាន់ឥន្ទ្រទេវីសម័យសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០)។

**គ- ប្រភេទ** រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ស្ថិតក្នុងប្រភេទអក្សរសិល្ប៍ទំនើប។

**ឃ-ចលនា** រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ស្ថិតក្នុងចលនាអក្សរសិល្ប៍ខេមរនិយម។

### ២. អ្នកនិពន្ធ

**ក- ឈ្មោះអ្នកនិពន្ធ** : លោក **សូន សុរិន្ទ**

**ខ- ជីវប្រវត្តិរបស់អ្នកនិពន្ធ**

លោក សូន សុរិន្ទ កើតនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ១៩៣០ លោកមានដើម កំណើត នៅសង្កាត់ជ្រៃ ស្រុក សង្កែ ខេត្តបាត់ដំបង។ លោកមានតួនាទីជាលេខាធិការការិយាល័យខេត្ត ហើយលោកបានចូល ជាសមាជិកសមាគមអ្នកនិពន្ធខ្មែរនៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ១៩៦០ ។ លោកបាននិពន្ធរឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់ ហើយបានយកទៅដាក់ក្នុងការប្រឡងប្រជែងអក្សរសាស្ត្រលើកទី១ នៅសមាគមអ្នកនិពន្ធខ្មែរនាឆ្នាំ ១៩៦០-១៩៦១។ ប្រលោមលោកនេះបានទទួលពានរង្វាន់ឥន្ទ្រទេវី លេខ១ ។

**គ- ស្នាដៃសំខាន់ៗ**

មានតែរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់តែមួយប៉ុណ្ណោះ ស្នាដៃផ្សេងទៀតរបស់លោក **សួន សុរិន្ទ** គេពុំឃើញមានឡើយ។

## ៣. កាលកំណត់តែង

**ក- ថ្ងៃខែឆ្នាំនៃការតាក់តែង** : រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ និពន្ធឡើងនៅឆ្នាំ១៩៦០-១៩៦១។

**ខ- ថ្ងៃខែឆ្នាំនៃការបោះពុម្ព** រឿងនេះត្រូវបានបោះពុម្ពនៅឆ្នាំ ១៩៦១ ។ នៅឆ្នាំ ១៩៩៣-៩៤ ក្រសួងអប់រំយុវជន និងកីឡា បានរៀបចំបញ្ចូលក្នុងកម្មវិធីសិក្សាសាលាចំណេះទូទៅសម្រាប់ថ្នាក់ទី១២ ។

## ៤. សង្គមបរិយាកាស

**ក- កាលប្រវត្តិ**

ដំណើររឿងបានប្រព្រឹត្តទៅក្នុងរបប~~សង្គមពីរគឺ~~ ចុងសម័យអាណានិគមនិយមបារាំង ឆ្នាំ ១៩៤៩ និងសម័យសង្គមរាស្ត្រនិយម ពោលគឺក្រោយពេល ដែលប្រទេសខ្មែរយើងទើបទទួលបានឯករាជ្យដំបូងបំផុត ពីពួកអាណានិគមនិយមបារាំង។

**ខ- ព្រឹត្តិការណ៍សំខាន់ៗ**

– ១៩៣៩សង្គ្រាមលោកលើកទី២បានផ្ទុះឡើងនៅពាសពេញពិភពលោកក្នុងនោះក៏បានរាលដាលដល់អាស៊ី។

- ១៩៤១ជប៉ុនបានចូលមកប្រទេសកម្ពុជា។

- ខែមីនា១៩៤៥ជប៉ុនបានធ្វើរដ្ឋប្រហារចាប់បារាំងឃុំឃាំងទូទាំងឥណ្ឌូចិន។

- ១មីនា១៩៤៥សម្តេចព្រះនរោត្តមសីហនុបានប្រកាសឯករាជ្យពីបារាំងដោយបង្កើត រដ្ឋាភិបាលឯករាជ្យមួយនៅថ្ងៃទី១៨ ខែមីនា ១៩៤៥។

- ១៩តុលា១៩៤៥ បារាំងបានវិលមកប្រទេសកម្ពុជាជាលើកទី២។

- ០៧ មករា១៩៤៦បានបង្កើតកិច្ចព្រមព្រៀងបណ្តោះអាសន្ន។ រ៉េស៊ីដង់ជាន់ខ្ពស់ត្រូវបាន ជំនួសដោយស្នងការសាធារណរដ្ឋបារាំងនិងរ៉េស៊ីដង់ប្រចាំខេត្តត្រូវជំនួសដោយទីប្រឹក្សាតំបន់ចំ នួន៧ហើយតំបន់នីមួយៗមាន២ខេត្ត។

- ១៩៤៩កងទ័ពខ្មែរឥស្សរៈបានធ្វើសកម្មភាពយ៉ាងសកម្មនិងពង្រឹងការត្រួតត្រារបស់ខ្លួន នៅលើផ្ទៃដីមួយភាគបីនៃប្រទេសកម្ពុជានិងប្រជាជនប្រហែលមួយលាននាក់ ដែលជាហេតុនាំឱ្យ សម្តេចសីហនុចរចាជាមួយបារាំងដើម្បីទានទារឯករាជ្យ។ ជាលទ្ធផល បារាំងបានប្រគល់ឯករាជ្យ ឱ្យកម្ពុជា ជាឯករាជ្យមួយក្នុងសហព័ន្ធឥណ្ឌូចិននៅថ្ងៃទី០៨ ខែវិច្ឆិកា ១៩៤៩។

- ១១ មេសា ១៩៥៣ ព្រះបាទនរោត្តមសីហនុបានចាកចេញពីបារាំងទៅកាណាដា សហរដ្ឋអាមេរិច។

- ១២ ឧសភា ១៩៥៣ ឯកឧត្តមប៉ែន នុតចូលមកក្នុងប្រទេសកម្ពុជាវិញ។

- ១៤ ឧសភា ១៩៥៣ ព្រះបាទនរោត្តមសីហនុចាកចេញពីតូក្យូមកទីក្រុងភ្នំពេញ។

- ក្នុងខែសីហា ១៩៥៣ការចរចានៅទីក្រុងភ្នំពេញរវាងតំណាងរដ្ឋាភិបាលបារាំងនិងតំ ណាងរដ្ឋាភិបាលខ្មែរ។

- ០៨ វិច្ឆិកា ១៩៥៣ ព្រះបាទនរោត្តមសីហនុយាងចូលមកគង់នៅទីក្រុងភ្នំពេញ។

- ០៩ វិច្ឆិកា ១៩៥៣ មុខព្រះបរមរាជវាំង ឧត្តមសេនីយបារាំងដឺឡង់ក្លាតជាមេទ័ពធំបង្អស់ របស់បារាំងនៅកម្ពុជាបានប្រគល់បញ្ជាការទ័ពរបស់ខ្លួនថ្វាយមកមហាក្សត្រខ្មែរ។

-នៅថ្ងៃទី០៣ ខែមីនាឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តមសីហនុបានបង្កើតគណបក្សសង្គម រាស្ត្រនិយមចូលរួមប្រកួតប្រជែងបោះឆ្នោតទទួលបាន៨៣ភាគរយនៃអាសនៈទាំងអស់។

-នៅថ្ងៃទី១១កញ្ញា ឆ្នាំ១៩៥៥ ព្រះនរោត្តមបានបង្កើតរដ្ឋាភិបាលសង្គមរាស្ត្រនិយមដើម្បី ដឹកនាំប្រទេសកម្ពុជា។

## II-ការវិភាគអត្ថបទ

## ក. ស្ថានភាពរឿង

### ១- សង្ខេបរឿង

ពូសួន សុខ និងមីងសន ជាកសិករនៅភូមិបវេល ស្រុកសង្កែ ខេត្តបាត់ដំបង មានកូនប្រុសម្នាក់ឈ្មោះ សួន សម ។ ពូសុខ ត្រូវពួកបារាំងចាប់យកទៅធ្វើទារុណកម្មរហូតដល់ស្លាប់នៅឆ្នាំ១៩៤៩ ដោយចោទប្រកាន់ថា ចូលដៃជាមួយឥស្សរៈ។ បន្ទាប់ពីឪពុកស្លាប់ទៅ សមបានបោះបង់ចោលការសិក្សាត្រឹមថ្នាក់ឧត្តមដ្ឋាន ដើម្បីមកបម្រើម្ដាយខ្លួនជាស្ដ្រីមេម៉ាយ នៅជាមួយម្ដាយបានមួយឆ្នាំ សមត្រូវខ្មែរឥស្សរៈចោទថាចូលដៃជាមួយបារាំង ហើយបានភៀសខ្លួនមកនៅក្នុងខេត្តបាត់ដំបង។

នៅឆ្នាំដដែលនោះ ម្ដាយសមត្រូវស្លាប់ដោយជំងឺអាសន្នរោគ។ សមបានទៅធ្វើបុណ្យសពឱ្យម្ដាយនៅឯស្រុកទាំងប្រថុយប្រថាន។ ដោយស្ថិតនៅក្នុងស្ថានភាពបែបនេះ សមក៏បានសម្រេចចាកចេញស្រុកកំណើត មករកការងារធ្វើនៅឯភ្នំពេញ ដោយបានស្នាក់នៅជាមួយភិក្ខុ**សៅ** នៅវត្តមហាមន្ត្រី។ ព្រះសង្ឃនេះបានជួយរកការងារឱ្យ **សម** បានធ្វើនៅក្នុងហាងទំនិញមួយ ដោយទទួលបានកម្រៃ១៥រក្នុងមួយថ្ងៃ។ ដោយអត់ទ្រាំនឹងការប្រមាថ មើលងាយមើលថោកពីបណ្ដាសំណាក់ថៅកែមិនបាន **សម**ក៏សម្រេចចិត្តឈប់ធ្វើការនៅទីនោះ។ នៅតាមបណ្ដាហាងជំនួញ និងកន្លែងការងាររាជការផ្សេងៗ ស្ទើរតែដូចគ្នាទាំងអស់សុទ្ធតែមានការមើលងាយ មើលថោកកម្មករដូចៗគ្នា។ ពេលនោះ**សម**ត្រូវធ្លាក់ខ្លួនជាកម្មករធាក់ស៊ីក្លូ ហើយទទួលបាននាង**សយ** ដែលជាស្ដ្រីបម្រើក្នុងគេហដ្ឋានគហបតីម្នាក់មកធ្វើជាប្រពន្ធ រួចបានមកជួលកូនខ្ទមតូចមួយនៅជិតផ្សារសួនថ្មីមកធ្វើជាទីស្នាក់អាស្រ័យ។ ក្នុងសភាពជាកម្មករធាក់ស៊ីក្លូ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹកដូចនេះ **សម**ត្រូវបង់ប្រាក់ថ្លៃឈ្នួលផ្ទះក្នុងមួយខែ១០០រ និងថ្លៃត្រីចក្រយាន៣០រទៀតក្នុងមួយថ្ងៃ។ ទោះជាសមខិតខំរកស៊ី ងូតញើសតាងទឹក យ៉ាងណាក៏ដោយក៏**សម**ពុំអាចរកលុយសម្រាប់បង់ថ្លៃឈ្នួល ទាំងនោះបានដែរ។ ថ្វីត្បិតតែសមខំអង្វរដល់អ្នកស្រី **គឹម លៀង** ដែលជាថៅកែត្រីចក្រយានយ៉ាង ណាក៏ដោយ ក៏ថៅកែស្រីនេះពុំមានចិត្តអាណិតអាសូរដល់ជីវិតកម្មករដូច**សម**តិចតួចឡើយ ។ ផ្ទុយទៅវិញ

ថៅកែស្រីរូបនេះ ក៏បានដកហូតស៊ីក្លូពី**សម**ថែមទៀត។ នៅពេលជាមួយគ្នានោះ **សៅ** ជាជនរកស៊ីឆក់ប្លន់បានមកបបួល**សម**ឱ្យរកស៊ីជាមួយខ្លួន តែសមបដិសេធព្រោះជាមុខរបរទុច្ចរិត។ ដោយគ្មានប្រាក់បង់ថ្លៃឈ្នួលផ្ទះ**សម** និងប្រពន្ធខ្លួន ត្រូវតា**សាន** ម្ចាស់ផ្ទះបណ្ដេញចេញពី ផ្ទះទៀត ទោះជាមានការអង្វរករយ៉ាងណាក៏ដោយ ក៏តា**សាន**នាយទុននេះ មិនអើពើអ្វីឡើយ ពួក នាយទុនទាំងនេះត្រូវការតែប្រាក់ប៉ុណ្ណោះ។ ដោយខ្វះទីពំនាក់អាស្រ័យ គេទាំងពីរនាក់ប្ដីប្រពន្ធ ក៏ បានធ្វើដំណើរជ្រកតាមសំយ៉ាបផ្ទះចិន គ្មានគោលដៅអ្វីឡើយ។ នៅវេលាល្ងាចមួយ គេក៏បានធ្វើ ដំណើរមកដល់វត្តលោកសង្ឃយួន គឺវត្តទួលប្រស្រី ក្នុងពេលនោះ គេមានប្រាក់តែ ១០០រគត់ ក្នុង ហោប៉ៅរបស់គេ។ ស្ថិតក្នុងស្ថានភាពតឹងតែងដូចនេះ នាង**សយ**ក៏បានសុំការអនុញ្ញាតិពី**សម** ដើម្បី ទៅនៅបម្រើថៅកែ**ហុក** ដែលមានប្រាក់ថ្លៃឈ្នួលក្នុងមួយខែ២០០រ ស្របពេលជាមួយគ្នានោះ**សម** បានធ្វើដំណើរទៅកាន់ស្រុកកំណើតដើម្បីលក់របស់របរបន្តិចបន្តួចគ្រាន់បានជាដើមទុនក្នុងការ ប្រកបមុខរបរចិញ្ចឹមជីវិត។ នៅវេលាយប់នាថ្ងៃដំបូង ថៅកែ**ហុក** ក៏បានប្រើឧបាយកល និងអំណាច ដ៏ឆ្គួតលីលា មកចាប់រំលោភលើនាង**សយ** ។ ដោយអត់ទ្រាំនឹងភាពឈឺចាប់ដ៏សែនព្រៃផ្សៃនេះ តទៅទៀតពុំបាន នាង**សយ** បានរត់ចេញពីផ្ទះថៅកែ**ហុក** មកស្នាក់នៅជាមួយនាយ**ម៉ី** និងនាង**មុំ** ដែល ជាសម្លាញ់ របស់ខ្លួនវិញ ។ ក្រោយពេលត្រឡប់មកពីបាត់ដំបងវិញ ដោយបានដឹងថាមានរឿងដ៏សែនអាម៉ាស់បែបនេះកើតឡើង**សម**បានសម្រេចចិត្តទៅសម្លាប់ថៅកែ**ហុក**ដើម្បីសងជំងឺចិត្ត ឱ្យប្រពន្ធរបស់ខ្លួន ទោះជាមានការអង្វរករពីប្រពន្ធរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏**សម**ពុំអើពើអ្វី ដែរ។ ដោយសារឧបាយកលរបស់នាយទុន និងដោយសារអំណាចទឹកប្រាក់ ១០.០០០រ បានធ្វើ ឱ្យ**ម**ត្រូវគេវាយយ៉ាងដំណំ និងត្រូវជាប់គុកចំនួន៣ខែទៀត។ នៅក្នុងគុកទៀតសោត ដោយ អំណាចទឹកប្រាក់របស់ហ៊ា**ហួរ** ដែលជាមេល្បែង **សម**ត្រូវអ្នកជាប់គុកដូចគ្នាព្រួតវាយធ្វើបាប ទៀត។ ពេលចេញពីគុកមកវិញ **សម** បានមករស់នៅជាមួយនាង**សយ** នៅផ្ទះ**ម៉ី** ជាបន្តទៀត ដោយបន្តមុខរបរជាអ្នកធាក់ស៊ីក្លូដូចដើមវិញ។

នៅវេលាយប់មួយ **សម**ត្រូវបានរថយន្តហ្សីបមួយគ្រឿងបើកបុកយ៉ាងធ្ងន់បណ្ដាលអោយទទួលរងនូវគ្រោះថ្នាក់យ៉ាងដំណំ។ ក្រោយពីបានជាសះស្បើយមក **សម**ក៏បានមកធ្វើជាកម្មករបម្រើ ការងារនៅក្នុងរោងចក្រសាប៊ូ ដោយទទួលបាននូវប្រាក់កម្រៃមួយថ្ងៃ៣០រ។ ដោយសារការខិតខំប្រឹងប្រែងរបស់ខ្លួន **សម**ត្រូវបានឡើងឋានៈជាកាប៉ូរ៉ាល់ ហើយបានមកនៅក្នុងរោងចក្រ

ជាមួយនឹង ប្រពន្ធរបស់ខ្លួន។ **សម**ត្រូវ**សេងហុង**ជាអ្នកចាត់ការថ្មី បណ្ដេញឱ្យឈប់ធ្វើការ។ ពេលនោះ**សម** ក៏បាននាំប្រពន្ធរបស់ខ្លួនត្រឡប់មករស់នៅជាមួយនាយ**ម៉ី** ដោយបន្តមុខរបរជាអ្នកធាក់ស៊ីក្លូបន្តទៀត។ក្រោយមកគេក៏បានចូលបម្រើការងារលើសែងនៅមាត់ទន្លេតែត្រូវគេមើលងាយ មើលថោក និងបញ្ឈប់ការងារទៀត។ ដោយគ្មានលទ្ធភាពបម្រើការងារនៅតាមហាង និងរោងចក្រនានាបាន **សម**បានផ្ដើមគំនិតបង្កើតជាសមាគមសម្ងាត់មួយដើម្បីជាប្រយោជន៍ដល់កម្មករទាំងអស់គ្នាក្នុង នោះ**សម**មានមុខងារជាប្រធានសមាគម។

ស្របពេលជាមួយគ្នានោះ ប្រទេសកម្ពុជាត្រូវមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ពេលនោះក៏មានអ្នកនយោបាយ២នាក់ មកនិយាយអង្វរ**សម** សូមឱ្យ**សម** អាណិតមេត្តាខ្លួន ឱ្យបានជាប់ឆ្នោតជាតំណាងរាស្ត្រ ដោយបានសន្យាថាក្រោយពីខ្លួនជាប់ជាតំណាងរាស្ត្រហើយ គេនឹងជួយពួកកម្មករឱ្យពេញសមត្ថភាព គេនឹងតវ៉ារាជរដ្ឋាភិបាលឱ្យជួយលើកស្ទួយជីវភាព កម្មករឱ្យបានស្រួល ដូចជា តវ៉ាម្ចាស់ត្រីចក្រយាន្ត ឱ្យយកថ្លៃឈ្នួលថោក ជួយជ្រោមជ្រែង ពួកកម្មករមានផ្ទះនៅ មានភ្លើង ទឹកម៉ាស៊ីនប្រើប្រាស់ជាដើម។ ក្រោយពីបានសម្រេចបំណងហើយ អ្នកនយោបាយបោកប្រាស់នោះ គេក៏បានភ្លេចអស់នូវអ្វីៗដែលបានសន្យាជាមួយពួកកម្មករ។ ហើយគេ ថែមទាំងបានបោះបង់ចោលនូវសមាគមនេះទៀតផង។ ទីបំផុត សមាគមនេះត្រូវរលាយរូប។ ទីស្នាក់ការសមាគម ត្រូវគេដកជួលឱ្យចិន យួន ដែលហ៊ានឱ្យថ្លៃឈ្នួលខ្ពស់។ **សម**ត្រូវទៅ ជួលកូនខ្ទមដែលនៅឆ្ងាយពីទីក្រុង ដែលពួកនាយទុនបានចាប់ដីថ្មីទុក។ **សម**នៅតែធាក់ស៊ីក្លូ ដដែល។ ពីមួយថ្ងៃទៅមួយថ្ងៃ កម្លាំងកាន់តែទ្រុឌទ្រោមៗ ប្រាក់ក៏គ្មាន។ នៅវេលាយប់មួយ នៅពេលដែល**សម**កំពុងធាក់ស៊ីក្លូដូចធម្មតា ដើម្បីសន្សំលុយទុកនៅពេលប្រពន្ធឆ្លងទន្លេ ស្រាប់តែជួបអ្នកលេងហើយប្លន់លុយពី**សម** តែ**សម**គ្មានលុយ ត្រូវពួកនេះធ្វើបាបគ្មានត្រាប្រណី។ ពេលប្រពន្ធឈឺពោះដោយមិនអាចទៅមន្ទីរពេទ្យបាន **សម**បានទៅពឹងគ្រូពេទ្យ**នរា** ឱ្យជួយ សង្គ្រោះនាង។ តែគ្រូពេទ្យមិនអាចជួយបាន ព្រោះគ្មានប្រាក់១.០០០៛ ជាកម្រៃដល់គាត់។ ទីបំផុត នាងត្រូវបាត់បង់ជីវិត ទោះជាមានការជួយជ្រោមជ្រែងពីសំណាក់យាយ**ប៉ោង** យាយ**ប៉ោះ** និង**សាន** យ៉ាងណាក៏ដោយ។

**សម**រស់នៅតែលតោល ប្រពន្ធក៏ស្លាប់ ប្រាក់ក៏គ្មាន ស៊ីក្លូក៏គេដកហូត។ ពេលនោះ**សម** ក៏ដាច់ចិត្តទៅពឹងពាក់លោក**យ៉េង** ដែលជាអ្នកធ្លាប់ពឹងពាក់ខ្លួនពីលើកមុន ឥឡូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ ព្រមទាំងមានស៊ីក្លូជួលធាក់ទៀតផង។ តែលោក**យ៉េង** បែរជាធ្វើមិនស្គាល់ ហើយ

ថែមទាំងមិនឱ្យស៊ីក្លូជួលធាក់ទៀត ព្រោះគ្មានប្រាក់កក់មុន។ **សម**ត្រូវជាប់គុកព្រោះអនាថា នៅពេលចេញពីគុកមកវិញ **សម**ក៏ត្រូវអត់បាយ ២-៣ថ្ងៃ ផឹកតែទឹកម៉ាស៊ីនតាមចិញ្ចើមថ្នល់ ព្រោះគ្មានលុយ។ ស្ថិតក្នុងសភាពទាល់ច្រកដូចនេះ **សម**ក៏ដាច់ចិត្តឆក់កាបូបពីបុរសពីរនាក់ប្ដីប្រពន្ធដែលទើបនឹងចេញពីរោងភាពយន្ត។ **សម**បានរួចខ្លួនពីការដេញចាប់ ហើយក៏បានយកប្រាក់ដែលឆក់បាននោះទៅទិញអាហារបរិភោគយ៉ាងឆ្អែតឆ្អល់ រួចក៏ត្រឡប់ទៅផ្ទះ**ម៉ី**វិញ។ គេទាំងពីរនាក់ក៏បានពិគ្រោះគ្នាថា អំពើនេះ គឺជាប្រការមួយមិនល្អ ប្រសិនជាយករបស់នោះ ទៅឱ្យម្ចាស់គេវិញ នោះគង់នឹងមានការអនុគ្រោះ ពីម្ចាស់របស់ជាពុំខាន។ ផ្ទុយទៅវិញ **សម**ត្រូវម្ចាស់ទ្រព្យគឺលោកឧកញ៉ា **សំបូរ សម្បត្តិ** ធ្វើបាប និងឱ្យប៉ូលិសចាប់ដាក់គុកអស់៦ខែទៀត។

ចេញពីគុក **សម**ត្រូវឡានរដ្ឋមន្ត្រីបុក។ ហើយរដ្ឋមន្ត្រីក្មេងរូបនេះ បានយកចិត្តទុកដាក់ជួយសង្គ្រោះ**សម** រួចយក**សម** ទៅបម្រើការងារនៅផ្ទះរបស់ខ្លួន។ **សម**រស់ក្រោមដំបូលផ្ទះរដ្ឋមន្ត្រីក្មេងដោយសុខសាន្ត។ ដោយយល់ឃើញថា ជីវិតកម្មកររស់នៅទីក្រុងគ្មានសុភមង្គលអ្វីទេនោះ **សម**ក៏សម្រេចចិត្តចាកចេញពីទីក្រុងភ្នំពេញ មកប្រកបមុខរបរជាកសិករវិញ។

បីឆ្នាំដំបូង គាត់ខិតខំបង្កបង្កើនផល តែមិនបានទទួលផល ព្រោះគាត់ធ្វើស្រែប្រវាស់មេឃ។ **សម**ត្រូវជាប់ឆ្នោតជាមេឃុំ នាសម័យសង្គមរាស្ត្រនិយម។ ក្នុងនាមប្រធានគណៈកម្មការកងឃុំ **សម**បានដឹកនាំប្រជា រាស្ត្រ អោឱ្យដើរតាមរបបសង្គមរាស្ត្រនិយម
ហើយគាត់ត្រូវបានចូលរួមសមាជជាតិលើកទី៩ នៅ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៦០។

មកដល់ភ្នំពេញ **សម**បានជិះស៊ីក្លូមើលទិដ្ឋភាពនៃទីក្រុង ឃើញថាមានភាពរីកចម្រើនជាង ៧-៨ឆ្នាំមុន។ **សម**បានរំឭកពីឆាកជីវិតពីអតីតកាលរបស់ខ្លួន ពិសេស បាននឹកដល់ខ្មោចប្រពន្ធកម្សត់របស់ខ្លួនជាខ្លាំង។ ក្រោយពីបានបំពេញការងារចប់សព្វគ្រប់របស់ខ្លួនហើយ **សម**បានវិលត្រឡប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញ ហើយបានប្រកបការងារជាកសិករជារៀងរហូតទៅ។

**២. រាយឈ្មោះតួអង្គ**

- **ពូស្វន សុខ** : ជាឪពុករបស់សម ត្រូវបារាំងចាប់ធ្វើទារុណកម្មរហូតស្លាប់ ។
- **មីងសន** : ជាប្រពន្ធពូស្វន សុខ និងជាម្ដាយរបស់សម ។
- **ស្វន សម** : ជាតួអង្គឯកក្នុងរឿង ។

- **នាងសយ** :  ជាភរិយារបស់សម ដែលត្រូវថៅកែហុកចាប់រំលោភហើយស្លាប់នៅពេលឆ្លងទន្លេដោយគ្មានប្រាក់។
- **ម៉ី និងនាងមុំ** :  ជាកម្មករធាក់ស៊ីក្លូ និងជាមិត្តភក្តិរួមសុខទុក្ខជាមួយសម ។
- **សួស សាន យាយប៉ោង យាយប៉ោះ** : ជាអ្នកជួយយកអាសារសម នៅពេលមានអាសន្ន។
- **យាយកាន** : ថៅកែត្រីចក្រយាន ដែលមានអធ្យាស្រ័យល្អចំពោះកម្មករ ។
- **ភិក្ខុសៅ** : ជាភិក្ខុមួយអង្គនៅវត្តមហាមន្ត្រី ជាអ្នកជួយសម ឱ្យបានការងារធ្វើក្នុងហាងទំនិញមួយ។
- **រដ្ឋមន្ត្រីក្មេង** : ជាអ្នកធ្វើឱ្យសមមានគ្រោះថ្នាក់ហើយក៏ជាអ្នកជួយសង្គ្រោះជីវិតសមដែរ។
- **ថៅកែហុក** : ជាអ្នកជំនួញមានទ្រព្យសម្បត្តិស្តុកស្តម្ភ ជានាយទុនដែលមានចិត្តកំណាចឃោរឃៅ ហើយជាអ្នករំលោភលើនាងសយ ដែលជាភរិយារបស់សម ។
- **អ្នកស្រីគឹម លៀង** : ជាប្រពន្ធរបស់ថៅកែ គឹម ឈុន ជាថៅកែត្រីចក្រយាន ស្គាល់តែពីលុយ ពុំមានការសន្តោសដល់កម្មករឡើយ។
- **ហ៊ា ហួរ** : អ្នកលេងល្បែងស៊ីសង ចូលទៅធ្វើថៅហ្វាយអ្នកទោសក្នុងគុក ។
- **សេង លី** : នាយទុនម្ចាស់ឧស្សាហកម្មសាប៊ូ ។
- **សេង អាន** : កូនរបស់សេង លី និងជាឈ្មួញនៅក្រៅប្រទេស ។
- **សេង ហុង** : ក្មួយរបស់សេង លី អ្នកចាត់ការថ្មី ជាអ្នកបណ្តេញសម និងកម្មករខ្មែរចេញពីរោងចក្រឧស្សាហកម្មសាប៊ូ ។
- **លោកយ៉េង** : អ្នកនយោបាយបោកប្រាស់កម្មករត្រីចក្រយាន្ត ។
- **អ្នកស្រីសំបូរ សម្បត្តិ** : ម្ចាស់ទ្រព្យគ្មានក្តីមេត្តា ។
- **គ្រូពេទ្យនរា** : គ្រូពេទ្យមើលឃើញតែប្រាក់ជាធំ ។
- **តាសានម្ចាស់ផ្ទះឈ្នួល** : ចិត្តឫស្យា ស្គាល់តែលុយ ។
- **ប៉ូលីស** : ជាអាជ្ញាធរ នាសម័យសង្គមរាស្ត្រនិយម ។
- **សួស** : ជាប៉ូវ៉ាល់អ្នកទោស ជាអ្នកការពារនាយទុន ។
- **សៅ** : អ្នកលេងក្នុងក្រុង ។
- **អាគុជ** : ជាអ្នកបំរើអ្នកស្រីគឹម លៀង ។

**៣.កាលអាកាស**

+ **កាល៖** ដំណើររឿងប្រព្រឹត្តទៅនៅចន្លោះឆ្នាំ១៩៤៩ដល់ឆ្នាំ១៩៦០ គឺប្រហែលរយៈពេល១១ឆ្នាំ។

+ **អាកាស៖** ដំណើររឿងបានប្រព្រឹត្តទៅនៅក្នុងទីកន្លែងនៃប្រទេសកម្ពុជារួមមានស្រុកបវេល ខេត្តបាត់ដំបង រាជធានីភ្នំពេញ វត្តភ្នំ វត្តមហាមន្ត្រី ផ្សារធំថ្មី...។

**ខ- សិក្សាអត្ថន័យនៃរឿង**

**១. ប្រធានរឿង** បញ្ហាសំខាន់ដែលអ្នកនិពន្ធលើកយកមកក្នុងពេលនេះគឺ «បញ្ហាទុរគតភាពរបស់កម្មករ កសិករ ស្ថិតនៅចុងសម័យអាណានិគមនិយមបារាំងនិងការរីកចម្រើន លើគ្រប់វិស័យនាសម័យសង្គមរាស្ត្រនិយម » ។

**២. មូលបញ្ហារឿង** មូលបញ្ហានៃរឿងស្ថិតនៅជុំវិញបញ្ហាជាច្រើនដូចជា ៖

– **បញ្ហាអសន្តិសុខរបស់សង្គមខ្មែរ**នៅចុងសម័យ**អាណានិគមនិយមបារាំង**

នាឆ្នាំ១៩៤៩ សង្គមកម្ពុជាត្រូវមានកម្លាំងពីរប្រទុសសារាយគ្នាមួយគឺ ពួកអាណានិគមនិយមបារាំង និងពីរ គឺពួកខ្មែរឥស្សរៈ កំលាំងទាំងពីរនេះ តែងតែប្រឈមមុខដាក់គ្នាជានិច្ច។ ដើម្បីបំបែកចលនានេះ បារាំងបានអនុវត្តនយោបាយឃោរឃៅមកលើប្រជារាស្ត្រខ្មែរ តួយ៉ាងនៅវត្តទីមួយ (ពូ**សួន-សុខ** ត្រូវបានពួកបារាំងចាប់វាយធ្វើបាប រហូតដល់ស្លាប់នៅឆ្នាំ១៩៤៩ ដោយចោទថាចូលដៃជាមួយខ្មែរឥស្សរៈ) ។

ស្ថិតនៅក្នុងស្ថានភាពបែបនេះ ប្រជាជនយើងមានការភិតភ័យយ៉ាងខ្លាំង។ ម្យ៉ាងខ្វះស្បៀងអាហារ ម្យ៉ាងទៀតខ្លាចស្លាប់ គេបានបង្ខំចិត្តផ្លាស់ប្តូរទីលំនៅជាញឹកញាប់ ដែលជាកត្តាមួយធ្វើអោយជីវភាពរបស់គេកាន់តែជួបប្រទះនូវការលំបាកវេទនារកទីបំផុតគ្មាន ជាក់ស្តែង**សម**បានផ្លាស់ ទីលំនៅជាញឹកញាប់ពីភូមិកំណើតមកបាត់ដំបង រួចពីបាត់ដំបងមកភ្នំពេញ ។

– **បញ្ហាជិះជាន់កេងប្រវ័ញ្ចរបស់ពួកនាយទុន និងមន្ត្រីរាជការពុករលួយមួយចំនួនមកលើកម្មករ និងកសិករ:**

បន្ទាប់ពីសង្គមកម្ពុជាយើងទទួលបានឯករាជ្យ ពីអាណានិគមនិយមបារាំង រាជរដ្ឋាភិបាលយើងត្រូវប្រឈមមុខនឹងបញ្ហាគ្រប់បែបយ៉ាង ដើម្បីអភិវឌ្ឍសង្គមជាតិ។ ស្របពេលជាមួយគ្នានោះ

ក្នុងដំណាក់កាលដំបូងនេះ យើងឃើញមានលេចឡើងនូវវណ្ណៈនាយទុន និងពពួកមន្ត្រីរាជការពុករលួយមួយចំនួនដែលជាអ្នកឱកាសនិយម ដែលតែងតែកើតមានជានិច្ចនៅក្នុងសង្គមមនុស្សជាតិ។ ពួកគេទាំងនេះ ពុំបានគិតគូរពីជីវភាពរបស់ប្រជាកសិករ កម្មករ និងប្រទេសជាតិឡើយ។ ផ្ទុយទៅវិញ ពួកគេទាំងនេះ បានខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីចំរាញ់យកផលពីពពួកកម្មករ ដោយពុំបានគិតពីសេចក្ដីលំបាកវេទនារបស់កម្មករឡើយ តួយ៉ាង **សេង ហុង** ជាអ្នកចាត់ការថ្មីរោងចក្រសាប៊ូបាននិយាយថា " អា**សម** ចាប់តាំងពីថ្ងៃស្អែកនេះទៅ អញត្រូវបន្ថយគូលីខ្មែរចេញ ១០នាក់... អញនឹងរកគូលីចិន យួន មកជំនួសវិញ ព្រោះគូលីខ្មែរធ្វើការយឺតណាស់ ហើយខ្ជិលណាស់........" ទំព័រ ១៥០ - ១៥១ ។

លើសពីនេះទៅទៀត គេបានមើលងាយមើលថោកដល់ប្រជាកម្មករ កសិករ និងស្ត្រីភេទដោយចាត់ទុកថា គ្រាន់ជាគ្រឿងសម្រាប់បម្រើការសប្បាយរបស់គេតែប៉ុណ្ណោះ តួយ៉ាង ថៅកែ**ហុក** "**សយ**ឯងជាអ្នកក្រ សេចក្ដីត្រូវការរបស់អ្នកក្រនោះមិនមែនប្រាក់ទេវី? ឯងបណ្ដោយឱ្យគ្នាត្រឹមតែមួយភ្លែតតែប៉ុណ្ណោះ ដោយគ្មានអ្នកណាដឹងឮ និងឃើញទេនោះ ឯងនឹងបានប្រាក់២០០រៀលទៅហើយ" (ទំព័រ ៧៥) ។

ចំពោះមន្ត្រីពុករលួយមួយចំនួន ក៏មិនខុសពីពពួកនាយទុននោះប៉ុន្មានដែរ គឺគេសម្លឹងឃើញតែប្រាក់ជាធំ តួយ៉ាងគ្រូពេទ្យ**នរា** គេបានពោលថា៖ "កុំយកបុណ្យបាបមកនិយាយនឹងខ្ញុំ ខ្ញុំមិនត្រូវការបុណ្យអញ្ចឹងទេ សុំយកទៅពេទ្យធំទៅ បើយកខ្ញុំទៅមើលទាល់តែគិតលុយឱ្យខ្ញុំ បើតិចណាស់ក៏ ១.០០០រៀលដែរ ខ្ញុំខំរៀនសូត្រមកអស់ប្រាក់មិនតិចទេ អ្នកឯង............................. យកទៅពេទ្យធំទៅ" (វគ្គទី១០) ។

ជារួមមកយើងឃើញថា ចំពោះពពួកនាយទុន និងមន្ត្រីពុករលួយមួយចំនួន គេគិតតែយកមាស-ប្រាក់ជាធំ ព្រោះគេយល់ថា "មានប្រាក់ គឺមានអ្វីៗទាំងអស់" គេអាចធ្វើព្យុះ ធ្វើផ្គរ ស្រេចតែចិត្តគេ ដោយគេពុំគិតពីច្បាប់ និងសីលធម៌នៅក្នុងសង្គមឡើយ។

– **បញ្ហាប្រជាភិថុតរបស់អ្នកនយោបាយបោកប្រាស់**

ដើម្បីបុណ្យសក្តិ-អំណាចរបស់គេ ពួកអ្នកនយោបាយបោកប្រាស់មួយចំនួនបានធ្វើប្រជាភិថុតគ្រប់បែបយ៉ាងដោយបានអះអាងថា៖ ខ្លួនគេម្នាក់ៗ សុទ្ធសឹងជាអ្នកស្នេហានឹងប្រជារាស្ត្រ។ នៅពេលដែលគេពុំទាន់បានកាន់កាប់អំណាច គេហាក់ដូចជាចេះរិភាគ គិតគូរដល់ជីវភាពលំបាក

វេទនារបស់របស់ប្រជារាស្ត្រ ហើយថែមទាំងបានសន្យាថា រាល់សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋគេខិតខំដោះស្រាយជូន។ ជាក់ស្តែង អ្នកនយោបាយជាបេក្ខជនបោះឆ្នោតបាននិយាយថា "ប្អូនអាណិតជួយខ្ញុំឱ្យមែនទែនណា៎ .....................ដោយឱ្យមានផ្ទះ ភ្លើង ទឹកម៉ាស៊ីនជាដើម.." (ទំព័រ ១១៦) តែក្រោយពីបានសម្រេចបំណងរបស់ខ្លួនហើយ ពួកគេពុំអើពើដោះស្រាយបំណងរបស់កម្មករសោះឡើយ តួយ៉ាងដូចជានៅពេលដែល**សម** ទៅរកជួលស៊ីក្លូធាក់នៅផ្ទះលោក**យ៉េង** ដែលជាសមាជិកសភាជាប់ឆ្នោតថ្មី លោក**យ៉េង** បែរជានិយាយថាៈ "ទេមិនបានទេគ្នាជួយឯងរបៀបនេះពុំបានទេ ស៊ីក្លូគ្នាថ្លៃណាស់ ... ហើយឯងរត់បាត់ទៅគ្នាធ្វើយ៉ាង ម៉េច?" លើសពីនេះទៀត ដោយការធុញទ្រាន់នូវការទទូចអង្វររបស់**សម** លោក**យ៉េង** បានពោលបន្តទៀតថា "ប្រយ័ត្នគ្នាហៅប៉ូលិសមកធ្វើសរសៃឱ្យរ៉ឺយ បើឯងនៅតែធ្វើរបៀបនេះទៀត" (ទំព័រ ២៦១) ។

ដូចនេះយើងឃើញថា ចំពោះពាក្យសន្យារបស់អ្នកនយោបាយមួយចំនួនជាមួយកម្មករនោះគ្រាន់តែជាពាក្យប្រជាភិថុតតែប៉ុណ្ណោះ ក្នុងន័យនេះ បានបញ្ជាក់ច្បាស់ថា អ្នកនយោបាយទាំងនេះមិនគ្រាន់តែជាមនុស្សអត្តទត្តបុគ្គលប៉ុណ្ណោះទេ គឺគេថែមទាំងបានបង្កើនការលំបាកដល់កម្មករអោយធ្ងន់ធ្ងរថែមទៀតផង។

– **បញ្ហាទុរគតភាពរបស់កម្មករ**

ដោយស្ថិតនៅក្នុងស្ថានភាពខ្វះមុខខ្វះក្រោយមិនចេះចប់មិនចេះហើយ ពិសេសដោយកម្មករគ្មានតួនាទី អ្វីក្រៅពីការផលិត និងលក់ពលកម្មឱ្យគេ កម្មករមួយចំនួនថែមទាំងគ្មានការងារធ្វើផងនោះ បញ្ហាទាំងនេះ បានបង្ខំឱ្យគេហ៊ានធ្វើអ្វីៗទាំងអស់ និងគ្រប់បែបយ៉ាងដោយពុំគិតពីតម្លៃ នៃសីលធម៌ និងច្បាប់សង្គមឡើយ។ តួយ៉ាង**សម** នៅពេលដែលគេអត់ឃ្លានពេក គេក៏បានទៅឆក់កាបូបពីលោកស្រី**សំបូរ សម្បត្តិ** ដើម្បីយកប្រាក់កាសទៅទិញអាហារសម្រាប់ចំអែតក្រពះរបស់ខ្លួន។ ក្រោយពេលបន្ថយការឃ្លានរបស់ខ្លួនមក**សម**បានឃើញនូវ កំហុសឆ្គងដែលខ្លួនបានប្រព្រឹត្ត។

សរុបមកភាពតោកយ៉ាក និងក្រីក្ររបស់កម្មករ អាស្រ័យដោយសង្គមពុំមានការធានា។

– **កសិករជាកម្លាំងស្នូលដ៏សំខាន់មួយក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ**

ក្រោយពីបានឆ្លងកាត់ការសោកល្បង ក្នុងជីវិតតែមួយរយៈកន្លងមក។ ពិសេសក្រោមមាគ៌ាដឹកនាំដ៏ភ្លឺស្វាង របស់អង្គសម្ដេចឪនៃយើង **សម**បានក្លាយខ្លួនជាកសិករមួយរូបយ៉ាងប្រពៃ ហើយគេបានបំផុសនៅក្នុងជួរប្រជាជន ដើម្បីខិតខំផលិតជាផលិតផល ជួយកសាងជាតិ ព្រោះគេយល់ឃើញថា កសិកម្មខ្មែរជាកត្តាកំណត់នូវសេដ្ឋកិច្ចជាតិឱ្យរីកលូតលាស់។

ជារួមមកយើងឃើញថា បញ្ហាទុរគតភាពរបស់កម្មករដែលកើតមានឡើងនោះ គឺបណ្ដាលមកពីកាកសំណល់នៃរបបអាណានិគមបានបន្សល់ទុកឱ្យ ជាពិសេសទៀត គឺបណ្ដាលមកពីសង្គមយើងទើបនឹងទទួលបានឯករាជ្យដំបូង ហើយអ្វីៗទាំងអស់ស្ថិតក្នុងការកសាងថ្មីឡើងវិញ ។

– **ការរីកចម្រើនរបស់រាស្ត្រ និងប្រទេសខ្មែរនាសម័យសង្គមរាស្ត្រនិយម**

ក្រោយភ្លៀងមេឃស្រឡះ ក្រោយពីការឆ្លងកាត់នូវដំណាក់កាលដ៏សែនទារុណមួយមក អ្នកនិពន្ធបានធ្វើឱ្យរាស្ត្រ និងប្រទេសខ្មែរជួបនូវបរិយាកាសភ្លឺស្វាង រីកចម្រើន សម្បូរសប្បាយរុងរឿង។ រាស្ត្រមានសុភមង្គល មានសិទ្ធិសេរីភាពបរិបូរ មានជីវភាពធូរធារ មានការងារធ្វើចាកផុតពីអំពើហុតឈាមនានា។ ទាំងអស់នេះ គឺអាស្រ័យដោយនយោបាយដឹកនាំដ៏ប៉ិនប្រសប់ និងឈ្លាសវៃរបស់ព្រះអគ្គមគ្គុទេសក៍ខ្មែរដ៏ឆ្នើម គឺសម្ដេចព្រះនរោត្ដមសីហនុវរ្ម័ន ដែលជាព្រះអគ្គមគ្គុទេសក៍ជាទីគោរពស្នេហានៃរាស្ត្រខ្មែរទូទៅ។

តើព្រះរាជមាគ៌ានយោបាយដឹកនាំទាំងនោះរួមមានអ្វីខ្លះ?

+ទាមទារ**ឯករាជ្យនៅកម្ពុជា ៖** ព្រះបាទសម្ដេចនរោត្ដមសីហនុវរ្ម័ន

បានលះបង់ព្រះកាយពល បញ្ញាញាណ ដណ្ដើមឯករាជ្យពីជនបរទេស (អាណានិគមចាស់ថ្មី)។

ដោយព្រះអង្គឈ្វេងយល់ថា ឯករាជ្យនេះហើយ

នាំឱ្យកម្ពុជាមានអធិបតេយ្យភាពពេញលេញបរិបូរ ដែលអាចឱ្យរាស្ត្រខ្មែរអ្នក ដឹកនាំខ្មែរ

អាចសម្រេចបានអ្វីៗទាំងអស់ដោយខ្លួនឯង។

**+ពង្រីកសន្តិសុខក្នុងប្រទេស ៖** នៅក្រោយពីឯករាជ្យ បានធ្លាក់ដល់ដៃរាស្ត្រខ្មែរ ហើយសម្ដេចព្រះបិតាឯករាជ្យជាតិ ព្រះអង្គបានរៀបចំវិធានការសព្វបែបយ៉ាង បំបាត់ពួកឧទ្ទាមគ្រប់ទីកន្លែង គឺធ្វើឱ្យរាស្ត្រខ្មែរគ្រប់ច្រកល្ហករស់នៅដោយសុខសាន្តឥតមានការភ័យបារម្ភចំពោះអសន្តិសុខទៀតឡើយ។

**+អភិវឌ្ឍជនបទ និងទីក្រុង ៖** នៅជនបទ ព្រះបិតាកសិកម្មជាតិ ព្រះអង្គបានរៀបចំជនបទ តាមបែបផែនការប្រាំឆ្នាំ គឺ រៀបចំភូមិ ឃុំ ដាច់ស្រយាល ឱ្យមានទឹកស្អាតប្រើប្រាស់ សង់មន្ទីរពេទ្យ សាលារៀន ផ្តល់ ស្ពាន បម្រើសុខភាព ការរៀនសូត្រ ការធ្វើដំណើររបស់កូនចៅព្រះអង្គ។ កសាង នយោបាយទឹក ដោយព្រះអង្គបានកសាងជាបន្ទាន់នូវប្រព័ន្ធទំនប់ ប្រឡាយជីកស្រះ ជីកអណ្តូង ទឹក អាង ដើម្បីយកទឹកធ្វើស្រែចម្ការ ឱ្យបានគ្រប់គ្រាន់ឥតមានការព្រួយបារម្ភ លែងឱ្យរាស្ត្រធ្វើស្រែ ប្រវាស់មេឃ រណបធម្មជាតិដូចមុនទៀត។ ព្រះអង្គចាត់តាំងមន្ត្រីកសិកម្ម បំផុសណែនាំកសិករ ចេះប្រើជី រើសពូជដំណាំ កែប្រែគុណភាពដីទៅតាមក្បួនខ្នាតបច្ចេកទេស។ ព្រះរាជនយោបាយ "ពង្រីកការរស់នៅទាន់សម័យ និងធ្វើកសិកម្មបែបវិទ្យាសាស្ត្រ" នេះ ញ៉ាំងកម្រិតជីវភាពរាស្ត្រខ្មែរ កើនឡើងឥតឈប់ឈរ។ ជនបទបានប្រែមុខមាត់ពីក្រៀមក្រោះ មកស្រស់ញញឹមប្រឹមប្រិយ។ រាស្ត្រខ្មែរម្នាក់ៗរស់នៅក្នុងក្តីសង្ឃឹម និងគោរពដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គសម្តេចឪ ដូច បិតាបង្កើតរបស់ខ្លួន។ ចំណែកនៅទីក្រុង ព្រះអង្គបានរៀបចំរាជធានីភ្នំពេញ ទៅជាទីក្រុងទំនើប សក្តិសមជាបេះដូងកម្ពុជា គឺនៅភ្នំពេញមានមជ្ឈមណ្ឌលវប្បធម៌ ពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ ឥតចន្លោះអ្វីមួយឡើយ។

**+ហត្ថកម្មកសាងជាតិ ៖** ក្នុងនយោបាយនេះ ព្រះបិតាឯករាជ្យជាតិ ព្រះអង្គពុំប្រកាន់ព្រះ រាជឋានៈឡើយ ព្រះអង្គតែងតែយាងចេញប្រតិបត្តិការហត្ថកម្ម ដោយផ្ទាល់ព្រះហស្តព្រះអង្គ ព្រះអង្គតម្រូវឱ្យមន្ត្រីរាជការគ្រប់រូប បោះនូវដងប៉ាកាក្នុងពេលកំណត់មួយច្បាស់លាស់ ហើយឱ្យ អ្នកទាំងនោះចូលរួមធ្វើហត្ថកម្ម ចាប់នង្គ័ល រនាស់ ចប បង្កី ជាមួយរាស្ត្រ ដើម្បីឱ្យអ្នកទាំងនោះដឹង សុខទុក្ខ និងជីវភាពរបស់រាស្ត្រពិតប្រាកដ។ ស្ថិតនៅក្នុងព្រះរាជនយោបាយនេះ ញ៉ាំងឱ្យការងារ លំបាកធំធេងទាំងប៉ុន្មាន បែរជាមានភាពងាយស្រួល ហើយនិងបានជោគជ័យ គ្រប់ជំហាន។

**+សមាជជាតិ ៖** រួចមកហើយ ភាពអយុត្តិធម៌សង្គម ត្រូវបានលោក **សួន សុរិន្ទ** លាត ត្រដាងយ៉ាងច្បាស់ក្នុងរឿងរបស់លោក។ ឈានចូលដល់សម័យសង្គមរាស្ត្រនិយម អង្គសម្តេចឪ បានរៀបចំឱ្យមាន "សមាជជាតិ" ឡើងដែលតែងតែប្រព្រឹត្តធ្វើនៅរៀងរាល់ខែធ្នូ។ ព្រះរាជ នយោបាយ នេះជាវេទិកាដ៏ពិសេសបំផុត ចូលរួមចំណែកកាត់បន្ថយនូវ "ភាពអយុត្តិធម៌ក្នុង សង្គម" ពីព្រោះ វេទិកានេះ ជាវេទិកាដែលតម្រូវឱ្យប្រជារាស្ត្រមានសិទ្ធិបញ្ចេញមតិ យោបល់ បង្ហាញពីចំណុចល្អ អាក្រក់របស់មន្ត្រីរាជការខ្មែរ ដែលបានអនុវត្តការងារបម្រើរាស្ត្របម្រើ

ជាតិកន្លងមក។ សមាជនេះ អាចឱ្យរាស្ត្ររិះគន់មន្ត្រីរាជការខ្មែរ ដែលប្រព្រឹត្តនូវអំពើផ្សេងៗ ផ្ទុយពីឆន្ទៈរាស្ត្រ។ ជាមួយគ្នានេះ អាចឱ្យរាស្ត្រលើកឡើងនូវសំណូមពរផ្សេងៗ ដែលខ្លួនចង់បានផ្តល់ជាមតិប្លែកៗ ជូនរាជរដ្ឋាភិបាល ក្នុងការកសាងជាតិ។ មិនតែប៉ុណ្ណោះ សមាជនេះជាវេទិកាមន្ត្រីរាជការផ្សព្វផ្សាយ និងពិភាក្សារួម ជាមួយរាស្ត្រពីទិសដៅ ផែនការកសាងជាតិជូនរាស្ត្រ ដើម្បីឱ្យរាស្ត្រខ្មែរស្ម័គ្រចិត្តរួចធ្វើការងាររួម គ្នាឡើង។ រួមមក នយោបាយបែបនេះជាប្រាំងទប់ស្កាត់ កុំឱ្យមន្ត្រីក្តី រាស្ត្រក្តី ដើរទៅរកផ្លូវខុស ដែលជាប្រភពបង្កឱ្យមានភាពអន្តរាយដល់ប្រទេសជាតិ។

+**សុខាភិបាល អប់រំ ៖** សម្តេចឪព្រះអង្គបានចាត់ចែង បង្កើតឱ្យមានមន្ទីរពេទ្យ សាលារៀនពីបឋមដល់ឧត្តមឱ្យបានច្រើនជាអតិបរមា ដើម្បីអភិវឌ្ឍន៍សុខភាព និងចំណេះដឹងពលរដ្ឋទូទៅដោយឥតរើសមុខ។

តាមរយៈនយោបាយទាំងនេះហើយ ដែលធ្វើឱ្យសម ដែលជាតំណាងប្រជារាស្ត្រខ្មែរ ទទួលបាននូវកម្រិតជីវភាពគ្មានទីពំនឹង មកជាជនមានពំនឹង និងក្លាយជាពលរដ្ឋដ៏ល្អប្រពៃរបស់ជាតិ។ បំណងប្រាថ្នានេះសមតែងតែប្រាថ្នាជាយូរយារណាស់មកហើយ។

## ៣. ទំនាស់

**+ ទំនាស់ទី១**

– គូទំនាស់ : ទំនាស់រវាងថៅកែស៊ីក្លូ គឹម លៀង និងសម

– បុព្វហេតុទំនាស់ : សមគ្មានលុយបង់ថ្លៃស៊ីក្លូឱ្យអ្នកស្រី គឹម លៀង

– ផលវិបាក : សមគ្មានស៊ីក្លូធាក់ ដើម្បីរកប្រាក់ចិញ្ចឹមជីវិត

– លទ្ធផល : សមគ្មានការងារត្រូវឱ្យនាងសយ ទៅបម្រើផ្ទះថៅកែហុក ហើយសមខ្លួនឯងត្រូវទៅលក់របស់របរនៅស្រុកកំណើតយកប្រាក់មកផ្គត់ផ្គង់ជីវភាព ។

**+ ទំនាស់ទី២**

– គូទំនាស់ : ទំនាស់រវាងសម និងថៅកែហុក

– បុព្វហេតុទំនាស់ : សមខឹងនឹងថៅកែហុក ដែលរំលោភប្រពន្ធរបស់ខ្លួន

– ផលវិបាក : សមឡើងផ្ទះថៅកែហុក ក្នុងគោលបំណងសម្លាប់ថៅកែហុក ចោល ដើម្បីសងសិកឱ្យប្រពន្ធខ្លួនតែសមត្រូវកូនថៅថៅកែហុក វាយដំទ្រោមខ្លួន ។

– លទ្ធផល : សមត្រូវថៅកែហុក ប្ដឹងពីបទប៉ុនប៉ងមនុស្សឃាត ហើយសមត្រូវជាប់គុករយៈពេល ៣ខែ ។

**+ ទំនាស់ទី៣**

– គូទំនាស់ : ទំនាស់រវាងសម និងថៅកែរោងចក្រសាប៊ូ

– បុព្វហេតុទំនាស់ : ថៅកែរោងចក្រសាប៊ូកាត់កម្មករខ្មែរលែងឱ្យធ្វើការ ហើយសមដឹកនាំកម្មករធ្វើការតវ៉ា ។

– ផលវិបាក : សមត្រូវបានបញ្ឈប់ពីការងារ

– លទ្ធផល : សមគ្មានការងារធ្វើរួចមកបង្កើតសមាគមសំងាត់ ។

**+ ទំនាស់ទី៤**

– គូទំនាស់ : ទំនាស់រវាងសម និងលោកគ្រូពេទ្យនរា

– បុព្វហេតុទំនាស់ : នាងសយឈឺពោះឆ្លងទន្លេ
ហើយសមទៅពឹងលោកគ្រូពេទ្យនរា ឱ្យជួយ តែសមគ្មានប្រាក់ លោកគ្រូពេទ្យនរា មិនជួយ។

– ផលវិបាក : នាងសយសម្រាលកូនដោយគ្មានគ្រូពេទ្យ គឺមានតែយាយម៉បបុរាណពីររូប គឺយាយប៉ោះ និងយាយប៉ោង ។

– លទ្ធផល : នាងសយ និងកូនត្រូវស្លាប់នៅពេលសម្រាលធ្វើឱ្យសម សោកសង្រេងពេកក្រៃ ។

**+ ទំនាស់ទី៥**

– គូទំនាស់ : ទំនាស់រវាងសម និងលោកឧកញ៉ា សំបូរ សម្បត្តិ

– បុព្វហេតុទំនាស់ : សមឆក់កាបូបលោកស្រីឧកញ៉ា សម្បត្តិ ហើយសមយកកាបូបទៅសងលោកឧកញ៉ា សំបូរ សម្បត្តិ តែលោកឧកញ៉ា សំបូរ សម្បត្តិ ប្ដឹងប៉ូលីសឱ្យចាប់សម ។

– ផលវិបាក : សមត្រូវកូនចៅរបស់ឧកញ៉ា សំបូរ សម្បត្តិ វាយយ៉ាងដំណំ ។

– លទ្ធផល : សមត្រូវជាប់គុកអស់រយៈពេល ៦ខែ ។

## ៤. វិភាគតួអង្គ

**ក. តួអង្គសម:**

**+ គុណសម្បត្តិ:**

- ជាមនុស្សស្មោះត្រង់ មានគំនិតមនុស្សនិយម
- ជាមនុស្សសុចរិត ស្រឡាញ់ការងារ
- ជាមនុស្សស្អប់ខ្ពើមអំពើអយុត្តិធម៌ និងអមនុស្សធម៌ ។
- ជាមនុស្សមានភក្តីភាពចំពោះភរិយា
- ជាមនុស្សក្លាហាន ហ៊ានក្រោកឈរតវ៉ាចំពោះនាយទុន
- ជាមនុស្សមិនលោភលន់ មើលឃើញតែប្រាក់
- ជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារ
- ជាមនុស្សស្គាល់កាលៈទេសៈរបស់ស្រុកទេស
- ជាកសិករគម្រូ
- ជាមនុស្សដែលប្រជាជនស្រឡាញ់បោះឆ្នោតផ្តល់សេចក្តីទុកចិត្តឱ្យធ្វើជាប្រធាន ឃុំ... ។

**+ គុណវិបត្តិ**

- ជាចោរឆក់
- ជាមនុស្សហិង្សានិយម ឆេវឆាវ
- ជាមនុស្សស្រឡាញ់លុយ
- ជាមនុស្សឆាប់ជឿទុកចិត្តអ្នកដទៃ។

**ខ. តួអង្គនាងសយ**

**+ គុណសម្បត្តិ**

- ជាស្ត្រីប្រកបដោយលក្ខណៈសម្បត្តិល្អ
- មានភក្តីភាពចំពោះប្តី
- ចេះយល់ពីទុក្ខ និងការលំបាករបស់ប្តី
- ចេះការពារកិត្តិយសខ្លួនជាស្រី
- មិនលង់ក្នុងអំណាចទឹកប្រាក់
- ចេះលួងលោម និងផ្តល់កម្លាំងចិត្តឱ្យប្តី
- ធ្វើអ្វីចេះពិភាក្សាប្តូរយោបល់ជាមួយប្តី ។

**+ គុណវិបត្តិ**

- គ្មាន

- នាងមិនបានចូលរួមជួយរំលែកជីវភាពគ្រួសារ។

គ. តួអង្គលោករដ្ឋមន្ត្រីក្មេង

+ គុណសម្បត្តិ

- ជាមនុស្សមានគុណធម៌ មេត្តាធម៌
- ជាមេដឹកនាំល្អ
- ជាមនុស្សមានស្មារតីទទួលខុសត្រូវ
- ជាមនុស្សមិនចេះរើសអើង
- ជាមនុស្សរៀនសូត្រ ចេះដឹង
- ស្រឡាញ់ភាពស្មោះត្រង់ និងអំពើសុចរិត
- ជាមនុស្សយល់ពីសុខទុក្ខអ្នកក្រ ជួយស្រោចស្រង់អ្នកក្រខ្សត់ ។

+ គុណវិបត្តិ

- គ្មាន
- មិនបានណែនាំដល់អ្នកបើកបរឱ្យមានការប្រុងប្រយ័ត្នបណ្តាលឱ្យប៉ះពាល់ដល់សម។

ឃ. តួអង្គលោកគ្រូពេទ្យនរា

+ គុណសម្បត្តិៈ

- ខិតខំរៀនសូត្ររហូតក្លាយជាគ្រូពេទ្យ

+ គុណវិបត្តិ

- ជាមនុស្សស្រឡាញ់តែលុយ
- ជាមនុស្សគ្មានមនសិការក្នុងវិជ្ជាជីវៈ
- ជាមនុស្សមើលងាយជីវិតអ្នកក្រខ្សត់
- ជាមន្ត្រីរាជការពុករលួយ
- ជាមនុស្សគ្មានមេត្តាធម៌ គ្មានមនុស្សធម៌
- ជាមនុស្សមានសម្តីពុំពីរោះពិសា។

ង. តួអង្គលោកយ៉េង

+ គុណសម្បត្តិ

- ចេះស្គាល់កាលៈទេសៈ និងស្ថានភាពរស់នៅម្ចាស់ឆ្នោត
- ជាវាគ្មិន យ៉ាងពូកែក្នុងការរកសំឡេងឆ្នោត

**+ គុណវិបត្តិ**

- ជាមនុស្សក្បត់ពាក្យសន្យា
- ជាតំណាងរាស្ត្របោកប្រាស់
- ជាមនុស្សយកគុណសងដោយទោស
- បានបុណ្យសក្តិដោយការយកប្រាក់ទៅទិញ
- ជាមនុស្សមើលងាយអ្នកក្រខ្សត់

**ច. តួអង្គថៅកែហុក**

**+ គុណសម្បត្តិ**

- យកមនុស្សធ្វើការងារក្នុងផ្ទះដើម្បីបានប្រាក់កម្រៃចិញ្ចឹមជីវិត ។

**+ គុណវិបត្តិ**

- ជាបិសាចល្មោភកាមតណ្ហា
- កាចសាហាវវាយដំមនុស្សក្រៅច្បាប់
- ជាមនុស្សអាងលើអំណាចប្រាក់
- គ្មានមេត្តាធម៌គ្មានមនុស្សធម៌

**ឆ. តួអង្គលោកឧកញ៉ា សំបូរ សម្បត្តិ**

**+ គុណសម្បត្តិ**

- រកស៊ីរហូតក្លាយជាអ្នកមានស្តុកស្តម្ភ

**+ គុណវិបត្តិ**

- គ្មានមេត្តាធម៌ គ្មានមនុស្សធម៌
- ជាមនុស្សហិង្សានិយម
- ប្រើមនុស្សវាយដំមនុស្សក្រៅប្រព័ន្ធច្បាប់ ។

**៥. ឧត្តមគតិរឿង**

តាមរយៈរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធបានអប់រំយើងជាអ្នកសិក្សានិង

អ្នកអានដូចតទៅ ៖

–អប់រំឱ្យមនុស្សកសាងតែអំពើល្អ ចេះតស៊ូក្នុងឆាកជីវិត ទោះបីជួបបញ្ហាស្មុគស្មាញយ៉ាងណាក៏មិនត្រូវប្រព្រឹត្តអំពើទុច្ចរិតដែរ។

–អប់រំមនុស្សឱ្យចេះជួយយកអាសារគ្នាក្នុងគ្រាក្រ និងពេលមានអាសន្ន។ ជាការពិតណាស់គ្រាក្រអាចឱ្យយើងឃើញ និងស្វែងរកមិត្តភក្តិ ឬសាច់ញាតិថា តើនរណាខ្លះដែលស្មោះត្រង់ជាមួយយើង ឬមិនចង់យកអាសារយើង។

–អប់រំឱ្យយើងស្គាល់ពីមុខមាត់អាក្រក់របស់នាយទុន មន្ត្រីរាជការ ភ្នាក់ងារមានសមត្ថកិច្ចនិងតំណាងរាស្ត្រ ដែលជាប់កម្អែលពីអាណានិគមបារាំង ដែលតែងតែធ្វើបាប គាបសង្កត់លើអ្នកទន់ខ្សោយ។ ពួកគេអាងអំណាច អាងទឹកប្រាក់ ជិះជាន់សង្កត់សង្កិន បៀតបៀនអ្នកក្រ មិនសមឋានៈជា "មនុស្ស" នោះឡើយ។ ចំណុចនេះ អ្នកនិពន្ធចង់អប់រំមនុស្សកុំឱ្យប្រកាន់ចរិតលក្ខណៈបែបនេះទៀត។

–អប់រំមនុស្សឱ្យចេះតស៊ូដើម្បីយុត្តិធម៌ ពោលគឺប្រឆាំងជានិច្ចរាល់អយុត្តិធម៌គ្រប់បែបយ៉ាង។ សមសុខចិត្តអត់ការងារធ្វើ ដោយសារតែការពារយុត្តិធម៌ឱ្យពួកកម្មករ។

–អប់រំប្រជាជនខ្មែរឱ្យយកចិត្តទុកដាក់លើវិស័យកសិកម្ម មានន័យថា អ្នកស្រែចម្ការមិនត្រូវបោះបង់ចោលការងារកសិកម្ម ហើយមករស់នៅក្នុងឈ្មោះជាជនចំណាកស្រុក ព្រោះជាការរត់ចោលការអភិវឌ្ឍខឿនសេដ្ឋកិច្ចសង្គមខ្មែរ។

–អប់រំឱ្យយើងមើលឃើញពីនយោបាយដឹកនាំសង្គម នៃរបបសង្គមរាស្ត្រនិយម ដែលផ្តើមកសាងសង្គមឡើងដោយនយោបាយលើកស្ទួយ ជួយកែប្រែជីវភាពរស់នៅរបស់រាស្ត្រពីសេចក្តីអត់ឃ្លាន ឱ្យមានជីវភាពល្អប្រសើរឡើងវិញ។

**គ- អត្ថរូប**

**១. វិធីតែងនិពន្ធ** : រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធគាត់តែងឡើងតាមបែបប្រលោមលោកពាក្យរាយ។

**២. ការផ្តើមរឿង** : អ្នកនិពន្ធផ្តើមរឿងនេះដោយការពិពណ៌នាពីស្ថានភាពគ្រួសារមួយ គឺគ្រួសាររបស់តួអង្គសម រួចចូលដំណើររឿងតែម្តង ។

**ឧ**: "ត្រកូលរបស់សួន សម ជាកសិករសាមញ្ញ ។ បុព្វបុរសរបស់សួន សម.....‶ ។

**៣. ដំណើររឿង** : នៅក្នុងដំណើររឿងនេះ អ្នកនិពន្ធប្រើវិធីតែងសំខាន់ៗជាច្រើនដូចជា៖

**+ វចនវិធី :** អ្នកនិពន្ធ ប្រើពាក្យសាមញ្ញលាយចម្រុះជាមួយពាក្យកម្ចីពីបាលីសំស្ក្រឹត ពាក្យសង្ឃសព្ទ ពាក្យរាជសព្ទ និងពាក្យកម្ចីពីបរទេស៖

❖ **ឧ:** – ពាក្យសាមញ្ញ: អ្នក, ស្រែ, កសិករ, ឪពុក...មាន់ស មាន់ខ្មៅនិយាយពី

– ពាក្យកម្ចីពីបាលីសំស្ក្រឹត: សាមញ្ញ, ឥស្សរ, បុព្វបុរស, បុណ្យ, កម្ពុជរដ្ឋ...

– ពាក្យសង្ឃសព្ទ : ភិក្ខុ និមន្ត...

– ពាក្យរាជសព្ទ: ព្រះរាជបំណាង, ព្រះករុណា, សម្ដេចព្រះឧបយុវរាជ...

– ពាក្យកម្ចីពីបរទេស : ស៊ីក្លូ, សូវៀត, ហិម៉ាឡាយ៉ា, ម៉ាស៊ីន...

**+ សំវាទវិធី :** តួអង្គសមនិយាយជាមួយនាងសយថា៖

**ឧ:** – សម : "មើលទៅថ្ងៃនេះ... បើបងរកប្រាក់មិនបាន ៦០រៀលទេ..."

– សយ : "...ផ្សងព្រេងទៅចុះបង ក្រែងលោថ្ងៃនេះហោងគ្រាន់បើបន្តិច" ។

**+ ឯកវាទវិធី :** តួអង្គសមនិយាយតែម្នាក់ឯង ។

**ឧ:** – ពេលអ្នកស្រី គឹម លៀង ដកហូតយកស៊ីក្លូវិញ សមបាននិយាយតែម្នាក់ឯងថា "ឱព្រះជាម្ចាស់អើយ! ព្រះអង្គគ្មានអាណិតអាសូរអ្នកក្រផងសោះ..." ។

**+ រចនាវិធី :** អ្នកនិពន្ធតាក់តែងរឿងនេះតាមរចនាបថប្រលោមលោកពាក្យរាយ ។

**ឧ:** – នាកណ្ដាលវស្សាន្តរដូវ ភ្លៀងធ្លាក់ចុះជោគជាំផែនដី... ។

**+ ពណ៌នាវិធី :** អ្នកនិពន្ធបានពិពណ៌នាពីតួអង្គសមថា ៖

**ឧ:** – "សមនៅសល់តែខោអាវមួយបន្លាស់ប៉ុណ្ណោះ ។ សមបានចូលទៅសុំសំណាក់អាស្រ័យជាមួយនឹងភិក្ខុមួយអង្គ..." ។

**+ វឌ្ឍមានវិធី :** ដំណើររឿងមានការវិវត្តតឹងតែងឡើងៗតាំងពីសមធាក់ស៊ីក្លូរស់នៅជាមួយនាងសយ នាងសយត្រូវថៅកែហុករំលោភ ទីបំផុតនាងសយស្លាប់នៅពេលឆ្លងទន្លេ... ។

**+ សន្ទេហវិធី :** អ្នកនិពន្ធធ្វើឱ្យអ្នកអាន អ្នកសិក្សាមានចម្ងល់ថា៖ តើសមយកទ្រព្យសម្បត្តិដែលឆក់បានទៅសងលោកឧកញ៉ាសំបូរ សម្បត្តិ វិញបែបនេះ សមរួចខ្លួនឬទេ?

**៤. បញ្ចប់រឿង** : អ្នកនិពន្ធបានបញ្ចប់រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដោយធ្វើឱ្យប្រជារាស្ត្រខ្មែរមានក្ដីសង្ឃឹម និងមានសុទិដ្ឋិនិយមក្នុងការរស់នៅក្រោមព្រះរាជកិច្ចដឹកនាំនៃព្រះ

ឧបយុវរាជ គឺសម្តេចនរោត្តមសីហនុ ដែលជាព្រះបិតាឯករាជ្យជាតិ ព្រះបិតាកសិកម្មជាតិ ព្រះបិតាហត្ថកម្មជាតិ
និងជាព្រះអគ្គមគ្គុទេសក៍ដ៏ឆ្នើមប្រកបដោយព្រះបញ្ញាញាណក្នុងរបបសង្គមរាស្ត្រនិយម។

**ឃ- អត្ថរស** : ឆ្លងតាមការសិក្សាអត្ថន័យ និងអត្ថរូបរបស់រឿងព្រះអាទិត្យថ្មីរះលើផែនដី ចាស់ យើងអាចដកហូតចេញនូវអត្ថរសសំខាន់ៗដូចតទៅ៖

**+ តថរស :** តម្លៃដែលលេចធ្លោជាងគេ គឺដំណើររឿងឆ្លុះបញ្ចាំងពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនខ្មែរដែលជួបប្រទះនឹងជីវភាពក្រីក្រដែលត្រូវពួកនាយទុន អ្នកកាន់អំណាចក្នុងសម័យអាណានិគមនិយមបារាំងកេងប្រវ័ញ្ច និងធ្វើបាបយ៉ាងសាហាវឃោរឃៅជាទីបំផុត។ សាច់រឿងក៏បានបង្ហាញពីភាពរីកចម្រើននៃរបបសង្គមរាស្ត្រនិយមដែលដឹកនាំដោយសម្តេចឪនរោត្តមសីហនុ ដែលជាក្តីសង្ឃឹមរបស់ប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់។

**+ សង្គមរស :** រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ប្រព្រឹត្តទៅនៅចុងសង្គមខ្មែរដែលគ្រប់គ្រងដោយរបបអាណានិគមនិយមបារាំង និងដើមរបបសង្គមរាស្ត្រនិយម។ ចន្លោះពេលនោះ (សម័យអន្តរកាល) ត្រូវពួកនាយទុន មន្ត្រីរាជការមួយចំនួនឆ្លៀតកេងចំណេញធ្វើមានបាន ពោលគឺធ្វើស្រែលើខ្នងប្រជារាស្ត្រក្រីក្រ។

**+ សច្ចរស :** ដំណើររឿងប្រព្រឹត្តនៅទីកន្លែងពិតប្រាកដមួយដែលយើងធ្លាប់ស្គាល់ គឺទួលប្រស្រី វត្តភ្នំ ផ្សារចាស់ ភ្នំពេញ បាត់ដំបង ស្រុកបវេល វត្តមហាមន្ត្រី... ។

**+ ទារុណរស :** អ្នកនិពន្ធបានបង្ហាញការរងទុក្ខសោករបស់សម និងការធ្វើទារុណកម្មរបស់អង្គរក្សលោកឧកញ៉ា សំបូរ សម្បត្តិ ។

**ឧ-** "...សមឈឺចាប់គ្រាំគ្រាពេញរាងកាយ... រង្វង់មុខរបស់សមហើមពោរឡើង ចិញ្ចើមនិងបបូរមាត់បែកឈាម..." ។

**+ ប្រលោមរស :** រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ជាប្រលោមលោកបែបមនោសញ្ចេតនា រំភើប កម្សត់ អណ្តែតអណ្តូង សប្បាយ ទុក្ខព្រួយ ជាមួយនិងតួអង្គ ។

**+ កុសលរស :** រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ បានបង្ហាញតម្លៃជាកុសលជាច្រើន គឺអប់រំមនុស្សឱ្យប្រព្រឹត្តអំពើល្អ អំពើសុចរិត ចេះតស៊ូក្នុងឆាកជីវិត ចេះជួយអាសារគ្នាក្នុងគ្រាអាសន្នអន់ក្រ និងមិនត្រូវវាយតម្លៃមនុស្សតាមសំបកក្រៅឡើយ។

## ខ- បញ្ហាសង្គម

### ១. នយោបាយ

**+ នយោបាយក្នុងប្រទេស** : ដំណើររឿងបានបង្ហាញពីការគ្រប់គ្រងប្រទេសចុងសម័យអាណានិគមនិយមបារាំង និងការគ្រប់គ្រងប្រទេសដោយរបបសង្គមរាស្ត្រនិយមដែលមានអង្គសម្ដេចឪនរោត្តមសីហនុ ជាព្រះអគ្គមគ្គុទេសក៍ដំផ្ទើម។

+ **ក្រៅប្រទេស** : ប្រទេសកម្ពុជាមានទំនាក់ទំនងការទូតជាមួយប្រទេសបារាំង សូវៀត និងអាមេរិក ព្រមទាំងមានការបញ្ជូននិស្សិតទៅសិក្សានៅប្រទេសបារាំងផងដែរ "...ជារដ្ឋមន្ត្រីនៃក្រសួងមួយដែលលោកទើបនិងត្រឡប់មកពីប្រទេសបារាំង កាលពីឆ្នាំទៅ..." ។

### ២. សេដ្ឋកិច្ច

**+ កសិកម្ម** : កសិកម្មនាសម័យសង្គមរាស្ត្រនិយម មានការរីកចម្រើនដល់កម្រិតកំពូល ប្រជារាស្ត្រធ្វើស្រែតាមប្រព័ន្ធធារាសាស្ត្រ និងនយោបាយទឹករបស់អង្គសម្ដេចឪ ហើយក្រសួងកសិកម្មបានផ្ដល់ភ្នាក់ងារកសិកម្មជួយហ្វឹកហាត់គ្រប់ផ្នែក។

**ឧ-** "សមនឹកពេញចិត្តចំពោះនយោបាយទឹក គឺហាត្ថកម្មលើកទំនប់រកអ្វីប្រៀបគ្មាន ស្រែសមបានចម្រើន ស្រែកសិករឯទៀតក៏បានចម្រើន..." ។

+ **សិប្បកម្ម** : មានសិប្បកម្មផលិតស៊ីក្លូ និងសិប្បកម្មផលិតសាប៊ូ ។

+ **ឧស្សាហកម្ម** : មានរោងចក្រឧស្សាហកម្មធំៗសម្រាប់ផលិតសម្ភារៈប្រើប្រាស់មាន ដូចជា រោងចក្រធ្វើក្រដាស រោងចក្រវាយនភណ្ឌ និងរោងវារីចក្រជាដើម ។

**ឧ-** "ការស្ថាបនារោងចក្រធ្វើក្រដាស..." ។

+ **គមនាគមន៍** : ប្រព័ន្ធគមនាគមន៍ទាំងបីគឺ ផ្លូវដែក ផ្លូវដី ផ្លូវអាកាស មានការរីកចម្រើនយ៉ាងខ្លាំងក្លា ព្រមទាំងមានស្ថាបនាស្ពានថ្មីៗ ។

**ឧ-** "សម្ពោធមហាថ្នល់មិត្តភាពខ្មែរ-អាមេរិកកាំង..." ។

+ **ពាណិជ្ជកម្ម** : មានហាងជំនួញ និងអាគារពាណិជ្ជកម្មខ្ពស់ៗ ។

**ឧ-** "...មានក្លិនអាសោចនោះ ឥឡូវបានក្លាយទៅជាសង្កាត់ជំនួញ ដែលមានគ្រឹះស្ថានធំៗខ្ពស់ៗដែរ..." ។

+ **ទេសចរណ៍** : ពុំមានអ្វីគួរឱ្យកត់សម្គាល់ តែគ្រាន់តែដឹងបានថា ប្រជារាស្ត្រក្នុង

រាជធានីភ្នំពេញបានទៅកម្សាន្តស្រូបយកខ្យល់អាកាសនៅវត្តភ្នំ ។

ឧ- "វត្តភ្នំកាលដើមឡើយ... ឥឡូវបានប្រែក្លាយទៅជាកន្លែងសម្រាប់ប្រជាជនដកដង្ហើមយកខ្យល់អាកាសដ៏ល្អបរិសុទ្ធ..." ។

+ **ហិរញ្ញវត្ថុ** : មានការប្រើប្រាស់រូបិយបណ្ណប្រាក់រៀលសម្រាប់ដោះដូរ និងទូទាត់ជាមួយទំនិញ ឬ ផលិតផល ។

ឧ- " សមទាញក្រដាសប្រាក់មួយដុំមកមើល... គឺជាលិខិតសន្យាក្នុងការខ្ចីប្រាក់ ២ម៉ឺនរៀល..." ។

**៣. សង្គមកិច្ច**

+ **ស្ថានភាពរស់នៅ** : ចុងសម័យអាណានិគមនិយមបារាំងប្រជារាស្ត្ររស់ក្នុងជីវភាពក្រលំបាកតោកយ៉ាក លុះមកដល់សម័យសង្គមរាស្ត្រនិយម ប្រជារាស្ត្ររស់ដោយសេចក្ដីថ្លៃថ្នូរ។

ឧ- " អ្នកស្រុកសមកាលពីដើមមានសភាពដុនដាបនោះ ឥឡូវក៏បានប្រែក្លាយទៅជាមានជីវភាពធូរធារជាងមុនច្រើន... " ។

+ **សុខាភិបាល** : សម័យអាណានិគមនិយមបារាំងវិស័យសុខាភិបាលនៅមានកម្រិត ទាបគ្រូពេទ្យត្រូវការតែលុយជាក់ស្ដែងគ្រូពេទ្យនរា លុះមកដល់សម័យសង្គមរាស្ត្រនិយមសុខាភិបាលមានការរីកចម្រើន មានការសាងសង់មន្ទីរពេទ្យជាច្រើនដូចជា មន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ព្រមទាំងបានបង្កើតសាលាពេទ្យថែមទៀត ។

ឧ- " ...ឥឡូវបានប្រែរូបទៅជាសាលាភូមិន្ទវិជ្ជាពេទ្យ... " ។

+ **សន្តិសុខសង្គម** : ប្រទេសទទួលបានឯករាជ្យពេញលេញ ហើយក្រោមការដឹកនាំបែបសង្គមរាស្ត្រនិយមបានធ្វើឱ្យប្រទេសមានសន្តិភាព មានសន្តិសុខសណ្ដាប់ធ្នាប់ល្អ ប្រជារាស្ត្រមានការធានាលើសិទ្ធិសេរីភាពសព្វបែបយ៉ាង ។

ឧ- " សមបានចូលរួមសមាជជាតិលើកទី៩... " ។

**៤. វប្បធម៌**

+ **ជំនឿ** : ប្រជាជនខ្មែរជឿលើកម្មផល និងជឿលើបុណ្យបាប ។

ឧ- សាន ពោលថា " ...នេះជាកម្មរបស់ប្រពន្ធសម ឯងទេសម ឯងកុំទុក្ខសោកអីខ្លាំងពេក... " ។

+ **ប្រពៃណីទំនៀមទម្លាប់** : ប្រជាជនខ្មែរមានប្រពៃណីបូជាសព ។

ឧ- យាយប៉ោងនិយាយ " ...យើងគិតគូរពីរឿងបូជាសពនាងសយ ទៅចុះ... " ។

**+ សាសនា** : ប្រជាជនខ្មែរគោរពបូជាចំពោះព្រះពុទ្ធសាសនា ហើយទីវត្តអារាមជាទីជួយសង្គ្រោះជនក្រីក្រទុរគត ជាក់ស្តែងសមបានស្នាក់នៅវត្តមហាមន្ត្រីជាមួយភិក្ខុសៅ។

**ឧ-** " ភិក្ខុសៅ បានជួយជ្រោមជ្រែងយកសម ទៅផ្ញើឱ្យធ្វើជាកម្មករលីសែង..." ។

**+ ការសិក្សាអប់រំ** : ការសិក្សាអប់រំមានការរីកចម្រើន ព្រោះប្រជាជនខ្មែរត្រូវបានទទួលការសិក្សាអប់រំតាំងពីថ្នាក់បឋម រហូតដល់មហាវិទ្យាល័យ ។

**ឧ-** "សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ មហាវិទ្យាល័យផុសឡើងជាច្រើន... "។

**+ សិល្បៈ** : មានការបញ្ចាំងភាពយន្តនៅតាមរោងភាពយន្តនានា ពិសេសវិស័យភាពយន្តមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

**ឧ-** " ...រោងភាពយន្តក៏កាន់តែមានចំនួនច្រើនឡើង..." ។

IV-**ការសន្និដ្ឋាន**

រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ជាស្នាដៃអក្សរសិល្ប៍ទំនើបមួយមិនចាញ់ស្នាដៃអក្សរសិល្ប៍ទំនើបនានារបស់បស្ចិមប្រទេសឡើយ។ ជាងនេះទៅទៀត រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ជាស្នាដៃមួយមានតម្លៃបំផុតនៅក្នុងខឿនអក្សរសាស្ត្រជាតិខ្មែរយើង ព្រោះរឿងនេះល្អទាំងផ្នែកអត្ថន័យ អត្ថរូប និងអត្ថរស ពោលគឺមានលក្ខណៈស៊ីសង្វាក់គ្នា។ អ្នកនិពន្ធរឿងនេះមានទឹកដៃខ្ពស់ក្នុងការតាក់តែង ចេះប្រើរូបារម្មណ៍ ចេះអន្ទងចិត្តអ្នកអាន អ្នកសិក្សាឱ្យមានជំនក់អារម្មណ៍តាមដាន និងសិក្សាអត្ថន័យរបស់រឿង ហើយអ្នកសិក្សាក៏អាចទទួលបាននូវពុទ្ធិថ្មីៗសម្រាប់យកទៅអនុវត្តក្នុងជីវភាពសង្គមផងដែរ ។

# ឯកសារពិគ្រោះ

១. សេចក្តីណែនាំលេខ ០៣ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៦ របស់ក្រសួងអប់រំយុវជន និងកីឡា ស្តីពីការបង្រៀនអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ដល់ថ្នាក់ទី១២

២. រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ របស់លោក សួន សុរិន្ទ ឆ្នាំ ១៩៦១

៣. វចនានុក្រមសម្តេច ជួន ណាត ពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧

៤. សិក្សាអត្ថបទរបស់លោក លាង ហាប់អាន ភាគ ១-២ ភ្នំពេញ១៩៦៦

៥. អក្សរសិល្ប៍ខ្មែរសតវត្សទី២០ របស់លោក ឃីង ហុកឌី ភ្នំពេញ២០០៧

៦. ការស្រាវជ្រាវពីជីវប្រវត្តិអ្នកនិពន្ធខ្មែរ អូសរ៉ូណេអូ របស់សាលាគរុវិជ្ជាជាន់ខ្ពស់ ឆ្នាំ១៩៨៦

៧.ប្រវត្តិវិទ្យា ថ្នាក់ទី១២ អ.យ.ក ឆ្នាំ២០១៧

៨.ប្រវត្តិវិទ្យាសម្រាប់បឋមសិក្សាក្រសួងអប់រំ ឆ្នាំ១៩៨៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង មហាវេស្សន្តរជាតក

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..........................អយក.**

## ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងមហាវេស្សន្តរជាតក»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១ -** អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍ « រឿងមហាវេស្សន្តរជាតក » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀននៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ -** អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ [illegible] ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានថែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ«**សិក្សាអត្ថបទអក្សរសិល្ប៍**» ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ«**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង មហាវេស្សន្តរជាតក**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក យិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ តាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ
ប្រកាស ..........................................................................................................i
បុព្វកថា ..........................................................................................................ii
គណៈកម្មការ.....................................................................................................iii
អារម្ភកថា.........................................................................................................iv
មាតិកា..............................................................................................................v
សេចក្តីផ្តើម.........................................................................................................
I. ការបង្ហាញអត្ថបទ............................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង....................................................................................
III. ទិដ្ឋភាពទំនាស់..............................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ.........................................................................................
V. ទិដ្ឋភាពសង្គម..................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ...........................................................................................
VII. ទិដ្ឋភាពតម្លៃ..................................................................................................
VIII. ការសន្និដ្ឋាន................................................................................................
IX. ឯកសារពិគ្រោះ...............................................................................................

# សិក្សាអត្ថបទអក្សរសិល្ប៍
# រឿង មហាវេស្សន្តរជាតក

## ៣សេចក្តីផ្តើម

រឿងព្រះវេស្សន្តរ ជាចលនាអក្សរសិល្ប៍ពុទ្ធនិយម ដែលមានលក្ខណៈប្រជាប្រិយភាពជាងរឿងជាតកនានា។ រឿងនេះបានរៀបរាប់ពីការកសាងបារមី ជាពិសេសការកសាងទានបារមីរបស់ព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គយកកំណើតជាព្រះពោធិសត្វ ហើយមានព្រះនាមថា ព្រះវេស្សន្តរ។

មួយវិញទៀតរឿងព្រះវេស្សន្តរគឺជារឿងបែបសាសនា ព្រោះតាមការស្រាវជ្រាវពីប្រភពនៃស្នាដៃ គេបានដឹងថា រឿងនេះជាស្នាដៃរបស់អ្នកប្រាជ្ញដ៏ធំមួយរូប នៅប្រទេសឥណ្ឌាបុរាណដែលបាននិពន្ធឡើងតាមព្រះពុទ្ធដីកាមាននៅក្នុងព្រះត្រៃបិតក។ ប៉ុន្តែអត្ថបទដែលយើងលើកយកមកសិក្សានៅពេលនេះ គឺស្នាដៃរបស់អ្នកនិពន្ធខ្មែរ ដែលបានបកប្រែជាភាសាជាតិយើង ប្រកបដោយពាក្យពេចន៍ ជាកម្រងកែវដោយបញ្ចូលនូវគោលគំនិត ទ្រឹស្តីពិសេសគឺជំនឿរបស់ពុទ្ធសាសនិកជនខ្មែរតាមបែបបទខ្មែរនិយមទៀតផង។ ដូចនេះ ទោះបីជារឿងនេះបែបសាសនា ក៏វាមិនដាច់ស្រឡះពីបញ្ហាខ្មែរឡើយ។

ការសិក្សារបស់យើងនៅពេលនេះ មិនបានទាត់ចោលគោលការណ៍ សម័យកាលរបស់ស្នាដៃឡើយ តែដោយបច្ចុប្បន្ននេះយើងមិនអាចដោះស្រាយបញ្ហាសង្គម តាមទស្សនៈបុរាណទាំងស្រុងបាន ទើបយើងផ្តើមចេញពីការស្វែងយល់ទស្សនៈសាសនា ដែលនៅមានឥទ្ធិពលយ៉ាងខ្លាំងនៅឡើយក្នុងទស្សនៈប្រជាជន ហើយធ្វើការរិះគន់ចំណុចអសកម្មខ្លះៗ រួចបណ្តុះទស្សនៈថ្មីជឿនលឿនដល់សិស្សានុសិស្ស និងអ្នកសិក្សា។

សង្ឃឹមថា ប្អូនៗនិងអ្នកស្រាវជ្រាវប្រាកដជានឹងក្តាប់បានរាល់មូលដ្ឋាន ទស្សនៈប្លែកៗទាំងឡាយ ហើយផ្សារភ្ជាប់ការសិក្សានេះទៅក្នុងជីវភាពជាក់ស្តែង ប្រកបដោយជោគជ័យ។

## I- ការបង្ហាញអត្ថបទ

### ១- អត្ថបទ

**១.១- ចំណងជើង** : មហាវេស្សន្តរជាតក

**១.២- ប្រភព** : ដកស្រង់ចេញពីមហាវេស្សន្តរជាតក ដែលបានបោះពុម្ពផ្សាយជាច្រើនលើកដោយពុទ្ធសាសន បណ្ឌិត្យព.ស.២៥០៩ គ.ស.១៩៦៦[1]និងមានមួយក្បាលមួយកណ្ឌចំនួន១៣ក្បាល និងមួយក្បាល១៣កណ្ឌ គ.ស១៩៦១។

[1] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ ទី១ កណ្ឌទសពរ ប្រដាប់ដោយគាថា១៩ បោះពុម្ពផ្សាយឡើងវិញលើកទី២ ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០

រឿងនេះស្ថិតក្នុងគម្ពីរទសជាតកនៃគម្ពីរព្រះត្រៃបិតកក្នុងព្រះពុទ្ធសាសនាមានដូចតទៅ ៖

១- វិន័យបិតក (ព្រះវិន័យ) រួមមាន ២១០០០ ធម្មក្ខន្ធ

២- សុត្តន្តបិតក (ព្រះសូត្រ) រួមមាន ២១០០០ធម្មក្ខន្ធ

៣- អភិធម្មបិតក (ព្រះអភិធម្ម) រួមមាន ៤២០០០ធម្មក្ខន្ធ

ក្នុងសុត្តន្តបិតកចែកចេញជា៥និកាយទៀតៈ

- ទីឃនិកាយ (ធម៌មានសេចក្តីវែងពិស្តារ)
- មជ្ឈិមនិកាយ (ធម៌មានសេចក្តីមធ្យម)
- សំយុត្តនិកា (ធម៌មានសេចក្តីប្រហែលគ្នា)
- អង្គុត្តរនិកាយ (ធម៌មានសេចក្តីជាក្រុមជាពួក)
- ខុទ្ទកនិកាយ (ធម៌មានសេចក្តីខ្លីៗ)

ក្នុងខុទ្ទកនិកាយចែកចេញជានិបាតជាច្រើនទៀត ហើយក្នុងនោះមានគម្ពីរមួយឈ្មោះ **«មហានិបាតជាតក»**ដែលបែងចែកជាច្រើនគម្ពីរទៀត ដែលក្នុងនោះមានគម្ពីរ **«ទសជាតក»** ដែលបានសម្តែងពីការបំពេញបារមីទាំង១០ជាតិរបស់ព្រះពោធិសត្វមុនពេលត្រាស់ដឹងជាព្រះពុទ្ធ។ ដោយរឿងទាំង១០របស់ព្រះពុទ្ធនោះមានដូចជា ៖

- **តេមិយជាតក** និយាយពីការបំពេញនេក្ខម្មបារមី គឺការចេញបួសរបស់ពោធិសត្វ
- **ជនកជាតក** និយាយពីការបំពេញវិរិយបារមី គឺសេចក្តីព្យាយាមដ៏មុតមាំ
- **សុវណ្ណសាមជាតក** និយាយពីការបំពេញមេត្តាបារមី គឺការកាន់ចិត្ត មេត្តា ករុណា ចំពោះមនុស្ស សត្វ
- **នេមិរាជជាតក** និយាយពីការបំពេញបញ្ញាបារមី គឺការតាំងចិត្តមាំក្នុងសីល
- **មហោសថជាតក** និយាយពីការបំពេញបញ្ញាបារមីគឺអ្នកមានបញ្ញាដ៏លើសលប់
- **ភូរិទត្តជាតក** និយាយពីការបំពេញសីលបារមី
- **ចន្ទកុមារជាតក** និយាយពីការបំពេញខន្តីបារមី គឺការកាន់ចិត្តអត់ធ្មត់
- **នារទជាតក** និយាយពីការបំពេញឧបេក្ខាបារមី គឺការកាន់ចិត្តជាកណ្តាល
- **បរិធូរជាតក** និយាយពីការបំពេញ**សច្ចបារមី** គឺការកាន់ពាក្យទៀងត្រង់
- **មហាវេស្សន្តរជាតក** និយាយពីការបំពេញ**ទានបារមី** គឺការចំណាយធនធានឱ្យទៅជាទានអ្នកដទៃ

**១.៣- ប្រភេទ** : ស្នាដៃអក្សរសិល្ប៍បុរាណខ្មែរ ដែលមាននិន្នាការនិងបម្រើឱ្យព្រះពុទ្ធសនាព្រះពុទ្ធឬពុទ្ធលិទ្ធិ។

**១.៤- ចលនា** : រឿងនេះស្ថិតក្នុងចលនាអក្សរសិល្ប៍ពុទ្ធនិយម ព្រោះការផ្តើមរឿង

ដោយបទនមស្ការរំឭកគុណព្រះរតនត្រៃ។ តួអង្គឯកបុរសគឺ «ព្រះពោធិសត្វ»ជាគូព្រេងនឹងគ្នាគ្រប់ជាតិ។ រីឯតួឯកស្រីគឺ«កន្សែស្រារពេជ្វ» លក្ខណៈពិសេសមួយទៀត រឿងនេះបានបង្ហាញពីការសរជាតិនៃតួអង្គទាំងឡាយទៀតផង។

### ២- អ្នករៀបរៀង

#### ២.១- ឈ្មោះអ្នករៀបរៀង

មហាវេស្សន្តរជាតកគឺរឿងមានប្រជាប្រិយភាពមួយដែលខ្មែរយើងបានទទួលឥទ្ធិពលពីប្រទេសឥណ្ឌាតាមរយៈការផ្សព្វផ្សាយពុទ្ធសាសនាចូលមកដែនដីសុវណ្ណភូមិ «អាស៊ីអាគ្នេយ៍» យើងនេះ។ ស្នាដៃខាងលើត្រូវបានប្រជារាស្ត្រខ្មែរ សម្រិតសម្រាំងផ្សព្វផ្សាយនិងកែច្នៃឱ្យកាន់តែពីរោះនៅលើសាស្ត្រាស្លឹករឹត ទៅតាមសម័យកាលជាបន្តបន្ទាប់តាំងពីបុរាណរៀងមកនៅគ្រប់ទិសទីនៃវត្តអារាមទូទាំងកម្ពុជរដ្ឋ។

ក្រោយមកលោក ញ៉ុក ថែម បានសម្រួលគម្ពីរសាស្ត្រាបុរាណ រួចរៀបរៀងចងក្រងជាសៀវភៅមួយឈ្មោះ**«មហាវេស្សន្តរជាតក»** បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យលើកទី២ នាឆ្នាំ១៩៥៣ និងបោះពុម្ពគ្រាទី៣-៤-៥-៦ ជាបន្តបន្ទាប់មកទៀត។ ចំណែកសៀវភៅដែលត្រូវលើកយកមកសិក្សាជាផ្លូវការទូទាំងប្រទេសកម្ពុជាតាំងពីមុនឆ្នាំ១៩៧៥ មកនោះ គឺ **«មហាវេស្សន្តរជាតក»**ដែលបានរៀបរៀងឡើងដោយលោកញ៉ុកថែម។ លោកបានប្រមូលឯកសារជាសាស្ត្រាស្លឹករឹតនៅគ្រប់ខេត្តខណ្ឌក្នុងប្រទេសកម្ពុជាយើងយកមកផ្ទៀងផ្ទាត់រៀបរៀងសម្រាយឃ្លាប្រយោគឱ្យស្រួលស្តាប់ទៅតាមភាសាសម័យថ្មី**«អក្សរសម័យថ្មី សេចក្តីសម័យចាស់»**ឡើងវិញ។

លោកញ៉ុក ថែមបានរៀបរៀង មហាវេស្សន្តរជាតកនេះជាពាក្យសម្រាយពីបាលីមកជាភាសាខ្មែរបែបកម្រងកែវ ងាយយល់ទៅតាមភាសាសម័យថ្មី ដោយកាត់ពាក្យបាលីវែងៗចោលទុកសល់នៅតែពាក្យបាលីខ្លីៗ ជាគាថាខាងដើមប៉ុណ្ណោះ។ ក្នុងការរៀបរៀងនេះលោករក្សាទុកតាមច្បាប់ដើមស្ទើរទាំងអស់ប៉ុន្តែក៏នៅមានច្បាប់ដើមខ្លះដែលរំលងបាត់ទៅដោយអ្នកចារចម្លងមកទើបលោករៀបរៀងជាថ្មីបំពេញសេចក្តីត្រង់ដែលបាត់នោះ។ឯតួគាថាបាលីដែលរំលងបាត់ទៅក៏លោកស្រង់យកមកដាក់បំពេញដែរ។

ដូចនេះលោក ញ៉ុក ថែម គឺជាអ្នករៀបរៀងចងក្រងសម្រួលច្បាប់ដើម ពីបុរាណចុងក្រោយបង្អស់នៃស្នាដៃ«មហាវេស្សន្តរជាតក»នេះដែលមជ្ឈដ្ឋានអ្នកសិក្សាអក្សរសិល្ប៍ខ្មែរបានទទួលស្គាល់។ លោកញ៉ុក ថែម ជាអតីតសាស្ត្រាចារ្យ នៅមហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រផ្នែកភាសាបាលី។

#### ២.២ - ជីវប្រវត្តិ

លោក ញ៉ុក ថែម កើតនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩០៣ នៅឃុំស្វាយប៉ោ ស្រុកសង្កែ

ខេត្តបាត់ដំបង។ បិតាលោកឈ្មោះ ញ៉ុំ រីឯមាតាឈ្មោះ ហៀក ជាជាតិខ្មែរ ជាកសិករ រស់នៅភូមិអូតាគី ឃុំជ្រៃស្រុក ខេត្តបាត់ដំបង។ កាលពីកុមារភាព គឺក្នុងឆ្នាំ១៩១៣លោកបានទៅរៀននៅវត្តពោធិ៍វាល ស្រុកសង្កែ ខេត្តបាត់ដំបង។ លោកបានសិក្សាអក្សរជាតិ ក្នុងសំណាក់លោកគ្រូអាចារ្យសន និងបានសិក្សាធម៌វិន័យក្នុងសំណាក់លោកគ្រូសូត្រ អ៊ីវ ទូច នៅវត្តពោធិវាល។ នៅឆ្នាំ ១៩១៨ លោកមានបព្វជ្ជាសាមណេរ។ ក្នុងឋានៈជាសាមណេរនេះ លោកបានសិក្សាធម៌វិន័យនិងភាសាបាលីក្នុងសំណាក់លោកគ្រូអាចារ្យផ្សេងៗ ក្នុងខេត្តបាត់ដំបង។ លោកបានទៅសិក្សានៅបរទេសដែរ គឺក្នុងឆ្នាំ១៩១៩ លោកបានបន្តវិជ្ជានៅបាងកក ប្រទេសថៃ។ លោកបានជាប់សញ្ញាបត្រធម្មសិក្សាជាន់ត្រី នៅអំឡុងឆ្នាំ១៩២១ និងជាប់សញ្ញាប័ត្រធម្មសិក្សាជាន់ទោ ក្នុងឆ្នាំ១៩២៣។ នៅឆ្នាំ១៩២៤ លោកបានឧបសម្ប័ទជាភិក្ខុ ហើយនៅក្នុងឆ្នាំដដែលនេះលោកបានជាប់សញ្ញាបត្របរិយត្តិភាសាបាលី ទីមហា៣ប្រយោគ។ ពីរឆ្នាំក្រោយមក គឺឆ្នាំ១៩២៦លោកបានជាប់ទីមហា៤ប្រយោគ ២ឆ្នាំតមកទៀត(១៩២៨)ជាប់ទីមហា៥ប្រយោគ និងជាទីបញ្ចប់លោកបានជាប់ទីមហា៦ប្រយោគនៅក្នុងឆ្នាំ១៩២៩។ លោកបានលាចាកសិក្ខាបទមកជាគ្រហស្ថ នៅឆ្នាំ១៩៣៦។

ពេលលោកទៅសិក្សានៅប្រទេសថៃ លោកក៏បានធ្វើការនៅទីនោះដែរ។ លោកធ្វើជាគ្រូបង្រៀនភាសាបាលីនៅទីក្រុងបាងកក ចាប់ពីគ.ស.១៩២៧ ទៅទល់នឹងគ.ស.១៩៣០ ទើបត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញដោយចូលធ្វើជាសមាជិកគណៈកម្មាការប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ។ នៅឆ្នាំ១៩៣៨លោកធ្វើការ នៅក្នុងព្រះរាជបណ្ណាល័យកម្ពុជាមានមុខងារជាអ្នកចាត់ចែងបោះពុម្ពផ្សាយនូវសៀវភៅផ្សេងៗ និងទស្សនាវដ្តីកម្ពុជសុរិយា។ នៅឆ្នាំបន្ទាប់មក(១៩៣៩) លោកបានធ្វើជាតំណាងសម្តេចព្រះនរោត្តមសុធារស និងជាអធិបតីពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ជាមួយតំណាងផ្សេងៗទៀត បានទៅរៀបចំកម្មវិធីសិក្សានិងពិធីសម្ពោធពុទ្ធសាសនបណ្ឌិត្យនៅក្រុងហ្លួងព្រះបាងនិងក្រុងវៀងច័ន្ទនាប្រទេសលាវ។ឆ្នាំ១៩៤២ លោកបានទៅសម្ពោធមន្ទីរសាសនបណ្ឌិត្យ ខេត្តឃ្លាំងប្រទេសវៀតណាមភាគខាងត្បូងនិងឆ្នាំ១៩៤៣ លោកជាតំណាងរៀបចំកម្មវិធីសិក្សាសម្រាប់ពុទ្ធសាសនបណ្ឌិត្យនៅប៉ាក់សេប្រទេសលាវ។

លោកញ៉ុក ថែម បានធ្វើជាសាស្ត្រាចារ្យខ្មែរនៅថ្នាក់ទី៥នៃសាលាគរុវិជ្ជានៅឆ្នាំ១៩៤៥ ហើយនៅឆ្នាំ១៩៤៦ លោកធ្វើការនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងជាសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិទៀតផង។ តែក្នុងឆ្នាំ១៩៥០ លោកលាឈប់ពីសាសនបណ្ឌិត្យ ចូលមកបម្រើតែក្រសួងសិក្សាធិការជាតិ ក្រោយពេលដែលបារាំងផ្ទេរវិទ្យាល័យស៊ីសុវត្ថិ មកជាសម្បត្តិជាតិ ហើយលោកធ្វើជាសាស្ត្រាចារ្យ ជាប់សន្សារហូតមក។ ប្រាំមួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៥៦ លោកសុំផ្លាស់ទៅធ្វើជាសាស្ត្រាចារ្យខ្មែរ នៅវិទ្យាល័យមុនីវង្សនាក្រុងបាត់ដំបង។ តែ

ក្នុងឆ្នាំ១៩៥៨ លោកបានផ្លាស់ទៅធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យនាក្រុងភ្នំពេញវិញក្នុងឋានៈជាសាស្ត្រាចារ្យផង និងអ្នកស្រាវជ្រាវឯកសារអក្សរសាស្ត្រខ្មែរ នៅវិទ្យាស្ថាននោះផង។ លោកជាសាស្ត្រាចារ្យខ្មែរ នៅសាលាភូមិន្ទរដ្ឋបាល។

**២.៣- ស្នាដៃសំខាន់ៗ**

លោកញ៉ុក ថែម មានស្នាជាច្រើន ៖

- មោកថា
- នានាជាតក
- វណ្ណនា
- ធម្មនិទ្ទេសភាគ១
- ទេវតាភាសិត
- ពុទ្ធភាសិត

លោកបានបន្សល់ស្នាដៃផ្នែកពុទ្ធសាសនា និងស្នាដៃប្រលោមលោកជាច្រើន ដូចជា៖

- ពុទ្ធប្បវត្តិសង្ខេប
- អនុពុទ្ធប្បវត្តិ ភាគ១-២
- ប្រជុំភាសិត ភាគ១-២
- មហាវេស្សន្តរជាតក
- ប្រជុំពុទ្ធភាសិត
- ជាតិសាសនាព្រះមហាក្សត្រ
- រឿងបិសាចស្នេហា (ប្រលោមលោកបោះពុម្ពឆ្នាំ១៩៤២) រឿងកុលាបប៉ៃលិន (ប្រលោមលោកបោះពុម្ពក្នុងឆ្នាំ១៩៣៦ ឬ១៩៤៣)
- ឯកសហារាត្រី (ភាគខ្លះប្រែ)
- ចូឡវេទល្លសូត្រ (ប្រែ)
- ចូឡវេទល្លសូត្រ (ប្រែ)
- វិធីប្រតិបត្តិធម៌
- ពន្លឺអាស៊ីទ្វីប (ប្រែ)
- បញ្ញាសជាតកសង្ខេប ភាគ១-២

**៣- កាលកំណត់រៀបរៀង**

**៣.១- ថ្ងៃ ខែ ឆ្នាំនៃការរៀបរៀង**

គម្ពីរដែលបានសម្រួលជាភាសាខ្មែរ មានចំណាស់ជាងគេ ដែលគេស្រាវជ្រាវឃើញសល់(ជាសាស្ត្រាចារលើស្លឹករឹត) ប្រហែលចងក្រងឡើងក្នុងរវាងសតវត្សទី១៨ឬ ១៩ នៃគ.ស

អំឡុងរជ្ជកាលព្រះអង្គឌួង «១៧៩៦-១៨៦០»។[2]

### ៣.២- ថ្ងៃ ខែ ឆ្នាំនៃការបោះពុម្ព

ឯកសារដែលលើកយកមកសិក្សានៅពេលនេះ ជាឯកសារដែលបោះពុម្ពផ្សាយ៣លើក របស់ពុទ្ធសាសនបណ្ឌិត្យព.ស. ២៥០៩ ថ្ងៃ១៥ ខែមិថុនា ឆ្នាំ១៩៦៦[3] ហើយត្រូវបានបោះពុម្ពផ្សាយឡើងវិញដោយអាគារបោះពុម្ពផ្សាយវប្បធម៌ ឆ្នាំ១៩៩០។

## ៤- សង្គមបរិយាកាស

### ៤.១- កាលប្រវត្តិ

រឿងព្រះវេស្សន្តរ ឋិតនៅក្នុងគម្ពីរ «អដ្ឋកថា» ដែលជាផ្នែកមួយនៃគម្ពីរ ខុទ្ទកនិកដែលមាននៅក្នុងព្រះត្រៃបិដកខាងផ្នែកសុត្តន្តបិដក។ គម្ពីនេះមានប្រភពនៅកោះសិរីលង្កា សរសេរជាសីហឡ[4]ភាសា។លុះមកដល់អំឡុងពេលប្រហែល៥០០ឆ្នាំ ក្រោយព្រះពុទ្ធបរិនិព្វាន ទើបពុទ្ធឃោសនាចារ្យមួយអង្គជាមហាថេរ នៅមគធរដ្ឋ«ឥណ្ឌា»និមន្តទៅកោះលង្កា ហើយបានប្រែត្រៃបិដកពីសីឡហភាសា មកជាមគធៈភាសាទាល់តែចប់។ ក្រោយមកគម្ពីរនេះ បានត្រូវនាំចូលមកក្នុងប្រទេសខ្មែរតាមរយៈការផ្សព្វផ្សាយលទ្ធិពុទ្ធសាសនា។[5]

### ៤.២- ព្រឹត្តិការណ៍សំខាន់ៗ

រឿងនេះ បានបង្ហាញពីព្រឹត្តិការសំខាន់ៗ តាមរយៈការបំពេញទានបរិច្ចាគទាំងប្រាំយ៉ាងរបស់តួអង្គព្រះពោធិសត្វព្រះនាមព្រះវេស្សន្ត ដែលមានធនបរិច្ចាគ គឺលះបង់ទ្រព្យសម្បត្តិជាទាន អង្គបរិច្ចាគ គឺលះបង់សរីរាង្គណាមួយជាទាន ជីវិតបរិច្ចាគ គឺលះបង់អាយុជីវិតជាទាន បុត្តបរិច្ចាគ គឺលះបង់កូនជាទាន និងភរិយាបរិច្ចាគ គឺលះបង់ប្រពន្ធជាទាន។ចំពោះការបំពេញទានបារមីក្នុងជាតិទី១០នេះ ព្រះអង្គត្រូវជួបប្រទះនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរ គឺរវាងអារម្មណ៍ ឬមនោសញ្ចេតនារបស់ទ្រង់ ចំពោះរាជបុត្រ និងមហេសី និងប្រជារាស្ត្រជាដើម។

## II-ការវិភាគអត្ថបទ

### ក.ស្ថានភាពរឿង

#### ក.១- សង្ខេបរឿង

[2] សិក្សាអត្ថបទរឿងព្រះវេស្សន្តរ ស្នាដៃរបស់សាស្ត្រាចារ្យអក្សរសិល្ប៍ សម្រាប់ថ្នាក់ទី១០និងអ្នកស្រាវជ្រាវ រៀបរៀង០២. សីហា.១៩៨៧

[3] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០

[4] (សំ. សឹហល; បា.សីហល ឬ សីហឡ ) លង្កា; ជាតិមនុស្សអ្នកនៅក្នុងកោះលង្កា
កោះសិង្ហល; ជាតិសិង្ហល, អ្នកសិង្ហល (ម. ព. លង្កា ផង) ។បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ អ. ថ. សិង-ហៈល់:, ដូចជា សិង្ហលទ្វីប កោះសិង្ហល (កោះលង្កា) សព្វថ្ងៃនេះហៅ គ្រីលង្កា (ស្រីលង្កា) ។ សិង្ហលភាសា ភាសាអ្នកសិង្ហល (សម្ដីអ្នកលង្កាទ្វីប) ។

[5] សិក្សាអត្ថបទរឿងព្រះវេស្សន្តរ ស្នាដៃរបស់សាស្ត្រាចារ្យអក្សរសិល្ប៍ សម្រាប់ថ្នាក់ទី១០និងអ្នកស្រាវជ្រាវ រៀបរៀង០២. សីហា.១៩៨៧

➤**ទី១** : **កណ្ឌទសពរ** (ពរទាំង១០ប្រការ)

ពេលដែលបានត្រាស់ហើយ ព្រះពុទ្ធសាមណគោតមទ្រង់គង់នៅក្នុងវត្តវេឡុវ័ននៃក្រុងរាជគ្រឹះដែនមគធរដ្ឋ ដើម្បីប្រកាសផ្សាយព្រះពុទ្ធសាសនា។ ក្រោយដែលបានអារាធនាអំពីឧទាយិត្ថេរជារាជាមាត្រលើកទី១០របស់ព្រះបាទស្រីសុទ្ធោទនៈពុទ្ធបិតាព្រះពុទ្ធអង្គក៏និមន្តមកថ្កានក្រុងកបិលពស្តុដោយមានភិក្ខុសង្ឃ អង្គអរហន្តាខីណាស្រពប្រមាណជា ពីរម៉ឺនជាបរិវារ។

កាលទ្រង់ មកដល់ចំពោះភក្ត្រក្រុមព្រះញាតិវង្ស ស្តេចសាក្យរាជ ចំនួន៨ម៉ឺន៤ពាន់រូបស្រាប់តែមានភ្លៀងបោក្ខព័សិធ្លាក់មកពីនភាល័យ។ ភ្លៀងនោះ ជាបុព្វហេតុនៃការសំដែងរឿងមហាវេស្សន្តរនេះ។

ក្នុងពេលភ្លៀងនោះ ព្រះពុទ្ធទ្រង់បានទេសនា អំពីប្រវត្តិបុព្វកម្មរបស់ ព្រះនាងសុបារសុប្បតី។ កាលមុនពេលបានមកជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យព្រះនាងសុបារសុប្បតី ជាស្រីសួគ៌។ លុះពេលដែលត្រូវច្យុតចាកទេវលោក ព្រះនាងបានទូលសុំព្រះពរ១០ប្រការអំពីព្រះឥន្ទ្រាធិរាជ។ពរទាំង១០នោះគឺៈ

១- សូមឱ្យបានជាអគ្គមហេសី ព្រះបាទស្រីសញ្ជ័យនាក្រុងជេតុត្តរនគរ[6]។

២- សូមឱ្យមានភ្នែកមូលខ្មៅយង់ឧបមាបីដូចកូនម្រឹគទើបកើត បានតែមួយឆ្នាំ ហើយមានភ្ញមោនោះកោង ទ្រទេស ទ្រទួយ បីដូចចង្កួយកៅទ័ណ្ឌ ពុំនោះសោតបីដូចព្រះពិស្ណុការកាន់ដងជក់ជ្រលក់ខ្មៅមកគូរមកវាសហោង ព្រះពរនេះឯង។

៣- សូមឱ្យមានឈ្មោះថា សុបារសុប្បតីដូចដែលប្រក្រតី នៅឰដ៏ត្រៃត្រិង្សពិភព។

៤- សូមឱ្យមានកូនប្រុសដ៏ប្រកបនូវកិត្តិយស ឱ្យឮទូទ័រអស្ចារ្យទាំងប្រលង់សកលជម្ពូទ្វីប អាចកាត់អំណោយទានជាឋានពំនាក់នៃស្នូមយាចកផងទាំងឡាយ។

៥- កាលណាបើខ្ញុំអម្ចាស់នឹងទ្រង់មានគភ៌នោះ កុំឱ្យមានផ្ទៃពោះធំប៉ោងប៉ើសច្រឡើសនឹងចុងដង្ហើមនោះឡើយឱ្យរាបសុភាពល្អបីដូចអ្នកយកកាំធ្នូច្រកក្នុងបំពង់នោះឯង។

៦- សូមកុំបីមានដោះសណ្តាយជាសំណើចនៃអ្នកផងទាំងឡាយឡើយ សូមមានដោះក្បោះក្បំសម ឧរាដូចផ្លែទន្លាប់មាសអ្នកយកមកផ្ទាប់នៅឰដ៏ទ្រូងរបស់ខ្ញុំអម្ចាស់។

៧- សូមកុំឱ្យមានសក់ស្កូវអាស្រូវអាក្រក់ សូមឱ្យមានសក់ខ្មៅយង់រលង់រលើបដូចស្លាបភមរា។

៨- សូមឱ្យមានសម្បុរនោះល្អិតល្អបីដូចពពិលមាសគិតដ៏ខាត់កុំបីឱ្យមានជិតដល់នូវផង់ធូលីដីខ្សាច់ឡើយ។

៩- សូមបានដោះស្រាយសត្វផងទាំងឡាយ ឱ្យរួចចេញអំពីទុក្ខទោស គឺលោកដាក់

---

[6] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០

ទ្រុងច្រូលច្រវាក់ខ្នោះឃ្នាងគុកតារាង នាំទៅនឹងសម្លាប់នោះក្តី ខ្ញុំសូមឱ្យដោះអ្នកទោសនោះឯង ឱ្យបានរួចចេញអំពីទុក្ខភ័យ។

១០-សូមឱ្យមានសព្វសត្វ គឺហង្ស ក្រៀល ក្ងាន ក្ងោក សឹងហើរឆ្វាត់ឆ្វៀល បន្លឺនូវសព្ទនោះឮល្វែងល្វើយពីរោះឮដ៏ព្រះរាជមន្ទីរ ដ៏ពេញមីរដេរដាសណាស់ណាន់តាន់តាប់នីទៅនូវគមគាក់ទំពួនទម្លៃ តឿ ខ្ទែ ខ្ទើយ ជាស្រីសឹង្គាផងច្រើន ហើយសូមឱ្យមានអ្នកប្រាជ្ញរាជបណ្ឌិតចេះធម៌អាថ៌ប្រស្នាបីដូចអ្នកសុរាទំពាសាច់ កុំបីឱ្យដាច់អំពីព្រះរាជមន្ទីរខ្ញុំអម្ចាស់ឡើយ។

ព្រះឥន្ទ្រាធិរាជជាឥស្សរកំពូលនៃអស់ទេវតាផងទាំងឡាយ ព្រះអង្គបង្ហៃរពរប្រទានព្រះនាងសុបារសុប្បតីទេវីស្រេចនូវប្រការអម្បាលណោះហើយ មានព្រះរាហឫទ័យនោះដ៏ពេញនូវអំណរអរក្រៃពេកហោង។

៙៙៙ • ៚៚៚

**➤ទី២ : កណ្ឌហេមពាន្ត** (សេចក្តីសរសើរពីព្រៃហេមពាន្ត)

នាងសុបារសុប្បតី បានច្យុតមកឋានមនុស្សលោក ជាបុត្រីនៃព្រះបាទមទ្ទរាជ ក្នុងមាតុលនគរ ហើយបានអភិសេកជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យនៅជេតុត្តរនគរ។ ព្រះពោធិសត្វច្យុតពីឋានត្រៃត្រិង្សមកចាប់បដិសន្ធិ។ ព្រះនាងក៏ប្រសូតបានព្រះរាជបុត្រមួយ ដ៏ល្អល្អះព្រះនាមថា«ព្រះវេស្សន្តរ»។ ព្រះរាជកុមារប្រសូតមកភ្លាម ក៏ចេះនិយាយភ្លាមថា « បពិត្រអ្នកមេទ្រព្យក្នុងផ្ទះយើងមានដែរទេ ... ខ្ញុំនឹងឱ្យទាន»។ ទន្ទឹមនឹងពេលព្រះនាងប្រសូតនោះ ក៏មានមេដំរីសូគិមួយហោះនាំយកកូនដំរីឈ្មោលមួយមកថ្វាយព្រះរាជកុមារ។ ដំរីនោះមាននាមថា«បច្ច័យនាគេន្ទ្រ»។

តាំងពីនៅជារាជកុមារមក ព្រះវេស្សន្តរតែងមានព្រះទ័យសប្បុរស ឱ្យទានដល់អ្នកក្រីក្រ។ ពេលចម្រើនព្រះជន្មឡើង ក៏បានរៀបអភិសេកមហេសី ជាមួយព្រះនាងមទ្រី ដែលជាព្រះរាជបុត្រីនៃព្រះបាទមទ្ទរាស្ត្រនាមាតុលនគរ។ ព្រះអង្គទ្រង់មានព្រះរាជបុត្រាមួយអង្គព្រះនាមជាលីនិងបុត្រីមួយអង្គព្រះនាមក្រស្នា។

ពេលនោះនៅស្រុកលឹង្គរាស្ត្រកើតមានទុរ្ភិក្ស ដោយគ្មានភ្លៀងធ្លាក់សោះ។ ស្តេចនគរនោះទ្រង់បានបញ្ជា ឱ្យព្រាហ្មណ៍៧នាក់ទៅសុំដំរីបច្ច័យនាគេន្ទ្រពីព្រះស្សន្តរ ដើម្បីឱ្យមានភ្លៀងធ្លាក់។ ព្រះវេស្សន្តរបានប្រទានដំរីមង្គលដល់ព្រាហ្មណ៍នៃស្រុកកលិង្គរាស្ត្រ ជាហេតុធ្វើឱ្យអ្នកស្រុកស្រីពិរាស្ត្រកើតចិត្តក្តៅក្រហាយ ហើយក៏នាំគ្នាឡើងទៅទូលព្រះបាទស្រីសញ្ជ័យសូមឱ្យបំបរបង់ព្រះវេស្សន្តរចេញពីនគរ ព្រះអង្គក៏យល់ព្រមបំពេញតាមសំណូមពររបស់អ្នកស្រុកនោះ។ ព្រះនាងមទ្រីក៏បានទូលសុំទៅតាមព្រះស្វាមី ដោយបានពិពណ៌នាអំពីទេសភាព

ព្រៃហេមពាន្ត ដែលជាកន្លែងព្រះវេស្សន្តរ បម្រុងនឹងចេញទៅបួសតាមការបំបរបង់នោះ ជូនព្រះស្វាមីស្តាប់យ៉ាងពីរោះ។

ឲ្យឲ្យ • ឲ្យឲ្យ

➤**ទី៣ : កណ្ឌទានកណ្ឌ** (ការធ្វើទានយ៉ាងអស្ចារ្យ)

កាលព្រះនាងសុបារសុប្បតី ទ្រង់ជ្រាបថា គេបំបរបង់ព្រះវេស្សន្តរ ក៏យាងទៅប្រាសាទព្រះវេស្សន្តរ ហើយសោយសោក រួចទើបទៅទូលអង្វរករព្រះស្វាមី តែមិនបានសម្រេច។ រីឯព្រះបាទស្រីសញ្ជ័យ ទ្រង់ឃាត់ព្រះនាងមទ្រីមិនឱ្យយាងទៅតាមស្វាមីឡើយ ប៉ុន្តែព្រះនាងមទ្រីបដិសេធ ហើយថែមទាំងបានទូលអំពីសភាពនៃស្រីមេម៉ាយដោយការប្រៀបធៀបថា៖

- ទន្លេ គ្មានទឹក ហៅថា ទន្លេអាក្រាត
- ដែន គ្មានស្តេច ហៅថា ដែនអាក្រាត
- ស្រី មេម៉ាយ ហៅថា ស្រីអាក្រាត

ព្រះបាទស្រីសញ្ជ័យទ្រង់បានត្រាស់សុំចៅទាំងពីរ ឱ្យនៅព្រះរាជវាំង តែព្រះនាងមទ្រីមិនយល់ព្រមទៀត។ ព្រះវេស្សន្តរលាព្រះមាតាបិតា នាំមហេសីនិងបុត្រាបុត្រី យាងឡើងគង់លើរាជរថបរទៅកាន់គិរីវង្កត។ ពេលនោះមានព្រាហ្មណ៍បួននាក់ មកសុំសេះអាជានេយ្យទាំងបួនដែលទឹមរាជរថ។ រួចមកព្រាហ្មណ៍ម្នាក់ទៀតទៅទូលសុំរាជរថ។ ព្រះវេស្សន្តរទ្រង់ប្រទានដោយគ្មានស្តាយស្រណោះហើយទ្រង់ពចៅជាលី ឯនាងមទ្រីពក្រស្នា ត្រាច់ដោយព្រះបាទទទេចូលទៅក្នុងព្រៃ។

ឲ្យឲ្យ • ឲ្យឲ្យ

➤**ទី៤ : កណ្ឌវនប្បវេសន៍** (ការចូលគង់ក្នុងព្រៃ)

ព្រះវេស្សន្តរ ទ្រង់នាំមហេសីនិងបុត្រា បុត្រី ទៅដល់មាតុលនគររបស់ពួកចេតរាស្ត្រអស់ចម្ងាយផ្លូវសាមសិបយោជន៍ ក្នុងអំឡុងតែមួយថ្ងៃដោយទេវតាជួញបង្រួញផ្លូវ។

ក្សត្រប្រាំមួយម៉ឺនអង្គក្នុងមាតុលនគរបានធ្វើបដិសណ្ឋារកិច្ចចំពោះព្រះអង្គ ហើយសុំយាងព្រះអង្គឱ្យសោយរាជ្យនៅនគរនោះ តែព្រះអង្គពុំព្រម។ ព្រះពោធិសត្វទ្រង់ផ្ទុំមួយរាត្រី រួចក៏នាំមហេសីនិងបុត្រធ្វើដំណើរតទៅទៀត។ ពួកក្សត្រចេតរាស្ត្រ បានដង្ហែព្រះអង្គចម្ងាយផ្លូវដប់ប្រាំយោជន៍រហូតដល់ទ្វារព្រៃភ្នំគិរីវង្កត ហើយទូលប្រាប់ពីចម្ងាយផ្លូវថា ដប់ប្រាំយោជន៍ទៀតរួចជ្រើសរើសកូនអ្នកស្រុកម្នាក់ ឈ្មោះចេតបុត្រដែលចេះសិល្បសាស្ត្រ ឱ្យទៅយាមមាត់ទ្វារព្រៃកុំឱ្យអ្នកណាចូលទៅបៀតបៀនព្រះអង្គបាន ទើបនាំគ្នាត្រឡប់ទៅវិញ។

ក្រោយពីបានយាងចូលទៅដល់គិរីវង្កតហើយ ព្រះវេស្សន្តរក៏ចូលទៅគង់នៅសាលាដែលព្រះឥន្ទ្រនិម្មិតថ្វាយ ដោយមានសួនច្បារ ស្រះស្រង់និងឧទ្យានយ៉ាងល្អ។ ក្សត្រទាំងបួនអង្គទ្រង់បួសជាឥសី ឥសីនីប្រកបដោយក្តីសុខសាន្តទៅ។

ឲ្យឲ្យ • ឲ្យឲ្យ

➤**ទី៥** : **កណ្ឌជូជក** (ការរៀបរាប់ពីតាជូជក)

កាលនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ជូជករូបអាក្រក់ ខុសពីមនុស្សធម្មតា។ នៅក្នុងស្រុកទុន្នវិដ្ឋព្រាហ្មណ៍គ្រាម ដើរតែសុំទានគេ។ ព្រាហ្មណ៍នេះសុំទានគេក៏សន្សំបានបើគិតជាមាសបានចំនួនមួយរយតម្លឹង យកទៅផ្ញើទុកនឹងត្រកូលព្រាហ្មណ៍មួយ ហើយដើរសុំទានគេទៀត។ និយាយពីត្រកូលព្រាហ្មណ៍នោះ តាំងពីបានទទួលបញ្ញើតាជូជករួចមក ក៏កើតជាក្ដីទីទ័លក្រ ហើយក៏យកប្រាក់តាជូជកចាយវាយអស់ទៅ។ ជូជកវិលមករកទារប្រាក់វិញ ពុំបានក៏គំរាមត្រកូលព្រាហ្មណ៍នោះយ៉ាងតឹងតែង។ ប្ដីប្រពន្ធព្រាហ្មណ៍ ក៏មូលមតិគ្នាសុខចិត្តប្រគល់កូនក្រមុំរូបស្រស់ស្អាតរបស់ខ្លួន ឈ្មោះនាងអមិត្តតាបនា ឱ្យទៅជាភរិយាតាជូជក។ តាជូជកយល់ព្រមនាំនាងនោះយកទៅស្រុកគាត់។

ពួកព្រាហ្មណ៍ក្មេងៗនៅក្នុងស្រុកនោះ ឃើញនាងអមិត្តតាបនា ចេះផ្គាប់ផ្គុនតាជូជក ក៏កើតក្ដីមួម៉ៅនឹងប្រពន្ធខ្លួន ដែលមិនចេះបម្រើប្ដីរួចវាយស្ដីបន្ទោសប្រពន្ធយ៉ាងខ្លាំង។ ពួកប្រពន្ធព្រាហ្មណ៍ក្មេងៗទាំងនោះ កើតក្ដីក្ដៅក្រហាយ ក៏នាំគ្នាទៅស្នាក់ជេរប្រទេច និងវាយដំនាងអមិត្តតាបនានៅកំពង់ទឹក។

ពេលមកដល់ផ្ទះវិញ នាងអមិត្តតាបនាបានស្រែកយំត្អូញត្អែរដាក់ប្ដី ទាំងខឹងសម្បារឱ្យទៅរកខ្ញុំបម្រើប្រុស ស្រីមកឱ្យនាង បើពុំនោះទេ នាងនឹងទៅដេកជាមួយពួកព្រាហ្មណ៍ក្មេងៗជាមិនខាន។ តាជូជកក៏ដាច់ចិត្ត ធ្វើដំណើរទៅសុំបុត្រា បុត្រីព្រះវេស្សន្តរទាំងទុក្ខវេទនាដោយត្រូវព្រាត់ប្រពន្ធក្មេងហើយខ្លួនក៏ចាស់ រីឯផ្លូវក៏វែងឆ្ងាយ។

តាជូជក ខំត្រដរទៅដល់មាត់ទ្វារព្រៃ ភ្នំគិរីវង្កតជិតលំនៅចេតបុត្រ ក៏ត្រូវហ្វូងឆ្កែរបស់ចេតបុត្រដេញចោមរោម ហើយគាត់ខំរត់សស្លើតសស្លក់ ឡើងដើមឈើដោយស្រែកទ្រហោយំរកព្រះវេស្សន្តរ។ ចេតបុត្រឃើញដូច្នោះ ក៏លើកធ្នូឡើងបម្រុងនឹងបាញ់សម្លាប់ ព្រោះយល់ថាជាស្ទមចង្រៃ ទៅបៀតបៀនព្រះវេស្សន្តរ។ តាជូជកខំពោលពាក្យកុហកថា ខ្លួនជារាជទូតរបស់ព្រះបាទស្រីសញ្ជ័យដែលប្រើឱ្យមកសួរសុខទុក្ខព្រះវេស្សន្តរ។ចេតបុត្រក៏ជឿឥតសង្ស័យ ហើយក៏ដាក់បង្អោង ឱ្យតាជូជកចុះមក។ រួចហើយក៏ជប់លៀងម្ហូបចំណីយ៉ាងយកចិត្តទុកដាក់ព្រមទាំងចង្អុលបង្ហាញផ្លូវទៅកាន់អាស្រមព្រះវេស្សន្តរ។

ឲឲឲ • ៚៚៚

➤**ទី៦** : **កណ្ឌចូឡពន** (ការពិពណ៌នាអំពីព្រៃតូច)

កាលចេតបុត្រព្រានព្រៃ បានជប់លៀងតាជូជកហើយ ក៏ពិពណ៌ពីផ្លូវ និងធម្មជាតិទៅកាន់អាស្រមព្រះវេស្សន្តរ ឱ្យតាជូជកស្ដាប់ ថែមទាំងបញ្ជាក់ថា កាលបើទៅដល់មុខបន្តិចនឹងជួបព្រះអច្ចុតឫសី ដែលតែងគង់ធ្វើពិធីបូជាយញ្ញនៅក្នុងព្រៃនោះ។ តាជូជកស្ដាប់ហើយក៏ដើរប្រទក្សិណចេតបុត្របីជុំ រួចក៏ធ្វើដំណើរចេញទៅ ។

ឲឲឲ • ៚៚៚

➤**ទី៧** : **កណ្ឌមហាពន** (អំពីព្រៃធំ)

តាជូជក បានធ្វើដំណើរកាត់ព្រៃទៅ ក៏បានជួបអច្ចុតឫសី រួចបានសួររកផ្លូវទៅអាស្រម

ព្រះវេស្សន្តរ តទៅទៀត ដោយកុហកថាខ្លួនជារាជទូតព្រះបាទស្រីសញ្ជ័យ។ អច្ចុតឫសីក៏ជឿស៊ប់ ក៏ធ្វើបដិសណ្ឋារកិច្ចតាជូជក ហើយឱ្យស្នាក់នៅមួយយប់។ លុះព្រឹកឡើង តាឥសីបានពិពណ៌នាប្រាប់ផ្លូវនិងរៀបរាប់ពីធម្មជាតិ ក្នុងព្រៃដ៏ធំយ៉ាងវែងឆ្ងាយពិស្តារទៅកាន់អាស្រមព្រះវេស្សន្តរ ឱ្យតាជូជកស្តាប់។ តាជូជកក៏លាឥសីចេញដំណើរទៅមុខទៀត។

៚៚៚ • ៙៙៙

➤**ទី៨ : កណ្ឌកុមារបព្វ** (ការប្រទានជាលីក្រស្នាឱ្យជូជក)

នៅពេលល្ងាច ជូជកក៏បានទៅដល់ជិតអាស្រមព្រះវេស្សន្តរគាត់ពុំទាន់ចូលទៅភ្លាមទេ ព្រោះដឹងថា ពេលនោះព្រះនាងមេទ្រីនៅក្នុងអាស្រម ហើយមុខជាឧបសគ្គចំពោះការសុំរាជបុត្រទាំងពីររបស់គាត់ជាមិនខាន។ រាត្រីនោះ នាងមេទ្រីបានសុបិនឃើញថា មានបុរសម្នាក់ទាបខ្មៅ ស្លៀកពាក់ត្រឹមជង្គង់សៀតផ្កាចារលើត្រចៀកកាន់អាវុធមុតថ្លារត់ចូលមកក្នុងសាលាចាប់ព្រះនាងផ្តួលចុះឆ្កៀលយកព្រះនេត្រទាំងពីរ កាត់យកព្រះអង្សាទាំងសងខាង ពុះទ្រូងរូងយកថ្លើមព្រះនាង។ ព្រះនាងតើនឡើងទៅគោះទ្វារអាស្រមព្រះស្វាមីទាំងរាត្រី ហើយរៀបរាប់ពីសុបិននោះថ្វាយព្រះវេស្សន្តរស្តាប់។ ព្រះវេស្សន្តរពុំបើកទ្វារទេ ហើយដោយយល់ហេតុការណ៍នោះ ព្រះអង្គក៏បំភាន់ប្រាប់ព្រះនាងថា សុបិននោះមិនអាក្រក់ទេ កុំឱ្យនាងភ័យហើយឱ្យទៅមើលកូនវិញក្រែងវាភ្ញាក់។

លុះព្រឹកឡើង ព្រះនាងមេទ្រីយកបុត្រទាំងពីរទៅផ្ញើព្រះស្វាមី ហើយចូលព្រៃរកបេះផ្លែឈើ។ ពេលដែលមេទ្រីចេញផុត តាជូជកក៏ចូលទៅសួរសុខទុក្ខព្រះវេស្សន្តរហើយទូលសុំបុត្រទាំងពីរ។ ព្រះវេស្សន្តរយល់ព្រមឥតរួញរា តែសុំឱ្យជូជកចាំព្រះនាងមទ្រី ត្រឡប់មកវិញសិន។ ជូជកខ្លាចនាងមេទ្រីមកនាំឱ្យខូចការខ្លួន ក៏ដៀលត្មះព្រះធិសត្វ។ រាជកុមារទាំងពីរមានការភិតភ័យយ៉ាងខ្លាំងពេលឃើញជូជក ក៏រត់ទៅពួនតែដោយការអង្វរកររបស់ព្រះបិតា ក៏ចេញមកវិញតាមបន្ទូលបិតា។ ជូជកក៏ចាប់ចងកុមារទាំងពីរវាយបណ្តើរចេញទៅ។ កុមាររើបម្រះរួចមកទួញសោកអង្វរករព្រះបិតាធ្វើឱ្យព្រះអង្គ កើតមានចិត្តអាណិតអាសូរបុត្រហើយខឹងនឹងជូជក យ៉ាងខ្លាំង។ ជូជកក៏មកវាយដំកុមារទាំងពីរ នៅចំពោះមុខព្រះវេស្សន្តរ ហើយចងបណ្តើរទៅវិញ។ ព្រះមហាឥសីទប់ព្រះទ័យពុំបាន ទ្រង់ចាប់ធ្នូសរផ្គងតម្រង់ឆ្ពោះតាជូជក បម្រុងនឹងប្រហារជីវិតតែទ្រង់រំឭករំងាប់កំហឹង ដោយគិតដល់ប្រពៃណីពោធិសត្វ ហើយក៏ដាក់ធ្នូចុះវិញ។

កុមារទាំងពីរក៏ត្រូវតាជូជកនាំយកទៅទាំងទុក្ខវេទនា។ កុមារទួញសោក ហើយក៏បានបួងសួងសូមឱ្យទេវតា ជួយនាំព័ត៌មានទៅទូលព្រះមាតាឆាប់មកតាមផ្លូវនេះ ហើយសូមឱ្យមកជួយអ្នកទាំងពីរ។

៚៚៚ • ៙៙៙

➤**ទី៩ : កណ្ឌមទ្រីបព្វ** (និយាយពីនាងមទ្រី)

ក្រោយពេលដែលជូជក បណ្ដើរចៅជាលីនិងនាងក្រស្នាចេញផុតពីបរិវេណអាស្រម សាលា ព្រះនាងមេទ្រី ដែលបានស្វែងរកបេះផ្លែឈើនោះ ចេះតែមានប្រផ្នូលចម្លែកៗ គឺព្រះនេត្រខាងឆ្វេងចេះតែរកាំព្រះនេត្រខាងស្ដាំចេះតែកម្រើកទាំងជ្រនីកនិងទំពក់ក៏ធ្លាក់របូតពីព្រះហស្ដខុសប្រក្រតីទាំងព្រឹក្សាសោតហាក់ដូចជាប្រែប្រួលខុសពីធម្មតាគឺដើមឈើណាដែលធ្លាប់មានផ្លែផ្កា ក៏ប្រែជាគ្មានទៅវិញ។ ព្រះនាងកើតទុក្ខជាខ្លាំង ហើយនឹកព្រួយអំពីបុត្រា បុត្រី និងព្រះស្វាមីនៅអាស្រម។ ដូចនេះហើយទើបពេលថ្ងៃរសៀលបន្តិចព្រះនាងក៏រលះរលាំងវិលមកកាន់អាស្រមវិញ។ លុះយាងមកដល់ច្រកផ្លូវមួយ ស្រាប់តែពើបពះប្រទះនិងសត្វដ៏សាហាវបីគឺរាជសីហ៍ ខ្លាធំ និងខ្លាដំបងដែលឈររាំងផ្លូវព្រះនាង។ នាងមទ្រីភិតភ័យយ៉ាងខ្លាំង ក៏លើកហត្ថាប្រណម្យសុំផ្លូវ តែត្រូវសត្វទាំងបីស្រែកគំរាមថែមទៀត។ ព្រះនាងភិតភ័យស្រឡាំងកាំងសន្លប់បាត់ស្មារតីក្រែងសត្វទាំងបីយាយីដល់ព្រះជន្ម។

ដល់ពេលព្រលប់យប់សន្ធិយាព្រះចន្ទ្រាពេញវង់រះឡើងយ៉ាងត្រចះត្រចង់ ទើបទេវបុត្រទាំងបីអង្គ ដែលបានកាឡាខ្លួនជាសត្វទាំងបីនោះ ក៏ថយចេញពីផ្លូវ។ ព្រះនាងមេទ្រីម្ចីម្ចាយាងមកកាន់អាស្រមស្រាប់តែឃើញស្ងាត់ជ្រងំខុសប្រក្រតី ព្រះនាងស្ទើរក៏ស្រែករកបុត្រទាំងពីរតែពុំឮសូរមាត់ឆ្លើយសោះ ព្រះនាងក៏រត់ទៅរកឯអាស្រមព្រះស្វាមី ក៏ពុំឃើញទៀត ទើបទូលសួរព្រះរាជស្វាមី តែស្វាមីពុំមានព្រះបន្ទូលអ្វីឡើយ។ព្រះនាង មានសេចក្ដីព្រួយបារម្ភដ៏លើសលន់ពន់ពេក ទើបយាត្រាត្រាច់រកព្រះរាជបុត្រសព្វទីកន្លែង ក្នុងព្រៃទាំងរាត្រីស្ងាត់ ផ្អើលអស់បក្សាបក្សីក៏នៅតែពុំឃើញ។ ព្រះនាងត្រឡប់មកអាស្រមវិញហើយសោយសោកសួរព្រះស្វាមីទៀតតែព្រះវេស្សន្តរបែរជាពោលពាក្យប្រចណ្ឌ័នាងដែលមកដល់អាស្រមរហូតដល់យប់ទៅទៀត។ ព្រះនាងក៏ដួលសន្លប់នៅចំពោះមុខព្រះស្វាមី។ព្រះវេស្សន្តរភិតភ័យខ្លាំងស្ទុះមកបីត្រកងហើយទ្រង់យកវារីមកស្រពព្រះភក្ត្រព្រះនាង ឱ្យមានស្មារតីឡើងវិញ។ ព្រះនាងបានទទូចសួររករាជបុត្រទៀតទើបព្រះវេស្សន្តរទ្រង់ត្រាស់ប្រាប់ថាទ្រង់បានដាក់ទានដល់ព្រាហ្មណ៍ទៅហើយសូមឱ្យព្រះនាងអនុមោទនាបុត្តទានបារមីផង។ សម្ដេចក្សត្រី ក៏ទ្រង់បានអនុមោទនាដោយសាទរចិត្តចំពោះបុត្តទានបារមីនៃព្រះស្វាមីនេះ។

៙៙៙ • ៚៚៚

➤**ទី១០ : ករណ្ឌាសក្កបព្វ** (និយាយពីអន្តរាគមន៍របស់ព្រះឥន្ទ្រ)

កាលនោះ ព្រះឥន្ទ្រាធិរាជទ្រង់ចុះមកជួយបំពេញ ទានបារមីព្រះពោធិសត្វ ឱ្យកាន់តែប្រពៃឡើងទៀត។ព្រះឥន្ទ្របានប្រែភេទជាព្រាហ្មណ៍ស្ទូមចាស់ជរាចូលមកសុំព្រះនាងមទ្រីទៅធ្វើជាមេផ្ទះរបស់គាត់។ ព្រះវេស្សន្តរ ក៏ព្រះរាជទានព្រះនាងមទ្រីឱ្យទៅព្រាហ្មណ៍ស្ទូម ដោយឥតមានព្រះហឫទ័យរួញរាឡើយ។ តែទ្រង់មានព្រះចិន្ដាព្រួយបារម្ភខ្លាចក្រែង ព្រះអគ្គមហេសីមិនសព្វព្រះហឫទ័យនឹងទានបារមីរបស់ព្រះអង្គ។ប៉ុន្តែព្រះនាងមេទ្រីក្រាបទូលថា កុំថាឡើយ

ដាក់ទានរូបកាយទោះបីព្រាហ្មណ៍នោះប្រាថ្នា សាច់ថ្លើម ដង្ហើមប្រមាត់ក៏ព្រះនាងយល់ព្រមឱ្យព្រះអង្គយកព្រះខ័នកាត់ដើម្បីបំពេញទានបារមីនេះដែរ។

ព្រះឥន្ទ្រ បានប្រែរូបដើមដ៏រុងរឿងមួយរំពេចហើយទ្រង់បានប្រគល់ថ្វាយព្រះនាងមទ្រីទៅព្រះវេស្សន្តរវិញ ហើយទ្រង់បានប្រទានពរប្រាំបីប្រការថ្វាយដល់ព្រះវេស្សន្តរគឺ៖

១- សូមឱ្យព្រះរាជបិតាស្តេចមកអញ្ជើញទៅគ្រងរាជ្យសម្បត្តិវិញ

២- សូមឱ្យមានអំណាចអាចដោះទុក្ខទោសសត្វលោកទាំងឡាយឱ្យផុតពីក្តីស្លាប់

៣- សូមឱ្យបានជួយសង្គ្រោះដល់ជនកម្សត់ទុរគតទូទៅឱ្យផុតក្តីក្រីក្រលំបាកវេទនា

៤- សូមកុំឱ្យមានចិត្តត្រេកត្រអាលក្នុងផ្លូវកាមគុណជាអកុសល

៥- សូមឱ្យចៅជាលីនិងនាងក្រស្នាបានគ្រប់គ្រងបុរីពិជ័យជេតុត្តរ

៦- កាលបើទៅដល់បុរីរាជធានីហើយសូមឱ្យមានអាហារទិព្វ កើតឡើងរៀងរាល់ថ្ងៃ

៧- សូមឱ្យការបរិច្ចាគទាន របស់ព្រះអង្គមិនមានការខ្វះខាតអ្វីឡើយ

៨- សូមឱ្យបានទៅកើតនាឋានតុសិតទេវលោកកុំបីអាក់ខានពេលរំលាយបញ្ចក្ខន្ធ

ৎৎৎ • ৡৡৡ

➤**ទី១១** : **កណ្ឌមហារាជបព្វ** (ជាលីក្រស្នាជួបព្រះបាទស្រីសញ្ជ័យ)

កាលតាជូជក បណ្តើរជាលី ក្រស្នាទៅតាមផ្លូវពេលឈប់ គាត់ឡើងដេកលើដើមឈើ មានទេពតាកាឡាខ្លួន ជាព្រះវេស្សន្តរនិងនាងមទ្រី ចូលមកបំបៅចៅជាលីនិងក្រស្នា ទាល់តែភ្លេតស្តប់ស្តល់ទើបភៀសខ្លួនបាត់ទៅ។ភ្លឺឡើងជូជកក៏នាំកុមាទាំងពីរទៅទៀតសំដៅទៅកលិង្គរាស្ត្រ ប៉ុន្តែដោយមានទេពតាបង្វែរចិត្តតាជូជក ក៏វង្វេងផ្លូវចូលទៅជេត្តរនគរហើយនាំកុមារដើរកាត់ខាងមុខព្រះលានព្រះរាជវាំង។ ព្រះបាទស្រីសញ្ជ័យ ទតឃើញតាចាស់ដឹកកុមារតូចៗដែលមានបួកពាសមរម្យ ក៏ត្រាស់ឱ្យអាមាត្យទៅនាំយកមក ទើបស្គាល់ច្បាស់ថា ជាលីនិងក្រស្នារួចត្រាស់សួរដោយសព្វគ្រប់។ កាលដឹងរឿងរ៉ាវអស់ហើយ ពួកអាមាត្យនិងនាម៉ឺនសព្វមុខមន្ត្រីក៏នាំគ្នាថ្កោលទោសព្រះវេស្សន្ទ្រយ៉ាងច្រើន ឯជាលីក៏ឆ្លើយដោយសារការពារព្រះបិតាយ៉ាងក្លាហានដែរ។ ព្រះបាទស្រីសញ្ជ័យទ្រង់លោះជាលីនិងក្រស្នាតាមតម្លៃដែលព្រះវេស្សន្តរបានកំណត់រួចទើបធ្វើពិធីទទួលព្រលឹងចៅទាំងពីរតាមប្រពៃណី។ ជាលីក្រាបទូលអំពីសេចក្តីវេទនារបស់ព្រះមាតាបិតាយ៉ាងច្បាស់លាស់ដល់ព្រះអយ្យកោ អយ្យកា។

ព្រះនរបតីទ្រង់ចាត់ឱ្យសេនាអាមាត្យរៀបចំយោធាដើម្បីទៅយាងព្រះវេស្សន្តរមកវិញ។ ៧ថ្ងៃក្រោយមក ព្រះរាជាទ្រង់លើកចតុរង្គសេនាទៅគិរីវង្កត ដោយមានជាលីជាអ្នកនាំផ្លូវ។ ចំណែកឯតាជូជកវិញ កាលបើបានទទួលរាជទ្រព្យជាតម្លៃលោះ ជាលីក្រស្នាហើយ ក៏បរិភោគអាហាររហូតទល់បែកពោះស្លាប់ក្នុងគ្រានោះទៅ។

ৎৎৎ • ৡৡৡ

➤**ទី១២ : កណ្ឌឆក្សត្រ** (ក្សត្រទាំង៦ជួបជុំគ្នា)

កាលព្រះបាទស្រីសញ្ជ័យ នាំរាជវង្សលើកចតុរង្គសេនា ឆ្ពោះទៅដល់ជិតគិរីវង្កតព្រះវេស្សន្តរទ្រង់ឮស្នូរគឹកកងរំពងនៃកងទ័ពហើយ ក៏ភិតភ័យនាំនាងមេទ្រី រត់ឡើងលើភ្នំតែព្រះនាងទូលរំឭកថា គ្មាសត្រូវណាមកយាយីបានឡើយ ព្រោះត្រូវព្រះឥន្ទ្រប្រទានរួចហើយ។ ព្រះវេស្សន្តរក៏នាំនាងមេទ្រីចុះមកវិញ ហើយបានជួបព្រះបិតានិងបុត្រាបុត្រី។ ដោយទប់ស្មារតីមិនបានទ្រង់ក៏សោយសោក រហូតសន្លប់ស្មារតីទាំងអស់គ្នា ឯពួកពលសេនាក៏នាំគ្នាយំសោកទាល់តែសន្លប់ដែរ។

ខណៈនោះមហាមេឃក៏បង្អុរភ្លៀងបោក្ខរព័សក៏បង្អុរធ្លាក់មកស្រោចស្រប់លើក្សត្រទាំង៦អង្គ និងពួកពលទាំងអស់ ឱ្យភ្ញាក់ស្មារតីឡើងវិញ ហើយគេក៏ក្រាលទូលព្រះវេស្សន្តរនិងព្រះមទ្រីយាងទៅសោយរាជ្យវិញ។

៙៙៙ • ៚៚៚

➤**ទី១៣ : កណ្ឌនគរកណ្ឌ** (ការយាងចូលនគរវិញ)

ព្រះបាទស្រីសញ្ជ័យ នាងសុបារសុប្បតីនិងនាម៉ឺននានាបាន សុំយាងព្រះវេស្សន្តរឱ្យទៅសោយរាជ្យនៅជេតុត្តរនគរវិញ ព្រះវេស្សន្តមិនទទួលភ្លាមទេ ទ្រង់លើករឿងដើមមកដំណាលថ្វាយព្រះបិតា។ ព្រះបាទស្រីសញ្ជ័យទ្រង់សុំទោសបុត្រ ហើយលួងលោមយ៉ាងខ្លាំងទើបព្រះវេស្សន្តរយល់ព្រម។

៙៙៙ • ៚៚៚

**ក.២- តួអង្គ**

➤ **តួអង្គឯក**

- ព្រះវេស្សន្តរស្វាមីនាងមទ្រី បុត្រព្រះបាទស្រីសញ្ជ័យ និងនាសុបារសុប្បតី
- ព្រះនាងមទ្រីជាមហេសីព្រះវេស្សន្តរ និងជាមាតាជាលី ក្រស្នា

➤ **តួអង្គរង**

- ព្រះបាទស្រីសញ្ជ័យជាព្រះមហាក្សត្រសោយនៅជេតុត្តរនគរ
- ព្រះនាងសុបារសុប្បតីជាមហេសីព្រះបាទស្រីសញ្ជ័យ
- ជជូក ជាព្រាហ្មណ៍ស្នូម សុំបុត្រព្រះវេស្សន្តរ
- ជាលី និងក្រឹស្នា ជាបុត្រព្រះវេស្សន្តរ និងនាងមទ្រី

➤ **តួអង្គបន្ទាប់បន្សំ**

- ព្រះឥន្ទ្រាធិរាជ ជាប្រទានពរទាំង១០ប្រការដល់ព្រះនាងសុបារសុប្បតីនិងពរ៨ប្រការដល់ព្រះវេស្សន្តរ
- នាងអាមិត្តតាបនា ជាប្រពន្ធព្រាហ្មណ៍ជជូក
- ចេតបុត្រ ជាកូនអ្នកស្រុកដែលក្សត្រឱ្យចាំច្រកផ្លូវទៅគិរីវង្កត

### គ.៣- កាលអាកាស

➤ **កាល** ដំណើររឿងបានប្រព្រឹត្តទៅនៅក្រោយពីព្រះពោធិសត្វបានត្រាស់ដឹង ក៏បានវិលមកទេសនាពីប្រវត្តិរឿងមហាវេស្សន្តរជាតក មានតំណាលថា «...ថានាកាលព្រះអង្គយោនយកកំណើតកើតជាព្រះពោធិសត្វ១ព្រះអង្គ ទ្រង់ព្រះនាមព្រះវេស្សន្តរនោះ អស់យើងខ្ញុំគ្រាន់តែបានឮព្រះបន្ទូលអម្បាលណោះឬនឹងដឹងជាតិសន្តានកន្លងរំលងទៅហើយនោះ យើងខ្ញុំពុំទាន់ឡើយបពិត្រព្រះដ៏មានបុណ្យអើយ សូមព្រះអង្គយកប្រាជ្ញាទិព្វវិសេសមួយឈ្មោះ បុព្វនិវាសានុស្សតិញ្ញាណ ទៅឱបក្រសោបអស់ធម៌ផងទាំងឡាយ ដែលកន្លងរំលងទៅហើយនោះ នាំយកមកសំដែងថ្លែងទេសនាជាសណ្តាប់ ប្រាប់អស់យើងខ្ញុំទាំងអម្បាលណោះហោង»។[7]

➤ **អាកាស**

ស្រុកស្រិពិរាស្ត្រ កលិង្គរាស្ត្រ ព្រៃភ្នំគិរីវង្កត ហេមពាន្ត កបិលពស្តុ ជេតុត្តរ ....។

### គ.៤- ព្រឹត្តិការណ៍សំខាន់

កាលដែលព្រះបរមសាស្ត្រាចារ្យ ទើបបានត្រាស់ ទ្រង់គង់ក្នុងនគររាជគ្រឹះ មានព្រះភិក្ខុសង្ឃអង្គអរហន្តចំនួន ២០ ពាន់ជាបរិវារ ទ្រង់យាត្រានិវត្តមកកាន់នគរកបិលពស្តុវិញ មានព្រះឧទាយីដែលព្រះបាទស្រីសុទ្ធោទន៍ ឱ្យទៅនិមន្តនោះជាមគ្គុទ្ទេសក៍ ។ គ្រានោះពួកស្តេចសក្យរាជព្រមព្រៀងគ្នាកំណត់យកសួនច្បារជារមណីយដ្ឋាន របស់ដៃនសក្កៈ ឈ្មោះនិគ្រោធារាមថ្វាយជាអារាមផ្តាច់មកចំពោះព្រះពុទ្ធជាម្ចាស់ ។ ព្រះរាជាទាំងឡាយនោះកាលយាងទៅធ្វើបដិសណ្ឋារៈចំពោះព្រះបរមគ្រូ ទ្រង់តែងតែរុញពួកយុវក្សត្រដែលក្មេងៗជាងព្រះពុទ្ធ ឱ្យចូលទៅគង់ខាងមុខៗ ឯពួកព្រឹទ្ធរាជ ក្រាញនៅតែខាងក្រោយៗ ដោយកិរិយាពុំព្រមថ្វាយបង្គំព្រះបរមសាស្តា ។ ព្រះភគវន្តាចារ្យ ទ្រង់ជ្រាបអធ្យាស្រ័យនៃពួកព្រះញាតិទាំងនោះ ទើបទ្រង់ចូលកាន់ចតុត្ថជ្ឈាន[8]ហោះទៅកាន់អាកាសវេហាស៍ ទ្រង់សម្តែងបាដិហារ្យជាគ្រឿងអស្ចារ្យប្លែកៗ។ ព្រះបាទសុទ្ធោទនមហារាជជាពុទ្ធបិតា ទ្រង់ទស្សនានូវការសេចក្តីអស្ចារ្យ ទ្រង់ផ្គងព្រះអញ្ជលីលើព្រះសិរសី ។ កាលព្រះចក្រីថ្វាយបង្គំហើយ ឥតមានស្តេចណាមួយឡើយដែលមិនថ្វាយបង្គំសោះ ។ កាលស្តេចទាំងនោះថ្វាយបង្គំហើយ ព្រះពុទ្ធជាម្ចាស់ទ្រង់ចុះអំពីអាកាសមកគង់លើព្រះបវរពុទ្ធអាសន៍ កណ្តាលញាតិសមាគម ។ លំដាប់នោះមហាមេឃក៏បង្អុរមកនូវភ្លៀងបោក្ខរព័ស៌ដ៏អស្ចារ្យ គឺថាជនណាចង់ទទឹកទើបទទឹក ជនណាពុំចង់ទទឹកក៏ឥតទទឹកទឹកឡើយ ។ ប្រជាជនទាំងអស់បានឃើញភ្លៀងនោះប្រឹងតែស្ញើចប្រឹងតែសរសើរថា ៖ ឱ! អស្ចារ្យណាស់តើហ្ន៎! ឱ! ចម្លែកប្លែកត្រកាលណាស់តើហ្ន៎! ឱ! អានុភាពនៃព្រះពុទ្ធអើយ ធំអ្វីមាល្បាយម្ល៉េះហ្ន៎ ។ ព្រះបរមសាស្តាទ្រង់មានព្រះពុទ្ធដីកាថា មិនមែនតែឥឡូវនេះទេ ពីបុព្វេគឺកាលតថាគតជាពោធិសត្វក៏មហាមេឃបង្អុរភ្លៀងបោក្ខរព័ស៌មានសភាពយ៉ាងនេះក្នុងញាតិសមាគមដែរ ។

[7] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០

[8] វចនានុក្រមខ្មែរ ចតុត្ថជ្ឈាន មានអង្គ ២ ដែរ លះ សុខៈ ចេញ ចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើយ ជា ២ នឹង ឯកគ្គតា ។

## ខ.អត្ថន័យ

យើងបានអធិប្បាយពីខាងដើមរួចមកហើយថា មហាវេស្សន្តរជាតកនេះ ស្ថិតនៅក្នុងគម្ពីរទសជាតកដែលនិយាយអំពីជាតិកំណើតទាំង១០របស់ព្រះសាមណគោតមមុនពេលបានត្រាស់ដឹង។ដោយរឿងជារឿងបែបសាសនាដូចនេះអត្ថន័យរបស់វាគឺស្ថិតនៅក្នុងការអប់រំតាមបែបសាសនាដែរ។

### ខ.១- ប្រធានរឿង

ព្រះវេស្សន្តរ ជាជាតិកំណើត ពោធិសត្វចុងក្រោយបង្អស់របស់ព្រះពុទ្ធ។ ក្នុងរឿងនេះព្រះពោធិសត្វមាននាមថា«**វេស្សន្តរ**»។ ព្រះពោធិសត្វបានយោនយកកំណើត ក្នុងជាតិទី១០នេះមកបំពេញ«**ទានបារមី**» ដើម្បីឈានទៅត្រាស់ដឹងជាព្រះពុទ្ធ។

ដំណើររឿងទាំងមូល បានលាតត្រដាងតែពីដំណើរជីវិតព្រះអង្គ ដែលផ្សារភ្ជាប់ទៅនឹងការដាក់ទានតែប៉ុណ្ណោះ។ ទោះបីរឿងនេះចែកចេញជាច្រើនកណ្ឌ មានចំណងជើងផ្សេងពីគ្នាយ៉ាងណាក៏ដោយ ក៏យើងឃើញថាសាច់រឿងមូលបានទាក់ទងទៅនឹងការដាក់ទានរបស់តួអង្គព្រះពោធិសត្វព្រះនាមព្រះវេស្សន្តរជានិច្ច។ដូចនេះហើយបានជាយើងអាចកំណត់ប្រធានរឿងខាងលើដោយខ្លីថា «**ការបំពេញទានបារមីរបស់ព្រះពោធិសត្វ ព្រះនាមព្រះវេស្សន្តរ**» ។

ក្នុងដំណើររឿង ក៏បានបង្ហាញតែពីការបំពេញទានបារមីរបស់តួអង្គព្រះវេស្សន្តរ ដោយការបំពេញមហាបរិច្ចាគ៥យ៉ាង គឺះ

➤ **ធនបរិច្ចាគ** ធម្មជាតិព្រះវេស្សន្តរគឺការបំពេញទាន ដោយមិនរើសមុខព្រះអង្គទ្រង់បំពេញទានដោយរីករាយជ្រះថ្លាទីបំផុត។ ព្រះអង្គចេះបរិច្ចាគទានតាំងតែពីវ័យនៅក្នុងផ្ទៃព្រះមាតាមកម្ល៉េះ។ បន្ទាប់ពីព្រះពោធិសត្វចាប់បដិសន្ធិពេលណាមក ធ្វើឱ្យព្រះមាតាមានហឫទ័យដោយឆន្ទៈ បំពេញទានកាន់តែខ្លាំងជាងមុនទៅទៀត។ នៅពេលដែលទ្រង់ប្រសូតមក ព្រះអង្គមានបន្ទូលចង់បំពេញទានតែម្ដង ដូចមានឃ្លាបញ្ជាក់ថា «...បពិត្រព្រះមេដ៏មានគុណធ្ងន់ប្រសើរអើយ តើអ្នកមានមាសដឹងអើយ ខ្ញុំនឹងចង់ឱ្យទានបន្តិចហះ »។[9]ពេលព្រះមាតាទ្រងស្រួបហើយ ព្រះវេស្សន្តរក៏យកមាសប្រាក់ដែលព្រះមាតាប្រទានឱ្យនោះបានដាក់ទានដល់ស្នមទាំងឡាយដោយគ្មានកាតអល់ឯកចិត្តស្មោះ។ ដល់ពេលចម្រើនវ័យឡើងព្រះមហាក្សត្រទ្រង់ប្រដាប់នូវគ្រឿងអលង្កាមានតម្លៃ មួយសែនតម្លឹងឱ្យដល់ព្រះវេស្សន្តរពាក់លម្អព្រះកាយ តែព្រះវេស្សន្តរទ្រង់បានដោះគ្រឿងអលង្កាទាំងនោះឱ្យដល់ស្រីៗមេនំមេនាងអស់រហូតដល់ប្រាំបួនលើក។ ពេលដែលនគរកលិង្គរាស្ត្រកើតទុរភិក្សរាំងស្ងួត ប្រជារាស្ត្រមានការអត់ឃ្លានខ្លាំង បានទូលសុំដំរីបច្ច័យនាគេន្ទ្ររបស់ព្រះវេស្សន្តរ ដើម្បីយកទៅស្រោចស្រង់ក្នុងនគរ

---

[9] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០ទំព័រទី១០

របស់ខ្លួន ពេលនោះព្រះវេស្សន្តរក៏ទ្រង់ប្រទានដំរីមង្គល នេះដល់នគរកលិង្គរាស្ត្រភ្លាម ដោយគ្មានការរារែកឡើយ។

ដូចនេះយើងឃើញថាធនបរិច្ចាគរបស់ព្រះវេស្សន្តរ បានបំពេញដោយគ្មានការខ្វះចន្លោះ គឺពេញហូរហៀរដូចទឹកមហាសមុទ្រដែលគ្មានកោះត្រើយយ៉ាងនោះដែរ។ វិសាលភាពនៃការបំពេញទានដោយគ្មានទីបញ្ចប់ ក្នុងបំណងប្រាថ្នាត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធដែលមនុស្សផងទាំងឡាយមិនមាននរណាម្នាក់ធ្វើដូចព្រះអង្គឡើយ។

➤ **អង្គបរិច្ចាគ និងជីវិតបរិច្ចាគ** បញ្ហានេះ អ្នកនិពន្ធមិនបង្ហាញដោយផ្ទាល់ថា ព្រះអង្គបរិច្ចាគជីវិត គឺអង្គប្រាណរបស់ព្រះអង្គទេ។ ប៉ុន្តែទោះបីអ្នកនិពន្ធមិនបានបង្ហាញក៏ដោយ បើយើងវិភាគទៅលើដំណើររឿងទាំងមូល នឹងឃើញថាព្រះអង្គបានបំពេញរួចទៅហើយ ព្រោះទង្វើរបស់ព្រះអង្គគឺដើម្បីប្រាថ្នានូវការត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ព្រះអង្គបានលះបង់នូវអ្វីៗទាំងអស់ដែលស្មូមយាចកចង់បាន ព្រះអង្គនឹងប្រទានទាំងអស់។ បញ្ហានេះព្រះអង្គលះបង់នូវបុត្រជាទីស្រឡាញ់ លះបង់ភរិយាដ៏ឧត្តមដោយគ្មានអ្នកណាប្រដូចបានឡើយ។ បញ្ហាទាំងនេះប្រៀបដូចជាការកាត់ពន្លះអង្គប្រាណ របស់ព្រះអង្គទៅជាពីរបីកំណាត់រួចទៅហើយ នេះប្រសិនបើយើងវិភាគទៅលើចិត្តសាស្ត្ររបស់មនុស្សពិតប្រាកដ។ យ៉ាងណាមិញអ្វីៗទាំងអស់ដែលព្រះវេស្សន្តរហ៊ានបូជា ដើម្បីគោលបំណងឧត្តមគតិមួយគឺការបំពេញទានបារមី គឺឆ្ពោះទៅសម្រេចជាតួអង្គព្រះសម្មាសម្ពុទ្ធ ហេតុនេះព្រះអង្គពិតជាអាចបាននូវជីវិតបរិច្ចាគ និងអង្គបរិច្ចាគហើយប្រហែលជាងាយស្រួល ជាងការបំពេញបុត្រ ភរិយាបរិច្ចាគទៅទៀត ព្រោះថាបុត្របរិច្ចាគ ភរិយាបរិច្ចាគនេះ ព្រះវេស្សន្តរត្រូវគោរពតាមសន្តានចិត្តរបស់បុគ្គលខ្លួនគេដែរ បើបុត្រភរិយាមិនអនុមោទនាជាមួយទានរបស់ព្រះអង្គទេទ្រង់ក៏មិនបានសម្រេចគោលបំណងក្នុងការបំពេញទាននេះដែរ។

ម្យ៉ាងទៀត ចំពោះការបំពេញទាននេះឃើញថា ព្រះវេស្សន្តរហាក់ដូចជាបានចប់សព្វគ្រប់អស់ដែរទោះបីដំណើររឿងអ្នកនិពន្ធមិនបានបង្ហាញពីការបរិច្ចាគអង្គនិងជីវិតរបស់ព្រះអង្គពោធិសត្វយ៉ាងណាក៏ដោយ។

➤ **បុត្តបរិច្ចាគ** នេះជាមហាបរិច្ចាគដ៏ធំធេង ដែលមនុស្សធម្មតាមិនអាចធ្វើដូចបានទេ។ នៅលើលោកនេះតើមាន មាតាបិតាណាមួយដែលហ៊ានលះបង់បុត្ររបស់ខ្លួន ទៅឱ្យអ្នកដទៃនោះ ព្រោះថាគ្រប់មាតា បិតាទាំងអស់តែងតែមានព្រហ្មវិហារធម៌ ចំពោះកូនរបស់ខ្លួនជានិច្ច។ ឪពុកម្តាយតែងតែមានការបង់កម្លាំងកាយចិត្តរបស់ខ្លួនដើម្បីអនាគតកូនជានិច្ច។ ដោយឡែកក្រឡេកចំពោះព្រះវេស្សន្តរជាពោធិសត្វវិញ ទ្រង់មានតួនាទីបំពេញបុត្រទាន តើព្រះអង្គព្រះអង្គអាចគេចចេញពីនិស្ស័យជាមនុស្សធម្មតាឬទេ?

ក្នុងការបរិច្ចាគទានដ៏ធំធេងនេះ ព្រះវេស្សន្តរមានទឹកព្រះទ័យបានប្រែប្រួលជាងមុនស្ទើរតែពុំអាចបំពេញទានបាននៅចំពេលដែលព្រះអង្គឃើញសកម្មភាពឃោរឃៅរបស់ ជូជកដែលធ្វើមកលើបុត្ររបស់ខ្លួននោះ។ តែទោះជាយ៉ាងណា គេក៏ឃើញនូវលក្ខណៈរបស់ព្រះវេស្សន្តរ សភាពជាពោធិសត្វដែលកំពុងសាងបារមី។

➤ ***ភរិយាបរិច្ចាគ*** ការបរិច្ចាគទាននេះលេចវត្តមានឡើង នៅពេលដែលព្រះវេស្សន្តរបានបរិច្ចាគបុត្ររួចមក ដែលទាននេះមានលក្ខណៈតឹងតែងដែរ។ បើគ្មានទឹកព្រះទ័យរបស់ព្រះនាងមទ្រីយល់ដល់ព្រះទ័យរបស់ព្រះវេស្សន្តរទេនោះ គឺពិតជាធ្វើឱ្យព្រះអង្គពុំអាចបំពេញទានបានឡើយ។ ក្នុងពេលទឹកព្រះទ័យព្រះនាងមទ្រី មានវិសាលភាពធំធេងជាងមហាសមុទ្រទៅទៀត ដែលធ្វើឱ្យអានអ្នកទស្សនាមិននឹកស្មានដល់ព្រះទ័យរបស់ព្រះនាង ដែលអាចលះបង់នូវអ្វីៗទាំងអស់ដើម្បីជួយបំពេញគោលដៅដ៏ធំធេងរបស់ព្រះពោធិសត្វ។សមដូចនាងបានបញ្ជាក់ពីអារម្មណ៍របស់នាងថា « បពិត្រអម្ចាស់អើយ កុំថាតែព្រះអង្គ ឱ្យទានខ្ញុំទៅព្រាហ្មណ៍ចាស់ជរា ក្រែងអាក់អន់ចិត្ត ព្រះគុណអើយបើព្រាហ្មណ៍គាត់ប្រាថ្នាសាច់ ឈាម ថ្លើម ដង្ហើមប្រមាត់ ក៏សូមឱ្យស្ដេចយកព្រះខ័នកាត់ខ្ញុំមទ្រីនេះចេញបំពេញព្រះបារមីទាន..»។[10]

ដូចនេះព្រះវេស្សន្តរ បានយកនាងមទ្រីឱ្យទៅព្រាហ្មណ៍ធ្វើជាទានចុងក្រោយបំផុតនេះ គឺក្នុងពេលដែលព្រះអង្គគង់នៅភ្នំគិរីវង្កតនោះ ពុំមែនទ្រង់ធ្វើឡើងដោយការទាល់ច្រក ឬគ្មានមធ្យាបាយ និងបីបាច់ថែរក្សា ឬក៏គ្មានការពិចារណានោះទេ។ ផ្ទុយទៅវិញព្រះអង្គធ្វើឡើងប្រកបដោយវិចារណញាណខ្ពង់ខ្ពស់ ក្នុងគោលបំណងស្វែងរកនូវសម្មាសម្ពោធិញាណឆ្ពោះអនាគត។

សរុបមកឃើញថា ព្រះវេស្សន្តរជាតួអង្គពោធិសត្វ ដែលបានបំពេញទានបារមី ដើម្បីត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធយ៉ាងពិតប្រាកដក្នុងបំណងជួយសង្គ្រោះសត្វលោកគ្រប់ប្រភេទ។ ការបំពេញទានបារមីនេះ មានលក្ខណៈអស្ចារ្យដែលមនុស្សធម្មតាមិនអាចធ្វើបានឡើយ។

### ខ.២- មូលបញ្ហារឿង

តាមរយៈការបង្ហាញពីមហាបរិច្ចាគទាំង៥ឃើញថា មនុស្សធម្មតាពិតជាពុំអាចធ្វើទៅបានឡើយ។ ដូចនេះបញ្ហាសំខាន់បំផុតក្នុងស្នាដៃនេះ វាស្ថិតនៅត្រង់ថា តើព្រះវេស្សន្តរអាចសម្រេចបំពេញទាននេះបានដោយរបៀបណា?

ការបរិច្ចាគទាំងនោះ មិនមែនជាការងារធម្មតាចំពោះព្រះអង្គនោះទេ គឺស្ថិតក្នុងដំណាក់ការតស៊ូព្យាយាមអត់ធ្មត់ដ៏លើសលុប។ សមដូចដំណើររឿងបានបង្ហាញឱ្យឃើញថា ទោះបីព្រះអង្គមានព្រះទ័យជ្រះថ្លាក្នុងការបំពេញទានបារមីយ៉ាងណាក៏ដោយ ក៏ការបំពេញទាននោះមិនមែនជាការងារធម្មតាចំពោះព្រះអង្គឡើយ ព្រោះពេលដែលព្រះអង្គបំពេញទានបារមីនោះទ្រង់ស្ថិតជា**«មនុស្ស»** ពោលគឺមិនទាន់ក្លាយជាព្រះនៅឡើយទេ។

យ៉ាងនេះហើយ ទើបតាមរយៈទានបារមីនេះ យើងអាចបំផុសបានបញ្ហាចោទសំខាន់ៗដូចតទៅ៖

**➤ បញ្ហាបុគ្គល និងកម្លាំងប្រជាធិប្បតេយ្យ**

ទោះបីព្រះវេស្សន្តរ កើតមកក្នុងត្រកូលក្សត្រ ឬក៏ក្នុងគំនរទ្រព្យសម្បត្តិ ងាយស្រួល ក្នុង

[10] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០ទំព័រទី១៩

ការបំពេញទានក៏ដោយ ក៏ព្រះអង្គត្រូវជួបប្រទះបញ្ហាមួយសំខាន់ក្នុងសង្គមមនុស្ស គឺការ«មិនយល់ស្របពីសំណាក់ប្រជារាស្ត្រ»។

តាមដំណើររឿង យើងឃើញថាអ្នកនគរស្រីពិរាស្ត្រ គេមិនទាន់យល់ពីការដាក់ទាននោះទេ ហើយការដែលព្រះវេស្សន្តរ បរិច្ចាគទ្រព្យធនរបស់ប្រទេសជាតិ ដោយមិនទាន់បានពន្យល់ដល់មហាជននោះ ព្រះអង្គត្រូវតែជួបឧបសគ្គដែលជា«មតិប្រជាធិប្បតេយ្យ»នេះដោយ ខានពុំបាន។ ដូចនេះហើយ ទើបពេលដែលព្រះអង្គប្រទានដំរីមង្គលឈ្មោះ បច្ច័យនាគេន្ទ្រ ឱ្យទៅពួកព្រាហ្មណ៍នៅស្រុកកលិង្គរាស្ត្រ ព្រះអង្គត្រូវអ្នកស្រីពិរាស្ត្របះបោរបណ្តេញពីនគរ។

➤ **បញ្ហា បុគ្គលនិងព្រហ្មវិហារធម៌**

ជាការពិតណាស់ ដែលព្រះវេស្សន្តរបានធ្វើការបរិច្ចាគដោយគ្មានរួញរាសូម្បីតែពេល ត្រូវគេបំបរបង់ហើយក៏នៅតែហ៊ានលះបង់គ្មានស្តាយស្រណោះដែរ។ តួយ៉ាងតាមផ្លូវទៅភ្នំគិរីវង្កត ព្រះអង្គបានដាក់ទានអាជានេយ្យទាំង៤ ព្រមទាំងរាជរថទៅពួកព្រាហ្មណ៍ ហើយចែកកូនគ្នាពធ្វើដំណើរដោយជើង។

ប៉ុន្តែប្រការមួយដែលមនុស្សធម្មតា រហូតដល់ព្រះពោធិសត្វ ពិតជាពុំអាចជៀសផុតបានគឺមនោសញ្ចេតនា ជាព្រហ្មវិហារធម៌របស់ឪពុកនិងកូន។ ព្រះអង្គអាចដាក់ទាន វត្ថុគ្មានវិញ្ញាណដោយគ្មានអង្គើចិត្តតែព្រះអង្គត្រូវតែខ្លោចចិត្ត អាណិតបុត្រពេលដែលដាក់ទានបុត្រឱ្យទៅព្រាហ្មណ៍បូស្សា ហើយឮវាចាត្អូញត្អែរយំយែកពីការឈឺចាប់របស់បុត្រ។

ដូចនេះហើយ ទើបព្រះអង្គស្ទើរតែប្រហារតាជូជកចោលទៅហើយ។ នេះមិនមែនជាឥទ្ធិពលនៃកំហឹងបុគ្គលទេ តែវាជាការជំរុញនៃព្រហ្មវិហារធម៌។

➤ **បញ្ហាបុគ្គល និងប្រយោជន៍ដទៃ**

បើនិយាយដលសម័យកាលនោះ ការចំណាយទ្រព្យធនរបស់ព្រះវេស្សន្តរពុំអាចចាត់ទុកថា ជាការប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជនឡើយ។ មួយវិញទៀត បើតាមដំណើររឿងដំរីបច្ច័យនាគេន្ទ្រ គឺជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ ជាអំណោយរបស់មេដំរីស្វេគិ ដែលហោះនាំមកថ្វាយ។ ដូចនេះហើយទើបព្រះអង្គ មិននឹកនាដល់ការប្រឆាំងពីអ្នកស្រីពិរាស្ត្រ។ លុះពេលដែលត្រូវគេបណ្តេញ ទើបព្រះអង្គយល់ពីបញ្ហានេះ ហើយសុខចិត្តចាកចោលនគរដោយគ្មានការប្រកែក។ ប្រការនេះហើយ ទើបនាំឱ្យព្រះវេស្សន្តរតែងតែស្វាបស្ទង់ឬអង្វករអ្នកដែលទាក់ទងដល់ផលប្រយោជន៍នៃទានរបស់ព្រះអង្គជានិច្ច។ ដូចជាធ្វើបុត្តបរិច្ចាគ ព្រះអង្គបានអង្វរនិងពន្យល់ហេតុផលពីការធ្វើទាននេះដល់បុត្រទាំងពីរថា«ក្រស្នាអើយ ធម្មតាជាកូនរែងដោយតាមពាក្យឪពុក នាងឯងស្មើសំពៅមាសចិញ្ចែង ឥតក្រែងកណ្តាលប្រវាលសមុទ្រសង្សារជ្រៅកន្លង សម្រាប់ចម្លងដាក់ដល់ត្រើយ ពោលគឺព្រះនិព្វាន ឪពុកនេះនឹងចម្លងអស់សត្វនិករអមរ

នូវទេវតា ឥន្ទ្រព្រហ្ម បន្សុំស្រមូលទៅឮដំនិព្វានអស់ហោង»។[11]ក្រោយពីបានស្តាប់ពាក្យទូន្មាន នេះរួចមក រាជបុត្រទាំងពីរក៏យល់ព្រមដោយខ្លួនឯង។ រីឯភរិយាបរិច្ចាគវិញ ក៏ទ្រង់មិនបង្ខំព្រះនាងមទ្រីដែរដោយព្រះអង្គលួចចោលកន្ទុយភ្នែក ដើម្បីស្ទាបស្ទង់ចិត្តព្រះនាងមទ្រីជាមុនៗនឹងសម្រេចព្រះទ័យធ្វើទានឱ្យទៅឥន្ទ្រព្រាហ្មណ៍ដែរ «...យល់ជានាងនឹងធ្លាក់ថ្លោះពុំពេញព្រះរាជហឫទ័យធម្មតាវិស័យចិត្តលោកិយផងទាំងឡាយពុំដែលចៀសឆ្ងាយពីគ្នាទើបសម្តេចព្រះបរមរាជា ស្តេចឆ្មៀងព្រះនេត្រទតមើលព្រះអគ្គមហេសីឱ្យបានជ្រាបអាការកិរិយា។ឯព្រះនាងក៏ដឹងក្នុងប្រាជ្ញាអធ្យាស្រ័យ ដឹងក្នុងព្រះរាជហឫទ័យស្វាមី ទើបព្រះនាងលើកអញ្ជលី អភិវាទក្រាបបង្គំទូលថា បពិត្រអម្ចាស់អើយ កុំថាតែព្រះអង្គ ឱ្យទានខ្ញុំទៅព្រាហ្មណ៍ចាស់ជរា ក្រែងអាក់អន់ចិត្ត ព្រះគុណអើយបើព្រហ្មណ៍គាត់ប្រាថ្នាសាច់ឈាម ថ្លើម ដង្ហើម ប្រមាត់ក៏សូមឱ្យស្តេចយកព្រះខ័នកាត់ខ្ញុំមទ្រីនេះចេញបំពេញព្រះបារមីទាន ... ខ្ញុំមទ្រីពុំមានចិត្តរួញរា នឹងសុំយកអាសាស្នងព្រះតេជះគុណ ដរាបលុះអស់ជីវិត សូមជួយបំពេញព្រះបារមីទាន សូមឱ្យព្រះអង្គបានត្រាស់ជាព្រះពុទ្ធ នាំសត្វចូលព្រះនិព្វាន បានដូចសេចក្តីប្រាថ្នា នាអនាគតកាលទៅហោង។[12]

និយាយរួមការបរិច្ចាគតាមបែបរឿង ព្រះវេស្សន្តរគឺការបរិច្ចាគ ដ៏តឹងតែជាទីបំផុតដែលមនុស្សសាមញ្ញប្រាកដជាមិនអាចធ្វើបាន មានតែព្រះវេស្សន្តរ ទើបអាចសម្រេចបាន។

**គ- ទំនាស់**

➤ទំនាស់ទី១

•**រឿងទំនាស់** : ការប្រទានដំរីបច្ច័យនាគេន្ទ្រឱ្យព្រាហ្មណ៍ស្រុកកលិង្គរាស្ត្រ

•**គូទំនាស់** : ព្រះវេស្សន្តរ ❮➤អ្នកស្រុកស្រីពិរាស្ត្រ

ទឹកព្រះទ័យរបស់ព្រះវេស្សន្តរ ដែលមានលេចចេញតាំងពីប្រសូត បានបង្ហាញឱ្យអ្នកផងទាំងពួងដឹងយ៉ាងច្បាស់ថា ព្រះអង្គជាបុគ្គលដែលមានព្រះទ័យទូលាយក្នុងការឱ្យទាន តែការធ្វើទានដំរីបច្ច័យនាគេន្ទ្រនេះ បានបង្កើតជាបញ្ហាស្មុគ្រស្មាញ ជាហេតុបណ្តាលឱ្យមានការបំបរបង់ព្រះអង្គចេញពីនគរ។ នេះជាសកម្មភាពការធ្វើទានរបស់ព្រះវេស្សន្តរ ដែលជាព្រះរាជទ្រព្យផ្ទាល់ខ្លួនសម្រាប់សាងបារមីក្នុងការសម្រេចសម្មាសម្ពោធិញាណ។

ព្រះអង្គជាតួអង្គកសាងបារមី កាលបើមានឱកាសនោះព្រះអង្គត្រូវតែកសាងភ្លាម។ ការប្រទានដំរីនេះ ចាត់ទុកជាការសង្គ្រោះចំពោះមនុស្សជាតិមួយដ៏សំខាន់ ឱ្យរួចផុតពីគ្រោះអន្តរាយដល់អាយុជីវិតដោយគ្រោះទុរភិក្ស គឺគ្មានភ្លៀងធ្លាក់សោះ។ ដោយហេតុនេះហើយ ទើបព្រះចៅកលិង្គរាស្ត្របានចាត់ឱ្យអាមាត្យឱ្យក្លែងខ្លួនជាព្រាហ្មណ៍៨នាក់ទៅសុំដំរីបច្ច័យនាគេន្ទ្រ

[11] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០ទំព័រទី១៩ទំព័រទី៣៥.៣៥

[12] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០ទំព័រទី១៩ទំព័រទី៣៥.៣៥ទំព័រទី១៨.១៩

ពីព្រះវេស្សន្តរឱ្យចូលមកប្រទេសរបស់ខ្លួន។ ទឹកភ្លៀង គឺជាបញ្ហាធំបំផុតរបស់មនុស្សជាតិ បើគ្មានភ្លៀងធ្លាក់ទេ នោះផលដំណាំត្រូវខូចខាតអន្តរាយ ហើយមានបញ្ហាផ្សេងៗ ទៀតដូចជាគ្រោះអត់ឃ្លាន ជំងឺរាតត្បាតដល់ជីវិតមនុស្ស សត្វគ្រប់ប្រភេទ នឹងកើតមានជាមិនខាន។ យ៉ាងណាមិញ ប្រទេសឥណ្ឌាបញ្ហាទឹកភ្លៀងមានសារៈសំខាន ព្រោះបើគ្មានទឹកភ្លៀងនាំជីវិតមនុស្សស្លាប់រាប់លាននាក់។ ព្រះវេស្សន្តរ មានកំណើតជាជនជាតិឥណ្ឌានៅសម័យបុរាណ ដែលទ្រង់ក៏ជួបប្រទះបញ្ហានេះ ដែលជាហេតុនាំឱ្យព្រះអង្គប្រឹងដោះស្រាយបញ្ហាអាយុជីវិតនៃមនុស្សជាតិឱ្យទាន់ពេលវេលា គឺត្រូវប្រទានដំរីមង្គលដល់អ្នកស្រុកកលិង្គរាស្ត្រ ដើម្បីឱ្យមានភ្លៀងប្រើប្រាស់គ្រប់វិស័យ។

ប៉ុន្តែក្នុងដំណើររឿងឃើញថា ធ្វើទានដំរីនេះបុគ្គលខ្លះយល់ថា គឺជាកំហុសមួយយ៉ាងធំរបស់ព្រះអង្គ ទោះបីដំរីនេះជាព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គក៏ដោយ ក៏ព្រះអង្គមិនត្រូវសម្រេចព្រះទ័យប្រទានទៅឱ្យប្រទេសដទៃដែរ ព្រះអង្គត្រូវរក្សាទុកដំរីនេះក្នុងប្រទេសរបស់ខ្លួន ព្រោះជាដំរីមង្គលសម្រាប់សេចក្តីចម្រើនប្រទេសទាំងមូល។ តាមជំនឿរបស់រាស្ត្រសម័យនោះ គេជឿថាព្រោះដំរីមង្គលទៅដល់ទីណា ទីនោះពិតជាមានភ្លៀងធ្លាក់ជាមិនខាន។ មិនតែប៉ុណ្ណោះ កាលបើគេសុបិននិមិត្តឃើញមានដំរី គេជឿថាមិនយូរទេ នឹងមានភ្លៀងធ្លាក់ជាមិនខាន។

ហេតុដូចនេះហើយ បើព្រះវេស្សន្តរប្រទានដំរីមង្គលនេះទៅស្រុកដទៃទៅហើយ តើអ្នករស់នៅក្នុងព្រះនគរទ្រង់ បានទឹកពីណាមកប្រើប្រាស់ ហើយអាយុជីវិតប្រទេសជាតិទាំងមូលទៅជាយ៉ាងណាដែរ?

បញ្ហានេះហើយ ដែលធ្វើឱ្យប្រជារាស្ត្រក្នុងនគរគឺអ្នកស្រុកស្រីពិរាស្ត្រ មានកំហឹងយ៉ាងខ្លាំង ទើបសំណូមពរឱ្យព្រះបាទស្រីសញ្ជ័យបំបរបង់ព្រះវេស្សន្តរចេញពីនគរ។ បើសិនជាឆ្លុះតាមព្រះទ័យរបស់ព្រះអង្គ អាចឱ្យគេយល់ថា ទាននេះគឺជាការសង្គ្រោះចំពោះមនុស្សជាតិ ដោះស្រាយបញ្ហាការរស់នៅរបស់មនុស្សដែលត្រូវកម្លាំងធម្មជាតិគាបសង្កត់។ ដូចក្នុងដំណើររឿងបានបញ្ជាក់ថា «រីអស់អ្នកនគរផងទាំងឡាយ ហេតុតែទេវតាតាមអាភៀសនោះមិញណាក៏សឹងតែខឹងនឹងព្រះពោធិសត្វនោះមហិមាក្រៃពេក ហើយបបួលគ្នាទៅជំនុំនៅនាមុខព្រលានស្រដីនូវពាក្យនោះភងរំពងឮទៅដល់នាកណ្តាល់អាកាស» យ៉ាងនេះទៅវិញ។ ដូច្នេះ ការដែលព្រះវេស្សន្តរបានដាក់ទានដំរីឱ្យទៅអ្នកនគរកលិង្គរាស្ត្រនោះ ពួកអ្នកស្រីពិរាស្ត្រ ឥតមានតូចចិត្តទោមនស្សខឹងចំពោះព្រះវេស្សន្តរបានឡើយ តែដោយហេតុមានការអាភៀសបញ្ចូលចិត្តក៏បណ្តាលឱ្យពួកអ្នកនគរដែលធ្លាប់រស់ដោយសារដំរីនោះ បែរជាមិនសប្បាយចិត្តនឹងព្រះអង្គ ហើយថែមទាំងក៏នាំគ្នាសុំឱ្យព្រះបាទស្រីសញ្ជ័យបំបរបង់ព្រះវេស្សន្តរចេញពីនគរទៅវិញ។

ដូច្នេះទំនាស់នេះបណ្តាលមកពីពួកទេវតា ដែលមានភារកិច្ចជួយជ្រោមជ្រែងដល់ព្រះវេស្សន្តរក្នុងការបំពេញទានបារមីឱ្យកាន់តែខ្លាំងឡើង ដែលនាំឱ្យព្រះអង្គឈានទៅបំពេញ

សត្តសតកមហាទានថែមទៀតផង។ ចំណែកការយាងទៅភ្នំគិរីវង្កតនោះ ព្រះអង្គកាន់តែមានឱកាសក្នុងការបំពេញទានបន្ថែមទៀតដើម្បីស្រោចស្រង់ជីវិតមនុស្សឱ្យរួចផុតពីគ្រោះអន្តរាយ

➤ទំនាស់ទី២

•**រឿងទំនាស់** : ការបដិសេធមិនព្រមទទួលរាជសម្បត្តិពីពួកក្សត្រចេតរាស្ត្រ

•**គូទំនាស់** : ព្រះវេស្សន្តរ ◀▶ ពួកចេតរាស្ត្រក្សត្រ

ពេលដែលត្រូវបំបរបង់ទៅនៅភ្នំគិរីវង្កត មុនពេលដល់ទីនោះ ក្រុមគ្រួសារព្រះវេស្សន្តរបានឆ្លងកាត់ដែនចេតរាស្ត្រជាក្សត្រចំណុះព្រះវេស្សន្តរ បានស្នើសុំព្រះអង្គឱ្យគ្រងរាជនៅទីនោះ។ យើងដឹងហើយថារាជបល្ល័ង្គជាទីស្ថានមួយដ៏ខ្ពង់ខ្ពស់ ដែលមនុស្សគ្រប់គ្នាតែងត្រូវការណាស់។ តែផ្ទុយទៅវិញព្រះវេស្សន្តរ ទ្រង់បដិសេធមិនព្រមទទួលទៅតាមសំណូមពរនេះឡើយ។ កាយវិការនេះយើងគួរលើកមកពិចារណាថា តើមូលហេតុអ្វីបានជាទ្រង់ប្រកែក។ ចំពោះសំណើរនេះយើងអាចពិចារណាថា អ្នកចេតរាស្ត្រជានគរចំណុះ នគរជេតុត្តរ ហើយការស្នើសុំគ្រាន់តែជាពាក្យគួរសមប៉ុណ្ណោះទើបព្រះវេស្សន្តរទ្រង់មិនព្រមទទួល។

ម៉្យាងទៀតព្រះអង្គមាន ការធុញទ្រាន់នឹងរាជសម្បត្តិទៅហើយ នេះជាមូលហេតុមួយសមហេតុផលដែរ ប៉ុន្តែបើយើងយកចិត្តមនុស្សមកវិភាគវិញ ឃើញថាមានលក្ខណៈផ្ទុយស្រឡះទៅវិញព្រោះជាចំណែកក្នុងការចង់បានទ្រព្យសម្បត្តិ អំណាច កិត្តិយស គឺមិនចេះឆ្អែតឆ្អន់ទេចំពោះមនុស្ស។

ក្នុងផ្ទៃរឿងទាំងមូលបង្ហាញថា នៅពេលដែលអ្នកស្រុកចេតរាស្ត្របានជួបព្រះវេស្សន្តរហើយ លុះក្រោយមកពេលដែលព្រះអង្គ បានរៀបរាប់រឿងរ៉ាវសព្វគ្រប់ ទាំងអស់គ្នាកើតចិត្តសង្វេគអាណិតព្រះអង្គហើយបានស្រុះស្រួលអញ្ជើញព្រះអង្គថា «សូមព្រះអង្គគ្រងរាជសម្បត្តិនៃនគរយើងនេះសឹងមានស្តេចចេតរាស្ត្រទាំងឡាយចោមរោមរាជាបរិវារ មួយសោតដែនចេតរាស្ត្រនេះធំទូលាយស្តុកស្តម្ភសម្បូរ បពិត្រថ្លៃប្រសើរអើយ សូមព្រះអង្គទទួលដើម្បីគ្រប់គ្រងរាជសម្បត្តិជាឥស្សរនៃយើងខ្ញុំហោង» ។

ព្រះអង្គមិនព្រមយល់ស្របពាក្យទាំងនេះឆ្លើយថា «បើយើងសោយរាជសម្បត្តិនានគរនេះហើយសមអ្នកស្រីពិរាស្តផងទាំងឡាយ គេនឹងបរពលសកលយោធាសេនាមាត្រ លើកទ័ពមីរដេរដាសដោយពេញទាំងក្រឡាមហាប្រថពី ខ្មីឃ្មាតសង្វាតមកចោមរោម មាតុលនគរនេះប្រាកដមិនទេឡើយហៃសំឡាញ់អើយម្ល៉ោះហើយវានឹងកើតជាកោឡាហលអំពើនូវចម្បាំងរាំងជល់ប្រកាប់ប្រចាក់គ្នា ឬអស់មនុស្សម្នាមហាជនផងទាំងឡាយ នោះសឹងស្លាប់ច្រើនពុំខានឡើយ ហេតុនោះហោង វាមិនកើតមកអំពីអ្នកណាឡើយវាកើតត្បិតយើងមកសោយរាជសម្បត្តិនៅទីនេះឯង ហេតុនេះយើងមិនទទួលឡើយ»។

សេចក្តីខាងលើនេះបានបញ្ជាក់ថា ព្រះមហាក្សត្រចេតរាស្ត្រ មានភក្តីភាពចំពោះព្រះវេស្សន្តរមែនប៉ុន្តែព្រះអង្គមិនព្រមទទួល ព្រះអង្គទ្រង់យល់ឃើញ ថានឹងកើតហេតុមិនល្អទេ

រវាងអ្នកមាតុលនគរ និងអ្នកស្រុកស្រីពិរាស្ត្រ ព្រោះតែព្រះអង្គ ទទួលរាជសម្បត្តិនេះ ជាគុណធម៌ដែល កម្រមានមនុស្សណាធ្វើដូចបានឡើយ។

រួមសេចក្តីមក រាជសម្បត្តិនៅមាតុលនគរ ដែលក្សត្រចេតរាស្ត្រចំនួន៦ម៉ឺននាក់បានអញ្ជើញនោះពុំមែនជាចំណុចធំរបស់ព្រះអង្គឡើយ គោលដៅដ៏ធំបំផុតនោះគឺឆ្ពោះទៅភ្នំគិរីវង្កត ដើម្បីសាងបាមីគឺនេក្ខមបារមី (ការបួស)។

➤**ទំនាស់ទី៣**

•**រឿងទំនាស់** : ការធ្វើបុត្តបរិច្ចាគ

•**គូទំនាស់** : ជូជក ◀▶ព្រះវេស្សន្តរ

កណ្ឌតាជូជក ហាក់ដូចជារឿងកំប្លែងមួយដាច់ដោយឡែកពីសាច់រឿងធំៗឯទៀតតែបើយើងធ្វើការពិនិត្យលើឧបកថាវិធីរបស់អ្នកនិពន្ធដែលលើកយកបញ្ហាតាជូជក យកមកពិចារណាឱ្យហ្មត់ចត់ទៅមានសារៈសំខាន់ដូចតទៅៈ

រឿងជូជក មិនមែនដាច់ចេញពីរឿងព្រះវេស្សន្តរ ដែលជាតម្លៃមនុស្សក្នុងសង្គមនោះទេ។ តួអង្គតាជូជកមានសារៈសំខាន់ណាស់សម្រាប់ការពិចារណាដោយអ្នកនិពន្ធបានពណ៌នាអំពីតួអង្គ និងជីវភាពច្បាស់លាស់ថា «មានជូជកម្នាក់ឈ្មោះជូជកព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមស្រដោង ច្រមុះកោងទ្រូងសឹងតែឆ្អឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ដំបារត្រចៀកយុយារក្រាស់ដូចឃ្នង់ភ្លើង ជើងកោងដូចជើងសេក ភ្នែកស្រលៀងស្រលី សាច់ពកដូចគេធ្វើរដិបរដុបយុយារ ប៉ុនផ្លែស្រម៉ ធ្មេញស ក្បាលវែងតូចដូចផ្លែញ្ញៅ»។

រីឯជីវភាពគាត់វិញ «គាត់ដើរសុំតែគេធីដោយសព្វជើងជណ្តើរ គាត់សុំទាំងត្រីឆ្អើ ត្រីងៀត ត្រីប្រៃស្លឹកគ្រៃ ខ្ទឹម ម្រេច អំបិល ក្រសាំង អំពិលពុំឱ្យសល់ដល់មួយមុខឡើយ។ គាត់សូមបានមកស្រេចហើយគាត់សន្សំច្រកទុក ក្នុងថង់យាមធំ គាត់ដើររកសូមគ្រប់ទីផ្សារផ្សោគ្រប់ស្រុក សុំទាំងប្រហុក ផ្អក ម៉ាំ សន្សំច្រកទុកក្នុងឆ្នាំង សុំទាំងម្លូស្លា ស្លាផ្កាកំបោរថ្នាំតាមចិត្តនឹកសុំទាំងផ្លូវទឹកផ្លូវគោក»។

លក្ខណៈនៃការពិពណ៌នានេះ បញ្ជាក់ឱ្យឃើញថា លក្ខណៈពីរយ៉ាងគឺ តាជូជកជាតួអង្គកំប្លែងមានរូបកាយប្លែក ជារូបរាងធម្មជាតិបានតាក់តែងមក។ ម្យ៉ាងទៀតរូបរាងបែបនេះគិតទៅគួរឱ្យសង្វេគទៅវិញ។ តាជូជកជាមនុស្សឯកោគ្មានទីពុំនាក់ ព្រោះគ្មានសាច់ញាតិបងប្អូនទេ គាត់បានដើរសុំទានគេយកមកធ្វើព្រាហ្មណ៍ប្តីប្រពន្ធជាសម្លាញ់។ ក្នុងការទាក់ទងគ្នានេះបានធ្វើឱ្យគាត់យកអមិត្តតាបនាធ្វើជាភរិយាជំនួសវិញ។ នៅពេលដែលតាជូជកមានវ័យជរារូបកាន់តែអាក្រក់ ហើយភរិយាមានវ័យក្មេង រូបសម្ផស្សស្រស់ស្អាតនោះ បានបណ្តាលឱ្យចិត្តអ្នកអានមានការប្លែកអារម្មណ៍និងសរសើរ គាត់ជាមនុស្សចាស់បានភរិយាក្មេង។ តែខ្លះក៏មានការមិនពេញចិត្តដែរ ដោយគាត់នៅល្មោភក្នុងផ្លូវកាមទាំងវ័យជរា។

ប៉ុន្តែនៅក្នុងសាច់រឿង តាជូជកមានប្រាជ្ញា ឆ្លាតវ័យចំណាស់ ប៉ិនប្រសប់ក្នុងការនិយាយ

បញ្ចុះបញ្ចូលព្រាហ្មណ៍ជាសម្លាញ់គាត់ថាគឺ «គាត់នឹងប្ដឹងចៅក្រមតុលាការ បើគាត់មានស្គាល់ចៅក្រមសាលាជាបក្សពួករបស់គាត់ គាត់នឹងឱ្យគេចាប់ដាក់គុកខ្នោះខ្នាង ឱ្យភ្នាក់ងាទាហានចាប់ចងវាយដំបែកឈាម»។ ពេលចេតបុត្តបានសំឡុតគំរាមបម្រុងនឹងបាញ់សម្លាប់គាត់ គាត់ក៏ប្រើថ្វីមាត់កុហកថា ខ្លួនជារាជគ្រូក្នុងព្រះបរមរាជវាំងជេតុត្តរនគរ ត្រូវព្រះបាទស្រីសញ្ជ័យបញ្ជូនមកក្នុងនាមជារាជទូត ដើម្បីសួរសុខទុក្ខនិងអញ្ជើញព្រះវេស្សន្តរទៅសោយរាជ្យវិញ។ ពេលបានជួបនឹងព្រះវេស្សន្តរបាននិយាយសរសើរយលើកជើងយ៉ាងច្រើន ជាគ្រឿងបន្ទន់ចិត្តដើម្បីសុំជាលី និងក្រឹស្នា។ ដូចនេះតួអង្គតាជូជកមានលក្ខណៈសំខាន់ជាច្រើនដូចជាៈ

ជាការបន្ធូរបរិយាកាសនៃអ្នកអាន អ្នកទស្សនាទាំងឡាយ ក្នុងខណៈពេលដែលមានការសោកសង្រេងជាមួយព្រះវេស្សន្តរកាលយាងទៅភ្នំគិរីវង្កតយ៉ាងអណោចអធម។កណ្ឌខាងដើមពុំធ្វើឱ្យអ្នកអានអ្នកទស្សនាបានសើចសប្បាយរីករាយទេ តែការអស្ចារ្យនៃការធ្វើទាននិងការទុក្ខព្រួយ ទំនាស់រវាងព្រះវេស្សន្តរនឹងអ្នកស្រីពិរាស្ត្រឥតធូរស្រាលឡើយ។ ការព្រាត់ប្រាស់មានទុក្ខវេទនានាំអ្នកអានកាន់តែមានការចង្អៀតចង្អល់ចិត្តតែពេលដល់កណ្ឌតាជូជកនេះភ្លាមក៏ភ្លេចរឿងចាស់អស់ហើយចាប់អារម្មណ៍រឿងថ្មីនេះវិញ។

កណ្ឌជូជកគឺជាស្ពានចម្លងអ្នកអាន អ្នកទស្សនា ឱ្យឃើញព្រះវេស្សន្តរគង់នៅព្រៃស្ងាត់ជាមួយមហេសីនិងបុត្រក្នុងជីវភាពរស់នៅ។

អ្នកនិពន្ធបានលើកយកតួអង្គតាជូជក មានការទំនាក់ទំនងជាមួយព្រះវេស្សន្តរ ដើម្បីបង្ហាញថាព្រះវេស្សន្តរមហាបុរសមានព្រះទ័យទូលាយក្នុងការឱ្យទានទាំងផ្លូវកាយនិងផ្លូវចិត្ត។

តួអង្គតាជូជក ជាតួអង្គដ៏សំខាន់ក្នុងការបំពេញទានបារមីរបស់ព្រះវេស្សន្តរ គឺការសុំជាលី និងក្រឹស្នាដែលធ្វើឱ្យព្រះវេស្សន្តរ ធ្វើបុត្របរិច្ចាគតាមព្រះរាជបំណងបាន។

ដូច្នេះតួអង្គតាជូជកមានសារៈសំខាន់ណាស់ ដែលធ្វើឱ្យសាច់រឿងមានសកម្មភាពរស់រវើកនិងមានលក្ខណៈលោកិយសច្ចៈផង ពីព្រោះថាអ្នកនិពន្ធចេះពិពណ៌នាលកខណៈតួអង្គនេះច្បាស់លាស់ទាំងរូបកាយ វីរភាពសកម្មភាពនានា ពោលគឺលើកយកតួអង្គដែលអាក្រក់ឱ្យមានសំណើចនិងកើតចិត្តសង្វេគ ជាពិសេសនោះ គឺជួយសម្រេចការបំពេញទានរបស់ព្រះវេស្សន្តរផង។

➤ **ទំនាស់ទី៤**

- **រឿងទំនាស់** : ការធ្វើកិរិយាបរិច្ចាគ
- **គូទំនាស់** : មទ្រី ◄► ព្រះវេស្សន្តរ

ស្ត្រីក្នុងអក្សរសិល្ប៍ខ្មែរ មាននាទីជាអ្នកបម្រើឧត្តមគតិសង្គម។ យ៉ាងណាមិញតួអង្គស្ត្រីនៅក្នុងរឿងព្រះវេស្សន្តរ ជាអ្នកមានលក្ខណៈនិងគុណសម្បត្តិល្អប្លែក និងជានិមិត្តរូបនៃសេចក្ដីល្អនៅក្នុងសង្គមជាតិ។ ព្រះនាងមទ្រី ជាកន្សែសារពេជ្ជក្នុងពុទ្ធនិយមនៃព្រះពោធិសត្វដែលជាកំពូលស្ត្រីប្រកបដោយគុណធម៌។

មួយជីវិតរបស់ព្រះនាងកសាងតែអំពើល្អក្នុងគ្រួសារ គឺការមើលថែរក្សាបុត្រ និងបម្រើស្វាមីយ៉ាងស្មោះស្ម័គ្រ។ ហេតុនេះហើយ បានជានាងទាមទារយាងចេញទៅតាមព្រះវេស្សន្តរ ក្នុងពេលដែលស្វាមីត្រូវអ្នកស្រុកស្រីពិរាស្ត្របំបរបង់ចេញពីនគរ ទោះបីព្រះនាងសុបារសុប្បតី និងព្រះបាទស្រីសញ្ជ័យ មិនចង់ឱ្យនាងចេញទៅតាមក៏ដោយ។ ជាក់ស្តែងព្រះនាងបានទូលប្រៀបធៀបថា«ទន្លេគ្មានទឹក ហៅទន្លេអាក្រាត ដែនគ្មានស្តេច ហៅដែនអាក្រាត ស្រីមេម៉ាយ ហៅស្រីអាក្រាត»។ គុណធម៌ដ៏ជ្រាលជ្រៅរបស់ព្រះនាង បានញ៉ាំងឱ្យមនោសញ្ចេតនាជស្វាមីភរិយារបស់ព្រះវេស្សន្តរ មានការលំបាកសម្រេចចិត្តក្នុងការធ្វើភរិយាបរិច្ចាគ ឱ្យទៅឥន្រ្ទព្រាហ្មណ៍។ហេតុនេះហើយបានជាព្រះអង្គ «...នាកាលសម្តេចព្រះវេស្សន្តរបវរពុទ្ធង្កុរ ព្រះអង្គព្រះរាជទានព្រះមទ្រី ឱ្យទៅជីចាស់ជរា ទ្រង់ព្រះចិន្តាគិតបារម្ភ ត្បិតពុំសមសេចក្តី ក្រែងពុំត្រូវព្រះរាជហឫទ័យនៃព្រះអគ្គជាយានឹងរួញរាចុចថយសទ្ធា បណ្តាលឱ្យកើតទុក្ខសោកា តាមធម្មតាប្រពៃណីលោកិយ បើក្រមុំកំលោះនោះ ទើបសមនឹងគ្នា ឥឡូវនេះនាងបានទៅព្រាហ្មណ៍ចាស់ជរាព្រឹទ្ធាចារ្យជាមនុស្សអន្ធការ ហិនទ្រព្យអាប់យសសក្តិ យល់ជានាងនឹងធ្លាក់ថ្លោះពុំពេញព្រះហឫទ័យ ធម្មតាវិស័យចិត្តលោកិយផងទាំងឡាយ ពុំដែលចៀសឆ្ងាយពីគ្នា ទើបសម្តេចព្រះបរមរាជាស្តេចឆ្មៀងព្រះនេត្រទតមើលព្រះអគ្គមហេសីឱ្យបានជ្រាបអាការកិរិយា»។ដោយនាងយល់ពីបំណងព្រះស្វាមីបែបនេះហើយទើបនាង«បពិត្រអម្ចាស់អើយ កុំថាតែព្រះអង្គ ឱ្យទានខ្ញុំទៅព្រាហ្មណ៍ចាស់ជរា ក្រែងអាក់អន់ចិត្ត ព្រះគុណអើយបើព្រាហ្មណ៍គាត់ប្រាថ្នាសាច់ ឈាម ថ្លើម ដង្ហើម ប្រមាត់ក៏សូមឱ្យស្តេចយកព្រះខ័នកាត់ខ្ញុំមទ្រីនេះចេញបំពេញព្រះបារមីទាន ... ខ្ញុំមទ្រីពុំមានចិត្តរួញរា នឹងសុំយកអាសាស្នងព្រះតេជះគុណ ដរាបលុះអស់ជីវិត សូមជួយបំពេញព្រះបារមីទាន សូមឱ្យព្រះអង្គបានត្រាស់ជាព្រះពុទ្ធ...»។

នៅទីបំផុតព្រះវេស្សន្តរក៏បានសម្រេចក្នុងការធ្វើភរិយាបរិច្ចាគដែលនាំឱ្យឥន្រ្ទព្រាហ្មណ៍ពេញព្រះទ័យនឹងសទ្ធាជ្រះថ្លារបស់ព្រះវេស្សន្តរ ជាពិសេសបានប្រទានពរទាំងប្រាំបីប្រការតាមបំណងដល់ព្រះវេស្សន្តរទៀតផង។

### ឃ- វិភាគតួអង្គ

➤ **ព្រះវេស្សន្តរ**

- **គុណសម្បត្តិ** ព្រះវេស្សន្តរជាតួអង្គព្រះពោធិសត្វ ដែលមានចិត្តគិតប្រាថ្នាតែសម្មាសម្ពោធិញ្ញាណ ព្រះអង្គតែងបំពេញទានគ្រប់ពេលវេលា តាំងពីតូចរហូតដល់ទីបញ្ចប់នៃជីវិតព្រះអង្គ។ ព្រះអង្គមិនដែលបានធ្វើឱ្យមានសេចក្តីក្តៅក្រហាយដល់ជនណាម្នាក់ សូម្បីតែពួកអ្នកស្រីពិរាស្ត្រដែលសុំបំបរបង់ព្រះអង្គឱ្យទៅរស់នៅក្នុងព្រៃក៏ដោយ។ក្នុងមួយជីវិតព្រះអង្គប្រាថ្នាតែមួយគត់គឺបានក្លាយទៅជាព្រះពុទ្ធអាចរំដោះមនុស្ស ឱ្យចៀសផុតកងទុក្ខទាំងឡាយដែលមាននៅក្នុងវាលវដ្តសង្សារនេះ។

- **គុណវិបត្តិ** ទ្រង់នៅមិនទាន់ដាច់ស្រឡះពីជីវិតមនុស្សសមញ្ញ ដោយប្រុងនឹងលើកធ្នូបាញ់ប្រហារព្រាហ្មណ៍ជូជកដែលវាយធ្វើបាបបុត្រនៅនឹងមុខ។ មានមតិខ្លះអគតិខ្លះអគតិខ្លះចំពោះទង្វើរបស់ទ្រង់ដែលបរិច្ចាគទ្រព្យធនមិនសមហេតុផល ដូចជាការធ្វើសត្តសត

កមហាទាន (ទាន៧មុខ១មុខស្មើ១០០) ទៅបំផុតទាននោះគ្មានអ្វីក្រៅពីបានត្រាស់ដឹងជាព្រះពុទ្ធអង្គនោះឡើយ។

➤**ព្រះបាទស្រីសញ្ជ័យ**

• **គុណសម្បត្តិ** ជាព្រះមហាក្សត្រដែលប្រកបដោយទសពិធរាជធម៌ មានហឫទ័យស្រឡាញ់កូនចៅភរិយា គោរពលទ្ធិប្រជាធិបតេយ្យស្របតាមសំណើររាស្ត្រដែលមិនពេញចិត្តនឹងទង្វើព្រះវេស្សន្តរ ហើយសុខចិត្តអនុញ្ញាតឱ្យកូនទៅរស់នៅភ្នំគិរីវង្កត។

• **គុណវិបត្តិ** ទ្រង់ដោយមានចិត្តអាណិតបុត្រពេក ពេលដែលដឹងតាមរយៈចៅជាលីនាងក្រឹស្នាថ្លែងពីទុក្ខលំបាករបស់បុត្រព្រះអង្គបានប្រកាន់យកអំណាចជាព្រះមហាក្សត្របានដង្ហែព្រះវេស្សន្តរពីក្នុងព្រៃមកចូលនគរវិញ ដោយពុំបានសាកសួរពីការសម្រេចចិត្តរបស់ប្រជារាស្ត្រទេ។

➤**ព្រះនាងសុបារសុប្បតី**

• **គុណសម្បត្តិ** ជាក្សត្រីដែលមានទឹកចិត្តទូលំទូលាយប្រាថ្នាចង់បានបុត្រមានព្រះកិត្តិនាមល្បីល្បាញក្នុងសង្គមនិងមានចិត្តរំដោះទុក្ខដល់អ្នកផងទាំងពួង។ ព្រះនាងបានធ្វើអំពើល្អគ្រប់បែបយ៉ាងប្រៀនប្រដៅបុត្រ ឱ្យមានចិត្តស្លូតបូតសុភាពរាបសារ ចេះអាណិតអាសូរដល់ជនកម្សត់ទុគត ព្រះនាងចេះធ្វើទានបរិច្ចាគជាគំរូល្អដល់បុត្រ គឺព្រះវេស្សន្តរក្នុងការកសាងអំពើល្អជាកុសលដោយមិនរើសអើងអំពីឋានៈវណ្ណៈឡើយ។

➤**ព្រះនាងមទ្រី**

• **គុណសម្បត្តិ** ជាព្រះនាងជាកន្សែសាពេជ្ជ ដែលពោរពេញទៅដោយឧត្តមគតិ គោរពការសម្រេចចិត្តរបស់ស្វាមី និងមានទឹកចិត្តស្មោះភក្ដីចំពោះស្វាមីគ្រប់ពេលវេលារួមសុខរួមទុក្ខជាមួយគ្រួសារឥតមានការត្អូញត្អែរឡើយ ទោះត្រូវស្វាមីពោលពាក្យស្ដីបន្ទោស ឬខុសឆ្គងយ៉ាងណាក៏ដោយ ក៏ព្រះនាងនៅតែពេញចិត្តនឹងបានអនុមោទនាដល់ស្វាមីដែលធ្វើបុត្របរិច្ចាគ ថែមទាំងស្ម័គ្រចិត្តបូជាសាច់ឈាមក្នុងការបរិច្ចាគទានរបស់ស្វាមីមិនប្រកែកឡើយ។

➤ **ជូជកព្រាហ្មណ៍**

គាត់នៅស្រុកទុន្នវិដ្ឋព្រាហ្មគ្រាម ជិតស្រុកកលិង្គរាស្ត្រមានមុខរបរជាស្វមយាចក។

• **គុណសម្បត្តិ** ជាព្រាហ្មណ៍ដែលមានចរិតព្យាយាមដើរសុំទានសព្វទីកន្លែង មិនថាក្រុងស្រុកស្រែតាមវត្តអារាម ហើយចេះសន្សំសំចៃ មានមារយាទល្អទុកដាក់ទ្រព្យសម្បត្តិដែលខ្លួនរកបានរាប់តម្លឹង។ មិនត្រឹមតែប៉ុណ្ណោះ ជូជកបានភរិយាដ៏ស្រស់ប្រិមប្រិយ ចេះស្រឡាញ់ថ្នាក់ថ្នមភរិយារហូតដើររកខ្ញុំបម្រើស្រីប្រុសឱ្យនាងថែមទៀត។

• **គុណវិបត្តិ** រូបារម្មណ៍របស់តាជូជក ត្រូវបានអ្នកនិពន្ធពណ៌នាលេចធ្លោនូវលក្ខណៈអាក្រក់១៨យ៉ាងដែលហៅថាបុរិសទោស១៨ប្រការ « ឯកោព្រាហ្មណោមានព្រាហ្មណ៍ឈ្មោះជូជកព្រឹទ្ធាចារ្យរូបអន្ធការ ស្គមច្រដោង ច្រមុះកោង ទ្រូងសុទ្ធតែឆ្អឹង សក់រឹងក្រញាងពោះធំកំប៉ោងលេងសំពៀតដំបារត្រចៀកយុរយារក្រាស់ដូចយ្លង់ភ្លើង ជើងកោងដូចជើងសេក

ភ្នែកស្រលៀងស្រលី ធ្មេញស ក្បាលវែងតូចម្ខាងដូចផ្លែភ្នៅ »[13]។ ចិត្តកំណាចឃោរឃៅប្រាថ្នាតែប្រយោជន៍ខ្លួនឯងធ្វើបាបកុមារ មានកលល្បិចខ្មៅងងឹតបោកបញ្ឆោត ចេតបុត្រវេស្សន្តរសុំបុត្រ ទីបំផុតមានចិត្តលោភលន់ហួសប្រមាណពេករហូតត្រូវបែកពោះស្លាប់ ដោយបរិភោគហួសកំណត់។

គាត់ជាព្រាហ្មណ៍ចាស់ រូបអាក្រក់ក្រៃលែង បើយើងពិនិត្យទៅលើសកម្មភាពរបស់តួអង្គនេះតាមសាច់រឿងឃើញថា ៖

-គាត់មានមុខរបរជាស្មូមសុំទានសុំទាំងសព្វថៃមទាំងចេះហួងហែងទ្រព្យធនរក្សាទ្រព្យធនយ៉ាងមធ្យ័ត រហូតសន្សំបានមាស១០០ដំឡឹងយកទៅផ្ញើនឹង ត្រកូលព្រាហ្មណ៍ជាសម្លាញ់ម្នាក់។

-ជាមនុស្សឆេវឆាវ បញ្ឆោតសំឡុត បំភ័យគេឯង បំភ័យព្រាហ្មណ៍ប្តីប្រពន្ធ ជាមិត្តភក្តិពីរឿងមាស១០០តម្លឹងដែលផ្ញើ ។

-មានចរិតខិលខូច មិនគិតខ្លួនចាស់ ប្រើល្បិចប៉ិនសម្រួលពាក្យសម្តី ក្នុងការដែលព្រាហ្មណ៍ជាមិត្តអង្វរលើកកូនឱ្យ «យើងនេះមកសុំតែទ្រព្យគាប់អ្នកជាពិបាក ហើយគិតយកបុត្រីមកឱ្យជាភរិយាយើងៗក៏ពុំសូវប្រាថ្នាទេ តែថាអ្នកឱ្យយើងហើយ នឹងលែងទទួលពុំបានយើងនឹងនាំទៅថ្កានឋានយើងនាយ ឥឡូវឯងហោង »។

-ចេះប្រច័ណ្ឌ ចំពោះភរិយាក្រមុំ ខ្លាចអ្នកដទៃហួងហែង និងមានល្បិចកលមាយាយំយែកអង្វរលួងលោម ឱ្យលុះក្នុងតណ្ហានៅពេលដែលបាននាងអមិត្តតាបនា។

-ពុំគិតខ្លួនចាស់ លោភលន់ ដើររកសុំទានគេមកតម្រូវចិត្តប្រពន្ធក្មេង ជាហេតុនាំឱ្យគាត់ធ្វើដំណើរកាត់ព្រៃសំដៅទៅភ្នំគិរីវង្កត សុំរាជកុមារអំពីព្រះវេស្សន្តរ។

-មានល្បិច ចេះកែកិច្ច មានកល បោកបញ្ឆោតចេតបុត្រ និងអច្ចុតឫសីថាខ្លួនជារាជបម្រើព្រះបាទស្រីសញ្ជ័យឱ្យមកទទួលព័ត៌មានចំពោះព្រះវេស្សន្តរ ជាហេតុនាំឱ្យចេត្របុត្រ ក៏ដូចអច្ចុតឫសីជឿស្លុងនិងបង្ហាញផ្លូវទៅភ្នំគិរីវង្កត។

-សាហាវឫស្យា និយាយពាក្យសំដីអាក្រក់ វាយធ្វើបាបក្មេង ដោយគ្មានអាណិតអាសូរដល់កុមារបន្តិចណាឡើយ។ ឧ. ទំព័រ ៣៦៦- ៣៦៧ «... ជាលី ក្រស្នាទូលអស់អំពី អំពើសាហាវដែលវាវាយធ្វើបាបខ្លួនយ៉ាងណាៗនោះ »។

សកម្មភាពរបស់តួអង្គជូជក ត្រូវបានបញ្ចប់ដោយអំពើ លោភលន់ឫស្យារបស់ គាត់។ បន្ទាប់ពីបានលោះរាជកុមារទាំងពីររួចតាជូជកក៏បានបរិភោគអាហារដែលព្រះបាទស្រីសញ្ជ័យជប់លៀងគាត់។ គាត់ស៊ីហួសប្រមាណ ស៊ីៗរហូតដល់ផ្ទុះបែកពោះស្លាប់។ លុះមរណាហើយទៀត ក៏ខ្មោចនោះត្រូវបញ្ជូនពីវត្តមួយទៅវត្តមួយ ដុតក៏ពុំឆេះទាល់តែគាស់ខ្មោចទម្លាក់ទៅក្នុង

---

[13] មហាវេស្សន្តរជាតកសម្រាប់ទេសន៍ បោះពុម្ពផ្សាយឡើងវិញលើកទី២ចំនួន៥២០០ច្បាប់ ដោយការផ្សាយរបស់អាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០ កណ្ឌទី៥ ទំព័រទី២

អូរ បានឆ្កែទាញ ឈ្លើងទាមក្អែកចោះរហូតធ្លាក់ទៅមហានគរហោង ការពិពណ៌នា ពីមរណភាពរបស់តាជូជក់នេះត្រូវបរិយាយដោយឡែកអំពីរឿង«ជូជកបរិភោគអាហារ»។

ដូចនេះតួអង្គជូជកមានដំណើរឯកភាព ទាំងរូបសម្បត្តិ និងសកម្មភាពចិត្តគំនិតរហូតដល់ពេលមរណា គឺអាក្រក់ជួរជាតិ ហួសវិស័យ។ រូបាម្មណ៍ដ៏កម្រនេះ ពិតជាកើតចេញពីទេពកោសល្យច្នៃប្រឌិតដ៏រស់រវើក របស់អ្នកនិពន្ធខ្មែរយើង វាសឡើង។ នោះជាតម្លៃសោភ័ណដ៏ត្រកាលក្នុងស្នាដៃអក្សរសិល្ប៍។

តែទោះបីជាមានលក្ខណៈសម្បត្តិអាក្រក់ ជួរជាតិយ៉ាងនេះក្តីក៏ តាជូជក គង់មានសេចក្តីសរសើរដល់ទានបារមីរបស់ព្រះវេស្សន្តរ ដោយពោមន្លពាក្យតបទុញរកពពួកអ្នកស្រីពិរាស្រ្ត និងអាមាត្យមន្ត្រី ដែលដាក់ទោសដល់ព្រះវេស្សន្តរ «ឯសម្តេចព្រះវេស្សន្តរ ពោធិវង្ស ព្រះអង្គតែងបានជាទីពុំនាក់ នៃមនុស្សសត្វតោកយ៉ាកលំបាក ផលទាំងឡាយ...ជាបឋមក្សត្រ ឥតមានឯណា មួយស្មើនឹងព្រះអង្គបាន ទើបព្រះរាជទាន ព្រះរាកុមារទាំងពីរឱ្យមកខ្ញុំ ព្រះអង្គដោយនូវកម្រិតឥតមុសា»។

**-ឧត្តមគតិរឿង**

រឿងរ៉ាវផ្សេងៗក្នុងគម្ពីរទសជាតក សុទ្ធតែបានលើកយកទស្សនៈនៃការអប់រំមកពន្យល់បង្ហាញអ្នកអាន អ្នកទស្សនាឱ្យស្គាល់និងយល់ច្បាស់នូវចលនាពុទ្ធនិយមពិតប្រាកដ។ មហាវេស្សន្តរជាតកជារឿងពោរពេញទៅដោយមតិទស្សនៈនៃការអប់រំ ហើយត្រង់ចំណុចខ្លះបានលាតត្រដាងនៃការអប់រំលើរឿងដទៃទៀតដែរ។ មហាវេស្សន្តរជាតក ជារឿងកសាងទានបារមី របស់ព្រះវេស្សន្តរជាតួអង្គគំរូដ៏ពិសេស ដែលមានព្រះទ័យទូលាយក្នុងការចែករំលែកទ្រព្យសម្បត្តិ ផ្តល់សេចក្តីសុខដល់អ្នកក្រីក្រលំបាកតោកយ៉ាកដោយមិនប្រកាន់វណ្ណៈពណ៌សម្បុរអ្វីឡើយ។

រឿងព្រះវេស្សន្តរ ជារឿងពុទ្ធនិយម ដែលមានលក្ខណៈល្អ មានគោលដៅអប់រំសមហេតុផលអ្នកនិពន្ធលើកយកទ្រឹស្តីពុទ្ធនិយមក្នុងព្រះពុទ្ធសាសនា មកបង្ហាញយ៉ាងច្បាស់លាស់។ មិនតែប៉ុណ្ណោះ អ្នកនិពន្ធបានរៀបរាប់ពីដំណើររឿងដោយប្រើបដិយោគវិធី ពោលគឺត្រង់ចំណុចណាដែលមានការត្រិះរិះពិចារណារកហេតុផលឱ្យច្បាស់លាស់មុននឹងជឿតាម។

**គ. អត្ថរូប**

**- ផ្តើមរឿង**

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។ ផុស្សតីវណ្ណាភេតិ ឥទំ សត្ថា កបិលវត្ថុំ ឱបនិស្សាយ និគ្រោធារាមេ វិហរន្តោ បោក្ខរវស្សំអារព្ភ កថេសិ។

សត្ថា មោះ សត្ថវាហោ សត្ថនាយកោ រីព្រះអង្គដ៏ជាគ្រូប្រសើរក្រៃលែង តែងអាចនានាំអស់ទេវតាមនុស្សសត្វផងទាំងឡាយ កៀរគរបរប្រមូលបញ្ចូលទៅកាន់អម្រឹតបុរី ស្រីហានគរនិព្វាន ដ៏ជាឋានបរមសុខក្សេមក្សាន្តប្រេមប្រាសនិរាទុក្ខប្រសើរហោង។....

**- តួរឿង**

អ្នកនិពន្ធបានប្រើនូវវិធីច្រើនយ៉ាងដើម្បីទ្រទ្រង់ដំណើររឿងទាំងមូល ឱ្យមានទំនាក់ទំនងគ្នាគឺៈ

➤ **វចនរូប** ការតាក់តែងរបស់អ្នកនិពន្ធបានប្រើពាក្យបាលី សំស្រ្កឹត រាជស័ព្ទ លាយម្រុះពាក្យខ្មែរបុរាណធម្មតានិងក្នុងសាសនាមួយចំនួន។

**ក. ពាក្យបាលី**

- ឯកកោព្រាហ្មណោ (ព្រាហ្មណ៍ម្នាក់)
- ជូជកកោនាម (ឈ្មោះជូជក)
- ទុន្នវិដ្ឋព្រាហ្មណ៍តាមវាសី (នៅស្រុកទុន្នវិទ្ធព្រហ្មណ៍)
- ពាក្យសំស្ក្រឹត
- ប្រឹថពី (អធិដ្ឋាន)

**ខ. រាជស័ព្ទ**

- ព្រះចេស្តារ
- មាតាបិតា
- មហាក្សត្រ
- ពាក្យខ្មែរច្រើនប្រើពាក្យបកប្រែពីបាលី។
- ពាក្យពុទ្ធសាសនា

ម្នាលភិក្ខុទាំងឡាយអើយ..................អំបាលម្នាលព្រាហ្មអើយ។

➤ **ពណ៌នាវិធី**

ក្នុងអត្ថបទអក្សរសិល្ប៍ខ្មែរយើង ពិសេសក្នុងរឿងបុរាណអ្នកនិពន្ធមិនបានបោះបង់ចោលនូវការពណ៌នាពីធម្មជាតិទេ ពិសេសរឿងមហាវេស្សន្តរជាតកមានស្ទើរតែគ្រប់កណ្ឌទាំងអស់ កវីបានលើកយកធម្មជាតិមកពិពណ៌នាយ៉ាងច្រើនដូចជានៅកណ្ឌចូឡពន (ព្រៃតូច) និងកណ្ឌមហាពន (ព្រៃធំ) ដែលរៀបរាប់ពីសត្វតូច ព្រៃរបោះរហូតដល់សត្វធំព្រៃស្រោងស្រងាត់។

**ក.ផ្នែករុក្ខជាតិ** កវីបានរៀបរាប់ឈើក្នុងព្រៃមានដូចជា ត្របែក ត្រសេក ស្តីស្តង់ គគីរ ឆាំឆា គុយ ក្តាំងងារ ចំប៉ាចំប៉ី មង្ឃុត ល្មុត សេដា ពុទ្រា អំពិល តាត្រាវ ពពាលខែ... ធម្មជាតិទាំងអស់មានលក្ខណៈជាខ្មែរ ដែលយើងធ្លាប់ជួបប្រទះ មានពិតនៅស្រុកខ្មែរ ព្រមទាំងពិពណ៌នាទៅតាមតួអក្សររៀងគ្នា ដែលមានពួក មានក្រុមដូចជាៈ

- ឈើមានផ្កាក្រអូប ៖ មានក្រវាន់ ចំប៉ី ចំប៉ា ក្តាំងងារ ក្រស្នា..........។
- ឈើមានខ្លឹមឬស្លឹក មានចន្ទន៍ នួនស្រី មាលតី ដីប្លី លំពាន់ កាំព្លក់ កាំព្លា.....។
- ឈើមានផ្លែជាអាហារ មានក្រសាំង ពង្រ គូលែន សិរមាន់ គុយស្វាយ......។
- ឈើមានខ្លឹមសម្រាប់ប្រើការ មានកកោះ គគីរ សុក្រំ ឈើទាល

ខ្លុង តែ្បង....។

**ខ.ផ្នែកវារីជាតិ** មានស្មៅ ឈូកស ឈូកច្រាល កុបុទ លំចង់ ព្រលិត កំពីង ពួយ...។

**គ.ផ្នែកមច្ឆាជាតិ** មានត្រីធំត្រីតូចច្រើនអនេក មានទាំងទឹកសាបទាំងទឹកប្រៃ នៅក្នុងស្រះបោក្ខរណីមានដូចជាត្រីឆ្តោក ឆ្ពិន ច្រកែង អណ្តែង ប្រា ទីពោ ក្រពើ ប្លាម៉ា អណ្តែងងាំង ផ្ទក់ក្រាយ ស្លាតក្ទាន់បង្គា បង្កង កំពិស ផ្សោត ចង្វា...។

**ឃ.ផ្នែកសត្វ** មានដូចជា រាជសីហ៍ ដំរីព្រៃ ខ្លា រមាស ឈ្លូស ប្រើស គោព្រៃ ខ្ទីង ចចក ស្វាន ស្វា ឆ្មាបា ចាមរី សំពោច ជ្រូកព្រៃ...។

**ង.ផ្នែកបក្សី** មានដូចជា ឥន្ទ្រី ត្មាត ខ្លែងស្រាក ក្ងោក ប៉ោលតោក មាន់ព្រៃ ចាប លលក ព្រាប...។

**ឃ.ផ្នែកសត្វឆ្អឹងកង** មានដូចជា សុច មូស មមង់ មមាច ក្អែប ខ្មួយ ខ្យាដំរី....។

**ច.ផ្នែកឧរង្គសត្វ** មានដូចជា ពស់វែកដំបូក ថ្លាន់ ក្រពើរនាម...។

ឃើញធម្មជាតិទាំងអស់នេះ មាននៅភ្នំហេមពាន្ត ដែលមានកំពូលធំៗរហូតដល់ ៨៤០០០កំពូលហើយកំពូល ដែលខ្ពស់ជាងគេនោះ គឺកំពូលភ្នំអេវរ៉េសមានកម្ពស់ ៨.៨៤៣ ម៉ែត្រនិងកំពូលភ្នំអណ្ណាបូណាមានកម្ពស់៨.០៧៥ម៉ែត្រ។ ភ្នំនេះសម្បូរដោយទឹកកកគ្រប់ពេល ស្ថិតនៅប្រទេសនេប៉ាល់ផ្នែកខាងជើង។ ធម្មជាតិទាំងនេះ សុទ្ធតែបញ្ចេញត្រួយ ស្លឹក ផ្កា ខ្ចី ចាស់ ទុំ គ្រប់ប្រភេទ។

➤ **បដិវិធី**

ជាសកម្មភាពទំនាស់កើតរវាងព្រះវេស្សន្តរនិងពួកអ្នស្រីពិរាស្ត្រដែលកើតទុក្ខមិនសុខចិត្តដោយព្រះវេស្សន្តរធ្វើទានដំរីដល់អ្នកស្រុកកលិង្គរាស្ត្រហើយទទូចសុំឱ្យបំបរបង់ព្រះវេស្សន្តរ ទៅរស់នៅភ្នំគិរីវង្កត។

➤ **សំវាទវិធី**

ការជជែកឆ្លើយឆ្លងរវាងតួអង្គព្រះវេស្សន្តរជាមួយមទ្រីៈ

- នាងមទ្រី «បពិត្រព្រះសម្មតិទេព អញខ្ញុំនេះឈ្មោះមទ្រី ជាខ្ញុំស្រីព្រះអង្គ»
- ព្រះវេស្សន្តរ «មទ្រីអើយ នាដំណើរនាងមកកាន់អញនេះ មានបំណងប៉ុនប៉ងនឹងទំលាយក្រឹត្យវត្តប្រណិបត៌អញនេះឱ្យអន្តរាយមិនទេឡើយ យើងបានស្រដីប្ដេជ្ញានឹងគ្នាហើយតើ»។

➤ **ឯកវាទវិធី**

ការគិតនឹងនិយាយតែម្នាក់ឯងដោយពុំមានគូរឆ្លើយឆ្លងជាមួយ។

ឧទាហរណ៍ : កាលនោះព្រះមហាក្សត្រទ្រង់ព្រះចិន្តាពិចារណា ដោយព្រះប្រាជ្ញទិព្វឈ្វេងយល់ថា «នាថ្ងៃស្អែកនេះឯងហើយនឹងមានស្មូមយាចកមួយមកសុំកូនអញ ទាំងពីរជាទានបារមី ហៅបុត្របរិច្ចាគនឹងបានបំពេញបរិបូរណ៍នាកាលថ្ងៃស្អែកនេះ។ បើដូច្នេះអញនឹង

ប្រាប់នាងមទ្រីដោយនូវពិតឯណាបាន ត្បិតជាសោកស្តាយស្រឡាញ់កូនទាំងពីរនេះណាស់ គួអញប្រាប់បង្វែងវិញ»។

➤ **ឧបមាណវិធី** ការប្រៀបធៀបដូចធម្មជាតិឬមនុស្ស សត្វ ទៅនឹងអ្វីមួយដើម្បីរៀបរាប់ ឬបំបាត់នូវទុក្ខកង្វល់ដែលមាននៅក្នុងចិត្ត ដូចជាការលំហែបំបាត់ទុក្ខព្រួយ សប្បាយរីករាយជាដើម។

ឧទាហរណ៍ : នៅពេលដែព្រះនាងយំមិនឃើញបុត្រទាំងពីរនៅអាស្រម នាងមទ្រីបានប្រៀបប្រដូចទាំងពីរទៅនឹងកូនសត្វដែលរកមេ «បីដូចកូនគោរត់រកមេ ពុំនោះសោតបីដូចកូនហង្សនៅលើកក់រង់ចាំមើលផ្លូវ»។

➤ **សន្ទេហវិធី** ការចង់ដឹងដំណើររឿងដែលកើតឡើង អ្នកនិពន្ធចេះធ្វើសាច់រឿងមានទំនាក់ទំនងគ្នា ចោទសួរថាតើព្រះវេស្សន្តរទៅរស់នៅក្នុងព្រៃអស់រយៈពេលយូរប៉ុណ្ណាទៅ តាជូជកទៅសុំបុត្រព្រះវេស្សន្តរបានដែរឬទេ?

មានវិធីច្រើនទៀត ដែលបានធ្វើឱ្យរឿងព្រះវេស្សន្តរ កាន់តែមានភាពល្បីល្បាញថែមទៀត។

- **បញ្ចប់រឿង**

បញ្ចប់រឿងបែបពុទ្ធនិយម កវីនិពន្ធតែងលើកយកការសជាតិ មកចង្អុលបង្ហានៅចុងបញ្ចប់រឿង។ ការដែលបង្ហាញបែបនេះ ជាកត្តាសំខាន់មួយសម្រាប់បញ្ជាក់នូវផលនៃកម្មដែលតួអង្គនីមួយៗបានប្រព្រឹត្តធ្វើល្អបានមកជាលក្ខណៈសកម្មភាពល្អបានប្រព្រឹត្តអ្នកធ្វើល្អបានមកជាលក្ខណៈសកម្មភាពល្អដូចជាព្រះពុទ្ធព្រះសារីបុត្ត មោគ្គល្លាន ឧប្បវណ្ណថេរីនាងវិសាខាជាដើ។ ចំណែកអ្នកធ្វើអាក្រក់បានជាតួអង្គអាក្រក់ ដូចជាទេវទត្តនាងចិញ្ចាជាដើម។

- រឿងព្រះវេស្សន្តរបញ្ចប់រឿងដោយការសជាតិដូចជា៖
- ព្រះវេស្សន្តរមកជាតួអង្គ ព្រះសម្មាសម្ពុទ្ធ
- ព្រះបាទស្រីសញ្ជ័យជាពុទ្ធបិតា
- ព្រះនាងមទ្រី ជាអង្គសិរិមហាយាជាមហេសី
- ជាលី ជារាហុលកុមារ ជាមហេសី
- ជាលី ជារាហុលកុមារ
- ជូជកជាទេវទត្ត។

**ឃ.អត្ថរស**

តម្លៃរបស់រឿងមហាវេស្សន្តរជាតកស្ថិតនៅលើទានបារមី ដែលបានសង្កត់ធ្ងន់ទៅលើសង្គមនិងសច្ចៈ ដែលកើតមានពិតនៅក្នុងជីវភាពពិតរបស់មនុស្ស។ រឿងនេះឱ្យតម្លៃលើពុទ្ធសាសនាដែលបាបប្រៀនប្រដៅមនុស្សទៅតាមលិទ្ធិពុទ្ធនិយមដោយអច្ឆរិយបុគ្គលដែលបានរកឃើញនូវអរិយសច្ចៈបួន បើអ្នកណាបានស្តាប់និប្រតិបតត្តិបាននឹង បានសេចក្តីសុខសាន្តផុតទុក្ខភ័យពិតប្រាកដ។ តាមរយៈនេះបានផ្តល់តម្លៃជាច្រើនមានដូចជា៖

➤**កាព្យរស**

រឿងមហាវេស្សន្តរកាលពីដើមសរសេរជាភាសាបាលី តែក្រោយមកត្រូវបានគេបកប្រែជាភាសាសម្រាយធម្មតាដែលមានលក្ខណៈងាយស្រួលអាន។

➤**កុសលរស**

រឿងបានបង្ហាញពីការអប់រំឱ្យចេះធ្វើបុណ្យកុសល ដើម្បីរួចផុតពីការព្រាត់ប្រាស់គ្នាការលំបាកវេទនា។ ជាក់ស្តែងក្នុងរឿងព្រះវេស្សន្តរបានបង្ហាញពីការធ្វើទានរបស់ព្រះវេស្សន្តរដើម្បីសម្រេចសម្មាសម្ពោធិញ្ញាណ។

➤**ទារុណរស**

នៅក្នុងរឿងទារុណរសបានស្តែងឡើង នៅពេលដែលព្រះវេស្សន្តរបានបរិច្ចាគទានបុត្រដល់ ព្រាហ្មណ៍ជូជក នៅពេលដែលឃើញកូនទាំងពីររត់មកឱ្យជួយ ហើយត្រូវតាជូជក់ចាប់ចងវាយគ្មាន ត្រាប្រណី។

➤**មហិទ្ធិរស**

ការបង្ហាញភាពអស្ចារ្យដែលមនុស្សទូទៅមិនអាចធ្វើដូចបាន ជាក់ស្តែងត្រង់កន្លែងដែលព្រះឥន្ទ្រប្រទានពរទាំង១០ប្រការដល់ព្រះនាងសុបារសុប្បតី ពេលព្រះឥន្ទ្រជប់អាស្រមដល់ព្រះវេស្សន្តរ នៅភ្នំគិរីវង្គត។

➤**កម្សត់រស**

ជាតម្លៃដែលលេចចេញពីទុក្ខវេទនាព្រាត់ប្រាស់ ដូចជានាងមេទ្រីដង្ហោយហៅរកបុត្រដែលបាន បាត់ទៅរហូតដួលសន្លប់បាត់ស្មារតី។

➤**សង្គមរស**

ជាតម្លៃស្តែងឡើងតាមរយៈដំណើររឿងនៃការបរិច្ចាគទានដ៏អស្ចារ្យរបស់ព្រះវេស្សន្តរ។

**ខ.បញ្ហាសង្គម**

១.នយោបាយ របបគ្រប់គ្រងប្រព្រឹត្តទៅប្រកាន់របបរាជានិយម មានតុលាការ ចៅក្រម ឬអ្នកកាត់ក្តី។ ដូចជាជូជកបានគំរាថារកចៅក្រមមកវិនិច្ឆ័យទោសត្រកូលព្រាហ្មណ៍ដែលយកមាសគាត់ផ្ញើមកចាយវាយអស់។

២.សេដ្ឋកិច្ច

- កសិកម្ម មានការប្រកបរបរធ្វើស្រែ។ ដូចជាអ្នកស្រុកកលិង្គរាស្ត្រជួបប្រទះនឹងគ្រោះ ទុរភិក្ស ដោយគ្មានភ្លៀង ក៏មកសុំដំរីបច្ច័យនាគេន្ទ្រ ដើម្បីនាំឱ្យមានភ្លៀងធ្លាក់មក។
- ផលិកម្ម អាចផលិតជារបស់ប្រើប្រាស់ ដូចជារទេះសេះជាដើម។
- ពាណិជ្ជកម្ម មានផ្សារ មានចរាចណ៍
- គមនាគមន៍ ធ្វើដំណើរ ដោយថ្មើរជើង ឬរទេះសេះ។

៣.សង្គមកិច្ច

- ស្ថានភាពរស់នៅ : ប្រជាជនរស់នៅក្រោមការគ្រប់គ្រងរបស់ព្រះរាជា

ប្រទេសមានអសន្តិសុខ (មានចោរ)។

- មុខរបរ និងជីវភាពប្រជាជន : ប្រជាជនប្រកបរបរកសិកម្ម និងសិប្បកម្ម។

៩.វប្បធម៌

- ជំនឿ : ជឿលើសុបិននិមិត្ត និងប្រផ្នូល។ ដូចជានាមទ្រីបានសុបិនចម្លែកដែលធ្វើឱ្យនាងព្រួយបារម្ភ មុននឹងទៅបេះផលាក្នុងព្រៃ គឺបានឃើញបុរសម្នាក់ទាបខ្មៅ ស្លៀកសំពត់អម្ពត់ សៀតផ្កាចារនៅត្រចៀក ចូលមកផ្ចួលនាងឆ្កៀលយកភ្នែកទាំងពីរ កាត់ ស្មានាងទាំងសងខាងពុះទ្រូងរូងយកថ្លើម និងបេះដូងទៅ។ រីឯភ្នែកឆ្វេងនាងចេះតែរកាំ ភ្នែកស្តាំចេះតែកម្រើក...។

-ប្រពៃណី ទំនៀមទម្លាប់ : រាជបុត្រមានការស្នងរាជ្យសម្បត្តិបន្តពីព្រះបិតា។

-សាសនា : កាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។

## III-ការសន្និដ្ឋាន

រឿងមហាវេស្សន្តរជាតក ជាស្នាដៃមួយល្អ ពេញលេញទាំងផ្នែកអត្ថន័យ អត្ថរូប និងអត្ថរស។ ដោយឡែកផ្នែកអត្ថន័យ បានផ្សារភ្ជាប់ទស្សនៈអប់រំតាមបែបសីលធម៌សាសនាដែលជាគោលការណ៍បម្រើឱ្យមនុស្សជាតិ។ តួអង្គទាំងអស់សុទ្ធតែបែរឆ្ពោះទៅរកឧត្តមគតិនេះ ហើយសង្គមជាតិក៏ពង្រឹងទស្សនៈនេះដែរ គឺជាសំណូមពរយុគសម័យដែលទាមទារឱ្យមនុស្សហ៊ានលះបង់អ្វីៗដែលជាលក្ខណៈបុគ្គលដើម្បីប្រយោជន៍មនុស្សទូទៅ។

ចំពោះផ្នែកអត្ថរូបវិញ ស្នាដៃនេះពិតជាលេចចេញពីទេពកោសល្យ ដ៏ល្អបំផុតរបស់បុព្វបុរសខ្មែរ ដែលមាននិស្ស័យខ្ពស់ក្នុងការតែងនិពន្ធ។

# បន្ទានុក្រមរឿងព្រះវេស្សន្តរ

«ក»

- **កន្សែស្រសារពេជ្ជ** ( ន. ) ស្រីជាអគ្គមហេសីរបស់ព្រះបរមពោធិសត្វជាបច្ឆិមជាតិក្នុងកាលដែលនៅជាគ្រហស្ថ ឬដែលបានត្រាស់ហើយ ក៏គង់នៅហៅស្រីនោះថា កន្សែស្រសារពេជ្ជ: នាងពិម្ពាយសោធរា ជាកន្សែស្រសារពេជ្ជនៃព្រះសាក្យមុនីគោតម
- **កណ្ឌ** កាន់ បា. ( ន. ) ព្រួញ; គ្រាប់កាំភ្លើង; ទង់; ដើម; កំណាត់, បរិច្ឆេទ, វគ្គ, ខ្សែ : សាស្រ្តាមួយកណ្ឌ ។
- **ក្លិង្គ** សំ. បា. ( ន. ) (កលិង្គ) ឈ្មោះដែន ១ នៅក្នុងមជ្ឈិមប្រទេស;ប្រជាជនដែលនៅក្នុងដែននោះ ក៏ហៅថា ក្លិង្គ ដែរ ។
- **កៅទណ្ឌ** --ទាន់ សំ.; បា. ( ន. ) (កោទណ្ឌ) ធ្នូ ។ សព្វថ្ងៃប្រើជារាជសព្ទ : ព្រះកៅទណ្ឌ គឺធ្នូសម្រាប់ក្សត្រទ្រង់រាជ្យ។
- **ធម្ម** ធ័ម-មៈ បា.; សំ.( ន. ) (ធម៌) ធម៌, សភាវៈទ្រទ្រង់សត្វលោក គឺ បុណ្យ, បាប, សុចរិត, ទុច្ចរិត; ហេតុ; សភាព; ធម្មតា; ប្រក្រតី; ធម្មជាត; ប្រាជ្ញាញាណ; គុណ; សេចក្ដីចម្រើន; អារម្មណ៍ខាងផ្លូវចិត្ត; ការរិះគិត; សង្ខារ; កិរិយាមារយាទ; បរិយត្តិ; ច្បាប់ ។ល។ ពាក្យនេះប្រើសម្រាប់រៀងភ្ជាប់ពីខាងដើមសព្ទដទៃទៀត ដូចជា ធម្មកថា (ធ័ម-មៈកៈ ថា) ន. (បា.) សម្ដីដែលជាធម៌; ការសំដែងធម៌។ធម្មកម្ម (ធ័ម មៈក័ម)ន.(បា.)អំពើ,កិច្ចការដែលប្រកបដោយធម៌,ដែលត្រូវតាមធម៌។ ព. ផ្ទ. អធម្មកម្ម។ ធម្មកាយ (ធ័ម-មៈ--) ន.(បា.; សំ. ធម៌កាយ) កាយមួយយ៉ាងក្នុងកាយទាំងបីរបស់ព្រះសព្វញ្ញុពុទ្ធគឺ រូបកាយ, នាមកាយ, ធម្មកាយ; ព្រះធម៌ដែលជាពុទ្ធភាសិតហៅថាធម្មកាយព្រោះទុកដូចជារូបកាយរបស់ព្រះអង្គសូម្បីទ្រង់បរិព្វានទៅហើយ ក៏នៅមានព្រះធម៌នេះជាតំណាងព្រះអង្គ។ ធម្មការ (ធ័ម-មៈ--)ន.(បា.ធម្ម+ការ) ឈ្មោះក្រសួងរដ្ឋមន្ត្រីសម្រេចកិច្ចការខាងសាសនា: ក្រសួងធម្មការ។ធម្មក្ខន្ធ (ធ័ម-ម័ក-ខ័ន) ន. (បា.; សំ. ធម៌ ស្កន្ធ) ពួកធម៌, កងធម៌; ចំនួនកងធម៌ជាពុទ្ធវចនៈក្នុងព្រះត្រៃបិដកហៅថា ព្រះធម៌៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ (ម. ព. ខន្ធ ផង)។ធម្មគុណ(ធ័ម-មៈ-គុណ) ន. (បា.; សំ. ធម៌គុណ) គុណព្រះធម៌ គឺសភាវៈដែលស្រោចស្រង់ទ្រទ្រង់សត្វអ្នកប្រតិបត្តិតាមគន្លងធម៌ឱ្យបានសេចក្ដីសុខ។ ធម្មគោរព(ធ័ម-មៈ-គោរប់) ន. (សំ. ធម៌ + គៅរវ; បា. ធម្ម + គារវ) សេចក្ដីកោតក្រែងចំពោះធម៌ គឺសេចក្ដីប្រព្រឹត្តប្រតិបត្តិតាមគន្លងធម៌ ។ ឈ្មោះសាស្រ្តាប្រែរយមួយខ្សែ សម្រាប់សំដែងជាមុនបង្អស់ប្រាប់សេចក្ដីគោរពធម៌ ក្នុងឱកាសបុណ្យធំៗ តាមទម្លាប់ពុទ្ធសាសនិកជនក្នុងកម្ពុជរដ្ឋ : សាស្រ្តាព្រះធម្មគោរព។

ធម្មចក្ក (ធ័ម-មៈច័ក)ន. (បា.; សំ. ធម៌ចក្រ)ចក្រគឺធម៌ឬធម៌ដូចជាកង់គឺធម៌ដែលព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សម្ដែងជាដំបូងបង្អស់ក្នុងកាលព្រះអង្គបានត្រាស់ទើបបាន ៥៩ថ្ងៃ, ទ្រង់សំដែងអរិយសច្ច ៤ បង្វិលដំណើរសេចក្ដីដូចជាកង់រទេះ។ធម្មចក្កប្បវត្តនសូត្រ (ធ័ម-មៈច័ក-ក័បប៉ៈវ័ត-តៈន៉ៈសូត) ន. (បា.--សុត្ត; សំ. ធម៌ចក្រប្រវត៌នសូត្រ) ឈ្មោះសូត្រដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងធម្មចក្ក ។ ធម្មចក្ខុ (ធ័ម-មៈ-ច័កខុ) ន. (បា.; សំ. ធម៌ចក្សុស៌ ឬ--ចក្សុ)ភ្នែកគឺធម៌ឬធម៌ទុកដូចជាភ្នែក, បានខាងឯអរិយមគ្គជាន់ក្រោមបីប្រភេទគឺ សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ;តែច្រើនសំដៅចំពោះសោតាបត្តិមគ្គ(ម. ព. មគ្គ និងអរិយមគ្គផង)។ ធម្មចេតិយ (ធ័ម-មៈចេតិយ៉ៈ ឬ--ចេដី) ន. (បា.; សំ. ធម៌ចៃត្យ)ចេតិយដែលបញ្ចុះព្រះធម៌។ធម្មមន្ទីរ,តួគម្ពីរឬទូដែលតម្កល់គម្ពីរ,ក្រាំង,សៀវភៅធម៌ជាពុទ្ធសាសនា,ជាសុភាសិតក៏ហៅថាធម្មចេតិយដែរ (ម.ព.ចេតិយ ផង)។ ធម្មជាត ឬធម្មជាតិ (ធ័ម-មៈ-ជាត) ន. (បា.) ធម៌, សភាវៈ, សភាព ។ ធម្មតា (ធ័ម-មៈ-ដា) ន. (បា.) ប្រក្រតី, អ្វីៗដែលតែងមានមក, ទំនៀម, ទម្លាប់ ។ ធម្មទាន (ធ័ម-មៈ--) ន. (បា.) ការឲ្យធម៌ គឺការសម្ដែងធម៌,និយាយ,បង្រៀនធម៌;ការកសាងគម្ពីរដីកាធម៌វិន័យៈ ធ្វើធម្មទាន, កសាងធម្មទាន; ធម្មទានមានផលច្រើនជាងទានទាំងពួង ព្រោះជាគ្រូប្រាប់ផ្លូវខុសត្រូវ ។ ធម្មទូត (ធ័ម-មៈ--) ន. (បា.)ទូតរបស់ធម៌គឺអ្នកដែលគេបញ្ជូនទៅកាន់ទីផ្សេងៗដើម្បីឱ្យផ្សាយធម៌។ ធម្មទេសនា (ធ័ម-មៈ-ទេសៈនា៉ ឬ--ទេស្នា) ន. (បា.) ការ, ដំណើរសំដែងធម៌។ ធម្មធាតុ (ធ័ម-មៈ-ធាត) ន. (បា.) អ្នកមានធាតុជាធម៌ គឺព្រះពុទ្ធ; ធាតុគឺធម៌។ ធម្មនិទ្ទេស (ធ័ម-មៈ-និត-ទេស) ន. (បា.) និទ្ទេសនៃធម៌, ការសម្ដែងញែកចែកនូវធម៌ ។ ធម្មនិយម ឬ ធម្មនិយាម (ធ័ម-មៈនិយំ ឬ--និយាម) ន.(បា.)សេចក្ដីកំណត់តាមធម្មតា។ធម្មនីតិ(ធ័ម-មៈ--) ន. (បា.) ឈ្មោះគម្ពីរមួយដែលសម្ដែងអំពីបែបគតិលោក និងគតិធម៌ ។ ធម្មនុញ្ញ ឬ ធម្មនូញ្ញ (ធ័ម-មៈ-នុញ, ឬ--នូញ) ន. (បា.) ឈ្មោះច្បាប់មួយក្រម សម្ដែងពីរបៀបការក្នុងតុលាការ (ម. ព. រដ្ឋធម្មនុញ្ញផង)។ធម្មន្តេវាសិក(ធ័ម-ម័ន-តេវាសិក) ន. (បា.) សិស្សព្រោះធម៌ គឺអ្នកសិក្សាធម៌អាថ៌អំពីសំណាក់គ្រូអាចារ្យណាមួយ។ធម្មប្បដិបត្តិ(ធ័ម-ម័ប-ប៉ៈ-ដិ-ប៉ុត-តិ ឬ--ប៉ៈដិបាត់) ន. (បា.) ការប្រតិបត្តិធម៌, ការប្រព្រឹត្តតាមច្បាប់ : ព្រះពុទ្ធទ្រង់លើកយកធម្មប្បដិបត្តិមកជាគោលធំបំផុត។ ធម្មប្បដិរូប (ធ័ម-ម័ប-ប៉ៈ ដិ--) ន. (បា.) ការប្រៀបប្រដូចស្រដៀងនឹងធម៌, ធម៌ប្លម, ធម៌ក្លែងក្លាយ : សេចក្ដីត្រង់ឃ្លានេះ គឺជាធម្មប្បដិរូបទេ ។ ធម្មប្បដិសម្ភិទា (ធ័ម-ម័ប-ប៉ៈដិសាំ-ភិទា) ន. (បា.) ការបែកប្រាជ្ញាយល់ធ្លុះធ្លាយក្នុងធម៌, ប្រាជ្ញាបែកភ្លឺស្វាងឥត

ទើសទាក់ក្នុងធម៌។ធម្មបថ(ធ័ម-មៈ-បត់) ន.(បា.) គន្លងធម៌,ផ្លូវធម៌។ធម្មបទ(ធ័ម-មៈ-បត់)ន.(បា.) ផ្លូវធម៌,លំអានធម៌។ឈ្មោះគម្ពីរព្រះពុទ្ធសាសនាក្នុងសុត្តន្តបិតកខាងពួកខុទ្ទកនិកាយហៅថាខុទ្ទកនិកាយ ធម្មបទ, ជាពុទ្ធភាសិតសុទ្ធតែជាគាថាទាំងអស់ហៅថា ធម្មបទគាថា ឬ គាថាធម្មបទ ។ ធម្មបទដ្ឋកថា (ធ័ម-មៈ-ប៉ៈទ័ត-ឋៈកៈថា)ន. (បា.) ឈ្មោះអដ្ឋកថា គឺគម្ពីរអធិប្បាយសេចក្តីគាថាធម្មបទ, អដ្ឋកថានេះមានពីរភាគ, ភាគខាងដើមហៅថា ធម្មបទដ្ឋកថាបុព្វភាគ, ភាគខាងចុងហៅថាធម្មបទដ្ឋកថាបច្ឆិមភាគ។ធម្មបរិយាយ (ធ័ម-មៈ-ប៉ៈរិយ៉ាយ ឬ--បរិ--) ន. (បា.) បរិយាយនៃធម៌, សេចក្តីអធិប្បាយវែកញែកធម៌, ការពន្យល់សេចក្តីតាមដំណើរធម៌ : ធម្មបរិយាយនេះមិនត្រូវតាមរបៀបទេ, ធម្មបរិយាយនោះពីរោះជ្រាលជ្រៅល្អណាស់។ធម្មបាមោជ្ជ(ធ័ម-មៈ-ប៉ាម៉ោច)ន.(បា.ធម្មប្បាមោជ្ជ; សំ. ធម៌ប្រមោទ ឬ ធម៌ប្រាមោទ្យ) សេចក្តីរីករាយចំពោះធម៌ ។ ធម្មបាល (ធ័ម-មៈ--) ន. (បា.) អ្នករក្សាធម៌ ។ ធម្មបីតិ (ធ័ម-មៈ-ប៉ីតិ) ន. (បា. ធម្មប្បីតិ; សំ. ធម៌ប្រីតិ) ដំណើរក្រេបផឹករសធម៌; សេចក្តីរីករាយចំពោះធម៌ : អ្នកមានធម្មបីតិក្នុងសន្តានរមែងសម្រេចឥរិយាបថទាំង ៤ ជាសុខ ។ ធម្មបូជា (ធ័ម-មៈ--) ន. (បា.) បូជាចំពោះធម៌, បូជាចំពោះអ្នកចេះធម៌ឬចំពោះអ្នកប្រព្រឹត្តធម៌ : វត្ថុនេះជាធម្មបូជារបស់ខ្ញុំ ។ ធម្មមន្ទីរ (ធ័ម-មៈ-មន់ទី) ន. (បា. ធម្មមន្ទិរ) ផ្ទះ, កន្លែងតម្កល់ធម៌គឺបណ្ណាល័យតម្កល់គម្ពីរផ្សេងៗ ។ ធម្មមាមកៈ (ធ័ម-មៈ-មាមៈកៈ) ន. (បា. ធម្មមាមក) អ្នកដែលរាប់អានគោរពថាព្រះធម៌ជារបស់អាត្មាអញ គឺអ្នកដែលជឿធម៌ជាពុទ្ធសាសនាស៊ប់ចិត្ត ឥតមានងាកបែរ ។ ធម្មមូល (ធ័ម-មៈ--) ន. (បា.) ឫសគល់នៃធម៌, ទីតាំងនៃធម៌ : សេចក្តីដឹងគុណគោរពអ្នកមានគុណ ជាធម្មមូល ។ ធម្មមោទនា (ធ័ម-មៈមោទៈនា) ន. (បា.) សេចក្តីរីករាយចំពោះធម៌ ។ ធម្មយុត្ត (ធ័ម-មៈ-យុត) ន. ឬ គុ. (បា.; សំ. ធម៌យុក្ត) អ្នកប្រកបដោយធម៌; ដែលប្រកបដោយធម៌ ។ ធម្មយុត្តិកនិកាយ (ធ័ម-មៈ-យុត-តិកៈ) ន. (បា.) ឈ្មោះគណៈបព្វជិតក្នុងព្រះពុទ្ធសាសនាសម័យសព្វថ្ងៃនេះ ដែលជាគូគ្នានឹងមហានិកាយ (ម. ព. នេះផង) ។ ធម្មរក្ខិត (ធ័ម-មៈរ័កខិត) ន. ឬ គុ. (បា.; សំ. ធម៌រក្សិត) អ្នករក្សាធម៌ ។ ពាក្យនេះច្រើនប្រើជាឈ្មោះភិក្ខុឬសាមណេរក្នុងព្រះពុទ្ធសាសនា ។ ចួនកាលប្រើជាសមណស័ក្តិទីរាជាគណៈក៏មាន ។ ធម្មរក្ខិតា (ធ័ម-មៈរ័កខិតា) ន. (បា.) ស្ត្រីដែលជនអ្នកប្រព្រឹត្តធម៌ត្រូវគ្នា គ្រប់គ្រងរក្សាជាធំត្រួតត្រាលើ : ស្ត្រីធម្មរក្ខិតា ។ ធម្មរក្សា (ធ័ម-មៈ-រ័កសា) ន. (បា. ធម៌ + រក្ស) ការរក្សាធម៌ ។ ពាក្យនេះសព្វថ្ងៃ ខ្មែរយើងប្រើជាងារមន្ត្រីក្នុងក្រុមសង្ឃការី : ព្រះធម្មរក្សា ។ ធម្ម

រតនៈ ឬ ធម្មរ័តន៍ (ធ័ម-មៈ-រៈតៈន៉ៈ ឬ--រ័ត) ន. (បា. ធម្មរតន, សំ.ធមិរត្ន) កែវគឺ ព្រះធម៌ ឬព្រះធម៌ដែលទុកជាកែវដ៏វិសេស។ ធម៌រត្ន ឬ ធម៌រ័ត្ន (ធ័ររ័ត) ន. (ដូច គ្នានឹង ធម្មរតនៈ ឬ ធម្មរ័តន៍) ។ ធម្មរាជ (ធ័ម-មៈ-រាច) ន. (បា.) លោកដែលជា ស្ដេចព្រោះត្រាស់ដឹងធម៌ (ព្រះសព្វញ្ញុពុទ្ធ) : ព្រះសម្ពុទ្ធជាធម្មរាជ ។ ធម្មលាភ (ធ័ម-មៈ-លាប) ន. (បា. ធម្ម + លាភ) លាភដែលកើតដោយធម៌, ការបានអ្វីៗ ដោយនូវធម៌ : ទ្រព្យនេះជាធម្មលាភរបស់ខ្ញុំ។ ធម្មលិខិត (ធ័ម-មៈ--) ន. (បា. ធម្ម + លិខិត) អ្នកសរសេរ, កត់ត្រា, ចម្លងធម៌ ។ ពាក្យនេះខ្មែរយើងប្រើជា សមណស័ក្តិខាងបព្វជិតទីរាជាគណៈជាន់ខ្ពស់ : ព្រះធម្មលិខិត; ចួនកាលព្រះ ករុណាជាម្ចាស់ជីវិតទ្រង់ប្រោសព្រះរាជទានតាំងដល់ទីសម្ដេចក៏មាន : សម្ដេច ព្រះធម្មលិខិត ។ ធម្មវិធី (ធ័ម-មៈ--) ន. (បា.) បែបផែននៃធម៌, វិធីប្រតិបត្តិធម៌ ។ ធម្មសង្គាយនា (ម. ព. ធម្មសង្គីតិ)។ ធម្មសង្គាហកត្ថេរ (ធ័ម-មៈ-សង់គាហៈក័ត-ថេរ៉ៈឬ-ថៃ) ន. (បា.) ពួកព្រះថេរៈអ្នកសង្គាយនាធម៌ គឺពួកព្រះថេរានុត្ថេរៈ ដែល ប្រជុំគ្នាផ្ទៀងព្រះត្រៃបិដក ដូចកាលប្រជុំធ្វើបឋមសង្គាយនាជាដើម។ ធម្មសង្គីតិ (ធ័ម-មៈ-សង់គីតិ) ន. (បា.) ការប្រជុំផ្ទៀងធម៌គឺការផ្ទៀងផ្ទាត់រួបរួមធម្មវិន័យឱ្យ មានរបៀបត្រឹមត្រូវតាមបែបដើម (ហៅថា ធម្មសង្គាយនា ក៏បាន)។ ធម្មសង្គីតិ កាចារ្យ (ធ័ម-មៈ-សង់គីតិកាចា) ន. (បា. សំ.; បា. ធម្មសង្គីតិកាចរិយ) ពួកលោក អាចារ្យអ្នកផ្ទៀងផ្ទាត់រួបរួមធម៌ (ពាក្យនេះជាវេវចនៈនៃ ធម្មសង្គាហកត្ថេរ) ។ ធម្មសភា (ធ័ម-មៈ-សៈភា) ន. (បា.; សំ. ធមិសភា) សាលាសម្រាប់ប្រជុំប្រឹក្សា អំពីធម៌។សាលាយុត្តិធម៌; សាលាជំនុំក្តី ។ធម្មស្សវនកាល (ធ័ម-ម័ស-សៈវ៉ៈន៉ៈ--) ន. (បា.; សំ.ធមិស្រវណកាល) កាល,ពេលដែលសាធុជនគួរស្ដាប់ធម៌ (ថ្ងៃសីល ឬក្រៅពីថ្ងៃសីលក៏ដោយ ដែលមានពេលឱកាសគួរសាធុជនស្ដាប់ធម៌ ហៅថា ធម្មស្សវនកាល) ។ ធម្មសាកច្ឆា (ធ័ម-មៈ-សាក័ច-ឆា) ន. (បា.) ការសន្ទនាអំពី ធម៌, ការប្រឹក្សា, សាកសួរអំពីធម៌ : ធ្វើធម្មសាកច្ឆា, ស្ដាប់ធម្មសាកច្ឆា ។ ធម្ម សាត្រ (ធ័ម-មៈ-សាត) ន. (ម. ព. ធម្មសាស្ត្រ) ។ ធម្មសាមី (ធ័ម-មៈ-សាម៉ី) ន. (បា. ធម្មស្សាមី; សំ. ធមិស្វាមិនិ) ម្ចាស់លើគេព្រោះបានត្រាស់ដឹងធម៌ (ព្រះសព្វ ញ្ញុពុទ្ធ) : ព្រះធម្មសាមី; ព្រះសម្មាសម្ពុទ្ធទ្រង់ជាធម្មសាមី ។ ធម្មសារ (ធ័ម-មៈ--) ន. (បា.) ខ្លឹមធម៌, ធម៌មានខ្លឹម គឺធម៌ដែលនាំអ្នកប្រព្រឹត្តឲ្យរួចចាកទុក្ខ ។ ធម្ម សាលា (ធ័ម-មៈ-សាល៉ា) ន. (បា.; សំ. ធមិសាលា) សាលាសម្រាប់សាធុជន ប្រជុំស្ដាប់ធម៌, ប្រឹក្សាអំពីធម៌ : សាលាសម្រាប់ប្រជុំរៀនធម៌ (រោងរៀនធម៌) ។ ធម្មសាសន៍ (ធ័ម-មៈ-សាស) ន. (បា.)ពាក្យប្រដៅប្រកបដោយធម៌,ពាក្យបណ្ដាំ

ឬឱវាទដែលទាក់ទងដោយច្បាប់ ។ ធម្មសាស្ត្រ (ធ័ម-មៈ-សាស) ន. (បា. សំ.; សំ. ធម្មសាស្ត្រ; បា. ធម្មសត្ថ) ឈ្មោះគម្ពីរសំដែងអំពីយុត្តិធម៌ (ខាងតុលាការ) : ច្បាប់ធម្មសាស្ត្រ។ ឈ្មោះក្រមច្បាប់យុត្តិធម៌ (ខាងតុលាការ) : ច្បាប់ធម្មសាស្ត្រ (ហៅក្លាយជា ធម្មសាត្រ ក៏មាន, គួរប្រើ ធម្មសាស្ត្រ ឬ ធម៌សាស្ត្រ វិញ ត្រឹមត្រង់តាមប្រភេទនៃពាក្យ) ។ធម្មសេនាបតី(ធ័ម-មៈ-សេនាប៉ៈដី)ន.(បា.ធម្មសេនាបតិ) នាមវិសេសរបស់ព្រះសារីបុត្តត្ថេរជាអគ្គសាវ័ក (សាវ័កខាងស្ដាំ) នៃព្រះសក្យមុនីសម្ពុទ្ធ;មានន័យមួយផ្សេងថាព្រះខីណាស្រពទាំងអស់ក៏សុទ្ធតែមាននាមវិសេសថា ធម្មសេនាបតីបានដែរ ព្រោះលោកច្បាំងឈ្នះសេនាគឺអកុសលធម៌ ដោយកម្លាំងវេហ៍ពលគឺកុសលធម៌ដូចៗគ្នាទាំងអស់; ប៉ុន្តែពាក្យនេះ ដែលប្រើប្រាកដចំពោះតែជានាមវិសេសរបស់ព្រះសារីបុត្តត្ថេរប៉ុណ្ណោះ : ព្រះសារីបុត្តជាធម្មសេនាបតី, ព្រះធម្មសេនាបតី ។ ធម្មសំវេគ (ធ័ម មៈ-សង្វេក ឬ ធ័ម-មៈ-សង្វែក) ន. (បា.)សេចក្ដីសំវេគចំពោះធម៌មានទុក្ខំ អនិច្ចំ អនត្តាជាដើម(ម. ព. សំវេគផង)។ ធម្មាចារ្យ (ធ័ម-មាចា) ន. (សំ. ធម៌ាចាយ៌; បា. ធម្មាចរិយ) អាចារ្យអ្នកបង្រៀនធម៌, គ្រូព្រះធម៌ : លោកជាធម្មាចារ្យរបស់ខ្ញុំ ។ ធម្មាធិករណ៍ (ធ័ម-មា-ធិ-ក) ន. (បា.ធម្មាធិករណ; សំ.ធម៌ាធិករណ) អធិករណ៍អំពីធម៌; សាលាយុត្តិធម៌, សាលាជំនុំក្ដី។ ធម្មាធិការ (ធ័ម-មា--) ន. (បា.; សំ ធម៌ាធិការ) ដូចគ្នានឹង ធម្មាធិករណ៍ដែរ។ ធម្មាធិការនាយក (ធ័ម-មាធិការ៉ៈនាយក់) ន. (បា.; សំ. ធម៌ាធិ--) នាយក (អធិបតីឬចាងហ្វាង) សាលាជំនុំក្ដី។ធម្មាធិការី(ធ័ម-មាធិការ៉ី) ន.(បា.;សំ. ធម៌ាធិការិន៑) អ្នកពិភាក្សាក្ដី, អ្នកជំនុំក្ដី (ចៅក្រម) ។ ធម្មាធិដ្ឋាន (--ធិតឋាន) ន. (បា.) ការផ្ដងតាំងចិត្តចំពោះធម៌; ការលើកយកធម៌ឬយកច្បាប់មកជាទីតាំង, ពាក្យឬប្រយោគ ដែលនិយាយសំដៅចំពោះអំពើឬចំពោះធម៌ត្រង់ៗតែម្យ៉ាង មិនបាននិយាយដល់រូបបុគ្គលអ្នកធ្វើអ្នកប្រព្រឹត្ត ដូចជាប្រយោគថា : បាបរមែងឱ្យផលអាក្រក់, បុណ្យរមែងឲ្យផលល្អ យ៉ាងនេះជាដើម ហៅថាពាក្យជា ធម្មាធិដ្ឋាន។ ព. ផ្ទ. បុគ្គលាធិដ្ឋាន (ម. ព. នោះផង) ។ ធម្មាធិបតេយ្យ (ធ័ម-មាធិប៉ៈតៃ) ន. ឬ គុ. (បា.) អ្នកដែលមានធម៌ជាអធិបតី គឺអ្នកដែលធ្វើអ្វីៗ អាងដល់ធម៌ និងច្បាប់ជាធំ;ដំណើរដែលអាងដល់ធម៌និងច្បាប់ជាធំ។ធម្មាធិប្បាយ (ធ័ម-មាធិប-បាយ) ន. (បា.)សេចក្ដីអធិប្បាយធម៌,ដំណើរពន្យល់ធម៌។ធម្មានុរូប គុ.(បា.ធម្ម+អនុរូប) ដែលសមគួរ, ដែលមានទំនងដ៏សមគួរតាមធម៌, ដែលស្របទៅតាមធម៌, ដែលសមរម្យត្រឹមត្រូវតាមច្បាប់។ ធម្មារម្មណ៍(--រ៉ម់) ន.(បា.) អារ ម្មណ៍របស់ចិត្ត; អារម្មណ៍ គឺធម៌ ឬធម៌ជាអារម្មណ៍។ក្នុងអភិធម្មត្ថសង្គហៈថាធម៌៦យ៉ាងគឺបសាទរូប១ សុខុមរូប១ ចិត្ត១ ចេតសិក១ រូប១ និព្វាន១ ហៅថាធម្មារម្មណ៍។ធម្មាសនៈ ឬធម្មាសន៍(ធ័មៈមាសៈន៉ៈឬធ័ម-មាស)ន.(បា.ធម្មាសន) អាសនៈសម្រាប់អង្គុយសំដែងធម៌ ឬសម្រាប់អង្គុយសូត្រធម៌, គ្រែសម្រាប់អង្គុយ សម្ដែងធម៌ : អង្គុយ

លើធម្មាសនៈ; គ្រែធម្មាសន៍ ។ ធម្មិក (ធ័ម-មិក) គុ. (បា.; សំ. ធម្មិក) ដែលប្រកបដោយធម៌ : ព្រះបាទធម្មិក,មនុស្សធម្មិក,ទ្រព្យធម្មិក, ភោជនធម្មិក ។ល។ ធម្មិករាជ(ធ័ម-មិកៈរាច) ន. (បា.; សំ. ធម្មិករាជ) ស្ដេចប្រកបដោយធម៌, ស្ដេចទ្រង់ទសពិធធម៌ : ព្រះមហាក្សត្រអង្គនុះ ទ្រង់ជាធម្មិករាជ។ ធម្មុទ្ទេស (ធ័ម-មុត-ទេស) ន.(បា.)ការលើកយកចំនួនមាតិកាធម៌នីមួយៗមកសម្ដែងប្រាប់ឱ្យដឹងថាប៉ុណ្ណេះប៉ុណ្ណោះ ធម្មកថិកមុននឹងអធិប្បាយពន្យល់ធម៌ណាមួយគប្បីសំដែងនូវធម្មុទ្ទេសសិន។ មួយទៀតថា ការលើកយកធម៌ ៤យ៉ាង មកពិចារណាឬយកមកសម្ដែងតាមការណ៍ពិត ហៅថាធម្មុទ្ទេស, ធម៌ ៤ នោះគឺ ៖

១- សត្វលោក សុទ្ធតែឥតទៀងទាត់ឋិតថេរចិរកាលទេ តែងតែលុះក្នុងអំណាចនៃរាជ-ព្យាធិ-មរណៈ គេចមិនផុតឡើយ

២- សត្វលោកឥតមានកន្លែងជ្រកពួនឱ្យរួចអំពីការភិតភ័យទេ

៣- សត្វលោកឥតមានទ្រព្យសម្បត្តិក្រៅពីកុសលកម្មដែលខ្លួនបានកសាងសន្សំទេ រមែងតែលះសរពើទាំងអស់ ហើយចេញចាកលោកនេះទៅៗ

៤- សត្វលោកជាទាសៈនៃតណ្ហាតែងតែមានការខ្វះកន្លះជានិច្ចមិនដែលពេញចំណង់ខ្លួនទេ។ល។

ლლლ𝓌ჯჯჯ

«ខ»

• **ខន្ធ** ខ័ន បា.; សំ. ( ន. ) (ស្កន្ធ) ក; ដើម; គំនរ : ពួក, កង, ប្រជុំ; កំណត់ខន្ធ ៥ គឺរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ។ ទម្លាយខន្ធ ឬរំលាងខន្ធ គឺស្លាប់ ។ រំលត់ខន្ធ គឺចូលនិព្វាន ។

ლლლ𝓌ჯჯჯ

«គ»

• **គម** ( គុ. ) ដែលមានខ្នងពកកំពូកស្រដៀងនឹងបូកគោ : មនុស្សគម, ខ្នងគម, គមគាក់ គមនិងគាក់ (ម. ព. គាក់ ផង) ។

ლლლ𝓌ჯჯჯ

«ច»

• **ច្យុត** សំ.; បា. ( កិ. ) (ចុត) ឃ្លាត, របូត, ស្លាប់, ដែលស្លាប់ហើយ; ច្រើននិយាយចំពោះតែទេវតាអស់ជីវិត : ទេវតាច្យុត ។

• **ចង្វួយ** ( ន. ) រំពាស់, ចុង ដូចយ៉ាងរំពាស់ធ្នូ ឬចុងស្នា ចុងកែងដៃ ជាដើម : ចង្វួយធ្នូ, ចង្វួយស្នា, ចង្វួយដៃ ។

ლლლ𝓌ჯჯჯ

«ជ»

• **ជេតុត្តរ** ជេតុត-ដ បា. ( ន. ) ឈ្មោះក្រុងមួយមាននិយាយក្នុងរឿងវេស្សន្តរជាតក

ជានគរដែលព្រះបាទវេស្សន្តរទ្រង់គង់ ។ ក្រុងកបិលវត្ថុ ឬ កបិលពស្តុ ក៏គឺក្រុងជេតុត្តរពីដើមនុ៎ះឯង ។

- **ជាលី** សំ.; បា. ( ន. ) (ជាលិនិ) ព្រះនាម/ព្រះរាជបុត្រ នៃព្រះបាទស្រីវេស្សន្តរ (ក្នុងវេស្សន្តរជាតក); ច្រើននិយាយថា : បាជាលី ឬ នាងក្រឹស្នា បាជាលី ។
- **ជាតក** ជាដក់ សំ. បា. ( ន. ) រឿងរ៉ាវពីក្នុងជាតិមុនៗ ដែលលោកអ្នកបានលុះញាណវិសេស សម្រាប់ដឹងជាតិ លោកសំដែងប្រាប់ យ៉ាងដូចជាតកទាំង ១០ មានតេមិយជាតកជាដើម ដែលព្រះសក្យមុនីសព្វញ្ញុពុទ្ធទ្រង់សំដែង ។ ឈ្មោះអង្គនៃពុទ្ធសាសនាមួយយ៉ាងក្នុងអង្គទាំង៩ ។
- **ជូជក** --ជក់ បា. ( ន. ) ឈ្មោះព្រាហ្មណ៍ម្នាក់ជាស្វាមី មានក្នុងរឿងវេស្សន្តរជាតក ។ គ្រោះជូជក គ្រោះធ្ងន់ដូចតាជូជកដែលបរិភោគអាហារច្រើនជ្រុលហួសប្រមាណ ទាល់តែចាក់ច្រាសស្លាប់ខ្លួនអសារឥតការ ខានបានប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិដែលព្រះបាទស្រីសញ្ជ័យ ទ្រង ។
- **ជ្រនីក** ( ន. ) ប្រដាប់សម្រាប់ជីក, ច្រើនធ្វើដោយកំណាត់ឈើ ឬ គល់ឫស្សី, ប្រើជាជំនួសចបជីក។

ឈឈឈញញញ

«ត»

- **តារាង** --រ៉ាង ( ន. ) ចម្រៀក,បន្ទះឈើឬឫស្សីជាដើមដែលដាក់ខ្វែងជាក្រឡា: ធ្វើតារាង, ចងតារាង ។ គំនូសបន្ទាត់មានក្រឡា ក៏ហៅតារាងដែរ : តារាងបញ្ជី។ ក្រដាសតារាង គឺក្រដាសដែលមានបន្ទាត់ខ្វែង។
- **តម្លឹង** តំ-លឹុង ( ន. ) ឈ្មោះទម្ងន់ដែលថ្លឹងមានចំនួន ១០ ជី : មាសមួយតម្លឹង។
- **ត្រាច់** ( កិ. ) ដើរ, ចរ, អន្ទោល : ត្រាច់ទៅមក (បុរាណពីដើមសរសេរ : ត្រេច)។ ត្រាច់វង្កាត់ គឺអន្ទោលកើតស្លាប់ក្នុងវាលវដ្តសង្សារ។
- **ត្រ័យត្រិង្ស** --ត្រឹង សំ.; បា. ( ន. ) (ត្រយស្រ្តឹសត្; តេត្តឹស ប. សំ. "សាមសិបបី"; ជាពាក្យប្រាប់ចំនួនទេវតា ៣៣ អង្គ ជាបរិវារនៃព្រះឥន្ទ្រ) ខ្មែរយើងប្រើពាក្យនេះជាឈ្មោះឋានកាមាវចរសួគ៌ជាន់ទី២: ឋានត្រ័យត្រិង្ស ឬត្រៃត្រិង្ស(ម. ព.តាវត្តិង្ស)។

ឈឈឈញញញ

«ថ»

- **ថ្កាន** ( អា. និ. ) កាន់, ត្រង់, ឆ្ពោះ, សំដៅ, ចំពោះទៅរក (ច្រើនប្រើតែក្នុងកាព្យ)។ ( ប. ) ពាក្យសម្រាប់និយាយផ្សំនឹងពាក្យថ្កើង : ថ្កើងថ្កាន គឺថ្កើងរុងរឿង, ថ្កើងមានកេរ្តិ៍ឈ្មោះខ្ពស់ត្រដែត ។

ឈឈឈញញញ

«ទ»

- **ទូទ័រ** ( កិ. ឬ កិ. វិ. ) ឮសូរខ្ទ័រទូទៅ, ឮសាយសុស : កិត្តិស័ព្ទរបស់អ្នកប្រាជ្ញអាចលេចឮទូទ័រសព្វទិសទី ។ ទូទ័រ

• **ទ្រទេស** ( គុ. ) ល្វាសល្ងន់សមរម្យ (ច្រើននិយាយតែពីក្បាច់ភ្ញី) ។
ទ្រទេសទ្រទ្ទយ ទ្រទេសទងវង ។

• **ទ្រទ្ទយ** ( គុ. ) ដែលមានសណ្ឋានរាង-ង ដូចគេស្ទួយ ។

• **ទ្រទេស** ( គុ. ) ល្វាសល្ងន់សមរម្យ (ច្រើននិយាយតែពីក្បាច់ភ្ញី) ។
ទ្រទេសទ្រទ្ទយ ទ្រទេសទងវង ។

ɷɷɷɷɷɷ

«**ន**»

• **និបាត** សំ. បា. ( ន. ) ឈ្មោះពួកគម្ពីរសម្ដែងរឿងនិទានរបស់ព្រះពុទ្ធ កាលកើតក្នុងជាតិមុនៗ ជាគម្ពីររាប់បញ្ចូលក្នុងព្រះត្រៃបិដកប៉ែកព្រះសូត្រ ខាងខុទ្ទកនិកាយ : គម្ពីរនិបាត, គម្ពីរនិបាតជាតក ។ និបាតជាតក

• **និមិត** បា.; សំ. ( កិ. ) (និម្មិត; និរ្មិត) បង្កើតដោយឫទ្ធិ, កាឡាខ្លួន, ដំណែងខ្លួន ។ (ប្រើជា និម្មិត ត្រឹមត្រូវជាង និមិត) ។ និម្មិត

ɷɷɷɷɷɷ

«**ប**»

• **បដិសន្ធិ** ប៉ៈដិសន់ធិ បា.; សំ. ( ន. ) (ប្រតិ--) តំណកំណើតសត្វ : ចាប់បដិសន្ធិក្នុងផ្ទៃមាតា ។ ព. ផ្ទ. ចុតិ ឬ ច្យុតិ ។

• **បោក្ខរព័សៃ** បោក-ខៈរ៉ៈ ព័រ បា.និង សំ. ក្ល.; បា.; សំ. ( ន. ) (បោក្ខរ "ឈូក" + វស្ស "ភ្លៀង" >បោក្ខរវស្ស; បុក្ករ + វម៌)ភ្លៀងមានអាការដូចជាទឹកធ្លាក់លើស្លឹកឈូក។ កាលដែលព្រះសក្យមុនីសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ហើយពុំយូរប៉ុន្មាន, ទ្រង់ស្ដេចត្រឡប់ចូលមកក្រុងកបិលវត្ថុជាជាតិភូមិរបស់ព្រះអង្គ ...ទ្រង់បណ្ដាលឱ្យធ្លាក់ភ្លៀងជាអស្ចារ្យ ក្នុងទីប្រជុំនៃពួកព្រះញាតិ, បើអ្នកណាចង់ឲ្យទទឹកក៏ទទឹក, អ្នកដែលមិនចង់ឲ្យទទឹកទេ ភ្លៀងនោះក៏ពុំទទឹកឡើយ គឺគ្រាន់តែធ្លាក់មកត្រូវប៉ុន្តែរអិលជ្រុះដូចជាទឹកធ្លាក់លើស្លឹកឈូក, ហៅថា បោក្ខរព័សៃ ឬ ភ្លៀងបោក្ខរព័ស្ស (ក្នុងពុទ្ធប្រវត្តិ) ។ បោក្ខរព័ស្ស

• **បព្វៈ** ប័ប-ព: បា.; សំ. ( ន.) (បព្វ; បរ៌និ) សន្លាក់; ថ្នាំង; ថ្នាក់; សង្កាត់; សង្កាត់សេចក្ដី : បព្វៈទី១ បព្វៈទី២ ។

• **ប្រលង់** --ល័ង់ ( ន. ) ក្រហូងតូចៗ ដែលដក់ទឹកប្រឡង់ (ច្រើនប្រើប្រឡង់ជាង) : ប្រឡង់ទឹក, វែកប្រឡង់។ ប្រឡង់

ɷɷɷɷɷɷ

«**ព**»

• **ព** ( កិ. ) លើកដាក់ចង្កេះកៀកនឹងដៃ ឈរឬដើរ : ពកូន ។ ព. ប្រ. ពផែនដី រក្សាផែនដី គឺគ្រប់គ្រងរក្សាអាណាចក្រនីមួយៗ ។ ពពោះ មានផ្ទៃពោះ

(ផើម)។ ទទួលរងធ្វើកិច្ចការរបស់អ្នកដទៃឱ្យនៅលើខ្លួនទាំងអស់; ទទួលរ៉ាប់រងទុក្ខលំបាកជាងគេឬជាជំនួសអ្នកដទៃ : ពកិច្ចការ, ពគំនរទុក្ខ, ពការនឿយហត់, ពរវល់ ។

ᨀᨀᨀ

«ម»

- **មទ្រី** ម័ត-ទ្រី ឬម:-- សំ.; បា. ( ន. ) (មទ្ទី) ព្រះនាមព្រះរាជបុត្រីមួយអង្គនៃព្រះបាទមទ្ទរដ្ឋត្រូវជាព្រះអគ្គមហេសីនៃព្រះបាទស្រីវេស្សន្តរ,ក្នុងវេស្សន្តរជាតក(ព. ពុ.) : ព្រះនាងមទ្រី ។
- **មទ្ទរដ្ឋ** ម័ត-ទ:រ័ត បា.; សំ. ( ន. ) (មទ្ទ + រដ្ឋ; មទ្រ + រាស្ត្រ) ដែនមទ្ទ:ឬដែនមទ្រ: (ឈ្មោះដែនមួយក្នុងប្រទេសឥណ្ឌា, ច្រើនមាននិយាយតំណាលក្នុងគម្ពីរខាងពុទ្ធសាសនា) ។ មទ្ររាស្ត្រ

ᨀᨀᨀ

«យ»

- **យោជន៍** យោច សំ. បា. ( ន. ) (យោជន) ឈ្មោះមាត្រាវាស់ឬរង្វាស់បុរាណ សម្រាប់ វាស់ ប្រវែងភូមិភាគឬចម្ងាយផ្លូវចំនួន៤គាវុត គឺ ៤០០ សិន : ផ្លូវចម្ងាយ ៨ យោជន៍ ។ បើវាស់កម្ពស់ដូចយ៉ាងកម្ពស់ភ្នំ, កម្ពស់ដើម ឈើធំជាដើមកំណត់ត្រឹម ៧ ហត្ថជា ១ យោជន៍ : ដើមជ្រៃក្រឹមកម្ពស់ ៣ យោជន៍កន្លះ (មើលក្នុងពាក្យ លិក្ខា ឬ លិក្យា ទៀតផង)។

ᨀᨀᨀ

«រ»

- **រាជគ្រឹះ** ឈ្មោះរាជធានីមួយរបស់ដែនមគធ: (ក្នុងបុរាណសម័យ) ជាក្រុងមានឈ្មោះលេចឮក្នុងគម្ពីរពុទ្ធសាសនា (ម. ព. មគធ: ផង) ។

ᨀᨀᨀ

«ល»

- **លោះ** ( កិ. ) ចេញថ្លៃយករបស់ដែលបញ្ចាំឬយកមនុស្សមកធ្វើជាទាស:ឬទាសី : លោះរបស់បញ្ចាំ; លោះមនុស្សប្រើ (មានតែក្នុងសម័យពីដើម) ។ សងប្រាក់ទៅម្ចាស់បំណុលសុំដកខ្លួនឲ្យរួចអំពីទាសភាព : លោះខ្លួនឲ្យរួចជាអ្នកជា ។ ចាញ់ : លោះកាំភ្លើង, លោះស្នា ។ ព. ប្រ. ស្ដីឲ្យម៉ុំងៗឬខ្ជាំងៗ ឬក៏ជេរពេញទ្រពងមាត់ឥតក្រែង : លោះតែពីរបីម៉ាត់ទៅ បាត់មាត់ដូចគេចុក ។

ᨀᨀᨀ

«វ»

• **វង្កត** វង់កត់ បា. ( ន. ) ឈ្មោះភ្នំមួយក្នុងពួកភ្នំហិមពាន្ត : ភ្នំវង្កត (ភ្នំមានសណ្ឋានវៀច); ហៅ វង្កតបព៌ត ឬ វង្កតគិរី ឬហៅតាមទម្លាប់ថា គិរីវង្កត ក៏បាន(មាននិយាយក្នុងវេស្សន្តរជាតក) ។

• **វេឡុវ័ន** បា.; សំ. ( ន. ) (វេឡុ; វេណុ ឬ វេណូ "ឫស្សី" + វន "ព្រៃ") ព្រៃឫស្សី ។ ឈ្មោះឧទ្យានព្រៃឫស្សីដែលព្រះបាទពិម្ពិសារ (មគធរាជ) សាងជាអារាមថ្វាយព្រះសក្យមុនី, ជាវត្តធំ កើតមានមុនវត្តឯទៀតៗក្នុងពុទ្ធកាល : វត្តវេឡុវ័ន ។

•**វេស្សន្តរ** វេស-សន់តៈរ៉ៈ ឬ--សន់-ដ បា. សំ. ( ន. ) (< វេស្ស "ឈ្មួញ; ពួកជនវេស្ស" + អន្តរ "ចន្លោះ; រវាងពាក់កណ្ដាល";វៃគ្យាន្តរ<វៃគ្យ + អន្តរ)រវាងឬទីពាក់កណ្ដាលផ្លូវពួកវេស្សៈ។ ព្រះនាមពោធិសត្វក្នុងមហាវេស្សន្ត\\រជាតក (បានជាថ្វាយព្រះនាមដូច្នេះ ព្រោះទ្រង់ប្រសូតក្នុងពាក់កណ្ដាលទីប្រជុំផ្លូវពួកវេស្សៈ)។ វេស្សន្តរជាតក (វេស-សន់-តៈរ៉ៈជាដក់) ឈ្មោះគម្ពីរជាតក សម្ដែងរឿងព្រះវេស្សន្តរ(គម្ពីរមហាជាតក៍)។

ឲឲឲ៙៚៚

«**ស**»

• **សរ** ស បា. ( កិ. ) រឭក, រឭកឃើញ, នឹកឃើញ, សាដឹងឡើងវិញ ។ សរជាតិ ដឹងជាតិ ។ សរញ្ញាណ ពិចារណាឬរំពឹងដឹងហេតុច្បាស់ទៅខាងអតីតកាល ឬខាងអនាគតកាល : ព្រះពុទ្ធទ្រង់សរញ្ញាណ... (បា. សរញ្ញាណ ន. ញាណឬប្រាជ្ញាជាគ្រឿងរឭកឃើញ) ។

• **សិន** ( ន. ) មាត្រារង្វាស់ឬចម្ងាយប្រវែង ២០ ព្យាម ។

• **សក្ក** បា.; សំ. ( ន. ) (សក្ក; គក្យ) ពួកសាក្យៈ, សាក្យរាជ; ព្រះសក្យមុនីគោតម ។ (សំ. គក្រ)ព្រះឥន្ទ្រ ។ សក្កជនបទ ឬ សក្ករដ្ឋ ជនបទឬខេត្តដែនរបស់ពួកសាក្យៈដែនជាជាតិភូមិរបស់ព្រះសក្យមុនីសម្ពុទ្ធ។ សក្កទេវរាជ ព្រះឥន្ទ្រាធិរាជ។ល។

• **សុទ្ធោទនៈ** សុត-ធោទៈ នៈ បា.; សំ. ( ន. ) (សុទ្ធោទន < សុទ្ធ "ស, ស្អាត" + ឱទន "បាយ"; គុទ្ធោទន ឬ គុទ្ធៅទន < គុទ្ធ + ឱទន) បាយសុទ្ធឬបាយ-ស ។ ព្រះនាមព្រះវរបិតានៃព្រះសក្យមុនីគោតម : ព្រះបាទសុទ្ធោទនៈពុទ្ធបិតា ឬ ព្រះបាទស្រីសុទ្ធោទន៍ក្សត្រិយ៍ក្រុងកបិលពស្តុ; ។ សុទ្ធោទន៍។

• **សុបិន** បា.; សំ. ស្វប្ន (ន.) ការដេកលក់ ។ ប្រើសំដៅសេចក្ដីថា"ការយល់សប្តិឃើញ" យប់មិញខ្ញុំមានសុបិនមិនល្អ។ សុបិននិមិត្ត ការយល់សប្តិឃើញមានទំនងជាគ្រឿងសង្កេតបាន ( ថានឹងមានហេតុអាក្រក់ឬល្អ ) ។

• **សស្លក់** ( ប. ) ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ សស្លើត ថា : សស្លក់ស្លើត ឬ សស្លើតសស្លក់ (ម. ព. សស្លើត និង សស្លើតសស្លក់) ។

• **ស្លឹករឹត** ( ន. ) ស្លឹកទ្រាំង ដែលកាត់ហាលថ្ងៃស្ងួតហើយសម្រាប់ប្រើការផ្សេងៗមាន ចារសាស្ត្រា, ត្បាញការុងជាដើម : សាស្ត្រាស្លឹករឹត, ការុងស្លឹករឹត, ដួនស្លឹករឹត ។ ឆ្អឹងរឹត ទ្រនុងស្លឹករឹត ។

•**សាស្ត្រាស្លឹករឹត** តាមការពន្យល់ពាក្យនេះរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត សាស្ត្រាក្នុងភាសាបាលីនិងសំស្រ្កឹតមានន័យថាក្បួនច្បាប់ដែលស្ដីអំពីចំណេះដឹង វិទ្យាសាស្ត្រ សាសនា ច្បាប់ ទ្រឹស្ដីផ្សេងៗអំពីជីវិត។ ហើយអ្នកអក្សរសាស្ត្រ មួយចំនួនបានលើកឡើងថាសាស្ត្រាស្លឹករឹតមានកំណើតតាំងពីសម័យអង្គរ។សាស្ត្រាស្លឹករឹតត្រូវបានផ្សព្វផ្សាយដល់ប្រជាជនខ្មែរច្រើនសម័យកាលយកមកប្រើប្រាស់បានច្រើនសម័យកាលវប្បធម៌នៃសិលាចារឹកក៏ត្រូវបានបាត់បង់បន្តិចម្ដងៗ។ប៉ុន្តែ ប៉ុន្តែ សព្វថ្ងៃសាស្ត្រាស្លឹករឹតភាគច្រើនប្រើប្រាស់តែក្នុងវត្ត អារាមខ្មែរតែប៉ុណ្ណោះ ដូចនេះ វាក៏ត្រូវបានបាត់បង់បន្តិចម្ដងៗ ដោយសារកំណែប្រែនៃបច្ចេកវិទ្យាទំនើប មានដូចជាសៀវភៅជាដើម។ សាស្ត្រាស្លឹករឹត មានន័យថាគម្ពីរដែលយកស្លឹករឹតមកចារដែលស្លឹកនោះគឺដើមទ្រាំង។សាស្ត្រាស្លឹករឹតអាចជាគម្ពីរសាសនា ឬ ជាគម្ពីរនៃពង្សាវតារខ្មែរ។

ៜៜៜ

«**ហ**»

• **ហិមពាន្ត** ហិ-មៈពាន បា. ( ន. ) (ហិមវន្ត "មានទឹកសន្សើម" > ហិមវន្ត; ខ្មែរប្រើ វ > ព, ព > ពា) ប្រទេសឬភ្នំមានទឹកសន្សើម : ព្រៃហិមពាន្ត, ភ្នំហិមពាន្ត (ម. ព. ហិមៈ ផង) ។ ខ្មែរប្រើក្លាយជា ហេមពាន្ត ក៏មាន, ប្រើក្លាយឃ្លាតទៅទៀតជា ហេម្ពពាន្ត ក៏មាន, ព. កា. ប្រើជា ហិមវ័ត, ហេមវ័ត, ហិមវ័ន្ត, ហេមវ័ន្ត, ហេមវា ក៏មាន; សម័យសព្វថ្ងៃនេះលេចឮឈ្មោះក្នុង

• **ហិមាល័យ** ឬ ហិមាលយា (ម. ព. នេះទៀតផង)។ ផុស្សតី ផុស-សៈដី ( ន. ) នាមព្រះនាងទេវីជាព្រះមាតានៃព្រះវេស្សន្តរក្នុងវេស្សន្តរជាតក (មហាជាតក៍) : ព្រះនាងផុស្សតី ជាព្រះអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យ...។ មហាជាតក៍ប្រែរយ ប្រើក្លាយជា សុបារសុបតី ឬ សុបារសបតី ឃ្លាតឆ្ងាយណាស់អំពីបាលីមហាវេស្សន្តរជាតក ។

ៜៜៜ

«**អ**»

• **អាជានេយ្យ** --នៃ បា.; សំ. ( ន. ) (អាជានីយ ក៏មាន; អាជានេយ) អ្នកដែលដឹងសេចក្តីឆាប់រួសរាន់, អ្នកមានចិត្តរួស, អ្នករហ័សដឹង ។ សេះមានពូជល្អ, សេះមានពូជលឿន; សេះមានល្បឿនលឿនរួសរាន់ទាន់ចិត្ត; សេះល្អដែលបង្ហាត់បានបទ : សេះអាជានេយ្យ (បុ. សរ. ជា អាជានៃយ ក៏មាន; ព. កា. ប្រើជា អាជានីយ

ក៏បាន)។សេះសិន្ធពអាជានេយ្យ សេះសិន្ធពមានល្បឿនលឿនរួសរាន់ទាន់ចិត្ត។ គម្ពីរពុទ្ធសាសនាប្រាប់សេចក្ដីថា អាជានេយ្យ មាន ៤ ប្រភេទគឺ ១-បុរសអាជានេយ្យ ព្រះពុទ្ធ, ព្រះអរហន្ត (បា. បុរិសាជានេយ្យ); ២-ដំរីអាជានេយ្យ ដំរីមង្គលដែលហ្មបង្ហាត់បានបទឬដំរីសឹក (បា. ហត្ថាជានេយ្យ); ៣-សេះអាជានេយ្យ សេះលឿនវិសេសដែលបង្ហាត់បានបទ(បា. អស្សាជា-នេយ្យ); ៤-គោអាជានេយ្យគោឧសភដែលបរិបូណ៌ដោយលក្ខណៈល្អហើយគេបង្ហាត់បានបទ (បា. គោអាជានេយ្យ ឬគវាជានេយ្យ) ។

- **អារាធនា** --រ៉ាធៈនា សំ. បា. ( ន. ) (អារាធន) សេចក្ដីពេញចិត្ត; ការរាប់រក; ការឱបអរ; ការយកចិត្តយកថ្លើម; ការប្រោសប្រាណ; ការបូជា; សេចក្ដីសម្រេច; ការនិមន្ត, ការអញ្ជើញ ។ ខ្មែរប្រើជា កិ. សំដៅសេចក្ដីថា "និមន្តឬអញ្ជើញដោយគោរព សូមឲ្យសូត្រឬឲ្យសម្ដែង, ឱ្យនិយាយអធិប្បាយ" ជាដើម (ប្រើចំពោះតែទៅរកបព្វជិត): ពួកឧបាសកឧបាសិកាអារាធនាសីល; អាចារ្យអារាធនាព្រះបរិត្ត, អារាធនាធម៌ទេសនា។(ព. កា.):អ្នកមានវិជ្ជាឥតអារាធនា កុំពោលអួតខ្លួន ព្រោះនាំឱ្យសាបបង់ភាពខ្ជាប់ខ្ជួន ចំណេះមាំមួនបែរជាទន់ខ្សោយ។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ សរសេរជា អារាធន តាមរូបដើម, ប្រើជាន. (អ. ថ. --រ៉ាធៈនៈ), ដូចជា អារាធនកថា ពាក្យនិមន្ត, ពាក្យអញ្ជើញ ។ អារាធនការណ៍ ហេតុដែលនាំឱ្យមានសេចក្ដីពេញចិត្ត, ឱ្យរាប់រក, ឱ្យយកចិត្តយកថ្លើម;... ។ អារាធនភាពភាពនៃសេចក្ដីពេញចិត្ត, នៃការរាប់រក... ។ល។

## ឯកសារពិគ្រោះ

១.សិក្សារឿងមហាវេស្សន្តរជាតក ឆ្នាំ១៩៩៤ បណ្ឌិត ធ សោ សាស្ត្រាចារ្យសាកលវិទ្យាល័យភ្នំពេញ

២.សិក្សាអត្ថបទរឿងព្រះវេស្សន្តរ សំរាប់ថ្នាក់ទី១០ សាធារណៈរដ្ឋប្រជាមានិតកម្ពុជា

៣.សាកល្បងសិក្សាមហាវេស្សន្តរជាតកពថ្នាក់ទី១ទំនើប និពន្ធដោយ «ឡុង សៀម» សាស្ត្រាចារ្យវិទ្យាល័យព្រះយុគន្ធរ ផ្សាយចេញពីបណ្ណាគារ សម្បូណ៌

៤.យើងហុកឌី មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី២០ ឆ្នាំ ២០០២

៥.ឈឹម សុមន៍ សង្ខេបទសជាតក ការផ្សាយរបស់ពុទ្ធសានបណ្ឌិត្យ ភ្នំពេញព.ស.២៥០២ គ.ស.១៩០២

៦.ញ៉ុក ថៃម មហាវេស្សន្តរជាតក ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស.២៥០៩ គ.ស.១៩៦៦ បោះពុម្ពផ្សាយឡើងវិញដោយអាគារបោះពុម្ពផ្សាយវប្បធម៌ ១៩៩០

៧.សៃម សូវ អត្ថាធិប្បាយមហាវេស្សន្តរជាតក មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រភ្នំពេញ គ.ស.១៩៦៨

៨.សៃនសូវ បរិមាធិប្បាយពិសេសព.ស.២៥១៣ គ.ស.១៩៧០

៩.លាង ហាប់ អាន សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរភាគ១និង២ ព.ស.២៥១១ គ.ស.១៩៦៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង មហោសថជាតក

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:.................................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងមហោសថជាតក»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងមហោសថជាតក » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមានការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាមអនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជានេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាពចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការបច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី»ការសិក្សាអត្ថបទអក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបានជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ"**សិក្សាអត្ថបទអក្សរសិល្ប៍**" ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជាៈ

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ«**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងមហោសថជាតក**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក យិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ គាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារឹទ្ធ

# មាតិកា

ទំព័រ

ប្រកាស ....................................................................................................i
បុព្វកថា ....................................................................................................ii
គណៈកម្មការ....................................................................................................iii
អារម្ភកថា....................................................................................................iv
មាតិកា....................................................................................................v
សេចក្ដីផ្ដើម....................................................................................................
I. ការបង្ហាញអត្ថបទ....................................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង....................................................................................................
III. ទិដ្ឋភាពទំនាស់....................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ....................................................................................................
V. ទិដ្ឋភាពសង្គម....................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ....................................................................................................
VII. ទិដ្ឋភាពតម្លៃ....................................................................................................
VIII. ការសន្និដ្ឋាន....................................................................................................
IX. ឯកសារពិគ្រោះ....................................................................................................

**សិក្សាអត្ថបទអក្សរសិល្ប៍**

## រឿង មហោសថជាតក

**I-ការបង្ហាញអត្ថបទ**

**១-អត្ថបទ**

**ក-ចំណងជើង** : **រឿងព្រះមហោសថ**

**ខ-ប្រភពរឿង**

រឿងមហោសថនេះ ក៏ជារឿងមួយមានប្រជាប្រិយភាពនៅក្នុងប្រទេសខ្មែរយើងដោយ អ្នកប្រាជ្ញខ្មែរបុរាណបានចារទុកក្នុងសាស្ត្រាស្លឹករឹតមានរបៀបរៀបចំពាក្យជាកម្រងកែវ ការប្រើ ពាក្យពេចន៍ អក្ខរាវិរុទ្ធក្នុងសម័យនោះ។ លុះសម័យក្រោយមកក្នុងព.ស២៥០៥ គ.ស១៩៦២ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានចម្លងបោះពុម្ពសៀវភៅមហោសថ ដោយរក្សាពាក្យពេចន៍តាមច្បាប់ដើមគ្រាន់តែបានកែអក្ខរាវិរុទ្ធមកប្រើតាមវចនានុក្រមខ្មែរសម័យនោះតែប៉ុណ្ណោះក្នុង ព.ស២៥០២ គ.ស១៩៥៩។ លោកបណ្ឌិតមហា ឈឹម សុមន៍ ជាសាស្ត្រាចារ្យនៅពុទ្ធិក វិទ្យាល័យព្រះសុរាម្រិត (ភ្នំពេញ)បានរៀបរៀងសៀវភៅសង្ខេបទសជាតកនេះឡើងសមស្របតាមវប្បធម៌ និងការរស់នៅរបស់ប្រជាជនខ្មែរ ដែលក្នុងនោះបង្ហាញអំពីអតីតពុទ្ធប្រវត្តិរបស់ ព្រះពុទ្ធបរមគ្រូនៃយើងទាំង១០ជាតិរួមទាំងរឿងមហោសថផងដែរដែលជាសេចក្តីសង្ខេបល្មម សមស្តាប់បានស្រួល។

ប្រភពដើមនៃរឿងនេះជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយជាតក មហានិបាត ដែលគេប្រកាន់ជឿថាជាព្រះពុទ្ធវចនៈក្នុងគម្ពីរជាតកអដ្ឋកថាដែលមានជាងពីរពាន់ឆ្នាំមកហើយ។

**គ-ប្រភេទរឿង** : រឿងព្រះមហោសថ ជាអក្សរសិល្ប៍បុរាណប្រភេទសាស្ត្រាទេសន៍។

**ឃ-ចលនា** : ស្ថិតក្នុងចលនាអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ។

**២-អ្នកនិពន្ធ**

**ក-ឈ្មោះអ្នកនិពន្ធ**

អ្នកនិពន្ធផ្ទាល់ គឺព្រះសមណគោតនាមជាអ្នកតំណាលរឿងនេះឡើង ខណៈពេលព្រះអង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ដោយរឿងនេះ មានការពេញនិយមពីសំណាក់ ប្រជាពលរដ្ឋខ្មែរ ដែលជាពុទ្ធសាសនិកគ្រប់កន្លែង។ដូច្នេះក្នុងព.ស២៤៨៩ត្រូវនឹងគ.ស១៩៤៦ ព្រះគ្រូបុរត្ថិមវាសី អ៊ូ ចេវ គង់នៅវត្តលង្កា បានរៀបចំសង្ខេបរឿងមហោសថនេះឱ្យ នៅខ្លី ដើម្បីកុំឱ្យវែងពេក និងងាយសម្តែងធម៌ទេសនា។ ក្រោយមកព្រះមហា គង់ កេត និង ព្រះចិន យ៉ាន គង់នៅវត្តបទុមគង្គា ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ក៏បានសរសេរ ជាសម្រាយសេចក្តីនូវរឿងព្រះមហោ

សុថ(មហោសថ) ដែលមាន៣ភាគនៅបណ្ណាគារគីមគី(រាជធានីភ្នំពេញ) ដើម្បីផ្សព្វផ្សាយជូនប្រជារាស្ត្រសម្រាប់ជាប្រយោជន៍នៃប្រាជ្ញាទាំងឡាយ ក្នុងប្រទេសកម្ពុជានាថ្ងៃទី១៣ ខែ តុលា ព.ស ២៤៩៥ គ.ស ១៩៥២។ ក្រោយមកទៀត លោកបណ្ឌិតមហា ឈឹម សុមន៍ ក៏បានធ្វើការកែសម្រួល និងសង្ខេបឡើងវិញនៅថ្ងៃទី១៦ ឧសភា ព.ស២៥០២ត្រូវនឹង គ.ស១៩៥៩ ហើយ ត្រូវបានក្រសួងសិក្សាធិការជាតិ និងវិចិត្រ សិល្បៈបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកម្រិតមធ្យម ថ្នាក់ទី២ទំនើប នាថ្ងៃទី១៣ មិថុនា ឆ្នាំ ១៩៦២និងអនុញ្ញាតឱ្យប្រើប្រាស់នៅគ្រប់សាលារៀន សាធារណៈក្នុងព្រះរាជណាចក្រកម្ពុជា។

## ខ-ជីវប្រវត្តិ

លោកបណ្ឌិតមហា ឈឹម សុមន៍កើតក្នុងឆ្នាំ១៩០៥ ព.ស ២៤៥០ នៅឃុំបសែត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ អាយុ១២ បួសជាសាមណេរសិក្សាក្នុងសំណាក់ព្រះគ្រូអាចារ្យ កន នៅឃុំវាល ស្រុក គងពិសី(លោកត្រូវជាក្មួយប្រសារបស់សម្តេចព្រះសង្ឃរាជ ជួន ណាត និងកូនប្រុសរបស់លោកឈ្មោះឈឹម សុមេធ ជាអតីតសាស្ត្រាចារ្យ និងបច្ចុប្បន្នធ្វើការនៅវិទ្យុ VOA)[1] ហើយនៅអាយុ២០ឆ្នាំ លោកចូលរៀនកច្ចាយនៈវេយ្យាករណ៍ និងសម្ព័ន្ធម្តងទៀតក្នុង សំណាក់ ព្រះជេគុណព្រះវិភទ្ធញ្ញាណសោម ឡុច(មហា៩ប្រយោគ) វត្តលង្កាក្រុងភ្នំពេញ។ នៅអាយុ២១ឆ្នាំ លោកជាសិស្សសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ហើយនៅឆ្នាំដដែល នេះលោកបានប្រឡងជាប់សាលាបាលីជាន់ខ្ពស់ និងធ្វើជាគ្រូឧទ្ទេសាចារ្យបង្រៀនភាសាបាលីរងនៅវត្តលង្កាកុសុមារាម ក្រុងភ្នំពេញ។លោកទទួលអនិច្ចកម្មនៅឆ្នាំ១៩៧៥។

## គ-ស្នាដៃសំខាន់ៗ

-ធម្មបទកថានានានិទាន (អាគារវិន័យ) វេយ្យាករណ៍បាលី

-ប្រស្នាវិន័យ ភាគ១.២.៣.៤ ពុទ្ធប្រវត្តិកថា (ប្រវត្តិទី១ នៃពុទ្ធសាសនា)

-អធិប្បាយគាថាធម្មបទ ភាគ ១.២.៣.៤ ជាតកធម្មបទ (គំរូតែងរឿង)

-ឧភយពាក្យវិលាសិនី (ភាគ ១ ខ្មែរ/ភាគ ១.២ បាលី)

-វិជ្ជាគុណកថាពាក្យកាព្យ ទសានុស្សតិ និងព្រះត្រៃលក្ខណ៍

-វិធីសម្ព័ន្ធសង្ខេប សង្ខេបទសជាតក ១៩៥៩

-កុម្ភជាតក ពុទ្ធឃោសាចារ្យប្រវត្តិ

-សង្គហធម៌៤ប្រការ អធិប្បាយសុភាសិត (កាព្យបទផ្សេងៗ)

[1] -ការអះអាងតាមសារអេឡិចត្រូនិច របស់បណ្ឌិតសភាចារ្យ ឃីង ហុកឌី នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៧។

-ពុទ្ធាឃោសាចារ្យ(ព្រមទាំងសៀវភៅជាច្រើនទៀតសរុបចំនួន ៣៣)...

**ឃ-តួនាទី**

-សមាជិកក្រុមជំនុំព្រះត្រៃបិដក

-សមាជិកអភិបាលសមាគមអ្នកនិពន្ធខ្មែរ

## ៣-កាលកំណត់តែង

រឿងមហោសថមានប្រភពដើមជាភាសាបាលីស្នាដៃអដ្ឋកថាចារ្យមាននៅក្នុងគម្ពីរខុទ្ទក និកាយជាតក និងគម្ពីរជាតកអដ្ឋកថា ដែលមានមកជាង២០០០ឆ្នាំមកហើយ។រឿងនេះ បានពុម្ព ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យនៅព.ស២៥០៥ដាក់ចំណងជើងថាមហោសថជាតក និងសៀវភៅ សង្ខេបទសជាតករបស់លោកបណ្ឌិតមហា ឈឹម សុមន៍ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ព ព.ស ២៥០២ គ.ស១៩៥៩។

រឿងមហោសថជាតកលោកអ្នកប្រាជ្ញបានប្រែចេញពីអដ្ឋកថាទសជាតក(រឿង១០ជាតិ) វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានចាត់ឱ្យចម្លងរឿងមហោសថជាតកនេះ ចេញពីសាស្ត្រា ស្លឹក រឹតបុរាណ។

សង្ខេបទសជាតក ជាស្នាដៃរបស់លោកបណ្ឌិតមហា **ឈឹម សុមន៍** អតីតសាស្ត្រាចារ្យ នៅ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតឆ្នាំ១៩៥៩។

## ៤-សង្គមបរិយាកាស

ព្រះពុទ្ធសាសនាបានចាប់បដិសន្ធិនៅលើពិភពលោកយើងតាំងពីសតវត្សរ៍ទី៦មុនគ្រិស្ត សករាជមកម្ល៉េះ។ សាសនាព្រះពុទ្ធនេះបាននាំមកដល់សុវណ្ណភូមិ គឺប្រទេសខ្មែរនៅសតវត្សរ៍ ទី៣មុន គ.សតាមរយៈព្រះភិក្ខុពីរអង្គ ព្រះនាមមហាត្ថេរ និងឧត្តរត្ថេរក្នុងរាជ្យព្រះបាទអសោក ប៉ុន្តែ ភស្តុតាងជាក់ស្តែងដែលមានលើទឹកដីខ្មែរគឺសិលាចារឹកវ៉ូកាញ់ស្ថិតនៅតំបន់ញ៉ាចាង កម្ពុជាក្រោម បច្ចុប្បន្ន បានបង្ហាញការគោរព និងជំនឿ កម្មផល អំពើល្អបុណ្យ បាបដែលជាទ្រឹស្តីដ៏ សំខាន់នៃ ព្រះពុទ្ធសាសនាថេរវាទ។សិលាចារឹកបានចារឡើងក្នុងរជ្ជកាលនៃព្រះបាទស្រីមារសតវត្សរ៍ទី៣ នៃគ.ស(សម័យនគរភ្នំ)។

រឿងព្រះមហោសថនេះ គឺជាដំណើររឿងដែលព្រះសម្មាសម្ពុទ្ធបានតំណាលដល់ពុទ្ធ សាសនិក ទាំងឡាយក្រោយពេលព្រះអង្គបានត្រាស់ដឹងហើយ។

ព្រះពុទ្ធបរមគ្រូនៃយើងគឺជាបិតានៃទស្សនវិជ្ជាសាសនាលើកយកទស្សនកម្មផលមកធ្វើជា កម្មវត្ថុសិក្សាស្វែងយល់រកហេតុផលនៃសេចក្តីសុខ និងក្តីទុក្ខ។ អរិយសច្ចៈ បួនយ៉ាង គឺកើត ចាស់ ឈឺ ស្លាប់ ដែលជាវដ្តសង្សាគ្មានមនុស្សណាម្នាក់អាចគេចផុតបានឡើយ។ ព្រះអង្គបានរក ឃើញថា មូលហេតុនៃទុក្ខគឺតណ្ហា និងអវិជ្ជា (គ្មានបញ្ញា)។ ដើម្បីបានត្រាស់ដឹងជាព្រះសម្មា សម្ពោធិញាណព្រះពុទ្ធបរមគ្រូនៃយើងបានបំពេញនូវបារមីអស់រាប់សិបជាតិ ទម្រាំទទួលបានការ

ត្រាស់ដឹងនេះ ហើយបានស្រោចស្រង់ជីវិតសត្វយ៉ាងច្រើននៅក្នុងលោកឱ្យបានសេចក្តីសុខផុតពីសេចក្តីទុក្ខនៃវាលវដ្តសង្សា។ បារមីទាំង១០(ទសជាតក) ដែលជាបារមីចុងក្រោយគេ ព្រះអង្គបានរកឃើញនូវបញ្ញាបារមី ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់កសាងសិរីក្នុងគ្រួសារ និង សង្គម។ សក្តានុពលនៃបញ្ញាអាចយកឈ្នះលើសត្រូវក្នុងខ្លួន និងសត្រូវក្រៅខ្លួនជាពិសេសពួក បច្ចាមិត្រទាំងឡាយដែលមានបំណងឈ្លានពានទឹកដី។

ព្រះពុទ្ធសាសនា គឺមានគម្ពីរព្រះត្រៃបិដកសម្រាប់សិក្សារៀនសូត្រ មានវិន័យបិដក សុត្តន្តបិដក អភិធម្មបិដក។ ក្រោយពីបានត្រាស់ដឹងជាព្រះពុទ្ធព្រះអង្គបាននិមន្តសម្តែងធម៌ទេសនាដល់មនុស្សសត្វទូទៅអស់រយៈពេល៤៥ឆ្នាំ ហើយរាល់ពេលសម្តែងធម៌ទេសនាត្រូវបានសាវ័កពីរអង្គរបស់ព្រះអង្គចម្លងទុក គឺព្រះអនន្តនិងព្រះមោគ្គលាន។ ក្រោយពីព្រះបរិនិព្វានទៅអតីតជាតិរបស់ព្រះអង្គត្រូវបានគេលើកមកសម្តែងជាធម៌ទេសនាជាគាថាខ្លីៗតរៀងមក។ កាលសម័យគ្រានោះមានមនុស្សរស់នៅច្រើនកុះករ មានព្រះនគរ ព្រះរាជបល្ល័ង្គ និងការសោយរាជ្យដោយ ព្រះមហាក្សត្រមួយអង្គមានព្រះមហេសី ស្រីស្នំបម្រើមន្ត្រីធំតូចគ្រប់ជាន់ថ្នាក់។ ប្រជារាស្ត្រសម័យកាលនោះគោរពប្រតិបត្តិណាស់ទៅលើព្រះមហាក្សត្រយ៉ាងស្មោះស្ម័គ្រ។ ពួកគេមានជំនឿលើកម្លាំងក្រៅខ្លួនថាពិតជាមានទេវតាព្រះឥន្ទជួយថែរក្សាកាលណាគេបានបួងសួងអ្វីមួយ ដូចជាសុំឱ្យមានកូនជាដើម។ ហោរាសាស្ត្រសម័យនោះឆុតឆាប់ណាស់ គឺព្រះមហាក្សត្រមានពួកហោរាជាទីប្រឹក្សា។ នៅសម័យបរមគ្រូនៃយើងក៏មានការធ្វើពាណិជ្ជកម្ម មានផ្សារធ្វើជំនួញសម្រាប់ដោះដូរ ដូចសម័យនេះដែរ។ ទៅណាមកណាផ្លូវឆ្ងាយផ្លូវជិត មានសត្វជាយានអូសទាញ។

**II-ការវិភាគអត្ថបទ**

**១-ស្ថានភាពរឿង**

**ក-សង្ខេបរឿង**

កាលព្រះបរមសាស្តាគង់នៅវត្តជេតពន ទ្រង់បានប្រារព្ធពីអតីតនិទានស្តីអំពីបញ្ញាបាមីរបស់ព្រះអង្គសំដែងជាធម្មទេសនាថា៖ កាលកន្លងទៅព្រះបាទវិទេហរាជសោយរាជ្យក្នុងនគរមិថិលាដែនវិទេហរាស្ត្រ។ ព្រះអង្គមានអ្នកប្រាជ្ញ៤នាក់ ឈ្មោះសេនក១ បុក្កុស១ កាមិន្ទ១ និង ទេវិន្ទ១។ ថ្ងៃមួយព្រះរាជាទ្រង់មានព្រះសុបិននិមិត្តជិតភ្លឺថា មានគំនរភ្លើង៤ភ្នក់គ្រង់ជ្រុងទាំង៤នៃព្រះរាជវាំងឆេះសន្ធោសន្ធៅឡើងស្មើនឹងកំពែងធំនៅត្រង់កណ្តាលភ្នក់ភ្លើងទាំង៤មានភ្លើងមួយប៉ុនអំពិលអំពែកឆេះភ្លែតឡើងភ្លឺជាងភ្នក់ភ្លើងទាំង៤ ហើយមានពន្លឺផ្សាយដល់ទ្វីប ទាំង៤រហូតដល់ព្រហ្មលោកមនុស្សទាំងឡាយកាន់គ្រឿងសក្ការទៅបូជាដោយជាន់លើគំនររងើកនោះពុំរលាកឡើយ។ ព្រះអង្គក៏ហៅអ្នកប្រាជ្ញទាំង៤នាក់មកសួរ។ អាចារ្យទាំង៤ទាយ ថានឹងមានអ្នកប្រាជ្ញជាគម្រប់៥កើតឡើងនៅថ្ងៃនេះ។ កាលនោះនៅស្រុកមួយឈ្មោះបាចិនវយមជ្ឈគ្រាមខាងកើតក្រុងមិថិលាមានសេដ្ឋីម្នាក់ឈ្មោះសិរីវឌ្ឍក៍និងភរិយានាមសុមនាទេវី។ ព្រះពោធិសត្វច្យុត

ចាកឋានតាវត្តិង្សមកចាប់កំណើតក្នុងត្រកូលសេដ្ឋីនេះ។ពេលប្រសូត្រមកព្រះឥន្ទបានយកថ្នាំទិព្វមកដាក់ក្នុងដៃទារក។ នាងសុមនាទេវីយកថ្នាំទៅជូនស្វាមីដែលមានជំងឺ៧ឆ្នាំមកហើយ ពិសាមើលក៏ជាពោគនេះភ្លាម។ ហេតុនេះបានជាមាតាបិតាសន្មត់នាមថា **មហោសថ**។ លុះចម្រើនវ័យបាន៧ឆ្នាំ ព្រះមហោសថ បបួលកុមារជាមិត្ត១០០០នាក់ យកប្រាក់ម្នាក់ៗមួយ កហាបណៈមកចូលហ៊ុនគ្នាចាត់ការជួលជាងកសាងសាលា៥ខ្នងសម្រាប់បំពេញកុសលផ្សេងៗ។

ក្រោយនោះព្រះបាទវិទេហរាជទ្រង់ភ្នកដល់ពាក្យទំនាយបណ្ឌិតទើបទ្រង់ចាត់ឱ្យអាមាត្យចេញទៅរកព្រះមហោសថ។ ព្រះមហាក្សត្រហៅអាចារ្យសេនកមកសួរថា តើល្មមទៅរកព្រះមហោសថមកតាំងជាអ្នកប្រាជ្ញហើយឬនៅ? អាចារ្យនេះមានចិត្តច្រណែនខ្លាចខាតលាភ ក៏ទូលទាស់ថាមនុស្សចេះសាងសាលាប៉ុណ្ណេះពុំទាន់ល្មមជាអ្នកប្រាជ្ញទេ។ ព្រះរាជាផ្តាំអាមាត្យឱ្យចាំល្បងពិសោធអ្នកប្រាជ្ញតទៅទៀត។ អាចារ្យទទួលព្រះរាជឱង្ការល្បងឃើញការពិសោធ១៩លើកខុសគ្នាៗហើយក្នុងការពិសោធឃើញមួយលើកៗតែងទូលព្រះរាជាម្តងសុំឱ្យនាំព្រះមហោសទៅតាំងជាអ្នកប្រាជ្ញប៉ុន្តែអាចារ្យទាំង៤ចេះតែជំទាស់ រហូតតំណក្រោយមកក៏បានយកព្រះមហោសថមកតាំងនាមជាអ្នកប្រាជ្ញានៅក្នុងនរគបានតាមព្រះទ័យ និងចាត់ទុកជារាជបុត្ររបស់ព្រះអង្គទៀតផង។

ថ្ងៃមួយព្រះរាជាក្រសាលឧទ្យាន។ ទ្រង់ទតសត្វបង្កួយមួយធ្វើក្បាលងឹកងោកនៅលើខ្លោងទ្វារ។ ទ្រង់សួរព្រះមហោសថថា បង្កួយនេះវាធ្វើអ្វីព្រះមហោសថតបថា វាគោរពព្រះអង្គ។ ព្រះរាជាទ្រង់សព្វព្រះទ័យឱ្យអាមាត្យទិញសាច់ឱ្យបង្កួយឱ្យវាស៊ីរាល់ថ្ងៃ។ ថ្ងៃមួយជាថ្ងៃសីល អាមាត្យបានស្វែងរកទិញសាច់មិនបានក៏យកប្រាក់ដែលមានតម្លៃស្មើតម្លៃសាច់ទៅចងនៅកសត្វបង្កួយជំនួសសាច់។ បង្កួយបានអលង្ការពាក់ក៏ក្រអឺតលែងគោរពស្តេច។ ព្រះរាជាក៏ឆ្ងល់ទ្រង់សួរព្រះមហោសថ។ ព្រះពោធិសត្វតបថា វាមើលងាយព្រះអង្គ។ ទ្រង់ឮដូច្នោះក៏ខ្ញាល់ហើយបញ្ជាអាមាត្យឱ្យបណ្តេញបង្កួយនោះកុំឱ្យនៅទីនោះ។

ថ្ងៃមួយព្រះរាជាយាងប្រពាតព្រៃទ្រង់ទតឃើញនាងស្រីម្នាក់ជាប់លើចុងដើមឧទុម្ពរចុះមកមិនរួចពីព្រោះមាណពជាប្តី គឺជាមនុស្សកាឡកណ្ណីបានយកបន្លាស្រះគល់រួចរត់បាត់ទៅ។ ព្រះរាជាសព្វព្រះទ័យរើសនាងនោះទៅអភិសេកធ្វើជាមហេសីប្រទាននាមជានាងឧទុម្ពរទេវី។ ថ្ងៃមួយទ្រង់បញ្ជិះនាងលើរាជរថ។ នាងឃើញបិង្គុត្តរមាណពកំពុងជម្រះស្មៅទើបនាងញញឹម ព្រះរាជាសួរនាងសើចអី នាងតបថា នាងសើចនឹងប្តីដើមរបស់នាង។ ស្តេចសួរអាចារ្យសេនក អាចារ្យក៏ទូលបង្ខុសថា ស្រីនេះមានឧបាយស្ងាត់កំបាំង។ ព្រះរាជាពិរោធ ហើយត្រាស់សួរ ព្រះមហោសថព្រះពោធិសត្វទូលថា ធម្មតាអ្នកអត់បុណ្យនៅរួមវាសនាជាមួយនឹងមនុស្សមានបុណ្យពុំបានទេ។ ព្រះរាជាទ្រង់សោមនស្ស។ ជាមួយគ្នានេះព្រះនាងឧទុម្ពរទេវីក៏សូមយកព្រះមហោសថទុកជា ព្រះអនុជពៅរួមឧទ្ទតែមួយ។

ព្រះរាជាក៏បានសាកល្បងនូវបញ្ញាលោកអាចារ្យទាំង៤ ដោយបង្កើតជាប្រស្នាទាក់ទងជា

សត្វពពែមួយត្រូវគេវាយបាក់ខ្នង និងឆ្កែមួយត្រូវគេវាយបាក់ជើងមួយ ដែលយកគ្នាជាមិត្ត ដើម្បីចោទសួរអ្នកប្រាជ្ញទាំង៥នាក់ថា សត្វម្រឹគ២មានជើង៧មាន ខ្នង១ តើសត្វអ្វី? អាចារ្យទាំង៤ដោះមិនរួចក៏ទៅសុំរៀនពីព្រះមហោសថ។ ព្រះពោធិសត្វឱ្យអាចារ្យសេនកទន្ទេញថា ពពែៗឱ្យអាចារ្យកាមិន្ទទន្ទេញថាឆ្កែៗ ឱ្យអាចារ្យទេវិន្ទទន្ទេញថា ទាំងពីរជាសម្លាញ់នឹងគ្នា ឱ្យអាចារ្យបុក្កុសទន្ទេញថាទាំងពីរស៊ីស្មៅផងស៊ីសាច់ផងដោយពុំយល់សេចក្តី។ លុះព្រឹកស្អែកឡើង ព្រះរាជាទ្រង់សណ្តាប់ចម្លើយរបស់អាចារ្យទាំង៤មិនដឹងសេចក្តីថាដូចម្តេច ហើយទ្រង់ក៏សួរព្រះមហោសថវិញ។ ព្រះមហោសថក៏ទូលព្រះអង្គតាមដំណើររឿងពពែ និងឆ្កែនេះ។ បន្ទាប់មកទ្រង់តាំងអ្នកទាំង៥ជាអ្នកប្រាជ្ញក្នុងនគរ។ នាងឧទុម្ពរទេវីទូលទាស់ថា អាចារ្យទាំង៤ នេះទៅរៀនដោះប្រស្នាពីព្រះមហោសថទេ ដែលមិនអាចឱ្យមានឋានៈស្មើនឹងព្រះមហោសថ ពុំសមឡើយ។ តមកព្រះរាជាក៏ទ្រង់លើយកបញ្ហាផ្សេងៗទៀតមកចោទសួរអាចារ្យទាំង៤ និងព្រះមហោសថឱ្យដោះស្រាយល្បងបញ្ញាគ្នា។ ព្រះមហោសថទ្រង់ឈ្នះអាចារ្យទាំងអស់នោះ។ ព្រះរាជាក៏តាំងព្រះមហោសថជាអ្នកប្រាជ្ញដ៏ឧត្តមនិងជាអគ្គមហាសេនាបតីក្នុងពេលនោះហើយបូជាគោឧសភ១ពាន់ ដំរីសេះអាជានេយ្យ១ម៉ឺន និងស្រុកសួយចំនួន១៦ដល់ ព្រះមហោសថ។

ព្រះនាងឧទុម្ពរទេវីគិតថាព្រះមហោសថមានអាយុ១៦ឆ្នាំដែលត្រូវដណ្តឹងភរិយាប្រទានចំពោះព្រះមហោសថ តែព្រះពោធិសត្វសុំលាទៅស្វែងរកភរិយាដោយខ្លួនឯង។ ព្រះអង្គបានឃើញនាងអមរាជាធីតាកុដម្ពីក៏ជាស្រីបញ្ចពិធកល្យាណីក៏សួរប្រស្នាជ្រាបថា ជាស្រីមានបញ្ញាក៏ចូលស្តីដណ្តឹងមកធ្វើជាភរិយាដូចក្តីប្រាថ្នា។ ទ្រព្យសម្បត្តិដែលនាងអមរាទទួលបានជាគ្រឿងបណ្ណាការជាទ្រព្យសម្បត្តិយ៉ាងច្រើនសន្ធឹក នាងបានចែកជា២ គឺមួយភាគចែកជូនមហាជន និងមួយភាគទៀតរក្សាទុកក្នុងឃ្លាំងព្រះរាជទ្រព្យ។ ចំពោះពួកអាចារ្យទាំង៤នាក់នេះវិញចេះតែរកឧបាយផ្សេងៗដើម្បីព្យាបាទព្រះមហោសថឥតឈប់ឈរឡើយ ប៉ុន្តែដោយព្រះពោធិសត្វ និងនាងអមរាមានបញ្ញាប៉ុនគ្នាក៏ចេះតែបានដោះប្រស្នានឹងឧបាយគ្រប់បែបយ៉ាងរបស់អាចារ្យទាំង៤រួចខ្លួនបានសុខសួស្តីរៀងមក។

ព្រះមហោសថមានតួនាទីជាអគ្គមហាសេនាបតី ព្រះពោធិសត្វមានសេចក្តីព្យាយាមរៀបចំនគរឱ្យបានចម្រើនរុងរឿង។ព្រះមហោសថបានចាត់ឱ្យគេធ្វើកំពែងប្រាំពីរជាន់ព័ទ្ធជុំវិញនគរ។ ទ្រង់ចាត់ការឱ្យមន្ត្រីទៅធ្វើការជាមួយនឹងស្តេច១០១នគរ ដើម្បីលបយកការណ៍ក្រែងមានស្តេចអង្គណាមួយចង់រំលោភលើនគរដទៃទៀត។ ព្រះមហោសថបានចិញ្ចឹមសេកសោមបណ្ឌិតមួយឈ្មោះមាធុរៈមានបញ្ញាឆ្លាតណាស់។ ទ្រង់ចាត់សេកនេះឱ្យទៅស៊ើបការណ៍បានដឹងថាអាចារ្យកេវដ្តព្រាហ្មណ៍ និងស្តេចចុល្លនីព្រហ្មទត្តនៃនគរឧត្តរបញ្ចាលមានបំណងវាយយកស្តេច១០១នគរធ្វើជាចំណុះ ហើយនឹងនាំពួកបរិវារទៅចាប់ព្រះបាទវិទេហរាជនៃនគរ មិថិលាប៉ុន្តែផែនការនេះត្រូវបរាជ័យ។ ស្តេចចុល្លនីបែរជាផ្ញើសារសុំជួបព្រះមហោសថ ដើម្បីសួរដេញដោលធម៌គ្នាវិញ។

ព្រះមហោសថក៏យល់ព្រម ហើយនាំពួកសេនាជំនិត១ពាន់នាក់ទៅកាន់ធម្មយុទ្ធមណ្ឌល។ ព្រះពោធិសត្វដឹងថា អាចារ្យកេវដ្តព្រាហ្មណ៍ចង់ឱ្យខ្លួនសំពះដើម្បីប្រកាសថាចុះចាញ់ក៏ទ្រង់ធ្វើឱ្យ កែវមណីរតន៍ទៅអាចារ្យនេះ។ អាចារ្យកេវដ្តព្រាហ្មណ៍បាន ឱនមកទទួលកែវក៏ត្រូវព្រះមហោសថសង្កត់កញ្ចរក់រឹ្វសមុខនឹងផែនដីចេញឈាមរហាម។ ចំណែកព្រះចុល្លនីត្រូវពួកព្រះមហោសថភ្ជង់អាវុធភ័យរត់ខ្វាត់ខ្វាយអស់។ ព្រះមហោសថបានចាត់ឱ្យព្រាហ្មណ៍ម្នាក់ឈ្មោះ អនុកេវដ្តព្រាហ្មណ៍ រៀនពីមន្តសម្ងាត់ទៅធ្វើកលបញ្ឆោតពួកពលសេនារបស់ព្រះបាទចុល្លនីព្រហ្មទត្ត ឱ្យពាក់សញ្ញាព្រះមហោសថរួចទូលទាស់ថា ពួកនេះមានចិត្តក្បត់នឹងព្រះអង្គ។ អនុកេវដ្តព្រាហ្មណ៍ បាននាំព្រះបាទចុល្លនីលបជិះសេះរត់ទាំងយប់ទៅ

ប្រោសចោលក្នុងព្រៃស្ងាត់ ហើយវិលមកនគរមិថិលាវិញ។ ក្រោយនោះអាចារ្យកេវដ្តព្រាហ្មណ៍ រកឧបាយកលសម្លាប់ព្រះបាទវិទេហរាជ និងព្រះមហោសថក៏ណែនាំព្រះបាទចុល្លនីឱ្យធ្វើសារថានឹងថ្វាយព្រះនាងបញ្ចាលចន្ទីជារាជបុត្រីថ្វាយដល់ព្រះបាទវិទេហរាជ។ ព្រះមហោសថដឹងឧបាយនេះតាមសេកស៊ើបការណ៍បានពីនាងសារិកាព្រះពោធិសត្វ បានចាត់ឱ្យរៀបចំក្រុងមួយឈ្មោះក្រុងឧបការនាខេត្តកប្បិលឯនាយទន្លេគង្គា។ មហោសថសុំឱ្យព្រះរាជារៀបចំព្រះពន្លាក្នុងនគរបញ្ចាលដើម្បីធ្វើពិធីរាជាភិសេក។ ព្រះបាទចុល្លនីយល់ព្រមឱ្យព្រះមហោសថ រៀបចំនគរដែលជាឱកាសបានរៀបទីកន្លែងសម្ងាត់ក្នុងនគរឧត្តរបញ្ចាលគឺទ្រង់ឱ្យជីកឧម្មង្គទៅឡើងចំជណ្តើរប្រាសាទស្តេចចុល្លនីដែលធ្វើការយ៉ាងសម្ងាត់អស់រយៈ៤ខែ។ ព្រះមហោសថក៏សុំទូលព្រះបាទវិទេហរាជយាងមកចាំនៅព្រះរាជបុរីឧបការជិតទន្លេគង្គាជាមួយនឹងអាចារ្យ៤នាក់។ក្នុងខណៈនេះព្រះបាទចុល្លនីនឹកថា មានឱកាសកាត់ព្រះសូរងព្រះបាទវិទេហរាជ និងព្រះមហោសថ ទើបលើកទ័ពចេញពីនគរទៅឡោមព័ទ្ធក្រុងឧបការនោះ។ ឆ្លៀតឱកាសល្អ ពួកសេនារបស់ព្រះមហោសថ ដែលបន្លំពួនក្នុងឧម្មង្គក៏ងើបឡើងយ៉ាងស្ងាត់ចំទីព្រះដំណាក់ស្តេចចុល្លនីចាប់បានព្រះរាជវង្ស៤អង្គ គឺនាងនន្ទាទេវីជាអគ្គមហេសីព្រះបាទចុល្លនី១ នាង បញ្ចាលចន្ទី ជាព្រះរាជបុត្រី១ បញ្ចាលច័ន្ទជាព្រះរាជបុត្រា១ នាងសលាកទេវី ជាមាតាព្រះបាទចុល្លនី១ នាំយកទៅរក្សាទុកខាងក្នុងប្របកំផែងវាំងក្រុងឧបការ។ ព្រះបាទចុល្លនី ប្រថាប់នៅខាងក្រៅកំផែងទ្រង់ឮនាងនន្ទាទេវីសោយសោកក៏មានព្រះទ័យងឿងឆ្ងល់ថា ហេតុអ្វីក៏នាងនេះមកយំនៅឯនគរព្រះបាទវិទេហរាជវិញ។ លុះពេលព្រលប់កងទ័ពព្រះបាទចុល្លនីទូងស្គរស្រែកហ៊ោរន្ទឺឡើង។ ព្រះបាទវិទេហរាជ និងអាចារ្យទាំង៤មិនដឹងរឿង ក៏ភ័យលោះ ព្រលឹងហើយអង្វរសុំព្រះមហោសថឱ្យជួយដោះទុក្ខ។ ព្រះមហោសថបានឱ្យសេនាចុចគន្លឹះឧម្មង្គនាំព្រះបាទវិទេហរាជ និងអាចារ្យទាំង៤ព្រមទាំងព្រះរាជវង្ស៤អង្គរបស់ស្តេចចុល្លនីដើរកាត់ក្នុងដីទៅឡើងចំមហាវិសាល គឺរោងធំដោយធ្វើពិធីរាជាភិសេករួចក៏ឱ្យនាំនាងចុះនាវា១០០គ្រឿងទៅកាន់ត្រើយម្ខាងហែបន្តទៅនគរមិថិលាវិញ។លុះព្រឹកឡើងស្តេចចុល្លនីចូលមកក្នុងព្រះរាជវាំងថ្មីឃើញព្រះមហោសថនៅតែឯងមានមុខស្រស់ស្រាយក៏ទ្រង់ឱ្យសេនាចូលចោមចាប់

មហោសថកាត់ដៃជើង ច្រមុះ ត្រចៀក។ ព្រះមហោសថតបថា បើព្រះអង្គឱ្យកាត់ដៃ ជើងត្រចៀក ច្រមុះរបស់ខ្ញុំយ៉ាងណាព្រះបាទវិទេហរាជនឹងឱ្យកាត់ដៃ ជើង ត្រចៀក ច្រមុះ របស់បញ្ចាលច័ន្ទ នាងបញ្ចាលចន្ទី នាងនន្ទាទេវីរបស់ព្រះអង្គយ៉ាងនោះដែរ។ ព្រះបាទចុល្លនី ទាល់បញ្ញាក៏ទ្រង់ សួរថា ព្រះអង្គបានរៀនកលមាយាជាទិព្វឬ? ព្រះមហោសថតបថា បណ្ឌិត ក្នុងលោកតែចេះកលមាយាទិព្វទើបរំដោះខ្លួនចាកទុកបាន។ តមកព្រះពោធិសត្វនាំស្តេចចុល្លនី និងស្តេច១០១ ទតឧម្មង្គ។ ស្តេចចុល្លនីបានកោតសរសើរពីបញ្ញាព្រះពោធិសត្វ ហើយក៏សុំស្បថថាលែងបៀតបៀនគ្នាតទៅ។ ចំណែកឯស្តេច១០១នគរក៏ថ្វាយបង្គំថ្លែងអំណរព្រះពោធិសត្វបានប្រទាននូវជីវិតចំពោះខ្លួន។ ព្រះមហោសថបានជម្រាបរឿងពីអតីតកាលមក បញ្ជាក់ថ្វាយស្តេចទាំង១០១នគរនោះថា ព្រះអង្គបានជួយជីវិតក្សត្រទាំងនេះជាច្រើនគ្រា ហើយដូចជាម្តងណានោះ ព្រះអង្គបានឱ្យមនុស្សទៅប្រានរំលំវាយបំបែកចាន កែវក្នុងពិធីជប់លៀងមួយដែលស្តេចចុល្លនីនេះ មានព្រះទ័យជឿតាមអាចារ្យកេវដ្តព្រាហ្មណ៍ចង់បំផុតពូជស្តេចក្នុងសកលជម្ពូទ្វីប ដោយដាក់ថ្នាំបំពុលឱ្យស្លាប់អស់។ ព្រះបាទចុល្លនីក៏ទទួលស្គាល់នូវកំហុសរបស់ព្រះអង្គចំពោះស្តេច១០១នគរផង។ ព្រះបាទចុល្លនីព្រមព្រៀងថ្វាយរាជសម្បត្តិ របស់ខ្លួនទាំងអស់ថ្វាយព្រះមហោសថ តែព្រះពោធិសត្វប្រកែក។ តមក ក្សត្រទាំងអស់ ទ្រង់ប្រទានរង្វាន់ចំពោះព្រះមហោសថរួចដង្ហែរព្រះអង្គចូលនគរមិថិលា វិញ។ ព្រះនាងបញ្ចាលចន្ទីនៅរួមជាមួយព្រះបាទវិទេហរាជបានរាជបុត្រមួយ។

កាលព្រះរាជបុត្រព្រះនាមតិខិណកុមារមានព្រះជន្ម១០ឆ្នាំ ព្រះរាជាក៏សុគត។ ព្រះមហោសថតាំងព្រះរាជកុមារឱ្យស្នងរាជបិតា ហើយក៏សុំលាទៅគង់នៅនគរឧត្តរបញ្ចាល ក្រោមការទំនុកបម្រុងរបស់ព្រះអង្គបានដោះប្រស្នាជាសញ្ញាជាមួយនាងបរិព្វាជិការនាមភេរីក៏ទើបត្រូវនាងនន្ទាទេវី មានគំនុំស្រាប់នាំដំណើរនេះទៅទូលបង្ខុសចំពោះព្រះស្វាមី។ ក្រោយព្រះរាជាសួរដឹងដើមទងថាព្រះមហោសថ និងនាងភេរីធ្វើសញ្ញាល្បងប្រាជ្ញាគ្នាល្អជាទេព្រះអង្គ ក៏ប្រោសប្រទានឋានៈព្រះពោធិសត្វជាអគ្គមហាសេនាបតី នាងភេរីក៏បានពិសោធសួរព្រះរាជាអំពីទឹកព្រះទ័យដែលព្រះអង្គស្រឡាញ់ព្រះមហោសថដោយស្មោះត្រង់មែន។ ព្រះបាទចុល្លនីថា តាំងពីព្រះមហាសថបណ្ឌិតមកកាន់ទីនេះ លោកបានធ្វើប្រយោជន៍ជាច្រើនដល់នគរ បើសិនខ្ញុំស្លាប់ទៅមុនក៏ព្រះមហោសថញ៉ាំងកូនចៅខ្ញុំទាំងឡាយឱ្យមានសេចក្តីសុខដែរ។ ព្រះមហោសថស្គាល់នូវប្រយោជន៍គ្រប់ប្រភេទទាំងបច្ចុប្បន្ននិងអនាគត។ស្តេចចុល្លនីសុខចិត្ត យកជីវិតក្រុម គ្រួសាររួមនិងជីវិតព្រះអង្គផងសរុបចំនួន៦នាក់ទៅថ្វាយអារក្សទឹកតាមការ គំរាមកំហែងតែដាច់ខាត់មិនឱ្យអារក្សទឹកយកជីវិតព្រះមហោសថទេ ព្រោះមហោសថជា និម្មិតរូបនៃសន្តិភាពក្នុងពិភពលោកទាំងមូល។

**ខ-តួអង្គ និង មុខងារ**

- ព្រះបាទវិទេហរាជ: ស្តេចសោយរាជ្យក្នុងនគរមិថិលាក្នុងដែនដីវិទេហរាស្ត្រ
- សិរីវឌ្ឍក: សេដ្ឋីនៅស្រុកបាចិនយវមជ្ឈគ្រាម និងជាបិតាព្រះមហាសថ

- សុមនាទេវី: ភរិយាសេដ្ឋីសិរីវឌ្ឍក៍ និងជាមាតារបស់ព្រះមហោសថ
- មហោសថ: ព្រះពោធិសត្វ ដែលជាបុត្រសេដ្ឋីសិរីវឌ្ឍក៍ និងនាងសុមនាទេវី
- អាចារ្យសេនក:ប្រធានអ្នកប្រាជ្ញរបស់ព្រះបាទវិទេហរា និងជាអ្នកច្រណែនព្រះមហោសថ
- អាចារ្យបុក្កុស: អ្នកប្រាជ្ញរបស់ព្រះបាទវិទេហរាជ
- អាចារ្យកាមិន្ទ: អ្នកប្រាជ្ញរបស់ព្រះបាទវិទេហរាជ
- អាចារ្យទេវិន្ទ: អ្នកប្រាជ្ញរបស់ព្រះបាទវិទហាជ
- អនុសេដ្ឋី: ជាបិតារបស់ទេវបុត្រ១០០០អង្គក្នុងស្រុកបាចិនវយមជ្ឈគ្រាម
- បិង្គុត្តរមាណព: កូនសិស្សអាចារ្យទិសាបាមោក្ខ និងជាស្វាមីទី១នាងឧទុម្ពរ
- ឧទុម្ពរទេវី: អគ្គមហេសីព្រះបាទវិទេហរាជ និងសុំមហោសថជាព្រះអនុជរូមឧទរ
- អមរាធីតាកុដុម្ពីក៍: ភរិយាមហោសថ ដែលមានភក្តីភាព និងសិរីក្នុងគ្រួសារ
- មាធុរ: សេកសោមរបស់មហោសថ និងជាអ្នកស៊ើបការណ៍
- អាចារ្យកេវដ្តព្រាហ្មណ៍: អ្នកប្រាជ្ញរបស់ព្រះបាទចុល្លនីព្រហ្មទត្ត
- ព្រះបាទចុល្លនីព្រហ្មទត្ត: ស្តេចសោយរាជ្យនៅនគរឧត្តរបញ្ចាល និងជាអ្នកឈ្លានពាន
- ព្រះនាងបញ្ចាលចន្ទី:ព្រះរាជបុត្រីព្រះបាទចុល្លនី និងជាមហេសីនៃព្រះបាទវិទេហរាជ
- ព្រះនាងសលាកទេវី: ព្រះមាតារបស់ព្រះបាទចុល្លនី
- បញ្ចាលច័ន្ទ: ព្រះរាជបុត្រារបស់បាទចុល្លនី
- នាងភេរី: បរិព្វាជិការបស់ព្រះបាទចុល្លនី
- តិខិណមន្ត្រីកុមារ: ប្អូនព្រះបាទចុល្លនី
- ធនុសេក្ខ: សម្លាញ់របស់ព្រះបាទចុល្លនី
- ព្រាហ្មណ៍បុរោហិតរបស់ព្រះបាទចុល្លនី
- ទេវបុត្រ១០០០អង្គ: ជាបរិវាររបស់មហោសថ
- អនុកេវដ្តព្រាហ្មណ៍: អ្នកទទួលការបណ្តុះបណ្តាលពីព្រះមហាសថ

**គ-កាលអាកាស**

ដំណើររឿងបានប្រព្រឹត្តទៅទាក់ទងជាមួយរឿងរ៉ាវនៃពុទ្ធប្រវត្តិ ជាពិសេសក្នុងពេលដែលព្រះអង្គយកកំណើតជាព្រះពោធិសត្វគឺព្រះមហោសថ ដែលជាអ្នកមានបញ្ញាបារមីដាច់គេដាច់ ឯង។ ដំណើររឿងបានទាក់ទងជាមួយទីកន្លែងដូចខាងក្រោម៖

-**កាល** : ថ្ងៃមួយក្នុងកាលកន្លងទៅ គ្រានោះ ព្រឹកឡើង កាលនោះ...

-**អាកាស** : នគរមិថិលា ស្រុកបាចិនវយមជ្ឈគ្រាម នគរឧត្តរបញ្ចាល ព្រះរាជវាំង ។ល។

**ឃ-ព្រឹត្តិការណ៍សំខាន់ៗ**

រឿងនេះបានកើតឡើងក្នុងពេលដែលព្រះសម្មាសម្ពុទ្ធនៅជាព្រះពោធិសត្វខិតខំកសាងនូវ

បញ្ញាបារមីសម្រាប់ដោះស្រាយបញ្ហាទាំងឡាយជូនមនុស្សលោកទូទៅ និងសម្រាប់ផ្ចាញ់ ពួកមាដែលតែងតែមកធ្វើទុក្ខបុកម្នេញដល់ការសមាធិរបស់ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើង។បញ្ញាបារមី ប្រែថា គុណជាតិជាគ្រឿងដល់នូវព្រះនិព្វាន។ បញ្ញាបារមីនេះ បានដល់ការត្រាស់ដឹងនៃនាមធម៌ទាំងឡាយ។

ជាទូទៅព្រះសមណគោតម គឺជាបុគ្គលដែលមានប្រាជ្ញាអស់មនុស្សទាំងឡាយបានលេចឡើងតាមរយៈការសម្តែងរបស់ព្រះភិក្ខុព្រឹទ្ធិ ដែលបានសម្តែងកោតសរសើរដល់បញ្ញារបស់ព្រះពុទ្ធប្រាប់ដល់ពពួកភិក្ខុសង្ឃអង្គអរហន្តនៅធម្មសភាសាលាជាកន្លែងរបស់ព្រះអង្គសម្តែងព្រះធម្មទេសនាដូចជា៖

-បញ្ញាបារមី គឺការដកព្រះទ័យផុតអំពីគ្រឿងឧបករណ៍ និងបុត្រ ភរិយា ហើយធ្វើនូវការវិនិច្ឆ័យចំពោះប្រយោជន៍និងមិនមែនប្រយោជន៍ដល់សព្វសត្វទាំងឡាយ។

-បញ្ញាឧបារមី គឺការដកព្រះទ័យផុតអំពីអវយវៈរបស់ព្រះអង្គ ហើយធ្វើនូវវិនិច្ឆ័យ

-បញ្ញាបរមត្ថបារមី គឺការដកព្រះទ័យផុតអំពីជីវិតរបស់ព្រះអង្គ ហើយធ្វើនូវវិនិច្ឆ័យចំពោះប្រយោជន៍និងមិនប្រយោជន៍ដល់សព្វសត្វទាំងឡាយ។

ដូច្នេះព្រឹត្តិការណ៍នៃរឿងគឺបានកើតក្នុងពេលព្រះពោធិសត្វកសាងបញ្ញាបារមីដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃយើង។

## ២-អត្ថន័យ

### ២-១-ប្រធានរឿង

ការប្រើប្រាស់បញ្ញាដើម្បីដោះស្រាយបញ្ហាផ្សេងៗ។

### ២-២-មូលបញ្ហារឿង

មូលបញ្ហារឿងដែលលេចធ្លោក្នុងដំណើររឿង គឺជុំវិញការកសាងបញ្ញាបារមីរបស់ព្រះពោធិសត្វដែលសត្រូវទាំងឡាយតែងតែចងសាកល្បងដូចជា ស្តេចវិទេហរាជនៃនគរមិថិលា លោកអាចារ្យទាំង៤ និងមហិច្ឆតាឈ្លានពាននៃស្តេចចុល្លនីនគរឧត្តបញ្ចាលជាដើម។

### ២-៣-បញ្ហាចោទ និងដំណោះស្រាយ

ព្រះមហោសថគឺជាពោធិសត្វដែលមានឫទ្ធានុភាពតាំងពីចាប់កំណើតមកម្លេះតាមរយៈមានឱសថទិព្វដែលទទួលបានពីព្រះឥន្ទ ដើម្បីព្យាបាលព្រះបិតា។ដោយមានឱសថទិព្វនេះ ទើបមានឈ្មោះថា មហោសថ។ ក្រៅពីនេះ មានទេវបុត្រចំនួន១០០០អង្គទៀត ដែលបានចាប់កំណើត ក្នុងត្រកូលអនុសេដ្ឋីនៅស្រុកបាចិនវយមជ្ឈគ្រាមខាងកើតនគរមិថិលា ហើយបានក្លាយជាបរិវាររបស់ព្រះមហាសថ។ នៅពេលព្រះមហោសថមានព្រះជន្ម៧ព្រះវស្សាក៏បានប្រមូលថវិកាពីទេវបុត្រ១០០០អង្គក្នុង១នាក់១កហាបណៈ ដើម្បីកសាងសាលា៥ខ្នងសម្រាប់បំពេញកុសលផ្សេងៗ។

ការបំពេញបារមីប្រកបដោយបញ្ញារបស់ព្រះមហាសថបែបនេះក្តីក៏អ្នកប្រាជ្ញទាំង៤នាក់របស់ស្តេចវិទេហរាជនៃនគរមិថិលាមិនទាន់ទទួលស្គាល់ថា ព្រះមហោសថជាអ្នកប្រាជ្ញ(បញ្ញា)ឡើយ។ ដូច្នេះហើយ ទើបមានការពិសោធសាកល្បងនូវបញ្ញារបស់ព្រះមហោសថចំនួន១៩លើក ហើយការពិសោធក្នុងម្តងៗត្រូវបានអាមាត្យទូលថ្វាយព្រះមហាក្សត្រ ដើម្បីបញ្ជាក់ថា មហោសថជាអ្នកប្រាជ្ញ។ សកម្មភាពនៃការពិសោធទាំង១៩លើករបស់ព្រះមហោសថមាន ដូចខាងក្រោមនេះ

**ក-បញ្ហាទី១៖ ការពិសោធប្រាជ្ញាព្រះមហោសថ**

-ទី១ មំសំ(សាច់)

ការដោះស្រាយបញ្ហាដោយធ្វើឱ្យសត្វខ្លែងភ័យក៏ទម្លាក់ដុំសាច់ចុះមកដីវិញ។

ថ្ងៃមួយមានសត្វខ្លែងមួយបានឆាបឆក់យកសាច់មួយដុំពីជ្រុញអ្នកលក់ហើរឆ្ពោះទៅកាន់អាកាស។ ក្មេងៗឃើញដូចនេះក៏នាំគ្នារត់ដេញតាមខ្លះដួលតែសត្វនោះមិនព្រមទម្លាក់។ ព្រះមហោសថក៏ឃាត់ក្មេងទាំងនោះរួចបានស្ទុះមួយទំហឹងទៅជាន់ស្រមោលសត្វខ្លែង ហើយស្រែកខ្លាំងៗធ្វើឱ្យលេកសម្លេងនោះទៅប៉ះនឹងសត្វខ្លែងបណ្តាលឱ្យសត្វខ្លែងភ័យក៏ទម្លាក់ដុំសាច់នោះចោល។ ដូច្នេះបញ្ញាអាចដោះស្រាយបញ្ហាបានគ្រប់ស្ថានភាពទោះបីបញ្ហានោះកើតនៅទីណាក៏ដោយ។

-ទី២ គោណោ (សត្វគោ)

ការដោះស្រាយបញ្ហារវាងបុរសម្ចាស់គោ និងចោរ។

មានបុរសម្នាក់ជិះគោបរទៅឱ្យស៊ីស្មៅរួចអង្គុយងក់នៅក្បែរគល់ឈើ។ ចោរបានលួចគោរត់ទៅបាត់។ ម្ចាស់គោភ្ញាក់ឡើងក៏ស្ទុះតាមប្រញាប់ប្រញាល់។ ម្ចាស់គោ និងចោរឈ្លោះ គ្នាថាខ្លួនជាម្ចាស់គោរៀងៗខ្លួន។អ្នកទាំងពីក៏នាំគ្នាទៅរកព្រះមហោសថជួយកាត់ក្តី។ ការប្តឹងគ្នារវាងម្ចាស់គោ និងចោរធ្វើឱ្យព្រះមហោសថចេញមុខដោះស្រាយប្រកបដោយយុត្តិធម៌។

ដូច្នេះ បញ្ញាព្រះមហោសថ វិនិច្ឆ័យបានគ្រប់ជ្រុងជ្រោយរវាងចោរ និងម្ចាស់គោប្រកបដោយគតិបណ្ឌិត។

-ទី៣ កណ្ឋិ (សង្វារ)

ដោះស្រាយបញ្ហាដោយឱ្យស្ត្រីម្ចាស់សង្វារឈ្នះស្ត្រីជាចោរ។

មានស្រីកំសត់ម្នាក់ក្រងខ្សែស្ងូត្រមានពណ៌ផ្សេងៗធ្វើសង្វារពាក់ជាគ្រឿងលម្អ។ពេលចុះងូតទឹកក្នុងស្រះបោក្ខរណីបានដោះសង្វារនោះទុកលើសំពត់។ស្ត្រីជាចោរម្នាក់បានឃើញសង្វារនោះក៏លួចចេញទៅ។ស្រីម្ចាស់សង្វារឡើងពីស្រះទឹកដេញតាមចោរនោះ ស្ត្រីជាចោរនោះបានប្រកែកថា សង្វារជារបស់ខ្លួនក៏ទៅប្តឹងព្រះមហោសថឱ្យកាត់ក្តី។ ការកាត់ក្តីរបស់ ព្រះមហោសថចំពោះស្ត្រីជាម្ចាស់សង្វារ និងចោរប្រកបដោយមានភស្តុតាងគ្រប់គ្រាន់ និងយុត្តិធម៌បំផុត។

-ទី៤សុត្តំ(អំបោះ)

ដោះស្រាយបញ្ហាដោយឱ្យស្ត្រីម្ចាស់ហុងអំបោះឈ្នះស្ត្រីជាចោរ។ មានស្ត្រីម្នាក់វៃអំបោះ

ដាក់ផ្លែទម្លាក់ខាងក្នុងធ្វើជាហុងអំបោះពេលធ្វើដំណើរទៅដល់

ស្រះបោក្ខរណីមួយក៏ទុកហុងអំបោះនៅលើអំបោះនៅលើសំពត់ហើយក៏ចុះទៅងូតទឹក ពេលនោះមានស្ត្រីចោរម្នាក់មកលួច ហើយម្ចាស់មកទាន់ទាយកវិញ ស្ត្រីចោរមិនព្រមឱ្យ។ រឿងនេះបានដឹងដល់ព្រះមហោសថហើយមហោសថបានហៅអ្នកទាំងពីរមកសួរតាមដំណើររឿង ពេលដឹងរឿងក៏បានកាត់ក្តីឱ្យស្រីជាម្ចាស់ហុងអំបោះឈ្នះ។

-ទី៥ បុត្តោ (កូន)

ការដោះស្រាយបញ្ហាឱ្យស្រីម្ចាស់កូនឈ្នះយក្ខិណី។

ស្ត្រីម្នាក់មានកូនមួយទុកចោលនៅមាត់ស្រះ ហើយចុះទៅងូតទឹកក្នុងស្រះបោក្ខរណី។ ពេលនោះមានយក្ខមួយមកប្រែក្រឡាយកកូននោះបម្រុងហែកស៊ី ម្តាយមកទាន់ក៏ដណ្តើម តែយក្ខនោះមិនព្រម ហើយប្រកែកឮដល់ព្រះមហោសថហើយព្រះមហោសថក៏បានគូសរង្វង់ដាក់កូននោះនៅចំកណ្តាលឱ្យស្រីទាំងពីរនាក់នោះដណ្តើមគ្នាម្ខាងចាប់ដៃ ម្ខាងចាប់ជើង។ ម្តាយពិតមានចិត្តអាណិតអាសូរកូនក៏បានលែងទៅ។ព្រះមហោសថក៏បានដឹង ហើយបង្ហាញ នូវស្រីជាយក្ខនោះជាចោរ។ ការវិនិច្ឆ័យទោសរបស់ព្រះមហោសថនេះដោយឈរលើទឹកចិត្តគុណធម៌ជាម្តាយដែលជាទូទៅមានចិត្តអាណិតអាសូរទន់ទោរចំពោះកូន ដែលខ្លាចកូនយំ កូនឈឺ និងមានរបួសផ្សេងៗ។

-ទី៦ គោធោ (បុរសឈ្មោះគោធកាឡ) ការដោះស្រាយបញ្ហាឱ្យបុរសតឿឈ្នះលើសាហា

យរបស់ប្រពន្ធ។

មានបុរស និងស្ត្រីជាប្តីប្រពន្ធនឹងបានធ្វើដំណើរទៅលេងស្រុកកំណើតខាងប្តីទៅដល់មាត់ស្ទឹងមួយមិនហ៊ានឆ្លង។ ពេលនោះមានបុរសម្នាក់មកជួយចម្លង តែការចម្លងនោះគឺយកប្រពន្ធទៅមុន ហើយក៏បង្ហួសទៅ។ បុរសជាប្តីខឹងយ៉ាងខ្លាំង ហើយឆ្លងទៅកាន់ក៏ប្រកែកគ្នាដំណឹងនេះឮដល់មហោសថ។ព្រះពោធិសត្វក៏បានដោះស្រាយបញ្ហានេះប្រកបដោយយុត្តិធម៌ ជាពិសេសផ្ចាញ់បុរសដែលចង់បានប្រពន្ធគេនោះឱ្យទាល់ច្រករកកលដោះសារមិនបាន។

-ទី៧រថោ(រទេះ)

ការដោះស្រាយទៅលើបញ្ហាការក្រឡាខ្លួនរបស់ព្រះឥន្ទទៅលួចរទេះបុរសម្នាក់ ដើម្បីសាកល្បងប្រាជ្ញាព្រះមហោសថ។ ព្រះមហោសថបានដោះស្រាយប្រកបដោយភាពវាងវៃ និងត្រឹមត្រូវ និងមានហេតុផលច្បាស់លាស់ជូនម្ចាស់រទេះ។

-ទី៨ ទណ្ឌោ (កំណាត់ឈើ)

ព្រះរាជាបានល្បងប្រាជ្ញាមហោសថ ដោយយកកំណាត់ឈើឈូសយ៉ាងស្អាតទៅឱ្យ អ្នកស្រុកបាចីនវយមជ្ឈគ្រាមទាយថា ខាងណាចុងខាងណាគល់។ អ្នកស្រុកពុំដឹងក៏ទៅ ពិគ្រោះ

ជាមួយសេដ្ឋី សេដ្ឋីក៏បានហៅមហោសថមកសួរ ហើយមហោសថក៏បានពន្យល់ មនុស្សគ្រប់គ្នាឱ្យយល់ ដោយឱ្យយកស្ទូត្រមកចងត្រង់កណ្តាលកំណាត់ឈើនោះទម្លាក់ទឹក ហើយមហោសថប្រាប់ថា ខាងដែលលិចទឹកមុខជាគល់ ខាងដែលលិចទឹកក្រោយជាចុង។

ដូច្នេះដំណោះស្រាយរបស់ព្រះមហោសថនេះគឺមានលក្ខណៈឡូស៊ិក និងសមហេតុផលបំផុតរបស់អង្គធាតុដែលធ្ងន់ត្រូវតែលិច។

-ទី៩ សីសំ (ក្បាល)

ព្រះរាជាពិសោធបញ្ញាព្រះមហោសថ ដោយឱ្យយកល្បាលខ្មោចប្រុសមួយស្រីមួយ ឱ្យអ្នកស្រុកបាចិនវយមជ្ឈគ្រាមទាយ។ អ្នកស្រុកមិនដឹងក៏ទៅសួរមហោសថ មហោសថបាន បកស្រាយថា លលាដ៍ក្បាល ដែលមានថ្នេរត្រង់ៗជាលលាដ៍ក្បាលមនុស្សប្រុស ឯលលាដ៍ក្បាលមានលក្ខណៈវៀចវិលជាលលាដ៍ក្បាលមនុស្សស្រី។ ការសន្និតរបស់ព្រះមហោសថនេះ គឺជាលក្ខណៈជាក់លាក់នៃសព៌ាង្គកាយរបស់មនុស្សជាពិសេសរវាងមនុស្ស និងមនុស្សស្រី។

-ទី១០ អហិ (ពស់)

ព្រះរាជាបានបញ្ជូនពស់ញី ឈ្មោលមួយគូទៅឱ្យអ្នកស្រុកបាចីនវយមជ្ឈគ្រាមទស្សន៍ទាយ។អ្នកស្រុកបាចិនវយមជ្ឈគ្រាមមិនស្គាល់ថា ណាមួយញីណាមួយឈ្មោលក៏ទៅពិគ្រោះជាមួយមហោសថ ព្រះពោធិសត្វក៏បានប្រាប់ថា ពស់ឈ្មោលក្បាលក្រាស់រាងក្រមឹប ភ្នែកធំ សង្វារធ្លុតអន្លាយៗ ឯពស់ញីក្បាលស្តើង រាងឆ្លឹម ភ្នែកតូច សង្វារធ្លុតកំបុតៗ។ដំណោះស្រាយរបស់ ព្រះមហោសថ គឺផ្អែកលើលក្ខណៈធម្មជាតិរបស់ពស់ញី និងពស់ឈ្មោល។

-ទី១១ កុក្កដោ (មាន់)

ព្រះបាទវិទេហរាជបានឱ្យអ្នកស្រុកបាចិនវយមជ្ឈគ្រាម បញ្ជូនឧសភមានសម្បុរសសុទ្ធ មានស្នែងព្វដ៍ជើងមានបួរលើក្បាល ស្រែករោទ៍មួយថ្ងៃបីកាលឱ្យទៅជាប្រញាប់។ អ្នកស្រុកមិន ស្គាល់ក៏ពិគ្រោះជាមួយព្រះមហោសថ។ ព្រះពោធិសត្វបានប្រាប់ថាឱ្យយកមាន់សឈ្មោល ដែលមានដុះឆ្នាល់នាជើង ដុះសិរលើក្បាល រងាវបីដងក្នុងមួយព្រឹកទៅថ្វាយ។ដូច្នេះ ដំណោះ ស្រាយនៃប្រស្នាស្តីពីសត្វមាន់នេះ ដែលបញ្ជាក់ថា ព្រះមហោសថជាអ្នកមានបញ្ញាស្គាល់ពី លក្ខណៈនៃសត្វមាន់ឈ្មោលបានយ៉ាងច្បាស់។

-ទី១២ មណិ (កែវមណី)

មានកែវមណីមួយដោតស្ទូត្រចូលទៅ ហើយដាច់យកស្ទូត្រមិនបាន។ ព្រះរាជាបញ្ជូនទៅឱ្យអ្នកស្រុកបាចិនគ្រាមហូតចេញ ហើយបញ្ចូលស្ទូត្រថ្មី។ អ្នកស្រុកគ្មានវិធីដោះស្រាយក៏ទៅសួរព្រះមហោសថ ព្រះអង្គក៏បានប្រាប់ឱ្យយកតែកែវមណីលាបទឹកឃ្មុំត្រង់រន្ធសងខាង ហើយត្របាញ់ស្ទូត្រថ្មីលាបទឹកឃ្មុំទៅដាក់បញ្ចូលបន្តិចទៅក្នុងរន្ធទើបឱ្យយកទៅដាក់ត្រង់រន្ធស្រមោច ស្រមោចធុំក្លិនក៏ចូលមកហើយបានខាំទាញស្ទូត្រចាស់ចេញស្ទូត្រថ្មីក៏ចូលទៅ។ ដំណោះស្រាយរបស់ ព្រះ

មហោសថគឺផ្អែកលើលក្ខណៈធម្មជាតិនៃសត្វស្រមោចដែលចូលចិត្តធំក្លិនទឹកឃ្មុំក៏ខាំទាញសរសៃរសូត្រចេញ។

-ទី១៣ វិជានន់(ការប្រសូតិ) ព្រះរាជាបានបញ្ជូនគោឈ្មោលពោះធំឱ្យអ្នកស្រុកបាចិនគ្រាមបង្កើតកូន ហើយបញ្ជូន

កូនគោឱ្យព្រះអង្គវិញ។ អ្នកស្រុកគ្មានមធ្យោបាយណាដោះស្រាយបានក៏បាននាំគ្នាទៅសួរ ព្រះមហោសថ។ ពោធិសត្វក៏ប្រាប់ឱ្យរកអ្នកមានថ្វីមាត់ធ្វើជាយំស្រែកដើរតម្រង់ទៅរាជវាំង។ ពេលនោះស្តេចក៏ហៅសួរបុរសនោះក៏ប្រាប់ថា កើតកូនមិនរួចឱ្យព្រះអង្គជួយបង្កើត។ ស្តេចមានបន្ទូលថាមិនដែលមានទេរើយមនុស្សប្រុសកើតកូនបុរសនោះក៏តបវិញថាម្តេចក៏ព្រះអង្គបញ្ជូនគោឈ្មោលឱ្យទៅអ្នកស្រុកបាចិនគ្រាមបង្កើតកូន? ព្រះរាជាបានដឹងថា នេះជាប្រាជ្ញា របស់ព្រះមហោសថ ក៏ព្រះអង្គសោមនស្សក្រៃហោង។

-ទី១៤ ឱទនំ (បាយ)

ស្តេចបានប្រាប់ដល់អ្នកស្រុកបាចិនគ្រាមថាឱ្យចំអិនបាយប្រកបដោយអង្គ៨បញ្ជូនមកថ្វាយយើងជាប្រញាប់ដោយវៀរចាកអង្ករ១ ទឹក១ ឆ្នាំង១ ចង្ក្រាន១ ភ្លើង១ អុស ១ មនុស្សប្រុសស្រី១ ហើយកុំនាំទៅតាមផ្លូវ១។ អ្នកស្រុកបានទៅពិគ្រោះនឹងព្រះមហោសថ មហោសថក៏បានប្រាប់ឱ្យយកចុងអង្ករ និងទឹកសន្សើមដាក់ក្នុងភាជន៍ថ្មីមិនមែនជាឆ្នាំងឱ្យចោះគល់ឈើតម្កល់ភាជន៍នោះ ហើយឱ្យយកភ្លើងរន្ទះបង្កាត់នឹងស្លឹកឈើចម្អិន និងឱ្យមនុស្ស ខ្ទើយនាំដើរក្បែរផ្លូវនោះទៅថ្វាយព្រះរាជា។ ដូច្នេះ ដំណោះស្រាយរបស់ព្រះមហោសថ គឺពឹងផ្អែកលើការច្នៃប្រឌិតដែលសម្រេចបានដូចលទ្ធផលដ៏ល្អមួយ។

-ទី១៥ វាលុកា (ដីខ្សាច់) ស្តេចបង្គាប់ឱ្យអ្នកស្រុកបាចិនគ្រាមវេញខ្សែពួរដីខ្សាច់មួយបង្ហូនទៅរាជវាំង។

ជនទាំងនោះបានទៅសួរមហោសថ ព្រះមហោសថក៏បានឱ្យរកបុរសពីរនាក់ចេះសម្តីហើយបង្គាប់ថា អ្នកត្រូវចូលទៅក្រាបបង្គំព្រះរាជាថា សូមទ្រង់មេត្តាប្រោស ពួកអ្នកស្រុក ពុំដឹងពីទំហំពួរនោះតូចឬធំទេ សូមព្រះអង្គកាត់ខ្សែពួរចាស់ប្រវែងមួយចំអាម ទូលបង្គំនឹងបានយកធ្វើជាគំរូ។ ស្តេចតបថា មិនធ្លាប់មានខ្សែពួរវេញពីដីខ្សាច់ពីកាលណាទេ។ បើគ្មានម្តេច ព្រះអង្គឱ្យអ្នកស្រុកបាចិនគ្រាមវេញខ្សែពួរខ្សាច់ម្តេចកើត។

-ទី១៦ តឡាកំ (ស្រះ) ព្រះរាជាបានបង្គាប់ឱ្យអ្នកស្រុកបាចិនគ្រាមបញ្ជូនស្រះបោក្ខរណីទៅរាជវាំង ដើម្បីក្រសាល។

អ្នកស្រុកគ្មានមធ្យោបាយក៏បានទៅសួរមហោសថពោធិសត្វក៏បានឱ្យហៅ មនុស្ស ពីរបីនាក់ដែលមានថ្វីមាត់កាន់ដំបង និងខ្សែពួរចុះទៅមុជទឹកស្រះលេងឱ្យភ្នែកក្រហម និង ប្រឡាក់ភក់ហើយឡើងទៅទូលស្តេចថាស្រះ ដែលព្រះអង្គឱ្យខ្ញុំយកមកថ្វាយនោះបានផ្អើល ដាច់ចូលព្រៃវិញ ហើយ

សូមព្រះអង្គប្រទានស្រះចាស់ឱ្យឱ្យទូលបង្គំយកទៅធ្វើផ្ទាក់ទាក់ស្រះនោះយកមកវិញផង។ ស្តេចថាមិនធ្លាប់មានស្រះនាំមកពីព្រៃទេ។ បើមិនមានម្តេចឱ្យអ្នក ស្រុកបាចិនគ្រាមបញ្ជូន ស្រះបោក្ខរណីមកថ្វាយដូចម្តេចកើត។

-ទី១៧ ឧយ្យានំ(សួនឧទ្យាន)

ព្រះរាជត្រាស់បង្គាប់ឱ្យបញ្ជូនឧទ្យានថ្មីមានដើមឈើលាស់ខ្ចីទៅរាជវាំង។ អ្នកស្រុកក៏ទៅ

សួរព្រះមហោសថពោធិសត្វបានហៅមនុស្សពីរបីនាក់ឱ្យយកខ្សែព្ធរ និង

ដំបងដើរទៅរាជវាំងទូលព្រះរាជាថាខ្ញុំនាំឧទ្យានដ៏ធំមកថ្វាយ ប៉ុន្តែឧទ្យាននោះធ្លាប់តែនៅក្នុង ព្រៃបានឃើញបុរីក៏ផ្អើលដាច់បោលចូលព្រៃវិញទៅ សូមព្រះអង្គប្រទានឧទ្យានចាស់ឱ្យទូលបង្គំដើម្បីយកទៅផ្សាំងជាផ្ទាក់។ព្រះរាជាថាមិនធ្លាប់មានឧទ្យាននាំមកពីព្រៃទេ។ អ្នកទាំងនោះថា បើគ្មានព្រះ អង្គឱ្យបញ្ជូនឧទ្យានថ្មីម្តេចកើត។

-ទី១៨ គទ្រភោ (សត្វលា)

អស្សតរព្រះរាជាបាក់ជើង ហើយបង្គាប់ឱ្យមហោសថយកអស្សតរ ដែលប្រសើរដូច

អស្សតរស្តេចឬប្រសើរជាងទៅថ្វាយ។មហោសថយកសត្វលាទៅថ្វាយដោយទូលថា អស្សតរដែលប្រសើរកើតចេញពីមេសេះអាជានេយ្យនិងបានជាសត្វលា។ដូច្នេះសូមព្រះអង្គទទួលយកសត្វលានេះចុះ ព្រះរាជាក៏យល់ព្រម ថែមទាំងយកមហោសថធ្វើជារាជបុត្ររបស់ ព្រះអង្គ។

-ទី១៩ មណិ(កែវមណី) មានកែវមណីមួយនៅក្នុងសម្បុកក្អែកលើដើមត្នោតក្បែរស្រះ

បោក្ខរណី តែអាចារ្យយកមិន

បានទាល់តែសោះ។ ព្រះរាជាឱ្យអាចារ្យសេនកយកចេញឱ្យបាន តែអាចារ្យចេញមិនបានទាល់តែសោះ។ ស្តេចក្រុងមិថិលាសួរមហោសថថា ហៃបាឯងអាចឱ្យយកកែវមណីនោះបាន ឬទេ មហោសថទូលថាការនេះពុំធ្ងន់ធ្ងរទេ។ មហោសថបានបង្ហាញដោយឱ្យយកភាជន៍ទឹក មកដាក់ក្បែរដើមត្នោតនោះទើបក្រាបបង្គំទូលព្រះរាជាថាកែវមណីនៅលើចុងត្នោតឯនោះទេ។

ក្រោយពេលដោះប្រស្នាទាំងឡាយរួច ព្រះបាទវិទេហរាជនៃនគរមិថិលា ដែនវិទេហ រាស្ត្រទ្រង់សព្វព្រះទ័យយ៉ាងខ្លាំង ប៉ុន្តែពុំទាន់បានតែងតាំងជាអ្នកប្រាជ្ញនោះទេតែទទួលជារាជ បុត្រផ្ទាល់ ហើយផ្គត់ផ្គង់សព្វគ្រប់មិនឱ្យខ្វះខាតឡើយ។

**ខ-បញ្ហាទី២៖ ព្រះមហោសថបានទទួលការគាំទ្រពីព្រះមហាក្សត្រ**

បន្ទាប់ពីបានទទួលការតែងតាំងជារាជបុត្រព្រះមហាក្សត្ររួចមក ព្រះមហោសថបានដោះស្រាយប្រស្នាជាច្រើន ដែលចោទដោយព្រះមហាក្សត្រវិទេហរាជមានដូចជា៖

-ប្រស្នាសត្វបង្គួយ(ការគោរព និងការមើលងាយរបស់សត្វបង្គួយលើព្រះមហាក្សត្រ)

សម័យថ្ងៃមួយមានសត្វបង្គួយមួយក្បាលបានចុះពីខ្លោងទ្វារមកធ្វើក្បាលងឹកងាកៗងាក់ងើកៗដែលជាសញ្ញាបញ្ជាក់ថា សត្វនេះចេះគោរពព្រះមហាក្សត្រក្នុងពេលដែលព្រះអង្គយាងមក

ដល់ទីនេះ។ ព្រះអង្គក៏បញ្ជាឱ្យអាមាត្យទិញសាច់ឱ្យសត្វបង្គួយនោះស៊ីជារៀងរាល់ថ្ងៃ ប៉ុន្តែក្រោយមកសត្វបង្គួយនោះមានចរិតក្រអឺតក្រទមបន្ទាប់ពីវាបានពាក់គ្រឿងអលង្ការ ដែលអាមាត្យបាន បំពាក់ឱ្យ ដើម្បីជំនួសនូវតម្លៃអាហាប្រចាំថ្ងៃ។ សត្វនេះបានគិតថា ព្រះមហាក្សត្រក៏មានគ្រឿងអលង្ការដូចអញដែរ។ទង្វើនេះនាំឱ្យព្រះមហាក្សត្រទ្រង់ព្រះពិរោធយ៉ាងខ្លាំងក៏បណ្តេញសត្វបង្គួយចេញទៅ។

ដូច្នេះ សកម្មភាពគោរព និងចរិតក្រអឺតក្រទមរបស់សត្វបង្គួយចំពោះព្រះមហាក្សត្រគឺបានដឹងតាមរយៈបញ្ញារបស់ព្រះមហោសថ ដែលព្រះពោធិសត្វបានយល់ពីទង្វើរបស់សត្វ។

-ប្រស្នាកាឡកណ្ណី(អ្នកគ្មានបុណ្យមិនអាចរួមរស់ជាមួយមនុស្សមានបុណ្យបានឡើយ)

មានសិស្សអាចារ្យទិសាបារមោក្ខម្នាក់ឈ្មោះបិង្គុត្តរមាណព ដែលអាចារ្យមានសេចក្តីពេញចិត្តបានរៀបការជាមួយកូនក្រមុំរបស់ខ្លួនជាភរិយា។ មាណពនោះជាមនុស្សកាឡកណ្ណី ដែលមិនអាចរួមរស់ជាមួយភរិយាហើយក៏រត់ចោលបាត់ទៅ។ ថ្ងៃមួយព្រះបាទវិទេហរាជទ្រង់ស្តេចចេញទៅប្រពាតព្រៃក៏បានឃើញនាងជាភរិយារបស់មាណពនៅលើចុងដើមឧទុម្ពរ។ ព្រះមហាក្សត្រក៏បានសួរដេញដោលនាងក៏បានដឹងរឿងពិតដែលបិង្គុត្តរមាណពជាស្វាមីបានបញ្ឆោតនាងឱ្យឡើងបេះផ្លែឧទុម្ពរហើយមាណពក៏រត់ចោលបាត់ទៅ។ ព្រះមហាក្សត្រក៏បានសង្គ្រោះនាងរួចរៀបអភិសេកនាងជាមហេសី ដែលមាននាមថា នាងឧទុម្ពរទេវី។ ព្រះនាងបានឃើញអតីស្វាមីរបស់នាងកាន់ចបកញ្ជៀបជម្រះស្មៅបែកញើសយ៉ាងរហាមទើបនាងញញឹមដាក់។ សកម្មភាពនេះ ត្រូវព្រះមហោសថពិចារណាថា អ្នកគ្មានបុណ្យមិនអាចរួមរស់ជាមួយមនុស្សមានបុណ្យបានឡើយ ហើយនាងឧទុម្ពរទេវីបានចាត់ទុកព្រះមហោសថជាព្រះអនុជរួមឧទរតែមួយ។

-ប្រស្នាពពែ ជាហេតុនាំឱ្យព្រះមហាសថមានសិរី

មានសត្វពពែមួយក្បាលទៅបរិភោគស្មៅនៅរោងដំរីត្រូវបានគេវាយបាក់ខ្នង និងសត្វឆ្កែមួយក្បាលទៀតទៅពាំដុំសាច់ពីរោងគ្រូត្រូវគេវាយបាក់ជើងមួយទៅដេកជាមួយគ្នាក្បែរកំពែងព្រះបរមរាជវាំង ហើយពពែបានទៅលួចសាច់ ឆ្កែបានទៅលួចស្មៅមកចែកគ្នាស៊ី។ ព្រះរាជា ទ្រង់យល់សត្វទាំងពីរជាមិត្តនឹងគ្នាក៏ទ្រង់លើកជាប្រស្នាចោទសួរដល់អ្នកប្រាជ្ញទាំង៤នាក់ថាសត្វម្រឹគពីរមានជើង៧ មានខ្នង១ជាសត្វអ្វី? ហើយបើឆ្លើយមិនត្រូវនឹងត្រូវបំបរបង់ពីនគរ។ អ្នកប្រាជ្ញទាំង៤បានក្រាបទូលថា ថ្ងៃស្អែកចាំឆ្លើយ ព្រោះប្រស្នានេះមានលក្ខណៈជ្រៅជ្រះ ណាស់ គឺយើងមិនអាចឆ្លើយរួចបានភ្លាមឡើយមានតែទៅសុំរៀនពីព្រះមហោសថទេ ដែលអាចឆ្លើយបាន។ ព្រះមហោសថបានឱ្យអាចារ្យសេនកៈ ទន្ទេញថា ពពែៗអាចារ្យកាមិន្ទៈ ទន្ទេញថា ឆ្កែៗ អាចារ្យទេវិន្ទៈ ទន្ទេញថា អ្នកទាំងពីរជាសម្លាញ់នឹងគ្នា និងអាចារ្យបុក្កុសៈ ទន្ទេញថា សត្វទាំងពីរស៊ីស្មៅផង និងស៊ីសាច់ផង។ លុះព្រឹកឡើងអាចារ្យទាំង៤នាក់ក៏បាន សូត្រប្រាប់ព្រះមហាក្សត្រទៅតាមការចាំមាត់ដោយពុំយល់សេចក្តីអ្វីឡើយ។ ព្រះមហាក្សត្រ ក៏បានសួរព្រះមហោសថអំពីរឿងនេះ ព្រះ

ពោធិសត្វក៏បានពន្យល់អំពីដំណើរសត្វពពែ និងសត្វឆ្កែយ៉ាងពិស្តារ។ ព្រះមហាក្សត្រក៏បានតែងតាំងព្រះមហោសថជាអ្នកប្រាជ្ញទាំង៥នាក់ រៀងទៅ ប៉ុន្តែព្រះនាងឧទុម្ពរទេវីបានទូលព្រះមហាក្សត្រថា មិនគួរឱ្យអាចារ្យទាំង៤នាក់មាន ឋានៈស្មើព្រះមហោសថឡើយ ពីព្រោះអ្នកទាំង៤នាក់នោះរៀនសូត្រពីព្រះមហោសថទេ។

ដូច្នេះ គេអាចនិយាយបានថា បញ្ញាព្រះមហោសថ គឺជាចំណេះវិជ្ជាដែលអាចធ្វើឱ្យគូសត្រូវដែលធ្លាប់តែប្រឆាំងជាមួយខ្លួនបានក្លាយសិស្ស ហើយសុំរៀនសូត្រតាមដែលពីពេលមុនមកលោកអាចារ្យទាំង៤មិនទទួលស្គាល់ព្រះមហាសថជាអ្នកប្រាជ្ញឡើយ។ សរុបមក បញ្ញាគឺជាអាវុធដ៏មុតស្រួចដែលអាចដោះស្រាយនូវបញ្ហាចំពោះមុខដែលប្រែក្លាយសត្រូវមកជាមិត្តនិងមានជំនឿទុកចិត្តពីព្រះមហាក្សត្រព្រមទាំងផ្តល់ឋានៈជាអ្នកប្រឹក្សា និងជាបងប្អូនរួមឧទរនៃព្រះមហេសីរបស់ព្រះរាជាទៀតផង។

-ប្រស្នាបណ្ឌិត៥នាក់

លំដាប់តទៅទៀត ព្រះរាជាបានសាកល្បងនូវបញ្ញារបស់អ្នកប្រាជ្ញទាំង៥នាក់ដោយ លើកជាប្រស្នាថា បុគ្គលមានប្រាជ្ញា ប៉ុន្តែគ្មានយសស័ក្តិទ្រព្យសម្បត្តិ តើនរណាប្រសើរជាង នរណា?

អាចារ្យសេនកៈពោលថា បុគ្គលមានមានតែប្រាជ្ញាគឺជាមនុស្សថោកទាប បុគ្គលដែល មានសិរី គឺយសស័ក្តិទ្រព្យសម្បត្តិ ទើបជាមនុស្សល្អប្រសើរ។

ព្រះមហោសថពោលថា អ្នកមានប្រាជ្ញ សូម្បីឥតមានយសក៏ប្រសើរជាងអ្នកមាន យសឥតប្រាជ្ញា ពីព្រោះជាមនុស្សល្ងង់អន្ធពាលធ្វើនូវអំពើបាបកម្មតាមតែការជួបប្រទះ គឺលោភ បុណ្យសក្តិ ប្រាក់កាសណាស់ លុះបានបុណ្យសក្តិ ប្រាក់កាសទៅជាអ្នកមាន ក៏ស្មានថា ឥស្សរិយយសនេះជារបស់អត្មាអញប្រសើរក្នុងលោកនេះ ម្លោះហើយក៏រឹតតែរលត់បញ្ញាទៅ ឃើញត្រឹមតែលោកនេះតែប៉ុណ្ណោះ ដោយឥតឃើញបរលោកសោះ បើដូច្នោះនឹងលំបាក ក្នុងលោកទាំងពីរ គឺស្លាប់ទៅៗលំបាកក្នុងនរករួចផុតពីនរកមកលំបាកក្នុងជាតិជាមនុស្សទាល់តែក្ររហេមរហាមតទៅទៀត។

អាចារ្យសេនកៈបានបន្តទៀតថា អ្នកមានប្រាជ្ញាឥតលំនៅស្តុកស្តម្ភ មានទ្រព្យធនតិច បើទុកជានិយាយត្រូវតាមហេតុការណ៍ក៏សម្តីនោះមិនបានការសម្រេចក្នុងកណ្តាលបរិស័ទដែរ ឯសិរីមិនមានដល់អ្នកមានប្រាជ្ញ ក្រទ្រព្យនោះទេដូចជាអំពិលអំពែកមិនប្រាកដក្នុងកន្លែងដែលព្រះអាទិត្យរះដូច្នេះ។

ព្រះមហោសថបន្តថា មិនមែនទេ មនុស្សអ្នកមានប្រាជ្ញារមែងមិនពោលពាក្យឡេះ ឡោះខុសច្បាប់ អ្នកមានប្រាជ្ញានោះទេតើដែលត្រូវគេបូជាគឺថាត្រូវមានសិរីក្នុងកណ្តាលសភា ក្នុងកាលខាងក្រោយ នឹងជាអ្នកទៅកាន់សុគតិទៀតផង។

ការជជែកគ្នារវាងអាចារ្យសេនកៈ និងព្រះមហោសថលើប្រស្នារវាងបញ្ញា និងទ្រព្យពីប្រស្នាមួយទៅប្រស្នាមួយទៀតមិនចេះចប់ ប៉ុន្តែព្រះមហោសថបានពណ៌នាអំពីបញ្ញាយ៉ាង ពិស្តារ

ដែលក្នុងនោះព្រះមហោសថអះអាងថា មនុស្សមានប្រាជ្ញា ទោះបីខ្ញុំគេក៏ដោយចុះ ហើយមនុស្សជាអ្នកល្ងង់ កាលបើករណីកិច្ចដ៏ធ្ងន់កើតឡើងហើយ អ្នកមានប្រាជ្ញារមែងចាត់ចែងនូវមធ្យោបាយយ៉ាងពេញលេញ អ្នកល្ងង់តតប្រាជ្ញាមុខជាវង្វេងវង្វាន់ក្នុងមធ្យោបាយនោះរកផ្លូវស្មុះរួចដោយឥតមានទីស្ថានពុំបានជាប្រាកដឡើយ។ ខ្ញុំព្រះបង្គំយល់ឃើញថា អ្នកមានប្រាជ្ញាទើបពិតជាមនុស្សប្រសើរមនុស្សពាលល្ងង់ខ្លៅមានយសពុំប្រសើរសោះឡើយ។ ព្រះមហាក្សត្រទ្រង់មានព្រះទ័យសោមនស្សនឹងបញ្ញារបស់ព្រះមហោសថ ទ្រង់ក៏បានតែងតាំងព្រះមហោសថជាអគ្គមហាសេនាបតីនិងផ្តល់នូវទ្រព្យយ៉ាងច្រើនសន្ធឹកទៀតផង។

ដូច្នេះតាមសន្ទនាដោះប្រស្នារវាងអាចារ្យទាំង៤ និងព្រះមហោសថ យើងឃោះញថា ប្រាជ្ញាពិតជាមានសារប្រយោជន៍ជាងទ្រព្យសម្បត្តិ និងយសសក្តិ ដែលគ្រាន់តែជាគ្រឿងលម្អមួយ របស់មនុស្ស និងសង្គមមនុស្សតែប៉ុណ្ណោះ។ ដោយឡែកប្រាជ្ញារបស់មនុស្សវិញ គឺជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហា និងទ្រព្យសម្បត្តិដែលចាយវាយមិនចេះអស់ មិនចេះរីងហើយមានតម្លៃទាំងបច្ចុប្បន្នភាព និងអនាគតកាលទៀតផង។ យ៉ាងណាមិញ ព្រះមហោសថដែលជាមានបញ្ញាចូលចិត្តដោះប្រស្នាបញ្ហគ្រប់ប្រការមិនថានៅទីណាទោះស្ថិតនៅជាមួយមហាក្សត្រក្តី រាស្ត្រក្តី សត្រូវក្តី។ប្រាជ្ញាបានប្រែក្លាយព្រះមហោសថទៅជាអ្នកប្រាជ្ញប្រចាំនគរ មិថិលា ហើយមានអំណាចបុណ្យសក្តិក្លាយទៅជាអគ្គមហាសេនាបតី និងជាព្រះអនុជរួមឧទរតែមួយជាមួយព្រះនាងឧទុម្ពរទេវីជាមហេសីព្រះមហាក្សត្ររីឯសត្រូវដែលតែផ្ចាញ់ផ្ចាល(អ្នកប្រាជ្ញទាំង៤)ហើយមិនទទួលស្គាល់ តែពេលនេះបានបាក់អំនួណអស់។

**គ-បញ្ហាទី៣៖ ដំណើរស្វែងរកភរិយារបស់ព្រះមហោសថ**

ព្រះមហោសថចម្រើនវ័យបាន១៦ឆ្នាំ ព្រះនាងឧទុម្ពរទេវី ដែលបានចាត់ទុកមហោសថ ជាព្រះអនុជមានបំណងស្វែងរកភរិយាឱ្យព្រះមហោសថ ប៉ុន្តែព្រះមហោសថសុំលាទៅស្វែងរកដោយខ្លួនឯង។ ព្រះមហោសថបានទៅជួបប្រសប់ជាមួយនឹងនាងអមរាធីតានៅស្រុកឧត្តរយវមជ្ឈគ្រាម។ នាងនោះជាស្ត្រីមានប្រាជ្ញាវាងវៃ ប្រកបដោយលក្ខិណាជាស្ត្រីមានបុណ្យខ្ពស់ ពុំមានអ្នកណាប្រាថ្នាយកជាភរិយាបានឡើយ។ ព្រះមហោសថពេញចិត្តនឹងនាងអមរាក៏ ពិសោធដោយលើដៃក្តាប់បង្ហាញនាងអមរាក្នុងន័យសួរថាតើនាងមានប្តីហើយនៅ។ នាងអមរាតបដោយលាដៃបង្ហាញព្រះមហោសថវិញ។ ព្រះមហោសថដឹងថានាងអមរាជាស្ត្រីក្រមុំពុំទាន់មានប្តីភ្លាមតាមរយៈកាយវិការតបនេះ។ ខណៈនោះ ព្រះមហោសថ និងនាងអមរាទេវីក៏ល្បងប្រាជ្ញាគ្នាទៅវិញទៅមកដើម្បីពិសោធប្រាជ្ញាគ្នាមានដូចជាល្បងប្រាជ្ញាពេលទទួលទានបបរ ល្បងផ្លែពុទ្រា ល្បងពីលក្ខិណា ស្រីពិត ល្បងពីដំណើរទៅកាន់នគរមិថិលា ល្បងចិត្តស្មោះសជាដើម។ ការពិសោធល្បងប្រាជ្ញា ទាំងប៉ុន្មាននេះធ្វើឱ្យព្រះមហោសថពេញចិត្តនឹងនាងអមរាជាខ្លាំង ឯនាងអមរាក៏ពេញចិត្តនឹងព្រះមហោសថវិញជាខ្លាំងដែរ។អ្នកទាំងពីរបានរៀបការដោយ មានព្រះមហាក្សត្រជាអ្នកឧបត្ថម្ភគ្រប់

យ៉ាង។

ដូច្នេះ ស្នេហាព្រះមហោសថ(ពោធិសត្វ) និងនាងអមរា(កន្ញែសាពេជ្ជ) ដែលជាគូព្រេង ពីអតីតជាតិ ហើយជាអ្នកមានបញ្ញាបារមីដូចគ្នារួមរស់ជាមួយគ្នាប្រកបដោយភាពស្មោះត្រង់ គ្មាននរណាម្នាក់មកបំបែកបានឡើយជាពិសេសអាចកំចាត់សត្រូវបានគ្រប់យ៉ាង(អាចារ្យទាំង៤ដែលមានបំណងអាក្រក់)។គេអាចនិយាយថា សុភមង្គលគ្រួសារកើតចេញពីបញ្ញា ភក្តីភាពស្មោះត្រង់ និងសិរីរបស់របស់នាងជាភរិយា។ ការរៀបចំគូស្រករ គឺជាសេរីភាពរបស់បុរស និងស្ត្រីក៏ពិតមែនក៏ប៉ុន្តែក៏ទាមទារនូវលក្ខណៈសម្បត្តិជាបញ្ញា សញ្ចេតនា ចំណេះ ជំនាញ និងទំនោរនៃចិត្តប្រហាក់ប្រហែលគ្នា នោះទើបអាចកសាងសង្គមគ្រួសារមួយប្រកបដោយ សុភមង្គល និងកិត្តិយស។

ព្រះមហោសថត្រូវបានព្រះមហាក្សត្រតែងតាំងជាអគ្គមហាសេនាបតីប្រចាំនគរ ហើយរៀបចំបម្រុងទុកនូវស្បៀងអាហាររៀបចំកងទ័ព និងកំពែងរួមជាមួយយុទ្ធសាស្ត្រនានា ដើម្បីទប់ទល់ជាមួយសត្រូវទីជិត និងទីឆ្ងាយ។

## ឃ-បញ្ហាទី៤ យុទ្ធវិធីទប់ទល់នឹងសត្រូវឈ្លានពាន

ក្រោយពីបានទទួលងារពីព្រះមហាក្សត្រជាអគ្គមហាសេនាបតីមក។ ព្រះមហាសថបានរៀបចំកងទ័ពឱ្យមានរបៀបរៀបរយ មានយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងត្រៀមស្បៀងអាហារគ្រប់គ្រាន់សម្រាប់តតាំងជាមួយសត្រូវ។ ចំពោះការធ្វើសង្គ្រាមជាមួយព្រះបាទចុល្លនីក្សត្រនគរឧត្តរបញ្ចាល ព្រះមហោសថបានប្រើបញ្ញាក្នុងការដោះស្រាយរាល់ឧបសគ្គដែលកើតឡើងចំពោះមុខ ប្រកបដោយសន្តិវិធី។ ព្រះមហោសថបានប្រើប្រាស់បញ្ញាបូកផ្សំជាមួយយុទ្ធវិធីក្នុងការធ្វើសង្គ្រាម ដើម្បីទទួលបានជោគជ័យលើគូសត្រូវ ហើយបានប្រើគ្រប់វិធីដូចជាសង់កំពែង ជីកស្រះជុំវិញ ចិញ្ចឹមក្រពើ មានទ្វារតូចធំប្រកបដោយអាវុធយុទ្ធភ័ណ្ឌពិសេសបានបញ្ជូនសេកសោមបណ្ឌិត ទៅស៊ើបការណ៍ថែមទៀត។

ព្រះមហោសថបានជ្រាបដំណឹង ហើយក៏ប្រុងប្រៀបពលបម្រុងចាំការពារបង្កើនគ្រឿងសស្ត្រាវុធយុទ្ធភណ្ឌ ព្រមទាំងស្បៀងអាហារឱ្យមានគ្រប់គ្រាន់ល្មមទុកប្រើប្រាស់បានយូរឆ្នាំហើយចាត់មនុស្សឱ្យបង្កប់ខ្លួនតាមព្រំដែននិងចុះចូលជាមួយបច្ចាមិត្តដើម្បីលួចគំនិតមកថ្វាយដល់ ព្រះអង្គ។ ឧបាយកលដ៏ល្អមួយទៀតដែលព្រះមហោសថបានធ្វើតែងទទួលបានការគាំទ្រពីព្រះមហាក្សត្រ និងអ្នកប្រាជ្ញ គឺព្រះមហោសថបានសង្គ្រោះអ្នកទាំងអស់នោះឱ្យរួចពីឧបាយដ៏អាក្រក់របស់ព្រះបាទចុល្លនី។

ព្រះមហោសថបានឱ្យគេជីកឧម្មង្គ ដើម្បីរំដោះព្រះបាទវិទេហរាជនៅពេលធ្វើដំណើរ ទៅរៀបអភិសេកជានាងបញ្ចាលចន្ទីបុត្រព្រះបាទចុល្លនី ហើយឆ្លៀតពេលនោះព្រះមហោសថ ក៏បានឱ្យដំបូន្មានដល់ព្រះមហាក្សត្រ និងពាក្យផ្ដាំផ្ញើផ្ទាល់មួយចំនួនផងដែរ។ មហោសថបាន ធ្វើការលើកលែងទោសព្រះបាទចុល្លនី ដែលប្រព្រឹត្តខុសច្រើនលើកច្រើនសារដោយភាពវាងវៃ។

ដូច្នេះ គេអាចនិយាយបានថា បញ្ញាជាវុធសម្រាប់ដោះស្រាយបានគ្រប់បញ្ហា និងសត្រូវគ្រប់ទិសទីដោយមិនចំណាយជីវិតមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់នោះទេ។ ការធ្វើសង្រ្គាមបែបបានឱ្យសត្រូវចុះចាញ់ដោយឥតលក្ខខណ្ឌ និងថែមផ្តល់ជារង្វាន់ដល់ព្រះពោធិសត្វទៀតផង។

**ខ-បញ្ហាទី៥ កិត្តិសព្ទបណ្ឌិតមហោសថ**

ចុងក្រោយព្រះមហោសថទទួលការគាំទ្រហួតក្លាយជាបណ្ឌិតដោយសារនាងភេរីបញ្ជ ជិកាបានលើកកិត្តិសព្ទនៃគុណសម្បត្តិរបស់ព្រះមហោសថចំពោះមុខព្រះរាជានិងនាហ្មឺនសព្វមុខមន្ត្រីនិងប្រជារាស្ត្រ។ បន្ទាប់មកព្រះរាជាទ្រង់ប្រទានឋានៈជាអគ្គមហាសេនាបតីព្រមទាំងគ្រឿងឥស្សរិយស និងទ្រព្យដទៃច្រើនឥតគណនាដល់ព្រះមហោសថ។ កិត្តិនាមនិងគុណធម៌របស់ព្រះមហាសថបានធ្វើឱ្យស្តេចចុល្លនីព្រហ្មទត្ត និងញាតិសន្តានសុខចិត្តស្លាប់បូជាជីវិតដល់ អារក្សទឹកតែដាច់ខាតមិនឱ្យមហោសថស្លាប់ទេ ពីព្រោះមហោសថជានិមិត្តរូបនៃសុខសន្តិភាពនិងអាចសង្គ្រោះនគរ និងប្រជាជនបានទូទាំងមហានរគ។ព្រះបាទចុល្លនីពោលថា តាំងពីព្រះមហាសថបណ្ឌិតមកកាន់ទីនេះ លោកបានធ្វើប្រយោជន៍ច្រើនដល់នគរបើសិនខ្ញុំស្លាប់ទៅមុនក៏ព្រះមហោសថញាំងកូនចៅខ្ញុំទាំងឡាយឱ្យមានសេចក្តីសុខដែរ។ ព្រះមហោសថស្គាល់នូវប្រយោជន៍គ្រប់ប្រភេទទាំងបច្ចុប្បន្ន និងអនាគត។ ស្តេចចុល្លនីសុខចិត្តយកជីវិតក្រុមគ្រួសាររួមនិងជីវិតព្រះអង្គផងសរុបចំនួន៦នាក់ទៅថ្វាយអារក្សទឹកតាមការគំរាមកំហែង តែដាច់ខាត់មិនឱ្យអារក្សទឹកយកជីវិតព្រះមហោសថទេ ព្រោះមហោសថជានិម្មិតរូបនៃសន្តិភាព ក្នុងពិភពទាំងមូល។

**២-៤-វិភាគតួអង្គ**

**១-ព្រះបាទវេទេហរាជ**

**ក-គុណសម្បត្តិ**

- ជាស្តេចសោយរាជ្យនៅនគរមិថិលា ដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ និងយកចិត្តទុកដាក់ប្រមែប្រមូលអ្នកចេះដឹង(អ្នកប្រាជ្ញ)សម្រាប់នគរក្នុងនោះមានដូចជា អាចារ្យទាំង៤ និងព្រះមហោសថ ព្រោះថា បញ្ញវន្ត គឺជាខួរក្បាលរបស់នគរដែលពាំនាំសន្តិភាព និងការអភិវឌ្ឍប្រទេស ពោលព្រះអង្គត្រូវការអ្នកចេះដឹងពិតប្រាកដនៅក្បែរខ្លួន។
- ជាស្តេចដែលចេះពិចារណាលើអភូតហេតុផ្សេងៗដែលបានកើតឡើងក្នុងនគរ គឺមានន័យថាព្រះអង្គមានព្រះទ័យយកចិត្តទុកដាក់លើជោគវាសនារបស់ប្រទេស និងប្រជារាស្ត្រ ព្រះអង្គជាស្តេចរាជធិបតេយ្យ ដែលចេះផ្តល់សិទ្ធគ្រប់គ្រាន់ក្នុងការជជែកវែកញែករកខុសត្រូវដូចជាករណីការដោះប្រស្នារវាងលោកអាចារ្យទាំង៤ និងព្រះមហោសថជាដើម។ មួយវិញព្រះអង្គជាក្សត្រ ដែលបានផ្តល់សិទ្ធគ្រប់យ៉ាងដល់ព្រះមហោសថក្នុងឋានៈជា អគ្គមហាសេនាបតី ដែលមានភារកិច្ចការពារប្រទេសជាតិ
- ជាស្តេចប្រកបដោយទសពិធរាជធម៌ ព្រហ្មវិហារធម៌ ចេះស្តាប់យោបល់ពីអ្នកដទៃជា

ពិសេសពីនាងឧទុម្ពរទេវី។ ព្រះអង្គបានផ្តល់បុណ្យសក្តិ និងទ្រព្យសម្បត្តិដល់អ្នកមានបញ្ញា និងមានស្នាដៃចំពោះព្រះអង្គ និងនគរដូចជាការផ្តល់គោរមងារដល់ព្រះមហោសថជា អគ្គមហាសេនាបតី និងចាត់ទុកជាបុត្រទៀតផង។ព្រះអង្គចេះទទួលកំហុសនៅពេលដឹងថា ខ្លួនមានកំហុស ពោលគឺព្រះមហាសថបានស្តីបន្ទោសពីការចាញ់កលស្តេចចុល្លនីព្រហ្មទត្ត និង បោកបញ្ឆោតរបស់លោកអាចារ្យកេវដ្តព្រាហ្មណ៍ឱ្យមករៀបអភិសេកជាមួយបុត្រីស្តេច ចុល្លនីព្រហ្មទត្តគឺព្រះនាងបញ្ចាលចន្ទី ដើម្បីចាប់ព្រអង្គ និងព្រះពោធិសត្វ។

**ខ. គុណវិបត្តិ**

- ព្រះអង្គឆាប់ជឿសម្តីញុះញង់ និងការសម្រេចចិត្តតាមការភូតភរកុហករបស់អ្នកដទៃដោយខ្វះការពិចារណាឱ្យបានល្អិតល្អន់និងហ៊ានបញ្ជាឱ្យគេយកព្រះមហោសថទៅសម្លាប់តាមការអុចអាលពីអាចារ្យទាំង៤នាក់។ លុះដល់នគរមានការឈ្លានពានពីអ្នកដទៃទើបស្វែងរកព្រះមហោសថមកជួយដោះស្រាយ។មួយវិញទៀតនៅពេលមានទុក្ខវេទនាយាយយីដល់ជីវិត និងនគរទើបព្រះអង្គមានការភ័យស្លន់ស្លោទើបឱ្យតម្លៃ និងដឹងគុណដល់ ព្រះមហោសថ។
- ជាស្តេចដែលចូលចិត្តស្រីដោយមិនគិតថា ស្ត្រីមេម៉ាយ ឬក្រមុំនោះទេដូចជាករណីនាងឧទុម្ពរទេវី ដែលជាអតីប្រពន្ធរបស់បិង្គុត្តរមាណព ហើយព្រះអង្គក៏មិនចេះគិតថា ស្ត្រីដែលជាមហេសីនោះជាបុត្ររបស់សត្រូវ ឬមិត្តនោះទេ ពោលគឺឱ្យតែគេថ្វាយដើម្បីបញ្ឆោតយកជីវិតក៏ព្រះអង្គមិនខ្វល់ដែរ។ព្រះអង្គមិនបានគិតថា ស្ត្រីខ្លះជាប្រភពនៃទំនាស់វិបត្តិ និងអាចឈានដល់ការវិនាសហីនហោចក្នុងនគរទាំងមូល។

## ២-ព្រះមហោសថ

**ក-គុណសម្បត្តិ**

- ជាតួអង្គព្រះពោធិសត្វដែលនឹងត្រាស់ជាព្រះសម្មាសម្ពុទ្ធមានបញ្ញាខ្ពស់ក្នុងការដោះស្រាយបញ្ហាបានគ្រប់យ៉ាង។ ព្រះមហោសថ មានភាពអច្ឆរិយតាំងពីកំណើត គឺបង្ហាញពីបាតុភូតចម្លែកដល់ព្រះបាទវិទេហរាជ និងពាំនាំយកថ្នាំទិព្វសម្រាប់សង្គ្រោះព្រះបិតាទៀត។ នៅអាយុ៧ឆ្នាំ ព្រះពោធិសត្វមានបរិវារហែហាម១ពាន់នាក់ និងចេះកៀរគរប្រមែប្រមូលថវិកា ក្នុង១នាក់មួយ កហាបណៈដើម្បីចូលហ៊ុនគ្នាចាត់ការជួលជាងកសាងសាលា៥ខ្នងសម្រាប់បំពេញកុសលផ្សេងៗ សម្រាប់បណ្តុះបណ្តាសិល្បៈ ដែលជាប្រភពនៃបញ្ញា និងឧទ្យានកម្សាន្ត ស្រះទឹកជាដើម។ ព្រះមហោសថជាកំពូលអ្នកប្រាជ្ញមានបញ្ញាតាំងពីកុមារភាពចេះដោះស្រាយបញ្ហាបានគ្រប់កាលៈ ទេសៈជាមួយសត្រូវគ្រប់ប្រភេទ ពីព្រោះព្រះអង្គបានយល់ពី បាតុភូតបញ្ហាដែលបានឡើង។ ម៉្យាងទៀតព្រះពោធិសត្វបានជួយសង្គ្រោះនាងឧទុម្ពរទេវី ជាមហេសីរបស់ព្រះរាជាដោយលើក ឡើងថា នាងមិនអាចរស់នៅជាមួយប្តីដើមរបស់នាង បានទេ ពីព្រោះនាងជាមនុស្សមានបុណ្យ និង

អតីតប្តីជាមនុស្សពុំមានបុណ្យ ដូច្នេះពួកគេមិន អាចរួមរស់នៅជាមួយគ្នាបានទេ។ ព្រះមហោសថ នៅតែឱ្យតម្លៃខ្ពស់ទៅលើចំណេះដឹង បញ្ញា បារមីដែលចាត់ទុកថា បញ្ញាជាប្រភព បុណ្យសក្តិ ទ្រព្យសម្បត្តិ កិត្តិយស និងសីលធម៌ គុណធម៌ ពោលគឺអ្នកមានប្រាជ្ញាសូម្បី ឥតមាន យសក៏ប្រសើរជាងអ្នកមានយសឥតប្រាជ្ញា ព្រោះជាមនុស្សល្ងង់អន្ធពាលធ្វើនូវតែអំពើបាបកម្ម តាមតែការជួបប្រទះ និងលោភបុណ្យសក្តិ ប្រាក់កាសណាស់លុះបានបុណ្យស័ក្តិ ប្រាក់កាស ទៅជាអ្នកមានក៏ស្មានថា ឥស្សរិយយសនេះ ជារបស់អត្មាអញប្រសើរក្នុងលោកនេះម្លេះ ហើយក៏ រឹតតែរលត់បញ្ញាទៅឃើញត្រឹមតែលោកនេះតែប៉ុណ្ណោះដោយឥតមើលឃើញបរលោកសោះ បើ ដូច្នេះវានឹងលំបាកក្នុងលោកទាំងពីរ គឺពេលស្លាប់ទៅក៏នៅតែលំបាកក្នុងនរករួចផុតពីនរកក៏មក លំបាកក្នុងជាតិជាមនុស្សទាល់តែក្ររហេមរហាមតរៀងទៀត។

- ព្រះមហោសថជាបុគ្គលដែលសណ្តោសប្រណីដល់សត្រូវរបស់ខ្លួន ដែលបានចុះចាញ់ដោយមិនយកទោសពៃរ៍អ្វីទាំងអស់ដូចជាលោកអាចារ្យទាំង៤ អាចារ្យកេវដ្តព្រាហ្មណ៍ ស្តេច វិទេហរាជ ស្តេចចុល្លនីព្រហ្មទត្ត ដែលតែងតែព្យាយាមប្រើល្បិចកល និងយុទ្ធវិធីផ្តាញ់ផ្តាល ព្រះមហោសថ និងប្រមាថជីវិត ពោលគឺព្រះពោធិសត្វបានប្រែក្លាយពីសត្រូវឱ្យមកជាមិត្តដ៏ល្អ តាមរយៈបញ្ញាដ៏ឈ្លាសវៃ។ ជាមួយការសណ្តោសប្រណីនេះភាគច្រើននៃអតីតសត្រូវបានសុខ ចិត្តថ្វាយព្រះរាជទ្រព្យសម្បត្តិ រាជបល្លង្គ និងហ៊ានបូជាជីវិតផ្ទាល់ខ្លួន និងជីវិតរបស់ មនុស្ស ក្នុងគ្រួសារ ដើម្បីស្លាប់ជំនួសព្រះមហោសថ។ដូច្នេះ កិត្តិយស កេរ្តិ៍ឈ្មោះ និងបុណ្យ សក្តិរបស់ ព្រះមហោសថ គឺទទួលបានតាមរយៈបញ្ញាបារមី និងការសន្តោសប្រណី។

- ការស្វែងរកគូស្រករបស់ព្រះមហោសថ គឺត្រូវផ្អែកលើស្ត្រីទាំងឡាយណាដែលមានបញ្ញាបារមី(ចំណេះដឹង) អាចដោះស្រាយប្រស្នារបស់ព្រះមហោសថ។ ការជ្រើសរើសភរិយា នេះគឺមិនសំដៅលើអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដែលកើតក្នុងត្រកូលក្សត្រ ឬត្រកូលអភិជន នោះទេ ពោលសំដៅលើមានបញ្ញាឈ្លាសវៃចេះដោះស្រាយបញ្ហាចំពោះមុខ ស្គាល់ខុស ស្គាល់ ត្រូវមានភក្តីភាព និងចេះកសាងគ្រួសារប្រកបដោយសិរីមង្គល។ ទោះបីព្រះនាងឧទុម្ពរទេវី ជាមហេសីរបស់ព្រះមហាក្សត្រ ដែលបានចាត់ទុកព្រះពោធិសត្វជាព្រះអនុជរួមឧទរ តែមួយធានាស្វែងរកភរិយាជូនព្រះមហោសថ ប៉ុន្តែព្រះពោធិសត្វមិនព្រមទទួលនោះទេ។ ជារួមព្រះមហោសថបានស្ដីដណ្តឹង និងរៀបការតាមប្រពៃណីជាមួយនាងអមរាទេវី ដែលជាកូនស្រីរបស់កសិករនៅ ឯស្រុកស្រែចំការ អ្នកមានបញ្ញាលើសអស់ស្ត្រីទាំងឡាយ និងមានញាតិមិត្តជិតខាងរាប់អាន ព្រមទាំងចេះធ្វើបុណ្យទានដើម្បីនាំសិរីមង្គលដល់គ្រួសារ ពោលគឺព្រះមហោសថ និងនាងអមរាជា គូព្រេងបានកសាងពីអតីតជាតិដែលមនុស្សដទៃទៀតពិបាកនឹងដូច។ ជាមួយគ្នានេះ ព្រះមហោសថមានភាពស្មោះត្រង់ ភក្តីភាពជាមួយនាងអមរាទេវី ទោះបីព្រះរាជាចុល្លនីព្រហ្មទត្ត បានថ្វាយ បវរកញ្ញាចំនួន១០០នាក់ឱ្យធ្វើជាភរិយាក៏ ព្រះមហោសថមិនបានទទួលយកតាមសំណើដែរ។

▪ ចំពោះវិស័យការពារជាតិវិញ ព្រះមហោសថក្រោយពីទទួលបានគោរមងារជាអគ្គមហាសេនាបតីពីស្តេចវិទេហរាជរួចមក។ព្រះពោធិសត្វបានអភិវឌ្ឍនគរឱ្យមានការរីកចម្រើនតាមរយៈការជីកគូរទឹក គូរខ្សាច់ គូរភក់ ស្រះទឹកធំៗសម្រាប់វិស័យកសិកម្ម។ជាមួយគ្នានេះ ព្រះពោធិសត្វមានយុទ្ធវិធី យុទ្ធសាស្រ្តគ្រប់គ្រាន់ក្នុងការការពារនគរមិថិលា ដោយព្រះអង្គបានរៀបចំធ្វើកំពែងប្រាំពីរជាន់ព័ទ្ធជុំវិញព្រះនគរ និងកសាងបន្ទាយធំៗជាច្រើន សម្រាប់ហ្វឹកហាត់ ពីកលយុគ និងវិន័យផ្សេងៗដើម្បីបង្កើនសមត្ថភាពកងទ័ព។ ព្រះពោធិសត្វបានត្រៀមបម្រុងស្បៀងអាហារ សស្រ្តាវុធយុទ្ធភណ្ឌគ្រប់យ៉ាងសម្រាប់ផ្គត់ផ្គង់កងទ័ពធ្វើសង្គ្រាមបានយូរឆ្នាំ រួមទាំងការបណ្ដុះបណ្ដាលផ្នែកចារកម្មដល់កងទ័ពដូចជាសេក សោម ដើម្បីស៊ើបការណ៍ពីគោលបំណងឈ្លានពានរបស់ស្តេចចុល្លនីមកលើនគរវិទេហរាជ។ ចំណែកឯលោកអាចារ្យអនុកេវដ្តព្រាហ្មណ៍ដែលបានទទួលការហ្វឹកហាត់ពីព្រះមហោសថក៏បានប្រើល្បិចបញ្ឆោតកងទ័ពរបស់ស្តេចចុល្លនីឱ្យចុះចូលជាមួយកងទ័ពព្រះមហោសថបានយ៉ាងច្រើន។ រីឯការទប់ទល់ជាមួយការឈ្លានពានពីស្តេចចុល្លនីព្រហ្មទត្ត និងអាចារ្យកេវដ្តព្រាហ្មណ៍នៃនគរឧត្តរបញ្ចាលវិញ ព្រះមហោសថបានប្រើវិធីចាប់រុញច្រានអាចារ្យកេវដ្តព្រាហ្មណ៍ឱ្យដួលខ្ទប់នឹងដីនិងបានរៀបចំ ជីកដីធ្វើឧម្មង្គដើម្បីការពារស្តេចវិទេហរាជ និងចាប់សមាជិករាជវង្សនៃនគរឧត្តរបញ្ចាលចំនួន ៩នាក់ធ្វើជាចំណាប់ខ្មាំងក្នុងគោលដៅឱ្យស្តេចចុល្លនី និងបក្សពួកសុំចុះចាញ់ដោយឥត លក្ខខណ្ឌ។

▪ គុណធម៌ និងការគិតពពីប្រយោជន៍រួមរបស់ព្រះមហោសថ ទោះបីព្រះពោធិសត្វមានមនុស្សជាច្រើនបានផ្ចាញ់ផ្ចាល និងប្រមាថដល់ជីវិតរបស់ព្រះអង្គក៏ដោយព្រះអង្គមិនបានចាប់កំហុសអូសដំណើររបស់សត្រូវឡើយ។ ផ្ទុយទៅវិញ ព្រះពោធិសត្វបានលើកលែងទោស និង សណ្ដោសប្រណីដល់សត្រូវគ្រប់ប្រភេទ។ព្រះមហោសត្វបានផ្ចាញ់សត្រូវទាំងអស់តាមរយៈ ការប្រើបញ្ញា និងកលយុទ្ធនានា ដើម្បីឱ្យលោកអាចារ្យទាំង៤នាក់ អាចារ្យកេវដ្តព្រាហ្មណ៍ ស្តេច វិទេហរាជ ស្តេចចុល្លនីព្រហ្មទត្ត ដោយការលើកលែងទោស និងការមិនបៀតបៀនជីវិតដល់ពួក គេ។ ការការគិតពីប្រយោជន៍រួមរបស់ព្រះមហោសថដូចជា ការកសាងសាលា ស្រះទឹក ឧទ្យានសម្រាប់ជាកុសលដល់អ្នកដទៃ ការមិនទទួលយករាជសម្បត្តិតាមសំណូមពររបស់ ស្តេចវិទេហរាជ និងស្តេចចុល្លនី ពីព្រោះព្រះពោធិសត្វគិតថានៅមានបេសកកម្មជាច្រើនទៀត ដែលត្រូវការព្រះអង្គឱ្យជួយដោះស្រាយ ដើម្បីកសាងសន្តិភាពមួយសម្រាប់ការរីកចម្រើន និងសេចក្ដីសុខរបស់ ប្រជារាស្រ្តទូទាំងនគរ។

**ខ. គុណវិបត្តិ**

▪ ចំពោះគុណវិបត្តិរបស់ព្រះមហោសថហាក់បីមានតិចតួចណាស់ដូចជាមិនចេះកោតក្រែងគោរពព្រះរាជានៃនគរមិថិលា នគរឧត្តរបញ្ចាល និងលោកអាចារ្យមួយចំនួនដែលមានវ័យចាស់ទុំជាងខ្លួនជាពិសេសបិតា(សេដ្ឋីសិរីវឌ្ឍក៍)អង្គុយលើអាសនៈខាងក្រោមចំណែកខ្លួន

ជាកូនអង្គុយលើអាសនៈខាងលើវិញ(ដូចប្រស្នាទី១៨)។

**៣-នាងអមរាទេវី**

**ក. គុណសម្បត្តិ**

- នាងអបរាទេវីជានារីដែលមានសម្រស់ស្រស់ស្អាត (បញ្ញាពិតកល្យាណី) បញ្ញាឈ្លាសវៃចេះដោះស្រាយបញ្ហាដែលបានកើតឡើងចំពោះមុខដូចជា អាចារ្យទាំង៤បានលួចវត្ថុមានតម្លៃរបស់ស្ដេចវិទេហារាជឱ្យនាងជាទាសីទូលយកទៅលក់ឯផ្ទះព្រះមហោសថ ដើម្បីដាក់កំហុសចាប់ព្រះពោធិសត្វ ប៉ុន្តែនាងមានបញ្ញាក៏ទាញក្រដាសមកកត់ត្រានូវថ្ងៃ ខែ និងឈ្មោះទាសីទាំង៤នាក់ ពីហេតុផលដែលចៅហ្វាយខ្លួនបានបញ្ជាឱ្យយកវត្ថុមានតម្លៃមកលក់។ ម្យ៉ាងវិញទៀតនាងអមរាបានដឹងច្បាស់ថាអាចារ្យទាំង៤នេះពិតជាមានបំណងអាក្រក់មកចែចង់នាងក្នុងខណៈពេលស្វាមីមិននៅ។ នាងបានរៀបចំអន្ទាក់ដាក់គន្លឹះយន្ត ដើម្បីទាញលោកអាចារ្យទាំង៤នាក់ឱ្យធ្លាក់ចូលក្នុងរណ្ដៅលាមកនោះទៅ។
- នាងអមរាទេវីជាស្ត្រីម្នាក់មានបញ្ញាខ្ពស់លើសគេ និងជាកូនកតញ្ញូចំពោះឪពុកម្ដាយហើយ ក៏ជាភរិយាដែលចិត្តស្មោះត្រង់ចំពោះស្វាមី ទោះបីគេផ្ដល់ជាមាសជាប្រាក់ដែលមិនអាចកាត់ថ្លៃបានក៏នាងនៅតែស្មោះត្រង់ជានិច្ច។នាងអមរាទេវីតែងតែផ្គត់ផ្គង់ជាអាហារ សម្ភារនានាដល់លោកឪពុកដែលកំពុងតែភ្ជួរស្រែ។ នាងក៏ជាស្ត្រីម្នាក់ដែលចេះស្វែងរកសិរីសម្រាប់គ្រួសារតាមរយៈការប្រើប្រាស់ទ្រព្យសម្បត្តិដ៏សន្ធឹកដែលទទួលបានក្នុងពេលរៀបអាពាហ៍ពិពាហ៍ ហើយនាងក៏បានធ្វើការបែងចែក១ភាគជូនមហាជនទូទៅ និង១ភាគទៀតរក្សាទុកនៅក្នុងឃ្លាំងរបស់ព្រះមហាក្សត្រដើម្បីជាប្រយោជន៍រួម។ ដូច្នេះ នាងអមរាទេវី គឺជាស្ត្រីដែលមានលក្ខណៈសម្បត្តិល្អគ្រប់យ៉ាងទាំងបញ្ញា ចរិយា និងរូបកាយជាក្ដីប្រាថ្នាដល់បុរសទាំង ឡាយក្នុងលោកីយ៍នេះ។

**ខ. គុណវិបត្តិ**

- ចំពោះគុណវិបត្តិវិញនាងអមរាបានធ្វើបាបអាចារ្យទាំង៤នាក់ ដោយដាក់អន្ទាក់ដល់លោកអាចារ្យទាំង៤នាក់ឱ្យធ្លាក់ចូលក្នុងរណ្ដៅ ហើយយកដុំឥដ្ឋវួសក្បាលទំពែក។

**៤-មាតាបិតាព្រះមហោសថ** (សេដ្ឋីសិរីវឌ្ឍក៍ និងនាងសុមនាទេវី)

**ក. គុណសម្បត្តិ**

- ជាមហាសេដ្ឋីដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភនៅស្រុកបាចិនវយមជ្ឈគ្រាមខាងក្រុងមិថិលាជាមាតាបិតាប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន និងផ្ដល់ឱកាសឱ្យកូនបានកសាងសាលា៥ខ្នង ស្រះទឹក សួនច្បារ សម្រាប់ជាកុសលដល់មនុស្សទូទៅ និងជាអ្នកមានសមាន ចិត្តល្អចេះជួយទុក្ខធុរៈអ្នកស្រុកទាំងឡាយដែលជួបការលំបាក។ ចំណែកឯសេដ្ឋីសិរីវឌ្ឍក៍ជា បិតាក៏បានជួយខ្នះខ្នែងដល់ព្រះមហោសថឱ្យបានឈ្នះប្រាជ្ញាស្ដេចវិទេហារាជ ដោយសុខចិត្តអង្គុយលើអាសនៈទាបជាងកូន ដើម្បីឱ្យព្រះមហោសថបានផ្វាញ់ស្ដេចវិទេហារាជ ។

### ខ. គុណវិបត្តិ

- សេដ្ឋីសិរីវឌ្ឍកជាមនុស្សដែលមានជំងឺប្រចាំកាយ លុះព្រះមហោសថប្រសូត្រមកទើបនាំថ្នាំទិព្វមកព្យាបាលជាហើយអ្នកទាំងទ្វេនេះពុំសូវមានប្រាជ្ញាដូចបុត្រាឡើយ។ ជាមួយគ្នានេះដែរ មាតា បិតា របស់ព្រះមហោសថមិនបានបំពេញកាតព្វកិច្ចជាឪពុកម្ដាយក្នុងការស្វែងរកប្រពន្ធ (នាងអមរាទេវី)ឱ្យព្រះមហាសថនោះឡើយ។

## ៥-អាចារ្យសេនក បុក្កុស កាមិន្ទ និងទេវិន្ទ

### ក. គុណសម្បត្តិ

- អាចារ្យទាំង៤នាក់ជាអ្នកប្រាជ្ញប្រចាំនគរមិថិលារបស់ស្ដេចវិទេហរាជ និងជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ជាងមនុស្សដទៃទៀតក្នុងនគរលើកលែងតែព្រះមហោសថ និងនាងអមរាទេវី។ ពួកគេជាទីប្រឹក្សាដ៏សំខាន់ ស្មោះត្រង់ និងតាមហែរហមព្រះមហាក្សត្រនៅគ្រប់ទីកន្លែង និងជាមនុស្សធ្វើឱ្យព្រះមហាក្សត្រឆាប់ជឿ។

### ខ. គុណវិបត្តិ

- ជាមនុស្សលោភលន់ ទ្រព្យសម្បត្តិ បុណ្យសក្តិអំណាច មិនចេះខ្លាចរអាអ្វីទាំងអស់ ក្រាញ់ននៀលហ៊ានធ្វើអ្វីៗគ្រប់យ៉ាងដើម្បីរក្សាអំណាចបានស្ថិតស្ថេរនិងមិនចេះខ្មាស់អៀនឡើយ ទោះបីចាញ់បញ្ញារបស់ព្រះមហោសថ១លើក ជា២លើកក៏ដោយនៅតែហ៊ានតតាំង ទាំងងឹតងងុលជាមួយព្រះមហោសថ។ជាចុងក្រោយលោកអាចារ្យទាំង៤សុខចិត្តទទួលយកព្រះមហោសថធ្វើជាគ្រូសម្រាប់ដោះស្រាយប្រស្នា ដោយទន្ទេញតាមព្រះមហោសថទាំងមិនយល់អ្វីទាំងអស់។ ក្រៅពីនេះ លោកអាចារ្យក៏ជាមនុស្សចូលមូលបង្កាច់ ញុះញង់ចោទប្រកាន់ ដូចករណីញុះញង់ព្រះវិទេហរាជដោយចោទថា ព្រះមហោសថមានគំនិតចង់ដណ្ដើមរាជ បល្ល័ង្ករបស់ព្រះអង្គនាំឱ្យព្រះអង្គខ្វាល់បង្គាប់ឱ្យគេសម្លាប់ព្រះមហោសថ។ជាងនេះ អាចារ្យទាំង៤ ជាពិសេសអាចារ្យសេនក:ជាប្រធាននៃអាចារ្យបានប្រមាថមើលងាយមើលថោកដល់ស្ត្រីភេទដូចជាទៅចែចង់នាងអមរានៅពេលដែលនាងនៅតែម្នាក់ឯង និងបានចោទនាង ឧទុម្ពរទេវីថា ស្រីមានឧបាយស្ទាត់កំបាំងចំពោះព្រះមហាក្សត្រក្នុងពេលដែលនាងបានសើចដាក់ប្ដីដើមរបស់នាងគឺបិង្គុត្តរមាណព។
- អាចារ្យទាំង៤ ជាមនុស្សមិនឱ្យតម្លៃលើអ្នកដទៃក្រៅពីក្រុមពួកខ្លួន គឺឱ្យតម្លៃតែលើទ្រព្យសម្បត្តិ និងអំណាចតែប៉ុណ្ណោះ។ ករណីព្រះមហាក្សត្រឱ្យលោកអាចារ្យទៅអញ្ជើញព្រះមហោសថដើម្បីទទួលស្គាល់ថា ជាអ្នកប្រាជ្ញ តែលោកអាចារ្យសេនក:បានទូលថ្វាយ ព្រះមហាក្សត្រវិញថា ព្រះមហោសថមិនទាន់ក្លាយជាអ្នកប្រាជ្ញទេ ពីព្រោះបានត្រឹមតែចេះការកសាងសាលាជាកុសលដល់អ្នកដទៃតែប៉ុណ្ណោះ។ លុះត្រាតែមានការសាកល្បងដោះស្រាយប្រស្នាបន្ថែមទៀត បើដោះស្រាយរួចនោះទើបជាអ្នកប្រាជ្ញ។ទង្វើកុហកភូតភររបស់លោក អាចារ្យទាំង៤នាក់នេះ ពីព្រោះពួកគេខ្លាចមហោសថមានប្រាជ្ញាជាង និងដណ្ដើមអំណាច។ ជាមួយគ្នានេះ

លោកអាចារ្យទាំង៤ឱ្យតម្លៃតែលើទ្រព្យសម្បត្តិ និងបុណ្យសក្តិ នោះទេដូចជា លោកអាចារ្យសេនកបានពោលថា បុគ្គលមានតែប្រាជ្ញា គឺជាមនុស្សថោកទាប បុគ្គលដែល មានសិរី គឺយសស័ក្តិ ទ្រព្យសម្បត្តិ ទើបជាមនុស្សល្អប្រសើរ។ អាចារ្យសេនកបានបន្តទៀតថា អ្នកមានប្រាជ្ញាឥតលំនៅស្កុកស្គម្កមានទ្រព្យធនតិច បើទុកជានិយាយត្រូវតាមហេតុការណ៍ ក៏សម្ដីនោះមិនបានការ សម្រេចក្នុងកណ្ដាលបរិស័ទដែររីឯសិរីមិនមានដល់អ្នកមានប្រាជ្ញាក្រទ្រព្យនោះទេដូចជាអំពិលអំពែកមិនប្រាកដក្នុងកន្លែងដែលព្រះអាទិត្យរះដូច្នេះ។

### ៦-ស្ដេចចុល្លនីព្រហ្មទត្ត

#### ក. គុណសម្បត្តិ

▪ ជាស្ដេចសោយរាជ្យនៅនគរឧត្តរបញ្ចាល ដែលមានភាពអង់អាចក្លាហាននិងគ្រប់គ្រងនគរចំនួន១០១ជាចំណុះ។ព្រះអង្គហ៊ានលះបង់ជីវិតខ្លួនដើម្បីពង្រីកនគរឱ្យបានធំទូលាយ និងប្រទេសមានសុខសន្តិភាព និងជាស្ដេចមានស្វាមីភក្តិជាមួយប្រពន្ធកូន និងចេះស្ដាប់ការផ្ដល់យោបល់ពីអ្នកដែលនៅជិតខ្លួនជាពិសេសលោកអាចារ្យកេវដ្តព្រាហ្មណ៍។ព្រះរាជាអង្គនេះ ចេះកែប្រែនូវកំហុសរបស់ខ្លួន និងមានការភ្ញាក់រឭកក្រោយពីចាញ់កលយុគសង្គ្រាមរបស់ព្រះមហោសថ។ ព្រះបាទចុល្លនីទាល់ប្រាជ្ញាក៏បានសុំរៀនកលមាយាទិព្វពីព្រះមហោសថបណ្ឌិត និងបានកោតសរសើរពីបញ្ញាព្រះពោធិសត្វ ហើយក៏សុំស្បថថា លែងបៀតបៀនគ្នាតទៅ។ ជាមួយគ្នានេះ ព្រះបាទចុល្លនីព្រហ្មទត្តក៏បានថ្វាយទ្រព្យសម្បត្តិ (មាស) ស្រុកសួយចំនួន៨០ ទាសី៤០០នាក់ បវរកញ្ញា១០០នាក់ជាភរិយា តែព្រះពោធិសត្វមិនព្រមទទួល ព្រមទាំងធ្វើពិធី ជប់លៀងចំនួន៧យប់ ៧ថ្ងៃថ្វាយព្រះមហោសថទៀតផង ហើយក៏អនុញ្ញាតឱ្យបណ្ឌិតមហោសថគង់នៅក្នុងនគរបន្តទៀត ពីព្រោះថាចាប់តាំងពីព្រះពោធិសត្វមានវត្តមាននៅទីនេះ លោកបានធ្វើប្រយោជន៍ជាច្រើនដល់នគរឧត្តរបញ្ចាល ធ្វើឱ្យនគរមានការរីកចម្រើន និងមានសុខសន្តិភាព តរៀងមក។មិនតែប៉ុណ្ណោះស្ដេចចុល្លនីសុខចិត្តយកជីវិតរបស់ព្រះអង្គ១ មាតា១ ព្រះនាងនន្ទាទេវី(មហេសី)១ តិខិណមន្ត្រីកុមារ(អនុជ)១ ធនុសេក្ខ(សម្លាញ់)១ និងបុរោហិត១ ពោលគឺសរុប ចំនួន៦នាក់យកទៅថ្វាយអារក្សទឹកតាមការគម្រាមកំហែង តែដាច់ខាតព្រះរាជា មិនអនុញ្ញាតឱ្យអារក្សទឹកយកជីវិតព្រះមហោសថនោះទេ ពីព្រោះថាមហោសថជានិម្មិតរូបនៃសន្តិភាព ក្នុងពិភពលោកទាំងមូល។ស្ដេចនគរឧត្តរបញ្ចាលទូលថា បើសិនខ្ញុំស្លាប់ទៅមុន ក៏ព្រះមហោសថញ៉ាំងកូនចៅខ្ញុំទាំងឡាយឱ្យមានសេចក្ដីសុខដែរ។ ព្រះមហោសថស្គាល់នូវប្រយោជន៍គ្រប់ប្រភេទទាំងបច្ចុប្បន្ននិងអនាគត។

#### ខ. គុណវិបត្តិ

▪ ជាស្ដេចអាក្រក់ សាហាវ ល្មោភសង្គ្រាម ល្មោភអំណាច ល្មោភទឹកដីឈ្លានពានលើប្រទេសជិតខាងដូចជា នគរមិថិលា និង១០១នគរថែមទៀត។ ជាស្ដេចមានកលយុគតិចតួច

ក្នុងការធ្វើសង្គ្រាមឈ្លានពានមានទឹកចិត្តសាហាវចង់ចាប់ព្រះមហោសថ និងស្ដេចវិទេហរាជ កាត់ត្រចៀក កាត់ច្រមុះ និងកាត់ដៃកាត់ជើង ដើម្បីប្លន់យកនគរមិថិលា។ជាមួយគ្នានេះ ស្ដេចអង្គនេះមិនបានបំពេញកាតព្វកិច្ចជាបិតាដ៏ល្អរបស់បុត្រីគឺព្រះនាងបញ្ចាលចន្ទីនោះទេ ព្រោះយកនាងធ្វើជាផ្ទាក់ដើម្បីចាប់ស្ដេចវិទេហរាជនៃនគរមិថិលា និងជាអ្នកខ្វះធម៌មេត្តាដល់ក្រុមគ្រួសារ សុខចិត្តឱ្យសមាជិក៥អង្គទៅស្លាប់ជួសព្រះមហោសថ។

## ៧-អាចារ្យកេវដ្ដព្រាហ្មណ៍

### ក. គុណសម្បត្តិ

- ជាអ្នកប្រាជ្ញក្នុងនគរឧត្តរបញ្ចាល និងជាអ្នកផ្ដល់យោបល់ដល់ព្រះបាទចុល្លនីព្រហ្មទត្ត និងជាអ្នកមានទឹកចិត្តក្លាហានក្នុងការដណ្ដើមទឹកដីពីនគរផ្សេងៗ និងជាអ្នកមានបញ្ញាចងធ្វើ ធម្មយុទ្ធ(ប្រយុទ្ធធម៌)ជាមួយព្រះមហោសថនៅទីធម្មយុទ្ធមណ្ឌល ដើម្បីចាប់ព្រះពោធិសត្វ។

### ខ. គុណវិបត្តិ

- ជាមនុស្សអាក្រក់ ដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ផ្ដួចផ្ដើមគំនិតធ្វើសង្គ្រាមជាមួយប្រទេសជិតខាងនិងបន្តគ្រប់គ្រងនគរចំនួន១០១។ជាមន្ត្រីមានសមត្ថភាពទាបក្នុងការធ្វើសង្គ្រាមជាមួយព្រះមហោសថ ពោលគឺត្រូវបានចាញ់ល្បិចកលនិងជាន់កស្ទើរស្លាប់ស្ទើររស់ នៅជាប់នឹងដី។

## ៨-នាងភេរីបរិព្វាជិកា

### ក. គុណសម្បត្តិ

- ជាអ្នកបួសប្រកបដោយប្រាជ្ញា និងឈ្លាសវៃ មានចិត្តស្មោះត្រង់ ស្រឡាញ់សន្តិភាព និងជាមនុស្សដែលមានសន្តានចិត្តល្អ ចេះជួយយកអាសាអ្នកដទៃ ចេះផ្ដល់ហេតុផលល្អៗ និងជាអ្នកអូសទាញឱ្យព្រះមហោសថចូលបួសជាមួយ ប៉ុន្តែព្រះពោធិសត្វមិនបានចូលបួសទេពីព្រោះមានកិច្ចការជាច្រើនដែលត្រូវបំពេញ។ បន្ទាប់មកទៀត នាងភេរីបរិព្វាជិកាពេញចិត្តពីគុណសម្បត្តិរបស់ព្រះមហោសថ ហើយនាំទៅប្រថាប់នៅមុខព្រះលាន ដែលមាននាម៉ឺនមន្ត្រី និងប្រជាជនប្រុសស្រីជាច្រើនចូលរួមជាបរិវារ។ ក្រៅពីនេះ នាងភេរីក៏បានពន្យល់ពីហេតុផលផ្សេងៗដែលជាមូលហេតុនៃស្ដេចចុល្លនីសុខចិត្តថ្វាយជីវិតមនុស្ស៦នាក់ដល់អារក្សទឹក។

### ខ. គុណវិបត្តិ

- ជាអ្នកបួសមានគំនិតផ្ចាញ់ផ្ចាល និងមានភាពអំណួតលើសម្ថភាពខ្លួនឯង។

## ២-៥-ឧត្តមគតិរឿង

-អប់រំមនុស្សទូទៅឱ្យចេះស្វែងរកនិងកសាងបញ្ញាដើម្បីដោះស្រាយបញ្ហាផ្សេងៗចំពោះមុខ និងចេះសាមគ្គីគ្នារួបរួមគ្នាកសាងសមិទ្ធផលនានាសម្រាប់ជាប្រយោជន៍រួមជាពិសេសសន្សំនូវបញ្ញាដល់បុគ្គលម្នាក់ៗ។

-ការប្រើប្រាស់បញ្ញានាំឱ្យមនុស្សមានកិត្តិយសដល់ខ្លួន ធនធានទ្រព្យសម្បត្តិ បុណ្យ សក្តិ

អំណាច និងមហាកិត្តិនាមខ្ពង់ខ្ពស់ ពោលគឺកសាងសន្តិភាពសម្រាប់មនុស្សជាតិ។

-អប់រំមនុស្សឱ្យចេះស្រឡាញ់សន្តិភាពចៀសវាងការបង្កសង្គ្រាម និងចេះដោះស្រាយដោយផ្អែកលើបញ្ញា។ ការសន្តោសប្រណី ការខន្តី និងការលើកលែងទោសដល់សត្រូវ គឺបានប្រែក្លាយពួកគេឱ្យទៅជាមិត្តដ៏ល្អ និងសងគុណយើងវិញ។

-ការរៀបចំនូវប្រព័ន្ធការពារប្រទេសមួយ ដោយផ្អែកលើការពង្រឹងវិស័យកងទ័ព ស្បៀងអាហារ សព្វាវុធ និងរៀបចំកំផែងច្រើនជាន់រួមទាំងការបណ្តុះបណ្តាលផ្នែកចារកម្ម ដើម្បីយកព័ត៌មានពីសត្រូវគ្រប់យុទ្ធសាស្ត្រ។

## ៣-អត្ថរូប

### ៣-១-វិធីតែងនិពន្ធ

តាមរយៈអត្ថរូបក្នុងរឿងព្រះមហោសថ ឃើញថាអ្នកនិពន្ធសរសេរជាពាក្យរាយជាភាសាខ្មែរ ភាសាបាលី សំស្រ្ដីតលាយឡំគ្នាធ្វើឱ្យអ្នកអាន អ្នកស្តាប់ងាយយល់ និងងាយស្តាប់យ៉ាង ពិរោះជាប់ចិត្ត។

### ៣-២-ការផ្ដើមរឿង

ក្នុងរឿងព្រះមហោសថនៃទសជាតកនេះ គឺផ្តើមរឿដោយប្រារព្ធបទមនស្សការ (អតីតេ ភិក្ខវេ...) រំឭកកាលពីព្រះបរមសាស្តាទ្រង់គង់ក្នុងវត្តជេតពនទ្រង់ប្រារព្ធនូវបញ្ញាបារមីរបស់ ព្រះអង្គទ្រង់សម្តែងធម៌ទេសនានោះថា បញ្ញាលោសព្វសេនាយជាដើម។សេចក្តីថា៖ ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាពណ៌នានូវបញ្ញាបារមីនៃព្រះតថាគត កាលព្រះសាស្តាចារ្យជាម្ចាស់ទ្រង់ និមន្តមកសួរក៏ក្រាបបង្គំទូលតាមដំណើរ ដែលខ្លួនប្រជុំគ្នានិយាយ។

### ៣-៣-ដំណើររឿង

ចាប់ផ្តើមជាគាថាបាលីរួចផ្តើមដំណើររឿង ដោយសង្កត់ទៅលើគោលឧត្តមគតិជាប្រធានរឿងយ៉ាងច្បាស់ដូចជា មហោសថជាតកនេះគេសង្កត់ទៅលើការដោះស្រាយដោយ ប្រើប្រាជ្ញាជាធំ។មហោសថជាតកនេះអ្នកនិពន្ធបានបង្ហាញពីសកម្មភាពរបស់តួអង្គមហោសថ ក្នុងការយកប្រាជ្ញាមកដោះស្រាយប្រកបដោយការពិតដឹងច្បាស់ ដើម្បីចោទ និងដោះស្រាយ បញ្ហាដោយល្បិច និងប្រកបដោយសិល្ប៍វិធីតែងនិពន្ធដ៏ល្អពីរោះពិសា ។ អ្នកនិពន្ធបានប្រើវិធីដូចជា៖

### ៣-៤ការបញ្ចប់រឿង

រឿងព្រះមហាសថ អ្នកនិពន្ធមានវិធីខ្ពស់ដោយឱ្យតួអង្គព្រះពោធិសត្វបានក្លាយជា តួអង្គអច្ឆរិយមានប្រាជ្ញាឈ្លាសវៃលើសអ្នកប្រាជ្ញក្នុងនគរ ហើយទទួលបានការគោរពទទួល ស្គាល់ពុំតាំងពីព្រះមហាក្សត្រ មន្ត្រីរាជការក្រុមអ្នកទាំងបួនលែងហ៊ានបៀតបៀនដោយខ្លាច បញ្ញាបារមីរបស់ព្រះមហោសថ។

## ក-វចនរូប ឬវចនវិធី

វចនរូប គឺសិក្សាអំពីវចនៈ ឬសព្ទដែលប្រើក្នុងអត្ថបទនៅក្នុងប្រវត្តិអ្នកនិពន្ធបានប្រើវិធីចម្រុះពាក្យដូចជាបាលី ពាក្យសំស្រ្កឹត ពាក្យរាជសព្ទ ក៏មានលាយចូលគ្នាជាមួយពាក្យមួយចំនួនផ្សេងទៀតផងដែរ។អត្ថបទនេះ គឺជាទសជាតកមួយសម្រាប់បណ្តុះបញ្ញាដល់កូនខ្មែរគ្រប់ជំនាន់ ។

- **ពាក្យបាលី**

-បដិសន្ធិ (ន. បា ) កំណាកំណើតសត្វ កើត ចាប់បដិសន្ធិក្នុង ផ្ទៃម្តាយ ។

-វិនិច្ឆ័យ ( ន. បា ) ការពិចារណាដោយល្អិត ការពិនិត្យឱ្យឃើញពិត ។

-បណ្ឌិត (ន. បា ) ជាអ្នកមានប្រាជ្ញា

-សោត (ន. បា ) ត្រចៀក ។

-ទុក្ខ (ន. បា ) សេចក្តីព្រួយ សេចក្តីលំបាក ។

-ផលានុផល ( ន. បា ) ផ្លែ និងផ្លែតាមលំដាប់ ផ្លែមុន និង ក្រោយផ្លែធំ និង ផ្លែតូច ។

-សរីរៈ (ន. បា ) អត្តភាព រូប រាងកាយ ខ្លួនប្រាណ ។

-អាវុធ ( ន. បា ) គ្រឿងប្រហារ គ្រឿងចម្បាំងផ្សេងៗ ដែលទីទៃពីសាស្រ្តា ។

-សយនា (ន. បា ) ទី រឺ កន្លែងដេក ដំណេក ការ ដេក ឥរិយាបថដេក ។

-មេត្តា (ន. បា ) មេត្រី សេចក្តីរាប់រក សេចក្តីរាប់អានគ្នា សេចក្តីប្រណីបំណងឱ្យអ្នកដទៃបានសេចក្តី សុខចម្រើនដូចខ្លួន ។

-អម្ពរ (ន. បា ) សំពត់ ឬអាកាស ។

-បាទា (ន. បា ) ជើងទាំងឡាយ ជើងទាំងពីរ ។

-បុគ្គល ( ន. បា ) ចិត្តវិញ្ញាណ រាងកាយ ខ្លួនប្រាណ ។

-សក្ការ ( ន. បា ) ការធ្វើគោរព សេចក្តីគោរព ការធ្វើបដិសណ្ឋារ តង្វាយ ដោយគោរពជំនូន គ្រឿងបូជា ។

-បដិសណ្ឋារៈ ( ន. បា ) ការទទួលរាក់ទាក់ ។

-បព្វជ្ជា (ន. បា) ការបួស ផ្នួស ។

-អភិសេក (ន. បា) ការស្រោចទឹកក្លស់ស័ង្ខ សន្មតឱ្យឡើងពេញជាក្សត្រគ្រងរាជ្យ ។

-បរិវារ (ន. បា) អ្នកចោមកំដរ អ្នកហែហមជាកិត្តិយស អ្នកត្រៀមខ្លួនចាំបម្រើ អ្នកបម្រើ ។

- **ពាក្យសំស្រ្កឹត**

-បុណ្យ (ន. សំ)គុណជាតិជាគ្រឿងជម្រះសន្តានចិត្តកុសលសេចក្តីសុខ។

-អស្ចារ្យ (គុ. សំ)គួរស្ងើចក្រៃពេក ដែលគួរទះដៃស្ងើចសរសើរ ។

-ប្រសូត (ន. សំ) សម្រាលកូន។

-ហឫទ័យ (ន. សំ) បេះដូង ដួងចិត្ត ទ្រូង។

-ទីនាំង (ន. សំ) ទីអង្គុយ ទីសម្រាប់ក្សត្រទ្រង់ប្រថាប់។

-ប្រយោជន៍(ន សំ) ដំណើរដែលគួរប្រកបអ្វីៗដែលគេត្រូវការ ដែលប្រកបទៅកើតការ ផលដែលសម្រេចពីការប្រកប។

-ព្រាហ្មណ៍ (ន. សំ) មនុស្សដែលកំណត់តាមលទ្ធិបុរាណពីព្រេងនាយថា ជាពូជដើមកើត មកពីព្រះឱស ព្រះព្រហ្ម។

-មហោស្រប (ន. សំ)របាំយ៉ាងធំ ការលេងរបាំយ៉ាងគគ្រឹកគគ្រេង ការរីករាយសប្បាយយ៉ាងខ្លាំង ដោយរបាំ ការបញ្ចេញរបស់ប្លែកៗដាក់តាំងជារបៀបយ៉ាងធំឱ្យមហាជន មើល។

-សូរសព្ទ (ន. សំ) សូរសម្លេង ឬ សម្លេងក្ងៀវក្លា សម្លេងខ្លាំង។

-ប្រទីប (ន. សំ) គោម ចង្កៀង។

-មាតុគ្រាម (ន. សំ) អ្នកដែលមានលំអានដូចមាតា។

-អន្តរាយ(ន.សំ)ហេតុដែលមានទំនាស់ក្នុងចន្លោះឬក្នុងពាក់កណ្តាលសេចក្តីទើសទាល់។

-សារថី (ន.សំ) អ្នកបររថ អ្នកបង្ហាត់សេះ។

-ទិវា (ន.សំ) ថ្ងៃ ។ ក្នុងវេលាថ្ងៃ នៅថ្ងៃ ។

-ព្យាយាម (ន.សំ) សេចក្តីខំប្រឹងប្រែង ការប្រឹងប្រែងដំណើរខ្មីឃ្មាតសង្វាត។

-អនុភាព (ន.សំ) សេចក្តីប្រាកដក្នុងចិត្ត ការចូលចិត្តស៊ប់ ជឿស៊ប់ សេចក្តីដឹងច្បាស់។

-អាស្រ័យ (ន.សំ) ទីតាំងសំណាក់ ទីលំនៅ ទីជ្រក ទីពឹងពាក់ ទីពំនាក់។

-កិត្តិសព្ទ (ន.សំ) សូរសរសើរ។

-ប្រាថ្នា (ន.សំ) ការតាំងបំណង ការផ្តងឬតាំងសូមសំណូមអោយសម្រេចបានដូចបំណង។

**ពាក្យរាជសព្ទ**

-ព្រះរាជបុត្រ : កូនប្រុស ។
-ព្រះរាជធីតា : កូនស្រី ។
-ព្រះសណ្តាប់ : ស្តាប់ ។
-ព្រះក្បៀរ : ទឹកដោះ។
-ព្រះសន្ធិយា : រាំងនន។
-ព្រះសយនា : ទី ឬកន្លែងដេក។
-ព្រះហស្ថ : ដៃ។
-ព្រះបាទា : ជើង។
-ព្រះពលំ : កម្លាំង។
-ព្រះឧរូ : ភ្លៅ។

**ខ-ពណ៌នាវិធី**

ជាវិធីមួយដែលអ្នកនិពន្ធរៀបរាប់ពីទិដ្ឋភាពទាំងឡាយនៅក្នុងដំណើររឿងតាំងពីដើមរហូតដល់ចប់។ការពណ៌នាអាចជាការរៀបរាប់ពីធម្មជាតិ តួអង្គ ទេសភាពនានា។ល។ តាមដំណើររឿងបានពណ៌នាពីស្រះបាក្ខរណីរបស់ព្រះមហោសថដូចជា៖

**គ-ឧបមានវិធី**

ជាវិធីមួយដែលអ្នកនិពន្ធបានធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពនៅក្នុងដំណើររឿងដើម្បីរំលេចចេញនូវជីវរូបារម្មណ៍ ឬមនោរម្មណ៍។ រឿងមហោសថត្រូវបានអ្នកនិពន្ធធ្វើឱ្យអ្នកអានបានធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពនៅក្នុងដំណើររឿងដើម្បីរំលេចចេញនូវជីវរូបារម្មណ៍ឬមនោរម្មណ៍ដូចជា៖ព្រះនាងនន្ទាទេវីមានឥន្ទ្រិយ៍ស្រស់បំព្រងរាងទ្រទេសទ្រទ្រង់ ឥតឆ្គងសព្វសព៌ាង្គកាយព្រះសោណីរីកត្រសាយដូចដំបារមាស មានព្រះដំណើរយាងយាស ដោយព្រះបាទាក្រហមទុំមានចង្កេះរាងក្លំសមដោយខ្សែរឹតវិចិត្រដោយមាសទឹកដប់មានរឹមព្រះ ឱស្ឋដូចផ្លែទន្លាប់ក្រហមទុំរលើបរលង់មានព្រះនេត្រថ្លាយង់ដូចភ្នែកកូន ម្រឹគទើបកើតថ្មីៗមាន ព្រះឧរូដូចប្រមោយដំរី មានព្រះស្តន់ទាំងពីរ ដូចផ្លែទន្លាប់ដែលគេកាត់យកមកភ្ជាប់នឹង ព្រះឱរា។

ចំណែកឯយក្ខិនីវិញមានលក្ខណៈដូចជា ភ្នែកក្រហម មិនចេះរអៀសខ្លួន ឥតស្រមោល និងមិនមែនករុណានោះទេ.........។ល។

**ឃ-ឯកវាទវិធី**

ជាវិធីដែលគេធ្វើឱ្យតួអង្គ ដែលទទួលរងទុក្ខទោសក្ដីមានការឈឺចាប់ ទុក្ខព្រួយក្ដី ឬកើតវិប្បដិសារៈអំពីរឿងអ្វីមួយដោយការនិយាយរំលឹកអំពីហេតុភេទរឿងរបស់ខ្លួនតែម្នាក់ឯង។ ជាក់ស្ដែងនៅក្នុងអត្ថបទ៖បង្គួយបានគ្រឿងអលង្ការពាក់ហើយក៏គិតថាអញមានអលង្ការ ពាក់ស្ដេចក៏មានអលង្ការពាក់ដូចគ្នា ចាំគោរពស្ដេចធ្វើអ្វី។

**ង-សំវាទវិធី**

ជាវិធីដែលអ្នកនិពន្ធ ករីធ្វើឱ្យតួអង្គពីរឬច្រើនឡើងទៅសន្ទនា និយាយសារសេងរវាងគ្នាអំពីបញ្ហាអ្វីមួយ ឬអំពីវិបត្តិទំនាស់ឈ្លោះទាស់ទែងគ្នាដោយពាក្យសម្ដី។ ជាក់ស្ដែងនៅក្នុងអត្ថបទ ៖ព្រះមហោសថនិយាយឆ្លងឆ្លើយជាមួយអមរានិងព្រះមហោសថនិយាយឆ្លងឆ្លើយនឹង ព្រះបាទចុល្លនី៖

-ព្រះបាទចុល្លនី : នែវ៉ីយចូរចោមព័ទ្ធចាប់អាមហោសថកាត់ដៃ ជើង ត្រចៀក ច្រមុះព្រោះធ្វើឱ្យស្ដេចវិទេហរាជរួចពីកណ្ដាប់ដៃយើងទៅវិញ។

-ព្រះមហោសថថា : បើព្រះអង្គឱ្យកាត់ដៃ ជើង ត្រចៀក ច្រមុះ របស់ខ្ញុំយ៉ាងណា ព្រះបាទវិទេហរាជ នឹងឱ្យកាត់ដៃ ជើង ត្រចៀក ច្រមុះ របស់បញ្ចាលច័ន្ទ របស់នាងបញ្ចាចន្ទី របស់នាងននន្ទាទេវី ជាព្រះរាជបុត្រាបុត្រីអគ្គមហេសីនៃព្រះអង្គយ៉ាងនោះដែរ។

**ច-សន្ទេហវិធី**

ជាវិធី ដែលកវីអ្នកនិពន្ធតែងសម្រាប់ធ្វើឱ្យអ្នកអានចង់ដឹងហើយចង់ដឹងទៀតអំពី រឿងណាមួយដោយគេបែងចែករឿងជាខណៈផ្សេងៗ។ ជាក់ស្តែងនៅក្នុងអត្ថបទនៅពេល ដែលបុរសឈ្មោះទីយបិដ្ឋិនាំប្រពន្ធនាយគោធកាឡឆ្លងស្ទឹង ធ្វើឱ្យអ្នកអានងឿងឆ្ងល់ថា តើរឿងហេតុនិងទៅជាយ៉ាងណា?

**ឆ-វឌ្ឍមានវិធី**

ជាវិធីដែលកវី អ្នកនិពន្ធតុបតែងដើម្បីផ្តល់នូវការចម្រើនបន្តិចម្តងៗនៃរឿង(សកម្មភាពតួអង្គក្តី)ធ្វើឱ្យមានស្ថានភាព ឬដំណើរតឹងតែងឡើងៗ។ជាក់ស្តែងនៅក្នុងអត្ថបទ ៖ អាចារ្យទាំង៤នាក់មិនព្រមឱ្យព្រះបាទវិទេហរាជតែងតាំងព្រះមហោសថជាអ្នកប្រាជ្ញ។

**ជ-រចនាវិធី**

ជាការប្រើឃ្លាប្រយោគរបស់អ្នកនិពន្ធ ដើម្បីឱ្យស្នាដៃឬអត្ថបទ មានសម្រស់ដើម្បីបង្កើតបានជាបរិយាកាសមួយអណ្តែតអណ្តូង សប្បាយរីករាយព្រួយបារម្ភ...។ ជាក់ស្តែងនៅក្នុងអត្ថបទអ្នកនិពន្ធបានបង្ហាញថា ព្រះរាជាទ្រង់សុបិននិមិត្តថា មានភ្លើងបួនភ្នក់នៅជ្រុងទាំងបួននៃព្រះរាជវាំងឆេះសន្ធោសន្ធៅស្មើនឹងកំពែងធំ ត្រង់កណ្តាលភ្នក់ភ្លើងទាំងបួននោះ មានភ្លើងមួយប៉ុនអំពិលអំពែកឆេះភ្លែតឡើងភ្លឺជាងភ្នក់ភ្លើងទាំងបួនធំៗ ភ្លឺឡើងៗទៅខាងលើ ទល់នឹងអកនិដ្ឋព្រហ្ម ជុំវិញពេញសកលចក្រវាល។

**ឈ-ចេតនារូបារម្មណ៍**

ជារូបារម្មណ៍ដែលកើតឡើងដោយកវីអ្នកនិពន្ធ ចេះបង្កើតនូវមនោសញ្ចេតនាដូចជា ទុក្ខព្រួយ សុខសប្បាយ កំហឹង ភ័យខ្លាច ត្រេកត្រអាល ច្រណែន សោកស្តាយ អាឡោះ អាល័យ សង្ឃឹម អស់សង្ឃឹម ស្រលាញ់ ឬពិសេសទៅទៀតដោយគេចេះយកជំនឿចំពោះ ទៅលើលទ្ធិ ឬសាសនា ណាមួយមកជាប់ជាមួយនឹងការនិពន្ធរបស់គេដើម្បីបង្កើតនូវសិល្ប៍ បរិយាកាស ធ្វើឱ្យពាក្យកាព្យទៅជាមានរូបារម្មណ៍ ចំពោះប្រធាន អ្នកអាន អ្នកទស្សនាឱ្យ មានជំនឿមួយរំពេច។ ជាក់ស្តែងក្នុងអត្ថបទរឿង៖ ក្នុងការនោះ សិរីវឌ្ឍកសេដ្ឋី ជាបិតា មាន រោគអស់៧ឆ្នាំ ហើយព្យាបាលមិនជាសោះ ទើបនាងសុមនាទេវីយកឱសថនោះទៅជូនស្វាមីពិសា រោគនោះក៏ជាភ្លាមមួយរំពេច។

**ញ-មនោរូបារម្មណ៍**

ជារូបារម្មណ៍ដែលកើតឡើងដោយសញ្ញាញាណដោយការពិចារណាពិភាក្សា សង្វេគ ត្រិះរិះ ដែលអាចធ្វើឱ្យសិល្ប៍មនោនៅក្នុងប្រធានារម្មណ៍ ញាប់ញ័រ រំភើបបាន។ សេចក្តី ពិចារណាឬយោបល់ក្នុងការអានទាញមតិមួយឱ្យជាប់ទៅនឹងមតិមួយទៀតឱ្យទាក់ទងទៅជា ការពិភាក្សាហើយឱ្យនិយមន័យឃើញនូវគំនិតនូវមតិជារូបរាងឡើង។យ៉ាងណាមិញនៅក្នុងរឿងបានបញ្ជាក់

ថា នៅពេលដែលព្រះរាជាទ្រង់សុបិនឃើញភ្នក់ភ្លើងទាំងបួននោះហើយ ព្រឹកឡើងទ្រង់ហៅអ្នកប្រាជ្ញទាំងបួនឱ្យមកធ្វើការទស្សន៍ទាយថានឹងមានហេតុការណ៍អ្វីកើតឡើង។

**៣-៣-ការបញ្ចប់រឿង**

រឿងមហោសថអ្នកនិពន្ធជាតក អ្នកនិពន្ធបញ្ចប់ដោយឱ្យតួអង្គមហោសថទទួលបាន នូវជោគជ័យក្នុងសកម្មភាពការកសាងបញ្ញាបារមី និងបានសរជាតិទៅជាព្រះពុទ្ធព្រមទាំង បានបង្ហាញពីការសរជាតិរបស់តួអង្គដទៃទៀតដូចជាៈ

-អាចារ្យសេនកៈ បានមកជាភិក្ខុកស្សប

-អាចារ្យកាមិន្ទ បានមកជាអម្ពដ្ឋព្រាហ្មណ៍

-អាចារ្យបុក្កុស បានមកជាបោដ្ឋបាទព្រាហ្មណ៍

-បញ្ចាលចន្ទរាជកុមារ បានមកជាភិក្ខុអនុរុទ្ធ

-អាចារ្យទេវិន្ទ បានមកជាសោណទណ្ឌព្រាហ្មណ៍

-អាចារ្យកេវដ្តព្រាហ្មណ៍ បានមកជាភិក្ខុទេវទត្ត

-នាងសលាកទេវី បានមកជាថូលនន្ទាភិក្ខុនី

-អនុកេវដ្តព្រាហ្មណ៍ បានមកជាភិក្ខុមោគ្គលាន

-នាងបញ្ចាលចន្ទី បានមកជានាងសុនរី តិត្ថិយសាវិកា

-សាវិការញី បានមកជានាងមល្លិការាជទេវី

-បាងឧទុម្ពរទេវី បានមកជាព្រះនាងគោតមីសក្យានី

-ព្រះបាទវិទេហរាជ បានមកជាកាឡុទាយីអាមាត្យ

-នាងភេរីបរិព្វាជិកា បានមកជានាងឧប្បលវណ្ណាថេរី

-បិតាបានមកជា ព្រះបាទសុទ្ធោទន៍

-មាតាបានមកជា នាងសិរិមហាមាយា

-នាងអមរាទេវី បានមកជានាងពិម្ពា

-តិខិណកុមារ បានមកជាធន្នភិក្ខុ

-ធនុសេក្ខ បានមកជារាហុលភិក្ខុ

-សេកសោម បានមកជាអានន្ទភិក្ខុ

-ស្តេចចុល្លនី បានមកជាព្រះសារីបុត្រភិក្ខុ

-ព្រះមហោសថ បានមកជាព្រះពុទ្ធ។

**៤-អត្ថរស** (**តម្លៃ**)

តម្លៃរឿងដែលជាមូលដ្ឋានស្ថិតនៅលើៈ

**ក-វិសេសរស** គឺមានក្នុងអំពើតស៊ូតតាំងក្នុងការទប់ទល់វាយបកទៅលើគូបដិបក្ខដោយប្រើបញ្ញា

ញាណដ៏អស្ចារ្យគ្មានគូប្រៀបរបស់ព្រះមហោសថ ជាអង្គព្រះពោធិសត្វនេះឯង។

**ខ-អច្ឆរិយរស**

តួអង្គមានលក្ខណៈអស្ចារ្យហួសពីលក្ខណៈមនុស្ស។ភាពអស្ចារ្យរបស់ព្រះមហោសថ គឺកើតមកភ្លាមចេះនិយាយបានភ្លាម(ម៉ែ! នេះថ្នាំទិព្វ)។ព្រះមហោសថមានអាយុត្រឹមតែ៧ឆ្នាំ ចេះប្រមូលទេវបុត្រ១០០០នាក់កសាងសាលា៥ខ្នង និងមានបញ្ញាខ្ពង់ខ្ពស់អាចដោះស្រាយប្រស្នាបានគ្រប់បែបយ៉ាង។

**គ-វីររស**

បង្ហាញពីសម្មភាពអង់អាចក្លាហានរបស់ព្រះមហោសថ។ មហោសថ គឺជាតួអង្គម្នាក់ ដែលហ៊ានលះបង់ជីវិតដើម្បីប្រយោជន៍មនុស្សទូទៅnigប្រទេសជាតិដូចមានឃ្លាមួយថា ព្រះពោធិសត្វដកព្រះខ័នឡើងលោតហក់១៨ជំហានបានកម្ពស់១៨ហត្ថចុះមកឈរឆ្ពោះទៅព្រះបាទចុល្លនីដែលកំពុងតែភ័យ ទ្រង់ក្រាបទូលថា ព្រះអង្គកុំព្រះរាជហឫទ័យថា ក្រែងខ្ញុំសម្លាប់តែបើព្រះអង្គចង់សម្លាប់ខ្ញុំវិញក៏សូមបំពេញព្រះរាជករណីយកិច្ច តាមព្រះរាជបំណង ចុះ.....។ល។

**ឃ-កុសលរស**

តាមរយៈដំណើររឿងទាំងមូលបានបង្ហាញឱ្យយើងចេះកសាងកុសលផលបុណ្យតាមរយៈសកម្មភាពផ្សេងៗដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធការជួយដោះស្រាយបញ្ហារបស់អ្នកដទៃការគោរព និងការរក្សាសីល។ កសាងសាលា៥ខ្នងដើម្បីសម្រាប់ជាកុសលដល់មនុស្ស ទូទៅ។

**៥-បញ្ហាសង្គម**

**១-នយោបាយ**

**ក-ក្នុងប្រទេស**

ការគ្រប់គ្រងប្រទេសតាមបែបរាជានិយម ដែលបន្តរាជ្យពីបិតាទៅបុត្រា ហើយព្រះរាជា ជាអ្នកសម្រេចរាល់កិច្ចការនៅក្នុងប្រទេស។ ព្រះមហាក្សត្រជាអ្នកសម្រេចកិច្ចការនានាដោយ មានការផ្លាស់ប្តូរយោបល់ទៅវិញទៅមកពីបណ្តាមន្ត្រីអ្នកមុខ អ្នកការ ក្នុងសវនាការដែលរៀបចំឡើងដោយព្រះមហាក្សត្រ មានមន្ត្រីទៅតាមឋានន្តរសក្តិដូចជា អាមាត្រ សេនា ទាហាន សេដ្ឋី អនុសេដ្ឋី និងចេះប្រមូលអ្នកប្រាជ្ញទាំងឡាយ(អាចារ្យ)យកមកធ្វើការជាមួយព្រះអង្គ និងសម្រាប់ពិគ្រោះយោបល់ និងកុមារមហាសថមានកុមារចំនួន១០០០ជាបរិវារ។

**ខ-ក្រៅប្រទេស**

ចំពោះនយោបាយក្រៅប្រទេស គឺនគរមិថិលាមានការទំនាក់ទំនងជាមួយ នឹងនគរ ផ្សេងៗទៀតមានទាំងនគរ១០១ និងនគរដែលគ្រប់គ្រងដោយព្រះបាទចុល្លនីដូចមានសម្តីថា ទ្រង់ចិញ្ចឹមសេកសោមបណ្ឌិតឈ្មោះមាធុរៈ ដើម្បីឱ្យស៊ើបការណ៍ស្តេចទាំង១០១នគរ និងនគរព្រះបាទចុល្លនីក៏បានដឹងថា ស្តេចចុល្លនីព្រហ្មទត្តនានគរឧត្តរបញ្ចាលជាមនុស្សអាក្រក់។ សម័យមួយព្រះបាទ

ចុល្លនី និងអាចារ្យកេវដ្តព្រាហ្មណ៍ព្រមទាំងទាហាននាំគ្នាលើកទ័ពទៅ ដណ្តើមនគរតូចៗមកជាចំណុះ រួចលើកទ័ពមកនគរធំៗទៀត។

## ២-សេដ្ឋកិច្ច

### ក-កសិកម្ម

នាសម័យកាលនោះអំណោយផលខាងកសិកម្មព្រៃឈើ បឹងបួរ ទន្លេ សមុទ្រ ភ្នំ ដែលជាសម្បត្តិធម្មជាតិដ៏មានតម្លៃសម្រាប់វិស័យកសិកម្ម។ តាមរយៈដំណើររឿងអ្នកនិពន្ធបានរៀប រាប់ឈ្មោះផ្លែទម្លាប់ ការចិញ្ចឹមសត្វ គោ សេះ ដំរី និងការធ្វើស្រែ និងទីកន្លែងទាក់ទង ជាមួយជនបទទាំងឡាយជាដើម។ (នាងអមរាក្រោកឡើងពីព្រឹកចម្អិននូវយាគូទៅជូនឪពុក នាឋានស្រែឯនាយស្ទឹង នាងដើរចេញទៅដោយនូវផ្លូវនោះ ហោង។)

### ខ-សិប្បកម្ម

តាមរយៈអត្ថបទរឿងបានបង្ហាញឱ្យឃើញថា ប្រជាជននាសម័យកាលនោះមានការផលិតរបស់របរសម្ភារៈសម្រាប់ប្រើប្រាស់ និងបំពេញតម្រូវការជីវភាពប្រចាំថ្ងៃដូចជា៖ ឆ្នាំង ចាន ចង្រ្កាន កញ្ច្រែង រទេះ ដេរប៉ាក់ សម្លៀកបំពាក់ ហ្វូល គ្រឿងអាវុធ គ្រឿងអលង្ការ សូត្រ អំបោះ សង្វារជាដើម។ ជាមួយគ្នានេះក៏មានការសាងសង់សាលាសម្រាប់ផ្នែកចម្លាក់ គំនូរ ជាងឈើ និងផ្នែកតុបតែងផ្សេងៗទៀតផង។

### គ-ពាណិជ្ជកម្ម

ចំពោះពាណិជ្ជកម្មនាសម័យកាលនោះ មានការលក់ដូរ ផលិតផលក្នុងស្រុកមានដូចជា សូត្រ កែវមណី គ្រឿងអលង្ការ គ្រឿងក្រអូប សម្លៀកបំពាក់ ត្រី សាច់ជាដើម។ ការដោះដូរ ទំនិញតាមរយៈការចាយវាយជាកហាបណៈ។ ជាមួយគ្នានេះ គេបង្កើតឱ្យមានសាលាសម្រាប់ ពួកអ្នកធ្វើជំនួញជាដើម។ក្រៅពីនេះ នៅមានការទិញដូរ ទំនិញពីនគរមួយទៅនគរផ្សេងទៀត ជាពិសេសនគរដែលមានព្រំដែនជាប់គ្នា។

### ឃ-គមនាគមន៍

នាសម័យកាលនោះមិនទាន់មានការរីកចម្រើនខាងវិស័យគមនាគមន៍នោះទេ ប៉ុន្តែតាម រយៈដំណើររឿងបានបង្ហាញឱ្យឃើញថា ទាំងក្សត្រទាំងរាស្ត្រធម្មតាគឺប្រើមធ្យោបាយដោយ ថ្មើរជើង ដោយរទេះគោ សេះ មិនថាទៅទីជិត ឬទីឆ្ងាយ ត្រូវធ្វើដំណើរកាត់តាមព្រៃភ្នំ និងតាម នាវា។ ព្រះមហោសថ ធ្វើពិធីរាជាភិសេកថ្វាយព្រះនាងបញ្ចាលចន្ទីចំពោះព្រះបាទវិទេហរាជ ក្នុងទីនោះហើយនាំចុះកាន់នាវាចំនួន៣០០គ្រឿងចម្លងឡើងទៅកាន់ត្រើយម្ខាងប្រគល់ឱ្យពួក សេនានៅត្រើយម្ខាងហែបន្តទៅកាន់នគរមិថិលា។

### ង-ទេសចរណ៍

ទោះបីវិស័យទេសចរណ៍ពុំទាន់មានលក្ខណៈជាផ្លូវការនាសម័យកាលនោះក៏ពិតមែន ប៉ុន្តែ

ដំណើររឿងបានបង្ហាញនូវទេសភាព សួនឧទ្យានសម្រាប់ព្រះរាជាយាងទត ជីកស្រះ បោក្ខរណី មានហ៊ុំព័ន្ធដោយឥដ្ឋដាំផ្កាវិចង់ស្បង្គ័ជ មានសួនច្បារនៅក្បែរភ្លឺស្រះដេរដាសដោយព្រឹក្សាលតាវល្លិ៍ផ្សេងៗដែលទ្រទ្រង់នូវផ្កា និងផ្លែជាទីមានម្លប់ត្រឈឹងត្រឈៃ។មហាជនប្រុស ស្រីទោះបីជាសមណៈ ឬព្រាហ្មណ៍តែងតែចូលមូលមកកាន់ទីនេះ និងមណ្ឌលកីឡាសម្រាប់ ប្រជុំលេងកីឡា។ តាមដំណើររឿងបញ្ជាក់ថា ថ្ងៃមួយព្រះបាទវិទេហរាជតម្រូវទៅដល់អ្នកស្រុក បាចិនគ្រាមថា យើងចង់ប្រពាតឧទ្យាន ប៉ុន្តែឧទ្យានចាស់របស់យើងមានឈើចាស់បាក់មែក រេចស្លឹកអស់ហើយ ត្រូវអ្នកស្រុកបាចិនគ្រាមបញ្ជូនឧទ្យានថ្មីមួយមានដើមឈើលាស់ខ្ចីមានផ្ការីកស្គុសស្គាយយកទៅព្រះរាជវាំងយ៉ាងប្រញាប់។

### ៣.សង្គមកិច្ច

### ក-ស្ថានភាពរស់នៅ

តាមរយៈអត្ថបទរឿងមនុស្សនាសម័យកាលនោះ មានមុខរបរមិនដូចគ្នាទេខ្លះជាអ្នកជំនួញ ខ្លះជាកសិករ មន្ត្រី ទាហាន អាចារ្យ អាមាត្យ ស្តេច សេដ្ឋី អនុសេដ្ឋីជាដើម។មុខរបរ និងជីវភាពរបស់ប្រជាជននៅសម័យនោះមានការប្រកបមុខរបរចិញ្ចឹមជីវិតជាច្រើនដូចជា ការធ្វើជំនួញ ធ្វើស្រែចម្ការ ចិញ្ចឹមសត្វ និងលក់ដូរនៅផ្សារ។ម្យ៉ាងវិញទៀត ការរស់របស់ប្រជាជន ក្នុងនគរនីមួយៗនៅពុំមានសន្តិសុខ សុវត្ថិភាពមានដូចជា ចោរលួចគោ លួចរទេះ យក្ខិនីលួច កូន និងចោរលួចប្រពន្ធ សង្វារ និងការឈ្លានពានពីនគរដទៃ។ សម័យមួយព្រះបាទ ចុល្លនី និងអាចារ្យកេវដ្ត ព្រាហ្មណ៍ព្រមទាំងទាហាននាំ គ្នាលើកទ័ពទៅដណ្តើមនគរតូចៗ ជាចំណុះរួចលើកទ័ពមក នគរធំៗទៀត។)

### ខ-សុខាភិបាល

ចំពោះវិស័យសុខាភិបាល យើងឃើញថាពុំទាន់មានភាពរីកចម្រើននៅឡើយទេ ប៉ុន្តែ មានថ្នាំទិព្វ ដែលព្រះឥន្ទយកដាក់ក្នុងបាតព្រះហស្តរបស់មហោសថ ដើម្បីជួយព្យាបាលព្រះបិតា។ ជាមួយគ្នានេះយើងឃើញមានការសាងសង់សាលាសម្ភព គឺមន្ទីរពេទ្យសម្រាលកូន សម្រាប់ស្ត្រីមានផ្ទៃពោះអនាថា ហើយការព្យាបាលសម័យនោះប្រើឱសថបុរាណ។

### គ-មុខរបរ និងជីវភាពរបស់ប្រជាជន

នៅសម័យនោះប្រជាជនប្រកបមុខរបរចិញ្ចឹមជីវិតជាច្រើនដូចជា ការធ្វើជំនួញ ធ្វើស្រែចម្ការ ចញ្ចឹមសត្វ និងលក់ដូរនៅផ្សារ។អ្នកខ្លះទៀតប្រកបរបរទុច្ចរិត ដើរបោកប្រាស់ លួច របស់សម្ភារៈរបស់ព្រះមហាក្សត្រលក់ចេញមកក្រៅ។ល។

### ៤-វប្បធម៌

### ក-ជំនឿ

មនុស្សនាសម័យនោះជឿលើការទស្សន៍ទាយ ដាក់ស្នេហ៍ក្រពើឆ្លាមមករ និងបុណ្យ បាប កម្មពៀរវេរាដែលបានសាងពីអតីតជាតិ បច្ចុប្បន្នជាតិ និងការបួងសួងបែរបន់ដល់វត្ថុ ស័ក្តិសិទ្ធិ អារុក្ខអារក្ស អ្នកតាទេវតាជាដើម។តាមរយៈរឿងមហោសថបានបង្ហាញពីជំនឿ ដោយជឿទៅលើការយល់សុបិន ហើយក៏បានឱ្យបណ្ឌិតអ្នកប្រាជ្ញធ្វើទស្សន៍ទាយពីអនាគត នៃប្រទេសជាតិ។ ព្រះរាជាទ្រង់យល់សុបិននិមិត្តជិតភ្លឺថា : មាននគរភ្លើង៤ភ្នក់ត្រង់ជ្រុងទាំង៤នៃព្រះរាជវាំង ឆេះសន្ធោសន្ធៅឡើង ស្មើនឹងកំពែងធំ ត្រង់កណ្តាលភ្នក់ភ្លើងទាំង ៤នោះមានភ្លើងមួយប៉ុនអំពិលអំពែក ឆេះភ្លែតឡើងភ្លឺជាង ភ្នក់ភ្លើងទាំង ៤ធំៗ ភ្លឺឡើងៗ ទៅខាងលើទាល់នឹងអកនិដ្ឋព្រហ្ម ជុំវិញពេញសកលមក្កវាល...។ ព្រឹកឡើងទ្រង់សួរអ្នក ប្រាជ្ញទាំង៤នាក់។បណ្ឌិតទាំង៤ ធ្វើទំនាយថ្វាយថា សូមទ្រង់ព្រះមេត្តាប្រោស មានអ្នកប្រាជ្ញ ផ្សេងទៀតជាគម្រប់ ៥ កើតឡើងគ្របសង្កត់ខ្ញុំព្រះអង្គទាំងឡាយជាអ្នកប្រាជ្ញទាំង៤នាក់។

**ខ-ទំនៀមទម្លាប់ប្រពៃណី**

ទំនៀមទម្លាប់ប្រពៃណីជាផ្នែកមួយយ៉ាងសំខាន់វាត្រូវបានឆ្លុះបញ្ចាំងពីការអនុវត្តនរបស់ខ្មែររយៈពេលដ៏យូរអង្វែង ហើយក៏រំលេចចេញនូវផ្នត់គំនិតបទដ្ឋានសង្គមនិងការឱ្យតម្លៃរបស់ មនុស្សក្នុងសង្គមដែរ។ ជាក់ស្តែងរឿងមហោសថបានបង្ហាញឱ្យឃើញថារាជបុត្រច្បងត្រូវ ឡើងស្នងរាជពីបិតាហើយត្រូវស្តីដណ្តឹងប្រពន្ធយកមកធ្វើជាភរិយា និងការលើកគ្រឿង បណ្តាការ។ ព្រះមហោសថចូលស្តីដណ្តឹងនាងអមរាពីឪពុកនាងដោយអង្គឯង ហើយទ្រង់នាំ នាងអមរាមកដល់ទីនៅនៃអាត្មា ចាត់ចែងរៀបមង្គលការជាមហោឡារិកក្រោមព្រះបរមរាជ ជួយឧបត្ថម្ភនៃព្រះវិទេហរាជ។

**គ-សាសនា**

តាមរយៈដំណើររឿងបានបង្ហាញថា មនុស្សក្នុងសង្គមនាសម័យនោះគឺគោរពជឿទៅលើព្រះពុទ្ធសាសនា បុណ្យបាបកម្មផល ពៀរវេរា ដែលបុគ្គលនោះបានប្រព្រឹត្ត ពោលគឺ ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់ ហើយត្រូវកាន់ភ្ជាប់នូវសីលប្រាំជានិច្ច។

**ឃ-ការអប់រំ**

ការអប់រំគឺទទួលបានតាមរយៈសាសនាព្រះពុទ្ធនិងព្រាហ្មណ៍បុរោហិតក្នុងរាជវាំងសម្រាប់ខ្សែរាជវង្ស។ ចំណែកឯប្រជារាស្ត្រសាមញ្ញទទួលអប់រំតាមរយៈគ្រួសារ និងសាសនា។ ព្រះមហោសថបានសាងសង់សាលា៥ខ្នង ដើម្បីបំពេញកុសលនានា និងការអប់រំក្បួនកលយុទ្ធដល់កងទ័ពសម្រាប់តតាំងជាមួយសត្រូវដែលមានបំណងឈ្លានពានពីសត្រូវ។

**ង-សិល្បៈ**

ផ្នែកសិល្បៈមានលក្ខណៈរីកចម្រើនទាំង ចម្លាក់ របាំ តន្ត្រី ល្ខោន និងល្បែងកីឡា និងសិល្បៈផ្នែកស្ថាបត្យកម្ម។ ព្រះពោធិសត្វបានឱ្យជាងសាងសាលាប្រាំខ្នង គឺសាលានៅ មណ្ឌល

កីឡា១ខ្នង សាលាសម្ភព១ខ្នង សាលាសម្រាប់សមណៈ និងព្រាហ្មណ៍អាគន្តុក ១ខ្នង សាលាសម្រាប់មនុស្សគន្តុកៈ ១ខ្នង សាលាសម្រាប់ពួកអ្នកជំនួញ១ខ្នង។ ក្នុងសាលានីមួយៗ ព្រះពោធិសត្វឱ្យគូរគំនូរ និងច្បាប់រចនាល្អអស្ចារ្យ ហើយឱ្យជីកស្រះបោក្ខរណីមួយឱ្យជាង រៀបឥដ្ឋជាផ្ទត់មានរំពត់(ញោច)មួយពាន់មានកំពង់មួយឱ្យដាំផ្កាលំចង់រំលេចទៅដោយទទួលចង្កុលឈើ មានពណ៌ប្រាំឱ្យដាំស្ងួនច្បារនៅក្បែរភ្លឺស្រះនោះដ៏ដេរដាស ដោយព្រឹក្សាលតាវល្លិផ្សេងៗ ដែលទ្រទ្រង់នូវផ្កា និងផ្លែជាទីមានម្លប់ត្រឈឹងត្រឈៃ។

## III. សេចក្តីសន្និដ្ឋាន

រឿងមហោសថនេះ តំណាលអំពីការកសាងបញ្ញាបារមីរបស់ព្រះបរមពោធិសត្វ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ។ រឿងនេះបានបង្ហាញយើងឱ្យឃើញនូវឥទ្ធិពល និងប្រយោជន៍នៃការ ប្រើប្រាស់នូវបញ្ញា ដើម្បីដោះបញ្ហាផ្សេងៗតាមរយៈការពិសោធទាំង១៩ ការតទល់ជាមួយ អាចារ្យទាំង៤ និងសត្រូវនៃនគរផ្សេងៗទៀតប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាព។ រឿងមហោសថជាតកជាអក្សរសិល្ប៍ដែលពោរពេញទៅដោយគំនិតលោកិយសច្ចៈ និងបង្កប់នូវបរមត្ថវិជ្ជាសម្រាប់ជាទស្សនៈដល់មនុស្សទូទៅយកទៅដោះស្រាយបញ្ហានានា ដែលជាអាយុជីវិតផ្ទាល់ខ្លួន គ្រួសារ និងសង្គមជាតិ។ មធ្យោបាយដ៏សំខាន់នោះគឺប្រាជ្ញានេះឯង។ ប្រាជ្ញាធ្វើឱ្យឈ្នះ រាល់ការប៉ុនប៉ងដោយកម្លាំងបាយ កម្លាំងអាវុធពីមនុស្សមួយចំនួនដែលជាជនមិច្ឆាទិដ្ឋិ។ ម្យ៉ាងវិញទៀត រឿងនេះបានពន្លេចឱ្យអ្នកអានទូទៅស្គាល់ច្បាស់ពីលក្ខណសម្បត្តិរបស់អ្នកប្រាជ្ញដែលជាមនុស្សមិនចេះភ្លេចគុណអ្នកដទៃមិនលោភលន់ មិនទន់ជ្រាយចំពោះមនុស្សកម្រោលព្រៃផ្សៃ និងចូលចិត្តនិយាយត្រង់ និយាយពិត ឥតលាក់លៀម គឺឃើញល្អថាល្អ ឃើញអាក្រក់ ថាអាក្រក់មិនចេះអែបអបដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។ទស្សនៈសំខាន់មួយទៀតយើងឃើញថា បញ្ញាជាគន្លឹះនៃការបង្កើតទ្រព្យសម្បត្តិ តែទ្រព្យសម្បត្តិវិញមិនអាចបង្កើតបញ្ញាបានឡើយ។

ដូច្នេះ យើងទាំងអស់គ្នាស្វះស្វែងកសាងនូវបញ្ញាទៅតាមគ្រប់រូបភាព ដែលបញ្ញានេះ ជាអាវុធមួយជួយដោះស្រាយបញ្ហារបស់មនុស្សបានគ្រប់ស្ថានភាពនិងកាលៈទេសៈនិងអាចចៀសវាងអំពើហិង្សាទាំងឡាយដែលអាចនាំមកនូវកិត្តិយសដល់ខ្លួនគ្រួសារ និងសង្គមជាតិ ទាំងមូល។

# ឯកសារពិគ្រោះ


- យឹង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ ១៩៩៨
- ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៩៩
- មីសែលត្រាណេ ការសិក្សារឿងរាមកេរ្តិ៍ ១៩៩៥
- លាង ហាប់អាន សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ រាមាយណៈឥណ្ឌា ១៩៦៦
- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ១៩៨៨
- វចនានុក្រមវចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ , ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ ថ្នាក់ទី១២ លេខ០៣ អយក.សណន. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦
- សេង សោភា សិក្សារបៀបធៀបរឿងរាមកេរ្តិ៍ និងរឿងរាមគៀតថៃ សារណាបញ្ចប់ បរិញ្ញាអក្សរសាស្ត្រខ្មែរ ឆ្នាំ២០០៧
- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
- ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លែង ឆ្នាំ១៩៧៣
- សៀវភៅសិក្សាគោលភាសាខ្មែរ សៀវភៅសិស្សថ្នាក់ទី១០ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១០
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរ សៀវភៅសិស្សថ្នាក់ទី១១ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៥
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរសៀវភៅសិស្សថ្នាក់ទី១២បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១២
- ទី ជីហួត រឿងតេជោយ៉ត (១៩៥២-១៩៨៧) និពន្ធឆ្នាំ១៩៨៣
- លី ធាមតេង សៀវភៅការផ្សាយរបស់អ្នកនិពន្ធខ្មែរ ឆ្នាំ១៩៧២។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង មាលាដួងចិត្ត

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:.................................អយក.**

**ប្រកាស**
**ស្តីពី**
**ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ**
**សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍**
**«រឿងមាលាដួងចិត្ត»**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងមាលាដួងចិត្ត » ដែលជាស្នាដៃនិពន្ធនិងរៀបរៀង របស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀន មធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សា ចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀន មធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# បុព្វកថា

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្ដុះបណ្ដាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្ដុះបណ្ដាលនាយក ព្រមទាំងមាន ការផ្លាស់ប្ដូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ បានរៀបចំចងក្រងឯកសារស្ដីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ«**សិក្សាអត្ថបទអក្សរសិល្ប៍**» ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ «**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង មាលាដួងចិត្ត**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ គាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ
ប្រកាស ......i
បុព្វកថា ......ii
គណៈកម្មការ......iii
អារម្ភកថា......iv
មាតិកា......v
សេចក្ដីផ្ដើម......
I. ការបង្ហាញអត្ថបទ......
II. ទិដ្ឋភាពទំនាកទំនងរឿង......
III. ទិដ្ឋភាពទំនាស់......
IV. ទិដ្ឋភាពវិភាគតួអង្គ......
V. ទិដ្ឋភាពសង្គម......
VI. ទិដ្ឋភាពតែងនិពន្ធ......
VII. ទិដ្ឋភាពតម្លៃ......
VIII. ការសន្និដ្ឋាន......
IX. ឯកសារពិគ្រោះ......

# សិក្សាអត្ថបទអក្សរសិល្ប៍

## រឿង មាលាដួងចិត្ត

### សេចក្តីផ្តើម

រឿងមាលាដួងចិត្ត គឺជាប្រលោមលោកបែបមនោសញ្ចេតនា និងប្រវត្តិសាស្ត្រមួយ ដែលបានបង្ហាញពីព្រឹត្តិការណ៍ផ្សេងៗដូចជារបបអាណានិគមនិយមបារាំងនៅក្នុងប្រទេសកម្ពុជា នយោបាយក្នុងប្រទេសនិងក្រៅប្រទេស សង្គ្រាមលោកលើកទី២ សង្គ្រាមរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសសៀម ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងសេចក្តីស្នេហារវាងកំលោះខ្មែរជាមួយនិងក្រមុំសៀមជាដើម។

I. **ទិដ្ឋភាពប្រវត្តិ ឬការបង្ហាញអត្ថបទ**

**ក- អត្ថបទ**

**១.ចំណងជើង**: រឿង មាលាដួងចិត្ត។

**២.ប្រភព**: រឿងនេះបានលើកយករឿងរ៉ាវក្នុងសង្គមខ្មែរដែលកើតឡើងឆ្លងកាត់បាតុភូតសង្គម ទាក់ទងនឹងជីវភាពរស់នៅ ប្រវត្តិសាស្ត្រ សង្គ្រាមលោកលើកទី២ ចន្លោះឆ្នាំ១៩៣៩-១៩៤៥។

**៣.ប្រភេទ** : អក្សរសិល្ប៍ទំនើបបែបប្រលោមលោកមនោសញ្ចេតនា និងប្រវត្តិសាស្ត្រ។

**៤. ចលនា** : អក្សរសិល្ប៍ខេមរនិយម។

**ខ.អ្នកនិពន្ធ**

**១. ឈ្មោះអ្នកនិពន្ធ** : លោក នូ ហាច។

**២. ជីវប្រវត្តិ**

**ជីវប្រវត្តិអ្នកនិពន្ធ នូ ហាច**

លោក នូ ហាច កើតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩១៦ នៅភូមិកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ ឪពុករបស់លោកឈ្មោះ ឃួន និង ម្តាយឈ្មោះ ឌិ រមួច។

**អំពីការសិក្សា** : ពីកុមារភាពលោក នូ ហាច ធ្លាប់បានបួសរៀននៅវត្តក្នុងស្រុកកំណើតរបស់ខ្លួនដោយចេះអានសាស្ត្រាបានយ៉ាងស្ទាត់។ នៅឆ្នាំ១៩៣២ លោកបានប្រឡងជាប់ ចូលរៀននៅអនុវិទ្យាល័យស៊ីសុវត្ថិ ហើយបានបន្តការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ រហូតដល់ឆ្នាំ១៩៣៩បានប្រឡងជាប់មធ្យមសិក្សាបត្រភាគ១។

**អំពីការងារ** : ក្រោយពេលប្រឡងជាប់មធ្យមសិក្សាបត្រភាគ១នៅឆ្នាំ១៩៣៩លោកបានចូលធ្វើការជាចៅក្រម។ នៅឆ្នាំ១៩៤៧លោកបានទៅបម្រើការនៅក្រសួងឃោសនាការដោយកាន់កាប់

ខាងការផ្សាយកាសែតកម្ពុជា។ ឆ្នាំ១៩៤៨ លោក នូ ហាច បានធ្វើជាលេខាធិការផ្ទាល់របស់ទ្រង់យុត្តិវង្ស កាលទ្រង់នៅជានាយករដ្ឋមន្ត្រី។ បន្ទាប់ពីទ្រង់យុត្តិវង្សសុគតទៅ លោកបានត្រឡប់មកធ្វើការនៅក្រសួងឃោសនាការវិញ ដោយធ្វើការនៅក្នុងខុទ្ទកាល័យ។ ឆ្នាំ១៩៥២ លោកចូលបម្រើការនៅក្រសួងការបរទេស ដោយមានមុខងារជាមន្ត្រីទូតខ្មែរ។ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥២ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៥៣ គឺនៅពេលដែលសម្តេចនរោត្តមសីហនុ ធ្វើជានាយករដ្ឋមន្ត្រី បានតែងតាំងលោក នូ ហាច ជារដ្ឋលេខាធិការក្រសួងសាធារណការ និងគមនាគមន៍ ដោយក្រឹតលេខ២៥២ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២។ លោក នូ ហាច បានចូលជាសមាជិកនៃសមាគមអ្នកនិពន្ធខ្មែរ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៥៨។ ការងារចុងក្រោយរបស់លោកគឺ ធ្វើការនៅក្រសួងការបរទេស ដោយបានទទួលដំណែងជា ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសឥណ្ឌូនេស៊ី ប្រហែលនៅឆ្នាំ១៩៦០ដល់ឆ្នាំ១៩៦៩។ ឆ្នាំ១៩៧២ បានត្រឡប់មកភ្នំពេញវិញគឺជាពេលដែលលោកចូល និវត្តន៍។

លោក នូ ហាច បានបាត់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(យើងហៅក្រៅផ្លូវការថារបបខ្មែរក្រហម ឬរបប ប៉ុល ពត ដែលរបបនេះមានរយៈពេល បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ គឺគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩)។

**៣- ស្នាដៃសំខាន់ៗ**

លោកនូ ហាច គឺជាសមាជិកនៃសមាគមអ្នកនិពន្ធខ្មែរ ដែលបានចូលជាសមាជិកនៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៥៨។ លោក នូ ហាច មានស្នាដៃតែងនិពន្ធសំខាន់ៗដូចជា៖

- រឿង ផ្កាស្រពោន និពន្ធនៅឆ្នាំ១៩៤៩
- រឿង នារីជាទីស្នេហា និពន្ធនៅឆ្នាំ១៩៥៣
- រឿង លាវណ្យ និងវរិទ្ធ និពន្ធនៅ(ភាគមួយនៅឆ្នាំ១៩៥៣ និងភាគពីរនៅឆ្នាំ១៩៥៥)
- រឿង មាលាដួងចិត្ត និពន្ធនៅឆ្នាំ១៩៣៩-១៩៤៦
- រឿងត្រួយជីវិត និពន្ធនៅឆ្នាំ១៩៧៣

**គ- កាលកំណត់តែង**

**១- ថ្ងៃ ខែ ឆ្នាំ នៃការតាក់តែងនិពន្ធ៖** រឿង មាលាដួងចិត្តបាននិពន្ធឡើងនៅឆ្នាំ១៩៣៩ និងបញ្ចប់នៅឆ្នាំ១៩៤៦ពុទ្ធសករាជ២៥១៦។

**២- ថ្ងៃ ខែ ឆ្នាំ នៃការបោះពុម្ព៖** រឿងនេះបោះពុម្ពជាលើកដំបូងនៅឆ្នាំ១៩៧២

**ឃ- សង្គមបរិយាកាស**

**១- កាលប្រវត្តិ**

រឿងមាលាដួងចិត្ត ជាប្រលោមលោកដែលឆ្លុះបញ្ចាំងពីសង្គមខ្មែររវាងឆ្នាំ១៩៣៩ដល់ឆ្នាំ១៩៤៦។ ក្នុងអំឡុងពេលនោះ ប្រទេសកម្ពុជាប្រកាន់យករបបរាជានិយម ហើយស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំង(១៨៦៣-១៩៥៣)។រចនាសម្ព័ន្ធគ្រប់គ្រងប្រទេសទាំងមូលស្ថិតនៅក្រោម

ការត្រួតត្រារបស់បារាំងតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។ ក្នុងពេលនេះដែរប្រទេសកម្ពុជាយើងទាមទារឯករាជទឹកដីដែលសៀមឈ្លានពានបានមកវិញមានខេត្តបាត់ដំបង សៀមរាប និងទឹកដីភាគខ្លះក្នុងខេត្តស្ទឹងត្រែង។ ស្ថានភាពទូទៅក្នុងប្រទេសពុំសូវមានភាពល្អប្រសើរទេដោយសារមានមន្ត្រីរាជការមួយចំនួនពុករលួយ កេងប្រវ័ញ្ចទ្រព្យសម្បត្តិជាតិ និងប្រជាជន។ បញ្ហាសន្តិសុខក៏ពុំមានលក្ខណៈល្អប្រសើរដែរ ពោលគឺប្រទេសយើងនៅមានសង្គ្រាមជាមួយប្រទេសសៀមដែលឈ្លានពានទឹកដីភាគខាងលិច។ ស្ថានភាពពិភពលោកក៏កំពុងចលាចលដែរ គឺដោយសារសង្គ្រាមលោកលើកទីពីរកំពុងរីករាលដាល។ដូចសម្ដីអ្នកនិពន្ធបានបញ្ជាក់នៅក្នុងកថាមុខថា៖ ″ប្រលោមលោក "មាលាដួងចិត្ត″ នេះនិទានផ្ដើមគឺនៅពេលសង្គ្រាមលោកលើកទីពីរចាប់ឆ្លលឆេះឡើងហើយមកចប់នៅចុងឆ្នាំ១៩៤៦ គឺនៅពេលខេត្តបាត់ដំបង និងដែនដីយើងទាំងប៉ុន្មានដែលបាត់បង់ទៅនោះ បានវិលត្រឡប់មកចូលរួមក្នុងសហគមន៍ជាតិវិញ″។

**២- ព្រឹត្តិការណ៍សំខាន់ៗ**

ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើងក្នុងពិភពលោក និងក្នុងប្រទេសកម្ពុជាស្របនឹងសង្គមបរិយាកាសនៃរឿង ដែលបានលាតត្រដាងពីឆ្នាំ១៩៣៩ដល់ឆ្នាំ១៩៤៦មាន៖

- សង្គ្រាមលោកលើកទីពីរកំពុងផ្ទុះឡើង និងរីករាលដាលយ៉ាងសន្ធោសន្ធៅនៅទ្វីបអឺរ៉ុប និងនៅអាស៊ីមានប្រទេសជប៉ុន។
- ប្រទេសកម្ពុជាស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំងត្រួតត្រាតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។
- សង្គ្រាមរវាងកងទ័ពបារាំងនៅឥណ្ឌូចិនជាមួយទ័ពសៀមដែលឈ្លានពានទឹកដីកម្ពុជា។
- កងទ័ពជប៉ុនចូលមកលុកលុយប្រទេសកម្ពុជា និងបណ្ដេញកងទ័ពបារាំង។
- ការចុះសន្ធិសញ្ញាសន្តិភាព"តូក្យូ″រវាងបារាំងជាមួយប្រទេសសៀមនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៤១ អំពីបញ្ហាសៀមឈ្លានពានទឹកដីកម្ពុជា។
- ប្រទេសសៀមប្រគល់ទឹកដីខេត្តបាត់ដំបង សៀមរាប និងទឹកដីភាគខ្លះក្នុងខេត្តស្ទឹងត្រែងឱ្យ មកប្រទេសកម្ពុជាវិញ។

## II. **ទិដ្ឋភាពទំនាក់ទំនងរឿង**

**១- សង្ខេបរឿង**

**វគ្គទី១៖ វិទ្យាល័យគ.ស១៩៣៩**

យុវជន ទីឃាវុធ ជាសិស្សរៀននៅថ្នាក់ទី២ទំនើបនៃវិទ្យាល័យព្រះស៊ីសុវត្ថិ។ គេជាមនុស្សចូលចិត្តបណ្ដែតអារម្មណ៍ឱ្យអណ្ដែតអណ្ដូងព្រមទាំងចូលចិត្តស្ដាប់ចម្រៀងសៀមទៀតផង។ ទីឃាវុធជាសិស្សឧស្សាហ៍ មានប្រាជ្ញាឈ្លាសវៃរៀនពូកែមុខវិជ្ជា ភាសាអង់គ្លេស បារាំង និងខ្មែរ ហើយថែម

ទាំងអាចរៀនភាសាថៃដោយខ្លួនឯងបានទៀតផង។ គេចូលចិត្តអានប្រលោមលោក និង កំណាព្យជាភាសាបារាំង និងអង់គ្លេសណាស់។ ពេលវិស្សមកាល ទីឃាវុធ បានទៅលេងឪពុកម្តាយ នៅភូមិអូតាគីខេត្តបាត់ដំបង។ ខណៈពេលធ្វើដំណើរតាមរថភ្លើងបានជួបកញ្ញាជនជាតិសៀមម្នាក់មានរូបសម្រស់ល្អផូរផង់ជាងនារីក្នុងសុបិនទៅទៀត។ នាងនោះឈ្មោះ ចន្ទមណី។ អ្នកទាំងពីរសាសងគ្នាពីនេះពីនោះ ស្រាប់តែរថភ្លើងមកដល់ចំណតតែម្តង។ ទីឃាវុធ នឹកស្តាយមិនចង់ឃ្លាតឡើយ។

## វគ្គទី២៖ យល់សប្តិគង់ក្លាយជាការពិតមួយដងមួយកាលដែរ

ក្រោយពីបានឈប់សម្រាកពិធីបុណ្យចូលឆ្នាំចិនរួចមក ទីឃាវុធ បានរៀបចំសម្ភារៈឥវ៉ាន់នានាដាក់ក្នុងកាបូបសរបស់ខ្លួន ដើម្បីត្រៀមឡើងរថភ្លើងត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ។ គាប់ជួនរាត្រីនោះក៏មានភ្លៀងធ្លាក់មួយមេធំ ដែលជាហេតុនាំឱ្យមានដក់ថ្លុកតាមផ្លូវ។ ព្រឹកឡើងទីឃាវុធបានធ្វើដំណើរចេញពីផ្ទះដើម្បីទៅទិញសំបុត្រជិះរថភ្លើង។ គ្រានោះស្រាប់តែមានឡានមួយបានបើកមក ហើយជះទឹកមកប្រឡាក់លើខ្លួនរបស់គាត់ពេញ។ គាត់មានកំហឹងខឹងខ្លាំងណាស់ពីព្រោះគាត់គិតថា ហេតុតែគេជាអ្នកមានទ្រព្យសម្បត្តិច្រើនទើបគេមានចរិកក្រអឺតក្រទមបែបនេះ។ ពេលទៅដល់កន្លែងទិញសំបុត្រស្រាប់តែ ទីឃាវុធ បានឃើញរថយន្តដដែលនោះចុះចតទិញសំបុត្រ រួមមាននារីជនជាតិសៀមបីនាក់ និងមានអ្នកថៅកុងឡានបានជញ្ជូនកាតាបសទៅដាក់លើរថភ្លើងផង។ ឃើញដូចនោះគាត់ក៏បានស្រវាទិញសំបុត្រឱ្យទាន់គ្នាផងដែរ។ មុនពេលរថភ្លើងចេញដំណើរមនុស្សម្នាក់ៗបានឡើងជិះរថភ្លើង ដែលពេញដោយសម្ភារៈច្រើនស្អេកស្កះរកកន្លែងអង្គុយមិនបាន។ ចំណែក ទីឃាវុធ ឡើងលើរថភ្លើងក្រោយគេក៏ត្រូវឈរបញ្ច្រៀតគ្នាតាមតែអាចធ្វើទៅបាន។ ដោយឃើញសេចក្តីលំបាកនិងនឹកឃើញដល់ពាក្យបណ្តាំរបស់អ្នកបើករថភ្លើងទើប ទីឃាវុធ បានស្នើបន្ទប់លេខ២សម្រាប់ស្ត្រីសៀមបីនាក់នោះចូលអង្គុយ។ ដោយឡែក ទីឃាវុធ ចង់ចេញពីបន្ទប់លេខពីរស្រាប់តែនាងក្រមុំសៀមម្នាក់ឈ្មោះ នាង ចន្ទមណី ហាមមិនឱ្យចេញពីព្រោះចង់ឱ្យនាយកម្លោះនោះជួយណែនាំពីទេសភាពនៅស្រុកខ្មែរ ដោយហេតុនាងជាអ្នកថ្មីថ្មោងមកស្រុកថៃ។ អ្នកទាំងពីរបានបណ្តុះនូវសេចក្តីស្និទ្ធស្នាលនឹងគ្នាទ្វេឡើងបន្តិចម្តងៗលើពាក្យសម្តីនិងកាយវិការ។ ពួកគេបានបរិភោគអាហារជាមួយគ្នានៅលើរថភ្លើងយ៉ាងសប្បាយរីករាយ។ មិនយូរប៉ុន្មានរថភ្លើងក៏បានមកដល់ក្រុងភ្នំពេញ។ ឪពុករបស់នាង ចន្ទមណី បានមកទទួលហើយនាងក្រមុំបានណែនាំទីឃាវុធដល់លោកឪពុករបស់ខ្លួន។ ឪពុករបស់នាងចន្ទមណីបានបបួលទីឃាវុធទៅលេងផ្ទះតែទីឃាវុធបដិសេធចាំពេលក្រោយ។ ក្រោយមកអ្នកទាំងនោះក៏បានបែកគ្នាត្រឹមនោះមក។

## វគ្គទី៣៖ អរុណាស្នេហា

ក្រោយពីបែកគ្នាមក ពេលរាត្រីបានមកដល់ ទីឃាវុធ បានដេកស្រមៃពីសម្រស់ដ៏ស្រស់ស្អាតរបស់នាង ចន្ទមណី ដោយវែកញែកលក្ខណៈរបស់នាងពីនេះពីនោះឥតដាច់រហូតទល់ភ្លឺ។ ថ្ងៃក្រោយមកជួនជាមានថ្ងៃបុណ្យឈប់សម្រាក ទីឃាវុធ បានទៅទស្សនាកុន។ គាប់ជួនបានជួបនឹង

គ្រួសាររបស់នាង ចន្ទមណី នៅទីនោះដែរ។ អ្នកទាំងអស់គ្នាបាននិយាយរាក់ទាក់គ្នាទៅវិញទៅមក ពីនេះពីនោះ និងរឿងដែលទីឃាវុធមិនសូវបានទៅលេងគ្រួសាររបស់នាងក្រមុំសៀមរូបនោះ។ រយៈកាលក្រោយមក ទីឃាវុធ បានទៅលេងផ្ទះគ្រួសាររបស់នាងចន្ទមណីជាញឹកញាប់។ អ្នកកម្លោះបានជូនគ្រួសារនោះឱ្យស្គាល់ទេសភាពក្នុងក្រុងភ្នំពេញនិងតំបន់មួយចំនួនទៀតនៅក្នុងស្រុកខ្មែរ។ អនុស្សាវរីយ៍បានបណ្ដុះចិត្តរបស់អ្នកកម្លោះឱ្យមានចិត្តលើនាងក្រមុំសៀមពីមួយថ្ងៃទៅមួយថ្ងៃ។ ចំណែកនាងក្រមុំរូបនោះក៏មានចិត្តមកលើទីឃាវុធខ្លះៗផងដែរ។ គាប់ជួនថ្ងៃមួយឪពុករបស់នាងចន្ទមណី បានទៅព្រៃនគរ ហើយទុកឱ្យកូនក្រមុំនៅផ្ទះតែម្នាក់ឯងជាមួយនឹងអ្នកបម្រើពីរនាក់ផ្សេង ទៀត។ នាងក្រមុំបានដើរចេញពីបន្ទប់ មកចាំនៅកន្លែងទទួលភ្ញៀវដូចសព្វមួយដង។ នាងបានយកសៀវភៅដែលបានខ្ចីពីទីឃាវុធយកមកអានដោយជក់ចិត្ត ស្លុងអារម្មណ៍ និងបានឃើញកំណាព្យមួយសន្លឹកនៅក្នុងសៀវភៅនោះផងដែរ។ និយាយពីទីឃាវុធថ្ងៃនោះដោយសារមិនមានស៊ីក្លូជិះទើបមកដល់ផ្ទះនាងដោយសេចក្ដីយឺតយ៉ាវ។ មកដល់ពេលណាអ្នកទាំងពីរបានបបួលគ្នាទៅមើលកុន។ ខណៈពេលនោះនាងចន្ទមណីបានយកក្រដាសកំណាព្យដែល ទីឃាវុធ តែងមកឱ្យសូត្រប្រែជាភាសាអង់គ្លេស និងភាសាសៀម។ ដោយសេចក្ដីកំណាព្យនោះគឺជាទឹកចិត្តស្នេហាដែល ទីឃាវុធ មានចំពោះនាងក្រមុំសៀមរូបនេះទី ឃាវុធ ក៏បានសម្រេចចិត្តសារភាពស្នេហ៍ចំពោះនាងតែម្ដង។ សេចក្ដីស្នេហានោះ នាងក្រមុំមិនបានបដិសេធឡើយ ដែលជាហេតុធ្វើឱ្យ ទីឃាវុធ មានទឹកចិត្តត្រេកអរជាពន់ពេករកអ្វីមកប្រៀបពុំបាន។ អ្នកទាំងពីរបានសន្យាគ្នាថា ត្រូវខិតខំរៀនសូត្រដើម្បីកសាងសុភមង្គលរបស់ពួកគេទៅថ្ងៃក្រោយ។ ទីឃាវុធ សន្យានឹងរៀនឱ្យបានចប់ថ្នាក់បរិញ្ញាបត្រលើជំនាញ មួយជាក់លាក់ ឯនាងចន្ទមណីក៏បានសន្យាថានឹងរៀនភាសាខ្មែរឱ្យបានស្ទាត់ជំនាញ។

**វគ្គទី៤៖ ភ្នំគូលែនឋានបរមសុខ**

ថ្ងៃអាទិត្យមួយ ទីឃាវុធ បានសម្រេចចិត្តទៅលេងគ្រួសាររបស់នាង ចន្ទមណី ដើម្បីលាទៅលេងស្រុកកំណើតក្នុងឱកាសវិស្សមកាលនាពេលខាងមុខ។ ដោយសេចក្ដីស្រឡាញ់ និងចង់ជួប ទី ឃាវុធ បានយូរនាង ចន្ទមណី ក៏បានប្រាប់ ទីឃាវុធ ឱ្យទៅលេងសៀមរាបអង្គរជាមួយនឹងគ្រួសាររបស់នាង។ ឪពុករបស់នាងក៏បានឯកភាពផងដែរ។

ទាំងអស់គ្នាបានឯកភាពគ្នា ហើយក្រោកពីព្រលឹមស្រាងៗ ដើម្បីធ្វើដំណើរទៅកាន់សៀមរាប។ ក្នុងដំណើរនេះមានរថយន្តពីរគ្រឿង ដែលរថយន្តខាងមុខមានទាំងកម្លោះអ្នកស្នាក់នៅអន្តេវាសិកដូច ទីឃាវុធ ដែរ ចំណែកឡានខាងក្រោយគឺឡានរបស់លោកទេពកោសល្យ។ ទៅដល់សៀមរាប ទីឃាវុធ បានសម្រេចចិត្តទៅស្នាក់នៅផ្ទះរបស់ វង្សវិទ្ធិ ព្រោះមានរថយន្តស្រាប់ ដែលជាការងាយស្រួលក្នុងការជូនមិត្តភក្ដិដើរកម្សាន្ត។ ប៉ុន្តែ ចន្ទមណី និងលោក ទេពកោសល្យ មិនបានស្នាក់នៅជាមួយ ទីឃាវុធ ឡើយ ព្រោះបានកក់បន្ទប់រួចជាស្រេចទៅហើយ។

ថ្ងៃមួយ វេតី បានមកលេងនឹង ទីឃាវុធ ហើយបានប្រមូលផ្លែគូលែនដែលផ្អែមៗមកឱ្យញ៉ាំ។

ដោយឃើញផ្លែគូលែននេះហើយទើបបណ្តាលចិត្តអ្នកទេសចរណ៍ទាំងអស់ចង់ទៅកម្សាន្តនៅភ្នំគូលែន។ ដោយឯកភាពគ្នា ទាំងអស់គ្នាបាននាំគ្នាធ្វើដំណើរទៅកាន់ភ្នំគូលែនប្រាកដមែន។ ទោះបីជាផ្លូវធ្វើដំណើរទៅ និងឡើងភ្នំមានការលំបាកយ៉ាងណាក៏ដោយ ក៏ពួកគេបានភ្លេចអស់រលីងដោយសារលង់នឹងសម្រស់ទេសភាពលៅលើភ្នំ និងព្រឹក្សានៅតាមដងផ្លូវ។ វេលាមួយនោះ ទីឃាវុធ និងនាងចន្ទមណី បានចូលទៅក្នុងរោងមួយដែលពេញដោយគ្រឿងសក្ការបូជា ហើយអ្នកទាំងពីរបានបួងសួងឱ្យស្នេហាអ្នកទាំងពីរបានប្រកបតែសេចក្តីសុខ និងសុភមង្គលតរៀងទៅ អ្នកផ្សេងទៀតបានរីករាយជាមួយនឹងទេសភាពព្រៃព្រឹក្សា ទឹកជ្រោះ ដុំថ្មតូចនានាយ៉ាងស្រស់ស្រាយ។

ក្រោយពីដំណើរកម្សាន្តបានបញ្ចប់ ទីឃាវុធ បានខំព្យាយាមរៀនសូត្រណាស់ដោយរំឭកមេរៀនចាស់ ថ្មីឡើងវិញក្នុងគោលបំណងដើម្បីឱ្យប្រឡងជាប់ជាស្ថាពរតាមគោលបំណងរបស់ខ្លួន។ សម្រាប់ទំនាក់ទំនងរវាងទីឃាវុធ និងនាងចន្ទមណី ក៏មិនបានជួបគ្នាផ្ទាល់ជាញឹកញាប់ឡើង គឺតាមរយៈសំបុត្រជាភាសាអង់គ្លេស។ ក្រោយពេលចូលកង ទីឃាវុធក៏បានប្រឡងជាប់ជាប្រាកដ។ គាត់បានសម្រេចចិត្តទៅលេងគ្រួសារនាងចន្ទមណី ដើម្បីប្រាប់ដំណឹងល្អអំពីការប្រឡងជាប់របស់ខ្លួន។ ទៅដល់ផ្ទះនាងស្រាប់តែស្ថានភាពរីករាយរបស់ទីឃាវុធបានផ្លាស់ប្តូរ ព្រោះប្រពន្ធរបស់លោកទេពកោសល្យឈឺនៅឯប្រទេសថៃ។ ម្លោះហើយគ្រួសាររបស់លោករួមនឹងកូនស្រីត្រូវវិលត្រឡប់ទៅប្រទេសថៃដើម្បីមើលប្រពន្ធដែលឈឺ។

## វគ្គទី៥៖ ពពកខ្មៅបាំងមេឃា

ក្រោយពីបានប្រឡងជាប់បានចំណាត់ថ្នាក់ល្អមក ភាពរីករាយមិនបានកើតឡើងចំពោះទីឃាវុធ ឡើយ ព្រោះម្ចាស់ស្នេហ៍របស់ខ្លួនបានឃ្លាតទៅឆ្ងាយ ហើយក៏មិនសូវមានដំណឹងឆ្លើយតបគ្នាទៅវិញទៅមកទៀត។ មិនយូរប៉ុន្មាននាងក្រមុំសៀមបានផ្ញើសំបុត្រមួយច្បាប់មក ទីឃាវុធ ដោយបានប្រាប់ថានាងមានសេចក្តីនឹករឭកចំពោះ ទីឃាវុធ យ៉ាងខ្លាំង និងប្រាប់ដំណឹងរបស់ម្តាយដែលបានធូរស្រាល ប៉ុន្តែមិនប្រាកដបានជាសះស្បើយពេលណាឡើយ។

រយៈពេលចេះតែកន្លងផុតទៅពីមួយថ្ងៃទៅមួយថ្ងៃ។ ស្ថានភាពពិភពលោកកាន់តែមានស្ថានភាពតានតឹងឡើងៗ។ ប្រទេសអាឡឺម៉ង់បានធ្វើសង្គ្រាមជាមួយប្រទេសប៉ូឡូញ។ ស្ថានភាពនោះដំបូងមិនបានធ្វើឱ្យ ទីឃាវុធ មានចំណាប់អារម្មណ៍ឡើយ ប៉ុន្តែក្រោយមកដោយមានប្រជាជនច្រើនពឹងឱ្យបកប្រែពត៌មានពីព្រៃនគរ និងបាងកកបានធ្វើឱ្យ ទីឃាវុធ ជក់ចិត្តនឹងស្ថានការណ៍ពិភពលោកយ៉ាងជាក់ច្បាស់។ ពេលនោះសង្គ្រាមលោកលើកទីពីរបានផ្ទុះឡើង។

ទីឃាវុធ បានធ្វើដំណើរចូលមកទីក្រុងភ្នំពេញ។ អ្នកកម្លោះបានជាប់កំណែន ហើយមានឋានៈបានស្ពាយកាំភ្លើង។ នៅក្នុងទីក្រុងពេលយប់ គឺគ្មានពន្លឺអ្វីបន្តិចឡើយ ងងឹតឈ្លប់រកមើលអ្វីមិនឃើញ។ ចំណែកថ្នាក់រៀនខាងទស្សនវិជ្ជាក៏ត្រូវបិទពីព្រោះគ្មានគ្រូ។ ដោយឡែក ទីឃាវុធ និងមិត្តទាំងអស់បានបើកឡើងវិញដោយត្រដាបត្រដួស ព្រោះខ្លួនក៏មិនសូវមានពេលដែរ។ ក្រោយមកថ្នាក់

ទស្សនវិជ្ជានេះបានបទជាស្ពាន។ សិស្សទាំងអស់រួមទាំង ទីឃារុធ ផងបានត្រូវបញ្ជូនទៅសិក្សានៅព្រៃនគរ។ នៅទីនោះអ្នកដឹកនាំសាលាលែងអនុញ្ញាតឱ្យសិស្សស្នាក់នៅទៀតហើយ គឺតម្រូវឱ្យជួលផ្ទះនៅខាងក្រៅសាលាជំនួសវិញ។ ដោយសេចក្តីខឹងក្រេវក្រោធពេក ទីឃារុធ បានតមាត់នឹងប្រធានសាលា ហើយក៏បានធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញវិញ។ ការសិក្សារបស់ទី ឃារុធ ត្រូវបានបញ្ចប់។ ចំណែកសេចក្តីស្នេហារបស់ខ្លួនក៏កាន់តែស្ងាត់ទៅៗ ស្របនឹងស្ថានភាពប្រទេសខ្មែរកាន់តែតានតឹងឡើងៗក្រោមអំណាចរបស់បារាំង។ បន្ទាប់មក លោកក៏ត្រូវបានចាត់ឱ្យមានឋានៈជាបាល័ដ្ឋខេត្តពោធិ៍សាត់តាំងពីពេលនោះមក។

## វគ្គទី៦៖ សេចក្តីលំបាកនៃអ្នករាជការតូច

ពូហ៊ីង មីងក្អាត់ ជាប្តីប្រពន្ធនឹងគ្នារស់នៅខេត្តពោធិ៍សាត់ ពួកគាត់មានកូនស្រីបីនាក់សុទ្ធតែចែកសម្បុកអស់ហើយ។ ទាំងពីរនាក់ប្តីប្រពន្ធជាមនុស្សឧស្សាហ៍ចូលចិត្តដាំបន្លែ ហើយក៏រៀបចំបន្ទប់មួយសម្រាប់ជួល។ ទីនេះជាទីដែល ទីឃារុធ ស្នាក់នៅពេលមកដល់ពោធិ៍សាត់។ ពេលមកដល់កន្លែងថ្មីនេះគេមានការលំបាកច្រើនព្រោះខ្វះខាតប្រាក់កាស។

ទី ឃារុធ ទាស់ចិត្តនឹងលោកចៅហ្វាយខេត្តណាស់ ព្រោះមន្ត្រីរូបនេះជាមនុស្សអែបអប ពុករលួយ កេងប្រវ័ញ្ច ចូលចិត្តស្រីស្រា ដែលធ្វើឱ្យ ទីឃារុធ និងមិត្តរួមការងារម្នាក់ទៀតឈ្មោះប្រាំមាឡ មិនអាចចូលចុះជាមួយគេបាន។ ថ្ងៃមួយមានឈ្មួញចិនម្នាក់ឈ្មោះ ហុងឈី បានយកប្រាក់៥០០រៀល មកសូក ទីឃារុធ តែត្រូវគេបដិសេធមិនទទួល។

## វគ្គទី៧៖ ស្ថានការណ៍កាន់តែអ័ព្ទអួរឡើង

តាំងពី ទីឃារុធប្រគល់លុយ៥០០រៀលឱ្យទៅថៅកែហុងឈីវិញ គេត្រូវលោកចៅហ្វាយខេត្តខឹងសម្បាយ៉ាងខ្លាំង ហើយដាក់ទណ្ឌកម្មឱ្យដើរត្រួតពន្ធនៅស្រុកបាកាប និងក្រគរ។

ស្ថានភាពពិភពលោកកាន់តែធ្លាក់ដុនដាប អាឡឺម៉ង់វាយប្រទេសហូឡង់ ប៊ែលហ្សិក និងបារាំងដោយងាយ។

ថ្ងៃទី២៤ មិថុនា ១៩៣៩ នាយករដ្ឋមន្ត្រីសៀមបានប្រកាសប្តូរឈ្មោះប្រទេសមកជា ថៃឡង់ក្នុងគោលបំណងលេបយកប្រទេស ឡាវ ភូមិភាគខ្លះនៃដែនដីតុងកឹង និងប្រទេសកម្ពុជាផងដែរ។ នៅថ្ងៃទី១២ មិថុនា ១៩៤០ រដ្ឋសភាសៀមបានធ្វើសច្ចាប័នកតិការសញ្ញាមិនឈ្លានពានរវាងបារាំង-ថៃ។ ចំណុចនេះបានផ្តល់ប្រយោជន៍ឱ្យសៀមបង្ខិតព្រំដែនចូលដីឡាវ។ ហើយនៅខែសីហាសៀមរំលោភមកបាចខិតប័ណ្ណ លើប្រទេសកម្ពុជាដើម្បីទាមទារយកខេត្តបាត់ដំបង និងសៀមរាប។

វែគី បានផ្ញើសំបុត្រឱ្យ ទី ឃារុធ មួយច្បាប់ដែលអត្ថន័យក្នុងនោះ ថាលោកទេពកោសល្យ និងចន្ទមណីជាអ្នកស៊ើបការណ៍ដែលរដ្ឋាភិបាលសៀមបញ្ជូនមក។ ដោយក្តីក្តៅក្រហាយនឹងរឿងនេះ ណាមួយត្រូវលោកចៅហ្វាយខេត្តដាក់ទណ្ឌកម្មផង ទីឃារុធ ក៏សម្រេចចិត្តចូលធ្វើទាហាន។

ថ្ងៃ២៧ វិច្ឆិកា កងទ័ពអាកាសសៀមបានទម្លាក់គ្រាប់បែកនៅទីក្រុងនានាក្នុងដែនឥណ្ឌូចិន។

ឆ្នាំ១៩៤១ សៀមចូលឈ្លានពានកម្ពុជាពេញទំហឹង ហើយទម្លាក់គ្រាប់បែកនៅសិរីសោភណ្ឌ មង្គលបុរី បាត់ដំបង និងស្ទឹងត្រែង។ ទីឃាវុធ ត្រូវទទួលបញ្ជាឱ្យនាំក្រុមរបស់ខ្លួនទៅពួនស្ទាក់សត្រូវនៅច្រកកូនអរមួយ ហើយត្រូវរងរបួសធ្ងន់ធ្ងរសន្លប់បាត់ស្មារតី។

## វគ្គទី៨៖ ស្រឡាញ់ជាតិបង្ក្រាបស្នេហា

ក្រុងអរញ្ញប្រះថេត គឺជាតំបន់មួយនៅជាប់នឹងព្រំប្រទល់ប្រទេសទាំងពីរ។ អង្គការនានាបានរើមកកាន់តំបន់នេះ ព្រោះដោយសារចំបាំងរវាងសៀមនឹងបារាំងកាន់តែខ្លាំងឡើងៗ។ ទីនោះក៏មានមន្ទីរវះកាត់មួយផងដែរ ដែលមានគ្រូពេទ្យជំនាញខាងដុកទ័រ និងគិលានុបដ្ឋាកជាច្រើន។ ក្នុងចំណោមគិលានុបដ្ឋាកទាំងនោះក៏មាន នាងចន្ទមណី ផងដែរ។ នាងបានគិតទៅដល់សេចក្ដីស្នេហារបស់នាងឥតដាច់សោះឡើយ។ ពេលនាងចូលបំរើការងារសង្គ្រោះនេះសង្គ្រាមក៏កាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយអ្នករងរបួសក៏កាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដែរ។

ថ្ងៃមួយពេលរថយន្តដឹកអ្នករបួសមកដល់ នាងសង្កេតឃើញបុរសម្នាក់ ប្រាកដណាស់ថាជាទីឃាវុធ។ នាងបានខំយកចិត្តទុកដាក់ និងបានបរិច្ចាគឈាមរបស់នាងជូនអ្នកជំងឺនេះយ៉ាងពេញទំហឹង។ ក្រោយមក ដោយរបួសរបស់អ្នកជំងឺមានសភាពគ្រោះថ្នាក់ទើបនាងយករថយន្តផ្ទាល់ខ្លួនបញ្ជូនទៅដល់មន្ទីរពេទ្យធំនាទីក្រុងបាងកក។ លោកទេពកោសល្យ និងនាងចន្ទមណីបានយកចិត្តទុកដាក់អ្នកកម្លោះនេះណាស់ ទាំងថ្នាំសង្កូវផងដែរ។ ប៉ុន្តែចំណែកខាងទីឃាវុធ ដោយសេចក្ដីភាន់ច្រឡំនឹងគូស្នេហ៍របស់ខ្លួនថាជាចារនារីនោះ ទើបធ្វើឱ្យខ្លួនសម្ដែងកិរិយាមារយាទមិនគប្បីទៅលើនាងចន្ទមណីទាំងកំរោល។

## វគ្គទី៩៖ សន្តិភាពតូក្យូ

សន្តិភាពតូក្យូគឺការចុះសន្ធិសញ្ញារវាងបារាំង និងសៀមដោយមានអាជ្ញាកណ្ដាលមួយគឺយីពុន។ ដំបូងសន្តិភាពហាក់ដូចជាមានភាពរកិបរកុប ចំណាយពេលកាន់តែច្រើន ជាហេតុនាំឱ្យយីពុនជាអាជ្ញាកណ្ដាល បានបង្ខំបារាំងឱ្យយល់ព្រមលើសន្ធិសញ្ញានៅលើកោះ យីពុនឈ្មោះ "ណាតុរិ"។ ខេត្តខ្មែរមួយចំនួនដូចជា សៀមរាប បាត់ដំបង ស្ទឹងត្រែង ត្រូវបានកាត់ចូលទៅក្នុងដីថៃដោយប្ដូរឈ្មោះទៅជាឈ្មោះរបស់វាទាំងអស់(ឈ្មោះជាភាសាថៃ)។ ចំណែកទីឃាវុធក្រោយបានជាសះស្បើយកាលណា បានត្រឡប់មកកាន់ស្រុកកំណើតរបស់ខ្លួនវិញ ហើយទទួលដំណែងជាចៅហ្វាយស្រុក។ ដោយព្រំប្រទល់ថ្មីនៃស្រុកដែលទីឃាវុធគ្រប់គ្រង និងសៀមនៅជិតគ្នា ជាហេតុនាំឱ្យមានលេចឮអំពើរត់ពន្ធឆ្លងដែនខុសច្បាប់នានា។ ប៉ុន្តែដោយមានការឃោគយល់គ្នាទៅវិញទៅមក ទើបខ្មែរអាចចូលទៅកាន់ប្រទេសសៀមបានម្ដៃប្រាំគីឡូម៉ែត្រដើម្បីស្វែងរកបងប្អូន។ មិនតែប៉ុណ្ណោះ មនុស្សគ្រប់គ្នាបានឆ្លងទៅមកលេងបងប្អូននានាដែលធ្វើស្រែក្នុងទឹកតំបន់នោះ។ ខ្លះទៀតបានទៅលេងនៅសៀមរាបអង្គរដែនប្រាសាទអស្ចារ្យរបស់ខ្មែរ។ និយាយពីអ្នកគ្រប់គ្រងថៃ ទីឃាវុធធ្វើទំនាក់ទំនងល្អឱ្យផុតតែពីមុខទេ ត្បិតសសរស្ដម្ភសៀមចេះតែទាក់ទង និងមានជំនួនមកជា

ហូរហែរ។ ទីឃារុធក៏បានបញ្ជូនជាជំនូនខ្លះទៅវិញផងដែរ ព្រោះដើម្បីកុំឱ្យជំពាក់គុណច្រើនពេក។ លើសពីនេះទៀត ទីឃារុធបានទៅលេងដល់ខេត្តខ្មែរចាស់ដើម្បីលើកទឹកចិត្តខ្មែរទាំងនោះថា យើងមិនបោះបង់អ្នកទេ។

ក្រោយបានសម្រេចចិត្តទៅលេងប្រជាជនខ្មែរខាងសៀម ទីឃារុធបានចេញដំណើរទៅជាមួយនឹងយានជំនិះរបស់ខ្លួន។ ទៅដល់ព្រំដែន សៀមបានមកទទួលរាក់ទាក់ដោយសមគួរ ហើយបានជូនលោកដើរមើលគ្រប់ទីកន្លែងក្នុងទឹកដីនោះ។ ការដើរមើលបានបញ្ចប់មន្ត្រីសៀមម្នាក់បានអញ្ជើញទីឃារុធទៅបរិភោគបាយនៅផ្ទះរបស់គាត់។ ប្រពន្ធរបស់អាំភើបានទទួលស្វាគមន៍ទីឃារុធដោយសមគួរជាទីបំផុត។ ទីឃារុធឃើញរូបរាង និងកាយវិការរបស់ប្រពន្ធអាំភើបានកើតចិត្តនឹកដល់ម្ចាស់បេះដូងរបស់ខ្លួនគឺនាងចន្ទមណី ប៉ុន្តែក្រោយមកក៏ប្រែជាខឹងទៅវិញ។ បន្ទាប់មកក៏តាំងពិចារណាពីការយកចិត្តទុកដាក់ជួយសង្គ្រោះរបស់មិត្តភក្តិសៀមទាំងពីរនាក់ ដោយសេចក្តីងឿងឆ្ងល់ក្រៃ។

ចំណែកនៅក្រុងបាងកក នាងចន្ទមណីមានសេចក្តីអាក់អន់ចិត្តអង្គុយគិតតែម្នាក់ឯង ចំពោះសកម្មភាពសោះកក្រោះរបស់ទីឃារុធមកលើរូបនាង តែនាងមិនបានយកជារឿងធំទេ ព្រោះជារឿងធម្មតា ដែលយុវជនមានគំនិតស្នេហាជាតិយ៉ាងនេះ។ ក្រោយមកទើបប៉ារបស់នាងបានបបួលនាងទៅលេងនៅខាងសៀមរាបដែនដីថ្មីរបស់សៀម ដែលមានការអញ្ជើញពីអាំភើ។

និយាយពីទីឃារុធវិញ ពេលត្រឡប់ដល់ស្រុកខ្មែរវិញ បានទទួលណាត់ជួបមួយនៅទីក្រុងភ្នំពេញគឺជួបជាមួយនឹងវេគី។ អ្នកទាំងពីរបាននិយាយឆ្លងឆ្លើយគ្នា។ ទីឃារុធប្រាប់ពីសេចក្តីដែលគ្រួសាររបស់នាងចន្ទមណីធ្វើល្អចំពោះខ្លួន ពេលខ្លួនត្រូវរបួសនៅក្នុងសង្គ្រាម។ ចំណែកវេគីបានបកស្រាយការយល់ច្រឡំរបស់ខ្លួនប្រាប់ទៅដល់ទីឃារុធ។ ក្រោយមកទីឃារុធតាំងកើតសេចក្តីសោកស្តាយនឹងអៀនខ្មាសនឹងសេចក្តីល្អដែលគេមានចំពោះខ្លួន តែបែរជាប្រើអាកប្បកិរិយាមិនគប្បីទៅលើគេ ដែលស្តែងថាខ្លួនជាមនុស្សពាលយ៉ាងនេះសោះ។

## វគ្គទី១០៖ ជួបភ័ក្រ្តហើយតែមានឧបសគ្គធំរារាំង

ក្នុងរយៈកាលដែលសង្គ្រាមលោកស្ទើរតែបញ្ចប់ទៅនោះ ពួកយីពុនបានធ្លាក់ខ្លួនចូលក្នុងរណ្តៅអន្តរាយ។ ក្រោយមកទើបបានប្រកាសថា ប្រទេសកម្ពុជាមានឯករាជ្យ។ ប្រទេសកម្ពុជានិងប្រទេសសៀមហាក់មានកម្លាំងស្មើៗគ្នា។

និយាយពីលោកចៅហ្វាយស្រុកវិញ គឺមានភ្ញៀវជនជាតិសៀមបួននាក់បានមកលេង និងហួសទៅលេងសៀមរាបអង្គរ។ លោកបានរៀបចំមនុស្សឱ្យរៀបបាយទឹកនៅមុខបារាយណ៍ឱ្យភ្ញៀវបរិភោគដើម្បីជាកិច្ចតបស្នងចំពោះអាំភើ។ ដំបូងទីឃារុធបានប្រកាសខ្លួនធ្វើជាអ្នកនាំផ្លូវ ព្រោះមិនបានដឹងថាអ្នកដែលមកជាមួយនឹងអាំភើនិងនាងចុល្លានន្ទគឺជាលោកទេពកោសល្យនិងនាងចន្ទណីសោះ។ ដំណើរកម្សាន្តបានដើរទៅដោយសេចក្តីអៀនខ្មាសគ្នាទៅវិញទៅមក ដែលញុំាងភាគីទីឃា

វុធ និងនាងចន្ទមណីហាក់មិនដែលស្គាល់គ្នាសោះ។ ដំណើរកម្សាន្តមិនបានចូលលេងប្រាសាទអង្គរវត្តទេ តែក៏ហួសទៅកាន់បារាយណ៍តែម្តង។ នៅទីនោះក្រោយបាយទឹករួចមក អ្នកគ្រប់គ្នាតាំងមានចិត្តស្ងប់ ហើយក៏សម្រាកលក់អស់ទៅ។ ដោយឡែកទីឃាវុធដេកមិនលក់ ក៏ចុះទៅងូតទឹកក្នុងបារាយ។ ចំណែកនាងចន្ទមណីក៏បានចុះទៅងូតទឹកផងដែរ។ នៅទីនោះអ្នកទាំងពីរបានបង្ហាញពីអារម្មណ៍របស់ខ្លួនដែលធ្វើខុសចំពោះគ្នា។ ជាពិសេសនោះគឺទីឃាវុធដែលសុំទោសចំពោះការយល់ច្រឡំនឹងសេចក្តីល្អរបស់គ្រួសារនាងចន្ទមណី។ ដោយភាពចុកអួលនិយាយមិនចេញបានត្រឹមទឹកភ្នែកបានស្រក់ចេញពីភ្នែកនាងចន្ទមណី។

## វគ្គទី១១៖ កង្ហាត្រដោកពោធិ៍លើចុងអំពិល

ក្រោយបែកគ្នាមក ស្ថានភាពពិភពលោកបានប្រែប្រួលឡើង។ខេត្តខ្មែរដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់សៀមបានចូលមកក្នុងដែនដីនៃការគ្រប់គ្រងរបស់ខ្មែរដូចដើមវិញ។ និយាយពីទីឃាវុធក្រោយមកក៏បានផ្លាស់ប្តូរពីខេត្តសៀមរាបមកកាន់តំណែងជាភូឈួយនៅខេត្តបាត់ដំបង។ ថ្ងៃមួយលោកទេពកោសល្យបានមកចូលជួបជាមួយនឹងទីឃាវុធដើម្បីដោះស្រាយរឿងបញ្ហាដីធ្លីដែលគាត់បានទិញកន្លងមក។ អ្នកទាំងពីរក៏បានសួរសុខទុក្ខគ្នា។ លោកទេពកោសល្យបានប្រាប់ដោយសេចក្តីគោរពថា គ្រួសាររបស់ខ្លួនបានមករស់នៅក្នុងប្រទេសកម្ពុជាជាស្ថាពរហើយ។ ដំណឹងនេះបានធ្វើឱ្យទីឃាវុធមានសេចក្តីត្រេកអរយ៉ាងខ្លាំង ព្រោះបានជួបនឹងម្ចាស់ស្នេហ៍ដូចបំណង។ ក្រោយមកទៀត ភូឈួយទីឃាវុធបានទៅលេងផ្ទះរបស់លោកទេពកោសល្យ តែបានជួបតែនាងចន្ទមណីម្នាក់គត់។ លោកនិងនាងចន្ទមណីបាននិយាយសាសងគ្នាទៅវិញទៅមករហូតបានយល់ចិត្តថ្លើមគ្នាសាជាថ្មី។ អ្នកទាំងពីរក៏បានស្រឡាញ់គ្នា និងផ្តើមស្នេហ៍ជាថ្មីឡើងវិញតាំងពីពេលនោះមក។

**២- តួអង្គ**

**ទីឃាវុធ** : ជាកូនកសិកររស់នៅភូមិអូរតាគីខេត្តបាត់ដំបង សិស្សវិទ្យាល័យស៊ីសុវត្ថិ

**ចន្ទមណី** : ជាក្រមុំជនជាតិថៃ កូនស្រីរបស់លោកទេពកោសល្ល និងជានារីដែលទីឃាវុធស្រឡាញ់យកធ្វើជាគូអនាគត។

**លោក ទេពកោសល្ល** : ជាឪពុករបស់នាងចន្ទមណី នាយទាហានស័ក្តិបីរបស់ថៃ។

**លោកចៅហ្វាយខេត្តពោធិ៍សាត់**

**ហុងឈី** : ជាឈ្មួញរកស៊ីទុច្ចរិត និងជាអ្នកមៅការដេរខោអាវប៉ូលិស។

**ប្រាមោទ្យ** : ជាសភាចារបុរសនៅខេត្តពោធិ៍សាត់ និងជាអ្នករាប់អានជាមួយទីឃវុធ។

**វេតី** : ជាអ្នកស៊ើបការណ៍សម្ងាត់ និងជាមិត្តភក្តិរបស់ទីឃាវុធ។

**សុខរិទ្ធ** : ជាប្តីរបស់នាងប្រភា។

**នាងប្រភា** : ជាប្រពន្ធលោកសុខរិន្ទ និងជាម្ដាយរបស់នាងឆដាវណ្ណ។

**វង្សរិទ្ធិ** : ជាកូនលោក សុខ រិន្ទ និងជាមិត្តភក្តិរបស់ទីឃាវុធ។

**សុវឌ្ឍន៍ ឬនាយអាភើ** : ជាមន្ត្រីសៀមមើលការខុសត្រូវនៅសរសរស្ដម។

**នាងចុល្លនន្ទ** : ជាប្រពន្ធរបស់សុវឌ្ឍន៍ ឬនាយអាំភើ។

**ពូហ៊ីង មីងក្អាត់** : ម្ចាស់ផ្ទះដែលទីឃាវុធជួលនៅ។

**ស៊ីមជិត ឬសមចិត្ត** : ជាគិលានុបដ្ឋាយិកា និងជាមិត្តរួមការងារជាមួយចន្ទមណីនៅមន្ទីរពេទ្យអារញ្ញប្រទេសថៃ។

**លោកជូឡុង** : ជាទេសរដ្ឋមន្ត្រីតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និងជាមេបញ្ជាការ កងទ័ពកម្ពុជា។

**ជីហ្សុងគ្បែរ** : ជាអ្នកដឹកនាំកងទ័ពបារាំង និងតំណាងភាគីប្រទេសបារាំង។

**នាយភារិន្ទ** : ជាមេចង្វាត់។

**៣- កាលអាកាស**

**៣.១- កាល(ពេលវេលា)**

ឆ្នាំ១៩៣៩-១៩៤៥ ដើមខែកុម្ភៈឆ្នាំ១៩៤០ ក្នុងខែឧសភា ថ្ងៃទី១២ខែមិថុនាគ.ស១៩៤០ ដើមខែកញ្ញា ចុងខែកញ្ញា ក្នុងខែវិច្ឆិកា ថ្ងៃទី១៦មករា ថ្ងៃទី២០មករា១៩៤១ ថ្ងៃទី២៨មករា ថ្ងៃទី៩មីនា គ.ស១៩៤៥ ថ្ងៃទី៨ ធ្នូ គ.ស១៩៤៦...។

**៣.២- អាកាស(ទីកន្លែង)**

ភ្នំពេញ វិទ្យាល័យស៊ីសុវត្ថិ បាត់ដំបង ពោធិសាត់ សៀមរាប ប៉ៃលិន កំពង់ចាម កំពង់ធំ ស្ទឹងត្រែង ភ្នំគូលែន ភូមិជ្រោយម្ទេស វត្តជ្រោយអំពិល ប្រទេសសៀម មន្ទីរពេទ្យសេនារក្ស ភូមិភ្នំធំ...។

III. **វិជ្ជមានភាពទំនាស់**

**១- ទំនាស់ទី១**

- **ទីកន្លែងទំនាស់ :** នៅខេត្តពោធិសាត់
- **បញ្ហាទំនាស់ :** ស្រោមសំបុត្រ(លុយ៥០០រៀល)
- **តួទំនាស់ :** ទីឃាវុធ នឹង ថៅកែហុងឈី

ទំនាស់នេះកើតឡើងពីការសូកប៉ាន់របស់ថៅកែហុងឈី ដើម្បីបិទបាំងអំពើពុករលួយរបស់ខ្លួន។ ការសូកប៉ាន់នេះមិនអាចទិញមនសិការស្នេហាជាតិរបស់ទីឃាវុធបានឡើយ ពោលគឺ ទីឃាវុធពុំព្រមទទួលសំណូកនេះឡើយ។ ទង្វើរបស់ទីឃាវុធបានធ្វើឱ្យថៅកែហុងឈី ខឹងយ៉ាងខ្លាំង។ ដូចពាក្យសម្ដីមួយឃ្លាបានបញ្ជាក់ថា «យីអានេះចំជាភ្លើមែន!គេយកនំឱ្យស៊ីហើយ នៅមិនចេះស៊ីទៀត។ មិនអីទេអានាង! ចាំមើលចុះគង់តែអញបានសម្រេចដូចប្រថ្នាទេ»។

- **ដំណោះស្រាយ** : ទំនាស់នេះត្រូវបានបញ្ចប់ដោយសន្តិវិធីគឺទីឃាវុធបានប្រគល់ប្រាក់ចំនួន៥០០រៀលទៅឱ្យ ថៅកែហុងឈីវិញ។

**២- ទំនាស់ទី២**

- **ទីកន្លែងទំនាស់** : នៅខេត្តពោធិសាត់
- **បញ្ហាទំនាស់** : ការមិនព្រមចុះហត្ថលេខាទទួលសាច់កំណាត់សំពត់
- **តួទំនាស់** : ទីឃាវុធ នឹង ចៅហ្វាយខេត្ត

ទំនាស់នេះកើតឡើងដោយសារចៅហ្វាយខេត្តបានទទួលសំណូកសូកប៉ាន់ពីថៅកែហុងឈីសាច់ណាត់សំពត់ដោយបង្ខំឱ្យទីឃាវុធចុះហត្ថលេខាទទួលយក។ ទង្វើបែបនេះធ្វើឱ្យទីឃាវុធពុំព្រមចុះហត្ថលេខាឱ្យដែលជាហេតុធ្វើឱ្យចៅហ្វាយខេត្តខឹងច្រឡោតតូងយ៉ាងខ្លាំងដោយធ្វើមុខក្រញូវដោយពោលថា " វុធឯងខ្ជិសេចក្ដីណាស់ ម្ដេចក៏ក្អេងក្អាងដល់ម្លឹង "។

- **ដំណោះស្រាយ** : ទីឃាវុធត្រូវបានចៅហ្វាយខេត្តបញ្ជូនឱ្យទៅ ត្រួតពិនិត្យពន្ធនៅតាមឃុំនានាក្នុងស្រុកបាកាននិងក្រគរ។

**៣- ទំនាស់ទី៣**

- **ទីកន្លែងទំនាស់** : នៅតាមព្រំប្រទល់ដែនកម្ពុជាថៃ
- **បញ្ហាទំនាស់** : សង្គ្រាមដណ្ដើមទឹកដី
- **តួទំនាស់** : កម្ពុជានិងថៃ

ទំនាស់នេះកើតឡើងដោយសារប្រទេសថៃមានគោលបំណងចង់លេបត្របាក់ទឹកដីកម្ពុជា បញ្ហានេះធ្វើឱ្យកម្ពុជាមិនព្រមឱ្យថៃចូលមកឈ្លានពានបានជាដាច់ខាត។ ហេតុដូចនេះធ្វើឱ្យសង្គ្រាមផ្ទុះឡើង ដែលបណ្ដាលឱ្យកងទ័ពទាំងសងខាងស្លាប់និងរបួសអស់ជាច្រើននាក់។

- **ដំណោះស្រាយ** : ដោះស្រាយដោយសន្តិវិធី(ការចរចា)។ សៀមត្រូវប្រគល់ខេត្តមួយចំនួនមកឱ្យខ្មែរវិញ ដោយមានការចុះហត្ថលេខាបានត្រឹមត្រូវ។

## IV. ទិដ្ឋភាពវិភាគតួអង្គ

**១- ទីឃាវុធ**

- **គុណសម្បត្តិ**
    - ជាយុវជនអង់អាចក្លាហាន ប្រឹងប្រែងរៀនសូត្រ
    - ជាមន្ត្រីមានឧត្តមគតិស្នេហាជាតិ
    - ចេះគិតឧត្តមប្រយោជន៍ជាតិ មិនអាត្មានិយម
    - មានសមត្ថភាពក្នុងការដឹកនាំប្រជាជន
    - ចេះប្រៀបធៀបខ្លួនទៅនឹងអ្នកដទៃ
    - រៀនពូកែមុខវិជ្ជាភាសាខ្មែរ បារាំង អង់គ្លេស

- ○ មានស្មារតីទទួលខុសត្រូវខ្លួនឯងមិនខ្លាចផលវិបាកអ្វីទាំងអស់
  - ○ ហ៊ានសារភាពកំហុសរបស់ខ្លួន
  - ○ មានសីលធម៌រស់នៅល្អ។
- **គុណវិបត្តិ**
  - ○ ឆាប់ជឿគេដោយមិនបានស៊ើបឱ្យដឹងពីការពិត
  - ○ ប្រើប្រាស់សម្ដីទ្រគោះបោះបោកដាក់អ្នកដែលបានជួយយកអាសាខ្លួន
  - ○ ជាមនុស្សរើវាយអណ្ដែតអណ្ដូងហួសហេតុ។

**២- ចន្ទមណី**

- **គុណសម្បត្តិ**
  - ○ មានរូបសម្បត្តិស្អាតស្រស់សោភា
  - ○ មានចរិយាថ្លៃថ្នូរ សុភាពរាបសា
  - ○ មានមនុស្សធម៌ ចេះអធ្យាស្រ័យល្អ
  - ○ មានភាពក្លាហាន
  - ○ ជាមនុស្សមានគុណធម៌ជួយសង្គ្រោះទាំងខ្មែរទាំងសៀម
  - ○ ជាមនុស្សមានភក្ដីភាពស្មោះនឹងស្នេហា។
- **គុណវិបត្តិ**
  - ○ មិនបានប្រាប់ដំណឹងដល់គូស្នេហ៍នៅពេលត្រឡប់ទៅស្រុកកំណើត
  - ○ មិនបានពន្យល់ប្រាប់ការពិតដល់គូស្នេហ៍ឱ្យដឹងពីដំបូង។

**៣- ទេពកោសល្លវិចិត្រករ**

- **គុណសម្បត្តិ**
  - ○ ជាមនុស្សមានសណ្ដានចិត្តទូលាយ
  - ○ ជាមនុស្សស្លូតត្រង់
  - ○ ជាមនុស្សចេះយកអាសារអ្នកដទៃ
  - ○ ជាមនុស្សមិនប្រកាន់វណ្ណៈ
  - ○ ជាមនុស្សមានព្រហ្មវិហារធម៌ចំពោះកូន។
- **គុណវិបត្តិ**
  - ○ ជាមនុស្សកំសាក ខ្វះសេចក្ដីក្លាហាន រត់ចោលស្រុកកំណើត
  - ○ ជាមនុស្សមិនបង្ហាញពីការពិតដែលខ្លួនបានប្រព្រឹត្ត។

**៤- ចៅហ្វាយខេត្ត**

- **គុណសម្បត្តិ**

- មានចំណេះដឹងខ្ពង់ខ្ពស់
- មានការងារធ្វើ មានឋានៈជាចៅហ្វាយខេត្ត
- គ្រប់គ្រងស្ថានភាពគ្រួសារបានល្អ(ប្រពន្ធច្រើន)។

- **គុណវិបត្តិ**
  - ជាមនុស្សចូលចិត្តការសប្បាយស្រីស្រាល្បែង
  - ជាមនុស្សគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន(អាត្មានិយម)
  - ជាមនុស្សគ្មានឧត្តមគតិស្នេហាជាតិ
  - ជាមន្ត្រីពុករលួយ។

**៥- ហុងឈី**

- **គុណសម្បត្តិ**
  - ជាមនុស្សមានប្រាជ្ញាឈ្លាសវៃក្នុងការប្រកបរបររកស៊ី(ពូកែរកប្រាក់)
  - ជាមនុស្ស ប៉ិនប្រសប់ក្នុងការធ្វើទំនាក់ទំនង។
- **គុណវិបត្តិ**
  - ជាមនុស្សទុច្ចរិតអាងអំណាចទឹកប្រាក់
  - មិនគិតពីផលប្រយោជន៍ជាតិ(អាត្មានិយម)
  - កេងប្រវ័ញ្ចទ្រព្យសម្បត្តិរដ្ឋ។

**៦- ប្រាមោទ្យ**

- **គុណសម្បត្តិ**
  - ជាមន្ត្រីស្មោះត្រង់
  - ជាមន្ត្រីស្អប់ខ្ពើមអំពើពុករលួយ
  - ជាមន្ត្រីស្គាល់ពីកាលៈទេសៈ។
- **គុណវិបត្តិ**
  - ខ្វះសេចក្តីក្លាហានក្នុងការបញ្ចេញមតិយោបល់
  - គិតពីសេចក្តីសុខផ្ទាល់ខ្លួន មិនគិតពីសុខទុក្ខអ្នកដទៃ
  - ខ្លាចបាត់មុខដំណែង។

**៧- វេតី**

- **គុណសម្បត្តិ**
  - ស្នេហាជាតិ
  - មិនលក់ឧត្តមគតិ
  - ចិត្តទូលាយ

- ចេះសារភាពនូវកំហុសរបស់ខ្លួន។

- **គុណវិបត្តិ**
  - ធ្វេសប្រហែសនឹងការងារ ធ្វើឱ្យអ្នកដទៃយល់ច្រឡំនិងគ្នា។

## V. **ទិដ្ឋភាពសង្គម**

### ក- វប្បធម៌

**១- ជំនឿ ប្រពៃណី ទំនៀមទម្លាប់** : ប្រជាជនខ្មែរជឿលើព្រះពុទ្ធសាសនាក្នុងការបួងសួងបន់ស្រន់សុំសេចក្ដីសុខសេចក្ដីចម្រើន។

- យុវជនទាំងពីសូត្រថ្វាយបង្គំដោយជឿស្មោះ ហើយដោយមានទឹកមុខយ៉ាងជ្រះថ្លាផង។
- សូមគុណព្រះបារមី

ជួយជ្រោមជ្រែងយើងខ្ញុំព្រះករុណាទាំងពីរនាក់ដែលមានបំណងស្នេហារឹតរួតយ៉ាងមាំមួន។ សូមឱ្យបានផុតពីសេចក្ដីលំបាក ហើយពានពារឧបសគ្គនានាទាំងពួង។

**២- សាសនា** : តាមរយៈដំណើររឿងបានបង្ហាញថាប្រជាជនគោរពបូជាព្រះពុទ្ធសាសនា

- មួយសន្ទុះមកទៀតអ្នកដំណើរបានចូលទៅក្នុងវត្តដែលមានទីលានទូលាយស្រឡះបោសស្អាតធេង មានមេកុដ្ឋប្រក់ក្បឿងមួយ ហើយកូនកុដ្ឋពីរ បីប្រក់ស្បូវជ្រកក្រោមម្លប់ខ្នុរព្រះវិហារតូចមួយដែលសង់ពុំទាន់រួច ហើយមានសាលាប្រក់ស្បូវមួយវែងសម្រាប់ជាទីសំណាក់នៃអ្នកដំណើរ។ អារាមនេះ ជាទីបរមសុខក្រៃលែង។

- ក្នុងពេលដែលចាស់ៗឈៀងចូលទៅថ្វាយបង្គំហើយយកអីវ៉ាន់ខ្លះប្រគេនចំពោះលោកគ្រូចៅអធិការ...។

- លុះបានដោះស្បែកជើងទុកនៅខាងក្រៅសាលាស្រេចហើយ យុវជនទាំងពីរក៏ចូលយកផ្កាទៅបូជាក្នុងថូមួយនៅប្របព្រះបល្ល័ង្ក ទើបនាំគ្នាលត់ជង្គង់សូត្រនមស្ការ...។

**៣- ការសិក្សាអប់រំ** : នៅសម័យកាលនោះយើងសង្កេតឃើញមានសិស្សរៀននៅតាមសាលា

- ក្នុងសយនដ្ឋានមួយនៃវិទ្យាល័យស៊ីសុវត្ថិដែលសេចក្ដីស្ងប់ស្ងាត់គ្របដណ្ដប់នៅឡើយព្រោះមិនទាន់ដល់ម៉ោង...។

- ទីឃាវុធជាសិស្សឧស្សាហ៍ មានប្រាជ្ញាឈ្លាសវៃនៅថ្នាក់ទីពីរនៃមធ្យមសិក្សា។អ្នកកម្លោះចូលចិត្តរៀនជីវភាសាណាស់ ហើយតែងបានលេខ បានទីល្អៗក្នុងវិជ្ជាភាសា អង់គ្លេស បារាំង និងខ្មែរ។

- ក្នុងឱកាសវ៉ាកងនេះ ទីឃាវុធ ខំព្យាយាមរើពិនិត្យរើទន្ទេញឡើងវិញនូវមេរៀនទាំងឡាយបម្រុងនឹងចូលប្រឡងក្នុងខែមិថុនាខាងមុខឱ្យបានជោគជ័យ។

**៤- សិល្បៈ** : នៅក្នុងរឿងនេះអ្នកនិពន្ធពុំបានលើកទម្រង់សិល្បៈណាមួយមកបង្ហាញច្បាស់លាស់ទេគឺគ្រាន់តែពន្លេចឱ្យឃើញពីសិល្បៈចម្រៀងតាមរយៈសាច់រឿងតែប៉ុណ្ណោះ។ ជាក់ស្ដែង

ដូចជា៖

- លោកចៅហ្វាយស្រុកផ្តាប់បុណ្យ បានកេណ្ឌអ្នកស្រុកឱ្យសង់រោងប្រក់ស្លឹកពីរខ្នងចំពីមុខបឹងធំដែលនៅកណ្តាលវាលស្រែបន្លែងដោយភ្លេងភ្លាត់ និងចម្រៀងអឹងកង។
- ក្នុងពេលស្តាប់វិទ្យុ បើកាលណា បើសម្លេងនារីសៀមច្រៀងបងស្តាប់ពីរោះ...ឈឺផ្សាក្នុងចិត្តក្រៃលែង។
- ក្របីស៊ីស្រូវបងមិនសូវហ៊ានដេញ ក្របីដើរចេញបងដេញឱ្យស្រីមើល ។

**ខ- សេដ្ឋកិច្ច**

**១- កសិកម្ម** : ប្រជាជនប្រកបរបរធ្វើស្រែចម្ការ និងដំណាំដាំដុះផ្សេងៗ

- ស្រមោលស្វូរៗនៅមុខខ្ទមស្រែ ខ្លះជាអ្នកបញ្ជាន់ដែលកំពុងបង្វិលត្របាញ់ លើភ្នែនកណ្តាប់នូវគំនួចគោបួនប្រាំសត្វ...។
- វាលស្រែក្តៅដូចជាភ្នក់ភ្លើងមួយយ៉ាងធំព្រះអាទិត្យចិត្តឃោរឃៅកំឡោចស្មៅនិងកញ្ច្រាំង...។
- ឧសភាបាននាំមកនូវភ្លៀងដំបូងដើមឆ្នាំហើយវាលស្រែក៏មានជីវិតដោយសកម្មភាពភ្ជួររាស់។ ហ៊ុយៗ ! គោទាញនឹមនង្គ័លយ៉ាងតឹងក...។
- ថ្ងៃៗឡើងពូហ៊ីង ដែលមានមាឌកន្តិលក្រអាញ ហើយសម្បុរខ្មៅដូចស្បែកសត្វដែលគាត់ខ្ចីឈ្មោះអីចឹង តែងថៃធូនដំណាំដាំដុះមិនឈប់ដៃទេ។
- នៅខាងនេះព្រំដែន ក៏ដូចជាខាងនោះដែរវាលស្រែបរិបូណ៌ទៅដោយការប្រកបរបរចិញ្ចឹមជីវិតតែម្យ៉ាង គឺបរធ្វើស្រែចម្ការ។ នាយ អាំភើ បានជូនសហាសេរិកខ្មែរ ដើរមើលគ្រប់ទិសទីដែលមានអ្នកស្រុកខាងពួកសៀមរាប មកភ្ជួររាស់។

**២- ឧស្សាហកម្ម** : ប្រជាជនបានផលិតរបស់របរប្រើប្រាស់មួយចំនួនដូចជា៖ អាវព្រៃ

- ម្លេះសមនៅលើទ្រូងអាវព្រៃ សាច់ម៉ដ្ឋខៃ កាត់ដេរយ៉ាងប្រណីតទុកឱ្យស្មានូវរងប៉ោងក្បូលើឱរា នាងពាក់បន្តោងពេជ្រដែលដេញរស្មីភ្លើងភ្លឺពព្រាយ។

**៣- សិប្បកម្ម**: តាមរយៈអត្ថបទនេះពុំបានបញ្ជាក់ពីការផលិតរបស់របរប្រើប្រាស់ទេ គឺគ្រាន់តែយើងឃើញតាមរយៈដំណើររឿងដែលបានបង្ហាញ ដូចជា៖ ជាល កញ្ជើ ស្បែកជើង...។

- គេច្រើនតែនាំគ្នាទៅកកកុញនៅយានថ្នាក់លេខ៤ជាមួយនឹងជាលត្រី កញ្ជើបន្លែ...។
- ជើងគាត់ពាក់ស្បែកជើងផ្លូខ្មៅចុងស្រួចហើយងឡើងលើ ហើយគាត់ដើរកាយក្រោយខ្នងបន្ទេមកក្រោយបន្តិចភ្នែកសម្លឹងទៅឆ្ងាយ មានឫកខ្ពស់ក្រអឺតបែបចង់សម្តែងឱ្យឃើញថាដីនេះ ទីនេះកាលពីដើមមិញជារបស់ប្តីអញ គឺនៅជារបស់ខ្លួនអញខ្លះដែរ។

**៤- ពាណិជ្ជកម្ម** : មានលក់ទំនិញ ភេសជ្ជៈ ម្ហូបអាហារនានានៅតាមទីផ្សារ

- ទីឃាវុធ បាននាំដំណើរការណ៍នេះ មកស្មើជាមួយមេខ្សែរថភ្លើងដែលកំពុងក្រេបកាហ្វេ

ខ្មៅ ក្លែមចាខ្ញៃនៅក្នុងរថលក់បាយ។

- ព្រឹកៗឡើងមីងក្អាត់រាងសង្វិតកន្ត្រៃវអារេវ សមដូចសត្វយកឈ្មោះគាត់ទៀតហើយគាត់តែងតែទូលចេក ល្មុត ដំឡូង ស្លាតាមរដូវ យកទៅលក់ឯផ្សារ។

**គ- សង្គមកិច្ច**

**១-ស្ថានភាពរស់នៅ** : យើងដឹងស្រាប់ហើយថា ប្រទេសកម្ពុជាស្ថិតនៅក្រោមរបបគ្រប់គ្រងរបស់ពួកអាណានិគមនិយមបារាំង។ ការរស់នៅរបស់ប្រជាជនមានភាពលំបាកខ្លាំង ដោយមន្ត្រីមួយចំនួន ពុំបានគិតគូពីផលប្រយោជន៍ជាតិ គឺគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន កេងប្រវ័ញ្ចញើសឈាមប្រជាជន។ ប្រទេសជាតិជួបតែបញ្ហាអសន្តិសុខមិនចេះចប់មិនចេះហើយ។

**២-សុខាភិបាល**

- **ក្នុងប្រទេស** : នៅក្នុងអត្ថបទរឿងនេះពុំបានបញ្ជាក់ពីសុខាភិបាលច្បាស់លាស់ទេ គឺគ្រាន់តែដឹងតាមរយៈពាក្យសម្ដីរបស់តួអង្គទីឃាវុធបញ្ជាក់ថា៖ « បើមានទាហានសៀមត្រូវរបួសដូចខ្លួន ក៏គង់មានពេទ្យខ្មែរ គិលានុបដ្ឋាកយិកាខ្មែរ បីបាច់ដោយយកចិត្តទុកដាក់ដូចគ្នាដែរ »។
- **ក្រៅប្រទេស** : នៅក្នុងអត្ថបទនេះ ផ្នែកសុខាភិបាលមានការរីកចម្រើនច្រើនដោយឃើញមានមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺដូចមានឃ្លាបញ្ជាក់ថា៖  រវាងបីម៉ោងមកហើយរថយន្តកាកបាទក្រហមបានបញ្ជូនអ្នករបួសមកប្រគល់ឱ្យមន្ទីពេទ្យក្នុងវត្ត។ទាំងពេទ្យធំ ទាំងសហការិនីបានវះកាត់ចាក់ដាក់ថ្នាំ  ឬរំរបួសឥតបានឈប់ដៃបានឡើយ។  តាមធម្មតា  មន្ទីរពេទ្យនេះគ្រាន់តែចាត់ការសើរៗបណ្ដោះអាសន្នតែប៉ុណ្ណោះព្រោះពុំមានបបនភណ្ឌអ្វីមាំមួនទេ។   ដោយហេតុដូច្នេះហើយបានជារាជការសឹកបានចាត់ឱ្យមានខ្សែរថភ្លើងពិសេសមួយសម្រាប់ដឹកអ្នកដំណើររាល់ថ្ងៃទៅថៃទាំនៅមន្ទីរពេទ្យធំៗនាក្រុងបាងកកទៀត។

**៣-មុខរបរនិងជីវភាព របស់ប្រជាជន** : តាមរយៈរឿងនេះឃើញថា ប្រជាជនមួយចំនួនប្រកបមុខរបរធ្វើស្រែចម្ការច្បារដំណាំ  ការលក់ដូរ និងជាមន្ត្រីរាជការ។ ចំពោះប្រជាជនដែលប្រកបរបរធ្វើស្រែចម្ការច្បារ
ដំណាំមានជីវភាពពុំសូវធូរធារប៉ុន្មានទេ គឺបានមួយរស់ៗតែប៉ុណ្ណោះ។ ចំណែក
ឯការប្រកបរបរលក់ដូរវិញឃើញថាមានលក្ខណៈប្រសើរគ្រាន់បើជាង។ ចំពោះមន្ត្រីរាជការវិញសរបញ្ជាក់ឱ្យឃើញថាមន្ត្រីណាចេះអែបចេះអបថៅហ្វាយនាយ នោះទើបមានជីវភាពធូរធារ។

**ឃ- នយោបាយ**

**១-ក្នុងប្រទេស**

ប្រទេសខ្មែរគោរពរបបរាជានិយម។ ការគ្រប់គ្រងប្រទេសស្ថិតនៅក្រោមរបបអាណានិគមនិយមបារាំង។ រាល់កិច្ចការទាំងអស់ គឺបារាំងជាអ្នកគ្រប់គ្រង។ បារាំងនិងសៀមបានចុះហត្ថលេខា

លើការផ្អាកឈប់បាញ់គ្នា ហើយនាំគ្នាទៅចរចារសន្តិភាពនៅក្រុងតូក្យូរាជធានីយីពុន។ កិច្ចចរចារនេះទាក់ទងដល់ជីវិតកម្ពុជមែនពិត តែខ្មែរពុំមានសិទ្ធចូលជជែកនឹងគេទេ។

**២-ក្រៅប្រទេស**

ប្រទេសសៀមមានគោលបំណងចង់លេបត្របាក់ទឹកដីរបស់ប្រទេសកម្ពុជានិងឡាវដោយប្រើយុទ្ធសាស្ត្រ " ក្របីស៊ីស្រូវ បងមិនស្ទូវហ៊ានដេញ ក្របីដើរចេញ បងដេញឱ្យស្រីមើល "។

ប្រទេសយីពុនមានមហិច្ឆតា ចង់ធ្វើអាណានិគមមកលើកម្ពុជានៅពេលដែលបារាំងធ្លាក់ដៃ។ យីពុននិងសៀមចាប់ដៃគ្នា កំចាត់បារាំង។

**ង- គមនាគមន៍:** ផ្លូវគមនាគមន៍ពុំទាន់មានភាពរីកចម្រើននៅឡើយដោយមានឃ្លាបញ្ជាក់ថា៖

- ផ្លូវនេះមានទឹកដក់តាមក្រឡុកច្រើនអនេកព្រោះខ្វះការជួសជុលជាយូរយារណាស់មកហើយ។ ផ្ទៃថ្នល់ជាភក់ស្អិតដូចបាយម៉ាន។
- ដើម្បីឱ្យទៅដល់ភ្នំបានពីព្រឹក អ្នកដំណើរតោងក្រោកពីស្រាងៗព្រោះផ្លូវដែលមានចម្ងាយជាងសែសិបគីឡូម៉ែត ពីសៀមរាបទៅភ្នំនោះ ច្រើនសម្បូរដោយដីខ្សាច់ និងដោយស្ពានទ្រុឌទ្រោម...។

## VI. ទិដ្ឋភាពតែងនិពន្ធ ឬអត្ថរូប

### ក- ផ្តើមរឿង

អ្នកនិពន្ធផ្តើមរឿងដោយពណ៌នាអំពីអារម្មណ៍របស់យុវជនម្នាក់ដែលកំពង់តែអណ្តែតត្រសែតទៅទីណាមួយ រួចទើបចាប់ផ្តើមពណ៌នាពីទិដ្ឋភាពនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ។

### ខ- តួរឿង

អ្នកនិពន្ធបានពណ៌នាដំណើររឿងដោយប្រើសិល្បវិធីតែងដូចខាងក្រោម៖

**១- ទម្រង់សំណេរ**

អ្នកនិពន្ធតែងរឿងនេះឡើងដោយសរសេរជាពាក្យរាយ និងពាក្យកាព្យដូចជា៖

- **ពាក្យរាយ៖** " វេតីបានផ្ញើសំបុត្រឱ្យទីយាវុធ..."។
- **ពាក្យកាព្យ៖**

គុណ្ឋីភាពរាត្រី

ធម្មជាតិនិទ្រាស្ងាត់ជ្រងំ　　　មាន់រងាវយំឮល្វឹងល្វើយ
ខ្យល់បក់ផាងដូងយោលទន់ផើយ　　　រំភើយបក់ផាត់ក្លិនម្លិះលា។
ព្រះចន្ទឈៀងគងភ្នំខ្មៅវែង　　　មេឃខ្ពស់ធំធេងវែងស្អាតថ្លា
សន្សើមប្រោះព្រំចុងព្រឹក្សា　　　ហៅសែនសុខាក្នុងរាត្រី។
តែក្នុងចិត្តខ្ញុំមានកង្វល់　　　រួបរឹតគិតដល់ត្រួយនារី
រូបនាងខ្ទតតាមគ្រប់ទិសទី　　　នាំឱ្យរក់រឹរអស់អង្គកាយ។

**២- បច្ចេកទេសក្នុងការតែង**

- ភាសា(ភាសាតំបន់ បាលី សំស្ក្រឹត បរទេសដទៃទៀត)

នៅក្នុងរឿងនេះអ្នកនិពន្ធតែងឡើងដោយប្រើប្រាស់ពាក្យពេចន៍ចម្រុះ៖

- ពាក្យសាមញ្ញរបស់អ្នកស្រុក : ( ឧ. ពូ មីង ត្អើក ...)
- ពាក្យសម្រាប់ឋានៈកណ្តាល :( ឧ. ខ្ញុំ ខ្ញុំប្របាទ ទានប្រោស ព្រះតេជព្រះគុណ...)
- ពាក្យបរិវាសព្វ : ( ឧ. ថ្មោងថ្មី ខ្សឹបខ្សៀវ ឃ្លៀងឃ្លាត គិតគូរ...)
- ពាក្យបាលីសំស្ក្រឹត : ( ឧ.បុរាណ ឱកាស ធម្មជាតិ...)
- ពាក្យកម្ចីបរទេស :
  - ពាក្យថៃ :( ឧ. យុន យុនផ កុន ក្លងប្រៈអាក់ឃី អាំជៈវ៉ុន អធិតថេវដេត ...)
  - ពាក្យចិន : ( ឧ. តាប៉ិ ជើងម៉ា ដង្វៅ តៃកុង ...)
  - ពាក្យបារាំង : ( ឧ. សុហ្វ័រ រ៉េស៊ីដង់ អាបង់ទ័រ ម៉ោសៀ ...)

- **ការប្រៀបធៀប(ទំហៀបន័យ)**

អ្នកនិពន្ធបានប្រើវិធីនេះដូចខាងក្រោម៖

- ទីឃាវុធអន្ទះអន្ទែងវិលវល់ក្នុងសេចក្តីសង្ស័យ...ក្នុងគ្រែមួយដែលមានសភាពដូចក្រាលនូវបន្លាចាក់មុតសាច់...។
- អ្នកបួសកាលពីមុនស្លាំងស្លឹតដូចទេសឯកនោះ...។
- ទេសភាពដ៏ត្រកាលនេះមាននាទីជាអង្រឹងសម្រាប់យោលរំសាយទុក្ខនៃយុវជនដែលស្រវឹងដោយឃ្លោង ដោយកាព្យថ្លាដូចចរណៃហើយស្អាតដូចពន្លឺព្រះចន្ទពេញបូណ៌មី។
- ថ្ងៃបាចរស្មីលើវាលស្រែ ឱទេសភាពប្រែពណ៌ដូចមាស
  ហើយផ្សាយនូវបរិយាកាស រីករាយត្រចះក្រោមមេឃខៀវ។

- **បុគ្គលិកកម្ម**

នៅក្នុងរឿងនេះអ្នកនិពន្ធបានប្រើបុគ្គលិកកម្មដូចខាងក្រោម៖

- សំឡេងអ្នកច្រូតច្រៀងតគ្នានឹងមាត់លលកដែលយំឆ្លើយឆ្លងពីចុងដង្កោមួយទៅមួយនាំឱ្យវិញ្ញាណឡើនឡង់ដោយសុខដុមនិងសំរានចិត្ត។
- អ្នកខ្លះឱនខ្នងរងដុំទឹកដែលធ្លាក់ពីលើ ហើយប្រកាសអួតថា វារីចេះគក់ចេះច្របាច់ស្រួលណាស់រើយ!។
- ដីទេចុះសន្សើមសូរទឹកហូរឮកាន់តែខ្លាំងៗ ហើយក្លាយទៅជាគ្រហឹម រញ្ជួយទាំងពសុធា។

- **ភាសាច្បាស់លាស់**

អ្នកនិពន្ធបានប្រើប្រាស់ភាសានេះនៅក្នុងអត្ថបទដូចជា «មុខឡើងក្រហម អរុណចាប់លាប ពណ៌ក្រហមទុំ ស្បែកជើងពណ៌ក្រម៉ៅខាត់រលោងស្រិលស្លៀកពាក់ស្រោមជើងខ្មៅ ស្បែកជើងខ្មៅ កន្ទេលក្រចូតពត្លក់ ...»។

- **ភាសារស់រវើក**

អ្នកនិពន្ធបានប្រើប្រាស់ភាសានេះនៅក្នុងអត្ថបទដូចជា «ចំរៀងទ្រហឹងអឹងកង ញញឹមស្រស់ពព្រាយ ខ្យល់បក់ភឹបៗ...»។

- **បំរៀបន័យ ឬមេតាផរ** : អ្នកនិពន្ធបានប្រើវិធីនេះដូចជា «ឆ្កាដៃឆ្កាជើង ចង្កេះភ្នំក្បាលស្រែ...»។
- **កំប្លែង ឬសំណើច** (អ្នកនិពន្ធពុំបានបង្ហាញឱ្យឃើញពីភាពកំប្លែង ឬសំណើចអ្វីទេ)
- **ទុក្ខសោក ឬភាពវេទនា** : តាមរយៈដំណើររឿងនេះអ្នកនិពន្ធបានបង្ហាញពីទុក្ខសោក ឬភាពវេទនារបស់ប្រជាជនខ្មែរដែលស្ថិតនៅក្រោមរបបអានិគមនិយមបារាំង។ រចនាសម្ព័ន្ធគ្រប់គ្រងប្រទេសទាំងមូលស្ថិតនៅក្រោមការត្រួតត្រារបស់បារាំងតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។ ម្យ៉ាងទៀតអ្នកនិពន្ធក៏បានបញ្ជាក់ពីសង្គ្រាមដែលធ្វើឱ្យប្រជាជនរងទុក្ខវេទនាផងដែរ ដូចជាសម្តីរបស់អ្នកនិពន្ធបានបញ្ជាក់នៅក្នុងកថាមុខថា៖ ″ប្រលោមលោក"មាលាដួងចិត្ត″នេះនិទានផ្តើមគឺនៅពេលសង្គ្រាមលោកលើកទីពីរចាប់ឆួលឆេះឡើងហើយមកចប់នៅចុងឆ្នាំ១៩៤៦ គឺនៅពេលខេត្តបាត់ដំបង និងដែនដីយើងទាំងប៉ុន្មានដែលបាត់បង់ទៅនោះ បានវិលត្រឡប់មកចូលរួមក្នុងសហគមន៍ជាតិវិញ″។

ឧទាហរណ៍ : នៅថ្ងៃទី៨ កមរា បច្ចាមិត្តចូលមកដុតបំផ្លាញ...ស្លាប់បាត់បង់ជីវិតអស់ច្រើននាក់ព្រោះតែសេចក្តីឈ្នានិះ និងលោភា។

- **ការសន្ទនាគ្នា(សំវាទវិធី) និងនិយាយ ឬគិតតែម្នាក់ឯង(ឯកវាទវិធី)**
  - **សំវាទវិធី** : រឿងនេះអ្នកនិពន្ធបង្កើតការសន្ទនាគ្នារវាងតួអង្គ និងតួអង្គដូចខាងក្រោម៖

  - គ្មានកំណាត់ឯណាថ្មីទៀតទេ...ឃើញថាគួរសមល្មមហើយ។
  - ទានប្រោសបើសំពត់ផុយដដែលទេ ខ្ញុំប្របាទម្ចាស់...ទទួលយកទេ។
  - វុធ ឯងខ្ចី...ដល់ម្លឹង!
  -ទានប្រោសទេ...ប៉ុន្មានថ្ងៃទេ។

  - **ឯកវាទវិធី** : អ្នកនិពន្ធបានពន្លេចនូវតួអង្គដែលអង្គុយសញ្ជឹងគិតតែម្នាក់ឯងដូចជា៖

ទីឃាវុធសញ្ជឹងគិតថា៖ ″ បើអញទទួលយកទៅ ម៉្លេះសមអញនឹងសងជំពាក់ប្រាក់ដែលបានខ្ចីពួកម៉ាកយកមកទិញប្រដាប់ប្រដារផ្សេងៗ... ″។

- **ការនិទានបែបបុរសទី១ ឬបុរសទី៣**

អ្នកនិពន្ធតាក់តែងរឿងនេះឡើងដោយការនិទានបែបបុរសទី១ ឬបុរសទី៣៖

- ○ **ការនិទានបែបបុរសទី១៖** ខ្ញុំ (ឧទាហរណ៍ : ខ្ញុំមិនបានស្មានថា ខ្លួនខ្ញុំមានអំណាចអីដល់ម្លេះទេ...)
- ○ **ការនិទានបែបបុរសទី៣៖** នាង ( ឧទាហរណ៍ : នាងដកក្រដាសពីរសន្លឹកបត់សៀតភ្លេចចោល ក្នុងសៀវភៅដែលនាងកំពុងអាន យកមកបង្ហាញមិត្តនាង។ )

**គ- បញ្ចប់រឿង**

រឿងមាលាដួងចិត្តអ្នកនិពន្ធបានបញ្ចប់ដោយឱ្យតួអង្គឯកបានដោះស្រាយបញ្ហាប្រទេសជាតិចប់សព្វគ្រប់រួចរាល់បរិបូណ៌ហើយ ទើបឱ្យតួអង្គគិតគូរពីបញ្ហាស្នេហា និងរួមរស់ជាមួយគ្នាយ៉ាងសុខសាន្ត។

## VII. ទិដ្ឋភាពតម្លៃ

**១-សកម្មភាពវិជ្ជមាន:**

តាមរយៈដំណើររឿងនេះអ្នកនិពន្ធបានបង្ហាញពី៖

- សម័យកាលមួយដែលសង្គមខ្មែរស្ថិតក្រោមការគ្រប់គ្រងរបស់ពួកអាណានិគមនិយមបារាំង ហើយមានមន្ត្រីខ្មែរមួយចំនួនដែលឃុបឃិតជាមួយពួកបារាំង គាបសង្កត់ជិះជាន់ប្រជារាស្ត្រតូចតាច។ ព្រមជាមួយគ្នានេះដែរអ្នកនិពន្ធក៏បានបង្ហាញពីសម័យកាលមួយដែលខ្មែរមានជម្លោះជាមួយសៀម ហើយខេត្តខ្មែរមួយចំនួនដែលសៀមកាន់កាប់ត្រូវបានមកខ្មែរវិញ។ ហើយនៅក្នុងដំណើររឿងនេះទៀតសោតអ្នកនិពន្ធក៏បានបង្ហាញពីភាពពិតជាក់ស្តែងដូចជា៖ ភ្នំពេញ(វិទ្យាល័យព្រះស៊ីសុវត្ថិ ...) ខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ ...។
- ចិត្តរបស់យុវជនខ្មែរដែលប្រកាន់ភ្ជាប់នូវអំពើល្អ និងភាពទៀងត្រង់ដែលបានស្តែងឡើងតាមរយៈ ៖ តួអង្គទីឃាវុធសុខចិត្តពិបាកខ្លួនមិនព្រមទទួលសំណូកពីថៅកែហុងឈី ដោយទុកឱ្យប៉ូលិស៥០០នាក់រងទុក្ខវេទនានោះទេ។ ទីឃាវុធបានតាំងចិត្តពីសាលាមកថានឹងយកចំណេះវិជ្ជាទៅបម្រើប្រទេសជាតិ ហើយឧត្តមគតិនេះនៅតែស្ថិតជាប់នឹងខ្លួនជានិច្ច។
- លក្ខណៈអង់អាចក្លាហាន ការតស៊ូប្តូផ្តាច់របស់យុវជនខ្មែរទាំងអស់ដើម្បីជាតិមាតុភូមិរបស់ខ្លួន។ ជាក់ស្តែងដូចជា៖ តួអង្គទីឃាវុធ និងយុវជនទាំងអស់ធ្វើការប្រឆាំងជាមួយសៀមស៊ូស្លាប់ក្រាញនៀលក្នុងសមរភូមិ ដើម្បីការពារបូរណភាពដែនដីជូនជាតិមាតុភូមិ។
- ការអប់រំឱ្យ៖
  - ○ មានគំនិតស្នេហាជាតិ ស្រឡាញ់ជាតិ
  - ○ គិតផលប្រយោជន៍ជាតិច្រើនជាងផលប្រយោជន៍ផ្ទាល់ខ្លួន
  - ○ ស្រឡាញ់អំពើយុត្តិធម៌ សុចរិតទៀងត្រង់
  - ○ បណ្តុះគំនិតស្អប់ខ្ពើមនូវអំពើទុច្ចរិត ពុករលួយ កេងប្រវ័ញ្ច ស៊ីសំណូកសូកប៉ាន់។
- តម្លៃនៃសង្គមខ្មែរ របៀបរបបនៃការរស់នៅ ជំនឿ ទំនៀមទំលាប់ប្រពៃណីដូចជា៖

- ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនៅមានកម្រិត។
- ប្រជាជនមានជំនឿយ៉ាងមុតមាំលើព្រះពុទ្ធសាសនា។
- របបគ្រប់គ្រងប្រទេសស្ថិតនៅក្រោមនឹមត្រួតត្រារបស់ពួកអាណានិគមនិយមបារាំង។

**២-សកម្មភាពអវិជ្ជមាន:**

តាមរយៈដំណើររឿងនេះអ្នកនិពន្ធបានបង្ហាញពីចំណុចអវិជ្ជមានមួយចំនួនដូចជា៖

- ទីឃាវុធ បានប្រើពាក្យសំដីមិនសមរម្យទៅលើនាងចន្ទមណី ដែលបានជួយសង្គ្រោះខ្លួន។ ឧទាហរណ៍ : «ល្អហើយនាងចារៈនារី ខ្ញុំធ្លាក់ក្នុងកណ្ដាប់ដៃហើយ យកទៅសម្លាប់តែម្ដងទៅល្អជាង កុំ...។»
- ចៅហ្វាយខេត្ត និងចៅកែ បានប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូក ស្រីស្រា ជះឥទ្ធិពលមិនល្អដល់អ្នកនៅក្រោមបង្គាប់ និងប្រជាជនផងដែរ។ ឧទាហរណ៍ : «យីអានេះ ចំជាភ្លើមែន! គេយកនំឱ្យស៊ីហើយ...ដូចប្រាថ្នាទេ»។

**VIII. ការសន្និដ្ឋាន**

ក្រោយពីបានសិក្សាស្នាដៃអក្សរសិល្ប៍រឿងមាលាដួងចិត្តរួចមកយើងឃើញថា ស្នាដៃនេះពិតជាល្អទាំងផ្នែកអត្ថរូប អត្ថន័យ និងអត្ថរស ព្រមទាំងបានបញ្ចូលនូវសិល្ប៍រូបារម្មណ៍តាំងពីដើមសាច់រឿងរហូតដល់បញ្ចប់រឿង។ ហើយនៅក្នុងរឿងនេះទៀតសោតក៏បានបង្ហាញឱ្យឃើញពីតម្លៃអប់រំជាច្រើនសម្រាប់កូនចៅជំនាន់ក្រោយៗទុកជាគតិ។ តម្លៃអប់រំនេះរួមមាន គំនិតស្រឡាញ់អំពើយុត្តិធម៌ ស្អប់ខ្ពើមអំពើពុករលួយ ស្រឡាញ់ជាតិនិយម សុខចិត្តលះបង់សេចក្ដីសុខផ្ទាល់ខ្លួន ដើម្បីសេចក្ដីសុខរបស់ប្រទេសជាតិទាំងមូល។បើទោះបីក្នុងសាច់រឿង តួអង្គស្រីមិនមែនជាជនជាតិខ្មែរក៏ដោយ ក៏អ្នកនិពន្ធមិនបានឱ្យតួអង្គប្រុសងប់ងល់នឹងសេចក្ដីស្នេហា ភ្លេចកិច្ចការរបស់ប្រទេសជាតិនោះឡើយ។ គឺអ្នកនិពន្ធបានបង្ហាញដោយឱ្យតួអង្គប្រុស ដោះស្រាយបញ្ហាប្រទេសជាតិរំដោះទឹកដីរបស់ប្រទេសមកវិញជាមុនសិន ទើបបែរមកគិតគូរពីរឿងស្នេហារបស់ខ្លួន។ ដូចនេះយើងជាអ្នកសិក្សាជំនាន់ក្រោយៗត្រូវចេះថែរក្សាស្នាដៃដ៏ល្អឯកនេះនិងរក្សានូវតម្លៃរបស់ខ្លួនក្នុងបុព្វហេតុជាតិមាតុភូមិ។

# ឯកសារពិគ្រោះ


- យឹង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ ១៩៩៨
- ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៩៩
- មីសែលត្រាណេ ការសិក្សារឿងរាមកេរ្តិ៍ ១៩៩៥
- លាង ហាប់អាន សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ រាមាយណៈឥណ្ឌា ១៩៦៦
- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ១៩៨៨
- វចនានុក្រមវចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ , ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ ថ្នាក់ទី១២ លេខ០៣ អយក.សណន. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦
- សេង សោភា សិក្សារបៀបធៀបរឿងរាមកេរ្តិ៍ និងរឿងរាមគៀតថៃ សារណាបញ្ចប់ បរិញ្ញាអក្សរសាស្ត្រខ្មែរ ឆ្នាំ២០០៧
- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
- ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លែង ឆ្នាំ១៩៧៣
- សៀវភៅសិក្សាគោលភាសាខ្មែរ សៀវភៅសិស្សថ្នាក់ទី១០ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១០
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរ សៀវភៅសិស្សថ្នាក់ទី១១ បោះពុម្ពផ្សាយ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៥
- សៀវភៅសិក្សាគោលអក្សរសាស្ត្រខ្មែរសៀវភៅសិស្សថ្នាក់ទី១២បោះពុម្ពផ្សាយដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១២
- នូ ហាច រឿងមាលាដួងចិត្ត (១៩៧៣-១៩៤៦) បោះពុម្ពឆ្នាំ១៩៤៧
- លី ធាមតេង សៀវភៅការផ្សាយរបស់អ្នកនិពន្ធខ្មែរ ឆ្នាំ១៩៧២។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង រាមកេរ្តិ៍

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:...................................អយក.**

## ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងរាមកេរ្តិ៍»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍« រឿងរាមកេរ្តិ៍ » ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណោះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណោះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណោះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ [illegible] ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

<u>កន្លែងទទួល:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

**បុព្វកថា**

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានថែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិបូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការចេះបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ"**សិក្សាអត្ថបទអក្សរសិល្ប៍**" ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជាៈ

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ **«ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង រាមកេរ្តិ៍»** នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក យិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ តាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុត្ថារីទ្ធ

# មាតិកា

ទំព័រ

ប្រកាស ..................................................................................................i
បុព្វកថា ..................................................................................................ii
គណៈកម្មការ..........................................................................................iii
អារម្ភកថា...............................................................................................iv
មាតិកា....................................................................................................v
សេចក្ដីផ្ដើម............................................................................................
I. ការបង្ហាញអត្ថបទ...................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង........................................................................
III. ទិដ្ឋភាពទំនាស់.....................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ................................................................................
V. ទិដ្ឋភាពសង្គម.......................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ..................................................................................
VII. ទិដ្ឋភាពតម្លៃ.........................................................................................
VIII. ការសន្និដ្ឋាន.......................................................................................
IX. ឯកសារពិគ្រោះ.....................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង រាមកេរ្តិ៍

## សេចក្ដីផ្ដើម

រាមកេរ្តិ៍ជាស្នាដៃដ៏ល្បីល្បាញនៅក្នុងអក្សរសិល្ប៍ខ្មែរ។គេចាត់ទុកស្នាដៃដ៏ប្រពៃនេះក្នុងរឿងអក្សរសិល្ប៍នៃទ្វីបអាស៊ីទៀតផង។ អក្សរសិល្ប៍រឿងរាមកេរ្តិ៍ដែលកវីខ្មែរយើងបានកែច្នៃពីរឿងរាមាយណៈរបស់ឥណ្ឌា មកជារបស់ជាតិខ្លួន ក៏ព្រោះខ្មែរយើងកាលពីដើមឡើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសឥណ្ឌា ដែលជាបុព្វហេតុនាំឱ្យប្រទេសនេះ យកវប្បធម៌របស់ខ្លួនមកផ្សព្វផ្សាយដល់ជាតិខ្មែរ ហើយវប្បធម៌នេះវាស្រាបទៅនឹងផ្នត់គំនិតខ្មែរ ដែលខ្មែរគំនិតខ្មែរ។ ម៉្យាងទៀត រឿងរាមកេរ្តិ៍ខ្មែរជារឿងដែលបានទ្រទ្រង់តម្លៃវប្បធម៌ជាតិអរិយធម៌ សិល្បករខ្មែរបានឆ្លាក់ដំណើររឿងនៅតាមជញ្ជាំងប្រាសាទ។ សម័យក្រោយមករូបចម្លាក់ទាំងនោះបានប្រែក្លាយទៅជាក្បាច់របាំតន្ត្រីយ៉ាងរស់រវើកដែលភ្ញៀវជាតិអន្តរជាតិទទួលនិងឱ្យតម្លៃយ៉ាងខ្ពស់បំផុត។

រឿងរាមកេរ្តិ៍ខ្មែរត្រូវបានគេធ្វើការកែច្នៃពីរឿងរាមាយណៈឥណ្ឌាមកជារបស់ខ្មែរ ហើយស្របតាមចិត្តគំនិតជាតិយើង ដែលអាចឱ្យខ្មែរយើងទទួលយកបាន និងដឹងឮគ្រប់គ្នាទូទាំងប្រទេស ព្រមទាំងចាត់ទុករឿងនេះទៀតសោតជាអក្សរសិល្ប៍ជាតិ ហើយស្ថិតនៅក្នុងព្រលឹងជាតិខ្មែរជាដរាប។

## I- ការបង្ហាញអត្ថបទ

### ១- អត្ថបទ

- **ចំណងជើង** រឿងរាមកេរ្តិ៍
- **ប្រភព**

ជាទូទៅគេតែងយល់ថា រាមកេរ្តិ៍បានចម្លងចេញពីរាមាយណៈឥណ្ឌា ព្រោះនៅឥណ្ឌាមានរឿងដូចជារឿង ដូចខាងលើនេះ ចំនួនបីរឿង ៖

ក-រឿងរាមាយណៈជាស្នាដៃរបស់លោកវាល្មិកិនិពន្ធនៅសតវត្សទី៣មុន គ្រិស្តសករាជ គឺលោកសរសេររឿងនេះ ក្នុងបំណងរំឭកពីសង្គ្រាមសាសនារវាងពួកអារ្យ៉ន ដែលជាអ្នកកាន់សាសនាហិណ្ឌូនៅឥណ្ឌា និងពួកលង្កាជាអ្នកកាន់ព្រះពុទ្ធសាសនា។ តួអង្គព្រះរាមក្នុងរឿងនេះ ជាអវតារព្រះវិស្ណុមានមុខងារចុះមកកម្ចាត់សភាវៈអាក្រក់គឺក្រុងរាពណ៍នៅលង្កា។ លោកវាល្មិកិជាអ្នកកាន់សាសនាហិណ្ឌូនៅប្រទេសឥណ្ឌា លោកបានប្រើគ្រប់មធ្យោបាយក្នុងការដឹក

នាំមនុស្សឱ្យស្អប់ពួកលង្កា ព្រោះពួកគេមិនព្រមគោរពសាសនាហិណ្ឌូដូចខ្លួន។ គេហៅពួកលង្កាថាជាពួករក្សសៈ ឬពួកយក្ស ដែលជាតំណាងឱ្យសភាវៈអាក្រក់។

ខ-រឿងអធ្យាត្មរាមាយណៈ ជាស្នាដៃរបស់ពួករាមានិយមអ្នកប្រាជ្ញ នៃសាសនាវិស្ណុសរសេររឿងនេះឡើង ដើម្បីទាក់ទាញមនុស្សឱ្យចូលរួមកាន់សាសនានេះ ដែលមានព្រះរាមជាអវតារទី៧ជាទីសក្ការៈ។ពួកនេះបានយល់ថា គម្ពីររាមាយណៈរបស់លោកវាល្មិកិពុំទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការទាក់ទាញមនុស្ស ឱ្យមានជំនឿស៊ប់ទៅលើសាសនា ព្រះវិស្ណុនៅឡើយ។ដោយហេតុថាដំណើររឿងរាមាយណៈ មានពេលខ្លះព្រះរាមបានប្រព្រឹត្តខុសធ្វើឱ្យខូចឈ្មោះអាទិទេព។ ដូចនេះគេយល់ថាត្រូវតែរៀបចំរឿងនេះឡើងវិញ គឺធ្វើយ៉ាងណាឱ្យតួអង្គព្រះរាមកុំឱ្យមានកំហុសគឺត្រឹម ត្រូវ និងមានជ័យជំនះតាំងពីដើមរហូតដល់ចប់។

គ-រឿងរាមចរិតមានសៈជាស្នាដៃរបស់លោក ទុលស៊ីដាស។ លោកនិពន្ធរឿងនេះ ក្នុងសតវត្សទី១៦បំណងទាក់ទាញមនុស្សកុំឱ្យជឿលើអាទិទេពខ្លាំងពេកហើយលោកក៏ពុំបដិសេធនឹងអាទិទេពដែរ។លោកយល់ថា រឿងមុនៗល្អសម្រាប់ផ្សាយសាសនាមែនហើយ តែការលើកតម្លៃអាទិទេពហួសហេតុពេកនាំឱ្យបាត់បង់តម្លៃមនុស្ស។ រឿងរបស់លោកដែលមានលក្ខណៈជាអាទិទេពផង និងជាមនុស្សផង។

ប៉ុន្តែមានយោបល់មួយទៀតថា អ្នកនិពន្ធខ្មែរតែងរឿងរាមកេរ្តិ៍ក្នុងសម័យកាល ដែលសង្គមខ្មែរមានទំនាស់សាសនាគឺព្រហ្មញ្ញសាសនាវិស្ណុនិយមនិងព្រះពុទ្ធសាសនាមហាយាន។ អ្នកនិពន្ធខ្មែរពុំបានលើកតម្កើងតួអង្គព្រះរាម ដែលជាអវតាររបស់ព្រះវិស្ណុនោះទេ តែក៏ពុំហ៊ានចេញមុខបង្អាប់ចំៗនោះទេ ដោយគ្រាន់តែឆ្លៀតប្រើពាក្យសម្តីឃ្លា ប្រយោគរិះគន់ខ្លះៗ ដើម្បីបន្ថយតម្លៃព្រះរាមពីអាទិទេពតែប៉ុណ្ណោះ។ ក្នុងសម័យ ដែលវិស្ណុនិយមកំពុងតែមានឥទ្ធិពលខ្លាំងហើយអ្នកនិពន្ធហ៊ានរិះគន់បែបនេះប្រាកដជាមានទំនោរទៅរកព្រះពុទ្ធសាសនា។ព្រះរាមក្នុងរាមកេរ្តិ៍ខ្មែរពុំមែនមានមុខងារមកកម្ចាត់សភាវៈអាក្រក់ ដូចព្រះរាមក្នុងរាមាយណៈឥណ្ឌានោះទេ។ ទំនាស់រវាងព្រះរាម និងក្រុងរាពណ៍មានមូលហេតុច្បាស់លាស់ គឺការប៉ះទង្គិចរវាងនឹងផលប្រយោជន៍ និងផលប្រយោជន៍គ្នា។ ដូចនេះរាមកេរ្តិ៍ខ្មែរ កើតឡើងដោយមានទំនាស់សាសនាពិសេសដោយសារនិន្នាការរបស់ខ្មែរដែលចង់បន្ថយឥទ្ធិពលព្រហ្មញ្ញសាសនា។

ជាការពិតណាស់ រឿងរាមកេរ្តិ៍បានជ្រាបចូលមកក្នុងប្រទេសកម្ពុជា តាំងពីយូរលង់ណាស់មកហើយ គឺមុនសម័យមហានគរទៅទៀត ពោលគឺឃើញចារឹកទុកនៅលើផ្ទាំងសិលាប្រាសាទអង្គរវត្តបានយ៉ាងល្អឥតខ្ចោះ ដែលទាំងនេះសរបញ្ជាក់ឱ្យឃើញថាបុព្វបុរសខ្មែរកាលពីជំនាន់ដើមមានការចងចាំសាច់រឿងបានស្ទាត់ជំនាញខ្លាំងណាស់។តើរឿងរាមកេរ្តិ៍មានប្រភពពិតប្រាកដយ៉ាងណាដែរ?

ដោយផ្អែកតាមឯកសារ សារណាបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ក្រោមប្រធានបទប្រៀបធៀបរឿងរាមកេរ្តិ៍ និងរ៉ាមគៀន[1] យើងឃើញថាមានការលើកជាមតិប្លែកៗគ្នា ដោយសំអាងទៅលើហេតុផលផ្សេងៗរៀងខ្លួន។ ជាក់ស្តែងយើងឃើញមានយោប់របស់លោក សរ សារុន លើកឡើងថា សំអាងសើរឿងរាមកេរ្តិ៍របស់ព្រះអង្គម្ចាស់វឌ្ឍនឆាយាវង្ស ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យដែលរួមមាន១៦ខ្សែ គឺពីខ្សែទី១ ដល់ខ្សែទី១០ និងពីខ្សែទី៧៥ ដល់ខ្សែទី៨០ ឃើញមានការបាត់បង់ពីខ្សែទី១១ ដល់ខ្សែទី៧៤។ លោកជឿថារឿងដែលនៅសេសសល់នេះ មានអ្នកនិពន្ធពីររូបផ្សេងគ្នា ព្រោះដោយសំអាងលើការប្រើប្រាស់ពាក្យពេចន៍ និងវិធីសាស្រ្តមានការខុសប្លែកគ្នាឆ្ងាយ គឺពីខ្សែទី៧៥ដល់ខ្សែទី៨០មានការងាយស្រួលចំពោះអ្នកអាន អ្នកស្តាប់ណាស់។

ចំណែកខ្សែដែលបាត់បង់ទៅ គេក៏មានចម្ងល់ដែរថា តើវាបាត់ទៅណា? បាត់មែនឬទេ? បើបាត់ហេតុអ្វីចាំបាច់បង់លេខទៅបញ្ចប់នៅលេខ៨០ទៅវិញ?

ចំពោះមូលហេតុនៃការបាត់បង់នេះលោក លាង ហាប់អាន មានទស្សនៈថា[2] វាអាចនៅរាត់រាយតាមវត្តអារាម ឬទីជនបទនានាដែលយើងពុំបានដឹង ព្រោះទីវត្តអារាមមិនត្រឹមតែជាកន្លែងសម្រាប់បូជាខាងសាសនាប៉ុណ្ណោះទេ ថែមទាំងជាឃ្លាំងសម្រាប់រក្សាគម្ពីរក្បួនខ្នាតតម្រាបុរាណ ហើយបច្ចុប្បន្នវាជាសម្បត្តិវប្បធម៌ជាតិដ៏សំខាន់ទៀតផង។ បើមិនដូច្នេះទេ គម្ពីរក្បួនខ្នាតទាំងនេះអាចនឹងត្រូវពួកបរទេសដែលលុកលុយមានសៀម បារាំង យួន ជាដើមបានប្រមូលយកទៅតម្កល់ទុកជាឯកសាររបស់ពួកវា យកទៅកែច្នៃបន្លំតាមវិធីផ្សេងជាដើម ដូចជាតម្រានានា និងរបស់មានតម្លៃគ្រប់ប្រភេទ រួមទាំងសិលាចារឹករូបចម្លាក់ ក្បាលអ្នកតានានា ដែលខ្មែរបានបាត់បង់ទៅហើយ បែរជាឃើញមានការតាំងនៅសារមន្ទីរនៃទីក្រុងបាងកកទៅវិញ។

ទស្សនៈនេះស្របគ្នានឹងការបញ្ជាក់របស់លោក អៀវ កើស[3] ដែលយល់ថាសៀមមានទំនាក់ទំនងជាមួយខ្មែរតាំងពីសតវត្សទី៣ មកដល់សតវត្សទី១៣ ហើយបន្តរហូតដល់ពេលដែលសៀមដណ្តើមបានសុខោទ័យនៅសតវត្សទី១៣ បន្ទាប់មកគឺពេលដែលបានវាយដេញឱ្យខ្មែរចាកចោលក្រុងអង្គរ និងពេលដែលសៀមវាយបំបែកបន្ទាយលង្វែកនាចុងសតវត្សទី១៦ សៀមកាន់តែទទួលអរិយធម៌ពីយើងពេញទីដោយប្រមូលគម្ពីរ សាស្រ្តាតម្រាផ្សេងៗផង ព្រមទាំងកៀរអ្នកប្រាជ្ញរាជបណ្ឌិត ប្រជាជនខ្មែរនិងទ្រព្យសម្បត្តិមានតម្លៃជាច្រើនយកទៅស្រុកវាទៀត។ ភាពស្របគ្នានេះបញ្ជាក់ថា រឿងរាមកេរ្តិ៍ពិតជាត្រូវបាត់បង់ពីខ្សែទី១១ដល់៧៤មែន។

[1] សារណាបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សាប្រៀបធៀបរឿងរាមកេរ្តិ៍ និងរ៉ាមគៀន និស្សិត សេ សោភា គ.ស ២០០១

[2] សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្សែ៧០ដល់៨០ លាង ហាប់អាន ១៩៩៩ទំព័រទី២ដល់ទី៦

[3] ភាសាខ្មែរ អៀវ កើស ទំព័រ ២៦៧

ប៉ុន្តែបើក្រឡេកមើលទស្សនៈថ្មីមួយ ដែលបានបង្ហាញពីការយល់ឃើញផ្សេងពីនេះមួយទៀត នៅក្នុងសារណាបរិញ្ញាបត្ររបស់និស្សិត ជូ កែវ[4] ក្រោមចំណងជើងថា ប្រៀបធៀបតួអង្គរឿងរាមកេរ្តិ៍និងរាមាយណៈបានបកស្រាយថារឿងរាមកេរ្តិ៍អាចនឹងមិនត្រូវបានបាត់ទេពីព្រោះយល់ថាតាមដំណើររឿងត្រឹមខ្សែទី១០ នេះក្រុងរាពណ៍បានបាត់បង់កូនទាំង១០ និងសេនាពូកែអស់ទៅហើយពុំមានលទ្ធភាពធ្វើការបន្តចម្បាំងទៀតទេ បើទៅមិត្តឈ្មោះមូលផលម៍នៅនគរក្រៅចក្រវាឡគង់នឹងមានលទ្ធភាព បន្តសង្គ្រាមយ៉ាងច្រើន មួយខ្សែប៉ុណ្ណោះ ក៏នឹងត្រូវចប់ទៅហើយ ។ ចំណែកការបង់លេខរំលងនោះ ឯកសារដដែលបានបកស្រាយថា គឺដើម្បីឱ្យស្របទៅនឹងជន្មាយុរបស់ព្រះពុទ្ធ គឺកំឡុងពេលដែលអ្នកនិពន្ធជាពុទ្ធសាសនិកដែលព្យាយាមទាញរឿងរាមកេរ្តិ៍ឱ្យខុសពីរាមាយណៈ ដោយហេតុថាព្រះពុទ្ធមានព្រះជន្ម៨០ព្រះវស្សា ទើបអ្នកនិពន្ធបង់លេខដេញពី៨០ចុះមកវិញ។

ផ្ទុយមកវិញតាមទស្សនៈលោក យឹង ហុកឌីយល់ថា[5] ខ្សែទី៨០មិនមែនជាទីបញ្ចប់នៃរឿងរាមកេរ្តិ៍ទេ ហើយនៅចន្លោះខ្សែទី១០ដល់ទី៧៥ ដោយបាត់ឯកសារទៀតផង។ ដោយពឹងលើការស្រាវជ្រាវចាប់តាំងពីឆ្នាំ១៩៦៧មកដល់បច្ចុប្បន្ននៅក្នុងស្រុក និងក្រៅស្រុក លោកបានរកឃើញឧបកថាមួយទៀតដែលនៅក្នុងច្បាប់នានា ហើយដែលអ្នកឯកទេសបានធ្វើការសិក្សាមកហើយ។ ឯកសារនេះ តម្កល់នៅបណ្ណាល័យអាស៊ី ក្រុងប៉ារីស ចុះលេខ៣៩B ដែលជាអំណោយរបស់លោក អែ ម៉ូនីញេ (E.Aymonier)។

តាមការអះអាងនេះ យើងឃើញថាមានការស្របគ្នានឹងមតិលោក លាង ហាប់អាន ពីបញ្ហាដែលថា រឿងរាមកេរ្តិ៍ខ្សែកណ្តាលនេះ ត្រូវបានបាត់បង់ ដោយការយាយីពីបរទេស លោកបានបង្ហាញពីឯកសាររបស់ខ្មែរតាំងពីក្បួនខ្នាត គម្ពីរក្រាំងស្លឹករឹត ដែលត្រូវបានគេយកទៅទុកនៅក្នុងបណ្ណាល័យនៃសារមន្ទីរ ឯបរទេសមានទីក្រុងប៉ារីសខ្លះទីក្រុងឡុងដ៍ខ្លះ និងប៊ែរឡាំងខ្លះ។ ពួកគេបានធ្វើការដឹកជញ្ជូនទាំងកប៉ាល់ៗទៅគ្រប់ទេសគេ។

ចំណែកនៅឯទីក្រុងមូស្គូ ក្នុងបណ្ណាល័យលេនីនមានសាស្ត្រាចារ្យខ្មែរច្រើនណាស់ តែគេបែរជាដាក់ថាក្បួនទាំងនេះជាតម្រារបស់សៀមទៅវិញ។ ប៉ុន្តែការពិតក្បួនខ្នាតទាំងនេះសុទ្ធសឹងជារបស់ខ្មែរ។ ឧបកថាដែលទើបនឹងរកឃើញថ្មីនេះ មានចំណងជើងថា « រាមកេរ្តិ៍កាលវៃយរាពណ៍សណ្តំយកព្រះរាមបាន»។ ការសិក្សារឿងរាមកេរ្តិ៍កន្លងមកពុំទាន់ឃើញមានរឿងថ្មីនេះនៅឡើយទេ ព្រោះគេច្រើនតែនិយមវិភាគនិងបកប្រែជាភាសាបារាំង ឬអង់គ្លេស។តែរឿងរាមកេរ្តិ៍របស់ព្រះអង្គម្ចាស់វឌ្ឍនឆាយាវង្សដែលផ្សាយចេញពីពុទ្ធសាសនបណ្ឌិតក្រោមការដឹក

[4] សារណារបស់និស្សិត ជូ កែវ១៩៩៩ទំព័រទី៣-៤

[5] ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ យឹង ហុកឌី ១៩៩៧ទំព័រទី១១៥-១១៦

នាំរបស់លោកស្រី S.Karpeles លោក យឹង ហុកឌី យល់ថាឯកសារថ្មីនេះមិនទាន់គ្រប់គ្រាន់ទេ ពោលគឺគ្រាន់តែជាផ្នែកមួយដែលផ្សារភ្ជាប់រឿងប៉ុណ្ណោះ ពោលគឺខ្វះឧបកថាស្ដីអំពីការបរាជ័យបញ្ចប់របស់រាពណ៍ ការលុយភ្លើងជាការបង្ហាញភក្ដីភាពរបស់នាងសីតា និងការត្រឡប់ចូលអយុធ្យារបស់ព្រះរាម ព្រះលក្ស្មណ៍ និងនាងសីតា។ ដូច្នេះប្រសិនបើមានឧបកថា ៣ឬ៤ បន្ថែមទៀតនោះ រាមកេរ្តិ៍ខ្មែរប្រហែលជានឹងអាចពេញលេញគ្រប់គ្រាន់ជាមិនខាន។

ឧបកថា«វៃយរាពណ៍សណ្ដំយកព្រះរាមបាន» ដែលយើងរកឃើញនេះ ជាឯកសារសរសេរដៃនៅលើក្រដាសជាបទពំនោលទាំងអស់មាន៦៩វគ្គបានសេចក្ដីថាសរុបត្រូវជា១៩២៩ឃ្លា តែខ្វះ១ឃ្លាក្នុងវគ្គ៩៩៦។ ឯកសារនេះសរសេរជាអក្សរជ្រៀង ហើយដែលលោកអែ ម៉ូនីញេ(Aymonier) បានសិក្សាជាដំបូងនៅខែតុលា ១៨៩៩ ដោយយោងតាមសំណេរដោយដៃខ្លះនៅលើទំព័រដើម។ លោកហ៊ានបញ្ជាក់បែបនេះគឺយោងលើឯកសារ CF.une episode du Ramakerit : Rama endormi par les malesfics de Vairy Radan, Paris L Harmattan, 1995,213p+Photos។ ក្នុងកម្រងសិក្សាកថានេះមានសេចក្ដីផ្ដើម ការសិក្សាប្រៀបធៀបនិងរាមកេរ្តិ៍ពោដោយតាចក់ រាមកេរ្តិ៍ថៃនិងរាមកេរ្តិ៍ គំនូរនៅវិហារព្រះកែវមរកតនៅភ្នំពេញព្រមទាំងមានសេចក្ដីប្រែជាភាសាបារាំង ហើយភ្ជាប់ជាមួយនូវអត្ថបទជាភាសាខ្មែរតាមអក្ខរាវិរុទ្ធច្បាប់ដើមនិងអក្ខរាវិរុទ្ធទំនើប ដោយយោងទៅលើវចនានុក្រមខ្មែរបោះពុម្ពផ្សាយនៅពុទ្ធសាសនបណ្ឌិត។

- **ប្រភេទ**

បើគេពិនិត្យតាមសាច់រឿងវិញឃើញថាស្នាដៃនេះគឺមានលក្ខណៈវែងអន្លាយពោរពេញទៅដោយសង្គ្រាមតស៊ូប្រយុទ្ធគ្នា អស់ពេលយ៉ាងយូរគេ អាចចាត់ទុករឿងរាមកេរ្តិ៍ក្នុងប្រភេទវីរកថា។ តែបើពិនិត្យទៅលើអត្ថរូបនៃរឿងប្រកបទៅដោយកំណាព្យ ហើយចែកជាវគ្គខ្លីៗ ជាឈុតជាឆាកដាច់ៗ ទៅតាមដំណើររឿង សម្រាប់សម្ដែងដោយតម្រូវឱ្យមានភ្លេងប្រគំផងនោះ រឿងនេះអាចចាត់ទុកក្នុងប្រភេទនាដ្យកថាទៅវិញ។ ប៉ុន្តែបើផ្អែកតាមលក្ខណៈទាំងពីរនេះ រាមកេរ្តិ៍ គឺជា «នាដ្យកថា» ប្រកបទៅដោយ«វីរលក្ខណៈ»។

- **ចលនា**

ដំណើររឿងបានឱ្យឃើញ ថាពេលខ្លះ ព្រះរាមមានសមត្ថភាពអស្ចារ្យ គឺខ្លាំងក្លាហួសពីមនុស្សធម្មតា។ដូចជានៅពេលផ្ដើមរឿងកវីបានបង្ហាញពិធីបូជាយញ្ញតាមព្រហ្មញ្ញសាសនា គឺហោមពិធីរបស់ឥសីពិស្វាមិត្រ។ តាមភស្តុតាងខាងលើនេះ គេអាចសន្និដ្ឋានថា រឿងរាមកេរ្តិ៍ស្ថិតក្នុងចលនាព្រាហ្មណ៍និយម។ តែពេលខ្លះទៀតព្រះរាមបែរជាមានលក្ខណៈ ជាមនុស្សទៅវិញគឺដោះស្រាយបញ្ហាតាម ដូចជាមនុស្សធម្មតា ដែលចេះគំរាមកំហែងកុហក បោកប្រាស់ប្រច័ណ្ឌជាដើម។ តាមហេតុផលនេះ អាចនិយាយថា រឿងរាមកេរ្តិ៍មានដំណោះស្រាយតាម

បែបមនុស្សសាមញ្ញ ដែលមានទំនោរទៅរកមនុស្សនិយម។

ទន្ទឹមនឹងនេះក្នុងស្នាដៃខាងលើ គេសង្កេតឃើញថាបើព្រះរាមមានសកម្មភាពដ៏ត្រឹមត្រូវនេះកវីហៅព្រះរាមតាមពុទ្ធសាសនាថា«ពុទ្ធង្កូរ»គឺសំដៅព្រះរាម(ខ្សែ១ទំព័រ៤៨)កន្សែសារពេជ្ជគឺសំដៅនាងសីតា(ខ្សែ២ទំព័រ៤)។ពេលខ្លះទៀតមានយកបញ្ហាកម្មផលក្នុងទ្រឹស្តីពុទ្ធនិយមមកបង្ហាញដែរ។ជាក់ស្តែងពេលនាងសីតាព្រាត់ពីព្រះរាមកវីប្រើពាក្យកម្មពៀរវេរា។ដូចនេះគេអាចសន្និដ្ឋានបានថា កវីនិពន្ធរឿងរាមកេរ្តិ៍ទទួលឥទ្ធិពលពីព្រះពុទ្ធសាសនាយ៉ាងច្រើន។

## ២- អ្នករៀបរៀង

- **ឈ្មោះអ្នករៀបរៀង** អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស

បើពិនិត្យតាមអត្ថន័យរឿងឃើញថា រាមកេរ្តិ៍ខ្មែរអាចតាក់តែងឡើង ក្នុងពេលដែលប្រទេសខ្មែរកំពុងមានទំនាស់សាសនា គឺក្នុងអំឡុងសតវត្សទី១១ទៅទី១២។ ចំណែកនៅតាមជញ្ជាំងប្រាសាទវិញគេឃើញមានរូបចម្លាក់មួយចំនួន ដែលទាក់ទងទៅនឹងដំណើររឿងរាមកេរ្តិ៍និងរាមាយណៈមាននៅតាមជញ្ជាំងប្រាសាទដូចជាប្រាសាទកោះកែ(ដើមស.វទី១០) ប្រាសាទបន្ទាយស្រី (កណ្តាលសតវត្ស ទី១០) ប្រាសាទបាពួន(ដើមស.វទី១១) ប្រាសាទអង្គរ(ដើម ស.វទី១២)។ចំណែកភាសាសរសេរក្នុងឯកសាររឿងរាមកេរ្តិ៍ របស់អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស ដែលយើងកំពុង សិក្សាសព្វថ្ងៃឃើញថាបទនិពន្ធនេះ សរសេរក្រោយសម័យអង្គរ ជាពិសេសគឺចាប់ពីខ្សែទី៧៥ដល់ខ្សែ៨០ ជាអត្ថបទងាយអានងាយយល់ ប្រហាក់ប្រហែលនឹងភាសាសរសេរទំនើបនេះដែរ។

ចំពោះអ្នកនិពន្ធរឿងរាមកេរ្តិ៍ បានឱ្យដឹងថា គឺមានការ សោកស្តាយយ៉ាងខ្លាំង ដោយមិនអាចស្រាវជ្រាវរកឃើញឈ្មោះអ្នកនិពន្ធឡើយ។ តែគេអាចសន្និដ្ឋានបានថា អ្នកនិពន្ធរាមកេរ្តិ៍ខ្មែរគឺជាអ្នកប្រាជ្ញដែលចេះភាសាសំស្ក្រឹតច្បាស់លាស់និងមានទំនោរទៅរកព្រះពុទ្ធសាសនា។ម្យ៉ាងទៀត បើយោលតាមពាក្យពេចន៍ប្រហែលជា មានអ្នកនិពន្ធ២នាក់គឺម្នាក់និពន្ធពីខ្សែ១ដល់ខ្សែ១០ម្នាក់ទៀត និពន្ធពីខ្សែ៧៥ ដល់ខ្សែ៨០។ ដូច្នេះបញ្ហាអ្នកនិពន្ធរាមកេរ្តិ៍ខ្មែរពុំទាន់មានអ្វីច្បាស់លាស់នៅឡើយទេ តែសង្ឃឹមថាអ្នកស្រាវជ្រាវជំនាន់ក្រោយ នឹងជួយស្រាវជ្រាវបន្តទៀត។

- **ជីវប្រវត្តិ** អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស[6]

ទ្រង់ស៊ីសុវត្ថិវឌ្ឍឆាយាវង្ស(១៨៩១-១៩៧២)បានមកបន្តការសិក្សា នៅសាលាវិទ្យាសាស្ត្រនយោបាយនៅប៉ារីសប្រទេសបារាំងហើយត្រឡប់ចូលកម្ពុជាវិញ។ ទ្រង់បានរៀប

[6] សង្ខេបរឿងរាមកេរ្តិ៍ សរសារុន សាស្ត្រាចារ្យនៅវិទ្យាស្ថានស្រាវជ្រាវឯកសារគរុកោសល្យ

អាពាហ៍ពិពាហ៍ជាមួយអ្នកម្នាង ស្បៃរឿងនាឆ្នាំ១៩២១។បន្ទាប់មកបានទទួលការតែងតាំងជានាយករដ្ឋមន្ត្រី (២៥/០៧/១៩៤៧-២០/០២/១៩៤៨)។ បន្ទាប់ពីទ្រង់ស៊ីសុវត្ថិវង្សឆាយាវង្សមកជាបន្តបន្ទាប់មកទៀតមានបុត្រាមួយអង្គក្នុងព្រះរាជវង្សដែលកើតរវាងចុងសតវត្សទី១៩ បានមកបន្តវិជ្ជានៅប្រទេសបារាំងគឺមានព្រអង្គម្ចាស់នរោត្តមអារ៉េណូយុគន្ធ(១៨៩៦-១៩៦៩?) ដែលបានមករៀនទស្សនវិជ្ជានៅប្រទេសបាំង ហើយទ្រង់បាននិពន្ធសៀវភៅមួយចំនួន។ទន្ទឹមនឹងជំនាន់ជំនាន់ព្រះអង្គម្ចាស់អារ៉េណូយុគន្ធរមានព្រះអង្គម្ចាស់មួយអង្គទៀតចៅហ្លួង នរោត្តមត្រូវជាបុត្រព្រះអង្គម្ចាស់

## ៣- **កាលកំណត់រៀបរៀង**

### - ថ្ងៃ ខែ ឆ្នាំ រៀបរៀង

ដោយហេតុថា រឿងរាមកេរ្តិ៍បានជ្រាបចូលក្នុងប្រទេសកម្ពុជាតាំងពីយូរលង់ណាស់មកហើយ តាមរយៈព្រហ្មញ្ញសាសនាហើយត្រូវបានគេធ្វើការកែច្នៃបន្សាំទៅនឹងស្ថានភាពសង្គមខ្មែរដែលមានការវិវត្តខាងនយោបាយនិងសាសនាឥតឈប់ឈរ ទើបបណ្តាលឱ្យបាត់បង់ព័ត៌មានរបស់អ្នកនិពន្ធ និងកាលបរិច្ឆេទទៅ ដោយពុំមានឯកសារណាបន្សល់ទុកឡើយ។

ហេតុនេះហើយ ទើបមានអ្នកស្រាវជ្រាវបានបង្ហាញកាលបរិច្ឆេទផ្សេងៗ គ្នាទៅតាមហេតុផលរៀងខ្លួនដូចជា៖

យោបល់ទី១ បណ្ឌិត មីសែលត្រាណេ[7]តាមរយៈសៀវភៅ «ការសិក្សារឿងរាមកេរ្តិ៍» បានអះអាងថា រឿងរាមកេរ្តិ៍បែបខ្មែរ ក្លាយទៅជាឧបករណ៍ស្ថិតនៅជាប់ដួងព្រលឹងខ្មែរ ក្នុងកែវភ្នែក និងក្នុងត្រចៀកខ្មែរ តាំងពីពាក់កណ្តាលសតវត្សទី៦ រហូតមកដល់សព្វថ្ងៃនេះដូចជាភស្តុតាង ជារូបចម្លាក់ព្រះលក្ខណ៍រាមបរមសូរ និងពលរាម នៅក្នុងរចនាបថភ្នំដា ជាសិលាចារឹក និងចម្លាក់នៅតាមជញ្ជាំងប្រាសាទខ្មែរនៅសម័យមុនអង្គរជាដើម។

ប៉ុន្តែដោយឡែក សាច់រឿងបែបខ្មែរត្រូវគេលើកយកមកសិក្សា ដើម្បីបង្ហាញពីជម្លោះរវាងព្រាហ្មណ៍សាសនា និងពុទ្ធសាសនាមហាយានក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី២ និងជ័យវរ្ម័នទី៨ នាសតវត្សទី១៣ទើបបានជាមានការតាក់តែងបង្អាប់តួអង្គព្រះរាមដែលជាអវតាររបស់ព្រះវិស្ណុឱ្យធ្លាក់ចុះមកជាមនុស្សធម្មតា តែឃោរឃៅព្រៃផ្សៃ ឥតគុណធម៌ ពោលគឺអន់ជាងមនុស្សសាមញ្ញទៅទៀត នេះសបញ្ជាក់ពីទឹកចិត្តនិងទំនោររបស់អ្នកនិពន្ធដែលជាពុទ្ធសាសនិកយ៉ាងពិតប្រាកដ។

យោបល់ទី២លោកញ៉ុកថែម[8]បានបញ្ជាក់នៅក្នុងតារាងប្រវត្តិសាស្ត្រអក្សរសិល្ប៍ខ្មែរ៖

-ខ្សែទី១ដល់ខ្សែទី១០ ប្រហែលរៀបរៀងនៅសតវត្សទី១៧-១៨ រវាងរជ្ជកាលព្រះបាទ

---

[7] ការសិក្សារឿងរាមកេរ្តិ៍មីសែលត្រាណេ ១៩៩៥ អារម្ភកថាទំព័រទី១ បន្ទាត់ទី៨ដល់ទី១៣

[8] ការសិក្សារឿងរាមកេរ្តិ៍ មីសែលត្រាណេ ១៩៩៥ ទំព័រទី៣

ជ័យជេដ្ឋាទី៤ មកទល់នឹងព្រះអង្គអេង ហើយតែងដោយអ្នកនិពន្ធម្នាក់ សាច់រឿងហាក់ដូចជាចប់មួយអន្លើទៅហើយ។

-ខ្សែទី៧៥ដល់ខ្សែទី៨០ប្រហែលតែងក្នុងរជ្ជកាលរបស់ព្រះពញាអង្គអេងមកទល់ពេលនឹងអង្គឌួងតែងដោយអ្នកនិពន្ធម្នាក់ផ្សេងទៀត។

យោបល់ទី៣៖អ្នកស្រី ពៅ សាវរស[9] បន្ទាប់ពីបានធ្វើការស្រាវជ្រាវបន្តអំពីលោកសាស្ត្រាចារ្យម៉ាក ទីនី ( Martini ) ដែលជាគ្រូរូចមក អ្នកស្រីបានយករឿងរាមកេរ្តិ៍មកសិក្សាតាមបែបវិទ្យាសាស្ត្រដោយគិតតាមភាសាវិទ្យា និងអត្ថបទបកប្រែហើយបោះពុម្ពចេញចំនួន ៥ភាគ ប៉ុន្តែពុំទាន់ចប់នៅឡើយទេអ្នកស្រីបានចែករឿងរាមកេរ្តិ៍ជាពីរជំពូកគឺ៖

-រាមកេរ្តិ៍ផ្នែកទី១ ត្រូវនឹងសៀវភៅពុទ្ធសាសនបណ្ឌិតភាគ១ដល់ភាគ១០ មានទាំងអស់ ៥០៣៤ វគ្គកំណាព្យតែងឡើងរវាងសតវត្សទី១៦-១៧។

-រាមកេរ្តិ៍ផ្នែកទី២ ត្រូវនឹងសៀវភៅពុទ្ធសាសនបណ្ឌិតភាគ៧៥ ដល់៨០មានទាំងអស់ ១៧៧៩វគ្គកំណាព្យតែងឡើងរវាងពាក់កណ្ដាលសតវត្សទី១៨។

ការបញ្ជាក់សករាជ និងសម័យកាលនោះយោងតាមសៀវភៅបែបនិរុត្តិសាស្ត្រ គឺសាច់រឿងត្រូវបានតែងសម្រាប់ស្មូត្រ ឬសម្ដែងជារបាំល្ខោនខោលល្ខោនស្បែក ដោយមានរចនាបថផ្ដើមសេចក្ដីជាពិសេសដូចជាបទសំណារសៀម បទសំណារមន បទពំនោល។ល។

យោបល់ទី៤៖ លោកស សារុន បានធ្វើការវិភាគទៅលើកាលបរិច្ឆេទរឿងដោយយោងទៅលើវិធីបីយ៉ាងគឺ:

វិធីទី១៖ គេអាចប្រៀបធៀបពាក្យសម្ដី ឃ្លាប្រយោគ ដែលមានប្រើក្នុងអត្ថបទ រឿងរាមកេរ្តិ៍ខ្សែទៅអក្សរសិល្ប៍សិលាចារឹកនៅសម័យណាមួយ។

វិធីទី២៖គេអាចប្រៀបធៀបដំណើររឿងរាមកេរ្តិ៍ទៅនឹងដំណើររឿដែលមានឆ្លាក់នៅតាមជញ្ជាំងប្រាសាទ គេអាចស្រាវជ្រាវរកឃើញមានប្រាសាទបួនដែលមានឆ្លាក់ដំណើររឿងទាក់ទងនឹងរឿងរាមកេរ្តិ៍ដូចជា៖

-ប្រាសាទកោះកេរ (ដើមសតវត្សទី១០)

-ប្រាសាទបន្ទាយស្រី (ពាក់កណ្ដាលទី សតវត្សទី១១)

-ប្រាសាទអង្គរវត្ត (ពាក់កណ្ដាលទី១ សតវត្សទី១២)

តាមរយៈចម្លាក់ទាំងឡាយនេះគេនៅតែជួបប្រទះការពិបាកក្នុងការបញ្ជាក់កាលបរិច្ឆេទនៃរឿងរាមកេរ្តិ៍ខ្មែរ ពីព្រោះដំណើររឿងនៃចម្លាក់ទាំងអស់នេះបានទាក់ទងនឹងរឿងរាមកេរ្តិ៍ខ្មែរផង និងជារឿងរាមាណៈណ្ឌាផង។

---

[9] សិក្សាសង្ខេបរឿងរាមកេរ្តិ៍ សរ សារុន ទំព័រទី១ បន្ទាត់ទី១៤

វិធីទី៣៖ គេអាចប្រៀបធៀបសង្គមបរិយាកាសដែលមាននៅក្នុងអត្ថបទរឿងរាមកេរ្តិ៍ខ្មែរទៅនឹងសង្គមបរិយាកាសដែលកើតមាននៅសម័យណាមួយ។ តាមដំណើររឿងរាមកេរ្តិ៍ខ្មែរគេអាចដកស្រង់នូវសង្គមបរិយាកាសមួយ ដែលស្ថិតនៅលើទំនាស់សាសនា រវាងសាសនាព្រះវិស្ណុ នឹងព្រះពុទ្ធសាសនា។ អ្នកនិពន្ធខ្មែរគ្មានបំណងលើកតម្កើងព្រះរាម ហើយពុំហ៊ានចេញមុខរិះគន់ព្រះរាមដែរគឺគ្រាន់តែឆ្លៀតឱកាសតាមដំណើររឿង ដើម្បីបញ្ចុះតម្លៃព្រះរាម។ ជួនកាលអ្នកនិពន្ធប្រើវិធីលើកតម្កើង ព្រះរាមបន្ទាប់មកទម្លាក់ចុះមកវិញ។ តាមសង្គមបរិយាកាសនេះគេអាចស្ទាបស្ទង់បានថា ពេលវេលានៃការតែងរឿងរាមកេរ្តិ៍ខ្មែរ ពុំមែនស្ថិតនៅក្នុងបរិយាកាសពុទ្ធនិយមទេ។ គេអាចធ្វើសម្មតិកម្មថាជាបរិយាកាសវិស្ណុនិយមដោយអ្នកនិពន្ធពុំហ៊ាន ចេញមុខប្រឆាំងនឹងព្រះរាមដោយវិធីត្រង់ទេ។

ការបញ្ចូលដំណើររឿងដែលទាក់ទងនឹងសង្គមបរិយាកាសខ្មែរបែបនេះ បានធ្វើឱ្យរឿងរាមកេរ្តិ៍ខ្មែរមានតម្លៃពិសេសរបស់ខ្មែរ។ ដូច្នេះតាមរយៈបរិយាកាស នៃទំនាស់សាសនា ដូចយើងបានអធិប្បាយរួចមកហើយ ធ្វើឱ្យយើងសន្និដ្ឋានថារឿងរាមកេរ្តិ៍ តែងឡើងប្រហែលចុងសតវត្សទី១២ និងដើមសតវត្សទី១៣។

- **ថ្ងៃ ខែ ឆ្នាំ នៃការបោះពុម្ព** ព.ស.២៥៣៩ ដោយពុទ្ធសាសនបណ្ឌិត្យ

## ៤- សង្គមបរិយាកាស

**- កាលប្រវត្តិ**

រឿងរាមកេរ្តិ៍ គឺជាការប្រែសម្រួលនៃរឿងរាមាយណៈ ដែលនិយាយពីរឿងចម្បាំងមួយយ៉ាងធំក្នុងប្រទេសឥណ្ឌាពីបុរាណ ហើយគេបានចាត់ទុកដាក់ថា គេចាត់ទុកថាជាស្នាដៃរបស់លោកវាល្មិកិ។ ពាក្យពេចន៍ដែលបានប្រើក្នុងរឿងនេះ ជាភាសាបាលីសំស្ក្រឹតក្នុងរវាងព.ស. ប្រមាណជា ៧៥០ឆ្នាំ ហើយក៏ផ្សព្វផ្សាយចេញពីខេត្តមួយទៅខេត្តមួយ។ អ្នកដែលនាំរឿងនេះនេះទៅនិយាយផ្សាយ ក៏ពោលបន្ថែមបន្ថយ ឬបំពេញតាមអធ្យាស្រ័យរបស់ខ្លួន ដើម្បីឱ្យបានពីរោះដល់អ្នកស្តាប់។ ជួនកាលទៀត មានយករឿងរ៉ាវដែលមានក្នុងស្រុកផ្សេងៗ មកបញ្ចូលជាមួយបន្ថែមទៀត ដើម្បីឱ្យបានអ្នកស្រុកកាន់ចូលចិត្តរឿងថែមទៀត។ ហេតុនេះហើយបានជាភាសាសំស្ក្រឹតដែលនិទានតៗគ្នាពីមួយទៅមួយ បានក្លាយទៅជាការគោរព និងជាអក្សរសាស្ត្រសម្រាប់សាសនាដ៏សំខាន់ ក៏ក្លាយទៅជាអំណាចនៃអក្សរសាស្ត្រ សម្រាប់ស្រុកភូមិនីមួយៗ។

**- ព្រឹត្តិការណ៍សំខាន់**

រឿងរាមកេរ្តិ៍ជាស្នាដៃអក្សរសិល្ប៍ តំណាងឱ្យសង្គមពេលនោះកំពុងមានទំនាស់វិបត្តិសាសនារវាងពុទ្ធសាសនានិងព្រាហ្មណ៍សាសនា រវាងនិកាយវិស្ណុនិងសិវៈ។

## II. ការវិភាគអត្ថបទ

## ក.ស្ថានភាពរឿង

- **សង្ខេបរឿង**

**❖ខ្សែទី១**

នៅនគរឰយុធ្យា មានមហាក្សត្រមួយព្រះអង្គព្រះនាមព្រះបាទទសរថព្រមទាំងមហេសី ៣ព្រះអង្គ គឺនាងកោសកល្យាណ នាងកៃកេសី និងនាងសមុទ្រ។ មហេសីទាំងបីអង្គនេះ គ្មានព្រះរាជបុត្រសោះ ព្រះអង្គក៏ធ្វើពិធីបូជាយញ្ញសុំបុត្រដោយយកសេះទៅដុតទាំងរស់។ ជាមួយនោះព្រះនារាយណ៍ក៏កាឡាខ្លួនជាមនុស្សខ្មៅម្នាក់យក បាយបាយាស[10] មកថ្វាយព្រះបាទទសរថ ហើយព្រះអង្គក៏បានយកបាយនោះចែកជាបីចំណែក ឱ្យទៅមហេសីទាំងបីអង្គបានសោយ គ្រប់ៗគ្នា។ ក្រោយមកមហេសីទាំងបីអង្គ ក៏មានបុត្រមែន គឺនាងកោសកល្យាណ ប្រសូតបានព្រះរាម នាងកៃកេសីប្រសូតបានព្រះភិរុត ចំណែកនាងសមុទ្រវិញ ប្រសូតបាន ព្រះលក្ស្មណ៍ និងព្រះសុត្រុត។

លុះក្រោយមកព្រះរាមនិងព្រះលក្ស្មណ៍ក៏បានយាងចេញទៅរៀនសិល្បជាមួយនឹងឥសីពិស្វាមិត្រ លុះត្រាតែចប់គម្ពីរវេទ។ បន្ទាប់ពីសិក្សាចប់រួចមក ឥសីពិស្វាមិត្រក៏បានរៀបចំធ្វើហោមពិធីជាកិត្តិយសថ្វាយដល់អ្នកទាំងពីរ។ នៅថ្ងៃមួយ មានយក្សកាឡាខ្លួនជា ក្អែកខ្មៅដ៏ធំមួយឈ្មោះកាកនាសូរ មកហោះឆាបបំផ្លាញអាស្រមរបស់ឥសីខ្ទេចខ្ទីអស់។ឥសីខឹងយ៉ាងខ្លាំង ហើយក៏ជបធ្នូសរឱ្យព្រះរាមបាញ់សម្លាប់កាកនាសូរនោះមួយរំពេច។

នៅឯនគរមិថិលា នាងសីតាជាបុត្រចិញ្ចឹមរបស់ព្រះជនកមានវ័យគ្រប់ការ។ ព្រះអង្គក៏បានរៀបចំពិធីលើកធ្នូស ដើម្បីជ្រើសរើសគូស្រករឱ្យនាង។ ឥសីពិស្វាមិត្រ ក៏នាំព្រះរាម និងព្រះលក្ស្មណ៍ទៅចូលរួមប្រឡងលើកធ្នូសររបស់ព្រះបាទជនក ដើម្បីយកនាងសីតាធ្វើជាមហេសីដែរ។ នៅទីនោះមានបេក្ខជនជាច្រើនរូបមកពីភពទាំងបី។សូម្បីតែព្រះឥសូរក៏ចុះមកប្រឡងនឹងគេដែរ។ ប៉ុន្តែគ្មានបេក្ខជនណាមួយលើកធ្នូសរនោះរួចឡើយ គឺមានតែព្រះរាមមួយអង្គទេដែលលើករួច។ ព្រះបាទជនក៏ឱ្យដំណឹងទៅព្រះបាទទសរថ ដើម្បីយាងមកជាអធិបតី ក្នុងពិធីរាជាភិសេករវាងព្រះរាម និងនាងសីតា។ ក្រោយមកព្រះរាម ព្រះក្ស្មណ៍ នាងសីតានិងព្រះបាទទសរថបានធ្វើដំណើរនិវត្តន៍មកនគរឰយុធ្យាវិញ ហើយបានជួបជាមួយមហាគ្រូសិល្បឈ្មោះរាមបរមសូរនៅកណ្តាលផ្លូវ។ រាមបរសូរបានចោទប្រកាន់ថា ព្រះរាមលួចឈ្មោះរបស់ខ្លួន ត្រូវតែមកសុំទោសខ្លួន។ព្រះរាមក៏បានផ្ចាញ់រាមបរមសូរក្នុងពេលនោះ។លុះមកដល់នគរព្រះបាទទសរថមានបំណង ចង់ឱ្យព្រះរាមឡើយសោយរាជ្យស្នងព្រះអង្គ ប៉ុន្តែត្រូវនាងកៃកេសីទូល

[10] ឈ្មោះបាយចម្អិនលាយ នឹងទឹកដោះគោ ព្រមទាំងគ្រឿងផ្សំមានតម្លៃផ្សេងៗ)

ជំទាស់ដោយសំអាងលើពាក្យសត្យ ដែលព្រះបាទទសរថបានសន្យាថា នឹងឱ្យបុត្ររបស់នាងកៃកេសី គឺព្រះភិរុតឡើងសោយរាជ្យនៅពេលដែលច្បាំងឈ្នះព្រះអាទិត្យ។ ព្រះបាទទសរថមានគំនិតចង់បំបែកនគរ ជាពីរផ្នែកប៉ុន្តែនាងកៃកេសី មិនយល់ព្រមហើយក៏តម្រូវឱ្យព្រះរាមចេញទៅក្នុងតាំងសិល្ប៍ក្នុងព្រៃចំនួន១៤ឆ្នាំ ទើបអាចចូលមកសោយរាជ្យសម្បត្តិវិញ។ ព្រះលក្ស្មណ៍ខ្ញាល់យ៉ាងខ្លាំងបម្រុងសម្លាប់នាងកៃកេសី ប៉ុន្តែត្រូវព្រះរាមហាមឃាត់។ បន្ទាប់មកព្រះរាម ព្រះលក្ស្មណ៍និងនាងសីតាក៏បានធ្វើដំណើរចូលព្រៃ ហើយជួបនឹងអ្នកថ្មើរព្រៃម្នាក់ឈ្មោះ កូខ័នដែលមានរូបរាងអាក្រក់ ប៉ុន្តែមានចិត្តល្អជួយរំលែកទុក្ខព្រះរាមដោយបានផ្គត់ផ្គង់ម្ហូបអាហារផ្សេងៗថ្វាយដល់ព្រះរាម។ ព្រះរាមចាត់ទុកកូខ័ន ជាបងប្អូនបង្កើត ប៉ុន្តែដោយព្រះអង្គពុំអាចនៅទីនោះបានក៏លាកូខ័នទៅភ្នំចិត្រកូដ ដើម្បីបួសជាឥសី ។

### ❖ខ្សែទី២

នៅពេលដែលព្រះរាមធ្វើដំណើរចេញពីកូខ័នមក ព្រះរាម បានទតឃើញព្រៃ មួយកំពុងឆេះដោយកំដៅព្រះអាទិត្យ។ជាមួយនោះស្លឹកឈើដែលខ្លោច ផ្កាឈើដែល ឆេះក្រៀមក៏ស្រាប់តែប្រែជារីកស្រស់ញញឹមឡើងវិញ។ រីឯព្រះអាទិត្យ ដែលកំពុងតែបញ្ចេញកម្តៅយ៉ាងខ្លាំង ក៏ស្រាប់តែបន្ថយកម្តៅរបស់ខ្លួនវិញ។ លុះធម្មជាតិរីកស្រស់ញញឹមហើយ ព្រះរាមក៏បានប្រៀបធៀបធម្មជាតិទៅនឹងរឿងរ៉ាវ របស់ព្រះអង្គថា ព្រះអង្គគឺជាផ្កាច្បាឆ្ព័រ នាងសីតាគឺជាផ្កាននោងតំណាងឱ្យមាសសុទ្ធព្រះលក្ស្មណ៍ជាផ្កាចម្ប៉ាតំណាងឱ្យមាសនព្វន្ត។ដោយឡែកតែនាងកៃកេសី តំណាងឱ្យកន្លង់ឬធ្យូងខ្មៅ។ ក្រោយមកក៏បានប្រៀបប្រដូចនាងកៃកេសីជាសត្វមយូរីដែលពាំទងឈូកឱ្យកូនវាស៊ី ដោយស្មានថាជាសត្វពស់។ ក្រោយមកព្រះរាម បានទៅជួបនឹងឥសីពារទ្វាទ្យដែលបានពន្យល់ព្រះរាមអំពីទ្រឹស្តីព្រាហ្មណ៍និយមខ្លះ ហើយក៏បានចង្អុលបង្ហាញផ្លូវឱ្យព្រះរាម ទៅបួសជាឥសីនៅភ្នំចិត្រកូដ។

នៅនគរព្វយុធ្យា ព្រះបាទទសរថទ្រង់សោយទីវង្គត។ នាងកៃកេសីបានសរសេរសំបុត្រទៅបញ្ឆោតព្រះភិរុតឱ្យមកគ្រងរាជ្យសម្បត្តិ ដោយក្លែងថា ឱ្យមកជាអធិបតីក្នុងពិធីរាជាភិសេកព្រះរាមនិងនាងសីតា។ ព្រះភិរុតត្រេកអរយ៉ាងខ្លាំង ហើយ ក៏ធ្វើដំណើរមកកាន់នគរភ្លាម ប៉ុន្តែព្រះអង្គទ្រង់ទតឃើញនគរ ស្ងាត់ជ្រងំប្រជារាស្ត្រ បោះបង់មុខរបរទាំងអស់។ លុះទ្រង់ជ្រាបរឿងពិតព្រះភិរុតខ្ញាល់យ៉ាងខ្លាំង មានបំណងចង់សម្លាប់នាងកៃកេសី ប៉ុន្តែដោយការអង្វររបស់ព្រះនាង ព្រះភិរុតក៏សុខចិត្តធ្វើដំណើរទៅតាមព្រះរាមឱ្យមកសោយរាជ្យវិញ។

ព្រះរាម មិនបានទទួលនូវសេចក្តីអង្វរករនេះទេ ព្រោះទ្រង់គោរពពាក្យសច្ចៈ ហើយក៏ប្រគល់សុពណ៌បាទតំណាងរាជ្យសម្បត្តិ ឱ្យទៅព្រះភិរុត។ នៅពេលដែល ព្រះភិរុតវិលត្រឡប់មកវិញ ព្រះរាម ព្រះលក្ស្មណ៍និងនាងសីតា ក៏បានចាកចេញពីភ្នំចិត្រកូដដែរ។ ក្សត្រទាំងបីអង្គ

បានធ្វើដំណើរទៅព្រៃភ្នំទណ្ឌការណ្យ ហើយបាន ជួបនឹងយក្សមួយឈ្មោះពិរាធ។

❖ **ខ្សែទី៣ ៖**

ពិរាធចូលឆក់យកនាងសីតា។ ព្រះលក្ស្មណ៍ផានាខ្លួនចេញតស៊ូយកនាងសីតាមកវិញ ប៉ុន្តែចាញ់យក្សព្រះរាមក៏ផ្លែងសសម្រាប់យក្សក្នុងពេលនោះទៅ។ ដោយមានចិត្តអាក់អន់ នឹងឫទ្ធានុភាពទ្រង់បែបនេះ ព្រះលក្ស្មណ៍ក៏សុំលាព្រះរាមចេញទៅតាំងសិល្ប៍ ដើម្បីរំលឹកមន្តអាគមដែលទ្រង់បានសិក្សាកន្លងមកឡើងវិញ។

ពេលនោះមានប្អូនស្រីយក្សមួយឈ្មោះនាងសូរបនខា បានមកសុំសេចក្តីស្នេហាពីព្រះរាមៗក៏បញ្ចុះបញ្ចូលឱ្យទៅជួបព្រះលក្ស្មណ៍ទៅវិញ។ ព្រឹត្តិការណ៍នេះបានប្រព្រឹត្តទៅមកចំនួនពីរលើក។ នៅទីបំផុត ដោយមានចិត្តសន្ធោរសន្ធៅនៃក្តីស្រឡាញ់ នាងសូរបនខាក៏ប្រើពាក្យសំដីមិនសមគួរធ្វើឱ្យព្រះលក្ស្មណ៍ក្រេវក្រោធ រហូតប្រើអំពើហិង្សា កាត់ដៃកោរសក់នាងសូរបនខាស្រែកទ្រហោយំរំពងពេញព្រៃ។ នាងសូរបនខា ក៏បានប្រែកាឡាជាយក្ខិនីវិញ ហើយក៏បានស្រែកឮរហូតទៅដល់ក្រុងខរជាបង។ ក្រុងខរជាបង ក៏បានបញ្ជូនមេទ័ពយក្សមួយរូប ឈ្មោះខុនទសណ៌ឱ្យមកនាំនាងសូរបនខាវិចូលនគរ ហើយក៏កេណ្ឌពលនាំគ្នាលើកទ័ពមកច្បាំងនឹងព្រះរាមព្រះលក្ស្មណ៍ ។

ក្រុងខរបានបញ្ជាឱ្យខុនទសណ៌ ចូលច្បាំងមុនគេបន្ទាប់មកត្រីមុខ ហើយក្រោយបំផុតគឺក្រុងខរខ្លួនឯង។ ប៉ុន្តែយក្សទាំងអស់ សុទ្ធតែត្រូវវិនាសដោយធ្នូសររបស់ព្រះរាមគ្មានសល់។ លុះឃើញបងរបស់ខ្លួនស្លាប់អស់ហើយ នាងសូរបនខាក៏យកដំណឹងនេះទៅប្រាប់ក្រុងរាពណ៍ជាបង ដែលសោយរាជ្យនៅនគរលង្កា។ នាងបានទាំងអួតសរសើរអំពីលំអងករបស់នាងសីតាហាក់ដុតចិត្តក្រុងរាពណ៍ឱ្យលុះក្នុងផ្លូវកាមគុណហើយក៏បានជំរុញឱ្យក្រុងរាពណ៍ទៅយកនាងសីតាមកធ្វើជាមហេសីទៀតផង។

ក្រុងរាពណ៍មានចិត្តត្រេកត្រអាលក៏បានពិភាក្សាជាមួយប្អូនៗរួចហើយក៏បានបញ្ជាទាំងបង្ខំឱ្យសេនាម្នាក់ឈ្មោះមហារីក កាឡាខ្លួនជាប្រើសមាស រត់កាត់អាស្រមបញ្ឆោតព្រះរាមងាយខ្លួនចូលចាប់នាងសីតា។ ពេលឃើញប្រើសមាសក្លែងក្លាយ នាងសីតាក៏បានបង្ខំឱ្យព្រះរាមចេញទៅបាញ់ប្រើសមាសនោះ ដើម្បីយកស្បែកមកធ្វើជាកម្រាល នៅពេលយាងចូលទៅសោយរាជ្យវិញ ទោះបីព្រះរាមបញ្ជាក់ថា ជាប្រើសមាសក្លែងក្លាយក៏ដោយ ក៏ព្រះនាងនៅតែទាមទារឱ្យព្រះរាមចេញទៅចាប់ប្រើសនោះឱ្យទាល់តែបាន។ ប្រើសមាសត្រូវសររបស់ព្រះរាម មុននឹងស្លាប់ក៏ស្រែកបន្លំជាសំឡេងព្រះរាមហៅឱ្យព្រះលក្ស្មណ៍ចេញទៅជួយទ្រង់ថា ត្រូវរបួស។ព្រះលក្ស្មណ៍ ដឹងថាជាល្បិចកលយក្សដែរ ប៉ុន្តែដោយការបង្ខំរបស់នាងសីតាក៏សុខចិត្តធ្វើដំណើរទៅតាមព្រះរាម។ ពេលនោះក្រុងរាពណ៍ក៏កាឡាខ្លួនធ្វើជាឥសីដើរតម្រង់មករកនាងសីតា។

❖ **ខ្សែទី៤**

ដោយបានឃើញព្រាហ្មណ៍ក្លែងក្លាយ នាងសីតាក៏ចេញមកធ្វើនមស្ការ។ ពេលនោះ

ព្រាហ្មណ៍អត់ទ្រាំមិនបានក៏សរសើរនាងសីតាថា ជានាងឧមាភករតីដែលស្វាមីបំបរបង់ចោល ហើយគេចង់មានភ្នែកមួយសែន អណ្តាតមួយលាន ទុកសម្រាប់មើល និងសរសើរទើបគេអស់ចិត្ត។ នាងសីតាក៏បានសរសើរអំពីឫទ្ធានុភាពរបស់ព្រះរាម ប្រាប់ទៅរាពណ៍វិញ ហើយបានសុំឱ្យក្រុងរាពណ៍ថយចេញពីអាស្រមនាងជាប្រញាប់ទៀតផង។ ក្រុងរាពណ៍ ក៏បានកាឡាខ្លួនជាយក្សទសមុខដ៏អស្ចារ្យឡើងវិញ ហើយខំអួតសរសើរពីឫទ្ធានុភាពរបស់គេ ប្រាប់នាងសីតា។ នាងសីតាបាន ឆ្លើយតបទៅវិញ ដោយបញ្ជាក់ពីទឹកចិត្តព្រះនាង ចំពោះស្វាមីរបស់នាង គឺភក្តីភាពចំពោះព្រះរាមជានិច្ច។ នៅទីបំផុតក្រុងរាពណ៍ ក៏បានឆក់យកនាងសីតាឆ្ពោះទៅក្រុងលង្កាបានដូចបំណង។ ពេលហោះចេញទៅ ក្រុងរាពណ៍បានជួបប្រយុទ្ធនឹងគ្រុឌមួយឈ្មោះជតាយុជាមិត្តសម្លាញ់របស់បិតាក្មេកនាងសីតា។ លុះច្បាំងគ្នាអស់រយៈពេលយូរទៅៗមិនឈ្នះមិនចាញ់ ក្រុងរាពណ៍ក៏លួចហួតចិញ្ចៀនរបស់នាងសីតា ចោលត្រូវជតាយុបាក់ស្លាបធ្លាក់ដល់ដី។ បន្ទាប់មកនាងសីតាក៏បានផ្តាំផ្ញើនឹងសត្វកុកឱ្យយកដំណឹងនេះទៅទូលថ្វាយព្រះរាមផង។ ក្រុងរាពណ៍បានយកនាងសីតាទៅទុកក្នុងសួនអលោក។ រីឯព្រះរាមព្រះលក្ស្មណ៍ក្រោយពេលដែលបាញ់ប្រើសរួច ក៏ធ្វើដំណើរមករកនាងសីតាវិញ លុះរកមិនឃើញក៏យំសោក ហើយធ្វើដំណើរទៅជួបនឹងជតាយុ ដែលបានប្រាប់ដំណឹងពីរឿងក្រុងរាពណ៍ មកឆក់យកនាងសីតា។ ព្រះរាមបានទៅជួបសត្វកុកទៀត កុកក៏បានយកដំណឹងនេះទៅប្រាប់នាងសីតាមកប្រាប់ដែរ ប៉ុន្តែត្រូវព្រះលក្ស្មណ៍ត្អូះតិះដៀល ដែលកុកក៏បានតិះដៀលវិញ។ ព្រះរាមខ្លាចពាក្យដំនៀលរបស់កុកនេះលេចឮវែងឆ្ងាយតទៅទៀត ក៏លើធ្នូសរបម្រុងបាញ់សម្លាប់សត្វកុក តែកុកបានសុំទោសហើយធានាជួយច្បាំងព្រះអង្គយកនាងសីតាមកវិញ ព្រះអង្គក៏ដាក់ធ្នូចុះ។ ព្រះរាមបានទៅជួបនឹងយក្សឈ្មោះកុម្ព័ន្ធ ដែលមានបំណងសម្លាប់ព្រះអង្គ តែត្រូវព្រះអង្គសម្លាប់ចោលក្នុងពេលនោះទៅ។

ចំណែកឯនៅក្នុងព្រៃហេមពាន្ត មានស្តេចក្របីមួយឈ្មោះមហិង្សរាជ បានសម្លាប់ក្របីឈ្មោលទាំងអស់ ហើយប្រមូលក្របីញីធ្វើជាប្រពន្ធ។ សូម្បីតែកូនខ្លួន ដែលកើតមកឈ្មោលក៏មហិង្សាសម្លាប់ចោលដែរ គឺទុកតែកូនញីប៉ុណ្ណោះ។ មានមេក្របីមួយឈ្មោះសន្តគីរីបានកើតកូនឈ្មោលមួយឈ្មោះទូភីហើយមានបំណងចង់ថែរក្សាក៏ភៀសខ្លួនសំងំក្នុងព្រៃ។នាងសន្តគីរីបានទូន្មានកូនឱ្យខំហាត់ ឱ្យបានខ្លាំងក្លាជាងមុនៗនឹងបានទៅជួបឪពុក។ ការខិតខំប្រឹងប្រែងរបស់ទូភីក៏បានសម្រេច ដោយមានកម្លាំងរហូតដល់រំលំដើមឈើធំៗរលំខ្ទេចខ្ទីអស់ ហើយក៏ទៅអង្វរករឪពុកឱ្យទទួលស្គាល់ខ្លួនជាកូន ប៉ុន្តែមហិង្សរាជមិនយល់ព្រម ហើយការប្រយុទ្ធគ្នារវាងឪពុកនឹងកូនក៏កើតមានឡើង។ នៅទីបំផុតទូភីបានប្រហារជីវិតឪពុកហើយបន្តបេសកកម្មឪពុកតទៅទៀត ។

តាំងពីពេលនោះមកទូភី  ក៏តែងតែដើររករឿងគេឯង  ដូចជារករឿងឥសីបញ្ចលឹង្គនាងទេពធីតារក្សាសមុទ្រហេមពាន្ត ហើយទីបំផុតក៏ទៅរករឿងពាលីជាស្តេចស្វាដែលសោយរាជ្យនៅខាស់ខិនបុរី។ ការប្រយុទ្ធគ្នារវាងទូភី និងពាលីបានប្រព្រឹត្តទៅអស់រយៈពេល៧យប់៧ថ្ងៃ។ ដោយប្រយុទ្ធនៅកណ្តាលវាលមិនឈ្នះមិនចាញ់    ពាលីក៏នាំទូរភីទៅប្រយុទ្ធក្នុងគុហារមួយ ដោយបញ្ជាឱ្យសុគ្រីពជាប្អូនយកថ្មមកសន្ទប់មាត់រូងបើកាលណាឃើញឈាមក្រហមដែលជាឈាមរបស់ខ្លួនហូរចេញមក។ ពាលីប្រើល្បិចកលសម្លាប់ទូភីបានដូចបំណង  តែដោយទេវតាបាចផ្កាអបអរសាទរច្រើនពេក ធ្វើឱ្យឈាមខ្មៅរបស់ក្របីប្រែទៅជាពណ៌ក្រហម  ដូចជាឈាមពាលីទៅវិញ។ សុគ្រីពឃើញឈាមក្រហមនឹកស្មានថាជាឈាមរបស់បងខ្លួន ក៏បម្រុងនឹងចូលទៅសងសឹកជំនួសបង តែពួកសេនាបានហាមឃាត់ ហើយយកថ្មសន្ទប់មាត់រូងនោះទៅ។

ពាលីបានកាត់ក្បាលក្របីទូភីចោលទំលាយថ្មសន្ទប់រូងនោះហើយក៏ធ្វើដំណើរមកដល់នគរវិញទាំងកំហឹងឆាបឆេះ។  ទោះបីសុគ្រីតខំពន្យល់ពីការពិតយ៉ាងណាក៏ដោយ   ក៏ពាលីពុំព្រមជឿដែរ  ហើយបានទះក្បាលប្អូននៅចំណោមមុខមន្ត្រីទាំងឡាយទៀតផង។ សុគ្រីពខ្មាសគេពេកក៏ហោះគេចតែត្រូវពាលី   តាមទះតប់ក៏ចុះមកវិញ។  ពាលីចាប់ជើងសុគ្រីពបានបម្រុងបោកសម្លាប់នៅលើកំពូលភ្នំតែសុគ្រីពរើរួច ហើយរត់ទៅពួននៅលើភ្នំមតង្គបពតិ។ពាលីពុំអាចចូលភ្នំនេះតាមសុគ្រីពបានឡើយ  ព្រោះគេបានធ្វើឱ្យឈាមទូភីហូរកាត់អាស្រមឥសីមតង្គ ជាហេតុនាំឱ្យឥសីខឹងដាក់បណ្តាសារឱ្យគេស្លាប់  បើសិនជាគេហ៊ានចូល។   សុគ្រីពឈឺចាប់គិតតែពីយំទាល់តែទឹកភ្នែកហូរក្លាយជាជ្រោះ។ នៅពេលនោះ មានតែក្មួយម្នាក់ឈ្មោះហនុមានទេដែលតាមជួយគាំពារកំដរ ។

### ❖ខ្សែទី៥

ពេលធ្វើដំណើរមកតាមរកនាងសីតា  ព្រះរាមព្រះលក្ស្មណ៍បានទៅសម្រាកនៅក្រោមដើមស្វាយមួយ។ព្រះរាមផ្ទំនៅលើភ្លៅព្រះលក្ស្មណ៍។ពេលនោះព្រះអាទិត្យនៅនឹងថ្កល់ថ្ងៃបាំងឆ័ត្រម្លប់ស្វាយនៅដដែលឱ្យព្រះរាមជ្រក។ នៅពេលឃើញព្រឹត្តិការណ៍ដូចនេះ  សុគ្រីពក៏បានឱ្យហនុមានតាមរកអ្នកមានបុណ្យ ។  ហនុមាន ឡើងលើដើមស្វាយ ឃើញរូបកងចក្រនៅក្នុងបាតដៃព្រះរាមក៏សម្គាល់ថាជាអ្នកមានបុណ្យហើយបេះស្លឹកស្វាយស្លុតីព្រះរាម។ព្រះលក្ស្មណ៍ខ្លាចព្រះរាមភ្ញាក់ក៏ទាញធ្នូបាញ់ហនុមាន ប៉ុន្តែធ្នូនោះត្រូវហនុមានឆក់យកទៅ។ ព្រះលក្ស្មណ៍ក៏ទាញធ្នូព្រះរាមបម្រុងបាញ់ទៀត  ប៉ុន្តែព្រះរាមភ្ញាក់ឡើង  ហើយសួររករឿងហេតុ។  ព្រះរាមឃើញស្វានោះប្លែកពីស្វាដទៃទៀត ព្រោះមានកុណ្ឌលពាក់នៅត្រចៀក។  ហនុមានក៏ចុះពីលើដើមស្វាយទទួលព្រះរាមជាថៅហ្វាយរបស់ខ្លួន ពីព្រោះព្រះរាមអាចមើលឃើញកុណ្ឌលរបស់ខ្លួន។ ហនុមានបានហាមាត់បញ្ចេញរស្មីព្រះអាទិត្យទាំង៧ ដែលស្ថិតនៅក្នុងមាត់របស់ខ្លួន។

ហនុមានបានស្នើឱ្យព្រះរាមជួយដោះស្រាយរឿងពាលីនិងសុគ្រីព។ ក្រោយមកព្រះរាម និងសុគ្រីពក៏បានចងមេត្រី នឹងគ្នាដោយសន្យាថា នឹងជួយគ្នាទៅវិញទៅមកពេល គឺព្រះរាម សម្លាប់ពាលីហើយសុគ្រីពរកកេណ្ឌទព័ស្វាថ្វាយព្រះរាម។សុគ្រីពបានស្នើឱ្យព្រះរាមល្បងឫទ្ធានុភាពឱ្យខ្លួនមើលមុនពេលច្បាំងនឹងពាលី។ ព្រះរាមបានបាញ់សរអគ្គីវាសរំលាយសពទូភីជាផេះ ហើយបញ្ចូលទៅបាតសមុទ្រ បន្ទាប់មកយកសរព្រហ្មមាស បាញ់កំទេចដើមសត្តបាលដែលដុះលើខ្នងនាគតាំងពីកំណើតផែនដី។ ក្រោយមក ព្រះរាមក៏បញ្ជាឱ្យសុគ្រីពហៅពាលីចេញច្បាំង។ ព្រះអង្គលបបាញ់ពាលីលើកទី១ មិនបានសម្រេច ព្រោះច្រឡំគ្នា។ ព្រះលក្ស្មណ៍ក៏បំពាក់កម្រងផ្កាឱ្យសុគ្រីព ហើយព្រះរាមក៏បាញ់ពាលីបាន ប៉ុន្តែមុននឹងស្លាប់ពាលីបានត្មះតិះដៀលព្រះរាមជាច្រើន។ នាងទេធីតាជាមហេសីពាលី បានចេញមកយំសោកលើសាកសពពាលី លុះត្រាតែក្តៅក្រហាយដល់ព្រះឥន្ទ្រ ក៏ឱ្យព្រលឹងរបស់ពាលីទៅចាប់កំណើត នៅស្ថានសួគ៌។

លុះបានសម្រេចបំណងហើយសុគ្រីពត្រូវបានព្រះរាមអភិសេកឱ្យសោយរាជ្យនៅខាស់ខិនបុរី។ ដោយសុគ្រីពមិនបានកេណ្ឌទ័ណ្ឌថ្វាយព្រះរាម ឱ្យទាន់ពេលវេលាព្រះរាមក៏កំហែងរករំលាយខាស់ខិនបុរីទាំងមូលចោល។ សុគ្រីតភ័យតក់ស្លុត ក៏កេណ្ឌទព័ស្វាថ្វាយព្រះរាម។

### ❖ខ្សែទី៦

សុគ្រីពបានទៅហៅហនុមាន ឯភ្នំកុន្ទលីហើយបញ្ជាឱ្យកាឡាខ្លួនប៉ុនម្រាមដៃ។ សុគ្រីពដាក់ហនុមានក្នុងថង់សំពត់ យកទៅប្រគល់ថ្វាយព្រះរាមៗអស់សង្ឃឹម ព្រោះឃើញហនុមានតូចពេក តែហនុមានក៏បញ្ចេញឫទ្ធានុភាព ឱ្យព្រះរាមឃើញភ្លាម។ លុះទ័ពស្វាជួបជុំគ្នាអស់ហើយ ព្រះរាមត្រូវការរកអ្នកខ្លាំងពូកែម្នាក់ ទៅស៊ើបការណ៍នៅក្រុងលង្កា។ សុគ្រីពឆ្លើយថាខ្លួនចាស់ហើយ បើគ្រាន់តែទៅបានវិលត្រឡប់មក វិញក្នុងពេលឆាប់មិនបាន។ ឯខុននន្ទឆ្លើយថា បើនឹងទៅត្រឡប់មកវិញបានតែខ្លាចនាងវិកតាសី ដែលហាមាត់នៅចាំក្លោងទ្វារលង្កាបបូរមាត់លើដល់ អាកាសបបូរមាត់ ក្រោមដល់បាតាល។ បើសិនជានរណាម្នាក់ទៅលង្កា តែងតែវង្វេងស្លាប់ក្នុងពោះនាង។ ដូចនេះមានតែហនុមានទេ ដែលអាចធ្វើដំណើរទៅបាន។ មុននឹងចេញទៅហនុមានបានសុំចិញ្ចៀនព្រះរាម ដើម្បីឱ្យនាងសីតាជឿជាក់ថា ខ្លួនជាសេនារបស់ព្រះរាម។ ហនុមានហោះហួសលង្កា ទៅជួបមុនីឥសីដែលចង្អុលប្រាប់ពីលង្កា ហើយពូតបាយ៣ដុំឱ្យហនុមានបរិភោគ។ ហនុមានស្មានថាតិចក៏ចំអកឱ្យឥសី ប៉ុន្តែបរិភោគបាយបីដុំនោះមិនអស់ក៏ខ្មាស់ឥសីហើយហោះទៅជួបនាងវិកតាសី ចាំក្លោងទ្វារលង្កា។ ហនុមានមិនឱ្យវិកតាសីដឹងទេ ព្រោះខ្លាចសង្គ្រាមកើតឡើង នាំឱ្យខូចពេលសន្យាជាមួយព្រះរាម។ ហនុមាន ក៏បោះចិញ្ចៀនទៅលើអាកាសរួចចូលតាមមាត់នាងវិកតាសី មកចេញតាមត្រចៀក ដើម្បីទ្រចិញ្ចៀន

វិញ។ ហនុមានបានទៅឃើញក្មួយក្រុងរាពណ៍ម្នាក់ ឈ្មោះកាមពាលី ឃើញអតិកាយកម្ពស់មួយយោជន៍ ឃើញទេពកញ្ញាទាំងឡាយ ដែលក្រុងរាពណ៍លួចយកមក ឃើញឃ្លាំងក្រុងរាពណ៍ ឃើញក្រុងរាពណ៍កំពុងផ្ទំជាមួយនាងមណ្ឌោគីរី។ ហនុមានបានចង់សក់អ្នកទាំងពីរជាប់គ្នាហើយសរសេរនៅមាត់ទ្វារថា បើចង់រួចត្រូវឱ្យនាងមណ្ឌោគីរីវាយក្បាលក្រុងរាពណ៍ពដង។ ហនុមានរកសីតាមិនឃើញសោះ ហើយក៏ទៅស៊ើបក្បែរពួកស្រីស្នំ ឮស្រីស្នំនិយាយពីក្រុងរាពណ៍ដែលមានមហេសីច្រើនណាស់ ហើយនៅតែទៅលួចព្រះជាយារបស់ព្រះរាមដែលមានតែមួយអង្គគត់ ហើយក្រុងរាពណ៍យកទៅទុកក្នុងសួនអសោក។ ហនុមានត្រេកអរខ្លាំងណាស់ ហើយក៏ទៅជួបនាងសីតាភ្លាម។ ប៉ុន្តែនាងសីតាមិនទទួលស្គាល់ ព្រោះនឹកស្មានថាក្រុងរាពណ៍កាឡាខ្លួន។ហនុមាននិទានរឿងប្រាប់នាងសីតាតាំងពីព្រះរាមសម្លាប់ពាលីនិងចងស្ពានមេត្រីជាមួយសុគ្រីពហើយប្រើខ្លួនឱ្យមកស៊ើបការណ៍រកនាង។ នាងសីតាសួររកភស្តុតាងហនុមានក៏ហុចចិញ្ចៀនថ្វាយនាង។ ក៏ប្រគល់ចិញ្ចៀននាងមក ឱ្យហនុមានទុកជាសាក្សីនៃការជួបគ្នា។ ក្រោយពេលលានាងសីតាមកវិញ ហនុមានក៏បានដើរបំផ្លាញក្រុងលង្កា ដោយបានសម្លាប់យក្សជាច្រើននាក់ដូចជាសហស្សកុមារ និងអតិកាយមេទ័ពយក្ស។ បន្ទាប់មកហនុមានបានធ្វើ ឱ្យឥន្ទ្រជិតចាប់បាន ប៉ុន្តែសម្លាប់មិនបានសោះ។ ហនុមានក៏ប្រាប់យក្ស ឱ្យយកសំពត់មករុំខ្លួនច្រើនជាន់ យកប្រេងមកចាក់ និងយកភ្លើងមកដុតទើបស្លាប់។ លុះដុតរួចហើយហនុមាន ក៏ហោះឡើងលើអាកាសទម្លាក់សំពត់នេះលើក្រុងលង្កាឆេះខ្ទេចខ្ទីរ រួចនាំដំណឹងនេះទៅទូលថ្វាយព្រះរាម។ ព្រះរាមត្រេកអរយ៉ាងខ្លាំង ព្រមទាំងឱ្យរង្វាន់ហនុមានយ៉ាងគាប់ចិត្ត។

### ❖ខ្សែទី៧

ពេលដែលបានដំណឹងពីហនុមានហើយ ព្រះរាមក៏លើកទ័ពស្វាទៅលង្កា តែដោយទ័ពស្វាមានគ្នាតិចពេក ព្រះរាមក៏ឱ្យសុគ្រីពជួយរកស្ដេចស្វាដែលមានឫទ្ធានុភាពមួយ ដើម្បីយកធ្វើជាមិត្តនៅពេលធ្វើសង្គ្រាម។ សុគ្រីពបានអួតសរសើរអំពីមហាជម្ពូនៅព្រៃហេមពាន្តថា មានឫទ្ធានុភាពស្មើគ្នានឹងក្រុងពាលី ហើយត្រូវជាមិត្តចាស់របស់ពាលីទៀត។ ព្រះរាមក៏បញ្ជូនឱ្យហនុមាននិងអង្គទនាំសារទៅចងសម្ព័ន្ធភាពជាមួយមហាជម្ពូដើម្បីសុំកងទ័ពជំនួយ។ ប៉ុន្តែហនុមានបានធ្វើកិរិយាព្រហើន កោងកាចដាក់មហាជម្ពូដូចជាពោលថា បើទៅដល់ថ្ងៃ ឱ្យលើកទ័ពថ្វាយព្រះរាមទាំងថ្ងៃមហាជម្ពូក៏ឱ្យសេនាចាប់ស្វាទាំងពីរដាក់គុក។ពេលយប់ហនុមានក៏សណ្ដំស្វាទាំងនោះ រួចក៏រត់ចេញមកក្រៅ។ ពេលចេញរួច ហនុមានបានលើកទាំងគ្រែមហាជម្ពូកំពុងផ្ទំ ហោះនាំយកទៅថ្វាយព្រះរាម។ ព្រះរាម ដោយខ្លាចមហាជម្ពូ ដែលក្រលេកឆេះ ក៏បញ្ជាឱ្យហនុមានទៅសុំខ្ចីអាវព្រះនារាយណ៍ដើម្បីកំហែងមហាជម្ពូឱ្យខ្លាច។ មហាជម្ពូបានសុខចិត្តចងស្ពានមេត្រីជាមួយព្រះរាម ប៉ុន្តែមិនព្រមធ្វើសហប្រតិបត្តិការខ្លួនឯងផ្ទាល់ទេ ក៏ឱ្យខុននីលនិង

ខុននលជំនួសខ្លួន។

លុះបានទ័ពហើយ ព្រះរាមក៏ឱ្យទ័ពស្វាសង់ស្ពានទៅកោះលង្កា ដោយលើកដុំថ្មទម្លាក់ទៅក្នុងសមុទ្រ។ ពួកនាងមណីមេខល្លា ជាទេពធិតារក្សាសមុទ្របបួលគ្នាពាំដុំថ្មនោះចេញ។ ពេលនោះសុគ្រីពធានាកាឡាខ្លួនឱ្យធំធ្វើជាស្ពាន រីឯអង្គទវិញធានាផឹកទឹកសមុទ្រឱ្យរីង ប៉ុន្តែព្រះរាមពុំព្រម ក៏ប្រកាសកំហែងនាងមណីមេខល្លា ដោយថ្លែងសរឱ្យទឹកសមុទ្រពុះ។ នាងមេខល្លាភិតភ័យក៏ធានាស្ថាបនាស្ពានមួយថ្វាយ ហើយព្រះរាមក៏លើកទ័ពស្វាទៅកោះលង្កា។

❖ **ខ្សែទី៨**

ព្រះរាមបានលើកទ័ពទៅដល់លង្កា ក្រុងរាពណ៍ក៏ទូងស្គរប្រមូលទ័ពរួចបញ្ជាពិភេកឱ្យទាយពីវាសនានគរលង្កា។ ពិភេកបានគន់គូរហើយ ក៏ស្នើក្រុងរាពណ៍ ឱ្យនាងសីតាទៅថ្វាយព្រះរាមវិញ។ពិភេគបានប្រដូចរាពណ៍ទៅនឹងក្អែកដែលពាំកែវពិទូរស្សរ្យកាន្តយកមកទុកឱ្យឆេះសម្បុក រួចប្រៀបធៀបទៅនឹងត្រីដែលស៊ីនុយ។ រាពណ៍ខឹងខ្លាំងណាស់ ក៏ដោះស្បែកជើងវាយក្បាលពិភេគៗក៏រត់ទៅសុំចុះចូលនឹងព្រះរាម។ មុនដំបូងព្រះរាមមិនទុកចិត្ត តែមហាជម្ពូហោរាបានទាយថាល្អ ព្រះរាមក៏យល់ព្រមទទួល។

ក្រុងរាពណ៍ខឹងនឹងពិភេកក៏មកគិតគូរនឹងនាងមណ្ឌោគីរី នាងក៏មានយោបល់ដូចពិភេកដែរ តែក្រុងរាពណ៍មិនព្រមស្តាប់ក៏ធ្វើសង្គ្រាមតាមល្បិចកលរបស់ខ្លួន។ ដូចជាឱ្យយក្សឈ្មោះរុក្ខសេនទៅយាមព្រៃ ដើម្បីកុំឱ្យទ័ពស្វាបេះផ្លែឈើស៊ីបាន។ ចម្បាំង ក៏កើតមានឡើងរវាងទ័ពស្វាដែលមានមេទ័ពឈ្មោះរុក្ខរក្ស និងទ័ពយក្សដែលមានមេទ័ពឈ្មោះរុក្ខសេន។ ទ័ពយក្សនិងទ័ពស្វាស្លាប់អស់ ប៉ុន្តែមានយក្សមួយរត់រួចខ្លួន ហើយទៅប្រាប់ក្រុងរាពណ៍ថា ហនុមានស្លាប់ព្រោះច្រឡំរុក្ខរក្សស្មានថាហនុមាន។

ក្រុងរាពណ៍ គ្រេកអរយ៉ាងខ្លាំង ក៏ឱ្យគេលើកឆ័ត្រជ័យពាសពេញអាកាស ដើម្បីឱ្យព្រះរាមដកទ័ព តែព្រះរាមថ្លែងសរកម្ទេចឆត្រ័ទាំងនោះឱ្យខ្ទេចខ្ទីរអស់។ ក្រុងរាពណ៍ភ័យភិតក៏ប្រើល្បិចមួយទៀត ដោយយកនាងសីតាហោះឡើងទៅលើអាកាស ដើម្បីបញ្ឈឺចិត្តព្រះរាម។ តែបានពិភេកប្រាប់ការពិតដល់ព្រះរាមៗក៏សូត្រមន្តឱ្យរាពណ៍ចុកពោះសន្លប់លើរាជរថ។

ព្រះរាមចាត់ឱ្យអង្គទ យកសារទៅថ្វាយក្រុងរាពណ៍ ដើម្បីធ្វើសង្គ្រាម ប៉ុន្តែទំនាស់រវាងអង្គទនិងយក្សក៏កើតមានឡើង ពីព្រោះពួកយក្សមានបំណងសម្លាប់អង្គទ។ នៅទីបំផុតអង្គទក៏ទះត្រូវក្រុងរាពណ៍មួយដៃសន្លប់ និងយកពេជ្រនៅលើក្បាលរាពណ៍រត់ យក្ស៥នាក់ទៅតាមតែត្រូវអង្គទវាយដាច់ក្បាល ព្រមទាំងនាំដំណឹងនេះទៅប្រាប់ព្រះរាម។

ក្រុរាពណ៍ក៏ចាត់កុម្ភកាណ៌ឱ្យចេញច្បាំងនឹងព្រះរាមហើយកុម្ភកាណ៌ស្នើឱ្យក្រុងរាពណ៍យកនាងសីតាទៅប្រគល់ថ្វាយព្រះរាមវិញដើម្បីកុំឱ្យមានសង្គ្រាមពិបាកដល់រាស្ត្រពីព្រោះរឿង

រាវទាំងអស់នេះ កើតមកពីនាងសូរបនខាទៅចង់ប្រុសខុសច្បាប់ប៉ុណ្ណោះ។ក្រុងរាពណ៍ក៏ចោទកុម្ភកាណ៌ថាខ្លាចស្លាប់ កុម្ភកាណ៌ក៏ដាច់ចិត្តចេញច្បាំង។

❖ **ខ្សែទី៩**

កុម្ភការណ៌បានលើកទ័ពយ៉ាងច្រើនទៅវាយព្រះរាម។ ក្នុងត្រីនោះ ព្រះរាមមើលឃើញផ្កាយចម្លែក ក៏ហៅឱ្យពិភេកមកទស្សន៍ទាយ។ ពិភេគទាយថា កុម្ភកាណ៌នឹងលើកទ័ពមកឆ្មក់ព្រះរាម។ ព្រះរាមក៏បញ្ជាឱ្យពិភេកទៅបញ្ចុះបញ្ចូលកុម្ភកាណ៌ឱ្យចូលទៅក្នុងទ័ពព្រះរាម ហើយព្រះអង្គនឹងឱ្យរង្វាន់ ព្រមទាំងបុណ្យសក្តិយ៉ាងធំ។កុម្ភកាណ៌បានអះអាងថា ទោះបីព្រះរាមមានឫទ្ធានុភាពខ្លាំងយ៉ាងណាក៏ដោយ ទោះបីក្រុងរាពណ៍ខុសយ៉ាងណាក៏ដោយ ក៏ខ្លួនពុំព្រមរស់នៅក្រោមការត្រួតត្រារបស់ព្រះរាមដាច់ខាត។

សង្គ្រាមក៏កើតមានឡើង រវាងព្រះលក្ស្មណ៍និងកុម្ភកាណ៌បានយកមោង្គសក្តិចោលព្រះលក្ស្មណ៍ត្រូវជើងយ៉ាងធ្ងន់ រហូតដល់សន្លប់បាត់ស្មារតី ដំបៅក៏ដុះឫសចាក់ដល់ឋានបាតាល។ ព្រះរាមយំសោកព្រោះមិនអាចជួយប្អូនបាន។ ពេលនោះពិភេកទទួលខ្លួនផ្សំថ្នាំ ដោយបញ្ជាឱ្យហនុមានទៅរកថ្នាំនៅព្រៃហេមពាន្ត ដូចជាឫស្សីរី កេសរបទុមាសង្ករណី ព្រមទាំងទឹកមូត្រគោឧសករាជ។ ហនុមានមិនស្គាល់ថ្នាំ ក៏លើកភ្នំទាំងមូលមកប្រគល់ឱ្យពិភេក ប៉ុន្តែនៅខ្វះថ្មរបស់មួយដុំ ដែលស្ថិតនៅក្រោមក្បាលដំណេកក្រុងរាពណ៍។ ហនុមានបានទៅសណ្តំពួកយក្សយកដុំថ្មនោះបានទៀត។ ប៉ុន្តែពិភេគបានបញ្ជាក់ថា បើព្រះអាទិត្យរះមកទាន់ ព្រះលក្ស្មណ៍នៅតែក្ស័យដដែល ព្រោះថ្នាំផ្សំពុំទាន់។ ហនុមានបានទៅឃាត់ដំណើរព្រះអាទិត្យ។ ព្រះអាទិត្យមិនយល់ព្រម ព្រោះខ្លាចខុសពេលវេលាមនុស្សលោក ហនុមានក៏វាយសេះព្រះអាទិត្យឱ្យរត់បាត់អស់។ របួសព្រះលក្ស្មណ៍បានជាសះស្បើយ ក៏ចេញច្បាំងម្តងទៀត។ ម្តងនេះ ព្រះលក្ស្មណ៍បានសម្លាប់កុម្ភកាណ៌។ ក្រុងរាពណ៍ បញ្ជាឱ្យឥន្ទ្រជិតចូលច្បាំងបន្ត។ សង្គ្រាមបានកើតឡើងយ៉ាងយូរទីបំផុត ឥន្ទ្រជិតផ្លែងសរនាគបាល ចាប់ទ័ពស្វានិងព្រះលក្ស្មណ៍ជាប់។ ព្រះរាមយំសោកម្តងទៀត ព្រោះទ្រង់មិនអាចជួយព្រះលក្ស្មណ៍បាន ហើយក៏កំហែងទេវតាស្ថានលើឱ្យជួយដោយប្រកាសថា ព្រះអង្គនឹងគ្រវែងធ្នូសរទៅស្ថានលើឱ្យឆេះខ្ទេចខ្ទីអស់ ប្រសិនបើព្រះលក្ស្មណ៍សុគត។ ទេវតាភ័យតក់ស្លុត ក៏ទៅអង្វរព្រះព្រហ្មឱ្យលែងគ្រុឌពីទ្រុង ដើម្បីដេញនាគឥន្ទ្រជិត។ នៅទីបំផុត ព្រះលក្ស្មណ៍និងទព័ស្វាក៏បានរួចជីវិត។

❖ **ខ្សែទី១០**

ពេលដឹងថា ព្រះលក្ស្មណ៍រួចជីវិតឡើងវិញ ក្រុងរាពណ៍ក៏ប្រើមធ្យោបាយផ្សេងទៀត។ គេភៀសខ្លួនឡើងលើកំពូលភ្នំស្លពិសពីនាគ ដើម្បីងាយសម្លាប់ទ័ពព្រះរាម។ ពិភេកបានឱ្យដំណឹងនេះទៅព្រះរាមភ្លាម។ ព្រះរាមបានចាត់ឱ្យហនុមានទៅបំផ្លាញ មន្តអាគមរបស់ក្រុង

រាពណ៍លុះត្រាតែសម្រេច។ ក្រុងរាពណ៍ខឹងខ្លាំងក៏ចាត់ឱ្យឥន្ទ្រជិតចេញច្បាំងម្តងទៀត។ ឥន្ទ្រជិតបានកាឡាខ្លួនជាពពក ក្នុងបំណងកុំឱ្យទ័ពព្រះរាមមើលទ័ពខាងខ្លួនឃើញ។ ទ័ពយក្សបានសម្លាប់ទ័ពស្វាអស់ជាច្រើន។ ព្រះរាម ព្រះលក្ស្មណ៍អស់សង្ឃឹម ព្រោះមើលទ័ពយក្សមិនឃើញសោះ ក៏បន់ស្រន់ទេវតាសុំឱ្យមើលទ័ពសត្រូវឃើញ។ ការបន់ស្រន់បានសម្រេច ហើយព្រះលក្ស្មណ៍ក៏ផ្លែងសរសម្លាប់ឥន្ទ្រជិតក្នុងពេលនោះទៅ។

លុះដឹងថាឥន្ទ្រជិតស្លាប់ ក្រុងរាពណ៍ក៏អង្គុយយំអស់ពេលយ៉ាងយូរ រួចក៏សម្រេចចិត្តយកនាងសីតាទៅប្រហាជីវិត ប៉ុន្តែមានមន្ត្រីយក្សម្នាក់ឈ្មោះរុក្ខសៈឃាត់ទាន់។ ដោយអះអាងថា ទំនៀមទម្លាប់មិនអនុញ្ញាត្តិឱ្យសម្លាប់មនុស្សឥតទោសយ៉ាងនេះទេ។ ក្រុងរាពណ៍យល់ព្រមហើយ ក៏បញ្ជាឱ្យកូនទាំង១០របស់ខ្លួន ចេញច្បាំងម្តងមួយៗលុះត្រាតែស្លាប់អស់គ្មានសល់។ អស់សង្ឃឹមវិលវល់ក្រុងរាពណ៍ ក៏ទៅចងស្ពានមេត្រីជាមួយមិត្តម្នាក់ឈ្មោះមូលផល័ម ឱ្យមកជួយច្បាំងបន្តទៀត។

### ❖ខ្សែទី៧៥

នៅថ្ងៃមួយ ក្នុងពេលដែលព្រះរាមនិងព្រះលក្ស្មណ៍យាងចេញទៅក្រសាលព្រៃ នាងសីតានៅក្នុងវាំងអផ្សុកពេកក៏នាំភីលៀងទៅស្រង់ទឹក។ បន្ទាប់មក សីតាបានគូររូបក្រុងរាពណ៍ហើយលុបវិញមិនជ្រះសោះឡើយ ដោយសារចាញ់បោកយក្ខិនីម្នាក់ឈ្មោះ«អាតុល័យ» ដែលត្រូវជាប្អូនក្រុងរាពណ៍ដែលតាមមកសងសឹក។ នៅពេលព្រះរាមវិលមកវិញ ព្រះនាងភ័យស្លន់ស្លោក៏យកក្តារគំនូរទៅលាក់ក្រោមក្រឡាបន្ទំរបស់ស្វាមី។ព្រះរាមក្តៅក្រហាយផ្ទំមិនលក់ដេញកាប់គេឯងពេញក្នុងរាជវាំង។ លុះព្រះលក្ស្មណ៍រកឃើញក្តារគំនូរនោះហើយ នាងសីតាក៏សារភាពការពិតនោះថ្វាយព្រះរាម។ ព្រះរាមជេរប្រមាថព្រះនាងយ៉ាងខ្លាំង ហើយក៏បញ្ជាឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅសម្លាប់ទាំងរាត្រី។

ព្រះលក្ស្មណ៍យល់ថានាងសីតាល្អបរិសុទ្ធ ពុំហ៊ានសម្លាប់ព្រះនាងឡើយ ហើយសុំឱ្យព្រះនាងចេញឱ្យផុតទៅ តែនាងសីតាពោលពាក្យគំរោះគំរើយ ដើម្បីបញ្ឆឺចិត្តឱ្យព្រះលក្ស្មណ៍ខឹងឆាប់សម្លាប់នាង។ ព្រះលក្ស្មណ៍លើកព្រះខ័នបម្រុងនឹងសម្លាប់ព្រះនាងពីរដង ប៉ុន្តែដាក់ចុះមកវិញ។ នៅលើទីបីព្រះលក្ស្មណ៍ធ្មេចភ្នែក លើកព្រះខ័នកាប់នាងសីតាទាល់តែសន្លប់ខ្លួនឯង។ ប៉ុន្តែនាងសីតាពុំស្លាប់ ព្រោះព្រះខ័នរបស់ព្រះលក្ស្មណ៍ក្លាយទៅជាកម្រងផ្កាដោយសារតែសច្ចៈធម៌របស់នាងជួយ។

ពេលដែលព្រះលក្ស្មណ៍លានាងសីតា ត្រឡប់មកវិញព្រះឥន្ទ្របានបណ្តាល ឱ្យកើតជាសត្វទ្រាយមួយដេកស្លាប់នៅក្បែរផ្លូវ ដើម្បីឱ្យព្រះអង្គក៏វះយកថ្លើមមកថ្វាយព្រះរាមឱ្យបានមុនថ្ងៃរះ។ ព្រះរាមបានត្មះតិលដៀលនាងសីតាម្តងទៀត នៅពេលឃើញថ្លើមសត្វទ្រាយនេះ ។

នាងសីតាបានដើរកាត់ព្រៃដោយក្ដីភ័យខ្លាច។ ពេលនោះព្រះឥន្ទ្របានកាឡាខ្លួជាមហិង្សា មកនាំព្រះនាងទៅកាន់អាស្រមឥសី «វជ្ជប្រិត» ដោយសុវត្ថិភាព។ លុះគម្រប់ទសមាសនាងបានប្រសូត្របុត្រក្រោមការឧបត្ថម្ភរបស់ឥសីវជ្ជប្រិតមុនី ព្រះឥន្ទ្រ ប្រពន្ធព្រះឥន្ទ្រទាំងបួនអង្គ ហើយនិងបរិពារដ៏ច្រើនទៀត។

ថ្ងៃមួយនាងសីតា ទៅកំពង់ទឹកឃើញស្វាញីពកូនជាប់នឹងខ្លួន យល់ថាវាការប្រសើរ ក៏វិលមកយកបុត្រទៅជាមួយដោយពុំឱ្យឥសីដឹង។ ឥសីបើកភ្នែកឡើងពុំឃើញចៅ ភ័យណាស់ក៏រៀបចំជបក្មេងមួយទៀតឱ្យដូចរាជកុមារមុន។ លុះនាងសីតាពកូនត្រឡប់មកវិញ ឥសីអរផងភ័យផងក៏តាំងស្ដីបន្ទោសនាងយ៉ាងខ្លាំង។

### ❖ខ្សែទី៧៦

ឥសីបម្រុងលុបរូបកុមាចោលប៉ុន្តែនាងសីតាសូមឱ្យលោក ជបឡើងវិញដើម្បី បានជាគូនឹងកូននាង។ កុមារជបនេះ ឈ្មោះ«ជប្បលក្សណ៍» ហើយបុត្របង្កើតរបស់នាងឈ្មោះ «រាមលក្សណ៍»។ អាយុបាន១០ឆ្នាំ រាជកុមារចេះសិល្ប៍មន្តយ៉ាងស្ទាត់ជំនាញបានលាគ្រូអាចារ្យ និងមាតាទៅក្រសាលព្រៃ។ រាមលក្សណ៍បានថ្លែងសរកម្ទេចដើមរាំងមួយដើមដើម្បីសាកល្បងឫទ្ធិមើល។ ការថ្លែងសរនេះបានធ្វើឱ្យពួកទេវៈរំជើបរំជួលគ្រប់ទិសទីធ្វើឱ្យឥសីពេញចិត្ត ហើយនិងធ្វើឱ្យនាងសីតាសរសើរបុត្រពូកែដូចព្រះរាម ជាបិតារបស់ទ្រង់ដែរ។ ពេលនោះ រាជកុមារបានដឹងជីវប្រវត្តិមាតាមួយចប់។

ស័ព្ទសររបស់រាជកុមារ បានធ្វើឱ្យអ្នកស្រុកពួយុធ្យា និងព្រះរាមភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ព្រះរាមឱ្យហោរាទស្សន៍ទាយហោពុំគ្រាន់តែទូលថា មានអ្នកមានឫទ្ធិមកល្បងសិល្ប៍ប៉ុណ្ណោះទេ ប៉ុន្តែសុំឱ្យព្រះរាមលែងសេះ«អស្សុតរ»ឱ្យដើរចេញដោយមានរាជសារភ្ជាប់ទៅនឹងកហើយនិងឱ្យហនុមានដើរចាំឃ្លាំចាំមើលពីក្រោយផង។ ឯសេចក្តីក្នុងសារនោះមានជាអាទិថា« បើនរណាពុំថ្វាយបង្គំសេះព្រះរាមទេនោះ ត្រូវចាប់យកទៅធ្វើទោស»។ ព្រះរាមធ្វើតាមហោរ ដោយឱ្យហនុមានឃ្លាំតាមពីក្រោយសេះ ហើយឱ្យព្រះភិរុត ព្រះសុត្រុតលើកទ័ពតាមពីក្រោយហនុមានថែមទៀត។ ប៉ុន្តែមុននឹងធ្វើដំណើរចេញទៅ ព្រះរាមបានប្រទានក្រោះ ទៅព្រះអនុជមួយម្នាក់ៗទុកការពារខ្លួន។

មុននឹងធ្វើដំណើរទៅព្រៃម្ដងទៀតនេះ រាជកុមារត្រូវមាតាហាមឃាត់យ៉ាងខ្លាំង ដោយនាងភ័យខ្លាចពីផលវិបាកនៃការថ្លែងសរពីថ្ងៃមុនផង ហើយនិងអំពីការពុំទាន់ចេះធ្វើសង្គ្រាមរបស់ក្មេងទាំងពីរនាក់ផង។ រាជកុមារឃើញសាររបស់ព្រះរាម ក៏ចាប់ជិះលេងដោយយល់ថាបើម្ចាស់គេមកសុំនឹងឱ្យគេវិញ។

ពេលនោះហនុមានបានស្ទុះមកចាប់រាជកុមារ ប៉ុន្តែត្រូវរាជកុមារវាយវាត់នឹងធ្នូសរដួល

សន្លប់ទៅលើព្រះធរណី។ លុះត្រូវព្រះពាយ ហនុមានដឹងខ្លួនឡើងវិញ ហើយបានកាឡាខ្លួនជាកូនស្វាព្រៃតូចមួយចូលទៅល្បងលួងលោម បញ្ឆោតចាប់ក្មេងទាំងពីរតែម្តង។

❖ **ខ្សែទី៧៧**

រាជកុមារបានវាយវាត់ហនុមាននឹងធ្នូសរ សន្លប់ម្តងទៀតនិងបោចវល្លិ៍តូចពមួយចងស្លាបសេក ហើយឱ្យបានយកឈើមកសាកមុខបញ្ជូនទៅព្រះរាមជួយស្រាយចំណងចេញ។ ហនុមានខំរើបម្រះខ្លួនឯងយ៉ាងណាក៏ពុំរួច ឱ្យព្រះភិរុតព្រះសុត្រុតជួយស្រាយទៀត ក៏ស្រាយពុំរួចដែរ។ ហនុមានខំដើរទាំងក្តីវេទនានិងអៀនខ្មាសខតាមដងព្រៃឆ្ពោះ ទៅឱ្យព្រះរាមជួយស្រាយចំណងនៅចំពោះមុខមន្ត្រីធំៗ។ ព្រះរាមស្រាយចំណងពីសេនា រួចហើយក៏ប្រើហនុមានឱ្យនាំព្រះភិរុត ព្រះសុត្រុតចូលច្បាំងចាប់កុមារ។ ដំបូងឡើងរាជកុមារមានជ័យជំនះ ទាំងខាងវាចាទាំងខាងឫទ្ធានុភាព ហើយព្រះភិរុតនិងព្រះសុត្រុតបានដួលសន្លប់ដោយត្រូវសរ។ ពលស្វាត្រូវជាប់ចំណង ហើយហនុមានត្រូវកុមារវាយសន្លប់ជាលើកទីបី ។

ទីបំផុតព្រះភិរុតនិងព្រះសុត្រុតដឹងខ្លួនឡើងវិញ ដោយអំណាចក្រោសព្រះរាម ហើយបានផ្លែងសរទៅត្រូវរាមលក្ស្មណ៍ដួលសន្លប់។ ហនុមានស្ទុះទៅចាប់អូសនាំក្មេងនេះ ទៅថ្វាយព្រះរាម។ ចំណែកជប្បលក្ស្មណ៍រត់រួចខ្លួន។

ព្រះរាមចាត់ឱ្យសេនាចងរាជកុមារបណ្តើរអាក្រោស នៅជុំវិញរាជធានី ហើយឱ្យយកទៅឃុំឃាំងទុកសម្លាប់ក្នុងរវាងបីថ្ងៃទៀត។ ពេលនោះមិនត្រឹម តែប្រជាពលរដ្ឋក្នុងឰយុធ្យាប៉ុណ្ណោះទេ ដែលយំអាណិតរាជកុមារ សូម្បីតែទេវៈរក្សារាជធានីក៏ជួយអាណិត ហើយចុះមកជួយឧបត្ថម្ភកុមារឱ្យបានធូស្រាលអំពីទុក្ខសោកដែរ។

ជប្បលក្ស្មណ៍ក៏បានយកដំណឹងដ៏ក្រៀមក្រំនេះ ទៅថ្វាយព្រះមាតា ធ្វើឱ្យព្រះនាងសីតាសោយសោកទាល់តែសន្លប់។ ប៉ុន្តែឥសីបានជួយធ្វើឱ្យនាងដឹងខ្លួន ហើយជួយទស្សន៍ទាយឱ្យនាងមានសង្ឃឹមឡើងវិញ។ ជប្បលក្ស្មណ៍បានយកចិញ្ចៀន ព្រះមាតាមួយវង់ ជាប់នឹងខ្លួនដើម្បីតាមទៅរកព្រះជេដ្ឋា។ លុះទៅដល់ជិតក្រុងឰយុធ្យា ជប្បលក្ស្មណ៍ ឮអ្នកស្រុកជំនុំគ្នាថាបងត្រូវស្លាប់នៅថ្ងៃស្អែកក៏តាំងពួនយំនៅក្នុងព្រៃអធិដ្ឋានឱ្យទេវៈជួយ។ ព្រះឥន្ទ្រទ្រង់បានចាត់នាងទេពរម្ភាឱ្យមកជួយរាជកុមារ។ ទេពអប្សរនេះ បានមកជួយជប្បលក្ស្មណ៍ៗក៏បានលបលួចផ្ញើចិញ្ចៀនទៅព្រះជេដ្ឋា នៅក្នុងក្អមទឹកដែលនាងធ្វើជាទូលទៅឱ្យអ្នកទោស។ ដោយពិធីដងទឹកនេះ ហើយនិងមាយាស្រីផង។ នាងទេពរម្ភាអាចចូលទៅរំដោះរាមលក្ស្មណ៍អំពីទីឃុំឃាំងបានមកវិញជួបជុំបងប្អូនដោយសុវត្ថិភាព។

❖ **ខ្សែទី៧៨**

ក្មេងទាំងពីរ បានជួបសំណោះសំណាលគ្នា ហើយបានស្រុះស្រួលគ្នា ទៅរង់ចាំដំណើរមកដល់របស់ព្រះរាមនៅក្នុងព្រៃមួយ។ បន្ទាប់ពីចាប់ពួកអ្នកយាមទ្វារ ទៅឃុំឃាំង រួចហើយព្រះរាមបាននាំចតុរង្គទៅតាមចាប់រាជកុមារ។ ព្រះរាមបានទៅជួបក្មេងទាំងពីរបានដូចបំណង ហើយបានសរសើរពីលំអនិងឫទ្ធានុភាពកុមារ រួចក៏ផ្លែងសរបង្កសង្គ្រាមឡើងមួយរំពេច ប៉ុន្តែសង្គ្រាមមិនចាញ់មិនឈ្នះឡើយ។

ព្រះរាជកុមារខឹងខ្លាំងណាស់ ក៏ផ្លែងសរបម្រុងផ្តាច់ជីវិតក្សត្រទាំងបួនអង្គចោល។ ប៉ុន្តែសររបស់គេក្លាយទៅជាកម្រងផ្កា។ ដោយឃើញហេតុអស្ចារ្យនេះ ព្រះរាមក៏អធិដ្ឋានបានត្រឹមត្រូវហើយ ក៏ផ្លែងសរទៀត តែសររបស់ព្រះរាមក្លាយជាអាហារសម្រាប់កុមារសោយទៅវិញ។ ព្រះរាមសួររាជកុមារ ទើបបានដឹងថា ជាបុត្ររបស់នាងសីតារួចសួរព្រះលក្ខណ៍ ទើបដឹងថា នាងពុំទាន់ស្លាប់ ក៏នាំអនុជចុះពីរាជរថទៅសុំឱ្យបុត្រ ព្រមទទួលស្គាល់និងនាំព្រះអង្គទៅជួបនាងសីតា។ ប៉ុន្តែរាជកុមារបាននិយាយបញ្ឈឺចិត្ត ដោយបដិសេធពុំព្រមស្គាល់ឪពុក ហើយក៏ដឹងដៃគ្នារត់ទៅរកព្រះមាតា។ ព្រះរាមនាំទ័ពរត់តាមក្រោយទាំងសោកសៅ។ កុមារទាំងពីរបានយកដំណឹងនេះ ទៅថ្វាយព្រះមាតា ជាហេតុនាំឱ្យនាងសោយសោកខ្សឹកខ្សួល យ៉ាងខ្លាំងដោយអាណិតបុត្រផងនិងខឹងចំពោះព្រះរាមផង ។

ព្រះរាមនៅក្រៅអាស្រម ឮមហេសីសោយសោកកើតទុក្ខ ក៏ស្រែកសុំឱ្យនាងបើកទ្វារព្រះអង្គក៏បានចូលទៅសុំទោសផ្ទាល់។ សីតាពឹងឱ្យឥសីចេញមកទទួលជំនួស។ ព្រះរាមបានបញ្ជាក់ពីបំណងល្អរបស់ព្រះអង្គប្រាប់ឥសី ហើយបានសួរតាបសនេះពីរឿងបុត្រទាំងពីររបស់នាងសីតា។លុះបានដឹងការពិត ហើយព្រះរាមបានពឹងឱ្យតាបសជួយជាអាជ្ញាកណ្តាល។ ទោះបីឥសីបានអូសទាញលួងលោមហើយព្រះរាមបានប្រកាសប្រាប់ថាព្រះអង្គខុសហើយជាច្រើនលើក ច្រើនសារក៏ដោយក៏នាងសីតាពុំព្រមភ្លេចរឿងចាស់បានដែរ។ ទីបំផុតសីតាអនុញ្ញាតឱ្យព្រះរាមជួបត្រឹមព្រះភក្ត្រនិងពាក្យសំដីខ្លះៗតែប៉ុណ្ណោះ។

❖ **ខ្សែទី៧៩**

នាងសីតាបញ្ឈឺចិត្តព្រះរាម ដោយបញ្ជាក់ថាកាលពីមុនព្រះអង្គដឹងថា នាងស្មោះត្រង់តាមរយៈហនុមានទៅស៊ើបការ និងតាមវិធីឱ្យនាងលុយភ្លើង ម្តេចនៅតែព្រះអង្គសម្លាប់នាងទៀត។ ឥឡូវនេះនាងមកនៅក្នុងព្រៃតែងជួបយក្សាជួបព្រានព្រៃផងនោះព្រះអង្គរឹតតែប្រច័ណ្ឌនិងយកទោសនាងខ្លាំងលើសមុនទៅទៀត។ ព្រះរាមសុំឱ្យព្រះនាងយកព្រះខ័នមកកាត់កព្រះអង្គចោលបើពុំអាណិតទេ។ ប៉ុន្តែនាងសីតាតបថា «បពិត្រពាក្យនេះពីរោះ មធូរស្មានស្មោះ មេត្រីផ្អែមលើសក្រៃលែង ចំណីឆ្អិនហើយឈីពោះមិនខាន»។

ព្រះរាមដឹងថា យកជ័យជម្នះលើពាក្យសត្យរបស់នាងពុំបាន ក៏រកមធ្យោបាយសុំបុត្រ ដើម្បីឱ្យនាងសីតាទៅតាម។ ប៉ុន្តែនាងសីតាបញ្ឈឺចិត្តព្រះរាមទៀត។ ព្រះរាមយំសោកចង់សម្លាប់ខ្លួននៅទីនោះ។ សីតាខ្លាចប្ដីស្លាប់ ក៏ហៅបុត្រមកប្រគល់ឱ្យព្រះរាមនៅពេលនោះទៅ។ ព្រះរាមនាំបុត្រទៅជួបនឹងព្រះអនុជទាំងបីអង្គ ព្រមទាំងហនុមាននិងសេនាទាំងអស់ នៅក្រៅអាស្រម។ អ្នកទាំងអស់គ្នាបានសុំទោសគ្នាទៅវិញទៅមក។

ព្រះរាមបានចូលទៅនគរវិញ ហើយបាននាំបុត្រទាំងពីរទៅថ្វាយបង្គំមាតាទាំងបីអង្គ។ ពេលនោះជីដូននិងចៅបានស្គាល់គ្នា ហើយបានសំណេះសំណាលគ្នា ពីរឿងអតីតកាល ។ ព្រះរាមបានចាត់សុមន្ត័មន្ត្រីឱ្យជ្រើសរើសរកកុមារីអាយុ១០ឆ្នាំ មានរូបឆោមល្អត្រកូលខ្ពស់មកធ្វើជាភីលៀងក្មេងទាំងពីរ។ ព្រះរាមបានចាត់ចែងជប់លៀងបុត្រយ៉ាងមហោឡារិក។

យប់មួយព្រះរាជកុមារយំរលឹកមាតាព្រះរាមក៏រលឹកដែរហើយក៏ចូលទៅលួងលោមបុត្រទាំងពីរ។ លុះព្រឹកឡើងព្រះរាម ឱ្យសេនានិងភីលៀងដង្ហែកុមារទៅជួបម្ដាយប៉ុន្តែមុននឹងចេញដំណើរទៅព្រះអង្គប្រាប់បុត្រ ឱ្យជួយអង្វរនាងសីតា ព្រមវិលចូលវាំងវិញ បើព្រះនាងមិនព្រមព្រះអង្គនឹងសុគតនៅថ្ងៃណាមួយ ហើយបើនិយាយដូច្នេះហើយ នៅតែមិនព្រម ទើបទ្រង់ឱ្យភីលៀងនៅបម្រើនាងនៅទីនោះ។

រាជកុមារបាននាំភីលៀងទៅជួបមាតាដូចបំណង។ ពេលនោះម្ដាយនិងកូនយំរលឹកគ្នាយ៉ាងខ្លាំង។ ចំណែកឯភីលៀងដែលធ្លាប់ដង្ហែរនាងសីតាទៅក្រសាលទឹកពីមុនមកនោះ ក៏យំរៀបរាប់ដែរ។ សីតាបានបញ្ជាក់ថា នេះជាកម្មរបស់នាងទេ។

❖ **ខ្សែទី៨០**

រាជកុមារ បានសុំអង្វរឱ្យមាតាវិលមកនគរវិញ តាមការបញ្ជោះរបស់បិតា។ ប៉ុន្តែនាងសីតាបដិសេធហើយថាទាល់តែព្រះរាមសុគតទៅ ទើបព្រះនាងចូលទៅថ្វាយបង្គំសពតែម្ដង។ ព្រះរាជកុមារសុំថ្វាយភីលៀងទុក ឱ្យនៅបម្រើព្រះនាងតទៅទៀតតាមបណ្ដាំបិតា។ ប៉ុន្តែសីតាបានបដិសេធទៀត ព្រោះនាងរស់នៅ១០ឆ្នាំមកគ្មាន ភីលៀងទេ។ ក្មេងទាំងពីរអស់ក្ដីសង្ឃឹម និងអាណិតបិតាផង និងមាតាផងក៏សោយសោកទាល់តែសន្លប់។ ព្រះនាងសីតា ក៏លួងលោមបុត្រទាល់តែព្រមទៅជាមួយ។ ដោយដឹងថានាងសីតាយល់ព្រមវិលមកវិញ លុះត្រាតែព្រះអង្គសុគតនោះ ព្រះរាមក៏ហៅព្រះអនុជនិងសេនាជំនិត១មកជុំនុំការ។ ហនុមាន បាននិម្មិតកោដ្ឋមាសដ៏ធំមួយ។ ពួកសុំជំនិតៗ បានរៀបចំខ្លួនបម្រុងនឹងធ្វើជាយាមយាម រាជកុមារទាំងពីរត្រូវគេនាំយកទៅឆ្វាយកិច្ចការក្នុងនគរនៅមានដំណើរការធម្មតា ព្រះរាមដើរលបៗ ទៅពួននៅក្បែរកោដ្ឋមាស។

ហនុមានទៅទូលនាងសីតា ដោយកុហកថាតាំងពីបានជួបព្រះនាងមកព្រះរាមកើតទុក្ខអត់បាយរហូតដល់ស្គមខ្លួន។ លុះដឹងថា ព្រះនាងដាច់អាល័យហើយ ព្រះអង្គសោយសោកលុះត្រាសុគត។ សីតាឮដូច្នេះ ក៏សោយសោកអាណិតស្ទើរសន្លប់បាត់ស្មារតី។ ឥសីបន្ទោសហើយបង្ខំឱ្យនាងចូលមកនគរវិញ។ ពួកស្នំទាំងឡាយ ឃើញនាងសីតាស្គមខុសធម្មតាក៏នាំគ្នាយំអាណិតព្រះនាង។ នាងសីតានឹកស្មាថាពួកស្នំនេះយំកំដរសពព្រះរាមក៏ក្តុកក្តួលអួលក្នុងចិត្តហើយគក់ទ្រូងនសៀលទាល់តែសន្លប់។ ជាឱកាសល្អរបស់ព្រះរាម ក៏យាងចេញពីទីកំបាំងមកចាប់នាងប្រកងបី។ នាងសីតាដឹងខ្លួនឡើងវិញក៏ស្តីបន្ទោសព្រះរាមថាជាក្បត់ឥតខ្មាស ហើយស្ទុះរត់ចេញទៅ។ ព្រះរាមខំរត់ចេញតាមចាប់នាងក្នុងបរិវេណព្រះមេរុពុំបានក៏ស្រែកហៅអនុជនិងហនុមានឱ្យជួយស្ទាក់ចាប់។

សីតាបានឧទ្ទិសសុំឱ្យគេជះពាក្យសត្យរបស់នាងជួយ។ ពេលនោះ ព្រះធរណីក៏បើកផ្លូវបញ្ជូននាង ទៅដល់ឋានភុជង្គនាគ។ ស្តេចនាគឈ្មោះ«ភិរុណ»និងមហេសី ឈ្មោះ«រតនាទេវី» បានយកសីតាទៅតម្កល់ទុកដូចជាព្រះមាតា។ ព្រះរាមប្រើហនុមាន ឱ្យតាមទៅស៊ើបរកនាងសីតានៅឋានភុជុង្គនាគ។ ហនុមានត្រូវនាងសីតាជេរគំពោះគំរើយ បណ្តេញឱ្យត្រឡប់មកវិញ។ ព្រះរាមទាល់តម្រិះក៏សរសេរអក្ខរាភ្ជាប់នឹងមុខសរ ហើយថ្លែងទៅនាងសីតានៅឋានបាតាល។

- **តួអង្គសំខាន់ៗ**[11]

➤**តួអង្គឯក**

- ព្រះរាម បុត្រព្រះបាទទសរថ និងនាងកោសកល្យាណជានារាយណ៍បែងភាគ។
- នាងសីតា ទេពកញ្ញា និងជាបុត្រចិញ្ចឹមដែល ព្រះបាទជនករើសបានពេលទៅច្រត់ព្រះនង្គ័ល។

➤**តួអង្គរង**

- ក្រុងរាពណ៍ ស្តេចយក្សសោយរាជ្យនៅនគរលង្កា។
- នាងកៃកេសី មហេសីព្រះបាទទសរថ។
- ព្រះបាទទសរថ ព្រះរាជាសោយរាជ្យ នគរឰយុធ្យា។

➤**តួអង្គបន្ទាប់បន្សំ**

- ព្រះនាងកោសកល្យាណ មហេសីព្រះបាទទរថ។
- ព្រះនាងសមុទ្រ មហេសីព្រះទសរថ។
- ព្រះលក្ស្មណ៍ បុត្រព្រះបាទទសរថនិងនាងសមុទ្រ។

[11] វិជ្ជាស្ថានជាតិអប់រំ

- ព្រះសុត្រុត — បុត្រព្រះបាទទសរថនិងព្រះនាងកៃកេសី។
- ព្រះភិរុត — បុត្រព្រះបាទទសរថនិងព្រះនាងកៃកេសី។
- ព្រះបាទជនក — ស្តេចនគរមិថិលា ជាបិតាចិញ្ចឹមនាងសីតា
- បេក្ខជនឋានទាំងបី — មកប្រឡងលើកធ្នូសរចង់បាននាងសីតា។
- កូខ័ន — ថ្មើរព្រៃរូបអាក្រក់តែចិត្តល្អស្ម័គ្របម្រើក្សត្រទាំងបី។
- ឥសីពារទ្វាទ្យ — ជាឥសីដែលទទួលក្សត្រទាំងបីឱ្យស្នាក់នៅបរមសាលា។
- នាងនិទ្រាទេពី — ទេពធីតាតំណាងឱ្យភាពងងុយដេក។
- ព្រះមុនីវិសិដ្ឋឥសី — ឥសីរៀបចំពិធីក្នុងនគរព្ធយុធ្យា។
- បិតាកៃកេសី — ជាអយ្យកោព្រះភិរុត។
- កាកនាសូរ — យក្សដែលខ្លួនជាក្អែកមកចឹកបំផ្លាញហោមពិធីឥសីពិស្វាមិត្រ។
- ឥសីពិស្វាមិត្រ — គ្រូអាចារ្យរបស់ព្រះរាម និងព្រះលក្ស្មណ៍។
- រាមបរមសូរ — យក្សដែលចោទថា ព្រះបាទទសរថលួចឈ្មោះខ្លួនដាក់ឱ្យកូន។
- បរទុស្ត — យក្សដែលបង្កចលាចលដល់ផែនដីតែត្រូវទសរថកម្ចាត់។
- ពិរាធ — យក្សដែលចង់ឆក់នាងសីតាជាបុត្រារបស់ព្រះកាល។
- នាងសូរបនខា — យក្ខីនីប្អូនស្រីក្រុងរាពណ៍ ដែលចែចង់ព្រះរាមព្រះលក្ស្មណ៍ តែត្រូវព្រះលក្ស្មណ៍កាត់សក់ ធ្វើបាបហើយក៏បានទៅនាំបងៗជាយក្សឱ្យមកសងសឹក។
- ក្រុងខរ — បងប្រុសនាងសូរបនខា។
- ក្រុងទុសណ៍ — ប្អូនប្រុសក្រុងខរ។
- ក្រុងរាពណ៍ — ស្តេចយក្សនៅនគរលង្កា ជាបងប្រុសសូរបនខា។
- មហាកុម្ភន្ធ — យក្ស។
- ត្រីមុខ — ជាបុត្រក្រុងខរ។
- មហារីក — បរិវាក្រុងរាពណ៍ដែលប្រែក្រឡាជាប្រើសមាសទៅបំភាន់នាងសីតា។
- ព្រះធរណី — ទេវៈដែលព្រះលក្ស្មណ៍បន់ឱ្យថែរក្សានាងសីតាពេលទ្រង់ទៅតាមព្រះរាម។
- ទេពារក្ស — ទេវៈដែលព្រះលក្ស្មណ៍បន់ឱ្យថែរក្សានាងសីតា ពេលទ្រង់ទៅតាមព្រះរាម។

- អារ័ក្ស — ទេវៈដែលព្រះលក្សណ៍បន់ឱ្យថែរក្សានាងសីតាពេលទ្រង់ទៅតាមព្រះរាម។
- គិរីទេពារ័ក្សព្រឹក្សា — ទេវៈដែលព្រះលក្សណ៍បន់ឱ្យថែរក្សានាងសីតាពេលទ្រង់តាមព្រះរាម។
- កុក — ជាសត្វដែលនាំដំណឹងនាងសីតាទៅប្រាប់ព្រះរាម។
- ជតាយុ — ស្ដេចគ្រុឌដែលចង់សង្គ្រោះនាងសីតា។
- មហិង្សរាជ — ស្ដេចក្របីនៅព្រៃហេមពាន្ត។
- សន្តគិរី — ប្រពន្ធមហិង្សរាជ។
- ទូភី — កូនបហិង្សារាជ និងសន្តគិរី។
- ឥសីបញ្ចលិង្គ — ជាឥសីដែលទៅប្រាប់ទូភីឱ្យទៅប្រឡងនឹងពាលី។
- ពាលី — ស្ដេចស្វានៅខាស់ខិនបូរី។
- សុគ្រីព — ប្អូនពាលី។
- ព្រះមង្គលឥសី — ឥសីដែលសង្គ្រោះសុគ្រីព។
- មហារាជិតា — អ្នកនាំទេវតាបាចផ្កាអបអរពាលី។
- ហនុមាន — បុត្រព្រះពាយនិងអញ្ចនទេវីនិងជាសេនាព្រះរាម។
- អង្គទ — បុត្រពាលីនិងនាងមណ្ឌោគិរី។
- ជម្ពូពាន — ស្ដេចស្វាដែលព្រះរាមបំភាន់ឱ្យបម្រើខ្លួន។
- ខុនជីពទ្វារ — សេនាស្វា។
- ខុននន្ទ — សេនាស្វា។
- នាងវិកតាសី — យក្ខិនីចាំការពារបូរីលង្កាជាប្អូនរាពណ៍។
- គន្ធព — យក្សសេនាពរាយណ៍។
- រុក្ខឆន្ទ — យក្សសេនាពរាយណ៍។
- សិងអាសុរា — យក្សសេនាពរាយណ៍។
- មណ្ឌោគិរី — មហេសីរាពណ៍។
- ទិព្វទេពកញ្ញា — មហេសីរាពណ៍។
- ទេពីទេពកញ្ញា — មហេសីរាពណ៍។
- ឥសីមុនី — ឥសីដែលជួយបង្ហាញផ្លូវនិងឱ្យបាយហនុមាន។
- កាមពាលី — ក្មួយរាពណ៍និងជាបុត្រអសុរីបុរ។
- អតិកាយ — យក្សការពារកំពែងសំរិទ្ធ។
- មហាកាយ — យក្សការពារកំពែងទង់ដែង។

- ឥន្រ្ទជិត កូនរាពណ៍។
- កុម្ភកាណ៌ ប្អូនរាពណ៍។
- ពិភេក ប្អូនរាពណ៍ជាហោរាបានចុះចូលនឹងព្រះរាម។
- ខុននីលនិងខុននល សេនាមហាជម្ពូពាន។
- ត្រីអង្គ និងត្រីបុត្រ សេនាព្រះរាម។
- រាពណាសូរិទ្រ្ទ ត្រីនិងយក្សផងដែរ។
- រុក្ខសេន សេនារាពណ៍។
- រុក្ខរៈ ទាហានព្រះរាម។
- ប្រហោតមន្ត្រី ហោរារបស់រាពណ៍។
- ក្លាមឿង យក្ស។
- ព្រះព្រហ្ម អ្នកឱ្យសរដល់ឥន្រ្ទជិត។
- អតមុខ ជាកូនរាពណ៍។
- មហាទរ ជាកូនរាពណ៍។
- បាសបុត្រ ជាកូនរាពណ៍។
- ទសមុខ ជាកូនរាពណ៍។
- ត្រីសិរ ជាកូនរាពណ៍។
- នារាត័ក ជាកូនរាពណ៍។
- មហាក្បាល ជាកូនរាពណ៍។
- ទូរមុខ ជាកូនរាពណ៍។
- កុមគទាធរ ជាកូនរាពណ៍។
- ពិតរក្ខ័ស យក្សដែលឃាត់រាពណ៍កុំឱ្យសម្លាប់នាងសីតា។
- ឧសភសេនាកេសរ ស័តពាលី ទាំងបីនេះជាសេនាព្រះរាម។
- រាក្សនិងមាលមាទ ជាបរិវាទរាពណ៍។
- អាតុល័យ យក្ខិនីដែលជាប់ញាតិនឹងរាពណ៍ មកបញ្ឆោតនាងសីតាដើម្បីសងសឹក។
- ត្រីមុខ និមិត្តជាទ្រាយឱ្យព្រះលក្ស្មណ៍វះថ្លើមថ្វាយព្រះរាម
- មហិង្សា សត្វក្របីដែលព្រះអង្គកោសិនិមិត្តនាំផ្លូវនាងសីតា
- ឥសីវជ្ជប្រិត ឥសីជួយចិញ្ចឹមនាងសីតានិងបុត្រ។
- ទេពអប្សរ ចុះមកជួយយកអាសារនាងសីតាពេលប្រសូតបុត្រ
- រាមលក្ស្មណ៍ បុត្រនាងសីតានិងព្រះរាម។

- ជប្បក្សុណ៍ បុត្រកើតដោយឥសីជប្ប។
- ទេវបុត្រ យកធ្នូមកឱ្យកុមារទាំងពីរ។
- នាងទេពរម្ភា ទេពធីតាចុះមកជួយយកអាសាររាជកុមារ។
- ព្រះភិរុណនាគា ស្ដេចនាគជួយនាងសីតា។
- នាងរតនា មហេសីស្ដេចនាគ។

- **កាលអវកាស**

➤**កាល**

ដំណើររឿងបានប្រព្រឹត្តទៅនៅពេលដែលព្រះរាមព្រះលក្ស្មណ៍រៀនចប់ត្រៃវេទ ពេលឡើងសោយរាជ្យ ព្រះរាមនិងក្រុងរាពណ៍បានប្រយុទ្ធគ្នាដើម្បីដណ្ដើមនាងសីតារៀងខ្លួន...។

➤**អវកាស**

ដំណើររឿងបានប្រព្រឹត្តទៅនៅអាស្រមឥសីពិស្វាមិត្រ នគរមិថិលា នគរឦយុធ្យា នគរលង្កា ក្នុងព្រៃ...។

- **ព្រឹត្តិការណ៍សំខាន់ៗ**

**ខ.អត្ថន័យ**

**១- ប្រធានរឿង**

រឿងរាមកេរ្តិ៍បង្ហាញពី«ដំណើរជីវិតរបស់ព្រះរាមដែលជាអវតាទី៧របស់ព្រះវិស្ណុ»។ ចំពោះដំណើរជីវិតព្រះរាម យើងអាចធ្វើការសង្កេត និងបែងចែកជាបីដំណាក់កាលៈ

➤ **ដំណាក់កាលទី១** ជាដំណាក់កាលដែលនិយាយពីយុវវ័យ និងការសិក្សារៀនសូត្រមន្តវិជ្ជា ព្រមទាំងការនិទេសខ្លួនរបស់ព្រះរាម ដោះស្រាយបញ្ហាទំនាស់ ដណ្ដើមរាជបល្ល័ង្កពី សំណាក់មាតាចុងគឺនាងកៃកេសី។

➤ **ដំណាក់កាលទី២** ជារយៈពេលមួយដែលព្រះរាមត្រូវចេញប្រឡូកក្នុងសង្គមខាងក្រៅ ហើយប្រឈមមុខនឹងសត្រូវបរទេសពីគ្រប់ទិសទីរួមទាំងបេសកកម្មរំដោះភរិយាមកវិញនោះទៀតផង។

➤ **ដំណាក់កាលទី៣** ជាការបញ្ជាក់ពីភាពប្រេះឆា ក្នុងរង្វង់ក្រុមគ្រួសាររបស់ព្រះរាម ដោយនាងសីតាពុំព្រមលើកលែងទោសឱ្យទ្រង់។

**២- មូលបញ្ហារឿង**

ក្នុងដំណើររឿងរាមកេរ្តិ៍ បានបង្ហាញពីហេតុផលយ៉ាងច្រើន ដើម្បីបញ្ជាក់នូវភាពជាមនុស្សរបស់ព្រះរាម ពោលគឺ«ដំណើរជីវិតនិងតម្លៃរបស់ព្រះរាម»។ រឿងនេះបម្រើឱ្យសាសនាព្រាហ្មណ៍ដែលកំណត់ព្រះរាមជាអវតារទី៧របស់ព្រះវិស្ណុមានលក្ខណៈជា«មនុស្ស ទេវៈ» មានភារមកកម្ចាត់យក្សក្រុងរាពណ៍នៅឋានកណ្ដាល។ ចំពោះលក្ខណៈទេវៈរបស់ព្រះរាមនៅ

ត្រង់មានមហិទ្ធឫទ្ធិខ្លាំងពូកែឈ្នះលើត្រៃភព ពិសេសកម្ចាត់អស់សភាវៈអាក្រក់(យក្ស)។ រីឯលក្ខណៈមនុស្សវិញ គឺស្ថិតនៅត្រង់បញ្ហាចោទនិងស្រាយស្ថិតក្នុងក្របខណ្ឌមនុស្ស និងក្នុងសង្គមមនុស្សជាមួយនោះកវីនិពន្ធខ្មែរបានលើកតម្កើងព្រះរាមហើយផ្នែកខ្លះទៀតបញ្ចុះតម្លៃទេវភាពបន្តិចម្តងៗរហូតក្លាយជាមនុស្សភាព ឬអន់ជាងមនុស្សសាមញ្ញទៀតផង។

- ករណីទី១ជួបបញ្ហារាជសម្បត្តិក្នុងនគររវាងពាក្យសត្យ និងប្រពៃណីក្សត្រគឺព្រះអង្គបានឱ្យតម្លៃលើពាក្យសត្យ ដោយលះបង់សេចក្តីនិងអំណាចផ្ទាល់ខ្លួន និរទេសចូលព្រៃធ្វើទៅបួសជាឥសីរយៈពេល១៤ឆ្នាំ ដែលធ្វើឱ្យប្រជារាស្ត្រមានការកោតសរសើរស្ញប់ស្ញែងយ៉ាងខ្លាំង។ ចំពោះទង្វើដ៏មានសីលធម៌បែបនេះហើយ ទំនាស់រាជបល្ល័ង្កត្រូវបានបញ្ចប់ដោយសន្តិវិធី។
- ករណីទី២ បញ្ហារំដោះនាងសីតាពីក្រុងរាពណ៍៖
  - ➤តាមបែបទេវៈ មានមហិទ្ធិឫទ្ធិខ្លាំងពូកែ និងមានទេវន្តអន្តរាគមន៍
  - ➤តាមបែបមនុស្សមានលក្ខណៈជាអត្តទត្ថភាពនិយម គ្រួសារនិយម សួនតួនិយមក្នុងការរំដោះនាងសីតា ដោយព្រះអង្គប្រើគ្រប់មធ្យោបាយ សម្លាប់រង្គាលបោកបញ្ឆោតញុះញង់ បញ្ចុះបញ្ចូល គំរាមកំហែង ឱ្យជាតិសាសន៍ដទៃមកធ្វើសង្គ្រាមស្លាប់ជំនួសខ្លួនជាដើម។ ទង្វើបែបនេះ បានបន្សល់ទុកនូវផលវិបាកចុងក្រោយសម្រាប់ទ្រង់ គឺជាជីវិតដែលឯកោកណ្តោចកណ្តែងគ្មានសុភមង្គលដល់ទីបំផុត។

## ៣- បញ្ហាទំនាស់

❖**ទំនាស់ទី១ :**

➤រឿងទំនាស់ : រាជសម្បត្តិ

➤គូទំនាស់ : កៃកេសី ◂▸ ព្រះរាម

តាមផ្នត់គំនិតប្រជារាស្ត្រខ្មែរ បានចងក្រងជាពាក្យប្រៀបធៀបថា «មនុស្ស នឹងប្រាក់ យក្សនឹងសាច់ ស្តេចនឹងរាជ្យ»។ តែចំពោះទំនាស់នេះបញ្ហាដែលចោទឡើង គឺការប្រកាន់យកពាក្យសត្យឬប្រពៃណីក្សត្រ។ ស្ថានភាពនេះ គឺតម្រូវឱ្យព្រះរាមជ្រើសរើសបានតែមួយគត់ គឺព្រះអង្គត្រូវឡើងគ្រងរាជ្យមុនព្រះភិរុតស្របតាមប្រពៃណីក្សត្រ។ ពេលនោះ ពាក្យសត្យរវាងកៃកេសីនិងព្រះបាទទសរថថា ឱ្យព្រះភិរុតឡើងគ្រងរាជ្យ នៅពេលច្បាំងឈ្នះព្រះអាទិត្យនឹងក្លាយទៅជាពាក្យឥតន័យ។តែដោយបញ្ហាទាំងពីរនេះសំខាន់ដូចគ្នាទើបនៅពេលដែលព្រះរាមដោះស្រាយបញ្ហា ដោយនិរទេសខ្លួនចូលព្រៃនិងពេលព្រះបាទទសរថសុគតព្រះភិរុត ពុំព្រមឡើងសោយរាជ្យតាមបំណងមាតាឡើយ។ មិនតែប៉ុណ្ណោះ ព្រះអង្គបែរជាខឹងនឹងម្តាយ ហើយព្រះអង្គ ក៏ទៅអង្វរព្រះរាមឱ្យយាងមកសោយរាជ្យវិញ ។ ទំនាស់នេះត្រូវបានដោះស្រាយតាមរយៈការលះបង់ដ៏ខ្ពង់ខ្ពស់របស់ព្រះរាម។

❖**ទំនាស់ទី២ :**

➤រឿងទំនាស់ : សង្គ្រាមរវាងព្រះរាម និងក្រុងរាពណ៍ ដើម្បីនាងសីតា

➤គូទំនាស់ : ក្រុងរាពណ៍ ❮❯ ព្រះរាម

សង្គ្រាមនេះបានកើតឡើងពីការប៉ះពាល់នូវកិត្តិយស និងផលប្រយោជន៍គ្នាទៅវិញទៅមកពោល គឺកើតចេញពីបុគ្គល ដែលបង្កឱ្យកើតមានសង្គ្រាមដ៏ធំគឺទាំងក្រុងរាពណ៍ និងទាំងព្រះរាមសុទ្ធតែធ្វើសង្គ្រាម ដើម្បីស្ដារកិត្តិយសរៀងៗខ្លួន។ យុទ្ធវិធីនៃការធ្វើសង្គ្រាមនេះមានដូចតទៅ៖

•**យុទ្ធវិធីរបស់ព្រះរាម** ៖ ទោះបីព្រះអង្គជាអវតារព្រះវិស្ណុយ៉ាងណាក្ដីក៏ព្រះអង្គត្រូវកេណ្ឌកងទ័ពឱ្យបានច្រើនដើម្បីយកឈ្នះក្រុងរាពណ៍ដោយប្រើគ្រប់វិធីឱ្យតែបានសម្រេចតាមគោលបំណងទ្រង់៖

| | |
|---|---|
| - បំបែកបំបាក់ដើម្បីត្រួតត្រា | បានញុះញង់បងប្អូនពាលីសុគ្រីពឱ្យមានទំនាស់នឹងគ្នាកាន់តែខ្លាំងរួចលបសម្លាប់ពាលីប្លន់យកអំណាចឱ្យសុគ្រីពក្នុងការកេណ្ឌទ័ពថ្វាយព្រះអង្គ។ |
| - គាបសង្កត់អ្នកទន់ខ្សោយ | បានគំរាមកំហែងនាងមណីមេខលាឱ្យសង់ស្ពានទៅក្រុងលង្កា។ |
| - នយោបាយកុហកបោកប្រាស់ | បានខ្ចីអាវព្រះនារាយណ៍មកពាក់បន្លំភ្នែកមហាជម្ពូ ដើម្បីឱ្យមេទ័ពនេះរណបទ្រង់និងយល់ ព្រមជួយកងទ័ពក្នុងការធ្វើសង្គ្រាម។ |
| - ប្រើចិត្តសាស្ត្រ | បានទិញទឹកចិត្តអ្នកក្រោមបង្គាប់ដើម្បីឱ្យមានចិត្តស្មោះក្នុងការបម្រើព្រះអង្គដូចជាបានបញ្ចុះបញ្ចូលឬក៏បញ្ជើចបញ្ជើដោយផ្ដល់រង្វាន់ឱ្យហនុមាន ផ្ដល់បុណ្យស័ក្តិឱ្យពិភេក ដែលបានចុះចូលខាងខ្លួនហើយអន្ទងលួងលោមកុម្ភការណ៍ ឱ្យស្ម័គ្រចិត្តនៅខាងខ្លួន។ |

•**យុទ្ធវិធីក្រុងរាពណ៍** ៖ ជាអ្នកបង្កសង្គ្រាមជាមួយនឹងព្រះរាមហើយក៏ជាអ្នកមានសមត្ថភាពខ្ពស់ក្នុងការធ្វើសឹកសង្គ្រាមដែរ។ ក្រុងរាពណ៍បានប្រើយុទ្ធវិធីសំខាន់ៗ ក្នុងការតបតនឹងព្រះរាមវិញ ដើម្បីឱ្យបានសម្រេចតាមបំណងខ្លួន៖

| | |
|---|---|
| - វិធីផ្ដាច់ស្បៀង | ឱ្យយក្សឈ្មោះរុក្ខសេនទៅយាមការពារព្រៃកុំទ័ពស្វាបេះផ្លែឈើស៊ីបាន។ |

- សង្គ្រាមចិត្តសាស្ត្រ យកនាងសីតា ហោះឡើងទៅលើអាកាស ដើម្បីបញ្ឆឺចិត្តព្រះរាមឱ្យបាត់បង់ប្រសិទ្ធភាពក្នុងការបញ្ជាសឹកសង្គ្រាម។
- យុទ្ធសាស្ត្រប្រើថ្នាំពិស បានស្លថ្នាំពិស ដើម្បីសម្លាប់ទ័ពស្វា «ស្រេចស្លថ្នាំពិសដ៏ប្រាកដ ក៏នៅសាចពលស័ត- សហាស្សពានរឱ្យលាញ»។[12]
- ប្រើអំណាចផ្តាច់ការ ប្រើអាជ្ញានិយមមកលើកងទ័ព មានះពុំព្រមស្តាប់តាមយោបល់អ្នកដទៃ ហើយបង្ខិតបង្ខំឱ្យគេគោរពតាមបញ្ជាខ្លួន។

❖ **ទំនាស់ទី៣ :**

➤រឿងទំនាស់ : ការប្រច័ណ្ឌ

➤គូទំនាស់ : ព្រះរាម➤➤សីតានិងបុត្រា(រាមលក្ស្មណ៍)

•ព្រះរាមនិងសីតា ៖ជម្លោះរវាងព្រះរាមនិងមហេសីមកពីការប្រច័ណ្ឌយ៉ាងខ្លាំងរបស់ព្រះអង្គចំពោះនាងសីតាជាមួយក្រុងរាពណ៍។ ព្រះរាមលែងស្គាល់ខុសលែងស្គាល់ត្រូវមិនព្រមស្តាប់ការពិតដែលសីតាព្យាយាមបកស្រាយថ្វាយព្រះអង្គឡើយ។នៅទីបំផុតព្រះអង្គក៏បញ្ជាឱ្យព្រះលក្ស្មណ៍យកសីតាទៅសម្លាប់ទាំងនាងមានគភ៌។ បញ្ហានេះជាបញ្ហាដ៏ធំក្នុងជីវិតនាងសីតា ហើយជាហេតុនាំឱ្យនាងធ្វើការសច្ចា លែងទទួលព្រះរាមជាស្វាមីតទៅទៀត។ ដោយសារតែពាក្យសត្យនេះ ទើបសីតានិងព្រះរាមត្រូវព្រាត់គ្នាអស់មួយជីវិត ទោះបីព្រះរាមខិតខំរកវិធីរួបរួមជាមួយនាងវិញក៏ដោយ។

•ព្រះរាមនិងរាមលក្ស្មណ៍៖ ដោយសារតែវិបត្តិឪពុកមិនស្គាល់កូនកូនក៏មិនស្គាល់ឪពុក កួបផ្សំនឹងសារជាតិចក្រពត្តិរបស់ព្រះរាមដែលល្មោភនឹងអំណាចព្រួយបារម្ភខ្លាចក្រែងមានអ្នកខ្លាំងពូកែជាងខ្លួន ក៏បង្កឱ្យកើតជាសង្គ្រាម ជាមួយនឹងកូនក្មេង ដែលជាកូនបង្កើតខ្លួននេះកើតឡើង។ សង្គ្រាមនេះ ក៏បានជំរុញឱ្យទ្រង់ទទួលដំណឹងពីនាងសីតានិងស្គាល់រាជបុត្រទ្រង់ដែរ។

## ៤- វិភាគតួអង្គ

### ១- ព្រះរាម

#### ❖គុណសម្បត្តិ

- មានឫទ្ធិអំណាចខ្លាំងក្លា មានសិល្បវិជ្ជាគ្មានគូប្រៀប ដូចជាការប្រកួតលើកធ្នូសរការផ្ចាញ់សត្រូវនានា។

[12] រាមកេរ្តិ៍ខ្សែទី១០ ទំព័រទី១ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ព លើកទី២ ឆ្នាំ១៩៥៩

- មានតេជះបារមីធ្វើឱ្យរុក្ខជាតិដែលក្រៀមស្វិតប្រែជារីកស្រស់បំព្រងសត្វសាហាវប្រែជាស្លូតព្រះអាទិត្យមិនហ៊ានគោចរដល់ព្រះអង្គផ្ទុំ ពេលសម្លាប់សត្រូវស្រាប់តែមានទេវតាបាចផ្កាជូនពរ។
- អាចបញ្ជូនដួងព្រលឹងទាំងឡាយ ទៅកើតឯឋានសួគ៌បានដូចជាពាលីនិងជតាយុជាដើម។
- ជាតំណាងសភាវៈល្អ កំចាត់នូវយក្សកំណាច ដែលបង្កចលាចលដល់មនុស្សលោក។
- ជាបុត្រដែលគោរពមាតាបិតា រក្សាកិត្តិយស និងពាក្យសច្ចៈរបស់បិតា លះបង់ប្រយោជន៍ផ្ទាល់ខ្លួនដោយចេញទៅសាងផ្នួសក្នុងព្រៃ។
- ជាស្វាមីដែលស្មោះត្រង់ លះបង់គ្រប់យ៉ាងដើម្បីភរិយា។
- ជាបងប្រុសដ៏ប្រពៃ ចេះអាណិតស្រឡាញ់ប្អូន ទូញសោកអាណិតប្អូនពេលត្រូវរបួសគ្រាំគ្រាចេះអប់រំណែនាំប្អូន។
- មានប្រាជ្ញាក្នុងសង្គ្រាម ចងសម្ព័ន្ធមេត្រីអ្នកជិតខាង
- ដើម្បីកុំឱ្យបាត់បង់រាស្ត្រខ្លួន ចេះអូសទទាញសត្រូវឱ្យចុះចូល ចេះដាក់ទោសនិងឱ្យរង្វាន់ដល់អ្នកដែលនៅក្រោមបង្គាប់ យល់ចិត្តសាស្ត្រមនុស្ស។
- មានចិត្តខន្តី មិនចងអាឃាតនឹងនាងកៃកេសី ទោះបីខ្លួនត្រូវលំបាកយ៉ាងណាក៏ដោយ ហើយថែមទាំងឃាត់ឃាំងព្រះលក្ខ្មណ៍ កុំឱ្យសម្លាប់នាងទៀតផង។

❖**គុណវិបត្តិ** ក្នុងរឿងរាមកេរ្តិ៍ខ្មែរបានបន្ទាបនូវតម្លៃទេវៈតាមបែបឥណ្ឌាដែលព្រះរាមជាអវតារមិនធ្លាប់មានគុណវិបត្តិសោះឡើយ ឱ្យធ្លាក់មកកម្រិតមនុស្សសាមញ្ញ ឬអន់ជាងនេះទៀត។

- ក្នុងនាមជាអវតាររបស់ព្រទេវៈប៉ុន្តែព្រះរាមត្រូវចុះចាញ់នាងកៃកេសីដែលជាស្រីទន់ខ្សោយម្នាក់ ទើបបានជាត្រូវនិរទេសទៅនៅក្នុងព្រៃរហូតដល់១៤ឆ្នាំ។
- ព្រះរាមត្រូចាញ់កលរាពណ៍ពុំដឹងកលល្បិចគេរហូតដល់គេឆក់យកនាងសីតាទៅបាន។
- ជាអ្នកមានឫទ្ធានុភាពផុតផែនដី តែបែរជាអសមត្ថភាពក្នុងការការពារ និងរំដោះមហេសីរបស់ខ្លួនដោយត្រូវពឹងពាក់ គេគ្រប់ៗគ្នា ហើយត្រូវធ្វើចម្បាំងអស់រយៈពេលដល់ទៅ១៤ឆ្នាំ។
- ដើម្បីប្រយោជន៍បុគ្គលព្រះរាមប្រើល្បិចគ្រប់រូបភាព តាមបែបជាទេវៈផង ជាមនុស្សផងហើយថោកទាបហួសពីការស្មានទៀតផង ដូចជាគម្រាមសុគ្រីពឱ្យ

កេណ្ឌទ័ពលួចខ្ចីកាឡាព្រះព្រះនារាយណ៍មកបំភាន់ភ្នែកមហាជម្ពូគម្រាមកំហែង នាងមេខលាជាដើម។

- ព្រះរាមបានប្រើឧបាយកលញុះញង់ ទឹកចិត្តដល់ពិភេក និងទ័ពស្វាដោយប្រើ វង្វាន់លួងលោមទឹកចិត្តនានា ដើម្បីឱ្យគេក្បត់ជាតិចូលបម្រើខ្លួនឯង។
- ពុំអាចមានសមត្ថភាពដឹងហេតុការណ៍ទាំងឡាយ ដូច្នេះត្រូវពឹងពាក់ពិភេកគ្រប់ ពេលវេលារួមទាំងការជួយសង្គ្រោះព្រះលក្ស្មណ៍ផង។
- ក្នុងនាមជាកូនប្រុស តែបែរជាទួញសោកនៅពេលមានបញ្ហា ដូចជាពេលសីតា ត្រូវក្រុងរាពណ៍ឆក់ ពេលព្រះលក្ស្មណ៍ត្រូវរបួសជាដើម។ពិសេសលួចបាញ់ពាលី ពីក្រោយខ្នង កាន់តែបង្ហាញច្បាស់ឡើងពីភាពទន់ខ្សោយនេះ។
- ចាញ់កលយក្សអាគុល័យ ហើយសង្ស័យលើភក្ដីភាពនាងសីតា។
- បាត់បង់អស់វិចារណញ្ញាណនិងមនុស្សធម៌ដោយបញ្ជាឱ្យព្រះលក្ស្មណ៍យក ប្រពន្ធរបស់ខ្លួនដែលកំពុងតែមានគភ៌ទៅសម្លាប់កណ្ដាលយប់ ហើយទាមទារ យកថ្លើមមកបង្ហាញទៀត មិនខុសគ្នាពីសត្វតិរច្ឆាននោះឡើយ។
- មានគំនិតចក្រពត្តិនិយម ខ្លាចអ្នកដទៃខ្លាំងពូកែជាងខ្លួន ហើយប្រើល្បិចចោទ ប្រកាន់ថាគេចង់បានរាជសម្បត្តិ ដើម្បីនាំខ្លួនគេមកប្រហារជីវិត។
- ព្រះរាមអន់ជាងក្មេងទៅទៀត ដោយត្រូវនាំទ័ពទាំងព្រះនគរទៅចាប់ក្មេង ព្រម
- ទាំងចាប់វាយបណ្ដើរអាក្រោសពេញនគរ បាត់បង់អស់នូវទសពិធរាជធម៌ និង គុណធម៌ជាព្រះរាជា។
- ចំណុចដែលធ្វើឱ្យព្រះរាមកាន់តែអន់ថយទៅទៀតនោះ គឺសូម្បី តែវិបត្តិគ្រួសារ ផ្ទាល់ក៏ដោះស្រាយមិនរួច មិនអាចឱ្យប្រពន្ធជឿជាក់បាន ហើយបែរជាប្រើល្បិច «ព្រះរាមចូលកោដ្ឋបញ្ឆោតនាងសីតា»ដោយបញ្ជាឱ្យប្រជារាស្ត្រ និងមន្ត្រីទូទាំង ព្រះនគរ ធ្វើជាទួញសោកកាន់ទុក្ខ ដើម្បីបោកប្រាសនាងសីតាព្រមទាំងរត់ដេញ ចាប់ព្រះនាងសីតាពេញព្រះដំណាក់ធ្វើឱ្យខ្មាសអស់អាមាត្រសព្វមុខមន្ត្រី។ ទីបំផុតសីតាក៏ដៀលត្មិះយ៉ាងខ្លាំង និងភៀសខ្លួនជ្រែកទៅដល់ឋានបាតាល ចោលព្រះរាមទៅ។
- ព្រះរាមពុំមានសមត្ថភាពស្រាយបញ្ហាក្នុងគ្រួសាររហូតផ្ញើងសរជាអក្ខរាទៅនគរ លង្កា ឱ្យពិភេកជួយដោះស្រាយ តែសរក៏ត្រូវធ្លាកើទៅក្នុងឋានបាតាលទៅវិញ។

**២- នាងសីតា**

❖**គុណសម្បត្តិ** ជាស្រីដែលមាន រូបរាងសម្រស់ល្អផ្ដាច់គេទូទាំងពិភពផែនដីធ្វើ

ឱ្យពួកទេវៈមនុស្ស ព្រមទាំងយក្សលើកគ្នាដើម្បីចង់បាននាងគ្រប់ៗគ្នាតាមរយៈការលើកធ្នូសរ ប្រកួតមហិទ្ធិឫទ្ធិនៅនគរព្រះជនក។

- មានសម្ផស្សឥតខ្ចោះរបស់ព្រះនាង ហើយសូម្បីតែក្រុងរាពណ៍ដែលមានក្បាល ដប់ម្ដេ ក៏ចង់ឱ្យមានភ្នែកមួយសែនទៀតសម្រាប់មើលនិងសរសើរនាងពុំអស់ សេចក្ដីទៀតផង។ ធ្វើម្ដេចកលភ្នែកគិតដ៏យង់មួយសែនសោតនឹងមើលគ្រាន់។
- នាងជាភរិយាដ៏ស្មោះត្រង់ចំពោះស្វាមី ទោះបីត្រូវព្រាត់ឆ្ងាយអស់រយៈពេល
- ១៥ឆ្នាំ ប៉ុន្តែនាងពុំផ្លាស់ប្ដូរភក្ដីភាពចំពោះព្រះរាមឡើយ ស៊ូស្លាប់មិនឱ្យអាស្រូវ ឈ្មោះ ឬរស់ដោយគ្មានព្រះរាម«មិនគឺរាពណ៍ចិត្តចោរកាចក្រៃ លួចលោះ កណ្ដាប់ដៃ ឥឡូវនឹងនាំទៅណា។ អង្គអញដឹតដោយយក្សា ចិត្តអញប្ដេជ្ញាស៊ូ ស្លាប់ពុំឱ្យអាស្រូវ...។ ទោះឥតនៅព្រះអង្គហោង អញសូមស្លាប់ផង ព្រះបាទ សម្ដេចរាមា...»។
- នាងសុខចិត្តលះបង់សេចក្ដីសុខផ្ទាល់ខ្លួនទៅតាមបម្រើស្វាមីក្នុងព្រៃ «ដងនោះ រតន៍រាជសីតា យំភ្លាងទូលថាបពិត្រសូមស្ដេចប្រណី។ ខ្ញុំនៅឱ្យម្ដេចជា ស្រីមេ ម៉ាយឥតប្ដី ស្លាប់រស់ខ្ញុំតាមផង។ សូមព្រះករុណាខ្ញុំហោង ខ្ញុំសូមទៅផងបម្រើ ស្ដេចនរបតី»។
- នៅពេលដែលរាពណ៍ចាប់យកទៅ នាងបានយំស្រែកផ្ដាំគេឯងគ្រប់ៗ មានទាំង ព្រៃព្រឹក្សាបុព្វតា ទេពអធ្វា កុក និងជតាយុផង។
- នាងគិតគូរដល់សុខទុក្ខព្រះលក្ស្មណ៍ ហើយអាណិតស្រឡាញ់ប្អូនស្មើជីវិត។ «ឈឺមួយលក្ស្មណ៍ប្រតិបត្តិ អញឯងប្រើគាត់ ជាកម្មនឹងកើតអន្តរាយ។ ឈឺមួយ ព្រះដ៏នារាយណ៍ ថាលក្ស្មណ៍មើលងាយពុំខ្លាច ព្រះរាអាជ្ញា...។ គុណាបងនិង ប្អូននេះណា ឥតអ្វីឧបមាផ្ទឹមបាន បើប្អូនក្សិណក្ស័យ ចាកស្ថាននាងព្រមស្លាប់ ព្រមប្អូនភ្ងា...»។
- សីតាជាមាតាដ៏ប្រពៃ ដែលព្យាយាមចិញ្ចឹមថែទាំបុត្រក្នុងព្រៃភ្នំជាមួយឥសីអប់រំ
- អប់រំប្រៀនប្រដៅស្រឡាញ់បុត្រដោយព្រហ្មវិហារធម៌ដ៏ប្រសើរ ទោះក្នុងគ្រា កម្សត់កម្រយ៉ាងណាក្ដី។
- ដោយបារមីនៃការគោរពពាក្យសត្យបានធ្វើឱ្យនាងចាកចោលព្រះស្វាមីដែល
- ឥតមនុស្សធម៌ចុះទៅឋានបាតតាល។ នាងជាស្ត្រីជឿនលឿន មានសុភវិនិច្ឆ័យ
- ត្រឹមត្រូវ គឺដោយសារការបាត់បង់នូវគុណធម៌ និងករុណាមេត្តារបស់ព្រះស្វាមី ធ្វើឱ្យនាងសម្រេចចិត្តរស់នៅឆ្ងាយពីព្រះរាម បន្តនូវការរស់នៅដោយសេរីភាព

ផ្លូវចិត្ត រស់ដោយមិនចាំបាច់ពឹងពាក់បុរសជាស្វាមីដូចនារីដទៃទៀតឡើយ។ សរុបសេចក្ដីមក សីតាជាគំរូនៃមាតាដ៏ល្អ ជាស្ត្រីមានគំនិតបដិវត្តន៍ ដើម្បីរួចផុតពីអំណាចកៀបសង្កត់ ហិង្សាវិធីរបស់បុរសខ្លះជាប្ដី។ វាបានសម្ដែងចេញយ៉ាងច្បាស់នូវលក្ខណៈមនុស្សនិយមនិងធាតុពិតនៅក្នុងសង្គមខ្មែរដែលនារីទាំងឡាយបានត្រូវគេជំរុញឱ្យចេះប្រើសិទ្ធិសេរីភាព និងចេះរស់ពឹងផ្អែកលើសមត្ថភាពខ្លួនឯង។

❖**គុណវិបត្តិ**

- សីតាជាមនុស្សលោភលន់ចង់បានប្រើសមាសទុកក្រាលរាជបល្ល័ង្កពេលត្រឡប់ទៅសោយរាជ្យវិញ។
- នាងមានការតក់ស្លុតឆាប់ជ្រួលច្របល់ មិនសង្កេតពិចារណា និងសង្ស័យលើសមត្ថភាពស្វាមី ទើបដេញព្រះលក្ស្មណ៍រហូតដល់បង្ករឿងឡើង។
- នាងឆោតល្ងង់ បណ្ដាលឱ្យយក្សបោកបានម្ដងហើយម្ដងទៀត រួមទាំងការគូររូបរួចយកទៅលាក់ក្រោមក្រឡាបន្ទំ ព្រះរាមជាដើម។
- នាងទៅយកកូនដោយមិនបានប្រាប់តាឥសីដឹងធ្វើឱ្យឥសីភិតភ័យយ៉ាងខ្លាំង។
- នៅចំពោះមុខអាមាត្យ សព្វមុខមន្ត្រី នាងបានតិះដៀលស្វាមី ដោយមិនគិតពីសន្ដានចិត្តជាភរិយាដែលតែងតែអត់ធ្មត់ និងខន្តីជានិច្ចនោះឡើយ។

## ៣- ព្រះលក្ស្មណ៍

❖**គុណសម្បត្តិ**

- ព្រះលក្ស្មណ៍ជាប្អូនដ៏ល្អ ដែលចេញទៅបម្រើបងនៅក្នុងព្រៃ និងជួយច្បាំងអស់រយៈពេល១៤ឆ្នាំ។
- ជាមនុស្សស្មោះត្រង់ភក្ដីភាពប្រតិបត្តិនិងបងថ្លៃអស់ពីបេះដូងដោយមិនទាមទារ
- គុណស្រ័យទោះបីជាពេញចិត្តឬមិនពេញចិត្តក៏មិនហ៊ានជំទាស់នឹងទ្រង់ឡើយ
- ជាអ្នកដែលវៀរចាកកាមគុណ មិនរវើរវាយនឹងនាងសូរបនខា ទោះបីស្រីយក្សប្រែកាយស្រស់ស្អាតមកចៃចង់ លួងលោមយ៉ាងណាក៏ដោយ។
- មានករុណាធម៌ចំពោះនាងសីតាដោយសុខចិត្តដោះលែងនាង។
- អង់អាចក្លាហានក្នុងសង្គ្រាមដោយមិនរាថយឡើយ ហ៊ានលះបង់ជីវិតក្នុងសមរភូមិ ក្នុងឋានៈជាអ្នកនាំមុខទ័ពដោយផ្ទាល់ និងពោរពេញទៅដោយមហិទ្ធិឫទ្ធិ។

❖**គុណវិបត្តិ**

- ឆេវឆាវមិនពិចារណាស្គាល់ខ្ពស់ទាប ចង់សម្លាប់នាងកែកេសីជាម្ដាយចុង។

- ជាអ្នកបង្កទំនាស់ធំឡើង ដោយសារតែខ្វះការពិចារណាក្នុងការប្រើហិង្សាមកលើនាងសូរបនខា ចាប់នាងដែលជាស្រីភេទ កាត់ដៃ ច្រមុះ ត្រចៀក មិនសមជាមនុស្សដឹងខុសត្រូវបន្តិចសោះ។
- អសមត្ថភាព ដោយសារចាញ់ដៃក្នុងសង្គ្រាមច្រើនលើកច្រើនសារស្ទើរតែបាត់បង់ជីវិត។
- មានភក្តីភាពចំពោះបងប្រុសហួសហេតុរហូតក្លាយជាមនុស្សចេះកុហក។

**៤- ហនុមាន**

**❖គុណសម្បត្តិ**

- ហនុមានអាណិតស្រឡាញ់ យកអាសារសុគ្រីពជាឪពុកមាជួយថែរក្សាពេលដែលសុគ្រីពត្រូវបណ្តេញចេញពីនគរ។
- ជាមេទ័ពមានឫទ្ធានុភាព អង់អាច ក្លាហាន វាងវៃលើសពួកយក្សនិងទេវ:។
- ជាសេនាដ៏ស្មោះត្រង់ បម្រើម្ចាស់ឥតងាករេ ឥតចង់បានសំណងឡើង គឺដោយសារតែហនុមានដែលជាកម្លាំងដ៏សំខាន់ និងចាំបាច់បំផុតដែលធ្វើឱ្យ ការរំដោះនាងសីតាក្នុងចម្បាំង១៨ឆ្នាំនេះអាចសម្រេចជោគជ័យ។
- ជាអ្នកមានស្មារតីនិងរាងកាយមាំមួន រហ័សរហួន មានយុទ្ធសាស្ត្រខ្ពង់ខ្ពស់ក្នុង
- សង្គ្រាមដូចជាការស៊ើបអង្កេត និងបំផ្លាញលង្កា ទៅបំផ្លាញពិធីស្លពិសរបស់
- ក្រុងរាពណ៍ និងរកថ្នាំពិស លួចថ្នាំក្រោមខ្នើយរាពណ៍យកមកសង្គ្រោះព្រះលក្ស្មណ៍ជាដើម។

**❖គុណវិបត្តិ**

- ជាខ្ញុំបម្រើដាច់ថ្លៃរបស់បរទេសមិនគិតគូរពីប្រទេសជាតិខ្លួននិងរាស្ត្ររបស់ខ្លួន។
- មានចរិត របិលរប៉ូច ធ្វើការហួសបទបញ្ជា លួចទៅស៊ើបការណ៍សម្ងាត់ តែបែរជាបង្កចលាចលពេញនគរលង្កា។
- មានភាពអំនួតក្អេងក្អាង ច្រឡើសបើសធ្វើឱ្យមហាជម្ពូខឹងសម្បារយ៉ាងខ្លាំង។
- រួមគំនិតថោកទាបបោកប្រាសនាងសីតា ធ្វើឱ្យនាងខឹងហនុមានហើយដៀលត្មិះយ៉ាងអសុរោះ។
- ក្នុងនាមជាមេទ័ពម្នាក់តែបែរជាចាញ់ដៃកូនក្មេង ត្រូវរាជកុមារចាប់ចងសាក់ថ្ងាស បញ្ជូនទៅឱ្យម្ចាស់ស្រាយវិញទើបស្រាយរួច ធ្វើឱ្យអាម៉ាស់យ៉ាងខ្លាំង។

**៥- សុគ្រីព**

**❖គុណសម្បត្តិ**

- ជាប្អូនដែលគោរពស្រឡាញ់ ស្តាប់បង្គាប់បងប្រុសគ្រប់បែបយ៉ាង ដោយគ្មានគំនិតប្រុងក្បត់។
- ជាមនុស្សគោរពពាក្យសច្ចៈ ដឹងគុណអ្នកដែលធ្វើគុណលើខ្លួន។
- ជាសេនាដែលស្មោះត្រង់បម្រើព្រះរាមដោយឥតងាករេ ដូចជាការកេណ្ឌទ័ពស្វាទៅ វាយនៅក្រុងលង្កា បង្ហាញឱ្យព្រះរាមទៅចងសម្ព័ន្ធមិត្ត ជាមួយនឹងមហា
- ជម្ពូពាន ចេញច្បាំងសម្លាប់យក្សអស់ជាច្រើន។

❖**គុណវិបត្តិ**

- ជាមនុស្សទន់ខ្សោយអសមត្ថភាពជាកូនប្រុស ពេលដែលជួបបញ្ហាបែរជាអង្គុយ
- យំរហូតអាចម៍ភ្នែកក្លាយជាភ្នំ ទឹកភ្នែកក្លាយជាទឹកជ្រោះធ្លាក់ហូរមក។
- ជាមនុស្សដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ពុំបានពិចារណាឱ្យបានដិតដល់ ព្រោះតែគំនុំផ្ទាល់ខ្លួនបែរជាហ៊ានសម្លាប់បងប្រុសបង្កើតដើម្បីតែអំណាចបុណ្យស័ក្តិ ដែលបរទេសលើកបន្ទុបបែរជាលក់ជាតិលក់ជីវិតស្ម័គ្របម្រើដោយនាំទាំងពូជពង្សវង្សត្រកូល ទាំងមូលទៅធ្វើកញ្ជះបរទេស ចេញរងអាវុធស្លាប់គរទឹកគរដី ដើម្បីបម្រើបុគ្គលសូនតួតែម្នាក់ប៉ុណ្ណោះ។
- ភ្លេចគុណអ្នកដទៃ ពេលដែលគេជួយបាន យសស័ក្តធំហើយនោះ សុគ្រីព
- សប្បាយភ្លេចកេណ្ឌទ័ពថ្វាយព្រះរាម លុះត្រាតែព្រះរាមកំហែងនឹងបំផ្លាញខាសខិនបុរីចោល ទើបសុគ្រីពប្រញាប់កេណ្ឌទ័ពថ្វាយ។

## ៦- ពាលី

❖**គុណសម្បត្តិ**

- មានកម្លាំងខ្លាំង លើសទូភីនិងក្រុងរាពណ៍ ព្រមទាំងមានប្រាជ្ញាវាងវៃ ដោយដឹងថាពិបាកយកឈ្នះទូភី ក៏បបួលទៅប្រកួតនៅក្នុងរូងភ្នំ ព្រោះឈ្វេងយល់ថាវាចង្អៀតធ្វើឱ្យសត្វក្របីពិបាកធ្វើចលនា។
- មានប្រាជ្ញា ដោយឱ្យសុគ្រីពចាំបិទរូងភ្នំសម្លាប់ទូភី ប្រសិនជាឃើញឈាមក្រហមរបស់ខ្លួនហូរមក ព្រោះមិនចង់ឱ្យទូភីដែលក្មេងក្អាងឥតកោតក្រែងនោះដើរបៀតបៀនគេដទៃ ឬពូជពង្សស្វារបស់ខ្លួនទៀតឡើយ។
- ជាស្តេចនិងជាស្វាមីដ៏ល្អព្រោះពេលឮថាពាលីស្លាប់ អាមាត្រ សេនា ស្នំក្រមការព្រមទាំងនាងតារាជាមហេសី បានទួញសោកស្តាយស្រណោះពេញនគរ។
- ជាវីរជន ក្លាហានពិតមិនខ្លាចស្លាប់មិនរាថយ មិនសុំជីវិតពីព្រះរាមឡើយ គឺសុខចិត្តស្លាប់ក្នុងកិត្តិយស ប្រសើរជាងរស់មានឈ្មោះថាជាជនកំសាក «បពិត្រស្វ៊

ស្លាប់គួរហោង ត្រូវសរហើយហោងជាស្នាមភីភិនអាត្មា។ មួយសោតក៏នៅពុទ្ធប្រាកដ គេរ៉ក្នុងពាលីលុះនូវបរាជ័យ។ ក្រែងពុទ្ធទាំងក្រែភព ពាលីខ្លាចស្លាប់ក៏សូមជីវិតរស់រឹង សូវស្លាប់ទៅជាលែងនឹងរស់នៅកុំដឹងពិពិនពិភេកអាត្មា។

❖**គុណវិបត្តិ**

- មានចរិតកាម ឆេវឆាវខ្វះការពិចារណា ប្រើអំណាចផ្ដាច់ការ មិនស្ដាប់ការបកស្រាយរបស់សុគ្រីព ហើយបណ្ដេញសុគ្រីពចេញពីនគរ។
- មានចរិត កាមគុណលួចប្រពន្ធរបស់ក្រុងរាពណ៍រហូតបានអង្គទមួយហើយលួចសូម្បីតែប្រពន្ធប្អូនរបស់ប្អូនប្រុសខ្លួន មកធ្វើជាកម្មសិទ្ធិគឺនាងតារាទេពី។

## ៧- មហាជម្ពូ

❖**គុណសម្បត្តិ** មហាជម្ពូជាស្ដេចស្វា នៅនគរហោមពាន្តបុរី មានអំណាចខ្លាំងពូកែដូចពាលីដែរព្រមទាំងមានភ្នែកក្រឡេកឆេះទៀតផង។

- មហាជម្ពូជាស្ដេចមានប្រាជ្ញា និងស្រឡាញ់ជាតិ ធ្វើយ៉ាងណារកល្បិចដោះខ្លួន
- មិនលក់ជាតិទៅធ្វើជាកញ្ជះបរទេសឡើយ ដោយហេតុសុខចិត្តបញ្ជូនខុននិលនិងខុននល ជាក្មួយទៅច្បាំងប្រសើរជាងយកប្រជារាស្ត្រទៅបម្រើគេទាំងនគរ។

❖**គុណវិបត្តិ**

- ដេកទ្រមក់រហូត ធ្វើឱ្យហនុមានលើកទាំងគ្រែទៅថ្វាយព្រះរាម។
- ចាញ់កលព្រះរាមដោយជឿថាព្រះរាមជាព្រះនារាយណ៍ «គិតថាអង្គទហនុមានធ្វើកលអញបានអញចាញ់នូវកលគាត់ងាយ។ បើថាអញព្រះនារាយណ៍ អញតើពាយងាយពុំកោតព្រះរាជអជ្ញា»។

## ៨- ក្រុងរាពណ៍

❖**គុណសម្បត្តិ** ជាស្ដេចយក្សសោយរាជ្យនៅនគរលង្កា ជាស្វាមីរបស់នាងមណ្ឌោគិរី។

- ជាបងប្រុសដែលអាណិតស្រឡាញ់ប្អូន ពេលដែលឮថាប្អូនៗត្រូវគេធ្វើបាបកាប់សម្លាប់ រាពណ៍ខឹងណាស់មានគំនិតសងសឹកលើសត្រូវភ្លាម។
- ជាស្ដេចយក្សអង់អាចក្លាហាន ពុំខ្លាចសឹកសង្គ្រាមតស៊ូស្វិតស្វាញជាមួយសត្រូវប្រសើរជាងចុះញ៉មធ្វើឱ្យបាត់បង់វីរភាព និងអាប់ឱនកិត្តិយសពូជពង្សយក្ស។
- ចេះយុទ្ធសាស្ត្រ និងល្បិចក្នុងសង្គ្រាមដោយ ឱ្យសេនាទៅយាមព្រៃកុំឱ្យទ័ពស្វាបេះផ្លែឈើស៊ីបាន។
- រាពណ៍ប្រើសង្គ្រាមចិត្តសាស្ត្រដោយបញ្ឆោះនាងសីតា បញ្ឈឺចិត្តព្រះរាម។

- ជាយក្សដែលមានការសម្រេចចិត្តរឹងមាំពុំរារែក ទោះបីអ្នកណាឃាត់ឃាំង ឬជំទាស់ក៏ដោយសូម្បីតែនាងមណ្ឌោគិរី កុម្ភការណ៍ ឬពិភេកក៏ដោយ។

❖**គុណវិបត្តិ**

- ល្មោភកាមតណ្ហាលួចប្រពន្ធគេប្រពន្ធឯងគ្រប់គ្នា ដូចជាលួចនាងទេពកញ្ញា ជាប្រពន្ធព្រះឥន្ទនាងមណ្ឌោគិរីប្រពន្ធពាលីនិងនាងសីតាថែមទៀត គឺសង្គ្រាមមិនមែនបណ្តាលមកពីតែការរសងសឹកឱ្យប្អូនប៉ុណ្ណោះទេ។ តែម្យ៉ាងទៀតមកពីក្រុងរាពណ៍ឮនាងសូរបនខា សរសើរពីសម្រស់ល្អឯកនាងសីតា ធ្វើឱ្យក្រុងរាពណ៍កើតមោហៈ ត្រេកត្រអាលចង់បាន ឥតពិចារណាពីផលវិបាកចុងក្រោយ។
- ផ្តាច់ការ អត្តនោម័ត ពុំស្តាប់មតិយោបល់អ្នកដទៃ ពុំគោរពសិទ្ធិមនុស្សក្នុងការបញ្ចេញមតិរបស់ពិភេក កុម្ភកាណ៌ និងនាងមណ្ឌោគិរី ធ្វើឱ្យក្រុងលង្កាត្រូវរលាយ។
- គំរាមកំហែង ផ្ទាញ់ផ្ទាលដើម្បីឱ្យសម្រេចបំណង ដូចជាគំរាមកំហែងមហារីកថា«មឹងពុំខ្លាចអញដ៏ជា ឥសូរមឹងថា បល្ល័ក៏មានរិទ្ធិក្រៃ។ មឹងកៀចកាចគួរត្រូវដៃ ដៃអញជ័យក្រៃពិជ័យនៃសាកាគរ»។
- បញ្ឆឺចិត្ត ញុះញង់ កុម្ភកាណ៌ចេញច្បាំង«ត្រាស់ថាអានេះឥតក្រែង ហ៊ានទូលទាស់ទែង ថាអញលុះល្មោភតណ្ហា ខ្លួនវាខ្លបខ្លាចសត្វស្វា មនុស្សទ្វេហាពុំហ៊ានអើតកចេញច្បាំង»។
- ពុំស្តាប់ហេតុផល និងបំណងល្អរបស់ពិភេកបែរជាខឹងដោះស្បែកជើងវាយក្បាលប្អូនចំពោះមុខមន្ត្រី បង្កផលពិបាកសម្រាប់ខ្លួន រហូតដល់ទីបញ្ចប់ដូចសម្តីនាងមណ្ឌោគិរី«ម្តេចដោលដល់ក្រេវក្រោធក្រៃក្រៅលែងវិស័យ បរមបូរាណក្សត្រា។ ដាលដោះព្រះសុពរណបាទា បោកបោះសិរសាពិភេកកណ្តាលពោរតន៍ មុខមន្ត្រីច្រើនក្តាត់ ពុំអាសូរគាត់ជាឯកឧទរមាតា»។
- មិនត្រឹមតែមិនស្តាប់ហេតុផលទេ ក្រុងរាពណ៍ ថែមទាំងប្រើសម្តីតិះដៀលបញ្ឆឺមហេសីថែមទៀត «រាពណ៍រឹងក្រេវក្រោធរឹងស្អូង បើដូចពាក្យហង ក៏មូលនឹងពិភេក មឹងយកពិភេកនោះជាប្តី ប្តីមឹងស្នេហាចំណារចំណង់ចិត្តហោង»។
- រាពណ៍ដេកទ្រមក់ធ្វើឱ្យហនុមាន លួចថ្មក្រោមខ្នើយ ព្រមទាំងចងសក់រាពណ៍ជាបនាងមណ្ឌោគិរីទៀតផង លុះត្រាតែនាងមណ្ឌោគិរីយកដៃឆ្វេង វាយក្បាលរាពណ៍បីដង ទើបចំណងការណ៍នេះធ្វើឱ្យរាពណ៍ខ្មាសគេយ៉ាងខ្លាំង។
- ឆោតល្ងង់ ធ្វើឱ្យហនុមាន បោកប្រាស់រហូតឆេះនគរលង្កា។

**៩- ពិភេក**

❖**គុណសម្បត្តិ** ជាអ្នកដែលមានគំនិតជំនាញខាងហោរាសាស្ត្រច្បាស់លាស់ទស្សន៍ទាយពុំដែលខុសម្តងណាឡើយ។ ដូចជាការទាយពីវាសនាក្រុងលង្កាពីហេតុភេទដោយការឆ្ងល់នានារបស់ព្រះរាមពីអាថ៌កំបាំងរបស់ពួកយក្សជាដើម

- មានជំនាញពេទ្យពូកែសក្តិសិទ្ធ ជួយព្យាបាលជំងឺព្រះលក្ស្មណ៍ ពេលត្រូវពិសមោងសក្តិរបស់ឥន្ទ្រជិត កុម្ភកាណ៌បានសះស្បើយ។
- មានភាពស្លូតត្រង់ និងចង់ឱ្យបងប្រុសលះបង់ផ្លូវអាក្រក់ដើម្បីជាតិ ចៀសផុតពីអន្តរាយ។
- មានស្មារតីនឹងនរ គឺមិនតក់ស្លុត ទោះបីក្នុងស្ថានភាពលំបាកតឹងតែង ឬនៅក្នុងសមរភូមិក៏ដោយ។

❖**គុណវិបត្តិ**

- ក្បត់ជាតិពូជពង្សសន្តានខ្លួនលក់ខ្លួនបម្រើសត្រូវ។
- ដោយសារតែគំនុំផ្ទាល់ខ្លួននាំអ្នកក្រៅមកបំផ្លាញនគរខ្លួន។
- ប្រជារាស្ត្រខ្លួនរងទុក្ខដោយសារខ្លួនខ្វះការពិចារណាឱ្យបានវែងឆ្ងាយ។
- ស្មោះត្រង់ព្យាបាលរបួសឱ្យសត្រូវ។

**១០- កុម្ភកាណ៌**

❖**គុណសម្បត្តិ** ជាយក្សកាន់សីល មានចេស្តាខ្លាំងពូកែ ធ្វើឱ្យព្រះលក្ស្មណ៍ត្រូវរបួសស្ទើរស្លាប់។

- មានចិត្តអត់ឱនសុខចិត្តធ្វើតាមបង ទោះបីដឹងថាបងធ្វើខុសក៏ដោយក៏ព្រមចេញច្បាំងដោយចិត្តអង់អាចក្លាហាន ដើម្បីរក្សាកិត្តិយសបងប្រុស។
- មានការពិចារណាដឹងខុសត្រូវ ស្គាល់គុណទោស ល្អអាក្រក់ ដោយពិចារណាឃើញយល់ថារឿងរ៉ាវទាំងអស់គឺ បណ្តាលមកពីនាងសូរបនខា ចង់ប្រុសខុសមាត្រា និងតណ្ហាឥតព្រំដែនរបស់ក្រុងរាពណ៍តែម្តង។
- ស្រឡាញ់កិត្តិយស ពុំសុខចិត្តលក់ខ្លួនបម្រើបរទេស លក់ឧត្តមគតិ ស្នេហាជាតិមាតុភូមិ គ្រួសារ និងបងប្រុសឡើយ ទោះបីគេប្រើបុណ្យស័ក្តិទិញទឹកចិត្តយ៉ាងណាក៏ដោយ។
- ឆ្លាសវៃរកឃើញប្រភពនាំឱ្យមានសង្គ្រាម។
- ចង់រំលត់សង្គ្រាមដោយសន្តិវិធី។
- បំពេញកាតព្វកិច្ចជាមេទ័ពល្អ។

- ជាមេដឹកនាំពោរពេញទៅដោយវីរភាព និងគុណធម៌។

**❖គុណវិបត្តិ**

- មោទនភាពនឹងជ័យជម្នះរបស់ខ្លួនហួសហេតុបណ្ដាលឱ្យរងគ្រោះ ទីបំផុត ព្រះលក្ស្មណ៍មានឱកាសវិលត្រឡប់មកសម្លាប់វិញ។

**១១- ឥន្ទ្រជិត**

**❖គុណសម្បត្តិ** មានសិល្ប៍សាស្ត្រខ្លាំងពូកែ អាចយកឈ្នះលើព្រះលក្ស្មណ៍បានដោយសរនាគបាសដែលបាញ់ទៅកើតជានាគរយពាន់មកចាប់សត្រូវ។

- មានសេចក្ដីអង់អាចក្លាហានមោះមុតក្នុងសង្គ្រាម។
- បុត្រប្រកបដោយកតញ្ញូចំពោះឪពុកម្ដាយ។

**❖គុណវិបត្តិ**

- មោទនភាពនឹងជ័យជម្នះរបស់ខ្លួននាំឱ្យរងគ្រោះថ្ងៃក្រោយ។

**១២- អង្គទ**

**❖គុណសម្បត្តិ**

- មានមហិទ្ធិឫទ្ធិពូកែ ជាសេនាដ៏ស្មោះត្រង់នាំសារទៅប្រកាសសង្គ្រាម។ បុត្រកតញ្ញូគោរពដឹងគុណមាតាដោយធ្វើគារវៈនាងមណ្ឌោគិរីនៅលង្កា ដោយលើកដៃឆ្វេងប្រណម្យ។

**❖គុណវិបត្តិ**

- លក់ឧត្ដមគតិ បម្រើសត្រូវដែលសម្លាប់ឪពុកបង្កើតរបស់ខ្លួន។
- ជាកូនប្រុសអកតញ្ញូចំពោះឪពុក បម្រើព្រះរាមតែសម្លាប់ឪពុកខ្លួន(ពាលី) មិនដោយគន្លង។
- ធ្វើការហួសបញ្ញាក្នុងនាមជាទូតបែរជាបង្កចលាចលពាសពេញលង្កា។

**១៣- ព្រះបាទទសរថ**

**❖គុណសម្បត្តិ**

- ស្រឡាញ់បុត្រគ្រប់គ្នាដោយអប់រំថែរក្សានិងបញ្ជូនទៅរៀនសិល្ប៍វិជ្ជាគ្រប់ៗគ្នា។
- ជាស្ដេចដែលគោរពពាក្យសត្យផង និងរាជបវេណីផង ដោយសុខចិត្តបែងចែកនគរជាពីរចំណែកដើម្បីបញ្ចប់បញ្ហាទំនាស់។

**❖គុណវិបត្តិ**

- ប្រទានសន្យាផ្ដេសផ្ដាសពុំពិចារណាទើបបង្កជាបញ្ហាឡើងរហូតបុត្រាត្រូវនិទេសទៅរស់នៅរសាត់អណ្ដែតនៅក្នុងព្រៃអស់រយៈពេល១៤ឆ្នាំ ហើយប៉ះពាល់

ព្រះកិត្តិយសទៀតផង។

- ធ្វើឱ្យខុសក្រិតក្រម បវេណីក្សត្រតាំងពីយូរលង់ណាស់មកហើយ។

**១៤- នាងកៃកេសី**

❖**គុណសម្បត្តិ**

- ជាម្ដាយដែលស្រឡាញ់និងចង់ឱ្យកូន ខ្ពង់ខ្ពស់មុខបានធ្វើជាស្ដេចសោយរាជ្យ។
- លើកតម្លៃពាក្យសត្យ

❖**គុណវិបត្តិ**

- មិនគោរពប្រពៃណីក្សត្រ។
- លោភលន់ចង់បានអំណាច ជាបុព្វហេតុធ្វើស្វាមីបាត់បង់ជីវិត។
- ក្លែងសំបុត្រ ឥសីដែលធ្វើឱ្យព្រះភិរុត យ៉ាងថោកទាប។

**១៥- ព្រះភិរុតនិងសុត្រុត**

❖**គុណសម្បត្តិ**

- គោរពស្រឡាញ់បងប្រុសដោយអស់ពីចិត្ត។
- ស្រឡាញ់ និងអាលោះអាល័យដល់បិតា ហើយគោរពតាមបវេណីរបស់រាជវង្ស សំខាន់ជាងការលោភលន់ចង់បានអំណាច។
- ចង់ឱ្យពាក្យសត្យរបស់បិតា បានសម្រេចដើម្បីរក្សាកិត្តិយសទ្រង់។

❖**គុណវិបត្តិ**

- ឆេវឆាវ ឥតពិចារណាដល់បំណងល្អរបស់មាតាខ្លួន ហើយបែរជារមិលគុណ បម្រុងនឹងមាតា។

**១៦- រាមលក្ស្មណ៍និងជបលក្ស្មណ៍**

❖**គុណសម្បត្តិ**

- កុមារទាំងពីរចេះអាណិតស្រឡាញ់ ជួយគ្នាទៅវិញទៅមក ដូចជាពេលគេចាប់រាមលក្ស្មណ៍ឥសីបានបង្កើតជបលក្ស្មណ៍ៗបានប្រើល្បិចទៅរំដោះ។
- មានសមត្ថភាព និងសិល្ប៍វិជ្ជាខ្ពង់ខ្ពស់ស្មើព្រះនរាយណ៍ជាបិតា គឺហួសពីក្មេងនានាដោយវាមានអាយុត្រឹមតែ១០ឆ្នាំតែខ្លាំងក្លាអស្ចារ្យ។
- ស្រឡាញ់ប្រណិប័តន៍មាតា នឹករឭកព្រះនាងយ៉ាងខ្លាំង។
- ព្យាយាមផ្សះផ្សាទំនាស់រវាងអ្នកមានគុណទាំងពីរ។
- អាចចាប់ហនុមាន ដែលជាមេទ័ពស្វាដ៏ពូកែចងស្លាបសេកបាន ហើយហនុមានស្រាយចំណងនោះពុំរួចទៀតផង លុះត្រាតែម្ចាស់ពិតប្រាកដ គឺព្រះរាមទើប

ស្រាយរួច។

❖**គុណវិបត្តិ**

- វរិុលវរប៉ូចល្មើសនឹងបម្រាមចាប់សេះរបស់ព្រះមហាក្សត្រជិះលេងទោះបីឃើញសារចងភ្ជាប់កសេះក៏ដោយ។
- ព្រហើនកោងកាច ពុំគោរពមនុស្សចាស់ ពុំចេះគួរសម។
- ទាមទារឱ្យព្រះរាមប្រាប់ពីពង្សសន្តានជាមុន ទើបប្រាប់ជាក្រោយ។
- ក្អេងក្អាង ហួសពីសមត្ថភាព ដោយខ្លួនមានតែពីរនាក់ ហើយជាកុមារតូចៗ បែរជាចង់តតាំងនឹងមហាក្សត្រ ដែលមានទ័ពច្រើននិងពូកែៗ។ នៅទីបំផុតរាមលក្ស្មណ៍ត្រូវចាញ់ដៃ ព្រះភិរុតនិងព្រះសុត្រុតធ្វើឱ្យគេចាប់បានហើយអាក្រោសពាសពេញនគរ។

- **ឧត្តមគតិរឿង**

ក្រោយពីបានសង្កេតវិភាគទៅលើគ្រប់ផ្នែកនៃរឿងយើងអាចសន្និដ្ឋានបានពីឧត្តមគតិសំខាន់ៗ ក្នុងស្នាដៃរឿងរាមកេរ្តិ៍ដូចតទៅៈ

- អប់រំដល់អ្នកដឹកនាំគ្រប់រូបកុំឈ្លក់វង្វេងនឹងសម្រស់ស្រី
- អប់រំយុវជន គ្រប់រូបកុំភ្លើតភ្លើន ចំពោះគ្នានិងគ្នានិងត្រូវទុកចិត្តគ្នាទៅវិញទៅមក
- អប់រំឱ្យមនុស្សគ្រប់រូបមានស្មារតីរឹងប៉ឹង ចំពោះហេតុការណ៍ដែលកើតឡើងចំពោះមុខពិសេស គឺដោះស្រាយបញ្ហាដោយសន្តិវិធី
- អប់រំមនុស្សគ្រប់រូប គ្រប់សាសន៍ឱ្យគោរពនិងរស់នៅជាមួយគ្នាដោយសន្តិភាព
- រស់នៅកុំអួតក្អេងក្អាង ហួសមាឌនាំឱ្យខ្លួនទទួលភាពអន្តរាយដោយមិនដឹងខ្លួន
- ចង់ឱ្យមានជំនឿខ្លះ ដែរលើគ្រូហោ ព្រោះថានៅក្នុងនគរមួយៗតែងតែមានអ្នកចេះទាយ ដើម្បីឱ្យនគររបស់ខ្លួនបានសុខសន្តិភាព
- ក្នុងសង្គមបរិយាកាស ដែលព្រហ្មញ្ញសាសនា កំពុងគ្របដណ្តប់លើសង្គមយ៉ាងជិតស្លុបស្រាប់តែគេបាន បង្ហាញចេញតាមរយ:សាច់រឿងនូវការបញ្ចុះទេវភាព
- ហើយលើកតម្លៃមនុស្ស ដែលមនុស្សតែងតែប្រឈមមុខ ដោះស្រាយបញ្ហាដោយប្រើសមត្ថភាព គំនិត ប្រាជ្ញា កលល្បិចរៀងៗខ្លួន ដើម្បីសម្រេចបើបញ្ហាណាធូរស្រាលដោះស្រាយបាន ប្រសិនជាធ្ងន់ធ្ងរក៏ត្រូវបរាជ័យ ដូចករណីព្រះរាមជាដើម។
- បង្ហាញនូវលក្ខណ: ចក្រពត្តិផ្តាច់ការរបស់ពួកជនមួយចំនួន ដែលបានធ្វើគ្រប់យ៉ាងដើម្បីបម្រើមហិច្ឆិតារបស់ខ្លួន

- បង្ហាញពីចរឹត ស្នេហាជាតិនិងក្បត់ជាតិរបស់ជនមួយចំនួននោះ
- អប់រំអ្នកដឹកនាំ ឱ្យចេះគិតគូរដល់ប្រជារាស្ត្រ គិតប្រយោជន៍រួមជាធំមិនអត្តនោម័តមិនព្រមស្តាប់យោបល់អ្នកក្រោមបង្គាប់នោះឡើយ។គោរពពាក្យសច្ចៈ ឬពាក្យសន្យារួចហើយ

**គ- អត្ថរូប**

- **វិធីតែងនិពន្ធ**

- **ភេទរូប** : ជារឿងវីរកថាខ្នាតវែងដែលមានទំនោរព្រាហ្មណ៍និយម។
- **និទានរូប** : ជាប្រភេទកំណាព្យច្រើន សម្រាប់សម្តែងឬសូត្រក្នុងមហោស្រព យើងសង្កេតលើជើងកាព្យ ឃើញថាមានលក្ខណៈបួនបែប គឺបែបពំនោលនៅពេលនេះគេពុំទាន់ឃើញមានហៅជាឈ្មោះបទពំនោលទេ។ គេប្រើឈ្មោះថា បទសំណោរ បទពិលាប បទជើតដោយបានគោរពតាមចំនួនព្យាង្គ ចំនួនឃ្លា ចំណាប់ចួន ដូចបទពំនោល។ ក្រៅពីនេះនៅមានបទផ្សេងទៀត គឺបទព្រហ្មគីតិ បទបន្ទោលកាក និងបទមួយចំនួនទៀត ដែលមិនគោរពតាមចំនួនឃ្លានិងព្យាង្គនៃបទណាមួយឡើយ។
- **វចនរូប** : ជាអត្ថបទបែបព្រាហ្មណ៍និយមមានប្រើពាក្យពេចន៍លាយចម្រុះ ដូចជា ៖

១. ពាក្យសំស្ក្រឹត

- ប្រឹថពី : ផែនដី
- សុមិត្រ : មិត្តល្អ
- ប្រមាថ : មើលងាយ
- អធិដ្ឋាន : ការតាំងចិត្តសុំបួងសួង
- អប្រិយ៍ : មិនជាទីស្រឡាញ់
- សត្យ : សេចក្តីទៀងត្រង់
- ម្រឹត្យូវ : មច្ចុរាជ
- ស្តុតី : សេចក្តីសរសើរ សេចក្តីស្ញើច

២. ពាក្យបាលី

- ភូធរ : អ្នកទ្រទ្រង់ផែនដី=មហាក្សត្រ
- នរបតី : ព្រះមហាក្សត្រ

- អធ្វារ : ផ្លូវដងព្រៃ
- ពុទ្ធពង្ស : ខ្សែសន្តានរបស់ព្រះពុទ្ធ សាច់សាលោហិតពូជពង្ស ព្រះពុទ្ធ

៣. ពាក្យខ្មែរបុរាណ

- លិតជូញជងង្ស : លុតជង្គង់
- ដំអឹង : រឹងទទឹង

• **រចនារូប**

➤បុនរុត្តវិធី : ជាវិធីផ្ទួនដែលប្រើសម្រាប់បង្កើតភាពជាក់ស្តែងនៃសកម្មភាពតួអង្គ។ ដូចជាក្នុងខ្សែទី៣(ទំ.១២) «សឹងជិះនូវជំនិះចេញចរ ជិះនាគជិះមករ ខ្លះជិះជំនិះម្រឹគា។ ជិះគោជិះគោមហិង្សា ខ្លះជិះលៀងភា ខ្លះសោតក៏ជិះរាជសីហ៍»។

➤សញ្ចយវិធី : ជាវិធីដែលប្រមូលហេតុផ្សេងៗមកផ្តុំគ្នាដើម្បីបង្ហាញនូវចលនាមួយរហ័ស។ ដូចជាក្នុងខ្សែទី៣(ទំ.១៩) «ព្រះដំព្រះចាប់ ព្រះស្រែកសន្ធាប់...»។

➤វេសមវិធី : ជាវិធីប្រើក្នុងការបង្ហាញតួអង្គដែលរូបរាងនិងចិត្តផ្ទុយគ្នា។ ដូចជាក្នុងខ្សែទី២(ទំ.៥២) ក្នុងការពណ៌នាពីកូខ័ន« ស័ក្តសូនជាអ្នកថ្មើរព្រៃ ខ្លួនខ្មៅក្រៅវិស័យ នូវធ្មេញសស្ទឹមភ្នែកច្រាល...»។

➤និយមេតិវិធី : ជារបៀបភ្ជាប់ព្យាង្គ ឬពាក្យនៅចុងឃ្លាទី១ លោតទៅភ្ជាប់ព្យាង្គនឹងព្យាង្គ ឬពាក្យដើមបន្ទាត់។ ដូចជាក្នុងខ្សែទី៤(ទំ.៣៦) « មានជាតិបុស្ស៍បុសនាគ សូរភីអញ្ចាំនផង ក្រស្នានូវចន្ទន៍មង្ឃុត ទងលតាដ៏លាយលាស់»។

• **វឌ្ឍមានវិធី** : ជាវិធីដែលកវីនិពន្ធតុបតែង ដើម្បីផ្តល់នូវការចម្រើនបន្តិចម្តងៗនៃរឿងធ្វើឱ្យបញ្ហាតឹងតែងឡើងៗ។ ដូចក្នុងខ្សែទី២ ព្រះពិរុណមានសកម្មភាពខាងផ្លូវចិត្ត តឹងតែងឡើងៗ កាលទ្រង់យាងមកនគរអយុធ្យា ដើម្បីធ្វើបុណ្យសពបិតា ហើយដឹងការពិតដែលកៃកេសីបណ្តេញព្រះរាមទៅក្នុងព្រៃធ្វើឱ្យកំហឹងកាន់តែផ្ទុះឡើង។

• **សន្ទេហាវិធី** : ជាវិធីបង្កើតចម្ងល់ដល់អ្នកអានឆ្ងល់រហូតដល់ទីបញ្ចប់ ដូចជា៖

- តើរាពណ៍ចាប់សីតាបានទេ?
- តើព្រះរាមរំដោះសីតាបាទេ?
- តើគ្រួសារព្រះរាមជួបជុំគ្នាវិញ?

- **សំវាទវិធី** : ជាវិធីដែលធ្វើឱ្យតួអង្គឆ្លើយឆ្លងគ្នា។ ដូចជាខ្សែទី៩(ទំ.២៨-៣០) ការសន្ទនារវាងគ្រុឌ និងព្រះរាមក្រុងគ្រុឌទូលរឹងស្នង បពិត្រព្រះក៏កន្លង...។ ហៃជតាយុមានគុណក្រៃ ឥតឯស្មើនៃ...»។
- **ឯកវាទវិធី** : ជាវិធីដែលតួអង្គរៀបរាប់តែម្នាក់ឯង «អុះឱសីតា មេជាពុំងាបង ម្ដេចឡើយប្រាប់ ឱមេព្រលឹងមាស ម្ដេចឡើយប្រាសពីបងទៅ»
- **ពណ៌នាវិធី** : ជាវិធីរៀបរាប់ពីរឿងរ៉ាវសកម្មភាព ពីទេសភាពជាច្រើន។ ដូចជាខ្សែទី២(ទំ.១)ការរៀបរាប់ដំណើរ ទៅកាន់ភ្នំចិត្រកូដ ក្នុងព្រៃហេមពាន្ត«សឹកខ្លះខ្លោចខ្លះបីក្រហម ស្បូវស្មៅគ្រៀងទ្រោម វិនាសន្ទូវភ្លើងព្រៃដាល...»។
- **សបន្តរត្តវិធី** : ជារធីដែលកវីនិពន្ធ ប្រើក្នុងការអធិប្បាយអំពីចម្បាំងការប្រយុទ្ធរវាងបដិក្ខពីររូបដែលមានកម្លាំងក្ដី មានសមត្ថភាពខាងគ្រឿងអាវុធ កលល្បិចក្ដី មន្តអាគមក្ដីប្រហែលៗគ្នា។ ដូចជាក្នុងខ្សែទី៣ (ទំ.៤២) ពីចម្បាំងរវាងព្រះរាមនិងក្រុងខរះ
    - «សរខរផ្លែងជានាគា សរព្រះរាជា ជាគ្រុឌច្រវាត់ឆ្វាត់ឆៀល»។
    - «សរខរជាគជបីសំទៀរ សរព្រះផ្គាចើពៀរ ជាគជលីហាសារសឹង្ហ»។
- **ឧមបាកថាវិធី** : ជាវិធីដែលផ្សារភ្ជាប់ឡើងពីដំណាក់ទី១ ទៅដំណាក់មួយទៀត។ ដូចជា«ឧបមាកថាស្ដីពីទូភី ពាលីមិត្តទាំងអស់របស់ទសកណ្ឋដែលមកបន្តចម្បាំង...»។
- **វិធីបង្ហាញតួអង្គ** : រឿងខ្លះមានការបង្ហាញច្រើនបែបខុសៗគ្នា។ ដូចជាការបង្ហាញព្រះរាមដោយអង្គឯង«មឹងមិនដឹងតេជរិទ្ធី អង្គអញឬអ្វី គឺព្រះនារាយណ៍កាឡា...»។
- **វិធីបង្ហាញលោកិយសច្ចៈ និងអច្ឆរិយៈ** : ជាការភ្ជាប់ពីស្ថានភាពពិតៗ របស់មនុស្សទៅនឹងភាពអស្ចារ្យរបស់ទេវៈ។ ជាក់ស្ដែងព្រះរាមជាមនុស្សធម្មតាតែពេលសម្លាប់យក្សហើយ ក៏មានទេវតាបាចផ្កាឱ្យពរជ័យ ដូចជាពេលសម្លាប់ទូសកានណ៍ និងក្រុងខររួចខ្សែទី៣(ទំ.២៨) «ទាំងពេលសហាស្សទសធមិ សតសហាស្សព្រះសុបារ សឹងហោះមកថ្វាយព្រះពរ...»។

➤ជីវរូបារម្មណ៍ : ការធ្វើអ្វីដែលគ្មានជីវិតទៅមានជីវិត។ក្នុងខ្សែទី (ទំ.១)៖

*«មើលមានព្រៃព្រឹក្សាសាខា សងខាងមាគ៌ា សឹងប្រែត្រ
ជាក់សប្បាយ»។

*«លូតលាស់មាលាលេច លាយដុះដាសរៀងរាយ រូបហាន
របៀបអភិរម្យ...»។

➤ឧបមានរូបារម្មណ៍: ជាការប្រើឈ្នាប់ដើម្បីប្រៀបធៀប។ ក្នុងខ្សែទី៤(ទំ.២៥)
ព្រះរាមប្រៀបធៀបលំអនាងសីតា៖

*«បងចាំនាថ្លាស បីដូចពពិលមាសមានន័យរស្មី...»។

*«ដូចព្រះចន្ទ្រពេញដ៏បរមី លោយល់ពន្លឺក្រៃ...»។

➤ឥន្ទ្រីរូបារម្មណ៍

-ចក្ខុរូបារម្មណ៍ : ដូចជាខ្សែទី៤(ទំ.៤២) «រីកូខ័នខែងមោះហិមារូបព្ធតា
ស្រមើលស្រមាកស្ពឹមស្ពៃ...»។

-សោតបារម្មណ៍: ដូចជាខ្សែទី៤(ទំ.២៥)«ខខឹងករកាន់កាច់ភ្នំ...។ ឮសព្វ
អឺអឹងខ្ទាយខ្វរ...»។

➤ឃានជីវ្ហារូបារម្មណ៍ : ពណ៌នាក្លិនកូខ័ន ខ្សែទី១(ទំ.៤៣)«ធុំក្លិនខ្លាំងឆ្អេះឆ្អាប
ក្រៃ ដូចត្មាដ៍វិស័យ...»។

➤កាយរូបារម្មណ៍ : រូបកាយសីតា ខ្សែទី៤(ទំ.២៥-២៦)៖

*«បងចាំសម្បុរប្អូនជិត ក្រៃលែងស្រលោរឿងខៀវ
អន្លង...»។

*«វាប្លែកសម្បុរនោះដ៏បីដង មួយថ្ងៃផ្សំ១បំព្រងទី...»។

*«បងចាំចង្កេះមួយក្តាប់ ក្រសោបព្រះហស្តជុំ...»។

➤កាមរូបារម្មណ៍ : ដូចជាខ្សែទី៤(ទំ.២៤)នាងសីតារៀបរាប់ពេលរាពណ៍
ចាប់ ៖

*«អុះឱសីតា មេជាពុំងារបងម្តេចឡើយប្រាស...»។

*«ឱមេព្រលឹងមាស ម្តេចឡើយពីបង...»។

- **ចេតនារូបារម្មណ៍** : ជាការអធិប្បាធ្វើឱ្យអ្នកអានទុក្ខព្រួយ សង្វេគ រំភើប ចំបែង
កំហឹង ភ័យខ្លាច...។ជឿស្លុងដោយឥតបាច់ពិចារណាវែងឆ្ងាយ
ឡើយ។ ដូចជាក្នុងខ្សែទី៣(ទំ.២៦) ពេលរាពណ៍ចាប់សីតា
បានព្រះរាមក៏ទួញសោក៖

*«ស្តេចសោយសោកសល់ ស្មើនឹងដាច់ខ្យល់សម្តេច
របតី...»។

*«បម្រះព្រះអង្គបីដោយប្រថពី នទៀលប្រមៀលមី ដោយព្រៃ...»។

*«ឈឺក្នុងព្រះអង្គរន្ធត្រង់ចំប្រប់ ព្រះហឫទ័យដូចៗនូវ មរណ៍...»។

*«ដូចនូវក្ស័យ ឈឺក្រៃសែនដ៏សោតសល់...»។

- **មនោឬបញ្ញារូបារម្មណ៍** : ជាឃ្លាប្រយោគដែលទាមទារឱ្យអានធ្វើការត្រិះរិះពិចារណាច្រើនទើបអាចធ្វើការយល់បាន។ ដូចជាក្នុងខ្សែទី៤(ទំ.២១) «អះហៅសរិលសត្វលោកា ពុំដែលចៀសកាឡាព្រះម្រឹត្យនូវយកប្រាណទោះបីនៅសុខសួស្តីក្សេមក្សាន្ត ពុំដែលហៅមានអាយុយូរយឺនរួចកាល អំណាចទូរយល់ទូរទាល់អនេកសង្វេយក្សល្ប៍ អ្នកផងនូវដៀលថាខ្លាច»។
- **និមិត្តរូបារម្មណ៍** : ជាការពណ៌នាអ្វីតំណាងឱ្យអ្វីផ្សេងទៀត។ ដូចជាខ្សែទី២( ទំ.៣) ព្រះរាមរៀបរាប់ថា

➤ផ្កាច្បារ=ឆ្ក័រ តំណាងព្រះរាម

➤ផ្កាចំប៉ា តំណាងព្រះលក្ស្មណ៍

➤ផ្កាននោង តំណាងនាងសីតា

➤កន្លង់ ឬឝ្យូង តំណាងនាងកៃកេសី

- **ការផ្ដើមរឿង**

ការផ្ដើមរឿងនៃស្នាដៃអក្សរសិល្ប៍ប្រភេទនេះ គឺចាប់ផ្ដើមឡើងដោយការបង្ហាញពីឈ្មោះរបស់អាទិទេពធំៗទាំងបី ព្រះព្រហ្ម ព្រះឥសូរ និងពិធីបូជាយញ្ញ ឬពិធីផ្សេងៗ។ [13] ចំណែកក្នុងរឿងរាមកេរ្តិ៍ បានបង្ហាញ «ដងនោះមានអសុរា មាន្យមួយនាមា ហៅកាកនាសូរស្តែង។ឮសព្ទសង្ខធុជថ្កើងថ្កែង ព្រតគម្តែង ឥសូរដ៏រាឫទ្ធា។អសុរនោះនិរ- មិត្ររូបាជាកាកមួយសា ហោះហើរនូវតេជបីពន្លឹក។ មកចឹកហោមសាស្ត្រាធម្មិក ឮសព្ទគគឹក ស្លឹកស្មឹភ្ញីញ័ររុះរោយ»។

- **តួរឿង**

➤តួអង្គ ព្រះរាមជាអាទិទេព ជាអវតារទី៧នៃព្រះវិស្ណុ បានច្យុតយកកំណើតជាមនុស្សប្រុសដ៏អស្ចារ្យ។ ចំណែកនាងសីតាវិញ ក៏ជាកំពូលនារីល្អឯក ដាច់គេ ជាហេតុនាំឱ្យមានបេក្ខជននៅឋានទាំងបី បានចូលរួមប្រឡងលើកធ្នូសិល្ប៍ ដើម្បីយកនាងសីតាជាមហេសី។ ក្រៅពីនេះទៀត មានតួអង្គផ្សេងទៀត ដូចជាគ្រុឌជតាយុ កុក ឥសីពិស្វាមិត្រជាដើម។

---

[13] ភាសាខ្មែរ ថ្នាក់ទី១០ សៀវភៅសិស្សទំព័រទី៥៨ បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១០

➤ដំណើររឿង មានចម្បាំងមិនចេះចប់ រវាងព្រះរាម និងក្រុងរាពណ៍ រហូតរលាយក្រុងលង្កាទាំងមូល និងស្លាប់អស់ពលយក្ស និងពលស្វាជាច្រើន។ មិនតែប៉ុណ្ណោះ ក៏មានផ្លែងសរ រវាងព្រះរាម ព្រះលក្ស្មណ៍ ឥន្រ្ទជិត ជាដើម។

➤ទីកន្លែង មានព្រៃហេមពាន្ត ទណ្ឌការណ្យ នគរឰយុធ្យា មិថិលា ជាដើម។

➤បញ្ហាស្រាយ បានប្រើសិល្ប៍វិជ្ជា មន្តអាគម ល្បិចកល សងសឹកគ្នាទៅវិញទៅមក។

➤ស្នេហា ទីបំផុតព្រះរាមជាអ្នកឈ្នះ បាននាងសីតាជាមហេសី។

➤ទំនាស់ កើតឡើងដោយសារតែក្រុងរាពណ៍តំណាងឱ្យសភាវៈអាក្រក់បានចាប់យកនាងសីតាដែលជាមហេសីរបស់ព្រះរាមដែលតំណាងឱ្យសភាវៈល្អ។

➤ឧត្តមគតិរឿង បានអប់រំមនុស្សឱ្យជឿលើអាទិទេព ហើយជឿថាទុក្ខសោក ល្អ អាក្រក់របស់ខ្លួនបណ្តាមកពីអាទិទេពជាអ្នកកំណត់។

- **បញ្ចប់រឿង**

តំណាងសភាវៈល្អ(ព្រះរាម) បានទទួលជោគជ័យលើសភាវៈអាក្រក់(ក្រុងរាពណ៍)។

**ឃ.អត្ថរស**

➤ **កាព្យរស** : ជាតម្លៃនៃស្នាដៃរឿងដែលកវីសរសេរឡើង ជាបទចម្រុះពីរោះរណ្តំណៃងណាងដោយរៀបរាប់ពីទេសភាពធម្មជាតិ ដំណើររឿងហេតុ អណ្តែតអណ្តូងលន្លង់លន្លោច ពោលគឺបានបង្កើតនូវទឹកចិត្តសង្វេគ សប្បាយ សោកសៅ ពេញចិត្តជាដើម។

➤ **ប្រលោមរស** : ជាការបង្កើតឱ្យមានលក្ខណៈអណ្តែតអណ្តូង លន្លង់លន្លោចផ្សព្រេងស្នេហាកម្សត់កម្រដូចជាការបរិយាពីដំណើរទៅក្នុងព្រៃរបស់ក្សត្រទាំងបី ហើយធ្វើឱ្យអ្នកអានមានចិត្តស្រងេះស្រងោចតាមរយៈការរៀបរាប់របស់កវី។ ដូចជាក្នុង ខ្សែទី១ (ទំ.៥០)

•ព្រះស្តេចត្រេចព្រៃព្រឹក្សា ដល់ឆ្នេរគង្គា មហាទីទូរគម។

•ឮសឹងស័ព្ទសត្វយំដោយដងព្រៃភ្នំ អន្លង់ត្រមោចចក្សត្រ។

➤ **វិសេសរស**

**១- សុន្ទរស** (ល្អ) : ជាការប៉ិនប្រសប់បង្ហាញយ៉ាងត្រឹមត្រូវតាមការពិត ឬគ្រប់លក្ខណៈនៃតួអង្គហើយច្បាស់លាស់។

ដូចជា ការបង្ហាញពីលក្ខណៈនៃនាងសីតា ដែលមានសោភ័ណ សម្ផស្ស រូបរាងយ៉ាងប្រណីតជាទេពកោសល្យស្តែងឡើងតាមរយៈអក្សរសិល្ប៍។

**២- មហត្ថរស** (សម្បើមអស្ចារ្យ) : ជាតម្លៃនៃការរៀបរាប់ពីរូបរាង ឬមហិទ្ធិរិទ្ធិអំណាចរបស់តួអង្គដែលអស្ចារ្យហួសពីការពិតដើម្បីលំអផ្ទៃរឿង។

ដូចជា ការរៀបរាប់ពីរូបរាង និងកម្លាំងរបស់ទូភីៈ

•សូរសព្ទសែនអសនី ផ្ទាស់ប្រែះប្រឹថពី គគឹកទាំងព្រៃព្រឹក្សា។

•ចតុជង្ឃ៍ឈរឈានយាត្រា រូស្តម្ភសេលា មហាគិរីពិត។

•ឬចងក្រងដូចរ័តន៍មរកត បាទាច្រំច្រត់ រន្ធត់ទាំងមហាប្រឋីពី។

**៣- វីររស** : ជាតម្លៃនៃការបង្ហាញពីភាពអង់អាចក្លាហាន មោះមុតរបស់តួអង្គ ដូចជាការប្រយុទ្ធរបស់ព្រះរាម និងក្រុងខជាដើម (ខ្សែទី៣ ទំ. ២១-២៨)។

**៤- នាដ្យរស** : ជាតម្លៃដែលលេចចេញពីភាពកម្សត់ ព្រាត់ប្រាស់ វិបត្តិគ្រួសារ ជាដើម។ ដូចជា ៖

- វិបត្តិដែលបណ្ដាលឱ្យសីតាត្រូវគេចោទប្រកាន់ ហើយយកទៅសម្លាប់ទាំងមានគភ៌។
- វិបត្តិដែលសីតាពុំព្រមត្រឡប់មកជួបជុំជាមួយព្រះរាម សុខចិត្តឱ្យគ្រួសារនិរាសព្រាត់ប្រាស់គ្នា ដើម្បី ជាការដាក់ទោសដល់ស្វាមី ដែលឃោរឃៅ

អមនុស្សធម៌ ។

**៥- ហាសរស** : ជាតម្លៃដែលកើតឡើងពីលក្ខណៈ សកម្មភាព ឬចលនានៃរឿងក្ដី តួអង្គក្ដី ដែលធ្វើឱ្យអ្នកអានរីករាយ សើច អបអរសាទរជ្រះចិត្ត ។ល។ ដូចជាហនុមានស៊ីបាយតសីបីពំនូតពុំអស់ហនុមានត្រូវសុគ្រីពចាប់ដាក់ក្នុងថ្នក់យកទៅថ្វាយព្រះរាម។

**៦- សមរស** : ជាតម្លៃដែលស្ថិតនៅលើការសម្ដែង នូវលក្ខណៈសកម្មភាពនៃរឿងស៊ីសង្វាក់គ្នាសមហេតុផល ច្បាស់លាស់ ស្របទៅនឹងបញ្ហា និងបរិយាកាសនៃរឿង។ ដូចជា រាពណ៍បម្រើមហារីក ប្រែក្រឡាជាប្រើសមាសទៅបញ្ឆោតនាងសីតាជាប្រការសមបំផុត ដោយគេយល់ពីចិត្តសាស្ត្ររបស់ស្ត្រី ថានាងប្រាកដជាអត់ទ្រាំពុំបាន និងអង្វរស្វាមីឱ្យដេញចាប់មិនខាន។

**៧- ទស្សនីយរស** : ជាតម្លៃនៃការរៀបរាប់ពីទស្សនីយភាព ធម្មជាតិ ព្រៃព្រឹក្សា បក្សាបក្សីមច្ឆា សំឡេងទឹកជ្រោះ សូរស័ព្ទតន្ត្រីធម្មជាតិដែលកើតជាលំអមួយ ដល់ចក្ខុ និងសោតវិញ្ញាណរបស់អ្នកអាន។ ដូចដើមខ្សែទី២ បានរៀបរាប់ពីទេសភាពដងព្រៃភ្នំ ម្រឹគីម្រឹគា ព្រៃព្រឹក្សា បុប្ផាជាតិ។

**៨- តថរស** : ជាតម្លៃនៃការបង្ហាញពីទំនាស់នៃការដណ្ដើមរាជបល្ល័ង្ក រវាងម្ដាយចុង គឺនាងកៃកេសី ដែលជារឿងធម្មតាតែងតែកើតមានក្នុងសង្គមមនុស្ស។

**៩- អច្ឆរិយរស** : ជាលក្ខណៈបង្ហាញពីតួអង្គ ឬលក្ខណៈអស្ចារ្យហួស ពីសមត្ថភាពមនុស្ស។ ដូចជា ព្រះឥន្ទ្រ ព្រះឥសូរ ព្រះនរាយណ៍ យក្ស...។

**១០- កុសលរស** : ជាតម្លៃស្ថិតនៅលើការ ទូន្មាន ប្រៀនប្រដៅ អប់រំឱ្យស្គាល់ល្អអាក្រក់គុណទោសជាដើម។ ដូចជាការអប់រំឱ្យស្រឡាញ់ជាតិមាតុភូមិ និងប្រជារាស្ត្រ អប់រំឱ្យវៀរចាកកាមគុណតណ្ហា ព្រោះវានឹងបង្ករឱ្យអន្តរា វិនាសដូចក្រុងរាពណ៍ ជាតួយ៉ាង។

**ខ.បញ្ហាសង្គម**

**១.នយោបាយ** ដោយផ្អែកតាមដំណើររឿងរាមកេរ្តិ៍បានបង្ហាញថា ការគ្រប់គ្រងសង្គមនាសម័យនោះប្រព្រឹត្តទៅដោយព្រះរាជា។ ការគ្រងរាជ្យសម្បត្តិដោយផ្អែកទៅលើរបាក្សត្រ ឬប្រពៃណីក្សត្រ ដែលតម្រូវឱ្យក្សត្រច្បងត្រូវឡើងគ្រងរាជ្យមុនក្សត្រប្អូន។ ម្យ៉ាងទៀតចំពោះកិច្ចការពារ ឬការធ្វើសង្គ្រាមប្រឈមមុខនឹងសត្រូវពិតជាមានយុទ្ធវិធីខ្ពស់មានការគ្រប់គងកងទ័ពបានល្អ និងមានល្បិចកលដើម្បីយកឈ្នះសត្រូវ។

**២.សេដ្ឋកិច្ច**

•កសិកម្ម ទោះបីដំណើររឿងបានបង្ហាញពីបញ្ហាទំនាស់ ឬការធ្វើសង្គ្រាមដ៏វែងអន្លាយយ៉ាងណាក៏ដោយ ក៏អាចឱ្យយើងសន្និដ្ឋានបានថា សម័យក្នុងរឿងរាមកេរ្តិ៍ប្រជារាស្ត្រនិយមធ្វើស្រែចំការចិញ្ចឹមជីវិត។ ជាក់ស្តែងព្រះបាទជនកបានធ្វើពិធីច្រត់ព្រះនង្គ័លដែលជានិមិត្តរូបនៃការធ្វើស្រែចំការនៅដើមរដូវវស្សា។ ដោយផ្អែកតាមសកម្មភាពនេះ សរបញ្ជាក់ថាជនជាតិខ្មែរបានប្រកបការងារស្រែចំការដើម្បីចិញ្ចឹមជីវិត។

•សិប្បកម្ម តាមការធ្វើសឹកសង្គ្រាម ដោយប្រើអាវុធនានា។ ក្នុងសម័យនោះការផលិតប្រព្រឹត្តទៅគេអាចផលិតគ្រឿងសព្វាវុធ ដូចជាដាវលំពែងជាដើម។

•ពាណិជ្ជកម្ម ដំណើររឿងហាក់ដូចជាមិនបានបង្ហាញពីវិស័យនេះច្បាស់លាស់ទេ។

•គមនាគមន៍ អាចធ្វើដំណើរថ្មើរជើង រទេះសេះដែលមានផ្លូវគោកសម្រាប់ទំនាក់ទំនងគ្នាពីតំបន់មួយឆ្ពោះតំបន់មួយ។

**៣.សង្គមកិច្ច** ជីវភាពរបស់ប្រជារាស្ត្រមិនសូវមានភាពធូរធារទេ ព្រោះសម័យកាលនោះបានកើតសង្គ្រាមអស់កាលដ៏យូរលង់មកហើយ។

**៤.វប្បធម៌**

•ជំនឿ តែងមានជំនឿទៅលើពាក្យដំនៀលរបស់សត្វកុក ដែលជាសត្វនាំមកនូវអពមង្គល។ យ៉ាងនេះហើយបានជាព្រះលក្ម្សណ៍ស្ទើរតែប្រហារសត្វកុកទៅហើយនៅពេលរិះគន់ទៅលើព្រះរាមថៃមិនចេះរក្សាមហេសីឱ្យបានល្អ។

•ប្រពៃណីទំនៀមទម្លាប់

ការជ្រើសរើសទុកដាក់កូនចៅឱ្យមានគូស្រករ ជាភារកិច្ចឪពុកម្តាយ។ ព្រះបាទជនកបានរៀបចំពិធីប្រឡងប្រជែងរកធីតុបតី(កូនប្រសាប្រុស)ដោយការប្រឡងលើកធ្នូសិល្ប៍ដែលមានទម្ងន់ធ្ងន់ស្មើនឹងបុរសមួយពាន់នាក់ទើបលើករួច។ វិធីនេះ ជាវិធីស្វែងរកបុរសមានសមត្ថភាពដូចជាព្រះរាម ដែលសក្តិសមជាស្វាមីនាងសីតា។

ការរៀបអភិសេកឬមង្គលការ ព្រះរាម និងសីតា បានប្រព្រឹត្តទៅនៅនគរមិថិលាជានគរព្រះបាទជនកឬគេហស្ថានខាងស្រី។ ព្រះបាទជនកក៏បានចាត់សេនាឱ្យយាងព្រះបាទទសរថបិតារបស់ព្រះរាមឱ្យមកយាងចូលរួមការរៀបអភិសេកនេះដែរ។

ការចូលកោដ្ឋបញ្ឆោតនាងសីតា ក៏បានស្តែងឱ្យឃើញពីវត្តមាននៃកោដ្ឋ ព្រោះ

ខ្មែរយើងនិយមប្រើកោដ្ឋ មានទំហំធំសម្រាប់ដាក់តម្កល់សពចំពោះមហាក្សត្រ ឬឥស្សរជននានា។ កោដ្ឋមួយទៀត មានទំហំតូចសម្រាប់ដាក់អដ្ឋិធាតុក្រោយពីបូជារួចមក។

ការប្រកាន់ពាក្យសត្យ ឬពាក្យសម្បថ ខ្មែរយើងតែងអនុវត្តនិងប្រកាន់ជារៀងរហូតមក។ ដូចជានាងសីតា បានសច្ចាថាមិនវិលចូលនគរវិញ ដរាបណាព្រះរាមមិនទាន់សុគតព្រោះដោយការប្រច័ណ្ឌរបស់ព្រះរាមមកលើព្រះនាង។

•សាសនាឥទ្ធិពលព្រាហ្មណ៍និយមបានរីកដុះដាលលើមនោគតិខ្មែរ នាសម័យបុរាណតាមរយៈរឿងរាមកេរ្តិ៍នេះ។ ព្រះរាមជាអវតាររបស់ព្រះវិស្ណុ ដែលមានឫទ្ធិបារមី ជាទីសក្ការៈនៃមនុស្សជងទាំងពួង។

**❖ការសន្និដ្ឋាន**

ឆ្លងតាមការសិក្សា វិភាគពិចារណាទៅលើរឿងរាមកេរ្តិ៍ខ្មែររួចមក យើងឃើញថា អ្នកនិពន្ធមានសិល្បវិធី ក្នុងការតែងនិពន្ធបានល្អមិនអាចកាត់ថ្លៃបាន។ រឿងនេះ មានតម្លៃគ្រប់សម័យកាលនិងគ្រប់ស្រទាប់មនុស្សក្នុងសង្គម ថ្វីបើរឿងរាមកេរ្តិ៍ មានអត្ថន័យ អត្ថរូប អត្ថរសប្រកបដោយលក្ខណៈអច្ឆរិយៈ លាយឡំទៅក៏ដោយ តែរឿងនោះក៏បានពន្លេចនូវលក្ខណៈមនុស្សនិយមផងដែរ។ លក្ខណៈមនុស្សនិយមនេះហើយដែលបានរួមចំណែកឆ្លុះបញ្ចាំងអំពីជំនឿ ប្រពៃណី ទំនៀមទម្លាប់ខ្មែរ និងជីវភាពរស់នៅរបស់ខ្មែរមួយផ្នែកផងដែរ។

ម្យ៉ាងទៀត រឿងរាមកេរ្តិ៍ត្រូវបានកវីនិពន្ធយើងយកអស់បញ្ញាញាណដើម្បីច្នៃប្រឌិតដោយកំណត់យកលោកិយសច្ចជាអាទិភាពដែលខុសប្លែកពីរឿងដើមរបស់ឥណ្ឌា ឱ្យតម្លៃទៅលើអច្ឆរិយភាពជាធំ។ មិនតែប៉ុណ្ណោះ កវីនិពន្ធយើងក៏បានបញ្ជ្រាបនូវទស្សនៈពុទ្ធលទ្ធិដើម្បីកំណត់ខ្លឹមសារស្នាដៃឱ្យកាន់តែសុក្រិត្យស្របតាមទស្សនៈមនុស្សខ្មែរនាសម័យកាល នោះដែលកំពុងតែមានទំនោរទៅរកសាសនាព្រះពុទ្ធ។

សរុបមក ក្នុងនាមជាកូនខ្មែរ យើងចាំបាច់ត្រូវខិតខំសិក្សាស្រាវជ្រាវចំណេះដឹងឱ្យទូលំទូលាយចំពោះវិស័យអក្សរសាស្ត្រជាតិខ្លួន ព្រមទាំងលើកតម្កើងស្នាដៃរបស់បុព្វបុរសឱ្យកាន់តែប្រសើរឡើងថែមទៀត។

# ឯកសារពិគ្រោះ


- យើង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ ១៩៩៨។
- ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៩៩។
- មីសែលត្រាណេ ការសិក្សារឿងរាមកេរ្តិ៍ ១៩៩៥
- លាង ហាប់អាន សិក្សាអត្ថបទរឿងរាមកេរ្តិ៍ខ្មែរ រាមាយណៈឥណ្ឌា ១៩៦៦
- សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី១០ ១៩៨៨
- វេចនានុក្រមវចនានុក្រមខ្មែរភាគ១ ភាគ២ បោះពុម្ពនៅគ្រាទី៥ ឆ្នាំ ១៩៦៧
- រាមកេរ្តិ៍ ខ្សែ១ដល់ខ្សែ១០ , ខ្សែ៧៥ដល់ខ្សែ៨០ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៣៩ គ.ស១៩៩៥
- សេចក្តីណែនាំស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ដល់ ថ្នាក់ទី១២ លេខ០៣ អយក.សណន. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦
- សេង សោភា សិក្សារបៀបធៀបរឿងរាមកេរ្តិ៍ និងរឿងរាមគៀតថៃ សារណាបញ្ចប់ បរិញ្ញាអក្សរសាស្រ្តខ្មែរ ឆ្នាំ២០០៧
- សង្គមវិជ្ជាខ្មែរ សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តមសិក្សា ដោយលោក«សរ សារុន ) ឆ្នាំ ១៩៧៣-៧៤
- ប្រជុំវប្បធម៌ វិទ្យាស្ថានជាតិខេមរយានកម្ម ដោយលោក ឡុច ផ្លែង ឆ្នាំ១៩៧៣
- សៀវភៅសិក្សាគោលភាសាខ្មែរ សៀវភៅសិស្សថ្នាក់ទី១០ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១០
- សៀវភៅសិក្សាគោលអក្សរសាស្រ្តខ្មែរ សៀវភៅសិស្សថ្នាក់ទី១១ បោះពុម្ពផ្សាយ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៥
- សៀវភៅសិក្សាគោលអក្សរសាស្រ្តខ្មែរសៀវភៅសិស្សថ្នាក់ទី១២បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង សូផាត

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:..............................អយក.**

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍
## «រឿងសូផាត»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ការសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

**ប្រការ ១** - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍ «រឿងសូផាត» ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀននិងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនិងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

## **បុព្វកថា**

ការពង្រឹងគុណភាពអប់រំ គឺជាឃ្លាមួយដែលបានចែងច្បាស់ក្នុងមុំមួយនៃយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អ និងពង្រឹងគុណភាពអប់រំដើម្បីផលិតធនធានមនុស្សប្រកបដោយគុណភាព មានចំណេះដឹង ជំនាញ និងគុណតម្លៃបរិប្ូរណ៍ រួមចំណែកអភិវឌ្ឍជាតិ និងស្របតាមតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់អាទិភាព១៥ ចំណុចរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការពង្រាយគ្រូបង្រៀន ការបណ្តុះបណ្តាលគ្រូ គុណវុឌ្ឍិគ្រូបង្រៀន ការងារអធិការកិច្ច ការវាយតម្លៃលទ្ធផលសិក្សា ការងារប្រឡង កម្មវិធីសិក្សា ការកសាង និងជួសជុលអគារសិក្សា គុណភាពអប់រំនៅឧត្តមសិក្សា ការងារកីឡា ការងារយុវជន ការអប់រំបច្ចេកទេស ការកសាងសាលារៀនជំនាន់ថ្មី និងការបណ្តុះបណ្តាលនាយក ព្រមទាំងមាន ការផ្លាស់ប្តូរពីរបៀបធ្វើការខ្លះ ពីការងារដោយឡែកតាមជំនាញនីមួយៗមកជាការងាររួមតាម អនុវិស័យ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់នេះ ក្រសួងអប់រំយុវជន និងកីឡា បាន ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការសិក្សាភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ ដែលមុខវិជ្ជា នេះជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាមុខវិជ្ជាដទៃទៀតឱ្យបានល្អប្រសើរ និងសម្រាប់ប្រើប្រាស់គ្រប់ ស្ថានភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ការសិក្សាអត្ថបទអក្សរសិល្ប៍រឿងទាំងមូល គឺជាសមត្ថភាព ចម្បងមួយនៅក្នុងភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ ដែលកើតចេញពីការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការច្នៃបង្កើតថ្មី។ ហេតុដូច្នេះហើយ ទើបគណៈកម្មការ បច្ចេកទេសផ្នែកភាសាខ្មែរនិងអក្សរសាស្រ្តខ្មែរ បានរៀបចំចងក្រងឯកសារស្តីពី"ការសិក្សាអត្ថបទ អក្សរសិល្ប៍នេះឡើង។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សៀវភៅការសិក្សាអត្ថបទអក្សរសិល្ប៍នេះ នឹងបាន ជាប្រយោជន៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការរៀននិងបង្រៀន ផ្នែក សិក្សាអត្ថបទអក្សរសិល្ប៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

## អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ ពិសេសផ្នែកអក្សរសិល្ប៍ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់នោះក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ"**សិក្សាអត្ថបទអក្សរសិល្ប៍**" ដើម្បីជាជំនួយដល់លោកគ្រូអ្នកគ្រូ និងអ្នកសិក្សាទាំងឡាយ ជាពិសេសប្អូនៗសិស្សានុសិស្សដែលកំពុងសិក្សានៅមធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ ក្នុងការរៀននិងបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍។

ក្នុងឯកសារនេះមានបង្ហាញពីខ្លឹមសារសំខាន់ៗដូចជា៖

- ការបង្ហាញអត្ថបទ
- ការវិភាគអត្ថបទ
- ការសន្និដ្ឋាន

គណៈកម្មការនិពន្ធសង្ឃឹមថាឯកសារ«**ការសិក្សាអត្ថបទអក្សរសិល្ប៍រឿង សូផាត**» នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការបង្រៀននិងរៀនផ្នែកសិក្សាអត្ថបទអក្សរសិល្ប៍ ព្រមទាំងរួមចំណែកលើកកម្ពស់គ្រប់សមត្ថភាពក្នុងភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់។

គណៈកម្មការយើងខ្ញុំយល់ច្បាស់ថា ទោះបីជាមានការប្រយ័ត្នប្រយែងយ៉ាងណាក៏ដោយក៏ការចងក្រងរៀបរៀងឡើងមកនេះ នៅតែមានកង្វះខាតផ្សេងៗ ទាំងគុណភាព បច្ចេកទេស និងការខុសឆ្គងលើសលស់នូវពាក្យពេចន៍មួយចំនួនដោយអចេតនាជាមិនខាន។ ដូច្នេះ សូមលោកអ្នកដែលប្រើប្រាស់សៀវភៅនេះ មេត្តាជួយផ្តល់យោបល់រិះគន់កែលម្អលើឯកសារនេះឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈកម្មការរៀបចំឯកសារ រង់ចាំទទួលនូវមតិយោបល់រិះគន់ និងស្តាបនាពីសំណាក់លោកអ្នកគ្រប់ពេលវេលាដោយមេត្រីភាព។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោក អោ សៀម
៥- លោក ឃិន ធី

## គណៈកម្មការនិពន្ធ

១- លោក យ៉ង់ កំស៊ាន
២- លោកស្រី មៅ តាន់ណារី
៣- លោក ព្រៃ សំបូរ
៤- លោក ងិន សុតារា
៥- លោក ប៉ែន សំភាស់
៦- លោកស្រី វ៉ាន់ សុភី
៧- លោក វ៉ិត សុខខេង
៨- លោកស្រី ផាន់ សុជាតា
១០- លោកស្រី សេង ពិសិដ្ឋនារី
១១- លោកស្រី បែន នាង
១២- លោក កួយ សូគាន
១៣- លោក អ៊ិត សុធា
១៤- លោក ណន ម៉ារ៉ាឌី

## គណៈកម្មការពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
២- ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ
៣- ឯកឧត្តម រស់ សាលីន
៤- លោកជំទាវ ទន់ សាអ៊ីម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

១- លោក លឹម សុគ្គារឹទ្ធ

# មាតិកា

ទំព័រ

ប្រកាស ....................................................................................................i
បុព្វកថា ....................................................................................................ii
គណៈកម្មការ....................................................................................................iii
អារម្ភកថា....................................................................................................iv
មាតិកា....................................................................................................v
សេចក្តីផ្តើម....................................................................................................
I. ការបង្ហាញអត្ថបទ....................................................................................................
II. ទិដ្ឋភាពទំនាកទំនងរឿង....................................................................................................
III. ទិដ្ឋភាពទំនាស់....................................................................................................
IV. ទិដ្ឋភាពវិភាគតួអង្គ....................................................................................................
V. ទិដ្ឋភាពសង្គម....................................................................................................
VI. ទិដ្ឋភាពតែងនិពន្ធ....................................................................................................
VII. ទិដ្ឋភាពតម្លៃ....................................................................................................
VIII. ការសន្និដ្ឋាន....................................................................................................
IX. ឯកសារពិគ្រោះ....................................................................................................

## សិក្សាអត្ថបទអក្សរសិល្ប៍

# រឿង សូផាត

## សេចក្ដីផ្ដើម

រឿង**សូផាត** គឺជាប្រលោមលោកទំនើប និងជាស្នាដៃដ៏ល្អរបស់លោក **រីម គីន** ដែលមានភាពល្បីល្បាញក្នុងទសវត្សទី៦០ ហើយត្រូវបានក្រសួងសិក្សាធិការជាតិដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា មធ្យមសិក្សាជាតិសម្រាប់ថ្នាក់ទី៥ទំនើប។

រឿងនេះអ្នកនិពន្ធបានសរសេរតាក់តែងឡើងតាំងពីឆ្នាំ១៩៣៨មកម្ល៉េះ ប៉ុន្តែពុំមានឱកាសបោះពុម្ពផ្សាយភ្លាមទេ។ សេចក្ដីលំបាកក្នុងការបោះពុម្ពផ្សាយនេះ គឺដោយសារពេលនោះស្រុកយើងពុំទាន់សម្បូររោងពុម្ពបោះផ្សាយ។ លុះដល់ឆ្នាំ១៩៤២រឿងនេះក៏បានកំណត់ជាឆ្នាំតាក់តែងហើយក៏បានបោះពុម្ពផ្សាយដូចបំណងអ្នកនិពន្ធដែរ។ កាលនោះលោក រីម គីន បានសុំសម្រួលខ្លះពី "សមាគមសិស្សចាស់នៃអនុវិទ្យាល័យ និងវិទ្យាល័យព្រះស៊ីសុវត្ថិ" ដើម្បីផ្ញើជាមួយសំណៅដៃដែលសុំច្បាប់អនុញ្ញាតពីរាជការ ហើយបានឱ្យទៅរោងពុម្ពមួយនៅក្នុងក្រុងច្រឡឹង(ព្រៃនគរ)ជាអ្នកបោះពុម្ពឱ្យ។ ឯការបោះពុម្ពផ្សាយលើកដំបូងទៀតសោតក៏មានចំនួនតិចតួចគឺ ២០០០ច្បាប់តែប៉ុណ្ណោះ។ ស្នាដៃនេះក៏សឹងទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់អ្នកនិយមអានរឿងប្រលោមលោកនៅប្រទេសយើង។ ហេតុនេះហើយបានជាក្រសួងសិក្សាធិការជាតិនាសម័យនោះបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា នៅមធ្យមសិក្សាសម្រាប់ថ្នាក់ទី៥ទំនើបតាំងពីឆ្នាំ១៩៥០ម្ល៉េះ។ ពិសេសដោយសាររឿងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការសិក្សា ព្រោះវាបានឆ្លុះបញ្ចាំងនូវរឿងរ៉ាវជីវិតទាំងក្នុងទីក្រុង ជនបទស្រុកស្រែចម្ការ ផ្សារភ្ជាប់នឹងជីវភាពរស់នៅជាក់ស្តែងដែលសង្គមខ្មែរទាំងមូលមិនដែលជួបប្រទះក្នុងជីវិតគ្រប់ៗគ្នា។ លើសពីនេះទៀតវាក៏បានបង្ហាញពីទឹកចិត្តអាណិតស្រឡាញ់ ការគោរពប្រណិបតន៍នូវគុណគ្រូអាចារ្យបាធ្យាយ ឪពុកម្ដាយ ដោយភ្ជាប់ទៅនឹងសាសនាប្រពៃណីទំនៀមទម្លាប់របស់ខ្មែរដែលមានអត្តសញ្ញាណជាតិ និងអារ្យធម៌ដ៏រុងរឿងតាំងពីដូនតាយើងរៀងមក។ វាក៏បានឆ្លុះបញ្ចាំងផងដែរនូវគ្រប់ទិដ្ឋភាពសង្គមសេដ្ឋកិច្ច វប្បធម៌ សាសនា នយោបាយរបស់ជាតិនាសម័យកាលនោះដែលមានលក្ខណៈល្អប្រសើរ។

ដូច្នេះដោយមើលឃើញដូចជាគុណតម្លៃដ៏ល្អវិសេសវិសាលនេះហើយទើបបច្ចុប្បន្ននេះ ក្រសួងអប់រំយុវជន និងកីឡាបានលើកយករឿងនេះ មកដាក់បញ្ចូលក្នុងកម្មវិធីសិក្សាមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដើម្បីឱ្យសិស្សានុសិស្សជំនាន់ក្រោយបានសិក្សាស្វែងយល់ ពីវណ្ណកម្មអក្សរសិល្ប៍របស់បុព្វបុរសយើងដែលបានកប់បាត់ក្នុងប្រវត្តិសាស្ត្រ។ ការសិក្សាអក្សរសិល្ប៍ខ្មែរអស់រយៈពេលជាយូរមកហើយនេះធ្វើឱ្យកូនខ្មែរមើលឃើញ ចេះឱ្យតម្លៃក៏ដូចជាលើកស្ទួយកិត្តិសព្ទអក្សរសិល្ប៍ជាតិ និងសិក្សារៀនសូត្រតាម ដើម្បីបន្តវេនស្នាដៃមរតកអ្នកជំនាន់មុនកុំឱ្យផុតរលត់ ដូចពាក្យស្លោកមួយពោលថា " អក្សរពណ្ណរាយ ជាតិថ្កើងថ្កាន "ដូច្នេះដែរ។

គណៈកម្មការរៀបចំឯកសារសិក្សាអត្ថបទរឿង "សូផាត"នេះរំពឹងថាតាមរយៈការបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សខ្មែរទាំងអស់នឹងយល់ដឹងជ្រួតជ្រាបពីឧត្តមគតិនៃរឿង ចេះវិភាគរឿងក៏ដូចជាទិដ្ឋភាពតំណែងនិពន្ធមួយទៀតដែលជាបទពិសោធល្អសម្រាប់សាបព្រោះចំណេះដឹងដល់មនុស្សជំនាន់ក្រោយឱ្យក្លាយជាអ្នកមានចំណេះដឹងបំណិនប្រសប់ និងជំនាញក្នុងការអនុវត្តក៏ដូចជាការងារតែងនិពន្ធទៀតផង។

ខាងក្រោមនេះគឺជាការលើកយករឿង "សូផាត"មកសិក្សាវិភាគដើម្បីបានជាទុនសម្រាប់គ្រូបង្រៀនក៏ដូចជាសិស្សានុសិស្សសិក្សាស្វែងយល់ទៅតាមទម្រង់សិក្សាអត្ថបទរឿងបែបប្រលោមលោកទំនើបដែលមាន។

## I- ទិដ្ឋភាពប្រវត្តិ

### ១- អត្ថបទ

- ចំណងជើង : រឿងសូផាត
- ប្រភព : មកពីប្រទេសកម្ពុជា
- ប្រភេទ : ប្រលោមលោកទំនើបបែបមនោសញ្ចេតនា
- ចលនា : ខេមរនិយមដែលឆ្លុះបញ្ចាំងពីសង្គមខ្មែរសម័យអាណានិគមនិយមបារាំង។

### ២.អ្នកនិពន្ធ

- ឈ្មោះអ្នកនិពន្ធ : **លោក រីម គីន**
- ជីវប្រវត្តិ

លោក រីម គីន ជាអ្នកនិពន្ធមួយរូបក្នុងសម័យអក្សរសាស្ត្រនាសតវត្សទី២០។ លោកមានស្រុកកំណើតនៅទីក្រុងភ្នំពេញក្នុងសង្កាត់លេខ៥។ កើតនៅឆ្នាំ ១៩១១ ហើយបិតាលោកជា

ភ្នាក់ងារត្រួតត្រាការក្នុងក្រុមសាធារណការដែលមានតួនាទីដើរមើលការងារកម្មករធ្វើផ្លូវពីស្រុកមួយទៅស្រុកមួយ ពីកន្លែងមួយទៅកន្លែងមួយពុំសូវទៀងទាត់ឡើយ។ ដោយសារឪពុកម្តាយមានភារកិច្ចគ្រួសារទៅប្រកបមុខងារនៅតាមស្រុកភូមិជាច្រើនដូច្នេះហើយទើបកុមារ រីម គីន បានជួបប្រជាជនជាច្រើនកន្លែង។ ជួនកាលឪពុកលោកមិននៅ លោកនៅកម្សត់តែពីរនាក់ម្តាយតាមស្រុកភូមិនានានោះ។ ជួនកាលនៅនឹងផ្ទះកំណើតនាក្រុងភ្នំពេញដែលជាហេតុនាំឱ្យលោកកើតបាននូវមនោសញ្ចេតនាស្រឡាញ់យ៉ាងលើសលប់ ព្រមទាំងជាប់ចិត្តនឹងជីវភាពអ្នកស្រុកស្រែចម្ការតាំងពីកុមារភាពមក។ ជាអកុសល ឪពុកលោកក៏បានទទួលមរណភាពដោយការប្រយុទ្ធនឹងពួកចោរប្លន់មួយក្រុមនៅភូមិកំពង់កន្ទួត ពេលដែលលោក មានអាយុទើបតែ៧ឆ្នាំ។ ដូច្នេះលោកត្រូវរស់នៅយ៉ាងកម្សត់ពីរនាក់ម្តាយនៅទីក្រុងភ្នំពេញ តែពុំពិបាកប៉ុន្មានទេព្រោះមានប្រាក់និវត្តន៍ពីខ្មោចឪពុក និងមាតាលោកមានចំណេះខាងហោរាសាស្រ្តដែលគ្រានោះអ្នកស្រុក អ្នកភូមិឡើងចុះញឹកញាប់បានថវិកាមួយចំនួនទៀតគ្រាន់ចិញ្ចឹមជីវិត។

អំពីបងប្អូនលោកមានច្រើននាក់ដែរ ប៉ុន្តែជាម្តាយទីទៃពីគ្នា ព្រោះលោករីមដែលជាឪពុកលោកមានប្រពន្ធមុនរួចហើយ មុននឹងភពប្រសព្វនឹងលោកស្រីសោ ដែលជាម្តាយរបស់លោកនោះ។

ក្នុងវ័យកុមារលោក រីម គីនបានរៀនអក្សរខ្មែរក្នុងដំណាក់ព្រះភិក្ខុមួយអង្គព្រះនាមអាចារ្យសាំង ដែលត្រូវជាបងជីដូនមួយញាតិខាងម្តាយ គង់នៅវត្តស្វាយដង្គំ សង្កាត់លេខ៣ ក្រុងភ្នំពេញ។ កុមារ រីម គីនជាក្មេងយកចិត្តទុកដាក់គោរពប្រណិបតន៍ព្រះសង្ឃពុំដែលមានឆ្គងឡើយ។ លោកថែមទាំងឧស្សាហ៍បោសសម្អាតកុដិសាលា ព្រះវិហារ ដងទឹក និងដាំទឹកក្តៅជាដើម។ កាលនោះកុមារ រីម គីន ជាប់ចិត្តបណ្តុះនិស្ស័យក្នុងអក្សរសាស្រ្តជាតិច្រើនណាស់ព្រោះលោកធ្លាប់ឮពួករៀនអានសាស្រ្តារឿង សាស្រ្តាច្បាប់ ក្នុងអក្សរសាស្រ្តខ្មែររៀងរាល់ថ្ងៃរហូតដល់បានស្តាប់បានឃើញភិក្ខុសោមលោករៀនអត្ថបទបាលីក្នុងដំណាក់លោកគ្រូអាចារ្យសាំងនោះផង។ ក្រោយមកកុមារនេះបានទទួលការសិក្សានៅសាលាកុមារីព្រះនរោត្តមរួចមករៀននៅសាលា ឌូដាត៍ ដឺឡាក្រេ(សព្វថ្ងៃជាសាលាព្រះអង្គអេង)រហូតដល់ប្រឡងជាប់វិញ្ញាបនបត្របឋមសិក្សា បារាំង-ឥណ្ឌូចិន(Certificate d'Etude Primaire Franco-Indochinois) ឆ្នាំបន្ទាប់មកនៅគ.ស ១៩២៩ លោកបានចូលរៀននៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ (កាលនោះស្ថិតនៅត្រង់មន្ទីរពេទ្យព្រះកេតុមាលាសព្វថ្ងៃនេះ)។

ក្រោយពីលោកប្រឡងសញ្ញាបត្រមធ្យមសិក្សាហើយ លោកក៏បានចូលបំពេញវិជ្ជាគរុកោសល្យទៀត។ បន្ទាប់មក លោកបានចេញទៅបម្រើការជាគ្រូបង្រៀនដែលរាជការផ្លាស់ទៅបង្រៀននៅខេត្តបាត់ដំបង។នៅពេលនោះហើយដែលអ្នកនិពន្ធ រីម គីនបានឈានចូលស៊ុបក្នុងជីវភាពព្រមជាមួយការរីកដុះដាលឡើងនូវចិត្តស្នេហាអក្សរសាស្ត្រដែលជាធាតុដើមនាំឱ្យមានការផ្ដួចផ្ដើមគំនិតរបស់លោកក្នុងកិច្ចការនិពន្ធរឿងរ៉ាវផ្សេងៗ។ មួយឆ្នាំក្រោយមកគឺនៅឆ្នាំ១៩៣៥ លោកក៏បានផ្លាស់ត្រឡប់មកទីក្រុងភ្នំពេញវិញដោយទទួលមុខងារជាអនុរក្សនៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយគ្រានោះលោកក៏បានរៀបអាពាហ៍ពិពាហ៍ផងដែរ។

លុះមកដល់គ.ស១៩៣៩ លោកក៏បានទៅបង្រៀននៅសាលាបឋមសិក្សាចាក់អង្រែ (សព្វថ្ងៃជាសាលាបឋមសិក្សាចៅពញាហុក)។ ក្រោយមកក៏មកបង្រៀននៅសាលាឧបសម្ព័ន្ធគរុវិជ្ជា(Annexe Nnormale )ដែលក្រោយនោះបន្តិច លោកក៏ប្រឡងជាប់ជាគ្រូបង្រៀន Instituteur ពេញយស។ រាជការក៏ឱ្យលោកបង្រៀននៅសាលាមធ្យមសិក្សាសាលាគរុកោសល្យតាំងពីគ.ស១៩៥៧មក ក្នុងឋានៈជាសាស្ត្រចារ្យខាងភាសាជាតិរហូតដល់ពេលសាលានេះបានប្រែក្លាយជាវិទ្យាស្ថានជាតិគរុកោសល្យ (NIE សព្វថ្ងៃ)។

ក្រៅពីបង្រៀននៅសាលារាជការ លោក រីម គីន ឆ្លៀតពេលទៅបង្រៀននៅសាលាឯកជនខ្លះទៀត ដើម្បីជួយបំប៉នភាសាជាតិឱ្យជ្រួតជ្រាបដល់យុវសិស្សខ្មែរទូទៅ។ ពេលទំនេរបន្តិចបន្តួចក្រៅពីកែវិញ្ញាសារបស់សិស្សលោកក៏ឆ្លៀតសរសេររឿងជាពាក្យរាយ ពាក្យកាព្យសៀវភៅសម្រាប់សិស្សរៀន និងបកប្រែរឿងខ្លះដែលល្អៗពីភាសាបរទេសទៀត។ ហេតុនេះហើយបានជាគេស្គាល់លោកច្រើនគ្នា ដោយកិត្តិយសក្នុងការសរសេរនេះ ត្បិតរឿងខ្លះបោះពុម្ពទៅក៏ទទួលការពេញនិយមសន្ធឹកសន្ធាប់ពីអ្នកអាន និងរឿងខ្លះទៀតយកទៅសម្ដែងជាសិល្បៈ ក៏ទទួលបានជោគជ័យ ដូចជាជោគជ័យក្នុងការប្រកួតប្រជែងក្នុងរាត្រីសិល្បៈនៅចំពោះព្រះភ័ក្ត្រនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តមសីហនុដែលព្រះអង្គទ្រង់ប្រោសព្រះរាជទានគ្រឿងឥស្សរិយយសដល់អ្នកនិពន្ធនេះជារឿយៗផង។

នៅគ.ស១៩៥៥ គ្រាដែលអ្នកនិពន្ធខ្មែរបានរួបរួមគ្នាធ្វើជាសមាគម លោក រីម គីនបានទទួលការទុកចិត្តពីអ្នកនិពន្ធទាំងអស់ តែងតាំងលោកធ្វើជាប្រធានសមាគមនេះអស់រយៈពេលពីរឆ្នាំ។

លុះដល់ខែតុលា គ.ស១៩៥៨ លោកបានមានជំងឺក្នុងក្បាលមកញាំញីអស់រយៈពេលបីខែ។ ជំងឺនេះពុំព្រមស្រាកស្រាន្តសោះ ទោះបីបើគ្រួសារលោកខិតខំថែទាំប្រកបដោយឱសថល្អយ៉ាងណាក៏ដោយ។ ដល់មកថ្ងៃអង្គារ ទី២៧ ខែមករា គ.ស១៩៥៩ មច្ចុរាជក៏ប្រហារផ្តាច់យកជីវិតលោកទៅ ក្នុងពេលទៀបអាធ្រាត ម៉ោង១១កណ្តាលយប់។ ការសោកស្តាយនៃក្រុមគ្រួសារ និងសហសេវិកជាអ្នកនិពន្ធទាំងអស់រួមទាំងបណ្តាជនទូទៅដែលជាអ្នកស្នេហាអក្សរសាស្ត្រផងដែរ។

ពិធីបុណ្យឈាបនកិច្ចនៃសពនេះ បានរៀបចំឡើងឧឡារិក កាលពីថ្ងៃទី៣១ ខែមករា គ.ស១៩៥៩ នៅឈាបនដ្ឋានវត្តឧណ្ណាលោមក្រោមកិច្ចឧបត្ថម្ភនៃក្រសួងសិក្សាធិការជាតិ ជាតំណាងសម្តេចព្រះឧបយុវរាជបានអញ្ជើញទៅបំពាក់គ្រឿងឥស្សរិយយស ដល់សពអ្នកនិពន្ធនេះជាបច្ឆាមរណានាមផង។

ក្រោយអ្នកនិពន្ធ រីម គីន ទទួលមរណភាពទៅ គេរើរកឃើញស្នាដៃលោកដែលសរសេរហើយសម្រេចបានខ្លះ ក៏បោះពុម្ពចេញផ្សាយ ហើយខ្លះទៀត ពុំទាន់បានបោះពុម្ពនៅឡើយ។

- **ស្នាដៃសំខាន់ៗ**

**ក- រឿងបោះពុម្ពផ្សាយហើយ**

១- រឿង សូ ផាត (បោះពុម្ពពីគ.ស១៩៥២)
២- រឿងចិត្តចងចាំ (រឿងល្ខោនបោះពុម្ពហើយ)
៣- រឿង ក្លាហាន (បោះពុម្ពហើយពីគ.ស១៩៤៩)
៤- រឿង ស្ត្រីកំព្រា (បោះពុម្ពហើយពីគ.ស១៩៥១)
៥- រឿង ទឹងមមឹង (បោះពុម្ពហើយពីគ.ស១៩៥៣)
៦- រឿងរតននារី (បោះពុម្ពហើយពីគ.ស១៩៥៤)
៧- រឿងមើលព្រះចន្ទ្រា (បោះពុម្ពក្នុងទស្សនាវដ្តីរាត្រីថ្ងៃសៅរ៍)
៨- រឿងសហការី (បោះពុម្ពក្នុងទស្សនាវដ្តីរាត្រីថ្ងៃសៅរ៍)
៩- រឿងពលវង្សា (បោះពុម្ពក្នុងទស្សនាវដ្តីរាត្រីថ្ងៃសៅរ៍)
១០- រឿងឈាមរកឈាម (បោះពុម្ពហើយពីគ.ស១៩៥៥)
១១- រឿងសេនាកំសត់ (បោះពុម្ពហើយពីគ.ស១៩៥៥)
១២- រឿងរៀនមើលពន្យល់ (បែបសិក្សា)

១៣- ប្រជុំរឿងព្រេង (បែបសិក្សា)

១៤- រឿងសាមណី (ផ្សាយក្នុងទស្សនាវដ្ដីវឌ្ឍនធម៌)

១៥- រឿងជំទាវយូ (ផ្សាយក្នុងទស្សនាវដ្ដីមិត្តសាលាបាលី)

១៦- រឿងថីមៅ (បោះពុម្ពក្នុងទស្សនាវដ្ដីរាត្រីថ្ងៃសៅរ៍)

១៧- រឿងប្រច័ណ្ឌ (បោះពុម្ពក្នុងទស្សនាវដ្ដីរាត្រីថ្ងៃសៅរ៍)

**ខ- រឿងពុំទាន់បានបោះពុម្ព**

១- រឿងចៅបាយក្ដាំង (បែបរឿងព្រេង)

២- រឿងមនុស្សកំណាញ់ (បែបរឿងព្រេង)

៣- រឿងខ្ញុំ (ពាក្យកាព្យ)

៤- រឿងឱ្យស្គាល់ (ពាក្យកាព្យ)

៥- រឿងកូនអ្នកកាប់ឧស (ពាក្យកាព្យ)

៦- រឿងមនុស្សគមទាំងបួន (រឿងល្ខោន)

៧- រឿងកុដុម្ពីក៏មន្ត្រីកិត្តិយស (រឿងល្ខោន)

៨- រឿងថ្លាងផ្ទុះធ្លាយ (រឿងល្ខោន)

៩- រឿងក្បាលគ្នាទំពែក (រឿងល្ខោន)

១០- រឿងកំលោះអាយុ៥០ឆ្នាំ (រឿងល្ខោន)

១១- រឿងគុនវុឌ្ឍី (រឿងល្ខោន)

១២- រឿងវិស្សមកាល (រឿងល្ខោន)

១៣- រឿងលួចស្រឡាញ់លួចកើតទុក្ខ (រឿងល្ខោន)

១៤- រឿងព្រះកុមារ (រឿងល្ខោន)

១៥- រឿងចោរគួរចេតនា (រឿងល្ខោន)

១៦- រឿងឡីស៊ីត (រឿងបកប្រែពីភាសាបរទេស)

១៧- រឿងគ្មានគ្រួសារ (រឿងបកប្រែពីភាសាបរទេស)

ក្រៅពីនេះមានព័ត៌មានថា លោកមានសរសេរស្នាដៃជាច្រើនទៀតតែបាត់បង់អស់ទៅយើងរកពុំបាន។ ចំនួនរឿងទាំងនេះលោកបានសរសេររៀបរាប់ក្នុងសៀវភៅមួយកត់ត្រាពីជីវប្រវត្តិផ្ទាល់ខ្លួនរបស់លោក ហើយដែលជាឯកសារផ្ទាល់របស់គ្រួសារលោក។

លើសពីនេះទៀតលោក លី ធាមតេង សមាជិកអ្នកនិពន្ធ និងជាគណៈកម្មការស្រាវជ្រាវអក្សរសាស្ត្រដែលបានចងក្រងពីជីវប្រវត្តិរបស់លោក រីម គីន ហើយលោកបានដកស្រង់សម្តីផ្ទាល់របស់លោក រីម គីន នៅពេលដែលលោកឈឺកាន់តែខ្លាំង ហើយលោកបាននិយាយប្រាប់មកលោកលី ធាមតេង លោកហែល សុផា និងលោកម៉ា ឡាយខេម ថា៖ " អស់លោកកុំបោះបង់សមាគម មានតែយើងអ្នកនិពន្ធនេះហើយជ្រោមជ្រែងអក្សរសាស្ត្ររុងរឿង..."

**៣-កាលកំណត់តែង :** រឿងនេះនិពន្ធឡើងនៅឆ្នាំ១៩៣៨

**៤-សង្គមបរិយាកាស**

**ក- កាលប្រវត្តិ**

ដំណើររឿង សូផាត ស្ថិតក្រោយសង្គ្រាមលោកលើកទី២ ឆ្នាំ១៩៣៩-១៩៤៥ដែលជប៉ុនចូលស្រុកបានដេញពួកអាណានិគមបារាំង។ ប្រទេសកម្ពុជាមានការផ្លាស់ប្តូរនាយករដ្ឋមន្ត្រីថ្មី(លោក ស៊ឺង ង៉ុកថាញ់) ។

ខ- ព្រឹត្តិការណ៍សំខាន់ៗ

ព្រឹត្តិការណ៍សំខាន់ៗក្នុងរឿងមាន៖

- ការផ្លាស់ប្តូរមន្ត្រីរាជការ ដូចជាមានសំបុត្រពីរាជការធំនៅភ្នំពេញផ្លាស់លោកចៅហ្វាយស្រុក ស្រុកសិរីសោភ័ណទៅទីក្រុងភ្នំពេញដើម្បីកាន់កាប់រាជការថ្មីទៀត(ជំពូក១)។
- ជម្លោះរវាងណារិន និងសិស្សសាលាធំៗនាំឱ្យមានវត្តមានសូ ផាត ទៅរស់នៅជាមួយលោកសូផាតឪពុកចិញ្ចឹមណា រិន(ជំពូក៣)
- វត្តមានចិញ្ចៀនដែលសូផាត ភ្លេចធ្វើឱ្យឪពុកស្គាល់កូនហើយយកចិត្តទុកដាក់ទំនុកបម្រុងសូ ផាតដោយអាថ៌កំបាំង(ជំពូកទី៥)
- សូផាតរត់ចេញពីផ្ទះ និងការស្តីដណ្តឹងនាងម៉ានយ៉ាន(ជំពូកទី៦)
- ការសម្លាប់ខ្លួនរបស់នាងម៉ានយ៉ានក្នុងថ្ងៃរៀបការ(ជំពូកទី១២)
- សូផាត ម៉ានយ៉ាន សំណាង និងក្រុមគ្រួសារទាំងសងខាងជួបជុំគ្នានៅមន្ទីរពេទ្យភ្នំពេញ(ជំពូក២១)

## II- **និដ្ឋភាពទំនាក់ទំនងរឿង**

**១-សង្ខេបរឿង**

លោកសួនជាកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់រស់នៅទីក្រុងភ្នំពេញ។ លោកមានអាយុ២៣ឆ្នាំ មានរូបសម្រស់សង្ហា ហើយត្រូវបានរាជការបញ្ជូនទៅធ្វើការរាជការកាន់តំណែងជាចៅហ្វាយស្រុក នៅស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង អស់រយៈពេលពីរឆ្នាំហើយ។ នៅទីនោះលោកបានស្រឡាញ់ស្ត្រីម្នាក់ដោយលួចលាក់ឈ្មោះសូយ៉ា ដែលជាកូនកំព្រា អាយុ១៧ឆ្នាំអស់រយៈពេល៧ខែកន្លងមកហើយ។ ថ្ងៃមួយលោកបានទទួលសំបុត្រពីរាជការតម្រូវឱ្យផ្លាស់ទៅធ្វើការនៅទីក្រុងភ្នំពេញវិញ។ លោកពិបាកចិត្តជាខ្លាំងដោយពុំអាចយកសូយ៉ាដែលកំពង់មានផ្ទៃពោះទៅជាមួយបាន ព្រោះម្ដាយលោកធ្លាប់ហាមមិនឱ្យទាក់ទងស្រីណាឡើយ។ លោកក៏បានទុកចិញ្ចៀនពេជ្រមួយវង់ដើម្បីបញ្ចាំចិត្តនាង។ មិនយូរប៉ុន្មាននាងក៏បានឆ្លងទន្លេបានកូនប្រុសមួយមានរូបស្រស់សង្ហាដូចឪពុក ហើយបានដាក់ឈ្មោះថា "សូផាត"។ ដោយសារលោកសួនទៅចោលនាងយូរឆ្នាំ ហើយពុំដែលផ្ញើសំបុត្រសួរសុខទុក្ខសោះ ក៏បានកើតទុក្ខទាស់រីងរៃ ហើយឈឺជាទម្ងន់ មិនអាចចិញ្ចឹមកូនបានក៏ឱ្យអ្នកជិតខាងចិញ្ចឹមជំនួស។ ប៉ុន្មានខែក្រោយមក នាងក៏លាចាកលោកទៅ។ លុះអាយុបាន៨ឆ្នាំអ្នកស្រុកក៏បានយកសូផាត ទៅប្រគេនលោកក្នុងវត្ត ទទួលការទំនុកបម្រុង អប់រំទូន្មាន រៀនសូត្រជាមួយក្មេងដទៃទៀត។ នៅក្នុងវត្ត សូផាត ជាក្មេងស្លូតបូត សុភាពរាបសារ ឧស្សាហ៍រៀនសូត្រ និងជួយកិច្ចការលោកជាងគេ។ លុះដល់អាយុ១២ឆ្នាំ សូផាត ក៏បានសុំលាលោកគ្រូដើម្បីទៅរកឪពុកនៅទីក្រុងភ្នំពេញ។ ព្រះអង្គបានយល់ព្រមហើយថែមទាំងបានផ្ដល់ដំបូន្មានមួយចំនួនដល់សូផាត ឱ្យចេះគោរពប្រណិបតន៍ចាស់ព្រឹទ្ធាចារ្យ ស្រឡាញ់ចំណេះវិជ្ជា ហើយលោកក៏បានសរសេរសំបុត្រមួយច្បាប់ឱ្យសូផាត ដើម្បីទៅជួបព្រះសង្ឃនៅវត្តឧណ្ណាលោមដើម្បីប្រគល់ទៅលោកបាល័ដ្ឋ ប៉ក់ រួចឱ្យលុយ៥រៀលនិងចិញ្ចៀនពេជ្រមួយវង់តាមខ្លួនផង។ សូផាតក៏បានធ្វើដំណើរតាមរថយន្តមកទីក្រុងភ្នំពេញដូចបំណង។ មកដល់វត្តឧណ្ណាលោមសួរព្រះសង្ឃនៅទីនោះដើម្បីរកលោកគ្រូបាល័ដ្ឋប៉ក់ ប៉ុន្តែមិនបានជួបព្រោះលោកសឹកហើយមិនដឹងទៅទីណាទេ។ ព្រះសង្ឃអង្គនោះក៏បានឱ្យសូផាតស្នាក់នៅវត្តមួយរយៈ។

ថ្ងៃមួយសូផាតក៏បានសុំលោកគ្រូចេញទៅដើរលេង ចៃដន្យក៏ប្រទះក្មេងមួយក្រុមកំពង់ឈ្លោះគ្នា។ សូផាតក៏បានជួបក្មេងតូចជាងគេឈ្មោះណារិន។ ពួកគេទាំងពីរក៏សុំគ្នាជាមិត្ត។ ណារិនពេញចិត្តសូផាតហើយក៏បបួលទៅផ្ទះ បានសុំឱ្យឪពុកចិញ្ចឹមរបស់គេគឺលោក សួនទទួលឱ្យស្នាក់នៅជាមួយផង។ សូផាត សប្បាយចិត្តណាស់ដោយបានរស់នៅទីនោះនិងបាន

បម្រើលោកអធិបតី សួន ដោយកិរិយាមាយាទល្អប្រពៃ ហើយត្រូវបានលោកយកចិត្តទុកដាក់ទំនុកបម្រុងឱ្យរៀនសូត្ររហូតប្រឡងជាប់សញ្ញាបត្របឋមសិក្សា វិជ្ជាបារាំង-ខ្មែរ លោកអធិបតីសប្បាយចិត្ត ហើយបានផ្តល់រង្វាន់ សូផាត និង ណារិន ប៉ុន្តែលោកបានឱ្យ ណារិនរៀនបន្ត។ ឯសូផាត លោកឱ្យធ្វើការជាស្មៀនក្នុងហាងជំនួញមួយ។ ថ្ងៃមួយពេលសូផាត ងូតទឹក គេក៏ដោះចិញ្ចៀនទុកក្បែរពាងទឹកហើយភ្លេចយក ក៏ស្រាប់តែនាង ម៉ានយ៉ានដែលជាបងបង្កើតណារិន បានរើសយកទៅឱ្យលោកអធិបតី សួន ។ លោកអធិបតីបានពិនិត្យមើលចិញ្ចៀនពេជ្រនោះចុះឡើងរួចភ្ញាក់ព្រើតព្រោះយល់ថាវាពិតជាចិញ្ចៀនដែលគាត់បានជូននាងសូយ៉ា ហើយ សូផាត នេះពិតជាកូនរបស់លោកជាមួយនាង សូយ៉ា មែនហើយ ប៉ុន្តែលោកបែរជារៀបឥរិយាបថ ជាមិនដឹងការពិត ហើយបានសួរនាំសូផាត និងប្រគល់ចិញ្ចៀនឱ្យសូផាតវិញ។ តាំងពីពេលនោះមក លោកអធិបតី សួន បានឱ្យគេរៀបចំបន្ទប់ស្នាក់នៅតូចមួយ តែស្អាតឱ្យសូផាតរស់នៅ និងយកចិត្តទុកដាក់សូផាតយ៉ាងខ្លាំងសមជាកូនរបស់លោក រហូតឱ្យសូផាតបានបន្តការសិក្សានៅកូលេសព្រះស៊ីសុវត្ថិ ជាមួយណារិនថែមទៀត។ ចំណែកនាងម៉ានយ៉ានវិញពីមួយថ្ងៃទៅមួយថ្ងៃបានលបលួចប្រតិព័ទ្ធលើរូបសូផាតបន្តិចម្តងៗរហូតដកចិត្តពុំបាន។ មិនតែប៉ុណ្ណោះសូម្បីតែនាង អ៊ូរីដែលរស់នៅជិតខាងក៏លួចស្រឡាញ់ ឈ្លក់នឹងសម្រស់របស់សូផាតដែរ រួចលួចឱ្យកន្សែងដៃទៅសូផាតទៀតផង តែសូផាតទទួលដោយសេចក្តីរាប់អានតែប៉ុណ្ណោះ។ ថ្ងៃមួយនាងបានដាច់ចិត្តលបជួបសូផាត ទាំងរាត្រី។ ចៃដន្យនាងម៉ានយ៉ានប្រទះឃើញក៏អាក់អន់ស្រពន់ចិត្តនឹងសូផាត ហើយចេះតែគេចមុខពីនាយ។ សូផាតបែរជាយល់ខុសថាម៉ានយ៉ាន គេចពីនាយប្រហែលមកពីនាយលួចស្រឡាញ់នាង ជាការខុសឆ្គងមិនសមរម្យចំពោះនាង។ សូផាតក៏សម្រេចចិត្តរត់ចេញពីផ្ទះដោយទុកសំបុត្រមួយច្បាប់ដើម្បីសុំទោសលោកអធិបតី និងម៉ានយ៉ានដែលស្រឡាញ់នាងមិនបានប្រមាណឋានៈរបស់ខ្លួន។ លោកអធិបតី និងក្រុមគ្រួសារបារម្ភយ៉ាងខ្លាំង ហើយបាននាំគ្នារត់រកគ្រប់ទីកន្លែង មិនបានជួបសោះ។ លុះមួយអាទិត្យក្រោយមកស្រាប់តែបុគ្គលិកក្រុមព្រះនគរបាលបានឱ្យដំណឹងថាបានឃើញខ្មោចលង់ទឹក អាយុប្រមាណម្ភៃឆ្នាំ។ លោកអធិបតីសែនតក់ស្លុតក្រៃលែង ហើយមានក្តីសោកសង្រេងជាពន់ពេក។ ពិសេសស្តាយកំហុសដែលពុំបានសារភាពប្រាប់កូនថា ជាឪពុកបង្កើត។ រីឯនាងម៉ានយ៉ានព្រួយចិត្តលើសគេទាំងអស់ត្បិតនាងគិតថា សូផាតស្លាប់ព្រោះតែនាង។ រំលងយូរមកស្រាប់តែមានបុរសម្នាក់ ឈ្មោះសំណាង បានស្តីដណ្តឹងនាង ហើយលោក

អធិបតីក៏យល់ព្រម ប៉ុន្តែនាងសុំបង្អង់សិន។ ក្រោយមកដោយសារសំណាង ចេះតែទទូចពេក នាងក៏យល់ព្រមដែរ។

ការពិត សូផាត ពុំបានស្លាប់ទេ។ ខ្មោចលង់ទឹកនោះជាអ្នកដទៃ។ សូផាតបានក្លែងឈ្មោះជា ផនស៊ី ហើយបានរត់ទៅសុំជ្រកកោននឹងមេស្រុកក្នុងភូមិថ្មី ឈ្មោះ សុខ ។ សូផាតបានជួយធ្វើការមេស្រុក សុខក្នុងឋានៈជាស្មៀនថ្មី ហើយទទួលបានការកោតសរសើរពីមេស្រុកនេះមិនដាច់ពីមាត់។ លុះយូរបន្តិច ស្រាប់តែមានអ្នករត់សំបុត្រម្នាក់មកជួបគាត់ ហើយប្រាប់ថាស្អែកលោកអធិបតីនឹងមកលេង ដោយមកទាំងលោកស្រី កូនស្រី និងគូរដណ្ដឹងមកដែរ។ សូផាត គ្រាន់តែឮភ្លាមភ្ញាក់ព្រើត។ លុះស្អែកឡើងពេលព្រលឹមក៏មានការរៀបប្រដាប់របៀបទទួលលោកភូឈ្មួយកុង្សីយ៍ដោយស្នាដៃ ផនស៊ី។ ដំណើរមកលេងនេះ លោកអធិបតីមានបំណងបីខគឺ ខទីមួយនឹករឭកសម្លាញ់ចាស់ ខទីពីរបំបាត់ទុក្ខកង្វល់ និងសោកស្ដាយការស្លាប់របស់សូផាត ខទីបីផ្សេងទៀតព្រោះតែនាងម៉ានយ៉ាន អផ្សុកឱ្យឪពុកជូនមកបន្លប់ទុក្ខព្រួយឯស្រុកស្រែ។ ក្រោយពីលោកមេស្រុកទទួលបដិសណ្ឋារកិច្ចភ្ញៀវរួចហើយក៏ចម្លែកបាត់រូប

ផនស៊ី រកពុំឃើញ។ លោកអធិបតី អ្នកក្នុងផ្ទះ និងលោកជំទប់ សួស សួរទៅក៏ពុំដឹង។ តាមពិត ផនស៊ី ពុតជាឈឺព្រោះគេស្គាល់ និងដឹងច្បាស់ពីក្រុមគ្រួសារលោកអធិបតីមកទីនេះទៅហើយ។ ម្ចាស់ផ្ទះ និងភ្ញៀវបានសំណេះសំណាលគ្នាពីនេះពីនោះរួចក៏និយាយពីការរៀបចំទីក្រុង នយោបាយ។ល។ ឯអ្នកស្រុកស្រែនិយាយពីផលល្លានុផលក្នុងស្រុក កសិកម្ម បញ្ហាទឹកជំនន់ ទឹកភ្លៀងក្នុងរដូវឆ្នាំថ្មី និងសាសនា។ ងាកមើលទៅនាងម៉ានយ៉ានឯណោះវិញមានទឹកមុខក្រៀមស្រពោន បានដើរលេងតែម្នាក់ឯងឯវាលស្រែក៏ប្រែជាសប្បាយនឹងអាកាសទូលាយស្រែនិងគុម្ពស្រូវខៀវស្រងាត់ និងសត្វយំទំនៅនឹងគុម្ពឫស្សី ដើមត្នោតដុះភ្លឹងសន្ធឹងទៅលើមេឃត្រូវជំនោរខ្យល់ម្ដងៗបក់ឮសូរស្លឹកចាស់ៗរណ្ដំគ្នាប្រាវៗ។ ខ្លះជ្រុះមកដល់ដី ធ្វើឱ្យនាងនឹកអណោចដល់សូផាត ដែលមិនគួរនឹងមកដាច់ជីវិតសូន្យសុងក្នុងទន្លេមេគង្គជាពន់ពេក។ ឯសំណាងវិញក៏តាមឈរមើល ហើយឆ្លៀតសារសេងនឹងនាង តែនាងមិនពេញចិត្តក៏ដើរគេចចេញស្រាប់តែជួបនឹងសូផាត ភ្ញាក់ព្រើត នឹកស្មានថាខ្មោចលង។ សូផាតក៏រត់គេចបាត់។ តាំងពីពេលនោះមកគេក៏លែងឃើញ ផនស៊ី រស់នៅភូមិថ្មរហូតមក។

ពេលមកដល់ផ្ទះវិញ នាងម៉ានយ៉ាន នៅតែទន្ទេញឈ្មោះសូផាតរហូត។ លោកអធិបតីបានខិតខំ លួងលោមនាងឱ្យមើលកុន ល្ខោនយ៉ាងណាក៏នាងនៅតែរវើរវាយ។ ទើបក្រោយមកឱ្យគេរៀបចំសែនព្រេន ក៏បានស្រាកស្រាន។ មិនយូរប៉ុន្មាននៅថ្ងៃ១០រោច ខែកត្តិក ក៏មានប្រារព្ធពិធីអាពាហ៍ពិពាហ៍ហៃកូនកម្លោះចូលរោងការ ល្ងាចសូត្រមន្ត និងរៀបលៀងភ្ញៀវនៅផ្ទះលោកអធិបតី។ លុះកណ្ដាលអធ្រាត្រនាងម៉ានយ៉ានបានឱ្យអ្នកតែងខ្លួនជូនទៅបត់ជើងនៅបង្គន់ឯមាត់ទន្លេផាលេស។ ការពិតនាងបានលោតទឹកសម្លាប់ខ្លួនដើម្បីបញ្ចប់ក្ដីអាឡោះអាល័យពីសូផាត ធ្វើឱ្យអ្នកសំអាងខ្លួនសង្ស័យតាមរកពុំឃើញ ឆោឡោពេញរោងកា។ ឯការស្លាប់របស់នាងត្រូវបានគេនឹកស្មានខុសៗគ្នា។ នាងម៉ានយ៉ានមិនស្លាប់ទេព្រោះមានអ្នកនេសាទត្រីម្នាក់បានឃើញហើយជួយស្រង់យកទៅផ្ទះ។ គឺអ្នកនេសាទនេះហើយជាអ្នកផ្ដល់ជម្រកឱ្យសូផាតនៅជាមួយ គាត់ឈ្មោះ រ៉េត នៅភូមិច្បារអំពៅ។ ហេតុតែជាគូក្រោយពីភ្ញាក់ពីសន្លប់មកម៉ានយ៉ាន បើកភ្នែកឃើញរូបសូផាត ពិតៗហើយមានសេចក្ដីសប្បាយរីករាយក្រៃលែង តែគេមានក្ដីបារម្ភក្នុងការរស់នៅជាមួយគ្នា។ រ៉េត យល់ចិត្តហើយបានពន្យ់ថា ៖ «ខ្លាចអ្នកណា យើងសុខចិត្តស្រឡាញ់គ្នា ហើយគ្មានអ្វីធំជាងចិត្តទេ ឪពុកម្ដាយដែលឱ្យមានប្ដីប្រពន្ធមិនគាប់ចិត្ត ថ្ងៃក្រោយមិនមែនឪពុកម្ដាយទទួលខុសត្រូវលើជីវិតយើងក្នុងមួយជាតិនេះទេ»

ពួកគេរស់នៅជាមួយ រ៉េត មួយរយៈប្រមាណមួយទៅពីរខែ ក៏បាននាំគ្នាទៅនៅស្រុកមួយឆ្ងាយបន្តិចពីទីរួមខេត្តស្វាយរៀង ប្រកបមុខរបរដាំដុះកសិកម្ម។ ថ្ងៃមួយដោយខ្វះពូជស្រូវ សូផាត ក៏បានធ្វើដំណើរមកភ្នំពេញដើម្បីទិញពូជស្រូវធ្វើស្រែ តែសំណាងអាក្រក់រថយន្តដែលគាត់ជិះមកពីព្រៃនគរកាត់អ្នកលឿងក៏បុកគោ ក្រឡាប់ ហើយសូផាតត្រូវបានបញ្ជូនមកមន្ទីរពេទ្យភ្នំពេញ។ ស្របពេលនោះនាងម៉ានយ៉ាននៅឯផ្ទះក៏មានជំងឺជាទម្ងន់ បានគ្រូពេទ្យម្នាក់ជាមិត្តភក្តិសំណាងជួយព្យាបាល តែមិនជាព្រោះជំងឺនាងធ្ងន់ក៏បញ្ជូននាងទៅមន្ទីរពេទ្យភ្នំពេញដែរ ហើយសរសេរសំបុត្រទៅប្រាប់សំណាង។ សំណាងក៏មកជួបនាងម៉ានយ៉ាននៅមន្ទីរពេទ្យជេរប្រមាថនាង ឮដល់សូផាតដែលសម្រាកនៅជាន់ទីមួយ ដែលកំពង់តែដើរមកជួបគ្នា។ សំណាង និងសូផាតក៏ប្រឈមមុខគ្នា ខាំមាត់តែសព្វខ្លួនដាក់គ្នា។ ដំណឹងនេះក៏បានម្ដាយឪពុកសំណាងបន្តទៅលោកអធិបតី។ លោកក៏ប្រញាប់ប្រញាល់មកដល់ភ្លាម ហើយទទួលស្គាល់កូនទាំងពីរដោយក្ដីសោមនស្សរីករាយក្រៃលែង។ អ្នកទាំងពីរបានប្រណិប័តន៍លោក។

លោកអធិបតីក៏បានបង្ហាញប្រាប់សូផាតថាជាកូនបង្កើត។ រីឯថ្លៃបណ្ណាកាទាំងប៉ុន្មាន លោកនឹងបង្វិលជូនទៅឪពុកម្ដាយសំណាងវិញឱ្យគ្រប់ចំនួន។

ប៉ុន្មានថ្ងៃក្រោយមក គេរៀបកាសូផាត និងម៉ានយ៉ានយ៉ាងអធិកអធមគគ្រឹកគគ្រេង។

**២- តួអង្គ**

- លោកសួន ជាចៅហ្វាយស្រុកសិរីសោភ័ណ ក្រោយមកក៏ផ្លាស់ទៅភ្នំពេញវិញ ធ្វើជាភូឈួយកុង្សីយ៍ មានម្ដាយជាស្ត្រីមេម៉ាយ។

- នាងសូយ៉ា ជាស្ត្រីដែលលោកសួនលួចស្រឡាញ់ កំព្រាគ្មានឪពុកម្ដាយ រស់នៅស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង។

- សូផាត ជាកូនរបស់លោកអធិបតីសួន និងនាងសូយ៉ា និងជាប្ដីរបស់នាងម៉ានយ៉ានជាស្មៀនរបស់ក្រុមហ៊ុនជំនួញ និងមេស្រុកសុខ។

- នាងម៉ានយ៉ាន ជាកូនចិញ្ចឹមរបស់លោកអធិបតីសួន ជាបងស្រីបង្កើតរបស់ណារិន និងជាប្រពន្ធរបស់សូផាត

- ណារិន ជាកូនចិញ្ចឹមរបស់លោកអធិបតីសួន ជាប្អូនប្រុសបង្កើតរស់ម៉ានយ៉ាន និងជាសម្លាញ់របស់សូផាត

- នាងអ៊ូរី ជាកូនក្រមុំអ្នកជិតខាងផ្ទះលោកអធិបតី

- សំណាង ជាបុរសរូបក្មេង និងជាគូដណ្ដឹងនាងម៉ានយ៉ាន

- ផនស៊ី ជាឈ្មោះបន្លំរបស់សូផាត

- ព្រះតេជគុណព្រះនាម ប៉ក់ ជាព្រះសង្ឃគង់នៅវត្តឧណ្ណាលោម

**៣-កាលអាកាស**

**ក-កាល**

- ថ្ងៃមួយលោកសួនបានទទួលសំបុត្រពីរាជការធំនៅភ្នំពេញផ្លាស់លោកទៅទីក្រុង។

-រំលងប៉ុន្មានខែនោះមកក្រោយពេលលោកសួនត្រលប់មកធ្វើការនៅភ្នំពេញ។

-ថ្ងៃមួយកុមារចូលទៅជិតលោកគ្រូថ្វាយបងញគំទូលលាព្រះតេជគុណទៅរកឪពុកនិងរៀនសូត្រនៅភ្នំពេញ។

-ថ្ងៃមួយជាពេលសិស្សសាលាចេញពីរៀនសូផាតដើរកាត់ពីភូមិបឹងរាំងមកវត្តក៏ជួបណារិនឈ្លោះនឹងសិស្សធំ២នាក់បានជួយរួចនាំទៅផ្ទះសុំឪពុកឱ្យសូផាតនៅជាមួយ។

- មានថ្ងៃមួយជាថ្ងៃអាទិត្យលោកអធិបតីសេនាត្រូវទទួលគ្រួសារមិត្តមកកម្សាន្តនៅផ្ទះ។

-ថ្ងៃមួយសូផាត និងណារិនបានប្រឡងជាប់សញ្ញាបត្របឋមសិក្សាវិជ្ជាបារាំង។

-ថ្ងៃមួយមុននឹងធ្វើការសូផាតចូលទៅជម្រះកាយក្នុងបន្ទប់ទឹក ភ្លេចចិញ្ចៀន។

- រំលងយូរថ្ងៃមកសូផាតនឹកក្នុងចិត្តថា « នាងម៉ានយ៉ានមានបើអន់ចិត្តអ្វីនឹងអញហើយម្ដេចក៏គេចវេះពីមុខអញម្ល៉េះ »។

- លុះព្រឹកព្រហាមកាលណាឡើង...(សូផាតរត់ចេញពីផ្ទះ)។

-លុះមួយអាទិត្យក្រោយមកបុគ្គលិកក្រុមព្រះនគរបាលចូលមកក្នុងផ្ទះជម្រាបលោកថា៖ « រាជការទើបនឹងបានរើសខ្មោចលង់ទឹកមួយ ខ្មោចក្មេង...»។

-ថ្ងៃមួយលោកប្រុស លោកស្រីហៅកូនមក ទើបសួរថា៖ កូន! ឪពុកម្ដាយចង់ឱ្យកូនសម្រេច...(សំណាងចូលស្ដីដណ្ដឹងម៉ានយ៉ាន)។

- លុះស្អែកឡើងពេលព្រលឹមនៅផ្ទះលោកមេស្រុកសុខ ភូមិថ្ម ប្រដាប់រៀបទទួលលោកភូឈួយកុង្សីយ៍គឺលោកសួន(នៅស្រុកស្រែ)។

- នៅថ្ងៃ១១រោច ខែកត្ដិកនៅគេហដ្ឋានលោកអធិបតីសេនារោងពិធីធ្វើហើយស្រេច(ពិធីហែកូនកំលោះ)។

- ថ្ងៃមួយសូផាតនិយាយទៅម៉ានយ៉ានថា៖ « អូន! ស្រុកច្បារអំពៅនៅនឹងច្រមុះស្រុកភ្នំពេញ គេថាដំរីស្លាប់យកចង្អេរមកបាំងមិនជិតទេ(សូផាតនិងម៉ានយ៉ានជួបគ្នាដោយមាននាយរ៉េកជួយទំនុកទីជម្រក) »។

- លុះប៉ុន្មានថ្ងៃក្រោយមកសូផាត និងម៉ានយ៉ាន នាំគ្នាទៅនៅស្រុកមួយឆ្ងាយបន្តិចពីទីរួមខេត្តស្វាយរៀង។

- លុះព្រលឹមឡើងសូផាតនឹងធ្វើដំណើរចាកចេញពី...។

- ថ្ងៃមួយនាងឈឺចាប់ខ្លាំងក្នុងក្បាល ក្ដៅខ្លួនញ័រចំប្រប់(ម៉ានយ៉ានត្រូវបញ្ជូនទៅមន្ទីរពេទ្យនៅភ្នំពេញ)

- ប៉ុន្មានថ្ងៃក្រោយមក គេរៀបការសូផាតនិងម៉ានយ៉ានយ៉ាងអ៊ឹកធឹក គគ្រឹកគគ្រេង។

**ខ- អាកាស**

- ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង

- ភ្នំពេញផ្ទះលោកអធិបតីសួន

- នៅផ្ទះមេស្រុកសុខ (ស្រុកស្រែ)

- នៅខេត្តស្វាយរៀង

- នៅមន្ទីរពេទ្យភ្នំពេញ

## III- **ទិដ្ឋភាពទំនាស់**

### **១- ទំនាស់វិបត្តិទី១**

ក- ទីកន្លែង : ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង

ខ- តួទំនាស់ : សួន និងសូយ៉ា

គ- បញ្ហាទំនាស់ : លោកអធិបតីសួនត្រូវបានរាជការផ្លាស់ឱ្យទៅបម្រើការនៅភ្នំពេញ

ឃ- ដំណោះស្រាយ : លោកអធិបតីសួនគោរពបញ្ជារាជការ និងបានផ្លាស់ទៅធ្វើការនៅក្រុងភ្នំពេញ។

### **២- ទំនាស់វិបត្តិទី២**

ក- ទីកន្លែង : នៅភ្នំពេញក្នុងគេហដ្ឋានលោកអធិបតី

ខ- តួទំនាស់ : សូផាតជាមួយលោកគ្រូថៅអធិការវត្ត

គ- បញ្ហាទំនាស់ : សូផាតចង់ទៅស្គាល់ទីក្រុងភ្នំពេញ និងស្វែងរកឪពុក។

ឃ-ដំណោះស្រាយ : សូផាតបានទៅដល់ទីក្រុងភ្នំពេញ។ ជួបព្រះសង្ឃនៅវត្តលង្កាបានស្នាក់នៅក្នុងវត្ត។

### **៣- ទំនាស់វិបត្តិទី៣**

ក- ទីកន្លែង : នៅភ្នំពេញក្នុងគេហដ្ឋានលោកអធិបតីសួន

ខ- តួទំនាស់ : សូផាតជាមួយនាងម៉ានយ៉ាន

គ- បញ្ហាទំនាស់ : សូផាតយល់ច្រឡំថា នាងម៉ានយ៉ានស្អប់ខ្ពើមខ្លួនត្បិតនាងមិនព្រមនិយាយរាក់ទាក់ដាក់ខ្លួន។

ឃ- ដំណោះស្រាយ : សូផាតបានរត់ចេញពីផ្ទះលោកអធិតីសួនដើម្បីកុំឱ្យរមិលនិងប៉ះពាល់កិត្តិយសលោក និងនាងម៉ានយ៉ានដែលជួយទំនុកបម្រុងឱ្យស្នាក់នៅ។

(សំណួរ : បើអ្នកជាសូផាតវិញ តើអ្នកដូចម្តេច?)

**៤- ទំនាស់វិបត្តិទី៤**

ក- ទីកន្លែង : នៅភ្នំពេញក្នុងគេហដ្ឋានលោកអធិបតី

ខ- តួទំនាស់ : នាងម៉ានយ៉ាន និងលោកសំណាង

គ- បញ្ហាទំនាស់ : ម៉ានយ៉ានស្រឡាញ់សូផាតតែពុំបានជួបសូផាតបែរជាឪពុកម្ដាយផ្គូផ្គងឱ្យទៅលោកសំណាងវិញ។

ឃ- ដំណោះស្រាយ : ម៉ានយ៉ានខកចិត្តបានទៅលោតទឹកសម្លាប់ខ្លួន។

(សំណួរ : តើដំណោះស្រាយបែបនេះត្រឹមត្រូវដែរឬទេ?)

**៥- ទំនាស់វិបត្តិទី៥**

ក- ទីកន្លែង : នៅមន្ទីរពេទ្យទីក្រុងភ្នំពេញ

ខ- តួទំនាស់ : នាងម៉ានយ៉ាន និងលោកសំណាង

គ- បញ្ហាទំនាស់ : លោកសំណាងខឹងនាងម៉ានយ៉ានហើយយល់ថា នាងបោកប្រាសទឹកចិត្តនិងទារថ្លៃបណ្ណាការ។

ឃ- ដំណោះស្រាយ : លោកអធិបតីសួនបានដោះស្រាយបញ្ហារវាងលោកសំណាងនិងនាងម៉ានយ៉ានដោយបង្វិលបណ្ណាការទាំងប៉ុន្មានជូនទៅលោកសំណាងវិញ។ សូផាត និងនាងម៉ានយ៉ានត្រូវបានផ្សំផ្គុំរៀបការជាភរិយាស្វាមី។

## IV- **ចរិតលក្ខណៈតួអង្គ**

**១- លោកសួន**

**ក- គុណសម្បត្តិ :** ជាអ្នកមានចិត្តសណ្ដោសប្រណីចំពោះ ណារិន កូនចិញ្ចឹមមានចិត្តសប្បុរសចំពោះសូផាត ជួយទំនុកបំរុងអ្នកទាំងពីរក្នុងការរស់នៅ រៀនសូត្រ។ ជាស្វាមីដ៏ល្អមានទឹកចិត្តនិងសេចក្ដីថ្លៃថ្នូរចំពោះភតិយា ជាចៅហ្វាយស្រុកនិងភូឈ្មួយកុង្សីយ៍របស់រាជការដែលធ្វើការបានល្អ រាជការមានជំនឿនិងទំនុកចិត្តឱ្យផ្ដល់កិត្តិយសពីចៅហ្វាយស្រុកសិរីសោភ័ណទៅជាភូឈ្មួយកុង្សីយ៍។

**ខ-គុណវិបត្តិ :** មានការលាក់លៀមអារម្មណ៍ក្នុងនាមជាឪពុកសូផាតដែលដឹងថាសូផាតជាកូនហើយតែពុំហ៊ានប្រាប់ការពិតដោយលួចលាក់មិនតាមដំបូន្មានម្ដាយមានភរិយាថ្មីទុក្ខនាងសូយ៉ាឱ្យឈឺរីងរៃរហូតស្លាប់។

**២- នាងសូយ៉ា :** ជាភរិយារបស់លោកចៅហ្វាយស្រុកសិរីសោភ័ណ ខេត្តបាត់ដំបងប៉ុន្តែពុំបានរៀបការស្របច្បាប់ទេ។

**ក- គុណសម្បត្តិ :** ជាភរិយាដ៏ល្អមានភក្តីភាពចំពោះស្វាមី។ ជាម្ដាយដ៏ល្អ តស៊ូក្នុងជីវិតដើម្បីចិញ្ចឹមកូនតាំងពីតូចរហូតដល់ធំទើបដាច់ចិត្តឱ្យសូផាតជាកូនធ្វើដំណើរទៅទីក្រុងភ្នំពេញដើម្បីសិក្សារៀនសូត្របន្តនៅភ្នំពេញនិងស្វែងរកឪពុក។

**ខ- គុណវិបត្តិ :** ជាអ្នកមានចិត្តទន់ខ្សោយ ឆាប់ភ័យនិងស្លុតពេលឮដំណឹងថាលោកសួនមានប្រពន្ធថ្មីបណ្ដោយខ្លួនមិនគិតវែងឆ្ងាយបណ្ដាលឱ្យធ្លាក់ខ្លួនទៅជាឈឺរីងរៃរហូតទាស់ស្លាប់ចោលកូននៅកំព្រា។

**៣- នាងម៉ានយ៉ាន :** ជាបងស្រីលោកណារិនដែលជាកូនស្រីចិញ្ចឹមរបស់លោកសួនរស់នៅក្នុងផ្ទះលោកសួនជាមួយប្អូនប្រុសណារិន។

**ក- គុណសម្បត្តិ :** ជាស្ត្រីក្រមុំ មានរូបសម្ផស្សល្អ មានចរិតស្លូតបូតសុភាពរាបសាសមជាស្ត្រីខ្មែរមេទម្យថ្លៃថ្នូរ មានការតស៊ូក្នុងជីវិត មានភក្តីភាពចំពោះសូផាត។

**ខ- គុណវិបត្តិ :** លួចស្រឡាញ់សូផាតតែមិនហ៊ាននិយាយការពិត។ ជាអ្នកគិតខ្លីពុំពិចារណាហ្មត់ចត់លោតទឹកសម្លាប់ខ្លួនតាមសូផាត។

**៤- លោកសូផាត :** ជាបុរសមានរូបសម្ផស្សស្រស់សង្ហា ជាកូនប្រុសរបស់លោកសួននិងនាងសូយ៉ា។

**ក- គុណសម្បត្តិ :** ជាកូនកតញ្ញូចំពោះអ្នកមានគុណជាមនុស្សមានការតស៊ូអំណត់ព្យាយាមក្នុងជីវិតបានខិតខំប្រឹងប្រែងរៀនសូត្រ។ មានចរិតស្លូតបូត សុភាពរាបសា ទន់ភ្លន់តែក្លាហានក្នុងការស្វែងរកចំណេះវិជ្ជានិងឪពុកនៅទីក្រុងភ្នំពេញ។ សូផាតមានចិត្តស្មោះត្រង់ចំពោះគូសង្សា ដូចជាភរិយារបស់ខ្លួន ហ៊ានលះបង់ជីវិតសំដែងភាពស្មោះត្រង់ចំពោះម៉ានយ៉ាន។ ជាអ្នកយកចិត្តទុកដាក់ក្នុងការងារជាស្មៀនរបស់លោកសួន របស់មេឃុំសួស ដែលសូផាតដូរឈ្មោះជាផនស៊ី។ ចេះជួយយកអាសាណារិន ដោយបានអន្តរាគមន៍ក្នុងជម្លោះជាមួយសិស្សធំៗ។ ស្គាល់កំហុសខ្លួនឯងដែលលួចស្រឡាញ់ម៉ានយ៉ាន។

**ខ- គុណវិបត្តិ :** មានគំនិតខ្លី កំសាកលោតទឹកសម្លាប់ខ្លួនតាមម៉ានយ៉ាន រត់គេចចេញពីផ្ទះលោកសួនដើម្បីដោះស្រាយបញ្ហាជាមួយនាងម៉ានយ៉ាន។

**៥- លោកណារិន** : ជាកូនចិញ្ចឹមរបស់លោកសួន និងជាប្អូនប្រុសរបស់ម៉ានយ៉ាន ជាសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ។

**ក- គុណសម្បត្តិ** : ជាកូនមានកតញ្ញូតាធម៌ចំពោះឪពុកចិញ្ចឹម មានការគោរពប្រតិបត្តិចំពោះឪពុកចិញ្ចឹម មានចិត្តអាណិតស្រឡាញ់សូផាតដោយក្ដីអាណិតអាសូរនិងបាននាំមកជួបលោកសួន សុំបានរស់នៅរៀនសូត្រជាមួយគ្នា រាប់គ្នាជាមិត្តភក្តិក៏ដូចជាបងប្អូនក្នុងផ្ទះតែមួយ។ ឧស្សាហ៍ព្យាយាមក្នុងការសិក្សា។

**ខ- គុណវិបត្តិ** : ធ្លាប់ជាមនុស្សមិនសូវមានទំនុកចិត្តលើខ្លួនក្នុងការប្រឡង "ខ្លួនខ្ញុំមិនគួរបានប្រឡងជាប់សោះ។ ធ្លាប់ជាសិស្សខ្ជិល ដើរលេងញឹកញយកើតទោសនឹងគេរឿយៗ នោះមិនត្រូវនឹងមានសំណាងបានប្រឡងជាប់សោះ"។

**៦- លោកសំណាង** : ជាគូដណ្ដឹងនាងម៉ានយ៉ាននិងជាកូនអ្នកមានម្នាក់ដែលតាមស្រឡាញ់និងស្ដីដណ្ដឹងនាងម៉ានយ៉ាន។

**ក- គុណសម្បត្តិ** : ជាអ្នកមានទឹកចិត្តស្រឡាញ់ចំពោះគូដណ្ដឹងដោយឱ្យអ្នកមានគុណចូលស្ដីដណ្ដឹងតាមប្រពៃណីខ្មែរត្រឹមត្រូវ។

**ខ- គុណវិបត្តិ** : មានចិត្តឆេវឆាវ គំគួនខឹងនឹងម៉ានយ៉ាន ប្រើពាក្យសម្ដីមិនសមរម្យចំពោះនាង ដែលជាស្រីធ្វើពុតអាក្រក់ណាស់ អាងខ្លួនជាអ្នកមាន ប្រើពាក្យគំរោះគំរើយថាខ្លួនបានចាយមាសប្រាក់ច្រើនណាស់។ មានចរិតមើលងាយស្ដ្រីភេទតាមរយៈការប្រើប្រាស់ទឹកប្រាក់។

**៧- នាងអ៊ីវី** : ជាកូនក្រមុំអ្នកជិតខាងមួយរូបរបស់លោកអធិបតីសួនដែលបានលបលួចប្រាថ្នាលើរូបសូផាតជាច្រើនតែសូផាតមិនដឹងខ្លួន។

**ក- គុណសម្បត្តិ** : នាងមានចិត្តស្រឡាញ់សូផាតដោយស្មោះ ព្រមទាំងបានហុចកូនកន្សែងតូចមួយឱ្យទៅសូផាតទៀតផង។

**ខ- គុណវិបត្តិ** : ហេតុតែស្រឡាញ់សូផាតខ្លាំងពេក ទប់កេរ្តិ៍ជាស្ត្រីពុំបាន។ នាងបានទៅជួបសូផាតដល់បន្ទប់ទាំងរាត្រី។

**៨- ព្រះតេជគុណព្រះនាមប៉ក់** : ជាព្រះសង្ឃគង់នៅវត្តឧណ្ណាលោមនិងជាអតីតមានងារជាបាល័ដ្ឋ។

**ក- គុណសម្បត្តិ** : ព្រះតេជគុណជាពុទ្ធសាសនិកដែលលមានគុណដ៏ធំធេងចំពោះ

សាសនានិងព្រះមហាក្សត្រ ជាបុគ្គលគួរជាទីគោរពរាប់អាន។ព្រះអង្គតែងយកអាសាមនុស្សគ្រប់រូបដែលសុំស្នាក់អាស្រ័យទីវត្តអារាមរបស់លោកដូចជាសូផាតពេលទៅជួបអាស្រ័យនឹងព្រះអង្គ។

**ខ- គុណវិបត្តិ** : ព្រះតេជគុណប៉ក់ឬលោកគ្រូកវីវង្សាប៉ក់បានសឹកមិនបានផ្តល់ដំណឹងដល់ព្រះតេជគុណនៅបាត់ដំបងធ្វើឱ្យសូផាតរកពុំឃើញ។

**៩- នាយរ៉ក** : ជាអ្នកនេសាទត្រី និងជាអ្នកបានជួយស្រោចស្រង់ជីវិតនាងម៉ានយ៉ាននិងធ្លាប់បានរៀនអក្សរនៅវត្តឧណ្ណាលោម។

**ក- គុណសម្បត្តិ** : ជាមនុស្សមានចិត្តសប្បុរសចេះយកអាសាមនុស្សផងគ្នា ដូចជាផ្តល់ទីជម្រកឱ្យសូផាតបានរស់នៅជាមួយ។ ពិសេសបានជួយស្រោចស្រង់ជីវិតនាងម៉ានយ៉ានពេលនាងលោតទឹកសម្លាប់ខ្លួន។ ជាអ្នកដែលបានផ្តល់ទំនុកបម្រុងដល់សូផាត និងម៉ានយ៉ានក្នុងនាមជាមិត្តសម្លាញ់។

**ខ- គុណវិបត្តិ** : បានរួមគំនិតលាក់បំពួនសូផាតឱ្យរស់នៅក្នុងផ្ទះរបស់ខ្លួនដោយមិនឱ្យឪពុកម្តាយឬសាច់ញាតិសូផាតនិងម៉ានយ៉ានបានដឹង។

## V- និដ្ឋភាពសង្គម

**១- វប្បធម៌**

**ក- ជំនឿ** : ជឿលើខ្មោច ព្រាយបិសាច(អបីជំនឿ)។

ក្នុងរឿងបង្ហាញអំពីតួអង្គសូយ៉ា និងនាងម៉ានយ៉ានឈឺហើយនិមន្តលោកសូត្រមន្ត។ ប្រជាជនគោរពប្រណិបតន៍ចំពោះព្រះសង្ឃ។

**ខ- ព្រពៃណីទំនៀមទម្លាប់** : ឪពុកម្តាយសំណាងបានចូលស្តីដណ្តឹង ភ្ជាប់ពាក្យ និងរៀបអាពាហ៍ពិពាហ៍ សំណាងនិងម៉ានយ៉ាន។

**គ- សាសនា** : ប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនាមានវត្តអារាមជាទីសក្ការៈបូជា។

តាមរយៈរឿងបង្ហាញអំពីសូផាតអាយុ១២ឆ្នាំត្រូវបានអ្នកស្រុកយកទៅផ្ញើព្រះសង្ឃក្នុងវត្តឯស្រុក។ លុះធំឡើងសូផាតបានទៅរកលោកគ្រូប៉ក់នៅវត្តឧណ្ណាលោមដើម្បីស្នាក់អាស្រ័យ និងរៀនសូត្រ។

**ឃ- ការអប់រំ** : សម័យនោះគេរៀននៅតាមសាលារៀន និងតាមវត្តអារាមដូចជា៖

- សូផាតរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិជាមួយណារិន

- នាយរ៉ក ធ្លាប់រៀននៅវត្តឧណ្ណាលោម

**ង- សិល្បៈ** : ក្នុងរឿងបានបង្ហាញអំពីសិល្បៈមួយចំនួនដូចជា៖

- ការប្រគំតន្ត្រី (ឧទាហរណ៍ : ពិធីមង្គលការនាងម៉ានយ៉ាន និងលោកសំណាង។
- ចម្រៀង (នាងសូយាបំពេរកូន)

ឧទាហរណ៍ : « សូផាតកូនអើយកូនគេងទៅ កូនពៅអាណិតតែមាតា ព្រួយចិត្តខ្លាំងណាស់ព្រោះឪបា ចោលម្តាយកំព្រាតែនឹងថ្លៃ។

**២- សេដ្ឋកិច្ច**

**ក - កសិកម្ម** : តាមដំណើររឿងបានបង្ហាញថាប្រជាជនខ្មែរនៅសម័យនោះប្រកបមុខរបរកសិកម្ម « ឧទាហរណ៍ : ឪពុកម្តាយនាងសូយ៉ាជាអ្នកប្រកបរបរកសិកម្ម មានទ្រព្យសម្បត្តិសមគួរ... នៅក្នុងស្រែគោកគាំងអស់រកទឹកដក់បន្តិចគ្មាន។ ស្រូវដែលស្ទូងអស់គ្មានសល់ »។ សូផាតមកទិញពូជស្រូវនៅភ្នំពេញដើម្បីធ្វើកសិកម្ម។

**ខ- ផលិតកម្ម** : អ្នកនិពន្ធបានបង្ហាញពីការពិភាក្សាគ្នារវាងលោកអធិបតីសួនពេលទៅផ្ទះមេស្រុកសុខសម្លាញ់របស់គាត់ « ឧទាហរណ៍ : អ្នកស្រែនិយាយពីផលល្ហានុផលក្នុងស្រុក និងកសិកម្មរបស់ខ្លួន »។

**គ- សិប្បកម្ម** : មានគ្រឿងអលង្ការធ្វើពីមាសពេជ្រ និងហាងលក់គ្រឿងអលង្ការ (ឧទាហរណ៍ : ហាងក្លិង្គដែលនៅមាត់ទន្លេ )។

**ឃ- ពាណិជ្ជកម្ម** : បានបង្ហាញពីកន្លែងលក់ដូរជាច្រើនដូចជាហាងលក់ទំនិញ និងទីផ្សារជាដើម (ឧទាហរណ៍ : សុផាតធ្វើការនៅហាងជំនួញ)។

**៣- សង្គមកិច្ច**

**ក- ស្ថានភាពរស់នៅ** : ការប្រកបមុខរបរធ្វើស្រែចម្ការដូចជាឪពុកម្តាយនាងសូយ៉ា។ ជាមន្ត្រីរាជការដូចជា លោកអធិបតីសួន។ ជាសិស្ស និស្សិតលោកសូផាត និងលោកណារិនរៀននៅកូលេសស៊ីសុវត្ថិ។

**ខ- សុខាភិបាល** : ផ្នែកនេះមានភាពរីកចម្រើនតែនៅទីក្រុងភ្នំពេញប៉ុណ្ណោះ។

- ពេលនាងម៉ានយ៉ានឈឺនៅខេត្តស្វាយរៀងគ្រូពេទ្យបានបញ្ជូននាងមកសម្រាកព្យាបាលនៅមន្ទីរពេទ្យភ្នំពេញ។
- សូផាតបានជួបគ្រោះថ្នាក់ចរាចរណ៍ក្រឡាប់ឡានហើយត្រូវបានបញ្ជូនមកមន្ទីរ

ពេទ្យភ្នំពេញដែរ។

**គ- គមនាគមន៍ :** លោកសួននិងសូផាតបានធ្វើដំណើរដោយរថយន្តពីបាត់ដំបងទៅភ្នំពេញ។ សូផាតបានធ្វើដំណើរពីស្វាយរៀងមកទិញពូជស្រូវនៅភ្នំពេញ។

**ឃ- នយោបាយ :** រឿងបានបង្ហាញពីការដឹកនាំគ្រប់គ្រងក្នុងប្រទេសបានល្អដែលមានសុខសន្តិភាព។

VI-**ទិដ្ឋភាពតំណែងនិពន្ធ**

**១- ផ្ដើមរឿង :** អ្នកនិពន្ធបានប្រើប្រាស់ការផ្ដើមរឿងដោយបង្ហាញឈ្មោះតួអង្គលោកអធិបតីសួនដែលមានតួនាទីក្នុងសង្គមការងារ និងមានកាលបរិច្ឆេទទទួលការងារ។

**២- តួរឿង**

**ក- ទម្រង់សំណេរ :** សរសេរជាពាក្យរាយ ងាយអាន ងាយស្ដាប់ និងនិយាយ។

**ខ- បច្ចេកទេសក្នុងការតាក់តែង**

- **ភាសា**
    - ភាសាសាមញ្ញ : **អ្នកបង បងអើយ មាសបង ប្អូនអើយ...**
    - បាលីសំស្រ្កឹត : **សោមនស្ស ករុណា ទុក្ខ...**
    - បរទេស : កូលេស...
- **ភាសាច្បាស់លាស់ :** ល្អឆើតឆាយ ខ្មៅអែ ខៀវស្រងាត់ ស្គមរីងរៃ...
- **ភាសារស់រវើក :** ស្រែកទ្រហឹងអឹងកង ស្ទុះសឹមៗ ដើរព្រិប!ព្រិប!...
- **ទុក្ខសោក ឬភាពវេទនា :**នៅក្នុងរឿងនេះអ្នកនិពន្ធបានលើកឡើងពីភាពទុក្ខសោកវេទនារបស់តួអង្គដូចជា ៖
    - វេលានោះ នាងសូយា និងមាតាកើតទុក្ខសោកសង្រេងសង្រៃអាឡោះអាល័យក្រៃពេក ស្ដាយរូបបុគ្គលដែលត្រូវជា...។
    - សូយាគ្រាន់តែឮពាក្យប៉ុណ្ណឹងស្រែកទ្រហោយំមួយរំពេច នាងគក់ទ្រូងផូងគ្មានប្រណី អួលស្ទះឈាមរត់ក្នុង...។
- **សំវាទវិធី :** តួអង្គក្នុងរឿងនិយាយឆ្លើយឆ្លងគ្នា។

  ឧទាហរណ៍ : លោកប្រុសមានប្រសាសន៍ "អញឱ្យគេរក សូផាត ឱ្យឃើញ!" ទើបស្រែកហៅ "អាជ័យ!"

ចៅជ័យរត់មក “ ព្រះបាទ! ” ...។

- **ឯកវាទវិធី :** លោកសួននិយាយម្នាក់ឯងពេលនាងម៉ានយ៉ានយកចិញ្ចៀនត្បូងពេជ្រដែលសូផាតភ្លេចក្នុងបន្ទប់ទឹកជូនលោកមើល។

- **ការនិទាន**

  • បែបបុរសទី១ (ខ្ញុំ...។)

  ឧទាហរណ៍ : ខ្ញុំអរគុណនឹងអ្នកបងហើយ។

  • បែបបុរសទី៣ (នាង ...។)

  ឧទាហរណ៍ : នាងផ្ដេកក្បាលទៅលើទ្រូងសង្សា។

**គ- បញ្ចប់រឿង**

អ្នកនិពន្ធបានបញ្ចប់រឿងដោយឱ្យតួអង្គនាងម៉ានយ៉ាន និងលោកសូផាតបានជួបគ្នាហើយត្រូវបានឪពុកម្ដាយទទួលស្គាល់ និងរៀបអាពាហ៍ពិពាហ៍ឱ្យ។

## VII- **ទិដ្ឋភាពតម្លៃ**

អ្នកនិពន្ធបានបង្ហាញអំពើល្អរបស់៖

- ព្រះសង្ឃដែលយកអាសារសូផាតឱ្យស្នាក់នៅជាមួយដើម្បីរៀនសូត្របន្ត។
- លោកអធិបតីសួនមានសមានចិត្តទទួលយកសូផាតស្នាក់អាស្រ័យក្នុងផ្ទះរបស់លោកតាមការស្នើសុំពីណារិនដោយសន្ដោសប្រណី។
- សូផាតបានគោរពប្រណិបតន៍ចំពោះអ្នកមានគុណដូចជាព្រះសង្ឃ មិត្តភក្តិ និងចៅហ្វាយនាយធ្វើឱ្យគេស្រឡាញ់រាប់អាន ទុកចិត្ត ឱ្យរស់នៅជាមួយ ទទួលឱ្យធ្វើការជាដើម។

ដូចនេះ តម្លៃរឿងសូផាតស្ថិតលើការ “ គោរពប្រណិបតន៍ និងសេចក្ដីតស៊ូអំណត់ព្យាយាម ” ដែលតួអង្គសូផាតមាន។

## VIII- **ការសន្និដ្ឋាន**

ការសិក្សារឿងសូផាតមានសារៈសំខាន់ចំពោះអ្នកសិក្សា ព្រោះអ្នកនិពន្ធបានឆ្លុះបញ្ចាំងនូវតថភាពសង្គមទាក់ទងតម្លៃនៃការសិក្សាអប់រំ ការសន្ដោសប្រណី ការគោរពប្រណិបតន៍ ការវិភាគ ដោះស្រាយបញ្ហា និងការតស៊ូអំណត់ព្យាយាមដើម្បីភាពជោគជ័យក្នុងជីវិត។

ឯកសារយោង៖

-សៀវភៅរឿងសូផាតបោះពុម្ពឡើងវិញដោយមជ្ឈមណ្ឌលពង្រឹងការអប់រំខ្មែរ តាមច្បាប់ដើមរបស់បណ្ណាគារសេង ងួនហួត ឆ្នាំ១៩៦៥
-សេចក្តីណែនាំស្តីពីការបង្រៀនពីសិក្សាអត្ថបទនៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ទី៨និងទី៩តាមលិខិតលេខ០២អយក.សណនចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៦